សៀវភៅនំម៉ាណាប្រចាំថ្ងៃ - ជាភាសាខ្មែរ

• ប្រចាំឆ្នាំ ២០២៦ សម្រាប់អានមួយឆ្នាំពេញ

នំម៉ាណាប្រចាំថ្ងៃ

តាំងពីឆ្នាំ ១៩៥១

សម្រាប់ការសិក្សាព្រះបន្ទូលផ្ទាល់ខ្លួន និងជាក្រុម ក៏ដូចជានៅតាមគ្រួសារ

រក្សាសិទ្ធិគ្រប់យ៉ាងដោយ៖ ©២០២៥ ODB Ministries, Grand Rapids, Michigan, ៤៩៥៥៥-០០០១, U.S.A. Used by permission. For other English literature produced by ODB Ministries, please write to ៣០០០ Kraft Ave SE, Grand Rapids, Michigan, ៤៩៥៥៥-០០០១, U.S.A.

ប្រែសម្រួលជាភាសាខ្មែរ ដោយ៖ លោក ឯក សត្យា
ពិនិត្យផ្ទៀងផ្ទាត់ និងកែសម្រួលអត្ថបទដោយ៖ លោក ឈាង បូរ៉ា, លោក ទេព រ៉ូ, លោក ពឹង ពេជ្រ ចិន្តា, លោក ចិន ធារ៉ា, លោក ហុង សម្ភស និងលោក ខែម បូឡុង

រចនាក្របដោយ៖ លោក វណ្ណដ្ឋា សុតរ៉ាប៊ី
រូបថតនៅលើក្រប៖ លោក Sam Moghadam Khamseh (unsplash.com)

បទគម្ពីរជាភាសាខ្មែរដកស្រង់ចេញពីព្រះគម្ពីរប៊ីប ឆ្នាំ១៩៥៤ (បានដកស្រង់ ដោយរក្សាអក្ខរាវិរុទ្ធដើម)។
រក្សាសិទ្ធិគ្រប់យ៉ាង ដោយសហគមន៍គ្រីស្ទបរិស័ទគណៈនិកាយប្រូតេស្តង់កម្ពុជា (សគបក)។
បោះពុម្ពផ្សាយដោយ៖ អង្គការសកម្មភាពកម្ពុជា

Email: info@khmermanna.com, Tell: ០៨៧ ២៣៣ ៩០៧, website នំម៉ាណាប្រចាំថ្ងៃ៖ https://khmermanna.com, FB page: https://www.facebook.com/dailykhmermanna,
Telegram: https://t.me/khmerdailymanna, Website ផ្លូវពិត៖ https://plovpit.com, FB page: https://www.facebook.com/plovpit



លោកអ្នកអាចស្តាប់សៀវភៅនេះជាសំឡេងដោយគ្រាន់តែចូលទៅកាន់គេហទំព័រ៖

www.khmermanna.com

ហើយចូលទៅក្នុងទំព័រនីមួយៗ ដើម្បីចុចប៊ូតុងសំឡេង ដែលលោកអ្នកចង់ស្តាប់។

ជំហាននៅក្នុងការអានសៀវភៅនំម៉ាណាប្រចាំថ្ងៃ

ជំហានទី១៖ សូមកំណត់ពេលវេលាច្បាស់លាស់ សម្រាប់ការអាន។ ឧទាហរណ៍ អ្នកប្រហែលជាចង់ជ្រើសរើសពេលវេលា នៅពេលព្រលឹម ពីម៉ោង ៥:៣០ ដល់ម៉ោង ៦:០០ជាដើម។ សូមព្យាយាមរក្សាពេលនេះ កុំឲ្យនរណាម្នាក់ ឬមានការអ្វីមករំខានអ្នកឡើយ ពីព្រោះពេលនោះ ជាពេលអ្នកមានការណាត់ជួបជាមួយនឹងព្រះអម្ចាស់។

ជំហានទី២៖ សូមស្វែងរកកន្លែងស្ងៀមស្ងាត់ ហើយអធិស្ឋាន សូមឲ្យព្រះប្រទានប្រាជ្ញា ដើម្បីឲ្យអ្នកអាចយល់ព្រះបន្ទូលទ្រង់ (ទំនុកដំកើង ១១៩:១៣, ៣៣-៣៥)។ ពេលនោះ អ្នកចាំបាច់ត្រូវមានចិត្តចង់យល់ដឹង និងគោរពតាមបំណងព្រះទ័យទ្រង់ ហើយមិនត្រូវគិតអំពីបញ្ហាអ្វីមួយ ឬអំពីការងារនោះឡើយ។

ជំហានទី៣៖ សូមអានឲ្យបានពីរដង នូវខគម្ពីរដែលសៀវភៅនំម៉ាណាប្រចាំថ្ងៃបានផ្តល់ឲ្យ។ ពេលអ្នកអានខគម្ពីរនោះ នៅលើកទីពីរ សូមគូសបន្ទាត់ពីក្រោមឃ្លាណាដែលអ្នកប៉ះពាល់ចិត្ត។

ជំហានទី៤៖ យោងតាមឃ្លាដែលអ្នកបានគូស សូមសួរខ្លួនឯងនូវសំណួរដូចខាងក្រោមនេះ៖

ក. អំពើបាប៖ តើមានអំពើបាបណា ដែលខ្ញុំត្រូវជៀសវាង ឬសារភាពចំពោះព្រះអង្គ?

ខ. ការសន្យា៖ តើព្រះបានមានបន្ទូលសន្យាមកកាន់ខ្ញុំ នៅក្នុងបទគម្ពីរនេះឬទេ?

គ. ឧទាហរណ៍គំរូ៖ តើតួអង្គនៅក្នុងសាច់រឿងនេះមានគំរូដ៏ល្អអ្វីខ្លះ ដែលគួឲ្យខ្ញុំយកតម្រាប់តាម?

ឃ. ការបង្គាប់៖ តើក្នុងបទគម្ពីរនេះ មានព្រះរាជបញ្ជាអ្វីខ្លះ ដែលខ្ញុំត្រូវអនុវត្តតាម?

ង. ចំណេះដឹង៖ តើបទគម្ពីរមួយជំពូកនេះ បានបង្រៀនខ្ញុំអំពីបុគ្គលិកលក្ខណៈអ្វីខ្លះ របស់ព្រះ និងមនុស្ស?

ជំហានទី៥៖ សូមកត់ចម្លើយរបស់អ្នក ទុកនៅក្នុងសៀវភៅផ្ទាល់ខ្លួនមួយក្បាល ហើយបន្ទាប់មកសូមអានអត្ថបទទាំងមូល នៅក្នុងសៀវភៅនំម៉ាណាប្រចាំថ្ងៃ។ សូមសួរខ្លួនឯងនូវសំណួរដូចជា៖

តើខ្ញុំត្រូវធ្វើអ្វីខ្លះ ដើម្បីគោរពប្រតិបត្តិព្រះ និងថ្វាយសិរីល្អដល់ព្រះនាមទ្រង់?

តើខ្ញុំត្រូវអនុវត្តកិច្ចការទាំងនោះ នៅពេលណា និងនៅកន្លែងណា?

តើខ្ញុំត្រូវធ្វើការល្អទាំងនោះ សម្រាប់នរណា?

ជំហានទី៦៖ សូមកត់ការសម្រេចចិត្តរបស់អ្នកទុកក្នុងសៀវភៅ ហើយទូលសូមព្រះប្រទានប្រាជ្ញា និងកម្លាំងសម្រាប់ប្រតិបត្តិតាមទ្រង់ (ទំនុកដំកើង ១១៩:១១៦-១១៧)។ សូមអធិស្ឋានទូលសូមព្រះការពារអ្នក និងជួតផ្គង់អ្នក នៅពេលដែលអ្នកធ្វើការបម្រើទ្រង់ (ទំនុកដំកើង ១១៩:១៣៣)។

ជំហានទី៧៖ សូមចាប់ផ្តើមអនុវត្តតាម។

ចូលរួមក្រុម
Telegram
ដើម្បីទទួលមេរៀនព្រះបន្ទូល
រៀងរាល់ថ្ងៃ

t.me/khmerdailymanna



ការស្អាងទំនាក់ទំនងជាមួយព្រះអម្ចាស់

ព្រះទ្រង់មានបន្ទូលមកកាន់អ្នកតាមរយៈព្រះគម្ពីរបរិសុទ្ធ។ ពេលដែលអ្នកបើកមើលបទគម្ពីរណាមួយក្នុងព្រះគម្ពីរ ចូរសួរខ្លួនឯងថា “តើបទគម្ពីរនេះមានន័យដូចម្តេចខ្លះ?” នៅក្នុងបទគម្ពីរ គឺមានសេចក្តីពិតខាងវិញ្ញាណ ដែលមានន័យ និងមានប្រយោជន៍ សម្រាប់មនុស្សគ្រប់ជំនាន់។ សូមអ្នកសួរខ្លួនឯងថា “តើជីវិតខ្ញុំត្រូវមានការផ្លាស់ប្រែចំណុចណាខ្លះ បន្ទាប់ពីខ្ញុំបានសិក្សាបទគម្ពីរនេះហើយ?” ព្រះវិញ្ញាណបរិសុទ្ធអាចកែប្រែការគិត ការនិយាយស្តី និងការប្រព្រឹត្តរបស់អ្នក ពេលដែលអ្នកអនុញ្ញាតឲ្យទ្រង់កែច្នៃជីវិតអ្នកដោយប្រើគោលការណ៍នៅក្នុងព្រះបន្ទូលទ្រង់។

ទំនាក់ទំនងដែលល្អ ជាការទាក់ទងគ្នាទៅវិញទៅមក ហើយទំនាក់ទំនងដែលយើងមានជាមួយព្រះ ក៏ត្រូវមានការទាក់ទងទៅវិញទៅមកផងដែរ។

ចូរឆ្លើយតបចំពោះព្រះ ដោយការអធិស្ឋាន។ ចូរសារភាពអំពើបាបរបស់អ្នក ហើយអរព្រះគុណទ្រង់ សម្រាប់ព្រះបន្ទូលសន្យារបស់ទ្រង់។ ចូរទូលសូមឲ្យទ្រង់ជួយអ្នកឲ្យមានការយល់ដឹង កាន់តែច្បាស់ អំពីអត្ថន័យនៃបទគម្ពីរ ដែលអ្នកកំពុងសិក្សា ព្រមទាំងដឹងថា បទគម្ពីរនេះអាចជួយអ្នកយ៉ាងដូចម្តេចខ្លះ ដើម្បីឲ្យអ្នកមានការផ្លាស់ប្រែ កាន់តែល្អដូចព្រះយេស៊ូវ។


ចូរកត់ត្រាទុកនូវអ្វីដែលអ្នកបានរៀន។ ចូរកត់ទុកនូវអ្វី ដែលអ្នកបានរកឃើញក្នុងព្រះបន្ទូលទ្រង់។ សៀវភៅកត់ត្រារបស់អ្នកនឹងជួយឲ្យអ្នកតាមដានការលូតលាស់ ដែលអ្នកមាននៅក្នុងសេចក្តីជំនឿ។ វានឹងជួយឲ្យអ្នកចងចាំនូវអ្វីដែលអ្នកបានរៀន ហើយបន្តជះឥទ្ធិពលមកលើការរស់នៅរបស់អ្នកពេញមួយថ្ងៃ។ ការកសាងទំនាក់ទំនងមិនមែនជាការងាយទេ។ យើងត្រូវមានការឧស្សាហ៍ព្យាយាម ការទំនាក់ទំនងជាទៀងទាត់ ការអត់ធ្មត់ ការទុកចិត្ត និងពេលវេលា។ ទំនាក់ទំនងជាមួយព្រះ ជាទំនាក់ទំនងសំខាន់បំផុត ដែលយើងមិនអាចអត់បាន។ ចូរយើងចំណាយពេលជាមួយទ្រង់ ក្នុងព្រះបន្ទូលទ្រង់ និងក្នុងការអធិស្ឋាន។ ចូរសន្ទនាជាមួយទ្រង់ ក្នុងគ្រប់ផ្នែកទាំងអស់នៃជីវិតអ្នក។ ចូរអនុញ្ញាតឲ្យទ្រង់មានបន្ទូលមកកាន់អ្នក ហើយចំណាយពេលនិយាយទៅកាន់ទ្រង់ ឲ្យបានញឹកញាប់។ កាលណាអ្នកបានអនុវត្តដូចនេះហើយ ជីវិតរបស់អ្នកនឹងបានចាក់ឫសចូលទៅក្នុងទ្រង់កាន់តែជ្រៅ ហើយអ្នកក៏នឹងបានទទួលលទ្ធផលជាទីគាប់ចិត្ត។


ដកស្រង់ និងសង្ខេបចេញពីសៀវភៅ *ក្នុងព្រះវត្តមានព្រះអង្គ៖ ការចំណាយពេលជាមួយព្រះ* និពន្ធដោយ លោក ដេននីស ហ្វីសស័រ រក្សាសិទ្ធិគ្រប់យ៉ាង © ២០១៣ Our Daily Bread Ministries.

ផ្លូវពិត
plovpit.com

សូមចូលមើលបណ្ណាគារ
ONLINE របស់យើងខ្ញុំៗ

















មើល សេចក្តីស្រឡាញ់យ៉ាងណាហ្ន ដែលព្រះវរបិតាបានផ្តល់មកយើងវាល់គ្នា (១យ៉ូហាន ៣:១)។

អត្តសញ្ញាណថ្មី ក្នុងព្រះយេស៊ូវ

ឥឡូវមិនដូចខ្ញុំកាលពីមុនទេ។ ខ្ញុំបានក្លាយជាមនុស្សថ្មីហើយ»។ នេះជាពាក្យសម្តីដ៏សាមញ្ញ ដែលកូនប្រុសខ្ញុំបានថ្លែងទៅកាន់សិស្សទាំងឡាយនៅក្នុងការជួបជុំគ្នានៅសាលា ដោយរៀបរាប់អំពីការផ្លាស់ប្តូរ ដែលព្រះទ្រង់បានប្រទានក្នុងជីវិតគាត់។ កាលពីមុន ចេហ្វ្រី (Geoffrey) គឺជាមនុស្សញៀនថ្នាំម្នាក់ តែក្រោយមកគាត់បានទទួលស្គាល់អំពើបាប និងកំហុសរបស់ខ្លួនឯង។ ហើយឥឡូវនេះ គាត់បានមើលឃើញខ្លួនគាត់ ជាកូនព្រះ។

ព្រះគម្ពីរបានលើកទឹកចិត្តយើង ដោយព្រះបន្ទូលដែលសន្យាថា «បានជាបើអ្នកណានៅក្នុងព្រះគ្រីស្ទ នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ មើល គ្រប់ទាំងអស់បានត្រឡប់ជាថ្មីវិញ» (២កូរិនថូស ៥:១៧)។ យើងក្លាយជាមនុស្សថ្មី ទោះកាលពីមុនយើងជានរណា ឬបានធ្វើអ្វីក៏ដោយ ពេលណាយើងទទួលជឿព្រះយេស៊ូវ ដើម្បីទទួលយកសេចក្តីសង្គ្រោះ និងការអត់ទោសបាប ដែលព្រះអង្គប្រទានតាមរយៈការសុគតនៅលើឈើឆ្កាង។ ចាប់តាំងពីសម័យសួនច្បារអេដែន ទោសកំហុសនៃអំពើបាបបានកាត់ផ្តាច់យើងចេញពីព្រះ តែព្រះអង្គបាន «ផ្សះផ្សាយើងនឹងព្រះអង្គទ្រង់ ដោយសារព្រះយេស៊ូវគ្រីស្ទ» «ឥតប្រកាន់ទោស» យើងទៀត (ខ.១៨-១៩)។ យើងជាកូនសួនភ្ងារបស់ព្រះអង្គ (១យ៉ូហាន ៣:១-២) ដែលព្រះអង្គបានលាងសម្អាត និងធ្វើឲ្យយើងកើតជាថ្មី ឲ្យមានលក្ខណៈដូចព្រះរាជបុត្រាព្រះអង្គ។

ព្រះយេស៊ូវបានរំដោះយើងឲ្យរួចពីបាប និងអំណាចរបស់បាបដែលគ្រប់គ្រងជីវិតយើង ហើយស្អាងយើងឡើងវិញឲ្យមានទំនាក់ទំនងថ្មីមួយជាមួយព្រះអង្គ បានជាយើងមានសេរីភាពក្នុងការរស់នៅ មិនមែនសម្រាប់ខ្លួនឯង តែសម្រាប់ព្រះអង្គ ដែលបានសុគតជួសយើង និងបានមានព្រះជន្មរស់ឡើងវិញ (២កូរិនថូស ៥:១៥)។ នៅថ្ងៃចូលឆ្នាំថ្មីនេះ ចូរយើងនឹកចាំថា សេចក្តីស្រឡាញ់របស់ព្រះដែលកែប្រែជីវិតយើងបានជំរុញយើងឲ្យរស់នៅ ដោយអត្តសញ្ញាណ និងគោលបំណងថ្មី។ សេចក្តីស្រឡាញ់របស់ព្រះអង្គក៏បានចង្អុលបង្ហាញអ្នកដទៃ ឲ្យងាកទៅរកព្រះអង្គសង្គ្រោះយើង ជាព្រះដែលអាចកែប្រែពួកគេឲ្យក្លាយជាមនុស្សថ្មីផងដែរ!—James Banks

តើអ្នកមានអារម្មណ៍យ៉ាងណា ពេលដែលបានដឹងថា ការចាប់ផ្តើមជាថ្មីអាចកើតមាន ជាមួយព្រះអម្ចាស់? តើអ្នកអាចរស់នៅជា «ស្មាព្រះហស្តថ្មី» របស់ព្រះអង្គដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការចាត់ព្រះរាជបុត្រាព្រះអង្គ ឲ្យសង្គ្រោះទូលបង្គំ។ សូមព្រះអង្គចាត់ទូលបង្គំឲ្យទៅកាន់មនុស្ស ដែលត្រូវការព្រះអង្គផងដែរ។

ថ្ងៃក៏រះឡើង ហើយលិចទៅវិញ (សាស្តា ១:៥)។

រកឃើញជីវិតមានន័យក្នុងព្រះអង្គ

រឿង ប្រលោមលោក ដែលលោក អឺណេស ហេមមីងវ៉េយ (Ernest Hemingway) បាននិពន្ធ គាត់បាន និយាយអំពីមនុស្សប្រមឹកពីរនាក់ជាមិត្តសំឡាញ់នឹងគ្នា ដែលបានស៊ូទ្រាំនឹងទុក្ខលំបាក ក្នុងអំឡុងសម័យ សង្គ្រាមលោកលើកទី១។ ពួកគេមានស្នាមសម្លាកនៅលើរូបកាយ និងក្នុងចិត្ត ដោយសារគ្រោះមហន្តរាយនៃ សង្គ្រាម ហើយបានព្យាយាមជម្នះវា ដោយការជប់លៀង ដំណើរផ្សងព្រេងធំៗ និងការសប្បាយក្នុងផ្លូវភេទ។ ពួកគេក៏តែងតែផឹកស្រា ដើម្បីបំបាត់ការឈឺចាប់ តែពួកគេនៅតែមិនសប្បាយចិត្ត។

លោក ហេមមីងវ៉េយ ក៏បានដាក់ចំណងជើងឲ្យរឿងប្រលោមលោកនេះថា ព្រះអាទិត្យក៏បានរះដែរ ដោយ ផ្អែកទៅលើបទគម្ពីរ សាស្តា ១:៥។ ក្នុងកណ្ឌគម្ពីរសាស្តា ស្តេច សាឡូម៉ូន បានហៅខ្លួនឯងថា «គ្រូប្រដៅ» (ខ.១)។ ទ្រង់បានសង្កេតឃើញថា អ្វីៗទាំងអស់សុទ្ធតែ «ឥតប្រយោជន៍» (ខ.២) ហើយក៏បានសួរថា «តើ មនុស្សមានកំរៃអ្វីខ្លះ ពីអស់ទាំងការដែលខ្លួនខំធ្វើ ដោយនឿយហត់នៅក្រោមថ្ងៃ?» (ខ.៣)។ ស្តេច សាឡូម៉ូន ក៏ បានទតឃើញរបៀបដែលថ្ងៃរះ និងលិចទៅវិញ ខ្យល់បកពីទិសណាទៅទិសណា និងទឹកទន្លេហូរមិនចេះឈប់ ចូលទៅក្នុងសមុទ្រដែលមិនចេះឆ្អែតឆ្អន់ (ខ.៥-៧)។ ទីបំផុត គ្មាននរណានឹកចាំអំពីពួកវាទៀតទេ (ខ.១១)។

ត្រង់ចំណុចនេះ លោក ហេមមីងវ៉េយ និងអ្នកនិពន្ធកណ្ឌគម្ពីរសាស្តាសុទ្ធតែចង់ឲ្យយើងត្រិះរិះពិចារណា អំពីភាពឥតប្រយោជន៍នៃការរស់នៅលើផែនដីនេះ។ ទោះជាយ៉ាងណាក៏ដោយ ស្តេច សាឡូម៉ូន បានផ្តល់ឲ្យនូវ គម្រុយដ៏ភ្លឺស្វាងនៃសេចក្តីសង្ឃឹមមកពីស្ថានសួគ៌នៅក្នុងកណ្ឌគម្ពីរសាស្តា។ យើងអាចមានក្តីសង្ឃឹមពិតប្រាកដ និងស្ថិតស្ថេរ។ កណ្ឌគម្ពីរសាស្តាបានបង្ហាញធាតុពិតរបស់យើងជាមនុស្ស តែក៏បានបង្ហាញឲ្យយើងដឹងថា ព្រះ ជានរណា។ គឺដូចដែលស្តេច សាឡូម៉ូន មានបន្ទូលថា «ការអ្វីដែលព្រះទ្រង់ធ្វើ នោះនឹងស្ថិតស្ថេរនៅជាដរាប» (៣:១៤) ហេតុនេះហើយ យើងអាចមានសេចក្តីសង្ឃឹមដ៏អស្ចារ្យ។ ដ្បិតព្រះទ្រង់បានប្រទានព្រះរាជបុត្រា ព្រះ នាមយេស៊ូវ ជាអំណោយដល់យើងរាល់គ្នា។

បើយើងមិនបាននៅជាប់ព្រះអង្គទេ យើងនឹងរសាត់អណ្តែតក្នុងសមុទ្រដែលគ្មានកោះត្រើយ។ តែតាមរយៈ ព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះដែលមានព្រះជន្មរស់ យើងបានទទួលការផ្សះផ្សាឲ្យជានឹងព្រះ ហើយរកឃើញ ជីវិតមានន័យ មានតម្លៃ និងគោលបំណង។—Tim Gustafson

តើអ្នកបានចំណាយពេលភាគច្រើនធ្វើការអ្វីខ្លះ តើវាមានន័យអ្វីចំពោះអ្នកទេ? តើអ្នកអាចផ្លាស់ប្តូរ អាទិភាពរបស់អ្នកដូចម្តេចខ្លះ ដើម្បីដើរតាមព្រះយេស៊ូវ?

ឱព្រះវរបិតានៃសេចក្តីស្រឡាញ់ សូមព្រះអង្គជួយទូលបង្គំឲ្យរកឃើញភាពពេញលេញ ក្នុងព្រះអង្គ។

គម្រោងអានព្រះគម្ពីរយ:ពេល១ឆ្នាំ | លោកុប្បត្តិ ៤-៦ និងម៉ាថាយ ២

ឱព្រះយេហូវ៉ាអើយ សូមឲ្យសេចក្តីសប្បុរសរបស់ទ្រង់សណ្ឋិតនៅលើយើងខ្ញុំ តាមដែលយើងខ្ញុំសង្ឃឹមដល់ទ្រង់ (ទំនុកតម្កើង ៣៣:២២)។

រកឃើញក្តីសង្ឃឹម

អ្នកវិទ្យាសាស្ត្រផ្នែកទឹកសមុទ្រឈ្មោះ ស៊ីលវ៉ា អឺល (Sylvia Earle) បានសង្កេតឃើញការថយចុះនៃផ្កាសមុទ្រនៅបាតសមុទ្រ។ គាត់ក៏បានបង្កើតអង្គការរបស់កកម្មពណ៌ខៀវ ជាអង្គការដែលមានការប្តេជ្ញាចិត្តចំពោះការអភិវឌ្ឍន៍ «តំបន់នៃក្តីសង្ឃឹម» នៃពិភពលោក។ តំបន់ពិសេសទាំងនេះ មានទីតាំងនៅជុំវិញពិភពលោក មាន «សារៈសំខាន់យ៉ាងខ្លាំង ចំពោះសុខភាពនៃមហាសមុទ្រ» ដែលមានផលប៉ះពាល់មកលើជីវិតរបស់មនុស្សនៅលើផែនដី។ តាមរយៈការថែរក្សាតំបន់ផ្កាថ្មទាំងនេះ អ្នកវិទ្យាសាស្ត្រទាំងឡាយក៏បានស្តាទំនាក់ទំនងរវាងជីវៈចម្រុះនៅបាតសមុទ្រឡើងវិញ និងបានអភិរក្សពូជសត្វជាច្រើនដែលជិតផុតពូជ។

ក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៣៣ អ្នកនិពន្ធបទគម្ពីរទំនុកតម្កើងបានទទួលស្គាល់ថា ព្រះទ្រង់មានបន្ទូលឲ្យអ្វីៗកើតមាន ហើយក៏បានធានាថា ស្តាព្រះហស្តទាំងអស់ដែលព្រះអង្គបានបង្កើតនឹងឈរមាំ (ខ.៦-៩)។ ដោយសារព្រះទ្រង់បានសោយរាជ្យលើជំនាន់មនុស្ស និងជាតិសាសន៍ទាំងឡាយ (ខ.១១-១៩) នោះមានតែព្រះអង្គទេ ដែលអាចស្តាងទំនាក់ទំនងឲ្យល្អឡើងវិញ និងសង្គ្រោះជីវិតមនុស្ស ហើយជួយឲ្យពួកគេមានក្តីសង្ឃឹមឡើងវិញ។ ទោះជាយ៉ាងណាក៏ដោយ ព្រះអង្គបានអញ្ជើញយើងឲ្យចូលរួមជាមួយព្រះអង្គ នៅក្នុងការថែរក្សាពិភពលោក និងមនុស្សដែលព្រះអង្គបានបង្កើតឲ្យមាននៅលើពិភពលោក។

រៀងរាល់ពេលដែលយើងសរសើរតម្កើងព្រះអង្គ សម្រាប់ការបង្កើតឥន្ទធនូដែលលាតសន្ធឹងនៅលើផ្ទៃមេឃដែលមានពពក ឬការបង្កើតទឹករលកក្នុងមហាសមុទ្រឲ្យបក់បោកច្រាំង ដែលមានផ្ទាំងថ្មធំៗ នោះយើងក៏អាចប្រកាសអំពី «សេចក្តីស្រឡាញ់ និងព្រះវត្តមានដ៏ស្ថិតស្ថេរ» របស់ព្រះអង្គ ខណៈពេលដែលយើងសង្ឃឹមដល់ព្រះអង្គ (ខ.២២)។

ពេលណាយើងជួបការលំបាក ឲ្យមានការបាក់ទឹកចិត្ត ឬការភ័យខ្លាច ដោយសារយើងបានគិតអំពីស្ថានភាពនៃពិភពលោកក្នុងពេលបច្ចុប្បន្ន យើងប្រហែលជាចាប់ផ្តើមជឿថា យើងមិនអាចនាំមកនូវការផ្លាស់ប្តូរបានឡើយ។ ទោះជាយ៉ាងណាក៏ដោយ ពេលណាយើងបានបំពេញតួនាទីរបស់យើង ជាផ្នែកមួយនៃក្រុមថែរក្សារបស់ព្រះអង្គ យើងអាចថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ ជាព្រះអាទិករ ហើយជួយអ្នកដទៃឲ្យរកឃើញក្តីសង្ឃឹមនៅក្នុងការជឿព្រះយេស៊ូវ។—Xochitl Dixon

តើព្រះទ្រង់បានប្រើធម្មជាតិ ដើម្បីលើកទឹកចិត្តអ្នកឲ្យមានក្តីសង្ឃឹមយ៉ាងដូចម្តេចខ្លះ? តើអ្នកអាចធ្វើការបម្រើ ជាផ្នែកមួយនៃក្រុមថែរក្សារបស់ព្រះអង្គ ដោយរបៀបណា?

ឱព្រះអាទិករ និងព្រះដ៏ទ្រទ្រង់ដែលមានក្តីស្រឡាញ់ សូមព្រះអង្គជួយទូលបង្គំឲ្យទាំអ្នកដទៃ ឲ្យមានក្តីសង្ឃឹមដល់ព្រះអង្គ ខណៈពេលដែលទូលបង្គំធ្វើការបម្រើព្រះអង្គក្នុងក្រុមថែរក្សា។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លោកុប្បត្តិ ៧-៩ និងម៉ាថាយ ៣

ហើយខំប្រឹងឲ្យអស់ពីចិត្ត និងនៅដោយស្រុតត់ស្រុតំ ទាំងប្រព្រឹត្តតែរឿងជារបស់ផងខ្លួន ហើយធ្វើការដោយដៃខ្លួនឯងផង (១ថែស្សាឡូនីច ៤:១១)។

ភាពស្មោះត្រង់ដ៏ស្រគត់ស្រគំ ក្នុងព្រះគ្រីស្ទ

ថ្ងៃមួយ ខ្ញុំបានចុះមកជាន់ខាងក្រោម ដើម្បីញ៉ាំអាហារពេលព្រឹក ក្នុងសណ្ឋាគារដែលខ្ញុំកំពុងស្នាក់នៅ។ អ្វីៗនៅក្នុងបន្ទប់ញ៉ាំអាហារនោះ សុទ្ធតែស្អាត មិនមានប្រឡាក់អ្វី។ គេបានតម្រៀបអាហារប៊ូហ្វេនៅលើតុរួចជាស្រេច។ អាហារ និងភេសជ្ជៈត្រជាក់ៗក៏មានពេញទូទឹកកក ស្លាបព្រានិងសមក៏មានពេញប្រអប់។ អ្វីៗហាក់ដូចជាបានរៀបចំយ៉ាងល្អឥតខ្ចោះ។

បន្ទាប់មក ខ្ញុំក៏បានឃើញបុរសម្នាក់កំពុងបំពេញអ្វីៗដែលខ្វះចន្លោះ ព្រមទាំងជូតសម្អាតរបស់អ្វីដែលប្រឡាក់។ គាត់មិនបានព្យាយាមទាក់ទាញការចាប់អារម្មណ៍ពីនរណាម្នាក់ទេ។ ប៉ុន្តែ ពេលខ្ញុំអង្គុយញ៉ាំអាហារកាន់តែយូរ ខ្ញុំក៏កាន់តែមានការស្ញប់ស្ញែងចំពោះគាត់។ គាត់មានភាពស្វាហាប់ក្នុងការងារណាស់ គាត់តែងតែកត់សម្គាល់ឃើញឆ្នាំងដែលនៅសល់ម្ហូបតិចតួច ហើយប្រញាប់ចាក់ម្ហូបបន្ថែម ដើម្បីកុំឲ្យភ្ញៀវរង់ចាំយូរ។ ក្នុងនាមខ្ញុំជាអ្នកធ្លាប់ធ្វើការក្នុងភោជនីយដ្ឋាន ខ្ញុំបានសង្កេតឃើញថា គាត់តែងតែមានភាពល្អិតល្អន់នៅក្នុងការងារ។ អ្វីៗហាក់ដូចជាល្អឥតខ្ចោះ ដោយសារបុរសម្នាក់នេះធ្វើការដោយចិត្តស្មោះត្រង់ ទោះមានមនុស្សតែពីរបីនាក់ចាប់អារម្មណ៍ក៏ដោយ។

ពេលខ្ញុំឃើញបុរសម្នាក់នេះ ធ្វើការងារយ៉ាងផ្ចិតផ្ចង់ដូចនេះ ខ្ញុំក៏បាននឹកចាំពាក្យពេចន៍ដែលសាវ័ក ប៉ុល បានបង្រៀនពួកជំនុំនៅទីក្រុងថែស្សាឡូនីចឲ្យ «ខំប្រឹងឲ្យអស់ពីចិត្ត និងនៅដោយស្រគត់ស្រគំ ទាំងប្រព្រឹត្តតែរឿងជារបស់ផងខ្លួន ហើយធ្វើការដោយដៃខ្លួនឯងផង» ដើម្បីឲ្យទីបន្ទាល់នៃការរស់នៅរបស់ពួកគេ បានទទួលការគោរពពីអ្នកខាងក្រៅ (ថែស្សាឡូនីច ៤:១១-១២)។ សាវ័ក ប៉ុល បានដឹងថា អ្នកបម្រើព្រះដែលមានចិត្តស្មោះត្រង់ អាចទទួលបានការគោរពពីអ្នកដទៃ គឺបានបញ្ជាក់ថា ការបម្រើដ៏តូចមួយដល់អ្នកដទៃ ដោយភាពថ្លៃថ្នូរ និងមានគោលបំណង អាចនាំឲ្យគេបើកចិត្តចង់ស្តាប់ដំណឹងល្អ។

ខ្ញុំមិនដឹងថា បុរសដែលខ្ញុំបានឃើញនៅថ្ងៃនោះជាអ្នកជឿព្រះយេស៊ូវឬអត់ទេ។ តែខ្ញុំអរព្រះគុណព្រះអង្គ ដែលបានប្រើភាពឧស្សាហ៍ព្យាយាមរបស់គាត់ ដើម្បីក្រើនរំឭកខ្ញុំឲ្យពឹងផ្អែកទៅលើព្រះអង្គ ក្នុងការរស់នៅ ដោយភាពស្មោះត្រង់ យ៉ាងស្រគត់ស្រគំ ដែលឆ្លុះបញ្ចាំងឲ្យគេឃើញផ្លូវដ៏ស្មោះត្រង់របស់ព្រះអង្គ។

—Adam R. Holz

តើសេចក្តីជំនឿរបស់អ្នក មានឥទ្ធិពលយ៉ាងណាមកលើរបៀបដែលអ្នកធ្វើការងារ? តើការរស់នៅជាអ្នកបម្រើដ៏ស្មោះត្រង់ បានធ្វើជាទីបន្ទាល់ដ៏មានអំណាចដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យចាំថា គ្មានការងារណាមួយមានភាពតូចតាច ក្នុងនគរព្រះអង្គឡើយ ដរាបណាទូលបង្គំបម្រើព្រះអង្គជារៀងរាល់ថ្ងៃ ដោយចិត្តស្មោះត្រង់ ដោយដឹងថា ព្រះអង្គនៅក្បែរនិងដឹកនាំទូលបង្គំជានិច្ច។

គម្រោងអានព្រះគម្ពីរមួយឆ្នាំ | លោកុប្បត្តិ ១០-១២ និងម៉ាថាយ ៤

ចូរឲ្យឯងរាល់គ្នាឈរតាមផ្លូវ ហើយមើលចុះ ត្រូវឲ្យសួរកផ្លូវចាស់ទាំងប៉ុន្មាន មើលជាមានផ្លូវណាដែលល្អ រួចឲ្យដើរតាមផ្លូវនោះចុះ (យេរេមា ៦:១៦)។

ព្រះអម្ចាស់ប្រទានទិសដៅសម្រាប់ការសម្រេចចិត្ត

បន្ទាប់ពីស្វាមីខ្ញុំមានជំងឺ ហើយក្តៅខ្លួនខ្លាំងជាច្រើនថ្ងៃ ច្បាស់ណាស់ស្វាមីខ្ញុំត្រូវទៅពេទ្យជាបន្ទាន់។ មន្ទីរពេទ្យក៏បានទទួលគាត់ឲ្យចូលសម្រាកព្យាបាលភ្លាមៗ។ បន្ទាប់ពីគាត់សម្រាកព្យាបាលបានពីរបីថ្ងៃ សុខភាពគាត់មានភាពល្អប្រសើរជាងមុន តែមិនទាន់ល្អគ្រប់គ្រាន់ល្មមនឹងឲ្យគាត់ចេញពីពេទ្យបាន។ ខ្ញុំត្រូវធ្វើការសម្រេចចិត្តដ៏ពិបាកថា ត្រូវនៅមើលគាត់ ឬត្រូវចុះបេសកកម្មដ៏សំខាន់ ដែលមានមនុស្សជាច្រើនចូលរួម។ ស្វាមីខ្ញុំបានប្រាប់ខ្ញុំមិនឲ្យព្រួយបារម្ភ ព្រោះគាត់អាចបន្តសម្រាកនៅមន្ទីរពេទ្យតែម្នាក់ឯងបាន។ តែចិត្តរបស់ខ្ញុំនៅចង់នៅមើលថែគាត់ផង ចង់ទៅធ្វើការផង។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំ អំពីពេលដែលរាស្ត្ររបស់ព្រះ ត្រូវការជំនួយរបស់ព្រះអង្គ នៅពេលដែលពួកគេត្រូវធ្វើការសម្រេចចិត្តដ៏សំខាន់ក្នុងជីវិត។ មានពេលជាច្រើនដងពេកហើយ ដែលពួកគេមិនបានស្តាប់តាមការបង្គាប់ដែលព្រះអង្គបានបើកសម្តែង។ ដូចនេះ លោក ម៉ូសេ ក៏បានជំរុញពួកបណ្តាជនឲ្យ «ជ្រើសរើសយកជីវិត» ដោយស្តាប់តាមព្រះរាជបញ្ជារបស់ព្រះអង្គ (ចោទិយកថា ៣០:១៩)។ នៅសម័យក្រោយមក ហោរា យេរេមា ក៏បានកែតម្រង់រាស្ត្ររបស់ព្រះអង្គ ដែលកំពុងដើរខុសផ្លូវ ដោយបញ្ជុះបញ្ចូលពួកគេឲ្យដើរតាមផ្លូវព្រះអង្គ ដោយប្រាប់ពួកគេថា «ចូរឲ្យឯងរាល់គ្នាឈរតាមផ្លូវ ហើយមើលចុះ ត្រូវឲ្យសួរកផ្លូវចាស់ទាំងប៉ុន្មាន មើលជាមានផ្លូវណាដែលល្អ រួចឲ្យដើរតាមផ្លូវនោះចុះ» (យេរេមា ៦:១៦)។ ផ្លូវចាស់របស់ព្រះគម្ពីរ និងការផ្គត់ផ្គង់របស់ព្រះអង្គកាលពីមុន អាចនាំផ្លូវយើង។

ខ្ញុំស្រមៃថា កាលនោះខ្ញុំកំពុងតែឈរនៅលើផ្លូវបំបែក ហើយខ្ញុំក៏បានប្រើប្រាជ្ញានៅក្នុងកណ្ឌគម្ពីរយេរេមា។ ស្វាមីខ្ញុំត្រូវការខ្ញុំ។ ការងាររបស់ខ្ញុំក៏ត្រូវការខ្ញុំផងដែរ។ ភ្លាមៗនោះ អ្នកគ្រប់គ្រងនៅកន្លែងធ្វើការខ្ញុំ ក៏បានទូរស័ព្ទមក ហើយលើកទឹកចិត្តខ្ញុំ ឲ្យនៅផ្ទះមើលថែស្វាមីខ្ញុំ។ ខ្ញុំក៏បានដកដង្ហើមធំ ហើយអរព្រះគុណព្រះសម្រាប់ការប្រទានដំណោះស្រាយ នៅពេលដែលខ្ញុំពិបាកសម្រេចចិត្ត។ ទិសដៅដែលព្រះទ្រង់ប្រទាន មិនតែងតែបង្ហាញខ្លួនឲ្យយើងឃើញច្បាស់ឡើយ តែព្រះអង្គពិតជាបានប្រទានវាមកមែន។ ពេលណាយើងត្រូវធ្វើការសម្រេចចិត្តជ្រើសរើសដ៏ពិបាក ចូរយើងប្រាកដថា យើងស្វែងរកបំណងព្រះទ័យព្រះអង្គ។—Elisa Morgan

តើនៅថ្ងៃនេះ អ្នកត្រូវការការទិសដៅពីព្រះអង្គ សម្រាប់ការសម្រេចចិត្តអ្វីខ្លះ? តើព្រះទ្រង់អាចបង្ហាញព្រះហឫទ័យព្រះអង្គ ដល់អ្នកយ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ពេលណាទូលបង្គំមានការស្ទាក់ស្ទើរក្នុងការសម្រេចចិត្ត សូមព្រះអង្គជួយទូលបង្គំ ឲ្យស្វែងរកបំណងព្រះទ័យព្រះអង្គ មុននឹងធ្វើការសម្រេចចិត្ត។

គម្រោងអានព្រះគម្ពីរយេ:ពេល១ឆ្នាំ | លោកុប្បត្តិ ១៣-១៥ និងម៉ាថាយ ៥:១-២៦

ព្រមទាំងបើកយកទ្រព្យដ៏វិសេសរបស់ខ្លួន ថ្វាយដង្វាយជាមាស ជាកំញាន ជាជ័រល្វីងទេស ដល់បុត្រនោះ (ម៉ាថាយ ២:១១)។

អត្ថន័យនៃដង្វាយរបស់ពួកហោរ

ថ្ងៃនេះ ជាទិវារំឭកអំពីពេលដែលពួកហោរទាំងបី ជាអ្នកប្រាជ្ញាដ៏សុភាព ដែលបានចូលគាល់ព្រះឱរសយេស៊ូវ ដូចដែលមានចែងក្នុងព្រះគម្ពីរ ក៏ដូចជាក្នុងបទចម្រៀងទំនុកសកលលេខ៧០ មានចំណងជើងថា «យើងហោរទាំងបីមកពីទិសបូព៌»។ តាមពិត ពួកគេមិនមែនជាស្តេច មកពីទិសខាងកើត ដូចអ្នកខ្លះបានពិពណ៌នានោះទេ ហើយអាចមានគ្នាលើសពី៣នាក់។

ទោះជាយ៉ាងណាក៏ដោយ យើងអាចដឹងច្បាស់ថា ពួកគេបាននាំយកដង្វាយបីយ៉ាងមកថ្វាយព្រះអង្គ ហើយបទចម្រៀងនេះក៏បានរៀបរាប់អំពីដង្វាយទាំងបីផងដែរ។ ព្រះគម្ពីរបានចែងថា ពេលដែលពួកហោរមកដល់ភូមិបេថ្លេហិម ពួកគេក៏បាន «បើកយកទ្រព្យដ៏វិសេសរបស់ខ្លួន ថ្វាយដង្វាយជាមាស ជាកំញាន ជាជ័រល្វីងទេស ដល់បុត្រនោះ» (ម៉ាថាយ ២:១១)។ ដង្វាយទាំងនោះជានិមិត្តរូបតំណាងឲ្យបេសកកម្មរបស់ព្រះយេស៊ូវ។ មាសជាតំណាងឲ្យតួនាទីរបស់ព្រះអង្គជាស្តេច។ កំញានដែលគេដុតក្នុងទីបរិសុទ្ធក្នុងព្រះវិហារ គឺជាតំណាងឲ្យភាពជាព្រះរបស់ព្រះអង្គ។ ហើយតាមធម្មតា គេប្រើជ័រល្វីងទេស សម្រាប់អប់សព។ យើងអាចឆ្ងល់ថា ហេតុអ្វីពួកគេថ្វាយជ័រល្វីងទេសដល់ព្រះអង្គ។

ក្នុងល្អះទី៤ ក្នុងទំនុកសកលនេះ គេច្រៀងថា «ជ័រល្វីងទេសជាដង្វាយផងខ្ញុំ នោះសំដែងការលំបាកយ៉ាងធំ កើតព្រះទ័យព្រួយ តតអ្នកណានឹងជួយ ហើយសុគតទាំងបង្គំ»។ បើយើងជាអ្នកនិពន្ធ យើងប្រហែលមិនចង់សរសេរអំពីការស្លាប់ដ៏សោកសៅនៅក្នុងរឿងនេះទេ តែព្រះទ្រង់បានសរសេរ។ ព្រោះការសុគតរបស់ព្រះយេស៊ូវជាចំណុចស្នូលនៃសេចក្តីសង្គ្រោះរបស់យើង។ ស្តេចហេរ៉ូឌថែមទាំងបានព្យាយាមតាមធ្វើគុតព្រះយេស៊ូវ កាលព្រះអង្គនៅជាទារក (ខ.១៣)។

ល្អះចុងក្រោយនៃបទចម្រៀងនេះ បានបង្រួមខ្លឹមសារទាំងបីបញ្ចូលគ្នា យ៉ាងដូចនេះថា «ទ្រង់មានព្រះជន្មរស់ឡើងវិញផង គឺជាព្រះពិតតែមួយព្រះអង្គ»។ សូមឲ្យរឿងណូអែលដ៏មានន័យពេញលេញនេះ បណ្តាលចិត្តយើងឲ្យច្រៀងសរសើរ ជាមួយពួកទេវតាថា «ហាលេលូយ៉ា ហាលេលូយ៉ា»។—Tim Gustafson

តើអ្នកមានអារម្មណ៍យ៉ាងណា ពេលអ្នកពិចារណាអំពីសេចក្តីពិតដែលថា ព្រះយេស៊ូវបានប្រសូត ដើម្បីសុគតជំនួសអ្នក? តើការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គបានបណ្តាលចិត្តអ្នកដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះវិញ្ញាណព្រះអង្គជួយទូលបង្គំឲ្យរស់នៅ ដោយការដឹងគុណព្រះរាជបុត្រាព្រះអង្គ ដែលបានលះបង់ព្រះជន្ម ដើម្បីទូលបង្គំ។

Daily Manna 2026_Content Enhance.indd 12 17/11/25 1:44 in the afternoon

ឱព្រះនៃពួកពលបរិវារអើយ សូមបង្វិលយើងខ្ញុំមកវិញ សូមឲ្យព្រះភក្ត្រទ្រង់ភ្លឺមក នោះយើងខ្ញុំនឹងបានរួចហើយ (ទំនុកតម្កើង ៨០:៧)។

ដល់ពេលវិលត្រឡប់មកព្រះអង្គវិញ

មានពេលមួយ ខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលបានឃើញរូបថត ដែលមិត្តភក្តិខ្ញុំម្នាក់បានផ្ញើរមក។ ក្នុងរូបថតទាំងនោះ ខ្ញុំឃើញឡានហ្វឺត ម៉ាស្តាំង ឆ្នាំ១៩៦៥ ដែលគាត់បានជួសជុលឲ្យស្អាតដូចដើមវិញ ធ្វើជាអំណោយដ៏ភ្ញាក់ផ្អើលសម្រាប់ភរិយាគាត់។ ឡាននោះមានផ្ទៃខាងក្រៅពណ៌ទឹកបិច យ៉ាន់ពណ៌ក្រមួនភ្លឺស្អាត ផ្ទៃខាងក្នុងពណ៌ខ្មៅ និងមានបំពាក់គ្រឿងទំនើបៗផងដែរ។ ហើយក៏មានរូបថតឡានដដែលនោះ មុនពេលគេជួសជុល ដែលមានរូបរាងចាស់ ពណ៌លឿងដែលមិនគួរឲ្យទាក់ទាញ។ គេប្រហែលជាពិបាកនឹកស្រមៃទុកជាមុនថា វានឹងមានការផ្លាស់ប្តូរយ៉ាងណា ប៉ុន្តែកាលគេទើបតែយកវាចេញពីរោងចក្រផលិតថ្មីៗ វាទំនងជាមានសម្រស់ដ៏ទាក់ទាញសម្រាប់មនុស្សជាច្រើន។ តែជាច្រើនឆ្នាំក្រោយមក វាក្លាយជាឡានចាស់មានការសឹករីករិល រលាត់ដាច់ និងកត្តាផ្សេងទៀត ដែលធ្វើឲ្យគេគិតថា វាដល់ពេលដែលគេត្រូវជួសជុលឲ្យស្អាតដូចដើម។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំស្ថានភាពរបស់រាស្ត្ររបស់ព្រះអម្ចាស់ក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៨០ ដែលក្នុងនោះ ក៏មានការអធិស្ឋានជាច្រើនដងថា «ឱព្រះអង្គអើយ សូមបង្វិលយើងខ្ញុំមកវិញ សូមឲ្យព្រះភក្ត្រទ្រង់ភ្លឺមក នោះយើងខ្ញុំនឹងបានរួចហើយ» (ខ.៣ និង ខ.៧, ១៩)។ ទោះប្រវត្តិសាស្ត្ររបស់ពួកគេបានរាប់បញ្ចូលការរំដោះពួកគេ ចេញពីទឹកដីអេស៊ីព្ទ និងការដាំពួកគេនៅលើទឹកដីដែលមានជីជាតិក៏ដោយ (ខ.៨-១១) ក៏ពេលវេលាដ៏ល្អដែលពួកគេមានពីដំបូងបានកន្លងផុតទៅ។ ដោយសារការបះបោរ ពួកគេក៏បានទទួលការជំនុំជម្រះ (ខ.១២-១៣)។ បានជាពួកគេទូលអង្វរព្រះអង្គថា «ឱព្រះនៃពួកពលបរិវារអើយ យើងខ្ញុំអង្វរដល់ទ្រង់ សូមបែរមកវិញ ហើយទតពីលើស្ថានសួគ៌មក» (ខ.១៤)។

តើអ្នកធ្លាប់មានអារម្មណ៍ថា ហត់នឿយ នៅឆ្ងាយ ឬដាច់ចេញពីព្រះអង្គឬទេ? តើអ្នកបានបាត់បង់ភាពស្គប់ស្គល់ខាងវិញ្ញាណហើយឬ? តើដោយសារអ្នកមិនបានរស់នៅឲ្យសមស្របតាមព្រះយេស៊ូវ និងបំណងព្រះទ័យព្រះអង្គឬ? ព្រះទ្រង់តែងតែស្តាប់ការអធិស្ឋានរបស់យើង ពេលណាយើងទូលសូមព្រះអង្គឲ្យស្តារយើងឡើងវិញ (ខ.១)។ តើមានអ្វីរារាំងអ្នកមិនឲ្យទូលសូមព្រះអង្គ?—Arthur Jackson

តើអ្នកបានដកពិសោធន៍នឹងការស្តារឡើងវិញរបស់ព្រះអង្គនៅពេលណាខ្លះ? តើផ្នែកណាខ្លះនៃជីវិតអ្នកដែលត្រូវការការស្តារឡើងវិញក្នុងពេលសព្វថ្ងៃ?

ឱព្រះវរបិតា ទូលបង្គំស្រកឃ្លានការស្តារឡើងវិញរបស់ព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យដឹងថា ទូលបង្គំត្រូវការការស្តារឡើងវិញ។

Daily Manna 2026_Content Enhance.indd 13 17/11/25 1:44 in the afternoon

ព្រះគ្រីស្ទបានសុគតជំនួសយើងវាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង (រ៉ូម ៥:៨)។

ព្រះអង្គសង្គ្រោះដែលស្ម័គ្រព្រះទ័យលះបង់

កាលលោក នីកូឡាស (Nicholas) កំពុងបើកបរ នៅពេលយប់រំលងអាធ្រាត្រ គាត់ក៏បានឃើញអគ្គីភ័យកំពុងឆាបឆេះផ្ទះមួយខ្នង។ គាត់ក៏បានឈប់ឡានលើផ្លូវចូលផ្ទះនោះ ហើយក៏បានប្រញាប់ចូលទៅក្នុងផ្ទះដែលកំពុងឆេះ ដោយបាននាំក្មេងៗបួននាក់ចេញខាងក្រៅដោយសុវត្ថិភាព។ ពេលដែលក្មេងជំទង់ជាអ្នកមើលក្មេងដឹងថា មានក្មេងម្នាក់ទៀត កំពុងជាប់នៅខាងក្នុងនៅឡើយ នាងក៏បានប្រាប់លោក នីកូឡាស។ គាត់ក៏បានរត់ចូលទៅក្នុងផ្ទះដែលមានភ្លើងឆេះសន្ធោសន្ធៅ ដោយគ្មានការស្ទាក់ស្ទើរ។ គាត់ក៏បានជាប់នៅក្នុងជាន់ទីពីរជាមួយក្មេងស្រីអាយុ៦ឆ្នាំម្នាក់ ដោយមិនអាចចុះមកខាងក្រោមវិញបាន។ គាត់ក៏បានវាយបំបែកបង្អួចផ្ទះ រួចលោតចេញមកខាងក្រៅ ដោយសុវត្ថិភាពជាមួយក្មេងនៅក្នុងដៃគាត់ ស្របពេលដែលក្រុមពន្លត់អគ្គីភ័យបានមកដល់។ យប់នោះ គាត់បានជួយសង្គ្រោះក្មេងទាំងអស់នៅក្នុងផ្ទះ ដោយសារគាត់គិតអំពីជីវិតរបស់អ្នកដទៃ ជាសំខាន់ជាងខ្លួនឯង។

លោក នីកូឡាស បានបង្ហាញចេញនូវរឿរភាព ដោយការស្ម័គ្រចិត្តលោះបង់សុវត្ថិភាពផ្ទាល់ខ្លួន ដើម្បីអ្នកដទៃ។ ការបង្ហាញចេញនូវសេចក្តីស្រឡាញ់ដ៏មានអំណាចនេះ បានធ្វើឲ្យខ្ញុំនឹកចាំអំពីសេចក្តីស្រឡាញ់ដែលមានការលះបង់ ដែលព្រះយេស៊ូវបានបង្ហាញចេញមក ដោយការលះបង់ព្រះជន្ម ដើម្បីរំដោះយើងឲ្យរួចពីបាប និងសេចក្តីស្លាប់។ «ដ្បិតកាលយើងនៅខ្សោយនៅឡើយ លុះដល់កំណត់ហើយ នោះព្រះគ្រីស្ទទ្រង់បានសុគតជំនួសមនុស្សទមិលល្មើស» (រ៉ូម ៥:៦)។ សាវ័ក ប៉ុល បាននិយាយសង្កត់ធ្ងន់ថា ព្រះយេស៊ូវជាព្រះដែលបានយកកំណើតជាមនុស្ស បានសម្រេចព្រះទ័យលះបង់ព្រះជន្ម ដើម្បីបង់ថ្លៃលោះយើងឲ្យរួចពីបាប ដែលយើងមិនអាចលោះខ្លួនយើងឲ្យរួចបាន។ «តែឯព្រះទ្រង់សំដែងសេចក្តីស្រឡាញ់របស់ទ្រង់ ដល់យើងរាល់គ្នាឲ្យឃើញច្បាស់ដោយព្រះគ្រីស្ទបានសុគតជំនួសយើងរាល់គ្នា នោះគឺក្នុងកាលដែលយើងនៅមានបាបនៅឡើយផង» (ខ.៨)។

ខណៈពេលដែលយើងអរព្រះគុណ និងជឿព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះដែលស្ម័គ្រព្រះទ័យសុគតដើម្បីយើង ព្រះអង្គអាចប្រទានកម្លាំងឲ្យយើងស្រឡាញ់អ្នកដទៃ ដោយការលះបង់តាមរយៈពាក្យសម្តី និងការប្រព្រឹត្តរបស់យើង។—Xochitl Dixon

តើអ្នកមានអារម្មណ៍យ៉ាងណា ពេលដែលអ្នកបានពិចារណាអំពីការលះបង់របស់ព្រះយេស៊ូវ ដោយសារព្រះអង្គស្រឡាញ់អ្នក? តើអ្នកអាចចាត់ទុកតម្រូវការអ្នកដទៃជាសំខាន់ជាងតម្រូវការខ្លួនឯង ដូចម្តេចខ្លះក្នុងសប្តាហ៍នេះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យទុកចិត្តលើការផ្គត់ផ្គង់របស់ព្រះអង្គ ខណៈពេលដែលទូលបង្គំគិតពីតម្រូវការអ្នកដទៃ ជាសំខាន់ជាងខ្លួនឯង។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | លោកុប្បត្តិ ២០-២២ និងម៉ាថាយ ៦:១៩-៣៤

អើ អញបានស្រឡាញ់ឯង ដោយសេចក្ដីស្រឡាញ់ដ៏ស្ថិតស្ថេរនៅអស់កល្ប (យេរេមា ៣១:៣)។

ស្រឡាញ់តាមរបៀបជាច្រើនរាប់មិនអស់

ក្នុងបទកំណាព្យដែលអ្នកស្រី អេលីហ្សាបិត បារេត (Elizabeth Barrett) បាននិពន្ធមានចំណងជើងថា បទពាក្យ៧ របស់ជនជាតិប៊ែទុយហ្គាល់ ស្ថិតក្នុងចំណោមបទកំណាព្យដែលល្បីល្បាញបំផុតក្នុងភាសាអង់គ្លេស។ ក្នុងកំណាព្យនោះ គាត់បានសរសេរឃ្លាដែលគួរឲ្យចាប់អារម្មណ៍ថា «តើខ្ញុំអាចស្រឡាញ់បង យ៉ាងដូចម្តេចខ្លះ? ខ្ញុំសូមរាប់របៀបដែលខ្ញុំស្រឡាញ់បង»។ គាត់បានសរសេរបទកំណាព្យនេះជូនលោក រ៉ូប៊ឺត ប្រោននីង (Robert Browning) មុនពេលអ្នកទាំងពីររៀបការជាមួយគ្នា។ លោក រ៉ូប៊ឺត មានការរំភើបចិត្តណាស់ ហើយក៏បានលើកទឹកចិត្តអ្នកស្រី អេលីហ្សាបិត ឲ្យបោះពុម្ពផ្សាយកម្រងបទកំណាព្យរបស់គាត់ទាំងអស់។ ប៉ុន្តែ ភាសានៃបទពាក្យ៧នេះ មានភាពទន់ភ្លន់ខ្លាំង ព្រោះជារឿងផ្ទាល់ខ្លួនរបស់គាត់ជាមួយលោក រ៉ូប៊ឺត ដូចនេះគាត់មានការខ្មាសអៀន ហើយក៏បានបោះពុម្ពផ្សាយ ដោយឲ្យគេគិតស្មានថា វាជាបទកំណាព្យដែលគេបកប្រែពីអ្នកនិពន្ធជនជាតិព័រទុយហ្គាល់។

ជួនកាល យើងអាចមានអារម្មណ៍ខ្មាសអៀន ពេលយើងបើកបង្ហាញក្តីស្រឡាញ់ដល់អ្នកដទៃ។ តែព្រះគម្ពីរបានបើកបង្ហាញសេចក្តីស្រឡាញ់របស់ព្រះ ដោយគ្មានការលាក់លៀមឡើយ។ កណ្ឌគម្ពីរយេរេមាបានរំឭកអំពីសេចក្តីស្រឡាញ់ ដែលព្រះអង្គបានបង្ហាញរាស្ត្រព្រះអង្គ ដោយព្រះបន្ទូលដ៏ស្រទន់ថា ព្រះអង្គបានស្រឡាញ់ពួកគេ ដោយសេចក្តីស្រឡាញ់ដ៏អស់កល្ប ហើយបានទាញនាំពួកគេឲ្យត្រឡប់មករកព្រះអង្គវិញ ដោយសេចក្តីសប្បុរសដ៏ស្ថិតស្ថេរ (យេរេមា ៣១:៣)។ ទោះរាស្ត្រព្រះអង្គបានងាកចេញពីព្រះអង្គក៏ដោយ ក៏ព្រះអង្គនៅតែសន្យាថា នឹងស្អាងពួកគេឡើងវិញ ហើយនាំពួកគេត្រឡប់មករកព្រះអង្គវិញ។ ព្រះអង្គប្រាប់ពួកគេថា ព្រះអង្គបានយាងមកប្រទានការសម្រាកដល់ពួកអ៊ីស្រាអែល (ខ.២)។

ព្រះយេស៊ូវបានបង្ហាញសេចក្តីស្រឡាញ់នៃការស្អាងឡើងវិញរបស់ព្រះវរបិតា ដោយប្រទានសន្តិភាព និងការសម្រាកដល់អស់អ្នកដែលវិលត្រឡប់មកព្រះអង្គវិញ។ ចាប់តាំងពីពេលព្រះអង្គផ្ទុំក្នុងស្នូកសត្វ ដល់ពេលព្រះអង្គសុគតនៅលើឈើឆ្កាង ហើយរហូតដល់ពេលដែលព្រះអង្គមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានបង្ហាញព្រះទ័យរបស់ព្រះវរបិតា ដែលចង់ហៅលោកីយ៍ដែលវង្វេង ឲ្យត្រឡប់មករកព្រះអង្គវិញ។ ពេលអ្នកបានអានព្រះគម្ពីរទាំងមូល អ្នកនឹងឃើញថា ព្រះទ្រង់បានបង្ហាញសេចក្តីស្រឡាញ់ម្តងហើយម្តងទៀត តាមមធ្យោបាយជាច្រើនរាប់មិនអស់ជារៀងរហូត។—James Banks

តើព្រះទ្រង់បានបង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នក យ៉ាងដូចម្តេចខ្លះ? តើអ្នកអាចបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះអង្គនៅថ្ងៃនេះ ដោយរបៀបណា?

ឱព្រះយេស៊ូវទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានស្រឡាញ់ទូលបង្គំ ដោយសារសេចក្តីស្រឡាញ់ជាបរិបូរ! សូមព្រះអង្គជួយទូលបង្គំ ឲ្យស្រឡាញ់ព្រះអង្គអស់ពីដួងចិត្ត នៅថ្ងៃនេះ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លោកុប្បត្តិ ២៣-២៤ និងម៉ាថាយ ៧

កាលខ្ញុំឮពាក្យទាំងនោះ ខ្ញុំក៏អង្គុយយំ ហើយសោកសៅអស់ពីរបីថ្ងៃ ខ្ញុំក៏តម ហើយអធិស្ឋាននៅចំពោះព្រះនៃស្ថានសួគ៌ (នេហេមា ១:៤)។

ការអំពាវនាវឲ្យអធិស្ឋាន

លោក អាប្រាហាំ លីនខិន (Abraham Lincoln) បានប្រាប់រឿងអាថ៌កំបាំងមួយដល់មិត្តភក្តិរបស់គាត់ម្នាក់ថា គាត់បានទទួលការជំរុញចិត្តជាច្រើនលើកច្រើនសារ ឲ្យលត់ជង្គង់ចុះ ដោយការជឿជាក់មិនអាចប្រកែកបានថា គាត់មិនមានកន្លែងណាផ្សេងទៀតដែលត្រូវទៅទេ។ ក្នុងសម័យសង្គ្រាមស៊ីវិលអាមេរិក ដ៏គួរឲ្យភ័យតក់ស្លុត លោកប្រធានាធិបតី អាប្រាហាំ លីនខិន មិនគ្រាន់តែបានចំណាយពេលអធិស្ឋានយ៉ាងខ្លាប់ខ្លួន តែក៏បានអំពាវនាវប្រជាជនទូទាំងផ្ទៃប្រទេសឲ្យចូលរួមអធិស្ឋានជាមួយគាត់ផងដែរ។ ក្នុងឆ្នាំ១៨៦១ គាត់បានប្រកាសជ្រើសរើសយកថ្ងៃមួយ ធ្វើជា «ទិវាបន្ទាបខ្លួនអធិស្ឋានតម»។ ហើយគាត់ក៏បានប្រារព្ធទិវានេះម្តងទៀតនៅឆ្នាំ១៨៦៣ ដោយលើកឡើងថា ប្រទេសជាតិ និងមនុស្សម្នាក់ៗមានកាតព្វកិច្ចពឹងផ្អែកលើអំណាចនៃការគ្រប់គ្រងរបស់ព្រះ ដោយសារភាពបាប និងកំហុសរបស់ខ្លួននៅចំពោះព្រះអង្គ ដោយការបន្ទាបខ្លួន សោកស្តាយចំពោះបាបរបស់ខ្លួន តែមានក្តីសង្ឃឹមដ៏មុតមាំថា ការប្រែចិត្តពិតប្រាកដនឹងនាំទៅរកសេចក្តីមេត្តា និងការអត់ទោសបាប»។

បន្ទាប់ពីពួកអ៊ីស្រាអែលបានរស់នៅជាចំណាប់ខ្មាំង ក្នុងចក្រភពបាប៊ីឡូនបាន៧០ឆ្នាំ ស្តេច ស៊ីរូស ក៏បានអនុញ្ញាតឲ្យពួកអ៊ីស្រាអែលវិលត្រឡប់ទៅទីក្រុងយេរូសាឡិមវិញ។ ពួកសំណល់នៃសាសន៍អ៊ីស្រាអែលក៏បានវិលត្រឡប់។ ពេលដែលលោក នេហេមា (នេហេមា ១:៦) ដែលជាអ្នកថ្វាយពែងដល់ស្តេចបាប៊ីឡូន (ខ.១១) ដឹងថា អ្នកដែលបានវិលត្រឡប់ទៅវិញ «គេមានសេចក្តីវេទនា ហើយត្រូវសេចក្តីត្មះតិះដៀលជាខ្លាំង» (ខ.៣) គាត់ក៏បាន «អង្គុយយំ» ហើយសោកសង្រេង និងអធិស្ឋានតមអស់ជាច្រើនថ្ងៃ (ខ.៤)។ គាត់ក៏បានតយុទ្ធក្នុងការអធិស្ឋាន ឲ្យប្រជាជាតិរបស់គាត់ (ខ.៥-១១)។ ហើយក្រោយមក គាត់ក៏បានអំពាវនាវប្រជាជនគាត់ ឲ្យអធិស្ឋានតមផងដែរ (៩:១-៣៧)។

ជាច្រើនសតវត្សរ៍ក្រោយមក ក្នុងសម័យចក្រភពរ៉ូម សាវ័ក ប៉ុល ក៏បានជំរុញគ្រីស្ទបរិស័ទ ឲ្យអធិស្ឋានឲ្យអ្នកដទៃ និងអ្នកកាន់អំណាចផងដែរ (១ធីម៉ូថេ ២:១-២)។ ព្រះនៃយើងនៅតែស្តាប់ការអធិស្ឋានរបស់យើង អំពីរឿងអ្វីដែលមានមានប្រយោជន៍សម្រាប់ជីវិតអ្នកដទៃ។—Alyson Kieda

ហេតុអ្វីព្រះទ្រង់បានបង្គាប់រាស្ត្រព្រះអង្គឲ្យអធិស្ឋានឲ្យប្រទេសជាតិរបស់ខ្លួន? តើថ្ងៃនេះអ្នកអាចអធិស្ឋានឲ្យនរណាខ្លះដែលអ្នកមិនស្គាល់?

ឱព្រះវរបិតា ពេលណាយើងខ្ញុំមានបញ្ហា សូមព្រះអង្គជួយយើងខ្ញុំ និងជ្រោសយើងខ្ញុំឲ្យជាផងដែរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លោកុប្បត្តិ ២៥-២៦ និងម៉ាថាយ ៨:១-១៧

បើសិនជាខ្ញុំចង់ឲ្យអ្នកនោះនៅទាល់តែខ្ញុំមក នោះតើអំពល់អ្វីដល់អ្នក ចូរឲ្យអ្នកមកតាមខ្ញុំចុះ (*យ៉ូហាន ២១:២២*)។

ផ្តោតទៅលើការដើរតាមព្រះយេស៊ូវ

មានពេលមួយខ្ញុំប្រាប់កូនស្រីខ្ញុំឲ្យសម្អាតបន្ទាប់ខាងមុខ មុនពេលចូលគេង។ គាត់ក៏បានឆ្លើយតបភ្លាមៗ ដោយសួរខ្ញុំថា ហេតុអ្វីខ្ញុំមិនប្រាប់ប្អូនស្រីគាត់ឲ្យទៅសម្អាតបន្ទប់នោះដែរ?

ការប្រចាំគ្នាយ៉ាងដូចនេះ ជាការប្រឆាំងតិចតួចដែលកើតឡើងជាញឹកញាប់នៅក្នុងគ្រួសារខ្ញុំ កាលកូនស្រីខ្ញុំនៅក្មេង។ ខ្ញុំតែងតែឆ្លើយតបទៅពួកគេវិញ ដូចសព្វមួយដងថា «កូនកុំបារម្ភអំពីបងប្អូនរបស់កូនអី។ ម៉ាក់ប្រគល់ភារកិច្ចនេះ ឲ្យកូនធ្វើហើយ»។

ក្នុងបទគម្ពីរយ៉ូហានជំពូក២១ យើងឃើញថា បញ្ហាដ៏សាមញ្ញនេះក៏បានកើតឡើងក្នុងចំណោមពួកសាវ័កផងដែរ។ ព្រះយេស៊ូវទើបតែបានស្តាំងសាវ័ក ពេត្រុស ឡើងវិញ បន្ទាប់ពីគាត់បានបដិសេធន៍ព្រះអង្គបីដង (មើលយ៉ូហាន ១៨១៥-១៨, ២៥-២៧)។ ព្រះអង្គក៏បានមានបន្ទូលទៅកាន់គាត់ថា «ចូរមកតាមខ្ញុំចុះ!» (២១:១៩) ដែលជាព្រះរាជបញ្ជាដ៏សាមញ្ញ តែនាំឲ្យមានការឈឺចាប់។ ព្រះយេស៊ូវក៏បានពន្យល់លោក ពេត្រុស ថា គាត់នឹងដើរតាមព្រះអង្គរហូតដល់អស់ជីវិត (ខ.១៨-១៩)។

លោក ពេត្រុស មិនបានយល់ព្រះបន្ទូលព្រះយេស៊ូវច្បាស់ទេ បានជាគាត់ទូលសួរព្រះអង្គ អំពីសាវ័កម្នាក់ទៀតដែលនៅក្រោយគាត់ថា «តើអ្នកនោះនឹងបានដូចម្តេចទៅ?» (ខ.២១)។ ព្រះយេស៊ូវក៏បានឆ្លើយថា «បើសិនជាខ្ញុំចង់ឲ្យអ្នកនោះនៅទាល់តែខ្ញុំមក នោះតើអំពល់អ្វីដល់អ្នក ចូរឲ្យអ្នកមកតាមខ្ញុំចុះ» (ខ.២២)។

ជាញឹកញាប់ យើងក៏មានបញ្ហានេះដូចសាវ័ក ពេត្រុស ផងដែរ! យើងចង់ដឹងអំពីការធ្វើដំណើរខាងវិញ្ញាណរបស់អ្នកដទៃ ហើយមិនបានគិតអំពីការអ្វីដែលព្រះកំពុងធ្វើក្នុងជីវិតយើង។ នៅចុងបញ្ចប់នៃជីវិតរបស់សាវ័ក ពេត្រុស កាលសេចក្តីស្លាប់របស់គាត់ជិតដល់ពេលកំណត់ តាមបទទំនាយរបស់ព្រះយេស៊ូវក្នុងបទគម្ពីរយ៉ូហានជំពូក២១ គាត់ក៏បានបកស្រាយព្រះរាជបញ្ជាដ៏សាមញ្ញរបស់ព្រះយេស៊ូវ ឲ្យយើងរស់នៅ «ដូចជាពួកកូនដែលស្តាប់បង្គាប់ ឥតបណ្តោយតាមសេចក្តីប៉ងប្រាថ្នា ដែលអ្នករាល់គ្នាមាន ពីកាលនៅល្ងង់ពីដើមនោះឡើយ តែចូរឲ្យអ្នករាល់គ្នាបានបរិសុទ្ធក្នុងគ្រប់កិរិយាទាំងអស់ ដូចជាព្រះដែលហៅអ្នករាល់គ្នាទ្រង់បរិសុទ្ធដែរ» (១ពេត្រុស ១:១៤-១៥)។ ការបង្រៀននេះគឺគ្រប់គ្រាន់ល្មមនឹងឲ្យយើងផ្តោតទៅលើព្រះយេស៊ូវ ជាជាងផ្តោតទៅលើមនុស្សនៅជុំវិញយើង។—Matt Lucas

តើអ្នកធ្លាប់ជួបការល្បួងឲ្យប្រៀបធៀបជីវិតខាងជំនឿរបស់អ្នកជាមួយអ្នកដទៃទេ? តើអ្នកអាចបន្តផ្តោតចិត្តទៅលើព្រះយេស៊ូវ នៅថ្ងៃនេះដោយរបៀបណា?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គបន្តកែប្រែទូលបង្គំ ឲ្យមានលក្ខណៈដូចព្រះរាជបុត្រាព្រះអង្គ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | លោកុប្បត្តិ ២៧-២៨ និងម៉ាថាយ ៨:១៨-៣៤

ព្រះយេហូវ៉ាទ្រង់គង់ជាមួយនឹងគាត់ ហើយការអ្វីដែលគាត់ធ្វើ នោះទ្រង់ធ្វើឲ្យចំរើនឡើងគ្រប់ជំពូក (លោកុប្បត្តិ ៣៩:២៣)។

ព្រះអង្គគង់នៅជាមួយអ្នកបម្រើព្រះអង្គ

ក្នុងជំរុំជនភៀសខ្លួនមួយក្នុងតំបន់មជ្ឈិមបូព៌ា ពេលដែលលោក រេហ្សា (Reza) បានទទួលព្រះគម្ពីរមួយក្បាល គាត់ក៏បានស្គាល់ព្រះយេស៊ូវ ហើយសម្រេចចិត្តទទួលជឿព្រះអង្គ។ គាត់បានអធិស្ឋានជាលើកដំបូងក្នុងព្រះនាមព្រះគ្រីស្ទសូមព្រះអង្គប្រើគាត់ ជាអ្នកបម្រើព្រះអង្គ។ ក្រោយមក បន្ទាប់ពីគាត់បានចាកចេញពីជំរុំនោះ ព្រះអង្គក៏បានឆ្លើយតបការអធិស្ឋានរបស់គាត់ ដោយប្រទានពរគាត់ឲ្យមានការងារធ្វើជាមួយអង្គការមនុស្សធម៌ ហើយក៏បានវិលត្រឡប់មកជំរុំវិញ ដើម្បីបម្រើមនុស្សដែលគាត់បានស្គាល់ និងស្រឡាញ់។ គាត់ក៏បានបង្កើតក្លឹបកីឡាថ្នាក់រៀនភាសា និងកន្លែងផ្តល់ប្រឹក្សាផ្នែកច្បាប់ ព្រោះគាត់ចង់ធ្វើអ្វីដែលគាត់អាចធ្វើបាន ដើម្បីផ្តល់ឲ្យប្រជាជនគាត់នូវសេចក្តីសង្ឃឹម។ គាត់ក៏បានមើលឃើញកម្មវិធីទាំងនេះ ជាឱកាសដើម្បីបម្រើអ្នកដទៃ និងចែកចាយប្រាជ្ញា និងសេចក្តីស្រឡាញ់របស់ព្រះអង្គ។

ពេលលោក រេហ្សា អានព្រះគម្ពីរ គាត់ក៏បានទទួលការប៉ះពាល់ចិត្តយ៉ាងខ្លាំងពីរឿងលោក យ៉ូសែប ក្នុងកណ្ឌគម្ពីរលោកុប្បត្តិ។ គាត់បានកត់សម្គាល់ឃើញថា ព្រះទ្រង់បានប្រើលោក យ៉ូសែប កាលគាត់នៅក្នុងគុក ដើម្បីសម្រេចផែនការព្រះអង្គ។ ដោយសារព្រះអង្គគង់នៅជាមួយលោក យ៉ូសែប ព្រះអង្គក៏បានបង្ហាញសេចក្តីសប្បុរសដល់គាត់ និងប្រទានពរគាត់ជាច្រើន។ មេគុកបានឲ្យលោក យ៉ូសែប មើលការខុសត្រូវក្នុងគុក ដោយមិនមានការព្រួយបារម្ភ ព្រោះព្រះអម្ចាស់បានប្រទានពរលោក យ៉ូសែប ក្នុងកិច្ចការអ្វីក៏ដោយដែលគាត់ធ្វើ (លោកុប្បត្តិ ៣៩:២៣)។

ព្រះទ្រង់សន្យាថា នឹងគង់នៅជាមួយយើងផងដែរ។ ទោះយើងកំពុងជាប់គុកខាងផ្លូវកាយ ឬផ្លូវចិត្ត ឬមានទុក្ខលំបាក ការបែកបាក់ ការខូចចិត្ត ឬការសោកសង្រេងក្តី យើងអាចទុកចិត្តថា ព្រះអង្គនឹងមិនចាកចេញពីយើងឡើយ។ ព្រះអង្គនឹងគង់ក្បែរយើងជានិច្ច គឺដូចដែលព្រះអង្គជួយលោក រេហ្សា ឲ្យបម្រើមនុស្សក្នុងជំរុំភៀសខ្លួន និងជួយលោក យ៉ូសែប ឲ្យគ្រប់គ្រងគុក។—Amy Boucher Pye

តើអ្នកបានដកពិសោធន៍នឹងជំនួយរបស់ព្រះអម្ចាស់ដូចលោក រេហ្សា និងលោក យ៉ូសែប នៅពេលណាខ្លះ? តើរឿងរបស់លោក យ៉ូសែប បានជួយអ្នកឲ្យទុកចិត្តព្រះអង្គកាន់តែខ្លាំងយ៉ាងដូចម្តេចខ្លះ?

ឱព្រះដ៏ជួយសង្គ្រោះ ព្រះអង្គមិនដែលចាកចេញពីទូលបង្គំ សូម្បីតែពេលដែលទូលបង្គំជួបកាលៈទេសៈពិបាកបំផុត។ សូមព្រះអង្គប្រទានទូលបង្គំនូវក្តីសង្ឃឹម និងបើកភ្នែកទូលបង្គំឲ្យឃើញព្រះអង្គធ្វើការក្នុងជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 18 17/11/25 1:44 in the afternoon

ចូរពិចារណាមើលទ្រង់ ដែលទ្រង់បានទ្រាំទ្រនឹងពួកមនុស្សមានបាប... ក្រែងលោអ្នកពាល់គ្នាត្រូវនឿយហត់ ហើយរសាយចិត្តចេញ (ហេព្រើរ ១២:៣)។

ការស៊ូទ្រាំថ្វាយព្រះយេស៊ូវ

កាលខ្ញុំកំពុងរៀននៅសាលាព្រះគម្ពីរកាលពីប៉ុន្មានឆ្នាំមុន យើងមានកម្មវិធីថ្វាយបង្គំប្រចាំសប្តាហ៍។ ក្នុងពេលថ្វាយបង្គំមួយលើកនោះ ខណៈពេលដែលសិស្សទាំងឡាយកំពុងច្រៀងបទ «ព្រះអម្ចាស់អស្ចារ្យ» ខ្ញុំសង្កេតឃើញសាស្ត្រាចារ្យបីរូបកំពុងច្រៀង ដោយចិត្តឆេះឆួល។ ទឹកមុខរបស់ពួកគាត់បង្ហាញចេញនូវក្តីអំណរ ដោយសារសេចក្តីជំនឿដែលពួកគាត់មានចំពោះព្រះអម្ចាស់។ ប៉ុន្មានឆ្នាំក្រោយមក ខណៈពេលដែលពួកគាត់ម្នាក់ៗកំពុងមានជំងឺដំណាក់ចុងក្រោយ សេចក្តីជំនឿរបស់ពួកគាត់បានជួយឲ្យពួកគាត់អាចស៊ូទ្រាំទុក្ខលំបាក និងលើកទឹកចិត្តអ្នកដទៃ។

សព្វថ្ងៃនេះ ការនឹកចាំអំពីរបៀបដែលពួកគាត់ច្រៀងសរសើរតម្កើងព្រះ បានបន្តលើកទឹកចិត្តខ្ញុំឲ្យបន្តដំណើរទៅមុខទៀតក្នុងទុក្ខលំបាករបស់ខ្ញុំ។ សម្រាប់ខ្ញុំ ពួកគាត់ស្ថិតក្នុងចំណោមគំរូនៃការលើកទឹកចិត្តរបស់មនុស្សជាច្រើន ដែលរស់នៅដោយជំនឿ។ ពួកគាត់បានរំឭកខ្ញុំ អំពីរបៀបដែលយើងអាចអនុវត្តតាមការបង្រៀនក្នុងបទគម្ពីរហេព្រើរ ១២:២-៣ ឲ្យមើលទៅព្រះយេស៊ូវជាប់ជានិច្ច ដែលព្រះអង្គ «បានរងទ្រាំនៅឈើឆ្កាង... ឲ្យតែបានសេចក្តីអំណរដែលនៅចំពោះទ្រង់» (ខ.២)។

ពេលណាទុក្ខលំបាក ដោយសារការបៀតបៀន ឬបញ្ហាប្រឈមក្នុងជីវិត ធ្វើឲ្យយើងពិបាកបន្តដំណើរទៅមុខទៀត ចូរយើងយកគំរូតាមអ្នកដែលបានធ្វើតាមព្រះបន្ទូលព្រះ ហើយទុកចិត្តព្រះបន្ទូលសន្យារបស់ព្រះអង្គ។ យើងអាច «រត់ក្នុងទីប្រណាំង ដែលនៅមុខយើង ដោយអំណត់» (ខ.១) ដោយចាំថា ព្រះយេស៊ូវ និងអ្នកដែលបានដើរក្នុងជំនឿមុនយើង អាចស៊ូទ្រាំនឹងទុក្ខលំបាក។ បទគម្ពីរនេះក៏បានលើកទឹកចិត្តយើងឲ្យ «ពិចារណាមើលទ្រង់» ដើម្បីកុំឲ្យយើងត្រូវនឿយហត់ ហើយរសាយចិត្តចេញឡើយ (ខ.៣)។

ទីបន្ទាល់របស់គ្រូខ្ញុំ ដែលកំពុងរស់នៅក្នុងនគរស្ថានសួគ៌ដោយអំណរបានបង្ហាញថា «ជីវិតនៃសេចក្តីជំនឿគឺសក្តិសមនឹងឲ្យយើងរស់នៅ។ ចូរបន្តរស់នៅដោយជំនឿទៀត»។—Karen Huang

តើនរណាបានបណ្តាលចិត្តអ្នក ឲ្យបន្តធ្វើដំណើរខាងសេចក្តីជំនឿ? តើគំរូរបស់ពួកគេបានលើកទឹកចិត្តអ្នក ឲ្យស៊ូទ្រាំនឹងទុក្ខលំបាក ដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យមើលទៅព្រះអង្គជាប់ជានិច្ច។ ពេលណាទូលបង្គំហត់នឿយ និងអស់សង្ឃឹម ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានគំរូដ៏ល្អ និងទីបន្ទាល់របស់អ្នកដទៃដែលបានដើរក្នុងព្រះអង្គមុនទូលបង្គំ។

Daily Manna 2026_Content Enhance.indd 19 17/11/25 1:44 in the afternoon

ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្តីឈឺចាប់របស់យើង (អេសាយ ៥៣:៤)។

ព្រះអង្គទទួលយកអំពើបាប

គ្រោះមហន្តរាយនៃរោងចក្រនុយក្លេអ៊ែរនៅខេត្តហ្វ៊ីគូស៊ីម៉ា ប្រទេសជប៉ុន កាលពីឆ្នាំ២០១១ ដែលបណ្តាលមកពីគ្រោះរញ្ជួយដីបានបញ្ចេញជាតិពុលវិទ្យុសកម្មដ៏ច្រើនលើសលប់ ហើយបានបង្ខំពលរដ្ឋជាង១៥ម៉ឺននាក់ ឲ្យចាកចេញពីតំបន់ដែលទទួលផលប៉ះពាល់។ អ្នកស្រុកម្នាក់បានរៀបរាប់ថា «គ្រោះមហន្តរាយនេះ ប្រៀបដូចជាព្រិលដែលគេមើលមិនឃើញ ធ្លាក់មកលើខេត្តហ្វ៊ីគូស៊ីម៉ា ហើយបន្តធ្លាក់ និងគ្របដណ្តប់ពីលើតំបន់នោះ»។ គេបានរកឃើញជាតិវិទ្យុសកម្មក្នុងកម្រិតខ្ពស់នៅក្នុងបន្លែ សាច់ និងតំបន់ទេសចរណ៍ដែលស្ថិតនៅចម្ងាយជាច្រើនគីឡូម៉ែត្រពីរោងចក្រនុយក្លេអ៊ែរ។ ដើម្បីប្រយុទ្ធប្រឆាំងនឹងជាតិពុលនោះ អ្នករស់នៅក្នុងតំបន់នោះ ក៏បានចាប់ផ្តើមដាំដើមផ្កាឈូកវ័ត្ត ដែលគេឮល្បីថា ពួកវាអាចស្រូបយកជាតិវិទ្យុសកម្មបាន។ ពួកគេបានយកគ្រាប់ផ្កាឈូកវ័ត្តជាង២សែនគ្រាប់ទៅដាំនៅទីនោះ ហើយសព្វថ្ងៃនេះ ដើមផ្កាឈូកវ័ត្តរាប់លានដើមកំពុងមានផ្ការីកស្គុះស្គាយក្នុងខេត្តហ្វ៊ីគូស៊ីម៉ា។

ព្រះទ្រង់បានរចនា និងបង្កើតដើមផ្កាឈូកវ័ត្ត ឲ្យមានអត្ថប្រយោជន៍ច្រើនលើសពីការរំពឹងគិតរបស់យើង។ ការនេះបានធ្វើឲ្យខ្ញុំនឹកចាំ អំពីដំណោះស្រាយដែលព្រះយេស៊ូវបានប្រើ ដើម្បីប្រោសពិភពលោកទាំងមូលឲ្យជា។ ព្រះគ្រីស្ទបានទទួលយកការឈឺចាប់របស់យើង ដាក់នៅលើព្រះកាយព្រះអង្គ ហើយបាន «រងអស់ទាំងសេចក្តីឈឺចាប់របស់យើង» (អេសាយ ៥៣:៤)។ ព្រះអង្គបានទទួលយកគ្រប់ទាំងការអាក្រក់ អំពើបាប និងការរីកសាយភាយនៃអំពើបាបក្នុងលោកីយ៍ និងមធ្យោបាយទាំងអស់ដែលមនុស្សបានប្រើ ដើម្បីបំផ្លាញខ្លួនឯង។

ព្រះអង្គបានទទួលយកបាបរបស់យើងទាំងអស់។ នៅលើឈើឆ្កាង សាច់ព្រះអង្គត្រូវគេ «ចាក់ទំលុះ» មិនមែនដោយសារព្រះអង្គមានកំហុស តែដោយសារ «អំពើរំលងរបស់យើង» (ខ.៥)។ ហើយដោយសារព្រះអង្គបានសុគត ដើម្បីលោះបាបយើង យើងអាចមានភាពពេញលេញ។ «យើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់» (ខ.៥)។

ព្រះគ្រីស្ទមិនគ្រាន់តែបានអត់ទោសឲ្យយើងតាំងពីយូរមកហើយប៉ុណ្ណោះទេ តែក៏បានផ្ទុកលើអង្គទ្រង់ ដោយអំពើអាក្រក់របស់យើង។ ព្រះយេស៊ូវបានទទួលយកទាំងអស់។ ហើយបន្ទាប់មក ព្រះអង្គក៏បានប្រោសយើងឲ្យជាខាងវិញ្ញាណ។—Winn Collier

តើមានការអាក្រក់ណា ដែលព្រះយេស៊ូវបានអត់ទោសឲ្យអ្នក? តើការដែលព្រះអង្គទទួលយកកំហុសរបស់អ្នក បានកែប្រែការយល់ដឹងរបស់អ្នកអំពីការអត់ទោសរបស់ព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ព្រះអង្គបានការពារ និងឃុំគ្រងទូលបង្គំ ហើយក៏បានយាងមកគង់នៅជាមួយទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំឲ្យធ្វើការល្អជាប្រយោជន៍ដល់អ្នកដទៃ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | លោកុប្បត្តិ ៣៣-៣៥ និងម៉ាថាយ ១០:១-២០

អ្នកណាក្នុងពួកអ្នករាល់គ្នាដែលចង់ធ្វើធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ (ម៉ាកុស ១០:៤៣)។

បម្រើអ្នកដទៃ ថ្វាយព្រះយេស៊ូវ

ក្រុសម្តែងស្រីឈ្មោះ នីស៊ែល នីខូល (Nichelle Nichols) មានគេនឹកចាំអំពីគាត់ ភាគច្រើនដោយសារគាត់បានសម្តែងតួអនុសេនីយ៍ទោ អ៊ូរ៉ា (Uhura) ក្នុងរឿងការធ្វើដំណើរក្នុងភពផ្កាយ។ ការដើរតួក្នុងរឿងនេះបាននាំឲ្យគាត់ទទួលបានជោគជ័យក្នុងអាជីព ដោយធ្វើឲ្យគាត់ក្លាយជាស្ត្រីអាមេរិកស្បែកខ្មៅមុនគេ ដែលបានដើរតួសម្តែងក្នុងកម្មវិធីទូរទស្សន៍ធំៗ។ តែរឿងនេះក៏បាននាំឲ្យគាត់ជោគជ័យលើសពីនេះទៀត។

អ្នកស្រី នីស៊ែល បានលាឈប់ពីការសម្តែងក្នុងខ្សែភាពយន្តការធ្វើដំណើរក្នុងភពផ្កាយក្នុងរដូវកាលទី១ ដើម្បីវិលត្រឡប់ទៅរកអាជីពក្នុងសាលមហោស្រពវិញ។ ប៉ុន្តែ បន្ទាប់មកគាត់ក៏បានជួបលោក ម៉ាទីន លូសើរ ឃីង ចេអរ (Martin Luther King Jr) ដែលបានជំរុញគាត់មិនឲ្យចាកចេញពីការសម្តែងនោះ។ លោក ម៉ាទីន លូសើរ ឃីង បានមានប្រសាសន៍ថា នេះជាលើកទីមួយហើយ ដែលជនជាតិអាមេរិកស្បែកខ្មៅមានមុខនៅលើកញ្ចក់ទូរទស្សន៍ក្នុងការដើរតួជាមនុស្សមានបញ្ញា ដែលអាចធ្វើអ្វីៗក៏បាន សូម្បីតែការធ្វើដំណើរនៅក្នុងភពផ្កាយក៏ដោយ។ តាមរយៈការសម្តែងជាឧត្តមសេនីយ៍ អ៊ូរ៉ា អ្នកស្រី នីស៊ែល ទទួលបានជោគជ័យដែលសំខាន់ជាងនេះទៀត ដែលជាការបង្ហាញស្ត្រី និងកុមារជាជនជាតិស្បែកខ្មៅ នូវការអ្វីដែលពួកគេអាចធ្វើបាន។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីលោក យ៉ាកុប និងលោក យ៉ូហាន ដែលបានទូលសូមមុខតំណែងល្អជាងគេពីរកន្លែងនៅក្នុងនគរព្រះអង្គ (ម៉ាកុស ១០:៣៧)។ ពួកគេប្រហែលជាគិតថា ការទទួលបានមុខតំណែងនោះ គឺជាជោគជ័យផ្ទាល់ខ្លួនដ៏អស្ចារ្យបំផុតហើយ! តែព្រះយេស៊ូវមិនគ្រាន់តែបានបកស្រាយអំពីការពិតដ៏ឈឺចាប់នៃការស្នើសុំរបស់ពួកគេ (ខ.៣៨-៤០) តែក៏បានត្រាស់ហៅពួកគេ ឲ្យមានគោលដៅដែលខ្ពស់ជាងនេះទៀត។ គឺដូចដែលព្រះអង្គមានបន្ទូលថា "អ្នកណាក្នុងពួកអ្នករាល់គ្នាដែលចង់ធ្វើធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ" (ខ.៤៣)។ ដូចនេះ សិស្សព្រះអង្គមិនត្រូវស្វែងរកជោគជ័យសម្រាប់ខ្លួនឯងប៉ុណ្ណោះឡើយ តែត្រូវប្រើមុខនាទីរបស់ខ្លួន ដើម្បីបម្រើអ្នកដទៃវិញ (ខ.៤៥)។

ដូចនេះ អ្នកស្រី នីស៊ែល នីកូល បានបន្តការដើរតួសម្តែងក្នុងរឿងការធ្វើដំណើរក្នុងភពផ្កាយ ដើម្បីប្រយោជន៍ជនជាតិអាមេរិកស្បែកខ្មៅ។ ចូរយើងកុំស្វែងរកភាពជោគជ័យសម្រាប់តែខ្លួនឯងឡើយ តែត្រូវប្រើមុខនាទីអ្វីក៏ដោយដែលយើងមាន ដើម្បីបម្រើអ្នកដទៃក្នុងព្រះនាមព្រះអង្គ។—Sheridan Voysey

តើសព្វថ្ងៃនេះ អ្នកមានគោលដៅអ្វីសម្រាប់អាជីពរបស់អ្នក? តើអ្នកអាចបើកទ្វារអ្វីខ្លះសម្រាប់អ្នកដទៃក្នុងពេលសព្វថ្ងៃ?

ឱព្រះយេស៊ូវ សូមព្រះអង្គបង្ហាញទូលបង្គំអំពីរបៀបប្រើតួនាទីទូលបង្គំ ដើម្បីបម្រើអ្នកដទៃ ដោយនូវព្រះនាមព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លោកុប្បត្តិ ៣៦-៣៨ និងម៉ាថាយ ១០:២១-៤២

រីឯការទាំងនោះបានកើតមកដល់គេទុកជាគំរូ ហើយបានកត់ទុកសំរាប់ជាសេចក្តីទូន្មានប្រដៅដល់យើងវាល់ (*១កូរិនថូស ១០:១១*)។

រៀនសូត្រពីកំហុសកាលពីអតីតកាល

ដើម្បីជៀសវាងកំហុសផ្នែកហិរញ្ញវត្ថុនៅពេលអនាគត ដូចកាលពីឆ្នាំ១៩២៩ និងឆ្នាំ២០០៨ ដែលនាំឲ្យសេដ្ឋកិច្ចមានការធ្លាក់ចុះធ្ងន់ធ្ងរ គេក៏បានបង្កើតបណ្ណាល័យកំហុសនៅទីក្រុងអេឌីនប៊ឺក ប្រទេសស្កុតឡង់ដ៍។ បណ្ណាល័យនោះបានប្រមូលផ្តុំសៀវភៅល្អៗជាង២ពាន់ក្បាល ដែលអាចជួយផ្តល់ការអប់រំ ដល់អ្នកជំនាញផ្នែកសេដ្ឋកិច្ចជំនាន់ក្រោយ។ បណ្ណារក្សដែលធ្វើការក្នុងបណ្ណាល័យនេះបានមានលើកឡើងថា បណ្ណាល័យនេះបានផ្តល់ឲ្យនូវឧទាហរណ៍ដ៏ឥតខ្ចោះរបស់មនុស្សឆ្លាត ដែលបន្តធ្វើកំហុសដ៏ល្ងង់ខ្លៅ។ បណ្ណារក្សទាំងនោះជឿថា វិធីតែមួយដើម្បីកសាងសេដ្ឋកិច្ចឲ្យរឹងមាំ គឺត្រូវរៀនពីកំហុសពីអតីតកាល។

សាវ័ក ប៉ុល បានរំឭកពួកជំនុំនៅទីក្រុងកូរិនថូសថា ដើម្បីជៀសវាងការចាញ់ការល្បួង និងមានជីវិតខាងវិញ្ញាណដ៏រឹងមាំ គឺត្រូវរៀនសូត្រពីកំហុសដែលរាស្ត្ររបស់ព្រះបានធ្វើកាលពីសម័យមុន។ ដូចនេះ ដើម្បីកុំឲ្យពួកគេមានទំនុកចិត្តលើកខ្លួនឯងពេក ដោយសារឯកសិទ្ធិខាងវិញ្ញាណ សាវ័ក ប៉ុល ក៏បានលើកឡើងអំពីបរាជ័យរបស់ពួកអ៊ីស្រាអែល ធ្វើជាគំរូសម្រាប់ឲ្យយើងរៀនសូត្រ ឲ្យបានប្រាជ្ញា។ ពួកអ៊ីស្រាអែលបានប្រព្រឹត្តការថ្វាយបង្គំរូបព្រះ អំពើកំផិត និងការរអ៊ូរទាំ អំពីផែនការ និងបំណងព្រះទ័យព្រះ ហើយក៏បានទាស់ប្រឆាំងនឹងអ្នកដឹកនាំដែលព្រះអង្គបានជ្រើសតាំងសម្រាប់ពួកគេ។ ដោយសារអំពើបាបរបស់ពួកគេ ពួកគេក៏បានទទួលរងការវាយផ្ចាល (*១កូរិនថូស ១០:៧-១០*)។ សាវ័ក ប៉ុល បានដកស្រង់ឧទាហរណ៍ក្នុងព្រះគម្ពីរ ដើម្បីជួយអ្នកជឿព្រះយេស៊ូវឲ្យជៀសវាងការប្រព្រឹត្តខុសតាមពួកអ៊ីស្រាអែល (*ខ.១១*)។

ខណៈពេលដែលព្រះទ្រង់ជួយយើង ចូរយើងរៀនសូត្រពីកំហុសយើង និងកំហុសអ្នកដទៃ ដើម្បីឲ្យយើងមានចិត្តដែលស្តាប់បង្គាប់ព្រះអង្គ។—Marvin Williams

តើយើងត្រូវនឹកចាំអំពីការដាស់តឿនណា ពេលយើងជួបការល្បួង? តើយើងអាចរៀនសូត្រពីកំហុសរបស់យើង និងអ្នកដទៃដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យរៀនសូត្រពីកំហុសរបស់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចស្តាប់បង្គាប់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 22 17/11/25 1:44 in the afternoon

នោះចូរលើសយកព្រះណា ដែលឯងចង់គោរពប្រតិបត្តិតាមនៅថ្ងៃនេះចុះ... តែឯអញ និងពួកគ្រួអញ យើងទាំងអស់គ្នានឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ (យ៉ូស្វេ ២៤:១៥)។

សម្រេចចិត្តដើរតាមព្រះ

នៅក្នុងការចេញផ្សាយរបស់កាសែតមួយនៅប្រទេសអង់គ្លេស គេបានអះអាងថា «ជាមធ្យម មនុស្សធ្វើការសម្រេចចិត្ត ចំនួន ៧៧៣៦១៨ដង ក្នុងមួយជីវិត។ ហើយក្នុងចំណោមនោះ យើងនឹងមានការស្តាយក្រោយ ចំពោះការសម្រេចចិត្ត ចំនួន ១៤៣២៦២ដង»។ ខ្ញុំមិនដឹងថា កាសែតនេះបានតួលេខនេះពីណាមកទេ ប៉ុន្តែយើងអាចដឹងច្បាស់ថា យើងម្នាក់ៗបានធ្វើការសម្រេចចិត្តរាប់មិនអស់ក្នុងជីវិតយើង។ ពេលយើងគិតអំពីចំនួននៃការសម្រេចចិត្តដ៏ច្រើនលើសលប់នេះ យើងប្រហែលមានអារម្មណ៍ថាលែងចង់ធ្វើអ្វីទៀត ជាពិសេសនៅពេលយើងពិចារណាអំពីការសម្រេចចិត្តទាំងអស់របស់យើងសុទ្ធតែមានលទ្ធផល ហើយលទ្ធផលខ្លះសំខាន់ជាងលទ្ធផលផ្សេងទៀត។

បន្ទាប់ពីពួកអ៊ីស្រាអែលរស់នៅវិលវល់ក្នុងវាលរហោស្ថានអស់៤០ឆ្នាំ ពួកគេក៏បានទៅដល់កន្លែង ដែលពួកគេត្រូវឆ្លងចូលទៅក្នុងទឹកដីថ្មី។ ក្រោយមក បន្ទាប់ពីបានចូលទៅក្នុងទឹកដីនោះ លោក យ៉ូស្វេ ជាអ្នកដឹកនាំរបស់ពួកគេក៏បានប្រាប់ពួកគេធ្វើការសម្រេចចិត្តកោតខ្លាចព្រះអម្ចាស់ ហើយបម្រើព្រះអង្គ ដោយចិត្តស្មោះត្រង់។ គាត់ក៏បានបង្គាប់ពួកគេឲ្យបោះបង់ចោលព្រះក្លែងក្លាយ ដែលពួកឰយុកោរបស់ពួកគេបានថ្វាយបង្គំ (យ៉ូស្វេ ២៤:១៤)។ គាត់ក៏បានប្រាប់ពួកគេថា «ចូររើសយកព្រះណា ដែលឯងចង់គោរពប្រតិបត្តិតាមនៅថ្ងៃនេះចុះ... តែឯអញ និងពួកគ្រួអញ យើងទាំងអស់គ្នានឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ (ខ.១៥)។

ខណៈពេលដែលថ្ងៃថ្មីមកដល់ យើងត្រូវប្រឈមមុខដាក់ការសម្រេចចិត្តសំខាន់ៗជាច្រើន។ ចូរយើងចំណាយពេលអធិស្ឋានទូលសូមព្រះអង្គដឹកនាំយើងក្នុងការសម្រេចចិត្ត។ យើងអាចសម្រេចចិត្តដើរតាមព្រះអង្គជារៀងរាល់ថ្ងៃ ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។—Bill Crowder

តើអ្នកមានការសោកស្តាយចំពោះការសម្រេចចិត្តណាខ្លះ? តើអ្នកបានរៀនសូត្របានអ្វីខ្លះពីកំហុសទាំងនោះ?

ឱព្រះវរបិតា ជូនកាលទូលបង្គំមានអារម្មណ៍ថា ជីវិតមានការពិបាកខ្លាំងពេក ហើយទូលបង្គំប្រឈមមុខដាក់ការសម្រេចចិត្តជាច្រើន។ សូមព្រះអង្គដឹកនាំទូលបង្គំក្នុងការសម្រេចចិត្ត ដើម្បីឲ្យទូលបង្គំថ្វាយព្រះកិត្តិនាមដល់ព្រះអង្គក្នុងការសម្រេចចិត្ត។

Daily Manna 2026_Content Enhance.indd 23 17/11/25 1:44 in the afternoon

ដ្បិតខ្ញុំបានធ្វើដំរាប់ទុកឲ្យអ្នករាល់គ្នាហើយ ដើម្បីឲ្យអ្នករាល់គ្នាគ្រាប់តាមការដែលខ្ញុំបានធ្វើឲ្យនោះ (យ៉ូហាន ១៣:១៥)។

បន្ទាបខ្លួនបម្រើ តាមគំរូព្រះយេស៊ូវ

នៅថ្ងៃខួបអាពាហ៍ពិពាហ៍ទី៥០ របស់លោក ឆាលី (Charley) និងអ្នកស្រី ជែន (Jan) ពួកគេក៏បានទៅញ៉ាំអាហារពេលព្រឹកនៅក្នុងហាងកាហ្វេមួយជាមួយកូនប្រុសរបស់ពួកគេឈ្មោះ ចន (Jon)។ ថ្ងៃនោះ ហាងកាហ្វេមិនមានអ្នករត់តុគ្រប់គ្រាន់ ដោយមានតែអ្នកគ្រប់គ្រងម្នាក់ ចុងភៅម្នាក់ ក្មេងស្រីជំទង់ពីរនាក់ ដែលកំពុងធ្វើការជាអ្នកទទួលភ្ញៀវផង អ្នករត់តុផង និងអ្នកសម្អាតផង។ នៅពេលដែលពួកគេបរិភោគអាហារពេលព្រឹកហើយ លោក ឆាលី ក៏បានសួរភរិយា និងកូនប្រុសរបស់ខ្លួនថា តើពួកគេមានកិច្ចការសំខាន់ដែលត្រូវធ្វើក្នុងរយៈពេលពីរបីម៉ោងទៀតទេ? ពួកគេឆ្លើយថា មិនមានទេ។

ដូចនេះ ដោយការអនុញ្ញាតពីអ្នកគ្រប់គ្រង លោក ឆាលី និងអ្នកស្រី ជែន ក៏បានចាប់ផ្តើមជួយលាងចានឲ្យភ្ញាជនីយដ្ឋាននោះ ខណៈពេលដែលលោក ចន ជាកូនប្រុសចាប់ផ្តើមសម្អាតតុអាហារ។ លោក ចន បានបកស្រាយថា ការអ្វីដែលបានកើតឡើងនៅថ្ងៃនោះ មិនមែនជារឿងចម្លែកទេ។ ឪពុកម្តាយរបស់គាត់តែងតែយកតម្រាប់តាមព្រះយេស៊ូវ ដែល «បានមក មិនមែនឲ្យគេបំរើដែរ គឺដើម្បីនឹងបំរើគេវិញ» (ម៉ាកុស ១០:៤៥)។

ក្នុងកណ្ឌគម្ពីរយ៉ូហាន ជំពូក១៣ ព្រះយេស៊ូវបានសោយអាហារជាលើកចុងក្រោយជាមួយពួកសាវ័ក។ នៅយប់នោះ ព្រះយេស៊ូវ ដែលជាគ្រូរបស់ពួកគេបានលាងជើងពួកគេម្នាក់ៗ ដើម្បីបង្រៀនពួកគេអំពីគោលការណ៍នៃការបន្ទាបខ្លួនបម្រើ (ខ.១៤-១៥)។ ដោយសារព្រះអង្គបានស្ម័គ្រព្រះទ័យធ្វើកិច្ចការដ៏តូចទាប ដែលជាការលាងជើងមនុស្ស១២នាក់ នោះពួកគេក៏គួរតែបម្រើអ្នកដទៃដោយអំណរផងដែរ។

ប្រភេទនៃការបម្រើនីមួយៗ ដែលយើងជួបប្រទះអាចមានលក្ខណៈខុសពីគ្នា ប៉ុន្តែអ្វីដែលដូចគ្នានោះគឺ ការបម្រើនីមួយៗសុទ្ធតែមានអំណរដ៏អស្ចារ្យ។ គោលបំណងនៃការបម្រើ គឺមិនមែនដើម្បីនាំមកនូវការសរសើរដល់អ្នកដែលកំពុងបម្រើនោះទេ តែយើងត្រូវបម្រើដោយសេចក្តីស្រឡាញ់ ដើម្បីនាំការសរសើរដល់ព្រះនៃយើង ដែលបានបន្ទាបព្រះកាយ និងលះបង់ព្រះជន្ម។—Cindy Hess Kasper

តើអ្នកធ្លាប់មានគេផ្តល់ជំនួយដល់អ្នកសម្រាប់កិច្ចការដ៏ពិបាក ដោយមិននឹកស្មានដល់នៅពេលណា? ហេតុអ្វីការបន្ទាបខ្លួន ជាផ្នែកដ៏សំខាន់នៃការបម្រើអ្នកដទៃ?

ឱព្រះអង្គសង្គ្រោះដែលមានសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានបង្រៀនទូលបង្គំឲ្យចេះអ្នកបម្រើអ្នកដទៃ។

Daily Manna 2026_Content Enhance.indd 24 17/11/25 1:44 in the afternoon

ចូរប្រយ័ត្នទឹងពួកគ្រូក្លែងក្លាយ ដែលគេមកឯអ្នករាល់គ្នា ដោយពាក់រោមចៀមបំប្លែងខ្លួន តែខាងក្នុងរបស់គេ ជាឆ្កែចចកដែលឆ្មក់ស៊ីវិញ (ម៉ាថាយ ៧:១៥)។

សេចក្តីស្រឡាញ់របស់ព្រះដែលការពារយើង

នៅពេលយប់មួយក្នុងរដូវក្តៅ សត្វបក្សីជាច្រើននៅក្បែរផ្ទះរបស់ខ្ញុំស្រាប់តែនាំគ្នាបញ្ចេញសម្លេងស្រែកយំទ្រហឹងអឺងកង។ សម្រែករបស់ពួកវាបានលាន់ឮកាន់តែខ្លាំងឡើង ខណៈពេលដែលសត្វចាបដែលយំពីរោះបានបញ្ចេញសម្លេងស្រែកហៅចេញពីដើមឈើមក។ ទីបំផុតយើងក៏បានដឹងអំពីមូលហេតុ។ នៅពេលថ្ងៃមានសត្វស្វាំងធំមួយក្បាលបានហើរឆ្ងាបពីចុងឈើមកធ្វើឲ្យសត្វបក្សីសម្រុកហើរចេញពីដើមឈើប្រសេចប្រសាចដោយបញ្ចេញសម្លេងស្រែកយ៉ាងជ្រួលច្របល់ ដើម្បីប្រកាសអាសន្នដល់បក្សីដទៃទៀត ខណៈពេលដែលពួកគេគេចពីគ្រោះថ្នាក់។

ក្នុងការរស់នៅរបស់យើង យើងអាចឮការដាស់តឿនខាងវិញ្ញាណ ដែលមានចែងក្នុងព្រះគម្ពីរ ដូចជាការដាស់តឿន ឲ្យប្រុងប្រយ័ត្នចំពោះពួកគ្រូខុសឆ្គងជាងដើម។ យើងប្រហែលសង្ស័យ ចំពោះការដាស់តឿនទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ដោយសារសេចក្តីស្រឡាញ់ដែលព្រះអង្គមានចំពោះយើង ព្រះអង្គបានប្រទានព្រះបន្ទូលក្នុងព្រះគម្ពីរ ដើម្បីឲ្យយើងដឹងច្បាស់ អំពីគ្រោះថ្នាក់ខាងវិញ្ញាណ។

ព្រះយេស៊ូវបង្រៀនថា «ចូរប្រយ័ត្នទឹងពួកគ្រូក្លែងក្លាយ ដែលគេមកឯអ្នករាល់គ្នា ដោយពាក់រោមចៀមបំប្លែងខ្លួន តែខាងក្នុងរបស់គេ ជាឆ្កែចចកដែលឆ្មក់ស៊ីវិញ» (ម៉ាថាយ ៧:១៥)។ ព្រះអង្គបានបង្រៀនទៀតថា «អ្នករាល់គ្នានឹងស្គាល់គេបាន ដោយសារផលគេបង្កើត... អស់ទាំងដើមឈើល្អ តែងមានផ្លែល្អ ឯដើមឈើអាក្រក់ក៏តែងមានផ្លែអាក្រក់ដែរ» ហើយព្រះអង្គក៏បានដាស់តឿនថា «អ្នករាល់គ្នានឹងស្គាល់គេបាន គឺដោយសារផលគេបង្កើត» (ខ.១៦-១៧, ២០)។

កណ្ឌគម្ពីរ សុភាសិត ២២:៣ បានរំឭកយើងថា «មនុស្សដែលមានគំនិតឆ្លៀវឆ្លាត គេឃើញសេចក្តីអាក្រក់មក ក៏ពួនខ្លួនទៅ»។ នៅក្នុងការដាស់តឿនទាំងអស់នេះ គឺសុទ្ធតែបង្កប់ទៅដោយសេចក្តីស្រឡាញ់របស់ព្រះដែលការពារយើង និងបានបង្ហាញក្នុងព្រះបន្ទូលព្រះអង្គ។

ដូចដែលបក្សីបានដាស់តឿនគ្នាវា អំពីគ្រោះថ្នាក់ជាយ៉ាងណា នោះចូរយើងស្តាប់បង្គាប់តាមការដាស់តឿនក្នុងព្រះគម្ពីរ ឲ្យគេចចេញពីគ្រោះថ្នាក់ខាងវិញ្ញាណ និងចូលទៅក្នុងព្រះហស្តនៃការជ្រកកោនរបស់ព្រះអង្គផងដែរ។—Patricia Raybon

តើអ្នកបានឮការដាស់តឿនខាងវិញ្ញាណអ្វីខ្លះនៅក្នុងចិត្តអ្នក? តើអ្នកមានខគម្ពីរយោងណាខ្លះសម្រាប់ការដាស់តឿននោះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានដាស់តឿនទូលបង្គំ ដោយសេចក្តីស្រឡាញ់តាមរយៈព្រះគម្ពីរ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យស្តាប់បង្គាប់តាមព្រះបន្ទូលព្រះអង្គនៅថ្ងៃនេះ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លោកុប្បត្តិ ៤៦-៤៨ និងម៉ាថាយ ១៣:១-៣០

សូមទ្រង់បែរមកមានសេចក្តីមេត្តាដល់ទូលបង្គំផង ដ្បិតទូលបង្គំនៅតែឯង ហើយមានសេចក្តីវេទនា (ទំនុកតម្កើង ២៥:១៦)។

ស្រែករកព្រះ ដោយទំនុកចិត្ត

ក្នុងសៀវភៅដែលលោកបណ្ឌិត រ៉ាស់សែល មួរ (Russell Moore) បាននិពន្ធមានចំណងជើងថា ទទួលចិញ្ចឹមអស់មួយជីវិត គាត់បានពិពណ៌នាអំពីការធ្វើដំណើររបស់គ្រួសារគាត់ទៅកាន់មណ្ឌលកុមារកំព្រាមួយកន្លែង ដើម្បីទទួលចិញ្ចឹមក្មេងម្នាក់។ ពេលពួកគេដើរចូលខាងក្នុងពួកគេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលបានជួបភាពស្ងប់ស្ងាត់ដ៏ចម្លែកនៅក្នុងអាគារ។

ទារកទាំងអស់នៅលើគ្រែ មិនដែលបញ្ចេញសម្លេងយំទាល់តែសោះ ហើយពួកគេក៏បានដឹងថា តាមពិតទារកទាំងនោះមិនយំ មិនមែនដោយសារពួកគេមានភាពស្ងប់ស្ងល់នោះទេ តែដោយសារពួកគេដឹងថា គ្មាននរណាម្នាក់យកចិត្តទុក រៀងរាល់ពេលដែលពួកគេស្រែកយំ។

ខ្ញុំមានការឈឺជាប់នៅក្នុងចិត្តយ៉ាងខ្លាំង ពេលដែលបានអានរឿងនេះ។ ខ្ញុំនៅចាំពេលដែលកូនខ្ញុំនៅតូច។ មានពេលជាច្រើនរាប់មិនអស់ ដែលខ្ញុំ និងភរិយាខ្ញុំមិនបានគេងពេញភ្នែក ដោយសារសម្លេងយំរបស់កូនយើង ដោយសារពួកគេមិនស្រួលខ្លួន ឬមានការភ័យខ្លាច។ យើងប្រញាប់ក្រោកទៅមើលពួកគេ ដើម្បីកម្សាន្តចិត្ត និងមើលថែពួកគេឲ្យអស់ពីចិត្ត។ សេចក្តីស្រឡាញ់ដែលយើងមានចំពោះកូនយើង គឺជាមូលហេតុដែលពួកគេស្រែកយំឲ្យយើងជួយ។

ក្នុងកណ្ឌគម្ពីរទំនុកតម្កើង មានទំនុកជាច្រើនលើសលប់ ដែលជាទំនុកនៃការទួញយំ និងបទទំនួញ ទៅកាន់ព្រះអម្ចាស់។ ពួកអ៊ីស្រាអែលបានថ្វាយពាក្យទំនួញដល់ព្រះអង្គផ្ទែកទៅលើទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះអង្គ។ ពួកគេជាវាស្ត្រ ដែលព្រះអង្គបានហៅថា «កូនច្បង» របស់ព្រះអង្គ (និក្ខមនំ ៤:២២) ហេតុនេះហើយពួកគេងាកទៅរកព្រះដែលជាព្រះវរបិតាពេលមានទុក្ខលំបាក។ គឺដូចដែលពួកគេបានបង្ហាញការទុកចិត្តនេះក្នុងបទគម្ពីរទំនុកតម្កើង ជំពូក២៥ យ៉ាងដូចនេះថា «សូមទ្រង់បែរមកមានសេចក្តីមេត្តាដល់ទូលបង្គំផង ដ្បិតទូលបង្គំនៅតែឯង... ឱសូមនាំទូលបង្គំចេញពីទុក្ខលំបាកនៃទូលបង្គំ» (ខ.១៦-១៧)។ ក្មេងៗយំ ដោយសារពួកគេមានទំនុកចិត្តមកលើសេចក្តីស្រឡាញ់របស់អ្នកថែរក្សាពួកគេ។ ក្នុងនាមយើងជាអ្នកជឿព្រះយេស៊ូវ និងជាកូនរបស់ព្រះ ព្រះអង្គបានប្រទានយើងនូវហេតុផល ដែលត្រូវស្រែករកព្រះអង្គ។ ព្រះអង្គស្តាប់ឮ ហើយយកព្រះទ័យទុកដាក់ ព្រោះព្រះអង្គមានសេចក្តីស្រឡាញ់ដ៏លើសលប់។—John Blasé

តើមានអ្នកទំនុកចិត្តក្នុងការស្រែករកព្រះអង្គយ៉ាងដូចម្តេចខ្លះ? តើហេតុអ្វី? តើអ្នកអាចពោលទំនួញរបស់អ្នកដល់ព្រះនៅថ្ងៃនេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គខ្លាំងណាស់សម្រាប់សេចក្តីស្មោះត្រង់ដែលព្រះអង្គមាន ចំពោះការស្រែកយំរបស់ទូលបង្គំព្រមទាំងឆ្លើយតប។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | លោកុប្បត្តិ ៤៩-៥០ និងម៉ាថាយ ១៣:៣១-៥៨

ឯយើងវាល់គ្នា យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន (១យ៉ូហាន ៤:១៩)។

មួយជំហានម្តង មួយជំហានម្តង

អ្នកគ្រូ ថេរីសា (Teresa) ជាអ្នកក្រុងអាវីឡា ជាអ្នកនិពន្ធដ៏ល្បីល្បាញក្នុងពួកជំនុំ នៅសតវត្សរ៍ទី១៦។ ក្នុងសំណេររបស់គាត់ គាត់បានលើកឡើងថា គ្រីស្ទបរិស័ទជាច្រើនបានស្វែងរកវិធីផ្គាប់ចិត្តខ្លួនឯងក្នុងការបម្រើព្រះក្នុងគ្រប់ការទាំងអស់។ គាត់បានបង្ហាញការសោកស្តាយ ចំពោះគ្រីស្ទបរិស័ទដែលបានព្យាយាមធ្វើកិច្ចការថ្វាយព្រះតាមរបៀបងាយស្រួលគ្រប់គ្រងជាង និងគួរឲ្យគាប់ចិត្តខ្លួនឯងជាង ជាជាងចុះចូលនឹងការដឹកនាំរបស់ព្រះទាំងស្រុង។ យើងច្រើនតែមានទំនោរទៅរកការលូតលាស់យឺតៗ មិនប្រាកដប្រជា និងថែមទាំងស្ទាក់ស្ទើរក្នុងការទុកចិត្តព្រះអង្គអស់ពីចិត្ត។ ហេតុនេះហើយ អ្នកគ្រូ ថេរីសា បានសារភាពថា សូម្បីតែពេលណាយើងវាស់ស្ទង់ជីវិតយើង តាមខ្នាតគំរូព្រះអង្គបន្តិចម្តងៗ យើងត្រូវតែស្តាប់ចិត្តក្នុងការទទួលអំណោយព្រះអង្គម្តងមួយដំណក់ម្តងមួយដំណក់ ទាល់តែយើងខ្ញុំបានថ្វាយជីវិតយើងខ្ញុំទាំងស្រុងដល់ព្រះអង្គ។

ក្នុងនាមយើងជាមនុស្ស ទំនុកចិត្តមិនកើតមានដោយឯកឯងឡើយ។ ហេតុនេះហើយ ការដកពិសោធន៍ជាមួយព្រះគុណ និងសេចក្តីស្រឡាញ់របស់ព្រះត្រូវការពេលវេលា។

ប៉ុន្តែ ពេលយើងអានបទគម្ពីរ ១យ៉ូហានជំពូក៤ យើងឃើញថា ព្រះទ្រង់ស្រឡាញ់យើងមុនយើងស្រឡាញ់ព្រះអង្គ (ខ.១៩) គឺស្រឡាញ់យើងយ៉ាងខ្លាំងបានជាព្រះអង្គស្ម័គ្រព្រះទ័យលះបង់ព្រះជន្មព្រះរាជបុត្រាព្រះអង្គ។ គឺដូចដែលសាវ័ក យ៉ូហាន បានសរសេរ ដោយការស្ងប់ស្ងែង និងការអរព្រះគុណថា «នេះហើយជាសេចក្តីស្រឡាញ់ មិនមែនជាយើងបានស្រឡាញ់ព្រះនោះទេ គឺទ្រង់បានស្រឡាញ់យើងវិញទេតើ» (ខ.១០)។

ព្រះទ្រង់បានប្រោសចិត្តយើងឲ្យជា បន្តិចម្តងៗយ៉ាងសុភាព ដើម្បីឲ្យយើងទទួលសេចក្តីស្រឡាញ់ ហើយព្រះគុណព្រះអង្គជួយយើង ឲ្យថ្វាយការភ័យខ្លាចរបស់យើងដល់ព្រះអង្គ ម្តងមួយដំហាន (ខ.១៨)។ ព្រះគុណព្រះអង្គពាល់ចិត្តយើងម្តងមួយដំហានៗ ទាល់តែយើងបានដកពិសោធន៍នឹងការចាក់បង្ហូរព្រះគុណ និងសេចក្តីស្រឡាញ់របស់ព្រះអង្គជាបរិបូរ។—Monica La Rose

តើអ្នកបានដកពិសោធន៍នឹងព្រះគុណព្រះ «មួយជំហានម្តងៗ» ក្នុងជីវិតអ្នកដូចម្តេចខ្លះ? តើសេចក្តីស្រឡាញ់របស់ព្រះបានជួយអ្នកជម្នះការភ័យខ្លាចដូចម្តេចខ្លះ ដើម្បីឲ្យអ្នកមានក្តីសង្ឃឹម និងទំនុកចិត្ត?

ឱព្រះដ៏ស្មោះត្រង់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានស្រឡាញ់ទូលបង្គំ មុនទូលបង្គំស្រឡាញ់ព្រះអង្គ សូម្បីតែនៅពេលដែលចិត្តទូលបង្គំមានរបួសខ្លាំងពេក និងឈឺចាប់ពេកធ្វើឲ្យពិបាកទុកចិត្តព្រះអង្គ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានឈោងមករកទូលបង្គំតាមមធ្យោបាយជាច្រើន។

Daily Manna 2026_Content Enhance.indd 27 17/11/25 1:44 in the afternoon

ត្រូវឲ្យរីករាយ ដោយព្រោះឈ្មោះអ្នករាល់គ្នាបានកត់ទុកនៅស្ថានសួគ៌វិញ (លូកា ១០:២០)។

ការផ្តោតចិត្តឲ្យបានត្រឹមត្រូវ

យើងបានស្គាល់លោក ខា (Kha) ជាងមួយឆ្នាំហើយ។ គាត់ជាផ្នែកមួយនៃក្រុមតូចរបស់ព្រះវិហារ ដែលមានការជួបជុំរៀងរាល់សប្តាហ៍ ដើម្បីពិភាក្សាអំពីការអ្វីដែលយើងបានរៀនអំពីព្រះ។ នៅពេលល្ងាចមួយ ក្នុងអំឡុងពេលយើងជួបប្រជុំគ្នាដូចសព្វមួយដង គាត់បានចែកចាយអំពីពេលដែលគាត់បានទទួលរង្វាន់នៅក្នុងការប្រកួតកីឡាអូឡាំពិក។ គាត់កម្រនិយាយអំពីរឿងដូចនេះណាស់ បានជាខ្ញុំស្ទើរតែមិនបានកត់សម្គាល់។ ខ្ញុំមិននឹកស្មានសោះថា ខ្ញុំបានស្គាល់កីឡាការអូឡាំពិកម្នាក់ ដែលបានបញ្ចប់ការប្រកួតយកមេដាយសរីទ្ធ។ ខ្ញុំមិនយល់ថា ហេតុអ្វីគាត់មិនបាននិយាយអំពីរឿងនេះពីមុនមកទេ តែគាត់ដឹងថា ជោគជ័យក្នុងកីឡា ជាផ្នែកពិសេសមួយនៃរឿងជីវិតរបស់គាត់ តែគ្រួសារ សហគមន៍ និងសេចក្តីជំនឿរបស់គាត់ ជាផ្នែកដែលសំខាន់ជាង និងជាចំណុចស្នូលនៃអត្តសញ្ញាណរបស់គាត់។

រឿងដែលបានចែងក្នុងកណ្ឌគម្ពីរ លូកា ១០:១-២៣ បានពិពណ៌នាអំពីសេចក្តីអ្វីដែលគួរតែបានធ្វើជាចំណុចស្នូលនៃអត្តសញ្ញាណរបស់យើង។ ព្រះយេស៊ូវបានចាត់សិស្ស៧២នាក់ ឲ្យចេញទៅប្រកាសប្រាប់អ្នកដទៃអំពីនគរព្រះ។ ពេលដែលពួកគេវិលត្រឡប់មកវិញ ពួកគេក៏បានរាយការណ៍ដល់ព្រះអង្គថា ទោះទាំងពួកអារក្សក៏ចុះចូលចំពោះពួកគេ ដោយព្រះនាមទ្រង់ដែរ (ខ.១៧)។ ព្រះយេស៊ូវបានទទួលស្គាល់ថា ព្រះអង្គបានប្រទានពួកគេនូវព្រះចេស្តា និងការការពារជាបរិបូរ តែព្រះអង្គមានបន្ទូលថា ពួកគេបានផ្តោតចិត្តទៅលើរឿងដែលមិនគួរផ្តោត។ ព្រះអង្គក៏បានបញ្ជាក់ថា ពួកគេគួរតែមានចិត្តអរសប្បាយ ដោយសារឈ្មោះពួកគេបានកត់ទុកក្នុងនគរស្ថានសួគ៌វិញ (ខ.២០)។

ទោះព្រះទ្រង់បានប្រទានជោគជ័យ ឬសមត្ថភាពច្រើនប៉ុណ្ណាក៏ដោយ ក៏យើងមានហេតុផលដែលត្រូវអរសប្បាយ ដោយសារឈ្មោះយើងបានកត់ទុកក្នុងនគរស្ថានសួគ៌ ហើយយើងបានអរសប្បាយនឹងព្រះវត្តមានព្រះអង្គក្នុងជីវិតយើងជារៀងរាល់ថ្ងៃ បើសិនជាយើងបានថ្វាយជីវិតយើងដល់ព្រះអង្គហើយ។—Kirsten Holmberg

តើអ្នកកំពុងផ្តោតចិត្តទៅលើអ្វី? តើអ្នកអាចផ្លាស់ប្តូរការផ្តោតចិត្តរបស់អ្នក ទៅរកការអ្វីដែលមានភាពអស់កល្បយ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានកត់ឈ្មោះទូលបង្គំក្នុងនគរស្ថានសួគ៌។ ទូលបង្គំមានចិត្តអរសប្បាយ ដែលបានស្គាល់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 28 17/11/25 1:44 in the afternoon

នោះគេនឹងដំដាវរបស់គេធ្វើជាផាល ហើយលំពែងគេធ្វើជាដង្កាវិញ (មីកា ៤:៣)។

កែប្រែវត្ថុគ្មានតម្លៃ ឲ្យមានភាពស្រស់ស្អាត

ភរិយាខ្ញុំឈ្មោះ មីសកា (Miska) បានទិញខ្សែករ និងក្រវិលកងពីប្រទេសអេត្យូពី។ ភាពប្រណិតដ៏សាមញ្ញ របស់គ្រឿងអលង្ការទាំងនេះ បានឆ្លុះបញ្ចាំងអំពីស្នាដៃសិល្បៈពិតៗ។ ទោះជាយ៉ាងណាក៏ដោយ ប្រវត្តិ របស់គ្រឿងអលង្ការនេះ គឺជាចំណុចដែលគួរឲ្យភ្ញាក់ផ្អើលបំផុត។ ដោយសារមានការប៉ះទង្គិចដ៏សាហាវ និង សង្គ្រាមស៊ីវិល ដែលបានកើតឡើងអស់ជាច្រើនទសវត្សរ៍ ទឹកដីរបស់ប្រទេសអេត្យូពីមានសម្បកបន្ទុះរបស់ គ្រាប់កាំភ្លើង និងគ្រាប់ផ្លោងនៅរាត់រាយស្ទើរគ្រប់ទីកន្លែង។ ជនជាតិអេត្យូពីក៏បានស្តាទឹកដីរបស់ខ្លួនឡើងវិញ ដោយសម្អាតកម្ទេចអំបែង ដោយមានសង្ឃឹមក្នុងចិត្ត។ ហើយសិល្បៈករក៏បានកែច្នៃសម្បកបន្ទុះគ្រាប់កាំភ្លើង ធ្វើជាគ្រឿងអលង្ការលក់។

ពេលដែលខ្ញុំបានឮអំពីរឿងនេះ ខ្ញុំក៏បាននឹកចាំព្រះបន្ទូលសន្យា ដែលហោរា មីកា បានប្រកាស ដោយចិត្ត ក្លាហាន ទៅកាន់រាស្ត្ររបស់ព្រះយ៉ាងដូចនេះថា គេ «នឹងដំដាវរបស់គេធ្វើជាផាល ហើយលំពែងគេធ្វើជាដង្កាវិញ» (៤:៣)។ ដាវ និងលំពែងត្រូវបានគេផលិតមកសម្រាប់សម្លាប់ជីវិតមនុស្ស តែព្រះទ្រង់បានប្រទាននូវដំណោះ ស្រាយប្រកបដោយព្រះចេស្តា ដោយកែប្រែពួកវាឲ្យក្លាយជាឧបករណ៍ដែលជួយទ្រទ្រង់ជីវិតវិញ។ លោកហោរា ក៏បានមានប្រសាសន៍ទៀតថា នៅថ្ងៃដែលព្រះទ្រង់យាងមកវិញ «អស់ទាំងគរនឹងលែងលើកដាវច្បាំងគ្នាទៀត ក៏មិនរៀនវិជ្ជាចំបាំងទៀតតទៅ» (ខ.៣)។

ការប្រកាសរបស់លោក មីកា នៅសម័យមុន មិនពិបាកឲ្យមនុស្សសម័យបច្ចុប្បន្នយល់ឡើយ។ ពិភពលោក នៅតែមានសង្គ្រាម និងអំពើហិង្សាមិនខុសពីទឹកដីអ៊ីស្រាអែលពីសម័យដើមទេ ហើយពិភពលោក ហាក់ដូចជា មិនអាចផ្លាស់ប្តូរឲ្យល្អឡើងវិញ។ ប៉ុន្តែ ព្រះទ្រង់បានសន្យាថា ថ្ងៃដ៏គួរឲ្យភ្ញាក់ផ្អើលនឹងមកដល់។ ដូចនេះ យើង ត្រូវចាប់ផ្តើមរស់នៅស្របតាមសេចក្តីពិតនេះ។ ព្រះទ្រង់កំពុងជួយយើង ឲ្យធ្វើការថ្វាយព្រះអង្គក្នុងពេលសព្វថ្ងៃ ដោយកែប្រែជីវិតមនុស្សជាច្រើន ឲ្យក្លាយជាស្នាព្រះហស្តដ៏ល្អឯក។—Winn Collier

តើអ្នកបានឃើញការអាក្រក់បានផ្លាស់ប្តូរ ដោយសេចក្តីស្រឡាញ់របស់ព្រះនៅទីណា? តើព្រះទ្រង់បាន កែប្រែជីវិតអ្នកឲ្យមានតម្លៃ និងភាពស្រស់ស្អាត ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គកែប្រែជីវិតយើងខ្ញុំ។ សូមព្រះអង្គធ្វើការតាមរយៈទូលបង្គំ ដើម្បីនាំមកនូវភាព ស្រស់ស្អាតទៅទីនេះ។

Daily Manna 2026_Content Enhance.indd 29 17/11/25 1:44 in the afternoon

ចូរឲ្យគ្រប់គ្នាបានឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ (យ៉ាកុប ១:១៩)។

ឆាប់នឹងស្តាប់ ក្រនឹងនិយាយ

មានពេលមួយខ្ញុំមានអារម្មណ៍ថា បេះដូងខ្ញុំលោតកាន់តែញាប់ ខណៈពេលដែលខ្ញុំបើកមាត់ ដើម្បីបដិសេធន៍ការចោទប្រកាន់ ដែលមិត្តជិតស្និទ្ធម្នាក់មានមកលើខ្ញុំ។ សារដែលខ្ញុំបានបង្ហោះសារតាមអនឡាញ មិនមានអ្វីជាប់ទាក់ទងនឹងគាត់ទេ។ ប៉ុន្តែ មុនពេលខ្ញុំឆ្លើយតប ខ្ញុំក៏បានអធិស្ឋានខ្សឹបៗ។ បន្ទាប់មក ខ្ញុំក៏បានសម្រួលអារម្មណ៍ ហើយក៏បានឮគាត់និយាយពាក្យពេចន៍ដែលបង្កប់ដោយការឈឺចាប់។ ខ្ញុំក៏បានដឹងច្បាស់ថា ការឈឺចាប់នោះមានភាពស៊ីជម្រៅ។ មិត្តភក្តិខ្ញុំកំពុងឈឺចាប់ ហើយខ្ញុំក៏លែងចង់ការពារខ្លួនឯងទៀត ខណៈពេលដែលខ្ញុំបានសម្រេចចិត្តលើកយករឿងនោះមកនិយាយជាមួយគាត់។

ក្នុងអំឡុងពេលសន្ទនាគ្នានោះ ខ្ញុំក៏យល់អំពីអត្ថន័យនៃបទគម្ពីរយ៉ាកុប ដែលបានជំរុញយើងឲ្យ «ឆាប់នឹងស្តាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹង» (១:១៩)។ ការស្តាប់អាចជួយឲ្យយើងឮអ្វីដែលបង្កប់នៅពីក្រោយពាក្យសម្តី ហើយជៀសវាងកំហឹង «ដែលមិនបានសំរេចតាមសេចក្តីសុចរិតរបស់ព្រះ» (ខ.២០)។ វាជួយឲ្យយើងយល់ចិត្តអ្នកនិយាយ។ ខ្ញុំយល់ឃើញថា ការឈប់បង្អង់ និងអធិស្ឋានមានប្រយោជន៍យ៉ាងខ្លាំង ចំពោះខ្ញុំក្នុងការសន្ទនាជាមួយមិត្តភក្តិខ្ញុំ។ ខ្ញុំកាន់តែឆាប់ឆ្លើយតប ចំពោះពាក្យសម្តីរបស់គាត់ ជាជាងអាក់អន់ចិត្តនឹងគាត់។ បើសិនជាខ្ញុំមិនបានឈប់បង្អង់សិន ដើម្បីអធិស្ឋាន ខ្ញុំប្រហែលជាវាយបកទៅគាត់វិញ ដោយបង្ហាញគំនិតខ្ញុំ ហើយចែកចាយថា ខ្ញុំមានការអាក់អន់ចិត្តប៉ុណ្ណា។

ខ្ញុំមិនតែងតែអនុវត្តតាមការបង្រៀនក្នុងកណ្ឌគម្ពីរយ៉ាកុបបានត្រឹមត្រូវទេ តែខ្ញុំអរព្រះគុណព្រះអង្គ ដែលខ្ញុំបានស្តាប់បង្គាប់តាមនៅថ្ងៃនោះ ។ ការឈប់បង្អង់ ដើម្បីអធិស្ឋានក្នុងចិត្ត ដើម្បីកុំឲ្យកំហឹង និងការអាក់អន់ចិត្តគ្រប់គ្រងពាក្យសម្តីរបស់ខ្ញុំ គឺជាគន្លឹះដើម្បីឲ្យខ្ញុំឆាប់នឹងស្តាប់ ហើយយឺតនឹងនិយាយ។ ខ្ញុំអធិស្ឋានសូមព្រះអង្គប្រទានខ្ញុំនូវប្រាជ្ញា ដើម្បីឲ្យបានអនុវត្តដូចនេះទៀត ឲ្យបានញឹកញាប់ (សុភាសិត ១៩:១១)។—Katara Patton

តើការបង្រៀនក្នុងបទគម្ពីរយ៉ាកុបខាងលើបានជួយអ្នកកាលពីមុន ដូចម្តេចខ្លះ? តើអ្នកអាចអនុវត្តតាមខគម្ពីរនេះ ក្នុងពេលបច្ចុប្បន្ន ដូចម្តេចខ្លះ?

ឱព្រះពេញដោយព្រះគុណ សូមព្រះអង្គរំឭកទូលបង្គំ ឲ្យរហ័សស្តាប់ តែកុំឲ្យឆាប់អាក់អន់ចិត្ត។

Daily Manna 2026_Content Enhance.indd 30 17/11/25 1:44 in the afternoon

ប្រហែលជាព្រះនាងបានតាំងឡើងក្នុងពេលវេលានេះឯងទេដឹង? (នាងអេសធើរ ៤:១៤)។

កន្លែងថ្មីដែលមានការពិបាក

បន្ទាប់ពីខ្ញុំបានពិនិត្យសុខភាពរកឃើញថា ខ្ញុំមានជំងឺមហារីកធ្ងន់ធ្ងរ ក្នុងនាមខ្ញុំជាប្តី និងឪពុកដែលមានកូនតូច មានសំណួរជាច្រើនវិលវល់ក្នុងគំនិតខ្ញុំ។ ឱព្រះអង្គអើយ ហេតុអ្វីរឿងនេះកើតឡើងចំពោះទូលបង្គំ? តើនេះជាផែនការដែលព្រះអង្គមានសម្រាប់ទូលបង្គំមែនឬ? អ្វីដែលគួរឲ្យភ្ញាក់ផ្អើលនោះគឺ ក្រុមគ្រួសារខ្ញុំទើបតែបានបម្រើព្រះអង្គក្នុងក្រុមបេសកកម្មមួយ ដែលបាននាំក្មេងៗជាច្រើនឲ្យទទួលព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ។ ព្រះអង្គបានប្រទានពរឲ្យការងារយើងមានផលផ្លែជាច្រើន។ យើងមានអំណរណាស់។ តែហេតុអ្វីយើងជួបរឿងដ៏សោកសៅនេះ?

នាង អេសធើរ ទំនងជាមានសំណួរជាច្រើនក្នុងការអធិស្ឋានទៅរកព្រះអម្ចាស់ បន្ទាប់ពីនាងត្រូវគេបង្ខំឲ្យចាកចេញទៅស្រុកកំណើតជាទីស្រឡាញ់ ចូលទៅរស់នៅក្នុងទឹកដីថ្មី (នាងអេសធើរ ២:៨)។ លោក ម៉ាដេកាយ ជាបងបួនដងដូនមួយរបស់នាងបានចិញ្ចឹមនាងដូចជាកូនបង្កើត បន្ទាប់ពីនាងក្លាយជាក្មេងកំព្រា (ខ.៧)។ ប៉ុន្តែ ក្រោយមកគេក៏បានយកនាងទៅធ្វើជាស្រីស្នំរបស់ស្តេច ហើយក៏នាងក៏បានក្លាយជាមហេសី (ខ.១៧)។ លោក ម៉ាដេកាយ មានការខ្វល់ខ្វាយអំពីរឿង ដែលកំពុងកើតឡើង ចំពោះនាងអេសធើរ (ខ.១១)។ ប៉ុន្តែ មួយរយៈក្រោយមក អ្នកទាំងពីរក៏បានដឹងថា ព្រះអម្ចាស់បានត្រាស់ហៅនាង ឲ្យមានតួនាទីដ៏មានឥទ្ធិពលសម្រាប់ពេលដែលពិបាកយ៉ាងនោះ (៤:១៤) គឺតួនាទីដែលនាងអាចប្រើ ដើម្បីជួយសង្គ្រោះប្រជាជនរបស់នាង ឲ្យរួចផុតពីសេចក្តីហិនវិនាស (ជំពូក ៧-៨)។

នេះជាភស្តុតាងបញ្ជាក់ថា ព្រះអម្ចាស់បានដាក់នាង អេសធើរ នៅក្នុងកន្លែងថ្មីដ៏ពិបាកស្របតាមផែនការដ៏ឥតខ្ចោះរបស់ព្រះអង្គ។ ព្រះអង្គក៏បានធ្វើដូចនេះ សម្រាប់ខ្ញុំផងដែរ។ ខណៈពេលដែលខ្ញុំកំពុងតយុទ្ធនឹងជំងឺមហារីក អស់ពេលជាច្រើនឆ្នាំ ខ្ញុំមានឯកសិទ្ធិក្នុងការចែកចាយសេចក្តីជំនឿរបស់ខ្ញុំដល់មនុស្សជាច្រើន ដែលជាអ្នកជំងឺ ក៏ដូចជាអ្នកថែទាំអ្នកជំងឺនៅមន្ទីរពេទ្យ។ តើព្រះអង្គបានដឹកនាំអ្នកចូលទៅកន្លែងកន្លែងណា ដែលថ្មីសម្រាប់អ្នក? ចូរទុកចិត្តព្រះអង្គ។ ដ្បិតព្រះអង្គល្អ ហើយផែនការរបស់ព្រះអង្គក៏ឥតខ្ចោះ (រ៉ូម ១១:៣៣-៣៦)។

—Tom Felten

តើព្រះអម្ចាស់បាននាំអ្នកចូលកន្លែងថ្មី នៅពេលណា? ហេតុអ្វីអ្នកអាចទុកចិត្តផែនការដ៏ឥតខ្ចោះរបស់ព្រះអង្គ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យទុកចិត្តព្រះអង្គ សូម្បីតែពេលដែលទូលបង្គំមិនដឹងថា ព្រះអង្គកំពុងធ្វើអ្វីក៏ដោយ។

Daily Manna 2026_Content Enhance.indd 31 17/11/25 1:44 in the afternoon

មនុស្សលោកតែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ (១សាំយ៊ូអែល ១៦:៧)។

មិនវិនិច្ឆ័យតែសម្បកក្រៅ

ជាច្រើនឆ្នាំមុន អ្នកស្រី ជូលី លែនស៍មែន (Julie Landsman) បានចូលរួមការប្រកួតផ្ដុំត្រែបារាំង សម្រាប់មហោស្រពអូប៉ែរ៉ាមេត្រូប៉ូលិសនៅទីក្រុងញូវយ៉ក។ ក្នុងកម្មវិធីប្រកួតនេះ បេក្ខជនម្នាក់ៗត្រូវផ្ដុំត្រែបារាំងរបស់ខ្លួន នៅក្រោយកញ្ចក់កុំឲ្យគណៈកម្មការឃើញមុខ ដើម្បីជៀសវាងការលំអៀង ដោយសារពួកគេសុទ្ធតែជាមនុស្សប្រុស។ អ្នកស្រី ជូលី ផ្ដុំត្រែបានល្អជាងគេ ហើយក៏បានឈ្នះការប្រកួតនោះ។ ប៉ុន្តែ ពេលនាងបោះជំហានចេញពីក្រោយកញ្ចក់ គណកម្មការខ្លះបានដើរគេចមុខនាងទៅខាងក្រោយបន្ទប់។ ពួកគេប្រាកដមិនចង់ឲ្យមនុស្សស្រីមានសមត្ថភាពធ្វើបានល្អដូចនេះទេ។

កាលពួកអ៊ីស្រាអែលទូលសូមព្រះអម្ចាស់ ប្រទានស្តេចមួយអង្គឲ្យគ្រប់គ្រងពួកគេ ព្រះអង្គក៏បានឆ្លើយតបដោយប្រទានបុរសម្នាក់ ដែលមានកាយសម្បទាល្អធ្វើជាស្តេចដូចជាតិសាសន៍ដទៃ (១សាំយ៊ូអែល ៨:៥ ៩:២)។ ប៉ុន្តែ ដោយសារស្តេច សូល បានសោយរាជ ដោយព្រះទ័យមិនស្មោះត្រង់ និងមិនស្តាប់បង្គាប់ព្រះ ព្រះអង្គក៏បានចាត់លោក សាំយូអែល ឲ្យទៅភូមិបេថ្លេហិម ដើម្បីចាក់ប្រេងតាំងមនុស្សម្នាក់ទៀតឲ្យឡើងគ្រងរាជ (១៦:១-១៣)។ ពេលលោក សាំយូអែល ឃើញលោក អេលាប ជាកូនច្បង គាត់ក៏បានសន្និដ្ឋានថា ព្រះទ្រង់បានជ្រើសរើសគាត់ឲ្យធ្វើស្តេច ព្រោះគាត់មានកាយសម្បទាគួរឲ្យស្ញប់ស្ញែង។ តែព្រះទ្រង់បានបង្រៀនលោកហោរាឲ្យគិតថា «ឯមនុស្សលោក តែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ» (ខ.៧)។ ព្រះទ្រង់ក៏បានជ្រើសរើស ដាវីឌ ឲ្យដឹកនាំរាស្ត្ររបស់ព្រះអង្គ (ខ.១២)។

ពេលយើងធ្វើការវាយតម្លៃមកលើសមត្ថភាព និងភាពស័ក្តិសមរបស់មនុស្សសម្រាប់បំពេញបំណងព្រះទ័យ ព្រះទ្រង់ទតមើលចារិកលក្ខណៈ ឆន្ទៈ និងបំណងចិត្តរបស់ពួកគេ។ ព្រះអង្គ ក៏បានត្រាស់ហៅយើង ឲ្យមើលទៅលោកីយ៍ និងមនុស្សតាមគំរូព្រះអង្គផងដែរ ដោយផ្តោតទៅលើចិត្តរបស់មនុស្ស គឺមិនមែនផ្តោតទៅលើរូបរាងខាងក្រៅ ឬសញ្ជាប័ត្រនោះឡើយ។—Marvin Williams

ហេតុអ្វីយើងមិនត្រូវវិនិច្ឆ័យអ្នកដទៃ តែសម្បកក្រៅ? តើការមានចិត្តត្រឹមត្រូវថ្វាយព្រះអម្ចាស់ មានន័យយ៉ាងណាចំពោះអ្នក?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំកុំឲ្យវាយតម្លៃមនុស្ស តែសម្បកក្រៅ។

Daily Manna 2026_Content Enhance.indd 32 17/11/25 1:44 in the afternoon

ទឹកបានត្រជាក់ដល់ព្រលឹងមនុស្សល្ងីល្ងើយជាយ៉ាងណា នោះដំណឹងល្អដែលមកពីស្រុកឆ្ងាយ ក៏យ៉ាងនោះដែរ (សុភាសិត ២៥:២៥)។

ពាក្យសម្តីនាំមកនូវចិត្តស្រស់ថ្លា

កាលខ្ញុំកំពុងឈរនៅក្នុងផ្ទះបាយ កូនស្រីខ្ញុំស្រាប់តែលាន់មាត់ថា មានសត្វរុយមួយក្បាលនៅក្នុងទឹកឃ្មុំ។ ខ្ញុំក៏បាននិយាយលេងជាមួយនាង ដោយដកស្រង់ពាក្យស្លោកមួយ ដែលពោលថា៖ យើងអាចប្រទះឃើញសត្វរុយនៅក្នុងទឹកឃ្មុំ ច្រើនជាងនៅក្នុងទឹកខ្មេះ។ កាលនោះ ខ្ញុំបានឃើញសត្វរុយនៅក្នុងទឹកឃ្មុំជាលើកដំបូង តែខ្ញុំបានដកស្រង់ពាក្យស្លោកនេះ ដោយសារវាបានបង្រៀនយើងថា ការស្នើសុំដ៏សុភាពអាចបញ្ចុះបញ្ចូលអ្នកដទៃបានច្រើនជាងការស្នើសុំដោយអាកប្បកិរិយាជូរល្វីង។

កណ្ឌគម្ពីរសុភាសិតបានប្រមូលផ្តុំសុភាសិតប្រកបដោយប្រាជ្ញាជាច្រើន ដែលព្រះវិញ្ញាណបានបណ្តាលឲ្យតែង។ សុភាសិតទាំងនេះដឹកនាំ និងបង្រៀនយើងនូវសេចក្តីពិតដ៏សំខាន់អំពីរបៀបរស់នៅ ដែលថ្វាយព្រះកិត្តិនាមដល់ព្រះ។ សុភាសិតជាច្រើនផ្តោតទៅលើទំនាក់ទំនងជាមួយមនុស្សនិងមនុស្ស ដោយរាប់បញ្ចូលទាំងផលប៉ះពាល់ ដែលពាក្យសម្តីរបស់យើងអាចមានមកលើអ្នកដទៃ។

ក្នុងសុភាសិតរបស់ស្តេច សាឡូម៉ូន ទ្រង់បានដាស់តឿនយើងមិនឲ្យនិយាយពាក្យមិនពិតមកលើអ្នកដទៃ (សុភាសិត ២៥:១៨)។ ទ្រង់បានបង្រៀនថា «អណ្តាតដែលនិយាយដើមគេ» នាំឲ្យមានភាពល្អក់កករនៅក្នុងទំនាក់ទំនង (ខ.២៣)។ ទ្រង់ក៏បានដាស់តឿន អំពីផលប៉ះពាល់នៃការរអ៊ូរទាំផងដែរ (ខ.២៤)។ ហើយទ្រង់ក៏បានលើកទឹកចិត្តអ្នកអានកណ្ឌគម្ពីរសុភាសិតថា ពាក្យសម្តីដែលនាំដំណឹងល្អ គឺជាព្រះពរដល់អ្នកស្តាប់ (ខ.២៥)។

ខណៈពេលដែលយើងព្យាយាមយកសេចក្តីពិតនេះមកអនុវត្តតាម សូមព្រះវិញ្ញាណប្រទានយើងនូវចម្លើយដ៏សមរម្យ (១ជ:១)។ ព្រះអង្គអាចជួយឲ្យពាក្យសម្តីរបស់យើងមានរស់ជាតិផ្អែម ក៏ដូចជានាំមកនូវភាពស្រស់ថ្លាក្នុងចិត្ត។—Lisa M. Samra

តើអ្នកបានឃើញផលប៉ះពាល់នៃពាក្យសម្តី នៅពេលណាខ្លះ? តើព្រះវិញ្ញាណបរិសុទ្ធអាចដឹកនាំអ្នក ឲ្យប្រើពាក្យសម្តីដែលនាំមកនូវភាពស្រស់ថ្លាក្នុងចិត្ត ដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំ ឲ្យបង្ហាញអ្នកដទៃ ឲ្យឃើញសេចក្តីអាណិតរបស់ព្រះអង្គ នៅក្នុងទំនាក់ទំនងរបស់ទូលបង្គំ ដោយប្រើពាក្យសម្ដីដែលប្រកបដោយគុណ និងសប្បុរស។

Daily Manna 2026_Content Enhance.indd 33 17/11/25 1:44 in the afternoon

តែមានព្រះគុណផ្តល់មកយើងវាល់គ្នារៀងវាល់ខ្លួន តាមខ្នាតអំណោយទាននៃព្រះគ្រីស្ទ (អេភេសូរ ៤:៧)។

អំណោយនៃព្រះគុណរបស់ព្រះអម្ចាស់

ខណៈពេលដែលខ្ញុំកំពុងកែក្រដាសប្រឡងសំណេរអត្ថបទរបស់និស្សិត ដែលខ្ញុំបង្រៀននៅមហាវិទ្យាល័យ ខ្ញុំមានការស្ញប់ស្ញែងចំពោះអត្ថបទដែលសិស្សម្នាក់បានសរសេរ។ គាត់សរសេរបានល្អណាស់! មិនយូរប៉ុន្មាន ខ្ញុំក៏បានដឹងថា សំណេរនោះល្អពេក គាត់មិនទំនងជាបានសរសេរដោយសមត្ថភាពខ្លួនឯងទេ។ ខ្ញុំក៏បានធ្វើការស្រាវជ្រាវបន្តិចបន្តួច ក៏បានដឹងថា តាមពិតគាត់បានចម្លងអត្ថបទនោះពីប្រភពនៅតាមអនឡាញ។

ខ្ញុំក៏បានផ្ញើអ៊ីមែលទៅសិស្សម្នាក់នោះ ដើម្បីឲ្យនាងបានដឹងអំពីកំហុសរបស់នាង។ នាងនឹងទទួលបានពិន្ទុសូន្យ សម្រាប់អត្ថបទនោះ តែនាងអាចសរសេរអត្ថបទថ្មីមួយទៀត ដើម្បីឲ្យបានពិន្ទុខ្លះ។ នាងក៏បានឆ្លើយតបថា នាងមានការសោកស្តាយចំពោះកំហុសរបស់នាង ហើយក៏បានអរគុណខ្ញុំ ដែលបានផ្តល់ឱកាសឲ្យនាងទោះនាងមិនសមនឹងទទួលឱកាសនោះក៏ដោយ។ ខ្ញុំក៏បានប្រាប់នាងថា យើងរាល់គ្នាសុទ្ធតែទទួលព្រះគុណពីព្រះយេស៊ូវជារៀងរាល់ថ្ងៃ ដូចនេះ ខ្ញុំមិនអាចបដិសេធន៍មិនព្រមផ្តល់ឱកាសឲ្យនាងឡើយ។

ព្រះគុណព្រះបានជួយឲ្យជីវិតយើងមានភាពល្អប្រសើរឡើងតាមមធ្យោបាយជាច្រើន ហើយប្រោសលោះយើងឲ្យរួចពីបាប។ លោក ពេត្រុស បានមានប្រសាសន៍ថា «យើងជឿថា បានសង្គ្រោះដោយព្រះគុណនៃព្រះអម្ចាស់យេស៊ូវ ដូចជាគេដែរ» (កិច្ចការ ១៥:១១)។ ដូចនេះ ព្រះគុណព្រះបាននាំមកនូវសេចក្តីសង្គ្រោះ។ សាវ័ក ប៉ុល បានបង្រៀនផងដែរថា «ដ្បិតបាបមិនត្រូវមានអំណាចលើអ្នករាល់គ្នាទៀតឡើយ ដោយព្រោះអ្នករាល់គ្នាមិននៅក្រោមក្រឹត្យវិន័យ គឺនៅក្រោមព្រះគុណវិញ» (រ៉ូម ៦:១៤)។ បានសេចក្តីថា ព្រះគុណព្រះអង្គជួយយើងមិនឲ្យរស់នៅក្រោមអំណាចរបស់បាបទៀតទេ។ ជាងនេះទៅទៀត ព្រះគុណក៏បានជួយឲ្យយើងអាចបម្រើព្រះអង្គផងដែរ គឺដូចដែលសាវ័ក ពេត្រុស បានបង្រៀនឲ្យប្រើ «អំណោយទានដែលគ្រប់គ្នាបានទទួលមក ទុកដូចជាអ្នកចែកចាយយ៉ាងល្អនៃព្រះគុណដ៏បែកជាច្រើនផ្សារភ្ជាប់វិញ» (១ពេត្រុស ៤:១០)។

ព្រះទ្រង់បានប្រទានព្រះគុណមក ឲ្យយើងទទួលដោយឥតគិតថ្លៃ (អេភេសូរ ៤:៧)។ ចូរយើងប្រើព្រះគុណដែលជាអំណោយនេះ ដើម្បីស្រឡាញ់ និងលើកទឹកចិត្តអ្នកដទៃ។—Dave Branon

តើអ្នកបានដកពិសោធន៍ជាមួយព្រះគុណព្រះខ្លាំងបំផុត នៅពេលណាក្នុងជីវិតអ្នក? តើអ្នកអាចបង្ហាញព្រះគុណដែលគួរឲ្យភ្ញាក់ផ្អើលដល់អ្នកដទៃនៅថ្ងៃនេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំឲ្យបង្ហាញព្រះគុណព្រះអង្គ តាមរយៈការទំនាក់ទំនងជាមួយអ្នកដទៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | និក្ខមនំ ១៩-២០ និងម៉ាថាយ ១៨:២១-៣៥

«ចូរឯងស្រឡាញ់អ្នកជិតខាង ដូចខ្លួនឯង» (*កាឡាទី ៥:១៤*)។

ចែកចាយ តាមការដឹកនាំរបស់ព្រះវិញ្ញាណ

គ្រូគង្វាលវ័យក្មេងម្នាក់មានទម្លាប់អធិស្ឋានរៀងរាល់ពេលព្រឹក ទូលសូមព្រះទ្រង់ប្រើគាត់ជារៀងរាល់ថ្ងៃ ឲ្យធ្វើជាព្រះពរសម្រាប់អ្នកដទៃ។ ជាញឹកញាប់ គាត់មានអំណរ ដែលព្រះទ្រង់ប្រទានឱកាសឲ្យគាត់រស់នៅជាព្រះពរ។ ថ្ងៃមួយ ក្នុងអំឡុងពេលសម្រាកពីការងារទីពីររបស់គាត់ គាត់ក៏បានអង្គុយនៅខាងក្រៅជាមួយមិត្តរួមការងារម្នាក់ដែលបានសួរគាត់អំពីព្រះយេស៊ូវ។ លោកគ្រូគង្វាលក៏បានឆ្លើយសំណួរទាំងប៉ុន្មានដែលបុរសនោះមាន។ គាត់មិនបានប្រកែកគ្នា ឬនិយាយខ្លាំងៗដាក់គេឡើយ។ លោកគ្រូគង្វាលក៏បានលើកឡើងថា ព្រះវិញ្ញាណបរិសុទ្ធបានដឹកនាំគាត់ ឲ្យមានឱកាសជជែកគ្នាជាមួយអ្នកដទៃ នៅពេលខ្លះប្រកបដោយប្រសិទ្ធភាព និងសេចក្តីស្រឡាញ់។ គាត់ក៏រកបានមិត្តភក្តិថ្មីម្នាក់ទៀតនៅថ្ងៃនោះ ជាមនុស្សដែលមានចិត្តស្រេកឃ្លានចង់ស្វែងយល់បន្ថែមអំពីព្រះ។

ការអនុញ្ញាតឲ្យព្រះវិញ្ញាណដឹកនាំយើង ជាវិធីល្អបំផុតដើម្បីនាំអ្នកដទៃឲ្យស្គាល់ព្រះយេស៊ូវ។ គឺដូចដែលព្រះអង្គមានបន្ទូលប្រាប់ពួកសាវ័កថា «កាលណាព្រះវិញ្ញាណបរិសុទ្ធបានមកសណ្ឋិតលើអ្នករាល់គ្នា នោះអ្នករាល់គ្នានឹងបានព្រះចេស្តា ហើយនឹងធ្វើជាទីបន្ទាល់ពីខ្ញុំនៅក្រុងយេរូសាឡិម ព្រមទាំងស្រុកយូដា និងស្រុកសាម៉ារីទាំងមូល ហើយរហូតដល់ចុងផែនដីបំផុតផង» (កិច្ចការ ១:៨)។

ផលផ្លែនៃព្រះវិញ្ញាណនោះគឺ «សេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត» (កាឡាទី ៥:២២-២៣)។ ក្រោមការដឹកនាំរបស់ព្រះវិញ្ញាណ លោកគ្រូគង្វាលវ័យក្មេងរូបនោះបានអនុវត្តតាមការបង្រៀនរបស់កណ្ឌគម្ពីរពេត្រុសដែលបានបង្គាប់យើងឲ្យ «ប្រុងប្រៀបជានិច្ចដោយសុភាព ហើយកោតខ្លាច ដើម្បីនឹងតបឆ្លើយដល់អ្នកណាដែលសួរពីហេតុនៃសេចក្តីសង្ឃឹមរបស់អ្នករាល់គ្នា» (១ពេត្រុស ៣:១៥)។

ទោះយើងបានរងទុក្ខ ដោយសារយើងជឿព្រះយេស៊ូវក៏ដោយ ក៏ពាក្យសម្តីយើងអាចបង្ហាញលោកីយ៍ឲ្យដឹងថា ព្រះវិញ្ញាណបរិសុទ្ធកំពុងដឹកនាំជីវិតយើង។ ការរស់នៅដែលមានទីបន្ទាល់ល្អ នាំឲ្យអ្នកដទៃមានចិត្តចង់ចូលទៅរកព្រះអង្គផងដែរ។—Patricia Raybon

តើអ្នកមានអាកប្បកិរិយាយ៉ាងណាខ្លះ ក្នុងការនិយាយប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ? ហេតុអ្វីការអនុញ្ញាតឲ្យព្រះវិញ្ញាណដឹកនាំជីវិតយើង ជួយឲ្យការជជែករបស់យើងកាន់តែមានប្រសិទ្ធភាព?

ឱព្រះអម្ចាស់ ពេលណាទូលបង្គំប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ សូមព្រះអង្គដឹកនាំទូលបង្គំ ឲ្យនិយាយដោយសេចក្តីស្រឡាញ់។

Daily Manna 2026_Content Enhance.indd 35 17/11/25 1:44 in the afternoon

មើល នឹងមានស្តេចមួយអង្គសោយរាជ្យដោយសុចរិត... ដូចផ្លូវទឹកហូរនៅទីហួតហែង (អេសាយ ៣២:១-២)។

ព្រះយេស៊ូវប្រទានទន្លេជីវិត

ខណៈពេលដែលគេកំពុងខួងដីរកធ្យូងថ្មប្រេងឆៅក្នុងប្រទេសមួយ ក្នុងចំណោមប្រទេសដែលមានអាកាសធាតុក្តៅហួតហែងបំផុតនៅលើពិភពលោក ក្រុមការងារនោះមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលបានរកឃើញប្រព័ន្ធទឹកក្រោមដីដ៏ធំសម្បើមមួយ។ ដូចនេះនៅឆ្នាំ១៩៨៣ គេក៏បានចាប់ផ្តើមអនុវត្តគម្រោង «ទន្លេសប្បនិមិត្ត» ខ្នាតធំ ដោយដាក់ប្រព័ន្ធទុយោទឹក ដើម្បីនាំទឹកមានគុណភាពខ្ពស់ចូលទៅក្នុងទីក្រុងមួយចំនួនដែលកំពុងត្រូវការទឹក។ នៅក្បែរកន្លែងដែលគេបង្កើតគម្រោងនេះមានផ្លាកមួយ ដែលមានអក្សរសរសេរពីលើថា «មានសរសៃឈាមជីវិតហូរចេញពីកន្លែងនេះ»។

ហោរា អេសាយ បានប្រើពាក្យប្រៀបប្រដូចអំពីទឹកក្នុងវាលរហោស្ថាន ដើម្បីពិពណ៌នាអំពីក្សត្រដ៏សុចរិតមួយអង្គ ដែលនឹងយាងមក (អេសាយ ៣២)។ ស្តេច ឬអ្នកដឹកនាំដែលគ្រប់គ្រង ដោយសេចក្តីយុត្តិធម៌ និងសេចក្តីសុចរិត គឺប្រៀបដូចជា «ផ្លូវទឹកហូរនៅទីហួតហែង ហើយដូចជាម្លប់នៃថ្មដាយ៉ាងធំនៅទីខ្សោះល្វើយ» (ខ.២)។ អ្នកដឹកនាំខ្លះជ្រើសរើសយកការទទួល ជាជាងការឲ្យ។ ទោះជាយ៉ាងណាក៏ដោយ សញ្ញាសម្គាល់របស់អ្នកដឹកនាំដែលថ្វាយព្រះកិត្តិនាមដល់ព្រះ គឺជាអ្នកដែលផ្តល់ឲ្យនូវជម្រក ទីជ្រកកោន ភាពស្រស់ថ្លា និងការការពារ។ កណ្ឌគម្ពីរអេសាយបានចែងថា «ឯការនៃសេចក្តីសុចរិត នោះនឹងបានជាសន្តិសុខ ហើយផលនៃសេចក្តីសុចរិត នោះនឹងបានជាសេចក្តីស្រាកស្រាន្ត និងជាសេចក្តីទុកចិត្តជាដរាបទៅ» (ខ.១៧)។

នៅសម័យក្រោយមក ព្រះបន្ទូលនៃសេចក្តីសង្ឃឹម ក្នុងកណ្ឌគម្ពីរអេសាយក៏បានសម្រេចក្នុងអង្គព្រះយេស៊ូវ ដែលព្រះអង្គបានយាងមកចាប់កំណើត ដើម្បីប្រទានសេចក្តីសង្គ្រោះ ហើយនឹងយាងមកវិញម្តងទៀត ដើម្បីយកយើងទៅនៅជាមួយព្រះអង្គជារៀងរហូត (១ថែស្សាឡូនិច ៤:១៦-១៧)។ ទន្លេសប្បនិមិត្ត គឺជាសមិទ្ធផលរបស់មនុស្ស ដែលថ្ងៃណាមួយ វានឹងរីងស្ងួត។ តែក្សត្រដ៏សុចរិតរបស់យើងបានប្រទានភាពស្រស់ថ្លា និងទន្លេជីវិតដែលមិនចេះរីងស្ងួតឡើយ។—Karen Pimpo

តើអ្នកត្រូវការព្រះយេស៊ូវប្រទានទន្លេជីវិត នៅកន្លែងណាខ្លះ? តើអ្នកអាចនាំភាពស្រស់ថ្លាដល់អ្នកដទៃតាមគំរូរបស់ព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការនាំមកនូវសន្តិភាព តាមរយៈការគ្រងរាជដ៏សុចរិតយ៉ាងល្អឥតខ្ចោះ។

Daily Manna 2026_Content Enhance.indd 36 17/11/25 1:44 in the afternoon

ដ្បិតបើមនុស្សណានឹងបានលោកីយ៍ទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ? (ម៉ាកុស ៨:៣៦)

បានចុះចូលព្រះយេស៊ូវទាំងស្រុង

កាលពីឆ្នាំ១៩២០ លោក ចន ស៊ុង (John Sung) ជាកូនទី៦របស់គ្រូគង្វាលជនជាតិចិនបានទទួលអាហាររូបករណ៍ ទៅរៀននៅសាកលវិទ្យាល័យមួយក្នុងសហរដ្ឋអាមេរិក។ គាត់បានបញ្ចប់ការសិក្សាដោយទទួលសញ្ញាប័ត្រកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ហើយក៏បានបញ្ចប់ថ្នាក់អនុបណ្ឌិត ព្រមទាំងថ្នាក់បណ្ឌិតផងដែរ។ ខណៈពេលដែលគាត់កំពុងបន្តការសិក្សានៅថ្នាក់ខ្ពស់ គាត់ក៏បានដើរចេញឆ្ងាយពីព្រះអម្ចាស់។ ក្រោយមកនៅពេលយប់មួយក្នុងឆ្នាំ១៩២៧ គាត់ក៏បានថ្វាយជីវិតគាត់ដាច់ដល់ព្រះគ្រីស្ទ ហើយក៏បានទទួលការត្រាស់ហៅឲ្យធ្វើជាគ្រូអធិប្បាយ។

គាត់មានឱកាសជាច្រើន ដើម្បីស្វែងរកការងារដែលមានប្រាក់កំរៃខ្ពស់ក្នុងប្រទេសចិន តែក្នុងការធ្វើដំណើរតាមកប៉ាល់ត្រឡប់មកផ្ទះវិញ គាត់បានទទួលការបណ្តាលចិត្ត ឲ្យលះចោលបំណងប្រាថ្នារបស់គាត់។ គាត់ក៏បានបោះសញ្ញាប័ត្រទាំងអស់ចូលទៅក្នុងទឹកសមុទ្រ ជានិមិត្តសញ្ញានៃការប្តេជ្ញាចិត្ត ដោយទុកតែសញ្ញាប័ត្របណ្ឌិតជូនឪពុកម្តាយរបស់គាត់ ដោយការគោរព។

លោក ចន ស៊ុង បានយល់អំពីអត្ថន័យនៃការក្លាយជាសិស្សព្រះអង្គ។ គឺដូចដែលព្រះអង្គមានបន្ទូលថា “ដ្បិតបើមនុស្សណានឹងបានលោកីយ៍ទាំងមូល តែបាត់ព្រលឹងទៅ នោះតើមានប្រយោជន៍អ្វីដល់អ្នកនោះ?” (ម៉ាកុស ៨:៣៦)។ ពេលណាយើងបដិសេធខ្លួនឯង ហើយបោះបង់ចោលជីវិតចាស់ ដើម្បីដើរតាមព្រះគ្រីស្ទ និងការដឹកនាំរបស់ព្រះអង្គ (ខ.៣៤-៣៥) គឺអាចមានន័យថា យើងលះបង់ចោលក្តីបំណង និងប្រយោជន៍ផ្ទាល់ខ្លួន ដែលរារាំងយើងមិនឲ្យដើរតាមព្រះអង្គ។

ក្នុងអំឡុងពេល១២ឆ្នាំក្រោយមក លោក ចន បានបំពេញបេសកកម្មដែលព្រះទ្រង់បានប្រទានអស់ពីចិត្ត ដោយផ្សាយដំណឹងល្អដល់មនុស្សរាប់ពាន់នាក់នៅទូទាំងប្រទេសចិន និងតំបន់អាស៊ីអាគ្នេយ៍។ ចុះចំណែកយើងវិញ? យើងប្រហែលមិនបានឮព្រះអង្គត្រាស់ហៅយើងឲ្យធ្វើជាគ្រូអធិប្បាយ ឬបេសកជនទេ តែទោះព្រះទ្រង់ត្រាស់ហៅយើងឲ្យបម្រើព្រះអង្គនៅកន្លែងណាក៏ដោយ ចូរយើងចុះចូលបំណងព្រះទ័យព្រះអង្គទាំងស្រុង ដោយអំណាចព្រះវិញ្ញាណបរិសុទ្ធធ្វើការក្នុងយើង។—Jasmine Goh

តើអ្នកត្រូវលះបង់អ្វីខ្លះ ដើម្បីឲ្យអ្នកអាចដើរតាមព្រះយេស៊ូវយ៉ាងពិតត្រង់? តើអ្នកមានក្តីប្រាថ្នាធំអ្វីខ្លះដែលកំពុងរារាំងអ្នកមិនឲ្យដើរតាមព្រះអង្គ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យលះបង់ចោលការអ្វីក៏ដោយ ដែលរារាំងទូលបង្គំមិនឲ្យចុះចូលនឹងព្រះអង្គទាំងស្រុង។

Daily Manna 2026_Content Enhance.indd 37 17/11/25 1:44 in the afternoon

គឺទ្រង់បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង (ភីលីព ២:៧)។

គំរូនៃការបន្ទាបខ្លួន ដោយការលះបង់

បន្ទាប់ពីការប្រកួតចប់ កីឡាករបាល់បោះមហាវិទ្យាល័យដ៏ល្បីល្បាញម្នាក់មិនបានចេញទៅណាទេ។ គាត់បានជួយអ្នកបោសសម្អាតរើសសម្បកដប និងកញ្ចប់អាហារដែលទស្សនិកជនបានចោលនៅកន្លែងអង្គុយ។ ពេលដែលអ្នកគាំទ្ររបស់គាត់ម្នាក់បានបង្ហោះវីដេអូសកម្មភាពរបស់គាត់ មានមនុស្ស ៨ម៉ឺននាក់បានមើលវីដេអូនោះ។ ក្នុងចំណោមពួកគេ មានមនុស្សម្នាក់សរសេរថា «យុវជនម្នាក់នេះស្ថិតក្នុងចំណោមមនុស្សដែលបន្ទាបខ្លួនបំផុត ដែលអ្នកធ្លាប់បានជួបក្នុងជីវិតអ្នក»។ សម្រាប់កីឡាករបាល់បោះម្នាក់នេះ ការចេញទៅជាមួយក្រុមរបស់ខ្លួន ដើម្បីអបអរជ័យជម្នះក្នុងការប្រកួត គឺមានភាពងាយស្រួលជាងការដើរើសសំរាម។ តែផ្ទុយទៅវិញ គាត់បានស្ម័គ្រចិត្តធ្វើកិច្ចការដ៏ពិបាកដែលគេរាល់គ្នាមើលរំលង។

ព្រះយេស៊ូវក៏បានបង្ហាញចេញនូវការបន្ទាបខ្លួន ដោយព្រះអង្គបានលះបង់កន្លែងដ៏ខ្ពង់ខ្ពស់ក្នុងនគរស្ថានសួគ៌ ដើម្បីទទួលយកតួនាទីជាអ្នកបម្រើនៅលើផែនដី (ភីលីព ២:៧)។ ព្រះអង្គបានស្ម័គ្រព្រះទ័យបន្ទាបព្រះកាយចុះ ដើម្បីយើងរាល់គ្នា។ ព្រះរាជកិច្ចរបស់ព្រះអង្គនៅលើផែនដីក៏បានរាប់បញ្ចូលការបង្រៀន ការប្រោសជំងឺ និងការស្រឡាញ់មនុស្សទាំងអស់ ហើយបេសកកម្មធំបំផុតរបស់ព្រះអង្គ គឺការសុគត និងមានព្រះជន្មរស់ឡើងវិញ ដើម្បីសង្គ្រោះពួកគេឲ្យរួចពីបាប។

ទោះគំរូរបស់ព្រះគ្រីស្ទអាចបណ្តាលចិត្តយើងឲ្យរើសសំរាម ជូតសម្អាតតុ ឬលើកអាហារឲ្យគេ តែគំរូព្រះអង្គមានអំណាចបំផុតក្នុងជីវិតយើង នៅពេលណាយើងកែប្រែអាកប្បកិរិយារបស់យើង ចំពោះអ្នកដទៃ។ ការបន្ទាបខ្លួនពិតប្រាកដ គឺជាលក្ខណៈសម្បត្តិនៅខាងក្នុង ដែលមិនគ្រាន់តែកែប្រែសកម្មភាពរបស់យើងប៉ុណ្ណោះទេ តែក៏កែប្រែចិត្តគំនិតយើងផងដែរ។ គំរូរបស់ព្រះអង្គបានបណ្តាលចិត្តយើងឲ្យ ចេះឲ្យតម្លៃអ្នកដទៃលើសខ្លួនឯង (ខ.៣)។

លោក អេនឌ្រូ មួរេយ (Andrew Murray) ជាអ្នកនិពន្ធ និងគ្រូអធិប្បាយបានមានប្រសាសន៍ថា «ការបន្ទាបខ្លួន គឺជាផ្នែកដ៏សំខាន់ និងគួរឲ្យទាក់ទាញនៃសេចក្តីបរិសុទ្ធ»។ សូមឲ្យជីវិតយើងឆ្លុះបញ្ចាំងឲ្យគេឃើញការបន្ទាបខ្លួន ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ ដូចដែលយើងបង្ហាញឲ្យគេស្គាល់ដួងព្រះទ័យរបស់ព្រះគ្រីស្ទ តាមរយៈទីបន្ទាល់នៃការរស់នៅដោយបន្ទាបខ្លួន (ខ.២-៥)។—Jennifer Benson Schuldt

តើការបន្ទាបព្រះកាយរបស់ព្រះយេស៊ូវបានបណ្តាលចិត្តអ្នកយ៉ាងដូចម្តេចខ្លះ? តើអ្នកកំពុងជួបការលំបាកឲ្យមានអំនួតនៅក្នុងផ្នែកណាខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការបន្ទាបព្រះកាយ ដើម្បីទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំឲ្យយកតម្រាប់តាមគំរូព្រះអង្គ ដោយចាត់ទុកតម្រូវការរបស់អ្នកដទៃ សំខាន់ជាងតម្រូវការខ្លួនឯង។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | និក្ខមនំ ២៧-២៨ និងម៉ាថាយ ២១:១-២២

អញ្ជើញអ្នកទៅឲ្យប្រកបដោយសេចក្តីសុខចុះ ដ្បិតយើងទាំង២នាក់បានស្បថគ្នា ដោយនូវព្រះនាមព្រះយេហូវ៉ាហើយ (១សាំយ៉ូអែល ២០:៤២)។

មិត្តភាពដ៏ជ្រាលជ្រៅក្នុងព្រះគ្រីស្ទ

នៅក្នុងព្រះវិហារនៃមហាវិទ្យាល័យព្រះគ្រីស្ទនៅទីក្រុងខេមប្រ៊ីជ ប្រទេសអង់គ្លេស មានវិមានមួយដែលគេបានសាងសង់ឡើង ជាការរំឭកដល់គ្រូពេទ្យពីរនាក់គឺលោក ចន ហ្វីញ (John Finch) និងលោក ថូម៉ាស បេន (Thomas Baines)។ គេបានដាក់រហ័សនាមឲ្យអ្នកទាំងពីរថា «មិត្តភក្តិដែលគ្មានអ្វីអាចបំបែកបាន»។ លោក ហ្វីញ និងលោក បេន បានរួមគ្នាធ្វើការស្រាវជ្រាវផ្នែកវេជ្ជសាស្ត្រ និងធ្វើដំណើរជាមួយគ្នាជាលក្ខណៈការទូត។ កាលលោក បេន លាចាកលោកក្នុងឆ្នាំ១៦៨០ លោក ហ្វីញ ក៏បានពោលទំនួញអំពី «មិត្តភក្តិចិត្តមួយថ្លើមមួយ» ដែលគ្មានអ្វីអាចបំបែកបានរយៈពេល ៣៦ឆ្នាំកន្លងមក។ មិត្តភាពរបស់ពួកគេមានពេញដោយក្តីស្រឡាញ់ ភាពស្មោះត្រង់ និងការប្តូរផ្តាច់។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំ មិត្តភាពដ៏រឹងមាំរវាងស្តេច ដាវីឌ និងព្រះអង្គម្ចាស់ យ៉ូណាថាន។ ពួកគេមានសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ ចំពោះគ្នាទៅវិញទៅមក (១សាំយ៉ូអែល ២០:៤១) ហើយថែមទាំងបានធ្វើពាក្យសម្បថ ដើម្បីប្តេជ្ញាចិត្តចំពោះគ្នាទៅវិញទៅមក (ខ.៨, ១៧, ៤២)។ មិត្តភាពរបស់ពួកគេមានភាពស្មោះត្រង់យ៉ាងខ្លាំង (១សាំយ៉ូអែល ១៩:១-២ ២០:១៣) ដោយព្រះអង្គម្ចាស់ យ៉ូណាថាន ថែមទាំងបានលះបង់សិទ្ធិស្នងរាជសម្បត្តិ ដើម្បីឲ្យស្តេច ដាវីឌ អាចក្លាយជាស្តេច (២០:៣០-៣១ មើល ២៣:១៥-១៨)។ ពេលដែលព្រះអង្គម្ចាស់ យ៉ូណាថាន សុគត ស្តេច ដាវីឌ ក៏បានពោលទំនួញថា សេចក្តីស្រឡាញ់ដែលព្រះអង្គម្ចាស់ យ៉ូណាថាន មានចំពោះទ្រង់ «នោះជាទីអស្ចារ្យ ក៏លើសជាងសេចក្តីស្រឡាញ់របស់ស្រីៗផង» (២សាំយ៉ូអែល ១:២៦)។

ក្នុងពេលសព្វថ្ងៃ យើងប្រហែលមានអារម្មណ៍មិនល្អនៅក្នុងការប្រៀបប្រដូចមិត្តភាព និងទំនាក់ទំនងប្តីប្រពន្ធនោះឡើយ តែមិត្តភាពរបស់ពួកគេអាចធ្វើជាគំរូដ៏ល្អ ដែលលើកទឹកចិត្តយើងឲ្យមានមិត្តភាពកាន់តែជ្រាលជ្រៅផងដែរ។ ព្រះយេស៊ូវបានអនុញ្ញាតឲ្យមិត្តសំឡាញ់ព្រះអង្គផ្អែកលើព្រះឱរារបស់ព្រះអង្គ (យ៉ូហាន ១៣:២៣-២៥) ហើយក្តីស្រឡាញ់ ភាពស្មោះត្រង់ និងការប្តេជ្ញាចិត្តដែលព្រះអង្គបានបង្ហាញយើងរាល់គ្នា អាចធ្វើជាមូលដ្ឋានគ្រឹះនៃមិត្តភាពដ៏ជ្រាលជ្រៅ ដែលយើងកសាងជាមួយគ្នា។—Sheridan Voysey

តើអ្នកយល់ឃើញថា ជំនឿដែលអ្នកមានចំពោះព្រះគ្រីស្ទ អាចធ្វើឲ្យទំនាក់ទំនងកាន់តែមានភាពរឹងមាំដូចម្តេចខ្លះ? តើអ្នកអាចបង្ហាញសេចក្តីស្រឡាញ់ ភាពស្មោះត្រង់ និងការប្តេជ្ញាចិត្តចំពោះមិត្តភក្តិរបស់អ្នកដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យកសាងមិត្តភាពកាន់តែជ្រាលជ្រៅ និងស្មោះត្រង់។

Daily Manna 2026_Content Enhance.indd 39 17/11/25 1:44 in the afternoon

មានមនុស្សដែលចែកផ្សាយទ្រព្យ តែចេះតែចំរើនកើន (សុភាសិត ១១:២៤)។

ឲ្យអំណោយដោយសេចក្តីស្រឡាញ់

ថ្ងៃដែលអ្នកស្រី ឃ្វែនដូលីន ស្តូលជីស (Gwendolyn Stulgis) រៀបអាពាហ៍ពិពាហ៍ គាត់បានស្លៀករ៉ូបរៀបការ ដូចដែលគាត់បានស្រមៃចង់បាន។ ក្រោយមក គាត់ក៏បានយករ៉ូបដែលគាត់បានប្រើហើយនោះទៅឲ្យមនុស្សម្នាក់ដែលគាត់មិនដែលស្គាល់។ គាត់ជឿថា រ៉ូបរបស់គាត់មិនសមនឹងឲ្យគាត់ព្យួរចោលក្នុងទូខោអាវ ឲ្យប្រឡាក់ធូលីដីនោះទេ។ កូនក្រមុំដទៃទៀតដែលរៀបការថ្មោងថ្មីក៏យល់ឃើញដូចគាត់ផងដែរ។ សព្វថ្ងៃនេះ មានស្ត្រីកាន់តែច្រើនបានចូលរួមជាមួយទំព័របណ្តាញសង្គមរបស់គាត់ ដើម្បីបរិច្ចាគ ឬទទួលរ៉ូបកូនក្រមុំដែលគេប្រើហើយ។ មានអ្នកបរិច្ចាគម្នាក់បានមានប្រសាសន៍ថា «ខ្ញុំសង្ឃឹមថា គេនឹងយករ៉ូបនេះទៅឲ្យកូនក្រមុំផ្សេងទៀតតគ្នាពីម្នាក់ទៅម្នាក់ទៀត ទាល់តែវារហែកប្រើលែងកើត ដោយសារការអបអរ ដែលមានក្នុងការប្រើប្រាស់រ៉ូបនេះ»។

ជាការពិតណាស់ ការចែករំលែកដោយចិត្តជ្រះថ្លា អាចធ្វើឲ្យយើងមានអារម្មណ៍រីករាយ។ គឺដូចមានសេចក្តីចែងមកថា «មានមនុស្សដែលចែកផ្សាយទ្រព្យ តែចេះតែចំរើនកើនឡើង ក៏មានមនុស្សដែលហួងហែងហួសខ្នាត តែគេចេះតែខ្វះខាតវិញ។

មនុស្សដែលមានចិត្តសុទ្ធានឹងបានបរិបូរ ហើយអ្នកណាដែលស្រោចទឹកដល់គេ នោះនឹងបានគេស្រោចទឹកដល់ខ្លួនដែរ» (សុភាសិត ១១:២៤-២៥)។

សាវ័ក ប៉ុល បានបង្រៀនគោលការណ៍នេះក្នុងព្រះគម្ពីរសញ្ញាថ្មីផងដែរ។ កាលគាត់និយាយពាក្យលាគ្នាទៅកាន់អ្នកជឿព្រះនៅទីក្រុងអេភេសូរ គាត់ក៏បានជូនពរពួកគេ (កិច្ចការ ២០:៣២) ហើយបានរំឭកពួកគេ អំពីសារៈសំខាន់នៃសេចក្តីសប្បុរស។ សាវ័ក ប៉ុល បានលើកឡើងអំពីក្រមសីលធម៌នៃការងាររបស់គាត់ ធ្វើជាគំរូសម្រាប់ឲ្យពួកគេយកតម្រាប់តាម។ គឺដូចគាត់មានប្រសាសន៍ថា «ខ្ញុំបានបង្ហាញអ្នករាល់គ្នាដោយគ្រប់ការទាំងអស់ថា គួរឲ្យខំធ្វើការដូច្នោះ ដើម្បីឲ្យបានជួយដល់ពួកអ្នកខ្សោយ ហើយនិងនឹកចាំពីព្រះបន្ទូលនៃព្រះអម្ចាស់យេស៊ូវ ដែលទ្រង់មានព្រះបន្ទូលថា ដៃលឲ្យ នោះបានពរជាជាងទទួល» (ខ.៣៥)។

ការបង្ហាញចេញនូវសេចក្តីសប្បុរស គឺបានឆ្លុះបញ្ចាំងឲ្យគេស្គាល់ចរិកលក្ខណៈរបស់ព្រះអម្ចាស់។ «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦)។ ដូចនេះ ចូរយើងយកតម្រាប់តាមគំរូដ៏រុងរឿងរបស់ព្រះអង្គ តាមការដឹកនាំរបស់ព្រះអង្គ។

—Patricia Raybon

តើថ្មីៗនេះ អ្នកទទួលបានឲ្យអំណោយល្អៗអ្វីខ្លះ ដល់អ្នកដទៃ? តើអំណោយរបស់អ្នកបានជួយនរណាម្នាក់ យ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គបើកចិត្តទូលបង្គំ ដើម្បីឲ្យអំណោយដល់អ្នកដទៃ ដោយសេចក្តីស្រឡាញ់របស់ព្រះអង្គក្នុងចិត្តទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | និក្ខមនំ ៣១-៣៣ និងម៉ាថាយ ២២:១-២២

ព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ហើយកុំឲ្យភ្លេចបណ្តាព្រះគុណណាមួយរបស់ទ្រង់ឡើយ (ទំនុកតម្កើង ១០៣:២)។

មានកម្លាំងឡើងវិញ ដោយសារការអរព្រះគុណ

បន្ទាប់ពីអ្នកស្រី គ្រីស្ទីណា ខូស្តា (Christina Costa) បានទៅពិនិត្យសុខភាពរកឃើញថា គាត់មានដុំសាច់ក្នុងខួរក្បាល គាត់បានកត់សម្គាល់ឃើញថា ភាគច្រើននៃការជជែកគ្នាអំពីការប្រឈមមុខដាក់ជំងឺមហារីកត្រូវបានគ្របដណ្តប់ទៅដោយការនិយាយអំពីការប្រយុទ្ធតទល់នឹងជំងឺមហារីក។ គាត់ក៏បានដឹងថា ការមានផ្នត់គំនិតដូចនេះបាននាំឲ្យគាត់មានអារម្មណ៍ហត់នឿយយ៉ាងខ្លាំង។ គាត់មិនចង់ចំណាយពេលជាង១ឆ្នាំដើម្បីធ្វើសង្គ្រាមជាមួយនឹងជំងឺមហារីកក្នុងរូបកាយរបស់គាត់ទេ។ ផ្ទុយទៅវិញ គាត់ក៏បានរកឃើញថា ដំណោះស្រាយដែលមានប្រយោជន៍បំផុត គឺជាការអនុវត្តនូវការអរព្រះគុណព្រះជារៀងរាល់ថ្ងៃ ដែលបានប្រទានឲ្យគាត់មានគ្រូពេទ្យព្យាបាលគាត់ និងប្រទានការប្រោសឲ្យជាដែលកំពុងកើតមានក្នុងខួរក្បាល និងរូបកាយគាត់។ គាត់បានដកពិសោធន៍នឹងការពិតដែលថា ទោះយើងជួបការលំបាកយ៉ាងណាក៏ដោយ ការអនុវត្តនូវការអរព្រះគុណព្រះ អាចជួយយើងជម្នះការធ្លាក់ទឹកចិត្ត និងជួយយើងឲ្យមានទឹកចិត្តក្នុងការស៊ូទ្រាំនឹងទុក្ខលំបាក។

រឿងរបស់អ្នកស្រី ខូស្តា បានរំឭកខ្ញុំថា ការអនុវត្តន៍នូវការអរព្រះគុណព្រះ មិនគ្រាន់តែជាកាតព្វកិច្ចរបស់អ្នកជឿប៉ុណ្ណោះទេ។ ជាការពិតណាស់ ព្រះទ្រង់សក្តិសមនឹងឲ្យយើងដឹងគុណ តែទោះជាយ៉ាងណាក៏ដោយ ការអរព្រះគុណមានប្រយោជន៍ចំពោះយើងណាស់។ ពេលណាយើងប្រាប់ខ្លួនឯងថា «ព្រលឹងអញអើយ ចូរសរសើរដល់ព្រះយេហូវ៉ាចុះ ហើយកុំឲ្យភ្លេចបណ្តាព្រះគុណណាមួយរបស់ទ្រង់ឡើយ» (ទំនុកតម្កើង ១០៣:២) យើងនឹកចាំថា ព្រះអម្ចាស់បានធ្វើការក្នុងជីវិតយើងតាមរបៀបជាច្រើនរាប់មិនអស់ ដោយធានាដល់យើងថា ព្រះអង្គនឹងអត់ទោសឲ្យយើង និងធ្វើការប្រោសឲ្យជាក្នុងរូបកាយ និងចិត្តយើង ហើយឲ្យយើងដកពិសោធន៍នឹង «សេចក្តីស្រឡាញ់ និងសេចក្តីអាណិត» របស់ព្រះអង្គ ព្រមទាំងរបស់ល្អជាច្រើនរាប់មិនអស់ក្នុងស្នាព្រះហស្តព្រះអង្គ (ខ.៣-៥)។

ជំងឺទាំងអស់មិនសុទ្ធតែមានការជាសះស្បើយក្នុងជីវិតនេះទេ តែចិត្តរបស់យើងតែងតែអាចមានភាពស្រស់ថ្លា និងកម្លាំងឡើងវិញ ពេលណាយើងអរព្រះគុណព្រះអង្គ ដ្បិតសេចក្តីស្រឡាញ់របស់ព្រះអង្គនឹងនៅជាប់ជាមួយយើងអស់កល្បជានិច្ច (ខ.១៧)។—Monica La Rose

តើអ្នកបានដកពិសោធន៍នឹងការប្រោសឲ្យជា តាមរយៈការអរព្រះគុណព្រះអង្គ យ៉ាងដូចម្តេចខ្លះ? តើអ្នកចង់អរព្រះគុណព្រះអង្គសម្រាប់ការអ្វីខ្លះនៅថ្ងៃនេះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលតែងតែប្រទានទូលបង្គំនូវហេតុផល ដែលត្រូវអរព្រះគុណ និងមានក្តីសង្ឃឹម។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | និក្ខមនំ ៣៤-៣៥ និងម៉ាថាយ ២២:២៣-៤៦

ពួកដែលចោទប្រកាន់នាង តើនៅឯណាគ្មានអ្នកណាកាត់ទោសនាងទេឬអី?
(យ៉ូហាន ៨:១០)

បង្ហាញសេចក្តីស្រឡាញ់ ដោយមិនកាត់ទោស

ថ្ងៃមួយ មិត្តភក្តិរបស់មែកគី (Maggie) បានមកចូលរួមកម្មវិធីថ្វាយបង្គំនៅថ្ងៃអាទិត្យ ដោយមានសំលៀកបំពាក់ដែលធ្វើឲ្យគេមានការភ្ញាក់ផ្អើល។ គេមិនគួរមានការភ្ញាក់ផ្អើលទេ ព្រោះនាងជាស្ត្រីរកស៊ីផ្លូវភេទ។ នាងក៏បានដើរទៅកេកន្លែងអង្គុយ ដោយមានអារម្មណ៍មិនស្រួលក្នុងចិត្ត។ នាងពិបាកអង្គុយ ដោយសារនាងបានស្លៀកសំពត់ខ្លីពេក ហើយនាងក៏បានអង្គុយឱបដៃក្នុងកម្មវិធីថ្វាយបង្គំ។

មែកគីក៏បានសួរនាង ក្រែងលោនាងរងា ហើយក៏បានប្រគល់កន្សែងបង់ករមួយ ឲ្យនាងគ្របពីលើជើង ដើម្បីកុំឲ្យគេមានការចាប់អារម្មណ៍ចំពោះការស្លៀកពាក់របស់នាង។

មែកគី បាននាំមនុស្សរាប់សិបនាក់ ឲ្យទទួលជឿព្រះយេស៊ូវ ដោយគ្រាន់តែបានអញ្ជើញពួកគេឲ្យមកព្រះវិហារ ហើយជួយពួកគេមានអារម្មណ៍កក់ក្តៅនៅក្នុងព្រះវិហារ។ ពន្លឺនៃដំណឹងល្អបានបង្ហាញចេញមកតាមរយៈរបៀបដែលនាងឈោងចាប់វិញ្ញាណបាត់បង់។ នាងបានប្រព្រឹត្តចំពោះអ្នកដទៃដោយភាពថ្លៃថ្នូរ ដែលនាំឲ្យគេបើកចិត្តស្តាប់ដំណឹងល្អ។

ព្រះគម្ពីរបានចែងថា ពួកអ្នកដឹកនាំសាសនាបានអូសស្ត្រីម្នាក់នៅចំពោះព្រះយេស៊ូវ ដោយការចោទប្រកាន់នាងថា បានផិតក្បត់។ ពេលនោះ ព្រះអង្គក៏បានមានបន្ទូល ធ្វើឲ្យពួកគេដើរចេញពីនាង ដោយមិនហ៊ានកាត់ទោសនាង។ នៅពេលដែលពួកគេចេញទៅអស់ ព្រះអង្គអាចស្តីបន្ទោសឲ្យនាង។ តែផ្ទុយទៅវិញ ព្រះអង្គគ្រាន់តែបានសួរសំណួរពីរប៉ុណ្ណោះ ពួកដែលចោទប្រកាន់នាង តើនៅឯណា គ្មានអ្នកណាកាត់ទោសនាងទេឬអី? (យ៉ូហាន ៨:១០)។ នាងក៏បានឆ្លើយថា គ្មាននរណានៅកាត់ទោសនាងទេ។ ដូចនេះ ព្រះយេស៊ូវក៏បានចែកចាយដំណឹងល្អដល់នាង ដោយព្រះបន្ទូលដ៏ខ្លីថា «ខ្ញុំក៏មិនកាត់ទោសនាងដែរ អញ្ជើញទៅចុះ តែកុំធ្វើបាបទៀតឡើយ» (ខ.១១)។

ចូរយើងកុំមើលស្រាលអំណាចនៃសេចក្តីស្រឡាញ់ដ៏ពិត ជាប្រភេទនៃសេចក្តីស្រឡាញ់ ដែលមិនថ្កោលទោស ហើយថែមទាំងប្រទាននូវសេចក្តីថ្លៃថ្នូរ និងការអត់ទោសដល់មនុស្សម្នាក់ៗ។—Tim Gustafson

តើអ្នកនឹងមានប្រតិកម្មដូចម្តេច ពេលអ្នកឃើញនរណាម្នាក់រស់នៅក្នុងអំពើបាបដែលគេស្អប់ខ្ពើម? តើអ្នកអាចអញ្ជើញនរណាទៅព្រះវិហារសប្តាហ៍នេះ ដោយរបៀបណា?

ឱព្រះប្រកបដោយព្រះគុណ សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ដែលមានវិញ្ញាណកាត់ទោសអ្នកដទៃ ហើយសូមព្រះអង្គជួយទូលបង្គំឲ្យបង្ហាញសេចក្តីស្រឡាញ់ និងព្រះគុណព្រះអង្គ ដល់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 42 17/11/25 1:44 in the afternoon

អ័ប្រាហាំ ហៅកន្លែងនោះថា «យេហូវ៉ា-យីរេ» ដូចជាគេក៏និយាយដរាបដល់សព្វថ្ងៃនេះដែរ ថា នៅភ្នំនៃព្រះយេហូវ៉ា គឺទ្រង់នឹងផ្គត់ផ្គង់ឲ្យ (លោកុប្បត្តិ ២២:១៤)។

ការចុះចូលព្រះអម្ចាស់ទាំងស្រុង

លោក ចាត់សិន វ៉ែន ដេវ៉ែនទ័រ (Judson Van DeVenter) បានរៀនគូរគំនូរប្រេង និងបានរៀនសិល្បៈ ព្រមទាំងបានក្លាយជាគ្រូសិល្បៈ។ ទោះជាយ៉ាងណាក៏ដោយ ព្រះទ្រង់មានផែនការខុសពីគោលដៅរបស់គាត់។ មិត្តភក្តិរបស់គាត់បានឲ្យតម្លៃមកលើការងារដែលគាត់ធ្វើក្នុងព្រះវិហារ ហើយក៏បានជំរុញគាត់ឲ្យទៅផ្សាយដំណឹងល្អ។ លោក ចាត់សិន ក៏មានអារម្មណ៍ថា ព្រះអម្ចាស់កំពុងត្រាស់ហៅគាត់ផងដែរ តែគាត់ពិបាកលះបង់សេចក្តីស្រឡាញ់ ដែលគាត់មានចំពោះការបង្រៀនសិល្បៈ។ គាត់ក៏បានព្យាយាមបដិសេធន៍ការត្រាស់ហៅនេះ តែក្រោយមកគាត់ក៏បានសារភាពថា ពេលដ៏សំខាន់បំផុតនៃជីវិតគាត់បានមកដល់ ហើយគាត់ក៏បានចុះចូលបំណងព្រះទ័យព្រះអង្គទាំងស្រុង។

យើងមិនដឹងថា លោក អ័ប្រាហាំ មានការឈឺចាប់ក្នុងចិត្តខ្លាំងប៉ុណ្ណាទេ នៅពេលដែលព្រះទ្រង់ត្រាស់ហៅគាត់ ឲ្យលះបង់អ៊ីសាក់ ជាកូនប្រុសគាត់។ នៅពេលដែលយើងបានដឹងថា ព្រះអង្គបានត្រាស់បង្គាប់លោក អ័ប្រាហាំ ឲ្យយកកូនប្រុសទៅធ្វើយញ្ញបូជាថ្វាយព្រះអង្គ (លោកុប្បត្តិ ២២:២) យើងអាចសួរខ្លួនឯងថា តើព្រះអង្គសព្វព្រះទ័យឲ្យយើងលះបង់អ្វីខ្លះដែលមានតម្លៃចំពោះយើង? យើងដឹងថា នៅទីបំផុតព្រះអង្គក៏បានទុកជីវិតឲ្យអ៊ីសាក់ (ខ.១២) ហើយរឿងនេះបានបង្រៀនយើងថា លោក អ័ប្រាហាំ បានស្ម័គ្រចិត្តលះបង់អ្វីៗដែលមានតម្លៃបំផុតចំពោះគាត់។ គាត់បានទុកចិត្តថា ព្រះអង្គនឹងផ្គត់ផ្គង់គាត់ក្នុងពេលដែលគាត់ធ្វើតាមការត្រាស់ហៅដ៏ពិបាករបស់ព្រះអង្គ។

បើយើងនិយាយថា យើងស្រឡាញ់ព្រះ តើយើងស្ម័គ្រចិត្តលះបង់របស់អ្វីដែលមានតម្លៃបំផុតចំពោះយើងទេ? លោក ចាត់សិន វ៉ែន ដឺវ៉ែនទ័រ បានទៅតាមការត្រាស់ហៅរបស់ព្រះអង្គ ឲ្យទៅផ្សាយដំណឹងល្អ ហើយក្រោយមកគាត់ក៏បាននិពន្ធបទចម្រៀងទំនុកសរសើរមានចំណងជើងថា «គ្រប់ទាំងអស់ ខ្ញុំថ្វាយព្រះយេស៊ូវ»។ ក្រោយមកព្រះទ្រង់ក៏បានត្រាស់ហៅលោក ចាត់សិន ឲ្យត្រឡប់មករកការងារបង្រៀនវិញ។ កាលនោះ យុវជនឈ្មោះ ប៊ីលី ក្រាហាំ (Billy Graham) ស្ថិតក្នុងចំណោមសិស្សរបស់គាត់ផងដែរ។

ពេលខ្លះ ព្រះទ្រង់មានផែនការសម្រាប់ជីវិតយើង ដែលយើងមិនយល់។ តែព្រះអង្គសព្វព្រះទ័យឲ្យយើងស្ម័គ្រចិត្តថ្វាយរបស់អ្វី ដែលយើងស្រឡាញ់បំផុត។ ការលះបង់នេះអាចបង្ហាញអំពីការប្តេជ្ញាចិត្តរបស់យើង។ ទោះជាយ៉ាងណាក៏ដោយ ចូរយើងចាំថា ព្រះអង្គបានលះបង់ព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ។

—Kenneth Petersen

តើព្រះទ្រង់បានត្រាស់ហៅអ្នក ឲ្យធ្វើអ្វីខ្លះ? តើអ្នកចាំបាច់ត្រូវលះបង់អ្វីខ្លះថ្វាយព្រះអង្គ ដើម្បីស្តាប់បង្គាប់ព្រះអង្គ?

ឱព្រះអម្ចាស់ ទូលបង្គំពិបាកថ្វាយជីវិតទូលបង្គំទាំងស្រុងដល់ព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យទុកចិត្តព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | និក្ខមនំ ៣៩-៤០ និងម៉ាថាយ ២៣:២៣-៣៩

យើងខ្ញុំអធិស្ឋាន ដល់ព្រះនៃយើងរាល់គ្នា ហើយតាំងពួកចាំយាម ឲ្យរាំងទាំងយប់ទាំងថ្ងៃ (នេហេមា ៤:៩)។

អធិស្ឋានសូមព្រះអង្គការពារ

មានពេលមួយ លោក វ៉ាលេស (Wallace) និងអ្នកស្រី ម៉ារី ព្រោន (Mary Brown) បានផ្លាស់ទៅរស់នៅក្នុងតំបន់ក្រីក្របំផុតនៃខេត្តបឺមីងហាម ប្រទេសអង់គ្លេស ដើម្បីទៅដឹកនាំព្រះវិហារ ដែលហៀបនឹងបិទទ្វារ។ នៅពេលនោះ ពួកគេមិនដឹងទេថា មានក្រុមជើងកាងមួយក្រុមបានយកព្រះវិហារ និងផ្ទះថ្មីរបស់ពួកគេធ្វើជាទីស្នាក់ការ។ គេបានយកដុំតដួគប់ចូលផ្ទះរបស់ពួកគេ និងបានដុតបំផ្លាញរបងផ្ទះ ហើយថែមទាំងបានគំរាមកំហែងកូនៗរបស់ពួកគេផងដែរ។ ការបៀតបៀននេះបានបន្តអស់ជាច្រើនខែ ដោយប៉ូលិសមិនអាចទប់ស្កាត់បាន។

កណ្ឌគម្ពីរនេហេមាបានរំឭកយើង អំពីរបៀបដែលពួកអ៊ីស្រាអែលបានជួសជុលកំផែងទីក្រុងយេរូសាឡិម ដែលបានបែកបាក់។ នៅពេលដែលពួកសត្រូវក្នុងតំបន់ជិតខាងបាននាំគ្នាបង្កវឿង ហើយក៏បានគំរាមថា នឹងប្រើហិង្សា (នេហេមា ៤:៨) ពួកអ៊ីស្រាអែលក៏បានអធិស្ឋានទៅរកព្រះអម្ចាស់ ហើយក៏បានដាក់អ្នកយាមឲ្យនៅចាំការពារ (ខ.៩)។ ក្រុមគ្រួសាររលោក ព្រោន បានជឿថា ព្រះទ្រង់បានប្រើខគម្ពីរនេះដឹកនាំពួកគេ ដូចនេះពួកគេក៏បានដឹកនាំកូនៗ និងមនុស្សពីរបីនាក់ទៀត ឲ្យដើរជុំវិញព្រះវិហារ អធិស្ឋានសូមព្រះអង្គដាក់ពួកទេវតាឲ្យធ្វើជាអ្នកយាម ដើម្បីការពារពួកគេ។ ពួកជើងកាងបានដេរប្រទេចពួកគេ ហើយនៅថ្ងៃបន្ទាប់ ពួកជើងកាងបានមកគ្នាតិចជាងមុនពាក់កណ្តាល។ នៅថ្ងៃបន្ទាប់ មានតែ៥នាក់ទេដែលមក ហើយនៅថ្ងៃបន្ទាប់ទៀត គេមិនឃើញមានពួកជើងកាងណាម្នាក់មកគំរាមកំហែងទៀតទេ។ ក្រោយមក គ្រួសាររបស់លោក ព្រោន ក៏បានឮគេប្រាប់ថា ពួកជើងកាងបានឈប់បង្កការភ័យខ្លាចដល់ប្រជាជននៅទីនោះទៀតហើយ។

ការឆ្លើយតប ដោយការអស្ចារ្យ ចំពោះការអធិស្ឋាននេះមិនមែនជារូបមន្តសម្រាប់ការពារខ្លួនយើងនោះទេ តែវាបានរំឭកយើងថា ការទាស់ប្រឆាំងនឹងកិច្ចការរបស់ព្រះនឹងកើតមានជាធម្មតា តែយើងត្រូវតយុទ្ធ ដោយការអធិស្ឋាន ធ្វើជាអាវុធរបស់យើង។ គឺដូចដែលលោក នេហេមា បានប្រាប់ប្រជាជនអ៊ីស្រាអែលថា "ចូរនឹករឭកដល់ព្រះអម្ចាស់ដែលទ្រង់ធំ ហើយគួរស្ញែងខ្លាចវិញ" (ខ.១៤)។ ព្រះអង្គថែមទាំងអាចប្រោសចិត្តរបស់មនុស្សឲ្យឈប់ប្រព្រឹត្តហិង្សាផងដែរ។—Sheridan Voysey

បើអ្នកជាលោក ព្រោន វិញ តើអ្នកនឹងធ្វើដូចម្តេច? តើនរណាខ្លះត្រូវការអ្នកអធិស្ឋាន សូមព្រះអម្ចាស់រំដោះឲ្យរួចផុតពីការភ័យខ្លាច?

ឱព្រះដ៏គួរស្ញែងខ្លាច សូមព្រះអង្គការពារក្រុមព្រះអង្គ ដោយពួកទេវតាដ៏មានអំណាច ហើយរំដោះចិត្តរបស់អ្នកទាស់ប្រទាំងព្រះអង្គ ឲ្យមានសេរីភាព។

Daily Manna 2026_Content Enhance.indd 44 17/11/25 1:44 in the afternoon

ចិត្តឆ្មើងឆ្មៃរបស់មនុស្សនឹងនាំឲ្យទាបថោកទៅ តែអ្នកណាដែលមានចិត្តសុភាពរាបទាប នោះនឹងបានកិត្តិសព្ទវិញ (សុភាសិត ២៩:២៣)។

អំនួតនាំទៅរកសេចក្តីអាម៉ាស់

អំនួតច្រើនតែនាំទៅរកសេចក្តីអាម៉ាស់ ដែលនេះជាមេរៀនដែលបុរសជាជាតិនំរវេយម្នាក់បានទទួល។ បុរសនោះមិនទាំងបានស្លៀកពាក់ខោអាវសម្រាប់រត់ប្រណាំងផង តែគាត់បានបបួលលោក ខាស្ទិន វ័រហម (Karsten Warholm) រត់ប្រណាំង។ លោក ខាស្ទិន បានបំបែកឯកតួកម្មក្នុងការរត់ប្រណាំងចម្ងាយ ៤០០ម៉ែត្រ។ គាត់បានហ្វឹកហាត់កីឡារត់ប្រណាំងក្នុងកីឡាដ្ឋានសាធារណៈមួយ។ នៅថ្ងៃនោះ គាត់ក៏បានយល់ព្រមប្រកួតជាមួយបុរសនោះ ហើយក៏បានឈ្នះ។ ពេលទៅដល់ទី កីឡាការរត់ប្រណាំងជើងឯកពីរលើកនេះ ក៏បានញញឹម ខណៈពេលដែលបុរសនោះទទូចសុំការរត់ប្រណាំងឡើងវិញ ដោយលើកហេតុផលថា ខ្លួនមានការចាប់ផ្តើមមិនបានល្អក្នុងការរត់នោះ។

កណ្ឌគម្ពីរ សុភាសិត ២៩:២៣ បានចែងថា "ចិត្តឆ្មើងឆ្មៃរបស់មនុស្សនឹងនាំឲ្យទាបថោកទៅ តែអ្នកណាដែលមានចិត្តសុភាពរាបទាប នោះនឹងបានកិត្តិសព្ទវិញ"។ បទគម្ពីរសុភាសិតបានចែងជាញឹកញាប់ អំពីរបៀបដែលព្រះទ្រង់ប្រៀនប្រដៅមនុស្សអួត (១១:២ ១៦:១៨ ១៨:១២)។ ពាក្យអំនួត ឬឆ្មើងឆ្មៃក្នុងខទាំងនេះមានន័យថា "អួតបំប៉ោង" ដោយលួចយកការសរសើរ ដែលព្រះទ្រង់ស័ក្តិសមនឹងទទួល។ ពេលណាយើងមានពេញដោយអំនួត គំនិតរបស់យើងមានការលើកតម្កើងខ្លួនឯង។ ព្រះយេស៊ូវមានបន្ទូលថា "អ្នកណាដែលតម្កើងខ្លួន នោះនឹងត្រូវបន្ទាបចុះវិញ ហើយអ្នកណាដែលបន្ទាបខ្លួន នោះនឹងបានតម្កើងឡើង" (ម៉ាថាយ ២៣:១២)។ ព្រះអង្គបានបង្រៀនយើងឲ្យដើរតាមការបន្ទាបខ្លួន និងភាពតូចទៀប។ គឺមិនមែនក្លែងធ្វើជាបន្ទាបខ្លួននោះទេ តែជាការស្គាល់ខ្លួនឯង និងទទួលស្គាល់ថា អ្វីៗគ្រប់យ៉ាងដែលយើងមានសុទ្ធតែមកព្រះ។ បានសេចក្តីថា យើងត្រូវមានប្រាជ្ញា ហើយមិនត្រូវប្រញាប់និយាយស្តីដោយអំនួតនោះទេ (សុភាសិត ២៩:២០)។

ចូរយើងទូលសូមព្រះទ្រង់ប្រទានយើងនូវចិត្ត និងប្រាជ្ញា ដើម្បីបន្ទាបខ្លួន ដើម្បីថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ ហើយជៀសវាងភាពអាម៉ាស់។—Marvin Williams

តើអ្នកបានដកពិសោធន៍ជាមួយការបន្ទាបខ្លួន ដែលនាំមកនូវកិត្តិយស នៅពេលណា? តើអ្នកអាចបន្ទាបខ្លួន នៅចំពោះព្រះដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គរំឭកទូលបង្គំថា ការបន្ទាបខ្លួន គឺជាផ្លូវឆ្ពោះទៅរកការថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លេវីវិន័យ ៤-៥ និងម៉ាថាយ ២៤:២៩-៥១

កុំឲ្យជំពាក់អ្វីដល់អ្នកណាឡើយ ជំពាក់បានតែសេចក្តីស្រឡាញ់ ដល់គ្នាទៅវិញទៅមកប៉ុណ្ណោះ (រ៉ូម ១៣:៨)។

វដ្តនៃសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះ

កាលខ្ញុំទើបតែទទួលជឿព្រះយេស៊ូវក្នុងវ័យ៣០ឆ្នាំ ខ្ញុំមានសំណួរជាច្រើន បន្ទាប់ពីបានថ្វាយជីវិតដល់ព្រះអង្គ។ ពេលដែលខ្ញុំចាប់ផ្តើមអានព្រះគម្ពីរ ខ្ញុំមានសំណួរកាន់តែច្រើន។ ខ្ញុំក៏បានទៅសួរមិត្តភក្តិម្នាក់ថា «តើធ្វើដូចម្តេចឲ្យខ្ញុំអាចស្តាប់បង្គាប់តាមព្រះរាជបញ្ជាទាំងអស់របស់ព្រះអង្គ? ខ្ញុំទើបតែផ្ទុះកំហឹងដាក់ប្តីរបស់ខ្ញុំ កាលពីពេលព្រឹកនេះ»។

គាត់ក៏បានប្រាប់ខ្ញុំ ឲ្យបន្តអានព្រះគម្ពីរ ហើយទូលសូមព្រះវិញ្ញាណបរិសុទ្ធជួយខ្ញុំ ឲ្យស្រឡាញ់អ្នកដទៃដូចដែលព្រះអង្គស្រឡាញ់ខ្ញុំ។

បន្ទាប់ពីខ្ញុំបានរស់នៅជាកូនព្រះបានរយៈពេលជាង២០ឆ្នាំ សេចក្តីពិតដ៏សាមញ្ញ និងមានន័យនេះ នៅតែជួយខ្ញុំឱបក្រសោបយកវដ្តនៃសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអង្គ ដែលមានបីជំហានដូចជា៖ ទីមួយ សាវ័កប៉ុល បានបញ្ជាក់ថា សេចក្តីស្រឡាញ់នោះជាចំណុចស្នូលនៃជីវិតរបស់អ្នកជឿព្រះយេស៊ូវ។ ទីពីរ អ្នកដើរតាមព្រះគ្រីស្ទដើរដោយស្តាប់បង្គាប់ ដោយបន្តស្រឡាញ់គ្នាទៅវិញទៅមក «ដ្បិតអ្នកដែលស្រឡាញ់ដល់គេ នោះបានធ្វើសំរេចតាមក្រឹត្យវិន័យហើយ» (រ៉ូម ១៣:៨)។ ទីបី យើងបំពេញតាមក្រឹត្យវិន័យ ព្រោះ «សេចក្តីស្រឡាញ់ ជាកិច្ចសំរេចតាមក្រឹត្យវិន័យហើយ» (ខ.១០)។

យើងអាចឆ្លើយតបដោយការអរព្រះគុណព្រះអង្គ ពេលណាយើងបានដកពិសោធន៍នឹងជម្រៅនៃសេចក្តីស្រឡាញ់ដែលព្រះទ្រង់មានចំពោះយើង ជាពិសេសសេចក្តីស្រឡាញ់ដែលព្រះអង្គបានបង្ហាញតាមរយៈការសុគតរបស់ព្រះគ្រីស្ទនៅលើឈើឆ្កាង។ ការមានចិត្តប្តូរផ្តាច់ចំពោះព្រះយេស៊ូវ ដោយការដឹងគុណ នាំឲ្យយើងស្រឡាញ់អ្នកដទៃ ដោយពាក្យសម្តី ការប្រព្រឹត្ត និងអាកប្បកិរិយារបស់យើង។ សេចក្តីស្រឡាញ់ពិតប្រាកដកើតចេញពីព្រះពិតតែមួយ ដែលជាសេចក្តីស្រឡាញ់ (១យ៉ូហាន ៤:១៦, ១៩)។

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គជួយយើងខ្ញុំឲ្យស្រឡាញ់អ្នកដទៃ តាមគំរូព្រះអង្គ។

—Xochitl Dixon

តើអ្នកពិបាកយល់អំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ ឬពិបាកស្រឡាញ់គេតាមគំរូព្រះអង្គនៅពេលណា? តើការដឹងថា ព្រះគ្រីស្ទស្រឡាញ់អ្នកទាំងស្រុង និងដោយគ្មានលក្ខខណ្ឌបានផ្លាស់ប្តូររបៀបដែលអ្នកគិតអំពីអ្នកដទៃដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំ ឲ្យជឿថា ព្រះអង្គស្រឡាញ់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចស្រឡាញ់អ្នកដទៃ តាមរយៈសេចក្តីស្រឡាញ់ដ៏ហួរហៀរដែលព្រះអង្គមានចំពោះទូលបង្គំ។

Daily Manna 2026_Content Enhance.indd 46 17/11/25 1:44 in the afternoon

តាំងពីក្មេងតូចមក អ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មាន ដែលអាចនឹងនាំឲ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវផង (២ធីម៉ូថេ ៣:១៥)។

ព្រះបន្ទូលរបស់ព្រះកែប្រែជីវិត

តាំងពីក្មេងតូចមក អ្នកបានស្គាល់បទគម្ពីរទាំងប៉ុន្មាន ដែលអាចនឹងនាំឲ្យអ្នកមានប្រាជ្ញាដល់ទីសង្គ្រោះ ដែលបានដោយសារសេចក្តីជំនឿជឿដល់ព្រះគ្រីស្ទយេស៊ូវផង (២ធីម៉ូថេ ៣:១៥)។

កាលអ្នកស្រី គ្រីស្ទីន (Kristin) ចង់ទិញសៀវភៅពិសេសមួយក្បាល ធ្វើជាអំណោយសម្រាប់លោក ហ្ស៊ូ-ហ៊ូ (Xio-Hu) ជាស្វាមីជនជាតិចិន គាត់ក៏បានដើរទិញសៀវភៅភាសាចិន តែនៅកន្លែងលក់សៀវភៅមានតែព្រះគម្ពីរទេ ដែលមានភាសាចិន។ ទោះអ្នកទាំងពីរមិនមែនជាអ្នកជឿព្រះគ្រីស្ទ គាត់សង្ឃឹមថា ស្វាមីគាត់នឹងពេញចិត្តនឹងអំណោយមួយនេះ។ ពេលស្វាមីគាត់ឃើញព្រះគម្ពីរជាលើកដំបូងស្វាមីគាត់ក៏បានខឹង តែទីបំផុតគាត់ក៏បានយកព្រះគម្ពីរនោះមកអាន។ ពេលគាត់អាន គាត់ក៏បានទទួលការប៉ះពាល់ចិត្ត ដោយសេចក្តីពិតក្នុងទំព័រព្រះគម្ពីរ។ អ្នកស្រី គ្រីស្ទីន មិនសប្បាយចិត្តពេលដែលបានឃើញស្វាមីខ្លួនមានការផ្លាស់ប្តូរដូចនេះ ហើយក៏បានចាប់ផ្តើមអានព្រះគម្ពីរដែរ ដើម្បីស្វែងរកកំហុសក្នុងព្រះគម្ពីរ។ តែគាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលគាត់បានទទួលជឿព្រះយេស៊ូវ តាមរយៈការអានព្រះគម្ពីរផងដែរ។

សាវ័ក ប៉ុល បានស្គាល់អំណាចនៃព្រះគម្ពីរ ដែលកែប្រែជីវិតមនុស្ស។ កាលគាត់សរសេរសំបុត្រពីក្នុងគុកនៅទីក្រុងរ៉ូម គាត់បានជំរុញលោក ធីម៉ូថេ ជាសិស្ស ឲ្យនៅជាប់ក្នុងសេចក្តីដែលគាត់បានរៀនពីបទគម្ពីរទាំងប៉ុន្មាន តាំងពីតូចមក (២ធីម៉ូថេ ៣:១៤-១៥)។ សាវ័ក ប៉ុល ដឹងថា លោក ធីម៉ូថេ នឹងជួបការទាស់ប្រឆាំង និងការបៀតបៀន បានជាគាត់ចង់ឲ្យលោក ធីម៉ូថេ កាន់ខ្ជាប់តាមព្រះបន្ទូល ដើម្បីឲ្យអាចជម្នះបញ្ហាប្រឈម ដោយរកឃើញកម្លាំង និងប្រាជ្ញាក្នុងព្រះគម្ពីរ ខណៈពេលដែលគាត់ចំណាយពេលជញ្ជឹងគិតអំពីសេចក្តីពិតក្នុងព្រះបន្ទូល។

ព្រះទ្រង់បានបញ្ចេញអំណាចក្នុងព្រះគម្ពីរដល់យើង តាមរយៈព្រះវិញ្ញាណព្រះអង្គ។ ពេលណាយើងនៅជាប់នឹងព្រះបន្ទូល ព្រះអង្គនឹងកែប្រែយើងឲ្យមានលក្ខណៈកាន់តែដូចព្រះអង្គ។ គឺដូចដែលព្រះអង្គបានកែប្រែលោក ហ្ស៊ូ ហ៊ូ និងអ្នកស្រី គ្រីស្ទីន ផងដែរ។—Amy Boucher Pye

តើអ្នកមានការផ្លាស់ប្រែដូចម្តេចខ្លះ តាមរយៈការចំណាយពេលអាន និងជញ្ជឹងគិតព្រះបន្ទូលក្នុងព្រះគម្ពីរ? តើអ្នកបានដកពិសោធន៍នឹងអំណាចនៃព្រះបន្ទូលនៅពេលណា?

ឱព្រះដែលបានបង្កើតជីវិតមនុស្សទាំងអស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការប្រទានព្រះគម្ពីរ ធ្វើជាសៀវភៅដែលនាំមកនូវជីវិត។ សូមព្រះអង្គជួយទូលបង្គំឲ្យចុះចូលព្រះអង្គ ខណៈពេលដែលទូលបង្គំអានព្រះគម្ពីរ។

ឱព្រះយេហូវ៉ាអើយ ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់នៅកណ្តាលអស់ទាំងសាសន៍ ហើយនឹងច្រៀងទំនុកសរសើរថ្វាយដល់ព្រះនាមទ្រង់ (២សាំយ៊ូអែល ២២:៥០)។

ខ្ញុំបានឃើញសេចក្តីស្មោះត្រង់របស់ព្រះអង្គ

នៅក្នុងការដឹកនាំចក្រភពអង់គ្លេសក្នុងរយៈពេល៧០ឆ្នាំ ក្សត្រី អេលីហ្សាប៊ែតទី២ បានទទួលស្គាល់សៀវភៅជីវប្រវត្តិរបស់ព្រះនាងតែមួយក្បាលប៉ុណ្ណោះដែលគេបាននិពន្ធ ដោយព្រះនាងបានដាក់បញ្ចូលបុព្វកថាដែលព្រះនាងបានសរសេរផ្ទាល់ដៃ ក្រោមចំណងជើងថា ក្សត្រីជាអ្នកបម្រើ និងក្សត្រដែលព្រះនាងបានបម្រើ។ សៀវភៅនេះបានចេញផ្សាយនៅក្នុងការអបអរខួបកំណើតរបស់ព្រះនាង គម្រប់ព្រះជន្ម៩០ព្រះវស្សា ដោយបានរំឭកអំពីរបៀបដែលសេចក្តីជំនឿរបស់ព្រះនាងបានដឹកនាំព្រះនាង ខណៈពេលដែលព្រះនាងធ្វើការបម្រើប្រទេសជាតិ។ ក្នុងបុព្វកថានោះ ក្សត្រីអេលីហ្សាប៊ែតបានបង្ហាញចេញនូវការដឹងគុណ ចំពោះមនុស្សទាំងអស់ដែលបានអធិស្ឋានឲ្យព្រះនាង ហើយព្រះនាងបានអរព្រះគុណព្រះ សម្រាប់សេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេររបស់ព្រះអង្គ។ ព្រះនាងបានសន្និដ្ឋានថា «ខ្ញុំពិតជាបានឃើញសេចក្តីស្មោះត្រង់របស់ព្រះអង្គ»។

បន្ទូលដ៏សាមញ្ញរបស់ក្សត្រី អេលីហ្សាប៊ែត បានធ្វើឲ្យខ្ញុំនឹកចាំអំពីទីបន្ទាល់របស់បុរស និងស្ត្រីជាច្រើនក្នុងប្រវត្តិសាស្ត្រ ដែលបានដកពិសោធន៍ជាមួយនឹងការថែរក្សាដ៏ស្មោះត្រង់របស់ព្រះអម្ចាស់ ដោយផ្ទាល់ៗខ្លួនក្នុងជីវិតរបស់ពួកគេ។ ស្តេច ដាវីឌ ក៏បាននិពន្ធបទចម្រៀងដ៏ពីរោះ ដើម្បីឆ្លុះបញ្ចាំងអំពីជីវិតរបស់ទ្រង់ផងដែរ។ ក្នុងបទគម្ពីរ២សាំយ៊ូអែល ជំពូក២២ បទចម្រៀងរបស់ទ្រង់ក៏បានចែងអំពីសេចក្តីស្មោះត្រង់របស់ព្រះអម្ចាស់នៅក្នុងការការពារស្តេច ដាវីឌ ផ្តង់ផ្តង់ទ្រង់ និងថែមទាំងជួយសង្គ្រោះទ្រង់ ឲ្យរួចផុតពីគ្រោះថ្នាក់ (ខ.៣-៤, ៤៤)។ ស្តេច ដាវីឌ ក៏បានឆ្លើយតបចំពោះសេចក្តីស្មោះត្រង់របស់ព្រះអម្ចាស់ ដោយសរសេរថា ទ្រង់នឹងច្រៀងទំនុកតម្កើងថ្វាយដល់ព្រះនាមព្រះអម្ចាស់ (ខ.៥០)។

យើងមានការលើកទឹកចិត្តកាន់តែខ្លាំង ពេលណាយើងបានដឹងថា ព្រះអង្គបានបង្ហាញសេចក្តីស្មោះត្រង់នៅក្នុងរយៈពេលដ៏យូរក្នុងជីវិតរបស់នរណាម្នាក់ ប៉ុន្តែយើងក៏អាចរាប់ព្រះពររបស់ព្រះអង្គក្នុងពេលសព្វថ្ងៃ ដែលបានបង្ហាញតាមរយៈការថែរក្សារបស់ព្រះអង្គ។ ការអរព្រះគុណរបស់យើងប្រែក្លាយជាការសរសើរតម្កើង ពេលណាយើងទទួលស្គាល់ថា យើងមិនបានធ្វើដំណើរឆ្លងកាត់ពេលដ៏ពិបាកនៃជីវិតយើង ដោយសមត្ថភាពខ្លួនឯង តែដោយសារការថែរក្សាដ៏ស្មោះត្រង់នៃព្រះវរបិតាដែលសេចក្តីស្រឡាញ់យើង។—Lisa M. Samra

តើអ្នកបានឃើញព្រះអង្គបង្ហាញសេចក្តីស្មោះត្រង់ យ៉ាងដូចម្តេចខ្លះ? តើអ្នកអាចបង្ហាញការដឹងគុណដល់ព្រះអង្គ យ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដ្បិតក្នុងរដូវកាលនីមួយៗនៃជីវិត ទោះនៅពេលដែលមានអំណរ ឬទុក្ខព្រួយ ព្រះអង្គតែងតែបង្ហាញសេចក្តីស្មោះត្រង់ជានិច្ច។

ប៉ុន្តែ ខ្ញុំប្រាប់ថា ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ...ហើយត្រូវអធិស្ឋាន ឲ្យអ្នកណាដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នាវិញ (ម៉ាថាយ ៥:៤៤)។

ការស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក

សង្គ្រាមស៊ីវិលអាមេរិកបានបណ្តាលឲ្យប្រជាជនមានចិត្តជូរល្វីងចំពោះគ្នាទៅវិញទៅមក។ លោកប្រធានាធិបតី អ័ប្រាហាំ លីនខិន (Abraham Lincoln) បានយល់ឃើញថា គាត់គួរតែនិយាយពាក្យសម្តីល្អៗទៅកាន់ពួកខ្មាំងសត្រូវនៅក្នុងភាគខាងត្បូងនៃសហរដ្ឋអាមេរិក។ ស្ត្រីម្នាក់ដែលមានការភ្ញាក់ផ្អើលក៏បានសួរគាត់ថា ហេតុអ្វីគាត់និយាយពាក្យល្អៗទៅកាន់សត្រូវយ៉ាងដូចនេះ។ គាត់ក៏បានឆ្លើយតបថា «លោកស្រី ពេលដែលខ្ញុំធ្វើឲ្យសត្រូវក្លាយជាមិត្ត តើខ្ញុំមិនបានឈ្នះពួកគេទេឬ?» ប៉ុន្មានសតវត្សរ៍ក្រោយមក លោកគ្រូ ម៉ាទីន លូស័រ ឃីង ជេអរ (Martin Luther King Jr) បាននឹកចាំអំពីពាក្យសម្តីដ៏មានន័យនេះ ហើយក៏បានមានប្រសាសន៍ថា «នេះជាអំណាចនៃសេចក្តីស្រឡាញ់ដែលប្រោសលោះ»។

នៅក្នុងការអំពាវនាវឲ្យអ្នកជឿព្រះគ្រីស្ទស្រឡាញ់ខ្មាំងសត្រូវរបស់ខ្លួន លោក ឃីង ក៏បានមើលទៅការបង្រៀនរបស់ព្រះអង្គ។ គាត់បានកត់សម្គាល់ឃើញថា អ្នកជឿប្រហែលពិបាកស្រឡាញ់អ្នកដែលបៀតបៀនពួកគេ តែសេចក្តីស្រឡាញ់នេះកើតចេញពី «ការចុះចូលបំណងព្រះទ័យព្រះទាំងស្រុង និងជាប់លាប់។

លោក ឃីង ក៏បានលើកយកសេចក្តីបង្រៀនរបស់ព្រះយេស៊ូវនៅលើភ្នំមកចែកចាយ ដែលក្នុងនោះ ព្រះអង្គមានបន្ទូលថា «ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ... ហើយត្រូវអធិស្ឋាន ឲ្យអ្នកណាដែលធ្វើទុក្ខបៀតបៀនដល់អ្នករាល់គ្នាវិញ ដើម្បីឲ្យបានធ្វើជាកូនរបស់ព្រះវរបិតានៃអ្នករាល់គ្នា ដែលគង់នៅស្ថានសួគ៌» (ម៉ាថាយ ៥:៤៤-៤៥)។ ព្រះយេស៊ូវបានបង្រៀនផ្ទុយនឹងការបង្រៀនរបស់មនុស្សនៅសម័យនោះ ដែលឲ្យស្រឡាញ់តែអ្នកជិតខាង ហើយស្អប់ខ្មាំងសត្រូវ។ ផ្ទុយទៅវិញ ព្រះវរបិតាប្រទានកម្លាំងដល់កូនព្រះអង្គ ឲ្យអាចស្រឡាញ់អ្នកដែលទាស់ប្រឆាំងពួកគេ។

យើងប្រហែលមានអារម្មណ៍ថា យើងមិនអាចស្រឡាញ់សត្រូវរបស់យើងបានទេ តែពេលណាយើងទូលសូមព្រះអង្គជួយយើង ព្រះអង្គនឹងឆ្លើយតបការអធិស្ឋានរបស់យើង។ ព្រះអង្គប្រទានសេចក្តីក្លាហាន ឲ្យយើងឱបក្រសោបយកការបង្រៀននេះ ដ្បិតព្រះយេស៊ូវមានបន្ទូលថា «ព្រះទ្រង់អាចនឹងធ្វើកើតទាំងអស់» (១៩:២៦)។

—Amy Boucher Pye

តើនរណាជាខ្មាំងសត្រូវរបស់អ្នក? បើអ្នកមានអារម្មណ៍ពិបាកស្រឡាញ់មនុស្សដែលទាស់ប្រឆាំងអ្នក តើអ្នកអាចថ្វាយអារម្មណ៍នេះ ដល់ព្រះអង្គយ៉ាងដូចម្តេចខ្លះ?

ឱព្រះនៃសេចក្តីស្រឡាញ់ ព្រះអង្គបានបង្កើតទូលបង្គំ ក៏ដូចជាអ្នកដែលធ្វើឲ្យទូលបង្គំឈឺចាប់ ឲ្យដូចរូបអង្គទ្រង់។ សូមព្រះអង្គជួយទូលបង្គំ ឲ្យមានទឹកចិត្តចំពោះពួកគេ ដូចព្រះអង្គផងដែរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លេវីវិន័យ ១៣ និងម៉ាថាយ ២៦:២៦-៥០

ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ (អេសាយ ១:១៨)។

ព្រះលោហិតព្រះយេស៊ូវបានលាងសម្អាត

តាមធម្មតា អ្វីៗដែលមនុស្សបង្កើតមក មិនតែងតែមានមានពណ៌ក្រហមស្រាប់ទេ។ តើអ្នកអាចដាក់ពណ៌ក្រហមស្រស់ នៅលើរូបថ្លែបោ៉មនៅលើអាវយឺត ឬនៅក្នុងក្រែមលាបបបូរមាត់ ដោយរបៀបណា? នៅសម័យដើម គេចំរាញ់យកលក្ខណ៍ពណ៌ក្រហមចេញពីដីឥដ្ឋ ឬថ្មពណ៌ក្រហម។ នៅក្នុងទសវត្សរ៍ឆ្នាំ១៤០០ ជនជាតិអាហ្សថេក បានច្នៃបង្កើតថ្នាំពណ៌ក្រហមចេញពីចៃពណ៌សរ ដែលនៅជាប់ដើមដំបងយក្ស ព្រោះចៃទាំងនោះមានឈាមពណ៌ក្រហម។ សព្វថ្ងៃនេះ គេបានប្រើសត្វល្អិតតូចៗទាំងនោះ ដើម្បីផលិតថ្នាំពណ៌ក្រហមសម្រាប់ផ្តត់ផ្តង់នៅទូទាំងពិភពលោក។

ក្នុងព្រះគម្ពីរពណ៌ក្រហម គឺពណ៌របស់ក្សត្រ ហើយក្នុងន័យធៀប វាជានិមិត្តសញ្ញាតំណាងឲ្យបាប និងក្តីអាម៉ាស់។ ជាងនេះទៅទៀត វាជាពណ៌របស់ឈាម។ កាលពួកទាហាន ដោះព្រះពស្ត្រព្រះយេស៊ូវចេញ ហើយយកអាវក្រហមមកបំពាក់ឲ្យទ្រង់វិញ (ម៉ាថាយ ២៧:២៨) និមិត្តសញ្ញាទាំងបីនោះបានបង្ហាញចេញនៅក្នុងរូបភាពពណ៌ក្រហមដ៏ឈឺចាប់ ដោយគេចំអកឲ្យព្រះអង្គថា ព្រះអង្គជាក្សត្រ គេបំពាក់សេចក្តីអាម៉ាស់ពីលើព្រះអង្គ ហើយពណ៌ក្រហមនោះ ជានិមិត្តសញ្ញាតំណាងឲ្យឈាម ដែលនឹងហូរចេញពីព្រះកាយព្រះអង្គក្នុងពេលដ៏ខ្លីខាងមុខ។ ប៉ុន្តែ កណ្ឌគម្ពីរអេសាយបានថ្លែងទំនាយអំពីព្រះយេស៊ូវដែលបំពាក់ទៅដោយពណ៌ក្រហម នឹងរំដោះយើងឲ្យរួចផុតពីបាបមានពណ៌ក្រហមទែង ដែលប្រឡាក់យើង។ គឺដូចដែលព្រះអម្ចាស់មានបន្ទូលថា «ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ» (១:១៨)។

ចំណុចមួយទៀតដែលគួរឲ្យចាប់អារម្មណ៍របស់សត្វល្អិតនៅលើដើមដំបងយក្ស ដែលគេយកទៅផលិតថ្នាំពណ៌ក្រហម។ តាមពិតពួកវាមានពណ៌សរនៅខាងក្រៅ។ ទាល់តែគេយកពួកវាទៅកិនទើបពួកវាចេញឈាមពណ៌ក្រហម។ រឿងនេះបានរំឭកយើង អំពីព្រះបន្ទូលហោរាអេសាយដែលបានចែងថា ទ្រង់ «ត្រូវគេវាយជាំដោយព្រោះអំពើទុច្ចរិតរបស់យើងទេ» (អេសាយ ៥៣:៥)។

ព្រះយេស៊ូវមិនមានបាបសោះ តែបានយាងមកសង្គ្រោះយើង ដែលមានបាបពណ៌ក្រហមទែង។ អ្នកឃើញទេក្នុងការសុគតដ៏ឈឺចាប់របស់ព្រះយេស៊ូវ ព្រះអង្គបានស៊ូទ្រាំងនឹងបាបពណ៌ក្រហមទែងរបស់យើង ដើម្បីឲ្យយើងបានសរដូចព្រិលៗ—Kenneth Petersen

តើ «អំពើបាប ...ដូចជាពណ៌ក្រហមទែង» បានប្រឡាក់ជីវិតអ្នកដូចម្តេចខ្លះ? តើព្រះយេស៊ូវអាចស្អាងអ្នកឡើងវិញ និងសម្អាតឲ្យអ្នកស្អាតដោយរបៀបណា?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការចាត់ព្រះរាជបុត្រា ព្រះយេស៊ូវ ដើម្បីប្រទានព្រះគុណនៃសេចក្តីសង្គ្រោះតាមរយៈព្រះលោហិតរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លេវីវិន័យ ១៤ និងម៉ាថាយ ២៦:៥១-៧៥

បើខ្ញុំប្រគល់រូបកាយខ្ញុំទៅឲ្យគេដុត តែគ្មានសេចក្តីស្រឡាញ់ នោះគ្មានប្រយោជន៍ដល់ខ្ញុំសោះ (១កូរិនថូស ១៣:៣)។

បានទទួលការបណ្តាលចិត្តពីសេចក្តីស្រឡាញ់

លោក ជីម (Jim) និងអ្នកស្រី ឡានីដា (Laneeda) គឺជាគូសង្សារ កាលរៀននៅមហាវិទ្យាល័យជាមួយគ្នា។ ពួកគេក៏បានរៀបការ ហើយជីវិតមានភាពសប្បាយរីករាយអស់ជាច្រើនឆ្នាំ។ បន្ទាប់មក អ្នកស្រី ឡានីដា ក៏បានចាប់ផ្តើមបញ្ចេញអាកប្បកិរិយាចម្លែក ដោយគាត់ស្រាប់តែរង្វេងផ្លូវ ហើយភ្លេចការណាត់ជួប។ ពេទ្យក៏បានពិនិត្យឃើញថា គាត់ស្ថិតក្នុងដំណាក់កាលដំបូងនៃជំងឺវង្វេងក្នុងវ័យ ៤៧ឆ្នាំ។ បន្ទាប់ពី លោក ជីម បានធ្វើការបម្រើគាត់ ជាអ្នកថែទាំបឋម លោក ជីម អាចនិយាយបានថា ជំងឺវង្វេងរបស់ភរិយាគាត់បានផ្តល់ឱកាសឲ្យគាត់ស្រឡាញ់ និងបម្រើភរិយាគាត់។ កាលលោក ជីម និយាយពាក្យសច្ចាក្នុងពេលរៀបការថា គាត់ព្រមទទួលយកអ្នកស្រី ឡានីដា ជាភរិយា គាត់មិននឹកស្មានថា គាត់នឹងមានឱកាសបម្រើភរិយាខ្លួន ដោយសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅដូចនេះទេ។

កាលសាវ័ក ប៉ុល ពន្យល់អំពីអំណោយនៃព្រះវិញ្ញាណបរិសុទ្ធ គាត់ក៏បានសរសេរយ៉ាងក្បោះក្បាយ អំពីគុណធម៌នៃសេចក្តីស្រឡាញ់ (១កូរិនថូស ១៣)។ គាត់បានបង្ហាញភាពខុសគ្នារវាងការបម្រើដើម្បីបំពេញតួនាទី និងការបម្រើដោយចិត្តដែលមានក្តីស្រឡាញ់។ គាត់ថា ការនិយាយដ៏អស្ចារ្យដែលគ្មានសេចក្តីស្រឡាញ់គឺប្រៀបដូចជាសម្លេងរំខានដែលគ្មានន័យអ្វីឡើយ (ខ.១)។ «ហើយបើខ្ញុំប្រគល់រូបកាយខ្ញុំទៅឲ្យគេដុត តែគ្មានសេចក្តីស្រឡាញ់ នោះគ្មានប្រយោជន៍ដល់ខ្ញុំសោះ» (ខ.៣)។ នៅចុងបញ្ចប់ សាវ័ក ប៉ុល ក៏បានមានប្រសាសន៍ថា «សេចក្តីដែលវិសេសជាងគេ គឺជាសេចក្តីស្រឡាញ់» (ខ.១៣)។

ការយល់ដឹងរបស់លោក ជីម អំពីសេចក្តីស្រឡាញ់ និងការបម្រើមានភាពស៊ីជម្រៅ ខណៈពេលដែលគាត់បម្រើប្រពន្ធគាត់។ មានតែសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ និងមិនចេះប្រែប្រួលប៉ុណ្ណោះ ដែលអាចជួយឲ្យគាត់មានកម្លាំង ដើម្បីមើលថែភរិយាគាត់ជារៀងរាល់ថ្ងៃ។ សរុបមក សេចក្តីស្រឡាញ់ដែលព្រះទ្រង់មានចំពោះយើង ជាគំរូនៃសេចក្តីស្រឡាញ់ដ៏ឥតខ្ចោះ ដែលមានការលះបង់ ជាមូលហេតុដែលព្រះអង្គចាត់ព្រះយេស៊ូវ ឲ្យយាងមកសុគត ដើម្បីលោះបាបយើង (យ៉ូហាន ៣:១៦)។ ការលះបង់ដោយសេចក្តីស្រឡាញ់របស់ព្រះអង្គនាំមកនូវការផ្លាស់ប្តូរ ក្នុងជីវិតយើងជារៀងរហូត។—Karen Pimpo

តើអ្នកបានព្យាយាមបម្រើអ្នកដទៃ ដោយគ្មានសេចក្តីស្រឡាញ់ដូចម្តេចខ្លះ? តើសេចក្តីស្រឡាញ់ចំពោះព្រះ និងអ្នកដទៃបានបណ្តាលចិត្តអ្នក យ៉ាងដូចម្តេចខ្លះនៅថ្ងៃនេះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានស្រឡាញ់ទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំឲ្យប្រព្រឹត្ត ដោយចិត្តដែលមានក្តីស្រឡាញ់ជារៀងរាល់ថ្ងៃ។

Daily Manna 2026_Content Enhance.indd 51 17/11/25 1:44 in the afternoon

ផលនៃសេចក្តីសុភាព និងសេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះគឺជាទ្រព្យសម្បត្តិ កិត្តិសព្ទ និងជីវិត (សុភាសិត ២២:៤)។

សារៈសំខាន់នៃការបន្ទាបខ្លួន

អ្នកស្រី ឃែរី (Carrie) បានលះបង់ពេលវេលាជាច្រើនម៉ោង ដើម្បីអាជីពរបស់គាត់មិនខុសពីគ្រូបង្រៀនជាច្រើនទៀត ដោយគាត់កែក្រដាសប្រឡងរបស់សិស្សជាញឹកញាប់ និងទំនាក់ទំនងជាមួយសិស្ស និងឪពុកម្តាយរបស់ពួកគេក្រៅម៉ោងធ្វើការ។ ក្នុងការប្រឹងប្រែងនេះ គាត់បានពឹងផ្អែកទៅលើមិត្តភាព និងជំនួយរបស់មិត្តរួមការងារ ហើយការសហការគ្នាបានជួយឲ្យគាត់កាន់តែមានភាពងាយស្រួលនៅក្នុងការងារដែលមានបញ្ហាប្រឈម។ ការស្រាវជ្រាវអំពីគ្រូបង្រៀន ក្នុងពេលថ្មីៗនេះបានរកឃើញថា ការសហការគ្នាមានអត្ថប្រយោជន៍កាន់តែខ្លាំង នៅពេលណាអ្នកដែលយើងធ្វើការជាមួយ បានបង្ហាញការបន្ទាបខ្លួន។ ពេលណាមិត្តរួមការងាររបស់យើងព្រមទទួលស្គាល់ភាពកម្សោយរបស់ខ្លួន នោះអ្នកដទៃមានអារម្មណ៍ថា មានសុវត្ថិភាពនៅក្នុងការចែកចាយចំណេះដឹងដល់គ្នាទៅវិញទៅមក ដោយជួយមនុស្សម្នាក់ៗនៅក្នុងក្រុមយ៉ាងមានប្រសិទ្ធភាព។

ព្រះគម្ពីរបានបង្រៀនយើងអំពីសារៈសំខាន់នៃការបន្ទាបខ្លួន ដែលមិនគ្រាន់តែមានប្រយោជន៍សម្រាប់ការសហការគ្នាប៉ុណ្ណោះទេ។ «សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា» គឺជាការយល់ដឹងដ៏ត្រឹមត្រូវថា ខ្លួនយើងជានរណា ធៀបនឹងសម្រស់ ព្រះចេស្តា និងភាពអស្ចារ្យរបស់ព្រះអង្គ។ សេចក្តីកោតខ្លាចនេះ នាំឲ្យយើងមានទ្រព្យសម្បត្តិ កិត្តិសព្ទ និងជីវិត (សុភាសិត ២២:៤)។ ការបន្ទាបខ្លួននាំឲ្យយើងរស់នៅក្នុងសហគមន៍ តាមរបៀបដែលមានប្រយោជន៍ដល់នគរព្រះ គឺមិនគ្រាន់តែដល់លោកីយ៍ ព្រោះយើងបានព្យាយាមស្វែងរកប្រយោជន៍អ្នកដទៃ។

យើងកោតខ្លាចព្រះ មិនមែនដើម្បីឲ្យបាន «ទ្រព្យសម្បត្តិ កិត្តិសព្ទ និងជីវិត» សម្រាប់ខ្លួនឯងនោះឡើយ ព្រោះនេះមិនមែនជាការបន្ទាបខ្លួនទាល់តែសោះ។ ផ្ទុយទៅវិញ យើងយកតម្រាប់តាមព្រះយេស៊ូវ ដែល «បានលះបង់ព្រះអង្គទ្រង់ មកយករូបភាពជាបាវបំរើវិញ» (ភីលីព ២:៧)។ ដូចនេះ យើងក៏អាចក្លាយជាផ្នែកមួយនៃរូបកាយព្រះគ្រីស្ទ ដែលរួបរួមគ្នាដោយការបន្ទាបខ្លួន ដើម្បីធ្វើការថ្វាយព្រះអង្គ ថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ និងនាំព្រះរាជសារអំពីជីវិត ទៅប្រាប់លោកីយ៍នៅជុំវិញយើង។—Kirsten Holmberg

តើការបន្ទាបខ្លួនមានន័យដូចម្តេចខ្លះសម្រាប់អ្នក? តើអ្នកបានឃើញការបន្ទាបខ្លួនរបស់មនុស្សម្នាក់មានប្រយោជន៍ចំពោះអ្នកដទៃដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមលះបង់សេចក្តីអំនួតរបស់ទូលបង្គំ ដើម្បីព្រះអង្គ។

Daily Manna 2026_Content Enhance.indd 52 17/11/25 1:44 in the afternoon

គ្មានអ្នកណាមានសេចក្តីស្រឡាញ់ជំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួកសំឡាញ់របស់ខ្លួននោះទេ (យ៉ូហាន ១៥:១៣)។

ស្រឡាញ់ដូចព្រះយេស៊ូវ

គេ បានធ្វើការពិពណ៌នាអំពីលោក ដន ហ្គីសេព បេរ៉ាដេលី (Don Guiseppe Berardelli) ជាអ្នកក្រុងខាស៊ីងហ្គោ ប្រទេសអ៊ីតាលីថា គាត់ជាមនុស្សដែលមនុស្សគ្រប់គ្នាស្រឡាញ់។ លោក ដន ជាមនុស្សគួរឲ្យស្រឡាញ់ ដែលចូលចិត្តជិះម៉ូតូកញ្ចាស់មួយគ្រឿងក្នុងទីក្រុង ហើយតែងតែនិយាយស្វាគមន៍គេថា «សូមឲ្យសន្តិភាព និងសេចក្តីល្អកើតមានដល់អ្នក»។ គាត់បានធ្វើការ ដោយមិនគិតពីការហត់នឿយ ដើម្បីយកអសារអ្នកដទៃ។ ប៉ុន្តែ ក្នុងឆ្នាំចុងក្រោយនៃជីវិតគាត់ គាត់មានបញ្ហាសុខភាព ដែលមានសភាពធ្ងន់ធ្ងរកាន់តែខ្លាំងនៅពេលដែលគាត់ឆ្លងជំងឺកូវីដ១៩។ សហគមន៍របស់គាត់ក៏បានឆ្លើយតប ដោយរៃលុយគ្នាទិញម៉ាស៊ីនជំនួយការដកដង្ហើមមួយគ្រឿងសម្រាប់គាត់។ ប៉ុន្តែ នៅពេលដែលស្ថានភាពរបស់គាត់កាន់តែមានសភាពធ្ងន់ធ្ងរ គាត់បានបដិសេធន៍មិនព្រមប្រើម៉ាស៊ីនដកដង្ហើមនោះ ហើយក៏បានសម្រេចចិត្តប្រគល់ម៉ាស៊ីននោះទៅអ្នកជំងឺដែលមានវ័យក្មេងជាងគាត់ ដែលកំពុងត្រូវការវា។ ការបដិសេធន៍របស់គាត់មិនបានធ្វើឲ្យនរណាម្នាក់មានការភ្ញាក់ផ្អើលឡើយ ព្រោះគាត់តែងតែមានចរិកលក្ខណៈជាមនុស្សដែលមានក្តីស្រឡាញ់ និងត្រូវបានគេកោតសរសើរថា មានសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ។

ការស្រឡាញ់អ្នកដទៃ គឺជាប្រធានបទដ៏សំខាន់ ដែលសាវ័ក យ៉ូហាន លើកយកមកនិយាយម្តងហើយម្តងទៀតក្នុងកណ្ឌគម្ពីរដំណឹងល្អ។ ការស្រឡាញ់អ្នកដទៃ និងការរស់នៅជាមនុស្សដែលគេស្រឡាញ់ គឺប្រៀបដូចជាជួងព្រះវិហារ ដែលបន្លឺសម្លេងទាំងយប់ថ្ងៃ ទោះស្ថិតក្នុងអាកាសធាតុបែបណាក៏ដោយ។ ហើយបទគម្ពីរយ៉ូហានជំពូក១៥ ក៏បានបង្ហាញចំណុចខ្ពស់បំផុតនៃសេចក្តីស្រឡាញ់ គឺមិនមែននៅពេលដែលមនុស្សគ្រប់គ្នាស្រឡាញ់យើងនោះទេ តែការស្រឡាញ់ដែលមានការលះបង់ គឺជាសេចក្តីស្រឡាញ់ធំបំផុត ព្រោះ «គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិត ជំនួសពួកសំឡាញ់របស់ខ្លួននោះទេ» (ខ.១៣)។

គំរូនៃក្តីស្រឡាញ់របស់មនុស្សដែលមានការលះបង់ តែងតែបណ្តាលចិត្តយើងឲ្យស្រឡាញ់អ្នកដទៃផងដែរ តែមិនអាចប្រៀបធ្ងឹមនឹងសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអម្ចាស់បានឡើយ។ ប៉ុន្តែ ចូរយើងកុំភ្លេចអនុវត្តតាមការបង្គាប់របស់ព្រះយេស៊ូវ ឲ្យយើង ស្រឡាញ់គ្នាទៅវិញទៅមក ដូចដែលព្រះអង្គបានស្រឡាញ់យើង (ខ.១២)។ ជាការពិតណាស់ ចូរយើងស្រឡាញ់មនុស្សទាំងអស់។—John Blasé

រវាងការស្រឡាញ់មនុស្សទាំងអស់ និងការដែលមនុស្សទាំងអស់ស្រឡាញ់យើង តើពេលខ្លះអ្នកមានការយល់ច្រឡំអំពីសេចក្តីទាំងពីរនេះទេ? តើហេតុអ្វី? តើការលះបង់ជីវិតដើម្បីមិត្តសំឡាញ់មានលក្ខណៈដូចម្តេចខ្លះក្នុងពេលបច្ចុប្បន្ន?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យស្រឡាញ់អ្នកដទៃ ដូចព្រះអង្គស្រឡាញ់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | លេវីវិន័យ ១៩-២០ និងម៉ាថាយ ២៧:៥១-៦៦

កំឡាំងអញបានពេញខ្នាត ដោយសេចក្ដីកម្សោយ (២កូរិនថូស ១២:៩)។

ភាពពេញវ័យក្នុងព្រះយេស៊ូវ

កាលពីក្មេង ខ្ញុំយល់ឃើញថា មនុស្សពេញវ័យមានប្រាជ្ញា ហើយមិនអាចធ្វើខុស។ ខ្ញុំគិតថា ពួកគេតែងតែដឹងថា ពួកគេត្រូវធ្វើអ្វី។ ថ្ងៃមួយ ពេលខ្ញុំធំឡើង ខ្ញុំក៏ដឹងថា ត្រូវធ្វើអ្វីផងដែរ។ ប៉ុន្តែ ពេលខ្ញុំពេញវ័យ កាលប៉ុន្មានឆ្នាំមុន ថ្ងៃមួយអ្វីដែលខ្ញុំរៀនបាននោះ គឺខ្ញុំនៅតែមិនដឹងថា ខ្ញុំត្រូវធ្វើអ្វីទេ។ នៅពេលដែលក្រុមគ្រួសារមានមនុស្សឈឺ ឬខ្ញុំមានបញ្ហានៅកន្លែងធ្វើការ ឬក៏មានការប៉ះទង្គិចក្នុងទំនាក់ទំនង ខ្ញុំតែងតែខិតខំគ្រប់គ្រងស្ថានការណ៍ និងស្វែងរកកម្លាំង ហើយទីបំផុតខ្ញុំគ្មានជម្រើសអ្វី ក្រៅពីបិទភ្នែក ហើយនិយាយខ្សឹបៗថា «ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំ។ ទូលបង្គំមិនដឹងថាត្រូវធ្វើអ្វីទេនៅពេលនេះ»។

សាវ័ក ប៉ុល ក៏យល់អំពីអារម្មណ៍ ដែលមានភាពកម្សោយផងដែរ។ «បន្លា» នៅក្នុងជីវិតគាត់ ដែលអាចជាជំងឺផ្លូវកាយ បានបណ្តាលឲ្យគាត់មានភាពនឿយណាយ និងការឈឺចាប់យ៉ាងខ្លាំង។ ទោះជាយ៉ាងណាក៏ដោយ តាមរយៈបន្លានោះសាវ័ក ប៉ុល បានដកពិសោធន៍ជាមួយនឹងសេចក្តីស្រឡាញ់ ព្រះបន្ទូលសន្យា និងព្រះពររបស់ព្រះ ដែលមានគ្រប់គ្រាន់សម្រាប់ឲ្យគាត់ស៊ូទ្រាំ និងជម្នះទុក្ខលំបាករបស់គាត់ (២កូរិនថូស ១២:៩)។ គាត់ដឹងថា ការមានភាពកម្សោយផ្តាល់ខ្លួនមិនមានន័យថា គាត់បរាជ័យខាងវិញ្ញាណនោះទេ។ ពេលណាយើងចុះចូលនឹងព្រះ ដោយទំនុកចិត្ត ព្រះអង្គនឹងប្រើភាពកម្សោយរបស់យើងជាឧបករណ៍ ដើម្បីធ្វើការនៅក្នុង និងតាមរយៈកាលៈទេសៈទាំងនោះ (ខ.៩-១០)។

ភាពពេញវ័យមិនមានន័យថា យើងដឹងអ្វីៗទាំងអស់នោះទេ។ ជាការពិតណាស់ យើងមានប្រាជ្ញាជាងមុន ពេលណាយើងមានវ័យកាន់តែចាស់ ប៉ុន្តែជាញឹកញាប់ភាពកម្សោយរបស់យើងច្រើនតែបានបង្ហាញថា យើងមានភាពកម្សោយប៉ុណ្ណា។ កម្លាំងពិតប្រាកដរបស់យើង គឺមាននៅក្នុងព្រះគ្រីស្ទ «ដ្បិតកាលណាខ្ញុំខ្សោយ នោះខ្ញុំមានកំឡាំងយ៉ាងចំណានវិញ» (ខ.១០)។ ជាការពិតណាស់ «ភាពពេញវ័យ» គឺមានន័យថា យើងស្គាល់ទុកចិត្ត និងស្តាប់បង្គាប់ព្រះអង្គ ហើយទទួលយកកម្លាំងពីព្រះអង្គ ពេលណាយើងដឹងថា យើងត្រូវការជំនួយរបស់ព្រះអង្គ។—Karen Huang

តើមានទុក្ខលំបាកអ្វីខ្លះ ដែលធ្វើឲ្យអ្នកដឹងថា អ្នកមានភាពទន់ខ្សោយ? តើអ្នកអាចស្តាប់បង្គាប់តាមការដឹកនាំរបស់ព្រះអង្គដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានធ្វើជាជំនួយ និងកម្លាំង ទូលបង្គំ។

Daily Manna 2026_Content Enhance.indd 54 17/11/25 1:44 in the afternoon

គឺមុនដែលអស់ទាំងភ្នំបានកើតឡើង... ចាប់តាំងពីអស់កល្ប រៀងទៅដល់អស់កល្បជានិច្ច នោះគឺទ្រង់ហើយជាព្រះ (ទំនុកតម្កើង ៩០:២)។

នៅក្នុងព្រះហស្តនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ

បន្ទាប់ពីសុខភាពខ្ញុំមានការចុះខ្សោយសារជាថ្មី ខ្ញុំមានការភ័យខ្លាច ចំពោះរឿងដែលមើលមិនឃើញ និងមិនអាចគ្រប់គ្រងបាននៅពេលអនាគត។ ថ្ងៃមួយ នៅពេលដែលខ្ញុំអានអត្ថបទទស្សនាវដ្តីវិទ្យាសាស្ត្រ ខ្ញុំរៀនសូត្របានថា អ្នកវិទ្យាសាស្ត្របានធ្វើការសិក្សាអំពីការកើនឡើងនៃល្បឿនរបស់ «ផែនដី នៅក្នុងការវិលជុំវិញខ្លួនឯង» ហើយក៏បានប្រកាសថា ផែនដី «មានចលនាយោលចុះឡើងៗ» ហើយ «កំពុងវិលកាន់តែញាប់»។ ពួកគេនិយាយថា ផែនដីបានវិលឿនជាងមុន១វិនាទីក្នុងមួយថ្ងៃ បានជាពួកគេអាចស្នើឲ្យគេដកយៈពេល១វិនាទីចេញពីម៉ោងអន្តរជាតិ។ ការបាត់យៈពេល១វិនាទីស្តាប់មើលទៅដូចជាមិនច្រើនទេ តែការដឹងថា ការវិលជុំវិញរបស់ផែនដីអាចមានការផ្លាស់ប្តូរ ហាក់ដូចជារឿងធំដុំមួយសម្រាប់ខ្ញុំ។ បញ្ហានេះបានរំឭកខ្ញុំថា អស្ថេរភាពតែបន្តិចកើតមានខ្ញុំជីវិតខ្ញុំ អាចធ្វើឲ្យខ្ញុំមានអារម្មណ៍ថាបាត់ភាពនឹងនរ។ ទោះជាយ៉ាងណាក៏ដោយ ការដឹងថា ព្រះទ្រង់កំពុងគ្រប់គ្រងលើអ្វីៗទាំងអស់បានជួយឲ្យខ្ញុំទុកចិត្តព្រះអង្គ ទោះរឿងដែលមើលមិនឃើញមានលក្ខណៈគួរឲ្យភ័យខ្លាច ឬកាលៈទេសៈរបស់ខ្ញុំហាក់ដូចជាមានភាពរង្គោះរង្គើរយ៉ាងណាក៏ដោយ។

ក្នុងបទគម្ពីរទំនុកតម្កើង ជំពូក៩០ លោក ម៉ូសេ បានពោលថា «មុនដែលអស់ទាំងភ្នំបានកើតឡើង ក្នុងកាលដែលទ្រង់មិនទាន់បង្កើតផែនដី និងមនុស្សលោកនៅឡើយ ចាប់តាំងពីអស់កល្បរៀងទៅដល់អស់កល្បជានិច្ច នោះគឺទ្រង់ហើយជាព្រះ» (ខ.២)។ លោក ម៉ូសេ បានទទួលស្គាល់ថា ព្រះទ្រង់មានព្រះចេស្តា ការគ្រប់គ្រង និងអំណាច គ្មានដែនកំណត់មកលើស្នាព្រះហស្តទាំងអស់ ហេតុនេះហើយគាត់ក៏បានប្រកាសថា ពេលវេលាមិនមានអំណាចមកលើព្រះអម្ចាស់បានទេ (ខ.៣-៦)។

ខណៈពេលដែលយើងព្យាយាមស្វែងយល់អំពីព្រះ និងពិភពលោកដ៏អស្ចារ្យដែលព្រះអង្គបានបង្កើត យើងនឹងបានដឹងថា ព្រះអង្គបានបន្តគ្រប់គ្រងយ៉ាងឥតខ្ចោះមកលើពេលវេលា និងអ្វីៗគ្រប់យ៉ាងដែលព្រះអង្គបានបង្កើត។ យើងក៏អាចទុកចិត្តថា ព្រះអង្គនឹងគ្រប់គ្រងមកលើអ្វីៗដែលយើងមើលមិនឃើញនៅពេលអនាគតផងដែរ។ ស្នាព្រះហស្តទាំងអស់របស់ព្រះអង្គនៅតែស្ថិតក្រោមការគ្រប់គ្រងក្នុងព្រះហស្តព្រះអង្គ។—Xochitl Dixon

តើការដឹងថា ព្រះទ្រង់គ្រប់គ្រងពេលវេលា និងអ្វីៗទាំងអស់បានជួយអ្នកឲ្យទុកចិត្តព្រះអង្គយ៉ាងដូចម្តេចខ្លះ ពេលអ្នកមានការភ័យខ្លាច? តើអ្នកអាចថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ តាមរយៈពេលវេលាដែលព្រះអង្គប្រទានអ្នកនៅថ្ងៃនេះ ដូចម្តេចខ្លះ?

ឱព្រះអាទិករ ដែលមិនចេះប្រែប្រួល ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការគ្រប់គ្រងពេលវេលារបស់ទូលបង្គំគ្រប់វិនាទីក្នុងព្រះហស្តព្រះអង្គ។

ចូរអរសប្បាយជានិច្ច ចូរអធិស្ឋានឥតឈប់ឈរ ចូរអរព្រះគុណក្នុងគ្រប់ការទាំងអស់ ពីព្រោះព្រះទ្រង់សព្វព្រះហឫទ័យឲ្យអ្នកពាល់គ្នាធ្វើយ៉ាងដូច្នោះ ដោយនូវព្រះគ្រីស្ទយេស៊ូវ (១ថែស្សាឡូនិច ៥:១៦-១៨)។

កត្តាជំរុញចិត្តឲ្យអធិស្ឋាន

មិត្តរួមការងារម្នាក់ធ្លាប់ប្រាប់ខ្ញុំថា ជីវិតនៃការអធិស្ឋានរបស់គាត់មានការរីកចម្រើន ដោយសារអ្នកគ្រប់គ្រងរបស់យើង។ ខ្ញុំមានការភ្ញាក់ផ្អើលពេលដែលបានឮដូច្នេះ ដោយនឹកស្មានថា អ្នកដឹកនាំដ៏ពិបាករបស់យើងបានចែកចាយការលើកទឹកចិត្តដល់គាត់ ហើយបានបង្រៀនគាត់អំពីការអធិស្ឋាន។ តាមពិត ខ្ញុំបានគិតខុស។ គាត់ក៏បានពន្យល់ថា រៀងរាល់ពេលគាត់ឃើញអ្នកគ្រប់គ្រងដើរមក គាត់តែងតែអធិស្ឋាន។ ពេលអធិស្ឋានរបស់គាត់មានការរីកចម្រើន ព្រោះគាត់បានអធិស្ឋានកាន់តែច្រើន មុនពេលគាត់សន្ទនាជាមួយអ្នកគ្រប់គ្រង។ គាត់ដឹងថា គាត់ត្រូវការជំនួយមកពីព្រះក្នុងទំនាក់ទំនងដ៏ពិបាកជាមួយអ្នកគ្រប់គ្រងរបស់គាត់នៅកន្លែងធ្វើការ ហើយគាត់ក៏បានអធិស្ឋានទៅរកព្រះអង្គកាន់តែខ្លាំង ដោយសារបញ្ហានេះ។

ការដែលមិត្តរួមការងាររបស់ខ្ញុំអធិស្ឋានក្នុងអំឡុងពេលដែលមានទំនាក់ទំនងដ៏ពិបាក គឺបានរំឭកខ្ញុំអំពីមេរៀនក្នុងបទគម្ពីរ១ថែស្សាឡូនិច ដែលសាវ័ក ប៉ុល បានរំឭកអ្នកជឿព្រះយេស៊ូវ ឲ្យអធិស្ឋានឥតឈប់ឈរ ហើយឲ្យអរព្រះគុណក្នុងគ្រប់កាលៈទេសៈ (៥:១៧-១៨)។ ទោះយើងជួបប្រទះបញ្ហាអ្វីក៏ដោយ ក៏ការអធិស្ឋានរបស់យើង គឺជាការអនុវត្តន៍ដ៏ល្អបំផុតក្នុងការរស់នៅ។ ការអធិស្ឋានជួយយើងឲ្យបន្តមានការប្រកបស្និទ្ធស្នាលជាមួយព្រះអង្គ ហើយអនុញ្ញាតឲ្យព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើង (កាឡាទី ៥:១៦) ជាជាងពឹងផ្អែកទៅលើគំនិតរបស់យើងជាមនុស្ស។ ការនេះក៏បានជួយយើងឲ្យរស់នៅជាមួយគ្នា ដោយមេត្រីភាព (១ថែស្សាឡូនិច ៥:១៣) ទោះយើងប្រឈមមុខដាក់ការប៉ះទង្គិចក៏ដោយ។

ខណៈពេលដែលព្រះទ្រង់ជួយយើង យើងអាចអរសប្បាយក្នុងព្រះអង្គ និងអធិស្ឋានអំពីរឿងគ្រប់យ៉ាង ហើយអរព្រះគុណព្រះអង្គជាញឹកញាប់។ ហើយការនោះនឹងជួយយើងឲ្យរស់នៅ ដោយមេត្រីភាពជាមួយបងប្អូនក្នុងព្រះគ្រីស្ទ។—Katara Patton

តើមានទំនាក់ទំនងអ្វី ដែលអ្នកចាំបាច់ត្រូវអធិស្ឋានឲ្យកាន់តែញឹកញាប់? តើការអធិស្ឋានរបស់អ្នកបានជួយអ្នកដើរតាមការដឹកនាំរបស់ព្រះ ជាជាងដើរតាមគំនិតមនុស្ស?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំឲ្យនឹកចាំ និងអធិស្ឋានជាប់ជានិច្ច ខណៈពេលដែលទូលបង្គំព្យាយាមរស់នៅ ដោយភាពសុខដុមជាមួយអ្នកដទៃ។

Daily Manna 2026_Content Enhance.indd 56 17/11/25 1:44 in the afternoon

ឱព្រះយេហូវ៉ាអើយ តើទ្រង់នឹងភ្លេចទូលបង្គំដល់កាលណាទៀត តើដល់អស់កល្បឬអី? (ទំនុកតម្កើង ១៣:១)

ព្រះអង្គឆ្លើយតប តាមព្រះទ័យប្រកបដោយប្រាជ្ញា

ក្រភពអង់គ្លេសជាទឹកដី ដែលមានការផ្សព្វផ្សាយប្រវត្តិសាស្ត្រដ៏សំបូរបែប។ ទោះអ្នកទៅដល់កន្លែងណាក៏ដោយ អ្នកនឹងឃើញផ្លាកដែលគេសរសេរអក្សរ ដើម្បីផ្តល់កិត្តិយសដល់បុគ្គលល្បីៗក្នុងប្រវត្តិសាស្ត្រ ឬដើម្បីរំឭកទីកន្លែងប្រវត្តិសាស្ត្រ ដែលធ្លាប់មានព្រឹត្តិការណ៍សំខាន់ៗកើតឡើង។ ប៉ុន្តែ ក្នុងចំណោមផ្លាកសញ្ញាទាំងនោះមានផ្លាកសញ្ញាមួយដែលមានលក្ខណៈចម្លែក។ នៅទីក្រុងស៊ែនវិច ប្រទេសអង់គ្លេសនៅក្បែរភោជនដ្ឋានអាហារពេលព្រឹក គេឃើញមានផ្លាកសញ្ញាមួយ ដែលមានអក្សរចារពីលើថា "នៅទីកន្លែងនេះ កាលពីថ្ងៃទី៥ ខែកញ្ញា ឆ្នាំ១៧៨២ មិនមានព្រឹត្តិការណ៍អ្វីកើតឡើងទេ"។

ជួនកាល យើងមានអារម្មណ៍ថា គ្មានអ្វីកើតឡើងសោះ បន្ទាប់ពីយើងបានអធិស្ឋាន។ យើងអធិស្ឋានហើយអធិស្ឋានទៀត ដោយទូលសូមអ្វីមួយពីព្រះវរបិតារបស់យើង ដោយរំពឹងថា ព្រះអង្គឆ្លើយតបក្នុងពេលឥឡូវនេះ។ ស្តេច ដាវីឌ ក៏បានបង្ហាញភាពនឿយណាយដូចនេះផងដែរ នៅពេលដែលទ្រង់អធិស្ឋានថា "ឱព្រះយេហូវ៉ាអើយ តើទ្រង់នឹងភ្លេចទូលបង្គំដល់កាលណាទៀត តើដល់អស់កល្បឬអី តើនឹងលាក់ព្រះភក្ត្រទ្រង់ចំពោះទូលបង្គំដល់កាលណា?" (ទំនុកតម្កើង ១៣:១)។ យើងក៏ងាយនឹងគិតដូចទ្រង់ផងដែរថា ព្រះអម្ចាស់អើយ តើពេលណាព្រះអង្គឆ្លើយតប?

ទោះជាយ៉ាងណាក៏ដោយ ព្រះនៃយើងមិនគ្រាន់តែមានប្រាជ្ញាដ៏តខ្ចោះប៉ុណ្ណោះទេ តែក៏បានរៀបចំពេលវេលាយ៉ាងត្រឹមត្រូវ។ ហេតុនេះបានជាស្តេច ដាវីឌ អាចបន្លឺសម្លេងថា "ទូលបង្គំនឹងច្រៀងថ្វាយព្រះយេហូវ៉ា ដ្បិតទ្រង់បានប្រោសការល្អជាបរិបូរដល់ទូលបង្គំហើយ" (ខ.៥)។ បទគម្ពីរ សាស្តា ៣:១១ បានរំឭកយើងថា "ទ្រង់បានបង្កើតរបស់សព្វសារពើឲ្យល្អ តាមរដូវកាល"។ ពាក្យ "ឲ្យល្អ" គឺមានន័យថា "សមរម្យ" ឬ "គួរឲ្យរីករាយ"។ ព្រះទ្រង់មិនតែងតែឆ្លើយតបការអធិស្ឋានរបស់យើងគ្រប់ពេល ប៉ុន្តែព្រះអង្គតែងតែសម្រេចបំណងព្រះទ័យប្រកបដោយប្រាជ្ញារបស់ព្រះអង្គ។ បានជាយើងអាចមានសង្ឃឹមឡើង ព្រោះពេលណាព្រះអង្គឆ្លើយតបការឆ្លើយតបរបស់ព្រះអង្គ គឺតែងតែល្អ ត្រឹមត្រូវ និងគួរឲ្យយើងអរព្រះគុណព្រះអង្គ។—Bill Crowder

តើនៅពេលណា អ្នកបានអធិស្ឋានសូមអ្វីមួយ ហើយមានអារម្មណ៍ថា ព្រះទ្រង់ប្រហែលមិនអើពើចំពោះការទូលសូមរបស់អ្នក? តើអ្នកបានរៀនសូត្រអ្វីខ្លះនៅក្នុងពេលដែលអ្នកកំពុងរង់ចាំនោះ?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គជួយទូលបង្គំរៀនឲ្យមានចិត្តអត់ធ្មត់ក្នុងការអធិស្ឋាន ដោយទុកចិត្តព្រះអង្គ។

Daily Manna 2026_Content Enhance.indd 57 17/11/25 1:44 in the afternoon

មើល អញបានបើកទ្វារចំហនៅមុខឯង គ្មានអ្នកណានឹងបិទបានទេ (វិវរណៈ ៣:៨)។

ទ្វារដែលព្រះអង្គបានបើកហើយ

កាលខ្ញុំនៅរៀនក្នុងសាលារៀននៅក្បែរទីក្រុងធំមួយ អ្នកប្រឹក្សាផ្នែកអប់រំបានមើលមុខខ្ញុំតែមួយដង ហើយក៏បានដាក់ឈ្មោះខ្ញុំក្នុងថ្នាក់រៀនតែងនិពន្ធភាសាអង់គ្លេស ដែលខ្សោយជាងគេនៅសាលានោះ។ ខ្ញុំបានផ្ទេរពីសាលាក្នុងទីក្រុង ដោយមានពិន្ទុខ្ពស់ និទ្ទេសល្អប្រសើរ ហើយថែមទាំងបានទទួលរង្វាន់ពីនាយកសាលាសម្រាប់ការតែងនិពន្ធ។ ដូចនេះ គេគួរតែបើកទ្វារចំហ ឲ្យខ្ញុំបានចូលរៀនថ្នាក់តែងនិពន្ធដែលល្អជាងគេក្នុងសាលាថ្មីនោះ តែអ្នកប្រឹក្សាផ្នែកអប់រំនោះគិតថា ខ្ញុំមិនស័ក្តិសម។

ពួកជំនុំកីឡាដិលភានៅសម័យដើម មុខជាបានយល់អំពីភាពអយុត្តិធម៌ដូចនេះ។ ពួកជំនុំដ៏តូចនេះ មានទីតាំងក្នុងទីក្រុង ដែលបានជួបគ្រោះរញ្ជួយដីកាលប៉ុន្មានឆ្នាំមុន ដែលបណ្តាលឲ្យមានការខូចខាតធ្ងន់ធ្ងរ។ ជាងនេះទៅទៀត ពួកគេបានជួបការវាយប្រហាររបស់សាតាំង (វិវរណៈ ៣:៩)។ ពួកជំនុំដ៏តូចនោះ មានកម្លាំងតិចដោយព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញបានកត់សម្គាល់ឃើញថា ពួកគេបានកាន់តាមពាក្យរបស់ព្រះអង្គ ហើយមិនបានលះបង់ព្រះនាមព្រះអង្គ (ខ.៨)។ ដូចនេះ ព្រះទ្រង់ក៏បានដាក់ទ្វារចំហមួយនៅពីមុខពួកគេ ដែលគ្មាននរណាអាចបិទបាន (ខ.៨)។ ជាការពិតណាស់ «ការអ្វីក៏ដោយដែលព្រះអង្គបានបើក គ្មាននរណាបិទបានទេ ហើយការអ្វីដែលព្រះអង្គបានបិទ នោះក៏គ្មាននរណាអាចបើកបានដែរ» (ខ.៧)។

រឿងនេះក៏កើតមានក្នុងការងារ ដែលយើងធ្វើថ្វាយព្រះអង្គផងដែរ។ មានទ្វារខ្លះមិនបានបើកចំហឲ្យយើង។ ទោះជាយ៉ាងណាក៏ដោយនៅក្នុងការងារតែងនិពន្ធសៀវភៅថ្វាយព្រះអម្ចាស់ ព្រះអង្គពិតជាបានបើកទ្វារឲ្យខ្ញុំ ដោយបានប្រទានពរមនុស្សនៅក្នុងតំបន់ជាច្រើនក្នុងពិភពលោកតាមរយៈការងារខ្ញុំ ទោះអ្នកប្រឹក្សាយោបល់នោះមានអាកប្បកិរិយាយ៉ាងណាក៏ដោយ។ ព្រះយេស៊ូវមានបន្ទូលថា បើព្រះអង្គបានបើកទ្វារឲ្យយើងហើយ គ្មាននរណាអាចបិទទ្វារនោះបានទេ (យ៉ូហាន ១០:៩)។ ចូរយើងចូលតាមទ្វារដែលព្រះអង្គបានបើកសម្រាប់យើង ហើយដើរតាមព្រះអង្គចុះ។—Patricia Raybon

តើព្រះអម្ចាស់បានបើកទ្វារណាខ្លះសម្រាប់អ្នក? តើការងារដែលអ្នកធ្វើបម្រើព្រះអង្គ និងជីវិតរបស់អ្នកមានការរីកចម្រើនយ៉ាងណា នៅពេលដែលអ្នករង់ចាំព្រះអង្គបើកទ្វារ?

ឱព្រះអម្ចាស់ ពេលណាទ្វារបិទ ទូលបង្គំងាកទៅរកព្រះអង្គ ដែលជាទ្វារដ៏បរិសុទ្ធ ហើយដើរទៅកន្លែងណា ដែលព្រះអង្គប្រាប់ឲ្យទូលបង្គំទៅ។

Daily Manna 2026_Content Enhance.indd 58 17/11/25 1:44 in the afternoon

ដូច្នេះ ចូរប្រដាប់កាយ ដោយចិត្តក្តួលអាណិត (កូល៉ុស ៣:១២)។

យកតម្រាប់តាមគំរូនៃសេចក្តីអាណិតរបស់ព្រះយេស៊ូវ

តើការរស់នៅជាក្បត្រ ឬក្បត្រីមានលក្ខណៈដូចម្តេច? ក្នុងនាមអ្នកស្រី អែនជេឡា ខេលី (Angela Kelly) ជាកូនស្រីរបស់អ្នកធ្វើការនៅកំពង់ផែ និងគ្រូពេទ្យ គាត់បានដឹងអំពីរឿងនេះ។ គាត់ធ្លាប់មានតួនាទីជាអ្នករៀបចំសំលៀកបំពាក់ឲ្យអតីតក្បត្រី អេលីហ្សាបិត ក្នុងរយៈពេល២ទសវត្សរ៍ចុងក្រោយនៃព្រះជន្មរបស់ព្រះនាង។ ព្រះនាងក៏មានការទទួលខុសត្រូវនៅក្នុងការលស្មៃកជើងថ្មីរបស់ព្រះនាង ដោយពាក់ស្បែកជើងទាំងនោះ ដើរក្នុងបរិវេណរាជវាំង។ មូលហេតុ គឺដោយសារគាត់មានចិត្តអាណិតចំពោះព្រះនាង ជាស្ត្រីចាស់ជរា ដែលជួនកាលត្រូវឈរជាច្រើនម៉ោងនៅក្នុងកម្មវិធីផ្សេងៗ។ ដោយសារអ្នកទាំងពីរពាក់ស្បែកជើងមានទំហំដូចគ្នា អ្នកស្រី ឃែលី អាចជួយកាត់បន្ថយការលំបាកខ្លះៗរបស់ព្រះនាង។

បទពិសោធន៍ផ្ទាល់ខ្លួនរបស់អ្នកស្រី ឃែលី ក្នុងការបម្រើក្បត្រី អេលីហ្សាបិត បានធ្វើឲ្យខ្ញុំនឹកចាំអំពីការលើកទឹកចិត្តដ៏កក់ក្តៅរបស់សាវ័ក ប៉ុល ដល់ពួកជំនុំនៅទីក្រុងកូល៉ុសឲ្យ «ចូរប្រដាប់កាយ ដោយចិត្តក្តួលអាណិត សប្បុរស សុភាព សំឡូត និងចិត្តអត់ធ្មត់» (កូល៉ុស ៣:១២)។ ពេលណាជីវិតយើង បានសង់ឡើងនៅលើព្រះយេស៊ូវ (២:៧) យើងក្លាយជា «ពួកអ្នករើសតាំង ដែលបរិសុទ្ធ ហើយស្ងួនភ្ងាដល់ព្រះ» (៣:១២)។ ព្រះអង្គជួយយើងដោះ «មនុស្សចាស់» របស់យើងចេញ ហើយប្រដាប់ខ្លួន ដោយ «មនុស្សថ្មី» (ខ.៩-១០) ដោយរស់នៅជាមនុស្ស ដែលស្រឡាញ់ និងអត់ទោសឲ្យអ្នកដទៃ ដ្បិតព្រះទ្រង់ស្រឡាញ់ និងអត់ទោសឲ្យយើង (ខ.១៣-១៤)។

នៅជុំវិញខ្លួនយើងមានមនុស្សជាច្រើន ដែលត្រូវការឲ្យយើងយល់ចិត្ត និងមានក្តីអាណិតចំពោះពួកគេ ក្នុងបញ្ហាប្រឈមក្នុងការរស់នៅរៀងរាល់ថ្ងៃ។ ការធ្វើដូចនេះ គឺបានយកតម្រាប់តាមព្រះយេស៊ូវ ជាមហាក្បត្ររបស់យើង ដែលតែងតែមានព្រះទ័យអាណិតចំពោះយើងជានិច្ច។—James Banks

តើព្រះទ្រង់មានព្រះទ័យអាណិតចំពោះអ្នកដូចម្តេចខ្លះ? តើអ្នកអាចបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គដល់នរណាខ្លះនៅថ្ងៃនេះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការអត់ទោសបាប និងសេចក្តីស្រឡាញ់ចំពោះទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំឲ្យទទួល និងចែកចាយដល់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 59 17/11/25 1:44 in the afternoon

អ្នករាល់គ្នាមិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ គឺជាជាតិតែ១នឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ (អេភេសូរ ២:១៩)។

ស្វាគមន៍មនុស្សដែលយើងមិនស្គាល់

លោក ដានីយ៉ែល ណាយើរី (Daniel Nayeri) បានពិពណ៌នាអំពីការធ្វើដំណើរដ៏លំបាករបស់គាត់ ជាមួយម្តាយ និងបងប្អូនស្រីគាត់រត់គេចពីការបៀតបៀន ដោយឆ្លងកាត់ជំរុំជនភៀសខ្លួនឆ្ពោះទៅរកកន្លែងមានសុវត្ថិភាពនៅសហរដ្ឋអាមេរិក ជាប្រទេសទី៣។ គាត់ថា រឿងដែលគាត់បានជួបមិនមែនសុទ្ធតែជារឿងសោកសៅទាំងអស់ឡើយ។ ប្តីប្រពន្ធវ័យចំណាស់មួយគូរបានស្ម័គ្រចិត្តធានាពួកគេ ឲ្យមករស់នៅសហរដ្ឋអាមេរិក ទោះពួកគេមិនដែលស្គាល់គ្នាក៏ដោយ។ ប៉ុន្មានឆ្នាំក្រោយមក លោក ដានីយ៉ែល នៅតែមិនយល់។ គាត់ក៏បានសរសេរថា «តើអ្នកជឿទេ? ពួកគេបានជួយក្រុមគ្រួសារខ្ញុំ ដោយមិនបានស្គាល់គ្នាសោះ។ ពួកគេមិនដែលបានជួបយើងទេ។ ហើយបើយើងជាមនុស្សអាក្រក់ ពួកគេនឹងមានរឿងធំមិនខាន។ ពួកគេពិតជាក្លាហាន មានចិត្តល្អ និងមិនខ្លាចគ្រោះថ្នាក់ខុសពីមនុស្សជាច្រើនដែលខ្ញុំធ្លាប់ស្គាល់»។

ទោះជាយ៉ាងណាក៏ដោយ ព្រះទ្រង់សព្វព្រះទ័យឲ្យយើងមានសេចក្តីអាណិតដូចនេះ ដល់អ្នកដែលយើងមិនស្គាល់។ គឺដូចដែលព្រះអង្គបានប្រាប់ពួកអ៊ីស្រាអែល ឲ្យមានចិត្តមេត្តាចំពោះជនបរទេស។ «ឯអ្នកប្រទេសក្រៅដែលមកស្នាក់នៅក្នុងពួកឯងរាល់គ្នា នោះត្រូវទុកដូចជាកើតនៅស្រុកឯងវិញ ហើយត្រូវស្រឡាញ់គេដូចជាខ្លួនឯងដែរ ដ្បិតឯងរាល់គ្នាពីដើមក៏ជាអ្នកស្នាក់នៅក្នុងស្រុកអេស៊ីព្ទដែរ» (លេវីវិន័យ ១៩:៣៤)។ ព្រះអង្គក៏បានព្យាករគ្រីស្ទបរិស័ទជាសាសន៍ដទៃផងដែរថា កាលពីមុន «អ្នករាល់គ្នានៅទីទៃពីព្រះគ្រីស្ទ... ជាមនុស្សដទៃខាងឯសេចក្តីសញ្ញា ដែលទ្រង់បានសន្យាទុក ក៏គ្មានសង្ឃឹម ហើយគ្មានព្រះក្នុងលោកីយ៍នេះដែរ» (អេភេសូរ ២:១២)។ ដូចនេះ ព្រះអង្គក៏បានបង្គាប់យើងរាល់គ្នា ដែលធ្លាប់រស់នៅដាច់ចេញពីព្រះ «កុំឲ្យភ្លេចសេចក្តីចៅរ៉ៅឡើយ» (ហេព្រើរ ១៣:២)។

សព្វថ្ងៃនេះ លោក ដានីយ៉ែល បានចម្រើនវ័យធំឡើងមានគ្រួសារផ្ទាល់ខ្លួន ហើយបានសរសើរតម្កើងព្រះដែលបានប្រើលោក ជីម (Jim) និងអ្នកស្រី ជីន ដសិន (Jean Dawson) ជាគ្រីស្ទបរិស័ទដ៏ល្អ ឲ្យទទួលគ្រួសាររបស់គាត់ ជាជនភៀសខ្លួនចូលស្នាក់នៅ រហូតដល់ពេលដែលពួកគេអាចរកបានផ្ទះផ្ទាល់ខ្លួន។

ព្រះអម្ចាស់បានស្វាគមន៍អ្នកប្រទេសក្រៅ ហើយក៏បានជំរុញយើងឲ្យស្វាគមន៍អ្នកដែលយើងមិនស្គាល់ផងដែរ។—Mike Wittmer

តើមាននរណាខ្លះកំពុងរស់នៅខាងក្រៅសហគមន៍របស់អ្នក? តើអ្នកអាចឈោងទៅរក និងស្វាគមន៍ពួកគេចូលក្នុងសហគមន៍អ្នកយ៉ាងដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យស្រឡាញ់មនុស្សដែលទូលបង្គំមិនស្គាល់។

Daily Manna 2026_Content Enhance.indd 60 17/11/25 1:44 in the afternoon

ពួកមានគ្នា២នាក់ នោះវិសេសជាជនៅតែឯង... ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញ (សាស្តា ៤:៩-១០)។

មានគ្នាច្រើន ល្អជាងនៅតែឯង

លោក សូរិន សូលយ៉ៃ (Søren Solkær) បានចំណាយពេលជាច្រើនឆ្នាំ ដើម្បីថតរូបសត្វទៀរ ជាបក្សីដ៏ស្រស់ស្អាត និងទិដ្ឋភាពដែលពួកវាបង្កើតគួរឲ្យពេចពិលរមិលមើល ដោយបញ្ចេញសម្លេងដ៏ពីរោះក្នុងការហោះហើរផ្លាស់ទីយ៉ាងរលូនជាហ្វូងមានគ្នារាប់សែនក្បាលរាំនៅលើមេឃ។ ការទស្សនាទិដ្ឋភាពដ៏អស្ចារ្យនេះ គឺប្រៀបដូចជាការអង្គុយមើលផ្ទាំងគំនូរ ដែលមានស្នាមជក់ធំមួយ ដែលគេគ្រាសទឹកខ្មៅចុះឡើងនៅលើមេឃ បង្កើតជាផ្ទាំងទស្សនីយភាពដ៏ស្រស់ស្អាត។ នៅប្រទេសដាណឺម៉ាក គេបានហៅទស្សនីយភាពរបស់សត្វទៀរថា ព្រះអាទិត្យពណ៌ខ្មៅ (ដែលជាចំណងជើងសៀវភៅថតរូបដ៏ល្បីល្បាញរបស់លោក សូលយ៉ៃ)។ អ្វីដែលគួរឲ្យកត់សម្គាល់បំផុតនោះ គឺរបៀបដែលសត្វទៀរហោះហើរតាមគ្នានៅកៀកគ្នាខ្លាំងណាស់ បើសិនជាសត្វទៀរណាមួយហើរខុសចង្វាក់តែបន្តិច ពួកគេនឹងមានការប៉ះទង្គិចគ្នាដ៏ធ្ងន់ធ្ងរមិនខាន។ ទោះជាយ៉ាងណាក៏ដោយ សត្វទៀរបានប្រើការប្រមូលផ្តុំគ្នា ដើម្បីការពារខ្លួនពួកវា។ ពេលណាសត្វស្វាំងហើរចុះមករកពួកវា សត្វបក្សីតូចៗទាំងនោះបានហើរជាក្បួនយ៉ាងណែន ហើយផ្លាស់ទីព្រមគ្នា ដោយបណ្តេញសត្វប្រមាញ់នោះ ដែលងាយនឹងចាប់ពួកវាធ្វើជាចំណី បើសិនជាពួកវានៅតែឯង។

ការនៅជុំគ្នា នោះប្រសើរជាងការនៅម្នាក់ឯង។ គឺដូចបទគម្ពីរសាស្តាបានចែងថា «មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង... ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញ តែវរហើយ អ្នកណាដែលដួលក្នុងកាលដែលនៅតែម្នាក់ឯង ឥតមានគ្នានឹងជួយជ្រោងឡើងវិញ» (៤:៩-១១)។ បើយើងនៅតែឯង នោះខ្មាំងសត្រូវងាយនឹងឆក់យកយើង។ យើងក៏ខ្វះការកម្សាន្តចិត្ត និងការពាររបស់អ្នកដទៃ។

ប៉ុន្តែ កាលណាយើងមានគ្នា យើងអាចជួយយកអសារគ្នាទៅវិញទៅមក។ គឺដូចដែលបទគម្ពីរសាស្តាបានចែងថា «បើមានខ្មាំងណាមក ដែលមានកំឡាំងជាង នោះ២នាក់នឹងអាចទប់ទល់បាន ឯពួរ៣ធ្លុងមិនងាយដាច់ទេ» (ខ.១២)។ ខណៈពេលដែលព្រះទ្រង់ដឹកនាំយើង ការដែលយើងនៅជុំគ្នា គឺប្រសើរជាងនៅតែឯង។

—Winn Collier

តើការនៅម្នាក់ឯង ងាយរងគ្រោះជាងការនៅជុំគ្នាដូចម្តេចខ្លះ? តើអ្នកអាចចូលទៅជិតអ្នកដទៃ ដោយរបៀបណា?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំរំឭកដ្ឋាចិត្តក្នុងការរស់នៅជាសហគមន៍ និងបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គដល់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 61 17/11/25 1:44 in the afternoon

ទ្រង់គង់នៅមុនទាំងអស់ ហើយរបស់ទាំងអស់ក៏ស្ថិតស្ថេរ ដោយសារទ្រង់ (កូល៉ុស ១:១៧)។

មិនមែនមានសំណាង តែដោយសារព្រះយេស៊ូវ

ឮសុរនារដ្ឋីការរុករកឃើញបានលើកឡើងថា ក្នុងចក្រវាលរបស់យើងមានភពចំនួនប្រហែល ៧០០គ្លីនទ្រីលាន (គឺចំនួនចាប់ផ្តើមដោយលេខ៧ មានលេខសូន្យ២០ខ្ទង់ខាងក្រោយ)។ ប៉ុន្តែ មានតែភពមួយទេដែលមានលក្ខណៈដូចផែនដី។ លោក អេរិក ហ្សាគ្រីសិន (Erik Zackrisson) ជាអ្នកប្រាជ្ញរូបវិទ្យាផ្នែកអវកាសបានមានប្រសាសន៍ថា លក្ខខណ្ឌមួយ ដែលតម្រូវឲ្យភពមួយអាចទ្រទ្រង់ជីវិតបាន គឺភពនោះត្រូវតែស្ថិតនៅលើគន្លង ដែលមិនឆ្ងាយពេក ហើយក៏មិនជិតពេកពីព្រះអាទិត្យ គឺក្នុងតំបន់ដែលមានសីតុណ្ហភាពល្អ ល្មមនឹងអាចមានទឹកបាន។ ក្នុងចំណោមភាព ៧០០គ្លីនទ្រីលាន ហាក់ដូចជាមានតែភពផែនដីទេ ដែលអាចបំពេញតាមលក្ខខណ្ឌនេះបានត្រឹមត្រូវ។ លោក ហ្សាគ្រីសិន ក៏បានសន្និដ្ឋានថា ផែនដីពិតជាមានសំណាងណាស់។

សាវ័ក ប៉ុល បានបញ្ជាក់ដល់ពួកជំនុំនៅទីក្រុងកូល៉ុសថា ចក្រវាលពិតជាមានមែន តែមិនមែនដោយសារចក្រវាលមានសំណាងនោះទេ ផ្ទុយទៅវិញគឺដោយសារការរៀបចំរបស់ព្រះយេស៊ូវ។ សាវ័ក ប៉ុល បានហៅព្រះគ្រីស្ទថា ព្រះអាទិករដែលបានបង្កើតពិភពលោក។ គឺដូចគាត់បានបង្រៀនថា «ដ្បិតគឺទ្រង់ហើយ ដែលបង្កើតគ្រប់ទាំងអស់» (កូល៉ុស ១:១៦)។ ព្រះយេស៊ូវមិនគ្រាន់តែជាព្រះដែលបានបង្កើតផែនដី ដោយព្រះចេស្តា តែព្រះអង្គថែមទាំងបានទ្រទ្រង់អ្វីៗទាំងអស់ឲ្យស្ថិតស្ថេរ (ខ.១៧) ក្នុងផែនដីដែលមិនក្តៅពេក និងមិនត្រជាក់ពេក តែមានអាកាសធាតុល្មមនឹងអាចឲ្យមនុស្សរស់នៅបាន។ អ្វីដែលព្រះយេស៊ូវបានបង្កើត នោះព្រះអង្គក៏បានទ្រទ្រង់ដោយប្រាជ្ញាដ៏ល្អឥតខ្ចោះ និងព្រះចេស្តាដ៏ស្ថិតស្ថេរ។

ខណៈពេលដែលយើងចូលរួម និងអរសប្បាយនឹងសម្រស់នៃស្នាព្រះហស្តរបស់ព្រះអង្គ ចូរយើងងាកចេញពីការបង្រៀនថា អ្វីៗកើតមានដោយចៃដន្យ ឬដោយសារមានសំណាង តែចូរបែរទៅរកព្រះនៃសេចក្តីស្រឡាញ់ដែលមានព្រះចេស្តា មានអធិបតេយ្យភាព និងមានគោលបំណង ដែលមានភាពពេញលេញជាព្រះ (ខ.១៩)។

—Marvin Williams

តើការដឹងថា ព្រះយេស៊ូវគ្រប់គ្រងអ្វីៗទាំងអស់ក្នុងពិភពធម្មជាតិ និងជីវិតអ្នកមានន័យដូចម្តេចសម្រាប់អ្នក? តើអ្នកអាចបង្ហាញការពឹងផ្អែកលើព្រះអង្គនៅថ្ងៃនេះ ដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការបង្កើត និងទ្រទ្រង់ស្នាព្រះហស្តព្រះអង្គ ដោយព្រះគុណ និងគោលបំណងរបស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 62 17/11/25 1:44 in the afternoon

ខ្ញុំបានដេកលក់ទៅ ហើយក៏ភ្ញាក់ឡើងវិញ ដ្បិតព្រះយេហូវ៉ាទ្រង់ទប់ទល់ខ្ញុំ (ទំនុកតម្កើង ៣:៥)។

គេងលក់យ៉ាងសុខសាន្ត ពេលមានបញ្ហា

ការនឹកឃើញរឿងអាក្រក់ៗ និងពាក្យចោទប្រកាន់ បានជន់ជោរនៅក្នុងគំនិតរបស់លោក សាល (Sal)។ គាត់គេងមិនលក់ ខណៈពេលដែលចិត្តគាត់មានពេញដោយការភ័យខ្លាច ហើយគាត់បែកញើសជោគខ្លួន។ កាលនោះ គឺនៅពេលយប់មុនពេលគាត់ទទួលបុណ្យជ្រមុជទឹក ហើយគាត់មិនអាចបញ្ឈប់ការគិតដ៏ខ្មៅងងឹតនោះបាន។ លោក សាល បានទទួលសេចក្តីសង្គ្រោះរបស់ព្រះយេស៊ូវ ហើយក៏បានដឹងថា ព្រះអង្គបានអត់ទោសឲ្យបាបរបស់គាត់ហើយ តែសង្គ្រាមខាងវិញ្ញាណនៅតែបន្ត។ នៅពេលនោះ ភរិយាគាត់ក៏បានចាប់ដៃគាត់ ហើយអធិស្ឋានឲ្យគាត់។ មួយសន្ទុះក្រោយមក សន្តិភាពក៏បានចូលមកជំនួសការភ័យខ្លាចក្នុងចិត្តរបស់លោក សាល។ គាត់ក៏បានក្រោកឡើង ហើយក៏បានសរសេរពាក្យពេចន៍ ដែលគាត់ចង់ចែកចាយមុនពេលគាត់ទទួលបុណ្យជ្រមុជទឹក ជាអ្វីដែលគាត់មិនអាចធ្វើបានកាលពីមុន។ ក្រោយមក គាត់ក៏បានគេងលក់យ៉ាងសុខសាន្ត។

ស្តេច ដាវីឌ ក៏បានជ្រាបថា ការគេងមិនលក់នៅពេលយប់មានអារម្មណ៍ដូចម្តេច។ កាលទ្រង់កំពុងរត់គេចពីបុត្រាទ្រង់ ព្រះនាម អាប់សាឡុម ដែលចង់ដណ្តើមរាជទ្រង់ (២សាំយ៊ូអែល ១៥-១៧) ទ្រង់ជ្រាបថា មានមនុស្សទាំងសល់សែន ដែលបានតាំងខ្លួនព័ទ្ធជុំវិញទាស់នឹងទ្រង់ (ទំនុកតម្កើង ៣:៦)។ ទ្រង់ក៏បានពោលទំនួញថា «ឱព្រះយេហូវ៉ាអើយ ពួកខ្មាំងនៃទូលបង្គំមាន គ្នាកាន់តែច្រើនឡើងយ៉ាងណា» (ខ.១)។ ទោះទ្រង់មានការភ័យខ្លាច និងការសង្ស័យយ៉ាងណាក៏ដោយ ក៏ទ្រង់បានស្រែករកព្រះអម្ចាស់ ជាខែលរបស់ទ្រង់ (ខ.៣)។ ក្រោយមក ទ្រង់ក៏បានដឹងថា ទ្រង់អាចពោលថា «ខ្ញុំបានដេកលក់ទៅ ហើយក៏ភ្ញាក់ឡើងវិញ ដ្បិតព្រះយេហូវ៉ាទ្រង់ទប់ទល់ខ្ញុំ» (ខ.៥)។

ពេលណាការភ័យខ្លាច និងទុក្ខលំបាកគ្របសង្កត់គំនិតយើង ហើយការសម្រាកត្រូវបានជំនួសដោយការគេងមិនលក់ យើងអាចរកឃើញក្តីសង្ឃឹម ខណៈពេលដែលយើងអធិស្ឋានទៅរកព្រះអង្គ។ យើងប្រហែលមិនអាចគេងលក់យ៉ាងសុខសាន្ត បានឆាប់រហ័សដូចលោក សាល និងស្តេច ដាវីឌ ទេ តែយើងអាចសម្រាកកាយ ហើយដេកលក់ទៅ ដោយសេចក្តីស្ងប់ ដ្បិតមានតែទ្រង់ទេ ដែលប្រោសឲ្យយើងនៅដោយសាន្តគ្រាណាបាន។

—Tom Felten

តើមានបញ្ហាអ្វីខ្លះកំពុងគ្របសង្កត់ចិត្ត និងគំនិតអ្នក? តើអ្នកអាចថ្វាយបញ្ហាទាំងអស់នោះ ដាច់ដល់ព្រះអង្គ ដោយការអធិស្ឋានដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការប្រទានសេចក្តីសង្ឃឹម និងសន្តិភាព ខណៈពេលដែលទូលបង្គំអធិស្ឋានទៅកាន់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 63 17/11/25 1:44 in the afternoon

នោះព្រះយេស៊ូវទ្រង់ក៏ឈប់ ហើយបង្គាប់ឲ្យគេនាំគាត់មក (លូកា ១៨:៤០)។

មានតែព្រះយេស៊ូវស្តាប់យើងឬ

គ្រែបានយកកូនឆ្មាដែលមានសភាពទន់ខ្សោយដាក់ក្នុងកេស យកមកទុកចោលនៅក្បែរកន្លែងធ្វើការខ្ញុំ ជាច្រើនថ្ងៃហើយ។ គេបានបោះបង់សត្វឆ្មានេះ ឲ្យរស់នៅអនាថា ហើយមនុស្សជាច្រើនមិនចាប់អារម្មណ៍ចំពោះវា ពេលដើរកាត់ពីមុខវា តែលោក ជូន (Jun) បានយកចិត្តទុកដាក់ចំពោះវា។ អ្នកបោសថ្នល់រូបនោះក៏បានយកសត្វមួយក្បាលនេះទៅផ្ទះ ជាកន្លែងដែលគាត់កំពុងរស់នៅជាមួយសត្វឆ្កែពីរក្បាល ដែលជាឆ្កែអនាថាផងដែរ។

លោក ជូនក៏បាននិយាយថា គាត់ចែករក្សាសត្វទាំងនោះ ព្រោះពួកវាជាសត្វដែលគ្មាននរណាយកចិត្តទុកដាក់។ គាត់ថា គាត់មើលឃើញជីវិតគាត់ដូចសត្វអនាថាទាំងនោះផងដែរ ហើយគ្មាននរណាយកចិត្តទុកដាក់ចំពោះអ្នកបោសថ្នល់ដូចគាត់ទេ។

កាលព្រះយេស៊ូវដើរទៅទីក្រុងយេរីខូរ តាមផ្លូវទៅទីក្រុងយេរូសាឡិម មានជនពិការភ្នែកម្នាក់កំពុងអង្គុយសុំទាននៅលើចិញ្ចើមផ្លូវ។ គាត់ក៏មានអារម្មណ៍ថា គ្មាននរណាយកចិត្តទុកដាក់ចំពោះគាត់ទេ។ ហើយនៅថ្ងៃនោះជាពិសេសនៅពេលដែលមនុស្សមួយហ្វូងដើរកាត់តាមនោះ ហើយគ្រប់គ្នាផ្តោតចិត្តទៅលើព្រះគ្រីស្ទ គ្មាននរណាម្នាក់ឈប់ ដើម្បីជួយអ្នកសុំទាននោះទេ។

មានតែព្រះយេស៊ូវទេ ដែលបានស្តាប់ឮសម្លេងបុរសនោះស្រែកហៅព្រះអង្គក្នុងកណ្តាលហ្វូងមនុស្ស។ ព្រះអង្គក៏បានសួរគាត់ថា «តើចង់ឲ្យខ្ញុំធ្វើអ្វីឲ្យអ្នក?» គាត់ទូលថា «ឱព្រះអម្ចាស់អើយ សូមឲ្យភ្នែកទូលបង្គំបានភ្លឺឡើង»។ បន្ទាប់មកព្រះយេស៊ូវមានបន្ទូលថា «ឲ្យភ្លឺចុះ សេចក្តីជំនឿអ្នកបានជួយសង្គ្រោះអ្នកហើយ»។ ស្រាប់តែភ្នែកគាត់បានភ្លឺភ្លាម (លូកា ១៨:៤១-៤២)។

តើយើងមានអារម្មណ៍ថា គេមិនយកចិត្តទុកដាក់ចំពោះយើង នៅពេលខ្លះទេ? តើយើងស្រែកមិនឮ ដោយសារមានមនុស្សជាច្រើន ដែលហាក់ដូចជាសំខាន់ជាងយើងឬ? ព្រះអង្គសង្គ្រោះយើងយកព្រះទ័យទុកដាក់ចំពោះមនុស្ស ដែលលោកីយមិនយកចិត្តទុកដាក់។ ចូរស្រែកព្រះអង្គ។ ខណៈពេលដែលអ្នកដទៃដើរហួសយើង ព្រះអង្គនឹងឈប់ ដើម្បីជួយយើង។—Karen Huang

តើការដឹងថា ព្រះយេស៊ូវទតឃើញអ្នកបានកែប្រែរបៀបដែលអ្នកគិតអំពីខ្លួនឯង និងជីវិតអ្នកដូចម្តេចខ្លះ? ក្នុងចំណោមអ្នកមាននរណាខ្លះ ដែលត្រូវការការយកចិត្តទុកដាក់ពីអ្នកដទៃ ហើយតើអ្នកអាចឈប់ដើម្បីលើកទឹកចិត្តពួកគេ ដោយសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការស្តាប់ឮទូលបង្គំ ពេលណាទូលបង្គំស្រែករកព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យដើរតាម និងសរសើរតម្កើងព្រះអង្គពេញមួយជីវិត ដូចមនុស្សខ្វាក់ដែលព្រះអង្គបានប្រោសឲ្យមើលឃើញ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ជនគណនា ១៧-១៩ និងម៉ាកុស ៦:៣០-៥៦

ស្រាប់តែឪពុករបស់កូននោះ ក៏បន្ទឺរាថាឡើងទាំងទឹកភ្នែកថា ខ្ញុំជឿហើយលោកម្ចាស់អើយ សូមជួយចំពោះសេចក្តីណាដែលខ្ញុំមិនជឿផង (ម៉ាកុស ៩:២៤)។

សូមព្រះអង្គជួយឲ្យយើងជឿ

«តើឯណាសេចក្តីជំនឿរបស់ខ្ញុំ? សូម្បីតែក្នុងជម្រៅចិត្តខ្ញុំ ក៏ខ្ញុំមិនអាចរកឃើញអ្វី ក្រៅពីភាពចន្លោះប្រហោង និងភាពងងឹត... បើព្រះទ្រង់ពិតជាមានមែន សូមព្រះអង្គអត់ទោសឲ្យទូលបង្គំផង»។

អ្នកប្រហែលមានការភ្ញាក់ផ្អើលពេលដែលបានដឹងថា អ្នកម្តាយ ថេរីសា (Mother Teresa) គឺជាអ្នកសរសេរពាក្យពេចន៍ទាំងអស់នេះ។ គាត់ជាអ្នកបម្រើព្រះដ៏ល្បីល្បាញ និងគ្មានការហាត់នឿយសម្រាប់អ្នកក្រនៅទីក្រុងកាល់គុត្តា ប្រទេសឥណ្ឌា។ តែមនុស្សជាច្រើនមិនដឹងទេថា គាត់បានតយុទ្ធនឹងសង្គ្រាមខាងសេចក្តីជំនឿ ដោយការលំបាកជាខ្លាំងអស់រយៈពេលជាង៥ទសវត្សរ៍។ បន្ទាប់ពីគាត់បានលាចាកលោកក្នុងឆ្នាំ១៩៩៧ គេក៏បានដឹងអំពីការតស៊ូនេះ នៅពេលដែលគេយកសៀវភៅកំណត់ត្រារបស់គាត់មួយផ្នែកមកបោះពុម្ពផ្សាយក្នុងសៀវភៅមានចំណងជើងថា សូមព្រះអង្គធ្វើជាពន្លឺរបស់ទូលបង្គំ។

តើយើងត្រូវធ្វើដូចម្តេច ពេលយើងមានការសង្ស័យ ឬមានអារម្មណ៍ថា ព្រះអង្គមិនគង់នៅក្បែរយើង? អ្នកជឿខ្លះមានបញ្ហានេះញឹកញាប់ជាងអ្នកជឿដទៃទៀត។ ប៉ុន្តែ អ្នកជឿព្រះយេស៊ូវដ៏ស្មោះត្រង់ជាច្រើនបានដកពិសោធន៍ជាមួយនឹងពេល ឬរដូវកាលនៃការសង្ស័យក្នុងចំណុចណាមួយនៃជីវិតរបស់ពួកគេ។

ខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលព្រះគម្ពីរបានផ្តល់ឲ្យយើងនូវលំនាំនៃការអធិស្ឋានដ៏មានន័យ ដែលបង្ហាញចេញនូវសេចក្តីជំនឿ និងការខ្វះជំនឿ។ ក្នុងបទគម្ពីរម៉ាកុសជំពូក៩ ព្រះយេស៊ូវបានជួបបុរសម្នាក់ ដែលកូនរបស់គាត់ត្រូវអារក្សចូលតាំងពីក្មេង (ខ.២១)។ នៅពេលដែលព្រះយេស៊ូវប្រាប់គាត់ថា គាត់ត្រូវមានសេចក្តីជំនឿ (ព្រោះការទាំងអស់នឹងសំរេចបាន ដល់អ្នកណាដែលជឿ ខ.២៣) បុរសនោះក៏បានឆ្លើយតបថា «ខ្ញុំជឿហើយ លោកម្ចាស់អើយ សូមជួយចំពោះសេចក្តីណាដែលខ្ញុំមិនជឿផង!» (ខ.២៤)។

គំរូនៃការទូលអង្វរដ៏ស្មោះត្រង់ និងអស់ពីចិត្តនេះក៏បានលើកទឹកចិត្តអ្នកដែលព្យាយាមជម្នះការសង្ស័យ ឲ្យសូមព្រះអង្គជួយដកការសង្ស័យចេញពីយើង ដោយទុកចិត្តថា ព្រះអង្គអាចការពារជំនឿយើង ហើយកាន់ដៃយើងជាប់ ក្នុងជ្រលងជ្រៅ និងងងឹតបំផុត ដែលយើងត្រូវឆ្លងកាត់។—Adam R. Holz

តើអ្នកមានការតយុទ្ធនឹងការសង្ស័យ ក្នុងការធ្វើដំណើរខាងវិញ្ញាណនៅពេលណាខ្លះ? តើមានធនធានខាងវិញ្ញាណអ្វីខ្លះ ដែលជួយឲ្យអ្នកប្រកាន់ខ្ជាប់នូវសេចក្តីជំនឿរបស់អ្នក?

ឱព្រះវរបិតា ជួនកាលទូលបង្គំមានការសង្ស័យ។ សូមព្រះអង្គជួយទូលបង្គំ ពេលណាទូលបង្គំមានអារម្មណ៍សង្ស័យ ចំពោះព្រះវត្តមានរបស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 65 17/11/25 1:44 in the afternoon

ដ្បិតអស់ទាំងសត្វនៅព្រៃសុទ្ធតែរបស់អញ (ទំនុកតម្កើង ៥០:១០)។

តើយើងជាម្ចាស់ ឬជាអ្នកទទួលបញ្ជើ?

មានពេលមួយ នាយកប្រតិបត្តិម្នាក់របស់ក្រុមហ៊ុន ដែលមានប្រាក់ពាន់លានបានថ្លឹងថ្លែងអំពីអ្វីៗដែលល្អបំផុតសម្រាប់គ្រួសារគាត់ ហើយក៏បានសួរខ្លួនឯងថា «តើខ្ញុំជាម្ចាស់របស់ទ្រព្យសម្បត្តិទាំងនេះ ឬព្រះទ្រង់គ្រាន់តែបានផ្ញើទ្រព្យសម្បត្តិទាំងនេះឲ្យខ្ញុំថែរក្សា?» គាត់មានការព្រួយបារម្ភអំពីការល្បួងដែលអាចកើតមាន ដោយសារទ្រព្យសម្បត្តិមហាសាលនោះ ដូចនេះគាត់មិនចង់ឲ្យកូនៗរបស់គាត់មានបន្ទុក ដោយសារបញ្ហាប្រឈមនេះទេ។ គាត់ក៏បានលះបង់ភាពជាម្ចាស់កម្មសិទ្ធិរបស់ក្រុមហ៊ុនគាត់ ហើយក៏បានប្រគល់ភាគហ៊ុនរបស់គាត់ ឲ្យទៅអង្គការមនុស្សធម៌១រយភាគរយ។ គាត់ទទួលស្គាល់ថា អ្វីៗគ្រប់យ៉ាងដែលគាត់មានសុទ្ធតែជាកម្មសិទ្ធិរបស់ព្រះបានជាគាត់ធ្វើការសម្រេចចិត្តឲ្យក្រុមគ្រួសារគាត់ ធ្វើការរកស៊ីចិញ្ចឹមជីវិតដោយខ្លួនឯង ហើយបរិច្ចាគប្រាក់ចំណេញនៅពេលអនាគត ឲ្យទៅអង្គការគ្រីស្ទបរិស័ទ។

ក្នុងបទគម្ពីរ ទំនុកតម្កើង ៥០:១០ ព្រះទ្រង់បានប្រាប់រាស្ត្រព្រះអង្គថា ដ្បិតអស់ទាំងសត្វនៅព្រៃសុទ្ធតែជាកម្មសិទ្ធិរបស់ព្រះអង្គ ព្រមទាំងហ្វូងសត្វទាំងប៉ុន្មាននៅលើភ្នំទាំងពាន់ផង។ ក្នុងនាមព្រះអង្គជាព្រះអាទិការដែលបានបង្កើតរបស់សព្វសារពើមក ព្រះអង្គមិនបានជំពាក់អ្វីនឹងយើងទេ ហើយក៏មិនត្រូវការអ្វីមួយពីយើងដែរ។ គឺដូចដែលព្រះអង្គមានបន្ទូលថា «អញមិនយកគោឈ្មោលពីផ្ទះឯង ឬពពែឈ្មោលពីក្រោលឯងឡើយ» (ខ.៩)។ ដោយព្រះទ័យសប្បុរស ព្រះអង្គប្រទានអ្វីៗទាំងអស់ ដែលយើងមាន និងប្រើប្រាស់ ក៏ដូចជាកម្លាំង និងសមត្ថភាពក្នុងការចិញ្ចឹមជីវិត។ ដោយសារព្រះអង្គបានប្រទាន ដូចដែលបទគម្ពីរទំនុកតម្កើងបានបង្ហាញយើងស្រាប់ នោះព្រះអង្គក៏សំក្តិសមនឹងឲ្យយើងថ្វាយបង្គំអស់ពីចិត្ត។

ព្រះទ្រង់ជាម្ចាស់លើអ្វីៗទាំងអស់។ ប៉ុន្តែ ដោយសារសេចក្តីល្អរបស់ព្រះអង្គ ព្រះអង្គថែមទាំងបានបន្ទាបព្រះកាយ ដើម្បីមានការប្រកបទាក់ទងជាមួយនរណាក៏ដោយដែលងាកបែរមករកព្រះអង្គ។ ព្រះយេស៊ូវ «បានមក មិនមែនឲ្យគេបំរើដែរ គឺដើម្បីនឹងបំរើគេវិញ ហើយនិងឲ្យជីវិតខ្លួនទុកជាថ្លៃលោះមនុស្សជាច្រើនផង» (ម៉ាកុស ១០:៤៥)។ ពេលណាយើងឲ្យតម្លៃមកលើព្រះដែលជាអ្នកប្រទានអំណោយ ហើយប្រើអំណោយទាំងនោះដើម្បីបម្រើព្រះអង្គ នោះយើងនឹងបានទទួលព្រះពរឲ្យអរសប្បាយ ក្នុងព្រះអង្គជារៀងរហូត។—James Banks

តើអ្នកចង់អរព្រះគុណព្រះអង្គសម្រាប់អ្វីខ្លះ ដែលព្រះអង្គបានប្រទានអ្នក? តើអ្នកអាចប្រើពួកវាក្នុងការបម្រើព្រះអង្គដូចម្តេចខ្លះ?

ឱព្រះអាទិការ ព្រះអង្គបានបង្កើតរបស់សព្វសារពើ។ សូមព្រះអង្គជួយទូលបង្គំឲ្យរស់នៅ ធ្វើជាអំណោយមកពីព្រះអង្គ សម្រាប់អ្នកដទៃជារៀងរាល់ថ្ងៃ។

Daily Manna 2026_Content Enhance.indd 66 17/11/25 1:44 in the afternoon

កាលណាបានឈប់សំរបស្ងាបចុះមកវិញហើយ នោះមានឮសំឡេងពីផ្ទៃមេឃ ដែលនៅពីលើក្បាលតួទាំងនោះ (អេសេគាល ១:២៥)។

ចែកចាយព្រះបន្ទូលព្រះអង្គ

តាមធម្មតា គេមិនគិតឃើញថា សត្វមេអំបៅជាសត្វដែលបញ្ចេញសម្លេងឮខ្លាំងនោះទេ។ ជាក់ស្តែង សម្លេងទទះស្លាបរបស់សត្វមេអំបៅស្តេច គឺពិតជាស្ងាត់ខ្លាំងណាស់ បានជាគេមិនអាចឮសម្លេងបាន។ ប៉ុន្តែ ក្នុងព្រៃទឹកភ្លៀងនៅប្រទេសមិចស៊ីកូ ជាកន្លែងដែលពួកវាចាប់ផ្តើមជីវិតដ៏ខ្លីរបស់ពួកវា ពេលណាពួកវាទទះស្លាបហើរទាំងហ្វូងក្នុងពេលតែមួយ សម្លេងទទះស្លាបព្រមគ្នាបានលាន់ឮខ្លាំង ដែលនាំឲ្យមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ពេលដែលសត្វមេអំបៅស្តេចចាប់លានក្បាលទទះស្លាបហើរក្នុងពេលតែមួយ ពួកវាបង្កើតបានសម្លេង ដែលលាន់ឮខ្លាំងដូចសម្លេងទឹកធ្លាក់យ៉ាងគំហុក។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីការពិពណ៌នាអំពីតួមានជីវិតដែលមានស្លាប៤ ក្នុងការបើកសម្តែងដែលហោរាអេសេគាលបានទទួល។ ទោះតួមានជីវិតទាំងនោះមានចំនួនតិចជាងសត្វមេអំបៅស្តេច ហោរា អេសេគាល បានប្រៀបប្រដូចសម្លេងទទះស្លាបរបស់ពួកគេទៅនឹង «សូរនៃទឹកធំ» (អេសេគាល ១:២៤)។ ពេលដែលតួមានជីវិតនោះឈរនៅត្រឹងមួយកន្លែង ហើយសម្របស្លាបចុះ ហោរាអេសេគាលក៏បានឮសម្លេងព្រះអម្ចាស់ត្រាស់បង្គាប់គាត់ ឲ្យថ្លែងព្រះបន្ទូលព្រះអង្គទៅកាន់ប្រជាជនអ៊ីស្រាអែល (២:៧)។

ហោរា អេសេគាល មិនខុសពីហោរាដទៃទៀត ដែលមានតួនាទីប្រកាសសេចក្តីពិតរបស់ព្រះអម្ចាស់ ដល់រាស្ត្រព្រះអង្គ។ សព្វថ្ងៃនេះ ព្រះអម្ចាស់បានបង្គាប់យើង ឲ្យចែកចាយសេចក្តីពិតនៃការល្អដែលព្រះអង្គបានធ្វើក្នុងជីវិតយើងទៅដល់មនុស្សនៅជុំវិញយើងផងដែរ (១ពេត្រុស ៣:១៥)។ ជួនកាល ព្រះអង្គឲ្យយើងប្រកាសព្រះបន្ទូលព្រះអង្គ ដោយសម្លេងឮៗ ដូចសន្ធឹកទឹកធ្លាក់។ ជួនកាល ព្រះអង្គឲ្យយើងចែកចាយព្រះបន្ទូលយ៉ាងស្ងប់ស្ងាត់។ ទោះយើងត្រូវប្រកាសព្រះបន្ទូលឮៗ ឬដោយភាពស្ងប់ស្ងាត់ក្តី យើងត្រូវតែប្រកាសតាមបង្គាប់ព្រះអង្គ ហើយយើងក៏ត្រូវត្រៀមត្រចៀករបស់យើងស្តាប់ព្រះបន្ទូល ដែលព្រះអង្គសព្វព្រះទ័យនឹងមានមកកាន់យើងនៅថ្ងៃនេះផងដែរ។—Kirsten Holmberg

តើព្រះអម្ចាស់សព្វព្រះទ័យឲ្យអ្នកចែកចាយព្រះបន្ទូលព្រះអង្គ ដល់នរណាខ្លះនៅថ្ងៃនេះ? តើអ្នកនឹងឆ្លើយតប ដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការត្រាស់ហៅទូលបង្គំ ឲ្យចែកចាយអំពីព្រះអង្គដល់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 67 17/11/25 1:44 in the afternoon

ដ្បិតគឺពីក្នុងចិត្តនោះឯងដែលចេញអស់ទាំងគំនិតអាក្រក់... សេចក្តីទាំងនោះទើបធ្វើឲ្យមនុស្ស ស្មោកគ្រោកមែន (ម៉ាថាយ ១៥:១៩-២០)។

ចិត្តដែលស្រឡាញ់ព្រះគ្រីស្ទ

ខ្ញុំធ្លាប់និយាយប្រាប់ខ្លួនឯងថា ដរាបណាខ្ញុំបិទមាត់មិននិយាយអ្វីសោះ ខ្ញុំនឹងមិនធ្វើអ្វីខុសឡើយ។ កាលនោះ ខ្ញុំកំពុងតែទប់កំហឹង ចំពោះមិត្តរួមការងារម្នាក់ បន្ទាប់ពីខ្ញុំមានការយល់ច្រឡំចំពោះពាក្យសម្តីរបស់គាត់។ ដោយសារយើងត្រូវជួបគ្នាជារៀងរាល់ថ្ងៃនៅកន្លែងធ្វើការ ខ្ញុំក៏បានសម្រេចចិត្តថា ខ្ញុំនឹងកាត់បន្ថយការនិយាយស្តី ដោយនិយាយតែពេលដែលចាំបាច់ប៉ុណ្ណោះ (ដើម្បីសងសឹក ដោយការមិននិយាយរកគាត់)។ តើការបង្ហាញចេញអាកប្បកិរិយាដ៏ស្ងាត់ស្ងៀមដូចនេះ ជាទង្វើត្រឹមត្រូវដែរឬទេ?

ព្រះយេស៊ូវបានមានបន្ទូលថា អំពើបាបកើតចេញពីចិត្តរបស់យើង (ម៉ាថាយ ១៥:១៩-២០)។ ការស្ងាត់ស្ងៀមរបស់ខ្ញុំអាចកុហកអ្នកដទៃ ឲ្យគិតថា ខ្ញុំមិនមានបញ្ហាអ្វីទេ ប៉ុន្តែខ្ញុំមិនអាចកុហកព្រះបានឡើយ។ ព្រះអង្គជ្រាបថា ខ្ញុំកំពុងលាក់កំហឹងនៅក្នុងចិត្តខ្ញុំ។ ខ្ញុំប្រៀបដូចជាពួកផារិស៊ី ដែលថ្វាយព្រះកិត្តិនាមដល់ព្រះអម្ចាស់តែបបូរមាត់ តែមិនបានគោរពប្រតិបត្តិព្រះអង្គនៅក្នុងចិត្តទេ (ខ.៨)។ ទោះសប្បុរសក្រៅរបស់ខ្ញុំមិនបានបង្ហាញអារម្មណ៍ពិតរបស់ខ្ញុំក៏ដោយ ក៏ភាពជូរល្វីងកំពុងតែរីកធំឡើងក្នុងចិត្តខ្ញុំ។ ក្តីអំណរ និងភាពជិតស្និទ្ធដែលខ្ញុំមានជាមួយព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ក៏បានរលាយបាត់អស់។ នេះជាផលវិបាកនៃការចិញ្ចឹមចិត្ត និងការលាក់បាំងអំពើបាបនៃការមិនអត់ទោសឲ្យគេ។

ដោយសារព្រះគុណព្រះ ខ្ញុំក៏បានប្រាប់មិត្តរួមការងារខ្ញុំអំពីអារម្មណ៍របស់ខ្ញុំ ហើយក៏បានសុំទោសគាត់។ គាត់ក៏បានអត់ទោសឲ្យខ្ញុំ ហើយទីបំផុតយើងក៏បានក្លាយជាមិត្តល្អ។ ព្រះយេស៊ូវបានមានបន្ទូលថា «ដ្បិតគឺពីក្នុងចិត្តនោះឯងដែលចេញអស់ទាំងគំនិតអាក្រក់» (ខ.១៩)។ ភាពជ្រះស្រឡះក្នុងចិត្តយើងពិតជាសំខាន់ ព្រោះការអាក្រក់ដែលលាក់នៅក្នុងចិត្តយើង អាចហៀបហូរចេញមកក្នុងការរស់នៅរបស់យើង។ ទាំងក្នុងចិត្ត និងសម្បកក្រៅរបស់យើង គឺសុទ្ធតែសំខាន់។—Karen Huang

ព្រះយេស៊ូវមានបន្ទូលថា បាបនៅក្នុងចិត្តយើងធ្វើឲ្យយើងមានភាពស្មោកគ្រោក។ តើមានគំនិតអាក្រក់អ្វីខ្លះ ដែលអាចធ្វើឲ្យចិត្តអ្នកមានបាប? តើអ្នកអាចអធិស្ឋានដូចម្តេចខ្លះអំពីបញ្ហានេះ?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ចំពោះបាបដែលទូលបង្គំកំពុងចិញ្ចឹមក្នុងចិត្តទូលបង្គំ។ ទូលបង្គំចង់ឲ្យចិត្តទូលបង្គំបានសស្អាត គាប់ព្រះទ័យព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យមានការផ្លាស់ប្រែ។

Daily Manna 2026_Content Enhance.indd 68 17/11/25 1:44 in the afternoon

ឲ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នករាល់គ្នា ដោយសារសេចក្តីជំនឿ (អេភេសូរ ៣:១៧)។

ព្រះវត្តមានរបស់ព្រះយេស៊ូវនៅក្នុងចិត្តយើង

ខណៈពេលដែលអាកាសធាតុត្រជាក់ខ្លាំងបានវាយប្រហារមកលើរដ្ឋរបស់ខ្ញុំ នៅភាគខាងលិចនៃសហរដ្ឋអាមេរិក ម្តាយរបស់ខ្ញុំជាស្ត្រីមេម៉ាយ បានព្រមមកស្នាក់នៅជាមួយគ្រួសារខ្ញុំ ទំាខ្យល់ព្យុះទឹកកកកន្លងផុតទៅ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីគ្រោះធម្មជាតិនេះបានកន្លងផុតទៅ គាត់មិនដែលបានត្រឡប់ទៅផ្ទះគាត់វិញទេ។ គាត់បានផ្លាស់មករស់នៅជាមួយគ្រួសារខ្ញុំអស់មួយជីវិត។ វត្តមានរបស់គាត់បានផ្លាស់ប្តូរក្រុមគ្រួសារខ្ញុំ តាមរបៀបវិជ្ជមានជាច្រើន។ ជារៀងរាល់ថ្ងៃ គាត់តែងតែមានពេលចែកចាយប្រាជ្ញា ផ្តល់យោបល់ល្អៗ ដល់សមាជិកគ្រួសារ និងចែកចាយអំពីរឿងរបស់បុព្វបុរសរបស់យើង។ គាត់និងស្វាមីរបស់ខ្ញុំបានក្លាយជាមិត្តល្អបំផុត ដោយពួកគេចូលចិត្តរឿងកំប្លែង និងមើលកីឡាដូចគ្នា។ គាត់មិនមែនជាភ្ញៀវរបស់គ្រួសារយើងទេ តែជាសមាជិកគ្រួសារអចិន្ត្រៃយ៍ដ៏សំខាន់ ដែលនាំមកនូវការផ្លាស់ប្តូរក្នុងចិត្តគំនិតយើង តាំងពីមុនពេលព្រះទ្រង់យកគាត់ទៅជាមួយព្រះអង្គ។

អនុស្សាវរីយ៍នេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីការពិពណ៌នារបស់សាវ័ក យ៉ូហាន អំពីព្រះយេស៊ូវថា ព្រះអង្គ «ស្នាក់នៅជាមួយនឹងយើងរាល់គ្នា» (យ៉ូហាន ១:១៤)។ នេះជាការពិពណ៌នាដែលប៉ះពាល់ចិត្តយ៉ាងខ្លាំង ព្រោះក្នុងព្រះគម្ពីរដើមភាសាក្រិក ពាក្យ «ស្នាក់នៅជាមួយ» គឺមានន័យថា «តាំងទីលំនៅជាមួយ»។

យើងទទួលព្រះយេស៊ូវដោយជំនឿ ជាព្រះដែលគង់នៅក្នុងចិត្តយើង។ គឺដូចដែលសាវ័ក ប៉ុល បានបង្រៀនថា ព្រះយេស៊ូវគង់នៅជាមួយ «ដើម្បីឲ្យទ្រង់បានប្រោសប្រទាន ឲ្យអ្នករាល់គ្នាបានព្រះចេស្តា ចំរើនកំឡាំងនៃមនុស្សខាងក្នុង ដោយសារព្រះវិញ្ញាណទ្រង់ តាមសិរីល្អនៃទ្រង់ដ៏ប្រសើរក្រៃលែង ឲ្យព្រះគ្រីស្ទបានសណ្ឋិតក្នុងចិត្តអ្នករាល់គ្នា ដោយសារសេចក្តីជំនឿ ប្រយោជន៍ឲ្យអ្នករាល់គ្នាបានចាក់ឫស ហើយតាំងមាំមួនក្នុងសេចក្តីស្រឡាញ់» (អេភេសូរ ៣:១៦-១៧)។

ព្រះយេស៊ូវបានយាងមកគង់នៅជាមួយយើង គឺមិនមែនជាភ្ញៀវរបស់យើងនោះទេ។ ព្រះអង្គគង់នៅជាមួយដើម្បីប្រទានកម្លាំងដល់អស់អ្នកដែលដើរតាមព្រះអង្គ។ ចូរយើងបើកទ្វារចិត្តរបស់យើងឲ្យធំទូលាយ ដើម្បីទទួលស្វាគមន៍ព្រះអង្គគង់នៅក្នុងជីវិតយើង ដោយសោយរាជ្យលើបល្ល័ង្កចិត្តយើង ដើម្បីដឹកនាំជីវិតយើងជារៀងរាល់ថ្ងៃ។—Patricia Raybon

តើការបើកចិត្តរបស់យើងទទួលព្រះគ្រីស្ទចូលគង់ មានន័យដូចម្តេចចំពោះអ្នក? តើអ្នកអាចចុះចូលនឹងការដឹកនាំរបស់ព្រះអង្គ ឲ្យកាន់តែខ្លាំងឡើង យ៉ាងដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ជាព្រះនៃសេចក្តីស្រឡាញ់ ខណៈពេលដែលព្រះអង្គគង់នៅក្នុងចិត្តទូលបង្គំ សូមព្រះអង្គកែប្រែទូលបង្គំឲ្យមានលក្ខណៈកាន់តែដូចព្រះអង្គ។

Daily Manna 2026_Content Enhance.indd 69 17/11/25 1:44 in the afternoon

ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលប្រាប់លោកថា ចូរក្រោកឡើងចុះទៅឯទីបោះទ័ពរបស់គេទៅ ដ្បិតអញបានប្រគល់គេមកក្នុងកណ្តាប់ដៃឯងហើយ (ពួកចៅហ្វាយ ៧:៩)។

ព្រះចេស្តារបស់ព្រះខ្លាំងពូកែជាង

កាលពីឆ្នាំ១៩៤៥ «កងទ័ពខ្មោច» បានជួយកងទ័ពអាមេរិក ឲ្យទទួលបានជ័យជម្នះនៅក្នុងការឆ្លងកាត់ទន្លេរ៉ាញចូលទឹកដីប្រទេសអាឡឺម៉ង់ ដោយបានជួយឲ្យកងទ័ពសម្ព័ន្ធមិត្តទទួលបានមូលដ្ឋានកងទ័ពដ៏សំខាន់នៅក្នុងប្រតិបត្តិការណ៍សឹកនៅសមរភូមិខាងលិចនៃសង្គ្រាមលោកលើកទី២។ តាមពិត កងទ័ពទាំងនោះសុទ្ធតែជាមនុស្សមិនមែនជាខ្មោចឡើយ ដែលជាផ្នែកមួយរបស់ទីបញ្ជាការកងទ័ពពិសេសទី២៣។ កាលនោះ កងទ័ពដែលមានគ្នា១១០០នាក់ បានធ្វើឲ្យសត្រូវយល់ឃើញថា ពួកគេមានគ្នា៣ម៉ឺននាក់ ដោយពួកគេប្រើរថក្រោះក្លែងក្លាយ និងចាក់មេក្រូបញ្ចេញសូរសន្ធឹកកងទ័ព និងយានយន្តជាច្រើនគ្រឿងបន្លាស់ទី។ល។ ដូចនេះ សមាជិករបស់កងទ័ពខ្មោច ដែលមានគ្នាតិចជាងសត្រូវបានធ្វើឲ្យសត្រូវជឿថា ពួកគេមានគ្នាច្រើនសន្ធឹក។

ពួកសាសន៍ម៉ាឌាន និងសម្ព័ន្ធមិត្តរបស់ពួកគេ ក៏មានការភ័យខ្លាចផងដែរ នៅចំពោះសត្រូវដែលមានគ្នាតិចដែលធ្វើឲ្យគេគិតស្មានថា ពួកគេមានគ្នាច្រើន (ពួកចៅហ្វាយ ៧:៨-២២)។ ព្រះអម្ចាស់បានប្រើលោក លូអីស គេឌាន ជាពួកចៅហ្វាយ ជាហោរា និងជាអ្នកដឹកនាំកងទ័ពអ៊ីស្រាអែល ឲ្យប្រើប្រាស់កងទ័ពដ៏តូចរបស់គាត់ ឲ្យធ្វើជាប្រភពនៃការភ័យខ្លាចរបស់ពួកខ្មាំងសត្រូវ។ ពួកគេក៏បានប្រើសម្លេងផ្លុំត្រែ សម្លេងបោកក្អម និងសម្លេងមនុស្ស និងរូបភាពបន្លាច ដោយដុតភ្លើងចន្លុះភ្លឺចិញ្ចាចធ្វើឲ្យសត្រូវគិតស្មានថា ពួកគេមានគ្នាច្រើន ដូចហ្វូងសត្វកណ្តូប (ខ.១២)។ ពួកអ៊ីស្រាអែលបានប្រយុទ្ធឈ្នះពួកសត្រូវនៅយប់នោះ ដោយប្រើកងទ័ពដែលបន្ថយចំនួនពី ៣២០០០នាក់ មកនៅត្រឹម ៣០០នាក់ ស្ថិតក្រោមការបញ្ជារបស់ព្រះអម្ចាស់ (ខ.២-៨)។ តើហេតុអ្វី? គឺដើម្បីឲ្យមនុស្សដឹងច្បាស់ថា នរណាពិតជាបានឈ្នះសង្គ្រាមនោះ។ គឺដូចព្រះអង្គប្រាប់លោក លូអីស គេឌាន ថា «ចូរក្រោកឡើងចុះទៅឯទីបោះទ័ពរបស់គេទៅ ដ្បិតអញបានប្រគល់គេមកក្នុងកណ្តាប់ដៃឯងហើយ» (ខ.៩)។

ពេលណាយើងមានអារម្មណ៍ទន់ខ្សោយ និងតូចទៀប ចូរយើងស្វែងរកព្រះអម្ចាស់ ហើយសម្រាកនៅក្នុងកម្លាំងរបស់ព្រះអង្គ។ ដ្បិតព្រះអង្គមានបន្ទូលថា «កំឡាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ» (២កូរិនថូស ១២:៩)។—Tom Felten

តើមានសត្រូវ ឬបញ្ហាប្រឈមដ៏ធំអ្វីខ្លះ ដែលអ្នកកំពុងជួបប្រទះ? តើអ្នកអាចសម្រាកនៅក្នុងព្រះចេស្តារបស់ព្រះដូចម្តេចខ្លះ ខណៈពេលដែលអ្នកប្រឈមមុខដាក់បញ្ហាទាំងនោះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំ ឲ្យរកឃើញកម្ងាំងរបស់ព្រះអង្គក្នុងភាពកម្សោយរបស់ទូលបង្គំ។

Daily Manna 2026_Content Enhance.indd 70 17/11/25 1:44 in the afternoon

ចូររំឭកគេ ឲ្យចុះចូលនឹងពួកនាម៉ឺន ហើយនិងពួកមានអំណាចទាំងអស់ ព្រមទាំងស្តាប់បង្គាប់ ហើយប្រុងប្រៀបធ្វើគ្រប់ទាំងការល្អ (ទីតុស ៣:១)។

ធ្វើការល្អថ្វាយព្រះអង្គ

តាមធម្មតា លោកផាទ្រីក (Patrick) មិនដាក់លុយជាប់ខ្លួនច្រើនទេ តែថ្ងៃមួយ គាត់ក៏មានអារម្មណ៍ថា គាត់គួរតែដាក់លុយ៥ដុល្លា ក្នុងហោប៉ៅគាត់មុនពេលចាកចេញពីផ្ទះ។ ក្នុងអំឡុងពេលអាហារថ្ងៃត្រង់ នៅសាលារៀនដែលគាត់ធ្វើការ គាត់ក៏បានដឹងថា ព្រះទ្រង់បានរៀបចំខ្លួនគាត់ ដើម្បីបំពេញតម្រូវការបន្ទាន់របស់មនុស្សម្នាក់។ នៅពេលអាហារថ្ងៃត្រង់នៅកន្លែងលក់អាហារ គាត់ក៏បានឮគេនិយាយគ្នាថា ក្មេងប្រុសម្នាក់ឈ្មោះស្កត់ធី (Scotty) កំពុងត្រូវការលុយ៥ដុល្លា ដើម្បីបង់ថ្លៃអាហារ ដើម្បីឲ្យអាចញ៉ាំអាហារថ្ងៃត្រង់បានពេញមួយសប្តាហ៍។ សូមយើងស្រមៃថា លោក លូអីស ផាទ្រីក មានអារម្មណ៍យ៉ាងណា នៅពេលដែលគាត់បានឲ្យលុយគាត់ទៅស្កត់ធី!

ក្នុងកណ្ឌគម្ពីរទីតុស សាវ័ក ប៉ុល បានរំឭកអ្នកជឿព្រះយេស៊ូវថា ពួកគេបានសង្គ្រោះ មិនមែនដោយសារការល្អ ដែលពួកគេបានធ្វើ (៣:៥) តែពួកគេគួរតែ «ប្រុងប្រៀបធ្វើគ្រប់ទាំងការល្អ» (ខ.៨ ខ.១៤)។ ជីវិតរបស់យើងអាចមានពេញដោយការជាប់រវល់ និងភាពប្រញាប់ប្រញាល់។ ពេលខ្លះ យើងប្រហែលមានអារម្មណ៍ពិបាកខ្លាំងពេក ក្នុងការព្យាយាមបំពេញតម្រូវការខ្លួនឯង។ ប៉ុន្តែ ក្នុងនាមយើងជាអ្នកជឿព្រះយេស៊ូវ យើងត្រូវតែត្រៀមខ្លួនជាស្រេច ដើម្បី «ធ្វើការល្អ»។ យើងមិនត្រូវមានអារម្មណ៍ពិបាកពេក ដោយសារការអ្វីដែលយើងមិនមាន ឬមិនអាចធ្វើបាន តែចូរយើងគិតអំពីការអ្វីដែលយើងពិតជាមាន និងអាចធ្វើបាន ដោយជំនួយមកពីព្រះអង្គ។ ពេលណាយើងមានផ្នត់គំនិតដូចនេះ យើងអាចជួយបំពេញតម្រូវការអ្នកដទៃ ហើយថ្វាយសិរីល្អដល់ព្រះអង្គ។ «ដូច្នេះ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរតម្កើង ដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌» (ម៉ាថាយ ៥:១៦)។—Arthur Jackson

តើមានអ្វីអាចរារាំងមិនឲ្យអ្នកត្រៀមខ្លួន ធ្វើការល្អក្នុងជីវិតអ្នក? តើអ្នកអាចរៀបចំជីវិតអ្នកឡើងវិញយ៉ាងដូចម្តេច ដើម្បីឲ្យអ្នកអាចត្រៀមខ្លួនជួយអ្នកដទៃ ដែលកំពុងខ្វះខាត?

ឱព្រះវរបិតា សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ នៅពេលណាទូលបង្គំព្រងើយកន្តើយចំពោះឱកាស ដើម្បីធ្វើការល្អ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យត្រៀមខ្លួនជួយអ្នកដទៃ ឲ្យកាន់តែច្រើន។

Daily Manna 2026_Content Enhance.indd 71 17/11/25 1:44 in the afternoon

ព្រះនាមព្រះយេហូវ៉ា ជាប៉មមាំមួន មនុស្សសុចរិតរត់ចូលទៅពឹងជ្រក ហើយមានសេចក្តីសុខ (សុភាសិត ១៨:១០)។

ព្រះដែលជាកន្លែងជ្រកកោនរបស់យើង

ខ្សែភាពយន្តដែលគួរឲ្យកត់សម្គាល់នៅឆ្នាំ២០១៩ មានចំណងជើងថា ស្ត្រីតូចតាចបានធ្វើឲ្យខ្ញុំនឹកចាំអំពីសៀវភៅរឿងប្រលោមលោកចាស់មួយក្បាលដែលបានដាច់ដោច ជាពិសេសគឺពាក្យលើកទឹកចិត្តរបស់តួអង្គឈ្មោះ ម៉ាមី (Marmee) ជាម្តាយដែលមានប្រាជ្ញា និងមានចិត្តសុភាព។ ខ្ញុំមានការចាប់អារម្មណ៍ចំពោះការពិពណ៌នារបស់សៀវភៅប្រលោមលោកនេះអំពីសេចក្តីជំនឿដ៏រឹងមាំរបស់គាត់ ដែលបានបង្កប់នៅក្នុងពាក្យសម្តីលើកទឹកចិត្តជាច្រើន ទៅកាន់កូនស្រីទាំងអស់របស់គាត់។ ខ្ញុំមានការចាប់អារម្មណ៍បំផុតចំពោះពាក្យសម្តីរបស់គាត់ ដែលបានលើកទឹកចិត្តថា «អ្នកអាចជួប... បញ្ហា និងការល្បួងជាច្រើន ប៉ុន្តែអ្នកអាចជម្នះបញ្ហា និងការល្បួងទាំងអស់ បើសិនជាអ្នករៀនទទួលកម្លាំង និងភាពស្រទន់ពីព្រះវរបិតារបស់អ្នកដែលគង់នៅស្ថានសួគ៌»។

សម្រង់សម្តីនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីសេចក្តីពិត ដែលបានចែងក្នុងបទគម្ពីរសុភាសិតថា «ព្រះនាមព្រះយេហូវ៉ា ជាប៉មមាំមួន មនុស្សសុចរិតរត់ចូលទៅពឹងជ្រក ហើយមានសេចក្តីសុខ» (១៨:១០)។ គេសង់ប៉មក្នុងទីក្រុងនៅសម័យបុរាណ ធ្វើជាកន្លែងជ្រកកោនក្នុងពេលមានគ្រោះថ្នាក់ ប្រហែលដោយសារការវាយប្រហារពីសត្រូវ។ ដូចគ្នានេះដែរ គឺតាមរយៈការរត់ទៅរកព្រះ ដែលអ្នកជឿព្រះយេស៊ូវអាចដកពិសោធន៍នឹងសន្តិភាព ក្នុងការថែរក្សារបស់ព្រះអង្គ ដែលជាទីជ្រកកោន និងកម្លាំងរបស់យើង (ទំនុកតម្កើង ៤៦:១)។

បទគម្ពីរ សុភាសិត ១៨:១០ បានប្រាប់យើងអំពីការពារដែលចេញមកពី «ព្រះនាម» របស់ព្រះ ដែលបង្ហាញថា ព្រះអង្គជានរណា។ ព្រះគម្ពីរបានពិពណ៌នាថា ព្រះអង្គជា «ជាព្រះទ្រង់មានព្រះហឫទ័យមេត្តាករុណា ហើយទន់សន្តោស ទ្រង់យឺតនឹងខ្ញាល់ ហើយមានសេចក្តីសប្បុរស និងសេចក្តីទៀងត្រង់ជាបរិបូរ» (និក្ខមនំ ៣៤:៦)។ ការការពាររបស់ព្រះអម្ចាស់ គឺបានមកពីកម្លាំង ក៏ដូចជាសេចក្តីស្រទន់ និងសេចក្តីស្រឡាញ់របស់ព្រះអង្គ ដែលបានបណ្តាលព្រះទ័យព្រះអង្គឲ្យប្រទានកន្លែងជ្រកកោនដល់មនុស្សដែលមានការឈឺចាប់។ សម្រាប់អស់អ្នកដែលកំពុងមានទុក្ខលំបាក ព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ បានប្រទានកន្លែងជ្រកកោននៅក្នុងកម្លាំង និងភាពស្រទន់របស់ព្រះអង្គ។—Lisa M. Samra

តើអ្នកបានដកពិសោធន៍នឹងកម្លាំងរបស់ព្រះអម្ចាស់ក្នុងពេលមានបញ្ហាដូចម្តេចខ្លះ? តើអ្នកបានឃើញព្រះអង្គថែរក្សា ដោយការកម្សាន្តចិត្តនៅពេលណាខ្លះ?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំ ឲ្យរត់ទៅរកព្រះអង្គទាំងក្នុងពេលមានក្តីសុខ ក៏ដូចជាពេលមានទុក្ខលំបាក។

នោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលតបថា «តើមានអ្វីនៅដៃឯងនោះ លោកទូលឆ្វើយថា មានដំបង?» (*និក្ខមនំ ៤:២*)។

ប្រើអ្វីក៏ដោយ ដែលព្រះទ្រង់បានប្រទាន

អាគារសាលាក្រុង នៅទីក្រុងប្រ៊ីសបេន ប្រទេសអូស្ត្រាលីត្រូវបានសាងសង់ក្នុងទសវត្សរ៍ឆ្នាំ១៩២០។ គេធ្វើកាំជណ្តើររបស់អគារនោះ ពីថ្មម៉ាបដ៏ប្រណិត ដែលមានប្រភពនៅក្នុងកន្លែងយកថ្ម ដែលលោក លូអីស ម៉ៃឃលអេនជេឡូ (Michelangelo) បានប្រើប្រាស់ក្នុងការឆ្លាក់រូបចម្លាក់ស្តេច ដាវីឌ។ ប៉មរបស់សាលាក្រុងនោះបានឆ្លុះបញ្ចាំងអំពីព្រះវិហារធំនៅទីក្រុងវេនីស ប្រទេសអ៊ីតាលី ដែលមានដំបូងធ្វើពីទង់ដែងធំបំផុតក្នុងតំបន់ខាងក្បែងនៃផែនដី។ ពួកអ្នកសាងសង់ចង់សាងសង់រូបចម្លាក់តំណាងឲ្យសន្តិភាព ដើម្បីតុបតែងកំពូលប៉ម តែពួកគេមិនមានថវិកាសម្រាប់ការសាងសង់។ កាលនោះ លោក លូអីស ហ្វ្រេត ចនសិន (Fred Johnson) ជាជាងតបណ្តេញទឹក ក៏បានជួយដោះស្រាយបញ្ហានេះ។ គាត់បានប្រើធុងទឹកបង្គន់ បង្គោលភ្លើងចាស់មួយដើម និងកំទេចដែកតូចៗ មកកែឆ្នៃធ្វើរូបដុំមូល ប្រៀបដូចជាមកុដនៅលើកំពូលប៉មនោះអស់រយៈពេលជាង១រយឆ្នាំហើយ។

ការដែលលោក លូអីស ហ្វ្រេដ ចនសិន បានប្រើរបស់អ្វីដែលគាត់មាន ដើម្បីសម្រេចកិច្ចការដ៏សំខាន់នោះ គឺបានរំឭកយើងថា យើងក៏អាចចូលរួមក្នុងកិច្ចការរបស់ព្រះអម្ចាស់ ដោយប្រើការអ្វីដែលយើងមាន ទោះតូចឬធំក្តី។ កាលព្រះអង្គបង្គាប់លោក ម៉ូសេ ឲ្យដឹកនាំពួកអ៊ីស្រាអែលចេញពីទឹកដីអេស៊ីព្ទ លោក ម៉ូសេ បានប្រកែកថា «មើល គេនឹងមិនជឿទូលបង្គំ ឬស្តាប់តាមទូលបង្គំទេ» (៤:១)។ ព្រះអង្គក៏បានឆ្លើយតបដោយសំណួរដ៏សាមញ្ញថា «តើមានអ្វីនៅដៃឯងនោះ?» (ខ.២) លោក ម៉ូសេ កំពុងកាន់ដំបងជាឈើធម្មតាមួយដើម។ ព្រះអង្គក៏បានប្រាប់គាត់ឲ្យបោះដំបងនោះទៅលើដី ហើយវាក៏បានក្លាយជាសត្វពស់ (ខ.៣)។ បន្ទាប់មក ព្រះអង្គក៏បានប្រាប់លោក ម៉ូសេ ឲ្យរើសពស់នោះ ហើយវាក៏បានប្រែក្លាយជាដំបងវិញ។ ព្រះអម្ចាស់ក៏បានពន្យល់ថា ការអ្វីដែលលោក ម៉ូសេ ត្រូវធ្វើ គឺត្រូវកាន់ដំបងនោះ ហើយទុកចិត្តថា ព្រះអង្គនឹងសម្រេចកិច្ចការដែលព្រះអង្គឲ្យគាត់ធ្វើ។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គឺព្រះអង្គបានប្រើដំបងក្នុងដៃរបស់លោក ម៉ូសេ ដើម្បីសង្គ្រោះជនជាតិអ៊ីស្រាអែល ឲ្យរួចផុតពីការកៀបសង្កត់របស់ជនជាតិអេស៊ីព្ទ (៧:១០-១២ ១៧:៥-៧)។

អ្វីដែលយើងមាន ប្រហែលហាក់ដូចជាមិនច្រើនសម្រាប់យើងទេ ប៉ុន្តែអ្វីដែលយើងមានសុទ្ធតែមានភាពគ្រប់គ្រាន់សម្រាប់ឲ្យព្រះអង្គប្រើ។ ព្រះអង្គទទួលយកធនធានដ៏សាមញ្ញរបស់យើង ហើយប្រើពួកវា ដើម្បីសម្រេចកិច្ចការព្រះអង្គ។—Winn Collier

តើមានកិច្ចការដ៏តូចអ្វីខ្លះ ដែលអ្នកអាចធ្វើថ្វាយព្រះអង្គ? ហេតុអ្វីអ្នកចាំបាច់ត្រូវចាត់ទុកចិត្តថា ព្រះអង្គអាចប្រើវា ដើម្បីសម្រេចផែនការព្រះអង្គ?

ឱព្រះអម្ចាស់ ទូលបង្គំសូមថ្វាយអ្វីៗទាំងអស់ដែលទូលបង្គំមាន។

គម្រោងអានព្រះគម្ពីរប្រចាំឆ្នាំ ១រយៈពេល១ឆ្នាំ | ចោទិយកថា ៥-៧ និងម៉ាកុស ១១:១-១៨

ខាងឯសេចក្តីឧស្សាហ៍ នោះកុំឲ្យខ្ជិលឡើយ ខាងឯវិញ្ញាណ នោះក៏ចូរព្យាយាមចុះ ដោយខំប្រឹងបំរើព្រះអម្ចាស់ (រ៉ូម ១២:១១)។

ការចែកចាយអំពីភាពឆេះឆួលចំពោះព្រះគ្រីស្ទ

កាលយើងបានជួបលោក លូអីស ហេនរី (Henry) ជាអ្នកជិតខាងលើកដំបូង គាត់បានដកព្រះគម្ពីរចាស់ដាច់រហែកមួយក្បាលចេញពីការបូបដែលគាត់តែងតែស្ពាយជាប្រចាំ។ គាត់មើលមកយើងដោយទឹកមុខរីករាយ ហើយសួរយើងថា តើយើងចង់ជជែកគ្នាជាមួយគាត់អំពីព្រះគម្ពីរដែរឬទេ។ យើងក៏បានងក់ក្បាល ហើយគាត់ក៏បានបើកទៅកាន់ទំព័រដែលគាត់បានគូសចំណាំនៅលើខគម្ពីរមួយចំនួន។ គាត់ក៏បានបង្ហាញសៀវភៅកត់ត្រាមួយក្បាល ដែលគាត់បានកត់ទុកអំពីអ្វីដែលគាត់រៀនបានពីព្រះគម្ពីរ ហើយក៏បានមានប្រសាសន៍ថា គាត់បានបង្កើតមេរៀនក្នុងកុំព្យូទ័រ ដែលមានពេញទៅដោយឯកសារយោងដទៃទៀត។

លោក លូអីស ហេនរី ក៏បានចែកចាយអំពីពេលដែលគាត់បានចេញពីស្ថានភាពគ្រួសារដ៏ពិបាក ហើយបន្ទាប់មក កាលគាត់កំពុងស្ថិតក្នុងស្ថានភាពឯកោ និងពិបាកបំផុត គាត់ក៏បានទទួលយកការសុគត និងការមានព្រះជន្មឡើងវិញរបស់ព្រះយេស៊ូវ ធ្វើជាមូលដ្ឋានគ្រឹះនៃសេចក្តីជំនឿរបស់គាត់ (កិច្ចការ ៤:១២)។ ជីវិតគាត់មានការផ្លាស់ប្តូរ ខណៈពេលដែលព្រះវិញ្ញាណបានជួយគាត់ ឲ្យដើរតាមគោលការណ៍របស់ព្រះគម្ពីរ។ ទោះលោក លូអីស ហេនរី បានថ្វាយជីវិតគាត់ដល់ព្រះអង្គកាលប៉ុន្មានឆ្នាំមុនក៏ដោយ ក៏ភាពក្លៀវក្លារបស់គាត់នៅតែថ្មីជានិច្ច ហើយបាននាំឲ្យមានការប៉ះពាល់ចិត្តណាស់។

ភាពឧស្សាហ៍របស់លោក លូអីស ហេនរី បានបណ្តាលចិត្តខ្ញុំជាអ្នកដើរតាមព្រះយេស៊ូវអស់ជាច្រើនឆ្នាំ ឲ្យពិចារណាអំពីភាពឆេះឆួលខាងវិញ្ញាណរបស់ខ្ញុំផងដែរ។ សាវ័ក ប៉ុល បានបង្រៀនយើងថា «ខាងឯសេចក្តីឧស្សាហ៍ នោះកុំឲ្យខ្ជិលឡើយ ខាងឯវិញ្ញាណ នោះក៏ចូរព្យាយាមចុះ ដោយខំប្រឹងបំរើព្រះអម្ចាស់» (រ៉ូម ១២:១១)។ ការបង្រៀននេះមិនពិបាកឲ្យយើងអនុវត្តន៍តាមទេ បើសិនជាយើងអនុញ្ញាតឲ្យព្រះបន្ទូលកែប្រែយើង ឲ្យមានអាកប្បកិរិយា ដែលអរព្រះគុណព្រះអង្គសម្រាប់ការគ្រប់យ៉ាង ដែលព្រះយេស៊ូវបានធ្វើសម្រាប់ខ្ញុំ។

ទោះយើងមានអារម្មណ៍ឡើង ឬចុះយ៉ាងណាក៏ដោយក្នុងជីវិតយើង ភាពឧស្សាហ៍ថ្វាយព្រះគ្រីស្ទកើតចេញពីទំនាក់ទំនងជាមួយព្រះអង្គ ដែលចេះតែចម្រើនឡើងជានិច្ច។ ពេលណាយើងបានស្គាល់ព្រះអង្គកាន់តែច្រើនប៉ុណ្ណា នោះយើងនឹងមើលឃើញតម្លៃព្រះអង្គកាន់តែច្បាស់ ហើយសេចក្តីល្អរបស់ព្រះអង្គក៏ជន់ជោរក្នុងវិញ្ញាណយើង ហើយហៀរហូរចូលទៅក្នុងលោកីយ៍។—Jennifer Benson Schuldt

តើអ្នកយល់ឃើញថា ព្រះយេស៊ូវមានអារម្មណ៍យ៉ាងណានៅពេលដែលព្រះអង្គទតឃើញអ្នកមានចិត្តឆេះឆួលចំពោះព្រះអង្គ? តើការអរព្រះគុណ និងភាពឧស្សាហ៍ខាងវិញ្ញាណមានទំនាក់ទំនងគ្នាដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យមានភាពឆេះឆួលជាថ្មី នៅក្នុងការស្គាល់ព្រះអង្គ!

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ចោទិយកថា ៨-១០ និងម៉ាកុស ១១:១៩-៣៣

ឱព្រះយេហូវ៉ាអើយ អស់ទាំងស្នាដៃរបស់ទ្រង់មាន ច្រើនប្រការណាស់ហ្ន៎ ទ្រង់បានធ្វើទាំងអស់ដោយប្រាជ្ញា (ទំនុកតម្កើង ១០៤:២៤)។

ព្រះអម្ចាស់បានបង្កើតពួកវាទាំងអស់

ថ្ងៃមួយ ខ្ញុំបាននាំកូនប្រុសខ្ញុំអាយុ៣ឆ្នាំ ឈ្មោះ ហ្សាវ៉ា (Xavier) ចូលមើលសួនត្រីក្រោមទឹកនៅឆ្នេរមុនតេរេយ ក្នុងរដ្ឋកាលីហ្វ័ញ៉ា។ ហ្សាវ៉ា ក៏បានកាន់ដៃខ្ញុំយ៉ាងណែន ពេលយើងដើរចូលទៅក្នុងសួនត្រីនោះ។ គាត់ចង្អុលទៅរកសត្វត្រីបាឡែនមានបូកខ្នង ដែលខ្លួនវាលាតសន្ធឹងពីលើពីដានកញ្ចក់ ដែលនៅពីលើយើង។ គាត់លាន់មាត់ថា «វាពិតជាធំណាស់!» គាត់បន្តបើកភ្នែកធំ ដោយការភ្ញាក់ផ្អើល ខណៈពេលដែលយើងដើរទស្សនាពីកន្លែងមួយទៅកន្លែងមួយទៀត។ យើងអស់សំណើច ពេលដែលយើងបានឃើញសត្វភេមុជទឹកចុះឡើងធ្វើឲ្យទឹកបាចសាច ក្នុងពេលពួកវាស៊ីចំណី។ យើងឈរដោយភាពស្ងប់ស្ងាត់នៅពីមុខបង្អួចកញ្ចក់ធំមួយរបស់សួនត្រី ដោយការជក់ចិត្តចំពោះសត្វពពុះសមុទ្រ ដែលកំពុងរ៉ាំក្នុងទឹកសមុទ្រពណ៌ខៀវ។ ខ្ញុំក៏បាននិយាយថា «ព្រះអង្គបានបង្កើតសត្វទាំងអស់ក្នុងមហាសមុទ្រ ដូចដែលព្រះអង្គបានបង្កើតប៉ា និងកូនផងដែរ»។ គាត់ក៏បាននិយាយឌ្បិបៗថា «ព្រះអង្គពិតជាអស្ចារ្យណាស់»។

ក្នុងបទគម្ពីរទំនុកតម្កើង១០៤ អ្នកនិពន្ធបទគម្ពីរទំនុកតម្កើងបានទទួលស្គាល់ការបង្កើតជាបរិបូររបស់ព្រះអម្ចាស់ ហើយគាត់ក៏បានបន្លឺសម្លេងច្រៀងថា «ឱព្រះយេហូវ៉ាអើយ អស់ទាំងស្នាដៃរបស់ទ្រង់មានច្រើនប្រការណាស់ហ្ន៎ ទ្រង់បានធ្វើទាំងអស់ដោយប្រាជ្ញា» (ខ.២៤)។ គាត់ប្រកាសថា «នុ៎ះន៏ សមុទ្រដ៏ធំ ហើយទូលាយនៅក្នុងទឹកនោះមានរបស់រវើកតតគណនា ជាសត្វទាំងតូចទាំងធំ» (ខ.២៥)។ គាត់ក៏បានថ្លែងអំពីសេចក្តីសប្បុរស និងការផ្គង់ផ្គង់ដ៏ស្កប់ស្កល់របស់ព្រះអង្គ សម្រាប់ជីវិតទាំងអស់ដែលព្រះអង្គបានបង្កើត (ខ.២៧-២៨)។ គាត់ក៏បានបញ្ជាក់ថា ព្រះអង្គក៏បានកំណត់ចំនួនថ្ងៃ ដែលជីវិតនីមួយៗអាចរស់នៅ (ខ.២៩-៣០)។

យើងអាចចូលរួមជាមួយអ្នកនិពន្ធបទគម្ពីរទំនុកតម្កើង ក្នុងការច្រៀងប្រកាសអំពីការប្តេជ្ញាចិត្តរបស់យើងថា «កាលនៅមានជីវិតនៅឡើយ នោះទូលបង្គំនឹងច្រៀងថ្វាយព្រះយេហូវ៉ាជាដរាប កាលទូលបង្គំមាននៅឡើយ នោះនឹងច្រៀងសរសើរដល់ព្រះនៃទូលបង្គំ» (ខ.៣៣)។ សត្វទាំងអស់ដែលមានជីវិត ទាំងតូចទាំងធំសុទ្ធតែអាចបណ្តាលចិត្តយើងឲ្យសរសើរតម្កើងព្រះអង្គ ព្រោះព្រះអង្គបានបង្កើតពួកវាមក។—Xochitl Dixon

តើនៅពេលណាខ្លះ ការពិចារណាអំពីពិភពលោកដ៏អស្ចារ្យដែលព្រះបានបង្កើត បានបណ្តាលចិត្តអ្នកឲ្យសរសើរតម្កើងព្រះអង្គ? តើព្រះអង្គបានប្រើស្នាព្រះហស្តព្រះអង្គ ដើម្បីជួយឲ្យអ្នកមានជំនឿកាន់តែរឹងមាំទៅលើព្រះចេស្តា និងការផ្គង់ផ្គង់របស់ព្រះអង្គដូចម្តេចខ្លះ?

ឱព្រះអាទិករ និងព្រះដ៏ផ្គត់ផ្គង់មានគ្រប់ចេស្តា ព្រះអង្គស័ក្តិសមនឹងឲ្យទូលបង្គំសរសើរតម្កើងព្រះអង្គ។

Daily Manna 2026_Content Enhance.indd 75 17/11/25 1:44 in the afternoon

ដូច្នេះ ចូរទៅចុះ ឲ្យបរិភោគអាហាររបស់ឯងដោយអំណរ ហើយផឹកស្រាទំពាំងបាយជូររបស់ឯង ដោយចិត្តរីករាយផង ដ្បិតព្រះទ្រង់បានទទួលការរបស់ឯងហើយ (សាស្តា ៩:៧)។

ការប្រើប្រាស់ពេលវេលាក្នុងជីវិត

កាលពីពេលថ្មីៗនេះ ខ្ញុំបានអានរឿងប្រលោមលោក ដែលនិយាយអំពីស្ត្រីម្នាក់ឈ្មោះ នីកូឡា (Nicola) ដែលបានបដិសេធន៍មិនព្រមទទួលស្គាល់ថា គាត់មានជំងឺមហារីកដំណាក់កាលចុងក្រោយ។ នៅពេលដែលមិត្តភក្តិរបស់គាត់បង្ខំគាត់ ឲ្យទទួលស្គាល់ការពិត គាត់ក៏បានប្រាប់ពីមូលហេតុ។ គាត់ប្រាប់ពួកគេថា គាត់បានខ្ជះខ្ជាយពេលវេលាក្នុងជីវិតគាត់។ គាត់ថា គាត់បានចាប់កំណើត នៅលើគំនរទ្រព្យសម្បត្តិ គាត់មានទេពកោសល្យ តែគាត់មិនបានប្រើជីវិតឲ្យមានប្រយោជន៍ គាត់មានភាពខ្ជិលច្រអូស ហើយមិនដែលបានធ្វើអ្វីជាដុំកំភួនទេ។ ពេលដែលគាត់ដឹងថា គាត់ជិតដល់ពេលលាចាកលោក គាត់មានអារម្មណ៍ថា គាត់សម្រេចបានសមិទ្ធផលតិចតួច ហើយគាត់មានការឈឺចាប់ខ្លាំងពេក មិនចង់ទទួលស្គាល់ការពិត។

កាលនោះ ខ្ញុំក៏កំពុងអានកណ្ឌគម្ពីរសាស្តាផងដែរ ហើយក៏បានរកឃើញភាពផ្ទុយគ្នា។ ព្រះអម្ចាស់ដែលជាគ្រូក្នុងកណ្ឌគម្ពីរសាស្តាមិនអនុញ្ញាតឲ្យយើងជៀសវាងការពិតនៃសេចក្តីស្លាប់ឡើយ បានជាទ្រង់មានបន្ទូលថា «នៅក្នុងស្ថានឃុំព្រលឹងមនុស្សស្លាប់ ជាកន្លែងដែលឯងត្រូវនៅ» (៩:១០)។ ហើយការនេះពិបាកនឹងឲ្យយើងប្រឈមមុខដាក់ (ខ.២) តែវាអាចនាំយើងឲ្យតម្លៃមកលើពេលវេលាដែលយើងកំពុងមាន (ខ.៤) ដោយពិតជាអរសប្បាយនឹងអាហារ និងក្រមគ្រួសារយើង (ខ.៧-៩) និងធ្វើការងារអស់ពីចិត្ត (ខ.១០) ហើយធ្វើការវិនិយោគ និងហ៊ានប្រថុយ (១១:១, ៦) ហើយធ្វើរឿងទាំងអស់នោះនៅចំពោះព្រះ ដែលនឹងជំនុំជម្រះយើងនៅថ្ងៃណាមួយ (ខ.៩ ១២:១៣-១៤)។

មិត្តភក្តិរបស់នីកូឡាក៏បានចង្អុលបង្ហាញដល់នាងថា ភាពស្មោះត្រង់ និងសេចក្តីសប្បុរសដែលនាងមានចំពោះពួកគេ តាំងពីដើមមក គឺជាភស្តុតាងបង្ហាញថា ការរស់នៅរបស់នាងមិនអត់ប្រយោជន៍នោះទេ។ ប៉ុន្តែ យើងរាល់គ្នាសុទ្ធតែអាចជៀសវាងរឿងវិបត្តិដូចនេះ ក្នុងចុងបញ្ចប់នៃជីវិតយើង ដោយអនុវត្តន៍តាមកណ្ឌគម្ពីរសាស្តាដែលបានបង្រៀនយើង ឲ្យនឹកចាំព្រះអាទិករបស់យើង (១២:១) ដើរតាមផ្លូវព្រះអង្គ ហើយឱបក្រសោបយកឱកាសនីមួយៗ ដែលព្រះអង្គប្រទាននៅថ្ងៃនីមួយៗ ដើម្បីរស់នៅ និងដើម្បីស្រឡាញ់។—Sheridan Voysey

តើអ្នកអាចមានអំណរក្នុងការប្រើប្រាស់ពេលវេលា ឲ្យមានប្រយោជន៍ ថ្វាយព្រះអង្គដូចម្តេចខ្លះនៅថ្ងៃនេះ? តើមានការល្អអ្វី ដែលអ្នកមិនទាន់បានធ្វើ?

ឱព្រះនៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ពេលថ្ងៃនេះ និងអំណោយនៅថ្ងៃនីមួយៗ។ ទូលបង្គំនឹងអរសប្បាយនឹងការប្រើប្រាស់ឱកាសដែលព្រះអង្គប្រទាន ដើម្បីធ្វើគ្រប់កិច្ចការទាំងអស់ក្នុងន័យថ្វាយបង្គំព្រះអង្គ។

គម្រោងអានព្រះគម្ពីរអេ:ពេល១ឆ្នាំ | ចោទិយកថា ១៤-១៦ និងម៉ាកុស ១២:២៨-៤៤

ខ្ញុំនឹងចូលទៅគាល់ស្តេច ដែលជាការខុសច្បាប់ហើយបើខ្ញុំត្រូវស្លាប់ ក៏ស្លាប់ទៅចុះ (នាងអេសធើរ ៤:១៦)។

មានចិត្តក្លាហាន ក្នុងព្រះគ្រីស្ទ

នៅជិតដើមដំបូងនៃសតវត្សរ៍ទី១៩ អ្នកស្រី ម៉ារី មែគដូវែល (Mary McDowell) កំពុងរស់នៅក្នុងតំបន់ដែលមានភាពខុសគ្នាស្រឡះពីកន្លែងពិឃាតសត្វចិញ្ចឹមយកសាច់ដ៏សាហាវព្រៃផ្សៃក្នុងទីក្រុងឈីកាហ្គោ។ ផ្ទះរបស់គាត់ស្ថិតនៅចម្ងាយតែ៣០គីឡូម៉ែត្រពីកន្លែងនោះ តែគាត់បានដឹងតិចតួចអំពីស្ថានភាពនៃដ៏គួរឲ្យសង្វេគរបស់កម្មករ ដែលធ្វើការនៅកន្លែងនោះ ដែលបានជំរុញពួកគេឲ្យធ្វើកូដកម្ម។ បន្ទាប់ពីគាត់បានដឹងអំពីទុក្ខលំបាកដែលពួកគេ និងក្រុមគ្រួសាររបស់ពួកគេកំពុងជួបប្រទះ គាត់ក៏បានផ្លាស់ទីលំនៅទៅរស់នៅក្នុងចំណោមពួកគេ ដោយជួយលើកកម្ពស់ស្ថានភាពនៃការរស់នៅរបស់ពួកគេ ឲ្យបានល្អប្រសើរឡើង។ គាត់ក៏បានជួយបំពេញតម្រូវការរបស់ពួកគេ ដោយបានបង្រៀនក្មេងៗក្នុងសាលារៀននៅខាងក្រោមហាងលក់ទំនិញតូចមួយផងដែរ។

ការជួយអ្នកដទៃឲ្យមានស្ថានភាពនៃការរស់នៅល្អប្រសើរជាងមុន ទោះខ្លួនមិនបានទទួលផលប៉ះពាល់ដោយផ្ទាល់ ក៏ជាការអ្វីដែលនាងអេសធើរបានធ្វើផងដែរ។ នាងបានក្លាយជាមហាក្សត្រីរបស់ចក្រភពពើស៊ី (នាងអេសធើរ ២:១៧) ហើយមានឯកសិទ្ធិខុសពីប្រជាជនអ៊ីស្រាអែលរបស់នាង ដែលកំពុងរស់នៅខ្ចាត់ខ្ចាយក្នុងការនិរទេសនៅទូទាំងចក្រភពពើស៊ី។ តែនាងបានទទួលយកបុព្វហេតុរបស់ប្រជាជនអ៊ីស្រាអែលក្នុងចក្រភពពើស៊ី និងបានប្រថុយជីវិត ដើម្បីពួកគេផងដែរ ដោយថ្លែងថា «ខ្ញុំនឹងចូលទៅគាល់ស្តេច ដែលជាការខុសច្បាប់ហើយបើខ្ញុំត្រូវស្លាប់ ក៏ស្លាប់ទៅចុះ» (៤:១៦)។ នាងអាចបន្តនៅស្ងៀម ព្រោះស្តេចដែលជាព្រះស្វាមីរបស់នាងមិនបានដឹងថា នាងជាជនជាតិយូដានោះទេ (២:១១)។ ប៉ុន្តែ នាងបានសម្រេចចិត្តថា នាងនឹងមិនព្រងើយកន្តើយចំពោះការអង្វររបស់សាច់ញាតិរបស់នាងបានជានាងធ្វើនូវរឿងដ៏ក្លាហាន ដើម្បីបើកបង្ហាញផែនការអាក្រក់ ដែលគេបានបង្កើត ដើម្បីសម្លាប់ជនជាតិយូដាឲ្យផុតពូជ។

យើងប្រហែលមិនមានឱកាសបំពេញបុព្វហេតុធំៗដូចនាង ម៉ារី មែកដូវែល ឬព្រះនាង អេសធើរនោះទេ តែយើងអាចសម្រេចចិត្តបំពេញតម្រូវការអ្នកដទៃ ហើយប្រើការអ្វីដែលព្រះទ្រង់បានប្រទានយើង ដើម្បីជួយពួកគេ។—Katara Patton

តើអ្នកកំពុងប្រើអ្វីដែលអ្នកមាន ដើម្បីជួយអ្នកដទៃយ៉ាងដូចម្តេចខ្លះ? តើអ្នកអាចបំពេញតួនាទីអ្វី ក្នុងការបំពេញតម្រូវការរបស់អ្នកដែលរស់នៅឆ្ងាយពីអ្នក?

ឱព្រះអម្ចាស់ សូមព្រះអង្គប្រទានទូលបង្គំនូវប្រាជ្ញា និងចិត្តក្លាហាន ដើម្បីបម្រើអ្នកដែលត្រូវការជំនួយ។

Daily Manna 2026_Content Enhance.indd 77 17/11/25 1:44 in the afternoon

ខ្ញុំបានអំពាវនាវដល់ព្រះយេហូវ៉ា ដោយសេចក្តីវេទនារបស់ខ្ញុំ ព្រះយេហូវ៉ាទ្រង់ក៏ទទួលស្តាប់ ហើយបានដាក់ខ្ញុំទុកនៅទីធំទូលាយ (ទំនុកតម្កើង ១១៨:៥)។

អំពាវនាវដល់ព្រះអង្គ ក្នុងទុក្ខវេទនា

កាលក្មេងស្រីជនជាតិស៊ីរីឈ្មោះ ជីណាន (Jinan) កំពុងជាប់ខ្លួននៅក្រោមអគារពីរជាន់ ដែលបានដួលរលំ ដោយសារគ្រោះរញ្ជួយដី នាងក៏បានស្រែកហៅក្រុមអ្នកជួយសង្គ្រោះ ខណៈពេលដែលនាងកំពុងប្រើខ្លួននាងជាខែលការពារប្អូនប្រុសរបស់នាង ឲ្យរួចផុតពីកំទេចថ្មដែលធ្លាក់នៅជុំវិញពួកគេ។ នាងក៏បានស្រែកហៅគេ ដោយសម្លេងដ៏សង្វេគថា «សូមយកខ្ញុំចេញពីកន្លែងនេះ។ ទោះអ្នកឲ្យខ្ញុំធ្វើអ្វី ក៏ខ្ញុំព្រមដែរ។ ខ្ញុំនឹងធ្វើជាអ្នកបម្រើរបស់អ្នក»។

ការស្រែកសូមឲ្យព្រះអម្ចាស់ជួយក្នុងសេចក្តីវេទនា គឺជារឿងដែលមានចែងក្នុងកណ្ឌគម្ពីរទំនុកតម្កើងទាំងមូល ដែលមានដូចជា៖ «ខ្ញុំបានអំពាវនាវដល់ព្រះយេហូវ៉ា ដោយសេចក្តីវេទនារបស់ខ្ញុំ» (១១៨:៥)។ យើងប្រហែលមិនដែលបានដកពិសោធន៍ជាមួយនឹងការជាប់ខ្លួនក្នុងអគារដែលបាក់ស្រុត ដោយសារគ្រោះរញ្ជួយដីទេ តែយើងរាល់គ្នាសុទ្ធតែ ស្គាល់ការភ័យខ្លាច ដោយសារការពិនិត្យសុខភាពឃើញមានជំងឺ ទុក្ខលំបាកផ្នែកសេដ្ឋកិច្ច ភាពមិនច្បាស់លាស់នៃពេលអនាគត ឬការបាត់បង់ទំនាក់ទំនងជាដើម។

ក្នុងពេលបែបនោះ យើងប្រហែលទូលសូមព្រះអម្ចាស់ជួយរំដោះយើង។ ប៉ុន្តែ ព្រះអង្គមិនត្រូវការឲ្យយើងបញ្ចុះបញ្ចូលព្រះអង្គ ឲ្យជួយយើងនោះទេ។ ព្រះអង្គបានសន្យាថានឹងឆ្លើយតប ហើយទោះព្រះអង្គមិនរំដោះយើងឲ្យរួចពីស្ថានភាពដ៏លំបាករបស់យើងភ្លាមៗក៏ដោយ ក៏ព្រះអង្គនៅតែគង់នៅជាមួយយើង ហើយកាន់ខាងយើង។ ហើយយើងក៏មិនចាំបាច់ត្រូវខ្លាចគ្រោះថ្នាក់ណាមួយ ដែលរាប់បញ្ចូលទាំងសេចក្តីស្លាប់ផងដែរ។ យើងអាចពោលឡើងជាមួយអ្នកនិពន្ធបទគម្ពីរទំនុកតម្កើងថា «ព្រះយេហូវ៉ាទ្រង់កាន់ខាងខ្ញុំ ជាមួយនឹងពួកអ្នកដែលជួយខ្ញុំដែរ ដូច្នេះខ្ញុំនឹងឃើញការកើតដល់ពួកអ្នកដែលស្អប់ខ្ញុំ តាមបំណងចិត្តខ្ញុំ» (ខ.៧)។

ព្រះអង្គមិនបានសន្យាថា យើងនឹងរួចពីគ្រោះថ្នាក់ភ្លាមៗ ដូច ជីណាន និងប្អូនប្រុសរបស់នាងឡើយ តែយើងអាចទុកចិត្តព្រះដ៏ស្មោះត្រង់របស់យើង ដែលបាននាំអ្នកនិពន្ធទំនុកតម្កើងទៅកន្លែងដ៏ធំទូលាយ (ខ.៥)។ ព្រះអង្គជ្រាបអំពីស្ថានភាពរបស់យើង ហើយព្រះអង្គនឹងមិនបោះបង់ចោលយើងឡើង ទោះក្នុងសេចក្តីស្លាប់ក៏ដោយ។—Matt Lucas

តើព្រះអម្ចាស់បានបង្ហាញសេចក្តីស្មោះត្រង់របស់ព្រះអង្គដូចម្តេចខ្លះ ពេលអ្នកជួបទុក្ខវេទនា? តើអ្នកបានឃើញព្រះវត្តមានព្រះអង្គដូចម្តេចខ្លះ ក្នុងអំឡុងពេលដ៏ពិបាក?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំស្រែករកព្រះអង្គ ដោយដឹងថា ព្រះអង្គឮទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលមានព្រះទ័យស្មោះត្រង់ និងមានសេចក្តីស្រឡាញ់ចំពោះទូលបង្គំ។

Daily Manna 2026_Content Enhance.indd 78 17/11/25 1:44 in the afternoon

សម័យ១យ៉ាកុបកំពុងតែស្ងួសំឡ នោះអេសាវមកពីវាលទាំងហេវ ក៏និយាយថា «សូមចែកសំឡក្រហមនោះឲ្យបងបរិភោគផង ដ្បិតបងហេវណាស់» (លោកុប្បត្តិ ២៥:២៩-៣០)។

មានតែព្រះអង្គទេ អាចបំបាត់ការស្រេកឃ្លាន

មានពេលមួយគេបានដឹកអាហារមានតម្លៃ១ពាន់ដុល្លា ទៅកាន់ម្ចាស់ផ្ទះម្នាក់ ដែលអាហារនោះរួមមាន៖ បង្គាចាំបុ អាហារអារ៉ាប់សារ៉ាម៉ា សាឡាត់ និងអាហារថ្លៃៗជាច្រើនទៀត។ ប៉ុន្តែ បុរសនោះមិនមានពិធីជប់លៀងទេ។ តាមពិត កូនប្រុសគាត់អាយុ៦ឆ្នាំ ជាអ្នកបញ្ជាទិញអាហារដ៏ច្រើនដូចនេះ។ តើរឿងនេះបានកើតឡើង ដោយរបៀបណា? បុរសជាឪពុកបានឲ្យកូនប្រុសគាត់លេងទូរស័ព្ទរបស់គាត់មុនម៉ោងចូលគេង ហើយក្មេងប្រុសនោះក៏បានប្រើទូរស័ព្ទគាត់ បញ្ជាទិញអាហារថ្លៃៗពីភោជនដ្ឋានមួយចំនួនក្នុងទីក្រុង។ គាត់ក៏បានសួរកូនប្រុសគាត់ថា «ហេតុអ្វីកូនធ្វើដូចនេះ?» កូនប្រុសគាត់ដែលកំពុងពួននៅក្រោមភួយ ក៏បានឆ្លើយថា «កូនឃ្លាន»។ ដូចនេះ ការឃ្លានអាហារ និងភាពមិនទាន់គ្រប់អាយុរបស់ក្មេងប្រុសនេះ បានបណ្តាលឲ្យមានការខាតបង់ប្រាក់ជាច្រើន។

ប៉ុន្តែ ការស្រេកឃ្លានអាហាររបស់លោក លូអ៊ីស អេសាវ បានបណ្តាលឲ្យគាត់ខាតបង់លើសពី១ពាន់ដុល្លា។ រឿងដែលបានចែងក្នុងបទគម្ពីរលោកុប្បត្តិជំពូក២៥ បានចែងថា កាលគាត់កំពុងអស់កម្លាំង និងឃ្លានអាហារ គាត់ក៏បានប្រាប់ប្អូនប្រុសគាត់ថា «សូមចែកសំឡក្រហមនោះឲ្យបងបរិភោគផង ដ្បិតបងហេវណាស់» (ខ.៣០)។ លោក លូអ៊ីស យ៉ាកុប ជាប្អូនក៏បានឆ្លើយតប ដោយទាមទារលោក លូអ៊ីស អេសាវ ឲ្យផ្ទេរអំណាចមរដករបស់បងច្បងមកឲ្យគាត់ (ខ.៣១)។ អំណាចកូនច្បង គឺបានរាប់បញ្ចូលហ៊ានៈពិសេសរបស់លោក លូអ៊ីស អេសាវ ជាកូនច្បង ព្រះពរដែលព្រះទ្រង់សន្យាប្រទានមរតកសម្រាប់កូនច្បង និងឯកសិទ្ធិក្នុងការធ្វើជាអ្នកដឹកនាំខាងវិញ្ញាណក្នុងគ្រួសារ។ ព្រោះតែចង់បំបាត់ការស្រេកឃ្លាន លោក លូអ៊ីស អេសាវ ក៏បានបរិភោគអាហាររបស់លោក លូអ៊ីស យ៉ាកុប ដោយការមើលងាយអំណាចមរតកនៃបងច្បង (ខ.៣៤)។

ពេលណាយើងជួបការល្បួង ឲ្យចង់បានអ្វីមួយ ចូរយើងកុំបណ្តោយឲ្យការស្រេកឃ្លាន ឬសេចក្តីប៉ងប្រាថ្នាខាងសាច់ឈាម ដឹកនាំយើងទៅរកការប្រព្រឹត្តខុស ឬអំពើបាបឡើយ ផ្ទុយទៅវិញចូរយើងឈោងទៅរកព្រះវរបិតាដែលគង់នៅស្ថានសួគ៌មានតែព្រះអង្គទេ ដែលអាចបម្ពែកវិញ្ញាណយើង ដោយ «សេចក្តីល្អ» (ទំនុកតម្កើង ១០៧:៩)។—Marvin Williams

តើអ្នកបានបណ្តោយឲ្យការល្បួងដឹកនាំអ្នកទៅរកការខាតបង់ដ៏ធ្ងន់ធ្ងរ នៅពេលណាខ្លះ? ហេតុអ្វីមានតែព្រះទេ ដែលអាចបំបាត់ការស្រេកឃ្លានដែលជ្រាលជ្រៅបំផុតរបស់អ្នកបាន?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំ កុំឲ្យបណ្តោយខ្លួនទៅតាមការល្បួង ដោយលះបង់សេចក្តីបរិសុទ្ធ និងសេចក្តីស្មោះត្រង់ ដើម្បីបំពេញអារម្មណ៍ខ្លួនឯងនោះឡើយ។ ទូលបង្គំ។

គម្រោងអានព្រះគម្ពីរអេ:ពេល១ឆ្នាំ | ចោទិយកថា ២៣-២៥ និងម៉ាកុស ១៤:១-២៦

មានការអាក្រក់យ៉ាងធ្ងន់១មុខ ដែលយើងបានឃើញនៅក្រោមថ្ងៃ គឺមានទ្រព្យសម្បត្តិដែលម្ចាស់រក្សាទុកដរាបដល់កើតអន្តរាយដល់ខ្លួន (សាស្តា ៥:១៣)។

បន្សល់ទុកកេរដំណែលដ៏ស្ថិតស្ថេរ

ការខ្យល់ព្យុះដីខ្សាច់ (Dust Bowl) បានបង្កវិនាសកម្ម ក្នុងទឹកដីសហរដ្ឋអាមេរិក ក្នុងអំឡុងសម័យមហាវិបត្តិសេដ្ឋកិច្ច លោក លូអីស ចន មីលប៊ឺន ដេវីស (John Millburn Davis) ជាអ្នកក្រុងហៃវ៉ាថា រដ្ឋខេនសាស់ បានសម្រេចចិត្តធ្វើឲ្យខ្លួនឯងបានកេរ្តិ៍ឈ្មោះល្បី។ ក្នុងនាមគាត់ជាមហាសេដ្ឋីដែលគ្មានកូនសម្រាប់ស្នងមរតក លោក លូអីស ដេវីស គួរតែបរិច្ចាគទ្រព្យសម្បត្តិគាត់ទៅកាន់អង្គការមនុស្សធម៌ ឬការអភិវឌ្ឍន៍សេដ្ឋកិច្ច។ តែផ្ទុយទៅវិញ គាត់បានខ្ជះខ្ជាយប្រាក់ជាច្រើនក្នុងការសាងសង់រូបចម្លាក់របស់គាត់ និងភរិយារបស់គាត់ដែលបានលាចាកលោក ដាក់តាំងនៅក្នុងវិមានបញ្ចុះសពក្នុងតំបន់ដែលគាត់រស់នៅទៅវិញ។

លោក លូអីស ដេវីស ក៏បានប្រាប់អ្នកស្រី អឺនី ផាល (Ernie Pyle) ដែលជាអ្នកកាសែតថា ប្រជាជននៅរដ្ឋខេនសាស់ស្អប់គាត់។ ប្រជាជនក្នុងតំបន់ចង់ឲ្យគាត់ធ្វើការសាងសង់ហេដ្ឋារចនាសម្ពន្ធសាធារណៈ ដែលមានដូចជាមន្ទីរពេទ្យ កន្លែងហែលទឹក ឬសួនច្បារជាដើម។ តែគាត់គ្រាន់តែនិយាយប្រាប់ពួកគេថា «វាជាលុយរបស់ខ្ញុំ ខ្ញុំចង់យកវាទៅធ្វើអ្វី ស្រេចតែខ្ញុំ»។

ស្តេចសាឡូម៉ូន ជាបុរសដែលមានទ្រព្យសម្បត្តិច្រើនជាងគេបំផុតក្នុងសម័យទ្រង់។ ទ្រង់បានបង្រៀនថា «អ្នកណាដែលស្រឡាញ់ប្រាក់ នោះនឹងមិនស្កប់ចិត្តដោយប្រាក់ប៉ុណ្ណោះទេ... កាលណារបស់ទ្រព្យបានចំរើនឡើង នោះពួកអ្នកដែលស៊ីទ្រព្យនោះ ក៏មានគ្នាច្រើនឡើងដែរ» (សាស្តា ៥:១០-១១)។ ត្រង់ចំណុចនេះ ស្តេចសាឡូម៉ូនមានការយល់ដឹងយ៉ាងច្បាស់អំពីភាពពុកផុយនៃទ្រព្យសម្បត្តិ។

សាវ៉ែក ប៉ុល ក៏បានយល់អំពីការល្បួងនៃទ្រព្យសម្បត្តិ ហើយបានសម្រេចចិត្តលះបង់ជីវិតគាត់នៅក្នុងការស្តាប់បង្គាប់ព្រះយេស៊ូវ។ កាលគាត់កំពុងរង់ចាំការកាត់ទោសប្រហារជីវិតក្នុងគុកមួយនៅទីក្រុងរ៉ូម គាត់បានសរសេរអំពីជំយជម្នះខាងវិញ្ញាណយ៉ាងដូចនេះថា «ដ្បិតខ្ញុំកំពុងតែត្រូវច្រួចចេញ ឯពេលវេលាដែលខ្ញុំត្រូវលាទៅក៏បានមកដល់ហើយ ខ្ញុំបានតយុទ្ធយ៉ាងល្អ... ខ្ញុំបានរត់ប្រណាំងជាស្រេច ខ្ញុំបានរក្សាសេចក្តីជំនឿទៅហើយ» (២ធីម៉ូថេ ៤:៦-៧)។

របស់អ្វីដែលស្ថិតស្ថេរមិនមែនជាថ្មដែលយើងឆ្លាក់សម្រាប់ខ្លួនឯង ឬទ្រព្យសម្បត្តិដែលយើងប្រមូលទុកសម្រាប់ខ្លួនយើងនោះទេ។ វាជាអ្វីដែលយើងបានចែករំលែក ដោយសេចក្តីស្រឡាញ់ចំពោះគ្នាទៅវិញទៅមក និងចំពោះព្រះអង្គ ជាព្រះដែលបានបង្រៀនយើងអំពីរបៀបស្រឡាញ់។—Tim Gustafson

តើអ្នកដទៃនឹងនឹកចាំអំពីអ្នក ដោយសារកត្តាអ្វីខ្លះ? តើអ្នកត្រូវមានការផ្លាស់ប្តូរអ្វីខ្លះ ខណៈពេលដែលអ្នកពិចារណាអំពីកេរដំណែលដ៏អស់កល្បជានិច្ច?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំឲ្យចាក់បង្ហូរជីវិតទូលបង្គំចេញ តាមមធ្យោបាយដ៏តូចមួយ នៅថ្ងៃនេះ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ចោទិយកថា ២៦-២៧ និងម៉ាកុស ១៤:២៧-៥៣

សូមអញ្ជើញឆ្ពោះមកជួយយើងខ្ញុំ ដែលនៅស្រុកម៉ាសេដូននេះផង (កិច្ចការ ១៦:៩)។

ចែកចាយជំនឿរបស់អ្នក

កាលពីឆ្នាំ១៧០១ ព្រះវិហារនៃប្រទេសអង់គ្លេសបានផ្តល់ដង្វាយឧបត្ថម្ភដល់សមាគមន៍ផ្សព្វផ្សាយដំណឹងល្អ ដើម្បីបញ្ជូនបេសកជន ឲ្យចេញទៅទូទាំងពិភពលោក។ បាវចនាដែលពួកគេបានជ្រើសរើសនោះគឺ transiens adiuva nos ជាភាសាឡាតាំងមានន័យថា «សូមឆ្លងមកជួយយើងខ្ញុំផង!» នេះជាពាក្យអំពាវនាវរបស់ទូតព្រះគ្រីស្ទជាអ្នកផ្សាយដំណឹងល្អតាំងពីសតវត្សរ៍ទី១ ដោយអ្នកដើរតាមព្រះយេស៊ូវបាននាំព្រះរាជសារនៃសេចក្តីស្រឡាញ់ និងការអត់ទោសរបស់ព្រះអង្គទៅកាន់លោកីយ៍ ដែលកំពុងស្រែកឃ្លានសេចក្តីសង្គ្រោះ។

ពាក្យ «សូមឆ្លងមកជួយយើងខ្ញុំផង!» មានប្រភពមកពី «ការអំពាវនាវរបស់ពួកជំនុំនៅស្រុកម៉ាសេដូន» ដូចបានពិពណ៌នាក្នុងបទគម្ពីរកិច្ចការជំពូក១៦។ កាលនោះ សាវ័ក ប៉ុល និងក្រុមការងាររបស់គាត់ទើបតែធ្វើដំណើរមកដល់ទីក្រុងត្រូអាស នៅតាមបណ្តោយឆ្នេរខាងលិចនៃតំបន់អាស៊ីតូច (សព្វថ្ងៃជាប្រទេសទួរគី ខ.៨)។ នៅទីនោះ មានយប់មួយ «ប៉ុលបានឃើញក្នុងការជាក់ស្តែង ជាមនុស្សពីស្រុកម៉ាសេដូនម្នាក់ឈរអង្វរគាត់ថា សូមអញ្ជើញឆ្លងមកជួយយើងខ្ញុំ ដែលនៅស្រុកម៉ាសេដូននេះផង» (ខ.៩)។ បន្ទាប់ពីបានទទួលការបើកសម្តែងនេះហើយ សាវ័ក ប៉ុល និងគូរកនរបស់គាត់ក៏បាន «រកឱកាសនឹងទៅឯស្រុកម៉ាសេដូនភ្លាម» (ខ.10)។ ពួកគេបានយល់អំពីសារៈសំខាន់នៃការអំពាវនាវនោះ។

មិនមែនមនុស្សទាំងអស់សុទ្ធតែបានទទួលការត្រាស់ហៅឲ្យឆ្លងសមុទ្រនោះទេ ប៉ុន្តែយើងអាចជួយទ្រទ្រង់អ្នកដែលបានទទួលការត្រាស់ហៅនោះ ដោយការអធិស្ឋាន និងដង្វាយឧបត្ថម្ភ។ ហើយយើងម្នាក់ៗសុទ្ធតែអាចប្រាប់អ្នកដទៃអំពីដំណឹងល្អរបស់ព្រះយេស៊ូវ ទោះនៅក្នុងបន្ទប់ នៅតាមផ្លូវ ឬក្នុងសហគមន៍ណាមួយក៏ដោយ។ ចូរយើងអធិស្ឋានសូមឲ្យព្រះដ៏ល្អរបស់យើងជួយយើងឲ្យអាចឆ្លងទៅរកអ្នកដទៃ ដើម្បីផ្តល់ជំនួយដ៏សំខាន់បំផុត គឺឱកាសទទួលការអត់ទោសបាបក្នុងព្រះនាមព្រះយេស៊ូវ។—Bill Crowder

តើព្រះទ្រង់កំពុងត្រាស់ហៅអ្នកឲ្យចែកចាយជំនឿរបស់អ្នក នៅកន្លែងណាខ្លះ? តើព្រះអង្គអាចប្រទានកម្លាំងឲ្យអ្នកអាចចែកចាយជំនឿនៅថ្ងៃនេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតានៃសេចក្តីស្រឡាញ់ ព្រះអង្គបានចាត់ព្រះរាជបុត្រាព្រះអង្គ ឲ្យមកសង្គ្រោះ និងអត់ទោសបាបឲ្យយើងខ្ញុំ។ សូមព្រះអង្គប្រទានទូលបង្គំនូវលទ្ធភាព ដើម្បីធ្វើជាអ្នកនាំដំណឹងល្អរបស់ព្រះអង្គ ឲ្យគេដឹងថា ព្រះអង្គបានប្រទានសេរីភាព និងការអត់ទោស ដល់មនុស្សទាំងអស់ដែលទទួលជឿព្រះយេស៊ូវ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ។

Daily Manna 2026_Content Enhance.indd 81 17/11/25 1:44 in the afternoon

អញសុខចិត្តឲ្យបណ្តាជនទាំងឡាយរបស់ព្រះយេហូវ៉ាចេះទាយដែរ ហើយឲ្យព្រះយេហូវ៉ាបានដាក់ព្រះវិញ្ញាណទ្រង់លើគេគ្រប់គ្នាចុះ (ជនគណនា ១១:២៩)។

អ្នកដឹកនាំដែលរួបរួមគ្នា ដើម្បីនគរព្រះ

កាលខ្ញុំបានចូលរួមក្រុមអ្នកនិពន្ធសៀវភៅកុមារគ្រីស្ទបរិស័ទ យើងបានអធិស្ឋានឲ្យគ្នាទៅវិញទៅមក ហើយជួយផ្សព្វផ្សាយសៀវភៅឲ្យគ្នាទៅវិញមក។ អ្នកខ្លះនិយាយថា យើងមានភាពល្ងង់ខ្លៅណាស់ដែលយើងមានការរួបរួមជាមួយគូរប្រជែងក្នុងការលក់សៀវភៅ។ ប៉ុន្តែ ក្រុមរបស់យើងជាក្រុមអ្នកដឹកនាំដែលផ្តោតចិត្តទៅលើនគរព្រះ និងលើកកម្ពស់សហគមន៍មិនមែនប្រកួតគ្នានោះទេ។ យើងមានគោលដៅដូចគ្នា គឺដើម្បីផ្សាយដំណឹងល្អ។ យើងបម្រើមហាក្សត្រតែមួយ គឺព្រះយេស៊ូវ។ យើងបានរួបរួមគ្នា ដើម្បីឈោងចាប់មនុស្សកាន់តែច្រើន ដោយការធ្វើបន្ទាល់ថ្វាយព្រះគ្រីស្ទ។

កាលព្រះអម្ចាស់បង្គាប់លោក ម៉ូសេ ឲ្យជ្រើសរើសពួកចាស់ទុំ៧០នាក់ ដែលមានបទពិសោធន៍ក្នុងការដឹកនាំព្រះអង្គមានបន្ទូលថា «អញនឹងចុះមកនិយាយនឹងឯង ហើយនឹងចែកព្រះវិញ្ញាណ ដែលសណ្ឋិតលើឯងទៅដាក់លើគេផង នោះគេនឹងជួយផ្ទុកនូវបន្ទុកបណ្តាជននេះជាមួយនឹងឯង ដើម្បីកុំឲ្យឯងត្រូវផ្ទុកតែម្នាក់ឯងឡើយ» (ជនគណនា ១១:១៦-១៧)។ ក្រោយមក លោក លូអ៊ីស យ៉ូស្វេ បានឃើញពួកចាស់ទុំពីរនាក់កំពុងថ្លែងទំនាយ ហើយក៏បានប្រាប់លោក ម៉ូសេ ឲ្យឃាត់ឃាំងពួកគេ។ លោក ម៉ូសេ ក៏បានមានប្រសាសន៍ថា «តើឯងច្រណែនជំនួសអញឬអី អញសុខចិត្តឲ្យបណ្តាជនទាំងឡាយរបស់ព្រះយេហូវ៉ាចេះទាយដែរ ហើយឲ្យព្រះយេហូវ៉ាបានដាក់ព្រះវិញ្ញាណទ្រង់ លើគេគ្រប់គ្នាចុះ» (ខ.២៩)។

ព្រះវិញ្ញាណបរិសុទ្ធអាចប្រទានកម្លាំងយើង ឲ្យជម្នះការល្បួង ដែលនាំចិត្តយើងឲ្យផ្តោតទៅលើការប្រកួតប្រជែងគ្នា ឬការប្រៀបធៀបគ្នា ដែលរារាំងយើងមិនឲ្យធ្វើការជាមួយអ្នកដទៃ។ ពេលណាយើងទូលសូមព្រះអង្គប្រទានភាពជាអ្នកដឹកនាំដែលផ្តោតចិត្តទៅលើនគរព្រះអង្គ ព្រះអង្គនឹងប្រើយើងផ្សាយដំណឹងល្អនៅទូទាំងពិភពលោក ហើយថែមទាំងអាចសម្រាលបន្ទុករបស់យើង ខណៈពេលដែលយើងបម្រើព្រះអង្គជាមួយគ្នា។

—Xochitl Dixon

តើអ្នកបានរួបរួមជាមួយអ្នកដទៃដូចម្តេចខ្លះ ដើម្បីបម្រើព្រះអង្គ? តើអ្នកអាចជួយទ្រទ្រង់នរណាខ្លះ ខណៈពេលដែលពួកគេបម្រើព្រះអង្គ ដោយអំណោយទានរបស់ពួកគេ?

ឱព្រះវិញ្ញាណបរិសុទ្ធ សូមព្រះអង្គជួយទូលបង្គំឲ្យមានភាពជាអ្នកដឹកនាំដែលផ្តោតចិត្តទៅលើនគរព្រះអង្គ ហើយប្តេជ្ញាចិត្តធ្វើការជាមួយអ្នកដទៃ ដើម្បីឈោងចាប់មនុស្សកាន់តែច្រើន ដោយព្រះរាជសារនៃដំណឹងល្អដែលសង្គ្រោះជីវិតឲ្យរួចពីបាប។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ចោទិយកថា ៣០-៣១ និងម៉ាកុស ១៥:១-២៥

ព្រះទ្រង់មានព្រះបន្ទូលទៅម៉ូសេថា «អញជាព្រះដ៏ជាព្រះ» (និក្ខមនំ ៣:១៤)។

ព្រះអង្គជាព្រះដ៏ជាព្រះ

លោក លូអីស ជែក (Jack) ជាសាស្ត្រាចារ្យទស្សនវិជ្ជា និងអក្សរសាស្ត្រ ដែលមានកម្រិតបញ្ញាខ្ពស់។ កាលគាត់មានអាយុ១៥ឆ្នាំ គាត់បានប្រកាសថា គាត់ជាមនុស្សដែលមិនជឿថា ព្រះមានពិតមែនទេ។ ពេលគាត់ពេញវ័យ គាត់មានការការពារយ៉ាងមុតមាំ សម្រាប់ «ជំនឿនៃមនុស្សដែលមិនជឿថា ព្រះមានពិតមែនទេ»។ មិត្តភក្តិជាគ្រីស្ទបរិស័ទបានព្យាយាមបញ្ចុះបញ្ចូលគាត់។ លោក លូអីស ជែកក៏បាននិយាយថា «មនុស្សគ្រប់គ្នា និងអ្វីៗទាំងអស់សុទ្ធតែមានជំនឿខុសពីគាត់»។ ប៉ុន្តែ គាត់បានទទួលស្គាល់ថា ព្រះគម្ពីរមានលក្ខណៈខុសពីស្នាដៃអក្សរសាស្ត្រ និងរឿងទេវកថាផ្សេងទៀត។ ក្នុងសំណេររបស់គាត់អំពីដំណឹងល្អ គាត់បាននិយាយថា «បើសិនជាមានរឿងទេវកថាណាមួយ ប្រែក្លាយជាការពិត នោះវានឹងមានលក្ខណៈដូចព្រះគម្ពីរ»។

មានបទគម្ពីរមួយ ដែលមានឥទ្ធិពលបំផុតមកលើលោក លូអីស ជែក គឺនិក្ខមនំជំពូក៣ ដែលក្នុងនោះ ព្រះទ្រង់កំពុងត្រាស់ហៅលោក ម៉ូសេ ឲ្យដឹកនាំពួកអ៊ីស្រាអែលចេញពីទឹកដីអេស៊ីព្ទ។ លោក ម៉ូសេ ក៏បានទូលសួរព្រះអង្គថា «តើទូលបង្គំជាអ្វី ដែលព្រះអង្គឲ្យទូលបង្គំទៅឯជាន៉ាន?» (ខ.១១)។ ព្រះអម្ចាស់ក៏បានឆ្លើយតបថា «អញជាព្រះដ៏ជាព្រះ» (ខ.១៤)។ ខគម្ពីរនេះបានបង្កប់អត្ថន័យដ៏ស្មុគស្មាញនៅក្នុងពាក្យ និងព្រះនាមរបស់ព្រះ តែបានឆ្លុះបញ្ចាំងអំពីព្រះវត្តមានដ៏អស់កល្បរបស់ព្រះ ចាប់តាំងពីអស់កល្បជានិច្ចរៀងមក។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះ នៅសម័យក្រោយមកព្រះយេស៊ូវក៏បានមានបន្ទូលដូចនេះអំពីអង្គទ្រង់ផងដែរថា «មុនដែលលោក លូអីស អ័ប្រាហាំ កើតមក នោះមានខ្ញុំហើយ» (យ៉ូហាន ៨:៥៨)។

លោក លូអីស ជែក ដែលមានឈ្មោះពេញថា ស៊ី អេស លូអីស (C. S. Lewis) មានការប៉ះពាល់ចិត្តយ៉ាងខ្លាំង ចំពោះខគម្ពីរនេះ។ នេះជាពាក្យ ដែលព្រះពិតគួរតែមានបន្ទូល គឺគ្រាន់តែមានបន្ទូលថា ព្រះអង្គជាព្រះដ៏ជាព្រះ។ ក្នុងពេលដែលជីវិតគាត់មានការផ្លាស់ប្រែ លោក លូអីស ក៏បានចុះចូលនឹងបំណងព្រះទ័យព្រះអង្គ ហើយទទួលស្គាល់ថា ព្រះអង្គជាព្រះ។ នេះជាការចាប់ផ្តើមនៃការធ្វើដំណើររបស់លោក លូអីស ឆ្ពោះទៅរកការទទួលជឿព្រះយេស៊ូវ។

យើងប្រហែលជាពិបាកទទួលជឿព្រះ ដូចលោក លូអីស ផងដែរ ឬប្រហែលជាមានជំនឿដែលក្តៅមិនក្តៅត្រជាក់មិនត្រជាក់។ យើងប្រហែលជាសួរខ្លួនឯងថា តើព្រះអង្គគឺជាព្រះពិតក្នុងជីវិតយើងមែនឬ?—Kenneth Petersen

តើអ្នកមានការយល់ឃើញយ៉ាងណា ពេលបានឃើញព្រះទ្រង់មានបន្ទូលថា ព្រះអង្គជាព្រះដ៏ជាព្រះ? តើការនេះអាចមានឥទ្ធិពលយ៉ាងណាខ្លះ មកលើការរស់នៅរបស់អ្នកនៅថ្ងៃក្រោយ?

ឱព្រះអម្ចាស់ ទូលបង្គំចូលមករកព្រះអង្គ ដោយការស្ញែងខ្លាច ពេលបានដឹងថា ព្រះអង្គជានរណា។ ព្រះអង្គជាព្រះ ក្នុងជីវិតទូលបង្គំ ហើយគ្មាននរណាផ្សេងទៀតដែលជាព្រះឡើយ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ចោទិយកថា ៣២-៣៤ និងម៉ាកុស ១៥:២៦-៤៧

ពួកចៅហ្វាយរាល់គ្នាអើយ ចូរបើកឲ្យដល់អ្នកបំរើរបស់អ្នកតាមត្រឹមត្រូវ ហើយទៀងត្រង់ចុះ ដោយដឹងថា អ្នកក៏មានចៅហ្វាយ១នៅស្ថានសួគ៌ដែរ (កូល៉ុស ៤:១)។

យើងមានចៅហ្វាយ១នៅស្ថានសួគ៌

ក្រសួងការងារនៃប្រទេសសិង្ហបុរីបានប្រកាសកាលពីឆ្នាំ២០២២ថា កម្មការអន្តោប្រវេសន៍ដែលកំពុងធ្វើការក្នុងប្រទេសសិង្ហបុរីត្រូវតែទទួលបានថ្ងៃឈប់សម្រាកយ៉ាងហោចណាស់១ថ្ងៃជារៀងរាល់ខែ ដែលចៅក្រែរបស់ខ្លួនមិនអាចបដិសេធន៍ ឬមិនអាចបង់លុយឲ្យពួកគេធ្វើការនៅថ្ងៃឈប់សម្រាក១ថ្ងៃនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ កម្មការទាំងឡាយមានការព្រួយបារម្ភថា ពួកគេមិនមាននរណាម្នាក់មើលថែមនុស្សជាទីស្រឡាញ់របស់ខ្លួននៅថ្ងៃនោះ។ ពួកគេអាចប្រើជម្រើសផ្សេង ដើម្បីឲ្យមនុស្សជាទីស្រឡាញ់បានទទួលការមើលថែនៅថ្ងៃនោះ តែគេពិបាកផ្លាស់ប្តូរផ្នត់គំនិតរបស់ចៅក្រែ ដែលមិនបានឲ្យតម្លៃមកលើតម្រូវការនៃការសម្រាករបស់កម្មករ។

ការប្រព្រឹត្តចំពោះអ្នកដទៃ ដោយការយោគយល់ មិនមែនជារឿងថ្មីទេ។ សាវ័ក ប៉ុល បានរស់នៅក្នុងសម័យដែលអ្នកបម្រើ ត្រូវគេចាត់ទុកជាកម្មសិទ្ធិរបស់ចៅហ្វាយខ្លួន។ តែនៅក្នុងបន្ទាត់ចុងក្រោយនៃការបង្រៀនរបស់គាត់ទៅកាន់ពួកជំនុំអំពីគ្រួសាររបស់គ្រីស្ទបរិស័ទដែលមានលក្ខណៈដូចព្រះគ្រីស្ទ គាត់មានប្រសាសន៍ថា ចៅហ្វាយទាំងឡាយត្រូវតែប្រព្រឹត្តចំពោះអ្នកបម្រើខ្លួន “ដោយយុត្តិធម៌” (កូល៉ុស ៤:១)។

ដូចដែលសាវ័ក ប៉ុល បានប្រាប់អ្នកបម្រើឲ្យធ្វើការ “ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្ស” (៣:២៣) នោះគាត់ក៏បានក្រើនរំឭកចៅហ្វាយទាំងឡាយថា ពួកគេក៏មានចៅហ្វាយ១នៅស្ថានសួគ៌ផងដែរ (៤:១)។ គោលបំណងរបស់គាត់ គឺដើម្បីលើកទឹកចិត្តអ្នកជឿព្រះនៅទីក្រុងកូល៉ុសឲ្យរស់នៅ ដោយការចុះចូលព្រះគ្រីស្ទធ្វើជាព្រះអម្ចាស់របស់ពួកគេ។ ក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃ ទោះយើងជាចៅហ្វាយនាយនិយោជក ក្នុងផ្ទះ ឬក្នុងសហគមន៍ក្តី យើងអាចទូលសូមព្រះអម្ចាស់ជួយយើង ធ្វើការអ្វីដែលត្រឹមត្រូវ និងយុត្តិធម៌ (ខ.១)។—Jasmine Goh

តើអ្នកមិនបានប្រព្រឹត្តចំពោះនរណាម្នាក់ ដោយយុត្តិធម៌នៅពេលណា? ក្នុងកន្លែងធ្វើការ ឬនៅផ្ទះ អ្នកត្រូវមានការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីឲ្យអ្នកអាចប្រព្រឹត្តចំពោះអ្នកដទៃ ដោយចិត្តមេត្តា?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ពេលណាទូលបង្គំមិនបានប្រព្រឹត្តចំពោះអ្នកដទៃ ដោយយុត្តិធម៌។ សូមព្រះអង្គជួយទូលបង្គំឲ្យចុះចូលព្រះអង្គ ធ្វើជាព្រះអម្ចាស់នៃជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 84 17/11/25 1:44 in the afternoon

មានពរហើយ អ្នកណាដែលយកព្រះយេហូវ៉ាជាទីពឹង (ទំនុកតម្កើង ៤០:៥)។

ការទុកចិត្តដែលនាំទៅរកសេចក្តីអំណរ

លីនដា (Linda) បានជួយសង្គ្រោះសត្វឆ្កែមួយក្បាលឈ្មោះ រូឌី (Rudy) ដើម្បីកុំឲ្យគេចាក់ថ្នាំសម្លាប់វា នៅកន្លែងសង្គ្រោះសត្វចិញ្ចឹម ហើយសត្វឆ្កែនោះក៏បានរស់នៅជាមួយនាងជារៀងរហូត។ រូឌី តែងតែដេកនៅក្បែរគ្រែគេងរបស់លីនដា យ៉ាងស្ងាត់ស្ងៀមអស់ អស់រយៈពេល១០ឆ្នាំ ប៉ុន្តែក្រោយមក វាស្រាប់តែចាប់ផ្តើមលោតឡើងទៅអង្គុយក្បែរនាង ហើយលិតមុខនាង។ លីនដា ក៏បានស្តីបន្ទោសឲ្យវា តែជារៀងរាល់ថ្ងៃ រូឌី នៅតែមានអាកប្បកិរិយាដូចនេះ។ លីនដា ក៏បាននិយាយថា «វាតែងតែលោតឡើងអង្គុយនៅលើភ្លៅខ្ញុំ ហើយលិតមុខខ្ញុំ រៀងរាល់ពេលខ្ញុំអង្គុយចុះ»។

ខណៈពេលដែលលីដាមានគម្រោងយករូឌីទៅសាលាបង្រៀនឆ្កែឲ្យស្តាប់បង្គាប់ម្ចាស់ នាងក៏បានចាប់ផ្តើមឆ្ងល់ថា ហេតុអ្វីរូឌីតែងតែលិតមុខនាង នៅត្រង់ចំណុចតែមួយនៅត្រង់ថ្គាមរបស់នាង។ លីនដា ក៏មានការសង្ស័យ ហើយក៏បានទៅជួបពេទ្យ។ ពេទ្យក៏បានរកឃើញថា នាងមានដុំសាច់តូចល្អិតនៅក្នុងឆ្អឹងថ្គាមរបស់នាង ដែលជាមហារីកឆ្អឹង។ គ្រូពេទ្យក៏បានប្រាប់នាងថា បើសិនជាមិនបានមកពិនិត្យឲ្យទាន់ពេលវេលាទេ នាងមុខជាស្លាប់មិនខាន។ លីនដា បានទុកចិត្តលើសភាវគតិរបស់រូឌី ហើយនាងមានការសប្បាយចិត្ត ដែលការទុកចិត្តនេះបានជួយឲ្យនាងរួចផុតពីសេចក្តីស្លាប់។

ការទុកចិត្តដ៏ត្រឹមត្រូវពិតជាមានសារៈសំខាន់ខ្លាំងណាស់។ ព្រះគម្ពីរបានបង្រៀនយើងជាញឹកញាប់ថា មានតែព្រះទេ ដែលយើងអាចទុកចិត្តបានទាំងស្រុង ដោយគ្មានការសង្ស័យ ហើយការទុកចិត្តព្រះអង្គថែមទាំងនាំទៅរកជីវិត និងក្តីអំណរ។ គឺដូចបទគម្ពីរ ទំនុកតម្កើង ៤០:៤ បានចែងថា «មានពរហើយ អ្នកណាដែលយកព្រះយេហូវ៉ាជាទីពឹង»។ ពាក្យមានពរក្នុងបទគម្ពីរទំនុកតម្កើង គឺមានអត្ថន័យសំដៅទៅលើក្តីអំណរដ៏ពោរពេញដែលកើតមានភ្លាមៗ និងមានភាពស្កប់ស្កល់។

ពេលណាយើងទុកចិត្តព្រះអង្គ យើងនឹងទទួលបានព្រះពរ ដែលជាសុភមង្គលដ៏ជ្រាលជ្រៅ និងពិតប្រាកដ។ យើងប្រហែលពិបាកទុកចិត្តព្រះអង្គនៅពេលខ្លះ ហើយលទ្ធផលដែលយើងទទួលបានក៏មិនមែនជាអ្វីដែលយើងបាននឹកស្មានដែរ។ ប៉ុន្តែ បើយើងទុកចិត្តព្រះអង្គ យើងនឹងក្លាយជាមនុស្សមានពរពិត។—Winn Collier

តើមានកត្តាអ្វីខ្លះដែលធ្វើឲ្យអ្នកពិបាកទុកចិត្តព្រះ? តើអ្នកនឹងមានការផ្លាស់ប្តូរដូចម្តេចខ្លះ ពេលដែលអ្នកពិតជាជឿថា ការទុកចិត្តព្រះអង្គនាំឲ្យអ្នកមានក្តីអំណរ?

ឱព្រះអម្ចាស់ ទូលបង្គំចង់បានសុភមង្គល ដែលមានតែព្រះអង្គទេដែលអាចប្រទានឲ្យបាន។ តែទូលបង្គំពិបាកទុកចិត្តព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យទុកចិត្តព្រះអង្គជារៀងរាល់ថ្ងៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យ៉ូស្វេ ៤-៦ និងលូកា ១:១-២០

ទាំងចំអែតចិត្តនៃអ្នកដែលមានទុក្ខវេទនា នោះពន្លឺរបស់ឯងនឹងភ្លឺឡើងក្នុងទីងងឹត (អេសាយ ៥៨:១០)។

ជួយអ្នកដទៃ ដោយជំនួយមកពីព្រះអង្គ

លោក លូអ៊ីស អូល ខាសូ (Ole Kassow) ជាអ្នកក្រុងខូផិនហេហ្គិន ចូលចិត្តជិះកង់ណាស់។ នៅពេលព្រឹកមួយ គាត់បានឃើញបុរសវ័យចំណាស់ម្នាក់កំពុងអង្គុយកាន់ឈើច្រត់ក្នុងសួនច្បារតែម្នាក់ឯង។ ពេលនោះ លោក លូអ៊ីស អូល ក៏បាននឹកឃើញគំនិតដ៏សាមញ្ញមួយ ដោយចង់ផ្តល់ឲ្យមនុស្សចាស់នូវក្តីអំណរ និងសេរីភាពនៅក្នុងការជិះកង់។ ដូចនេះ នៅថ្ងៃដែលមានមេឃស្រឡះល្អ គាត់ក៏បានធាក់ស៊ីក្លូមកមណ្ឌលថែទាំមនុស្សចាស់ជរា ហើយក៏បានឲ្យមនុស្សចាស់ដែលស្នាក់នៅទីនោះជិះស៊ីក្លូគាត់ដោយឥតគិតថ្លៃ។ គាត់មានការសប្បាយចិត្តណាស់ នៅពេលដែលបុគ្គលិកដែលធ្វើការនៅទីនោះ និងមនុស្សចាស់ម្នាក់បានក្លាយជាអ្នកដំណើរដំបូង ដែលបានជិះស៊ីក្លូគាត់ក្នុងកម្មវិធីជិះស៊ីក្លូដោយមិនប្រកាន់អាយុ។

សព្វថ្ងៃនេះ អស់រយៈពេលជាង២០ឆ្នាំហើយ ដែលក្តីស្រមៃរបស់លោក លូអ៊ីស អូល បានក្លាយជាការពិតនៅក្នុងការជួយមនុស្សចាស់ឲ្យបានជិះស៊ីក្លូកម្សាន្ត ដោយកម្មវិធីរបស់គាត់បានក្លាយជាព្រះពរដល់មនុស្សចាស់ប្រហែល ៥៧៥០០០នាក់ ដែលបានជិះស៊ីក្លូចំនួន ២.៥លានជើង។ តើពួកគេជិះស៊ីក្លូទៅកន្លែងណាខ្លះ? គឺទៅជួបមិត្តភក្តិទៅញ៉ាំការ៉ែម និងជិះលំហែកាយតាមផ្លូវដែលមានខ្យល់បក់លំហើយ។ អ្នកដំណើររបស់គាត់បាននិយាយថា ពួកគេបានគេងលក់ស្រួលជាងមុន ញ៉ាំអាហារបានឆ្ងាញ់ជាងមុន ហើយក៏មានអារម្មណ៍មិនសូវឯកោដូចមុន។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំ ព្រះបន្ទូលដ៏មានន័យរបស់ព្រះអម្ចាស់ទៅកាន់រាស្ត្រព្រះអង្គក្នុងបទគម្ពីរ អេសាយ ៥៨:១០-១១ ដែលបានចែងថា «បើឯងផ្តល់សេចក្តីសប្បុរស ដល់មនុស្សស្រេកឃ្លាន ទាំងចំអែតចិត្តនៃអ្នកដែលមានទុក្ខវេទនា នោះពន្លឺរបស់ឯងនឹងភ្លឺឡើងក្នុងទីងងឹត ហើយសេចក្តីងងឹតរបស់ឯងនឹងបានភ្លឺដូចជាវេលាថ្ងៃត្រង់ ព្រះយេហូវ៉ាទ្រង់នឹងនាំផ្លូវឯងជានិច្ច ហើយនឹងចំអែតព្រលឹងឯងនៅក្នុងទីហួតហែង ទ្រង់នឹងធ្វើឲ្យឆ្អឹងឯងបានមាំមួន ឯងនឹងបានដូចជាសួនច្បារដែលគេស្រោចទឹក ហើយដូចជាក្បាលទឹកដែលមិនខានហូរឡើយ»។

ព្រះទ្រង់ប្រាប់រាស្ត្រព្រះអង្គថា «ពួកអ្នកដែលនឹងកើតពីឯងមក គេនឹងសង់ទីចាស់ដែលខូចបង់ឡើងជាថ្មី» (ខ.១២)។ តើព្រះអង្គអាចធ្វើអ្វីខ្លះតាមរយៈយើង? ព្រះអង្គអាចជួយយើងឲ្យមានលទ្ធភាពជួយអ្នកដទៃ ដូចនេះចូរយើងត្រៀមខ្លួនជាស្រេច ដើម្បីជួយអ្នកដទៃ។—Patricia Raybon

ក្នុងតំបន់ដែលអ្នករស់នៅ តើមាននរណាខ្លះត្រូវការជំនួយ? តើអ្នកអាចផ្តល់ជំនួយដ៏សាមញ្ញអ្វីខ្លះ ដល់ពួកគេនៅថ្ងៃនេះ?

ឱព្រះអម្ចាស់ សូមព្រះអង្គបង្ហាញទូលបង្គំនូវរបៀបដ៏សាមញ្ញ ដែលទូលបង្គំអាចជួយអ្នកដទៃ ដើម្បីឲ្យពួកគេអាចរកឃើញជីវិតក្នុងព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យ៉ូស្វេ ៧-៩ និងលូកា ១:២១-៣៨

ពួកកូនតូចៗអើយ យើងមិនត្រូវស្រឡាញ់ ដោយពាក្យសំដី ឬដោយបបូរមាត់ប៉ុណ្ណោះឡើយ គឺដោយការប្រព្រឹត្ត និងសេចក្តីពិតវិញ (១យ៉ូហាន ៣:១៨)។

បង្ហាញសេចក្តីស្រឡាញ់តាមរយៈការប្រព្រឹត្ត

តើមានកត្តាអ្វីដែលបណ្តាលឲ្យនរណាម្នាក់ ជួយគួរប្រជែងរបស់ខ្លួន? សម្រាប់ម្ចាស់ភោជនីយដ្ឋាន គឺលោក លូអីស អាដូលហ្វូ (Adolfo) ក្នុងរដ្ឋឺនឌុនស៊ីន គាត់បានឆក់ឱកាសលើកទឹកចិត្តម្ចាស់ភោជនីយដ្ឋានដទៃទៀតក្នុងតំបន់ ឲ្យចេះសម្របខ្លួននឹងបទបញ្ជាអំពីការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ។ លោក លូអីស អាដូលហ្វូ បានដឹងជាមុនអំពីបញ្ហាប្រឈមក្នុងការបន្តបើកភោជនីយដ្ឋាន ក្នុងសម័យជំងឺកូវីដកំពុងរីករាលដាល។ បន្ទាប់ពីគាត់បានទទួលការលើកទឹកចិត្តពីអំពើសប្បុរសធម៌របស់ម្ចាស់អាជីវកម្មដទៃទៀត គាត់ក៏បានចំណាយប្រាក់ផ្ទាល់ខ្លួន ដើម្បីទិញគូប៉ុនដែលមានតម្លៃសរុបជាង២ពាន់ដុល្លា ចែកឲ្យអតិថិជនរបស់គាត់ដោយឥតគិតថ្លៃ ដើម្បីឲ្យពួកគេប្រើគូប៉ុននោះ ទៅទិញអាហារនៅភោជនីយដ្ឋានដទៃទៀតក្នុងតំបន់ដែលគាត់រស់នៅ។ នេះជាការបង្ហាញចេញនូវសេចក្តីស្រឡាញ់ ដែលមិនមែនតាមរយៈពាក្យសម្តីតែម៉្យាង តែតាមរយៈការប្រព្រឹត្តផងដែរ។

កណ្ឌគម្ពីរយ៉ូហានបានលើកទឹកចិត្តគ្រីស្ទបរិស័ទទាំងអស់ឲ្យបង្ហាញចេញនូវសេចក្តីស្រឡាញ់ក្នុងការប្រព្រឹត្ត ផ្អែកទៅលើគំរូនៃសេចក្តីស្រឡាញ់ ដែលព្រះយេស៊ូវបានបង្ហាញ ដោយស្ម័គ្រព្រះទ័យលះបង់ព្រះជន្ម ដើម្បីសង្គ្រោះមនុស្សជាតិ (១យ៉ូហាន ៣:១៦)។ តាមបទគម្ពីរនេះ ការលះបង់ជីវិតដើម្បីបងប្អូនខ្លួន (ខ.១៦) គឺជាការបង្ហាញចេញនូវសេចក្តីស្រឡាញ់ តាមគំរូព្រះយេស៊ូវ ដែលរាប់បញ្ចូលការប្រព្រឹត្តជាក់ស្តែងជារៀងរាល់ថ្ងៃ ដែលមានដូចជាការចែករំលែករបស់ទ្រព្យជាដើម។ ការស្រឡាញ់តែពាក្យសម្តីមិនទាន់គ្រប់គ្រាន់ទេ សេចក្តីស្រឡាញ់តម្រូវឲ្យមានការប្រព្រឹត្តដោយចិត្តស្មោះត្រង់ និងមានន័យ (ខ.១៨)។

ការបង្ហាញសេចក្តីស្រឡាញ់ក្នុងការប្រព្រឹត្តអាចមានការពិបាក ព្រោះវាច្រើនតែតម្រូវឲ្យមានការលះបង់ផ្ទាល់ខ្លួន ឬការលះបង់ប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីប្រយោជន៍អ្នកដទៃ។ យើងអាចបោះជំហានទៅមុខ ដោយសេចក្តីស្រឡាញ់ ដោយជំនួយពីព្រះវិញ្ញាណរបស់ព្រះ និងនឹកចាំសេចក្តីស្រឡាញ់ដ៏ហួរហៀរដែលព្រះអង្គមានសម្រាប់យើង។—Lisa M. Samra

តើអ្នកបានដកពិសោធន៍នឹងសេចក្តីស្រឡាញ់ តាមរយៈការប្រព្រឹត្តដូចម្តេចខ្លះ? តើអ្នកអាចបោះជំហានទៅមុខ ដោយសេចក្តីស្រឡាញ់ចំពោះនរណាម្នាក់ តាមការប្រព្រឹត្តដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យយកគំរូតាមព្រះអង្គ ហើយបោះជំហានទៅមុខ ដោយបង្ហាញសេចក្តីស្រឡាញ់ពិតប្រាកដ តាមរយៈការប្រព្រឹត្តរបស់ទូលបង្គំនៅថ្ងៃនេះ។

Daily Manna 2026_Content Enhance.indd 87 17/11/25 1:45 in the afternoon

ទាំងប្រព្រឹត្តដោយទៀងត្រង់ នៅក្នុងពួកសាសន៍ដទៃ... នោះឲ្យគេបានសរសើរដល់ព្រះ នៅថ្ងៃដែលទ្រង់យាងមកជ្រាស ដោយគេឃើញការល្អរបស់អ្នករាល់គ្នាវិញ (១ពេត្រុស ២:១២)។

សេចក្តីស្រឡាញ់ ដែលនាំឲ្យគេសរសើរតម្កើងព្រះ

ស្ត្រីម្នាក់ដែលអង្គុយនៅលើកៅអីជាប់ខ្ញុំក្នុងយន្តហោះ បានប្រាប់ខ្ញុំថា នាងមិនជឿព្រះ ហើយគាត់ក៏គ្មានជំនឿសាសនាដែរ។ គាត់បានផ្លាស់ទីលំនៅទៅទីក្រុងមួយ ដែលមានគ្រីស្ទបរិស័ទជាច្រើនរស់នៅ។ នៅពេលដែលគាត់បានលើកឡើងថា ភាគច្រើននៃអ្នកជិតខាងរបស់គាត់ទៅព្រះវិហារនៅថ្ងៃអាទិត្យ ខ្ញុំក៏បានសួរគាត់អំពីបទពិសោធន៍របស់គាត់ នៅក្នុងការរស់នៅទីនោះ។ គាត់ថា គាត់មិនដឹងថា គាត់អាចសងគុណពួកគេវិញដោយរបៀបណាទេ។ នៅពេលដែលគាត់នាំឪពុករបស់គាត់ជាជនពិការទៅរស់នៅជាមួយគាត់ក្នុងប្រទេសនោះ អ្នកជិតខាងរបស់គាត់បានសង់ផ្លូវសម្រាប់ឲ្យឪពុកគាត់អាចជិះរទេះរុញចេញចូលផ្ទះរបស់គាត់ ហើយក៏បានបរិច្ចាគគ្រែពេទ្យមួយគ្រឿង និងថ្នាំពេទ្យដល់ឪពុកគាត់។ គាត់ក៏បាននិយាយថា «បើសិនជាការរស់នៅជាគ្រីស្ទបរិស័ទធ្វើឲ្យមនុស្សមានចិត្តសប្បុរស នោះមនុស្សគ្រប់គ្នាគួរតែក្លាយជាគ្រីស្ទបរិស័ទ»។

នេះជាអ្វីដែលព្រះយេស៊ូវសព្វព្រះទ័យឲ្យគាត់និយាយ! ព្រោះព្រះអង្គបានប្រាប់សិស្សព្រះអង្គថា «ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺនៅមុខមនុស្សលោក លូអីស យ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរតម្កើង ដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌» (ម៉ាថាយ ៥:១៦)។ លោក លូអីស ពេត្រុសបានឮព្រះរាជបញ្ជារបស់ព្រះគ្រីស្ទ បានជាគាត់បង្រៀនគ្រីស្ទបរិស័ទឲ្យ «ប្រព្រឹត្តដោយទៀងត្រង់នៅក្នុងពួកសាសន៍ដទៃ ដើម្បីនៅកន្លែងណា ដែលគេនិយាយដើមពីអ្នករាល់គ្នាទុកដូចជាមនុស្សប្រព្រឹត្តអាក្រក់ នោះឲ្យគេបានសរសើរដល់ព្រះ នៅថ្ងៃដែលទ្រង់យាងមកជ្រាស ដោយគេឃើញការល្អរបស់អ្នករាល់គ្នាវិញ» (១ពេត្រុស ២:១២)។

អ្នកជិតខាងយើងដែលមិនជឿព្រះយេស៊ូវ ប្រហែលមិនយល់អំពីជំនឿ និងមូលហេតុដែលយើងជឿទេ។ តែកុំបារម្ភអំពីបញ្ហានេះឡើយ ដរាបណាយើងនៅមានឱកាសបង្ហាញសេចក្តីស្រឡាញ់ តាមរយៈការប្រព្រឹត្តរបស់យើង។ ស្ត្រីដែលអង្គុយនៅកៅអីជាប់ខ្ញុំក្នុងយន្តហោះមានការស្ងប់ស្ងែងចំពោះអ្នកជិតខាងរបស់នាង ដែលនៅតែបន្តយកចិត្តទុកដាក់ចំពោះនាង ទោះនាងមិនបានខ្វល់ពីគេក៏ដោយ។ នាងដឹងថា ពួកគេមានសេចក្តីស្រឡាញ់ចំពោះនាង ដោយសារព្រះយេស៊ូវ ហើយនាងក៏បានអរព្រះគុណព្រះអង្គ។ នាងប្រហែលមិនទាន់បានជឿព្រះអង្គទេ តែការល្អដែលនាងបានបើកចំហចិត្ត ហើយនាងអរព្រះគុណព្រះអង្គ ដែលអ្នកដទៃទទួលជឿព្រះអង្គ។—Mike Wittmer

តើក្នុងចំណោមមនុស្សដែលអ្នកស្គាល់ មាននរណាខ្លះ ដែលត្រូវការព្រះយេស៊ូវ? តើអ្នកអាចស្រឡាញ់ពួកគេយ៉ាងដូចម្តេចខ្លះ ដោយយល់ដល់ព្រះអង្គ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមពន្ធឹព្រះអង្គចែងចាំងតាមរយៈទូលបង្គំ។

Daily Manna 2026_Content Enhance.indd 88 17/11/25 1:45 in the afternoon

ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញ នោះក៏បង្កើតផលជាច្រើនឡើង (យ៉ូហាន ១២:២៤)។

ការកើតជាថ្មីក្នុងព្រះយេស៊ូវ

គេបានឮល្បីថា លោក លូអីស លីអូណាដូ ដា វីនស៊ី (Leonardo da Vinci) គឺជាបុរសដែលនាំឲ្យមានការរស់ឡើងវិញនៃវិស័យសិល្បៈ និងវិទ្យាសាស្ត្រជាច្រើនមុខនៅអឺរ៉ុប។ កម្រិតប្រាជ្ញាដ៏ខ្ពង់ខ្ពស់របស់គាត់ បាននាំឲ្យមានភាពជឿនលឿននៅក្នុងមុខវិជ្ជាសិក្សា និងសិល្បៈជាច្រើន។ ប៉ុន្តែ លោក លូអីស លីអូណាដូ បានកត់ត្រាក្នុងសៀវភៅកំណត់ហេតុរបស់គាត់អំពី «គ្រោងទន្លាយរបស់យើង» និងបានពោលទំនួញថា មនុស្សក្នុងពេលបច្ចុប្បន្នកំពុងតែស្លាប់ «ដោយមិនបានបន្សល់ទុកការដំណែល ដែលគេនឹងនៅតែនឹកចាំ»។

គាត់មានប្រសាសន៍ថា «ខ្ញុំគិតថា ខ្ញុំកំពុងរៀនអំពីរបៀបរស់នៅ។ ខ្ញុំក៏កំពុងរៀនអំពីរបៀបស្លាប់»។ គាត់ប្រហែលមិនបានដឹងទេថា គាត់ហៀបនឹងរកឃើញសេចក្តីពិត។ ការរៀនស្លាប់ គឺជាផ្លូវឆ្ពោះទៅរកជីវិត។ បន្ទាប់ពីព្រះយេស៊ូវយាងចូលទីក្រុងយេរូសាឡិម ដោយក្បួនដង្ហែនៃជ័យជម្នះ (យ៉ូហាន ១២:១២-១៩) ព្រះអង្គមានបន្ទូលថា «បើគ្រាប់ស្រូវដែលធ្លាក់ចុះទៅដីមិនងាប់ទេ នោះក៏នៅតែ១ដដែល តែបើងាប់វិញនោះក៏បង្កើតផលជាច្រើនឡើង» (ខ.២៤)។ ត្រង់ចំណុចនេះ ព្រះអង្គកំពុងមានបន្ទូលអំពីការសុគតរបស់ព្រះអង្គ ហើយក៏បានរាប់បញ្ចូលការស្លាប់របស់យើងផងដែរ៖ «អ្នកណាដែលស្រឡាញ់ជីវិតខ្លួន នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលស្អប់ជីវិតខ្លួននៅលោកីយ៍នេះវិញ នោះនឹងរក្សាជីវិតទុក ដរាបដល់អស់កល្បរៀងទៅ» (ខ.២៥)។

សាវ័ក ប៉ុល ក៏បានបង្រៀនផងដែរថា «យើងបានត្រូវកប់ជាមួយនឹងទ្រង់ហើយ ដោយទទួលជ្រមុជក្នុងសេចក្តីស្លាប់ ដើម្បីឲ្យយើងបានដើរក្នុងជីវិតបែបថ្មី ដូចជាព្រះគ្រីស្ទបានរស់ពីស្លាប់ឡើងវិញ ដោយសារសិរីល្អនៃព្រះវរបិតាដែរ ដ្បិតបើយើងបានជាប់ជាមួយនឹងទ្រង់ ក្នុងការដែលជាគំរូពីសេចក្តីសុគតរបស់ទ្រង់ នោះក៏នឹងបានជាប់ក្នុងសេចក្តីរស់ឡើងវិញរបស់ទ្រង់ដែរ» (រ៉ូម ៦:៤-៥)។

តាមរយៈសេចក្តីស្លាប់ ព្រះយេស៊ូវបានប្រទានការកើតជាថ្មី ដល់យើងរាល់គ្នាជាអ្នកជឿព្រះអង្គ។ ព្រះអង្គបានបើកផ្លូវឲ្យយើងចូលទទួលជីវិតអស់កល្បជានិច្ចសម្រាប់ឲ្យយើងរស់នៅជាមួយព្រះវរបិតា។—Tim Gustafson

តើអ្នកបានឲ្យតម្លៃមកលើជីវិតរបស់អ្នកយ៉ាងដូចម្តេចខ្លះ? តើអ្នកចាំបាច់ត្រូវផ្លាស់ប្តូរតម្លៃទាំងនោះយ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានអត្ថន័យ និងគោលបំណងដល់ជីវិតរបស់ទូលបង្គំ ដែលគ្មានឥរណាម្នាក់អាចផ្តល់ឲ្យបាន។

Daily Manna 2026_Content Enhance.indd 89 17/11/25 1:45 in the afternoon

យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បានធ្វើដល់យើងដែរ (ម៉ាថាយ ២៥:៤០)។

ស្រឡាញ់ព្រះដោយស្រឡាញ់អ្នកដទៃ

គ្រួសាររបស់លោក លូអីស អាល់បា (Alba) បានជួបរឿងដ៏កម្រ។ បន្ទាប់ពីកូនស្លោះមួយគូរបានចាប់កំណើតបាន១៣ខែ កូនស្លោះមួយគូរទៀតក៏បានចាប់កំណើតក្នុងគ្រួសារគាត់។ តើពួកគេអាចមានការទទួលខុសត្រូវនៅក្នុងការចិញ្ចឹមកូន ក៏ដូចជានៅក្នុងការធ្វើការងារ ដោយរបៀបណា? ពេលនោះមិត្តភក្តិ និងសាច់ញាតិរបស់ពួកគេក៏បានជួយយកអសារពួកគេ។ តាយាយទាំងសង្ខាងក៏បានជួយមើលកូនស្លោះរបស់ពួកគេនៅពេលថ្ងៃ ដើម្បីឲ្យពួកគេអាចធ្វើការ និងរកប្រាក់បង់ថ្លៃពេទ្យ។ ក្រុមហ៊ុនមួយបានឧបត្ថម្ភកន្លងបសម្រាប់ទារកដល់ពួកគេពេញមួយឆ្នាំ។ មិត្តរួមការងាររបស់ពួកគេក៏បានលះបង់ថ្ងៃឈប់សម្រាកផ្ទាល់ខ្លួនសម្រាប់ពួកគេ។ ពួកគេក៏បានយល់ស្របថា បើគ្មានជំនួយពីសហគមន៍របស់ពួកគេទេ នោះពួកគេមុខជាជួបការលំបាកយ៉ាងខ្លាំង។ តាមពិត ក្នុងពេលសម្ភាសតាមទូរទស្សន៍ ក្នុងការផ្សាយផ្ទាល់ ពិធីករម្នាក់បានទុកក្បាលមេក្រូរបស់ខ្លួនចោល ដើម្បីរត់ទៅចាប់កូនរបស់ពួកគេម្នាក់ ដែលកំពុងដើរតេះតះ ព្រោះតែចង់ជួយមើលថែកូនរបស់ពួកគេ។

ក្នុងបទគម្ពីរ ម៉ាថាយ ២៥:៣១-៤៦ ព្រះយេស៊ូវបានមានបន្ទូលជាពាក្យប្រៀបប្រដូច ដើម្បីចង្អុលបង្ហាញថា ពេលណាយើងបម្រើអ្នកដទៃ នោះយើងក៏បម្រើព្រះផងដែរ។ ការបម្រើនោះរួមមានការចែកអាហារ និងទឹកដល់អ្នកស្រេកឃ្លាន ការផ្តល់កន្លែងស្នាក់នៅដល់ជនអនាថា ការចែកសំលៀកបំពាក់ដល់អ្នកដែលគ្មានសំលៀកបំពាក់ និងមើលថែអ្នកមានជំងឺជាដើម (ខ.៣៥-៣៦)។ ព្រះអង្គក៏បានមានបន្ទូលសរុបថា «យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថាបានធ្វើដល់យើងដែរ» (ខ.៤០)។

ការបង្រៀនថា ការបម្រើអ្នកដទៃគឺជាការបម្រើព្រះយេស៊ូវ គឺបានលើកទឹកចិត្តយើងឲ្យបម្រើអ្នកជិតខាង ក្រុមគ្រួសារ ពួកជំនុំ និងលោកីយ៍។ ដូចនេះ ពេលណាយើងជួយបំពេញតម្រូវការរបស់អ្នកដទៃ នោះមានន័យថា យើងកំពុងបម្រើព្រះអង្គ។ ហើយពេលណាយើងស្រឡាញ់អ្នកដទៃ នោះមានន័យថា យើងស្រឡាញ់ព្រះអង្គផងដែរ។—Elisa Morgan

តើអ្នកអាចបម្រើព្រះយេស៊ូវក្នុងសហគមន៍របស់អ្នកនៅថ្ងៃនេះ យ៉ាងដូចម្តេចខ្លះ? តើអ្នកអាចស្រឡាញ់ព្រះ ដោយស្រឡាញ់អ្នកដទៃដូចម្តេចខ្លះ?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គបើកភ្នែកទូលបង្គំឲ្យមើលឃើញតម្រូវការរបស់អ្នកដទៃ ដើម្បីឲ្យទូលបង្គំអាចជួយបំពេញតម្រូវការពួកគេ និងស្រឡាញ់ព្រះអង្គកាន់តែខ្លាំងឡើង។

Daily Manna 2026_Content Enhance.indd 90 17/11/25 1:45 in the afternoon

អ្នករាល់គ្នាភាន់ច្រឡំទេ ពីព្រោះមិនយល់គម្ពីរ ឬព្រះចេស្តានៃព្រះសោះ (ម៉ាថាយ ២២:២៩)។

មើលរំលងចំណេះដឹងមូលដ្ឋាន

ក្រុមហ៊ុនមែកដូណាល់ បានកាន់កាប់ដំណែងជាស្តេចលក់អាហាររហ័សអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ ដោយសារនំបឺហ្គ័រ១ភាគ៨របស់ខ្លួន។ ក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ក្រុមហ៊ុនអាហាររហ័សមួយទៀតដែលជាគូប្រជែងមានគំនិតថ្មីមួយ ដើម្បីដណ្តើមដំណែងពីក្រុមហ៊ុននេះ។ ក្រុមហ៊ុនA&W បានផ្តល់ឲ្យអតិថិជននូវនំបឺហ្គ័រ១ភាគ៣ ដែលមានទំហំធំជាងនំបឺហ្គ័ររបស់ក្រុមហ៊ុនមែកដូណាល់ តែលក់ក្នុងតម្លៃដូចគ្នា។ ជាងនេះទៅទៀត នំបឺហ្គ័ររបស់ក្រុមហ៊ុនA&W បានឈ្នះការប្រកួតភ្លក់រស់ជាតិ ដោយបិទភ្នែកជាច្រើនលើកច្រើនសារ។ ប៉ុន្តែ ក្រុមហ៊ុននេះបានបរាជ័យ ដោយសារលក់នំបឺហ្គ័រនោះមិនដាច់។ ទីបំផុត គេក៏បានឈប់ធ្វើនំបឺហ្គ័រនោះលក់ទៀត។ ការស្រាវជ្រាវបានបង្ហាញថា អតិថិជនបានគិតលេខខុស ដោយគិតស្មានថា នំបឺហ្គ័រ១ភាគ៣ តូចជាងនំបឺហ្គ័រ១ភាគ៤។ គំនិតដ៏ឆ្លាតវៃបានបរាជ័យ ដោយសារមនុស្សមានការយល់ច្រឡំក្នុងចំណេះដឹងមូលដ្ឋាន។

ព្រះយេស៊ូវបានដាស់តឿនយើងអំពីការយល់ច្រឡំដែលងាយនឹងកើតមាន។ អ្នកដឹកនាំសាសនាបានរៀបគម្រោងដាក់អន្ទាក់ ដើម្បីបង្ខូចព្រះនាមព្រះអង្គក្នុងអំឡុងសប្តាហ៍ដែលព្រះអង្គត្រូវសុគតនៅលើឈើឆ្កាង។ ពួកគេបានលើកយករឿងដ៏ចម្លែកមួយអំពីស្ត្រីម្នាក់ ដែលក្លាយជាស្ត្រីមេម៉ាយ៧ដង ដោយសារប្តីរបស់គាត់ទាំងអស់បានស្លាប់ចោលគាត់ (ម៉ាថាយ ២២:២៣-២៨)។ ព្រះយេស៊ូវក៏បានឆ្លើយតប ដោយបង្ហាញឲ្យគេដឹងថា រឿងនេះមិនពិបាកយល់ទេ។ ផ្ទុយទៅវិញ បញ្ហាស្ថិតនៅត្រង់ថា ពួកគេមិនយល់បទគម្ពីរ និងព្រះចេស្តារបស់ព្រះ (ខ.២៩)។ ព្រះអង្គមានបន្ទូលថា គោលបំណងជាចម្បងរបស់ព្រះគម្ពីរ គឺមិនមែនដើម្បីឆ្លើយតបសំណួរ ឬប្រស្នាដែលឡូជិកឬទស្សនវិជ្ជានោះទេ តែដើម្បីនាំយើងឲ្យស្គាល់ និងស្រឡាញ់ព្រះយេស៊ូវ ហើយ «មានជីវិតអស់កល្ប» ក្នុងព្រះអង្គ (យ៉ូហាន ៥:៣៩)។ នេះជាចំណេះដឹងមូលដ្ឋានដែលអ្នកដឹកនាំសាសនាទាំងនោះមិនយល់។

យើងក៏មានការយល់ច្រឡំអំពីចំណេះដឹងមូលដ្ឋានជាញឹកញាប់ផងដែរ។ គោលបំណងធំបំផុតរបស់ព្រះគម្ពីរ គឺដើម្បីជួយមនុស្សឲ្យមានការប្រកបទាក់ទងជាមួយព្រះយេស៊ូវ ជាព្រះដ៏រស់។ យើងនឹងជួបរឿងដ៏ឈឺចាប់បើសិនជាយើងមើលរំលងចំណុចនេះ។—Winn Collier

តើអ្នកមានការមើលរំលងចំណេះដឹងមូលដ្ឋានក្នុងព្រះគម្ពីរ យ៉ាងដូចម្តេចខ្លះ? តើអ្នកអាចវិលត្រលប់មកចំណេះមូលដ្ឋានក្នុងព្រះគម្ពីរអំពីព្រះយេស៊ូវ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ពេលទូលបង្គំមានការរវាំងង៍ សូម្បីតែនៅក្នុងរឿងដ៏សាមញ្ញ សូមព្រះអង្គជួយទូលបង្គំឲ្យមានការយល់ដឹងដ៏ត្រឹមត្រូវ។

Daily Manna 2026_Content Enhance.indd 91 17/11/25 1:45 in the afternoon

ទ្រង់ទតឃើញដើមល្វា១ពីចំងាយ ដែលមានសន្ទឹក រួចទ្រង់យាងទៅមើល ក្រែងរកបានផ្លែខ្លះ (ម៉ាកុស ១១:១៣)។

អ្នកជឿដែលមានផលផ្លែ

ស៊ីនឌី (Cindy) មានចិត្តរំភើបរីករាយ ចំពោះការងារដែលគាត់ទើបតែទទួលបាន ក្នុងក្រុមហ៊ុនមិនយកប្រាក់ចំណេញមួយ។ នេះជាឱកាសដ៏ល្អសម្រាប់នាំមកនូវការផ្លាស់ប្តូរក្នុងសង្គម! មិនយូរប៉ុន្មានគាត់ក៏បានដឹងថា មិត្តរួមការងារគាត់មិនមានចិត្តភ្លៀវភ្លាដូចគាត់ទេ។ ពួកគេបានសើចចំអកឲ្យបេសកកម្មរបស់ក្រុមហ៊ុននោះ ហើយពួកគេតែងតែមានការដោះសានៅពេលណាពួកគេធ្វើការមិនបានល្អ ហើយទន្ទឹមនឹងនោះពួកគេកំពុងស្វែងរកមុខតំណែងដែលមានប្រាក់ខែច្រើនជាងនៅកន្លែងផ្សេង។ ស៊ីនឌី ក៏មានការស្តាយក្រោយ ដែលបានដាក់ពាក្យចូលធ្វើការនៅកន្លែងនោះ។ កាលនាងមើលពីចម្ងាយ នាងគិតស្មានថា កន្លែងធ្វើការនោះល្អអស្ចារ្យណាស់ តែពេលនាងមើលឲ្យជិត នាងមានការខកចិត្តយ៉ាងខ្លាំង។

នេះជាបញ្ហាដែលព្រះយេស៊ូវបានជួបជាមួយដើមល្វា ដូចមានចែងក្នុងបទគម្ពីរប្រចាំថ្ងៃនេះ (ម៉ាកុស ១១:១៣)។ ដើមល្វានោះមានស្លឹកដែលជាសញ្ញាបង្ហាញថា វានឹងឆាប់មានផ្លែមុនរដូវ។ តែវាមិនបានចេញផ្លែសោះ។ ព្រះយេស៊ូវក៏បានដាក់បណ្តាសាឲ្យដើមល្វានោះថា «កុំឲ្យអ្នកណាស៊ីផ្លែឯងទៀតជារៀងរាបដរាបទៅ» (ខ.១៤)។ នៅពេលព្រឹកស្អែកដើមឈើនោះក៏បានក្រៀមស្វិតអស់ (ខ.២០)។

ព្រះគ្រីស្ទធ្លាប់បានអធិស្ឋានតម ៤០ថ្ងៃ ដូចនេះព្រះអង្គអាចទ្រាំនឹងការអត់អាហារបាន។ ការដាក់បណ្តាសាឲ្យដើមល្វានោះ មិនមានទាក់ទងអ្វីនឹងការឃ្លានអាហាររបស់ព្រះអង្គទេ តែព្រះអង្គកំពុងបង្រៀនយើងនូវមេរៀនមួយ។ ដើមឈើនោះជាតំណាងឲ្យប្រជាជាតិអ៊ីស្រាអែល ដែលធ្លាប់បានដើរតាមជំនឿត្រឹមត្រូវ តែពួកគេបានរង្វេងចេញវិញ។ ពួកគេហៀបនឹងធ្វើគុតព្រះមែស៊ីរបស់ពួកគេ ដែលជាព្រះរាជបុត្រានៃព្រះ។ តើពួកគេនឹងកាន់តែមានភាពក្រៀមក្រោះប៉ុណ្ណាទៀត?

យើងប្រហែលចូលចិត្តមើលពីចម្ងាយ តែព្រះយេស៊ូវយាងចូលមកជិត រកមើលផលផ្លែនៃព្រះវិញ្ញាណបរិសុទ្ធក្នុងជីវិតយើង។ ផលផ្លែរបស់យើងមិនមែនសម្រាប់ឲ្យគេកោតស្ញែងយើងទេ។ ប៉ុន្តែ ផលផ្លែយើងត្រូវតែមានលក្ខណៈពិសេស នៅត្រង់ចំណុចដែលថា យើងនៅតែមានក្តីស្រឡាញ់ ក្តីអំណរ និងសន្តិភាពក្នុងពេលដ៏ពិបាក (កាឡាទី ៥:២២)។ យើងអាចបង្កើតផលផ្លែថ្វាយព្រះយេស៊ូវ ដោយពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធ។

—Mike Wittmer

តើអ្នកដទៃមើលឃើញផលផ្លែអ្វីខ្លះក្នុងជីវិតអ្នក? តើអ្នកអាចមានផលផ្លែកាន់តែច្រើន ដោយរបៀបណា?

ឱព្រះអម្ចាស់ សូមព្រះវិញ្ញាណព្រះអង្គលោះមែកទូលបង្គំ ដើម្បីឲ្យទូលបង្គំបង្កើតផលផ្លែកាន់តែច្រើនឡើង។

Daily Manna 2026_Content Enhance.indd 92 17/11/25 1:45 in the afternoon

ខ្ញុំឲ្យសេចក្តីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក (យ៉ូហាន ១៣:៣៤)។

បញ្ញត្តិថ្មីមួយ ឲ្យស្រឡាញ់

រាជវង្សានុវង្សរបស់ចក្រភពអង់គ្លេស មានប្រពៃណីចែកអំណោយដល់ប្រជាជនក្រីក្រ នៅថ្ងៃព្រហស្បតិ៍ម៉ូនឌី នៅមុនថ្ងៃសុក្រដ៏ល្អក្នុងរដូវកាលនៃការប្រារព្ធបុណ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ។ ប្រពៃណីនេះមានដើមកំណើតនៅក្នុងអត្ថន័យរបស់ពាក្យ ម៉ូនឌី ដែលប្រែមកពីពាក្យឡាតាំង មែនដាទុម (mandatum) ប្រែមកថា «បញ្ជា»។ នៅពេលយប់មុនពេលព្រះអង្គសុគត ព្រះអង្គបានប្រទានព្រះរាជបញ្ជាថ្មីមួយ ដល់ពួកសាវ័កជាមិត្តសំឡាញ់ព្រះអង្គ ដោយបន្ទូលថា «ខ្ញុំឲ្យសេចក្តីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ» (យ៉ូហាន ១៣:៣៤)។

ព្រះយេស៊ូវជាអ្នកដឹកនាំ ដែលបានបំពេញតួនាទីជាអ្នកបម្រើ ខណៈពេលដែលព្រះអង្គលាងជើងឲ្យពួកសាវ័កដែលជាមិត្តសំឡាញ់ព្រះអង្គ (ខ.៥)។ បន្ទាប់មក ព្រះអង្គក៏បានប្រាប់ពួកគេឲ្យយកតម្រាប់តាមព្រះអង្គ ដោយបន្ទូលថា «ខ្ញុំបានធ្វើជំរាប់ទុកឲ្យអ្នករាល់គ្នាហើយ ដើម្បីឲ្យអ្នករាល់គ្នាគ្រាប់តាមការដែលខ្ញុំបានធ្វើឲ្យនោះ» (ខ.១៥)។ ហើយនៅក្នុងការលះបង់ដ៏ធំបំផុតនោះ ព្រះអង្គក៏បានលះបង់ព្រះជន្ម ដោយសុគតនៅលើឈើឆ្កាង (១៩:៣០)។ ព្រះអង្គបានលះបង់អង្គទ្រង់ ដោយសេចក្តីមេត្តា និងសេចក្តីស្រឡាញ់ ដើម្បីឲ្យយើងអាចអរសប្បាយនឹងជីវិតពេញបរិបូរ។

ប្រពៃណីរបស់រាជវង្សានុវង្សនៃចក្រភពអង់គ្លេស ក្នុងការបម្រើអ្នកក្រនៅតែបន្តធ្វើជានិមិត្តរូបតំណាងឲ្យការយកតម្រាប់តាមគំរូរបស់ព្រះយេស៊ូវ។ យើងប្រហែលមិនបានកើតនៅកន្លែងដែលមានឯកសិទ្ធិពិសេស តែពេលណាយើងជឿព្រះយេស៊ូវ យើងក្លាយជាសមាជិកនៃមហាគ្រួសាររបស់ព្រះអង្គ។ ហើយយើងក៏អាចបង្ហាញសេចក្តីស្រឡាញ់ ដោយធ្វើតាមបង្គាប់ព្រះអង្គ។ ពេលណាយើងពឹងផ្អែកព្រះវិញ្ញាណរបស់ព្រះអង្គ ដើម្បីកែប្រែជីវិតយើងពីខាងក្នុង យើងអាចឈោងទៅរកអ្នកដទៃ ដោយការយកចិត្តទុកដាក់ ការបញ្ជាក់ និងព្រះគុណ។

—Amy Boucher Pye

តើអ្នកបានសង្កេតមើល ឬយកគំរូតាមភាពជាអ្នកដឹកនាំដែលបម្រើអ្នកដទៃឬទេ? តើអ្នកអាចស្រឡាញ់គ្នាទៅវិញទៅមក យ៉ាងដូចម្តេចខ្លះនៅថ្ងៃនេះ?

ឱព្រះអង្គសង្គ្រោះដ៏អស្ចារ្យ ព្រះអង្គបានប្រទានអំណោយនៃសេចក្តីស្រឡាញ់ដ៏អស្ចារ្យ! ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានធ្វើជាអ្នកបម្រើដែលល្អបំផុត ដោយលះបង់ព្រះជន្ម ដើម្បីទូលបង្គំ។

Daily Manna 2026_Content Enhance.indd 93 17/11/25 1:45 in the afternoon

ព្រោះព្រះគ្រីស្ទទ្រង់បានរងទុក្ខម្តង ដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ ដោយទ្រង់ត្រូវគេធ្វើគុតខាងសាច់ឈាម តែបានវិញ្ញាណប្រោសឲ្យរស់វិញ (១ពេត្រុស ៣:១៨)។

ព្រះយេស៊ូវបានរងទុក្ខ និងសុគតជំនួសយើង

មានរឿងព្រេងដំណាលមកថា ស្តេច លេអូនីដាសទី១ (Leonidas I) បានដឹកនាំកងទ័ពនគរស្ប៉ាតា ដែលមានគ្នាតែ៣រយនាក់ ទៅតទល់នឹងកងទ័ពចក្រភពពែរស៊ីដែលមានគ្នាច្រើនជាងរាប់សែននាក់ ដឹកនាំដោយស្តេច សើរស៊ី (Xerxes) ក្នុងអំឡុងពេលនៃការឈ្លានពានរបស់ចក្រភពពើស៊ីចូលទឹកដីក្រិក។ ស្តេច លេអូនីដាស ជ្រាបថា កងទ័ពសត្រូវមានគ្នាច្រើនជាងកងទ័ពទ្រង់យ៉ាងលើសលប់ ដូចនេះទ្រង់ក៏បានសម្រេចព្រះទ័យប្រយុទ្ធដោយចិត្តអង់អាច រហូតដល់ដង្ហើមចុងក្រោយនៅក្នុងច្រកផ្លូវធើម៉ូភីលេ ជាច្រកផ្លូវដ៏ចង្អៀតចូលទឹកដីក្រិក។ ការលះបង់របស់ទ្រង់ និងកងទ័ពរបស់ទ្រង់បានពន្យារពេលការឈ្លានពានរបស់កងទ័ពពើស៊ីចូលទឹកដីក្រិក ដោយបានផ្តល់ឱកាសឲ្យកងទ័ពមកពីនគរក្រិកផ្សេងទៀតអាចដកថយ ដើម្បីទៅប្រមូលផ្តុំគ្នានៅពេលក្រោយទៀត ហើយទីបំផុតកងទ័ពក្រិកអាចយកជ័យជម្នះមកលើកងទ័ពពើស៊ីក្នុងសង្គ្រាមដ៏ធំនេះ។

ការលះបង់របស់ស្តេច លេអូនីដាស និងកងទ័ពស្ប៉ាតារបស់ទ្រង់បានជួយសង្គ្រោះប្រជាជនក្រិករាប់លាននាក់ ឲ្យរួចផុតពីការកាប់សម្លាប់ និងការកៀបសង្កត់របស់ចក្រភពពើស៊ី។ រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីការលះបង់ព្រះជន្មរបស់ព្រះយេស៊ូវកាលពីជាង២ពាន់ឆ្នាំមុន ដើម្បីបុព្វហេតុធំលើសនេះទៀត ដែលជាការរំដោះមនុស្សឲ្យរួចផុតពីបាប និងសេចក្តីស្លាប់ខាងវិញ្ញាណអស់កល្បជានិច្ច។ «ទ្រង់បានរងទុក្ខម្តង ដោយព្រោះបាបដែរ គឺជាព្រះដ៏សុចរិត ទ្រង់រងទុក្ខជំនួសមនុស្សទុច្ចរិត ដើម្បីនឹងនាំយើងរាល់គ្នាទៅដល់ព្រះ» (១ពេត្រុស ៣:១៨)។ ក្នុងនាមព្រះអង្គជាដង្វាយលោះបាប ដែលគ្មានបាបសោះ ព្រះអង្គបានរងទុក្ខ និងសុគតម្តងជាសម្រេច (ហេព្រើរ ១០:១០) សម្រាប់មនុស្សទាំងអស់ដែលជឿព្រះអង្គ។ ព្រះអង្គបានទទួលយកទោសបាបរបស់យើង ដាក់នៅលើអង្គទ្រង់នៅលើឈើឆ្កាង។ ការសុគតរបស់ព្រះគ្រីស្ទជំនួសយើង នៅលើឈើឆ្កាងបានផ្តល់ឲ្យនូវ «ក្តីសង្ឃឹម» ដល់យើង (១ពេត្រុស ៣:១៥, ១៨ យ៉ូហាន ១០:១៥) ហើយក៏បានផ្សះផ្សាយើងឲ្យជានឹងព្រះផងដែរ។

បានជាយើងអាចអរសប្បាយ និងរកឃើញការកម្សាន្តចិត្ត និងទំនុកចិត្តក្នុងសេចក្តីពិតដែលថា មានតែតាមរយៈការសុគតរបស់ព្រះគ្រីស្ទជំនួសយើង ជាមនុស្សមានបាបទេ ទើបយើងអាចរួចផុតពីបាប និងសេចក្តីស្លាប់អស់កល្បជានិច្ច ហើយមានផ្លូវចូលទៅរកការប្រកបទាក់ទងជាមួយព្រះនៃសេចក្តីស្រឡាញ់។—Marvin Williams

តើការសុគតរបស់ព្រះគ្រីស្ទជំនួសអ្នក បានកែប្រែជីវិតអ្នកដូចម្តេចខ្លះ? តើការដែលអ្នកមានផ្លូវចូលទៅរកព្រះ និងមានជីវិតអស់កល្ប មានន័យយ៉ាងណាសម្រាប់អ្នក?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការសុគតជំនួសទូលបង្គំ ដើម្បីឲ្យទូលបង្គំមានផ្លូវចូលទៅរកព្រះវរបិតា។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ពួកចៅហ្វាយ ៧-៨ និងលូកា ៥:១-១៦

ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់ (អេសាយ ៥៣:៥)។

ការលះបង់របស់ព្រះគ្រីស្ទ

មុនពេលលោក លូអីស ជីម ខាវីហ្សែល (Jim Caviezel) ដើរតួសម្តែងជាព្រះយេស៊ូវ ក្នុងខ្សែភាពយន្ត រឿង ការលះបង់របស់ព្រះគ្រីស្ទ លោក លូអីស មែល គីបសិន (Mel Gibson) បានដាស់តឿនគាត់ថា ការដើរតួសម្តែងនេះនឹងមានការពិបាកយ៉ាងខ្លាំង ហើយអាចមានផលប៉ះពាល់អវិជ្ជមានមកលើអាជីពរបស់គាត់នៅក្នុងហូលីវូដ។ លោក លូអីស ជីម ក៏បានទទួលយកការដើរតួសម្តែងនេះ ដោយនិយាយថា គាត់ត្រូវតែដើរតួសម្តែងក្នុងរឿងនេះ ទោះពិបាកយ៉ាងណាក៏ដោយ។

ក្នុងអំឡុងពេលថតរឿងនោះ លោក លូអីស ជីម ត្រូវរន្ទះបាញ់ម្តង គាត់បានស្រកគីឡូអស់២៣គីឡូ ហើយត្រូវគេវាយជ្រុលដៃបណ្តាលឲ្យបួសនៅក្នុងឈុតធ្វើទារុណកម្មព្រះយេស៊ូវ។ ក្រោយមក គាត់ក៏បានលើកឡើងថា “ខ្ញុំមិនចង់ឲ្យគេមើលឃើញខ្ញុំទេ តែចង់ឲ្យគេមើលឃើញព្រះយេស៊ូវវិញ។ ការប្រែចិត្តអាចកើតមាន តាមរយៈខ្សែភាពយន្តនេះ”។ ខ្សែភាពយន្តនេះប៉ះពាល់ចិត្តលោក លូអីស ជីម និងមនុស្សជាច្រើននៅកន្លែងថតកុន ហើយមានតែព្រះអម្ចាស់ទេ ដែលបានជ្រាបថា មានមនុស្សប៉ុន្មានលាននាក់ ដែលបានទស្សនារឿងនេះ ហើយមានការផ្លាស់ប្តូរនៅក្នុងជីវិត។

ខ្សែភាពយន្តរឿង ការលះបង់របស់ព្រះគ្រីស្ទ បានឆ្លុះបញ្ចាំងអំពីពេលដែលព្រះយេស៊ូវបានទទួលរកទុក្ខវេទនាជាទីបំផុត ចាប់តាំងពីពេលដែលព្រះអង្គយាងចូលក្នុងទីក្រុងយេរូសាឡិម ដោយការដង្ហែនៃជ័យជម្នះ និងបានរាប់បញ្ចូលការក្បត់របស់មិត្តសំឡាញ់ ការចំអក ការវាយដំ និងការឆ្កាងអង្គទ្រង់។ រឿងនេះសុទ្ធតែបានចែងក្នុងដំណឹងល្អទាំងបួន។

បទគម្ពីរអេសាយជំពូក៥៣ បានថ្លែងទំនាយទុកជាមុនអំពីការរងទុក្ខ និងលទ្ធផលនៃការសុគតរបស់ព្រះអង្គ។ គឺដូចមានសេចក្តីចែងមកថា “ទ្រង់ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់” (ខ.៥)។ យើងម្នាក់ៗ “យើងទាំងអស់គ្នាបានទាសចេញដូចជាចៀម គឺយើងបានបែរចេញទៅតាមផ្លូវយើងរៀងខ្លួន” (ខ.៦)។ ប៉ុន្តែ ដោយសារការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ យើងអាចមានសន្តិភាពជាមួយព្រះ។ ការរងទុក្ខ និងការសុគតរបស់ព្រះអង្គ បានបើកផ្លូវឲ្យយើងចូលទៅប្រកបទាក់ទងជាមួយព្រះអង្គ។—Alyson Kieda

តើអ្នកមានការប៉ះពាល់ចិត្តបំផុត មកលើផ្នែកណាខ្លះនៃព្រះជន្មរបស់ព្រះគ្រីស្ទ? តើការរងទុក្ខរបស់ព្រះអង្គ បាននាំមកនូវសេចក្តីល្អអ្វីខ្លះសម្រាប់អ្នក?

ឱព្រះអង្គសង្គ្រោះ ទូលបង្គំមិនអាចថ្លែងឲ្យអស់សេចក្តីថា ទូលបង្គំមានការដឹងគុណយ៉ាងណាចំពោះការរងទុក្ខ ការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ពួកចៅហ្វាយ ៩-១០ និងលូកា ៥:១៧-៣៩

ទ្រង់មិនគង់នៅទីនេះទេ ដ្បិតទ្រង់មានព្រះជន្មរស់ឡើងវិញហើយ ដូចជាទ្រង់បានមានព្រះបន្ទូលទុក ចូរមកមើលកន្លែងដែលទ្រង់បានផ្ទំចុះ (ម៉ាថាយ ២៨:៦)។

ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញហើយ!

មុនពេលលោក ឆាល ស៊ីមាន (Charles Simeon) ចូលរៀននៅសកលវិទ្យាល័យខេមប្រ៊ីជ ប្រទេសអង់គ្លេស គាត់ចូលចិត្តសត្វសេះ និងសំលៀកបំពាក់ណាស់ បានជាគាត់ចំណាយលុយជាច្រើនជារៀងរាល់ឆ្នាំទៅលើការស្លៀកពាក់របស់គាត់។ ប៉ុន្តែ ដោយសារសកលវិទ្យាល័យរបស់គាត់បានតម្រូវឲ្យគាត់ចូលរួមកម្មវិធីលៀងព្រះអម្ចាស់ជាទៀងទាត់ គាត់ក៏បានចាប់ផ្តើមស្វែងយល់អំពីជំនឿរបស់គាត់។ បន្ទាប់ពីគាត់បានអានសៀវភៅដែលអ្នកជឿព្រះយេស៊ូវបាននិពន្ធ គាត់ក៏មានការផ្លាស់ប្រែដ៏អស្ចារ្យនៅថ្ងៃអាទិត្យ ដែលគេប្រារព្ធបុណ្យព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ។ កាលគាត់ក្រោកពីគេងនៅពេលព្រលឹមនៅថ្ងៃទី៤ ខែឧសភា ឆ្នាំ១៧៧៩ គាត់ក៏បានបន្លឺសម្លេងថា «ព្រះយេស៊ូវគ្រីស្ទបានមានព្រះជន្មរស់ឡើងវិញហើយ! ហាលេលូយ៉ា! ហាលេលូយ៉ា!» ខណៈពេលដែលគាត់មានការលូតលាស់ក្នុងជំនឿលើព្រះ គាត់ក៏មានចិត្តប្តូរផ្តាច់នៅក្នុងការសិក្សាព្រះគម្ពីរ អធិស្ឋាន និងចូលរួមកម្មវិធីថ្វាយបង្គំព្រះ។

នៅថ្ងៃដែលព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ ការផ្លាស់ប្តូរក៏បានកើតមានក្នុងជីវិតរបស់ស្ត្រីពីរនាក់ ដែលបានមកដល់ផ្នូររបស់ព្រះយេស៊ូវមុនគេ។ នៅទីនោះ ពួកគេបានឃើញការរញ្ជួយដី ខណៈពេលដែលទេវតាមួយអង្គប្រមៀលថ្មចេញពីច្រកចូលក្នុងផ្នូរព្រះអង្គ។ ទេវតាក៏បានប្រាប់ពួកគេថា «កុំឲ្យភ័យអី ដ្បិតខ្ញុំដឹងហើយថា នាងរកព្រះយេស៊ូវដែលត្រូវឆ្កាង តែទ្រង់មិនគង់នៅទីនេះទេ ដ្បិតទ្រង់មានព្រះជន្មរស់ឡើងវិញហើយ ដូចជាទ្រង់បានមានព្រះបន្ទូលទុក ចូរមកមើលកន្លែងដែលទ្រង់បានផ្ទំចុះ» (ម៉ាថាយ ២៨:៥-៦)។ ពួកគេមានចិត្តត្រេកអរជាពន់ពេក ដោយបានថ្វាយបង្គំព្រះយេស៊ូវ ហើយក៏បានរត់ទៅប្រាប់ដំណឹងល្អ ដល់មិត្តសំឡាញ់របស់ខ្លួនជាសិស្សរបស់ព្រះអង្គ។

ការជួបព្រះគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ មិនមែនសម្រាប់តែមនុស្សសម័យបុរាណប៉ុណ្ណោះទេ ព្រោះព្រះអង្គបានសន្យាថា យើងនឹងបានជួបព្រះអង្គមុខទល់នឹងមុខនៅថ្ងៃណាមួយ។ តែទំរាំតែពេលនោះមកដល់ យើងអាចប្រកបស្និទ្ធស្នាលជាមួយព្រះអង្គ នៅក្នុងការរៀនព្រះគម្ពីរ និងអធិស្ឋានជារៀងរាល់ថ្ងៃ ដោយទុកចិត្តថា ព្រះអង្គស្រឡាញ់យើង ហើយបន្តជួយយើងឲ្យមានការផ្លាស់ប្រែក្នុងជីវិត។—Amy Boucher Pye

តើព្រះអម្ចាស់បានបង្ហាញអង្គទ្រង់ដល់អ្នក យ៉ាងដូចម្តេចខ្លះ? តើអ្នកមានការផ្លាស់ប្រែដូចម្តេចខ្លះតាមរយៈការប្រកបជាមួយព្រះអង្គជារៀងរាល់ថ្ងៃ?

ឱព្រះយេស៊ូវ ដែលមានព្រះជន្មរស់ឡើងវិញ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការយាងមក និងការសុគតនៅលើឈើឆ្កាង ដើម្បីឲ្យទូលបង្គំមានជីវិតអស់កល្ប។ ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ពួកចៅហ្វាយ ១១-១២ និងលូកា ៦:១-២៦

ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ (ហេព្រើរ ១០:២៥)។

ការជួបជុំគ្នាក្នុងព្រះយេស៊ូវ

កាលខ្ញុំកំពុងឆ្លងកាត់អំឡុងពេលនៃការឈឺចាប់ផ្លូវអារម្មណ៍ និងវិញ្ញាណ និងការតស៊ូ ដោយសារកាលៈទេសៈដ៏ពិបាក ក្នុងជីវិតខ្ញុំ ខ្ញុំមានអារម្មណ៍ថា បើខ្ញុំដកខ្លួនចេញពីពួកជំនុំរបស់ខ្ញុំ ជីវិតខ្ញុំនឹងមានភាពងាយស្រួលជាង។ (ហើយជួនកាល ខ្ញុំពិតជាបានឆ្ងល់ថា ហេតុអ្វីខ្ញុំចាំបាច់ត្រូវទៅព្រះវិហារ?) ប៉ុន្តែ ខ្ញុំនៅតែបានទទួលការបណ្តាលចិត្តឲ្យបន្តចូលរួមជាមួយពួកគេនៅថ្ងៃអាទិត្យ។

ទោះស្ថានភាពរបស់ខ្ញុំ នៅតែមិនមានការផ្លាស់ប្តូរអស់រយៈពេលជាច្រើនឆ្នាំ ការថ្វាយបង្គំ ការជួយជុំថ្វាយបង្គំព្រះ ជាមួយអ្នកជឿដទៃទៀត ការជួបជុំគ្នាអធិស្ឋាន និងសិក្សាព្រះគម្ពីរ បានផ្តល់ឲ្យខ្ញុំនូវការលើកទឹកចិត្ត ដែលខ្ញុំត្រូវការ ដើម្បីស៊ូទ្រាំ និងនៅតែមានសេចក្តីសង្ឃឹម។ ហើយជាញឹកញាប់ ខ្ញុំមិនគ្រាន់តែបានឮការចែកចាយ ឬការបង្រៀនដែលលើកទឹកចិត្តប៉ុណ្ណោះទេ តែក៏បានទទួលការកម្សាន្តចិត្ត ហើយមានគេយកចិត្តទុកដាក់ក្នុងការស្តាប់ខ្ញុំចែកចាយបញ្ហារបស់ខ្ញុំ ដោយការអាណិត និងសេចក្តីស្រឡាញ់។

កណ្ឌគម្ពីរហេព្រើរបានបង្រៀនយើងថា «ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថាថ្ងៃនោះជិតមកដល់ហើយ» (ហេព្រើរ ១០:២៥)។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរដឹងថា ពេលណាយើងប្រឈមមុខដាក់ទុក្ខលំបាក និងបញ្ហាក្នុងជីវិតយើង យើងត្រូវការការលើកទឹកចិត្តពីអ្នកដទៃ ហើយអ្នកដទៃក៏ត្រូវការការលើកទឹកចិត្តពីយើងផងដែរ។ ដូចនេះ កណ្ឌគម្ពីរនេះក៏បានរំឭកយើងផងដែរ ឲ្យ «កាន់ខ្ជាប់ តាមសេចក្តីបន្ទាល់របស់សេចក្តីសង្ឃឹមនោះ ឥតរើរាយ... ហើយត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្តាលឲ្យមានសេចក្តីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង» (ខ.២៣-២៤)។ នេះជាផ្នែកដ៏ធំមួយនៃការលើកទឹកចិត្ត។ ហេតុនេះហើយ ព្រះទ្រង់ដឹកនាំយើងឲ្យបន្តជួបជុំគ្នា។ ថ្ងៃនេះអាចមាននរណាម្នាក់ត្រូវការការលើកទឹកចិត្តរបស់អ្នក ដោយសេចក្តីស្រឡាញ់ ហើយអ្នកនឹងមានការភ្ញាក់ផ្អើលចំពោះការអ្វីដែលអ្នកទទួលបានមកវិញ។—Alyson Kieda

តើអ្នកបានទទួលការកម្សាន្តចិត្ត ពីការជួបជុំគ្នានៅព្រះវិហារនៅពេលណា? ហេតុអ្វី? តើនរណាខ្លះត្រូវការការគាំទ្រ និងការលើកទឹកចិត្តរបស់អ្នក?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គជួយទូលបង្គំ កុំឲ្យឈប់ជួបប្រជុំគ្នាឡើយ តែឲ្យពិសោធន៍នឹងសន្តិភាព និងសេចក្តីស្រឡាញ់របស់ព្រះអង្គជាមួយគ្នា។

សូមឲ្យទ្រង់បានដូចជាភ្លៀងធ្លាប់ចុះមកលើវាល ដែលច្រូតស្មៅហើយ គឺដូចជាភ្លៀង១មេៗដែលស្រោចដី (ទំនុកតម្កើង ៧២:៦)។

អ្នកដឹកនាំ ក្នុងទំនុកតម្កើង ៧២

កាលពីខែកក្កដា ឆ្នាំ២០២២ នាយករដ្ឋមន្ត្រីនៃប្រទេសអង់គ្លេស ត្រូវបង្ខំចិត្តចុះចេញពីតំណែង បន្ទាប់ពីមនុស្សជាច្រើនបានយល់ឃើញថា លោកស្រីបានបរាជ័យនៅក្នុងការរក្សាភាពស្អាតស្អំ (នាយករដ្ឋមន្ត្រីរូបនេះបានលាលែងពីតំណែង បន្ទាប់ពីបានទទួលការតែងតាំងបានតែ៣ខែប៉ុណ្ណោះ)។ ព្រឹត្តិការណ៍នេះបានកើតឡើងនៅពេលដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាល បានចូលរួមពិធីអធិស្ឋានក្នុងពេលបរិភោគអាហារពេលព្រឹកប្រចាំឆ្នាំរបស់សមាជិកសភា ហើយក៏បានទទួលការបណ្តាលចិត្ត ឲ្យរស់នៅដោយភាពស្អាតស្អំ ហើយក៏បានសម្រេចចិត្តចុះចេញពីតំណែង។ នៅពេលដែលរដ្ឋមន្ត្រីដទៃទៀតចុះចេញពីតំណែងជាបន្តបន្ទាប់ នាយករដ្ឋមន្ត្រីរូបនោះក៏បានដឹងថា គាត់ក៏ត្រូវចុះចេញផងដែរ។ នេះជារឿងដែលគួរឲ្យកត់សម្គាល់ណាស់ ដែលបានកើតឡើង បន្ទាប់ពីពួកគេបានចូលរួមកម្មវិធីជួបជុំគ្នាអធិស្ឋានដ៏ស្ងប់ស្ងាត់។

ព្រះគម្ពីរក៏បានបង្រៀនអ្នកជឿព្រះយេស៊ូវឲ្យអធិស្ឋាន ឲ្យអ្នកដឹកនាំនយោបាយផងដែរ (១ធីម៉ូថេ ២:១-២) ហើយបទគម្ពីរ ទំនុកតម្កើងជំពូក៧២ ក៏បានផ្តល់ឲ្យនូវលំនាំនៃការអធិស្ឋានដ៏ល្អ ដោយបានពិពណ៌នាអំពីតួនាទីរបស់អ្នកដឹកនាំប្រទេស និងការអធិស្ឋានឲ្យអ្នកដឹកនាំប្រទេសបំពេញតួនាទីទាំងនោះឲ្យបានល្អ។ បទគម្ពីរនេះក៏បានបកស្រាយថា អ្នកដឹកនាំល្អ ជាអ្នកដឹកនាំដែលប្រកាន់ខ្ជាប់នូវយុត្តិធម៌ និងភាពស្អាតស្អំ (ខ.១-២) ជាអ្នកការពារមនុស្សដែលងាយរងគ្រោះ (ខ.៤) បម្រើអ្នកក្រ (ខ.១២-១៣) ហើយទាស់ប្រឆាំងនឹងការកៀបសង្កត់ (ខ.១៤)។ ការកាន់កាប់តំណែងរបស់ពួកគេពិតជានាំមកនូវភាពស្រស់ថ្លាណាស់ គឺប្រៀបដូចជាភ្លៀងដែលស្រោចស្រពដី (ខ.៦) ដោយនាំភាពសម្បូរសប្បាយដល់ប្រទេសជាតិ (ខ.៣, ៧, ១៦)។ មានតែព្រះមែស៊ីទេ ដែលអាចបំពេញតួនាទីទាំងនោះបានល្អឥតខ្ចោះ (ខ.១១) ដូចនេះតើមាននរណាអាចធ្វើជាគំរូនៃអ្នកដឹកនាំបានល្អជាងព្រះអង្គទៀត?

សុខុមាលភាពរបស់ប្រទេសជាតិ មានការពឹងផ្អែកយ៉ាងខ្លាំងមកលើភាពស្អាតស្អំរបស់អ្នកដឹកនាំប្រទេស។ ចូរយើងអធិស្ឋាន សូមឲ្យប្រទេសជាតិយើងមានអ្នកដឹកនាំ ដែលមានលក្ខណៈដូចអ្នកដឹកនាំ ដែលមានចែងក្នុងបទគម្ពីរទំនុកតម្កើងជំពូក៧២ ចូរយើងអធិស្ឋានសូមព្រះអង្គជួយពួកគេ ឲ្យមានចរិកលក្ខណៈដូចមានចែងក្នុងបទគម្ពីរទំនុកតម្កើងនេះ។—Sheridan Voysey

តើអ្នកស្វែងរកលក្ខណៈសម្បត្តិអ្វីខ្លះ ក្នុងអ្នកដឹកនាំ? តើអ្នកអាចអធិស្ឋានកាន់តែញឹកញាប់ដូចម្តេចខ្លះ ឲ្យអ្នកដឹកនាំក្នុងតំបន់ និងក្នុងប្រទេសរបស់អ្នក?

ឱព្រះវរបិតា សូមព្រះអង្គប្រទានកម្ងាន់ដល់អ្នកដឹកនាំរបស់យើងខ្ញុំ ឲ្យធ្វើជាមនុស្សប្រកាន់ខ្ជាប់នូវសេចក្តីយុត្តិធម៌ ភាពស្អាតស្អំ និងសេចក្តីល្អ។

អ្នកធ្មាំទ្វារក៏បើកឲ្យអ្នកនោះ ហើយហ្វូងចៀមស្តាប់តាមសំឡេងគាត់ដែរ ឯចៀមរបស់គាត់ នោះគាត់ហៅតាមឈ្មោះវានីមួយៗនាំចេញទៅក្រៅ (យ៉ូហាន ១០:៣)។

ទូលបង្គំបានឮព្រះអង្គហើយ

កូន ង៉ែតឈ្មោះ ក្រាហាំ (Graham) បញ្ចេញសម្លេងយំ ហើយបម្រះខ្លួនធ្វើដើងផឹកៗ ខណៈពេលដែលម្តាយគាត់បានពរគាត់នៅលើភ្លៅ ដោយគ្រូពេទ្យបានដាក់ឧបករណ៍ជំនួយការស្តាប់ក្នុងត្រចៀកគាត់។ នៅពេលដែលគ្រូពេទ្យបើកឧបករណ៍នោះ ក្រាហាំក៏បានឈប់យំ។ គាត់បើកភ្នែកធំៗ ហើយមានទឹកមុខញញឹម។ គាត់អាចស្តាប់ឮសម្លេងម្តាយគាត់កំពុងលួងគាត់ លើកទឹកចិត្ត និងហៅឈ្មោះគាត់។

ក្រាហាំ ក៏បានស្តាប់ឮសម្លេងម្តាយគាត់និយាយ តែគាត់ត្រូវការជំនួយ ក្នុងការរៀនស្គាល់សម្លេងគាត់ ហើយយល់អំពីអត្ថន័យរបស់ពាក្យសម្តីគាត់។ ព្រះយេស៊ូវក៏បានអញ្ជើញមនុស្សឲ្យមានការរៀនសូត្រស្រដៀងនេះផងដែរ។ ពេលណាយើងទទួលជឿព្រះគ្រីស្ទជាព្រះអង្គសង្គ្រោះរបស់យើង យើងក្លាយជាចៀម ដែលព្រះអង្គបានស្គាល់យ៉ាងច្បាស់ ហើយដឹកនាំដោយផ្ទាល់ (យ៉ូហាន ១០:៣)។ យើងអាចចម្រើនឡើងក្នុងការទុកចិត្ត និងស្តាប់បង្គាប់ព្រះអង្គ ខណៈពេលដែលយើងរៀនស្តាប់សម្លេងព្រះអង្គ និងប្រព្រឹត្តតាម (ខ.៤)។

ក្នុងគ្រាសញ្ញាចាស់ ព្រះទ្រង់មានបន្ទូលតាមរយៈពួកហោរា។ ក្នុងគ្រាសញ្ញាថ្មី ព្រះយេស៊ូវជាព្រះដែលយកសាច់ឈាមជាមនុស្ស មានបន្ទូលដោយផ្ទាល់មកកាន់រាស្ត្រព្រះអង្គ។ សព្វថ្ងៃនេះ អ្នកជឿព្រះយេស៊ូវ មានឱកាសទទួលព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះអង្គជួយយើងឲ្យយល់ និងស្តាប់បង្គាប់តាមព្រះបន្ទូល ដែលព្រះអង្គបានបណ្តាលចិត្តគេឲ្យកត់ទុកក្នុងព្រះគម្ពីរ។ យើងអាចនិយាយទៅកាន់ព្រះយេស៊ូវដោយផ្ទាល់ តាមរយៈការអធិស្ឋានរបស់យើង ខណៈពេលដែលព្រះអង្គមានបន្ទូលមកយើងតាមរយៈព្រះគម្ពីរ និងរាស្ត្ររបស់ព្រះអង្គ។ ពេលណាយើងស្គាល់សម្លេងព្រះអង្គ ដែលតែងតែស្របនឹងព្រះបន្ទូលក្នុងព្រះគម្ពីរ យើងអាចបន្លឺសម្លេងសរសើរតម្កើង ដោយអរព្រះគុណថា «ព្រះអង្គអើយ ទូលបង្គំឮព្រះអង្គហើយ!»—Xochitl Dixon

តើព្រះអម្ចាស់បានប្រើព្រះគម្ពីរ ដើម្បីបើកបង្ហាញអង្គទ្រង់ ដល់អ្នកក្នុងសប្តាហ៍នេះដូចម្តេចខ្លះ? តើអ្នកអាចចែកចាយប្រាជ្ញារបស់ព្រះអង្គ ដល់អ្នកដទៃ ដែលត្រូវការការកម្សាន្តចិត្ត ឬការលើកទឹកចិត្តដូចម្តេចខ្លះនៅថ្ងៃនេះ?

ឱព្រះអង្គអើយ ទូលបង្គំឮព្រះអង្គហើយ! សូមព្រះអង្គជួយទូលបង្គំ ឲ្យទទួល និងចែកចាយសេចក្តីពិត និងសេចក្តីស្រលាញ់ ដែលព្រះអង្គបង្ហាញមកទូលបង្គំ ពេលណាទូលបង្គំអានព្រះគម្ពីរ។

Daily Manna 2026_Content Enhance.indd 99 17/11/25 1:45 in the afternoon

អញនឹងនៅជាមួយនឹងវាក្នុងគ្រាទុក្ខលំបាក (ទំនុកតម្កើង ៩១:១៥)។

ក្នុងព្រះហស្តព្រះអង្គ

នៅពេលដែលក្មេងស្រីអាយុ៥ឆ្នាំ ឈ្មោះសារ៉ា (Sarah) ឮសម្លេងម៉ូទ័រខ្លួងធ្មេញ នាងមានការភ័យខ្លាចយ៉ាងខ្លាំង។ នាងក៏បានស្នុះលោតចេញពីកៅអីពេទ្យធ្មេញ ហើយបដិសេធន៍មិនព្រមឡើងអង្គុយនៅលើកៅអីនោះទៀត។ ពេទ្យធ្មេញក៏បានងក់ក្បាលដោយយល់អំពីស្ថានភាព ហើយក៏បានប្រាប់ប៉ារបស់នាងឲ្យអង្គុយនៅលើកៅអីនោះ។ លោក ចេសិន (Jason) ជាឪពុកគិតស្មានថា ពេទ្យឲ្យគាត់ធ្វើដូចនេះ ដើម្បីបង្ហាញកូនស្រីគាត់ថា ការឲ្យពេទ្យព្យាបាលធ្មេញមានភាពងាយស្រួលប៉ុណ្ណា។ ប៉ុន្តែ បន្ទាប់មកពេទ្យធ្មេញក៏បានងាកទៅក្មេងស្រីនោះ ហើយប្រាប់នាងឲ្យឡើងអង្គុយនៅលើភ្លៅរបស់ប៉ានាង។ ដោយសារនាងស្ថិតក្នុងរង្វង់ដៃនៃការធានារបស់ឪពុកនាង នាងក៏បានសម្រួលអារម្មណ៍បានទាំងស្រុង ហើយគ្រូពេទ្យអាចបន្តការព្យាបាលធ្មេញរបស់នាង។

នៅថ្ងៃនោះ លោក ចេសិន បានរៀនសូត្រមេរៀនដ៏ប្រសើរអំពីការកម្សាន្តចិត្តនៃព្រះវត្តមាននៃព្រះវរបិតារបស់គាត់ ដែលគង់នៅស្ថានសួគ៌។ គាត់ថា «ជួនកាល ព្រះទ្រង់មិនដកបញ្ហា ដែលយើងកំពុងឆ្លងកាត់ តែព្រះអង្គកំពុងបង្ហាញខ្ញុំថា ព្រះអង្គនឹងគង់នៅជាមួយខ្ញុំជានិច្ច»។

កណ្ឌគម្ពីរទំនុកតម្កើងជំពូក៩១ បានចែងអំពីព្រះវត្តមាននៃការកម្សាន្តចិត្ត និងព្រះចេស្តារបស់ព្រះអង្គ ដែលផ្តល់ឲ្យយើងនូវកម្លាំង ដើម្បីប្រឈមមុខដាក់ការលំបាក។ ពេលណាយើងដឹងថា យើងអាចសម្រាកក្នុងព្រះហស្តដ៏មានចេស្តា ដែលបានផ្តល់ឲ្យយើងនូវការធានា គឺដូចដែលព្រះអង្គបានសន្យាអ្នកដែលស្រឡាញ់ព្រះអង្គថា អស់អ្នកដែលស្រែករកព្រះអង្គ ព្រះអង្គនឹងឆ្លើយតប ហើយនឹងគង់នៅជាមួយពួកគេក្នុងគ្រាមានទុក្ខលំបាក (ខ.១៥)។

មានបញ្ហាប្រឈម និងទុក្ខលំបាកជាច្រើនក្នុងជីវិតយើង ដែលមិនងាយជៀសរួច ហើយយើងត្រូវឆ្លងកាត់ការឈឺចាប់ និងទុក្ខវេទនា។ ប៉ុន្តែ ព្រះពាហុនៃការធានារបស់ព្រះអង្គឱបយើងបានជាយើងអាចស៊ូទ្រាំនឹងវិបត្តិ និងកាលៈទេសៈរបស់យើង ហើយអនុញ្ញាតឲ្យព្រះអង្គពង្រឹងជំនឿយើង ខណៈពេលដែលយើងឆ្លងកាត់បញ្ហាទាំងនោះ។—Leslie Koh

តើអ្នកកំពុងឆ្លងកាត់ទុក្ខលំបាកអ្វីខ្លះ ពេលឥឡូវនេះ? តើអ្នកអាចរំឭកខ្លួនឯងថា ព្រះអង្គតែងតែគង់នៅក្បែរអ្នកដូចម្តេចខ្លះ?

ឱព្រះវរបិតាប្រកបដោយព្រះគុណ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ព្រះវត្តមានដែលបានជានាទូលបង្គំក្នុងទុក្ខលំបាករបស់ទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំឆ្លងកាត់បញ្ហាទាំងនោះ ដោយដឹងថាព្រះអង្គតែងតែគង់នៅជាមួយទូលបង្គំជានិច្ច។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | នាងរស់ ១-៤ និងលូកា ៨:១-២៥

ទ្រង់ក៍ធ្វើឲ្យចិត្តគេសង្ឃឹមដល់អស់កល្បទៅមុខ (សាស្តា ៣:១១)។

ព្រះវត្តមានក្នុងពេលបច្ចុប្បន្ន និងជារៀងរហូត

ម៉ូនិច (Monique) កំពុងជួបការលំបាក។ នាងមានមិត្តភក្តិជាអ្នកជឿព្រះយេស៊ូវ ហើយនាងបានឲ្យតម្លៃមកលើរបៀបដែលពួកគេប្រឈមមុខដាក់ទុក្ខលំបាកក្នុងជីវិត។ នាងថែមទាំងមានចិត្តច្រណែនបន្តិច មកលើពួកគេ។ ប៉ុន្តែ ម៉ូនិច មិនបានគិតថា នាងអាចរស់នៅដូចពួកគេឡើយ ព្រោះនាងគិតថា ការជឿព្រះគ្រីស្ទ គឺជាការអនុវត្តតាមក្រិត្យវិន័យជាច្រើន។ ទីបំផុត មិត្តរួមថ្នាក់នាងម្នាក់នៅមហាវិទ្យាល័យ ក៏បានជួយពន្យល់នាងថា ព្រះទ្រង់មិនសព្វព្រះទ័យឲ្យនាងធ្វើអ្វីតាមចិត្តឡើយ ផ្ទុយទៅវិញព្រះអង្គសព្វព្រះទ័យឲ្យនាងរស់នៅឲ្យបានល្អបំផុត ទោះនាងជួបការលំបាក និងមានក្តីអំណរយ៉ាងណាក៏ដោយ។ នៅពេលដែលនាងបានយល់អំពីរឿងនេះ នាងក៏បានត្រៀមខ្លួនជាស្រេច ដើម្បីទទួលជឿព្រះយេស៊ូវ ជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះ ហើយក៏បានឱបក្រសោបយកសេចក្តីពិតអំពីសេចក្តីស្រឡាញ់ ដែលព្រះទ្រង់មានចំពោះនាង។

ស្តេច សាឡូម៉ូន ក៏អាចផ្តល់ឲ្យម៉ូនិចនូវយោបល់ស្រដៀងនេះផងដែរ។ ទ្រង់ទទួលស្គាល់ថា លោកីយ៍នេះពិតជាមានទុក្ខព្រួយមែន។ ជាការពិតណាស់ មានពេលសម្រាប់គ្រប់ការទាំងអស់ (សាស្តា ៣:១) «មានពេលសំរាប់សោយសោក និងពេលសំរាប់លោតកញ្ឆែង» (ខ.៤)។ ប៉ុន្តែ ជាងនេះទៅទៀត ព្រះអម្ចាស់ក៏បាន «ធ្វើឲ្យចិត្តគេសង្ឃឹមដល់អស់កល្បទៅមុខ» (ខ.១១)។ ពេលដ៏អស់កល្បជានិច្ច គឺជាពេលដែលពួកគេនឹងបានទៅរស់នៅក្នុងព្រះវត្តមានព្រះអង្គអស់កល្បជានិច្ច។

ម៉ូនិច ក៏បានទទួលជីវិតពេញបរិបូរនៅពេលដែលនាងទទួលជឿព្រះយេស៊ូវ (យ៉ូហាន ១០:១០)។ ប៉ុន្តែ នាងទទួលបានលើសនេះទៀត! ដោយសេចក្តីជំនឿ នាងមាន«ចិត្តដែលសង្ឃឹមដល់អស់កល្បទៅមុខ» (សាស្តា ៣:១១) ព្រោះព្រះអង្គបានសន្យាថា នៅពេលអនាគត នាងនឹងមិននឹកចាំអំពីទុក្ខលំបាកក្នុងជីវិតទៀតឡើយ (សាស្តា ៦៥:១៧) ហើយនឹងបានទៅរស់នៅក្នុងព្រះវត្តមានដ៏រុងរឿងរបស់ព្រះអង្គអស់កល្បជានិច្ច។—Dave Branon

តើអ្នកបានពិសោធន៍នឹងជីវិតពេញបរិបូរ ដែលព្រះយេស៊ូវបានប្រទានហើយឬនៅ? តើក្នុងជីវិតអ្នកមានចំណុចណាខ្លះ ដែលអ្នកចង់អរព្រះគុណព្រះអង្គ?

ឱព្រះយេស៊ូវ ស្តេច សាឡូម៉ូន បានមានបន្ទូលដ៏ត្រឹមត្រូវ។ ជីវិតមនុស្សមានដំណើរឡើងចុះៗជានិច្ច។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានជួយជីវិតទូលបង្គំឲ្យមានតម្លៃ និងសន្តិសមនឹងឲ្យទូលបង្គំមានការតស៊ូ។ ហើយទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការប្រទានក្តីអំណរដ៏អស់កល្ប ដែលកំពុងរង់ចាំទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១សាំយ៉ូអែល ១-៣ និងលូកា ៨:២៥-៥៦

ព្រមទាំងប្រដាប់ខ្លួន ដោយមនុស្សថ្មីវិញ ដែលកើតមកក្នុងសេចក្តីសុចរិត ហើយក្នុងសេចក្តីបរិសុទ្ធ របស់ផងសេចក្តីពិត តាមភាពព្រះ (អេភេសូរ ៤:២៤)។

រស់នៅជាមនុស្សថ្មី ក្នុងព្រះគ្រីស្ទ

ដើមស្រល់ពណ៌ខៀវដែលយើងបានដាំកំពុងតែជ្រុះផ្លែ និងស្លឹករបស់វា។ អ្នកជំនាញខាងព្យាបាលដើមឈើក៏បានមើលដើមស្រល់នោះ ហើយក៏បានពន្យល់អំពីបញ្ហារបស់វា។ គាត់ថា «ដើមស្រល់ពណ៌ខៀវតែងតែជ្រុះស្លឹក តាមធម្មជាតិរបស់វា»។ ខ្ញុំសង្ឃឹមថា គាត់មានការពន្យល់ល្អជាងនេះ ឬមានការព្យាបាលសម្រាប់ដើមស្រល់នោះ តែគាត់បានញាក់ស្មា ហើយនិយាយពាក្យដដែលៗថា «ដើមស្រល់ពណ៌ខៀវ តែងតែជ្រុះស្លឹក តាមធម្មជាតិរបស់វាអញ្ចឹងឯង»។ ដូចនេះ វាជ្រុះស្លឹកតាមធម្មជាតិរបស់វា។ វាមិនអាចផ្លាស់ប្តូរបានទេ។

តែអរព្រះគុណព្រះអង្គ ក្នុងជីវិតខាងវិញ្ញាណយើង គ្មានទម្លាប់ ឬអាកប្បកិរិយាណាដែលមិនអាចផ្លាស់ប្តូរនោះឡើយ។ សាវ័ក ប៉ុល បាននិយាយសង្កត់ធ្ងន់អំពីសេចក្តីពិតដែលជួយរំដោះនេះ ទៅកាន់អ្នកជឿព្រះនៅទីក្រុងអេភេសូរ។ គាត់ថា «គំនិតគេត្រូវបង្អាប់ ហើយគេដាច់ចេញពីព្រះជន្មព្រះ ដោយសារសេចក្តីខ្លៅល្ងង់ក្នុងខ្លួនគេ ព្រោះចិត្តគេរឹងទទឹង។ គេលែងខ្លាចបាប បានជាគេប្រគល់ខ្លួនទៅខាងសេចក្តីអាសអាភាស ដើម្បីនឹងប្រព្រឹត្តសេចក្តីស្មោកគ្រោកគ្រប់យ៉ាង ដោយចិត្តរ៉ាក់រ៉ិញ» (អេភេសូរ ៤:១៨-១៩)។

ប៉ុន្តែ គាត់ក៏បានបង្រៀនទៀតថា «ដោយសារអ្នករាល់គ្នាបានឮអំពីព្រះយេស៊ូវ និងសេចក្តីពិតរបស់ព្រះអង្គហើយ»... «នោះត្រូវឲ្យអ្នករាល់គ្នាបានដោះមនុស្សចាស់ ដែលតែងតែខូចទៅ តាមសេចក្តីប៉ងប្រាថ្នារបស់សេចក្តីឆបោកចោលចេញ» (ខ.២១-២២)។ គាត់ក៏បានប្រាប់ពួកគេ «ឲ្យគំនិតក្នុងចិត្តបានកែប្រែជាថ្មីឡើង។ ព្រមទាំងប្រដាប់ខ្លួន ដោយមនុស្សថ្មីវិញ ដែលកើតមកក្នុងសេចក្តីសុចរិត ហើយក្នុងសេចក្តីបរិសុទ្ធរបស់ផងសេចក្តីពិត តាមភាពព្រះ» (ខ.២២-២៤)។

បន្ទាប់មក គាត់ក៏បានបង្ហាញការរស់នៅតាមរបៀបថ្មី ដោយឈប់កុហក ជម្នះសេចក្តីកំហឹង ឈប់ជេរប្រទេច ឈប់លួចជាដើម «ស៊ូឲ្យអ្នកនោះទ្រាំនឿយហត់ជាជាង ទាំងធ្វើការល្អដោយដៃខ្លួនវិញ ដើម្បីឲ្យមានអ្វីនឹងចែកដល់អ្នកណាដែលត្រូវការផង» (ខ.២៨)។ ជីវិតថ្មីរបស់យើងក្នុងព្រះគ្រីស្ទ អនុញ្ញាតឲ្យយើងរស់នៅក្នុងជីវិតដែលស័ក្តិសមនឹងការត្រាស់ហៅរបស់ព្រះអង្គ ដោយចុះចូល ហើយដើរតាមផ្លូវរបស់ព្រះអង្គសង្គ្រោះនៃយើង។—Patricia Raybon

តើការប្រដាប់ខ្លួន ដោយមនុស្សថ្មី មានន័យដូចម្តេចខ្លះ? តើអ្នកអាចដើរតាមផ្លូវរបស់ព្រះអង្គសង្គ្រោះដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំមានការផ្លាស់ប្រែ នៅថ្ងៃនេះ ខណៈពេលដែលទូលបង្គំចុះចូល ដើម្បីឲ្យទូលបង្គំមានលក្ខណៈដូចព្រះអង្គ។

Daily Manna 2026_Content Enhance.indd 102 17/11/25 1:45 in the afternoon

ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច (ទំនុកតម្កើង ១០៧:១)។

រឿង៥យ៉ាងដែលអ្នកចង់អរព្រះគុណព្រះ

យោងតាមការស្រាវជ្រាវមួយបានឲ្យដឹងថា មនុស្សដែលមានការដឹងគុណអស់ពីចិត្តចំពោះព្រះសម្រាប់ការអ្វីដែលពួកគេមាន បានរៀបរាប់ថា ពួកគេគេងលក់ស្រួលជាង មានរាគសញ្ញានៃជំងឺតិចជាង និងមានសុភមង្គលច្រើនជាងអ្នកដែលមិនដឹងគុណ។ ទាំងនេះជាអត្ថប្រយោជន៍ដែលគួរឲ្យស្ងប់ស្ងែងណាស់។ អ្នកជំនាញខាងចិត្តសាស្ត្រក៏បានលើកទឹកចិត្ត ឲ្យយើង មាន «សៀវភៅកត់ត្រាអំពីការដឹងគុណ» ដើម្បីជួយឲ្យសុខុមាលភាពយើងកាន់តែប្រសើរឡើង ដោយកត់ត្រាអំពីរឿងប្រាំយ៉ាង ដែលយើងចង់អរព្រះគុណព្រះសម្រាប់សប្តាហ៍នីមួយៗ។

ព្រះគម្ពីរបានបង្រៀនយើងឲ្យមានទម្លាប់អរព្រះគុណព្រះ តាំងពីយូរមកហើយ។ ពោលគឺបានបង្រៀនយើងឲ្យអរព្រះគុណព្រះអង្គ សម្រាប់រឿងជាច្រើន រាប់ចាប់តាំងពីអាហារ និងទំនាក់ទំនងប្តីប្រពន្ធ (១ធីម៉ូថេ ៤:៣-៥) រហូតដល់សម្រស់នៃរបស់សព្វសារពើដែលព្រះអង្គបានបង្កើត (ទំនុកតម្កើង ១០៤) ហើយបានបង្រៀនយើង ឲ្យចាត់ទុកអ្វីដែលព្រះអង្គបានប្រទាន ជាអំណោយ ហើយអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានទាំងនោះ។ បទគម្ពីរទំនុកតម្កើងជំពូក១០៧ បានកត់ទុកនូវរឿងប្រាំយ៉ាង ដែលជនជាតិអ៊ីស្រាអែលអាចអរព្រះគុណព្រះ ដែលមានដូចជា ការរំដោះពួកគេចេញពីវាលរហោស្ថាន (ខ.៤-៩) ការរំដោះពួកគេឲ្យមានសេរីភាព (ខ.១០-១៦) ការប្រោសពួកគេឲ្យជាពីជម្ងឺ (ខ.៣៣-៤២)។ បទគម្ពីរទំនុកតម្កើងជំពូក១៣៦ បានប្រាប់យើងម្តងហើយម្តងទៀតថា «ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា» ដោយសារសេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេររបស់ព្រះអង្គ។

តើអ្នកមានសៀវភៅសម្រាប់កត់ត្រាអំពីអ្វីដែលអ្នកចង់អរព្រះគុណព្រះអង្គទេ? សូមសរសេរអំពីរឿង៥យ៉ាងដែលអ្នកចង់អរព្រះគុណព្រះអង្គ នៅពេលឥឡូវនេះ? អ្នកអាចអរព្រះគុណព្រះអង្គ សម្រាប់អាហារដែលអ្នកបានបរិភោគ ទំនាក់ទំនងប្តីប្រពន្ធដែលអ្នកមាន ឬសម្រាប់ការដែលជួយសង្គ្រោះអ្នក រហូតមកដល់ពេលសព្វថ្ងៃ។ ចូរអរព្រះគុណព្រះអង្គ សម្រាប់សត្វចាប ដែលកំពុងច្រៀងយ៉ាងពីរោះនៅខាងក្រៅ ក្លិនឈ្ងុយឈ្ងប់ពីផ្ទះបាយ កៅអីដ៏មានផាសុខភាព និងសម្លេងរបស់មនុស្សជាទីស្រឡាញ់។ ទាំងអស់នេះសុទ្ធតែជាអំណោយ និងសញ្ញានៃសេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេររបស់ព្រះ។—Sheridan Voysey

ហេតុអ្វីអ្នកគិតថា ព្រះគម្ពីរបានបង្រៀនយើងជាញឹកញាប់ឲ្យអរព្រះគុណព្រះអង្គ? តើរឿង៥យ៉ាង ដែលអ្នកចង់អរព្រះគុណព្រះ នៅថ្ងៃនេះមានអ្វីខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការល្អនីមួយៗ ដែលព្រះអង្គបាននាំចូលជីវិតទូលបង្គំ។ ហើយដែលសំខាន់បំផុតនោះ គឺទូលបង្គំ សូមអរព្រះគុណព្រះអង្គ ដែលបានលះបង់ព្រះជន្មដើម្បីសង្គ្រោះទូលបង្គំឲ្យរួចពីបាប។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១សាំយ៊ូអែល ៧-៩ និងលូកា ៩:១៨-៣៦

គ្រាដែលមនុស្សសុចរិតមានសេចក្តីសុខស្រួល នោះទីក្រុងក៏រីករាយសាទរ (សុភាសិត ១១:១០)។

នាំមកនូវក្តីអំណរដល់ទីក្រុង

កាលប្រទេសបារាំង និងប្រទេសអាហ្សង់ទីនជួបគ្នាក្នុងវគ្គផ្តាច់ព្រ័ត្រនៃការប្រកួតកីឡាបាល់ទាត់ពានរង្វាន់ពិភពលោកឆ្នាំ២០២២ ទស្សនិកជនបានតាមដានទស្សនាការប្រកួតដែលគួរឲ្យភ្ញាក់ផ្អើល បានជាមនុស្សជាច្រើនបានហៅការប្រកួតនេះថា «ការប្រកួតបាល់ទាត់ពានរង្វាន់ពិភពលោកដែលអស្ចារ្យបំផុតក្នុងប្រវត្តិសាស្ត្រ»។ នៅពេលដែលវិនាទីចុងក្រោយបានចូលមកដល់ ក្រុមទាំងពីរទទួលបានពិន្ទុស្មើគ្នា ៣ទល់នឹង៣ ហើយក៏បានប្រកួតប៉េណាំងទី។ បន្ទាប់ពីក្រុមកីឡាការប្រទេសអាហ្សង់ទីនទទួលបានជោគជ័យក្នុងការប្រកួត ប្រជាជនអាហ្សង់ទីនទូទាំងប្រទេសក៏បានធ្វើការអបអរសាទរ។ ប្រជាជនអាហ្សង់ទីនជាង១លាននាក់ បានមកជុំគ្នាយ៉ាងកកកុញក្នុងតំបន់ប្រជុំជននៃទីក្រុងបូនុស អៃរេស។ ខ្សែវីដេអូដែលគេថតដោយប្រើឧបករណ៍ដ្រូនត្រូវបានគេចែកចាយបន្តពេញបណ្តាញសង្គម ដោយបង្ហាញទិដ្ឋភាពដ៏អ៊ូអរ និងរីករាយនេះ។ អ្នកយកព័ត៌មានទូរទស្សន៍BBC ម្នាក់បានពិពណ៌នាថា ទីក្រុងនោះមានភាពរញ្ជួយញាប់ញ័រ ដោយសារ «បន្ទុះនៃក្តីអំណរ»។

ជានិច្ចជាកាល ក្តីអំណរគឺជាអំណោយដ៏អស្ចារ្យ។ ទោះជាយ៉ាងណាក៏ដោយ បទគម្ពីរសុភាសិតបានពិពណ៌នាថា ទីក្រុង និងប្រជាជននៅទីក្រុងមួយ អាចពិសោធន៍នឹងក្តីអំណរ ដែលមានភាពជ្រាលជ្រៅជាង និងមានរយៈពេលយូរជាងការអបអរជ័យជម្នះនៃការប្រកួតបាល់ទាត់នោះទៅទៀត។ គឺដូចដែលបទគម្ពីរសុភាសិតបានចែងថា «គ្រាដែលមនុស្សសុចរិតមានសេចក្តីសុខស្រួល នោះទីក្រុងក៏រីករាយសាទរ» (១១:១០)។ នៅពេលណាមនុស្សដែលពិតជារស់នៅ តាមការរៀបចំរបស់ព្រះសម្រាប់មនុស្សជាតិ ចាប់ផ្តើមមានឥទ្ធិពលល្អមកលើសហគមន៍របស់គាត់ ក្តីអំណរក៏បានចាប់ផ្តើមកើតមាន ព្រោះការនេះមានន័យថា សេចក្តីយុត្តិធម៌របស់ព្រះកំពុងតែចាក់ឫសក្នុងសង្គមរបស់ពួកគេ។ ភាពលោភលន់បានថយចុះ។ អ្នកក្រកកើយញ៉ែជំនួយ។ អ្នកដែលគេកៀបសង្កត់ទទួលបានការការពារ។ ពេលណាការរស់នៅ តាមផ្លូវដ៏ត្រឹមត្រូវរបស់ព្រះមានភាពរីកចម្រើន ក្តីអំណរ និងព្រះពរក៏បានកើតមានក្នុងទីក្រុងនោះផងដែរ (ខ.១១)។

បើយើងពិតជារស់នៅតាមផ្លូវរបស់ព្រះ នោះយើងនឹងនាំមកនូវក្តីអំណរដល់សហគមន៍របស់យើង។ របៀបដែលយើងរស់នៅតាមផ្លូវព្រះអង្គ នឹងជួយឲ្យសហគមន៍យើងមានភាពល្អប្រសើរឡើង និងកាន់តែមានភាពពេញលេញ។ ព្រះអម្ចាស់កំពុងត្រាស់ហៅយើង ឲ្យមានចំណែកជាមួយព្រះអង្គ ក្នុងការប្រោសលោកីយ៍ឲ្យជា។ ព្រះអង្គបានអញ្ជើញយើងឲ្យនាំមកនូវក្តីអំណរដល់ទីក្រុងរបស់យើង។—Winn Collier

តើទីក្រុងអ្នកត្រូវការក្តីអំណរ ត្រង់ផ្នែកណាខ្លះ? តើអ្នកអាចនាំមកនូវក្តីអំណររបស់ព្រះអម្ចាស់នៅទីនោះដោយរបៀបណា?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យចូលរួមជាមួយព្រះអង្គ ក្នុងការទាំក្តីអំណរដល់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 104 17/11/25 1:45 in the afternoon

យើងត្រូវដោះចោលអស់ទាំងការរបស់សេចក្តីងងឹតចេញ ហើយពាក់គ្រឿងសឹករបស់ពន្លឺវិញ (រ៉ូម ១៣:១២)។

ប្រដាប់ខ្លួន ដោយព្រះអម្ចាស់យេស៊ូវ

មានពេលមួយ ខ្ញុំមានចិត្តរំភើបរីករាយណាស់ ដែលបានពាក់វ៉ែនតាថ្មីជាលើកដំបូង ប៉ុន្តែពីរបីម៉ោងក្រោយមក ខ្ញុំចង់បោះវាចោល។ ភ្នែកខ្ញុំឈឺ ហើយក្បាលខ្ញុំក៏ឈឺ ដោយសារភ្នែកខ្ញុំត្រូវសម្របនឹងលេខវ៉ែនតាថ្មី។ ស្លឹកត្រចៀកខ្ញុំក៏ឈឺទៀត ដោយសារដងវ៉ែនតា ដែលខ្ញុំមិនធ្លាប់ប្រើ។ នៅថ្ងៃបន្ទាប់ ខ្ញុំមានការភ្ញាក់ផ្អើល នៅពេលដែលខ្ញុំនឹកចាំថា ខ្ញុំត្រូវតែពាក់វាទៀត។ ខ្ញុំត្រូវតែសម្រេចចិត្តប្រើវ៉ែនតានោះជាប្រចាំ ដើម្បីឲ្យរាងកាយខ្ញុំសម្របខ្លួននឹងវា។ ខ្ញុំបានចំណាយពេលជាច្រើនសប្តាហ៍ ប៉ុន្តែក្រោយមក ខ្ញុំស្ទើរតែភ្លេចថា ខ្លួនឯងកំពុងពាក់វ៉ែនតានោះ។

ការប្រើឧបករណ៍ថ្មី តម្រូវឲ្យយើងចំណាយពេលសម្របខ្លួនជាមួយវា ប៉ុន្តែមួយរយៈពេលក្រោយមក យើងក៏មានទម្លាប់ប្រើវា ហើយវាក៏កាន់តែសមនឹងយើង។ យើងថែមទាំងបានស្គាល់អ្វីដែលយើងមិនដែលបានស្គាល់កាលពីមុន។ ក្នុងបទគម្ពីររ៉ូមជំពូក១៣ សាវ័ក ប៉ុល បានបង្រៀនអ្នកជើរតាមព្រះយេស៊ូវឲ្យ «ពាក់គ្រឿងសឹកនៃពន្លឺ» (ខ.១២) ហើយអនុវត្តនូវការរស់នៅដ៏ត្រឹមត្រូវ។ ពួកគេបានជឿព្រះយេស៊ូវហើយ តែពួកគេហាក់ដូចជាធ្លាក់ចូលទៅក្នុង «ភាពងោកងុយ» ហើយមិនចង់មានការរីកចម្រើនខាងវិញ្ញាណបន្តែមទៀត ដូចនេះពួកគេចាំបាច់ត្រូវ «ភ្ញាក់ឡើង» ហើយចាត់វិធានការ ប្រព្រឹត្តឲ្យបានសមរម្យ ហើយលះចោលអំពើបាបគ្រប់យ៉ាង (ខ.១១-១២)។ សាវ័ក ប៉ុល បានលើកទឹកចិត្តពួកគេឲ្យប្រដាប់កាយដោយព្រះយេស៊ូវ ហើយផ្លាស់ប្រែឲ្យមានលក្ខណៈកាន់តែដូចព្រះអង្គក្នុងគំនិត និងការប្រព្រឹត្តរបស់ខ្លួន (ខ.១៤)។

នៅពេលដែលយើងទើបតែទទួលជឿព្រះយេស៊ូវ យើងមិនអាចរស់នៅដោយឆ្លុះបញ្ចាំងឲ្យគេឃើញផ្លូវរបស់ព្រះអង្គភ្លាមៗបានឡើយ គឺផ្លូវដែលមានសេចក្តីស្រឡាញ់ សុភាព សប្បុរស មានពេញដោយព្រះគុណ និងស្មោះត្រង់។ យើងត្រូវការពេលវេលាយូរអង្វែង ដើម្បីរៀនពាក់គ្រឿងសឹកនៃពន្លឺរៀងរាល់ថ្ងៃ ទោះយើងមិនចង់ពាក់ ដោយសារយើងមានអារម្មណ៍ថាពិបាកក៏ដោយ។ ទន្ទឹមនឹងនោះ ព្រះអង្គកំពុងតែកែប្រែយើងឲ្យកាន់តែល្អប្រសើរឡើង។—Karen Pimpo

តើការប្រដាប់កាយដោយព្រះយេស៊ូវ មានន័យដូចម្តេច ក្នុងពេលសព្វថ្ងៃ? តើការអនុវត្តន៍នូវការរស់នៅដែលមានលក្ខណៈកាន់តែដូចព្រះយេស៊ូវ អាចមានភាពងាយស្រួល នៅពេលក្រោយមកទៀត ដោយរបៀបណា?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានកែប្រែទូលបង្គំជារៀងរាល់ថ្ងៃ។

Daily Manna 2026_Content Enhance.indd 105 17/11/25 1:45 in the afternoon

អញនឹងតាំងឯងឡើង ទុកជាសេចក្ដីសញ្ញាដល់បណ្តាជន ហើយជាពន្លឺភ្លឺដល់អស់ទាំងសាសន៍ ដើម្បីនឹងធ្វើឲ្យភ្នែកមនុស្សខ្វាក់បានភ្លឺឡើង (អេសាយ ៤២:៦-៧)។

ភ្នែកមនុស្សខ្វាក់បានភ្លឺឡើង

អ្នកស្រី ចេនេវីវ (Genevieve) ត្រូវមានតួនាទីធ្វើជា «ភ្នែក» សម្រាប់កូនរបស់គាត់ទាំង៣នាក់ ដែលសុទ្ធតែមានជំងឺភ្នែកឡើងបាយពីកំណើត។ ពេលណាគាត់នាំពួកគេចូលភូមិរបស់គាត់ក្នុងសាធារណៈរដ្ឋបេនីន នៅភាគខាងលិចទ្វីបអាហ្វ្រិក គាត់តែងតែស្ពាយកូនតូចនៅលើខ្នងគាត់ ហើយកាន់ដៃកូនពីរនាក់ទៀតនៅសង្ខាង។ គាត់តែងតែមានការប្រុងប្រយ័ត្ន ដើម្បីកុំឲ្យមានគ្រោះថ្នាក់។ ក្នុងវប្បធម៌ដែលគេជឿថា ការពិការភ្នែកបានកើតឡើងពីអំពើមន្តអាគម អ្នកស្រី ចេនេវីវ មានការអស់សង្ឃឹម ហើយក៏បានស្រែកអង្វរព្រះ សូមព្រះអង្គជួយគ្រួសារគាត់។

ក្រោយមក មានបុរសម្នាក់ក្នុងភូមិរបស់គាត់បានប្រាប់គាត់អំពីនាវាមេត្តាករុណា ជាអង្គការគ្រីស្ទបរិស័ទដែលផ្តល់ឲ្យនូវការវះកាត់ដោយឥតគិតថ្លៃ តាមគំរូរបស់ព្រះយេស៊ូវក្នុងការនាំក្តីសង្ឃឹម និងការប្រោសឲ្យជាដល់អ្នកក្រ។ គាត់មិនដឹងថា ពួកគេអាចជួយគាត់បានឬអត់ទេ តែគាត់បានទៅរកពួកគេ។ នៅពេលដែលក្មេងៗក្រោកឡើង បន្ទាប់ពីការវះកាត់រួច ពួកគេអាចមើលឃើញឡើងវិញ!

រឿងរបស់ព្រះច្រើនតែនិយាយអំពីមនុស្ស ដែលស្ថិតនៅក្នុងភាពងងឹត ហើយព្រះអង្គប្រទានពន្លឺដល់ពួកគេ។ ហោរាអេសាយ បានប្រកាសថា ព្រះអម្ចាស់នឹងធ្វើជា «ពន្លឺសម្រាប់សាសន៍ដទៃ» (អេសាយ ៤២:៦)។ ព្រះអង្គ «ធ្វើឲ្យភ្នែកមនុស្សខ្វាក់បានភ្លឺឡើង» (ខ.៧) ដោយបានប្រទានការមើលឃើញខាងសាច់ឈាម តែក៏បានប្រទានការមើលឃើញខាងវិញ្ញាណផងដែរ។ ហើយព្រះអង្គសន្យាថានឹង «ដឹកដៃ» រាស្ត្ររបស់ព្រះអង្គ (ខ.៦)។ ព្រះអង្គប្រោសមនុស្សខ្វាក់ឲ្យមើលឃើញ ហើយប្រទានពន្លឺដល់អ្នកដែលកំពុងរស់នៅក្នុងភាពងងឹត។

បើអ្នកមានអារម្មណ៍ថា ភាពងងឹតបានគ្របដណ្តប់ជីវិតអ្នក ចូរតោងឲ្យជាប់សេចក្តីសង្ឃឹម ខណៈពេលដែលអ្នកឱបក្រសោបព្រះបន្ទូលសន្យានៃព្រះវរបិតានៃសេចក្តីស្រឡាញ់ និងទូលសូមព្រះអង្គប្រទានពន្លឺដល់ជីវិតអ្នក។—Amy Boucher Pye

តើព្រះអម្ចាស់បានបើកភ្នែកអ្នកខាងសាច់ឈាម ឬខាងវិញ្ញាណដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ព្រះអង្គមិនសព្វព្រះទ័យឲ្យនរណាម្នាក់រស់នៅក្នុងភាពងងឹតទេ។ សូមព្រះអង្គបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គដល់អ្នកដែលខ្វាក់ភ្នែកខាងវិញ្ញាណ ដើម្បីឲ្យពួកគេអាចមើលឃើញ។

Daily Manna 2026_Content Enhance.indd 106 17/11/25 1:45 in the afternoon

ឯច្រកភ្នំទាំងប៉ុន្មាន នោះក៏មានស្រូវដាសពាសពេញទីទាំងនោះបន្លឺឡើង ដោយអំណរ ហើយក៏ច្រៀងផង (ទំនុកតម្កើង ៦៥:១៣)។

អស់ទាំងទួលព័ទ្ធដោយសេចក្តីអំណរ

ខ្ញុំបាននិយាយកំប្លែងជាញឹកញាប់ជាមួយម្តាយក្មេកខ្ញុំ អំពីសមត្ថភាពរបស់គាត់ ក្នុងការជជែកជាមួយសត្វឆ្កែរបស់គាត់។ គាត់ឆ្លើយតបចំពោះសម្លេងព្រូសរបស់ពួកវា ដោយការយល់ចិត្ត ដោយសេចក្តីស្រឡាញ់។ គាត់ និងម្ចាស់ឆ្កែផ្សេងទៀត ក៏ប្រហែលជារៀនស្តាប់សម្លេងសើចរបស់សត្វឆ្កែរបស់ខ្លួនផងដែរ។ អ្នកវិទ្យាសាស្ត្របានរកឃើញថា សត្វជាច្រើន រួមមានសត្វឆ្កែ សត្វគោ សត្វកញ្ជ្រោង សត្វឆ្មាទឹក និងសេក សុទ្ធតែមានសំណើចដែរ ជា «សញ្ញានៃភាពរីករាយ ដែលបង្ហាញចេញជាសម្លេង»។ ការស្គាល់សម្លេងទាំងអស់នេះច្បាស់ ជួយឲ្យគេអាចញែកឲ្យដាច់រវាងអាកប្បកិរិយារីករាយ និងអាកប្បកិរិយាកំហឹងរបស់សត្វ ដែលមនុស្សអាចមានការយល់ច្រឡំ។

ការដែលសត្វបង្ហាញចេញនូវសំណើច និងភាពសប្បាយរីករាយ បានផ្តល់ឲ្យយើងនូវការបើកបង្ហាញដ៏រីករាយអំពីការដែលស្តាប់ព្រះហស្តដទៃទៀតអាចសរសើរតម្កើងព្រះ តាមរបៀបផ្សេងៗរៀងខ្លួន។ ខណៈពេលដែលស្តេចដាវីឌក្រឡេកមើលជុំវិញខ្លួនទ្រង់ ទ្រង់សង្កេតឃើញថា «អស់ទាំងទួលក៏ព័ទ្ធដោយសេចក្តីអំណរដែរ» ហើយច្រកភ្នំទាំងប៉ុន្មាន នោះក៏មានស្រូវដាសពាសពេញទីទាំងនោះ «បន្លឺឡើង ដោយអំណរ ហើយក៏ច្រៀងផង» (ទំនុកតម្កើង ៦៥:១២-១៣)។ ស្តេច ដាវីឌ បានទទួលស្គាល់ថា ព្រះទ្រង់យកព្រះទ័យទុកដាក់ចំពោះទឹកដី និងធ្វើឲ្យចម្រើនឡើង ដោយប្រទានសម្រស់ និងអាហារ។

ទោះអ្វីៗនៅជុំវិញខ្លួនយើងហាក់ដូចជាមិន «ច្រៀង» ដូចមនុស្សក៏ដោយ ក៏ពួកវាបានធ្វើបន្ទាល់ ចំពោះព្រះរាជកិច្ចដ៏សកម្មរបស់ព្រះអម្ចាស់ក្នុងការបង្កើតពួកវាមក ហើយអញ្ជើញយើងឲ្យលើកសម្លេងឡើង ថ្វាយការសរសើរដល់ព្រះអង្គ។ ក្នុងនាមយើងជាផ្នែកមួយនៃផែនដី ចូរយើងបានពេញដោយ «ភាពស្ងប់ស្ងែងចំពោះភាពអស្ចារ្យរបស់ព្រះអង្គ» ហើយឆ្លើយតបចំពោះព្រះអង្គ ដោយ «បទចម្រៀងនៃក្តីអំណរ» (ខ.៨)។ យើងអាចទុកចិត្តថា ព្រះអង្គនឹងស្តាប់ឮ ហើយយល់។—Kirsten Holmberg

តើអ្វីៗនៅជុំវិញខ្លួនយើង បានលើកទឹកចិត្តយើងឲ្យសរសើរតម្កើងព្រះដូចម្តេចខ្លះ? តើអ្នកបានឃើញស្នាព្រះហស្តព្រះអង្គ សរសើរតម្កើងព្រះអង្គនៅកន្លែងណាទៀត?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានបន្តព្រះរាជកិច្ចរបស់ព្រះអង្គក្នុងស្នាព្រះហស្តព្រះអង្គ។

Daily Manna 2026_Content Enhance.indd 107 17/11/25 1:45 in the afternoon

ព្រះអម្ចាស់ទ្រង់ឈរជិតគាត់មានព្រះបន្ទូលថា «ចូរសង្ឃឹមឡើង ប៉ុលអើយ ដ្បិតអ្នកត្រូវធ្វើបន្ទាល់នៅក្រុងរ៉ូមដូចជាបានធ្វើបន្ទាល់សព្វគ្រប់ពីខ្ញុំនៅក្រុងយេរូសាឡិមដែរ» (កិច្ចការ ២៣:១១)។

ព្រះអង្គជាភ្នាក់ងារនៃសន្តិភាព

ណូរ៉ា (Nora) បានទៅចូលរួមបាតុកម្មអហិង្សា ព្រោះគាត់មានអារម្មណ៍ឈឺចាប់យ៉ាងខ្លាំង ចំពោះបញ្ហាអយុត្តិធម៌ក្នុងសង្គម។ បាតុកម្មក៏បានប្រព្រឹត្តទៅយ៉ាងស្ងាត់ស្ងៀមតាមការគ្រោងទុក។ បាតុករបានដើរជង្ហែនៅក្នុងភាពស្ងាត់ស្ងៀមដ៏មានអំណាច កាត់តាមតំបន់ប្រជុំជនក្នុងទីក្រុង។ បន្ទាប់មក ស្រាប់តែមានឡានក្រុងពីរគ្រឿងដឹកពួកញុះញង់ពីតំបន់ខាងក្រៅទីក្រុង មកដល់កន្លែងបាតុកម្មអហិង្សា។ មិនយូរប៉ុន្មាន កុប្បកម្មក៏បានផ្ទុះឡើង ដោយភាពវឹកវរ និងអំពើហិង្សា។ ណូរ៉ា ក៏បានចាកចេញពីបាតុកម្មនោះ ដោយការបាក់ទឹកចិត្តយ៉ាងខ្លាំង។ បំណងល្អរបស់បាតុករទាំងនោះហាក់ដូចជាគ្មានផលផ្លែទាល់តែសោះ។

កាលសាវ័ក ប៉ុល ទៅព្រះវិហារនៅទីក្រុងយេរូសាឡិម ពួកអ្នកទាស់ប្រឆាំងគាត់ក៏បានឃើញគាត់នៅទីនោះ។ ពួកគេគឺជាសាសន៍យូដា មកពី «ស្រុកអាស៊ី» (កិច្ចការ ២១:២៧) ហើយបានចាត់ទុកព្រះយេស៊ូវ ជាការគំរាមកំហែងមកលើ ជីវិតរបស់ពួកគេ។ ពួកគេក៏បានស្រែកចេញនូវពាក្យកុហក និងពាក្យចចាមអារ៉ាមអំពីសាវ័ក ប៉ុល ហើយភ្លាមៗនោះ ពួកគេក៏បានញុះញង់ឲ្យមានភាពវឹកវរ (ខ.២៨-២៩)។ ហ្វូងមនុស្សក៏បានអូសសាវ័ក ប៉ុល ចេញពីព្រះវិហារ ហើយវាយដំគាត់។ ពួកទាហានរត់មករកហ្វូងមនុស្ស។

នៅពេលសាវ័ក ប៉ុល ត្រូវពួកទាហានរ៉ូមុាំងចាប់ខ្លួន គាត់ក៏បានសុំការអនុញ្ញាតពីមេទ័ពធំ ឲ្យគាត់និយាយទៅកាន់ហ្វូងមនុស្ស (ខ.៣៧-៣៨)។ នៅពេលដែលគាត់បានទទួលការអនុញ្ញាត គាត់ក៏បាននិយាយទៅកាន់ហ្វូងមនុស្សជាភាសារបស់ពួកគេ ធ្វើឲ្យពួកគេមានការភ្ញាក់ផ្អើល ហើយយកចិត្តទុកដាក់ចំពោះការចែកចាយរបស់គាត់ (ខ.៤០)។ គាត់ក៏បានកែប្រែកុប្បកម្ម ឲ្យក្លាយជាឱកាសចែកចាយទីបន្ទាល់នៃសេចក្តីសង្គ្រោះដែលគាត់បានទទួល (២២:២-២១)។

អ្នកខ្លះចូលចិត្តប្រើអំពើហិង្សា និងការបែកបាក់។ ចូរកុំអស់សង្ឃឹមឡើយ។ ពួកគេមិនអាចឈ្នះបានទេ។ ព្រះទ្រង់កំពុងស្វែងរកអ្នកជឿដែលមានចិត្តក្លាហាន ដើម្បីចែកចាយអំពីពន្លឺ និងសន្តិភាពរបស់ព្រះអង្គ ដល់លោកីយ៍ដែលកំពុងអស់សង្ឃឹម។ ចូរយើងប្រើស្ថានភាពដែលមានវិបត្តិនោះ ជាឱកាស ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គដល់នរណាម្នាក់។—Tim Gustafson

តើអ្នកបានជួបរឿងវិបត្តិ ដែលអ្នកមិនអាចយល់នៅពេលណា? តើអ្នកគិតថា ព្រះវិញ្ញាណបរិសុទ្ធអាចប្រទានប្រាជ្ញា សម្រាប់ធ្វើអ្វីម្យ៉ាង ក្នុងពេលនោះយ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា ចិត្តរបស់ទូលបង្គំមានការឈឺចាប់ ដោយសារលោកិយដែលប្រេះបែក។ សូមព្រះអង្គជួយទូលបង្គំឲ្យដឹងថា ព្រះវត្តមាននៃព្រះវិញ្ញាណព្រះអង្គ មានព្រះចេស្តាជាង់ការវាយប្រហារណាមួយរបស់លោកីយ៍ មកលើទូលបង្គំ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ១សាំយ៊ូអែល ១៩-២១ និងលូកា ១១:២៩-៥៤

ឯផែនដីបានខូច ហើយនៅទទេ មានសុទ្ធតែងងឹតនៅគ្របលើជំរៅទឹក ហើយព្រះវិញ្ញាណនៃព្រះក៏រេរានៅពីលើទឹក (លោកុប្បត្តិ ១:២)។

ព្រះនៃសណ្តាប់ធ្នាប់

លោក សេត (Seth) បានចម្រើនវ័យធំឡើង ក្នុងគ្រួសារដែលមានពេញដោយភាពប្រេះបែក និងភាពវឹកវរ ដូចនេះជីវិតគាត់មានពេញដោយភាពរញ៉េរញ៉ៃ។ ម្តាយរបស់គាត់បានទទួលរងអំពើហិង្សាពីឪពុក គាត់ជាប្រចាំរហូតដល់ពេលដែលឪពុកគាត់បានបញ្ចប់ជីវិតខ្លួនឯង។ មានពេលមួយ លោក សេតចង់បញ្ចប់ជីវិតខ្លួនឯង។ គាត់បានប្រមូលថ្នាំទាំងអស់នៅក្នុងទូដាក់ថ្នាំក្នុងផ្ទះគាត់ ប៉ុន្តែគាត់ស្រាប់តែនឹកគិតថា តើខ្ញុំនឹងទៅទីណា បន្ទាប់ពីខ្ញុំស្លាប់ទៅ? ដោយសារព្រះគុណព្រះ លោក សេត មិនបានស្លាប់នៅថ្ងៃនោះទេ។ ហើយក្រោយមក បន្ទាប់ពីគាត់បានរៀនព្រះគម្ពីរជាមួយមិត្តភក្តិម្នាក់ គាត់ក៏បានទទួលជឿព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ។ ការមើលឃើញសម្រស់ និងសណ្តាប់ធ្នាប់នៅក្នុងស្នាព្រះហស្តរបស់ព្រះ បានបណ្តាលចិត្តគាត់ឲ្យចូលទៅរកព្រះអង្គ។ គាត់និយាយថា «ខ្ញុំមើលឃើញអ្វីៗមានសម្រស់ស្រស់ស្អាតណាស់។ មាននរណាម្នាក់បានបង្កើតពួកវាមក»។

ក្នុងបទគម្ពីរលោកុប្បត្តិជំពូក១ យើងឃើញថា ព្រះទ្រង់ពិតជាបានបង្កើតរបស់សព្វសារពើ។ ហើយទោះ «ផែនដីបានខូច» (ខ.២) ព្រះអង្គបានធ្វើឲ្យភាពគ្មានសណ្តាប់ធ្នាប់ក្លាយជាមានសណ្តាប់ធ្នាប់។ ព្រះអង្គបានញែកពន្លឺ ចេញពីភាពងងឹត (ខ.៤) ដាក់ឲ្យមានដីដុះឡើងនៅចន្លោះទឹកសមុទ្រ (ខ.១០) ហើយព្រះអង្គបង្កើតរុក្ខជាតិ និងសត្វ តាមប្រភេទរបស់ពួកវា (ខ.១១-១២, ២១, ២៤-២៥)។ ព្រះដែលបានបង្កើតផ្ទៃមេឃ និងផែនដី ហើយដាក់អ្វីៗទាំងអស់ ក្នុងកន្លែងរបស់វា (អេសាយ ៤៥:១៨) ហើយបន្តនាំមកនូវសន្តិភាព និងសណ្តាប់ធ្នាប់ដល់ជីវិត ដែលចុះចូលនឹងព្រះគ្រីស្ទ។

ជីវិតមនុស្សអាចមានភាពវឹកវរ និងបញ្ហាប្រឈមៗ ចូរសរសើរតម្កើងព្រះអង្គថា ព្រះអង្គ «មិនមែនជាព្រះនៃសេចក្តីវឹកវរទេ គឺទ្រង់ជាព្រះនៃសេចក្តីសុខសាន្តវិញ ដូចក្នុងអស់ទាំងពួកជំនុំរបស់ពួកបរិសុទ្ធដែរ» (១កូរិនថូស ១៤:៣៣)។ ចូរយើងស្រែករកព្រះអង្គនៅថ្ងៃនេះ ហើយសូមព្រះអង្គជួយយើងរកឃើញភាពស្រស់ស្អាត និងសណ្តាប់ធ្នាប់ដែលមានតែព្រះអង្គអាចប្រទានឲ្យបាន។—Tom Felten

តើមានភាពវឹកវរអ្វីដែលអ្នកកំពុងជួបប្រទះក្នុងជីវិតអ្នក? តើព្រះទ្រង់អាចជួយអ្នកនាំមកនូវសណ្តាប់ធ្នាប់ និងសន្តិភាពក្នុងជីវិតអ្នកដូចម្តេចខ្លះ?

ឱព្រះអាទិករ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការប្រទានសន្តិភាព និងសណ្តាប់ធ្នាប់ក្នុងជីវិតទូលបង្គំ។ ក្នុងព្រះអង្គ អ្វីៗដែលប្រេះបែកប្រែក្លាយជាមានភាពស្រស់ស្អាត។

ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង (ម៉ាថាយ ៦:៣៣)។

ព្រះអង្គជ្រាបអំពីតម្រូវការរបស់យើង

មានពេលមួយលោក លែនដូ (Lando) ជាអ្នកបើកឡានហ្ស៊ីបនី ក្នុងទីក្រុងម៉ានីល ប្រទេសភីលីពីន បានទៅអង្គុយញ៉ាំកាហ្វេនៅតាមស្តង់លក់កាហ្វេតាមចិញ្ចើមថ្នល់។ អ្នកដំណើរតាមផ្លូវសាធារណៈចាប់ផ្តើមមានឡើងវិញ បន្ទាប់ពីការបិទខ្ទប់ក្នុងសម័យកូវីដបានបញ្ចប់។ ហើយគាត់គិតឃើញថា ព្រឹត្តិការណ៍នៃការប្រកួតកីឡានៅថ្ងៃនេះ គឺមានន័យថា គាត់មានអ្នកដំណើរច្រើនជាងធម្មតា។ គាត់ថា គាត់នឹងរកបានប្រាក់ចំណូលដែលគាត់បានបាត់ក្នុងពេលកន្លងមក ហើយអាចឈប់ព្រួយបារម្ភបានហើយ។

ពេលគាត់ហៀបនឹងបើកឡានចេញទៅ គាត់ក៏បានប្រទះឃើញលោក រុននី (Ronnie) នៅលើបង់ក្បែរនោះ។ អ្នកបោសថ្នល់រូបនោះ ហាក់ដូចជាកំពុងមានបញ្ហាអ្វីមួយ ដែលត្រូវការនិយាយប្រាប់គេ។ ប៉ុន្តែ លោក លែនដូ គិតថា វិនាទីនីមួយៗសុទ្ធតែមានតម្លៃចំពោះមុខរបររបស់គាត់។ បើគាត់បានដឹកអ្នកដំណើរកាន់តែច្រើន នោះគាត់មានប្រាក់ចំណូលកាន់តែច្រើន។ គាត់គិតថា គាត់មិនអាចឈប់ទេ។ ប៉ុន្តែ គាត់មានអារម្មណ៍ថា ព្រះអម្ចាស់សព្វព្រះទ័យឲ្យគាត់ចូលទៅរកលោក រុននី ដូចនេះគាត់ក៏បានទៅមើលលោក រុននី។

ព្រះយេស៊ូវជ្រាបថា ការឈប់ព្រួយបារម្ភមិនមែនជាការងាយទេ (ម៉ាថាយ ៦:២៥-២៧) ដូចនេះ ព្រះអង្គបានធានាយើងថា ព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌បានជ្រាបច្បាស់ថា យើងត្រូវការអ្វី (ខ.៣២)។ ព្រះអង្គបានរំឭកយើងថា យើងមិនត្រូវមានការថប់បារម្ភទេ តែត្រូវទុកចិត្តព្រះអង្គ ហើយប្តេជ្ញាចិត្តធ្វើអ្វីដែលព្រះអង្គសព្វព្រះទ័យឲ្យយើងធ្វើ (ខ.៣១-៣៣)។ ពេលណាយើងឱបក្រសោប ហើយស្តាប់បង្គាប់តាមបំណងព្រះទ័យព្រះអង្គ យើងអាចមានទំនុកចិត្តថា ព្រះវរបិតានៃយើង ដែលឲ្យ «តិណជាតិដុះនៅវាលក្នុងថ្ងៃនេះ ហើយថ្ងៃស្អែកត្រូវគេដុតនៅជើងក្រាន» ព្រះអង្គនឹងបំពេញតម្រូវការយើង តាមបំណងព្រះទ័យព្រះអង្គ ដូចដែលព្រះអង្គផ្គត់ផ្គង់ដល់ស្នាព្រះហស្តទាំងអស់ (ខ.៣០)។

ដោយសារការសន្ទនារបស់លោក លែនដូ ជាមួយលោក រុននី ជាអ្នកបោសថ្នល់ ទីបំផុតលោក រុននី ក៏បានអធិស្ឋានទទួលជឿព្រះគ្រីស្ទនៅថ្ងៃនោះ។ លោក លែនដូ បានចែកចាយថា «នៅថ្ងៃនោះ ព្រះអង្គនៅតែប្រទានពរគាត់ ឲ្យមានអ្នកដំណើរគ្រប់គ្រាន់។ ព្រះអង្គបានរំឭកខ្ញុំថា ព្រះអង្គយកព្រះទ័យទុកដាក់ចំពោះតម្រូវការខ្ញុំ ហើយខ្ញុំគ្រាន់តែស្តាប់បង្គាប់តាមព្រះអង្គប៉ុណ្ណោះ»។—Karen Huang

តើមានការថប់បារម្ភអ្វីខ្លះ ដែលបានធ្វើជាបន្ទុកធ្ងន់នៅលើចិត្តអ្នក? តើអ្នកអាចថ្វាយការព្រួយបារម្ភរបស់អ្នកដល់ព្រះអង្គដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំមិនចាំបាច់ត្រូវព្រួយបារម្ភឡើយ ព្រោះព្រះអង្គបានសន្យាថា នឹងថែរក្សា ហើយផ្គត់ផ្គង់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១សាំយ៊ូអែល ២៥-២៦ និងលូកា ១២:៣២-៥៩

បើខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា នោះខ្ញុំនឹងត្រឡប់មកវិញ នឹងទទួលអ្នករាល់គ្នាទៅឯខ្ញុំ ប្រយោជន៍ឲ្យអ្នករាល់គ្នាបាននៅកន្លែងដែលខ្ញុំនៅនោះដែរ (យ៉ូហាន ១៤:៣)។

បាននៅផ្ទះជាមួយព្រះយេស៊ូវ

មានពេលមួយដ្លរ៉ូធី (Dorothy) បានគោះកែងស្បែកជើងពណ៌ក្រហមដូចត្បូងទទឹម ហើយនិយាយថា «គ្មានកន្លែងណាល្អជាងផ្ទះទេ»។ ក្នុងខ្សែភាពយន្តរឿងអ្នកប្រាជ្ញនៃនគរអូហ្ស ស្បែកជើងនោះមានសមត្ថភាពពិសេស អាចដឹកជញ្ជូនដ្លរ៉ូធី និងតូតូ ពីនគរអូហ្ស ត្រឡប់មកផ្ទះរបស់ពួកគេក្នុងរដ្ឋនេសាស់វិញ។

គួរឲ្យស្តាយណាស់ ពួកគេមិនមានស្បែកជើងពណ៌ក្រហមសម្រាប់គ្រប់គ្នាទេ។ មនុស្សជាច្រើនក៏មានចិត្តចង់ទៅផ្ទះដូចដ្លរ៉ូធីផងដែរ តែការរកឃើញផ្ទះដ៏កក់ក្តៅ ជូនកាល មិនងាយស្រួលដូចការនិយាយទេ។

ការរស់នៅក្នុងពិភពលោក ដែលមនុស្សមានការផ្លាស់ប្តូរទីលំនៅញឹកញាប់ ដោយគ្មានភាពស្ថិតស្ថេរ អាចនាំឲ្យយើងមានអារម្មណ៍ថា ខ្វះភាពកក់ក្តៅ ដោយមិនដឹងថា យើងនឹងអាចរកបានកន្លែង ដែលយើងពិតជាមានអារម្មណ៍កក់ក្តៅឬអត់ទេ។ អារម្មណ៍ដូចនេះ ក៏អាចឆ្លុះបញ្ចាំងអំពីការពិតដែលស៊ីជម្រៅជាងនេះទៀត គឺដូចដែលលោក ស៊ីអេស លូអីស (C. S. Lewis) បានបកស្រាយថា «បើខ្ញុំពិនិត្យមើលក្នុងជម្រៅចិត្តខ្ញុំឃើញថា ខ្ញុំមានសេចក្តីប៉ងប្រាថ្នាមួយ ដែលគ្មានបទពិសោធន៍ណាមួយក្នុងលោកីយ៍នេះ អាចធ្វើឲ្យស្កប់ស្កល់បាន នោះមូលហេតុទំនងបំផុតដែលខ្ញុំមានបញ្ហានេះ គឺដោយសារព្រះទ្រង់បានបង្កើតខ្ញុំមក សម្រាប់ឲ្យរស់នៅក្នុងពិភពលោកមួយទៀត»។

នៅពេលយប់មុនពេលព្រះយេស៊ូវសុគតនៅលើឈើឆ្កាង ព្រះអង្គបានមានបន្ទូលធានាដល់មិត្តសំឡាញ់ទ្រង់អំពីផ្ទះនោះថា «នៅក្នុងដំណាក់នៃព្រះវរបិតាខ្ញុំ មានទីលំនៅជាច្រើន ពុំនោះ ខ្ញុំបានប្រាប់អ្នករាល់គ្នាហើយ ខ្ញុំទៅរៀបកន្លែងឲ្យអ្នករាល់គ្នា» (យ៉ូហាន ១៤:២)។ គឺផ្ទះដែលយើងនឹងទទួលបានការស្វាគមន៍ និងសេចក្តីស្រឡាញ់។

តែយើងក៏អាចមានអារម្មណ៍កក់ក្តៅដូចនេះក្នុងពេលបច្ចុប្បន្នផងដែរ។ យើងជាផ្នែកមួយនៃមហាគ្រួសាររបស់ព្រះ ដែលជាពួកជំនុំរបស់ព្រះអង្គ ជាសហគមន៍សម្រាប់ឲ្យយើងរស់នៅជាមួយបងប្អូនប្រុសស្រីក្នុងព្រះគ្រីស្ទ។ ទំរាំដល់ថ្ងៃដែលព្រះយេស៊ូវយកយើងទៅនៅផ្ទះ ដែលចិត្តរបស់យើងស្រេកឃ្លានចង់បាននោះ យើងអាចរស់នៅក្នុងពេលបច្ចុប្បន្ន ក្នុងសន្តិភាព និងក្តីអំណររបស់ព្រះអង្គ។ យើងតែងតែនៅជាប់ជាមួយព្រះអង្គ ដូចនៅក្នុងផ្ទះដ៏កក់ក្តៅជានិច្ច។—Bill Crowder

តើមានអ្វីធ្វើឲ្យអ្នកមានអារម្មណ៍ថា អ្នកនៅផ្ទះដ៏កក់ក្តៅ ហើយហេតុអ្វី? តើការដឹងថា ព្រះយេស៊ូវនឹងនាំអ្នកទៅនៅជាមួយព្រះអង្គជារៀងរហូតមានប្រយោជន៍យ៉ាងណាខ្លះដល់អ្នក ក្នុងការរស់នៅក្នុងលោកីយ៍នេះ?

ឱព្រះនៃសេចក្តីស្រឡាញ់ និងព្រះគុណ សូមព្រះអង្គជួយទូលបង្គំឲ្យទន្ទឹងរង់ចាំការរស់នៅ ក្នុងផ្ទះនៅស្ថានសួគ៌ជាមួយព្រះអង្គ ក្នុងព្រះវត្តមានព្រះអង្គជារៀងរហូត។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១សាំយ៉ូអែល ២៧-២៩ និងលូកា ១៣:១-២២

ខ្ញុំទូន្មានអ្នកពាល់គ្នាថា ចូរឲ្យអ្នកពាល់គ្នាដើរបែបគួរនឹងការងារ ដែលទ្រង់បានហៅមកធ្វើចុះ (អេភេសូរ ៤:១)។

ត្រៀមខ្លួនចេញទៅតាមការត្រាស់ហៅ

សៀវភៅមានចំណងជើងថា តួលេខដែលបានបម្រុងទុកបានពិពណ៌នាអំពីការត្រៀមខ្លួនរបស់លោក ចន គ្លែន (John Glenn) សម្រាប់ការហោះហើរចូលទៅក្នុងទីអវកាសនៅក្រៅភពផែនដី។ កុំព្យូទ័រក្នុងឆ្នាំ១៩៦២ នៅមានភាពក្មេងខ្ចី និងរញ៉េរញ៉ៃ ងាយនឹងធ្វើការគណនាខុស។ លោក គ្លែន មិនបានទុកចិត្តលើកុំព្យូទ័រទាំងនោះទេ ហើយមានការព្រួយបារម្ភ អំពីការគណនាសម្រាប់ការបាញ់បង្ហោះយានអវកាស។ តែគាត់ស្គាល់ស្ត្រីម្នាក់មានខួរក្បាលឆ្លាតវៃ ដែលកំពុងធ្វើការក្នុងបន្ទប់ខាងក្រោយ អាចធ្វើការគណនាបានយ៉ាងសុក្រឹត។ គាត់ទុកចិត្តនាង។ លោក គ្លែន ក៏បាននិយាយថា «បើនាងនិយាយថា ការគណនាសម្រាប់ការបាញ់បង្ហោះយាននោះមានភាពត្រឹមត្រូវ ខ្ញុំអាចត្រៀមខ្លួនជាស្រេចសម្រាប់ការធ្វើដំណើរទៅទីអវកាស»។

ស្ត្រីនោះមានឈ្មោះ ខាត់ធើរីន ចនសិន (Katherine Johnson) ជាគ្រូបង្រៀន និងជាស្ត្រីមានកូនបីនាក់។ នាងស្រឡាញ់ព្រះយេស៊ូវ ហើយបានធ្វើការបម្រើព្រះអង្គក្នុងពួកជំនុំរបស់នាង។ ព្រះទ្រង់បានប្រទានពរគាត់ ឲ្យមានគំនិតឆ្លាតគួរឲ្យកត់សម្គាល់។ អង្គការណាសា ក៏បានហៅគាត់ឲ្យចូលធ្វើការនៅចុងទសវត្សរ៍ឆ្នាំ១៩៥០ ដើម្បីជួយដល់កម្មវិធីអវកាស។ គាត់ជា «ស្ត្រីវិយឆ្លាត» ដែលលោក គ្លែន ត្រូវការក្នុងការងារគាត់ និងស្ថិតក្នុងចំណោម «មនុស្សកុំព្យូទ័រ» ដែលគេបានជួលឲ្យធ្វើការក្នុងអង្គការណាសាក្នុងសម័យនោះ។

ព្រះទ្រង់ប្រហែលមិនបានត្រាស់ហៅយើងឲ្យធ្វើជាអ្នកជំនាញផ្នែកគណិតវិទ្យាដ៏ឆ្លាតវៃឡើយ តែព្រះអង្គបានហៅយើងរាល់គ្នាឲ្យទទួល «ព្រះគុណផ្តល់មកយើងរាល់គ្នារៀងរាល់ខ្លួន តាមខ្នាតអំណោយទាននៃព្រះគ្រីស្ទ» (អេភេសូរ ៤:៧)។ យើងត្រូវរស់នៅ ក្នុងជីវិតដែលសក្តិសមនឹងការត្រាស់ហៅ ដែលយើងបានទទួល (ខ.១)។ យើងជាផ្នែកមួយនៃរូបកាយ ដែលសុទ្ធតែធ្វើការតាមផ្នែករបស់ខ្លួន (ខ.១៦)។

ការគណនាលេខរបស់អ្នកស្រី ខាត់ធើរីន ចនសិន បានផ្តល់ឲ្យនូវការបញ្ជាក់ សម្រាប់ទិសដៅនៃការបាញ់បង្ហោះយានអវកាស។ លោក គ្លែន ក៏បានជិះយាននោះចូលទៅក្នុងគន្លងយ៉ាងសុក្រឹត ដូចការគ្រោងទុក។ តែការងារនេះគ្រាន់តែជាការត្រាស់ហៅមួយ ក្នុងការត្រាស់ហៅដែលអ្នកស្រី ខាត់ធើរីន បានទទួល។ សូមយើងចាំថា ព្រះអង្គក៏បានហៅគាត់ ឲ្យធ្វើជាម្តាយ គ្រូបង្រៀន និងអ្នកបម្រើក្នុងព្រះវិហារផងដែរ។ យើងប្រហែលចង់សួរខ្លួនឯងថា ព្រះទ្រង់បានត្រាស់ហៅយើងឲ្យធ្វើអ្វីខ្លះ ទោះការងារនោះធំឬតូចក្តី។ តើយើង «បានត្រៀមខ្លួនចេញទៅ» ដោយប្រើអំណោយនៃព្រះគុណដែលព្រះអង្គប្រទាន ដោយរស់នៅក្នុងជីវិតដែលស័ក្តិសមនឹងការត្រាស់ហៅឬទេ (ខ.១)?—Kenneth Petersen

តើព្រះទ្រង់បានត្រាស់ហៅអ្នកឲ្យធ្វើអ្វី? តើព្រះអង្គបានប្រទានអំណោយទានអ្វីខ្លះមកអ្នក?

ឱព្រះអង្គអើយ សូមព្រះអង្គជួយទូលបង្គំឲ្យឱបក្រសោបយកការអ្វីដែលព្រះអង្គបានប្រទានទូលបង្គំ ហើយរស់នៅក្នុងជីវិតដែលស័ក្តិសមនឹងការត្រាស់ហៅរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១សាំយ៊ូអែល ៣០-៣១ និងលូកា ១៣:២៣-៣៥

មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្តីស្លាប់វិញ (សុភាសិត ១៤:១២)។

ការជ្រើសរើសយកផ្លូវជីវិត

មានពេលមួយ លោកគ្រូគង្វាល ដាមៀន (Damian) បានរៀបចំពេលទៅសួរសុខទុក្ខអ្នកជំងឺពីរនាក់ដែលជិតស្លាប់ក្នុងមន្ទីរពេទ្យផ្សេងគ្នា ហើយធ្លាប់បានជ្រើសរើសយកផ្លូវជីវិតពីរខុសគ្នា។ អ្នកជំងឺទីមួយជាស្ត្រីដែលក្រុមគ្រួសារស្រឡាញ់យ៉ាងខ្លាំង។ ការបម្រើអ្នកដទៃដោយមិនគិតប្រយោជន៍ផ្ទាល់ខ្លួន បានបណ្តាលឲ្យមនុស្សជាច្រើនស្រឡាញ់គាត់។ គ្រីស្ទបរិស័ទផ្សេងទៀតបានមកជួបជុំគ្នា នៅជុំវិញគាត់ ដោយថ្វាយបង្គំព្រះ អធិស្ឋានឲ្យគាត់ ហើយក្តីសង្ឃឹមក៏បានកើតមានពេញបន្ទប់ដែលគាត់សម្រាកព្យាបាល។ ក្នុងមន្ទីរពេទ្យមួយទៀត សាច់ញាតិរបស់សមាជិកពួកជំនុំរបស់លោកគ្រូ ដាមៀម ក៏កំពុងតែមានជំងឺជិតស្លាប់ផងដែរ។ បុរសនោះមានចិត្តរឹងទទឹង ជាហេតុនាំឲ្យការរស់នៅមានការលំបាកយ៉ាងខ្លាំង ហើយក្រុមគ្រួសាររបស់គាត់មានភាពរញ៉េរញ៉ៃក្នុងការរស់នៅ ដោយសារការសម្រេចចិត្តខុស និងទង្វើអាក្រក់របស់គាត់។ បរិយាកាសនៃជីវិតចុងក្រោយរបស់អ្នកទាំងពីរ បានឆ្លុះបញ្ចាំងអំពីភាពខុសគ្នានៃការរស់នៅរបស់ពួកគេ។

អ្នកដែលបានខកខានមិនបានពិចារណា អំពីគោលដៅដែលពួកគេកំពុងធ្វើដំណើរឆ្ពោះទៅរកក្នុងជីវិត ច្រើនតែជាប់គាំងជីវិតក្នុងកន្លែងដ៏លំបាក មិនចង់ឲ្យរស់នៅ និងឯកោ។ បទគម្ពីរសុភាសិត ១៤:១២ បានកត់សម្គាល់ថា "មានផ្លូវមួយដែលមើលទៅដូចជាត្រឹមត្រូវល្អ ដល់មនុស្ស តែចុងបំផុតនៃផ្លូវនោះ គឺជាសេចក្តីស្លាប់វិញ"។ ទោះយើងក្មេងឬចាស់មានជំងឺ ឬមានសុខភាពល្អ មានទ្រព្យសម្បត្តិច្រើន ឬក្រីក្រក្តី យើងនៅតែមានឱកាសពិនិត្យមើលផ្លូវជីវិតរបស់យើងឡើងវិញ គឺមិនទាន់យឺតពេលទេ។ តើផ្លូវនោះនាំយើងឆ្ពោះទៅរកកន្លែងណា? តើវាថ្វាយព្រះកិត្តិនាមដល់ព្រះទេ? តើវាជួយ ឬរំខានអ្នកដទៃ? តើវាជាផ្លូវល្អបំផុតសម្រាប់អ្នកជឿព្រះយេស៊ូវឬទេ?

ការសម្រេចចិត្តមានសារៈសំខាន់ណាស់។ ហើយព្រះដែលគង់នៅស្ថានសួគ៌ នឹងជួយយើងធ្វើការសម្រេចចិត្តល្អបំផុត ខណៈពេលដែលយើងងាកមករកព្រះអង្គ តាមរយៈព្រះយេស៊ូវ ជាព្រះរាជបុត្រាព្រះអង្គ ដែលមានបន្ទូលថា "អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក" (ម៉ាថាយ ១១:២៨)។—Arthur Jackson

តើអ្នកត្រូវការពិនិត្យ និងកែតម្រង់ផ្លូវនៃជីវិតរបស់អ្នកឡើងវិញឬទេ? តើមានអ្វីរារាំងអ្នកមិនឲ្យទូលសូមជំនួយ និងសេចក្តីក្លាហានមកពីព្រះ ដើម្បីធ្វើការកែតម្រង់នោះ?

ឱព្រះយេស៊ូវ ព្រះអង្គជាប្រភពនៃជីវិត។ សូមព្រះអង្គប្រទានទូលបង្គំនូវសេចក្តីក្លាហាន និងកម្លាំង ដើម្បីថ្វាយជីវិតទូលបង្គំដល់ព្រះអង្គ និងធ្វើអ្វីដែលថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 113 17/11/25 1:45 in the afternoon

អញបានធ្វើដល់គេ ដូចជាអ្នកដែលលើកបង្គើបនឹម នៅកគោហើយដាក់ស្មៅនៅមុខវា (ហូសេ ១១:៤)។

សេចក្តីស្រឡាញ់ដ៏សុភាពរបស់ព្រះអង្គ

ក្នុងវីដេអូដែលគេបានថតកាលពីឆ្នាំ២០១៧ គេឃើញបុរសជាឪពុកម្នាក់កំពុងលួងកូនប្រុសគាត់មានអាយុ២ខែ ឲ្យបាត់យំ ខណៈពេលដែលទារកនោះកំពុងទទួលវ៉ាក់សាំង។ ទិដ្ឋភាពក្នុងវីដេអូនេះបាននាំឲ្យមានការចាប់អារម្មណ៍នៅទូទាំងពិភពលោក មកលើរបៀបដែលឪពុកបង្ហាញសេចក្តីស្រឡាញ់ចំពោះកូនរបស់គាត់។ បន្ទាប់ពីពេទ្យបានចាក់វ៉ាក់សាំងរួចរាល់ហើយ បុរសជាឪពុកក៏បានលើកកូនប្រុសគាត់ពរនៅជិតថ្ពាល់គាត់ ហើយកូនគាត់ក៏បានឈប់យំក្នុងរយៈពេលតែពីរបីនាទីប៉ុណ្ណោះ។ គ្មានអ្វីដែលនាំមកនូវការធានា ខ្លាំងជាងការថែទាំដ៏ស្រទន់របស់ឪពុកម្តាយដែលមានសេចក្តីស្រឡាញ់ចំពោះកូនរបស់ខ្លួនឡើយ។

ក្នុងព្រះគម្ពីរមានការពិពណ៌នាល្អៗជាច្រើនអំពីព្រះអម្ចាស់ ថាព្រះអង្គជាឪពុកម្តាយមានក្តីស្រឡាញ់ ជារូបភាពដែលឆ្លុះបញ្ចាំងអំពីសេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅ ដែលឪពុកម្តាយមានចំពោះកូនរបស់ខ្លួន។ ក្នុងគ្រាសញ្ញាចាស់ ហោរាហូសេ បានទទួលព្រះរាជសារពីព្រះអម្ចាស់ ដើម្បីប្រកាសដល់ពួកអ៊ីស្រាអែលកំពុងរស់នៅក្នុងនគរខាងជើង ក្នុងអំឡុងសម័យនគរបែកបាក់។ ព្រះអង្គបានត្រាស់ហៅពួកគេ ឲ្យវិលត្រឡប់មករកទំនាក់ទំនងជាមួយព្រះអង្គវិញ។ លោកហូសេក៏បានរំឭកពួកគេ អំពីសេចក្តីស្រឡាញ់របស់ព្រះ ក្នុងនាមព្រះអង្គជាឪពុកដ៏សុភាព គឺដូចដែលព្រះអង្គមានបន្ទូលថា៖ «ក្នុងគ្រានោះដែលអ៊ីស្រាអែលនៅក្មេងនៅឡើយនោះអញបានស្រឡាញ់វា ក៏បានហៅកូនអញចេញពីស្រុកអេស៊ីព្ទមក» (ហូសេ ១១:១)។

ព្រះបន្ទូលសន្យាដែលបានធានាអំពីការយកព្រះទ័យទុកដាក់ ដោយសេចក្តីស្រឡាញ់ ក៏សម្រាប់យើងរាល់គ្នាផងដែរ។ ព្រះអង្គនៅតែហៅយើងថា កូនរបស់ព្រះអង្គ ទោះយើងស្វែងរកការថែរក្សាដ៏សុភាពរបស់ព្រះអង្គបន្ទាប់យើងបានបដិសេធន៍សេចក្តីស្រឡាញ់របស់ព្រះអង្គមួយរយៈពេល ឬដោយសារការឈឺចាប់ និងទុក្ខវេទនាក្នុងជីវិតយើងក៏ដោយ (១យ៉ូហាន ៣:១) ហើយព្រះហស្តនៃការកម្សាន្តចិត្តរបស់ព្រះអង្គ តែងតែបើកចំហ ដើម្បីទទួលយើង (២កូរិនថូស ១:៣-៤)។—Lisa M. Samra

តើអ្នកបានដកពិសោធន៍នឹងសេចក្តីស្រឡាញ់របស់ព្រះ ជាព្រះវរបិតាដែលថែរក្សាអ្នក យ៉ាងដូចម្តេចខ្លះ? តើអ្នកមានការព្រួយបារម្ភអ្វីខ្លះ សម្រាប់នាំមកថ្វាយព្រះអង្គនៅថ្ងៃនេះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានហៅទូលបង្គំថាកូនព្រះអង្គ ហើយប្រទានការថែរក្សាដ៏សុភាព ពេលណាទូលបង្គំរត់ទៅរកព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២សាំយ៊ូអែល ៣-៥ និងលូកា ១៤:២៥-៣៥

នៅថ្ងៃទី៦គេប្រជុំគ្នា នៅច្រកភ្នំបេរ៉ាកា (៦របាក្សត្រ ២០:២៦)។

ជ្រលងនៃការសរសើរតម្កើងព្រះ

លោក វីលៀម ខោភ័រ (William Cowper) ជាកវីកំណាព្យ ដែលមានជំងឺធ្លាក់ទឹកចិត្តអស់រយៈពេលភាគច្រើននៃជីវិតគាត់។ បន្ទាប់ពីគាត់បរាជ័យក្នុងការព្យាយាមធ្វើអត្តឃាត គាត់ក៏បានសម្រេចចិត្តចូលទៅសម្រាកព្យាបាលក្នុងមន្ទីរពេទ្យសម្រាប់មនុស្សវិកលចរិត។ ប៉ុន្តែ នៅទីនោះតាមរយៈការថែទាំរបស់គ្រូពេទ្យជាគ្រីស្ទបរិស័ទ លោក ខោភ័រ ក៏បានទទួលយកសេចក្តីជំនឿដ៏កក់ក្តៅ និងសំខាន់ចំពោះព្រះយេស៊ូវ។ មិនយូរប៉ុន្មាន គាត់ក៏បានក្លាយជាមិត្តភក្តិរបស់លោក ចន ញូតុន (John Newton) ជាគ្រូគង្វាល និងអ្នកនិពន្ធទំនុកសកល ដែលបានលើកទឹកចិត្តគាត់ ឲ្យចូលរួមនិពន្ធបទចម្រៀងទំនុកសកលមួយបទសម្រាប់ពួកជំនុំរបស់ពួកគេ។ ក្នុងចំណោមទំនុកសកលដែលលោក ខោភ័រ បាននិពន្ធ ក៏មានបទ «ព្រះអង្គធ្វើការតាមរបៀបដ៏អាថ៌កំបាំង» ផងដែរ ដែលគាត់បាននិពន្ធ ផ្អែកទៅលើទីបន្ទាល់របស់គាត់ គឺដូចដែលគាត់បានសរសេរយ៉ាងដូចនេះថា «ឱពួកបរិសុទ្ធដ៏ស្មោះត្រង់អើយ ចូរមានចិត្តក្លាហានឡើង អ័ភ្រែដែលអ្នកភ័យខ្លាចយ៉ាងនេះ គឺបានបង្កប់ទៅដោយសេចក្តីមេត្តាធំដល់ម្ល៉ះ ហើយនឹងរលាយបាត់ ចេញជាព្រះពរធ្លាក់មកលើអ្នក»។

ប្រជាជននៃនគរយូដា ក៏បានជួបសេចក្តីសប្បុរសរបស់ព្រះអម្ចាស់ តាមរបៀបដែលពួកគេមិននឹកស្មានដល់ដូចលោក ខោភ័រងដែរ។ នៅពេលដែលកងទ័ពសត្រូវបានចងសម្ព័ន្ធគ្នា ដើម្បីឈ្លានពានទឹកដីរបស់ពួកគេ ស្តេចយ៉ូសាផាត ក៏បានឲ្យពួកបណ្តាជនមកជួបជុំគ្នាអធិស្ឋាន។ ខណៈពេលដែលកងទ័ពនៃនគរយូដាដើរដង្ហែជាក្បួនទៅកាន់សមរភូមិ ពួកប្រុសៗនៅជួបមុខគេក៏បានសរសើរតម្កើងព្រះអម្ចាស់ (២របាក្សត្រ ២០:២១)។ ពួកសត្រូវឈ្លានពានក៏មានការភាន់ភាំង កាប់សម្លាប់គ្នាឯង ដោយគ្មានពួកគេណាម្នាក់អាចរត់គេចឡើយ ដោយបន្សល់ទុកនូវយុទ្ធភណ្ឌ ដែលពួកយូដាត្រូវចំណាយពេល៣ថ្ងៃ ដើម្បីចាប់យក (ខ.២៤-២៥)។

នៅថ្ងៃទី៤ គេក៏បានហៅទីកន្លែងដែលពួកកងទ័ពសត្រូវបានប្រមូលផ្តុំគ្នាទាស់នឹងរាស្ត្ររបស់ព្រះអម្ចាស់ថា ច្រកភ្នំបេរ៉ាក (ខ.២៦) ដែលមានន័យត្រង់ថា «ជ្រលងនៃការសរសើរតម្កើង ឬព្រះពរ»។ នេះជាការផ្លាស់ប្តូរដ៏អស្ចារ្យ! សេចក្តីមេត្តារបស់ព្រះអាចកែប្រែជ្រលង ដែលពិបាកបំផុតរបស់យើង ឲ្យក្លាយជាកន្លែងសរសើរតម្កើង ខណៈពេលដែលយើងថ្វាយទុក្ខលំបាកទាំងអស់នោះដាច់ដល់ព្រះអង្គ។—James Banks

តើអ្នកបានឃើញព្រះទ្រង់នាំការល្អ ចេញពីទុក្ខលំបាកក្នុងជីវិតអ្នកដូចម្តេចខ្លះ? តើអ្នកអាចអរព្រះគុណព្រះអង្គនៅថ្ងៃនេះ សម្រាប់ការអ្វីខ្លះ?

ឱព្រះនៃសេចក្តីស្រឡាញ់ ទូលបង្គំសូមសរសើរតម្កើងព្រះអង្គ ដ្បិតគ្មានជ្រោះណា ដែលជ្រៅជាងសេចក្តីស្រឡាញ់របស់ព្រះអង្គឡើយ។

Daily Manna 2026_Content Enhance.indd 115 17/11/25 1:45 in the afternoon

ចូរដេញតាមសេចក្តីមេត្រី ចំពោះមនុស្សទាំងអស់ចុះ (ហេព្រើរ ១២:១៤)។

គ្រួសារពិតជាសំខាន់ណាស់

មានពេលមួយ បងស្រី និងបងប្រុសខ្ញុំ ហើយនិងខ្ញុំបានធ្វើដំណើរតាមយន្តហោះ ចេញពីរដ្ឋដែលយើងកំពុងរស់នៅរៀងខ្លួន ដើម្បីទៅចូលរួមពិធីបុណ្យសពរបស់ពូរបស់យើង ហើយក៏បានទៅសួរសុខទុក្ខជីដូនរបស់យើង ដែលមានអាយុ៩០ឆ្នាំ។ គាត់បានក្លាយជាជនពិការ ដោយសារដាច់សរសៃឈាមខួរក្បាល ហើយក៏បានបាត់បង់សមត្ថភាពនិយាយ ហើយអាចប្រើបានតែដៃស្តាំរបស់គាត់ប៉ុណ្ណោះ។ ខណៈពេលដែលយើងកំពុងអង្គុយនៅជុំវិញគ្រែគេងគាត់ គាត់ក៏បានលូកដៃស្តាំរបស់គាត់ មកចាប់ដៃយើងម្នាក់ៗ ដោយទាញដៃយើងមកដាក់ពីលើគ្នា ចំបេះដូងគាត់ ហើយក៏បានអង្អែលដៃយើងថ្នមៗ ឲ្យនៅនឹងមួយកន្លែង។ តាមរយៈភាសាកាយវិការរបស់គាត់ គាត់កំពុងប្រាប់យើងថា «គ្រួសារសំខាន់ណាស់»។ គាត់កំពុងនិយាយពាក្យនេះ តាមរយៈកាយវិការមកកាន់បងប្អូនបង្កើត ដែលមានការបែកបាក់ទំនាក់ទំនង និងដាច់ចេញឆ្ងាយពីគ្នា។

ក្នុងពួកជំនុំ ជាមហាគ្រួសារនៃព្រះ យើងក៏អាចមានការបែកបាក់ និងដាច់ចេញពីគ្នាផងដែរ។ យើងប្រហែលជាបានបណ្តោយឲ្យចិត្តល្ងីល្ងើដូរចត់ បំបែកយើងចេញពីគ្នា។ កណ្ឌគម្ពីរហេព្រើរបានបង្រៀនយើងអំពីចិត្តដូរល្ងើដែលបានបំបែកលោក អេសាវ ចេញពីលោក យ៉ាកុប ជាប្អូនប្រុសរបស់គាត់ (ហេព្រើរ ១២:១៦) ហើយក៏បានជំរុញយើងជាបងប្អូន ឲ្យរួបរួមគ្នាក្នុងមហាគ្រួសារនៃព្រះ។ «ចូរដេញតាមសេចក្តីមេត្រី ចំពោះមនុស្សទាំងអស់» (ខ.១៤)។ ត្រង់ចំណុចនេះ ពាក្យដេញតាមបានបង្ហាញចេញនូវការលះបង់ស្ម័គ្រពីចិត្ត ក្នុងការផ្សះផ្សាជាមួយបងប្អូនក្នុងមហាគ្រួសាររបស់ព្រះ។ និយាយរួម យើងម្នាក់ៗសុទ្ធតែខិតខំដេញតាមសេចក្តីមេត្រី។

គ្រួសារពិតជាសំខាន់ណាស់ គឺទាំងគ្រួសារនៅផែនដី ក៏ដូចជាមហាគ្រួសាររបស់ព្រះ ដែលជាអ្នកជឿព្រះអង្គ។ ចូរយើងរាល់គ្នាខិតខំរួបរួមគ្នា ដោយសេចក្តីស្រឡាញ់ផងដែរ។—Elisa Morgan

តើការដេញតាមសេចក្តីមេត្រី ចំពោះមនុស្សទាំងអស់ក្នុងមហាគ្រួសាររបស់ព្រះ មានន័យដូចម្តេចចំពោះអ្នក? តើមាននរណាខ្លះដែលអ្នកត្រូវផ្សះផ្សាជាមួយ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការនាំទូលបង្គំចូលទៅជិតព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យខិតខំរស់នៅ ដោយសន្តិភាពជាមួយមនុស្សទាំងអស់ក្នុងមហាគ្រួសាររបស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 116 17/11/25 1:45 in the afternoon

អាហារដែលមនុស្សណាបាន ដោយការកំភូត នោះរមែងឆ្ងាញ់ដល់ខ្លួន តែក្រោយមក មាត់មានពេញទៅដោយក្រួសវិញ (សុភាសិត ២០:១៧)។

ភាពជូរល្វីង នៃបង្អែមដែលបានលួចគេ

ក្រុមមួយក្រុមក្នុងប្រទេសអាឡឺម៉ង់ បានលួចទូរសព្ទដៃមួយ ផ្ញើកទៅដោយស្ករសូកូឡាជាង២០គោន ក្នុងទូរបង្កកអាហារ។ គេបានប៉ាន់ប្រមាណថា ស្ករសូកូឡាដែលមានរស់ជាតិផ្អែមឆ្ងាញ់នោះ មានតម្លៃសរុបប្រហែលជាមឺនដុល្លា។ ប៉ូលិសក្នុងតំបន់ក៏បានអំពាវនាវ ឲ្យគេរាយការណ៍មកកាន់ប៉ុស្តិ៍ប៉ូលីសជាបន្ទាន់ បើសិនជាមាននរណាម្នាក់បានទទួលស្ករសូកូឡាក្នុងបរិមាណច្រើនខុសពីធម្មតា ឬបានទទួលតាមរបៀបមិនប្រក្រតី។ ជាការពិតណាស់ អ្នកដែលបានលួចស្ករសូកូឡាដ៏ផ្អែមឆ្ងាញ់នោះ នឹងទទួលផលវិបាកដ៏ជូរល្វីង និងខកចិត្តមិនខាន បើសិនជាពួកគេត្រូវប៉ូលិសចាប់ខ្លួន និងទទួលទោសតាមច្បាប់!

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំ គោលការណ៍ក្នុងបទគម្ពីរសុភាសិតដែលបានចែងថា «អាហារដែលមនុស្សណាបាន ដោយការកំភូត នោះរមែងឆ្ងាញ់ដល់ខ្លួន តែក្រោយមក មាត់មានពេញទៅដោយក្រួសវិញ» (២០:១៧)។ អ្វីៗដែលយើងទទួលបាន ដោយការបោកប្រាស់ ឬតាមផ្លូវខុស អាចហាក់ដូចជាមានរស់ជាតិផ្អែមពីដំបូង ដោយមានភាពរំភើបរីករាយ និងការអរសប្បាយតែមួយរយៈពេល។ ប៉ុន្តែ ទីបំផុតរស់ជាតិរបស់វា ក៏លែងផ្អែមឆ្ងាញ់ទៀត ហើយការបោកប្រាស់របស់យើង ក៏បាននាំឲ្យយើងមានការភ័យខ្លាច និងមានបញ្ហា។ ផលវិបាកនៃកំហុស ការភ័យខ្លាច និងបាប អាចបំផ្លាញជីវិត និងកេរ្តិ៍ឈ្មោះរបស់យើង។ គឺដូចមានសេចក្តីចែងថា «សូម្បីតែកូនក្មេងក៏សំដែងខ្លួន ដោយសារកិរិយាប្រព្រឹត្តរបស់វាដែរ ឲ្យដឹងជាកិរិយានោះបរិសុទ្ធ ហើយត្រឹមត្រូវឬយ៉ាងណា» (ខ.១១)។ សូមឲ្យពាក្យសម្តី និងសកម្មភាពរបស់យើង បង្ហាញឲ្យគេឃើញចិត្តដ៏បរិសុទ្ធ ដែលយើងមានសម្រាប់ព្រះអម្ចាស់ គឺមិនមែនឃើញចិត្តជូរល្វីង ដែលអាត្មានិយមនោះទេ។

ពេលណាយើងជួបការល្បួង ចូរយើងទូលសូមព្រះអង្គចម្រើនកម្លាំងយើង ហើយជួយយើងឲ្យនៅតែស្មោះត្រង់ចំពោះព្រះអង្គ។ ព្រះអង្គអាចជួយយើងឲ្យជៀសវាង «រស់ជាតិផ្អែម» ដែលមានរយៈពេលខ្លី ជាការចាញ់ការល្បួង ហើយដឹកនាំយើង ឲ្យពិចារណាយ៉ាងប្រុងប្រយ័ត្នអំពីផលវិបាកយូរអង្វែងនៃការសម្រេចចិត្តរបស់យើង។—Marvin Williams

តើការល្បួងនាំទៅរកលទ្ធផលដ៏ជូរល្វីងសម្រាប់អ្នក នៅពេលណាខ្លះ? តើអ្នកនៅតែបន្តមានចិត្តស្មោះត្រង់ចំពោះព្រះដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំត្រូវការកម្លាំងមកពីព្រះអង្គ ដើម្បីជម្នះការល្បួង ហើយនៅតែស្មោះត្រង់ចំពោះព្រះអង្គ។

ពួរ៣ធ្នូដ៏មិនងាយដាច់ទេ (សាស្តា ៤:១២)។

ការជួយទ្រទ្រង់គ្នា ក្នុងព្រះគ្រីស្ទ

មានពេលមួយ លោក យ៉ូរដិន (Jordon) បានចូលរួមកម្មវិធីប្រកួតជីវិតពិត ដែលមានចាក់ផ្សាយក្នុងទូរទស្សន៍ ដែលក្នុងនោះ អ្នកចូលរួមទាំងអស់ត្រូវរស់នៅម្នាក់ឯងក្នុងតំបន់ព្រៃភ្នំ ដោយប្រើស្បៀងអាហារ និងសម្ភារៈតិចបំផុត ឲ្យបានរយៈពេលយូរបំផុតតាមដែលអាចធ្វើទៅបាន។ គាត់បានបង្ខំចិត្តបោះបង់ចោលការប្រកួត មិនមែនដោយសារគាត់ខ្លាចសត្វខ្លាឃ្មុំកាចសាហាវ អាកាសធាតុត្រជាក់ដល់ក្អក ការមានរបួស ឬការស្រេកឃ្លានអាហារនោះទេ តែគឺដោយសារគាត់មានអារម្មណ៍ឯកោពេក ហើយមានបំណងចិត្តចង់ត្រឡប់ទៅគ្រួសារគាត់វិញ។ គាត់ថា "ខ្ញុំដឹងថា វិធីតែមួយដើម្បីឲ្យខ្ញុំអាចជោគជ័យក្នុងការប្រកួតនេះបាន គឺត្រូវបំភ្លេចផ្ទះ និងប្រពន្ធ កូនប្រុស និងកូនស្រីរបស់ខ្ញុំ។ តែខ្ញុំដឹងថា ខ្ញុំមិនអាចឈប់គិតអំពីពួកគេបានទេ។ យើងមានចំណងទាក់ទងដ៏រឹងមាំក្នុងចិត្ត និងវិញ្ញាណយើងគ្មានអ្វីអាចបំបែកបានឡើយ"។

យើងអាចមានជំនាញរស់នៅម្នាក់ឯងក្នុងព្រៃ ប៉ុន្តែការកាត់ផ្តាច់ខ្លួនយើងចេញពីសហគមន៍ គឺជាផ្លូវឆ្ពោះទៅរកបរាជ័យក្នុងជីវិត។ គឺដូចដែលបទគម្ពីរសាស្តាបានចែងថា "មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង... ដ្បិតបើដួល នោះម្នាក់នឹងជ្រោងគ្នាឡើងវិញ" (៤:៩-១០)។ ពួកជំនុំដែលថ្វាយព្រះកិត្តិនាមដល់ព្រះគ្រីស្ទ មានភាពចាំបាច់ដល់ការលូតលាស់របស់យើង ទោះសហគមន៍នោះមានភាពរញ៉េរញ៉ៃយ៉ាងណាក៏ដោយ។ យើងមិនអាចជម្នះទុក្ខលំបាកក្នុងលោកីយ៍នេះបានទេ បើសិនជាយើងព្យាយាមដោះស្រាយ ដោយពឹងសមត្ថភាពខ្លួនឯងតែម្យ៉ាង។

ការហាត់នឿយតែម្នាក់ឯង គឺជាការនឿយហាត់ដែលគ្មានន័យ (ខ.៨)។ បើយើងនៅតែម្នាក់ឯង យើងងាយនឹងជួបគ្រោះថ្នាក់ (ខ.១១-១២)។ ឯពួរ៣ធ្នូងមិនងាយដាច់ទេ គឺខុសពីខ្សែដែលមានតែ១ធ្នូង (ខ.១២)។ ពួកជំនុំដែលជាអំណោយនៃសេចក្តីស្រឡាញ់ និងយកព្រះគ្រីស្ទជាទីមួយមិនគ្រាន់តែផ្តល់ឲ្យយើងនូវការលើកទឹកចិត្តប៉ុណ្ណោះទេ តែក៏ផ្តល់ឲ្យយើងនូវកម្លាំងសម្រាប់តស៊ូ ទោះមានបញ្ហាប្រឈមយ៉ាងណាក៏ដោយ។ យើងត្រូវការគ្នាទៅវិញទៅមក។—Karen Pimpo

តតើអ្នកអាចប្តេជ្ញាចិត្តចំណាយពេលជាមួយមហាគ្រួសារនៃអ្នកជឿ ដូចម្តេចខ្លះ? នៅក្បែរអ្នក តើមាននរណាខ្លះដែលឯកោ និងត្រូវការជំនួយ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានពួកជំនុំមក ជាអំណោយដែលមិនអាចខ្វះបាន។ សូមបើកភ្នែកទូលបង្គំ ឲ្យស្រឡាញ់ និងចំណាយពេលជាមួយអ្នកដទៃនៅថ្ងៃនេះ។

Daily Manna 2026_Content Enhance.indd 118 17/11/25 1:45 in the afternoon

ខ្ញុំប្រាប់សេចក្តីទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នា បានសេចក្តីសុខសាន្ត ដោយសារខ្ញុំ (យ៉ូហាន ១៦:៣៣)។

ព្រះយេស៊ូវជាអ្នកបង្កើតសន្តិភាពពិតប្រាកដ

កាលពីថ្ងៃទី៣០ ខែខែធ្នូ ឆ្នាំ១៨៦២ សង្គ្រាមស៊ីវិលនៅអាមេរិកបានរីករាលដាលកាន់តែខ្លាំង។ កងទ័ពរដ្ឋសហព័ន្ធ និងកងទ័ពរដ្ឋសហភាពបានបោះជំរំនៅចម្ងាយ៧រយម៉ែត្រពីគ្នា នៅលើត្រើយម្ខាងម្នាក់នៃទន្លេស្នោន ក្នុងរដ្ឋថេនេស៊ី។ ខណៈពេលដែលពួកគេកំពុងកំដៅខ្លួននៅជុំវិញភ្លើងជំរុំ កងទ័ពរដ្ឋសហព័ន្ធក៏បានចាប់កាន់វីយូឡុង និងហាម៉ូនីកាមកប្រគំភ្លេងបទ «យែងគី ឌូឌល»។ កងទ័ពរដ្ឋសហភាពក៏បានឆ្លើយតប ដោយប្រគំបទ «ឌីស៊ី»។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ កងទ័ពទាំងពីរក៏បានប្រគំភ្លេងរួមគ្នានូវបទ «ឱផ្ទះដ៏កក់ក្តៅ»។ ទោះជាយ៉ាងណាក៏ដោយ ភាពត្រូវរ៉ូវគ្នា ដោយសូរសម្លេងតន្ត្រីមិនមានរយៈពេលយូរទេ។ នៅពេលព្រឹកឡើង ពួកគេក៏បានដាក់វីយូឡុងចុះ ហើយចាប់កាន់កាំភ្លើងឡើងវិញ។ នៅថ្ងៃនោះ ការប្រយុទ្ធគ្នាបានបណ្តាលឲ្យទាហានជាង២ម៉ឺននាក់ បាត់បង់ជីវិត។

ការប្រឹងប្រែងរបស់យើងជាមនុស្សក្នុងការបង្កើតសន្តិភាព ពិតជាមានភាពរួញខ្លីណាស់។ ការប្រយុទ្ធគ្នាបានបញ្ចប់នៅកន្លែងមួយ ហើយក៏បានផ្ទុះឡើងនៅកន្លែងផ្សេងទៀត។ ជម្លោះក្នុងទំនាក់ទំនង អាចរកឃើញភាពសុខដុម តែប៉ុន្មានខែក្រោយមក ជម្លោះក៏បានកើតឡើងជាថ្មី។ ព្រះគម្ពីរបានបង្រៀនយើងថា មានតែព្រះអម្ចាស់ទេ ដែលអាចប្រទានសន្តិភាពដ៏ស្ថិតស្ថេរបាន។ ព្រះយេស៊ូវមានបន្ទូលយ៉ាងច្បាស់ថា «ខ្ញុំប្រាប់សេចក្តីទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាបានសេចក្តីសុខសាន្ត ដោយសារខ្ញុំ» (១៦:៣៣)។ យើងមានសន្តិភាព ឬសេចក្តីសុខសាន្តក្នុងព្រះយេស៊ូវ។ ខណៈពេលដែលយើងចូលរួមក្នុងបេសកកម្មសន្តិភាពរបស់ព្រះអង្គ មានតែការផ្សះផ្សា និងការបង្កើតជាថ្មីរបស់ព្រះអង្គទេ ដែលធ្វើឲ្យសន្តិភាពពិតប្រាកដកើតមានបាន។

ព្រះគ្រីស្ទបានប្រាប់យើងថា យើងមិនអាចជៀសវាងការប៉ះទង្គិចគ្នានៅលើផែនដីនេះបានទេ។ ព្រះយេស៊ូវមានបន្ទូលថា «នៅលោកីយ៍នេះ នោះអ្នករាល់គ្នាមានសេចក្តីវេទនាមែន ប៉ុន្តែត្រូវសង្ឃឹមឡើង ដ្បិតខ្ញុំបានឈ្នះលោកីយ៍ហើយ» (ខ.៣៣)។ ការប្រឹងប្រែងរបស់យើងដោយពឹងអាងខ្លួនឯង ច្រើនតែនាំឲ្យមានការខកចិត្ត តែព្រះនៃសេចក្តីស្រឡាញ់របស់យើង (ខ.២៧) បង្កើតឲ្យមានសន្តិភាពក្នុងលោកីយ៍ដែលមានការប្រែប្រួល។—Winn Collier

តើអ្នកបានឃើញមនុស្សបង្កើតឲ្យមានសន្តិភាព នៅកន្លែងណាខ្លះ? តើការបង្កើតសន្តិភាពរបស់ព្រះអម្ចាស់ មានភាពខុសប្លែកពីសន្តិភាពរបស់មនុស្សដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គបង្ហាញទូលបង្គំ នូវផ្លូវឆ្ពោះទៅរកសន្តិភាព។

Daily Manna 2026_Content Enhance.indd 119 17/11/25 1:45 in the afternoon

តែព្រះទ្រង់បានដាក់ចុះនូវអវយវៈនីមួយៗ ក្នុងរូបកាយតាមព្រះហឫទ័យទ្រង់ (*១កូរិនថូស ១២:១៨*)។

រួបរួមដោយអំណោយទានផ្សេងគ្នា ក្នុងព្រះគ្រីស្ទ

ក្នុងអត្ថបទដែលសាស្ត្រាចារ្យ ដេនីល បូមែន (Daniel Bowman Jr) បាននិពន្ធមានចំណងជើងថា «ការបម្រើ និងលក្ខណៈផ្សេងៗនៃការបម្រើ» គាត់បានរៀបរាប់អំពីការលំបាក ក្នុងការសម្រេចចិត្តជ្រើសរើសយកបៀបនៃការបម្រើពួកជំនុំគាត់ ក្នុងនាមគាត់ជាមនុស្សមានជំងឺអូទិបហ្សឹម។ គាត់បានពន្យល់ថា «អ្នកជំងឺអូទីហ្សឹមត្រូវតែបង្កើតផ្លូវថ្មីសម្រាប់ដើរទៅមុខរៀងរាល់ពេល ជាផ្លូវពិសេស ដែលត្រូវការពេលវេលាសម្រាកម្នាក់ឯង ដើម្បីឲ្យមានកម្លាំងឡើងវិញ ទាំងខាងផ្លូវចិត្ត ផ្លូវអារម្មណ៍ និងផ្លូវកាយ... តាមញាណទាំង៥ និងក្នុងកម្រិតនៃភាពសុខស្រួល... នៅពេលណាមួយនៅថ្ងៃនីមួយៗ ទោះគេបានឲ្យតម្លៃមកលើយើង ផ្អែកទៅលើកម្លាំងរបស់យើង ហើយមានការយោគយល់ចំពោះតម្រូវការរបស់យើងឬអត់ក៏ដោយ ជាជាងមិនរាប់បញ្ចូលយើងក្នុងចំណោមអ្នកដទៃ ដោយសារភាពខ្វះចន្លោះរបស់យើង»។ល។ គាត់ក៏បានរៀបរាប់ទៀតថា «សម្រាប់មនុស្សជាច្រើន ការសម្រេចចិត្តដូចនេះនាំមកនូវការផ្លាស់ប្តូរអាទិភាព ឬរបៀបនៃការរស់នៅរបស់ពួកគេឲ្យបានត្រឹមត្រូវ ដោយមានផលល្អចំពោះពួកគេ តែអាចមានផលប៉ះពាល់មិនល្អមកលើខ្ញុំ»។

លោក បូមែន ជឿថា ការបង្រៀនអំពីភាពពេញវ័យ ដែលសាវ័ក ប៉ុល បានពិពណ៌នាក្នុងបទគម្ពីរ ១កូរិនថូស ជំពូក១២ អាចធ្វើជាជំណោះស្រាយដែលនាំមកនូវការប្រោសឲ្យជា។ ដែលក្នុងនោះ ខ.៤ ដល់ខ.៦ បានពិពណ៌នាថា ព្រះទ្រង់បានប្រទានអំណោយទានផ្សេងៗគ្នា ដល់រាស្ត្ររបស់ព្រះអង្គម្នាក់ៗ ដើម្បី «ប្រយោជន៍រួម» (ខ.៧)។ ពួកគេម្នាក់ៗជា អវយវៈនៃរូបកាយព្រះគ្រីស្ទ «ដែលមិនអាចខ្វះបាន» (ខ.២២)។ ពេលណាពួកជំនុំទទួលស្គាល់អំណោយទានខុសៗគ្នា ដែលព្រះទ្រង់បានប្រទាន ពួកគេអាចជួយទ្រទ្រង់សមាជិករបស់ពួកគេឲ្យបម្រើ តាមអំណោយទានរបស់ខ្លួន ជាជាងដាក់សម្ពាធមកលើពួកគេម្នាក់ៗ ឲ្យរួមចំណែកតាមរបៀបដូចគ្នា។

តាមរយៈការអនុវត្តន៍ដូចនេះ មនុស្សម្នាក់ៗអាចរកឃើញភាពរីកចម្រើន និងភាពពេញលេញ ហើយមានទំនុកចិត្តថា ពួកគេមានចំណែកដ៏មានតម្លៃក្នុងរូបកាយព្រះគ្រីស្ទ (ខ.២៦)។—Monica La Rose

តើអ្នកបានទទួលព្រះពរ ពីអំណោយទានពិសេសរបស់អ្នកដទៃ យ៉ាងដូចម្តេចខ្លះ? តើពួកជំនុំអាចលើកទឹកចិត្តឲ្យមានការបម្រើតាមរបៀបផ្សេងគ្នាដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការបង្កើតយើងខ្ញុំមក ឲ្យមានអំណោយទានផ្សេងគ្នា។ សូមព្រះអង្គជួយទូលបង្គំឲ្យចេះឲ្យតម្លៃ មកលើអវយវៈនីមួយៗនៃរូបកាយព្រះគ្រីស្ទ។

Daily Manna 2026_Content Enhance.indd 120 17/11/25 1:45 in the afternoon

ខ្ញុំមិនព្រមខ្លាចឡើយ ព្រោះព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ តើមនុស្សនឹងធ្វើដល់ខ្ញុំជាយ៉ាងណាបាន (ហេព្រើរ ១៣:៦)។

ព្រះទ្រង់ជាជំនួយរបស់ខ្ញុំ

មិត្តភក្តិរបស់ខ្ញុំឈ្មោះ រ៉ាលេក (Raleigh) កំពុងឈានចូលវ័យ៨៥ឆ្នាំ! ចាប់តាំងពីពេលដែលខ្ញុំបានសន្ទនាជាលើកដំបូងជាមួយគាត់ ប្រហែល៣៥ឆ្នាំមុន គាត់បានផ្តល់ឲ្យនូវការលើកទឹកចិត្តជាច្រើនសម្រាប់ខ្ញុំ។ នៅពេលដែលគាត់បានលើកឡើងអំពីរឿងនេះ នៅពេលថ្មីៗនេះ ចាប់តាំងពីពេលដែលគាត់បានចូលនិវត្តន៍ គាត់បានបញ្ចប់ការនិពន្ធសៀវភៅមួយក្បាល ហើយចាប់ផ្តើមការងារមួយទៀតសម្រាប់បម្រើព្រះក្នុងផ្នែកនិពន្ធសៀវភៅ ។ ពេលនោះ ខ្ញុំមានការចាប់អារម្មណ៍ណាស់ តែមិនមានការភ្ញាក់ផ្អើលទេ។

ក្នុងព្រះគម្ពីរ កាលលោក កាលែប មានអាយុ៨៥ឆ្នាំ គាត់ក៏មិនបានឈប់ធ្វើការបម្រើព្រះអង្គដែរ។ ជំនឿនិងភាពបួរផ្តាច់ដែលគាត់មានចំពោះព្រះអម្ចាស់ បានជួយទ្រទ្រង់ជីវិតគាត់ក្នុងការឆ្លងកាត់ការរស់នៅ ក្នុងវាលរហោស្ថានជាច្រើនទសវត្សរ៍ និងក្នុងសង្គ្រាម ដើម្បីថែរក្សាមរតកដែលព្រះទ្រង់សន្យាប្រទានរាស្ត្រអ៊ីស្រាអែល។ គឺដូចដែលគាត់បានមានប្រសាសន៍ថា «សព្វថ្ងៃនេះខ្ញុំនៅតែមានកំឡាំង ដូចក្នុងកាលដែលលោក ម៉ូសេ បានចាត់ខ្ញុំឲ្យទៅនោះនៅឡើយ កំឡាំងខ្ញុំតឡូរនេះក៏ដូចជាកាលពីដើមដែរ សំរាប់នឹងទៅច្បាំងទាំងចេញទៅហើយចូលមកវិញផង» (យ៉ូស្វេ ១៤:១១)។ តើគាត់អាចមានជ័យជម្នះ ដោយរបៀបណា? លោក កាលែប បានប្រកាសថា គឺដោយព្រះអម្ចាស់គង់នៅជាមួយគាត់ (ខ.១២)។

ព្រះទ្រង់ជួយអ្នកដែលទុកចិត្តព្រះអង្គអស់ពីចិត្ត ទោះពួកគេមានអាយុប៉ុន្មានស្ថិតក្នុងដំណាក់កាលណា ឬកាលៈទេសៈមួយណាក្នុងជីវិតក៏ដោយ។ ព្រះអម្ចាស់បានបង្ហាញអង្គទ្រង់ ឲ្យមនុស្សបានឃើញតាមរយៈព្រះគ្រីស្ទ។ កណ្ឌគម្ពីរដំណឹងល្អបានបណ្តាលចិត្តយើងឲ្យជឿលើព្រះ តាមរយៈការអ្វីដែលយើងឃើញក្នុងព្រះគ្រីស្ទ។ ព្រះអង្គបានបង្ហាញឲ្យយើងដឹងថា ព្រះអម្ចាស់យកព្រះទ័យទុកដាក់ និងអាណិតដល់មនុស្សទាំងអស់ ដែលស្វែងរកជំនួយពីព្រះអង្គ។ គឺដូចដែលបទគម្ពីរហេព្រើរបានទទួលស្គាល់ថា «ខ្ញុំមិនព្រមខ្លាចឡើយ ព្រោះព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ» (ហេព្រើរ ១៣:៦)។ ទោះយើងក្មេង ឬចាស់ ខ្សោយ ឬខ្លាំង ជាប់ចំណង ឬមានសេរីភាព មានកាយសម្បទាគ្រប់គ្រាន់ ឬពិការក្តី តើមានអ្វីរារាំងយើងឲ្យទូលសូមជំនួយពីព្រះអង្គ នៅថ្ងៃនេះ?—Arthur Jackson

តើមាននរណាខ្លះ បណ្តាលចិត្តអ្នកឲ្យមានជំនឿលើព្រះ? តើអ្នកយល់ឃើញថា ព្រះទ្រង់មានប្រភពនៃជំនួយក្នុងគ្រប់ការទាំងអស់យ៉ាងដូចម្តេចខ្លះ?

ឱព្រះដ៏មានគ្រប់ចេស្តា សូមព្រះអង្គជួយទូលបង្គំ ឲ្យមើលឃើញព្រះអង្គជាជំនួយសម្រាប់ទូលបង្គំក្នុងកាលៈទេសៈទាំងអស់។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២សាំយ៉ូអែល ២១-២២ និងលូកា ១៨:២៤-៤៣

ដ្បិតកាលខ្ញុំខ្វះខាតនៅថែស្សាឡូនីច នោះអ្នករាល់គ្នាបានផ្ញើទៅជួយខ្ញុំម្តងពីរដងផង (ភីលីព ៤:១៦)។

រួមគ្នាធ្វើការបម្រើព្រះអង្គ

ក្រុមអ្នកជួយសង្គ្រោះបានសហការគ្នា ដើម្បីជួយបុរសពីរនាក់ កំពុងជាប់នៅលើកោះមួយ ក្នុងតំបន់ប្រជុំកោះមីក្រូនេស៊ី។ ការធ្វើការជាក្រុមមានសារៈសំខាន់ ព្រោះការីករាលដាលនៃជំងឺកូវីដ បានតម្រូវឲ្យពួកគេរក្សាគម្លាតក្នុងការទំនាក់ទំនង។ អ្នកបើកយន្តហោះ ដែលបានឃើញអ្នកលិចកប៉ាល់ទាំងនោះ ក៏បានប្រើវិទ្យុទាក់ទង ផ្តល់ដំណឹងដល់នាវាកងទ័ពជើងទឹកអូស្ត្រាលី។ នាវានោះក៏បានបញ្ជូនឧទ្ធម្ភាគចក្រពីរគ្រឿង ដោយមានអាហារ ទឹក និងថ្នាំពេទ្យទៅជាមួយ។ ក្រោយមក ឆ្មាំសមុទ្រអាមេរិកក៏បានធ្វើដំណើរមកដល់ ដើម្បីពិនិត្យសុខភាពរបស់បុរសទាំងនោះ ហើយក៏បានឲ្យវិទ្យុទាក់ទងមួយគ្រឿងដល់ពួកគេ។ ទីបំផុត ទូកល្បាតប្រចាំដំបន់មីក្រូនេស៊ី ក៏បានជូនពួកគេទៅដល់គោលដៅរបស់ពួកគេ។

យើងអាចសម្រេចកិច្ចការជាច្រើន ពេលណាយើងធ្វើការជាមួយគ្នា។ អ្នកជឿព្រះនៅទីក្រុងភីលីព បានរួបរួមគ្នាក្នុងការប្រឹងប្រែងឧបត្ថម្ភសាវ័ក ប៉ុល។ អ្នកស្រី លីឌា និងក្រុមគ្រួសារបានស្វាគមន៍គាត់ឲ្យចូលស្នាក់នៅផ្ទះរបស់ពួកគេ (កិច្ចការ ១៦:១៣-១៥)។ លោក ក្លេមិន និងសម្ព័ន្ធតែអ្នកស្រី អើរ៉ូឌា និងអ្នកស្រី ស៊ុនទីច (ដែលមិនចុះសម្រុងនឹងគ្នា) ក៏សុទ្ធតែបានធ្វើការដោយផ្គាល់ជាមួយលោក ដើម្បីផ្សាយដំណឹងល្អផងដែរ (ភីលីព ៤:២-៣)។ ក្រោយមក នៅពេលដែលសាវ័ក ប៉ុល ជាប់គុកក្នុងទីក្រុងរ៉ូម ពួកជំនុំក៏បានប្រមូលស្បៀងអាហារ ហើយផ្ញើទៅគាត់ តាមរយៈលោក អេប៉ាប្រូឌីត (ខ.១៤-១៨)។ ប្រហែលសំខាន់បំផុតនោះ ពួកជំនុំនៅទីក្រុងភីលីពបានអធិស្ឋានឲ្យគាត់ ជាទៀងទាត់ ក្នុងពេលដែលគាត់ធ្វើការបម្រើព្រះ (១:១៩)។

គំរូនៃអ្នកជឿព្រះ ដែលធ្វើការបម្រើព្រះអង្គជាមួយគ្នាក្នុងពួកជំនុំដំបូង អាចបណ្តាលចិត្តយើងក្នុងពេលសព្វថ្ងៃ ឲ្យមានការរួបរួមផងដែរ។ ការសហការជាមួយបងប្អូនរួមជំនឿក្នុងការអធិស្ឋាន និងការ បម្រើអ្នកដទៃ ដឹកនាំ និងផ្តល់ឲ្យយើងនូវកម្លាំង ដើម្បីសម្រេចកិច្ចការកាន់តែច្រើន ជាងពេលដែលយើងធ្វើការតែម្នាក់ឯង។ គឺដូចពាក្យស្លោកមួយពោលថា «បើយើងនៅម្នាក់ឯង យើងម្នាក់ៗប្រៀបដូចជាទឹកមួយដំណក់ តែពេលណាយើងរួមគ្នា យើងជាមហាសមុទ្រ»។—Jennifer Benson Schuldt

តើអ្នកធ្វើការបម្រើព្រះបានល្អ ជាមួយអ្នកជឿដទៃទៀត នៅពេលណាខ្លះ? តើមានអ្វីជាមូលដ្ឋាននៃចំណងទាក់ទងខាងវិញ្ញាណ ដែលអ្នកមានជាមួយពួកគេ?

ឱព្រះអម្ចាស់ សូមព្រះអង្គបង្ហាញទូលបង្គំនូវរបៀបរួបរួមជាមួយអ្នកដទៃ ដែលកំពុងបម្រើព្រះអង្គ។

Daily Manna 2026_Content Enhance.indd 122 17/11/25 1:45 in the afternoon

អ្នកដែលបានទទួលពូជនៅក្នុងបន្ទា នោះគឺជាអ្នកដែលឮព្រះបន្ទូល រួចសេចក្តីខ្វល់ខ្វាយនៅជីវិតនេះ និងសេចក្តីឆបោករបស់ទ្រព្យសម្បត្តិមកខ្ទប់ព្រះបន្ទូលជាប់ មិនឲ្យពូជនោះកើតផលឡើយ (ម៉ាថាយ ១៣:២២)។

ដករុក្ខជាតិចង្រៃនៃការព្រួយបារម្ភចេញ

បន្ទាប់ពីខ្ញុំបានកប់គ្រាប់ពូជពីរបីគ្រាប់ក្នុងច្បារក្រោយផ្ទះខ្ញុំ ខ្ញុំក៏បានរង់ចាំមើលលទ្ធផល។ ខ្ញុំបានមើលអត្ថបទ ដែលបានបកស្រាយថា គ្រាប់ពូជទាំងនោះនឹងចេញពន្លក បន្ទាប់ពីបានកប់វាបានពី ១០ទៅ១៤ថ្ងៃ ហើយខ្ញុំក៏បានពិនិត្យមើលពួកវាជាញឹកញាប់ នៅពេលដែលខ្ញុំស្រោចទឹកពីលើដី។ មិនយូរប៉ុន្មាន ខ្ញុំក៏បានឃើញស្លឹកពណ៌បៃតងតូចៗពីរបីសន្លឹក ប្រឹងដុះចេញពីក្នុងដីមក។ ភាពសប្បាយរីករាយរបស់ខ្ញុំក៏បានរលាយទៅវិញយ៉ាងឆាប់រហ័ស នៅពេលដែលប្តីរបស់ខ្ញុំប្រាប់ខ្ញុំថា ពួកវាជារុក្ខជាតិចង្រៃទេ។ គាត់ក៏បានលើកទឹកចិត្តខ្ញុំឲ្យឆាប់ដកពួកវាចេញ ដើម្បីកុំឲ្យពួកវារាំងខ្ទប់រុក្ខជាតិ ដែលខ្ញុំកំពុងព្យាយាមដាំ។

ព្រះយេស៊ូវក៏បានមានបន្ទូលអំពីសារៈសំខាន់នៃការជម្នះឧបសគ្គ ដែលអាចរារាំងមិនឲ្យយើងលូតលាស់ខាងវិញ្ញាណ។ ព្រះអង្គក៏បានពន្យល់ជាពាក្យប្រៀបប្រដូច យ៉ាងដូចនេះថា៖ នៅពេលដែលកសិករព្រោះគ្រាប់ពូជរបស់គាត់មានគ្រាប់ពូជខ្លះ «ធ្លាក់ទៅកណ្តាលបន្លាៗក៏ដុះឡើងខ្ទប់ជិត» (ម៉ាថាយ ១៣:៧)។ គុម្ពបន្លា និងរុក្ខជាតិចង្រៃរាំងខ្ទប់រុក្ខជាតិល្អៗ មិនឲ្យលូតលាស់ (ខ.២២)។ ហើយការព្រួយបារម្ភក៏ពិតជារារាំងការលូតលាស់ខាងវិញ្ញាណរបស់យើង។ ការអានព្រះគម្ពីរ និងអធិស្ឋាន គឺជាវិធីសាស្ត្រដ៏ប្រសើរ ដើម្បីឲ្យជំនឿយើងមានការលូតលាស់ តែខ្ញុំចាំបាច់ត្រូវប្រុងប្រយ័ត្ន ចំពោះគុម្ពបន្លានៃការព្រួយបារម្ភ។ ពួកវា «រាំងខ្ទប់» ព្រះបន្ទូលដ៏ល្អ ដែលព្រះអង្គបានសាបព្រោះក្នុងខ្ញុំ ដោយធ្វើឲ្យខ្ញុំផ្តោតទៅលើបញ្ហាផ្សេងៗ។

ផលផ្លែខាងវិញ្ញាណដែលមានក្នុងព្រះគម្ពីរមានដូចជា សេចក្តីស្រឡាញ់ សេចក្តីអំណរ និងសន្តិភាពជាដើម (កាឡាទី ៥:២២)។ តែដើម្បីឲ្យយើងបង្កើតផលផ្លែទាំងនោះ យើងត្រូវពឹងផ្អែកកម្លាំងព្រះអង្គ ដើម្បីដករុក្ខជាតិចង្រៃនៃការព្រួយបារម្ភ ដែលអាចរំខានយើង និងបណ្តាលឲ្យយើងផ្តោតទៅលើអ្វីផ្សេង ក្រៅពីព្រះអង្គ។—Katara Patton

តើព្រះអង្គកំពុងជួយអ្នកបណ្តុះគ្រាប់ពូជ របស់អ្នកយ៉ាងដូចម្តេចខ្លះ? តើអ្នកអាចដករុក្ខជាតិចង្រៃនៃការព្រួយបារម្ភ ដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គក្រើនរំឭកទូលបង្គំ ឲ្យដករុក្ខជាតិចង្រៃចេញ ឲ្យបានញឹកញាប់ ដោយដកចេញការព្រួយបារម្ភ និងគំនិតដែលខូចអាក្រក់ ដើម្បីឲ្យទូលបង្គំអាចលូតលាស់ និងបង្កើតផលផ្លែក្នុងព្រះអង្គ។

Daily Manna 2026_Content Enhance.indd 123 17/11/25 1:45 in the afternoon

មើល អញចាត់ទេវតា១ឲ្យនាំមុខឯង ដើម្បីនឹងជួយទំនុកបំរុងឯងតាមផ្លូវ (និក្ខមនំ ២៣:២០)។

ព្រះអង្គចាត់ទេវតាឲ្យថែរក្សាយើង

អ្នក ស្រីបេវ (Bev) បានទៅពិនិត្យសុខភាពម្តងហើយម្តងទៀត ហើយមិនមានពេលគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការផ្សេងទៀត ដូចនេះគាត់មានអារម្មណ៍ថា ពិបាកខ្លាំងពេក ហើយក៏ហត់នឿយផង។ ក្រុមវេជ្ជបណ្ឌិតបានប្រាប់គាត់ថា ពួកគេកំពុងស្វែងរកមហារីក ក្នុងផ្នែកណាមួយនៃរូបកាយគាត់។ ការនេះបានធ្វើឲ្យគាត់ថប់បារម្ភ។ តែជារៀងរាល់ថ្ងៃ ពេលណាគាត់ងាកទៅរកព្រះអង្គ ឬអានព្រះគម្ពីរ ព្រះអង្គបានលើកទឹកចិត្តគាត់ ដោយសេចក្តីស្មោះត្រង់ ដោយព្រះវត្តមាន និងសន្តិភាពដ៏ស្ថិតស្ថេរ ដែលព្រះអង្គបានសន្យាប្រទាន។ គាត់បានតយុទ្ធនឹងភាពមិនច្បាស់លាស់ និងបានរៀនថ្វាយដង្វាយដល់ព្រះអង្គជាញឹកញាប់ នូវការថប់បារម្ភអំពីពេលអនាគត។ នៅពេលព្រឹកមួយនោះ មុនពេលការវះកាត់ធ្ងន់ធ្ងរមួយចាប់ផ្តើម អ្នកស្រី បេវ ក៏បានអានខគម្ពីរមួយក្នុងបទគម្ពីរនិក្ខមនំជំពូក២៣ ដែលបានចែងថា «មើល អញចាត់ទេវតា១ឲ្យនាំមុខឯង ដើម្បីនឹងជួយទំនុកបំរុងឯងតាមផ្លូវ» (ខ.២០)។

នេះជាពាក្យពេចន៍ដែលព្រះទ្រង់បានមានបន្ទូលតាមរយៈលោក ម៉ូសេ ទៅកាន់ពួកអ៊ីស្រាអែល ដែលជារាស្ត្រព្រះអង្គ។ កាលនោះ ព្រះអង្គកំពុងប្រទានក្រឹត្យវិន័យដល់រាស្ត្រព្រះអង្គ ឲ្យប្រព្រឹត្តតាម និងដឹកនាំពួកគេទៅកាន់ទឹកដីថ្មី (ខ.១៨-១៩)។ ប៉ុន្តែ នៅក្នុងពេលដែលព្រះអង្គបង្គាប់ពួកគេ ព្រះអង្គក៏បានប្រាប់ពួកគេថា ព្រះអង្គនឹងចាត់ទេវតាមួយអង្គ ឲ្យនាំមុខពួកគេ «ឲ្យការពារពួកគេនៅតាមផ្លូវ»។ ទោះជីវិតរបស់អ្នកស្រី បេវ មិនបានស្ថិតក្នុងស្ថានភាពដូចពួកគេក៏ដោយ ក៏គាត់បាននឹកចាំថា បទគម្ពីរផ្សេងទៀតក៏បានចែងអំពីទេវតា ដែលព្រះអម្ចាស់ចាត់ឲ្យមកថែរក្សារាស្ត្រព្រះអង្គផងដែរ។ គឺដូចដែលបទគម្ពីរ ទំនុកតម្កើង ៩១:១១ បានចែងថា «ដ្បិតទ្រង់នឹងបង្គាប់ដល់ពួកទេវតារបស់ទ្រង់ពីដំណើរឯង ឲ្យបានថែរក្សាឯងក្នុងគ្រប់ទាំងផ្លូវរបស់ឯង»។ ហើយបទគម្ពីរហេព្រើរ ១:១៤ បានប្រាប់យើងថា ព្រះទ្រង់ចាត់ទេវតាព្រះអង្គជា «វិញ្ញាណបម្រើ» ដើម្បីបម្រើអ្នកជឿព្រះយេស៊ូវ។

បើយើងបានទទួលជឿព្រះគ្រីស្ទ ព្រះអង្គក៏ចាត់ ទេវតាមួយអង្គ ឬច្រើនអង្គនៅក្បែរយើងសម្រាប់បម្រើយើងផងដែរ។—Anne Cetas

តើព្រះទ្រង់អាចធ្វើអ្វីខ្លះសម្រាប់អ្នក តាមរយៈទេវតារបស់ព្រះអង្គ? តើការដឹងដូចនេះបានលើកទឹកចិត្តអ្នកដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដ្បិតព្រះអង្គតែងតែគង់នៅក្បែរ ហើយព្រះអង្គក៏មានទេវតាមើលថែកូនព្រះអង្គផងដែរ។

Daily Manna 2026_Content Enhance.indd 124 17/11/25 1:45 in the afternoon

ដើម្បីអធិស្ឋានដោយព្រះវិញ្ញាណរាល់ពេលរាល់វេលា... សេចក្តីទូលអង្វរឲ្យពួកបរិសុទ្ធទាំងអស់ (អេភេសូរ ៦:១៨)។

អធិស្ឋាន ហើយចាំយាម

ពេលណាអ្នកជឿព្រះយេស៊ូវមានការតយុទ្ធក្នុងសង្គ្រាមខាងវិញ្ញាណ ពួកគេចាំបាច់ត្រូវមានចិត្តឆេះឆួលក្នុងការអធិស្ឋាន។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីម្នាក់នៅរដ្ឋផ្លរីដាបានជួបគ្រោះថ្នាក់ ដោយសារគាត់អធិស្ឋាន ដោយគ្មានការប្រុងប្រយ័ត្ន។ ថ្ងៃមួយ ពេលគាត់កំពុងបើកបររថយន្ត គាត់ក៏បានបិទភ្នែកអធិស្ឋាន។ គាត់មិនបានឈប់នៅត្រង់ចំណុចផ្លូវប្រសប់ ដែលមានផ្លាកសញ្ញាប្រាប់ឲ្យឈប់ ហើយក៏បានបើកចេញពីផ្លូវថ្នល់ដោយមិនដឹងខ្លួន ចូលទៅក្នុងទីធ្លាផ្ទះរបស់គេ។ បន្ទាប់មក គាត់ក៏បានព្យាយាមបើកថយក្រោយចេញពីទីធ្លានោះ តែមិនអាចចេញរួច។ គាត់មិនមានរបួស តែប៉ូលិសបានធ្វើការជាកពិន័យគាត់សម្រាប់ការបើកបរដោយការធ្វេសប្រហែស និងការបំផ្លាញទ្រព្យសម្បត្តិអ្នកដទៃ។ គាត់ជាអ្នកពូកែអធិស្ឋាន តែគាត់បានភ្លេចផ្នែកជាគន្លឹះនៃបទគម្ពីរ អេភេសូរ ៦:១៨ ដែលបានបង្រៀនឲ្យចាំយាម ឬមានការប្រុងប្រយ័ត្ន។

ការអធិស្ឋាន និងការចាំយាមជាផ្នែកមួយនៃគ្រឿងសឹកទាំងមូលដែលព្រះប្រទាន ដូចដែលសាវ័ក ប៉ុល បានលើកឡើង កណ្ឌគម្ពីរអេភេសូរជំពូក៦។ ទីមួយ យើងគួរតយុទ្ធនឹងសង្គ្រាមខាងវិញ្ញាណ ដោយការអធិស្ឋាន។ បានសេចក្តីថា យើងអធិស្ឋានក្នុងព្រះវិញ្ញាណ ដោយពឹងផ្អែកលើអំណាចនៃព្រះវិញ្ញាណ។ ហើយពឹងផ្អែកលើការដឹកនាំ និងឆ្លើយតបចំពោះការបណ្តាលចិត្តពីព្រះអង្គ ដោយអធិស្ឋាន គ្រប់កាលៈទេសៈ (ខ.១៨)។ ទីពីរ សាវ័ក ប៉ុល បានលើកទឹកចិត្តយើងឲ្យ "ចាំយាម"។ ការចាំយាមខាងវិញ្ញាណ អាចជួយយើងត្រៀមខ្លួនសម្រាប់ការយាងមកវិញរបស់ព្រះយេស៊ូវ (ម៉ាកុស ១៣:៣៣) ដោយមានជ័យជម្នះលើការល្បួង (១៤:៣៨) ហើយទូលអង្វរសម្រាប់អ្នកជឿដទៃទៀត (អេភេសូរ ៦:១៨)។

ខណៈពេលដែលយើងតយុទ្ធនឹងសង្គ្រាមខាងវិញ្ញាណជារៀងរាល់ថ្ងៃ ចូរឲ្យជីវិតរបស់យើង បានប្រកាន់ខ្ជាប់នូវ "ការអធិស្ឋាន និងការចាំយាម" ក្នុងការតយុទ្ធនឹងអំណាចនៃសេចក្តីអាក្រក់ ហើយចាក់ទម្លុះភាពងងឹតដោយពន្លឺនៃព្រះគ្រីស្ទ។—Marvin Williams

តើការមានផ្នត់គំនិតដែល «អធិស្ឋាន និងចាំយាម» បានជួយអ្នកតយុទ្ធនឹងសង្គ្រាមខាងវិញ្ញាណដូចម្តេចខ្លះ? តើការចាំយាម ឬមានការប្រុងប្រយ័ត្នខាងវិញ្ញាណ មានន័យដូចម្តេចចំពោះអ្នក?

ឱព្រះអង្គអើយ សូមព្រះអង្គជួយទូលបង្គំឲ្យចាំយាម និងអធិស្ឋានសម្រាប់ខ្លួនឯង និងអ្នកដទៃ។

Daily Manna 2026_Content Enhance.indd 125 17/11/25 1:45 in the afternoon

ឯយើងវិញ យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន (១យ៉ូហាន ៤:១៩)។

យើងមិនអាចស្រឡាញ់ ខ្លាំងជាងព្រះអង្គ

កាលពី ហ្សាវ៉ា (Xavier) កូនប្រុសរបស់ខ្ញុំ នៅរៀនក្នុងសាលាមត្តេយ្យ គាត់បានលាតសន្ធឹងដៃគាត់ ហើយនិយាយថា "កូនស្រឡាញ់ម៉ាក់ ធំប៉ុណ្ណេះ"។ ខ្ញុំក៏បានលាតសន្ធឹងដៃខ្ញុំ ហើយនិយាយថា "ម៉ាក់ស្រឡាញ់កូន ធំប៉ុណ្ណេះ"។ គាត់ក៏បានដាក់ដៃចុះ ហើយច្រត់ចង្កេះ រួចនិយាយថា "កូនស្រឡាញ់ម៉ាក់មុន"។ ខ្ញុំក៏បានគ្រវីក្បាល ហើយប្រាប់គាត់ថា "ម៉ាក់បានស្រឡាញ់កូនមុន តាំងពីពេលដែលព្រះអង្គដាក់កូនក្នុងផ្ទៃម្តាយ"។ ហ្សាវ៉ា ក៏បានបើកភ្នែកធំៗ "ម៉ាក់ឈ្នះហើយ" ខ្ញុំប្រាប់គាត់ថា "យើងឈ្នះទាំងអស់គ្នា ព្រោះព្រះយេស៊ូវស្រឡាញ់យើងមុន"។

សព្វថ្ងៃនេះ ហ្សាវ៉ា មានគ្រួសារហើយ។ ខណៈពេលដែលគាត់ត្រៀមខ្លួនសម្រាប់កំណើតកូនដំបូងរបស់គាត់ ខ្ញុំក៏បានអធិស្ឋានសូមឲ្យគាត់បានស្រឡាញ់កូនគាត់ខ្លាំងជាងកូនគាត់ស្រឡាញ់គាត់ ខណៈពេលដែលពួកគេបង្កើតអនុស្សាវរីយ៍ដ៏ផ្អែមល្ហែមជាមួយគ្នា។ ប៉ុន្តែ ខណៈពេលដែលខ្ញុំត្រៀមខ្លួនធ្វើជាជីដូន ខ្ញុំមានការភ្ញាក់ផ្អើល ពេលបានដឹងថា ខ្ញុំស្រឡាញ់ចៅប្រុសរបស់ខ្ញុំខ្លាំងប៉ុណ្ណា នៅពេលដែល ហ្សាវ៉ា ប្រាប់ខ្ញុំថា ភរិយាគាត់កំពុងមានផ្ទៃពោះ។

សាវ័ក យ៉ូហាន បានធ្វើការបញ្ជាក់ថា សេចក្តីស្រឡាញ់ដែលព្រះយេស៊ូវមានចំពោះយើងបានផ្តល់ឲ្យយើងនូវសមត្ថភាព ដើម្បីស្រឡាញ់ព្រះអង្គ និងអ្នកដទៃ (១យ៉ូហាន ៤:១៩)។ ការដឹងថា ព្រះអង្គស្រឡាញ់យើងបានផ្តល់ឲ្យយើងនូវទំនុកចិត្ត ដែលជួយឲ្យយើងមានទំនាក់ទំនងកាន់តែជ្រាលជ្រៅជាមួយព្រះអង្គ (ខ.១៥-១៧)។ ពេលណាយើងបានស្គាល់ជម្រៅនៃសេចក្តីស្រឡាញ់ ដែលព្រះអង្គមានចំពោះយើង (ខ.១៩) យើងអាចលូតលាស់ ក្នុងសេចក្តីស្រឡាញ់ ដែលយើងមានចំពោះព្រះអង្គ ហើយបង្ហាញសេចក្តីស្រឡាញ់របស់យើង ក្នុងទំនាក់ទំនងជាមួយអ្នកដទៃទៀត (ខ.២០)។ ព្រះយេស៊ូវមិនគ្រាន់តែបានប្រទានអំណាចយើង ឲ្យអាចស្រឡាញ់ តែក៏បានបង្គាប់យើងឲ្យស្រឡាញ់ គឺដូចមានសេចក្តីចែងមកថា "យើងបានទទួលបញ្ញត្តនេះពីព្រះមកថា អ្នកណាដែលស្រឡាញ់ដល់ព្រះ នោះត្រូវតែស្រឡាញ់ដល់បងប្អូនដែរ" (ខ.២១)។ ព្រះអង្គតែងតែមានសេចក្តីស្រឡាញ់លើសគេ។ ទោះយើងខំប្រឹងស្រឡាញ់ខ្លាំងប៉ុណ្ណា ក៏នៅតែមិនអាចស្រឡាញ់ច្រើនជាងព្រះអង្គស្រឡាញ់យើងបានឡើយ។—Xochitl Dixon

តើការដឹងថា ព្រះស្រឡាញ់អ្នកបានជួយអ្នកឲ្យស្រឡាញ់អ្នកដទៃដូចម្តេចខ្លះ? តើអ្នកអាចបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកដទៃនៅសប្តាហ៍នេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះសង្គ្រោះនៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានស្រឡាញ់ទូលបង្គំជាមុន ដើម្បីឲ្យទូលបង្គំអាចស្រឡាញ់អ្នកដទៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១ពង្សាវតារក្សត្រ ៨-៩ និងលូកា ២១:១-១៩

គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង (ម៉ាថាយ ២៨:១៨)។

ព្រះយេស៊ូវមិនប្រកាន់អតីតកាលរបស់យើង

បន្ទាប់ពីព្រះយេស៊ូវបានរំដោះកូនប្រុសខ្ញុំឈ្មោះ ចេហ្វ (Jeff) ឲ្យរួចផុតពីការញៀនថ្នាំ ខ្ញុំនៅតែមានការព្រួយបារម្ភអំពីគាត់។ យើងបានឆ្លងកាត់ការលំបាកជាច្រើនជាមួយគ្នា ហើយជួនកាលខ្ញុំនៅតែផ្តោតចិត្តទៅលើអតីតកាលដ៏ពិបាករបស់គាត់ ជាជាងផ្តោតចិត្តទៅលើអនាគតដែលព្រះទ្រង់បានរៀបចំសម្រាប់គាត់។ ឪពុកម្តាយដែលមានកូនញៀនថ្នាំ ច្រើនតែមានការព្រួយបារម្ភថា ពួកគេនឹងវិលត្រឡប់ទៅរកការសេពគ្រឿងញៀនទៀត ហើយថ្ងៃមួយក្នុងការជួបជុំគ្រួសារ ខ្ញុំក៏បានប្រាប់ចេហ្វថា «កូនកុំភ្លេច យើងមានខ្មាំងសត្រូវមួយ ហើយវាមានអំណាចខ្លាំងណាស់»។ គាត់ក៏បានឆ្លើយតបថា «បាទប៉ាខ្ញុំដឹងហើយ វាមានអំណាច តែវាមិនអាចគ្រប់គ្រងកូនបានទេ»។

ក្នុងពេលនោះ ខ្ញុំក៏បាននឹកចាំអំពីអំណាចរបស់ព្រះយេស៊ូវដែលបានជួយសង្គ្រោះយើង ឲ្យរួចពីបាប ហើយបានកែប្រែជីវិតយើង ពេលណាយើងមើលទៅព្រះអង្គ។ ភ្លាមៗនោះ ខ្ញុំក៏បាននឹកចាំពាក្យពេចន៍ដែលព្រះអង្គមានបន្ទូល ទៅកាន់សិស្សព្រះអង្គ មុនពេលព្រះអង្គជិតដល់ពេលយាងទៅព្រះវរបិតានៅស្ថានសួគ៌វិញ។ គឺដូចដែលព្រះអង្គមានបន្ទូលថា «គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង» (ម៉ាថាយ ២៨:១៨)។

ព្រះយេស៊ូវដែលបានសុគតនៅលើឈើឆ្កាង ហើយមានព្រះជន្មរស់ឡើងវិញ បានបើកផ្លូវឲ្យយើងចូលទៅរកព្រះអង្គ ទោះយើងមានអតីតកាលដូចម្តេចក៏ដោយ។ ព្រះអង្គគ្រប់គ្រងពេលអតីតកាល និងពេលអនាគតរបស់យើង។ ដោយសារព្រះអង្គបានសន្យាថា ព្រះអង្គនឹងគង់នៅជាមួយយើងជារៀងរហូត (ខ.២០) នោះយើងអាចទុកចិត្តថា ព្រះអង្គនឹងសម្រេចបំណងព្រះទ័យព្រះអង្គ ហើយជីវិតយើងស្ថិតក្នុងព្រះហស្តព្រះអង្គជានិច្ច។ ព្រះយេស៊ូវបានប្រទានយើងនូវក្តីសង្ឃឹម ប្រសើរជាងក្តីសង្ឃឹមទាំងអស់ ជាក្តីសង្ឃឹមដែលល្អយ៉ាងខ្លាំងចំពោះយើង បានជាយើងចង់ចែកចាយដល់អ្នកដទៃ។ អារក្ស និងលោកីយ៍អាចមានអំណាចតែមួយរយៈពេលប៉ុណ្ណោះ តែគ្រប់ទាំងអំណាច ជាកម្មសិទ្ធិរបស់ព្រះយេស៊ូវជារៀងរហូត។—James Banks

តើអំណាចរបស់ព្រះយេស៊ូវបានផ្តល់ឲ្យអ្នកនូវក្តីសង្ឃឹមដូចម្តេចខ្លះ? តើមានការអ្វីខ្លះដែលព្រះអង្គបានធ្វើសម្រាប់អ្នក ដែលអ្នកអាចចែកចាយដល់អ្នកដទៃ នៅថ្ងៃនេះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការត្រាស់ហៅទូលបង្គំឲ្យចូលមករកព្រះអង្គ ដោយសេចក្តីស្រឡាញ់។ សូមព្រះអង្គដឹកនាំទូលបង្គំទៅរកនរណាម្នាក់ ដែលទូលបង្គំអាចចែកចាយសេចក្តីស្រឡាញ់របស់ព្រះអង្គ ដល់ពួកគេនៅថ្ងៃនេះ។

Daily Manna 2026_Content Enhance.indd 127 17/11/25 1:45 in the afternoon

ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ (យ៉ូហាន ៣:១៦)។

ព្រះអាទិករដែលយើងអាចទុកចិត្ត

ក្នុងរឿង «មនុស្សចម្លែក» ក្នុងរឿងប្រឌិតគិនស្តាញ (Frankenstein) ដែលអ្នកស្រី ម៉ារី សេលី (Mary Shelley) បាននិពន្ធស្ថិតក្នុងចំណោមតួអង្គដែលគេបានស្គាល់ច្រើនជាងគេក្នុងរឿងនិទាន ដែលកើតចេញពីការស្រមើស្រមៃ ក្នុងវប្បធម៌បស្ចិមប្រទេស។ ក្នុងរឿងប្រលោមលោកដ៏ល្បីល្បាញនេះលោក វីចទ័រ ហ្វ្រែងគិនស្តាញ (Victor Frankenstein) ជាអ្នកវិទ្យាសាស្ត្រ ដែលមានការស្រមើស្រមៃបានបង្កើតមនុស្សចម្លែកនោះ ពីសាកសពរបស់មនុស្ស។ ប៉ុន្តែ អ្នកដែលចូលចិត្តអានរឿងប្រលោមលោក ដ៏ល្បីល្បាញនេះ ក៏បានដឹងផងដែរថា ភាគច្រើនគេអាចធ្វើការសន្និដ្ឋានថា អ្នកស្រី សេលី ពិតជាបានបង្ហាញធាតុពិតរបស់តួអង្គអ្នកវិទ្យាសាស្ត្ររូបនេះ ថាជាមនុស្សចម្លែកពិតប្រាកដ។ បន្ទាប់ ពីគាត់បានបង្កើតមនុស្សចម្លែកនោះ ឲ្យមានបញ្ញា គាត់បានបដិសេធន៍មិនព្រមស្តាប់ការណែនាំរបស់វា ក៏មិនព្រមរាប់រកវា ឬធ្វើឲ្យវាសង្ឃឹមថា វានឹងមានសុភមង្គលឡើយ។ អាកប្បកិរិយានេះហាក់ដូចជាកំពុងតែធ្វើឲ្យមនុស្សចម្លែកនោះ ធ្លាក់ចូលទៅក្នុងការបាក់ទឹកចិត្ត និងកំហឹង។ មនុស្សចម្លែកនោះក៏បានប្រឈមមុខដាក់លោក វិកទ័រ ដោយពោលទំនួញថា «ឱលោកដែលជាអ្នកបង្កើតខ្ញុំអើយ តើលោកនឹងបំផ្លាញខ្ញុំវិញយ៉ាងដោតជ័យ ដោយគ្មានក្តីអាណិតឬ»។

ព្រះគម្ពីរបានបង្ហាញឲ្យយើងដឹងថា ព្រះដែលជាអ្នកបង្កើតអ្វីៗគ្រប់យ៉ាង មានភាពខុសស្លែកយ៉ាងណាពីអ្នកវិទ្យាសាស្ត្រក្នុងរឿងប្រលោមលោកនេះ ដោយព្រះអង្គមានសេចក្តីស្រឡាញ់មិនចេះប្រែប្រួល និងមិនចេះនឿយណាយ ចំពោះស្នាព្រះហស្តរបស់ព្រះអង្គ។ ព្រះអង្គមិនមែនចេះតែបង្កើតអ្វីៗមក តែបានបង្កើតពិភពលោកដោយសេចក្តីស្រឡាញ់ ឲ្យមានភាពស្រស់ស្អាត (លោកុប្បត្តិ ១:៣១)។ ហើយសូម្បីតែនៅពេលដែលមនុស្សជាតិបានងាកបែរពីព្រះអង្គ ហើយជ្រើសរើសយកសេចក្តីអាក្រក់ ការប្តេជ្ញាព្រះទ័យ និងសេចក្តីស្រឡាញ់ដែលព្រះអង្គមានចំពោះពួកគេ នៅតែមិនប្រែប្រួល។

គឺដូចដែលព្រះយេស៊ូវបានពន្យល់លោក នីកូដេម ថា ព្រះអម្ចាស់មានសេចក្តីស្រឡាញ់ចំពោះមនុស្សខ្លាំងណាស់ បានជាព្រះអង្គស្ម័គ្រព្រះទ័យលះបង់ព្រះរាជបុត្រាតែមួយ ដែលព្រះអង្គស្រឡាញ់បំផុត (យ៉ូហាន ៣:១៦) ដើម្បីសង្គ្រោះមនុស្សជាតិឲ្យរួចពីបាប។ ព្រះយេស៊ូវបានលះបង់ព្រះជន្ម ដោយទទួលទោសនៃអំពើបាបរបស់យើង «ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (ខ.១៥)។ យើងមានព្រះអាទិករមួយអង្គ ដែលយើងអាចទុកចិត្ត អស់ពីចិត្ត និងជីវិតរបស់យើង។—Monica La Rose

តើអ្នកអាចឆ្លើយតបចំពោះសេចក្តីស្រឡាញ់របស់ព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះអង្គអើយ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានធ្វើជាព្រះអាទិករ ដែលទូលបង្គំអាចទុកចិត្ត។

Daily Manna 2026_Content Enhance.indd 128 17/11/25 1:45 in the afternoon

អញបានឮពាក្យអធិស្ឋានរបស់ឯង ក៏បានឃើញទឹកភ្នែកឯងហើយ មើល អញនឹងប្រោសឲ្យឯងបានជា (២ពង្សាវតាក្សត្រ ២០:៥)។

ការអធិស្ឋានតែងតែមានសារៈសំខាន់

នៅព្រះវិហារខ្ញុំ មានក្រុមការងារដែលទទួលសំណូមពរអធិស្ឋានផ្សេងៗ ពីសមាជិកពួកជំនុំ រៀងរាល់សប្តាហ៍ ដើម្បីឲ្យយើងអាចអធិស្ឋានឲ្យពួកគេម្នាក់ៗ ហើយសរសេរសំបុត្រផ្ញើទៅពួកគេផងដែរ។ ក្នុងចំណោមពួកគេ មានអ្នកខ្លះបានសំណូមពរឲ្យយើងអធិស្ឋានសូមព្រះអង្គប្រទានពរ សម្រាប់ការស្នែនក្បាលនៅមន្ទីរពេទ្យក្នុងពេលខាងមុខ។ អ្នកខ្លះសុំឲ្យយើងអធិស្ឋានឲ្យកូនពួកគេវិលត្រឡប់មកព្រះវិហារវិញ។ ហើយខ្លះទៀត សូមព្រះអង្គកម្សាន្តចិត្តលោក ដេវ (Dave) ដែលបានបាត់បង់ភរិយា។ ហើយមានសំណូមពរជាច្រើនរាប់មិនអស់ទៀត ដែលធ្វើឲ្យយើងមានអារម្មណ៍ថា យើងមិនមានពេលវេលាគ្រប់គ្រាន់ ដើម្បីអធិស្ឋានឲ្យពួកគេឲ្យបានគ្រប់គ្នា ហើយក៏មានអារម្មណ៍ថា គេមិនឲ្យតម្លៃមកលើការប្រឹងប្រែងរបស់យើង។ បញ្ហានេះមានការផ្លាស់ប្តូរ បន្ទាប់ពីខ្ញុំបានទទួលកាតថ្លែងអំណរគុណអស់ពីចិត្ត ពីលោក ដេវ ជាស្វាមីដែលប្រពន្ធទើបតែលាចាកលោកដោយគាត់បានភ្ជាប់ជាមួយដំណឹងមរណៈភាពរបស់ភរិយាគាត់ផងដែរ។ ពេលនោះ ខ្ញុំមានការយល់ដឹងជាថ្មីថា ការអធិស្ឋានឲ្យអ្នកដទៃនៅតែមានមានភាពចាំបាច់ទេ។

ព្រះយេស៊ូវបានធ្វើជាគំរូនៃការអធិស្ឋានជាទៀងទាត់អស់ពីចិត្ត និងដោយជំនឿពេញដោយក្តីសង្ឃឹម។ មុនពេលព្រះអង្គយាងឡើងស្ថានសួគ៌វិញ ព្រះអង្គបានដាក់អាទិភាពឲ្យការចេញទៅរកកន្លែងស្ងប់ស្ងាត់ដើម្បីអធិស្ឋាន (ម៉ាកុស ១:៣៥ ៦:៤៦ ១៤:៣២)។

រយៈពេលរាប់រយឆ្នាំ មុនពេលព្រះអង្គយាងមកប្រសូត ស្តេចអ៊ីស្រាអែលព្រះនាម ហេសេគា បានរៀនសូត្រអំពីមេរៀនដ៏សំខាន់នេះផងដែរ។ ទ្រង់ជ្រាបថា ទ្រង់នឹងសុគតដោយសារជំងឺក្នុងពេលដ៏ខ្លីខាងមុខ (២ពង្សាវតាក្សត្រ ២០:១)។ ទ្រង់ក៏បានព្រះកន្សែង ដោយព្រះទ័យសោកសៅយ៉ាងខ្លាំង តែទ្រង់ក៏បាន «បែរព្រះភក្ត្រទៅឯជញ្ជាំង អធិស្ឋានដល់ព្រះយេហូវ៉ា» (ខ.២)។ នៅពេលនោះ ព្រះអម្ចាស់ក៏បានឆ្លើយតបចំពោះទ្រង់ភ្លាមៗ។ ព្រះអង្គក៏បានប្រោសជំងឺរបស់ស្តេចហេសេគាឲ្យជា ដោយបន្ថែមអាយុឲ្យទ្រង់រស់នៅបាន១៥ឆ្នាំទៀត ហើយក៏បានសន្យាថា នឹងជួយសង្គ្រោះនគររបស់ទ្រង់ ឲ្យរួចផុតពីកងទ័ពខ្មាំងសត្រូវ (ខ.៥-៦)។ ព្រះអម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់ស្តេច ហេសេគា មិនមែនដោយសារទ្រង់បានរស់នៅក្នុងជីវិតដ៏ល្អនោះទេ តែដើម្បីថ្វាយព្រះកិត្តិនាមដល់អង្គទ្រង់ ហើយដោយយល់ដល់ស្តេច ដាវីឌ ជាអ្នកបម្រើព្រះអង្គ (ខ.៦)។ យើងមិនតែងតែទទួលការឆ្លើយតបសម្រាប់ការអធិស្ឋានរបស់យើងនោះទេ តែយើងអាចទុកចិត្តថា ព្រះអម្ចាស់កំពុងធ្វើការនៅក្នុង និងតាមរយៈការអធិស្ឋាននីមួយៗ។—Karen Pimpo

តើនរណាខ្លះត្រូវការឲ្យអ្នកអធិស្ឋានឲ្យ នៅថ្ងៃនេះ? តើអ្នកអាចរំឭកខ្លួនឯងដូចម្តេចខ្លះ ឲ្យឈប់បង្អង់សិន ដើម្បីអធិស្ឋានឲ្យបានញឹកញាប់?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានស្តាប់ទូលបង្គំអធិស្ឋាន។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១ពង្សាវតាក្សត្រ ១៤-១៥ និងលូកា ២២:២១-៤៦

តែវេលាណាដែលទូលបង្គំភ័យ នោះទូលបង្គំនឹងទុកចិត្តដល់ទ្រង់ (ទំនុកតម្កើង ៥៦:៣)។

ជម្នះទុក្ខលំបាក ដោយសេចក្តីជំនឿ

ការពិនិត្យសុខភាពជាទៀងទាត់ សម្រាប់ក្មេងប្រុសអាយុ៨ឆ្នាំម្នាក់ឈ្មោះ កាល់វីន (Calvin) បានបន្សល់ទុកស្លាកស្នាមមួយចំនួន នៅលើរូបកាយគាត់ដែលគេមិននឹកស្មានដល់។ ក្នុងអំឡុងពេលនៃការជួបគ្រូពេទ្យ គេបានចាក់ថ្នាំឲ្យគាត់ពីរបីម្តង ហើយគេក៏បានបិទបង់ស្អិតពីលើកន្លែងចាក់ឆ្នាំនោះ។ កាលពួកគេដល់ពេលត្រូវបកបង់ស្អិតនៅផ្ទះ កាល់វីន ក៏បានបញ្ចេញសម្លេងយំ ដោយការភ័យខ្លាច។ បុរសជាឪពុកក៏បានព្យាយាមលួងកូនប្រុសគាត់ ដោយនិយាយថា «កាល់វីន កូនដឹងហើយថា ប៉ាមិនដែលធ្វើការអាក្រក់មកលើកូនទេ»។ បុរសជាឪពុកចង់ឲ្យកូនប្រុសខ្លួនទុកចិត្តគាត់ ជាជាងខ្លាចការឈឺចាប់ក្នុងការបកបង់ស្អិតចេញ។

មិនមែនមានតែក្មេង។អាយុ៨ឆ្នាំទេ ដែលមានការភ័យខ្លាច នៅចំពោះមុខនៃការឈឺចាប់។ ការរះកាត់ ការបែកបាក់ពីមនុស្សជាទីស្រឡាញ់ បញ្ហាផ្លូវចិត្ត និងបញ្ហាប្រឈមផ្សេងទៀត គឺសុទ្ធតែបណ្តាលឲ្យយើងមានការភ័យខ្លាច ដកដង្ហើមធំ សោកសង្រេង និងតូញតែរ។

ស្តេច ដាវីឌ ក៏ធ្លាប់ស្ថិតក្នុងពេលភ័យខ្លាចជាច្រើនដង។ មានពេលមួយនោះ ទ្រង់បានរត់ចូលទឹកដីរបស់សាសន៍ភីលីស្ទីន ខណៈពេលដែលទ្រង់រត់គេចពីស្តេចសូលដែលមានការច្រណែនឈ្នានីស។ នៅពេលដែលសាសន៍ភីលីស្ទីនមើលទ្រង់ស្គាល់ ទ្រង់មានការថប់បារម្ភ ចំពោះគ្រោះថ្នាក់ដែលអាចកើតមានចំពោះទ្រង់ (មើល ១សាំយ៊ូអែល ២១:១០-១១) ទ្រង់មានការភ័យខ្លាចយ៉ាងខ្លាំង ចំពោះស្តេច អ័គីស ជាស្តេចក្រុងកាថ (ខ.១២)។ នៅពេលដែលទ្រង់នឹកចាំអំពីពេលដ៏ពិបាកនោះ ទ្រង់ក៏បានតែងជាទំនុកតម្កើងថា «តែវេលាណាដែលទូលបង្គំភ័យ នោះទូលបង្គំនឹងទុកចិត្តដល់ទ្រង់... គឺសេចក្តីពឹងពាក់របស់ទូលបង្គំ នោះបានទុកនៅក្នុងព្រះ ទូលបង្គំនឹងមិនខ្លាចឡើយ តើសាច់ឈាមនឹងអាចធ្វើអ្វីដល់ទូលបង្គំបាន» (ទំនុកតម្កើង ៥៦:៣-៤)។

តើយើងគួរធ្វើដូចម្តេច នៅពេលដែលទុក្ខលំបាកក្នុងជីវិត ធ្វើឲ្យយើងមានការភ័យខ្លាច? ពេលនោះ យើងអាចទុកចិត្តលើព្រះវរបិតារបស់យើង ដែលគង់នៅស្ថានសួគ៌។—Arthur Jackson

តើមានទុក្ខលំបាកអ្វីខ្លះ ដែលកំពុងតែធ្វើឲ្យអ្នកមានការភ័យខ្លាចក្នុងពេលបច្ចុប្បន្ន? តើអ្នកអាចសម្រាកក្នុងការថែរក្សារបស់ព្រះអង្គដូចម្តេចខ្លះ ខណៈពេលដែលអ្នកនាំការភ័យខ្លាចមកថ្វាយ នៅចំពោះព្រះវរបិតារបស់អ្នក ដែលគង់នៅស្ថានសួគ៌ ដោយការអធិស្ឋាន?

ឱព្រះអង្គអើយ ទូលបង្គំមានការភ័យខ្លាចនៅក្នុងសាច់ឈាម និងភាពផុយស្រួយរបស់ទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំឲ្យមើលឃើញ និងដកពិសោធន៍នឹងសេចក្តីស្រឡាញ់ និងការថែរក្សារបស់ព្រះអង្គ ក្នុងពេលដែលទូលបង្គំជួបការល្បងល និងទុក្ខលំបាក។

Daily Manna 2026_Content Enhance.indd 130 17/11/25 1:45 in the afternoon

គេនឹងមកដោយទឹកភ្នែក និងពាក្យទូលអង្វរ អញនឹងនាំមុខគេ ហើយដំរង់គេដើរទៅក្បែរមាត់ទន្លេ (យេរេមា ៣១:៩)។

ទឹកភ្នែកនៃក្តីអំណរ

ថ្ងៃមួយនៅពេលដែលលោក ឌីន (Dean) ចេញពីផ្ទះ គាត់ក៏បានឃើញមិត្តភក្តិគាត់មួយចំនួនកំពុងរង់ចាំគាត់នៅក្រៅផ្ទះ ដោយមានដៃកាន់ប៉ែងប៉ោងហោះ។ មិត្តភក្តិគាត់ម្នាក់ឈ្មោះ ចស (Josh) ក៏បានដើរចេញមក ហើយក៏បានប្រាប់គាត់ថា ពួកគេបានយកបទកំណាព្យរបស់គាត់ទៅចូលរួមក្នុងការប្រកួតមួយ។ រួចលោក ចស ក៏បានប្រគល់ស្រោមសំបុត្រទៅគាត់។ នៅក្នុងស្រោមសំបុត្រនោះ គាត់ក៏បានឃើញកាតមួយសន្លឹក ដែលមានអក្សរសរសេរពីលើថា «រង្វាន់សម្រាប់ជ័យលាភីលេខ១» ហើយមិនយូរប៉ុន្មាន ពួកគេម្នាក់ៗក៏បានអបអរគាត់ ដោយចិត្តរំភើបរីករាយរហូតចេញទឹកភ្នែក។ មិត្តភក្តិរបស់លោក ឌីន បានធ្វើនូវរឿងដ៏មានន័យ ដោយបានបញ្ជាក់ឲ្យគេដឹងថា គាត់ពិតជាមានអំណោយទានផ្នែកតែងនិពន្ធ។

ការអរសប្បាយរហូតដល់ស្រក់ទឹកភ្នែក គឺជាបទពិសោធន៍ដែលយើងប្រហែលពិបាកយល់។ តាមធម្មតា ការស្រក់ទឹកភ្នែកគឺជាការឆ្លើយតប ចំពោះការឈឺចាប់ មិនមែនក្តីអំណរនោះទេ ហើយក្តីអំណរបង្ហាញចេញមក ដោយការសើចសប្បាយ មិនមែនដោយទឹកភ្នែកទេ។ អ្នកចិត្តសាស្ត្រជាជនជាតិអ៊ីតាលីម្នាក់បានកត់សម្គាល់ឃើញថា ទឹកភ្នែកនៃក្តីអំណរកើតមាន នៅពេលដែលយើងមានការប៉ះពាល់ចិត្តផ្ទាល់ខ្លួនក្នុងលក្ខណៈស៊ីជម្រៅ ដែលមានដូចជាពេលដែលយើងមានអារម្មណ៍ថា គេស្រឡាញ់យើងខ្លាំង ឬយើងបានសម្រេចគោលដៅដ៏សំខាន់មួយ។ ការនេះនាំឲ្យពួកគេសន្និដ្ឋានថា ទឹកភ្នែកនៃក្តីអំណរ កំពុងចង្អុលបង្ហាញយើងឲ្យជញ្ជឹងគិតអំពីអត្ថន័យរបស់ជីវិតយើង។

ខ្ញុំយល់ឃើញថា ទឹកភ្នែកនៃក្តីអំណរកើតមាន នៅកន្លែងណាក៏ដោយដែលព្រះយេស៊ូវបានយាងទៅដល់។ តើឪពុកម្តាយរបស់បុរសដែលពិការភ្នែកពីកំណើត អាចទប់ទឹកភ្នែកបានទេ នៅពេលដែលព្រះយេស៊ូវបានប្រោសភ្នែកគាត់ឲ្យជា (យ៉ូហាន ៩:១-៩)។ ពុំនោះទេ តើនាង ម៉ារា និងនាង ម៉ាថា អត់ទប់ទឹកភ្នែកបានទេ នៅពេលដែលព្រះអង្គប្រោសប្អូនប្រុសគាត់ឲ្យរស់ឡើងវិញ (១១:៣៨-៤៤)? នៅគ្រាដែលព្រះទ្រង់នាំរាស្ត្រព្រះអង្គ ចូលទៅក្នុងពិភពលោក ដែលព្រះអង្គបានស្តាឲ្យល្អឡើងវិញ ព្រះអង្គមានបន្ទូលថា ទឹកភ្នែកនៃក្តីអំណរនឹងធ្លាក់ចុះពីលើថ្ពាល់របស់ពួកគេ ហើយព្រះអង្គនឹងដឹកនាំពួកគេត្រឡប់ទៅផ្ទះវិញ ដោយយកព្រះទ័យទុកដាក់ចំពោះពួកគេយ៉ាងខ្លាំង (យេរេមា ៣១:៩)។

បើទឹកភ្នែកនៃក្តីអំណរបានចង្អុលបង្ហាញយើង ឲ្យពិចារណាអំពីអត្ថន័យរបស់ជីវិត សូមយើងស្រមៃអំពីថ្ងៃដ៏ប្រសើរបំផុត ដែលនឹងមកដល់។ នៅពេលនោះ ទឹកភ្នែកនៃក្តីអំណរនឹងហូរធ្លាក់ចុះមកលើថ្ពាល់យើង ហើយយើងនឹងដឹងច្បាស់ថា ជីវិតយើងមានន័យ គឺនៅពេលដែលយើងបានរស់នៅដោយការប្រកបជិតស្និទ្ធជាមួយព្រះអង្គ។

—Sheridan Voysey

តើអ្នកធ្លាប់ស្រក់ទឹកភ្នែកនៃក្តីអំណរ នៅពេលចុងក្រោយបំផុត នៅពេលណា? តើអ្នកយល់ឃើញថា ជីវិតមានន័យ មានលក្ខណៈដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការត្រៀមក្តីអំណរ សម្រាប់ប្រទានដល់អ្នកដែលស្រឡាញ់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយេះពេល១ឆ្នាំ | ១ពង្សាវតារក្សត្រ ១៩-២០ និងលូកា ២៣:១-២៥

អ្នកណាដែលមានបញ្ញត្តរបស់ខ្ញុំ ហើយកាន់តាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ ឯអ្នកណាដែលស្រឡាញ់ខ្ញុំ នោះជាទីស្រឡាញ់នៃព្រះវរបិតាខ្ញុំហើយ (យ៉ូហាន ១៤:២១)។

ការស្តាប់បង្គាប់ដោយសេចក្តីស្រឡាញ់

ក្នុងអំឡុងពេលកម្មវិធីមង្គលការរបស់ខ្ញុំ គ្រូគង្វាលដែលបានផ្សំផ្គុំខ្ញុំ និងស្វាមីខ្ញុំបានសួរខ្ញុំថា «តើអ្នកសន្យាថា នឹងស្រឡាញ់ គោរព និងស្តាប់បង្គាប់ស្វាមីរបស់អ្នក រហូតអស់មួយជីវិតទេ?» ពេលនោះ ខ្ញុំក៏បានមើលមុខស្វាមីខ្ញុំ ដោយនិយាយខ្សឹបៗថា «តើខ្ញុំត្រូវស្តាប់បង្គាប់គាត់ឬ?» យើងកសាងទំនាក់ទំនងរបស់យើង ផ្អែកទៅលើសេចក្តីស្រឡាញ់ និងការគោរព មិនមែនដោយការស្តាប់បង្គាប់ដោយគ្មានការពិចារណា ដូចពាក្យសច្ចានោះទេ។ ឪពុកក្មេកខ្ញុំក៏បានថតរូបវីដេអូជាប់ទិដ្ឋភាពដែលខ្ញុំបើកភ្នែកធំៗ ខណៈពេលដែលខ្ញុំកំពុងពិចារណាអំពីពាក្យស្តាប់បង្គាប់ រួចខ្ញុំនិយាយថា «ចាស ខ្ញុំយល់ព្រម»។

ប៉ុន្មានឆ្នាំក្រោយមក ព្រះអម្ចាស់ក៏បានបង្ហាញឲ្យខ្ញុំដឹងថា ការប្រឆាំងរបស់ខ្ញុំចំពោះពាក្យ ស្តាប់បង្គាប់ គឺមិនមានជាប់ទាក់ទងអ្វីនឹងទំនាក់ទំនងដ៏ស្មុគស្មាញរវាងប្តីនិងប្រពន្ធនោះទេ។ កាលពីមុនខ្ញុំយល់ឃើញថា ការស្តាប់បង្គាប់ គឺជា «ការស្ថិតក្រោមការគ្រប់គ្រង» ឬ «ការបង្ខំឲ្យចុះចូល» តែព្រះគម្ពីរមិនបានបង្រៀនដូចនេះទេ។ ផ្ទុយទៅវិញ ពាក្យស្តាប់បង្គាប់ក្នុងព្រះគម្ពីរ គឺបានបង្ហាញអំពីសេចក្តីស្រឡាញ់ដែលយើងអាចមានចំពោះព្រះ តាមរបៀបជាច្រើន។ ខណៈពេលដែលខ្ញុំ និងស្វាមីខ្ញុំអបអរខួបទី៣០ឆ្នាំ នៃអាពាហ៍ពិពាហ៍របស់យើង យើងនៅតែរៀនស្រឡាញ់ព្រះយេស៊ូវ និងស្រឡាញ់គ្នាទៅវិញទៅមក ដោយអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។

នៅពេលដែលព្រះយេស៊ូវមានបន្ទូលថា «អ្នកណាដែលមានបញ្ញត្តរបស់ខ្ញុំ ហើយកាន់តាម គឺអ្នកនោះហើយដែលស្រឡាញ់ខ្ញុំ» (យ៉ូហាន ១៤:១៥) គឺព្រះអង្គកំពុងបង្ហាញយើងថា ការស្តាប់បង្គាប់តាមបទគម្ពីរ គឺកើតចេញពីទំនាក់ទំនងដែលមានសេចក្តីស្រឡាញ់ និងភាពជិតស្និទ្ធជាមួយព្រះអង្គ (ខ.១៦-២១)។

សេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ គ្មានភាពអាត្មានិយម គ្មានលក្ខខណ្ឌ និងមិនដែលបង្ខំ ឬមានការបំពានឡើយ។ ពេលណាយើងដើរតាម និងថ្វាយព្រះកិត្តិនាមដល់ព្រះអង្គក្នុងទំនាក់ទំនងគ្រប់ប្រភេទរបស់យើង ព្រះវិញ្ញាណបរិសុទ្ធអាចជួយយើង ឲ្យយល់ថា ការស្តាប់បង្គាប់ព្រះអង្គគឺជាទង្វើនៃការទុកចិត្ត និងថ្វាយបង្គំព្រះ ដោយប្រាជ្ញា និងសេចក្តីស្រឡាញ់។—Xochitl Dixon

តើទស្សនរបស់អ្នកអំពីការស្តាប់បង្គាប់ព្រះមានការផ្លាស់ប្តូរយ៉ាងណាខ្លះ នៅពេលដែលអ្នកបានដឹងថា ការស្តាប់បង្គាប់ព្រះ ជាសកម្មភាពនៃសេចក្តីស្រឡាញ់ និងការទុកចិត្តព្រះអង្គ? តើព្រះអម្ចាស់បានបង្ហាញថា អ្នកអាចទុកចិត្តព្រះអង្គ ដោយផ្អែកទៅលើអ្វីខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យស្រឡាញ់ព្រះអង្គ និងអ្នកដទៃ តាមរយៈការស្តាប់បង្គាប់តាមបទគម្ពីរ។

ដូច្នេះ ដែលមានអំណោយទានផ្សេងពីគ្នា តាមព្រះគុណដែលផ្តល់មកយើង ទោះបើជាសេចក្តីទំនាយ នោះក៏ត្រូវទាយតាមខ្នាតនៃសេចក្តីជំនឿ (រ៉ូម ១២:៦)។

បុគ្គលិកលក្ខណៈ និងអំណោយទានដែលព្រះប្រទាន

កាលប៉ុន្មានទសវត្សរ៍មុន ខ្ញុំបានទៅចូលរួមដំណើរកម្សាន្តមួយរបស់និស្សិតមហាវិទ្យាល័យ ដែលនៅពេលនោះ ម្នាក់ៗសុទ្ធតែនិយាយអំពីការធ្វើតេស្តបុគ្គលិកលក្ខណៈរបស់អ្នកចូលរួម។ ក្នុងចំណោមពួកគេមានអ្នកខ្លះថា ពួកគេមានបុគ្គលិកលក្ខណៈបែបនេះ ហើយខ្លះទៀតថាបែបនោះ។ ខ្ញុំក៏បាននិយាយកំប្លែងជាមួយពួកគេ អំពីបុគ្គលិកលក្ខណៈរបស់ខ្ញុំ។

ចាប់តាំងពីពេលនោះមក ខ្ញុំបានរៀនសូត្រច្រើន អំពីការធ្វើតេស្តនោះ និងការធ្វើតេស្តដទៃទៀត ដែលមានដូចជាការធ្វើតេស្តបុគ្គលិកលក្ខណៈភាពជាអ្នកដឹកនាំជាដើម។ ខ្ញុំយល់ឃើញថា ការធ្វើតេស្តទាំងនោះមានលក្ខណៈគួរឲ្យចាប់អារម្មណ៍ណាស់ ព្រោះពួកវាអាចជួយយើង ឲ្យយល់អំពីខ្លួនឯង និងអ្នកដទៃ តាមរបៀបដែលមានប្រយោជន៍ និងបើកបង្ហាញឲ្យយើងដឹងអំពីចំណង់ចំណូលចិត្ត ចំណុចខ្លាំង និងចំណុចខ្សោយរបស់យើង។ ដរាបណាយើងមិនផ្តោតទៅលើពួកវាខ្លាំងពេក យើងអាចប្រើពួកវាជាឧបករណ៍មានប្រយោជន៍ ដែលព្រះអម្ចាស់ប្រើ ដើម្បីជួយយើងឲ្យមានការលូតលាស់។

ព្រះគម្ពីរមិនបានផ្តល់ឲ្យយើងនូវការធ្វើតេស្តបុគ្គលិកលក្ខណៈរបស់យើង ប៉ុន្តែព្រះគម្ពីរពិតជាបានបញ្ជាក់អំពីលក្ខណៈពិសេសរបស់មនុស្សម្នាក់ៗក្នុងព្រះនេត្រព្រះ (មើលទំនុកតម្កើង ១៣៩:១៤-១៦ យេរេមា ១:៥) ហើយបង្ហាញយើង អំពីរបៀបដែលព្រះទ្រង់ប្រទានយើងម្នាក់ៗនូវបុគ្គលិកលក្ខណៈ និងអំណោយទានពិសេសរៀងខ្លួន ដើម្បីបម្រើអ្នកដទៃ ក្នុងនគរព្រះអង្គ។ ហេតុនេះហើយ ក្នុងបទគម្ពីរ រ៉ូម ១២:៦ សាវ័កប៉ុលបានបង្រៀនយើងថា យើង «មានអំណោយទានផ្សេងពីគ្នា តាមព្រះគុណដែលផ្តល់មកយើង»។

គាត់ក៏បានពន្យល់ថា អំណោយទានទាំងនោះ មិនមែនសម្រាប់ឲ្យយើងប្រើដើម្បីតែខ្លួនយើងនោះទេ តែដើម្បីបម្រើរាស្ត្ររបស់ព្រះ ដែលជារូបកាយព្រះគ្រីស្ទ (ខ.៥)។ អំណោយទានទាំងនោះ បានបង្ហាញព្រះគុណ និងសេចក្តីល្អរបស់ព្រះអង្គ ដែលធ្វើការ នៅក្នុង និងតាមរយៈយើងរាល់គ្នា ហើយក៏បានអញ្ជើញយើងម្នាក់ៗ ឲ្យរស់នៅជាឧបករណ៍ដ៏ពិសេស នៅក្នុងការធ្វើការបម្រើព្រះអង្គ។—Adam R. Holz

តើទស្សនរបស់អ្នកអំពីការស្តាប់បង្គាប់ព្រះមានការផ្លាស់ប្តូរយ៉ាងណាខ្លះ នៅពេលដែលអ្នកបានដឹងថា ការស្តាប់បង្គាប់ព្រះ ជាសកម្មភាពនៃសេចក្តីស្រឡាញ់ និងការទុកចិត្តព្រះអង្គ? តើព្រះអម្ចាស់បានបង្ហាញថា អ្នកអាចទុកចិត្តព្រះអង្គ ដោយផ្អែកទៅលើអ្វីខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់អំណោយដែលព្រះអង្គបានប្រទានទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យឱបក្រសោបយករបៀបដែលព្រះអង្គបានជួយទូលបង្គំឲ្យស្រឡាញ់ និងបម្រើអ្នកដទៃ ក្នុងនគរព្រះអង្គ។

គម្រោងអានព្រះគម្ពីរយេ:ពេល១ឆ្នាំ | ២ពង្សាវតារក្សត្រ ១-៣ និងលូកា ២៤:១-៣៥

នោះអេលីសេក៏អធិស្ឋានថា «ឱព្រះយេហូវ៉ាអើយ សូមទ្រង់ប្រោសឲ្យភ្នែកវាបានមើលឃើញ» (២ពង្សាវតាក្សត្រ ៦:១៧)។

បុគ្គលិកលក្ខណៈ និងអំណោយទានដែលព្រះប្រទាន

អ្នកស្រី ជយ (Joy) មានការខ្វល់ខ្វាយអំពីអ្នកស្រី ស៊ែនឌី (Sandy) ជាសាច់ញាតិរបស់គាត់ ដែលកំពុងតយុទ្ធនឹងការញៀនស្រា និងជំងឺផ្លូវចិត្តអស់ជាច្រើនឆ្នាំហើយ។ នៅពេលគាត់ទៅផ្ទះរបស់អ្នកស្រី ស៊ែនឌី គាត់ឃើញទ្វារចាក់សោរជាប់ ហើយហាក់ដូចជាមិនមានមនុស្សរស់នៅ។ នៅពេលដែលគាត់ និងអ្នកដទៃទៀតមានគម្រោងស្វែងរកអ្នកស្រី ស៊ែនឌី គាត់ក៏បានអធិស្ឋានថា «ឱព្រះអង្គអើយ សូមព្រះអង្គជួយទូលបង្គំឲ្យមើលឃើញអ្វីដែលទូលបង្គំមើលមិនឃើញ»។ ខណៈពេលដែលពួកគេកំពុងចាក់ចេញ អ្នកស្រី ជយ ក៏បានក្រឡេកមកក្រោយ មើលទៅផ្ទះរបស់អ្នកស្រី ស៊ែនឌី ហើយក៏បានឃើញវាំងននមានចលនាកំរើកតិចៗ។ នៅពេលនោះ គាត់ដឹងថា អ្នកស្រី ស៊ែនឌីនៅមានជីវិតទេ។ ក្រុមសង្គ្រោះបន្ទាន់ក៏បានមកជួយគាត់ទាន់ពេលវេលា ហើយអ្នកស្រី ជយ មានអំណរណាស់ ដែលព្រះអង្គបានឆ្លើយតបការអធិស្ឋានរបស់គាត់។

ហោរាអេលីសេបានដឹងអំពីអំណាចនៃការទូលសូមព្រះអម្ចាស់ បង្ហាញការពិតដល់គាត់។ នៅពេលដែលកងទ័ពនគរស៊ីរីបានឡោមព័ទ្ធទីក្រុងរបស់ពួកគេ អ្នកបម្រើរបស់ហោរាអេលីសេ ក៏បានញ័រខ្លួន ដោយការភ័យខ្លាច។ ទោះជាយ៉ាងណាក៏ដោយ អ្នកបម្រើព្រះរូបនេះមិនមានការភ័យខ្លាចឡើង ព្រោះព្រះអង្គក៏បានជួយឲ្យគាត់មើលឃើញអ្វីដែលគេមើលមិនឃើញ។ លោក អេលីសេក៏បានអធិស្ឋានឲ្យព្រះអង្គបើកភ្នែកអ្នកបម្រើគាត់ ឲ្យមើលឃើញទិដ្ឋភាពពិតដែលកំពុងកើតឡើង ហើយព្រះអង្គក៏បើកភ្នែកអ្នកបំរើនោះ ឲ្យគាត់ក៏មើលទៅឃើញភ្នំនោះ មានពេញដោយពលសេះ និងរទេះចំបាំង ដែលសុទ្ធតែជាភ្លើង នៅព័ទ្ធជុំវិញអេលីសេ» (២ពង្សាវតាក្សត្រ ៦:១៧)។

ព្រះអម្ចាស់ក៏បានដកការបាំងនៅចន្លោះពិភពខាងវិញ្ញាណ និងពិភពខាងសាច់ឈាម ឲ្យលោក អេលីសេ និងអ្នកបម្រើគាត់មើលឃើញរឿងពិតដែលកំពុងកើតមាន។ អ្នកស្រី ជយ ជឿថា ព្រះអម្ចាស់បានជួយគាត់ឲ្យមើលឃើញវាំងននមានចលនាតិចៗ ធ្វើឲ្យគាត់មានសង្ឃឹមឡើង។ យើងក៏អាចទូលសូមព្រះអង្គ ឲ្យប្រទានយើងនូវការមើលឃើញខាងវិញ្ញាណ ដើម្បីឲ្យយើងអាចដឹងថា មានអ្វីខ្លះកំពុងកើតឡើងចំពោះយើង ទោះក្នុងជីវិតមនុស្សជាទីស្រឡាញ់ ឬក្នុងសហគមន៍របស់យើងក្តី។ ហើយយើងក៏អាចធ្វើជាឧបករណ៍នៃសេចក្តីស្រឡាញ់ សេចក្តីពិត និងសេចក្តីអាណិតរបស់ព្រះអង្គផងដែរ។—Amy Boucher Pye

តើអ្នកអាចអធិស្ឋានដូចម្តេចខ្លះ ដើម្បីសូមព្រះអង្គបើកភ្នែកអ្នក ឲ្យមើលឃើញសេចក្តីពិតរបស់ព្រះអង្គក្នុងស្ថានភាពដែលធ្វើឲ្យអ្នកបាក់ទឹកចិត្ត? តើព្រះអង្គបានបើកបង្ហាញការពិតដូចម្តេចខ្លះ ឲ្យអ្នកបានដឹងកាលពីពេលកន្លងទៅ?

ឱព្រះវរបិតានៃសេចក្តីមេត្តា សូមព្រះអង្គបើកភ្នែកទូលបង្គំ ឲ្យមើលឃើញសេចក្តីស្រឡាញ់ និងព្រះគុណរបស់ព្រះអង្គ ដែលទូលបង្គំអាចចែករំលែកជាមួយអ្នកដទៃ។

គម្រោងអានព្រះគម្ពីរប្រចាំឆ្នាំ ១ឆ្នាំ | ២ពង្សាវតាក្សត្រ ៤-៦ និងលូកា ២៤:៣៦-៥៣

ទីរហោស្ថាន ហើយទីហួតហែង នឹងមានសេចក្តីអំណរ ឯសមុទ្រខ្សាច់ នឹងរីកពាយ ហើយផ្កាឡើង ដូចជាកុលាប (អេសាយ ៣៥:១)។

ធ្វើឲ្យវាលរហោស្ថានមានផ្ការីក

កាលពីជាងមួយរយឆ្នាំមុន ព្រៃឈើបានគ្របដណ្តប់ផ្ទៃដីរបស់ប្រទេសអេត្យូពី ប្រហែល៤០ភាគរយ ប៉ុន្តែសព្វថ្ងៃនេះ ប្រទេសនេះ មានព្រៃឈើនៅសល់តែ៤ភាគរយនៃផ្ទៃដីសរុបប៉ុណ្ណោះ។ ការកាប់ឆ្ការព្រៃធ្វើកសិកម្ម ដោយមិនបានអភិរក្សព្រៃឈើ បានបណ្តាលឲ្យមានវិបត្តិអេកូឡូស៊ីធ្ងន់ធ្ងរ។ ភាគច្រើននៃព្រៃឈើតូចៗដែលនៅសល់ ស្ថិតនៅក្រោមការការពាររបស់ពួកជំនុំ។ អស់ជាច្រើនឆ្នាំមកហើយ ដែលពួកជំនុំតៅហ៊ីដូ ជាពួកជំនុំអ័រតូដុកអេត្យូពី បានថែរក្សាព្រៃឈើតូចៗទាំងនោះ នៅក្នុងកណ្តាលវាលរហោស្ថាន ដែលសួតហួតហែង។ បើអ្នកមើលរូបដែលគេថតពីលើយន្តហោះមក អ្នកអាចឃើញបណ្តុំព្រៃឈើ ប្រៀបដូចជាកោះតូចៗដែលមានពណ៌បៃតងស្រស់ នៅកណ្តាលសមុទ្រខ្សាច់ពណ៌ត្នោត។ អ្នកដឹកនាំពួកជំនុំទាំងនោះបានទទូចថា ការថែទាំព្រៃឈើទាំងនោះ ជាផ្នែកមួយនៃការស្តាប់បង្គាប់ព្រះ ក្នុងនាមជាអ្នកថែរក្សាស្នាព្រះហស្តដែលព្រះអង្គផ្ញើទុកនឹងយើង។

ហោរាអេសាយបានសរសេរបទគម្ពីរផ្ញើទៅកាន់ប្រជាជនអ៊ីស្រាអែល ដែលកំពុងរស់នៅក្នុងទឹកដីដែលមិនសូវមានជីជាតិ ជាវាលរហោស្ថាន និងទទួលការគំរាមកំហែងពីភាពវាំងស្ងួត។ ហើយគាត់ក៏បានពិពណ៌នា អំពីពេលអនាគត ដែលព្រះទ្រង់បានរៀបចំ យ៉ាងដូចនេះថា «ទីរហោស្ថាន ហើយទីហួតហែង នឹងមានសេចក្តីអំណរ ឯសមុទ្រខ្សាច់ នឹងរីកពាយ ហើយផ្កាឡើងដូចជាកុលាប» (អេសាយ ៣៥:១)។ ព្រះអម្ចាស់សព្វព្រះទ័យនឹងប្រោសរាស្ត្រព្រះអង្គឲ្យជា តែព្រះអង្គក៏សព្វព្រះទ័យនឹងប្រោសផែនដីឲ្យជាផងដែរ។ ព្រះអង្គនឹងបង្កើតផ្ទៃមេឃ និងផែនដីថ្មី (៦៥:១៧)។ ក្នុងផែនដីថ្មីរបស់ព្រះអង្គ វាលរហោស្ថាននឹងមានផ្ការីកស្គុះស្គាយ (៣៥:១)។

ព្រះអម្ចាស់យកព្រះទ័យទុកដាក់ចំពោះស្នាព្រះហស្តព្រះអង្គ ដែលរាប់បញ្ចូលរាស្ត្រព្រះអង្គផងដែរ ហើយការនេះក៏បានលើកទឹកចិត្តយើងឲ្យថែរក្សាស្នាព្រះហស្តព្រះអង្គ។ យើងអាចរស់នៅស្របតាមផែនការរបស់ព្រះអង្គសម្រាប់ផែនដី ដោយចូលរួមថែរក្សាអ្វីៗដែលព្រះអង្គបានបង្កើត។ យើងអាចចូលរួមជាមួយព្រះអង្គ ក្នុងការកែប្រែវាលរហោស្ថាន ឲ្យមានជីវិត និងភាពស្រស់ស្អាតឡើងវិញ។—Winn Collier

តើអ្នកឃើញផ្នែកណាខ្លះនៃស្នាព្រះហស្តព្រះអង្គ ដែលត្រៀមក្រោះ ឬកំពុងរងទុក្ខ? តើអ្នកនឹងចូលរួមដូចម្តេចខ្លះ ក្នុងការកែប្រែវាលរហោស្ថានឲ្យក្លាយជាកន្លែងមានផ្ការីកស្គុះស្គាយ?

ឱព្រះអាទិករ សូមព្រះអង្គបង្ហាញទូលបង្គំ នូវរបៀបព្យាបាល និងស្តារឡើងវិញនូវអ្វីៗដែលប្រេះបែក ក្នុងលោកីយ៍នេះ។

Daily Manna 2026_Content Enhance.indd 135 17/11/25 1:45 in the afternoon

ដ្បិតគឺដោយព្រះគុណ ដែលអ្នកពាល់គ្នាបានសង្គ្រោះ ដោយសារសេចក្តីជំនឿ ហើយសេចក្តីនោះ ក៏មិនមែនកើតពីអ្នកពាល់គ្នាដែរ គឺជាអំណោយទានរបស់ព្រះវិញ (អេភេសូរ ២:៨)។

ឈប់ព្យាយាមជួយសង្គ្រោះខ្លួនឯង

ជាច្រើនឆ្នាំកន្លងមក ទីក្រុងញូយ៉កបានចាប់ផ្តើមធ្វើយុទ្ធនាការណ៍ផ្សព្វផ្សាយអំពី «សុវត្ថិភាពក្នុងជណ្តើរយន្ត» ដើម្បីអប់រំប្រជាជន អំពីរបៀបរម្ងាប់អារម្មណ៍ ហើយមានសុវត្ថិភាព នៅពេលពួកគេជាប់នៅក្នុងជណ្តើរយន្ត។ អ្នកជំនាញបានរាយការណ៍ថា អ្នកដំណើរខ្លះដែលជាប់ក្នុងជណ្តើរយន្ត បានបាត់បង់ជីវិតនៅពេលដែលពួកគេព្យាយាមគាស់ទ្វារជណ្តើរយន្តចេញ ឬព្យាយាមចេញពីជណ្តើរយន្ត តាមមធ្យោបាយផ្សេងទៀត។ ដំណោះស្រាយល្អបំផុត គឺគ្រាន់តែចុចប៊ូតុង ដើម្បីផ្តល់ដំណឹងឲ្យគេមកជួយ ហើយរង់ចាំក្រុមសង្គ្រោះបន្ទាន់មកដល់។

សាវ័កប៉ុលបានបង្រៀនយើង អំពីផែនការជួយសង្គ្រោះខុសពីនេះ គឺផែនការសម្រាប់ជួយអ្នកដែលកំពុងជាប់នៅក្នុងចំណងនៃអំពើបាប។ គាត់បានរំឭកពួកជំនុំនៅទីក្រុងអេភេសូរ អំពីភាពអស់សង្ឃឹមខាងវិញ្ញាណរបស់ពួកគេ ដោយសារពួកគេបានស្លាប់ខាងឯបាប (អេភេសូរ ២:១)។ ពួកគេបានជាប់អន្ទាក់ ដោយស្តាប់បង្គាប់អារក្ស (ខ.២) ហើយបដិសេធន៍មិនព្រមស្តាប់បង្គាប់ព្រះ។ ការនេះបានបណ្តាលឲ្យពួកគេជាប់នៅក្នុងសេចក្តីក្រោធរបស់ព្រះ។ តែព្រះអង្គមិនបានទុកឲ្យពួកគេជាប់នៅក្នុងភាពងងឹតខាងវិញ្ញាណជារៀងរហូតឡើយ។ ហើយអ្នកដែលជឿព្រះយេស៊ូវ «បានសង្គ្រោះ ដោយសារព្រះគុណព្រះអង្គ» (ខ.៥, ៨)។ ដូចនេះ ពួកគេត្រូវឆ្លើយតបចំពោះផែនការជួយសង្គ្រោះរបស់ព្រះអង្គ ដោយជំនឿ។ ហើយការមានជំនឿលើព្រះអង្គ គឺមានន័យថា យើងឈប់ព្យាយាមជួយសង្គ្រោះខ្លួនឯង ហើយទូលសូមព្រះអង្គជួយសង្គ្រោះយើង។

ដោយសារព្រះគុណព្រះ សេចក្តីសង្គ្រោះឲ្យរួចពីអន្ទាក់នៃអំពើបាប មិនកើតចេញពីយើងនោះទេ តែជា «អំណោយមកពីព្រះ» ដែលបានប្រទានមកតាមរយៈព្រះយេស៊ូវតែមួយអង្គគត់ (ខ.៨)។

—Marvin Williams

ហេតុអ្វីអ្នកមិនអាចជួយខ្លួនឯង ឲ្យរួចផុតពីអន្ទាក់របស់បាប? តើព្រះអម្ចាស់បានផ្តល់ដំណោះស្រាយយ៉ាងខ្លះ ដើម្បីឲ្យជួយសង្គ្រោះអ្នក?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដ្បិតកាលទូលបង្គំជាប់ក្នុងអន្ទាក់របស់បាប ហើយព្យាយាមសង្គ្រោះខ្លួនឯង ព្រះអង្គបានសម្រេចផែនការជួយសង្គ្រោះ ដោយចាត់ព្រះអង្គសង្គ្រោះឲ្យមករំដោះទូលបង្គំ។

Daily Manna 2026_Content Enhance.indd 136 17/11/25 1:45 in the afternoon

ត្រូវឲ្យចេញសំដីថាតែមែនៗ ឬ ទេៗប៉ុណ្ណោះ សេចក្តីណាដែលលើសអំពីនោះទៅ នោះមកតែពីអាកំណាចទេ (ម៉ាថាយ ៥:៣៧)។

ការប្រកាន់គោលជំហរ ក្នុងព្រះគ្រីស្ទ

ក្នុងខ្សែភាពរឿងម្ចាស់ចិញ្ចៀន ផ្អែកទៅលើរឿងប្រលោមលោក ដែលលោក ចូលខិន (Tolkien) បាននិពន្ធ លោក ហ្គន់ដូល (Gandalf) ជាតួអង្គស្លៀករ៉ូបពណ៌ប្រផេះ បានប្រឈមមុខដាក់លោក សារូមិន (Saruman) ជាតួអង្គស្លៀករ៉ូបពណ៌ស បន្ទាប់ពីលោក សារូមិន បានបោះបង់ចោលគោលជំហររបស់គាត់ ក្នុងការជួយការពារភូមិភាគកណ្តាលនៃផែនដី ឲ្យរួចផុតពីអំណាចនៃសេចក្តីអាក្រក់របស់លោក សៅរ៉ុន (Sauron)។ ជាងនេះទៅទៀត លោក សារូមិន ថែមទាំងបានចងសម្ព័ន្ធមិត្តជាមួយលោក សៅរ៉ុនទៀតផង! នៅពេលនោះ អ្នកទាំងពីរ ដែលជាអតីតមិត្តភក្តិ ក៏បានដឹកនាំទ័ពប្រយុទ្ធគ្នាក្នុងសង្គ្រាមដ៏ធំមួយ រវាងការល្អ និងការអាក្រក់។ បើសិនជាលោក សារូមិន បានប្រកាន់គោលជំហររបស់របស់ខ្លួន ដោយមិនងាករេ ហើយធ្វើការអ្វីដែលត្រឹមត្រូវនោះគាត់ក៏មិនក្លាយជាមនុស្សអាក្រក់ដែរ។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំស្តេចសូល ដែលមានបញ្ហា ក្នុងការប្រកាន់គោលជំហររបស់ទ្រង់។ ក្នុងរឿងមួយនោះ ទ្រង់បានធ្វើរឿងដ៏ត្រឹមត្រូវ ដោយបណ្តេញ «អស់ទាំងពួកគ្រូខាប និងពួកគ្រូអន្ទងខ្មោចពីស្រុកចេញ» (១សាំយ៉ូអែល ២៨:៣)។ នេះជាទង្វើដ៏ល្អ ដ្បិតព្រះទ្រង់បានប្រកាសថា ការទៅពឹងពួកគ្រូខាប គ្រូអន្ទងខ្មោច គឺជាទង្វើដែលគួរឲ្យស្អប់ខ្ពើម នៅចំពោះព្រះអង្គ (ចោទិយកថា ១៨:៩-១២)។ ប៉ុន្តែនៅពេលដែលស្តេចសូលឃើញកងទ័ពរបស់សាសន៍ភីលីស្ទីន មានគ្នាច្រើនសន្ធឹក ទ្រង់ក៏ទូលអង្វរឲ្យព្រះអម្ចាស់ជួយ តែព្រះអម្ចាស់មិនបានឆ្លើយតប ដោយសារទ្រង់បានប្រព្រឹត្តខុស។ ស្តេចសូលក៏បានឲ្យគេទៅហៅគ្រូអន្ទងខ្មោចមក ដើម្បីសុំឲ្យគ្រូនោះជួយទ្រង់ (១សាំយ៉ូអែល ២៨:៧)។ ដូចនេះទ្រង់ក៏បានធ្វើបាបទាស់នឹងព្រះអម្ចាស់ថែមទៀត ទោះទ្រង់ជ្រាបថា វាជាការបំពានសេចក្តីបង្គាប់របស់ព្រះអម្ចាស់ក៏ដោយ។

ប្រហែល១ពាន់ឆ្នាំក្រោយមក ព្រះយេស៊ូវក៏បានមានបន្ទូលទៅកាន់ពួកសាវ័កថា «ត្រូវឲ្យចេញសំដីថាតែមែនៗ ឬ ទេៗប៉ុណ្ណោះ សេចក្តីណាដែលលើសអំពីនោះទៅ នោះមកតែពីអាកំណាចទេ» (ម៉ាថាយ ៥:៣៧)។ អាចនិយាយម្យ៉ាងទៀតថា បើយើងបានប្តេជ្ញាចិត្តស្តាប់បង្គាប់តាមព្រះគ្រីស្ទ យើងចាំបាច់ត្រូវប្រកាន់ខ្ជាប់ការប្តេជ្ញាចិត្តនោះ ដោយភាពពិតត្រង់ជានិច្ច។ ចូរយើងប្រកាន់គោលជំហរ ក្នុងការធ្វើតាមបង្គាប់ព្រះអង្គ ដោយពឹងផ្អែកជំនួយមកពីព្រះអង្គ។—Tom Felten

តើមានអ្វីជួយឲ្យអ្នកប្រកាន់ខ្ជាប់នូវការប្តេជ្ញាចិត្តរបស់អ្នក? តើហេតុអ្វីអ្នកចាំបាច់ត្រូវប្រកាន់គោលជំហរក្នុងការរស់នៅដោយភាពពិតត្រង់?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យប្រកាន់គោលជំហរ ក្នុងការដើរតាមផ្លូវព្រះអង្គ ឲ្យបានខ្ជាប់ខ្ជួន។

គម្រោងអានព្រះគម្ពីរឆ្នាំ | ២ពង្សាវតារក្សត្រ ១៣-១៤ និងយ៉ូហាន ២

ដ្បិតខ្ញុំនឹកចាំពីសេចក្តីជំនឿស្មោះត្រង់ ដែលនៅក្នុងអ្នក សេចក្តីជំនឿនោះបាននៅក្នុងយាយឡូអ៊ីស ជាជីដូនរបស់អ្នកជាមុនដំបូង រួចក៏នៅក្នុងអ្នកអើនីស ជាម្តាយអ្នកដែរ (២ធីម៉ូថេ ១:៥)។

បន្សល់ទុកកេរដំណែលខាងវិញ្ញាណ

កាលខ្ញុំ និងបងស្រីខ្ញុំ ស្ថិតក្នុងវ័យជំទង់ យើងមិនយល់អំពីមូលហេតុដែលម្តាយរបស់យើង បានសម្រេចចិត្តទទួលជឿព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះទេ តែយើងមិនអាចបដិសេធន៍ការផ្លាស់ប្រែ ដែលយើងបានមើលឃើញក្នុងជីវិតគាត់បានឡើយ។ គាត់មានសន្តិភាព និងក្តីអំណរច្រើនជាងមុន ហើយក៏បានចាប់ផ្តើមបម្រើព្រះ ដោយចិត្តស្មោះត្រង់ក្នុងព្រះវិហារ។ គាត់មានចិត្តស្រេកឃ្លានចង់រៀនព្រះគម្ពីរណាស់ បានជាគាត់ទៅរៀននៅសាលាព្រះគម្ពីរហូតដល់បញ្ចប់ការសិក្សា។ រយៈពេល១ឆ្នាំ បន្ទាប់ពីម្តាយខ្ញុំបានសម្រេចចិត្តទទួលជឿព្រះ បងស្រីខ្ញុំក៏បានទទួលជឿព្រះគ្រីស្ទ ហើយចាប់ផ្តើមធ្វើការបម្រើព្រះអង្គ។ ហើយពីរបីឆ្នាំក្រោយមក ខ្ញុំក៏បានទទួលជឿព្រះយេស៊ូវ និងចាប់ផ្តើមបម្រើព្រះអង្គផងដែរ។ ជាច្រើនឆ្នាំក្រោយមក ឪពុកខ្ញុំក៏បានទទួលជឿព្រះអង្គ។ ការសម្រេចចិត្តរបស់ម្តាយខ្ញុំ ក្នុងការទទួលជឿព្រះគ្រីស្ទ បានជះឥទ្ធិពលនៃជីវិតផ្លាស់ប្រែ ដែលបានបណ្តាលចិត្តក្រុមគ្រួសារ និងសាច់ញាតិរបស់យើងឲ្យទទួលជឿព្រះយេស៊ូវជាបន្តបន្ទាប់។

កាលសាវ័កប៉ុលសរសេរសំបុត្រចុងក្រោយរបស់គាត់ ផ្ញើទៅលោក ធីម៉ូថេ ហើយបានលើកទឹកចិត្តគាត់ឲ្យស៊ូទ្រាំក្នុងជំនឿ លើព្រះយេស៊ូវ គាត់បានធ្វើការកត់សម្គាល់ អំពីមរតកនៃសេចក្តីជំនឿរបស់គាត់ បានជាគាត់មានប្រសាសន៍ថា «ដ្បិតខ្ញុំនឹកចាំពីសេចក្តីជំនឿស្មោះត្រង់ ដែលនៅក្នុងអ្នក សេចក្តីជំនឿនោះបាននៅក្នុងយាយឡូអ៊ីស ជាជីដូនរបស់អ្នកជាមុនដំបូង រួចក៏នៅក្នុងអ្នកអើនីស ជាម្តាយអ្នកដែរ ហើយខ្ញុំជឿជាក់ថា ក៏នៅក្នុងអ្នកផង» (២ធីម៉ូថេ ១:៥)។

ការសម្រេចចិត្តរបស់ស្ត្រីដែលជាម្តាយ និងជីដូនជាច្រើន ក្នុងការទទួលជឿព្រះយេស៊ូវ អាចមានឥទ្ធិពលមកលើមនុស្សជាច្រើនជំនាន់។ ការដែលម្តាយ និងជីដូនរបស់លោក ធីម៉ូថេបានជួយថែបំប៉នជំនឿរបស់គាត់ ដើម្បីឲ្យគាត់អាចក្លាយជាមនុស្សដែលព្រះទ្រង់បានត្រាស់ហៅគាត់ឲ្យក្លាយទៅជា។

ក្នុងទិវាអ្នកម្តាយ និងនៅថ្ងៃដែលមានជាបន្តបន្ទាប់ទៀត ចូរយើងផ្តល់កិត្តិយសដល់ម្តាយទាំងឡាយ ដែលបានធ្វើការសម្រេចចិត្តដើរតាមព្រះយេស៊ូវ។

ចូរយើងបន្សល់ទុកនូវកេរដំណែលខាងវិញ្ញាណ សម្រាប់មនុស្សជាទីស្រឡាញ់របស់យើងផងដែរ។—Nancy Gavilanes

តើមានស្ត្រីណាខ្លះកោតខ្លាចព្រះ ដែលអ្នកអាចផ្តល់កិត្តិយសនៅថ្ងៃនេះ? តើមានកេរដំណែលខាងវិញ្ញាណអ្វីខ្លះ ដែលអ្នកចង់បន្សល់ទុកសម្រាប់អ្នកដទៃ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានម្តាយដែលកោតខ្លាចព្រះ។ សូមព្រះអង្គជួយទូលបង្គំឲ្យបន្សល់ទុកនូវកេរដំណែលខាងវិញ្ញាណដល់អ្នកដទៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២ពង្សាវតារក្សត្រ ១៥-១៦ និងយ៉ូហាន ៣:១-១៨

ខ្ញុំស្បថដោយនូវព្រះយេហូវ៉ា ដ៏មានព្រះជន្មរស់ថា សេចក្ដីណាដែលព្រះនៃខ្ញុំទ្រង់មានព្រះបន្ទូលមក នោះខ្ញុំនឹងបញ្ចេញតាមសេចក្ដីនោះឯង (២របាក្សត្រ ១៨:១៣)។

ហ៊ានប្រឆាំងនឹងទស្សនៈដែលពេញនិយម

បន្ទាប់ពីសន្និសីទសន្តិភាពនៅទីក្រុងប៉ារីស សង្គ្រាមលោកលើកទី១ ក៏បានបញ្ចប់ លោក ហ្វឺឌីណង់ ហ្វូច (Ferdinand Foch) ជាអគ្គមេបញ្ជាការនៃកងទ័ពប្រទេសបារាំង បានធ្វើការសង្កេតមើលស្ថានការណ៍ពិភពលោក ហើយក៏បានមានប្រសាសន៍ដោយចិត្តជូរល្វីងថា «ពិភពលោក មិនទាន់មានសន្តិភាពនៅឡើយទេ។ នេះគ្រាន់តែជាបទឈប់បាញ់គ្នា ដែលមានរយៈពេល២០ឆ្នាំ»។ ទស្សនៈរបស់លោក ហ្វូច បានប្រាសចាកទស្សនៈដ៏ពេញនិយមរបស់មនុស្សនៅសម័យនោះ ដែលបានយល់ឃើញថា សង្គ្រាមលោកលើកទី១ ដ៏គួរឲ្យតក់ស្លុតនេះ គឺជា «សង្គ្រាមដែលបានបញ្ចប់សង្គ្រាមទាំងអស់»។ ២០ឆ្នាំ និង២ខែក្រោយមក សង្គ្រាមលោកលើកទី២ ក៏បានផ្ទុះឡើង។ លោក ហ្វូច ពិតជានិយាយត្រូវ។

តាំងពីយូរមកហើយ លោក មីកាយ៉ា ជាហោរាពិតតែមួយរបស់ព្រះ ក្នុងតំបន់ដែលគាត់រស់នៅ ក្នុងសម័យរបស់គាត់ បានថ្លែងទំនាយយ៉ាងត្រឹមត្រូវសម្រាប់នគរអ៊ីស្រាអែល អំពីលទ្ធផលនៃសឹកសង្គ្រាម (២របាក្សត្រ ១៨:៧)។ ផ្ទុយទៅវិញ ហោរាក្លែងក្លាយទាំង៤០០នាក់ របស់ស្តេច អ័ហាប់ បានថ្លែងទំនាយថា ស្តេចនឹងមានជ័យជម្នះក្នុងសង្គ្រាមទៅវិញ។ ហេតុនេះហើយ មន្ត្រីម្នាក់ដែលនាំហោរា មីកាយ៉ា ចូលគាល់ស្តេចក៏បានប្រាប់គាត់ថា «មើល ពួកហោរាទាំងអស់សុទ្ធតែទាយល្អ ដល់ស្តេចព្រមគ្នា ដូច្នេះសូមឲ្យពាក្យលោកបានដូចជាពាក្យរបស់ហោរាទាំងនោះ ដោយពោលតែសេចក្ដីល្អដែរ» (ខ.១២)។

លោក មីកាយ៉ាក៏បានឆ្លើយតបថា «សេចក្ដីណាដែលព្រះនៃខ្ញុំទ្រង់មានព្រះបន្ទូលមក នោះខ្ញុំនឹងបញ្ចេញតាមសេចក្ដីនោះឯង» (ខ.១៣)។ គាត់បានថ្លែងទំនាយថា ពួកអ៊ីស្រាអែលនឹង «ខ្ចាត់ខ្ចាយទៅ នៅលើភ្នំ ប្រៀបដូចជាហ្វូងចៀម ដែលគ្មានអ្នកគង្វាល» (ខ.១៦)។ លោក មីកាយ៉ា ពិតជានិយាយត្រូវ។ ពួកសាសន៍ស៊ីរីក៏បានសម្លាប់ស្តេច អ័ហាប់ ហើយកងទ័ពទ្រង់ក៏បានបាក់ទ័ពរត់ខ្ចាត់ខ្ចាយ (ខ.៣៣-៣៤ ១ពង្សាវតារក្សត្រ ២២:៣៥-៣៦)។

យើងដែលជាអ្នកដើរតាមព្រះយេស៊ូវ ក៏ត្រូវចែកចាយព្រះរាជសាររបស់ព្រះអង្គ តាមគំរូលោក មីកាយ៉ាផងដែរ ទោះអ្វីដែលយើងត្រូវចែកចាយនោះ ផ្ទុយនឹងទស្សនៈដ៏ពេញនិយមរបស់មនុស្សភាគច្រើនក៏ដោយ។ ព្រះយេស៊ូវមានបន្ទូលថា «ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ» (យ៉ូហាន ១៤:៦)។ មនុស្សជាច្រើនមិនចូលចិត្តព្រះបន្ទូលព្រះអង្គ ក្នុងបទគម្ពីរនេះទេ ព្រោះពួកគេយល់ឃើញថា ព្រះបន្ទូលព្រះអង្គហាក់ដូចជាមានភាពចង្អៀតចង្អល់ពេក។ ពួកគេថា ព្រះបន្ទូលព្រះអង្គមានភាពត្រឹមត្រូវផ្តាច់មុខតែម្នាក់ឯងពេក។ ប៉ុន្តែ ព្រះគ្រីស្ទបាននាំមកនូវព្រះបន្ទូលកម្សាន្តចិត្ត ដល់មនុស្សទាំងអស់។ ព្រះអង្គស្វាគមន៍នរណាក៏ដោយដែលងាកបែរមករកព្រះអង្គ។—Tim Gustafson

ពេលណាព្រះវិញ្ញាណបរិសុទ្ធដឹកនាំអ្នក ឲ្យនិយាយ ឬធ្វើអ្វីមួយ តើអ្នកនឹងនិយាយ ឬធ្វើដោយសេចក្ដីស្រឡាញ់ដូចម្តេចខ្លះ? តើអ្នកត្រូវកែតម្រង់ការសន្និដ្ឋានរបស់អ្នក ដោយព្រះបន្ទូលព្រះអង្គដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គប្រទានទូលបង្គំនូវប្រាជ្ញា ដើម្បីឲ្យអាចយល់សេចក្ដីពិតរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២ពង្សាវតារក្សត្រ ១៧-១៨ និងយ៉ូហាន ៣:១៩-៣៦

រួចយើងបានឱ្យមខាងសេចក្តីសប្បាយ ពីព្រោះនៅក្រោមថ្ងៃ មនុស្សឥតមានអ្វីល្អជាងការស៊ីផឹក ហើយមានចិត្តរីករាយនោះទេ (សាស្តា ៨:១៥)។

ភាពរួញខ្លីនៃពេលដ៏រីករាយ

ផ្កាសាគ្ការីកស្គុះស្គាយ និងបញ្ចេញក្លិនដ៏ក្រអូប ដោយបានតុបតែងទឹកដីប្រទេសជប៉ុន ឲ្យមានទេសភាពពណ៌ស៊ីជម្ងប់ដ៏ស្រទន់យ៉ាងស្រស់ស្អាត ក្នុងរដូវផ្ការីករៀងរាល់ឆ្នាំ ហើយបាននាំមកនូវភាពរីករាយ ដល់ប្រជាពលរដ្ឋ ក៏ដូចជាភ្ញៀវទេសចរណ៍ដែលមកកម្សាន្តនៅប្រទេសជប៉ុន។ សម្រស់ផ្ការីកដែលមានរយៈពេលខ្លីនោះ បានក្រើនរំឭកជនជាតិជប៉ុនឲ្យគយគន់ភាពស្រស់ស្អាត និងស្រូបយកក្លិនដ៏ក្រអូបនៃផ្កាសាគ្ការ ទាន់នៅមានឱកាស។ ភាពរួញខ្លីនៃបទពិសោធន៍ដ៏រីករាយនេះ នាំមកនូវអារម្មណ៍សោកស្តាយ ចំពោះភាពមិនស្ថិតស្ថេរ។ ពួកគេក៏បានហៅការសប្បាយដែលកន្លងផុតទៅយ៉ាងឆាប់រហ័សថា «ការស្គាល់រយៈពេលខ្លី»។

ក្នុងនាមយើងជាមនុស្ស យើងចង់មានអារម្មណ៍ដ៏រីករាយ ហើយបន្លាយពេលដ៏រីករាយ ឲ្យមានរយៈពេលកាន់តែវែង។ នេះជាបញ្ហាដែលយើងមិនពិបាកយល់ទេ។ តែការពិតដែលថា ជីវិតយើងមានពេញដោយទុក្ខលំបាក គឺមានន័យថា យើងត្រូវតែរៀនមើលទៅទុក្ខលំបាក និងការសប្បាយ តាមកញ្ចក់ឆ្លុះនៃសេចក្តីជំនឿ លើព្រះដែលមានក្តីស្រឡាញ់។ យើងមិនចាំបាច់ត្រូវមានគំនិតអវិជ្ជមានច្រើនពេក ឬគួរតែមានគំនិតវិជ្ជមានពេកអំពីជីវិតរបស់យើងនោះឡើយ។

កណ្ឌគម្ពីរសាស្តាបានផ្តល់ឲ្យយើងនូវគំរូដ៏មានប្រយោជន៍សម្រាប់ការរស់នៅ។ មនុស្សជាច្រើនយល់ឃើញថា កណ្ឌគម្ពីរនេះបាននិយាយអំពីរឿងអវិជ្ជមានជាច្រើន តែទោះជាយ៉ាងណាក៏ដោយ ស្តេច សាឡូម៉ូន ដែលបានសរសេរថា «អ្វីៗសុទ្ធតែអសារឥតការ» (១:២) ក៏បានលើកទឹកចិត្តអ្នកអានរបស់គាត់ ឲ្យរកឃើញក្តីអំណរ ក្នុងរឿងដ៏សាមញ្ញក្នុងជីវិតយើង ដោយមានបន្ទូលថា នៅក្រោមថ្ងៃ មនុស្សគ្មានកិច្ចការអ្វីដែលល្អជាងការបរិភោគ អាហារ និងផឹកភេសជ្ជៈ ហើយមានចិត្តរីករាយនោះទេ» (៨:១៥)។

ក្តីអំណរកើតមាន នៅពេលណាយើងទូលសូមព្រះអង្គជួយយើងឲ្យ «មានប្រាជ្ញា» ហើយរៀនសង្កេតមើល «ការទាំងអស់ដែលព្រះអង្គបានធ្វើ» (ខ.១៦-១៧) ក្នុងពេលដ៏រីករាយ ក៏ដូចជាពេលដ៏ពិបាក (៣:១១-១៤ ៧:១៣-១៤) ដោយដឹងថា គ្មានពេលណាមួយ ដែលស្ថិតស្ថេរនៅលើផែនដីនេះទេ។—Kirsten Holmberg

តើអ្នកកំពុងស្ថិតក្នុងរដូវកាលណាមួយក្នុងជីវិត? តើអ្នកអាចរកឃើញក្តីអំណរក្នុងរដូវកាលនោះដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានធ្វើជាប្រភពនៃភាពស្រស់ស្អាត និងក្តីអំណរក្នុងជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 140 17/11/25 1:45 in the afternoon

[សាតាំង] ជាអ្នកកំភូត ហើយជាឪពុកនៃសេចក្តីនោះឯង (យ៉ូហាន ៨:៤៤)។

ការកុហក និងសេចក្តីពិត

ហ៊ីត្លែរ (Adolf Hitler) ជឿថា ការកុហកធំៗមានអំណាចជាងការកុហកតូចៗ ហើយគួរឲ្យសោកស្តាយណាស់ គាត់បានយកទ្រឹស្តីនេះមកអនុវត្តន៍យ៉ាងជោគជ័យ។ ក្នុងដើមដំបូងនៃអាជីពនយោបាយរបស់គាត់ គាត់បានអះអាងថា គាត់មិនមានមហិច្ឆតាទេ តែគាត់ពេញចិត្តក្នុងការគាំទ្រអ្នកដទៃឲ្យសម្រេចគោលដៅរបស់ពួកគេ។ ពេលគាត់ឡើងកាន់អំណាចដឹកនាំប្រទេសអាឡឺម៉ង់ គាត់និយាយថា គណៈបក្សរបស់គាត់មិនមានចេតនាធ្វើទុក្ខបុកម្នេញមកលើនរណាម្នាក់ទេ។ ក្រោយមក គាត់ក៏បានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីបង្ហាញឲ្យគេយល់ឃើញថា គាត់ជាបិតាជាតិ និងជាអ្នកដឹកនាំប្រកបដោយក្រមសីលធម៌។ ប៉ុន្តែ មនុស្សរាប់សិបលាននាក់បានរងគ្រោះ និងបាត់បង់ជីវិតដោយសារសង្គ្រាមលោកលើកទី២ និងអំពើប្រល័យពូជសាសន៍ដែលគាត់បានបង្កឡើង។

សាតាំងបានប្រើការកុហក ដើម្បីគ្រប់គ្រងជីវិតយើងផងដែរ។ ឲ្យតែមានឱកាស វាតែងតែបង្កការភ័យខ្លាច កំហឹង និងភាពអស់សង្ឃឹម ព្រោះវាជាអ្នកកំភូត និងជាឪពុកនៃសេចក្តីកំភូត (យ៉ូហាន ៨:៤៤)។ សាតាំងមិនអាចនិយាយការពិតបានទេ ព្រោះព្រះយេស៊ូវមានបន្ទូលថា មិនមានសេចក្តីពិតនៅក្នុងខ្លួនវា។

មានការកុហកមួយចំនួន ដែលអារក្សជាខ្មាំងសត្រូវរបស់យើងបានប្រើ។ ទីមួយ វានាំយើងគិតថា ការអធិស្ឋានរបស់យើងមិនសំខាន់ទេ។ ទេ ការអធិស្ឋានសំខាន់ណាស់។ ព្រះគម្ពីរបានចែងថា «សេចក្តីទូលអង្វរដ៏អស់ពីចិត្តរបស់មនុស្សសុចរិត នោះពូកែណាស់» (យ៉ាកុប ៥:១៦)។ ទីពីរ វាកុហកទៀតថា ពេលណាយើងមានបញ្ហា យើងគ្មានច្រកចេញឡើយ។ វានិយាយខុសទៀតហើយ។ គ្មានការអ្វីដែលព្រះទ្រង់ធ្វើមិនកើតនោះឡើយ (ម៉ាកុស ១០:២៧) ហើយ «ទ្រង់ក៏រៀបផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន» (១កូរិនថូស ១០:១៣)។ ទីបី វានាំឲ្យយើងគិតថា ព្រះអង្គមិនស្រឡាញ់យើងទេ។ ការគិតដូចនេះក៏ខុសដែរ ព្រោះគ្មានអ្វីអាច «ពង្រាត់យើង» ចេញពីសេចក្តីស្រឡាញ់របស់ព្រះ ដែលនៅក្នុងព្រះយេស៊ូវគ្រីស្ទបានឡើយ (រ៉ូម ៨:៣៨-៣៩)។

សេចក្តីពិតរបស់ព្រះ មានអំណាចជាងការកុហករបស់សាតាំង។ បើយើងស្តាប់បង្គាប់តាមការបង្រៀនរបស់ព្រះយេស៊ូវ ដោយពឹងអាងកម្លាំងមកពីព្រះអង្គ ហើយ «យើងបានស្គាល់សេចក្តីពិត» និងបដិសេធន៍សេចក្តីកុហកនោះសេចក្តីពិត នឹងរំដោះយើងឲ្យមានសេរីភាព (យ៉ូហាន ៨:៣១-៣២)។—Jennifer Benson Schuldt

តើមានការកុហកអ្វីខ្លះ ដែលអ្នកទំនងជាជឿ? តើព្រះទ្រង់សព្វព្រះទ័យឲ្យអ្នកកែប្រែគំនិតជាថ្មី ដោយសេចក្តីពិតរបស់ព្រះអង្គដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ព្រះអង្គជាផ្លូវ ជាសេចក្តីពិត និងជាជីវិត។ សូមព្រះអង្គបង្ហាញទូលបង្គំឲ្យឃើញការកុហកដែលទូលបង្គំកំពុងជឿតាម ហើយសូមជួយទូលបង្គំឲ្យតោងជាប់សេចក្តីពិត ដែលទូលបង្គំបានអានក្នុងព្រះគម្ពីរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២កង្សាវតារក្សត្រ ២២-២៣ និងយ៉ូហាន ៤:៣១-៥៤

ព្រះនាមទ្រង់ប្រសើរគ្រប់លើផែនដីយ៉ាងណាទៅ (ទំនុកតម្កើង ៨:១)។

ស្ងប់ស្ងែងចំពោះស្នាព្រះហស្តព្រះអង្គ

កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២២ អ្នកវិទ្យាសាស្ត្របានទទួលរង់ចាំ រូបភាពដំបូងបំផុតនៃទីអវកាសស្ថិតនៅឆ្ងាយបំផុត ដែលកែវយឺតអវកាស ចេមស៍ វើប (James Web) ថតបាន។ កែវយឺតមើលផ្កាយដែលមានបច្ចេកវិទ្យាទំនើបបំផុតនេះ អាចអនុញ្ញាតឲ្យអ្នកវិទ្យាសាស្ត្រ ឆ្លុះមើលរូបភាពបានចម្ងាយកាន់តែឆ្ងាយចូលទៅក្នុងចក្រវាល ដែលមនុស្សជាតិមិនដែលបានមើលដល់កាលពីមុនមក។ បន្ទាប់ពីបានបាញ់បង្ហោះដោយជោគជ័យ ភ្លាមៗនោះរូបភាពដ៏គួរឲ្យពេចពិលរមិលមើលក៏បានលេចឡើងនៅលើអេក្រង់កុំព្យូទ័រ ហើយគេក៏បានឃើញបណ្តុំផ្កាយ ខារីណា នេប៊ុឡា ដែលមានទេសភាពពពកបែបអវកាសដ៏ស្រស់ស្អាត ដែលគេមិនបានឃើញស្អាតដូចនេះពីមុនមកទេ។ តារាវិទូនៅអង្គការណាសាម្នាក់ បានដកស្រស់សម្តីលោក ខាល សាហ្គិន (Carl Sagan) ជាអ្នកមិនជឿថា ព្រះមានមែនដ៏ល្បីល្បាញ ដែលបាននិយាយថា «មានអ្វីមួយអស្ចារ្យកំពុងរង់ចាំយើង នៅកន្លែងដ៏អស្ចារ្យនោះ»។

ជួនកាល មនុស្សអាចមើលទៅព្រះ ដោយមិនបានឃើញព្រះអង្គ។ ប៉ុន្តែ ស្តេច ដាវីឌ ជាអ្នកនិពន្ធបទគម្ពីរទំនុកតម្កើង បានសម្លឹងមើលមេឃ ហើយដឹងច្បាស់ថា ទ្រង់កំពុងទតឃើញអ្វី។ ហេតុនេះហើយ ទ្រង់មានបន្ទូលថា «ទ្រង់បានតម្កល់សិរីល្អទ្រង់ទុកនៅលើស្ថានសួគ៌» (ទំនុកតម្កើង ៨:១)។ លោក សាហ្គិន មិនបាននិយាយខុសទេ នៅពេលដែលគាត់ថា «មានអ្វីមួយដ៏អស្ចារ្យកំពុងរង់ចាំយើង» ប៉ុន្តែគាត់មិនបានទទួលស្គាល់អ្វីដែលស្តេច ដាវីឌ បានយល់ច្បាស់ និងពោលថា «កាលណាទូលបង្គំពិចារណាមើលផ្ទៃមេឃ ជាការដែលព្រះហស្តទ្រង់បានធ្វើ គឺទាំងខែ និងផ្កាយ ដែលទ្រង់បានប្រតិស្ឋានទុក នោះតើមនុស្សជាអ្វី ដែលទ្រង់នឹករឭកដល់គេ ហើយកូនមនុស្សផង ដែលទ្រង់ប្រោសដូច្នេះ» (ខ.៣-៤)។

ពេលណាយើងមើលឃើញរូបភាពទីអវកាសជ្រៅបំផុត យើងនឹងមានចិត្តស្ងប់ស្ងែង ភាគច្រើនមិនមែនដោយសារបច្ចេកវិទ្យាទំនើប ដែលជួយឲ្យយើងមើលឃើញរូបភាពទាំងនោះ តែដោយសារយើងកំពុងមើលឃើញស្នាព្រះហស្តដែលព្រះអង្គបានបង្កើត។ យើងស្ងប់ស្ងែង ព្រោះក្នុងវិសាលភាពនៃស្នាព្រះហស្តដ៏ច្រើនលើសលប់ព្រះអង្គបានបង្កើតយើង «ឲ្យត្រួតលើអស់ទាំងការនៃព្រះហស្តទ្រង់» (ខ.៦)។ ជាការពិតណាស់ «អ្វីមួយដ៏អស្ចារ្យដែលកំពុងរង់ចាំយើងនោះ» គឺជាព្រះអម្ចាស់ ដែលកំពុងរង់ចាំលើកអ្នកជឿព្រះយេស៊ូវ ឲ្យទៅនៅជាមួយព្រះអង្គនៅពេលដែលព្រះអង្គយាងមកវិញ។ ពេលនោះនឹងមានទិដ្ឋភាពដែលគួរឲ្យពេចពិលរមិលមើល លើសរូបភាពណាៗទាំងអស់ដែលយើងធ្លាប់ឃើញ។—Kenneth Petersen

តើអ្នកមានការយល់ឃើញដូចម្តេចខ្លះ នៅពេលដែលអ្នកមើលទៅរូបភាពនៃទីអវកាសដ៏សែនជ្រៅ? តើអ្នកបានដកពិសោធន៍នឹងព្រះវត្តមានព្រះអង្គដូចម្តេចខ្លះ នៅក្នុងការមើលរូបភាពទាំងនោះ?

ឱព្រះអាទិករ ទូលបង្គំមានចិត្តស្ងប់ស្ងែង ចំពោះសិរីល្អនៃស្ថានសួគ៌ និងសម្រស់នៃស្នាព្រះហស្តព្រះអង្គ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការថែរក្សាទូលបង្គំនៅក្នុងចំណោមស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២ពង្សាវតារក្សត្រ ២៤-២៥ និងយ៉ូហាន ៥:១-២៤

យើងខ្ញុំមានចិត្តជឿជាក់ ហើយក៏សុខចិត្តស៊ូចេញពីរូបកាយនេះ ទៅនៅជាមួយនឹងព្រះអម្ចាស់ជាជាង (២កូរិនថូស ៥:៨)។

ផ្លាស់ទៅរស់នៅជាមួយព្រះ

មិត្តភក្តិរបស់ខ្ញុំឈ្មោះ យ៉ូអាន (Joann) បានលាចាកលោក ដោយសារជំងឺដាច់សរសៃឈាមខួរក្បាលខណៈពេលដែលរីសក្លឺណា កំពុងចាប់ផ្តើមរាតត្បាតក្នុងឆ្នាំ២០២០។ ពីដំបូង ក្រុមគ្រួសាររបស់គាត់បានជូនដំណឹងថា កម្មវិធីបុណ្យសពរបស់គាត់ នឹងប្រារព្ធទៅក្នុងព្រះវិហាររបស់គាត់ ប៉ុន្តែក្រោយមក ពួកគេក៏បានសម្រេចចិត្តធ្វើពិធីបុណ្យសពនៅផ្ទះវិញ ដើម្បីបន្ថយចំនួនមនុស្សដែលមកជួបជុំគ្នា។ ពួកគេក៏បានជូនដំណឹងតាមបណ្តាញសង្គមថា ពិធីបុណ្យសពរបស់អ្នកស្រី យ៉ូអាន វ៉ានន័រ (Joann Warners) បានផ្លាស់ប្តូរកន្លែងជួបជុំគ្នា។

ជាការពិតណាស់ វិញ្ញាណរបស់គាត់បានផ្លាស់ទៅរស់នៅកន្លែងថ្មីហើយ! គាត់បានផ្លាស់ពីទីកន្លែងនៅផែនដី ទៅទីកន្លែងក្នុងស្ថានសួគ៌។ ព្រះអម្ចាស់បានកែប្រែជីវិតគាត់ កាលប៉ុន្មានឆ្នាំមុន ហើយគាត់ក៏បានបម្រើព្រះអង្គ ដោយសេចក្តីស្រឡាញ់ជិត៥០ឆ្នាំហើយ។ សូម្បីតែនៅពេលដែលគាត់ជិតដល់ពេលស្លាប់ ក្នុងមន្ទីរពេទ្យ គាត់នៅតែសួរនាំអំពីមនុស្សជាទីស្រឡាញ់របស់គាត់ ដែលកំពុងជួបការលំបាក។ សព្វថ្ងៃនេះ គាត់បានទៅនៅជាមួយព្រះអង្គហើយ គឺមានន័យថា គាត់បានផ្លាស់ទៅរស់នៅកន្លែងថ្មី។

សាវ័ក ប៉ុល ក៏មានចិត្តចង់ទៅរស់នៅជាមួយព្រះគ្រីស្តក្នុងស្ថានសួគ៌ ជាកន្លែងថ្មីផងដែរ (២កូរិនថូស ៥:៨) តែគាត់ក៏យល់ឃើញថា បើគាត់នៅមានជីវិតនៅលើផែនដី នោះគាត់មានប្រយោជន៍ជាង សម្រាប់មនុស្សដែលគាត់កំពុងធ្វើការបម្រើ។ ហេតុនេះហើយ គាត់ក៏បានសរសេរសំបុត្រប្រាប់ពួកជំនុំនៅទីក្រុងភីលីពថា «បើខ្ញុំនៅក្នុងសាច់ឈាមតទៅទៀត នោះមានប្រយោជន៍ដល់អ្នករាល់គ្នាជាជាង» (ភីលីព ១:២៤)។ ពេលណាយើងសោកសង្រេង ចំពោះការលាចេញរបស់នរណាម្នាក់ ដូចអ្នកស្រី យ៉ូអាន យើងប្រហែលជាចង់ស្រែករកព្រះអង្គ ដោយទូលអង្វរ ក្នុងន័យស្រដៀងនេះដែរថា យើងកំពុងត្រូវការពួកគេឲ្យបន្តរស់នៅជាមួយយើង និងមនុស្សជាច្រើន ដែលពួកគេស្រឡាញ់ និងបម្រើ។ ប៉ុន្តែ ព្រះទ្រង់ជ្រាបថា ពេលណាជាពេលល្អបំផុតដែលពួកគេ ក៏ដូចជាយើងត្រូវផ្លាស់ទៅរស់នៅជាមួយព្រះអង្គ។

ដោយពឹងអាងកម្លាំងមកពីព្រះវិញ្ញាណ ចូរយើងដាក់គោលដៅថា យើងនឹង «សង្វាត ឲ្យបានគាប់ដល់ព្រះហឫទ័យទ្រង់» (២កូរិនថូស ៥:៩) ទាល់តែយើងបានឃើញព្រះអង្គ មុខទល់នឹងមុខ ដែលជាការប្រសើរជាងឆ្ងាយណាស់។—Anne Cetas

តើអ្នកបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះ និងចំពោះអ្នកដទៃនៅកន្លែងដែលអ្នកកំពុងនៅក្នុងពេលនេះ ដោយរបៀបណា? តើអ្នកអាចបម្រើព្រះអង្គនៅថ្ងៃនេះ ដោយរបៀបណា?

ឱព្រះអម្ចាស់ ទូលបង្គំសូមថ្វាយជីវិតទូលបង្គំដាច់ដល់ព្រះអង្គ។ សូមព្រះអង្គបំពេញទូលបង្គំ ដោយព្រះវិញ្ញាណនៃសេចក្តីស្រឡាញ់ ហើយធ្វើឲ្យជីវិតទូលបង្គំមានតម្លៃចំពោះព្រះអង្គ។

គម្រោងអានព្រះគម្ពីរឆ្នាំ:ពេល១ឆ្នាំ | ១រ៉ាជក្សត្រ ១-៣ និងយ៉ូហាន ៥:២៥-៤៧

អញបានបំពេញគាត់ដោយព្រះវិញ្ញាណនៃព្រះ ឲ្យមានគំនិតវាងវៃ មានយោបល់មានចំណេះ ចេះធ្វើការគ្រប់មុខទាំងអស់ (និក្ខមនំ ៣១:៣)។

ព្រះអង្គប្រទានលទ្ធភាពសម្រាប់ធ្វើការ

មានពេលមួយ ប្រធានរបស់ខ្ញុំបានប្រាប់ថា កិច្ចការដែលខ្ញុំត្រូវធ្វើ នៅកន្លែងតាំងពិព័រណ៍សៀវភៅអន្តរជាតិ គឺត្រូវរៀបចំឲ្យមានការផ្សាយបន្តផ្ទាល់នៅកន្លែងនោះ។ ខ្ញុំមានអារម្មណ៍ភ័យខ្លាច ព្រោះការងារនេះជាការងារថ្មីសម្រាប់ខ្ញុំ។ ខ្ញុំក៏បានអធិស្ឋានថា ព្រះអង្គអើយ សូមព្រះអង្គជួយទូលបង្គំ ព្រោះទូលបង្គំមិនដែលបានធ្វើការងារដូចនេះពីមុនមកទេ។

ព្រះអម្ចាស់ក៏បានប្រទានធនធាន និងមនុស្សជួយណែនាំខ្ញុំ ដែលពួកគេជាអ្នកបច្ចេកទេស និងអ្នកផ្សាយសំឡេងដែលមានបទពិសោធន៍ ហើយថែមទាំងបានជួយរំឭកខ្ញុំ អំពីព័ត៌មានលម្អិតក្នុងពិធីតាំងពិព័រណ៍ ដែលខ្ញុំបានមើលរំលង។ ពេលខ្ញុំក្រឡេកមកមើលកម្មវិធីផ្សាយនោះឡើងវិញ ខ្ញុំក៏បានដឹងថា ការផ្សាយនោះមានដំណើរការល្អ ព្រោះព្រះអង្គជ្រាបថា ខ្ញុំត្រូវការអ្វី ហើយក៏បានបណ្តាលចិត្តខ្ញុំឲ្យប្រើប្រាស់ជំនាញ ដែលព្រះអង្គបានប្រទានខ្ញុំរួចជាស្រេចហើយ។

ពេលណាព្រះអម្ចាស់ត្រាស់ហៅយើង ឲ្យធ្វើកិច្ចការអ្វីមួយ ព្រះអង្គក៏ប្រទានយើងនូវលទ្ធភាពផងដែរ។ កាលព្រះអង្គចាត់តាំងលោក បេតសាលាល ឲ្យធ្វើការក្នុងរោងឧបោសថ គាត់ក៏មានជំនាញជាជាងដែលមានបទពិសោធន៍ស្រាប់ហើយ។ ព្រះអង្គក៏បានបំពាក់សមត្ថភាពដល់គាត់បន្ថែមទៀត ដោយប្រទានពរគាត់ ឲ្យពេញដោយព្រះវិញ្ញាណបរិសុទ្ធ និងប្រាជ្ញា ការយល់ដឹង ចំណេះដឹង និងជំនាញគ្រប់ប្រភេទ (និក្ខមនំ ៣១:៣)។ ព្រះទ្រង់ក៏បានឲ្យលោក អូហូលីអាប់ ធ្វើជាជំនួយការរបស់គាត់ ហើយប្រទានកម្លាំងពលការបន្ថែមដល់គាត់ (ខ.៦)។ ដោយជំនួយមកពីព្រះអង្គ ក្រុមការងារក៏បានរចនា និងសង់រោងឧបោសថ ព្រមទាំងតុបតែងលម្អ ហើយផលិតឯកសណ្ឋានរបស់ពួកសង្ឃផងដែរ។ ទាំងអស់នេះសុទ្ធតែមានសារៈសំខាន់ ចំពោះការថ្វាយបង្គំដ៏ត្រឹមត្រូវរបស់ពួកអ៊ីស្រាអែល នៅគ្រាសញ្ញាចាស់ (ខ.៧-១១)។

ឈ្មោះ បេតសាលាល មានន័យថា «នៅក្រោមម្លប់ (ឬការការពារ) របស់ព្រះ»។ ពួកជាងទាំងនោះធ្វើការងារក្នុងគម្រោងពេញមួយជីវិត នៅក្រោមការការពារ អំណាច និងការផ្គត់ផ្គង់របស់ព្រះ។ ចូរយើងស្តាប់បង្គាប់តាមការបណ្តាលចិត្តរបស់ព្រះអង្គ ដោយចិត្តក្លាហាន ខណៈពេលដែលយើងធ្វើកិច្ចការថ្វាយព្រះអង្គ រហូតដល់ចប់សព្វគ្រប់។ ព្រះអង្គជ្រាបថា យើងត្រូវការអ្វី នៅពេលណា និងដោយរបៀបណា។—Karen Huang

តើមានកិច្ចការអ្វីខ្លះ ដែលព្រះទ្រង់កំពុងត្រាស់ហៅឲ្យអ្នកធ្វើ? តើអ្នកអាចអធិស្ឋានសូមព្រះអង្គដឹកនាំអ្នក ក្នុងផ្នែកណាខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានលទ្ធភាពដែលទូលបង្គំត្រូវការ។

Daily Manna 2026_Content Enhance.indd 144 17/11/25 1:45 in the afternoon

សេចក្តីសង្គ្រោះស្រេចនូវព្រះនៃយើងរាល់គ្នា ដែលគង់លើបល្ល័ង្ក ហើយស្រេចនឹងកូនចៀមផង (វិវរណៈ ៧:១០)។

នាំឲ្យគេស្គាល់ និងសរសើរព្រះអង្គ

ការងារបកប្រែព្រះគម្ពីរ របស់អ្នកស្រី ខាត់ធ្រីន (Kathryn) បានទទួលការបណ្តាលចិត្តពីសេចក្តីស្រឡាញ់ដែលគាត់មានចំពោះព្រះអម្ចាស់ និងចំពោះប្រជាជនឥណ្ឌា។ គាត់មានអំណរណាស់ពេលដែលបានឃើញស្ត្រីនៅក្នុងប្រទេសឥណ្ឌា មានការយល់ដឹងកាន់តែស៊ីជម្រៅក្នុងព្រះគម្ពីរ តាមរយៈការអានព្រះគម្ពីរបឹបជាភាសាកំណើតរបស់ពួកគេ។ គាត់ក៏បានកត់សម្គាល់ថា ពេលណាពួកគេអានព្រះគម្ពីរ «ពួកគេច្រើនតែចាប់ផ្តើមស្រែកហូរ ឬទះដៃ។ ពួកគេបានអានអំពីព្រះយេស៊ូវ ហើយពួកគេក៏បានលាន់មាត់ថា "ព្រះបន្ទូលព្រះអង្គពិតជាអស្ចារ្យណាស់"»។

អ្នកស្រី ខាត់ធ្រីន ចង់ឲ្យមនុស្សកាន់តែច្រើនថែមទៀត បានអានព្រះគម្ពីរជាភាសារបស់ពួកគេ។ គាត់ក៏បាននឹកចាំក្នុងចិត្តគាត់ អំពីការបើកសម្តែង ដែលសាវ័ក យ៉ូហាន បានទទួលនៅលើកោះប៉ាតម៉ូស។ ព្រះអម្ចាស់បាននាំគាត់ឈរនៅចំពោះមុខបល្ល័ង្ករបស់ព្រះអង្គនៅស្ថានសួគ៌ ដែលនៅទីនោះ គាត់ក៏បានឃើញ «មនុស្ស១ហ្វូងយ៉ាងធំ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា ក៏ឈរនៅមុខបល្ល័ង្ក និងកូនចៀម» (វិវរណៈ ៧:៩)។ ពួកគេថ្វាយបង្គំព្រះទាំងអស់គ្នា ដោយនិយាយថា «សេចក្តីសង្គ្រោះស្រេចនូវព្រះនៃយើងរាល់គ្នា ដែលគង់លើបល្ល័ង្ក ហើយស្រេចនឹងកូនចៀមផង» (ខ.១០)។

ព្រះទ្រង់បន្តបន្ថែមចំនួនមនុស្សកាន់តែច្រើនលើសលប់ ដែលសរសើរតម្កើងព្រះអង្គ។ ព្រះអង្គមិនគ្រាន់តែប្រើការងាររបស់អ្នកបកប្រែព្រះគម្ពីរ និងអ្នកអធិស្ឋានឲ្យពួកគេប៉ុណ្ណោះទេ តែក៏ប្រើអ្នកដែលឈោងទៅរកអ្នកជិតខាង ដោយសេចក្តីស្រឡាញ់ ដើម្បីចែកចាយដំណឹងល្អនៃព្រះយេស៊ូវ។ យើងអាចអរសប្បាយ នៅក្នុងបេសកកម្មដែលពេញដោយអំណរនេះ ដោយមានការស្ញើចចំពោះរបៀប ដែលព្រះទ្រង់នាំមនុស្សកាន់តែច្រើន ឲ្យចូលរួមជាមួយទេវតា ក្នុងការសរសើរតម្កើងព្រះអម្ចាស់ថា «សូមថ្វាយព្រះពរ សិរីល្អ ប្រាជ្ញា ពាក្យអរព្រះគុណ កិត្តិនាម ព្រះចេស្តា និងឥទ្ធិឫទ្ធិ ដល់ព្រះនៃយើងរាល់គ្នា នៅអស់កល្បជានិច្ចរៀងរាបតទៅ អាម៉ែន» (ខ.១២)។—Amy Boucher Pye

តើអ្នកបានឃើញព្រះអម្ចាស់នាំមនុស្សឲ្យសរសើរតម្កើង និងថ្វាយព្រះកិត្តិនាមដល់ព្រះអង្គដូចម្តេចខ្លះ? តើព្រះអង្គអាចអញ្ជើញអ្នកឲ្យចូលរួម ក្នុងបេសកកម្មនៃការចែកផ្សាយដំណឹងល្អនៃព្រះយេស៊ូវ ដូចម្តេចខ្លះ?

ឱព្រះដ៏ជួយសង្គ្រោះ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានព្រះយេស៊ូវ ធ្វើជាអំណោយ។ សូមព្រះអង្គជួយទូលបង្គំឲ្យចែកចាយ ដល់អ្នកដទៃអំពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១យ៉ូហាន ៧-៩ និងយ៉ូហាន ៦:២២-៤៤

នោះអញនឹងជ្រោសឯងរាល់គ្នា ហើយនឹងធ្វើសំរេចដល់ឯងរាល់គ្នា តាមពាក្យល្អរបស់អញ ដោយធ្វើឲ្យឯងរាល់គ្នាវិលមកឯទីនេះវិញ (យេរេមា ២៩:១០)។

ព្រះអម្ចាស់ក្នុងពេលអតីតកាល និងពេលបច្ចុប្បន្ន

ក្រុមគ្រួសារខ្ញុំបានចាកចេញពីទីក្រុងអ៊ូរីហ្គិន ជាច្រើនឆ្នាំមកហើយ។ យើងមានអនុស្សាវរីយ៍ជាច្រើននៅទីនោះ ហើយការទៅលេងទីក្រុងនោះ កាលពីពេលថ្មីៗនេះ បានធ្វើឲ្យខ្ញុំនឹកឃើញរឿងជាច្រើនដែលខ្ញុំបានភ្លេច ដែលមានដូចជា ការប្រកួតកីឡាបាល់ទាត់សម្រាប់ក្មេងស្រី ផ្ទះចាស់របស់យើង ការជួបជុំគ្នានៅព្រះវិហារ និងភោជនីយដ្ឋានម៉ិចស៊ីកូរបស់មិត្តភក្តិយើង។ ទីក្រុងនោះមានការផ្លាស់ប្តូរ តែខ្ញុំនៅអាចនៅចាំចំណុចល្អៗជាច្រើន ល្មមនឹងលើកទឹកចិត្តខ្ញុំឲ្យចង់ត្រឡប់មកលេងម្តងទៀត។

កាលពួកអ៊ីស្រាអែលត្រូវគេនិរទេស ឲ្យចូលទៅរស់នៅជាឈ្លើយសឹកក្នុងចក្រភពបាប៊ីឡូន ពួកគេនឹកមនុស្ស ទីកន្លែងសំខាន់ៗ និងវប្បធម៌ដែលពួកគេធ្លាប់មានកាលពីមុន។ ពួកគេបានភ្លេចថា ពួកគេត្រូវគេនិរទេសដោយសារពួកគេបានបះបោរប្រឆាំងនឹងព្រះ។ កាលហោរាក្លែងក្លាយប្រាប់ពួកគេថា ពួកគេនឹងវិលត្រឡប់មកស្រុកកំណើតវិញ ក្នុងរយៈពេល២ឆ្នាំទៀត (យេរេមា ២៨:២-៤ ២៩:៨-៩) ពួកគេក៏បានជឿពួកហោរាក្លែងក្លាយទាំងនោះ។ ពួកគេងាយនឹងស្តាប់តាមពាក្យកុហករបស់ពួកហោរាក្លែងក្លាយទាំងនោះ ដែលបានសន្យាថា ពួកគេនឹងវិលត្រឡប់មកវិញ ក្នុងពេលឆាប់ៗ។

ព្រះអម្ចាស់មិនបានយល់ស្រប នឹងពួកថ្លែងទំនាយក្លែងក្លាយ ឬនាំមកនូវការសន្យាភូតកុហកនោះឡើយ។ បានជាព្រះអង្គមានបន្ទូលថា «កុំឲ្យពួកហោរា និងពួកគ្រូទាយរបស់ឯង ដែលនៅកណ្តាលពួកឯងរាល់គ្នាបញ្ឆោតឯងឡើយ» (២៩:៨)។ ព្រះអង្គមានផែនការសម្រាប់រាស្ត្រព្រះអង្គ ឲ្យពួកគេមានសេចក្តីសង្ឃឹម នៅពេលអនាគត (ខ.១១)។ ពួកគេស្ថិតក្នុងស្ថានភាពដែលមានបញ្ហាប្រឈមថ្មីៗ ដែលនាំឲ្យមានទុក្ខលំបាកជាច្រើន តែព្រះអម្ចាស់គង់នៅជាមួយពួកគេ។ គឺដូចដែលព្រះអង្គបានប្រាប់ពួកគេថា «ឯងរាល់គ្នានឹងស្វែងរកអញ ហើយនឹងឃើញផង គឺកាលណាឯងស្វែងរកអញឲ្យអស់អំពីចិត្ត» (ខ.១៣)។ ព្រះអង្គនឹងនាំពួកគេវិលត្រឡប់មកស្រុកកំណើតវិញ (ខ.១៤) តាមពេលវេលារបស់ព្រះអង្គ។

ការផ្តោតទៅលើពេលអតីតកាល អាចបង្វែរគំនិតយើងចេញពីសេចក្តីពិត ដោយយើងចង់ឲ្យពេលអតីតកាលវិលត្រឡប់មកដូចដើមវិញ។ ចូរយើងកុំភ្លេចការអ្វីដែលព្រះអម្ចាស់កំពុងតែធ្វើក្នុងជីវិតយើង ក្នុងពេលបច្ចុប្បន្ន ឡើយ។ ព្រះអង្គនឹងសម្រេចព្រះបន្ទូលសន្យារបស់ព្រះអង្គ។—Matt Lucas

តើថ្ងៃនេះ អ្នកកំពុងប្រឈមមុខដាក់ការលំបាកអ្វីខ្លះ? តើព្រះអម្ចាស់កំពុងបង្ហាញសេចក្តីស្មោះត្រង់របស់ព្រះអង្គ ក្នុងពេលដ៏ពិបាកនោះដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យបន្តមើលទៅព្រះអង្គ ក្នុងពេលបច្ចុប្បន្ន ដោយមិនផ្តោតចិត្តទៅលើពេលអតីតកាល។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១របាក្សត្រ ១០-១២ និងយ៉ូហាន ៦:៤៥-៧១

អេសាវ ក៏រត់មកទទួល ហើយឱបថើប រួចយំជាមួយគ្នាទាំង២នាក់ (លោកុប្បត្តិ ៣៣:៤)។

បង្ហាញចេញនូវសេចក្តីសប្បុរសរបស់ព្រះគ្រីស្ទ

កាលលោក អាយហ្សេយ៉ា (Isaiah) ចូលរួមការប្រកួតកីឡាវាយកូនបាល់បេសបិល ពានរង្វាន់ជើងឯកប្រចាំតំបន់ គាត់ត្រូវគេគប់កូនបាល់ចំក្បាល ធ្វើឲ្យគាត់ដួលទៅលើដី ហើយគាត់យកដៃទប់ក្បាលគាត់។ តែអរព្រះគុណព្រះអង្គ ដែលមួកសុវត្ថិភាពបានការពារក្បាលគាត់ មិនឲ្យមានរបួសធ្ងន់។ តើគាត់គួរតែឆ្លើយតបទៅគេវិញ ដោយចិត្តសប្បុរស ឬដោយការសងសឹក? នៅពេលដែលគេបន្តការប្រកួត លោក អាយហ្សេយ៉ា ក៏បានកត់សម្គាល់ឃើញ អ្នកគប់កូនបាល់កំពុងឈរញ័រខ្លួន ដោយសារកំហុសដែលខ្លួនបានធ្វើដោយអចេតនា។ ក្នុងពេលនោះ លោក អាយហ្សេយ៉ា ក៏បានធ្វើនូវរឿងដែលគេមិននឹកស្មានដល់ ដោយគាត់ដើរទៅរកកីឡាករនោះ ហើយឱបកីឡានោះ ដោយការកម្សាន្តចិត្ត ហើយលោក អាយហ្សេយ៉ា ក៏បានបញ្ជាក់ដល់កីឡានោះថា គាត់មិនអីទេ។ វីដេអូដែលគេថតបានសកម្មភាពគាត់នៅពេលនោះ ត្រូវគេយកទៅបង្ហោះនៅតាមបណ្តាញសង្គម ហើយមានមនុស្សជាច្រើនបានចែកចាយបន្តគ្នា។

ក្នុងស្ថានភាពដែលអាចបណ្តាលឲ្យមានការវាយតប់គ្នា លោក អាយហ្សេយ៉ា បានសម្រេចចិត្តជ្រើសរើសយកសេចក្តីសប្បុរស។

ក្នុងកណ្ឌគម្ពីរសញ្ញាចាស់ យើងឃើញថា លោក អេសាវ បានធ្វើនូវរឿងស្រដៀងនេះផងដែរ ទោះជាមានការពិបាកជាងនេះរាប់រយដងក៏ដោយ ដោយគាត់បានសម្រេចចិត្តបោះបង់ចោលផែនការសងសឹកអស់ជាច្រើនឆ្នាំមកលើលោក យ៉ាកុប ជាប្អូនប្រុស ដែលពូកែបោកប្រាស់អ្នកដទៃ។ បន្ទាប់ពីលោក យ៉ាកុប បានវិលត្រឡប់មកផ្ទះវិញ បន្ទាប់គាត់បាននិរទេសខ្លួនបាន២០ឆ្នាំ លោក អេសាវ ក៏បានបង្ហាញនូវចិត្តសប្បុរស និងការអត់ឱនទោសជាជាងសងសឹក ចំពោះកំហុសដែលលោក យ៉ាកុប បានធ្វើមកលើគាត់។ នៅពេលដែលលោក អេសាវ បានឃើញលោក យ៉ាកុប គាត់ក៏បានរត់ទៅឱបលោក យ៉ាកុប (លោកុប្បត្តិ ៣៣:៤)។ លោក អេសាវក៏បានទទួលយកការសុំទោសរបស់លោក យ៉ាកុប ហើយក៏បានបញ្ជាក់ឲ្យលោក យ៉ាកុប ដឹងថាគាត់មិនអីទេ (ខ.៩-១១)។

នៅពេលណានរណាម្នាក់បង្ហាញចេញនូវការសោកស្តាយ ចំពោះកំហុសដែលបានធ្វើមកលើយើង យើងត្រូវធ្វើការសម្រេចចិត្តថា យើងនឹងបង្ហាញចេញនូវចិត្តសប្បុរស ឬការសងសឹក។ ការសម្រេចចិត្តអត់ទោសឲ្យគេ ដោយចិត្តសប្បុរស គឺជាការយកគំរូតាមព្រះយេស៊ូវ (រ៉ូម ៥:៨) ហើយជាផ្លូវឆ្ពោះទៅរកការផ្សះផ្សា។—Lisa M. Samra

តើគេបានបង្ហាញចិត្តសប្បុរសចំពោះអ្នក បន្ទាប់ពីអ្នកបានទទួលស្គាល់កំហុស នៅពេលណា? តើអ្នកអាចបង្ហាញចិត្តសប្បុរសដល់អ្នកផ្សេងទៀត យ៉ាងដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំ ឲ្យដើរតាមគំរូរបស់ព្រះអង្គ ដោយបង្ហាញសេចក្តីសប្បុរស ពេលណាគេធ្វើខុសមកលើទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១របាក្សត្រ ១៣-១៥ និងយ៉ូហាន ៧:១-២៧

ដ្បិតព្រះនេត្រនៃព្រះយេហូវ៉ាចេះតែទតច្រវាត់ នៅគ្រប់លើផែនដីទាំងមូល ដើម្បីនឹងសម្តែងព្រះចេស្តា ជួយដល់អស់អ្នកណាដែលមានចិត្តស្មោះត្រង់ចំពោះទ្រង់ (២របាក្សត្រ ១៦:៩)។

បន្តមានភាពរឹងមាំខាងវិញ្ញាណ

ខ្សែភាពយន្ត រឿង ដឹ រ៉ាក់គី (The Rocky) និយាយអំពីកីឡាការប្រដាល់សកលម្នាក់ ដែលទទួលការជំរុញចិត្ត ពីការប្តេជ្ញាចិត្ត ស៊ូស្លាប់មិនព្រមបោះបង់ចោលការតស៊ូ ដែលបានជម្នះឧបសគ្គដ៏ពិបាកបំផុត ដើម្បីក្លាយជាជើងឯកទម្ងន់ធ្ងន់។ ក្នុងខ្សែភាពយន្ត ដឹ រ៉ាក់គី វគ្គ៣ តួអង្គរ៉ាក់គី មានការស្ទប់ស្ទែង ចំពោះភាពជោគជ័យរបស់ខ្លួនឯង។ ដោយសារភាពល្បីល្បាញរបស់គាត់ គាត់ក៏បានទៅថតស្ប៉តពាណិជ្ជកម្ម ដែលគេចាក់ផ្សាយតាមទូរទស្សន៍ធ្វើឲ្យគាត់មិនមានពេលគ្រប់គ្រាន់សម្រាប់ការហ្វឹកហាត់។ ជើងឯកកីឡាប្រដាល់រូបនេះក៏បានប្រែជាទន់ជ្រាយ ហើយគេក៏បានបបួលគាត់ប្រកួតគ្នាក្រៅសង្វៀន ហើយក៏ត្រូវគេវាយឲ្យសន្លប់។ បន្ទាប់មក គាត់ក៏បានព្យាយាមស្តាមមត្ថភាពប្រយុទ្ធរបស់គាត់ឲ្យខ្លាំងឡើងវិញ។

ក្នុងន័យខាងវិញ្ញាណ ស្តេច អេសា នៃនគរយូដាក៏បានបាត់បង់សមត្ថភាពប្រយុទ្ធដងដែរ។ ក្នុងដើមដំបូងនៃការគ្រប់គ្រងរបស់ទ្រង់ ទ្រង់បានពឹងផ្អែកទៅលើព្រះអម្ចាស់នៅក្នុងការប្រឈមមុខដាក់បញ្ហាធំៗ។ ខណៈពេលដែលកងទ័ពរបស់សត្រូវមានគ្នាច្រើនជាង លើកទ័ពចូលទឹកដីទ្រង់ ទ្រង់ក៏បានអធិស្ឋានថា «ព្រះយេហូវ៉ាជាព្រះនៃយើងរាល់គ្នាអើយ សូមជួយយើងខ្ញុំផង ដ្បិតយើងខ្ញុំផ្អែកលើទ្រង់ជាទីពឹង គឺដោយនៅតែព្រះនាមទ្រង់ប៉ុណ្ណោះ ដែលយើងរាល់គ្នាបានមក ទាស់នឹងពួកមានគ្នាច្រើនទាំងនេះ» (២របាក្សត្រ ១៤:១១)។ ព្រះអម្ចាស់ក៏បានឆ្លើយតបការអធិស្ឋានរបស់ទ្រង់ ដោយប្រទានពរកងទ័ពរបស់សាសន៍យូដាក៏បានវាយបំបាក់កងទ័ពសត្រូវឲ្យរត់ខ្ចាត់ខ្ចាយ (ខ.១២-១៥)។

ជាច្រើនឆ្នាំក្រោយមក នគរយូដាក៏បានទទួលរងការគំរាមកំហែងសារជាថ្មី។ នៅពេលនេះ ស្តេច អេសា ដែលមានទំនុកចិត្តលើខ្លួនឯង បានព្រងើយកន្តើយចំពោះព្រះអម្ចាស់ ហើយក៏បានពឹងស្តេចរបស់នគរស៊ីរី (១៦:២-៣)។ ពេលនោះ ទ្រង់ហាក់ដូចជាមានជ័យជម្នះទៀត។ ប៉ុន្តែ ព្រះអម្ចាស់មិនបានសព្វព្រះទ័យទេ។ ហោរា ហាណានី ក៏បានប្រាប់ស្តេច អេសាថា ទ្រង់បានឈប់ទុកចិត្តលើព្រះអម្ចាស់ហើយ (ខ.៧-៨)។ ហេតុអ្វីទ្រង់មិនបានពឹងផ្អែកលើព្រះអម្ចាស់ដូចកាលពីមុន?

ព្រះនៃយើងមានលក្ខណៈដែលយើងអាចទុកចិត្តបានទាំងស្រុង។ ព្រះនេត្រព្រះអង្គ «ចេះតែទតច្រវាត់ នៅគ្រប់លើផែនដីទាំងមូល ដើម្បីនឹងសំដែងព្រះចេស្តា ជួយដល់អស់អ្នកណាដែលមានចិត្តស្មោះត្រង់ចំពោះទ្រង់» (ខ.៩)។ ពេលណាយើងបន្តមានភាពរឹងមាំខាងវិញ្ញាណ ដោយពឹងផ្អែកលើព្រះអង្គទាំងស្រុង យើងនឹងបានដកពិសោធន៍ជាមួយព្រះចេស្តាព្រះអង្គ។—Mike Wittmer

ពេលដែលអ្នកមានវ័យកាន់តែចាស់ តើអ្នកកាត់តែងាយស្រួល ឬកាន់តែពិបាកទុកចិត្តព្រះវរបិតាដែលគង់នៅស្ថានសួគ៌? ហេតុអ្វីអ្នកគិតថា កាន់តែពិបាក? តើព្រះអង្គបានពង្រឹងជំនឿអ្នកដូចម្តេចខ្លះ?

និយាយទូលព្រះយេស៊ូវ ទូលបង្គំសូមសម្រាកក្នុងព្រះអង្គជាបន្ថែមទៀតជារៀងរាល់ថ្ងៃ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ២របាក្សត្រ ១៦-១៨ និងយ៉ូហាន ៧:២៨-៥៣

ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការដែលព្រះហស្តទ្រង់ធ្វើ (ទំនុកតម្កើង ១៩:១)។

មើលថ្ងៃលិចសរសើរតម្កើងព្រះ

លោក អាលែក ស្មលលេយ (Alex Smalley) ចង់ឲ្យគេរាល់គ្នាឆាប់ក្រោកពីដំណេក ឬប្រហែលជាសម្រាកលំហែនៅពេលល្ងាច។ តើហេតុអ្វី? គឺដើម្បីគយគន់ទេសភាពថ្ងៃរះ និងថ្ងៃលិច។ ពេលវេលាទាំងនោះ កន្លងផុតទៅឆាប់រហ័ស ជាពេលដែលមានភាពស្រស់ស្អាតបំផុត ដែលនាំឲ្យមនុស្សមានចិត្តស្ងប់ស្ងែងក្នុងថ្ងៃនីមួយៗ។ នេះបើយោងតាមលោក ស្មលលេយ ជាអ្នកស្រាវជ្រាវឈានមុខគេ ក្នុងការសិក្សារបស់ជនជាតិអង់គ្លេស អំពីទេសភាពដ៏គួរឲ្យស្ងប់ស្ងែង ដែលកើតឡើងពីកត្តាអាកាសធាតុ។ ទេសភាពថ្ងៃរះ និងថ្ងៃលិចដ៏ស្រស់ស្អាតអាចធ្វើឲ្យយើងមានអារម្មណ៍ល្អជាងមុន និងបង្កើតអារម្មណ៍វិជ្ជមាន ហើយកាត់បន្ថយស្ត្រេសគឺបានច្រើនជាងទេសភាពដែលមានផ្ទៃមេឃស្រឡះពណ៌ខៀវឬមានផ្កាយពេញមេឃនៅពេលយប់ទៅទៀត។ លោក ស្មលលេយ មានប្រសាសន៍ថា «ពេលណាអ្នកមើលឃើញអ្វីមួយលាតសន្ធឹងធំធេង ហើយមានភាពស្រស់ស្អាតក្រៃលែង ឬអ្វីមួយដែលធ្វើឲ្យអ្នកមានអារម្មណ៍ស្ងប់ស្ងែង អ្នកអាចមានអារម្មណ៍ថា បញ្ហាមានការថមថយ ហើយអ្នកមិនចាំបាច់ត្រូវព្រួយបារម្ភច្រើន អំពីបញ្ហាទាំងនោះទៀតទេ»។

ការរកឃើញភាពអស្ចារ្យក្នុងធម្មជាតិយ៉ាងដូចនេះ បានធ្វើឲ្យខ្ញុំនឹកចាំអំពីហោរា យេរេមា ដែលបានពោលសរសើរព្រះអម្ចាស់ថា «ឱព្រះអម្ចាស់យេហូវ៉ាអើយ មើល ទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី ដោយសារព្រះចេស្តាដ៏ធំរបស់ទ្រង់ និងព្រះពាហុដ៏លើកសំរេច គ្មានអ្វីដែលពិបាកពេកដល់ទ្រង់ទេ» (យេរេមា ៣២:១៧)។

ស្តេច ដាវីឌ ក៏បានគយគន់ស្នាព្រះហស្តដ៏ស្រស់ស្អាតរបស់ព្រះអម្ចាស់ ដោយប្រកាសថា «ផ្ទៃមេឃសំដែងពីសិរីល្អនៃព្រះ ហើយលំហអាកាសក៏បង្ហាញការ ដែលព្រះហស្តទ្រង់ធ្វើ» (ទំនុកតម្កើង ១៩:១)។ «ព្រះអាទិត្យក៏រះពីជើងមេឃម្ខាង ហើយដើរវង់ទៅដល់ជើងមេឃម្ខាង គ្មានរបស់អ្វីលាក់កំបាំងពីកំដៅនៃព្រះអាទិត្យទេ» (ខ.៦)។ ហេតុនេះហើយ ទ្រង់ក៏បានពិពណ៌នាថា «ឯក្រឹត្យវិន័យរបស់ព្រះយេហូវ៉ានោះគ្រប់លក្ខណ៍ ក៏កែព្រលឹងឡើងវិញ» (ខ.៧)។ ស្មាព្រះហស្តដ៏រុងរឿងរបស់ព្រះអង្គឆ្លុះបញ្ចាំង អំពីព្រះអាទិការដែលមានគ្រប់ចេស្តា។ នៅថ្ងៃនេះ សូមយើងចំណាយពេលមើលទៅផ្ទៃមេឃ ហើយស្ងើចសរសើរព្រះអង្គ!—Patricia Raybon

តើអ្នកចូលចិត្តទៅមើលថ្ងៃរះ ឬថ្ងៃលិចនៅកន្លែងណា? ពេលណាអ្នកមើលទៅភាពស្រស់ស្អាតនៃផ្ទៃមេឃ តើអ្នកបាននឹកចាំអំពីលក្ខណៈសម្បត្តិអ្វីខ្លះរបស់ព្រះអង្គ?

ឱព្រះវរបិតា ក្នុងស្ថានសួគ៌ដ៏រុងរឿងរបស់ព្រះអង្គ ព្រះអង្គបានបង្ហាញទូលបង្គំ នូវភាពអស្ចារ្យនៃព្រះចេស្តាព្រះអង្គ។

Daily Manna 2026_Content Enhance.indd 149 17/11/25 1:45 in the afternoon

ព្រះដែលទ្រង់វាយផ្ចាល នោះសំរាប់ជាប្រយោជន៍ដល់យើងវិញ ដើម្បីឲ្យយើងបានសេចក្ដីបរិសុទ្ធ របស់ទ្រង់ (ហេព្រើរ ១២:១០)។

កែតម្រង់ ដើម្បីជាប្រយោជន៍យើង

រឿងប្រៀបប្រដូច ដែលលោក ចច មែកដូណាល់ (George MacDonald) បាននិពន្ធមានចំណងជើងថា ស្ត្រីមានប្រាជ្ញា បានដំណាលអំពីភាពអាត្មានិយមរបស់ក្មេងស្រីពីរនាក់ ដែលនាំមកនូវសេចក្ដីទុក ដល់គេរាល់គ្នា រាប់បញ្ចូលទាំងខ្លួនឯងដែរ ទាល់តែមានស្ត្រីមានប្រាជ្ញាម្នាក់ បាននាំពួកគេធ្វើតេស្តជាបន្តបន្ទាប់ ដើម្បីជួយពួកគេឲ្យក្លាយជាក្មេង «គួរឲ្យស្រឡាញ់» ឡើងវិញ។

បន្ទាប់ពីក្មេងស្រីទាំងពីរបានបរាជ័យនៅក្នុងការធ្វើតេស្តនីមួយៗ ហើយមានអារម្មណ៍អៀនខ្មាស និងឯកោទីបំផុត រ៉ូសាមុន (Rosamond) ជាក្មេងស្រីម្នាក់ក្នុងចំណោមក្មេងទាំងពីរ ក៏បានដឹងថា នាង មិនអាចកែប្រែអត្តចរិតរបស់នាង បានទេ។ នាង ក៏បានសួរស្ត្រីអ្នកប្រាជ្ញថា «អ្នកគ្រូ អាចជួយខ្ញុំបានទេ?» ស្ត្រីនោះក៏បានឆ្លើយថា «ដោយសារប្អូនសួរខ្ញុំហើយ នោះខ្ញុំប្រហែលជាអាចជួយប្អូនបាន»។ ដោយសារជំនួយរបស់ស្ត្រីអ្នកប្រាជ្ញ រ៉ូសាមុន ក៏បានចាប់ផ្តើមមានការផ្លាស់ប្តូរ។ បន្ទាប់មក នាងក៏បានសុំឲ្យស្ត្រីអ្នកប្រាជ្ញអត់ទោសឲ្យនាង ចំពោះកំហុសដែលនាង បានបង្កឡើង។ ស្ត្រីអ្នកប្រាជ្ញក៏បានប្រាប់នាង ថា «អ្នកគ្រូ ស្តីប្រដៅឲ្យប្អូន គឺដោយសារអ្នកគ្រូស្រឡាញ់ប្អូន»។

នៅពេលខ្លះ ព្រះអម្ចាស់វាយផ្ចាលយើង។ យើងចាំបាច់ត្រូវយល់អំពីហេតុផលរបស់ព្រះអង្គ។ ការកែតម្រង់របស់ព្រះអង្គ គឺមិនមែនជាការសងសឹកមកលើយើងទេ តែដោយសារព្រះអង្គយកព្រះទ័យទុកដាក់ចំពោះសុខុមាលភាពរបស់យើង ក្នុងនាមព្រះអង្គជាឪពុក (ហេព្រើរ ១២:៦)។ ព្រះអង្គក៏សព្វព្រះទ័យឲ្យយើងមានសេចក្ដីបរិសុទ្ធរបស់ព្រះអង្គ ដោយអរសប្បាយនឹងការច្រូតកាត់ផលនៃ សេចក្ដីសុចរិត និងសេចក្ដីសុខសាន្ត (ខ.១០-១១)។ ភាពអាត្មានិយមនាំមកនូវទុក្ខវេទនា តែសេចក្ដីបរិសុទ្ធធ្វើឲ្យយើងមានភាពពេញលេញ មានអំណរ និងគួរឲ្យស្រឡាញ់ដូចព្រះអង្គផងដែរ។

រ៉ូសាម៉ុន បានសួរស្ត្រីអ្នកប្រាជ្ញថា ហេតុអ្វីគាត់ស្រឡាញ់ក្មេងស្រីអាត្មានិយមដូចនាង។ គាត់ក៏បានឱនទៅថើបនាង ហើយឆ្លើយប្រាប់ថា គាត់មានការជឿជាក់ថា នាងនឹងក្លាយជាមនុស្សល្អ។ រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំថា ការកែតម្រង់របស់ព្រះ ក៏កើតចេញពីសេចក្ដីស្រឡាញ់ និងបំណងព្រះទ័យ ដែលចង់កែប្រែយើងឲ្យបានល្អ តាមបំណងព្រះទ័យព្រះអង្គ។—Sheridan Voysey

តើអ្នកមានការយល់ឃើញដូចម្តេចខ្លះ អំពីការវាយផ្ចាលរបស់ព្រះកាលពីមុន? តើព្រះអង្គអាចកែតម្រង់អ្នកដូចម្តេចខ្លះ ក្នុងពេលថ្មីៗនេះ ដើម្បីឲ្យអ្នកកាន់តែមានសេចក្ដីបរិសុទ្ធ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការកែតម្រង់ ទោះមានការឈឺចាប់នៅពេលខ្លះក៏ដោយ។ ព្រះអង្គប្រទានការកែតម្រង់ ដើម្បីជាប្រយោជន៍ដល់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ១របាក្សត្រ ២២-២៤ និងយ៉ូហាន ៨:២៨-៥៩

ដូច្នេះ យើងខ្ញុំជាទូតដំណាងព្រះគ្រីស្ទ... គឺយើងខ្ញុំអង្វរគេជំនួសព្រះគ្រីស្ទថា ចូរឲ្យបានជាមេត្រីនឹងព្រះចុះ (២កូរិនថូស ៥:២០)។

ទៅប្រាប់គេ អំពីការអ្វីដែលព្រះអង្គបានធ្វើ

លោក ប៊ីល ថូបៀស (Tobias) មិត្តភក្តិរបស់ខ្ញុំ ដែលរៀនជាមួយគ្នានៅមហាវិទ្យាល័យ។ គាត់បានទៅធ្វើការបម្រើព្រះ ជាបេសកជននៅលើកោះមួយ ក្នុងមហាសមុទ្របាស៊ីហ្វិកអស់ជាច្រើនឆ្នាំ។ គាត់បានចែកចាយទីបន្ទាល់របស់យុវជនវ័យក្មេងម្នាក់ ដែលបានចាកចេញពីស្រុកកំណើតទៅស្វែងរកភាពមានបាន។ តែមិត្តភក្តិគាត់ម្នាក់បាននាំគាត់ ទៅព្រះវិហារ ដែលនៅទីនោះ គាត់បានឮដំណឹងល្អរបស់ព្រះយេស៊ូវ ហើយគាត់ក៏បានទទួលជឿព្រះអង្គជាព្រះអង្គសង្គ្រោះ។

យុវជននោះចង់នាំដំណឹងល្អទៅចែកចាយដល់ប្រជាជនគាត់ ដែល «កំពុងផុងខ្លួនជ្រៅក្នុងអំពើមន្តអាគម» ដូចនេះ គាត់ក៏បានស្វែងរកបេសកជនម្នាក់ ឲ្យទៅឈោងចាប់ពួកគេ។ ប៉ុន្តែ មានបេសកជនម្នាក់បានប្រាប់គាត់ឲ្យចេញទៅប្រាប់ពួកគេ អំពីការអ្វីដែលព្រះបានធ្វើសម្រាប់គាត់ (មើលម៉ាកុស ៥:១៩)។ គាត់ក៏បានធ្វើតាមការណែនាំរបស់បេសកជនរូបនោះ។ មនុស្សមួយចំនួនក្នុងស្រុកកំណើតរបស់គាត់ក៏បានទទួលជឿព្រះយេស៊ូវ តែភាពផុសផុលធំបំផុតកើតមាន នៅពេលដែលមេធ្មប់ម្នាក់ប្រចាំតំបន់នោះបានដឹងថា ព្រះយេស៊ូវជាផ្លូវ ជាសេចក្តីពិត និងជាជីវិត (យ៉ូហាន ១៤:៦)។ មេធ្មប់នោះបានទទួលជឿព្រះយេស៊ូវ ហើយក៏បានចែកចាយអំពីព្រះអង្គនៅទូទាំងតំបន់ដែលពួកគេរស់នៅ។ ក្នុងរយៈពេល៨ឆ្នាំ ការធ្វើបន្ទាល់របស់យុវជននោះ នាំឲ្យមានការបង្កើតពួកជំនុំបាន៧កន្លែងក្នុងតំបន់នោះ។

ក្នុងបទគម្ពីរ២កូរិនថូស សាវ័ក ប៉ុល បានបង្ហាញនូវផែនការដ៏ច្បាស់លាស់មួយ សម្រាប់ផ្សាយដំណឹងល្អដល់អ្នកដែលមិនបានស្គាល់ព្រះគ្រីស្ទ ហើយបេសកជននោះក៏បានអនុវត្តតាម ដោយប្រាប់យុវជននោះជាអ្នកជឿព្រះ ឲ្យទៅផ្សាយដំណឹងល្អ។ យើងត្រូវធ្វើដា «ទូតព្រះគ្រីស្ទ» ជាអ្នកតំណាងព្រះអង្គ ដោយអនុញ្ញាតឲ្យព្រះអង្គប្រើយើង នាំព្រះបន្ទូលព្រះអង្គចែកចាយអ្នកដទៃ (៥:២០)។ អ្នកជឿម្នាក់ៗមានរឿងពិសេសរៀងខ្លួន ដើម្បីចែកចាយអំពីរបៀបដែលព្រះយេស៊ូវ បានធ្វើឲ្យពួកគេកើតជាថ្មី ហើយបានផ្សះផ្សាពួកគេឲ្យជានឹងព្រះ (ខ.១៧-១៨)។ ចូរយើងប្រាប់អ្នកដទៃ អំពីការអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង ជាទីបន្ទាល់ ដែលធ្វើឲ្យពួកគេបើកចិត្តឲ្យទទួលដំណឹងល្អរបស់ព្រះអង្គ។—Dave Branon

តើសេចក្តីសង្គ្រោះរបស់ព្រះយេស៊ូវ មានន័យយ៉ាងណាចំពោះអ្នក? តើអ្នកអាចត្រៀមខ្លួនដូចម្តេចខ្លះដើម្បីចែកចាយរឿងរបស់អ្នក ដល់អ្នកដទៃ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យចែកចាយរឿងនៃសេចក្តីជំនឿទូលបង្គំ ជាមួយអ្នកដទៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១របាក្សត្រ ២៥-២៧ និងយ៉ូហាន ៩:១-២៣

និងចែកឲ្យដល់ពួកអ្នកដែលសោយសោក នៅក្រុងស៊ីយ៉ូនបានភួងលំអជំនួសផេះ ហើយប្រេងនៃសេចក្តីអំណរជំនួសសេចក្តីសោកសៅ ព្រមទាំងអាវពាក់នៃសេចក្តីសរសើរ ជំនួសទុក្ខធ្ងន់ដែលគ្របសង្កត់ (អេសាយ ៦១:៣)។

ភាពស្រស់ស្អាត ក្នុងកន្លែងអស់សង្ឃឹម

នៅពេលល្ងាចមួយនោះ ខ្ញុំបានកត់សម្គាល់ឃើញថ្មាលដំណាំជាជួរ ក្នុងដីឡូរំក្បែរផ្ទះខ្ញុំ។ ជួរនីមួយៗមានស្លឹកឈើពណ៌បៃតងតូចៗដុះចេញពីដី ជាមួយពន្លកតូចៗ។ នៅពេលព្រឹកបន្ទាប់ ពេលខ្ញុំកំពុងធ្វើដំណើរតាមផ្លូវ ខ្ញុំក៏បានឈប់ត្រឹងមួយកន្លែង ពេលដែលខ្ញុំបានឃើញកូនដើមផ្កាធូលីបពណ៌ក្រហម ក្នុងចំនួនច្រើនសន្ធឹក កំពុងដុះឡើង ក្នុងដីឡូនោះ។

ក្នុងរដូវស្លឹកឈើជ្រុះកាលពីឆ្នាំមុន មានមនុស្សមួយក្រុមបានយកមើមដើមផ្កាធូលីបមកដាំ ក្នុងដីឡូដែលគេទុកចោល នៅទូទាំងភាគខាងត្បូងនៃទីក្រុងឈីកាហ្គោ។ ពួកគេបានជ្រើសរើសយកពូជផ្កាធូលីបពណ៌ក្រហម ជាតំណាងឲ្យការរើសអើងរបស់ធនាគារ មកលើអ្នកស្នើសុំប្រាក់កម្ចី ដែលមានផលប៉ះពាល់មកលើតំបន់ ដែលជនជាតិភាគតិចរស់នៅ។ ផ្កាធូលីបទាំងនោះជាតំណាងឲ្យផ្ទះ ដែលគេអាចសាងសង់នៅលើដីឡូទាំងនោះ។

រាស្ត្ររបស់ព្រះបានស៊ូទ្រាំនឹងបញ្ហាប្រឈមជាច្រើន ដែលរាប់ចាប់តាំងពីការនិរទេសចេញពីស្រុកកំណើត រហូតដល់ការរើសអើង ដោយប្រកាន់ពូជសាសន៍ជាដើម។ តែយើងនៅតែអាចរកឃើញក្តីសង្ឃឹម។ កណ្ឌគម្ពីរអេសាយបានរំឭកប្រជាជនអ៊ីស្រាអែល ក្នុងអំឡុងពេលនិរទេសថា ព្រះអម្ចាស់នឹងមិនចាកចេញពីពួកគេឡើយ។ ព្រះអង្គនឹងប្រទាន «ភួងលម្អ» ជំនួសផេះ។ សូម្បីតែអ្នកក្រក៏នឹងទទួល «ដំណឹងល្អ» (៦១:១)។ ព្រះអម្ចាស់បានសន្យាថានឹងកែប្រែវិញ្ញាណដែលអស់សង្ឃឹម ឲ្យក្លាយជា «អាវនៃសេចក្តីសរសើរ»។ ពាក្យប្រៀបប្រដូចទាំងនេះបានបង្ហាញនូវសិរីល្អរបស់ព្រះអង្គ ហើយនាំក្តីអំណរដល់រាស្ត្រព្រះអង្គ ដែលបានប្រែក្លាយជា «ដើមឈើនៃសេចក្តីសុចរិត» គឺមិនមែនជាឈ្លើយសឹកដែលអស់អស់សង្ឃឹមទៀតទេ (ខ.៣)។

ផ្កាធូលីបទាំងនោះក៏បានបង្ហាញឲ្យយើងដឹងថា ព្រះអម្ចាស់អាចបង្កើតឲ្យមានភាពស្រស់ស្អាត ចេញពីដី និងការរើសអើង។ ខ្ញុំបានទន្ទឹងរង់ចាំពេលដែលខ្ញុំនឹងបានគយគន់ផ្កាធូលីបទាំងនោះ រៀងរាល់ដូវផ្ការីក ហើយដែលសំខាន់ជាងនេះទៀតនោះ គឺខ្ញុំរង់ចាំក្តីសង្ឃឹមដែលកើតមានជាថ្មីក្នុងតំបន់ដែលខ្ញុំរស់នៅ និងសហគមន៍ដទៃទៀត។—Katara Patton

តើអ្នកបានឃើញភាពស្រស់ស្អាត ជំនួសឲ្យភាពអស់សង្ឃឹមក្នុងផ្នែកណាខ្លះ ក្នុងសហគមន៍របស់អ្នក? តើអ្នកអាចជួយបង្កើតឲ្យមានភាពស្រស់ស្អាត ក្នុងកន្លែងអស់សង្ឃឹមដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានភាពស្រស់ស្អាត នៅពេលណាស្ថានភាពទូលបង្គំហាក់ដូចជាអស់សង្ឃឹម។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ១កូរិនថូស ២៨-២៩ និងយ៉ូហាន ៩:២៤-៤១

ចូរឲ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែលទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន (១ពេត្រុស ៥:៨)។

ដល់ពេលទៅផ្ទះរបស់យើង

នៅពេលដែលមិត្តភក្តិខ្ញុំឈ្មោះ អែ (Al) និង ខាត់ធី ស្គីហ្វ័រ (Kathy Schiffer) បើកបរយន្តហោះដ៏ល្បីល្បាញរបស់ពួកគេ ដែលនៅសល់ពីសម័យសង្គ្រាមលោកលើកទី២ ទៅកាន់កន្លែងតាំងពិព័រណ៍យន្តហោះ ការឆ្លើយតបរបស់អតីតយុទ្ធជនចំពោះយន្តហោះរបស់ពួកគេ មានន័យបំផុតចំពោះពួកគេ។ អតីតយុទ្ធជនដែលមានវ័យចាស់មួយចំនួន បានចូលមករកពួកគេ ដើម្បីជជែកគ្នាអំពីសង្គ្រាម ដែលពួកគេបានបម្រើការជាកងទ័ព និងយន្តហោះដែលពួកគេបានបើកបរ។ ភាគច្រើន នៅពេលដែលពួកគេលើកយករឿងសង្គ្រាមរបស់ពួកគេមកនិយាយ ពួកគេបានចែកចាយទាំងទឹកភ្នែក។ ពួកគេជាច្រើននាក់បានមានប្រសាសន៍ថា ដំណឹងល្អបំផុតដែលពួកគេបានទទួល ក្នុងអំឡុងពេលពួកគេកំពុងប្រើប្រទេសជាតិ គឺដំណឹងដែលគេប្រកាសថា «សង្គ្រាមចប់ហើយ! តោះយើងត្រឡប់ទៅផ្ទះវិញ»។

ពាក្យសម្តីដ៏មានន័យរបស់មនុស្សជំនាន់មុន បានធ្វើឲ្យខ្ញុំនឹកចាំ អំពីសង្គ្រាមដែលអ្នកជឿព្រះយេស៊ូវកំពុងតែតយុទ្ធ ជាការប្រយុទ្ធដ៏ល្អនៃសេចក្តីជំនឿ ប្រឆាំងនឹងអារក្សដែលជាសត្រូវខាងវិញ្ញាណរបស់យើង។ សាវ័កពេត្រុស បានដាស់តឿនយើងថា «អារក្សដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន» (១ពេត្រុស ៥:៨)។ វាល្បួងយើង តាមមធ្យោបាយផ្សេងៗ ហើយប្រើការបាក់ទឹកចិត្ត ក្នុងទុក្ខលំបាក និងការបៀតបៀន ដើម្បីព្យាយាមទាញនាំយើង ចេញឆ្ងាយពីជំនឿលើព្រះយេស៊ូវ។ សាវ័ក ពេត្រុស ក៏បានជំរុញអ្នកអានសំបុត្រគាត់ ក៏ដូចជាយើងរាល់គ្នាក្នុងពេលបច្ចុប្បន្ន «ឲ្យដឹងខ្លួន ហើយចាំយាម» ជានិច្ច (១ពេត្រុស ៥:៨)។ យើងពឹងផ្អែកលើព្រះវិញ្ញាណបរិសុទ្ធ ដើម្បីកុំឲ្យខ្មាំងសត្រូវយើង រុញច្រានយើងឲ្យចុះចាញ់ ហើយដួលចុះនោះឡើយ។

យើងដឹងថា ថ្ងៃមួយ ព្រះយេស៊ូវនឹងយាងមកវិញ។ ពេលណាព្រះអង្គយាងមកវិញ ឬយើងលាចាកលោកមុនពេលព្រះអង្គយាងមកវិញ ព្រះអង្គនាំយើងទៅផ្ទះរបស់យើង នៅស្ថានសួគ៌ បន្ទាប់ពីសង្គ្រាមខាងវិញ្ញាណបញ្ចប់ជាស្ថាពរ យើងនឹងមានអារម្មណ៍ស្រដៀងនឹងពួកទាហាន ដែលបានវិលត្រឡប់ទៅផ្ទះវិញ នៅក្រោយសង្គ្រាមលោកលើកទី២។ ព្រះបន្ទូលព្រះអង្គហៅយើងជាកូនព្រះអង្គ ទៅនៅជាមួយព្រះអង្គ នឹងនាំឲ្យយើងស្រក់ទឹកភ្នែក ដោយក្តីអំណរ ពោរពេញក្នុងចិត្តយើង។—Anne Cetas

តើអ្នកត្រូវការជំនួយអ្វីខ្លះពីព្រះអម្ចាស់ ដើម្បីតតាំងនឹងផែនការរបស់វិញ្ញាណអាក្រក់? តើបងប្អូនរួមជំនឿរបស់អ្នកអាចជួយអ្នកដូចម្តេចខ្លះ ក្នុងរឿងនេះ?

ឱព្រះដ៏មានចេស្តា ព្រះអង្គជំប្រសើរលើសអ្វីៗទាំងអស់ ដែលទាស់ប្រឆាំងនឹងទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំឲ្យពឹងផ្អែកលើកម្លាំង និងព្រះចេស្តាព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២បាក្សត្រ ១-៣ និងយ៉ូហាន ១០:១-២៣

លុះពេលប្រហែលជាកណ្ដាលអធ្រាត្រ ប៉ុល និងស៊ីឡាស កំពុងតែអធិស្ឋាន ហើយច្រៀងសរសើរដល់ព្រះ (កិច្ចការ ១៦:២៥)។

ការសរសើរតម្កើង ដោយមិនបានព្រៀងទុក

ក្នុងអំឡុងដំណើរបេសកកម្មរយៈពេលខ្លី នៅប្រទេសអេក្វាឌ័រ ក្រុមការងាររបស់យើងបានរួមដំណើរជាមួយក្រុមមួយទៀតមកពីអង្គការក្នុងតំបន់ ដើម្បីទៅឈោងចាប់យុវជនមួយក្រុម ដែលកំពុងរស់នៅក្នុងតង់ ក្នុងតំបន់អនាធិបតេយ្យ ដោយការលំបាកជាខ្លាំង។ ពួកគេមានចិត្តរីករាយ ដែលបានជួបយើង! យើងក៏បានចែកចាយទីបន្ទាល់ ពាក្យលើកទឹកចិត្ត និងអធិស្ឋានជាមួយគ្នា។ ផ្នែកដែលខ្ញុំចូលចិត្តបំផុតនៅថ្ងៃនោះ គឺនៅពេលដែលសមាជិកក្រុមការងារប្រចាំតំបន់ បានលេងហ្គីតានាំយើងច្រៀងសរសើរតម្កើង និងថ្វាយបង្គំព្រះ ដោយមិនព្រៀងទុក ជាមួយមិត្តភក្តិថ្មីៗរបស់យើងនៅពេលខែភ្លឺ។ ពេលនោះពិតជាមានន័យណាស់។ ពួកគេរស់នៅក្នុងស្ថានភាពដែលហាក់ដូចជាគ្មានសង្ឃឹម តែពួកគេមានក្តីសង្ឃឹម និងក្តីអំណរ ដែលមានតែព្រះយេស៊ូវទេ ដែលអាចប្រទានឲ្យបាន។

បទគម្ពីរកិច្ចការជំពូក១៦ ក៏បានចែងអំពីការច្រៀងសរសើរតម្កើង ដោយមិនបានព្រៀងទុកផងដែរ។ តែការច្រៀងសរសើរតម្កើងមួយនេះ បានធ្វើឲ្យកក្រើកគុកក្នុងទីក្រុងភីលីព។ សាវ័ក ប៉ុល និងលោក ស៊ីឡា សត្រូវគេចាប់ខ្លួនដាក់គុក គេវាយដុំ ធ្វើទារុណកម្ម ខណៈពេលដែលពួកគេកំពុងធ្វើការបម្រើព្រះយេស៊ូវ។ ពួកគេមិនបានអស់សង្ឃឹមឡើយ តែផ្ទុយទៅវិញពួកគេថ្វាយបង្គំព្រះ ដោយ «ការអធិស្ឋាន និងការច្រៀងសរសើរព្រះអង្គ» នៅក្នុងគុក។ «នោះស្រាប់តែកើតមានកក្រើកដីដ៏ខ្លាំង ដល់ម្ល៉េះបានជារញ្ជួយដល់ជើងជញ្ជាំងគុកផង ហើយទ្វារទាំងប៉ុន្មានរបើកចេញភ្លាម ខ្នោះក៏រហើបចេញទាំងអស់ទៅ» (ខ.២៥-២៦)។

ពេលនោះ មេគុកគិតចង់សម្លាប់ខ្លួន ប៉ុន្តែពេលគាត់ដឹងថា អ្នកទោសមិនបានគេចខ្លួន គាត់មានការស្ទាប់ស្ទែងចំពោះការអ្វីដែលព្រះអម្ចាស់បានធ្វើ ហើយក្រុមគ្រួសាររបស់គាត់ក៏បានទទួលសេចក្តីសង្គ្រោះ (ខ.២៧-៣៤)។

ព្រះអម្ចាស់សព្វព្រះទ័យនឹងស្តាប់យើងសរសើរតម្កើងព្រះអង្គ។ ចូរយើងថ្វាយបង្គំព្រះអង្គ ក្នុងអំឡុងពេលដែលយើងរីករាយ ក៏ដូចជាពេលដែលយើងជួបទុក្ខលំបាកក្នុងជីវិតផងដែរ។—Nancy Gavilanes

តើព្រះទ្រង់បានជួយឲ្យអ្នកសរសើរតម្កើង និងថ្វាយបង្គំព្រះអង្គដូចម្តេចខ្លះ នៅក្នុងពេលដែលមានការលំបាក? តើព្រះអង្គបានបើកសម្តែងអង្គទ្រង់ តាមរបៀបដែលគួរឲ្យកត់សម្គាល់ដូចម្តេចខ្លះ នៅពេលដែលអ្នកសរសើរតម្កើង និងថ្វាយបង្គំព្រះអង្គនៅពេលនោះ?

ព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យសរសើរតម្កើងព្រះអង្គ ទោះទូលបង្គំកំពុងប្រឈមមុខដាក់បញ្ហាអ្វីក៏ដោយ។

Daily Manna 2026_Content Enhance.indd 154 17/11/25 1:45 in the afternoon

ចូរមានចិត្តសប្បុរសនឹងគ្នាទៅវិញទៅមក ព្រមទាំងមានចិត្តទន់សន្តោស ហើយអត់ទោសគ្នា (អេភេសូរ ៤:៣២)។

កុំភ្លេចបង្ហាញសេចក្តីសប្បុរស

តើខ្ញុំមានការស្តាយក្រោយ ចំពោះរឿងអ្វីខ្លះ?” នេះជាសំណួរ ដែលលោក ចន សូនឌ័រ (George Saunders) ជាអ្នកនិពន្ធដ៏ល្បីល្បាញ បានឆ្លើយក្នុងការឡើងថ្លែងសន្ទរកថា ក្នុងពិធីចែកសញ្ញាប័ត្រនៅឆ្នាំ២០១៣ នៅមហាវិទ្យាល័យ ស៊ីរ៉ាគូស។ វិធីសាស្ត្ររបស់គាត់នៅក្នុងការឆ្លើយសំណួរនេះ គឺបានលើកទឹកទឹកចិត្តមនុស្សមានវ័យចាស់ជាង ឲ្យចែកចាយអំពីការស្តាយក្រោយមួយ ឬពីរយ៉ាង ដែលពួកគេមានក្នុងជីវិត ដល់មនុស្សមានវ័យក្មេងជាង ដែលអាចរៀនសូត្រពីគំរូរបស់ពួកគេ។ គាត់ក៏បានលើកឡើងផងដែរ អំពីរឿងមួយចំនួនដែលគេគិតស្មានថា គាត់មានការស្តាយក្រោយ ដែលមានដូចជា ភាពក្រីក្រ និងការមានការងារមិនល្អ។ តែលោក សូនឌ័រ មានប្រសាសន៍ថា គាត់មិនមានការសោកស្តាយចំពោះរឿងទាំងនេះទេ។ ទោះជាយ៉ាងណាក៏ដោយ អ្វីដែលគាត់ពិតជាស្តាយក្រោយនោះ គឺការខកខានមិនបានបង្ហាញសេចក្តីសប្បុរសដល់អ្នកដទៃ ឬខកខានមិនបានឆក់ឱកាសបង្ហាញចិត្តសប្បុរសដល់នរណាម្នាក់។

សាវ័ក ប៉ុល បានសរសេរសំបុត្រផ្ញើទៅពួកជំនុំនៅទីក្រុងអេភេសូរ ដោយឆ្លើយសំណួរដែលសួរថា តើជីវិតគ្រីស្ទបរិស័ទមានលក្ខណៈដូចម្តេចខ្លះ? យើងប្រហែលប្រញាប់ឆ្លើយសំណួរនេះ ដោយលើកឡើងថា គ្រីស្ទបរិស័ទត្រូវមានទស្សនៈនយោបាយបែបណាមួយ ត្រូវជឿសវាងសៀវភៅ ឬខ្សែភាពយន្ត និងថ្វាយបង្គំតាមរបៀបណាមួយជាដើម។ ប៉ុន្តែ សាវ័ក ប៉ុល មិនបាននិយាយតែអំពីបញ្ហាក្នុងសម័យដែលគាត់រស់នៅនោះទេ។ គាត់បានលើកឡើង អំពីការជៀសវាងការ «ពោលពាក្យអាក្រក់» (អេភេសូរ ៤:២៩) និងការជម្រះចោលចិត្តជូរល្វីង និងកំហឹង (ខ.៣១)។ ហើយគាត់ក៏បានប្រាប់យើងផងដែរថា «ចូរមានចិត្តសប្បុរសនឹងគ្នាទៅវិញទៅមក» (ខ.៣២)។ ហើយមូលហេតុ គឺដោយសារព្រះអម្ចាស់ក៏បានបង្ហាញសេចក្តីសប្បុរស ចំពោះយើងតាមរយៈព្រះគ្រីស្ទផងដែរ។

យើងជឿថា អ្នកជឿព្រះយេស៊ូវត្រូវមានលក្ខណៈសម្បត្តិល្អៗជាច្រើន ហើយក្នុងចំណោមនោះ យើងក៏ត្រូវមានសេចក្តីសប្បុរសចំពោះអ្នកដទៃផងដែរ។—John Blasé

តើថ្មីៗនេះ អ្នកខកខានមិនបានបង្ហាញសេចក្តីសប្បុរស នៅកន្លែងណាខ្លះ? តើអ្នកអាចមានជោគជ័យនៅក្នុងការបង្ហាញសេចក្តីសប្បុរសនៅថ្ងៃនេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ដោយសារព្រះអង្គមានសេចក្តីសប្បុរសចំពោះទូលបង្គំ សូមព្រះអង្គជួយទូលបង្គំឲ្យមានចិត្តសប្បុរសចំពោះអ្នកដទៃផងដែរ។

Daily Manna 2026_Content Enhance.indd 155 17/11/25 1:45 in the afternoon

ឯមនុស្សល្អ គេក៏យកសេចក្តីល្អពីកំណប់ល្អ ដែលកប់ទុកក្នុងចិត្តគេ (លូកា ៦:៤៥)។

ពាក្យសម្តីដែលឆ្លុះបញ្ចាំងចិត្តរបស់យើង

តើអ្នកអាចលប់បំបាត់ពាក្យសម្តីអសីលធម៌ ដោយរបៀបណា? វិទ្យាល័យមួយបានសម្រេចបង្កើតច្បាប់ ឲ្យសិស្សទាំងអស់ធ្វើការសន្យាថា ពួកគេនឹង «ឈប់ប្រើពាក្យសម្តីអសីលធម៌»។ សិស្សទាំងអស់នោះបានធ្វើការសន្យាថា «ខ្ញុំសូមសន្យាថា ខ្ញុំនឹងមិនប្រើពាក្យអសុរោះគ្រប់ប្រភេទនៅក្នុងទីធ្លាសាលារបស់យើង»។ នេះជាការប្រឹងប្រែង ដែលគួរឲ្យគោរព ប៉ុន្តែព្រះយេស៊ូវបានបង្រៀនថា គ្មានច្បាប់ ឬការសន្យា ឬក៏ការសច្ចាតែបបូរមាត់ណា ដែលអាចគ្របបាំងក្លិនស្អុយនៃពាក្យសម្តីអសុរោះរបស់យើងបានឡើយ។

ដើម្បីលប់បំបាត់ក្លិនអសោចនៃពាក្យសម្តី ចេញពីមាត់របស់យើង ជាដំបូងយើងត្រូវកែប្រែចិត្តគំនិតជាថ្មីជាមុនសិន។ ដែលមនុស្សអាចស្គាល់ពូជរបស់ដើមឈើ ដោយសារផ្លែរបស់វាជាយ៉ាងណា (លូកា ៦:៤៣-៤៤) នោះព្រះយេស៊ូវក៏បានមានបន្ទូលថា ពាក្យសម្តីរបស់យើង គឺជាភស្តុតាងដែលបញ្ជាក់ថា ចិត្តរបស់យើងមានភាពសមស្របជាមួយព្រះអង្គ និងផ្លូវរបស់ព្រះអង្គឬអត់។ ផ្លែឈើជាតំណាងឲ្យពាក្យសម្តីរបស់យើង «ដ្បិតមាត់គេពោលបញ្ចេញសេចក្តីបរិបូរ ដែលនៅក្នុងចិត្តជានិច្ច» (ខ.៤៥)។ ត្រង់ចំណុចនេះ ព្រះគ្រីស្ទកំពុងចង្អុលបង្ហាញថា បើយើងពិតជាចង់កែប្រែពាក្យសម្តី ដែលចេញពីមាត់យើងមក ជាដំបូងយើងត្រូវផ្តោតទៅលើការកែប្រែចិត្ត ដោយពឹងផ្អែកជំនួយមកពីព្រះអង្គ។

ការសន្យាតែបបូរមាត់មិនមានប្រសិទ្ធភាពអ្វី ក្នុងការទប់ស្កាត់ពាក្យសម្តីអសីលធម៌ ដែលចេញពីចិត្ត ដែលមិនបានផ្លាស់ប្រែនោះឡើយ។ យើងអាចលប់បំបាត់ពាក្យសម្តីអសុរោះបាន ដោយជាដំបូង យើងត្រូវទទួលជឿព្រះយេស៊ូវ (១កូរិនថូស ១២:៣) ហើយបន្ទាប់មក យើងត្រូវពេញដោយព្រះវិញ្ញាណបរិសុទ្ធ (អេភេសូរ ៥:១៨)។ ព្រះអង្គធ្វើការក្នុងយើង ដើម្បីបណ្តាលចិត្ត និងជួយយើងឲ្យបន្តនិយាយពាក្យអរព្រះគុណដល់ព្រះ (ខ.២០) ហើយនិយាយពាក្យលើកទឹកចិត្ត និងពាក្យកែតម្រង់ដល់អ្នកដទៃ (៤:១៥, ២៩ និងកូល៉ុស ៤:៦)។—Marvin Williams

តើពាក្យសម្តីរបស់ខ្ញុំ បានឆ្លុះបញ្ចាំងអំពីអ្វីខ្លះក្នុងចិត្តខ្ញុំ? តើខ្ញុំអាចទូលសូមព្រះវិញ្ញាណបរិសុទ្ធកែប្រែពាក្យសម្តីរបស់ខ្ញុំ ក្នុងពេលសព្វថ្ងៃ ដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យនិយាយពាក្យសម្តី ដែលថ្វាយសិរីល្អដល់ព្រះអង្គ ហើយកែតម្រង់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 156 17/11/25 1:45 in the afternoon

ចូរមានចិត្តអាណិតដល់ពួកអ្នកខ្វះ ដែលមានសេចក្តីសង្ស័យផង (យូដាស ១:២២)។

ណែនាំឲ្យងាកមករកសេចក្តីពិតវិញ

កាលខ្ញុំនៅរៀន ការអញ្ជើញទៅញ៉ាំអាហារពេលល្ងាច ពីអ្នកដឹកនាំពួកជំនុំរបស់ខ្ញុំគឺលោកគ្រូ ហារ៉ូល (Harold) និងអ្នកគ្រូ ផាម ជាភរិយា (Pam) បានធ្វើឲ្យខ្ញុំមានអារម្មណ៍កក់ក្តៅ តែក៏បានធ្វើឲ្យខ្ញុំមានអារម្មណ៍ភ័យអរផងដែរ។ ថ្មីៗនេះ ខ្ញុំបានចូលរួមការសិក្សាព្រះគម្ពីរជាមួយក្រុម ដែលមានការបង្រៀនប្រាសចាកគោលលទ្ធិក្នុងព្រះគម្ពីរ។ ដូចនេះ ខ្ញុំបារម្ភថា តើពួកគាត់នឹងស្តីប្រដៅខ្ញុំអំពីរឿងនោះឬទេ?

ពេលយើងញ៉ាំនំភីហ្សាជុំគ្នានៅពេលល្ងាចនោះ ពួកគាត់ក៏បានចែកចាយអំពីគ្រួសាររបស់ពួកគាត់ ហើយក៏បានសួរអំពីក្រុមគ្រួសាររបស់ខ្ញុំ។ ពួកគាត់ក៏បានស្តាប់ខ្ញុំចែកចាយ អំពីកិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ អំពីឆ្កែរបស់ខ្ញុំឈ្មោះ ប៊ូឈិ (Buchi) និងមនុស្សដែលខ្ញុំចូលចិត្ត។ ក្រោយមកពួកគេក៏បានដាស់តឿនខ្ញុំយ៉ាងប្រុងប្រយ័ត្ន អំពីក្រុមដែលខ្ញុំកំពុងចូលរួមការសិក្សាព្រះគម្ពីរជាមួយ ហើយក៏បានពន្យល់ថា ក្រុមនោះមានការបង្រៀនដែលខុសឆ្គងនៅត្រង់ចំណុចណាខ្លះ។

ការដាស់តឿនរបស់ពួកគេបាននាំខ្ញុំចេញពីការកុហក ដែលក្រុមនោះបានបង្រៀនខ្ញុំ ហើយនាំខ្ញុំចូលទៅជិតសេចក្តីពិតក្នុងព្រះគម្ពីរ។ កណ្តាគម្ពីរយូដាសបានប្រើពាក្យសម្តីធ្ងន់ៗ ក្នុងការដាស់តឿនអំពីពួកគ្រូខុសឆ្គង ដោយជំរុញអ្នកជឿ ឲ្យ «ការពារសេចក្តីជំនឿ» (យូដាស ១:៣)។ ហើយក៏បានដាស់តឿនយើងថា នៅគ្រាចុងក្រោយនឹងមានមនុស្សចំអក... ជាមនុស្សដែលនៅដោយវិស័យសាច់ឈាម ដែលគ្មានព្រះវិញ្ញាណទេ (ខ.១៨-១៩)។ ទោះជាយ៉ាងណាក៏ដោយ កណ្តាគម្ពីរនេះក៏បានបង្រៀនអ្នកជឿ ឲ្យមានសេចក្តីអាណិតដល់ពួកអ្នកខ្លះ ដែលមានការសង្ស័យ ឬដើរតាមការបង្រៀនខុសឆ្គង (ខ.២២) ដោយទៅក្បែរពួកគេ និងបង្ហាញក្តីអាណិត ដោយមិនបន្ថែមបន្ថយសេចក្តីពិត។

កាលនោះ លោកគ្រូ ហារ៉ូល និងអ្នកគ្រូ ផាម ដឹងថា ខ្ញុំមិនបានចាក់ឫសមាំក្នុងជំនឿទេ តែគាត់មិនបានប្រកាន់ទោសខ្ញុំផ្ទុយទៅវិញ គាត់បានផ្តល់ឲ្យនូវការកែតម្រង់ និងប្រាជ្ញាក្នុងនាមជាបងប្អូនក្នុងជំនឿ។ សូមព្រះអម្ចាស់ប្រទានពរយើង ឲ្យមានសេចក្តីស្រឡាញ់ និងការអត់ធ្មត់ដូចនេះផងដែរ ដោយប្រើប្រាជ្ញា និងសេចក្តីអាណិត ក្នុងការទំនាក់ទំនងជាមួយអ្នកដែលមានជំនឿខ្សោយ ឬដើរតាមការបង្រៀនខុសឆ្គង។—Karen Huang

តើអ្នកអាចឈោងទៅរកនរណាខ្លះ ដែលកំពុងមានជំនឿខ្សោយ ឬកំពុងដើរតាមការបង្រៀនខុសឆ្គង? តើអ្នកអាចណែនាំពួកគេយ៉ាងដូចម្តេចខ្លះ ឲ្យងាកទៅរកសេចក្តីពិតនៃព្រះគម្ពីរ ដោយសេចក្តីស្រឡាញ់?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យនិយាយពាក្យសម្តី ដែលថ្វាយសិរីល្អដល់ព្រះអង្គ ហើយកែតម្រង់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 157 17/11/25 1:45 in the afternoon

ដែលទ្រង់បានជួយសង្គ្រោះយើង ហើយបានហៅយើងមកក្នុងការងារបរិសុទ្ធ មិនមែនដោយការដែលយើងធ្វើទេ គឺដោយដំរិះ និងព្រះគុណនៃទ្រង់វិញ (២ធីម៉ូថេ ១:៩)។

ធ្លាស់ប្រែពីខ្វះចន្លោះ ទៅជាបរិសុទ្ធ

កាលពីក្មេង កូនស្រីខ្ញុំចូលចិត្តលេងដុំឈើសរបស់ជនជាតិស្វីស ក្នុងពេលអាហារថ្ងៃត្រង់។ គាត់បានយកបន្ទះឈើសពណ៌លឿងនោះ មកដាក់ពីលើមុខគាត់ដូចម៉ាស់ ហើយប្រាប់ខ្ញុំឲ្យមើលទៅគាត់ ដោយភ្នែកពណ៌បៃតង ដ៏ចែងចាំង កំពុងមើលមុខខ្ញុំ ចេញពីរន្ធ២ នៅលើបន្ទះឈើសនោះ។ ក្នុងនាមខ្ញុំជាម្តាយវ័យក្មេង ដុំឈើសរបស់ជនជាតិស្វីសមានរន្ធច្រើន គឺបានធ្វើឲ្យខ្ញុំនឹកចាំអំពីភាពខ្វះចន្លោះជាច្រើននៅក្នុងការប្រឹងប្រែងរបស់ខ្ញុំ ដែលមានពេញដោយសេចក្តីស្រឡាញ់ពិតប្រាកដ តែមិនមានភាពល្អឥតខ្ចោះ ពោលគឺខ្ញុំនៅខ្វះសេចក្តីបរិសុទ្ធ។

យើងពិតជាចង់រស់នៅក្នុងជីវិតដែលបរិសុទ្ធ ជាជីវិតដែលបានញែកចេញថ្វាយព្រះ ហើយមានចរិកលក្ខណៈដូចព្រះយេស៊ូវ។ តែពីមួយថ្ងៃទៅមួយថ្ងៃ សេចក្តីបរិសុទ្ធហាក់ដូចជានៅខ្ពស់ពេក យើងឈោងមិនដល់។ យើងនៅបន្តមើលឃើញ «ភាពខ្វះចន្លោះ» ក្នុងជីវិតយើង។

ក្នុងបទគម្ពីរ ២ធីម៉ូថេ ១:៦-៧ សាវ័ក ប៉ុល បានជំរុញលោក ធីម៉ូថេ ជាសិស្សរបស់គាត់ ឲ្យរស់នៅតាមការត្រាស់ហៅ ឲ្យមានសេចក្តីបរិសុទ្ធ។ សាវ័ក ប៉ុល ក៏បានបកស្រាយថា «ទ្រង់បានហៅយើងមកក្នុងការងារបរិសុទ្ធ មិនមែនដោយការដែលយើងធ្វើទេ គឺដោយដំរិះ និងព្រះគុណនៃទ្រង់វិញ» (ខ.៩)។ ជីវិតយើងអាចបរិសុទ្ធមិនមែនដោយសារយើងមានចរិកលក្ខណៈល្អ តែដោយសារព្រះគុណព្រះ ដែលព្រះអង្គបានប្រទានមកក្នុងព្រះគ្រីស្ទយេស៊ូវ មុនអស់ទាំងកល្ប (ខ.៩)។ តើយើងអាចទទួលយកព្រះគុណព្រះ ហើយរស់នៅ ដោយពឹងអាងអំណាចដែលយើងទទួលបានតាមរយៈព្រះគុណព្រះអង្គដែរឬទេ?

ព្រះអង្គបានត្រាស់ហៅយើងឲ្យរស់នៅក្នុងជីវិតដែលបរិសុទ្ធ ទោះនៅក្នុងភារកិច្ចជាឪពុកម្តាយ ក្នុងទំនាក់ទំនងប្តីប្រពន្ធ ឬក្នុងការស្រឡាញ់អ្នកជិតខាងក៏ដោយ។ ហើយយើងអាចបរិសុទ្ធបាន មិនមែនដោយសារការប្រឹងប្រែង ដោយពឹងអាងសមត្ថភាពរបស់យើង តែដោយសារតែព្រះគុណព្រះអង្គ។—Elisa Morgan

តើអ្នកមានការយល់ឃើញយ៉ាងណា ចំពោះសេចក្តីបរិសុទ្ធផ្ទាល់ខ្លួន? តើអ្នកអាចទូលសូមព្រះអង្គរំឭកអ្នកដូចម្តេចខ្លះអំពីព្រះគុណដ៏លើសលប់របស់ព្រះអង្គ ដែលនាំមកនូវសេចក្តីបរិសុទ្ធក្នុងជីវិតអ្នក?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យពឹងផ្អែកលើព្រះគុណព្រះអង្គ មិនមែនពឹងផ្អែកលើសមត្ថភាពខ្លួនឯងក្នុងការរស់នៅ ក្នុងជីវិតដែលបរិសុទ្ធ។

Daily Manna 2026_Content Enhance.indd 158 17/11/25 1:45 in the afternoon

អ្នកណាដែលមានចិត្តមេត្តា ឲ្យគេខ្ចី នោះបានសប្បាយហើយ (ទំនុកតម្កើង ១១២:៥)។

បានឲ្យ និងចែករំលែក ដោយចិត្តសប្បុរស

កាលខ្ញុំ និងភរិយាខ្ញុំឈ្មោះ ខារី (Cari) បានបញ្ចប់ការសិក្សានៅមហាវិទ្យាល័យ យើងបានជាប់បំណុលគោប់ពាន់ដុល្លារៀងៗខ្លួន បានជាយើងចាំបាច់ត្រូវស្វែងរកដំណោះស្រាយ ដើម្បីបញ្ចុះអត្រាការប្រាក់ឲ្យបានទាបជាងមុន។ យើងក៏បានទៅស្នើប្រាក់កម្ចីពីធនាគារក្នុងតំបន់មួយ តែពួកគេបានបដិសេធន៍ ដោយសារយើងមិនបានរស់នៅ ឬធ្វើការក្នុងទីក្រុងនោះ ឲ្យបានច្រើនឆ្នាំ។ ពីរបីថ្ងៃក្រោយមក ខ្ញុំក៏បានចែកចាយអំពីបញ្ហានេះ ដល់មិត្តភក្តិខ្ញុំម្នាក់ឈ្មោះ មីង (Ming) ដែលជាចាស់ទុំក្នុងពួកជំនុំរបស់យើង។ ពេលគាត់ជូនដំណើរខ្ញុំចេញមកវិញ គាត់ក៏បានប្រាប់ខ្ញុំថា គាត់នឹងពិភាក្សាជាមួយភរិយាគាត់។

ពីរបីម៉ោងក្រោយមក ទូរស័ព្ទខ្ញុំក៏បានរោទ៍ឡើង។ គាត់ក៏បានប្រាប់ខ្ញុំថា គាត់និងភរិយាគាត់ចង់ឲ្យប្រាក់យើងខ្ចី ដោយគ្មានការប្រាក់។ ខ្ញុំមិនដឹងថា ត្រូវនិយាយថាម៉េចទេពេលនោះ ដូចនេះខ្ញុំក៏បានប្រាប់គាត់ថា ខ្ញុំមិនបានស្នើសុំប្រាក់កម្ចីពីគាត់ទេ។ គាត់ក៏បាននិយាយដោយចិត្តរីករាយថា គាត់ក៏ដឹងដែរថា ខ្ញុំមិនបានស្នើប្រាក់កម្ចីពីគាត់ តែគាត់ និងភរិយាគាត់ចង់ឲ្យប្រាក់កម្ចី ដោយឥតការប្រាក់ ហើយក្រោយមកខ្ញុំ និងខារី ក៏បានសងពួកគេវិញ នៅពេលណាយើងមានលទ្ធភាព។

ខ្ញុំជឿថា លោក មីង និងអ្នកស្រី អាន (Ann)ជាភរិយា មានចិត្តសប្បុរស ដោយសារពួកគេស្រឡាញ់ព្រះយេស៊ូវ។ គឺដូចដែលព្រះគម្ពីរបានប្រាប់យើងថា “អ្នកណាដែលមានចិត្តមេត្តា ឲ្យគេខ្ចី នោះបានសប្បាយហើយ អ្នកនោះនឹងរក្សាទុកនូវកិច្ចការខ្លួន តាមសេចក្តីយុត្តិធម៌” (ទំនុកតម្កើង ១១២:៥)។ អ្នកដែលទុកចិត្តព្រះ អាចមានចិត្ត “រឹងមាំ” និងបាន “តាំងខ្ជាប់ខ្ជួន” (ខ.៧-៨) ដោយដឹងថា ព្រះអង្គជាប្រភពនៃអ្វីៗទាំងអស់ដែលល្អក្នុងជីវិតពួកគេ។

ព្រះទ្រង់មានសេចក្តីសប្បុរសចំពោះយើង ដោយប្រទានយើងនូវជីវិត និងការអត់ទោសបាប។ ចូរយើងមានចិត្តសប្បុរសក្នុងការចែកចាយសេចក្តីស្រឡាញ់ និងធនធានយើងដល់អ្នកដែលត្រូវការ។—James Banks

តើព្រះអម្ចាស់បានបង្ហាញសេចក្តីសប្បុរសដល់អ្នកដូចម្តេចខ្លះ? តើអ្នកអាចចែកចាយ សេចក្តីសប្បុរសរបស់ព្រះអង្គ ដល់អ្នកដែលខ្វះខាត នៅថ្ងៃនេះយ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតានៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានទូលបង្គំនូវអំណោយនៃជីវិត និងផ្គត់ផ្គង់តម្រូវការទូលបង្គំជារៀងរាល់ថ្ងៃ។ សូមព្រះអង្គជួយទូលបង្គំឲ្យទុកចិត្តព្រះអង្គ ហើយមានចិត្តសប្បុរស ដូចព្រះអង្គដែរ។

Daily Manna 2026_Content Enhance.indd 159 17/11/25 1:45 in the afternoon

បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង (១យ៉ូហាន ១:៩)។

បានសម្អាត ដោយព្រះគ្រីស្ទ

ខ្ញុំបានធ្វើដំណើរបេសកកម្មរយៈពេលខ្លីលើកទី១ ទៅកាន់តំបន់ព្រៃអាម៉ាហ្សូនក្នុងប្រទេសប្រេស៊ីល ដើម្បីជួយសាងសង់ព្រះវិហារមួយខ្នងនៅជាប់មាត់ទន្លេ។ នៅពេលរសៀលមួយនោះ យើងបានទៅសួរសុខទុក្ខប្រជាជនពីរបីគ្រួសារក្នុងតំបន់នោះ ដែលប្រើធុងចម្រោះទឹក។ នៅពេលដែលម្ចាស់ផ្ទះបានចាក់ទឹកល្អក់ចូលទៅក្នុងតម្រង ពីរបីនាទីក្រោយមក ធុងចម្រោះទឹកក៏បានដកភាពក្រខ្វក់ចេញពីទឹក ហើយទឹកស្អាតក៏បានហូរចេញមក។ នៅពេលនោះ ខ្ញុំក៏បាននឹកចាំអំពីអត្ថន័យនៃការលាងសម្អាតរបស់ព្រះគ្រីស្ទ មកលើបាបរបស់យើង។

នៅពេលដែលយើងចូលមករកព្រះយេស៊ូវ ដោយមានកំហុស និងក្តីអាម៉ាស់ ហើយទូលសូមព្រះអង្គអត់ទោសឲ្យយើង ហើយយើងទទួលជឿព្រះអង្គជាព្រះអង្គសង្គ្រោះ ព្រះអង្គក៏បានលាងសម្អាតយើង ឲ្យរួចពីបាប ហើយធ្វើឲ្យយើងកើតជាថ្មី។ ព្រះអង្គបានសម្អាតយើងឲ្យស្អាត ដូចទឹកល្អក់ ដែលបានប្រែក្លាយជាទឹកស្អាត ដែលអាចផឹកបាន។ យើងពិតជាមានអំណរណាស់ ពេលដែលបានដឹងថា យើងមានភាពត្រឹមត្រូវចំពោះព្រះអង្គ ដោយសារការលះបង់ព្រះជន្មរបស់ព្រះយេស៊ូវ (២កូរិនថូស ៥:២១) ហើយដឹងថា ព្រះអង្គដកបាបយើងចេញឲ្យឆ្ងាយ ដូចទិសខាងកើត នៅឆ្ងាយពីខាងលិច (ទំនុកតម្កើង ១០៣:១២)។

ប៉ុន្តែ សាវ័ក យ៉ូហាន បានរំឭកយើងថា ការនេះមិនមែនមានន័យថា យើងនឹងឈប់ធ្វើបាបទៀតឡើយ។ ពេលណាយើងភ្លាត់ប្រព្រឹត្តបាបទៀត ចូរយើងនឹកចាំថា យើងនៅតែអាចទទួលការសម្អាត ដូចទឹកដែលឆ្លងកាត់តម្រងទឹក ហើយមានការកម្សាន្តចិត្ត ដោយដឹងថា “បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង” (១យ៉ូហាន ១:៩)។

ចូរយើងរស់នៅ ដោយមានទំនុកចិត្ត ដោយដឹងថា ព្រះគ្រីស្ទនៅតែបន្តលាងសម្អាតយើង រហូតដល់ពេលយើងបានទៅរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច។—Nancy Gavilanes

ហេតុអ្វីអ្នកចាំបាច់ត្រូវទូលសូមព្រះយេស៊ូវ អត់ទោសបាបឲ្យអ្នក? តើអ្នកមានអារម្មណ៍យ៉ាងណា ពេលដែលបានដឹងថា អ្នកមិនចាំបាច់រស់នៅជាទាសកររំនៃបាបទៀតទេ?

ឱព្រះអង្គអើយ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដ្បិតព្រះអង្គស្មោះត្រង់ ហើយសុចរិតក្នុងការអត់ទោសឲ្យទូលបង្គំ ពេលណាទូលបង្គំសារភាពបាបនៅចំពោះព្រះអង្គ។

Daily Manna 2026_Content Enhance.indd 160 17/11/25 1:45 in the afternoon

បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍ នឹងឱព្រះអង្គអើយ ព្រលឹងទូលបង្គំដង្ហក់រកទ្រង់ ដូចជាក្តាន់ញីដង្ហក់រកជ្រោះទឹក (ទំនុកតម្កើង ៤២:១)។

ទឹកដែលយើងមិនអាចខ្វះបាន

ខ្ញុំ និងមិត្តភក្តិខ្ញុំ បានពិនិត្យមើលបញ្ជីសកម្មភាព ដែលយើងបានធ្វើហើយ នៅក្នុងការដើរកម្សាន្តក្នុងជ្រលងយក្ស គ្រែន ខេនញ៉ៀន។ មុននោះ យើងឆ្ងល់ថា យើងមានទឹកគ្រប់គ្រាន់ឬទេ ខណៈពេលដែលយើងចាប់ផ្តើមដំណើរកម្សាន្តនោះ ហើយទឹកក៏បានអស់យ៉ាងឆាប់រហ័ស។ យើងបានអស់ទឹកផឹក ហើយយើងត្រូវដើរតាមផ្លូវវែងអន្លាយ ទៅរកច្រកចេញពីជ្រលងយក្សនេះ។ យើងក៏បានអធិស្ឋាន ខណៈពេលដែលយើងកំពុងដង្ហក់រកទឹក។ បន្ទាប់មក រឿងដែលយើងមិននឹកស្មានដល់ក៏បានកើតឡើង។ ពេលនោះ យើងបានឃើញទឹកសុទ្ធបីដប ដែលគេបានដាក់ក្នុងប្រទ្បោះជញ្ជាំងថ្ម ដែលមានអក្សរសរសេរពីលើថា “ខ្ញុំដឹងថា អ្នកនឹងត្រូវការទឹកនេះ។ សូមផឹកដោយរីករាយ!” យើងក៏បានមើលមុខគ្នាទៅវិញទៅមក ដោយការហួសចិត្ត ហើយក៏បានពោលពាក្យអរព្រះគុណព្រះ។ យើងក៏បានចាប់ផ្តើមផឹកទឹកនោះពីរបីក្អឹក ហើយយកទឹកនោះទៅជាមួយយើង តាមកំណាត់ផ្លូវចុងក្រោយចេញពីតំបន់នោះ។ ក្នុងមួយជីវិតរបស់ខ្ញុំ ខ្ញុំមិនដែលមានការស្រេកទឹក និងអរព្រះគុណព្រះខ្លាំងដូចពេលនោះទេ។

អ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើង មិនដែលបានទៅដល់តំបន់ជ្រលងភ្នំ គ្រែន ខេនញ៉ៀនទេ តែគាត់ដឹងថា សត្វក្តាន់មានអាការៈដូចម្តេចខ្លះ នៅពេលដែលវាមានការស្រេកទឹកខ្លាំង ឬមានការភ័យខ្លាច។ ពាក្យ “ក្តាន់ញីដង្ហក់” (ទំនុកតម្កើង ៤២:១) ជាពាក្យ ដែលធ្វើឲ្យយើងនឹកឃើញការស្រេកទឹក និងការឃ្លានអាហារយ៉ាងខ្លាំង ដែលធ្វើឲ្យយើងខ្លាចសេចក្តីស្លាប់។ គាត់បានប្រៀបប្រដូចកម្រិតនៃការស្រេកទឹករបស់សត្វក្តាន់ ទៅនឹងការស្រេកឃ្លានរកព្រះ បានជាគាត់ទូលព្រះអង្គថា “ឱព្រះអង្គអើយ ព្រលឹងទូលបង្គំដង្ហក់រកទ្រង់” (ខ.១)។

ព្រះអម្ចាស់ជាជំនួយ ដែលតែងតែនៅជាប់ជាមួយយើងជានិច្ច គឺប្រៀបដូចជាទឹកដែលយើងមិនអាចខ្វះបាន។ យើងដង្ហក់រកព្រះអង្គ ព្រោះព្រះអង្គប្រទានកម្លាំង និងភាពស្រស់ថ្លាជាថ្មី ដល់ជីវិតដ៏នឿយហត់របស់យើង ដោយប្រទានឲ្យយើងនូវលទ្ធភាពសម្រាប់ធ្វើដំណើរបន្តទៅមុខទៀត។—John Blasé

តើអ្នកមានការស្រេកទឹក ការឃ្លានអាហារ និងការភ័យខ្លាចខ្លាំងបំផុតនៅពេលណា? ហេតុអ្វីអ្នកគួរតែស្រេកឃ្លានព្រះវត្តមានរបស់ព្រះ?

ឱព្រះនៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានកម្លាំងដល់ទូលបង្គំជាថ្មី ដើម្បីបំពេញជីវិតទូលបង្គំឲ្យមានភាពពេញលេញ។ សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ដែលបានស្វែងរកប្រភពនៃកម្លាំងផ្សេងទៀត ក្រៅពីព្រះអង្គ។

Daily Manna 2026_Content Enhance.indd 161 17/11/25 1:45 in the afternoon

មុនដែលអញបានជប់បង្កើតឯងនៅក្នុងពោះម្តាយ នោះអញស្គាល់ឯងហើយ កាលមុនដែលឯងសំរាលចេញពីផ្ទៃមកនោះអញបានញែកឯងជាបរិសុទ្ធផង (យេរេមា ១:៥)។

ព្រះអង្គស្រឡាញ់ តាំងពីមុនពេលយើងចាប់កំណើត

ប្តូ មានអារម្មណ៍ថា ប៊ូតុងឡែក («likes») ដែលមានរូបមេដៃនៅលើហ្វេសប៊ុក គឺជាប៊ូតុងដែលយើងប្រើញឹកញាប់បំផុត ដើម្បីបង្ហាញថា យើងចូលចិត្តអ្វីមួយ។ ប៉ុន្តែ តាមពិតនិមិត្តសញ្ញានៃការបញ្ជាក់អំពីការចូលចិត្តនេះ ទើបតែត្រូវបានគេប្រើប្រាស់តាំងពីឆ្នាំ២០០៩ ។

លោក ចាស្ទីន រ៉ូសេនស្ទេន (Justin Rosenstein) ជាអ្នករចនាប៊ូតុង «like» បានមានប្រសាសន៍ថា គាត់ចង់ជួយកែប្រែពិភពលោក ឲ្យក្លាយជាកន្លែងដែលមនុស្សមានការលើកទឹកចិត្ត ជាជាងជាន់ឈ្លីគ្នាទៅវិញទៅមក។ ប៉ុន្តែ លោក រ៉ូសេនស្ទេន មានការសោកស្តាយយ៉ាងខ្លាំង នៅពេលដែលមនុស្សជាច្រើនកំពុងតែញៀននឹងបណ្តាញសង្គម ដែលកំពុងប្រើប្រាស់ប៊ូតុងឡែក «likes»។

ខ្ញុំយល់ឃើញថា រឿងនេះបានឆ្លុះបញ្ចាំងអំពីបញ្ហារបស់មនុស្សជាទូទៅ ដែលត្រូវការអ្នកដទៃបញ្ជាក់អំពីការចូលចិត្ត និងការភ្ជាប់ទំនាក់ទំនងជាមួយពួកគេ។ យើងចង់ដឹងថា អ្នកដទៃពិតជាស្គាល់យើង កត់សម្គាល់យើង ហើយជាពិសេសចូលចិត្តយើង។ បញ្ហានេះមិនមែនទើបតែកើតមានទេ។ មនុស្សជាតិមានចិត្តស្រេកឃ្លានចង់ស្គាល់ និងចង់ឲ្យគេស្គាល់ខ្លួនឯង តាំងពីសម័យដែលព្រះអម្ចាស់បង្កើតមនុស្សដំបូង។

ប៉ុន្តែ ប៊ូតុង «like» ហាក់ដូចជា មិនបានធ្វើឲ្យយើងពិតជាមានអារម្មណ៍ថា គេចូលចិត្តយើងនោះទេ តើមែនទេ? តែអរព្រះគុណព្រះអង្គ ព្រោះយើងបម្រើព្រះ ដែលមានសេចក្តីស្រឡាញ់ជ្រាលជ្រៅ ជាងអ្វីដែលយើងអាចដកពិសោធន៍ក្នុងបណ្តាញសង្គមទៅទៀត។ ក្នុងបទគម្ពីរ យេរេមា ១:៥ ព្រះអង្គបានបង្ហាញអំពីការជាប់ទាក់ទងដែលព្រះអង្គមានជាមួយហោរាម្នាក់ ដែលព្រះអង្គបានត្រាស់ហៅឲ្យចូលមករកអង្គទ្រង់។ គឺដូចដែលព្រះអង្គមានបន្ទូលថា «មុនដែលអញបានជប់បង្កើតឯងនៅក្នុងពោះម្តាយ នោះអញស្គាល់ឯងហើយ កាលមុនដែលឯងសំរាលចេញពីផ្ទៃមកនោះអញបានញែកឯងជាបរិសុទ្ធផង»។

ព្រះអម្ចាស់បានស្គាល់ហោរា យេរេមា តាំងពីមុនពេលគាត់ចាប់កំណើត ហើយក៏បានរៀបផែនការ ឲ្យគាត់រស់នៅក្នុងជីវិតដែលមានន័យ និងមានបេសកកម្ម (ខ.៨-១០)។ ហើយព្រះអង្គអញ្ជើញយើង ឲ្យចូលទៅក្នុងជីវិតដែលមានគោលបំណង ដោយស្គាល់ និងប្រកបស្និទ្ធស្នាលជាមួយព្រះវរបិតា ដែលពិតជាស្គាល់ ស្រឡាញ់ និងចូលចិត្តយើង ដោយភាពជិតស្និទ្ធយ៉ាងខ្លាំង។—Adam R. Holz

តើការស្គាល់ព្រះ ដោយភាពជិតស្និទ្ធមានឥទ្ធិពលយ៉ាងណាមកលើរបៀបដែលអ្នកទំនាក់ទំនងជាមួយអ្នកដទៃ? តើការរស់នៅ ដោយមានគោលបំណង នាំឲ្យមានសន្តិភាពក្នុងចិត្តដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យសម្រាកក្នុងសេចក្តីស្រឡាញ់ និងការត្រាស់ហៅ ដោយដឹងថា ព្រះអង្គយកព្រះទ័យទុកដាក់ចំពោះទូលបង្គំ ខណៈពេលដែលព្រះអង្គកំពុងកែច្នៃទូលបង្គំជារៀងរាល់ថ្ងៃ តាមផែនការរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២ពង្សាវតារ ២៣-២៤ និងយ៉ូហាន ១៥

រួចព្រះយេស៊ូវទ្រង់យកនំប៉័ងនោះអរព្រះគុណ រួចចែកទៅឲ្យពួកសិស្ស គេក៏ចែកដល់ពួកអ្នក ដែលអង្គុយ បានចែកទាំងត្រីតូចនោះបែបដូច្នោះដែរ តាមតែគេចង់បាន (យ៉ូហាន ៦:១១)។

អរព្រះគុណព្រះអង្គ ដែលប្រទានអាហារ

មិត្តភក្តិរបស់ខ្ញុំបានប្រញាប់រិលត្រឡប់ពីកន្លែងធ្វើការដ៏មមាញឹកនៅមន្ទីរពេទ្យ ដោយឆ្ងល់ថា តើគាត់គួរធ្វើម្ហូបអ្វី មុនពេលស្វាមីគាត់រិលត្រឡប់ពីកន្លែងធ្វើការដែលមានការរវល់ច្រើនដែរ។ គាត់បានធ្វើម្ហូបសាច់មាន់នៅថ្ងៃអាទិត្យ ហើយញ៉ាំម្ហូបដែលនៅសល់ នៅថ្ងៃច័ន្ទ។ បន្ទាប់មក នៅថ្ងៃអង្គារ ពួកគេញ៉ាំម្ហូបសាច់មាន់ទៀត តែលើកនេះ គឺធ្វើមាន់ដុត។ គាត់ក៏បានរកឃើញសាច់ត្រីពីរដុំក្នុងកន្លែងបង្កកសាច់ក្នុងទូទឹកកក តែគាត់ដឹងថា ស្វាមីគាត់មិនចូលចិត្តញ៉ាំសាច់ត្រីនោះទេ។ តែគាត់មិនអាចរកអ្វីផ្សេងសម្រាប់ធ្វើម្ហូបឲ្យហើយក្នុងរយៈពេលពីរបីនាទី គាត់ក៏បានសម្រេចចិត្តធ្វើម្ហូបសាច់ត្រីនោះ។

នៅពេលដែលគាត់ដាក់ចាននៅលើតុ ស្វាមីគាត់ក៏បានមកដល់ គាត់ក៏បាននិយាយប្រាប់ស្វាមីគាត់ក្នុងលក្ខណៈសុំទោសថា «ខ្ញុំដឹងថា នេះមិនមែនជាម្ហូបដែលបងចូលចិត្តទេ»។ ស្វាមីគាត់ក៏បានមើលទៅលើ ហើយនិយាយថា «មិនអីទេអូន ឲ្យតែមានអាហារនៅលើតុ គឺបងសប្បាយចិត្តហើយ»។

អាកប្បកិរិយារបស់ស្វាមីគាត់ បានធ្វើឲ្យខ្ញុំនឹកចាំអំពីសារៈសំខាន់នៃការដឹងគុណ និងអរព្រះគុណព្រះសម្រាប់ការផ្គត់ផ្គង់យើងជារៀងរាល់ថ្ងៃ ទោះយើងមានម្ហូបអ្វីបរិភោគក៏ដោយ។ ការអរព្រះគុណព្រះអង្គ សម្រាប់អាហារប្រចាំថ្ងៃ គឺជាការយកគំរូតាមព្រះយេស៊ូវ។ កាលព្រះអង្គសោយអាហារជាមួយសាវ័កពីរនាក់ បន្ទាប់ពីព្រះអង្គមានព្រះជន្មរស់ឡើងវិញ ព្រះអង្គបានលើកនំប៉័ងឡើង អរព្រះគុណ ហើយក៏បានកាច់នំប៉័ងចែកពួកគេបរិភោគ (លូកា ២៤:៣០)។ ព្រះអង្គបានអរព្រះគុណព្រះវរបិតា ដូចកាលពីមុនផងដែរ គឺនៅពេលដែលព្រះអង្គប្រទានអាហារដល់មនុស្ស៥ពាន់នាក់ ដោយប្រើនំប៉័ងតែ៥ដុំ និងត្រី២កន្ទុយ (យ៉ូហាន ៦:៩)។ ពេលណាយើងអរព្រះគុណព្រះ សម្រាប់ការប្រទានអាហារប្រចាំថ្ងៃ និងសម្រាប់ការផ្គត់ផ្គង់ដទៃទៀត ការដឹងគុណរបស់យើងបានយកគំរូតាមព្រះយេស៊ូវ ហើយថ្វាយព្រះកិត្តិនាមដល់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌។ តើមានការអ្វីខ្លះដែលយើងចង់អរព្រះគុណព្រះអង្គនៅថ្ងៃនេះ?—Katara Patton

តើអ្នកបានបង្ហាញការដឹងគុណដល់ព្រះយេស៊ូវ ញឹកញាប់ប៉ុណ្ណា? តើការនេះបានថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានអាហារប្រចាំថ្ងៃ និងបំពេញតម្រូវការផ្សេងទៀត ដែលទូលបង្គំមាន។

Daily Manna 2026_Content Enhance.indd 163 17/11/25 1:45 in the afternoon

ដែលឲ្យ នោះបានពរជាជាងទទួល (កិច្ចការ ២០:៣៥)។

មានអំណរនៅក្នុងការឲ្យ

កាលកូនប្រុសរបស់អ្នកស្រី យ៉ារី (Keri) ដល់ពេលដែលត្រូវទទួលការវះកាត់មួយលើកទៀត ទាក់ទងនឹងជំងឺចុះខ្សោយសាច់ដុំ គាត់ចង់បង្ហែរអារម្មណ៍របស់គាត់ ចេញពីស្ថានភាពរបស់គ្រួសារគាត់ ដោយធ្វើអ្វីម៉្យាងសម្រាប់អ្នកដទៃ។ ដូចនេះ គាត់ក៏បានប្រមូលស្បែកជើង ដែលកូនប្រុសគាត់ឈប់ពាក់ តែនៅល្អ ហើយគាត់ក៏បានយកស្បែកជើងទាំងនោះ ទៅបរិច្ចាគឲ្យអង្គការគ្រីស្ទបរិស័ទមួយ។ ការបរិច្ចាគរបស់គាត់ក៏បានបណ្តាលចិត្តមិត្តភក្តិ និងសមាជិកគ្រួសារ ក៏ដូចជាអ្នកជិតខាងឲ្យចូលរួមជាមួយគាត់ ហើយមិនយូរប៉ុន្មានពួកគេប្រមូលបានស្បែកជើង២រយគូ សម្រាប់បរិច្ចាគ។

ទោះការបរិច្ចាគស្បែកជើងនោះ ត្រូវបានធ្វើឡើង ដើម្បីជាប្រយោជន៍ដល់អ្នកដទៃក៏ដោយ ក៏អ្នកស្រី យ៉ារី មានអារម្មណ៍ថា ក្រុមគ្រួសារគាត់បានទទួលព្រះពរលើសអ្នកដែលបានទទួលស្បែកជើងទាំងនោះទៅទៀត។ គាត់ថា ទង្វើសប្បុរសធម៌នោះ បានលើកទឹកចិត្តក្រុមគ្រួសារគាត់ណាស់ ហើយបានជួយឲ្យពួកគាត់ផ្តោតចិត្តទៅលើរឿងក្រៅខ្លួន។

សាវ័ក ប៉ុល បានដឹងអំពីសារៈសំខាន់នៃការឲ្យអំណោយ ដោយចិត្តសប្បុរស។ ក្នុងការធ្វើដំណើរទៅទីក្រុងយេរូសាឡិម គាត់ក៏បានឈប់នៅទីក្រុងអេភេសូរ។ គាត់ដឹងថា គាត់មិនទំនងជាមានឱកាសមកសួរសុខទុក្ខពួកជំនុំ ដែលគាត់បានបង្កើតនៅទីនោះទៀតទេ។ ក្នុងពាក្យចុងក្រោយ ទៅកាន់ពួកចាស់ទុំ គាត់ក៏បានរំឭកពួកគេអំពីកិច្ចការដែលគាត់ខិតខំធ្វើថ្វាយព្រះ (កិច្ចការ ២០:១៧-២០) ហើយក៏បានលើកទឹកចិត្តពួកគេឲ្យខិតខំធ្វើការបម្រើព្រះអង្គផងដែរ (ខ.៣៥)។ បន្ទាប់មក គាត់ក៏បាននិយាយបញ្ចប់ដោយដកស្រង់ព្រះបន្ទូលព្រះយេស៊ូវថា "ដែលឲ្យនោះមានពរ ជាជាងទទួល" (ខ.៣៥)។

ព្រះយេស៊ូវសព្វព្រះទ័យឲ្យយើងធ្វើការលះបង់ អស់ពីចិត្ត និងដោយបន្ទាបខ្លួន (លូកា ៦:៣៨)។ ពេលណាយើងចុះចូលនឹងការដឹកនាំរបស់ព្រះអង្គ ព្រះអង្គនឹងប្រទានឱកាសឲ្យយើងធ្វើការលះបង់។ យើងនឹងមានការការភ្ញាក់ផ្អើល ចំពោះក្តីអំណរ ដែលយើងនឹងបានទទួល ពីការលះបង់នោះផងដែរ។—Alyson Kieda

តើព្រះអង្គកំពុងត្រាស់ហៅអ្នក ឲ្យធ្វើការលះបង់សម្រាប់អ្នកដទៃ ដូចម្តេចខ្លះ? តើអ្នកធ្លាប់បានទទួលសេចក្តីសប្បុរស ពីអ្នកដទៃនៅពេលណាខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំ ឲ្យចេះលះបង់ពេលវេលា និងធនធានរបស់ទូលបង្គំដល់អ្នកដទៃ ដោយសេចក្តីស្រឡាញ់។

Daily Manna 2026_Content Enhance.indd 164 17/11/25 1:45 in the afternoon

ដូច្នេះ ចូរឯងរាល់គ្នាលះចោលអស់ទាំងព្រះដទៃ ដែលមាននៅក្នុងពួកឯងចេញទៅ ហើយផ្ចង់ចិត្តដំរង់ទៅឯព្រះយេហូវ៉ា ជាព្រះនៃសាសន៍អ៊ីស្រាអែលវិញ (យ៉ូស្វេ ២៤:២៣)។

ការល្បួងនៅតែកើតមាន

ក្បែរប្រសៅខ្លះ នៅក្នុងក្រុមសិក្សាព្រះគម្ពីរមានអាយុជិត៨០ឆ្នាំហើយ ដូចនេះខ្ញុំមានការភ្ញាក់ផ្អើល ពេលដែលបានដឹងថា ពួកគេកំពុងព្យាយាមជម្នះការត្រេកត្រអាលផ្លូវភេទ។ វាជាការតយុទ្ធ ដែលបានចាប់ផ្តើមតាំងពីពេលពួកគេស្ថិតក្នុងវ័យឃុវជន ហើយនៅតែបន្តមានក្នុងជីវិតពួកគេ។ ជារៀងរាល់ថ្ងៃ ពួកគេបានធ្វើការប្តេជ្ញាចិត្តថា នឹងដើរតាមព្រះយេស៊ូវ ដោយព្យាយាមជម្នះអំពើបាបនេះ ហើយក៏បានទូលសូមការអត់ទោសបាប នៅពេលណាពួកគេបានភ្លាត់ធ្វើខុសទៀត។

យើងប្រហែលមានការភ្ញាក់ផ្អើល នៅពេលណាបុរសដែលកោតខ្លាចព្រះ នៅតែតយុទ្ធនឹងការល្បួង នៅក្នុងដំណាក់កាលចុងក្រោយនៃជីវិតពួកគេ តែយើងប្រហែលមិនគួរមានការភ្ញាក់ផ្អើលទេ។ រូបព្រះគឺជាអ្វីក៏ដោយ ដែលព្យាយាមជំនួសព្រះ នៅក្នុងចិត្តរបស់យើង ហើយពួកវានឹងលេចឡើងម្តងទៀត បន្ទាប់ពីយើងបានសន្និដ្ឋានថាពួកវាលែងមានក្នុងជីវិតយើងទៀត តាំងពីយូរមកហើយ។

ក្នុងព្រះគម្ពីរសញ្ញាចាស់ លោក យ៉ាកុប បានទទួលការជួយសង្គ្រោះ ឲ្យរួចពីពូរបស់គាត់ឈ្មោះឡាបាន់ និងលោក អេសាវ ជាបងប្រុសរបស់គាត់។ គាត់បានវិលត្រឡប់មកស្រុកបេតអែលវិញ ដើម្បីថ្វាយបង្គំព្រះ និងសរសើរតម្កើងព្រះអង្គ សម្រាប់ព្រះពរជាច្រើន ដែលគាត់បានទទួល តែក្រុមគ្រួសារគាត់នៅតែបន្តរក្សាទុករូបព្រះរបស់សាសន៍ដទៃ ដែលលោក យ៉ាកុប ត្រូវតែកប់ចោល (លោកុប្បត្តិ ៣៥:២-៤)។ នៅចុងបញ្ចប់នៃកណ្ឌគម្ពីរយ៉ូស្វេ បន្ទាប់ពីពួកអ៊ីស្រាអែលបាន ឈ្នះខ្មាំងសត្រូវក្នុងសង្គ្រាម ហើយចូលតាំងទីលំនៅក្នុងទឹកដីកាណាន លោក យ៉ូស្វេ នៅតែបន្តជំរុញពួកគេ ឲ្យលះបង់ព្រះរបស់សាសន៍ដទៃ ដែលរស់នៅក្នុងចំណោមពួកគេ ហើយក៏ឲ្យថ្វាយចិត្តដាច់ដល់ព្រះអម្ចាស់វិញ(យ៉ូស្វេ ២៤:២៣)។ ហើយព្រះនាង មីកាល ជាមហេសីរបស់ស្តេច ដាវីឌ ក៏ទំនងជាបានរក្សាទុកតួរូបព្រះផងដែរ ព្រោះព្រះនាងបានដាក់រូបព្រះមួយនៅលើគ្រែ ដើម្បីបោកបញ្ឆោតពួកទាហានដែលមកធ្វើគុតទ្រង់ (១សាំយ៊ូអែល ១៩:១១-១៦)។

ការថ្វាយបង្គំរូបព្រះក្នុងជីវិតគ្រីស្ទបរិស័ទ គឺជារឿងដែលកើតមានជាធម្មតា លើសពីការរំពឹងគិតរបស់យើងទៅទៀត ហើយព្រះអង្គក៏មានព្រះទ័យអត់ធ្មត់ ទោះយើងមិនសមនឹងឲ្យព្រះអង្គអត់ធ្មត់ចំពោះយើងក៏ដោយ។ ការល្បួងឲ្យយើងងាកបែរទៅរកពួកវា ក៏នឹងកើតមាន តែការអត់ទោសរបស់ព្រះអង្គ មានអំណាចខ្លាំងជាងការល្បួងនោះ។ ចូរយើងញែកខ្លួនយើងជាបរិសុទ្ធថ្វាយព្រះយេស៊ូវ ដោយងាកបែរចេញពីបាបយើង ហើយរកឃើញការអត់ទោសក្នុងព្រះអង្គ។—Mike Wittmer

តើអ្នកបានជួបការល្បួង ឲ្យធ្វើអំពើបាបអ្វីខ្លាំងជាងគេ? តើអ្នកត្រូវបំផ្លាញរូបព្រះទាំងនោះ ជាដំហានៗដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមសារភាពបាបរបស់ទូលបង្គំ ហើយសូមទទួលការអត់ទោសពីព្រះអង្គ តាមរយៈព្រះយេស៊ូវដោយការអរព្រះគុណ។

គម្រោងអានព្រះគម្ពីរឆ្នាំ: ពេល១ឆ្នាំ | ២របាក្សត្រ ៣០-៣១ និងយ៉ូហាន ១៨:១-១៨

ចូរឲ្យគ្រប់គ្នាធ្វើតាមដែលសំរេចក្នុងចិត្តចុះ មិនមែនដោយស្តាយ ឬដោយបង្ខំឡើយ (២កូរិនថូស ៩:៧)។

ការដាក់ដង្វាយ ដោយចិត្តសប្បុរស

ក្រិយាខ្ញុំ ឈ្មោះស៊ូ (Sue) បានធ្វើការមួយសប្តាហ៍ម្តងក្នុងក្លិបសិក្សាព្រះគម្ពីរសម្រាប់សិស្សសាលា។ នៅទីនោះ គេបានលើកទឹកចិត្តក្មេងៗឲ្យដាក់ដង្វាយ ដើម្បីជួយដល់កុមារក្នុងប្រទេសអ៊ុយក្រែន ដែលកំពុងទទួលរងការបំផ្លិចបំផ្លាញ ដោយសារសង្គ្រាម។ រយៈពេល១សប្តាហ៍ បន្ទាប់ពីស៊ូបានប្រាប់មែគី (Maggie) ជាចៅស្រីរបស់យើងមានអាយុ១១ឆ្នាំអំពីគម្រោងនេះ យើងក៏បានទទួលសំបុត្រមួយច្បាប់ពីគាត់។ ក្នុងស្រោមសំបុត្រនោះ យើងឃើញមានលុយ ៣.៤៥ដុល្លា ភ្ជាប់ជាមួយក្រដាសមួយសន្លឹក ដែលគាត់បានសរសេរពីលើថា «ចៅមានលុយសម្រាប់ជួយក្មេងៗនៅប្រទេសអ៊ុយក្រែនតែប៉ុណ្ណោះទេ។ ចៅនឹងផ្ញើថែមទៀត នៅពេលក្រោយ»។

ស៊ូមិនបានប្រាប់មែគី ឲ្យជួយដល់ក្មេងៗទាំងនោះទេ តែព្រះវិញ្ញាណបរិសុទ្ធប្រហែលជាបានបណ្តាលចិត្តនាង។ ហើយមែគី ស្រឡាញ់ព្រះយេស៊ូវ ហើយបានព្យាយាមរស់នៅថ្វាយព្រះអង្គ ក៏បានឆ្លើយតបចំពោះការបណ្តាលចិត្តនេះ។

យើងអាចរៀនសូត្របានច្រើនណាស់ នៅពេលដែលយើងគិតអំពីអំណោយដ៏តូច ដែលនាងបានឲ្យដល់ចិត្តដ៏ធំទូលាយ។ ការនេះបានឆ្លុះបញ្ចាំងអំពីការបង្រៀនរបស់សាវ័ក ប៉ុល ក្នុងបទគម្ពីរ២កូរិនថូស ជំពូក៩។ ទីមួយ សាវ័ក ប៉ុល បានបង្រៀនថា យើងត្រូវតែព្រោះ «ដោយចិត្តសប្បុរស» (ខ.៦)។ អំណោយដែលបានឲ្យដោយមិនសោកស្តាយ គឺជាអំណោយសប្បុរស។ សាវ័ក ប៉ុល ក៏បានបង្រៀនផងដែរថា យើងត្រូវឲ្យអំណោយ ដោយអំណរ តាមការបណ្តាលចិត្តរបស់ព្រះ និងតាមលទ្ធភាពរបស់យើង គឺមិនមែនដោយបង្ខំចិត្តនោះទេ (ខ.៧)។ ហើយគាត់ក៏បានលើកឡើងអំពីតម្លៃរបស់ «អំណោយសម្រាប់អ្នកក្រ» (ខ.៩) ដោយដកស្រង់បទគម្ពីរ ទំនុកតម្កើង ១១២:៩។

ពេលណាយើងមានឱកាសឲ្យអំណោយ ឬដាក់ដង្វាយឲ្យអ្នកដទៃ ចូរយើងនឹកចាំថា ព្រះអង្គសព្វព្រះទ័យឲ្យយើងឆ្លើយតប ដូចម្តេចខ្លះ។ ពេលណាយើងមានចិត្តសប្បុរស និងរីករាយក្នុងការដាក់ដង្វាយដល់អ្នកដែលត្រូវការ តាមការដឹកនាំរបស់ព្រះអង្គ នោះមានន័យថា យើងដាក់ដង្វាយ ដែលនឹងនាំឲ្យមានការអរព្រះគុណព្រះអង្គ (២កូរិនថូស ៩:១១)។ នេះជាការឲ្យ ដោយចិត្តដែលធំទូលាយ។—Dave Branon

តើមានការអ្វីបណ្តាលចិត្តអ្នក ឲ្យដាក់ដង្វាយដល់អ្នកដទៃ ដោយចិត្តសប្បុរស? តើអ្នកព្យាយាមបំពេញតម្រូវការរបស់ពួកគេ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គដឹកនាំទូលបង្គំ ឲ្យក្លាយជាអ្នកឲ្យ ដោយចិត្តសប្បុរស តាមបំណងព្រះទ័យព្រះអង្គ ដោយបង្ហាញឲ្យគេស្គាល់ព្រះទ័យដ៏សប្បុរសរបស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 166 17/11/25 1:45 in the afternoon

តែឯអ្នក ចូរឲ្យមានគំនិតនឹងធឹងក្នុងគ្រប់ការទាំងអស់វិញ ចូរទ្រាំទ្រនឹងសេចក្តីលំបាក ចូរឲ្យអ្នកធ្វើការជាគ្រូផ្សាយដំណឹងល្អចុះ (២ធីម៉ូថេ ៤:៥)។

ពេលវេលាដែលនៅសល់ សុទ្ធតែសំខាន់

កាលកប៉ាល់ទីតានិចបុកថ្ពាំងទឹកកកក្នុងខែខែមេសាឆ្នាំ១៩១២ លោកគ្រូគង្វាល ចន ហាភ័រ (John Harper) រកបានកន្លែងអង្គុយមួយសម្រាប់កូនស្រីគាត់មានអាយុ៦ឆ្នាំនៅលើទូកសង្គ្រោះបន្ទាន់ ដែលមានចំនួនកំណត់។ គាត់ក៏បានប្រគល់អាវសុវត្ថិភាពរបស់គាត់ទៅអ្នកដំណើរម្នាក់ ហើយក៏បានផ្សាយដំណឹងល្អ ដល់នរណាក៏ដោយ ដែលចង់ស្តាប់គាត់ចែកចាយ។ ខណៈពេលដែលកប៉ាល់ទីតានិចកំពុងលិច មនុស្សរាប់រយនាក់កំពុងរង់ចាំការជួយសង្គ្រោះ ដែលមិនទំនងជាអាចកើតមាន លោក ហាភ័រ ក៏បានហែលទឹកទៅរកមនុស្សម្នាក់ហើយម្នាក់ទៀត ដែលកំពុងអណ្តែតនៅលើទឹក ហើយប្រាប់ពួកគេថា «ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ» (កិច្ចការ ១៦:៣១)។

ក្នុងអំឡុងពេលនៃការជួបជុំនៅទីក្រុងអនតារីយ៉ូ សម្រាប់អ្នកដែលបានរួចជីវិតក្នុងហេតុការណ៍លិចកប៉ាល់ទីតានិច បុរសម្នាក់បានប្រាប់គេថា គាត់គឺជា «មនុស្សចុងក្រោយ ដែលលោកគ្រូគង្វាល ចន ហាភ័រ បាននាំឲ្យជឿព្រះ»។ ពីដំបូងគាត់បានបដិសេធន៍ នៅពេលដែលលោកគ្រូ ហាភ័រ ប្រាប់គាត់ឲ្យទទួលជឿព្រះយេស៊ូវ តែបន្ទាប់មកគាត់ក៏បានទទួលជឿព្រះអង្គ នៅពេលដែលគ្រូអធិប្បាយរូបនេះបានប្រាប់គាត់ម្តងទៀត ឲ្យទទួលជឿព្រះអង្គ។ គាត់បានឃើញលោកគ្រូ ហាភ័រ លះបង់ពេលវេលាចុងក្រោយនៃជីវិតរបស់ខ្លួន ដើម្បីចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវ មុនពេលដែលគ្រូគង្វាលរូបនេះបាត់បង់ជីវិត ដោយសារទឹកសមុទ្រត្រជាក់ពេក ហើយក៏បានលិចចុះទៅក្នុងទឹក។

ក្នុងសំបុត្រដែលសាវ័ក ប៉ុល បានសរសេរផ្ញើលោក ធីម៉ូថេ គាត់បានលើកទឹកចិត្តលោក ធីម៉ូថេ ឲ្យមានការផ្សាយដំណឹងល្អ ដោយការបន្ទាន់ និងការប្តេជ្ញាចិត្ត និងការលះបង់ស្រដៀងនេះផងដែរ។ គាត់បានបញ្ជាក់ដល់លោក ធីម៉ូថេ អំពីព្រះវត្តមានរបស់ព្រះយេស៊ូវ ដែលតែងតែគង់នៅជាមួយ និងបញ្ជាក់អំពីការយាងមកវិញរបស់ព្រះអង្គ ហើយទន្ទឹមនឹងនោះ គាត់ក៏បានបង្គាប់លោក ធីម៉ូថេ ឲ្យផ្សាយដំណឹងល្អ ដោយចិត្តអត់ធ្មត់ និងភាពច្បាស់លាស់ (២ធីម៉ូថេ ៤:១-២)។ លោកសាវ័កក៏បានរំឭកគ្រូអធិប្បាយវ័យក្មេងនេះ ឲ្យនៅតែផ្តោតចិត្តទៅលើការផ្សាយដំណឹងល្អ ទោះអ្នកខ្លះនឹងបដិសេធន៍ព្រះយេស៊ូវក៏ដោយ (ខ.៣-៥)។

ពេលវេលាដែលយើងនៅសល់ នៅលើផែនដីនេះ មានចំនួនកំណត់ ដូចនេះចូរយើងប្រើពេលនីមួយៗឲ្យមានប្រយោជន៍។ យើងអាចទុកចិត្តថា ព្រះវរបិតានៃយើងបានរៀបចំកន្លែងឲ្យយើងនៅនគរស្ថានសួគ៌ ខណៈពេលដែលយើងប្រកាសថា «ព្រះយេស៊ូវជាព្រះអង្គសង្គ្រោះ!»—Xochitl Dixon

តើការដឹងថា ចំនួនថ្ងៃរបស់យើងមានកំណត់ បានបង្កើនភាពបន្ទាន់របស់អ្នកក្នុងការផ្សាយដំណឹងល្អអំពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ ដូចម្តេចខ្លះ? តើអ្នកនឹងឈោងទៅរកអ្នកដទៃ នៅថ្ងៃនេះ ដោយរបៀបណា?

ឱព្រះយេស៊ូវ សូមព្រះអង្គប្រទានទូលបង្គំនូវឱកាសចែកចាយអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គដល់អ្នកដទៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ២ពង្សាវតារ ៣៤-៣៦ និងយ៉ូហាន ១៩:១-២២

អស់អ្នកណាដែលស្លាប់ក្នុងព្រះអម្ចាស់ នោះមានពរហើយ (វិវរណៈ ១៤:១៣)។

ផ្នូររបស់ឧកញ៉ាសេបណា

លោក ដាប់ប៊ិលយូ ប៊ី យីត (W. B. Yeats) ចង់ឲ្យគេបញ្ចុះសពគាត់ នៅជើងភ្នំ «ប៊ែន ប៊ុលប៊ែន» ជាភ្នំដែលមានកំពូលរាបស្មើ ហើយគេបានដាក់ឈ្មោះឲ្យភ្នំនេះ ផ្អែកទៅលើចំណងជើងរបស់បទកំណាព្យចុងក្រោយរបស់គាត់។ គេបានឆ្លាក់ឃ្លាចុងក្រោយនៃកំណាព្យគាត់ នៅលើផ្លាកឈ្មោះផ្នូររបស់គាត់ថា៖ «ចូរយើងពិចារណាអំពីជីវិត និងសេចក្តីស្លាប់ ដោយមិនលម្អៀង នោះសេះនឹងផាយទៅបាត់!»។

មានការយល់ឃើញខុសៗគ្នាជាច្រើន អំពីអត្ថន័យរបស់ពាក្យមួយឃ្លានេះ។ អ្នកនិពន្ធបទកំណាព្យនេះប្រហែលជាបានទទួលស្គាល់ ធាតុពិតនៃជីវិត និងសេចក្តីស្លាប់។ ទោះជាយ៉ាងណាក៏ដោយ បំណងរបស់លោក យីត ក៏បានសម្រេច ដោយគេបានបញ្ចុះសពគាត់នៅជើងភ្នំនោះ ស្របតាមអ្វីដែលគេបានឆ្លាក់នៅលើផ្លាកឈ្មោះផ្នូរគាត់។ ប៉ុន្តែ ការពិតដែលមនុស្សពិបាកទទួលយកនោះគឺ ជីវិតរបស់អ្នកដទៃនៅតែបន្ត ដោយគ្មានយើង ទោះយើងធ្លាប់មានឥទ្ធិពលយ៉ាងណា មុនពេលយើងលាចាកលោកក៏ដោយ។

ក្នុងអំឡុងពេលដ៏ពិបាក នៃប្រវត្តិសាស្ត្ររបស់នគរយូដា លោក សេបណា ជាឧកញ៉ាមានមុខនាទីជារដ្ឋបាលនៃរាជវាំងបានឲ្យគេសង់ផ្នូរមួយសម្រាប់ខ្លួនគាត់ ដើម្បីឲ្យគេនៅនឹកចាំអំពីកេរដំណែលរបស់គាត់ បន្ទាប់ពីគាត់ស្លាប់។ ប៉ុន្តែ ព្រះអម្ចាស់បានមានបន្ទូលតាមរយៈហោរា អេសាយ ថា «ឯងមានការអ្វីនៅទីនេះ តើមានញាតិសន្តានណានៅទីនេះ បានជាឯងធ្វើម៉ែងសំរាប់ខ្លួនដូច្នេះ ដូចជាអ្នកណាដែលធ្វើម៉ែងសំរាប់ខ្លួននៅលើទីខ្ពស់ គឺជាប់ទីលំនៅសំរាប់ខ្លួននៅក្នុងថ្ម» (អេសាយ ២២:១៦)។ លោក ហោរា ក៏បានប្រាប់គាត់ថា «ទ្រង់នឹងរុំឆ្ងាក់ឯងជាពិត ហើយបោះឯងទៅក្នុងស្រុក១ធំទូលាយ ដូចជាគេបោះបុំអំបោះ ឯងនឹងស្លាប់នៅទីនោះវិញ» (ខ.១៨)។

លោក សេបណា បានយល់ច្រឡំ។ ទីកន្លែងបញ្ចុះសពរបស់យើងមិនសំខាន់នោះទេ អ្នកដែលយើងបម្រើទើបសំខាន់ ចំពោះយើង។ អ្នកបម្រើព្រះយេស៊ូវ មានការកម្សាន្តចិត្តដ៏លើសលប់ ព្រោះព្រះគម្ពីរបានចែងថា «អស់អ្នកណាដែលស្លាប់ក្នុងព្រះអម្ចាស់ នោះមានពរហើយ» (វិវរណៈ ១៤:១៣)។ យើងបម្រើព្រះ ដែលតែងតែយកព្រះទ័យទុកដាក់ចំពោះ «ការលាចាកលោក» របស់យើង។ ព្រះអង្គកំពុងទន្ទឹងរង់ចាំពេលដែលយើងទៅដល់ស្ថានសួគ៌ ហើយស្វាគមន៍យើងចូលផ្ទះដ៏អស់កល្ប!—Tim Gustafson

តើការរស់នៅរបស់ខ្ញុំ បានឆ្លុះបញ្ចាំងដូចម្តេចខ្លះ អំពីអ្នកដែលខ្ញុំកំពុងធ្វើការបម្រើ? តើអ្នកចង់ឲ្យគេនឹកចាំអ្នកដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំ ឲ្យរស់នៅជារៀងរាល់ថ្ងៃ ដោយទន្ទឹងរង់ចាំពេលដែលទូលបង្គំនឹងទៅរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច។

Daily Manna 2026_Content Enhance.indd 168 17/11/25 1:45 in the afternoon

ទូលបង្គំនឹងអរព្រះគុណដល់ទ្រង់ ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់ ព្រលឹងទូលបង្គំក៏ដឹងច្បាស់ហើយ (ទំនុកតម្កើង ១៣៩:១៤)។

ស្នាព្រះហស្តដ៏អស្ចារ្យរបស់ព្រះ

ជីវិទ្យាសាស្ត្រផ្នែកប្រព័ន្ធប្រសាទមានការរីកចម្រើនយ៉ាងខ្លាំង ក្នុងការយល់ដឹងអំពីរបៀបដែលខួរក្បាលមានដំណើរការ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អ្នកវិទ្យាសាស្ត្របានទទួលស្គាល់ថា ពួកគេស្ថិតនៅក្នុងដំណាក់កាលដំបូងនៃការយល់ដឹងអំពីខួរក្បាលមនុស្ស។ ពួកគេមានយល់ដឹងអំពីរចនាសម្ព័ន្ធរបស់ខួរក្បាល ផ្នែកខ្លះនៃមុខងាររបស់វា និងផ្នែកនៃខួរក្បាល ដែលឆ្លើយតបចំពោះបរិស្ថានជុំវិញ ភ្ញោចញាណរបស់យើងឲ្យមានការឆ្លើយតប បង្កើតឲ្យមានចលនា និងផ្ទុកទៅដោយអារម្មណ៍។ ប៉ុន្តែ ពួកគេនៅតែមិនអាចយល់អំពីរបៀបដែលទំនាក់ទំនងទាំងអស់នេះ រួមចំណែកនៅក្នុងការបង្កើតឲ្យមានអាកប្បកិរិយា ការយល់ដឹង និងការចងចាំឡើយ។ មនុស្សជាតិគឺជាស្នាព្រះហស្តដែលមានភាពស្មុគស្មាញយ៉ាងខ្លាំង ដែលនៅតែមានអាថ៌កំបាំងជាច្រើនដែលយើងមិនដឹង។

ស្តេច ដាវីឌ បានទទួលស្គាល់ភាពអស្ចារ្យនៃរូបកាយរបស់មនុស្ស។ ទ្រង់បានប្រើពាក្យប្រៀបប្រដូច ក្នុងការសរសើរតម្កើងព្រះចេស្តារបស់ព្រះអម្ចាស់ ដែលបានបង្ហាញចេញមក តាមរយៈការគ្រប់គ្រងរបស់ព្រះអង្គ មកលើដំណើរការនៃធម្មជាតិទាំងមូល គឺដូចដែលព្រះអង្គ «ធ្វើគ្រឿងនៃស្តេចដាវីឌនៅក្នុងផ្ទៃម្តាយ» (ទំនុកតម្កើង ១៣៩:១៣)។ ទ្រង់បានរៀបរាប់ទៀតថា «ដ្បិតទ្រង់បានបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ ឯស្នាដៃនៃទ្រង់ ក៏សុទ្ធតែអស្ចារ្យទាំងអស់» (ខ.១៤)។ មនុស្សនៅសម័យបុរាណបានយល់ឃើញថា ការលូតលាស់របស់ទារកក្នុងផ្ទៃម្តាយ គឺជាអាថ៌កំបាំងដ៏អស្ចារ្យ (សូមមើល សាស្តា ១១:៥)។ ទោះស្តេច ដាវីឌ មានការយល់ដឹងមានកំណត់អំពីភាពស្មុគស្មាញដ៏អស្ចារ្យរបស់រូបកាយមនុស្សក៏ដោយ ក៏ទ្រង់នៅតែឈរស្ងប់ស្ងែង ចំពោះស្នាព្រះហស្ត និងព្រះវត្តមានដ៏អស្ចារ្យរបស់ព្រះអម្ចាស់ (ទំនុកតម្កើង ១៣៩:១៧-១៨)។

ភាពអស្ចារ្យ និងគួរស្ងប់ស្ងែងនៃភាពស្មុគស្មាញរបស់រូបកាយមនុស្ស បានឆ្លុះបញ្ចាំងអំពីព្រះចេស្តា និងអំណាចគ្រប់គ្រងរបស់ព្រះដ៏អស្ចារ្យនៃយើង។ បានជាយើងអាចឆ្លើយតប ដោយការសរសើរតម្កើង ការកោតខ្លាច និងការស្ងប់ស្ងែង!—Marvin Williams

តើការយល់ដឹងអំពីការចនាដ៏ស្មុគស្មាញរបស់រូបកាយអ្នក បាននាំឲ្យអ្នកសរសើរតម្កើងព្រះដូចម្តេចខ្លះ? តើអ្នកអាចអរព្រះគុណព្រះ តាមរបៀបដ៏ប៉ិនប្រសប់ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមសរសើរតម្កើងព្រះអង្គ សម្រាប់ការបង្កើតទូលបង្គំមកយ៉ាងគួរកោត គួរអស្ចារ្យ។ ព្រះអង្គជាព្រះអាទិករដ៏អស្ចារ្យ!

Daily Manna 2026_Content Enhance.indd 169 17/11/25 1:45 in the afternoon

ដូច្នេះ ឲ្យអ្នករាល់គ្នាប្រុងប្រៀបខ្លួនជាស្រេចដែរ ដ្បិតកូនមនុស្សនឹងមកនៅវេលាដែលអ្នករាល់គ្នាមិនគិត (ម៉ាថាយ ២៤:៤៤)។

ការរំពឹងថា ព្រះយេស៊ូវនឹងយាងមកវិញ

មានពេលមួយ មិត្តភក្តិខ្ញុំម្នាក់ឈ្មោះ ប៉ុល (Paul) កំពុងរង់ចាំជាងមកជួសជុលទូរទឹកកករបស់គាត់។ គាត់ក៏បានបើកទូរស័ព្ទរបស់គាត់ ឃើញសារដែលក្រុមហ៊ុនលក់គ្រឿងអេឡិចត្រូនិកបានផ្ញើមក។ ក្នុងសារនោះ គាត់ឃើញគេសរសេរថា «យេស៊ូវ កំពុងធ្វើដំណើរមកហើយ រំពឹងថា នឹងមកដល់នៅម៉ោងប្រហែល ១១:៣៥នាទីព្រឹក»។ មិនយូរប៉ុន្មានលោក ប៉ុល ក៏បានដឹងថា តាមពិតជាងជួសជុលនោះមានឈ្មោះយេស៊ូវ។

ប៉ុន្តែ តើយើងអាចរំពឹងថា ព្រះយេស៊ូវ ជាព្រះរាជបុត្រានៃព្រះ នឹងយាងមកដល់នៅពេលណា? កាលព្រះអង្គបានយាងមកយកកំណើតជាមនុស្ស កាលពីជាង២ពាន់ឆ្នាំមុន ហើយបានទទួលទោសនៃបាបរបស់យើង ព្រះអង្គមានបន្ទូលថា ព្រះអង្គនឹងយាងមកវិញ តែមានតែព្រះវរបិតាទេ ដែលបានជ្រាបថា ព្រះអង្គនឹងយាងមក «នៅថ្ងៃ និងម៉ោងណា» (ម៉ាថាយ ២៤:៣៦)។ តើយើងនឹងមានការផ្លាស់ប្តូរអាទិភាពរបស់យើង ក្នុងការរស់នៅប្រចាំថ្ងៃ ដូចម្តេចខ្លះ បើសិនជាយើងពិតជាបានដឹងអំពីពេលដែលព្រះអង្គសង្គ្រោះរបស់យើងនឹងយាងមកវិញ? (យ៉ូហាន ១៤:១-៣)។

ដើម្បីជាស់តឿនយើងឲ្យមានការប្រុងប្រយ័ត្ន ក្នុងការត្រៀមខ្លួនសម្រាប់ការយាងមកវិញរបស់ព្រះយេស៊ូវ ព្រះអង្គបានមានបន្ទូលថា «ដូច្នេះ ឲ្យអ្នករាល់គ្នាប្រុងប្រៀបខ្លួនជាស្រេចដែរ ដ្បិតកូនមនុស្សនឹងមកនៅវេលាដែលអ្នករាល់គ្នាមិនគិត» (ម៉ាថាយ ២៤:៤៤)។ ព្រះអង្គបានក្រើនរំឭកយើង ឲ្យ «ចាំយាម ដ្បិតអ្នករាល់គ្នាមិនដឹងជាពេលណា ដែលព្រះអម្ចាស់នៃអ្នករាល់គ្នានឹងយាងមកទេ» (ខ.៤២)។

នៅថ្ងៃដែលព្រះគ្រីស្ទយាងមកវិញ យើងនឹងមិនទទួលសារក្នុងស័ព្ទ ដែលនឹងជាស់តឿនយើងឲ្យប្រុងប្រៀបខ្លួនទេ។ ហេតុនេះហើយ តាមរយៈព្រះចេស្តានៃព្រះវិញ្ញាណ ធ្វើការតាមរយៈយើង ចូរយើងរស់នៅរៀងរាល់ថ្ងៃដោយសម្លឹងឆ្ពោះទៅរកភាពអស់កល្បជានិច្ច ដោយបម្រើព្រះអង្គ និងឆក់ឱកាសនីមួយៗ ដើម្បីចែកចាយព្រះបន្ទូលនៃសេចក្តីស្រឡាញ់ និងក្តីសង្ឃឹមដល់អ្នកដទៃ។—Cindy Hess Kasper

តើការរង់ចាំការយាងមកវិញរបស់ព្រះយេស៊ូវ បានលើកទឹកចិត្តអ្នកឲ្យមានការផ្លាស់ប្តូរដូចម្តេចខ្លះ? តើអ្នករំពឹងថា នឹងទទួលបានអ្វី នៅពេលដែលព្រះអង្គយាងមកវិញ?

ឱព្រះវរបិតា ខណៈពេលដែលទូលបង្គំកំពុងរង់ចាំព្រះយេស៊ូវយាងមកវិញ ដោយចិត្តអត់ធ្មត់ សូមព្រះអង្គជួយទូលបង្គំឲ្យស្អាប់បង្អាប់ព្រះអង្គ ដេញតាមសេចក្តីបរិសុទ្ធ និងរស់នៅ ក្នុងការរំពឹងថា ព្រះគ្រីស្ទនឹងយាងមកវិញក្នុងពេលឆាប់ៗ។

Daily Manna 2026_Content Enhance.indd 170 17/11/25 1:45 in the afternoon

កូនស្រីអើយ សេចក្តីជំនឿនាង បានជួយសង្គ្រោះនាងហើយ (ម៉ាកុស ៥:៣៤)។

ទុក្ខវេទនា និងជំនឿដ៏ជ្រាលជ្រៅ

ក្នុងអំឡុងពេលនៃការសិក្សាព្រះគម្ពីរ ក្នុងពេលព្រឹកថ្ងៃសៅរ៍ សមាជិករបស់យើងម្នាក់មានការភ័ន្តភាំង ព្រោះកូនស្រីជាទីស្រឡាញ់របស់គាត់ដែលបានដើរផ្លូវខុស បានវិលត្រឡប់មកទីក្រុងវិញហើយ ប៉ុន្តែគាត់មានអារម្មណ៍ថាពិបាក ក្នុងការរស់នៅជាមួយនាង នៅក្រោមដំបូលផ្ទះតែមួយ ដោយសារអាកប្បកិរិយារបស់នាង។ អ្នកចូលរួមការសិក្សាព្រះគម្ពីរម្នាក់ទៀត មិនមានសុខភាពល្អក្នុងរូបកាយរបស់ខ្លួន ដោយសារផលប៉ះពាល់របស់ជម្ងឺរ៉ាំរ៉ៃ និងការមានវ័យកាន់តែចាស់។ ការទៅជួបគ្រូពេទ្យជាច្រើនលើក បានផ្តល់ឲ្យនូវភាពធូរស្រាលតែបន្តិចបន្តួច។ គាត់មានការបាក់ទឹកចិត្ត។ តែដោយសារការរៀបចំរបស់ព្រះ បទគម្ពីរម៉ាកុស ជំពូក៥ ជាបទគម្ពីរដែលពួកគេលើកយកមកសិក្សាជាមួយគ្នា នៅថ្ងៃនោះ។ ហើយនៅពេលដែលការសិក្សាបានបញ្ចប់ គាត់កើតមានក្តីសង្ឃឹម និងក្តីអំណរយ៉ាងខ្លាំង។

ក្នុងបទគម្ពីរ ម៉ាកុស ៥:២៣ លោក យ៉ៃរ៉ូស ជាឪពុកដែលមានកូនស្រីកំពុងឈឺធ្ងន់ បានទូលអង្វរព្រះយេស៊ូវថា “កូនស្រីទូលបង្គំជិតស្លាប់ហើយ សូមទ្រង់យាងទៅដាក់ព្រះហស្តលើវា ឲ្យបានជា នោះវានឹងរស់វិញ”។ នៅតាមផ្លូវទៅកាន់ផ្ទះរបស់ក្មេងស្រីនោះ ព្រះយេស៊ូវបានប្រោសស្ត្រីម្នាក់ ឲ្យជាសះស្បើយពីជំងឺរ៉ាំរ៉ៃ ដោយមានបន្ទូលថា “កូនស្រីអើយ សេចក្តីជំនឿនាង បានជួយសង្គ្រោះនាងហើយ” (ខ.៣៤)។ លោក យ៉ៃរ៉ូស និងស្ត្រីនោះ បានទទួលការជំរុញចិត្តពីសេចក្តីជំនឿ ដែលពួកគេមានចំពោះព្រះអង្គ បានជាពួកគេទៅរកព្រះអង្គ ហើយពួកគេមិនបានខកចិត្តឡើយ។ ប៉ុន្តែ ក្នុងករណីទាំងពីរនេះ មុនពេលពួកគេជួបព្រះយេស៊ូវ ស្ថានភាពរបស់ពួកគេកាន់តែមានការលំបាក តែក្រោយមក អ្វីៗក៏បានល្អប្រសើរឡើង។

ទុក្ខលំបាកក្នុងជីវិតកើតមានចំពោះមនុស្សគ្រប់រូប ដោយមិនរើសមុខ។ ទោះយើងមានភេទ អាយុ ជាតិសាសន៍ ឬឋានៈអ្វីក៏ដោយ យើងរាល់គ្នាសុទ្ធតែជួបស្ថានភាព ដែលធ្វើឲ្យយើងភ័ន្តភាំង ហើយបណ្តាលឲ្យយើងស្វែងរកដំណោះស្រាយ។ ចូរយើងកុំបណ្តោយឲ្យបញ្ហាប្រឈម រារាំងយើងមិនឲ្យងាកទៅរកព្រះយេស៊ូវឡើយ តែផ្ទុយទៅវិញចូរយើងប្រើវាជាឱកាស ដើម្បីប្រើសេចក្តីជំនឿកាន់តែជ្រាលជ្រៅ ចំពោះព្រះដែលជ្រាបអំពីអារម្មណ៍របស់យើង ពេលយើងឈោងទៅរកព្រះអង្គ (ខ.៣០) ហើយអាចធ្វើឲ្យអ្វីៗមានភាពល្អប្រសើរឡើង ក្នុងជីវិតយើង។—Arthur Jackson

តើការរង់ចាំការយាងមកវិញរបស់ព្រះយេស៊ូវ បានលើកទឹកចិត្តអ្នកឲ្យមានការផ្លាស់ប្តូរដូចម្តេចខ្លះ? តើអ្នករំពឹងថា នឹងទទួលបានអ្វី នៅពេលដែលព្រះអង្គយាងមកវិញ?

ឱព្រះយេស៊ូវ ព្រះអង្គជ្រាបអំពីស្ថានភាពដ៏ឈឺចាប់ ក្នុងជីវិតទូលបង្គំ។ សូមព្រះអង្គធ្វើឲ្យទូលបង្គំមានភាពរឹងមាំក្នុងជំនឿ ទោះអ្វីៗប្រែក្លាយពីអាក្រក់ ទៅជាអាក្រក់កាន់តែខ្លាំងយ៉ាងណាក៏ដោយ។

Daily Manna 2026_Content Enhance.indd 171 17/11/25 1:45 in the afternoon

កុំឲ្យប្រើសេរីនោះ ទុកជាឱកាសដល់សាច់ឈាមឡើយ គឺត្រូវបំរើគ្នាទៅវិញទៅមក ដោយសេចក្តីស្រឡាញ់វិញ (កាឡាទី ៥:១៣)។

ចិត្តដែលចូលចិត្តបម្រើអ្នកដទៃ

កាល «ពូ» របស់ខ្ញុំ ឈ្មោះ អេម៉ូរី (Emory) លាចាកលោក មនុស្សជាច្រើនបានបង្ហាញចេញនូវការគោរពដល់គាត់។ ប៉ុន្តែ ការផ្តល់កិត្តិយសទាំងនោះ បានបង្កប់នូវខ្លឹមសាររួមដ៏ជាប់លាប់មួយគឺ លោកពូ អេម៉ូរី បានបង្ហាញសេចក្តីស្រឡាញ់របស់គាត់ដល់ព្រះ តាមរយៈការបម្រើអ្នកដទៃ។ គុណល្អបំផុតរបស់គាត់គឺបានធ្វើឡើង ក្នុងអំឡុងសម័យសង្គ្រាមលោកលើកទី១ ក្នុងជួរកងទ័ព ដែលនៅទីនោះ គាត់បានបម្រើការជាពេទ្យទាហាន ដែលចូលទៅក្នុងសមរភូមិ ដោយមិនកាន់អាវុធក្នុងដៃ។ គាត់ទទួលបានមេដាយកិត្តិយសដ៏ខ្ពង់ខ្ពស់របស់កងទ័ព សម្រាប់វីរភាពរបស់គាត់ ប៉ុន្តែគេបាននឹកចាំអំពីគាត់ ដោយសារការបម្រើ ដោយសេចក្តីស្រឡាញ់ទាំងក្នុងអំឡុងសម័យសង្គ្រាម និងក្រោយសម័យសង្គ្រាម។

ការដែលលោក អេម៉ូរី បម្រើអ្នកដទៃ ដោយមិនគិតប្រយោជន៍ផ្ទាល់ខ្លួន គឺស្របទៅតាមការបង្រៀនរបស់សាវ័ក ប៉ុល ទៅកាន់ពួកជំនុំនៅទីក្រុងកាឡាទីយ៉ាងដូចនេះថា «បងប្អូនអើយ ព្រះទ្រង់បានហៅអ្នករាល់គ្នាមក ឲ្យមានសេរីភាព តែកុំឲ្យប្រើសេរីនោះ ទុកជាឱកាសដល់សាច់ឈាមឡើយ គឺត្រូវបំរើគ្នាទៅវិញទៅមក ដោយសេចក្តីស្រឡាញ់វិញ» (កាឡាទី ៥:១៣)។ ប៉ុន្តែ តើយើងបម្រើដោយរបៀបណា? ក្នុងភាពប្រែប្រួលរបស់យើង សាច់ឈាមរបស់យើងទាញនាំយើងគិតប្រយោជន៍ខ្លួនឯងជាមុន ជាជាងខ្វល់អំពីអ្នកដទៃ ដូចនេះតើការមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ខុសពីនិស្ស័យសាច់ឈាមយើង មានប្រភពចេញពីណា?

ក្នុងបទគម្ពីរភីលីព ២:៥ សាវ័ក ប៉ុល បានផ្តល់ឲ្យនូវការលើកទឹកចិត្តថា ក្នុងទំនាក់ទំនងជាមួយអ្នកដទៃយើង «ត្រូវតែមានគំនិតគិតដូចជាព្រះគ្រីស្ទយេស៊ូវិញ»។ សាវ័ក ប៉ុល ក៏បានពិពណ៌នាអំពីព្រះគ្រីស្ទដែលបានស្ម័គ្រព្រះទ័យសុគតនៅលើឈើឆ្កាង ដោយសារសេចក្តីស្រឡាញ់ដ៏លើសលប់ចំពោះយើងរាល់គ្នា។ ទាល់តែព្រះវិញ្ញាណព្រះអង្គកែប្រែគំនិតយើង ឲ្យគិតដូចព្រះគ្រីស្ទ ទើបព្រះអង្គញែកយើងចេញ ហើយជួយឲ្យយើងអាចធ្វើការលះបង់ ដើម្បីអ្នកដទៃ ដោយឆ្លុះបញ្ចាំងអំពីការលះបង់ដ៏ខ្ពស់បំផុតរបស់ព្រះយេស៊ូវ ដើម្បីយើងរាល់គ្នា។ ចូរយើងចុះចូលនឹងព្រះរាជកិច្ចរបស់ព្រះយេស៊ូវ ដែលកំពុងធ្វើការក្នុងចិត្តយើង។—Bill Crowder

តើអ្នកដទៃបានធ្វើការលះបង់ ដើម្បីបម្រើអ្នកដូចម្តេចខ្លះ? តើអ្នកអាចបម្រើអ្នកដទៃ ដូចម្តេចខ្លះ ដោយរាប់ចាប់ពីគ្រួសាររបស់អ្នកទៅ?

ឱព្រះវរបិតានៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានគំរូដ៏ឥតខ្ចោះរបស់ព្រះយេស៊ូវ និងការលះបង់របស់ព្រះអង្គ ដើម្បីទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យមានគំនិតគិតដូចព្រះយេស៊ូវិញ។

Daily Manna 2026_Content Enhance.indd 172 17/11/25 1:45 in the afternoon

ស្រាប់តែអ្នកនោះបានជាភ្លាម ក៏យកគ្រែដើរទៅ (យ៉ូហាន ៥:៩)។

សង្ឃឹមថា នឹងបានការប្រោសឲ្យជា

ហេតុផលថ្មីមួយដែលធ្វើឲ្យគេមានសង្ឃឹមបានលេចឡើងសម្រាប់មនុស្សដែលពិការ ដោយសារមានរបួសនៅឆ្អឹងខ្នង។ ក្រុមអ្នកស្រាវជ្រាវជនជាតិអាឡឺម៉ង់ បានរកឃើញវិធីភ្ញោចប្រព័ន្ធប្រសាទឲ្យលូតលាស់ឡើងវិញ ដើម្បីតភ្ជាប់នូវសរសៃប្រសាទរវាងសាច់ដុំ និងខួរក្បាលដែលបានដាច់។ ការបណ្តុះនេះបានជួយឲ្យសត្វកណ្តុរដែលពិការ អាចដើរឡើងវិញបាន ហើយគេនឹងបន្តធ្វើតេស្ត ដើម្បីកំណត់ឲ្យច្បាស់ថា ការព្យាបាលនោះមានសុវត្ថិភាព និងប្រសិទ្ធភាពសម្រាប់មនុស្សឬអត់។

អ្វីដែលអ្នកវិទ្យាសាស្ត្របានព្យាយាមស្វែងរក សម្រាប់អ្នកដែលមានភាពពិការ ក៏ជាអ្វីព្រះយេស៊ូវបានប្រទានមក តាមរយៈការអស្ចារ្យផងដែរ។ មានពេលមួយ ព្រះអង្គយាងទៅស្រះទឹក បេថែសដា ជាកន្លែងដែលមនុស្សជាច្រើនមានជំងឺបានទៅ ដោយសង្ឃឹមថា នឹងទទួលបានការប្រោសឲ្យជា។ ព្រះអង្គក៏បានទតឃើញបុរសម្នាក់ដែលពិការ៣៨ឆ្នាំហើយ (យ៉ូហាន ៥:៥)។ បន្ទាប់ពីបុរសនោះបានបញ្ជាក់ច្បាស់ថា គាត់ពិតជាចង់ទទួលការប្រោសឲ្យជា ព្រះអង្គក៏បានបង្គាប់គាត់ឲ្យក្រោកឈរ ហើយដើរ។ “ស្រាប់តែអ្នកនោះបានជាភ្លាម ក៏យកគ្រែដើរទៅ” (ខ.៩)។

ព្រះអង្គមិនបានសន្យាថា ជំងឺខាងសាច់ឈាមរបស់យើងនឹងបានជាទាំងអស់ ក្នុងជីវិតនៅលើផែនដីនេះទេ ហើយមានមនុស្សផ្សេងទៀតនៅមាត់ស្រះនោះ ដែលមិនបានទទួលការប្រោសឲ្យជានៅថ្ងៃនោះ។ តែអ្នកដែលជឿព្រះអង្គ អាចដកពិសោធន៍នឹងការប្រោសឲ្យជា ដែលព្រះអង្គប្រទាន គឺប្រោសឲ្យជាពីភាពអស់សង្ឃឹម ទៅជាមានសង្ឃឹម ពីភាពជូរល្វីង ទៅជាប្រកបដោយព្រះគុណ ពីសេចក្តីសម្អប់ទៅជាសេចក្តីស្រឡាញ់ ពីការចោទប្រកាន់ទៅជាការអត់ទោស។ គ្មានការរកឃើញរបស់វិទ្យាសាស្ត្រណា (ឬទឹកស្រះណា) ដែលអាចផ្តល់ឲ្យយើងនូវការប្រោសឲ្យជាដូចនេះបានទេ ព្រោះវាកើតមានឡើង ដោយសារសេចក្តីជំនឿប៉ុណ្ណោះ។—Kirsten Holmberg

តើអ្នកបានជួបការល្បួង ឲ្យស្វែងរកការប្រោសឲ្យជាខាងវិញ្ញាណនៅក្នុងការអ្វីផ្សេងក្រៅពីព្រះយេស៊ូវនៅកន្លែងណា? តើអ្នកមានការលើកទឹកចិត្តយ៉ាងណា ពេលដែលបានដឹងថា ថ្ងៃមួយអ្នកជឿព្រះយេស៊ូវនឹងបានទទួលការប្រោសឲ្យជាទាំងស្រុងខាងរូបកាយផងដែរ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការព្យាបាលជំងឺធំបំផុត ដែលជាបាបរបស់ទូលបង្គំ ហើយបានស្តារសុខភាពខាងវិញ្ញាណរបស់ទូលបង្គំឡើងវិញ តាមរយៈព្រះយេស៊ូវ។

Daily Manna 2026_Content Enhance.indd 173 17/11/25 1:45 in the afternoon

កាលណាច្រូតចំរូតនៅស្រែរបស់ឯង... ត្រូវទុកសំរាប់អ្នកដទៃ និងពួកកូនកំព្រា ហើយនឹងស្រីមេម៉ាយវិញ (ចោទិយកថា ២៤:១៩)។

សេចក្តីជំនឿដែលសប្បុរស

កាលពីបីឆ្នាំមុន ពួកជំនុំរបស់យើងបានទទួលការអញ្ជើញ ឲ្យទទួលជនភៀសខ្លួនចូលស្នាក់នៅ បន្ទាប់ពីពួកគេបានភៀសខ្លួនចេញប្រទេសកំណើត ដោយសារការផ្លាស់ប្តូរអ្នកដឹកនាំ ដែលនាំឲ្យមានភាពវឹកវរ។ ក្រុមគ្រួសារទាំងមូលបានធ្វើដំណើរមកដល់ ដោយមានតែបង្វែចតួចមួយ។ ក្រុមគ្រួសារមួយចំនួនក្នុងពួកជំនុំរបស់ខ្ញុំ បានបើកទ្វារផ្ទះទទួលពួកគេឲ្យចូលរស់នៅជាមួយ ហើយសូម្បីតែគ្រួសារដែលនៅសល់តែបន្ទប់តូចមួយ ក៏បានស្វាគមន៍ពួកគេឲ្យចូលស្នាក់នៅជាមួយផងដែរ។

ការទទួលស្វាគមន៍ដោយចិត្តសប្បុរសដូចនេះ បានឆ្លុះបញ្ចាំងអំពីព្រះរាជបញ្ជារបស់ព្រះចំពោះពួកអ៊ីស្រាអែល នៅពេលដែលពួកគេចូលរស់នៅក្នុងទឹកដីសន្យា (ចោទិយថា ២៤:១៩-២១)។ ដោយសារពួកគេរស់នៅក្នុងសង្គមកសិកម្ម ពួកគេមានការយល់ដឹងអំពីសារៈសំខាន់នៃការប្រមូលផល។ ស្រូវដែលពួកគេបានច្រូតកាត់ មានសារៈសំខាន់យ៉ាងខ្លាំង ចំពោះការរស់នៅក្នុងឆ្នាំក្រោយ។ ហេតុនេះហើយ ព្រះអម្ចាស់ក៏បានបង្គាប់ពួកគេឲ្យ ទុកគួរស្រូវខ្លះ សម្រាប់ជនបរទេសដែលមកស្នាក់នៅក្នុងចំណោមពួកគេ ក៏ដូចជាសម្រាប់ពួកក្មេងកំព្រា និងស្ត្រីមេម៉ាយ (ខ.១៩) ហើយក៏បានប្រាប់ពួកគេឲ្យទុកចិត្តលើការផ្គត់ផ្គង់របស់ព្រះអង្គ។ ពួកអ៊ីស្រាអែលត្រូវតែបង្ហាញចេញនូវចិត្តសប្បុរស មិនគ្រាន់តែចែករំលែកដល់អ្នកដទៃ នៅពេលដែលពួកគេមានគ្រប់គ្រាន់ប៉ុណ្ណោះទេ តែក៏ត្រូវចែករំលែក ដោយទុកចិត្តលើការផ្គត់ផ្គង់របស់ព្រះអង្គផងដែរ។

ការស្វាគមន៍អ្នកដទៃយ៉ាងដូចនេះ ក៏បានរំឭកពួកគេឲ្យនឹកចាំថា កាលពីមុនពួកគេក៏ធ្លាប់រស់នៅជាទាសកររក្នុងទឹកដីអេស៊ីព្ទផងដែរ (ខ.១៨, ២២)។ កាលពីមុន ពួកគេធ្លាប់រស់នៅក្រោមការគាបសង្កត់ និងភាពលំបាកគោកយ៉ាក។ ការបង្ហាញចេញនូវសេចក្តីសប្បុរសរបស់ពួកគេ គឺជាការរំឭកអំពីសេចក្តីសប្បុរស ដែលព្រះអង្គមានចំពោះពួកគេ នៅក្នុងការរំដោះពួកគេឲ្យរួចពីចំណង។

អ្នកជឿព្រះយេស៊ូវ ក៏បានទទួលការលើកទឹកចិត្តឲ្យប្រព្រឹត្តចំពោះអ្នកដទៃ ដោយចិត្តសប្បុរសផងដែរ។ គឺដូចដែលសាវ័ក ប៉ុល បានរំឭកយើងថា «ទោះបើទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ ដោយព្រោះអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានមានឡើង ដោយសារសេចក្តីកម្ររបស់ទ្រង់» (២កូរិនថូស ៨:៩)។ ដូចនេះ យើងត្រូវមានចិត្តសប្បុរសចំពោះអ្នកដទៃ ព្រោះព្រះអង្គបានបង្ហាញព្រះទ័យសប្បុរសចំពោះយើងរួចហើយ។—Matt Lucas

តើមាននរណាម្នាក់ជួយអ្នកក្នុងពេលដែលអ្នកមានការខ្វះខាត នៅពេលណា? តើអ្នកនឹងចែករំលែកដល់អ្នកដទៃ ដោយទុកចិត្តលើការផ្គត់ផ្គង់របស់ព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គបើកភ្នែកទូលបង្គំ ឲ្យមើលឃើញតម្រូវការរបស់អ្នកដែលខ្វះខាតក្នុងសហគមន៍របស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | នេហេមា ៧-៩ និងកិច្ចការ ៣

ព្រះទ្រង់ព្រោសមនុស្សត្រមោចឲ្យបែកជាគ្រួសារឡើង (ទំនុកតម្កើង ៦៨:៦)។

មិត្តសំឡាញ់សម្រាប់មនុស្សឯកោ

អ្នកស្រី ហូលី ឃុត (Holly Cooke) មិនមានមិត្តភក្តិសូម្បីតែម្នាក់ ពេលគាត់ផ្លាស់មករស់នៅក្នុងទីក្រុងឡុងដ៍ ប្រទេសអង់គ្លេស ដើម្បីធ្វើការនៅទីនោះ។ គាត់មានអារម្មណ៍វេទនា នៅចុងសប្តាហ៍។ ទីក្រុងឡុងដ៍ស្ថិតក្នុងចំណោមទីក្រុងដែលប្រជាជនមានការពិបាកចិត្តច្រើនជាងគេនៅលើពិភពលោក នេះបើយោងតាមការស្ទង់មតិជាសកល ៥៥ភាគរយ នៃប្រជាជននៅទីក្រុងនេះបាននិយាយថា ពួកគេមានអារម្មណ៍ឯកោ ខណៈពេលដែលនៅទីក្រុងលីសបិន ប្រទេសប៉ទុយហ្គាល់ មានប្រជាជនតែ១០ភាគរយ:ប៉ុណ្ណោះ ដែលមានអារម្មណ៍ឯកោ។

ដើម្បីតភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃ អ្នកស្រី ហូលី ក៏បានជម្នះការភ័យខ្លាចរបស់គាត់ ដោយបង្កើតបណ្តាញសង្គមមួយ ដែលមានឈ្មោះថា ក្លិបនារីឯកោនៅទីក្រុងឡុងដ៍ ហើយក្រោយមកមានមនុស្សប្រហែល ៣ម៉ឺន៥៣៣នាក់ បានចូលរួម។ មានការជួបជុំតាមក្រុមតូចៗ រៀងរាល់សប្តាហ៍ នៅកន្លែងពិកនិកក្នុងសួនច្បារ នៅកន្លែងរៀនសិល្បៈ នៅថ្នាក់រៀនធ្វើគ្រឿងអលង្ការ នៅកន្លែងអាហារពេលល្ងាច និងសូម្បីតែនៅកន្លែងហាត់ប្រាណក៏ដោយ។

បញ្ហាប្រឈមនៃភាពឯកោ មិនមែនទើបតែកើតមានក្នុងសម័យយើងទេ ហើយការប្រោសឲ្យជាសម្រាប់អារម្មណ៍ឯកោក៏បានកើតមានតាំងពីយូរមកហើយ។ គឺដូចដែលស្តេច ដាវីឌ បានសរសើរតម្កើងព្រះអម្ចាស់ថា ព្រះអង្គប្រោសមនុស្សឯកោ ឲ្យមានគ្រួសារ ហើយក៏នាំអ្នកជាប់ចំណង ឲ្យចេញទៅរកសេរីភាព ដោយសម្លេងច្រៀង (ទំនុកតម្កើង ៦៨:៦)។ ការទូលសូមព្រះអម្ចាស់ឲ្យនាំយើងទៅរកមិត្តភក្តិ ដែលមានលក្ខណៈដូចព្រះគ្រីស្ទ គឺជាឯកសិទ្ធិដ៏បរិសុទ្ធ និងជាការទូលសូមដែលយើងអាចថ្វាយដល់ព្រះអង្គនៅពេលណាក៏បាន។ គឺដូចដែលស្តេច ដាវីឌ បានពោលសរសើរព្រះអម្ចាស់ថា «ព្រះដែលគង់នៅក្នុងទីលំនៅបរិសុទ្ធ ទ្រង់ជាឪពុកដល់ពួកកំព្រា និងជាចៅក្រមដល់ពួកមេម៉ាយ» (ខ.៥) «សូមឲ្យព្រះអម្ចាស់បានប្រកបដោយព្រះពរ ដែលទ្រង់ទទួលយកបន្ទុកយើងខ្ញុំរាល់ៗថ្ងៃ គឺជាព្រះដ៏ជាទីសង្គ្រោះដល់យើងខ្ញុំ» (ខ.១៩)។

ព្រះយេស៊ូវជាមិត្តសំឡាញ់ពិត! ព្រះអង្គធ្វើជាមិត្តសំឡាញ់របស់យើងជារៀងរហូត ដោយរាប់ចាប់ពីពេលដែលព្រះអង្គគង់នៅជាមួយយើង ដោយព្រះវត្តមានប្រកបដោយសិរីល្អ គ្រប់ពេលវេលា។ ចូរយើងយកគំរូតាមព្រះអង្គ ដោយធ្វើជាមិត្តសំឡាញ់ពិតប្រាកដ សម្រាប់អ្នកដទៃជំនួសវិញ។—Patricia Raybon

តើអ្នកមានការអរសប្បាយក្នុងមិត្តភាពជាមួយព្រះយេស៊ូវ នៅត្រង់ចំណុចណា? តើព្រះអង្គបានបង្រៀនអ្នកឲ្យធ្វើជាមិត្តសំឡាញ់ពិតចំពោះអ្នកដទៃ ដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ពេលណាចិត្តទូលបង្គំមានអារម្មណ៍ឯកោ សូមព្រះអង្គចង្អុលបង្ហាញទូលបង្គំ ឲ្យដាក់ទៅរកមិត្តសំឡាញ់ដ៏ល្អ ដែលគិតចាប់ពីព្រះអង្គទៅ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | នេហេមា ១០-១១ និងកិច្ចការ ៤:១-២២

អញនឹងចាត់ឯងឲ្យទៅផារ៉ោន ដើម្បីឲ្យឯងបាននាំរាស្ត្រអញ គឺជាពួកកូនចៅអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទមក (និក្ខមនំ ៣:១០)។

ព្រះនៃសេរីភាព

បន្ទាប់ពី លោកប្រធានាធិបតី អេប្រាហាំ លិនខិន (Abraham Lincoln) បានចេញសេចក្តីប្រកាសដោះលែងទាសករទាំងអស់នៅភាគខាងត្បូងនៃសហរដ្ឋអាមេរិក រដ្ឋសហព័ន្ធដែលមិនចង់ដោះលែងទាសករក៏បានផ្តាច់ខ្លួន បណ្តាលឲ្យមានសង្គ្រាមស៊ីវិលផ្ទុះឡើង។ ប៉ុន្តែ បន្ទាប់ពីរដ្ឋសហព័ន្ធបានចុះចាញ់ រដ្ឋតិចសាស់នៅតែមិនទទួលស្គាល់សេរីភាពរបស់ទាសករ។ ទោះជាយ៉ាងណាក៏ដោយ នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៨៦៥ លោក ហ្គរដិន ក្រែងជ័រ (Gordon Granger) ជាមេទ័ពរបស់លោក អ័ប្រាហាំ លីនខិន ក៏បានដឹកនាំចូលទៅក្នុងទីក្រុងកាល់វេស្តុន រដ្ឋតិចសាសន៍ ហើយបានធ្វើការទាមទារ ឲ្យគេដោះលែងទាសករទាំងអស់។ សូមយើងស្រមៃអំពីការភ្ញាក់ផ្អើល និងក្តីអំណររបស់ទាសករ នៅពេលដែលគេដោះខ្នោះច្រវាក់ចេញពីជើងពួកគេ បន្ទាប់ពីគេបានឮការប្រកាសនោះ។

ព្រះអម្ចាស់ទតឃើញមនុស្សដែលត្រូវគេសង្កត់សង្កិន ហើយនៅទីបំផុត ព្រះអង្គក៏ប្រកាសថា ព្រះអង្គនឹងប្រទានសេរីភាព ដល់អ្នកដែលរស់នៅក្រោមភាពអយុត្តិធម៌។ ព្រះអង្គប្រកាសអំពីសេរីភាពក្នុងសម័យបច្ចុប្បន្ន ក៏ដូចនៅសម័យរបស់លោក ម៉ូសេ។ ព្រះអង្គបានបង្ហាញអង្គទ្រង់នៅក្នុងគុម្ពបន្លាឆេះ ដោយមានបន្ទូលជាលក្ខណៈបន្ទាន់ថា ព្រះអង្គបានឃើញសេចក្តីវេទនារបស់រាស្ត្រព្រះអង្គ ដែលនៅស្រុកអេស៊ីព្ទហើយ (និក្ខមនំ ៣:៧)។ ព្រះអង្គមិនគ្រាន់តែបានទតឃើញអំពើសាហាវព្រៃផ្សៃដែលសាសន៍ដទៃ បានប្រព្រឹត្តចំពោះពួកអ៊ីស្រាអែលប៉ុណ្ណោះទេ តែព្រះអង្គថែមទាំងមានផែនការរំដោះពួកគេផងដែរ។ គឺដូចដែលព្រះអង្គប្រកាសថា «អញបានចុះមក ដើម្បីនឹងជួយដោះគេឲ្យរួចចេញពីកណ្តាប់ដៃនៃពួកសាសន៍អេស៊ីព្ទ អញនឹងនាំគេឡើងចេញពីស្រុកនោះ ទៅឯស្រុកយ៉ាងល្អដ៏ធំទូលាយជាស្រុកដែលមានទឹកដោះ និងទឹកឃ្មុំហូរហៀរវិញ» (ខ.៨)។ ព្រះអង្គសព្វព្រះទ័យនឹងប្រើលោក ម៉ូសេ ឲ្យចេញទៅប្រកាសអំពីសេរីភាពដល់ប្រជាជនអ៊ីស្រាអែល។ គឺដូចដែលព្រះអង្គបានបង្គាប់គាត់ថា «អញនឹងចាត់ឯងឲ្យទៅផារ៉ោន ដើម្បីឲ្យឯងបាននាំរាស្ត្រអញ គឺជាពួកកូនចៅអ៊ីស្រាអែលចេញពីស្រុកអេស៊ីព្ទមក» (ខ.១០)។

ថ្ងៃណាមួយព្រះអង្គនឹងរំដោះយើង ឲ្យរួចផុតពីចំណង និងភាពអយុត្តិធម៌ទាំងអស់ ទោះព្រះអង្គមិនបានសម្រេចផែនការឲ្យបានឆាប់រហ័ស តាមការរំពឹងគិតរបស់យើងក៏ដោយ។ ព្រះអង្គប្រទានក្តីសង្ឃឹម និងសេរីភាពដល់មនុស្សទាំងអស់ ដែលកំពុងស្ថិតក្រោមការសង្កត់សង្កិន។—Winn Collier

តើអ្នកបានឃើញព្រះអម្ចាស់ធ្វើការក្នុងជីវិតអ្នកដែលគេសង្កត់សង្កិន ដើម្បីជួយពួកគេដូចម្តេចខ្លះ? តើព្រះអង្គបានអញ្ជើញអ្នក ឲ្យចូលរួមក្នុងព្រះរាជកិច្ចរបស់ព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ លោកីយ៍នេះមានពេញទៅដោយការសង្កត់សង្កិន។ មនុស្សងាយនឹងធ្លាក់ចូលក្នុងភាពអស់សង្ឃឹម។ សូមព្រះអង្គជួយទូលបង្គំឲ្យនៅតែជឿជាក់ មកលើបំណងព្រះទ័យរបស់ព្រះអង្គក្នុងការប្រទានសេរីភាពដល់មនុស្សទាំងអស់។

គម្រោងអានព្រះគម្ពីរយ:ពេល១ឆ្នាំ | នេហេមា ១២-១៣ និងកិច្ចការ ៤:២៣-២៧

ឯសេចក្តីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ សេចក្តីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច សេចក្តីស្មោះត្រង់របស់ទ្រង់ធំណាស់ (បរិទេវ ៣:២២-២៣)។

ព្រះអង្គនៅតែមានសេចក្តីស្រឡាញ់ចំពោះយើង

អ្នកស្រី ស៊ូសិន (Susan) មិនបានទិញរបស់អ្វីមួយសម្រាប់ខ្លួនឯងទេ ក្រៅពីរបស់របរដែលចាំបាច់សម្រាប់គ្រួសារ។ គាត់បានអនុវត្តដូចនេះអស់រយៈពេល៣ឆ្នាំ។ ការរីករាលដាលនៃជំងឺកូវីត១៩ មានផលប៉ះពាល់មកលើប្រាក់ចំណូលរបស់មិត្តភក្តិខ្ញុំម្នាក់នេះ ហើយគាត់ក៏បានឱបក្រសោបយកការរស់នៅដ៏សាមញ្ញ។ គាត់បានចែកចាយថា ថ្ងៃមួយ នៅពេលដែលគាត់កំពុងបោសសំអាតផ្ទះរបស់គាត់ គាត់ក៏បានកត់សម្គាល់ឃើញថា របស់របរប្រើប្រាស់នៅក្នុងផ្ទះគាត់ មានភាពចាស់រឹការិល និងស្លេកពណ៌អស់។ គឺនៅពេលនោះហើយ គាត់ក៏បានចាប់ផ្តើមនឹកដល់ពេលដែលគាត់ទិញរបស់របរថ្មីៗដាក់ក្នុងផ្ទះ ដែលនាំឲ្យមានចិត្តស្រស់ស្រាយ និងរំភើបរីករាយ។ អ្វីៗនៅជុំវិញខ្លួនគាត់ ហាក់ដូចជាមានភាពហាត់នឿយ និងចាស់រឹការិល។ ពេលនោះ គាត់ហាក់ដូចជាលែងមានសេចក្តីសង្ឃឹមថា ការល្អនឹងកើតមាននៅពេលអនាគតទៀតទេ។

អ្នកស្រី ស៊ូសិន ក៏បានរកឃើញការកម្សាន្តចិត្តក្នុងកណ្តាគម្ពីរ ដែលហោរាយេរេមាបាននិពន្ធ បន្ទាប់ពីទីក្រុងយេរូសាឡិមបានដួលរលំ ដោយសារកងទ័ពបាប៊ីឡូន។ កណ្តាគម្ពីរបរិទេវបានពិពណ៌នាអំពីរបួសនៃការសោកសង្រេងដែលលោកហោរា និងប្រជាជនគាត់កំពុងឆ្លងកាត់។ ទោះជាយ៉ាងណាក៏ដោយ ក្នុងពេលនៃការសោកសង្រេងនោះ ក្តីសង្ឃឹមក៏បានកើតមាន ដោយសារសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់។ បានជាហោរា យេរេមាពោលថា «សេចក្តីមេត្តាករុណារបស់ទ្រង់ នោះមិនចេះផុតឡើយ សេចក្តីទាំងនោះ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច» (៣:២២-២៣)។

អ្នកស្រី ស៊ូសិន បាននឹកចាំថា សេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់ព្រះអម្ចាស់ ចេះតែថ្មីឡើងរាល់តែព្រឹកជានិច្ច។ ពេលណាកាលៈទេសៈរបស់យើង ធ្វើឲ្យយើងលែងមានសង្ឃឹមថា ការល្អនឹងកើតមាននៅពេលអនាគត ចូរយើងនឹកចាំអំពីសេចក្តីស្មោះត្រង់របស់ព្រះអង្គ ហើយទុកចិត្តលើការផ្គត់ផ្គង់របស់ព្រះអង្គ។ យើងអាចមានក្តីសង្ឃឹមនៅក្នុងព្រះអង្គ ដោយទំនុកចិត្ត ដោយដឹងថា ក្តីសង្ឃឹមរបស់យើងនឹងមិនប្រែជាការខកចិត្តឡើយ (ខ.២៤-២៥) ព្រោះក្តីសង្ឃឹមរបស់យើង បានជាប់នៅក្នុងសេចក្តីស្រឡាញ់ និងសេចក្តីអាណិតដ៏ស្ថិតស្ថេររបស់ព្រះអង្គ។

អ្នកស្រី ស៊ូសិន ក៏បានពោលថា សេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ តែងតែថ្មីសម្រាប់គាត់ជារៀងរាល់ថ្ងៃ។ គាត់អាចមើលទៅមុខ ដោយសេចក្តីសង្ឃឹម។—Karen Huang

តើអ្នកមានអារម្មណ៍ថា អស់សង្ឃឹមក្នុងស្ថានភាពរបស់អ្នកនៅពេលណាខ្លះ? តើព្រះបន្ទូលសន្យាអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ដែលចេះតែថ្មីជានិច្ច បានផ្តល់ឲ្យអ្នកនូវក្តីសង្ឃឹមដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដ្បិតសេចក្តីស្រឡាញ់របស់ព្រះអង្គ តែងតែស្ថិតស្ថេរជារៀងរាល់ថ្ងៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | នាងអេសធើរ ១-២ និងកិច្ចការ ៥:១-២១

អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ ចូរមកឯខ្ញុំ ខ្ញុំនឹងឲ្យអ្នករាល់គ្នាឈប់សំរាក (ម៉ាថាយ ១១:២៨)។

រកឃើញការសម្រាកក្នុងព្រះយេស៊ូវ

វិញ្ញាណដែលនឿយព្រួយ មិនដែលស្កប់ចិត្តនឹងទ្រព្យសម្បត្តិ និងភាពជោគជ័យឡើយ។ ជីវិតរបស់តារាចម្រៀងជនបទដ៏ល្បីល្បាញម្នាក់បានបង្ហាញឲ្យយើងដឹងថា នេះជាការពិតមែន។ បទចម្រៀងរបស់គាត់ជិត៤០អាល់ប៊ុម បានជាប់ចំណាត់ថ្នាក់ នៅក្នុងចំណោមកំពូលបទចម្រៀងជនបទទាំង១០ ដែលពេញនិយមបំផុត។ ប៉ុន្តែ គាត់បានរៀបការជាច្រើនលើក ហើយធ្លាប់ជាប់គុកផងដែរ។ ទោះគាត់សម្រេចបានជោគជ័យច្រើនប៉ុណ្ណាក៏ដោយ ក៏គាត់ធ្លាប់ពោលទំនួញថា "វិញ្ញាណរបស់ខ្ញុំ មានភាពនឿយព្រួយ ដែលខ្ញុំមិនអាចជម្នះបានដោយភាពល្បីល្បាញ ការរៀបការជាមួយអ្នកថ្មី ឬការស្វែងរកអត្ថន័យជីវិត... វានៅតែមានភាពហត់នឿយនោះគឺមានរហូតដល់ថ្ងៃដែលខ្ញុំស្លាប់"។ គួរឲ្យស្តាយណាស់ គាត់គួរតែបានរកឃើញការសម្រាកសម្រាប់វិញ្ញាណគាត់ មុនពេលជីវិតគាត់បញ្ចប់។

ព្រះយេស៊ូវបានធ្វើការអញ្ជើញដល់មនុស្សទាំងអស់ ឲ្យចូលមករកព្រះអង្គផ្ទាល់ៗខ្លួន (ម៉ាថាយ ១១:២៨) គឺមនុស្សដែលមានភាពនឿយព្រួយ ដោយសារបន្ទុកនៃអំពើបាប និងផលវិបាករបស់វា មិនខុសពីតារាចម្រៀងរូបនេះឡើយ។ ពេលណាយើងទទួលសេចក្តីសង្គ្រោះក្នុងព្រះយេស៊ូវ ព្រះអង្គនឹងដកបន្ទុកចេញពីយើង ហើយប្រទានយើងនូវការសម្រាក។ អ្វីដែលយើងត្រូវធ្វើនោះគឺ ត្រូវជឿព្រះអង្គ ហើយរៀនសូត្រពីព្រះអង្គអំពីរបៀបរស់នៅក្នុងជីវិតពេញបរិបូរ ដែលព្រះអង្គបានប្រទាន (យ៉ូហាន ១០:១០)។ ការទទួលយកនឹមនៃភាពជាសិស្សរបស់ព្រះគ្រីស្ទ នាំឲ្យយើងរកឃើញការសម្រាកសម្រាប់វិញ្ញាណយើង (ម៉ាថាយ ១១:២៩)។

ពេលយើងចូលទៅរកព្រះយេស៊ូវ ព្រះអង្គមិនបានកាត់បន្ថយការទទួលខុសត្រូវ ដែលយើងត្រូវមានចំពោះព្រះអង្គនោះឡើយ។ ព្រះអង្គប្រទានសន្តិភាព ដល់វិញ្ញាណដ៏ហត់នឿយរបស់យើង ដោយប្រទានយើងនូវរបៀបរស់នៅក្នុងព្រះអង្គ ដោយបន្ទុកដែលថ្មី និងស្រាលជាងមុន។ និយាយរួម ព្រះអង្គប្រទានយើងនូវការសម្រាកដ៏ពិត។—Marvin Williams

តើអ្នកមានអារម្មណ៍នឿយព្រួយ និងមានបន្ទុកធ្ងន់ដូចម្តេចខ្លះ ក្នុងពេលឥឡូវនេះ? តើអ្នកមានអារម្មណ៍យ៉ាងណា ពេលបានទទួលការសម្រាក ដែលព្រះយេស៊ូវសន្យាប្រទាន?

ឱព្រះយេស៊ូវ សូមព្រះអង្គប្រទានព្រះពរ ដល់វិញ្ញាណដ៏ហត់នឿយរបស់ទូលបង្គំ ឲ្យរកឃើញសន្តិភាព និងការសម្រាកក្នុងព្រះអង្គ តែមួយប៉ុណ្ណោះ។

Daily Manna 2026_Content Enhance.indd 178 17/11/25 1:45 in the afternoon

ត្រូវដំឡើងពោធនុបោសថតាមគំរូដែលបានបង្ហាញឲ្យឯងឃើញនៅលើភ្នំ (និក្ខមនំ ២៦:៣០)។

អគារសម្រាប់ថ្វាយបង្គំព្រះ

នៅពេលដែលអគាររដ្ឋសភារបស់ចក្រភពអង់គ្លេស ទទួលរងការបំផ្លិចបំផ្លាញដោយសារការទម្លាក់គ្រាប់បែក ក្នុងសម័យសង្គ្រាមលោកលើកទី២ លោក វីនស្តិន ឈើឈីល (Winston Churchill) ជានាយករដ្ឋមន្ត្រី បានប្រាប់រដ្ឋសភាថា ពួកគេត្រូវសាងសង់អគាររដ្ឋសភា ឲ្យមានរូបរាងដូចដើមវិញ។ អគារនោះត្រូវមានទំហំតូច ដើម្បីឲ្យការជជែកវែកញែកតទល់នៅតែអាចបន្តមាន។ វាត្រូវមានរាងមូលទ្រវែង ជាជាងមានរៀងពាក់កណ្តាលរង្វង់ ដោយអនុញ្ញាតឲ្យអ្នកនយោបាយឡើងទៅនិយាយនៅត្រង់ចំណុចកណ្តាល។ ការរៀបចំនេះបានថែរក្សាប្រព័ន្ធគណបក្សរបស់ចក្រភពអង់គ្លេសឲ្យស្ថិតស្ថេរ ដែលក្នុងនោះសមាជិកគណបក្សឆ្វេងនិយម និងស្តាំនិយមអាចអង្គុយទល់មុខគ្នានៅក្នុងសាលប្រជុំ ដោយតម្រូវឲ្យមានការគិតយ៉ាងប្រុងប្រយ័ត្ន មុនពេលពួកគេសម្រេចចិត្តចុះចូលគណបក្សមួយទៀត។ លោក ឈើឈីល ក៏បានធ្វើការសន្និដ្ឋានថា «យើងសាងសង់អគាររបស់យើង ហើយក្រោយមក អគាររបស់យើងមានឥទ្ធិពលមកលើអាកប្បកិរិយា ទម្លាប់ និងវប្បធម៌របស់យើង»។

ព្រះអម្ចាស់ហាក់ដូចជាយល់ស្របចំពោះទស្សនៈនេះ។ កណ្ឌគម្ពីរនិក្ខមនំមាន៨ជំពូក (ជំពូក ២៤-៣១) ដែលបានចែងអំពីការបង្គាប់របស់ព្រះអង្គអំពីរបៀបសាងសង់ឆាងឧបោសថ ហើយមាន៦ជំពូកទៀត (ជំពូក ៣៥-៤០) ដែលពិពណ៌នាអំពីរបៀបដែលពួកអ៊ីស្រាអែលបានធ្វើតាមបង្គាប់របស់ព្រះអង្គ។ ព្រះអង្គយកព្រះទ័យទុកដាក់ ចំពោះការថ្វាយបង្គំរបស់ពួកគេ។ នៅពេលដែលពួកបណ្តាជនដើរចូលក្នុងបរិវេណនៃឆាងឧបោសថ ភាពចាំងចែងនៃមាស និងពណ៌ដ៏ស្រស់ស្អាតនៃវាំងននរបស់ឆាងឧបោសថ (២៦:១, ៣១-៣៧) បានធ្វើឲ្យពួកគេមានចិត្តស្ងប់ស្ងែងយ៉ាងខ្លាំង។ អាសនាសម្រាប់ដុតយញ្ញបូជា (២៧:១-៨) និងចានក្លាំសម្រាប់ដាក់ទឹកលាងសម្អាត (៣០:១៧-២១) បានរំឭកពួកគេអំពីការលះបង់ ដើម្បីអត់ទោសឲ្យបាបរបស់ពួកគេ។ ខាងក្នុងឆាងឧបោសថ មានជើងចង្កៀង (២៥:៣១-៤០) តុដាក់នំបុ័ង (២៥:២៣-៣០) អាសនាសម្រាប់ដុតគ្រឿងក្រអូប (៣០:១-៦) និងហិបសញ្ញា (២៥:១០-២២)។ វត្ថុនីមួយៗសុទ្ធតែមានសារៈសំខាន់យ៉ាងខ្លាំង។

នៅគ្រាសញ្ញាថ្មី ព្រះអម្ចាស់មិនប្រទានការបង្គាប់ជាលម្អិតអំពីទីកន្លែងថ្វាយបង្គំ ដូចព្រះអង្គបង្គាប់ពួកអ៊ីស្រាអែលនៅគ្រាសញ្ញាចាស់ទេ តែមិនមានន័យថា ការថ្វាយបង្គំរបស់យើងមានសារៈសំខាន់តិចជាងការថ្វាយបង្គំរបស់ពួកគេនោះទេ។ រូបកាយរបស់យើងទាំងមូល គឺជាព្រះវិហារដែលត្រូវញែកជាបរិសុទ្ធ សម្រាប់ឲ្យព្រះអង្គចូលគង់សណ្ឋិត។ ចូរយើងថ្វាយរូបកាយទុកជាយញ្ញបូជារស់ ហើយបរិសុទ្ធ ដែលគាប់ព្រះហឫទ័យដល់ព្រះ ហើយប្រើរូបកាយយើងជាឧបករណ៍សម្រាប់ថ្វាយបង្គំ និងបម្រើព្រះអង្គ (រ៉ូម ១២:១)។ ចូរឲ្យអ្វីៗដែលយើងធ្វើបានរំឭកយើងថា ព្រះអង្គជានរណា ហើយព្រះអង្គធ្វើអ្វីខ្លះ។—Mike Wittmer

តើការថ្វាយបង្គំរបស់អ្នកបានបង្រៀនអ្នកអ្វីខ្លះអំពីព្រះ និងសេចក្តីស្រឡាញ់ដែលព្រះអង្គមានចំពោះអ្នក? តើអ្នកត្រូវមានការផ្លាស់ប្តូរអ្វីខ្លះ?

ឱព្រះវរបិតា ព្រះអង្គស័ក្តិសមនឹងការថ្វាយបង្គំល្អបំផុតរបស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយ:ពេល១ឆ្នាំ | នាងអេសធើរ ៦-៨ និងកិច្ចការ ៦

ចូរបង្គាប់ឲ្យគេធ្វើគុណ និងការល្អជាបរិបូរ ព្រមទាំងចែកទានដោយសទ្ធា ហើយប្រុងប្រៀបនឹងជួយគេផង (១ធីម៉ូថេ ៦:១៨)។

ជាអ្នកមានខាងឯការល្អ

អ្នកស្រី អូសេឡា មែកខាធី (Oseola McCarty) បានធ្វើការងារដ៏ហត់នឿយ ជាអ្នកបោកគក់សំលៀកបំពាក់ អស់៧ទសវត្សរ៍ ដែលមានការបោកគក់ និងការពូតខោអាវដោយដៃ។ នៅទីបំផុត គាត់ក៏បានត្រៀមខ្លួនជាស្រេច ដើម្បីចូលនិវត្តន៍ក្នុងអាយុ៨៦ឆ្នាំ។ គាត់បានសន្សំប្រាក់ចំណូលតិចតួចរបស់គាត់ ក្នុងរយៈពេលជាច្រើនឆ្នាំនោះ ហើយសហគមន៍របស់គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង នៅពេលដែលគាត់បានបរិច្ចាគលុយ ១៥ម៉ឺនដុល្លា ឲ្យសកលវិទ្យាល័យមួយនៅក្បែរផ្ទះគាត់ ដើម្បីបង្កើតមូលនិធិអាហារូបករណ៍សម្រាប់សិស្សក្រីក្រ។ មនុស្សរាប់រយនាក់មានការប៉ះពាល់ចិត្ត ចំពោះអំពើសប្បុរសធម៌របស់គាត់ដែលមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយក៏បានចូលរួមបរិច្ចាគប្រាក់ជាមួយគាត់ ដែលធ្វើឲ្យមូលនិធិអាហារូបករណ៍នោះ មានចំនួនកើនឡើងច្រើនជាងមុន៣ដង។

អ្នកស្រី អូសេឡា បានយល់ឃើញថា តម្លៃពិតប្រាកដនៃទ្រព្យសម្បត្តិរបស់គាត់ មិនស្ថិតនៅត្រង់ការប្រើប្រាស់វា ដើម្បីប្រយោជន៍ផ្ទាល់ខ្លួននោះទេ តែដើម្បីធ្វើជាព្រះពរសម្រាប់អ្នកដទៃ។ សាវ័ក ប៉ុល បានបង្រៀនលោក ធីម៉ូថេ ឲ្យបង្គាប់ដល់អ្នកមានក្នុងលោកីយ៍នេះ ឲ្យធ្វើការល្អ ឲ្យបានច្រើនជាបរិបូរ (១ធីម៉ូថេ ៦:១៨)។ យើងម្នាក់ៗទទួលបានទ្រព្យសម្បត្តិតិចឬច្រើន ជាបញ្ញើពីព្រះអម្ចាស់ ទោះជាលុយកាក់ ឬជាធនធានដទៃទៀតក៏ដោយ។ សាវ័ក ប៉ុល បានដាស់តឿនយើងឲ្យទុកចិត្តព្រះ ជាជាងទុកចិត្តលើធនធានរបស់យើង (ខ.១៧) ហើយសន្សំទ្រព្យនៅស្ថានសួគ៌ ដោយធ្វើការល្អ និងចែករំលែក (ខ.១៨)។

ក្នុងការបង្រៀនរបស់ព្រះអម្ចាស់អំពីទ្រព្យសម្បត្តិ ការរស់នៅដោយភាពកំណាញ់ និងគ្មានចិត្តសប្បុរស នឹងនាំឲ្យយើងមានអារម្មណ៍ថាខ្វះខាត និងមិនចេះស្កប់ស្កល់។ ការចែករំលែកដល់អ្នកដទៃ ដោយសេចក្តីស្រឡាញ់គឺជាផ្លូវឆ្ពោះទៅរកភាពពេញលេញ។ ការមានចិត្តកោតខ្លាច និងស្កប់ស្កល់ចំពោះអ្វីដែលយើងមាន ជាជាងផ្តោតទៅលើការស្វែងរកបន្ថែម គឺជាកំរៃយ៉ាងធំ (ខ.៦)។ តើយើងមានចិត្តសប្បុរសដូចម្តេចខ្លះ ក្នុងការចែករំលែកធនធានរបស់យើង ដូចអ្នកស្រី អូសេឡា? ចូរយើងព្យាយាមធ្វើជាអ្នកមានខាងឯការប្រព្រឹត្តល្អនៅថ្ងៃនេះ តាមការដឹកនាំរបស់ព្រះ។—Karen Pimpo

តើថ្ងៃនេះ អ្នកមានឱកាសបង្ហាញសេចក្តីសប្បុរស នៅពេលណាខ្លះ? តើការចែករំលែកអ្វីដែលអ្នកមាន នាំឲ្យអ្នកមានចិត្តស្កប់ស្កល់កាន់តែខ្លាំង ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានទូលបង្គំនូវធនធានសម្រាប់ការរស់នៅ។ ទូលបង្គំសូមថ្វាយធនធានទាំងនោះដាច់ដល់ព្រះអង្គនៅថ្ងៃនេះ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | នាងអេសធើរ ៩-១០ និងកិច្ចការ ៧:១-២១

កុំខ្លាចអី ដ្បិតព្រះទ្រង់បានយាងមកប្រយោជន៍តែនឹងល្បងអ្នករាល់គ្នាទេ ហើយឲ្យអ្នករាល់គ្នាបានកោតខ្លាចដល់ទ្រង់ (និក្ខមនំ ២០:២០)។

ការភ័យខ្លាចដ៏ត្រឹមត្រូវ

មនុស្សជាច្រើនមានការភ័យខ្លាចមិនសមហេតុផល ចំពោះអ្វីមួយ ឬស្ថានភាពអ្វីមួយរៀងៗខ្លួន។ អ្នកខ្លះខ្លាចសត្វពីងពាង (ទោះអ្នកខ្លះបានប្រកែកថា ការខ្លាចសត្វពីងពាងជារឿងធម្មតាក៏ដោយ)។ អ្នកខ្លះទៀតខ្លាចប៉ែងប៉ោង ហើយអ្នកផ្សេងទៀតខ្លាចស្ករសូកូឡា។ ការភ័យខ្លាចទាំងនេះ ស្ថិតក្នុងចំណោមការភ័យខ្លាចប្លែកៗជាង៤០០ ដែលពិតជាមានមែន និងត្រូវបានគេធ្វើការសិក្សា និងកត់ត្រាទុកក្នុងឯកសារ។ និយាយរួម មនុស្សយើងហាក់ដូចជាអាចមានការភ័យខ្លាច ចំពោះរឿងភាគច្រើន ដែលកើតមានក្នុងពិភពលោក។

ពួកអ៊ីស្រាអែលក៏មានការភ័យខ្លាច បន្ទាប់ពីពួកគេបានទទួលក្រឹត្យវិន័យ១០ប្រការ គឺដូចមានសេចក្តីចែងថា «កាលបណ្តាជនទាំងអស់គ្នាបានឮផ្គរលាន់ និងសូរផ្លុំស្នែង ហើយឃើញផ្លេកបន្ទោរ និងភ្នំហុយផ្សែងឡើងដូច្នេះ នោះស្រាប់តែគេញ័ររន្ធត់ ហើយក៏ថយទៅឈរនៅទីឆ្ងាយវិញ» (និក្ខមនំ ២០:១៨)។ លោក ម៉ូសេ ក៏បានកម្សាន្តចិត្តពួកគេ ដោយមានប្រសាសន៍គួរឲ្យចាប់អារម្មណ៍បំផុតថា «កុំខ្លាចអី ដ្បិតព្រះទ្រង់បានយាងមកប្រយោជន៍តែនឹងល្បងអ្នករាល់គ្នាទេ ហើយឲ្យអ្នករាល់គ្នាបានកោតខ្លាចដល់ទ្រង់ ដើម្បីកុំឲ្យអ្នករាល់គ្នាធ្វើអំពើបាបឡើយ» (ខ.២០)។ ត្រង់ចំណុចនេះ លោក ម៉ូសេ មិនបាននិយាយជាន់កែងខ្លួនឯងទេ នៅពេលដែលគាត់ប្រាប់គេកុំឲ្យមានការភ័យខ្លាច តែគាត់ក៏បានប្រាប់គេឲ្យកោតខ្លាចដល់ព្រះវិញ។ តាមពិត ក្នុងព្រះគម្ពីរដើមភាសាហេព្រើរ ពាក្យ «ខ្លាច» យ៉ាងហោចណាស់មានន័យពីរ គឺការភ័យញ័រចំពោះអ្វីមួយ ឬការកោតខ្លាច ដោយការគោរពចំពោះព្រះ។

យើងប្រហែលអស់សំណើច ពេលដែលបានដឹងថា មានអ្នកខ្លះខ្លាចប៉ែងប៉ោង ឬស្ករសូកូឡា ឬក៏អ្វីមួយដែលមិនគួរឲ្យខ្លាចចំពោះយើង។ ប៉ុន្តែ ការភ័យខ្លាចប្រភេទនេះ មានផ្នែកដែលសំខាន់ជាង និងស៊ីជម្រៅជាងនៅក្នុងការពិតដែលថា មនុស្សយើងអាចមានការភ័យខ្លាចចំពោះអ្វីៗគ្រប់យ៉ាង។ ការភ័យខ្លាចលួចចូលទៅក្នុងជីវិតយើងស្ងាត់ៗ ដូចជាសត្វពីងពាងវាចូលក្នុងផ្ទះយើង ហើយលោកីយ៍អាចជាកន្លែងដែលគួរឲ្យខ្លាច។ ខណៈពេលដែលយើងព្យាយាមជម្នះការភ័យខ្លាចដែលមិនសមហេតុផល ឬការភ័យខ្លាចដែលមានហេតុផល ចូរយើងនឹកចាំថា ព្រះនៃយើងជាព្រះដែលយើងត្រូវកោតខ្លាច ដោយព្រះអង្គបានប្រទានយើង នូវព្រះវត្តមាននៃការកម្សាន្តចិត្ត ក្នុងពេលដែលយើងស្ថិតក្នុងភាពងងឹត។ —Kenneth Petersen

តើអ្នកខ្លាចអ្វីខ្លះ ក្នុងជីវិតអ្នក? តើសេចក្តីស្រឡាញ់របស់ព្រះ បានជួយអ្នកជម្នះការភ័យខ្លាចទាំងនោះដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំមានការភ័យខ្លាច ចំពោះរឿងជាច្រើន។ សូមព្រះអង្គកម្សាន្តចិត្តទូលបង្គំ ហើយជួយទូលបង្គំឲ្យសម្រាកក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 181 17/11/25 1:45 in the afternoon

នោះខ្ញុំមិនដែលលែងអរព្រះគុណ ដោយព្រោះអ្នកពាល់គ្នាឡើយ គឺខ្ញុំតែងដំណាលពីអ្នកពាល់គ្នា ក្នុងសេចក្តីអធិស្ឋានរបស់ខ្ញុំវិញ (អេភេសូរ ១:១៦)។

អ្នកខ្លាំងពូកែខាងការអធិស្ឋាន

លោក ជន (Jørn) ជាកសិករ ដែលជួលដីស្រែរបស់គេ ដើម្បីធ្វើស្រែ។ គេមិនគិតថា គាត់នឹងទទួលបានផលចំណេញច្រើននោះទេ។ តែទោះគាត់មានភ្នែកខ្សោយ និងកាយសម្បទាមិនគ្រប់គ្រាន់ក៏ដោយ គាត់បានធ្វើការលះបង់ ដើម្បីអ្នកភូមិរបស់គាត់ក្នុងប្រទេសនរវេយ ដោយអធិស្ឋានឲ្យពួកគេអស់ជាច្រើនយប់ នៅពេលណាការឈឺចាប់ក្នុងខ្លួនគាត់ ធ្វើឲ្យគាត់មិនអាចគេងលក់។ ក្នុងការអធិស្ឋាននោះ គាត់បានអធិស្ឋានឲ្យពួកគេ ម្តងមួយគ្រួសារ ដោយបញ្ចេញឈ្មោះរបស់ពួកគេម្នាក់ៗ និងថែមទាំងបានអធិស្ឋានឲ្យក្មេងៗដែលគាត់មិនទាន់បានជួបផងដែរ។ អ្នកភូមិស្រឡាញ់វិញ្ញាណដ៏សុភាពរបស់គាត់ ហើយក៏បានទៅសុំយោបល់ និងការណែនាំប្រកបដោយប្រាជ្ញាពីគាត់។ បើសិនជាគាត់មិនអាចជួយពួកគេ តាមរបៀបជាក់ស្តែងណាមួយ ពួកគេនៅតែមានអារម្មណ៍ថា ព្រះអម្ចាស់បានប្រទានពរពួកគេ តាមរយៈសេចក្តីស្រឡាញ់ដែលគាត់បានបង្ហាញដល់ពួកគេ ដោយបានទទួលសេចក្តីស្រឡាញ់ពីគាត់។ នៅពេលដែលលោក ជន ទទួលមរណៈភាព គេបានធ្វើពិធីបុណ្យសពធំជាងគេសម្រាប់គាត់ នៅក្នុងសហគមន៍របស់ពួកគេ ទោះគាត់មិនមានសាច់ញាតិនៅក្នុងភូមិនោះក៏ដោយ។ ការអធិស្ឋានរបស់គាត់ បានបង្កើតផលផ្លែជាច្រើនហួសក្តីស្រមៃរបស់គាត់។

បុរសដែលបានបន្ទាបខ្លួននេះ បានយកគំរូតាមសាវ័ក ប៉ុល ដែលបានស្រឡាញ់មនុស្សដែលគាត់បានបម្រើ និងអធិស្ឋានឲ្យពួកគេ កាលគាត់កំពុងជាប់ឃុំក្នុងគុក។ គាត់បានសរសេរសំបុត្រទៅពួកជំនុំនៅទីក្រុងអេភេសូរ កាលគាត់កំពុងជាប់គុក នៅទីក្រុងរ៉ូម ដោយអធិស្ឋានសូមព្រះអម្ចាស់ប្រទានពួកគេនូវ «ព្រះវិញ្ញាណដែលប្រោសឲ្យមានប្រាជ្ញា ហើយក៏បើកសំដែង ឲ្យដឹងពីដំណើរស្គាល់ទ្រង់» និងសូមឲ្យភ្នែកនៃចិត្តរបស់ពួកគេ «បានភ្លឺឡើង» (អេភេសូរ ១:១៧-១៨)។ គាត់ពិតជាចង់ឲ្យពួកគេស្គាល់ព្រះយេស៊ូវច្បាស់ ហើយរស់នៅ ដោយសេចក្តីស្រឡាញ់ និងការរួបរួម តាមរយៈអំណាចនៃព្រះវិញ្ញាណ។

លោក ជន និងសាវ័ក ប៉ុល មានការប្តូរផ្តាច់ទាំងស្រុង ចំពោះព្រះអម្ចាស់ ដោយបានអធិស្ឋានឲ្យមនុស្សដែលពួកគេស្រឡាញ់ និងបម្រើ។ ចូរយើងរៀនសូត្រពីគំរូរបស់ពួកគេ ហើយយកតម្រាប់តាមក្នុងការស្រឡាញ់ និងប្រើអ្នកដទៃនៅថ្ងៃនេះ។—Amy Boucher Pye

តើអ្នកបានស្គាល់នរណាខ្លះ ជាមនុស្សខ្លាំងពូកែខាងការអធិស្ឋាន ដោយចិត្តសុភាព? តើគំរូរបស់គាត់បានឆ្លុះបញ្ចាំង ឲ្យគេបានស្គាល់ព្រះទ័យរបស់ព្រះគ្រីស្ទ ដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ព្រះអង្គបម្រើអ្នកដទៃ និងបំពេញតម្រូវការរបស់ពួកគេ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យស្រឡាញ់ និងបម្រើព្រះអង្គ ដោយក្តីអំណរ ជារៀងរាល់ថ្ងៃ។

Daily Manna 2026_Content Enhance.indd 182 17/11/25 1:45 in the afternoon

គេបានប្រាប់ដល់ខ្ញុំ ពីគ្រប់ទាំងកិរិយា ដែលនាងបានប្រព្រឹត្តនឹងម្តាយក្មេក តាំងពីប្តីនាងស្លាប់ចោលទៅ (នាងរស់ ២:១១)។

រៀនសូត្រពីគ្នាទៅវិញទៅមក

ឆ្នាំ:ពេលប៉ុន្មានឆ្នាំ មុនពេលកម្មវិធីហ្សឹម (Zoom) ត្រូវបានគេយកមកប្រើក្នុងការជួបជុំជាក្រុមពីចម្ងាយ តាមបណ្តាញអ៊ីនធឺណិត មិត្តភក្តិខ្ញុំម្នាក់បានអញ្ជើញខ្ញុំ ឲ្យចូលរួមជាមួយគាត់ក្នុងការជួបគ្នាតាមអនឡាញមើលមុខគ្នាឃើញ ដើម្បីពិភាក្សាគ្នាអំពីកម្មវិធីមួយ។ តាមរយៈភាពតានតឹងដែលខ្ញុំបានបង្ហាញក្នុងអ៊ីមែល ដែលខ្ញុំបានផ្ញើទៅគាត់ គាត់អាចមើលដឹងថា ខ្ញុំមិនទាន់យល់អំពីរបៀបចូលរួមជាមួយគាត់ ដូចនេះគាត់ក៏បានណែនាំខ្ញុំ ឲ្យស្វែងរកក្មេងជំទង់ម្នាក់ ជួយពន្យល់ខ្ញុំអំពីរបៀបចូលរួមក្នុងការជួបគ្នាតាមអនឡាញមើលមុខគ្នាឃើញ។

ការណែនាំរបស់គាត់ បានចង្អុលបង្ហាញអំពីតម្លៃនៃទំនាក់ទំនងរវាងមនុស្ស ស្ថិតក្នុងជំនាន់ផ្សេងគ្នា។ រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីទំនាក់ទំនងរវាងនាង រស់ និងនាង ណាអូមី។ គេច្រើនតែសរសើរនាង រស់ ដោយសារគាត់ជាកូនប្រសារស្រី ដែលមានចិត្តស្មោះត្រង់ ដែលបានសម្រេចចិត្តមិនវិលត្រឡប់ទៅស្រុកកំណើត ដើម្បីរួមដំណើរជាមួយនាង ណាអូមី ជាម្តាយក្មេកទៅភូមិបេថ្លេហិម (នាងរស់ ១:១៦-១៧)។ នៅពេលដែលពួកគេទៅដល់ភូមិនោះ នាង រស់ ក៏បានប្រាប់នាង ណាអូមីថា «ឥឡូវនេះ សូមបើកឲ្យខ្ញុំទៅឯស្រែ ដើម្បីនឹងរើសសន្សំស្រូវ តាមអ្នកណាដែលអាណិតមេត្តាដល់ខ្ញុំ» (២:២)។ នាងបានជួយស្ត្រីចំណាសម្នាក់នេះ ដែលក្រោយមកបានជួយនាងឲ្យបានរៀបការជាមួយលោក បូអូស ជាម្ចាស់ស្រែ។ ការណែនាំរបស់នាង ណាអូមី សម្រាប់នាង រស់ បានបណ្តាលចិត្តលោក បូអូស ឲ្យទិញទ្រព្យសម្បត្តិរបស់បងប្អូនសាច់ថ្លៃរបស់នាង ហើយក៏បានទទួលយកនាងជាភរិយា (៤:៩-១០)។

ការប្រឹក្សាយោបល់ប្រកបដោយប្រាជ្ញា ដែលអ្នកជំនាន់មុនផ្តល់ឲ្យអ្នកជំនាន់ក្រោយ មានសារៈសំខាន់ និងគួរឲ្យយើងគោរព។ ប៉ុន្តែ រឿងរបស់នាង រស់ និងនាង ណាអូមី បានរំឭកយើងថា ការប្រឹក្សាយោបល់ដែលមនុស្សវ័យក្មេងជាង ផ្តល់ឲ្យមនុស្សមានវ័យចាស់ជាង ក៏អាចមានតម្លៃដែរ។ យើងមានអ្វីៗជាច្រើនដែលត្រូវរៀនសូត្រពីមនុស្ស មានវ័យតិចជាងយើង ក៏ដូចជាពីមនុស្សដែលចាស់ជាងយើង។ ចូរយើងព្យាយាមបង្កើតទំនាក់ទំនងប្រកបដោយសេចក្តីស្រឡាញ់ និងភាពស្មោះត្រង់ជាមួយមនុស្សស្ថិតក្នុងជំនាន់ផ្សេងពីយើង។ ការនេះនឹងនាំមកនូវព្រះពរសម្រាប់យើង និងអ្នកដទៃ ហើយជួយយើងរៀនសូត្រអំពីអ្វីដែលយើងមិនទាន់បានដឹង។—Katara Patton

តើអ្នកបានរៀនសូត្រអ្វីខ្លះ ពីមនុស្សដែលមានវ័យក្មេងជាងអ្នក? តើអ្នកអាចឈោងទៅរកមនុស្សក្នុងជំនាន់ផ្សេងពីអ្នក ដូចម្តេចខ្លះ នៅថ្ងៃនេះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការប្រទានប្រាជ្ញា តាមរយៈមនុស្សជំនាន់ចាស់និងជំនាន់ថ្មី។ សូមព្រះអង្គបង្រៀនទូលបង្គំឲ្យយល់អំពីតម្លៃនៃការឲ្យយោបល់ទៅវិញទៅមក ពីមនុស្សក្នុងវ័យផ្សេងគ្នា។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យ៉ូប ៥-៧ និងកិច្ចការ ៨:១-២៥

តែឥឡូវនេះ គេសង្វាតចង់បានស្រុក១ដ៏ប្រសើរជាង គឺខាងស្ថានសួគ៌វិញ (ហេព្រើរ ១១:១៦)។

ការធ្វើដំណើរខាងវិញ្ញាណដ៏ពិបាក

ជារៀងរាល់ឆ្នាំ មានមនុស្សជាង២រយលាននាក់ មានជំនឿសាសនាផ្សេងគ្នា បានធ្វើធម្មយាត្រាទៅកាន់ទីសក្ការៈសំខាន់ៗរបស់សាសនាពួកគេ។ អស់រយៈពេលជាច្រើនជំនាន់មកហើយ ដែលមនុស្សជាច្រើនយល់ឃើញថា ការធ្វើធម្មយាត្រា គឺជាការធ្វើដំណើរទៅកាន់ទីសក្ការៈ ដើម្បីទទួលព្រះពរបែបណាមួយ។ ពួកគេខិតខំធ្វើយ៉ាងណាទៅឲ្យដល់ព្រះវិហារ ទីសក្ការបូជា ឬទីតាំងផ្សេងទៀត ដែលពួកគេអាចទទួលពរជ័យពីសាសនា ឬព្រះរបស់ពួកគេ។

ទោះជាយ៉ាងណាក៏ដោយ សម្រាប់គ្រីស្ទបរិស័ទជាជនជាតិឃែល នៅចក្រភពអង់គ្លេស ពួកគេបានធ្វើដំណើរទៅទទួលព្រះពរតាមរបៀបផ្សេងពីនេះ។ ពួកគេធ្វើដំណើរដោយគ្មានគោលដៅចូលទៅក្នុងព្រៃ ឬទីវាលដែលគ្មានមនុស្សនៅ ឬជិះទូកសាត់អណ្តែត តាមចរន្តទឹកសមុទ្រ ដោយគ្មានគោលដៅ ព្រោះពួកគេយល់ឃើញថា ការធ្វើដំណើរនោះ គឺជាការរៀនទុកចិត្ត ព្រោះក្នុងទឹកដីដែលពួកគេមិនស្គាល់។ បានសេចក្តីថា សម្រាប់ពួកគេ ព្រះពរមិនមែនជាអ្វីដែលពួកគេអាចរកបាននៅត្រង់គោលដៅនៃការធ្វើដំណើរ តែអាចរកបាននៅតាមផ្លូវដែលពួកគេធ្វើដំណើរ។

បទគម្ពីរហេព្រើរ ជំពូក១១ ជាបទគម្ពីរដ៏សំខាន់ ដែលជនជាតិឃែល បានយកមកប្រើ ក្នុងការធ្វើដំណើរនេះ។ ការរស់នៅក្នុងព្រះគ្រីស្ទ គឺជាការចាកចេញពីផ្លូវរបស់លោកីយ៍ ហើយជាការធ្វើដំណើរទៅកាន់ទីក្រុងរបស់ព្រះអម្ចាស់ (ខ.១៣-១៦) ដូចនេះពួកគេយល់ឃើញថា ពួកគេត្រូវទុកចិត្តថា ព្រះនឹងផ្គត់ផ្គង់ពួកគេ ក្នុងការធ្វើដំណើរដ៏ពិបាក តាមផ្លូវដែលពួកគេមិនស្គាល់ ដើម្បីឲ្យពួកគេកើតមានសេចក្តីជំនឿដ៏រឹងមាំ ដូចវីរបុរសនៃសេចក្តីជំនឿក្នុងសម័យដើម (ខ.១-១២)។

យើងមិនចាំបាច់ត្រូវធ្វើដំណើរខាងសាច់ឈាមចូលទៅក្នុងវាលរហោស្ថាន ឬសមុទ្រដើម្បីទទួលព្រះពរ ឬរៀនសូត្រអំពីជំនឿនោះទេ ប៉ុន្តែសម្រាប់អ្នកដែលទុកចិត្តព្រះយេស៊ូវ ការរស់នៅជាគ្រីស្ទបរិស័ទ គឺជាការធ្វើដំណើរខាងវិញ្ញាណឆ្ពោះទៅរកនគរស្ថានសួគ៌ ដែលត្រូវឆ្លងកាត់ព្រៃភ្នំ ភាពទាល់ច្រក និងវាលរហោស្ថានខាងវិញ្ញាណ។ ខណៈពេលដែលយើងកំពុងធ្វើដំណើរខាងវិញ្ញាណ ចូរយើងកុំខកខាន មិនបានទទួលព្រះពរក្នុងការដកពិសោធន៍ជាមួយនឹងការផ្គត់ផ្គង់របស់ព្រះ នៅតាមផ្លូវឡើយ។—Sheridan Voysey

តើអ្នកអាចបើកចំហចិត្តដូចម្តេចខ្លះនៅថ្ងៃនេះ ដើម្បីទទួលអំណោយរបស់ព្រះនៅតាមផ្លូវនៃជីវិត? តើអ្នកអាចរំឭកខ្លួនឯងដូចម្តេចខ្លះ ឲ្យនឹកចាំថា លោកីយ៍នេះមិនមែនជាផ្ទះពិតប្រាកដរបស់អ្នកទេ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការបង្ហាញឲ្យទូលបង្គំដឹងថា ទុក្ខលំបាកក្នុងជីវិត គឺជាឱកាស សម្រាប់ឲ្យសេចក្តីជំនឿរបស់ទូលបង្គំលូតលាស់កាន់តែស៊ីជម្រៅ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យ៉ូប ៨-១០ និងកិច្ចការ ៨:២៦-៤០

អញនឹងបើកផ្លូវទឹកឲ្យហូរនៅលើទីខ្ពស់ត្រងិល ហើយនឹងទឹកផុសនៅកណ្តាលច្រកភ្នំ (អេសាយ ៤១:១៨)។

មើលឃើញពេលអនាគត ដែលមានសង្ឃឹម

បន្ទាប់ពីបានទទួលរងការបំផ្លិចបំផ្លាញពីខ្យល់ព្យុះកាទ្រីណា កាលពីឆ្នាំ២០០៥ រដ្ឋញូអ័រលិន បានធ្វើការសាងសង់ឡើងវិញបន្តិចម្តងៗ។ ទីក្រុង ឡូវ៉ែរ ណាញ វ៉ែដ គឺជាតំបន់ដែលទទួលរងការវាយប្រហារខ្លាំងជាងគេ ដោយប្រជាជននៅទីនោះ នៅតែខ្វះខាតធនធានក្នុងកម្រិតមូលដ្ឋាន បន្ទាប់ពីគ្រោះធម្មជាតិនេះ បានកន្លងផុតទៅអស់ជាច្រើនឆ្នាំ។ លោក ប៊ឺនែល ខុលតុន (Burnell Cotlon) ក៏បានផ្តួចផ្តើមគំនិតនាំមកនូវការផ្លាស់ប្តូរ។ នៅខែវិច្ឆិកា ឆ្នាំ២០១៤ គាត់បានបើកហាងលក់គ្រឿងទេសទីមួយក្នុងទីក្រុងនោះ។ គាត់ថា នៅពេលដែលគាត់ទិញអគារ ដើម្បីបើកហាងនោះ គេគ្រប់គ្នាគិតស្មានថា គាត់ឆ្កួត ប៉ុន្តែភ្ញៀវទីមួយដែលចូលទិញគ្រឿងទេសនៅទីនោះបានស្រក់ទឹកភ្នែក ដោយសារខ្លួនមិនដែលនឹកស្មានថា តំបន់ដែលគាត់រស់នៅមានការចាប់ផ្តើមឡើងវិញទេ។ ម្តាយរបស់គាត់មានប្រសាសន៍ថា គាត់បានមើលឃើញអ្វី ដែលម្តាយគាត់មើលមិនឃើញ ម្តាយគាត់សប្បាយចិត្តណាស់ ដែលបានដឹងថា គាត់បានឆក់យកឱកាសនោះ។

ព្រះអម្ចាស់បានបើកសម្តែងឲ្យហោរា អេសាយ មើលឃើញពេលអនាគត ដែលមានសង្ឃឹម នៅចំពោះមុខនៃវិនាសកម្ម។ ដោយសារព្រះអង្គទតឃើញអ្នកក្រតោកយ៉ាកកំពុងស្វែងរកទឹកផឹក តែរកមិនបាន (អេសាយ ៤១:១៧) ព្រះអង្គបានសន្យាថា នឹងកែប្រែវាលរហោស្ថានឲ្យក្លាយជាកន្លែងមានទឹកហូរ និងមានទឹកផុសនៅលើដីស្ងួតហែង (ខ.១៨)។ នៅពេលដែលរាស្ត្ររបស់ព្រះអង្គបានស្គាល់ភាពសម្បូរសប្បាយ បន្ទាប់ពីមានការស្រេកឃ្លាន និងការស្រេកទឹក ពួកគេនឹងបានដឹងថា ព្រះហស្តរបស់ព្រះអង្គបានធ្វើការទាំងអស់នេះ (ខ.២០)។

ព្រះអង្គនៅតែជាអ្នកផ្តួចផ្តើមឲ្យមានការស្អាងឡើងវិញ ដែលនៅតែធ្វើការយ៉ាងសកម្ម ដើម្បីនាំមកនូវពេលអនាគត ដែលស្នាព្រះហស្តរបស់ព្រះអង្គ នឹងបានរួចពីចំណងនៃសេចក្តីពុករលួយ (រ៉ូម ៨:២១)។ ពេលណាយើងទុកចិត្តលើសេចក្តីល្អរបស់ព្រះអង្គ ព្រះអង្គនឹងជួយឲ្យយើងមើលឃើញសេចក្តីសង្ឃឹម ដែលអាចកើតមាននៅពេលអនាគត។—Monica La Rose

តើអ្នកបានមើលឃើញការចាប់ផ្តើមឡើងវិញ បន្ទាប់ពីមានវិនាសកម្មនៅពេលណា? តើអ្នកអាចរួមចំណែកអ្វីខ្លះ ក្នុងព្រះរាជកិច្ចនៃការស្អាងឡើងវិញរបស់ព្រះអម្ចាស់?

ឱព្រះនៃការស្អាងឡើងវិញ សូមព្រះអង្គជួយទូលបង្គំមើលឃើញក្តីសង្ឃឹមនៅក្នុងព្រះអង្គ និងក្នុងពេលអនាគតដែលព្រះអង្គកំពុងប្រទានមក។

Daily Manna 2026_Content Enhance.indd 185 17/11/25 1:45 in the afternoon

អ្នកស្លូនភ្ងាផង៑ព្រះយេហូវ៉ា នឹង៑នៅជិតទ្រង់ដោយសុខសាន្ត (ចោទិយកថា ៣៣:១២)។

អ្នកជាមនុស្សជាទីស្រឡាញ់

មានពេលមួយ ក្មេងស្រីឈ្មោះ អាលី (Allie) បានបង្ហាញភាពសោកសៅរបស់នាង ដោយយកបន្ទះឈើមួយសន្លឹក មកសរសេរពីលើ ហើយដាក់ព្យួរនៅក្នុងសួនច្បារសាធារណៈ ដោយខ្លឹមសារដូចនេះថា «និយាយដោយស្មោះត្រង់ ខ្ញុំពិបាកចិត្តណាស់។ គ្មាននរណាចង់ចំណាយពេលជាមួយខ្ញុំទេ ហើយខ្ញុំបានបាត់បង់មនុស្សតែម្នាក់គត់ ដែលយកចិត្តទុកដាក់ចំពោះខ្ញុំ។ ខ្ញុំយំជារៀងរាល់ថ្ងៃ»។

នៅពេលដែលមនុស្សម្នាក់បានប្រទះឃើញសំណេររបស់នាង អ្នកនោះក៏បានយកដីសមកដាក់នៅសួនច្បារ ហើយសុំឲ្យគេសរសេរពាក្យលើកទឹកចិត្តសម្រាប់ អាលី។ ពួកសិស្សដែលរៀននៅសាលាក្បែរនោះ ក៏បានសរសេរពាក្យលើកទឹកចិត្តរាប់សិបឃ្លា នៅលើបន្ទះឈើនោះថា «យើងស្រឡាញ់អ្នក» «ព្រះស្រឡាញ់អ្នក» «អ្នកជាមនុស្សជាទីស្រឡាញ់»។ នាយកសាលានោះ ក៏បានមានប្រសាសន៍ថា «នេះជាមធ្យោបាយតូចមួយ ដែលយើងអាចឈោងទៅរក ឬប្រហែលជាអាចបំពេញចន្លោះប្រហោងក្នុងចិត្តនាង។ នាងជាតំណាងឲ្យយើងទាំងអស់គ្នា ព្រោះយើងរាល់គ្នាសុទ្ធតែធ្លាប់ ឬយើងនឹងមានភាពសោកសៅ និងទុក្ខលំបាកនៅពេលណាមួយ»។

ឃ្លាដែលគេសរសេរថា «អ្នកជាមនុស្សជាទីស្រឡាញ់» បានធ្វើឲ្យខ្ញុំនឹកចាំថា មុនពេលលោក ម៉ូសេ លាចាកលោក គាត់បាននិយាយពាក្យជូនពរដ៏មានន័យ ទៅកាន់ពូជអំបូរបេនយ៉ាមីន នៃសាសន៍អ៊ីស្រាអែលថា «ឯចំណែកពួកបេនយ៉ាមីន នោះក៏ថា អ្នកស្លូនភ្ងាផងព្រះយេហូវ៉ា នឹងនៅជិតទ្រង់ដោយសុខសាន្ត ទ្រង់គ្របបាំងគេជានិច្ច ហើយគេនឹងនៅជាកណ្តាលព្រះអង្សាទាំង២របស់ទ្រង់» (ចោទិយកថា ៣៣:១២)។ លោក ម៉ូសេ ជាអ្នកដឹកនាំដ៏រឹងមាំ ដែលព្រះអម្ចាស់បានជ្រើសតាំង ដោយគាត់បានឈ្នះនគរដែលជាខ្មាំងសត្រូវ និងបានទទួលក្រឹត្យវិន័យដប់ប្រការ ហើយបានដំរុញពួកគេឲ្យដើរតាមព្រះអង្គ។ មុនពេលលាចាកលោក គាត់បានបង្ហាញឲ្យពួកគេដឹងថា ព្រះអម្ចាស់មានព្រះទ័យយ៉ាងណា ចំពោះពួកគេ។ ពាក្យ សួនភ្ងា ឬមនុស្សជាទីស្រឡាញ់ ក៏អាចប្រើសម្រាប់យើងផងដែរ គឺដូចដែលព្រះយេស៊ូវមានបន្ទូលថា «ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម៉្លេះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ» (យ៉ូហាន ៣:១៦)។

ខណៈពេលដែលព្រះអម្ចាស់ជួយយើង ឲ្យសម្រាកយ៉ាងសុខសាន្តក្នុងសេចក្តីពិតដែលថា អ្នកជឿព្រះយេស៊ូវម្នាក់ៗ សុទ្ធតែជា «កូនស្លូនភ្ងា» យើងអាចឈោងទៅរកអ្នកដទៃ ដោយសេចក្តីស្រឡាញ់ តាមគំរូរបស់អស់អ្នកដែលឈោងទៅរកអាលីផងដែរ។—Anne Cetas

តើអ្នកបានរៀនសម្រាកយ៉ាងសុខសាន្ត ក្នុងសេចក្តីស្រឡាញ់របស់ព្រះអម្ចាស់ដូចម្តេចខ្លះ? តើអ្នកអាចចែករំលែក សេចក្តីស្រឡាញ់នោះ ដល់អ្នកដទៃ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យទុកចិត្តលើសេចក្តីស្រឡាញ់របស់ព្រះអង្គ ហើយចែកចាយសេចក្តីស្រឡាញ់របស់ព្រះអង្គដល់មនុស្សជុំវិញទូលបង្គំ។

គម្រោងអានព្រះគម្ពីរ១ឆ្នាំ | យ៉ូប ១៤-១៦ និងកិច្ចការ ៩:២២-៤៣

នោះតើអំពល់អ្វីដល់អ្នក ចូរឲ្យអ្នកមកតាមខ្ញុំចុះ (យ៉ូហាន ២១:២២)។

តើអំពល់អ្វីដល់អ្នក?

មានពេលមួយក្មួយស្រីខ្ញុំអាយុ៦ឆ្នាំ បានសួរខ្ញុំថា ហេតុអ្វីគាត់ទទួលបានស្គរគ្រាប់មានរស់ជាតិសូប្រ៊ីតែបងប្អូនគាត់ទទួលបានស្គរគ្រាប់មានរសជាតិទំពាំងបាយជូរ? តាមរយៈអាកប្បកិរិយារបស់ក្មួយប្រុសក្មួយស្រីរបស់ខ្ញុំ ខ្ញុំរៀនសូត្របានថា ក្មេងៗច្រើនតែប្រៀបធៀបរបស់អ្វីដែលគាត់បានទទួល ជាមួយនឹងរបស់អ្វីដែលអ្នកដទៃបានទទួល។ បញ្ហានេះមានន័យថា ក្នុងនាមខ្ញុំជាម្តាយមីងដែលស្រឡាញ់ពួកគាត់ ខ្ញុំត្រូវធ្វើការសម្រេចចិត្តប្រកបដោយប្រាជ្ញា មុននឹងឲ្យអ្វីមួយដល់ពួកគេ។

ជួនកាល ខ្ញុំក៏បានប្រៀបធៀបរបស់អ្វីដែលព្រះប្រទានខ្ញុំ ជាមួយនឹងរបស់ដែលព្រះអង្គប្រទានអ្នកដទៃផងដែរ។ ខ្ញុំទូលសួរព្រះអង្គថា «ហេតុអ្វីទូលបង្គំបានរបស់នេះ តែនាងបានរបស់នោះអញ្ចឹង?» សំណួរនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីអ្វីដែលលោក ស៊ីម៉ូន ពេត្រុស បានសួរព្រះយេស៊ូវនៅសមុទ្រកាលីឡេ។ កាលនោះ ព្រះយេស៊ូវទើបតែបានប្រទានការស្អាងឡើងវិញ និងការអត់ទោសបាបដល់គាត់ បន្ទាប់ពីគាត់បានបដិសេធន៍ព្រះអង្គ ហើយព្រះអង្គក៏បានប្រាប់គាត់ថា គាត់នឹងបានថ្វាយសិរីល្អដល់ព្រះ ដោយការស្លាប់ ដោយសារសេចក្តីជំនឿ (យ៉ូហាន ២១:១៥-១៩)។ ពេលនោះ គាត់មិនបានឆ្លើយតបថា បាទ ចំពោះការត្រាស់ហៅរបស់ព្រះយេស៊ូវទេ តែគាត់បែរជាសួរព្រះអង្គថា «ព្រះអម្ចាស់អើយ តើអ្នកនោះនឹងបានដូចម្តេចទៅ?» (ខ.២១)។

ព្រះយេស៊ូវក៏បានឆ្លើយតបថា «បើសិនជាខ្ញុំចង់ឲ្យអ្នកនោះនៅទាល់តែខ្ញុំមក នោះតើអំពល់អ្វីដល់អ្នក ចូរឲ្យអ្នកមកតាមខ្ញុំចុះ» (ខ.២២)។ ខ្ញុំជឿថា ព្រះយេស៊ូវក៏មានបន្ទូលដូចនេះ ចំពោះយើងផងដែរ។ ពេលណាព្រះអង្គបានប្រទានយើងនូវទិសដៅ ក្នុងផ្នែកណាមួយនៃជីវិតយើងហើយ ព្រះអង្គសព្វព្រះទ័យឲ្យយើងទុកចិត្តព្រះអង្គ។ យើងមិនត្រូវប្រៀបធៀបផ្លូវដើររបស់យើង ជាមួយផ្លូវដែលអ្នកដទៃដើរទេ ប៉ុន្តែយើងគ្រាន់តែត្រូវដើរតាមព្រះអង្គប៉ុណ្ណោះ។

សាវ័កពេត្រុសក៏បានដើរតាមព្រះអម្ចាស់ជាង៣០ឆ្នាំ ក្នុងនាមជាអ្នកដឹកនាំពួកជំនុំដំបូង ប្រកបដោយចិត្តក្លាហាន។ កំណត់ត្រាប្រវត្តិសាស្ត្រក៏បានបង្ហាញផងដែរថា គាត់បានទទួលយកសេចក្តីស្លាប់ ដោយគ្មានការភ័យខ្លាចនៅក្រោមការគ្រប់គ្រងរបស់អធិរាជ នេរ៉ូ ជាស្តេចដ៏សាហាវព្រៃផ្សៃនៃចក្រភពរ៉ូម៉ាំង។ ចូរយើងមានចិត្តប្តូរផ្តាច់ដោយគ្មានងាករេ និងគ្មានការប្រៀបធៀបជាមួយអ្នកដទៃក្នុងការដើរតាមព្រះ ដោយទុកចិត្តលើសេចក្តីស្រឡាញ់ និងទិសដៅរបស់ព្រះអង្គ។—Karen Huang

តើអ្នកបានប្រៀបធៀបស្ថានភាពរបស់អ្នកជាមួយអ្នកដទៃ នៅពេលណាខ្លះ? តើអ្នកអាចដើរតាមព្រះអង្គតាមរបៀបដ៏ត្រឹមត្រូវដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យទុកចិត្ត និងដើរតាមព្រះអង្គ ដោយមិនប្រៀបធៀបខ្លួនឯងជាមួយអ្នកដទៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យ៉ូប ១៧-១៩ និងកិច្ចការ ១០:១-២៣

តែដោយកាន់តាមសេចក្តីពិតដោយសេចក្តីស្រឡាញ់វិញ នោះឲ្យយើងបានធំឡើង ខាងឯគ្រប់ការទាំងអស់ក្នុងទ្រង់ ដែលទ្រង់ជាសិរសា គឺជាព្រះគ្រីស្ទ (អេភេសូរ ៤:១៥)។

បម្រើដើម្បីផ្គាប់ចិត្ត

លោក អេនឌ្រូ ខាដ (Andrew Card) គឺជាប្រធានខុទ្ទកាល័យនៃសេតវិមានរបស់លោកប្រធានាធិបតីអាមេរិក ចច ដាប់ប៊ិលយូ ប៊ូស (George W. Bush)។ ក្នុងការសម្ភាសទាក់ទងនឹងតួនាទីរបស់គាត់ នៅក្នុងសេតវិមាន គាត់បានបកស្រាយថា «ក្នុងបន្ទប់របស់បុគ្គលិកម្នាក់នៅសេតវិមាន មានស៊ុមរូបថតមួយ ព្យួរលើជញ្ជាំងបង្ហាញអំពីគោលបំណងរបស់ពួកគេ ដែលមានអក្សរសរសេរពីលើថា យើងធ្វើការបម្រើ តាមការសម្រេចរបស់លោកប្រធានាធិបតី។ ប៉ុន្តែ មិនមែនមានន័យថា យើងធ្វើការងារ ដើម្បីផ្គាប់ចិត្តលោកប្រធានាធិបតី ឬដើម្បីធ្វើឲ្យគាត់ពេញចិត្តយើងនោះទេ។ ផ្ទុយទៅវិញ យើងធ្វើការបម្រើ ដើម្បីប្រាប់គាត់អំពីការអ្វីដែលគាត់ចាំបាច់ត្រូវដឹង ក្នុងការងាររបស់គាត់»។ ការងាររបស់គាត់ គឺជាការគ្រប់គ្រងសហរដ្ឋអាមេរិក។

នៅក្នុងតួនាទី និងទំនាក់ទំនងជាច្រើនដែលយើងមាន យើងងាយរអិលជើងចូលទៅក្នុងការបំពេញចិត្តអ្នកដទៃ ជាជាងស្អាងគ្នាទៅវិញទៅមក ក្នុងការរួបរួមគ្នា ដូចដែលសាវ័ក ប៉ុល ច្រើនតែជំរុញឲ្យយើងធ្វើ។ ក្នុងបទគម្ពីរអេភេសូរជំពូក៤សាវ័ក ប៉ុល បានបង្រៀនថា «ទ្រង់បានប្រទានឲ្យអ្នកខ្លះបានធ្វើជាសាវ័ក ខ្លះជាគ្រូអធិប្បាយ ខ្លះជាគ្រូផ្សាយដំណឹងល្អ ខ្លះជាគ្រូគង្វាល ហើយខ្លះជាគ្រូបង្រៀន ប្រយោជន៍នឹងនាំឲ្យពួកបរិសុទ្ធបានគ្រប់លក្ខណ៍ឡើង សំរាប់ធ្វើការជំនួយ ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទឡើង ទាល់តែយើងរាល់គ្នាបានរួបរួម ខាងឯសេចក្តីជំនឿជាស្រេច» (ខ.១១-១៣)។ ក្នុងខ.១៥-១៦ សាវ័ក ប៉ុល បានបង្រៀនយើងឲ្យជឿសវាងការផ្គាប់ចិត្តមនុស្ស ដោយនិយាយសង្កត់ធ្ងន់ថា យើងត្រូវប្រើអំណោយទានទាំងនេះ ដោយកាន់តាមសេចក្តីពិតដោយសេចក្តីស្រឡាញ់ ដើម្បីឲ្យរូបកាយព្រះគ្រីស្ទបានស្អាងឡើងក្នុងសេចក្តីស្រឡាញ់។

ក្នុងនាមយើងជាអ្នកជឿព្រះយេស៊ូវ យើងបម្រើមនុស្ស ដើម្បីស្អាងពួកគេឡើង និងដើម្បីបំពេញគោលបំណងរបស់ព្រះ មិនមែនដើម្បីផ្គាប់ចិត្តមនុស្សនោះទេ។ ទោះអ្នកដទៃពេញចិត្តឬអត់ យើងត្រូវផ្គាប់ចិត្តព្រះ ខណៈពេលដែលព្រះអង្គធ្វើការតាមរយៈយើង ដើម្បីបង្កើតឲ្យមានការរួបរួមក្នុងពួកជំនុំព្រះអង្គ។—Elisa Morgan

តើអ្នកធ្វើការបម្រើ ដើម្បីផ្គាប់ចិត្តនរណា? តើអ្នកនិយាយស្តី តាមការដឹកនាំរបស់ព្រះវត្តមានព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យមានចិត្តចង់ផ្គាប់ព្រះទ័យព្រះអង្គ ដោយនិយាយអំពីសេចក្តីពិត ដោយសេចក្តីស្រឡាញ់ ចំពោះបងប្អូនប្រុសស្រីរបស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យ៉ូប ២០-២១ និងកិច្ចការ ១០:២៤-៤៨

រួចឲ្យអរសប្បាយឡើងអស់៧ថ្ងៃនៅចំពោះ ព្រះយេហូវ៉ាជាព្រះនៃឯង (លេវីវិន័យ ២៣:៤០)។

ការបោះជំរុំរបស់ជាតិសាសន៍ទាំងមូល

មានពេលមួយខ្ញុំបានទៅបោះជំរុំក្នុងតំបន់ដែលមានសត្វព្រៃច្រើន នៅពេលយប់នៅក្រោមផ្ទៃមេឃនៃតំបន់អាហ្វ្រិកខាងលិច ដែលមានផ្កាយភ្លឺផ្លេក។ នៅរដូវប្រាំងយើងអាចបោះជំរុំ ដោយមិនចាំបាច់មានតង់សម្រាប់គេងក៏បាន ប៉ុន្តែការដុតភ្លើងបំភ្លឺពិតជាសំខាន់ណាស់។ ប៉ារបស់ខ្ញុំក៏បានប្រាប់ខ្ញុំឲ្យជួយមើលភ្លើងកុំឲ្យរលត់ ខណៈពេលដែលគាត់បន្ថែមកំណាត់ឈើពីលើភ្លើង។ ភ្លើងធ្វើឲ្យសត្វព្រៃមិនហ៊ានចូលមកជិតយើង។ សត្វដែលព្រះបានបង្កើតមានភាពអស្ចារ្យ ប៉ុន្តែយើងមិនដែលចង់ឲ្យសត្វខ្លារខិន ឬសត្វពស់លបចូលក្នុងកន្លែងបោះជំរុំរបស់យើងទេ។

ប៉ារបស់ខ្ញុំជាបេសកជននៅតំបន់ខាងជើងនៃប្រទេសហ្គាណា ហើយគាត់ពូកែរៀនសូត្រពីអ្វីៗនៅជុំវិញខ្លួនគាត់។ ការបោះជំរុំក៏បានផ្តល់ឱកាសឲ្យយើងរៀនសូត្របានច្រើនដែរ។ព្រះអម្ចាស់បានប្រើការបោះជំរុំជាឱកាសដើម្បីបង្រៀនរាស្ត្ររបស់ព្រះអង្គ។ រៀងរាល់មួយឆ្នាំម្តង ពួកអ៊ីស្រាអែលត្រូវរស់នៅក្នុងជម្រក ធ្វើពី «ធាងលម៉ើ និងមែកឈើញឹកស្និទ្ធ ព្រមទាំងធាងចាកពីមាត់ស្ទឹងផង» អស់រយៈពេលពេញមួយសប្តាហ៍ (លេវីវិន័យ ២៣:៤០)។ ព្រះអម្ចាស់មានគោលបំណងពីរយ៉ាង សម្រាប់ប្រពៃណីនេះ។ គឺដូចដែលព្រះអង្គបានប្រាប់ពួកគេថា «ពួកអ្នកទាំងប៉ុន្មានដែលកើតក្នុងវង្សសាសន៍អ៊ីស្រាអែល អាស្រ័យនៅក្នុងបារាំនោះអស់៧ថ្ងៃ ដើម្បីឲ្យអស់ទាំងដំណកូនចៅឯងរាល់គ្នាបានដឹងថា អញបានឲ្យពួកកូនចៅអ៊ីស្រាអែលនៅក្នុងបារាំដូច្នេះ ក្នុងកាលដែលអញនាំគេចេញពីស្រុកអេស៊ីព្ទមក» (ខ.៤២-៤៣)។ ប៉ុន្តែ ព្រឹត្តិការណ៍នោះក៏មានលក្ខណៈជាពិធីបុណ្យផងដែរ ព្រោះព្រះអង្គបានប្រាប់ពួកគេឲ្យអរសប្បាយ នៅចំពោះព្រះអង្គ ឲ្យបាន៧ថ្ងៃ (ខ.៤០)។

អ្នកខ្លះប្រហែលជាគិតថា ការបោះជំរុំគ្រាន់តែបាននាំមកនូវភាពសប្បាយរីករាយ ប៉ុន្តែព្រះអម្ចាស់បានបង្គាប់ឲ្យពួកអ៊ីស្រាអែលចំណាយពេលបោះជំរុំ១សប្តាហ៍ ដើម្បីឲ្យពួកគេនឹកចាំអំពីសេចក្តីល្អរបស់ព្រះអង្គ ដោយចិត្តរីករាយ។ យើងងាយនឹងភ្លេចអត្ថន័យនៃពិធីបុណ្យសំខាន់ៗរបស់គ្រីស្ទបរិស័ទ។ ពិធីបុណ្យក្នុងជំនឿគ្រីស្ទបរិស័ទអាចជួយឲ្យយើងនឹកចាំ អំពីចារិកលក្ខណៈរបស់ព្រះនៃសេចក្តីស្រឡាញ់។ ព្រះអង្គក៏បានបង្កើតភាពសប្បាយរីករាយ សម្រាប់ពិធីបុណ្យទាំងនោះផងដែរ។—Tim Gustafson

តើអ្នកចូលចិត្តពិធីបុណ្យក្នុងជំនឿគ្រីស្ទបរិស័ទមួយណាជាងគេ ហើយហេតុអ្វី? តើការប្រារព្ធពិធីនោះបានរំឭកអ្នក អំពីសេចក្តីល្អរបស់ព្រះអម្ចាស់ដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការដាក់ភាពសប្បាយរីករាយក្នុងស្មារព្រះហស្ត និងពិធីបុណ្យរបស់ព្រះអង្គ។

ទូលបង្គំនឹងមានចិត្តរីករាយចំពោះបញ្ញត្តទ្រង់ទាំងប៉ុន្មាន ឥតភ្លេចព្រះបន្ទូលទ្រង់ឡើយ (ទំនុកតម្កើង ១១៩:១៦)។

អំណោយដែលកែប្រែជីវិត

មានពេលមួយ ខ្ញុំបានស្ម័គមន៍ក្រុមយុវជន ខណៈពេលដែលខ្ញុំ និងស្វាមីខ្ញុំចែកព្រះគម្ពីរដល់ពួកគេ។ ខ្ញុំប្រាប់ពួកគេថា «ព្រះអង្គនឹងប្រើអំណោយដ៏មានតម្លៃទាំងនេះ ដើម្បីកែប្រែជីវិតអ្នក»។ នៅពេលយប់នោះ មានសិស្សពីរបីនាក់បានប្តេជ្ញាចិត្តថា នឹងអានកណ្ឌគម្ពីរដំណឹងល្អយ៉ូហានទាំងអស់គ្នា។ យើងក៏បានបន្តលើកទឹកចិត្តក្រុមយុវជននេះ ឲ្យអានព្រះគម្ពីរនៅផ្ទះ ខណៈពេលដែលយើងបង្រៀនពួកគេ ក្នុងអំឡុងពេលនៃការជួបជុំរៀងរាល់សប្តាហ៍។ ជាង១សប្តាហ៍ក្រោយមក ខ្ញុំក៏បានជួបសិស្សរបស់យើងម្នាក់។ នាងថា នាងនៅតែបន្តប្រើព្រះគម្ពីរដែលខ្ញុំបានឲ្យនាង។ ក្រោយមក ខ្ញុំក៏បានឃើញទីបន្ទាល់ដ៏ល្អនៃជីវិតរបស់នាង ដែលពេញដោយសេចក្តីជំនឿ។

ព្រះអម្ចាស់ប្រទានអំណោចដល់រាស្ត្រព្រះអង្គ ឲ្យអាន និងសូត្រខគម្ពីរ ព្រមទាំងចាំទំព័រដែលពួកគេអាចរកមើលខគម្ពីរផងដែរ។ ព្រះអង្គជួយឲ្យយើងអាចបន្តដើរតាមផ្លូវនៃសេចក្តីបរិសុទ្ធ ដោយរស់នៅស្របតាមខគម្ពីរ (ទំនុកតម្កើង ១១៩:៩)។ ព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងស្វែងរកបំណងព្រះទ័យ និងស្តាប់បង្គាប់ព្រះអង្គ ខណៈពេលដែលយើងប្រើសេចក្តីពិតដែលមិនចេះប្រែប្រួលរបស់ព្រះអង្គ ដើម្បីរំដោះយើងឲ្យរួចពីបាប និងកែប្រែជីវិតយើង (ខ.១០-១១)។ ជារៀងរាល់ថ្ងៃ យើងអាចទូលសូមព្រះអង្គជួយយើង ឲ្យស្គាល់ព្រះអង្គ និងយល់ព្រះបន្ទូលព្រះអង្គ ដែលមានចែងក្នុងព្រះគម្ពីរ (ខ.១២-១៣)។

ពេលណាយើងស្គាល់តម្លៃនៃការរស់នៅតាមផ្លូវរបស់ព្រះ យើងអាច «អរសប្បាយ» ក្នុងការបង្រៀនរបស់ព្រះអង្គ ដូចមនុស្សដែលអរសប្បាយនឹងទ្រព្យសម្បត្តិគ្រប់យ៉ាង (ខ.១៤-១៥)។ បានជាយើងអាចច្រៀង ដូចអ្នកនិពន្ធបទគម្ពីរទំនុកតម្កើងថា «ទូលបង្គំនឹងមានចិត្តរីករាយចំពោះបញ្ញត្តទ្រង់ទាំងប៉ុន្មាន ឥតភ្លេចព្រះបន្ទូលទ្រង់ឡើយ» (ខ.១៦)។ ខណៈពេលដែលយើងទូលសូមព្រះវិញ្ញាណបរិសុទ្ធចម្រើនកម្លាំងយើង យើងអាចប្រើពេលវេលាដ៏មានតម្លៃនីមួយៗ ដោយអធិស្ឋាន និងអានព្រះគម្ពីរ ជាអំណោយមកពីព្រះអម្ចាស់ ដើម្បីកែប្រែជីវិតយើង។—Xochitl Dixon

តើអ្នកបានចំណាយពេលសិក្សាព្រះគម្ពីរដូចម្តេចខ្លះ? តើការអរសប្បាយក្នុងការសិក្សាព្រះគម្ពីរ បានកែប្រែចិត្តគំនិតដែលអ្នកមានចំពោះការត្រាស់ហៅឲ្យស្តាប់បង្គាប់ព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះដ៏រស់ សូមព្រះអង្គជួយទូលបង្គំឲ្យអរសប្បាយ ចំពោះព្រះបន្ទូលដ៏មានតម្លៃ ខណៈពេលដែលព្រះអង្គចម្រើនកម្លាំងទូលបង្គំឲ្យចុះចូលនឹងប្រាជ្ញា និងអំណាចព្រះអង្គក្នុងជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 190 17/11/25 1:45 in the afternoon

ដោយហេតុនោះបានជាយើងស្រែកឡើងថា ឱអ័ប្បា ព្រះវរបិតាអើយ (រ៉ូម ៨:១៥)។

ព្រះវរបិតាតែងតែស្តាប់យើង

ប្រៃ:ពេលប៉ុន្មាននាទី បន្ទាប់ពីលោកប្រធានាធិបតីអាមេរិក ហារី ទ្រូមិន (Harry Truman) ធ្វើការប្រកាសថា សង្គ្រាមលោកលើកទី២បានបញ្ចប់ហើយ ទូរស័ព្ទបានរោទ៍ឡើង ក្នុងផ្ទះឈើតូចមួយ ក្នុងទីក្រុងគ្រែនីយូ រដ្ឋមីស៊ូរី។ ដូនចាស់ម្នាក់អាយុ៩២ឆ្នាំ បានទុកកិច្ចការចោលមួយឡែកសិន ដើម្បីលើកទូរស័ព្ទនិយាយ។ ភ្ញៀវដែលមកលេងផ្ទះគាត់ ក៏បានឮគាត់និយាយថា "ហាឡូ... ចាស់ ម៉ាក់សុខសប្បាយទេ។ ចាស់ ម៉ាក់កំពុងស្តាប់វិទ្យុ... ឥឡូវនេះ បើសិនជាអាច កូនមកលេងម៉ាក់ផង... ជំរាបលា"។ ដូនចាស់ក៏បានងាកមកភ្ញៀវរបស់គាត់ ហើយនិយាយថា "ហារី កូនប្រុសខ្ញុំ ទូរស័ព្ទមក។ ហារី គឺជាកូនល្អ... ពេលទូរស័ព្ទរោទ៍ ខ្ញុំដឹងថា គាត់ទូរស័ព្ទមកខ្ញុំ។ គាត់តែងតែទូរស័ព្ទប្រាប់ខ្ញុំ បន្ទាប់ពីបញ្ហាអ្វីមួយបានបញ្ចប់"។

ទោះយើងមានភាពជោគជ័យប៉ុណ្ណា ឬមានវ័យចាស់ប៉ុណ្ណា យើងតែងតែចង់ទូរស័ព្ទទៅកាន់ឪពុកម្តាយរបស់យើង។ យើងចង់ឮពួកគាត់និយាយបញ្ជាក់ថា យើងជា "កូនល្អ!"។ ទោះយើងមានភាពជោគជ័យប៉ុណ្ណាក៏ដោយ ក៏យើងនៅតែជាកូនប្រុស ឬកូនស្រីរបស់ពួកគាត់ជារៀងរហូត។

ប៉ុន្តែ គួរឲ្យស្តាយណាស់ មិនមែនគ្រប់គ្នាសុទ្ធតែមានទំនាក់ទំនងប្រភេទនេះ ជាមួយឪពុកម្តាយនៅផែនដីទេ។ ប៉ុន្តែ តាមរយៈព្រះយេស៊ូវ យើងសុទ្ធតែអាចមានព្រះអម្ចាស់ ធ្វើជាឪពុករបស់យើង។ ព្រះគ្រីស្ទនាំអ្នកដើរតាមព្រះអង្គ ចូលក្នុងមហាគ្រួសារនៃព្រះ ហើយ "អស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ" (រ៉ូម ៨:១៤)។ សព្វថ្ងៃនេះ "យើងក៏បានគ្រងមរដកដែរ គឺជាអ្នកគ្រងមរដកនៃព្រះជាមួយនឹងព្រះគ្រីស្ទផង" (ខ.១៧)។ យើងមិននិយាយទៅកាន់ព្រះអង្គក្នុងនាមជាបាវបម្រើទេ តែសព្វថ្ងៃនេះមានសិទ្ធិហៅព្រះអង្គថា "ឱអ័ប្បា ព្រះវរបិតាអើយ" គឺដូចព្រះយេស៊ូវបានហៅព្រះវរបិតា នៅមុនពេលទ្រង់សុគត (ខ.១៥ និងមើល ម៉ាកុស ១៤:៣៦)។

តើអ្នកចង់ឲ្យមាននរណាម្នាក់ស្តាប់អ្នកនិយាយទេ? តើអ្នកមានតម្រូវការអ្វីខ្លះ? ចូរអធិស្ឋានទៅកាន់ព្រះវរបិតាដែលកំពុងគង់នៅក្នុងផ្ទះដ៏អស់កល្បរបស់អ្នកចុះ។—Mike Wittmer

តើអ្នកមានដំណឹង ឬតម្រូវការអ្វី ដែលអ្នកចូលចិត្តចែកចាយដល់ឪពុកម្តាយខាងសាច់ឈាមរបស់អ្នក? តើអ្នកអាចទូលព្រះវរបិតាដែលគង់នៅស្ថានសួគ៌ អំពីរឿងអ្វីខ្លះ? ព្រះអង្គកំពុងតែស្តាប់អ្នកស្រាប់ហើយ។

ឱព្រះវរបិតាប្រកបដោយព្រះគុណ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានឯកសិទ្ធិឲ្យទូលបង្គំអាចចូលទៅជួបព្រះអង្គ ដោយការអធិស្ឋានទៅពេលណាក៏បាន។

Daily Manna 2026_Content Enhance.indd 191 17/11/25 1:45 in the afternoon

ដូច្នេះ យ៉ាកុប នៅតែម្នាក់ឯង ហើយមានម្នាក់មកចំបាប់នឹងគាត់រហូតដល់ភ្លឺ (លោកុប្បត្តិ ៣២:២៤)។

បោកចំបាប់ជាមួយព្រះអម្ចាស់

ដំណើរកិច្ចដែលខ្ញុំបានរាប់អានជាយូរមកហើយ បានផ្ញើសំបុត្រមួយច្បាប់មកខ្ញុំ បន្ទាប់ពីស្វាមីខ្ញុំបានទទួលមរណៈភាព។ ក្នុងសំបុត្រនោះគាត់បានសរសេរថា «លោក អ័ឡិន (Alan) គឺជាអ្នកបោកចំបាប់ជាមួយព្រះ។ គាត់ប្រៀបដូចជាលោក យ៉ាកុប ក្នុងព្រះគម្ពីរសញ្ញាចាស់ និងជាមូលហេតុដែលខ្ញុំទទួលជឿព្រះ រហូតដល់ពេលសព្វថ្ងៃ»។ ខ្ញុំមិនដែលបានគិតចង់ប្រៀបធៀបការតយុទ្ធរបស់ស្វាមីខ្ញុំ ជាមួយនឹងការតយុទ្ធរបស់លោក យ៉ាកុប ជាអយ្យកោរបស់សាសន៍អ៊ីស្រាអែលនោះទេ ប៉ុន្តែគាត់មានចំណុចដែលដូចលោក យ៉ាកុប។ ពេញមួយជីវិតគាត់ គាត់មានសំណួរជាច្រើន សម្រាប់ព្រះអម្ចាស់ ជាការតយុទ្ធនឹងព្រះអង្គ ដែលប្រៀបដូចជាលោក យ៉ាកុប បោកចំបាប់ជាមួយព្រះអង្គផងដែរ។ គាត់ស្រឡាញ់ព្រះ តែមិនតែងតែអាចទទួលស្គាល់ការពិតដែលថា ព្រះអង្គស្រឡាញ់គាត់ បានអត់ទោសឲ្យគាត់ ហើយស្តាប់ឮគាត់អធិស្ឋានទេ។ តែជីវិតគាត់បានទទួលព្រះពរជាច្រើន ហើយគាត់ក៏មានឥទ្ធិពលជាវិជ្ជមានទៅលើមនុស្សជាច្រើន។

ជីវិតរបស់លោក យ៉ាកុប មានចារឹកលក្ខណៈជាការតយុទ្ធ។ គាត់បានធ្វើការបោកបញ្ឆោតលោក អេសាវ ជាបងប្រុសគាត់ ដើម្បីឲ្យបានសិទ្ធិធ្វើជាបងច្បង។ គាត់បានរត់ចោលផ្ទះ ហើយបានតយុទ្ធជាច្រើនឆ្នាំជាមួយលោក ឡាបាន់ ជាសាច់ញាតិ និងជាឪពុកក្មេករបស់គាត់។ បន្ទាប់មក គាត់ក៏បានរត់គេចពីលោក ឡាបាន់ ទៀត។ គាត់ស្ថិតក្នុងភាពឯកោ ហើយខ្លាចមិនហ៊ានជួបលោក អេសាវ។ ប៉ុន្តែ គាត់ក៏បានជួបទេវតារបស់ព្រះអម្ចាស់ (លោកុប្បត្តិ ៣២:១) ដែលប្រហែលជាការរំឭក អំពីការយល់សប្តិដែលព្រះអម្ចាស់បានបណ្តាលឲ្យគាត់មាន កាលពីមុន (២៨:១០-២២)។ បន្ទាប់មក លោក យ៉ាកុប ក៏បានបោកចំបាប់ជាមួយ «បុរសម្នាក់» ដែលជាព្រះអម្ចាស់បង្ហាញអង្គទ្រង់ក្នុងលក្ខណៈជាមនុស្ស។ ព្រះអង្គក៏បានប្តូរឈ្មោះគាត់មកជា អ៊ីស្រាអែល ព្រោះគាត់ «មានអំណាចចំពោះព្រះ ហើយនឹងមនុស្សក៏បានឈ្នះផង» (៣២:២៨)។ ព្រះអម្ចាស់បានគង់នៅជាមួយ និងស្រឡាញ់លោក យ៉ាកុប ទោះគាត់មានការតយុទ្ធនឹងព្រះអង្គយ៉ាងណាក៏ដោយ។

យើងរាល់គ្នាសុទ្ធតែមានការតយុទ្ធ។ តែយើងមិនឯកោទេ ព្រោះព្រះអម្ចាស់គង់នៅជាមួយយើង ក្នុងទុក្ខលំបាកទាំងនោះ។ អស់អ្នកដែលជឿព្រះអង្គ គឺជាអ្នកដែលព្រះអង្គស្រឡាញ់ បានអត់ទោសឲ្យ និងបានសន្យាថា នឹងប្រទានជីវិតអស់កល្ប (យ៉ូហាន ៣:១៦)។ យើងអាចតោងព្រះអង្គឲ្យជាប់ ដោយទុកចិត្តលើព្រះបន្ទូលសន្យា ពឹងផ្អែកលើកម្លាំងរបស់ព្រះអង្គ ជាពិសេសក្នុងពេលដែលមានទុក្ខលំបាក ឬការតយុទ្ធ។—Alyson Kieda

តើអ្នកបានបោកចំបាប់នឹងព្រះអម្ចាស់ នៅពេលណាខ្លះ? តើអ្នកមានការកម្សាន្តចិត្តយ៉ាងណា ពេលដែលបានដឹងថា ព្រះអង្គគង់នៅជាមួយអ្នក ក្នុងទុក្ខលំបាករបស់អ្នក?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំ ឲ្យថ្វាយសំណួរ និងទុក្ខលំបាករបស់ទូលបង្គំ ដល់ព្រះអង្គ ដោយដឹងថា ព្រះអង្គស្តាប់ឮពាក្យទូលបង្គំអធិស្ឋាន។ ថ្ងៃណាមួយទូលបង្គំនឹងមិនមានសំណួរ ឬការសង្ស័យទៀតឡើយ។

គម្រោងអានព្រះគម្ពីរអស់រយៈពេល១ឆ្នាំ | យ៉ូប ៣០-៣១ និងកិច្ចការ ១៣:២៦-៥២

ព្រោះគ្រឿងសស្ត្រាវុធពិជ័យសង្គ្រាមរបស់យើងខ្ញុំ មិនមែនជារបស់ខាងសាច់ឈាម (២កូរិនថូស ១០:៤)។

អាវុធរបស់យើងក្នុងសង្គ្រាម

មិត្តភក្តិថ្មីរបស់លោកគ្រូគង្វាល បេលេយ (Bailey) បានចែកចាយដល់លោកគ្រូ បេលេយ អំពីបញ្ហារបស់គាត់ ដែលមានការបំពានផ្លូវភេទ និងការញៀនរូបអាសអាភាស។ ឃុវជនម្នាក់នោះជាអ្នកជឿព្រះយេស៊ូវ ប៉ុន្តែគាត់បានជួបការបំពានផ្លូវភេទ និងបានមើលរូបអាសអាភាសក្នុងវ័យក្មេង ធ្វើឲ្យគាត់ជួបបញ្ហា ដែលគាត់មិនអាចដោះស្រាយដោយខ្លួនឯងបាន។ គាត់ក៏បានធ្លាក់ចូលក្នុងភាពអស់សង្ឃឹម ហើយក៏បានឈោងទៅរកជំនួយ។

ក្នុងនាមយើងជាអ្នកជឿព្រះគ្រីស្ទ យើងតយុទ្ធនឹងអំណាចនៃសេចក្តីអាក្រក់ដែលយើងមើលមិនឃើញ (២កូរិនថូស ១០:៣-៦)។ ប៉ុន្តែ ព្រះអង្គបានប្រទានអាវុធ សម្រាប់ឲ្យយើងតយុទ្ធក្នុងសង្គ្រាមខាងវិញ្ញាណ។ ទោះជាយ៉ាងណាក៏ដោយ អាវុធនោះ មិនមែនជាអាវុធរបស់លោកីយ៍ទេ។ ផ្ទុយទៅវិញ យើងមាន «ឥទ្ធិឫទ្ធិដែលមកពីព្រះ សំរាប់នឹងរំលំទីមាំមួនវិញ» (ខ.៤)។ តើការបកស្រាយនេះមានន័យដូចម្តេច? «ទីមាំមួន» ត្រូវបានគេសង់ឡើងយ៉ាងរឹងមាំ។ អាវុធដែលព្រះនៃយើងបានប្រទាន គឺរាប់បញ្ចូលអាវុធនៃសេចក្តីសុចរិត នៅដៃខាងស្តាំសម្រាប់ប្រយុទ្ធ និងនៅខាងឆ្វេងសម្រាប់ការពារ (៦:៧)។ បទគម្ពីរ អេភេសូរ ៦:១៣-១៨ ក៏បានរៀបរាប់អំពីអាវុធជាច្រើន ដែលជួយការពារយើង ដែលរួមមានព្រះបន្ទូល សេចក្តីជំនឿ សេចក្តីសង្គ្រោះ ការអធិស្ឋាន និងការទ្រទ្រង់របស់អ្នកជឿដទៃទៀត។ ពេលណាយើងប្រឈមមុខដាក់កម្លាំងដែលធំជាង និងខ្លាំងជាងយើង ការប្រើប្រាស់អាវុធទាំងនេះឲ្យបានត្រឹមត្រូវ អាចជួយយើងឲ្យឈរមាំមួន ដោយមិនជំពប់ដួល។

ព្រះអម្ចាស់ក៏ជាអ្នកប្រឹក្សាយោបល់ និងមានឯកទេសដទៃទៀត សម្រាប់ជួយអស់អ្នកដែលកំពុងតយុទ្ធនឹងអំណាច ដែលធំពេក មិនអាចជម្នះដោយខ្លួនឯងបាន។ នៅក្នុង និងតាមរយៈព្រះយេស៊ូវ យើងមិនចាំបាច់ត្រូវចុះចាញ់ ក្នុងការតយុទ្ធនោះទេ។ នេះជាដំណឹងដ៏ល្អ ដែលលើកទឹកចិត្តយើងឲ្យមានសង្ឃឹម និងចិត្តក្លាហានឡើង។ យើងមានគ្រឿងសឹករបស់ព្រះអង្គហើយ ចូរកុំរាថយឡើយ!—Arthur Jackson

តើអ្នកអាចឈោងទៅរកនរណាខ្លះ ដើម្បីស្វែងរកជំនួយ ក្នុងពេលមានទុក្ខលំបាក? តើអ្នកនឹងប្រើអាវុធអ្វីខ្លះ?

ឱព្រះយេស៊ូវ ព្រះអង្គមានព្រះចេស្តាជាងអំណាចគ្រប់យ៉ាង ដែលទូលបង្គំអាចមើលឃើញ និងមើលមិនឃើញ។ ទូលបង្គំត្រូវការព្រះវត្តមាន និងព្រះចេស្តាព្រះអង្គ ធ្វើការក្នុងជីវិតទូលបង្គំនៅថ្ងៃនេះ។

Daily Manna 2026_Content Enhance.indd 193 17/11/25 1:45 in the afternoon

ដ្បិតព្រះទ្រង់មិនមែនជាអ្នករមិលគុណ ដែលទ្រង់នឹងភ្លេចការអ្នករាល់គ្នាធ្វើ និងសេចក្តីស្រឡាញ់ ដែលអ្នករាល់គ្នាបានសំដែងដល់ព្រះនាមទ្រង់ ដោយបានបំរើពួកបរិសុទ្ធ ហើយក៏នៅតែបំរើទៀតនោះទេ (ហេព្រើរ ៦:១០)។

ជាប់ខ្លួននៅក្នុងភក់ជ្រៅ

ថ្ងៃមួយ នៅក្នុងរោងចក្រផលិតស្ករសូកូឡា ម៉ាស ក្នុងរដ្ឋផេនស៊ីលវេនា មានកម្មករពីរនាក់បានធ្លាក់ចូលក្នុងស៊ុំទែនធំមួយ ដែលផ្ទុកទៅដោយស្ករសូកូឡារាវ។ អ្នកខ្លះប្រហែលជាគិតថា វាជារឿងដែលកំប្លែង ឬប្រហែលជាគិតថា វាជាលទ្ធផលដែលគួរឲ្យពេញចិត្តរបស់អ្នកដែលចូលចិត្តស្ករសូកូឡា។ បុរសទាំងនេះមិនមានរបួសទេ តែពួកគេបានជាប់នៅក្នុងស៊ុំទែនដែលមានទឹកស្ករសូកូឡាផ្អែមឆ្ងាញ់ត្រឹមចង្កេះ ដោយមិនអាចចេញមកខាងក្រៅ ដោយខ្លួនឯងបាន។ ទីបំផុត ក្រុមអ្នកពន្លត់អគ្គីភ័យក៏បានចោះប្រហោង នៅចំហៀងស៊ុំទែននោះ ដើម្បីជួយពួកគេចេញមកខាងក្រៅ ដោយសុវត្ថិភាព។

កាលហោរា យេរេមា បានជាប់ខ្លួនក្នុងភក់ នៅក្នុងគុកងងឹត រឿងរបស់គាត់មិនមានរស់ជាតិផ្អែមដូចនេះទេ។ ក្នុងនាមគាត់អ្នកនាំព្រះរាជសាររបស់ព្រះ មកប្រកាសដល់ប្រជាជននៅទីក្រុងយេរូសាឡិម គាត់ក៏បានប្រាប់ពួកគេឲ្យចាកចេញពីទីក្រុងយេរូសាឡិមជាបន្ទាន់ ព្រោះទីក្រុងនេះនឹងធ្លាក់ចូលទៅក្នុងកណ្តាប់ដៃកងទ័ពរបស់ស្តេចបាប៊ីឡូន (យេរេមា ៣៨:៣)។ ពួកមន្ត្រីខ្លះរបស់ស្តេច សេដេគា ក៏បានទាមទារឲ្យគេប្រហារជីវិតហោរា យេរេមា ព្រោះពួកគេអះអាងថា ពាក្យសម្តីរបស់គាត់កំពុងតែបំបាក់ទឹកចិត្តពួកទាហាន (ខ.៤)។ ស្តេចក៏ព្រមតាមពួកគេ ហើយគេក៏បានយកខ្សែសំរួតគាត់ ចុះទៅក្នុងគុកងងឹតដែលមានសុទ្ធតែភក់ (ខ.៦)។

នៅពេលដែលមន្ត្រីម្នាក់ទៀតរបស់ស្តេច ដែលជាសាសន៍ដទៃ បានជួយរកខុសត្រូវឲ្យលោក យេរេមា ដោយលើកឡើងថា អ្វីដែលពួកមន្ត្រីផ្សេងទៀតបានប្រព្រឹត្តចំពោះគាត់ គឺជាការអាក្រក់ជូរជាតិណាស់ ស្តេច សេដេគា ក៏បានដឹងថា ទ្រង់បានធ្វើខុសមកលើគាត់ ហើយក៏បានបង្គាប់លោក អេបេឌ-មេលេក ឲ្យស្រង់គាត់ចេញពីគុកងងឹត (ខ.៩-១០)។

សូម្បីតែនៅពេលដែលយើងកំពុងធ្វើរឿងដ៏ត្រឹមត្រូវដូចលោក យេរេមា ក៏ដោយជួនកាលយើងប្រហែលជាមានអារម្មណ៍ថា យើងហាក់ដូចជាកំពុងជាប់ខ្លួននៅក្នុងភក់ជ្រៅ។ ស្ថិតក្នុងពេលបែបនេះ ចូរយើងទូលសូមព្រះអម្ចាស់លើកទឹកចិត្តយើង ឲ្យមានសង្ឃឹមឡើង ខណៈពេលដែលយើងកំពុងរង់ចាំជំនួយព្រះអង្គ នៅចំពោះមុខបញ្ហាដែលយើងកំពុងជួបប្រទះនោះ។—Kirsten Holmberg

តើគេបានធ្វើខុសមកលើអ្នក នៅពេលដែលអ្នកធ្វើរឿងដ៏ត្រឹមត្រូវ នៅពេលណា? តើព្រះអម្ចាស់បានជួយទ្រទ្រង់អ្នក ក្នុងពេលនោះ ដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទ្រទ្រង់ទូលបង្គំ ខណៈពេលដែលទូលបង្គំខិតខំស្តាប់បង្គាប់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយេរៈពេល១ឆ្នាំ | យ៉ូប ៣៤-៣៥ និងកិច្ចការ ១៥:១-២១

តើយើងខ្ញុំបានឃើញទ្រង់ឈឺ ឬជាប់គុក ហើយបានមកឯទ្រង់ពីកាលណា? (ម៉ាថាយ ២៥:៣៩)

មានន័យថាបានបម្រើព្រះយេស៊ូវ

កាលពីដើមទសវត្សរ៍ឆ្នាំ១៨០០ អ្នកស្រី អេលីហ្សាប៊ែត ហ្វ្រាយ (Elizabeth Fry) មានអារម្មណ៍តក់ស្លុតចំពោះស្ថានភាពរបស់ពន្ធនាគារស្ត្រី នៅទីក្រុងឡុងដ៍។ ស្ត្រីជាអ្នកទោស និងកូនៗរបស់ពួកគេបានរស់នៅបញ្ចូតគ្នា នៅទីនោះ ហើយគេឲ្យពួកគេគេងនៅលើកម្រាលឥដ្ឋក្នុងអាកាសធាតុដ៏រងា។ ពួកគេគ្មានគ្រែគេងឲ្យបានកក់ក្តៅ ប៉ុន្តែមន្ទីរឃុំឃាំងមានក្បាលប៉ូបឺនេ ដែលពួកគេអាចបើកយកស្រាធឹកកម្តៅខ្លួន។ គាត់បានទៅមើលគុកនោះអស់ជាច្រើនឆ្នាំ និងបានជំរុញឲ្យមានការផ្លាស់ប្តូរ ដោយផ្តល់ឲ្យពួកគេនូវសំលៀកបំពាក់ លើកសាលារៀន និងបង្រៀនព្រះគម្ពីរដល់ពួកគេផងដែរ។ ប៉ុន្តែ អ្នកទោសជាច្រើនបានទទួលការប៉ះពាល់ចិត្តខ្លាំងបំផុត ដោយសារវត្តមាននៃសេចក្តីស្រឡាញ់របស់គាត់ និងសារនៃសេចក្តីសង្ឃឹម ដែលគាត់បានចែកចាយដល់ពួកគេនៅទីនោះ។

គាត់បានប្រព្រឹត្តដោយចិត្តសប្បុរស ដោយសារគាត់អនុវត្តតាមការបង្គាប់របស់ព្រះយេស៊ូវ ឲ្យបម្រើជនទុរគត។ ជាក់ស្តែង កាលនៅលើភ្នំដើមអូលីវ ព្រះអង្គបានចែកចាយរឿងមួយចំនួន ដែលនិយាយអំពីគ្រាចុងក្រោយ ហើយក្នុងចំណោមនោះ មានរឿងមួយដែលនិយាយអំពីការស្វាគមន៍ «ពួកសុចរិតចូលទៅក្នុងជីវិតអស់កល្បជានិច្ច» (ម៉ាថាយ ២៥:៤៦)។ ក្នុងរឿងនេះ ស្តេចបានប្រាប់ពួកមនុស្សសុចរិតថា ពួកគេបានថ្វាយទឹកឲ្យព្រះអង្គសោយ យាងព្រះអង្គចូលគង់ខាងក្នុង ហើយបានទៅសួរសុខទុក្ខព្រះអង្គនៅក្នុងគុក (ខ.៣៥-៣៦)។ នៅពេលដែលពួកគេមិនចាំថា ពួកគេបានធ្វើនូវរឿងទាំងនេះពីពេលណា ទ្រង់ក៏បានឆ្លើយតបថា «យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បានធ្វើដល់យើងដែរ» (ខ.៤០)។

ពិតជាអស្ចារ្យណាស់ ពេលណាយើងបម្រើអ្នកដទៃ ដោយជំនួយពីព្រះវិញ្ញាណបរិសុទ្ធ នោះមានន័យថាយើងក៏កំពុងបម្រើព្រះយេស៊ូវផងដែរ! យើងអាចបម្រើអ្នកដទៃ ដោយផ្ទាល់ ដូចដែលអ្នកស្រី អេលីហ្សាប៊ែប ហ្វ្រាយ បានបម្រើដល់អ្នកទោសទាំងនោះ ហើយក៏អាចបម្រើអ្នកដទៃពីចម្ងាយ ដោយអធិស្ឋានទូលអង្វរឲ្យគេ ឬផ្ញើសារលើកទឹកចិត្តគេ។ ព្រះយេស៊ូវបានត្រាស់ហៅយើង ឲ្យស្រឡាញ់ព្រះអង្គ ដោយប្រើអំណោយទានខាងវិញ្ញាណ និងអ្វីដែលយើងមាន ដើម្បីយកអសារអ្នកដទៃ។—Amy Boucher Pye

តើអ្នកមានអារម្មណ៍យ៉ាងណា ពេលដែលបានឮថា ការបម្រើអ្នកដទៃ ក៏ជាការបម្រើដល់ព្រះយេស៊ូវផងដែរ? តើអ្នកអាចឈោងទៅរកនរណាម្នាក់ ដែលកំពុងមានការខ្វះខាត យ៉ាងដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ជាព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គជួយទូលបង្គំឲ្យដឹងថា ទូលបង្គំអាចបង្ហាញសេចក្តីស្រឡាញ់ តាមរយៈការប្រព្រឹត្តរបស់ទូលបង្គំនៅថ្ងៃនេះ នៅកន្លែងណាខ្លះ។

Daily Manna 2026_Content Enhance.indd 195 17/11/25 1:45 in the afternoon

តើមានអ្វីឃាត់មិនឲ្យខ្ញុំទទួលបុណ្យជ្រមុជទឹកបាន? (កិច្ចការ ៨:៣៦)

តើគេស្វាគមន៍ខ្ញុំទេ?

អ្នកស្រី សាលី ហ្វៀល (Sally Field) ជាតួសម្តែង ដែលនៅទីបំផុត គាត់ក៏បានស្គាល់អារម្មណ៍ដែលយើងម្នាក់ៗចង់មាន។ កាលគាត់ទទួលបានពាន់រង្វាន់អូស្កាជាលើកទីពីរ ក្នុងឆ្នាំ១៩៨៥ គាត់បាននិយាយ នៅក្នុងសន្ទរកថាទទួលពាន់រង្វាន់អូស្កាយ៉ាងដូចនេះថា «ខ្ញុំចង់បានការគោរពរបស់អ្នកទាំងអស់គ្នា លើសអ្វីៗទាំងអស់។ កាលទទួលពានរង្វាន់អូស្កាលើកទីមួយ ខ្ញុំមិនមានអារម្មណ៍ដូចនេះទេ។ តែលើកនេះ ខ្ញុំមានអារម្មណ៍ថា បានទទួលការគោរព។ ហើយខ្ញុំក៏មិនអាចបដិសេធន៍ការពិតដែលថា ក្នុងពេលនេះ អ្នកទាំងអស់គ្នាមិនខុសពីខ្ញុំទេ»។

ជនជាតិអេធីយ៉ូពី ដែលជាមនុស្សកម្រៀវ ក៏មានការស្ងប់ស្ងែង ចំពោះការទទួលស្វាគមន៍ដែលគាត់បានទទួលផងដែរ។ ក្នុងនាមគាត់ជាសាសន៍ដទៃ គេបានបដិសេធន៍មិនឲ្យគាត់ចូលទៅក្នុងបរិវេណខាងក្នុងនៃព្រះវិហារនៅទីក្រុងយេរូសាឡិមទេ (មើល អេភេសូរ ២:១១-១២ និងចោទិយកថា ២៣:១)។ ប៉ុន្តែ គាត់ចង់ឲ្យគេទទួលស្វាគមន៍គាត់។ សាវ័ក ភីលីពក៏បានប្រទះឃើញគាត់ កំពុងត្រឡប់ពីការធ្វើដំណើរទៅចូលរួមពិធីបុណ្យនៅទីក្រុងយេរូសាឡិម (កិច្ចការ ៨:២៧)។

បុរសអេធីយ៉ូពីនោះកំពុងអានបទគម្ពីរអេសាយ ដែលក្នុងនោះ ព្រះអម្ចាស់បានសន្យាថា «ពួកកម្រៀវ ដែលរក្សាថ្ងៃឈប់សំរាកទាំងប៉ុន្មាន ក៏រើសយកអ្វីៗដែលគាប់ចិត្តអញ ព្រមទាំងកាន់ខ្ជាប់តាមសេចក្ដីសញ្ញារបស់អញថា អញនឹងឲ្យគេមានទីកន្លែង១នៅក្នុងវិហារអញ ហើយឲ្យមានឈ្មោះឆ្លាក់នៅជញ្ជាំងខាងក្នុង ដែលវិសេសជាងកូនប្រុសកូនស្រីទៅទៀត អញនឹងឲ្យគេមានឈ្មោះដ៏នៅអស់កល្បជានិច្ច ជាឈ្មោះដែលមិនត្រូវកាត់ចេញឡើយ» (អេសាយ ៥៦:៤-៥)។ បន្ទាប់មក សាវ័ក ភីលីពក៏បានចែកចាយដំណឹងល្អអំពីព្រះយេស៊ូវ ឲ្យគាត់ស្តាប់ ហើយគាត់ក៏បានឆ្លើយតបថា «មើល នុ៎ះន៏ទឹក តើមានអ្វីឃាត់មិនឲ្យខ្ញុំទទួលបុណ្យជ្រមុជទឹកបាន?» (កិច្ចការ ៨:៣៥-៣៦)។

ត្រង់ចំណុចនេះ គាត់កំពុងតែចង់សួរថា តើគេពិតជាទទួលស្វាគមន៍គាត់ទេ? តើគាត់ពិតជាអាចចូលរួមជាមួយគេឬទេ? សាវ័ក ភីលីពបានធ្វើបុណ្យជ្រមុជទឹកឲ្យគាត់ ជាសញ្ញាបង្ហាញថា ព្រះយេស៊ូវបានដកនាំងទាំងអស់ចេញហើយ (អេភេសូរ ២:១៨)។ ព្រះយេស៊ូវបានឱបក្រសោបយក និងបង្រួបបង្រួម មនុស្សទាំងអស់ដែលងាកចេញពីបាប ហើយទទួលជឿព្រះអង្គ។ បុរសកម្រៀវនោះក៏ទៅតាមផ្លូវដោយអរសប្បាយ (កិច្ចការ ៨:៣៩)។ ទីបំផុត គាត់ក៏មានចំណែកក្នុងមហាគ្រួសារនៃព្រះយ៉ាងពេញលេញ។—Mike Wittmer

ហេតុអ្វីអ្នកជឿព្រះយេស៊ូវទាំងអស់ សុទ្ធតែមានចំណែកក្នុងមហាគ្រួសាររបស់ព្រះអង្គ? តើការធ្វើបុណ្យជ្រមុជទឹក បានជួយឲ្យអ្នកយល់អំពីការពិតនេះកាន់តែច្បាស់ប៉ុណ្ណា?

ឱព្រះយេស៊ូវ ទូលបង្គំជាកម្មសិទ្ធិរបស់ព្រះ និងជាសមាជិកមហាគ្រួសាររបស់ព្រះអង្គ ព្រោះទូលបង្គំជាកូនព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យ៉ាកុប ៣៨-៤០ និងកិច្ចការ ១៦:១-២១

ដែលមនុស្សលោកពិចារណាមើលទេ ឯមនុស្សលោក តែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ (១សាំយ៉ូអែល ១៦:៧)។

សូមព្រះអង្គពិនិត្យមើលចិត្តទូលបង្គំ

ដើម្បីកាត់បន្ថយការខ្ជះខ្ជាយផលិតផលអាហារ ក្រុមហ៊ុនផ្សាំទំនើបមួយ នៅប្រទេសសិង្ហបុរីបានលក់ផ្លែឈើ និងបន្លែដែលមានស្នាមជាំបន្តិចបន្តួច ក្នុងតម្លៃថោកជាងតម្លៃធម្មតា។ កម្មវិធីនេះបានកាត់បន្ថយការខ្ជះខ្ជាយផលិតផលអាហារបាន៧៧១តោន ដែលកាលពីមុន គេអាចបោះពួកវាចោល ដោយសារពួកវាមានសោភ័ណភាពដែលមិនគ្រប់ស្តង់ដារអាហារ។ មិនយូរប៉ុន្មាន អ្នកដើរទិញឥវ៉ាន់ក៏បានដឹងថា រូបរាងខាងក្រៅរបស់បន្លែ និងផ្លែឈើ ស្នាមឆ្កួត និងរូបរាងមិនស្អាត មិនបានធ្វើឲ្យប៉ះពាល់ដល់រស់ជាតិ និងជីវជាតិរបស់ពួកវាទេ។ គេមិនតែងតែអាចកំណត់អ្វីដែលមាននៅខាងក្នុង ផ្អែកទៅលើរូបរាងខាងក្រៅឡើយ។

ហោរា សាំយូអែល បានយល់អំពីបញ្ហាស្រដៀងនេះផងដែរ នៅពេលដែលព្រះអម្ចាស់ចាត់គាត់ ឲ្យទៅចាក់ប្រេងតាំងឲ្យស្តេចរបស់សាសន៍អ៊ីស្រាអែល ដែលត្រូវស្នងរាជបន្ទាប់ (១សាំយ៉ូអែល ១៦:១)។ កាលគាត់បានឃើញ អេលាប ជាកូនច្បងរបស់លោក អ៊ីសាយ គាត់គិតស្មានថា អេលាប ជាមនុស្សដែលព្រះអម្ចាស់បានជ្រើសរើស។ ប៉ុន្តែ ព្រះអង្គមានបន្ទូលថា «កុំឲ្យមើលតែឫកពាខាងក្រៅ ឬកំពស់ខ្លួននោះឡើយ ដ្បិតអញមិនទទួលអ្នកនេះទេ ពីព្រោះព្រះទ្រង់មិនទតចំពោះសេចក្ដី ដែលមនុស្សលោកពិចារណាមើលទេ ឯមនុស្សលោកតែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ» (ខ.៧)។ ក្នុងចំណោមកូនប្រុសទាំង៨នាក់ របស់លោក អ៊ីសាយ ព្រះអម្ចាស់បានជ្រើសរើស ដាវីឌ ជាកូនពៅ ដែលកំពុងឃ្វាលហ្វូងចៀម (ខ.១១) ឲ្យធ្វើជាស្តេច ដែលត្រូវឡើងស្នងរាជបន្ទាប់។

ព្រះអម្ចាស់យកព្រះទ័យទុកដាក់ ចំពោះចិត្តរបស់យើង ជាជាងរបស់ក្រៅខ្លួនដែលយើងមាន ដូចជា ការអប់រំ ប្រាក់ចំណូល ឬការងារស្ម័គ្រចិត្តដែលយើងបានធ្វើជាដើម។ ព្រះយេស៊ូវបានបង្រៀនសិស្សព្រះអង្គ ឲ្យផ្តោតទៅលើការសម្អាតចិត្តឲ្យបរិសុទ្ធ ដោយជម្រុះចោលភាពអាត្មានិយម និងគំនិតអាក្រក់ ព្រោះ «គឺជាសេចក្ដីដែលចេញពីមនុស្សមកទេតើ ដែលធ្វើឲ្យស្មោកគ្រោកនោះ» (ម៉ាកុស ៧:២០)។ ដូចនេះ ចូរយើងពិនិត្យមើលចិត្ត គំនិត និងគោលបំណងរបស់យើង ដោយជំនួយមកពីព្រះអង្គ ក្នុងគ្រប់ការអ្វីទាំងអស់ដែលយើងធ្វើ គឺដូចដែលហោរា សាំយូអែល មិនបានរៀនទុកចិត្តលើសប្បុកក្រៅរបស់មនុស្សទេ។

—Jasmine Gohr

តើអ្នកបានធ្វើ «ការល្អ» ដោយបំណងមិនល្អនៅពេលណា? តើធ្វើដូចម្តេចឲ្យអ្នកអាចដឹងច្បាស់ថា អ្នកបានធ្វើអ្វីមួយ ដោយចិត្តបរិសុទ្ធ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំ ឲ្យធ្វើអ្វីដែលថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរប្រចាំឆ្នាំ | យ៉ូប ៤១-៤២ និងកិច្ចការ ១៦:២២-៤០

តែព្រះគុណរបស់ព្រះអម្ចាស់នៃយើង បានចំរើនជាបរិបូរហូរហៀរឡើង ព្រមទាំងសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ ដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវផង (១ធីម៉ូថេ ១:១៤)។

ព្រះពរជាបរិបូរមកពីស្ថានសួគ៌

មានពេលមួយ ខ្ញុំបានបញ្ជាទិញផ្លែចេកអំបូង៨ផ្លែ។ ប៉ុន្តែ នៅពេលដែលខ្ញុំបើកមើលក្នុងថង់ឥវ៉ាន់ ដែលគេបានដឹកមកដល់ផ្ទះខ្ញុំ ខ្ញុំក៏បានឃើញផ្លែចេក២០ផ្លែ។ ភ្លាមៗនោះ ខ្ញុំក៏បានដឹងថា ការផ្លាស់ទីលំនៅរបស់ខ្ញុំទៅប្រទេសអង់គ្លេស គឺមានន័យថា ខ្ញុំបានផ្លាស់ប្តូរការបញ្ជាទិញទំនិញ ក្នុងទម្ងន់គិតជា ផោន ទៅជាគីឡូក្រាមវិញ។ ដូចនេះ ខ្ញុំស្មានថា ខ្ញុំបានបញ្ជាទិញផ្លែចេកទម្ងន់៣ផោន តាមពិតខ្ញុំមិនបានដឹងទេថា ខ្ញុំបានបញ្ជាទិញផ្លែចេក៣គីឡូក្រាម ដែលមានទម្ងន់ជិត៧ផោន។

ដោយសារខ្ញុំមានផ្លែចេកច្រើន ខ្ញុំក៏បានធ្វើនំប័ុងរស់ជាតិចេកជាច្រើនដុំ ដើម្បីចែករំលែកព្រះពរព្រះអង្គ ជាមួយអ្នកដទៃ។ នៅពេលដែលខ្ញុំកំពុងលាយម្សៅជាមួយផ្លែចេកអំបូង ខ្ញុំក៏បានចាប់ផ្តើមគិតអំពីផ្នែកដទៃទៀតនៃជីវិតខ្ញុំ ដែលខ្ញុំបានដកពិសោធន៍ជាមួយភាពពេញបរិបូរដែលមិនស្មានដល់ ហើយហើយព្រះអង្គបានប្រើផ្លូវនីមួយៗ នាំខ្ញុំងាកបែរទៅរកព្រះអង្គ។

សាវ័ក ប៉ុល ក៏ធ្លាប់បានជញ្ជឹងគិតអំពីព្រះពរជាបរិបូរក្នុងជីវិតគាត់ តាមរបៀបស្រដៀងនេះផងដែរ។ ក្នុងសំបុត្រដែលគាត់ផ្ញើទៅលោក ធីម៉ូថេ គាត់បានរៀបរាប់អំពីជីវិតគាត់ មុនពេលគាត់ទទួលជឿព្រះយេស៊ូវ ដោយហៅខ្លួនឯងថា “អ្នកប្រមាថ ធ្វើទុក្ខបៀតបៀន ហើយព្រហើនឈ្លានពាន” (១ធីម៉ូថេ ១:១៣) និងមនុស្សមានបាបអាក្រក់ផុតលេខ (ខ.១៦)។ ព្រះអម្ចាស់ក៏បានចាក់បង្ហូរព្រះគុណ សេចក្តីជំនឿ និងសេចក្តីស្រឡាញ់របស់ព្រះអង្គ ជាបរិបូរ ចូលក្នុងជីវិតគាត់ (ខ.១៤)។ បន្ទាប់ពីគាត់ បានរំឭកអំពីព្រះពរជាបរិបូរក្នុងជីវិតគាត់ហើយ គាត់ក៏បានថ្វាយការសរសើរតម្កើងដល់ព្រះអង្គ ដោយប្រកាសថា ព្រះអង្គស័ក្តិសមនឹងទទួលព្រះកិត្តិនាម និងសិរីល្អអស់កល្បជានិច្ចរៀងរាបតទៅ (ខ.១៧)។

យើងរាល់គ្នាក៏បានទទួលព្រះគុណដ៏ច្រើនលើសលប់ មិនខុសពីសាវ័ក ប៉ុល ទេ នៅពេលដែលយើងទទួលសេចក្តីសង្គ្រោះរួចពីបាប (ខ.១៥)។ ខណៈពេលដែលយើងឈប់បង្អង់ ដើម្បីជញ្ជឹងគិត អំពីព្រះពរជាច្រើនរាប់មិនអស់ យើងនឹងបានចូលរួមជាមួយសាវ័ក ប៉ុល ក្នុងការសរសើរតម្កើងដោយការអរព្រះគុណ ដល់ព្រះដ៏សប្បុរសនៃយើង។—Lisa M. Samra

តើអ្នកបានដកពិសោធន៍ជាមួយនឹងព្រះពរជាបរិបូរ ក្នុងជីវិតអ្នកដូចម្តេចខ្លះ? តើអ្នកអាចសរសើរតម្កើងព្រះអង្គ ដូចម្តេចខ្លះនៅថ្ងៃនេះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានអំណោយនៃព្រះគុណដ៏លើសលប់។

គម្រោងអានព្រះគម្ពីរអស់រយៈពេល១ឆ្នាំ | ទំនុកតម្កើង ១-៣ និងកិច្ចការ ១៧:១-១៥

ពីព្រោះព្រះទ្រង់នឹងនាំគ្រប់ការទាំងអស់មកដើម្បីជំនុំជំរះ ព្រមទាំងអ្វីៗដែលលាក់កំបាំងផង ទោះល្អឬអាក្រក់ក្តី (សាស្តា ១២:១៤)

បើកបង្ហាញបាបរបស់អ្នក

មានចោរម្នាក់បានលួចចូលក្នុងហាងជួសជុលទូរស័ព្ទមួយកន្លែង ដោយវាយបំបែកទូកញ្ចក់ដាក់តាំងទូរស័ព្ទ ហើយក៏បានចាប់ផ្តើមប្រមូលទូរស័ព្ទ និងសម្ភារៈមួយចំនួនទៀត ចូលក្នុងហោប៉ៅរបស់ខ្លួន។ គាត់បានព្យាយាមលាក់បាំងអត្តសញ្ញាណរបស់គាត់ មិនឲ្យគេមើលមុខគាត់ស្គាល់ក្នុងកាមេរ៉ាសុវត្ថិភាព ដោយគាត់បានយកប្រអប់ក្រដាសឡាំងមកគ្របក្បាលគាត់។ ប៉ុន្តែ ក្នុងអំឡុងពេលធ្វើសកម្មភាព ក្រដាសឡាំងនោះក៏បានរបើកចេញពីក្បាលគាត់ បានមួយភ្លែត ធ្វើឲ្យគេអាចមើលឃើញមុខគាត់។ ពីរបីនាទីក្រោយមក ក៏បានបើកមើលវីដេអូដែលកាមេរ៉ាសុវត្ថិភាពថតបានសកម្មភាពលួចរបស់ចោរនោះ ហើយក៏បានទូរស័ព្ទប្តឹងប៉ូលិស។ ប៉ូលិសក៏បានចាប់ខ្លួនចោរនោះ នៅក្រៅហាងមួយ នៅក្បែរនោះ។ រឿងនេះបានក្រើនរំឭកយើងថា អំពើបាបនីមួយៗដែលយើងមាន នឹងត្រូវបានបើកបង្ហាញនៅថ្ងៃណាមួយមិនខាន។

មនុស្សតែងតែព្យាយាមលាក់បាំងបាបរបស់ខ្លួន ដោយសារនិស្ស័យសាច់ឈាមរបស់ពួកគេ។ ប៉ុន្តែ កណ្ឌគម្ពីរសាស្តាបានចែងថា យើងត្រូវស្តាប់បង្គាប់តាមក្រឹត្យវិន័យរបស់ព្រះអម្ចាស់ អំពើបាបទាំងអស់ដែលយើងបានលាក់បាំង នឹងត្រូវបើកបង្ហាញ នៅចំពោះព្រះនេត្រដ៏សុចរិត និងការជំនុំជម្រះដ៏សុចរិតរបស់ព្រះអង្គ (១២:១៤)។ អ្នកនិពន្ធបានសរសេរថា «ចូរកោតខ្លាចដល់ព្រះ ហើយកាន់តាមបញ្ញត្តទ្រង់ចុះ ដ្បិតប៉ុណ្ណេះឯងជាកិច្ចទាំងមូលដែលមនុស្សត្រូវធ្វើ» (ខ.១៣)។ រាល់ការប្រព្រឹត្តទាំងអស់ ដែលក្រឹត្យវិន័យ១០ប្រការបានហាម (លេវីវិន័យ ៤:១៣) នឹងមិនអាចគេចផុតពីការជំនុំជម្រះរបស់ព្រះអង្គបានទេ។ ព្រះទ្រង់នឹងនាំគ្រប់ការទាំងអស់ទៅជំនុំជំរះ ព្រមទាំងអ្វីៗដែលលាក់កំបាំងផង ទោះល្អឬអាក្រក់ក្តី។ ប៉ុន្តែ ដោយសារព្រះគុណព្រះអង្គ យើងអាចរកឃើញការអត់ទោសបាប ក្នុងព្រះយេស៊ូវ និងក្នុងការលះបង់របស់ព្រះអង្គ ដើម្បីយើងរាល់គ្នា (អេភេសូរ ២:៤-៥)។

ពេលណាយើងបានស្គាល់ព្រះរាជបញ្ជារបស់ព្រះអង្គ ហើយកត់ទុកក្នុងចិត្តយើង ការនេះអាចនាំឲ្យយើងកោតខ្លាចព្រះអង្គ និងមានការស់នៅ ស្របតាមព្រះរាជបញ្ជាព្រះអង្គ។ ចូរយើងថ្វាយបាបរបស់យើងដល់ព្រះអង្គ ហើយដកពិសោធន៍ជាថ្មី ជាមួយព្រះទ័យរបស់ព្រះអង្គ ដែលមានក្តីស្រឡាញ់ និងការអត់ទោស។—Marvin Williams

តើអ្នកអាចបន្តកោតខ្លាចព្រះ យ៉ាងដូចម្តេចខ្លះ? តើធ្វើដូចម្តេច ឲ្យអ្នកអាចនឹកចាំព្រះរាជបញ្ជារបស់ព្រះអង្គ ក្នុងសប្តាហ៍នេះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមប្រែចិត្តចេញពីបាប ដែលទូលបង្គំបានលាក់បាំង។ សូមព្រះអង្គទតមើលទូលបង្គំ ដោយព្រះទ័យមេត្តា និងជួយទូលបង្គំរស់នៅ ឲ្យបានត្រឹមត្រូវ នៅចំពោះព្រះអង្គ។

Daily Manna 2026_Content Enhance.indd 199 17/11/25 1:45 in the afternoon

គេចាប់តាំងថ្វាយដង្វាយដុតដល់ព្រះយេហូវ៉ា គឺពីថ្ងៃដំបូង ក្នុងខែអស្សុជ តែជើងជញ្ជាំងរបស់ព្រះវិហារនៃព្រះយេហូវ៉ា មិនទាន់បានដាក់នៅឡើយ (អែសរ៉ា ៣:៦)។

ថ្វាយបង្គំព្រះអង្គ មុនពេលចាប់ផ្តើមការងារ

ខ្ញុំមិនដែលមានគម្រោងបង្កើតអង្គការមិនរកប្រាក់ចំណេញ ដែលធ្វើការ ក្នុងផ្នែកទំនាក់ទំនងរបស់មនុស្ស ពេញវ័យ ហើយនៅពេលដែលខ្ញុំមានអារម្មណ៍ថា ព្រះអង្គកំពុងត្រាស់ហៅខ្ញុំឲ្យធ្វើការងារនេះ ខ្ញុំមានសំណួរជាច្រើន។ តើខ្ញុំអាចទៅស្វែងរកប្រាក់ឧបត្ថម្ភសម្រាប់ការងារមនុស្សធម៌នេះ ដោយរបៀបណា ហើយនរណាគួរជួយខ្ញុំបង្កើតអង្គការនេះ? នៅពេលនោះ ខ្ញុំក៏បានទទួលជំនួយប្រសើរបំផុត សម្រាប់បញ្ហាទាំងនេះ មិនមែននៅក្នុងសៀវភៅរបស់គ្រូជោគជ័យ តែនៅក្នុងព្រះគម្ពីរ។

កណ្ឌគម្ពីរអែសរ៉ា បានផ្តល់ឲ្យនូវការបង្រៀនដែលមានប្រយោជន៍យ៉ាងខ្លាំង សម្រាប់អស់អ្នកដែលព្រះទ្រង់បានត្រាស់ហៅ ឲ្យសាងសង់អ្វីមួយថ្វាយព្រះអង្គ។ កណ្ឌគម្ពីរនេះបានកត់ទុកអំពីរបៀបដែលជនជាតិយូដាបានសាងសង់ទីក្រុងយេរូសាឡិមឡើងវិញ បន្ទាប់ពីពួកគេត្រូវសាសន៍ដទៃនិរទេសអស់ជាច្រើនឆ្នាំ ដោយបានឆ្លុះបញ្ចាំង អំពីរបៀបដែលព្រះអម្ចាស់បានផ្គត់ផ្គង់ផ្នែកហិរញ្ញវត្ថុ តាមរយៈការដាក់ជង្វាយរបស់ពួកបណ្តាជន និងប្រាក់ជំនួយរបស់ស្តេច (អែសរ៉ា ១:៤-១១ ៦:៨-១០) និងបានឆ្លុះបញ្ចាំងអំពីរបៀបដែលអ្នកស្មគ្រគិត្ត និងពួកជាងធ្វើការសាងសង់ (១:៥ ៣:៧)។ កណ្ឌអែសរ៉ាបានបង្ហាញអំពីសារៈសំខាន់នៃការទុកពេលសម្រាប់ធ្វើការរៀបចំការងារ ដោយពន្យារពេលការសាងសង់ រហូតដល់ឆ្នាំទីពីរនៃការវិលត្រឡប់របស់ប្រជាជនយូដាពីការនិរទេស (៣:៨)។ កណ្ឌគម្ពីរនេះក៏បានបង្ហាញអំពីការប្រឆាំងការសាងសង់ ដែលអាចកើតមាន (ជំពូក៤)។ ប៉ុន្តែ រឿងនេះមានចំណុចមួយ ដែលខ្ញុំមានការចាប់អារម្មណ៍ជាងគេ។

រយៈពេល១ឆ្នាំពេញ មុនពេលការសាងសង់ចាប់ផ្តើម ប្រជាជនយូដាបានសាងសង់អាសនាថ្វាយព្រះអម្ចាស់ (៣:១-៦)។ ពួកបណ្តាជនបានថ្វាយបង្គំព្រះអង្គ ទោះគេមិនទាន់បានសាងសង់គ្រឹះនៃព្រះវិហាររបស់ព្រះអង្គក៏ដោយ (ខ.៦)។ ដូចនេះ ពួកគេត្រូវមានការថ្វាយបង្គំ មុនពេលការសាងសង់ចាប់ផ្តើម។

តើព្រះអម្ចាស់កំពុងត្រាស់ហៅអ្នក ឲ្យចាប់ផ្តើមធ្វើកិច្ចការថ្មីឬទេ? គោលការណ៍របស់ហោរាអែសរ៉ានៅតែសំខាន់ ទោះអ្នកកំពុងចាប់ផ្តើមការងារមនុស្សធម៌ ការសិក្សាព្រះគម្ពីរជាក្រុម គម្រោងសាងសង់អ្វីមួយ ឬកិច្ចការថ្មីមួយនៅកន្លែងធ្វើការក៏ដោយ។ សូម្បីកិច្ចការដែលព្រះអង្គប្រទានយើង ក៏អាចបង្វែរការចាប់អារម្មណ៍របស់យើងចេញពីព្រះអង្គបានដែរ ហេតុនេះហើយ ចូរយើងផ្តោតទៅលើព្រះអង្គជាមុនសិន។ មុនពេលយើងធ្វើការងាររបស់យើង ចូរយើងថ្វាយបង្គំព្រះអង្គ។ —Sheridan Voysey

ហេតុអ្វីអ្នកគិតថា ជនជាតិយូដាត្រូវសាងសង់អាសនាជាមុនសិន? តើការថ្វាយបង្គំព្រះមានភាពចាំបាច់សម្រាប់ដំណើរការនៃការងាររបស់អ្នកនៅថ្ងៃនេះ ដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ ធ្វើជាព្រះអម្ចាស់លើអស់ព្រះអម្ចាស់ ដោយរាប់បញ្ចូលទាំងកិច្ចការដែលព្រះអង្គឲ្យទូលបង្គំធ្វើ នៅថ្ងៃនេះផងដែរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៧-៩ និងកិច្ចការ ១៨

ក៏ធៀបដូចជាទឹកសន្សើមនៅលើភ្នំហ៊ើម៉ូន ដែលធ្លាក់មកលើភ្នំនៃក្រុងស៊ីយ៉ូន (ទំនុកតម្កើង ១៣៣:៣)។

ការរួបរួមគ្នាក្នុងព្រះគ្រីស្ទ ដើម្បីការផ្លាស់ប្តូរ

បណ្ឌិត ទីហ្វានី ហ្គោលសិន (Dr. Tiffany Gholson) បានឃើញអំពើឧក្រិដ្ឋកម្មកំពុងមានផលប៉ះពាល់តាមរបៀបជាច្រើន មកលើទីក្រុងរបស់គាត់ គឺទីក្រុងសេនលូអ៊ីស ខាងកើត ជាទីក្រុងតូចមួយនៅរដ្ឋមីសសួរី សហរដ្ឋអាមេរិក។ ទោះជាយ៉ាងណាក៏ដោយ នៅឆ្នាំ២០២៣អំពើឃាតកម្មក្នុងទីក្រុងនេះបានធ្លាក់ចុះ៣១ភាគរយ ហើយអំពើឧក្រិដ្ឋកម្មជាទូទៅក៏បានថយចុះ៣៧ភាគរយផងដែរ។ តើរឿងនេះបានកើតឡើងដោយរបៀបណា? ការថយចុះនេះ គឺបណ្តាលមកពីការធ្វើការជាដៃគូរ។ អង្គការគ្រីស្ទបរិស័ទមួយ បានសហការជាមួយប៉ូលិសរដ្ឋ និងប៉ូលិសទីក្រុង និងសាលារៀន ដើម្បីបង្កើតក្រុមអនុវត្តន៍ច្បាប់ដើម្បីសុវត្ថិភាពសាធារណៈ ដោយរួមកម្លាំងគ្នាបង្កើតឲ្យមានការផ្លាស់ប្តូរ ដើម្បីប្រជាពលរដ្ឋទាំងអស់។

បណ្ឌិត ហ្គោលសិន ក៏បានលើកឡើងថា ការសហការគ្នានេះមានភាពស្មិតល្មួត គឺប្រៀបដូចជាការរៀបការជាប្តីប្រពន្ធ ដោយសមាជិកម្នាក់ៗនៃក្រុមការងារនេះរួបរួមគ្នាជាដៃគូ ដើម្បីជួយប្រជាពលរដ្ឋ។ មជ្ឈមណ្ឌលសុខភាពផ្លូវចិត្ត ជាសាលារៀនដែលគាត់កំពុងដឹកនាំ ក៏បានរាប់បញ្ចូលគ្រូបង្រៀនគិលានុបដ្ឋាយិកា និងបុគ្គលិករបស់សាលា នៅក្នុងការជួយទ្រទ្រង់កុមារ ដែលបានទទួលផលប៉ះពាល់ពីអំពើឧក្រិដ្ឋកម្ម ឬគ្រោះថ្នាក់ផ្សេងៗ។ ភ្នាក់ងារដទៃទៀត ក៏បានផ្តល់ជំនួយផ្សេងៗផងដែរ។ ប៉ូលិសបានប្តេជ្ញាចិត្តថា នឹងធ្វើការសន្ទនាបន្ថែមទៀតជាមួយប្រជាជននៅតាមដងផ្លូវ ហើយស្តាប់សំណើរបស់ពួកគេ។

ស្តេច ដាវីឌ ជាអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងបានពោលថា «មើល ដែលបងប្អូននៅមូលជាមួយគ្នា ដោយចិត្តព្រមត្រៀង នោះជាការល្អ ហើយសមគួរយ៉ាងណាទៅ» (ទំនុកតម្កើង ១៣៣:១)។ ទ្រង់មានបន្ទូលទៀតថា ការរួបរួមគ្នានេះ «ក៏ធៀបដូចជាទឹកសន្សើមនៅលើភ្នំហ៊ើម៉ូន ដែលធ្លាក់មកលើភ្នំនៃក្រុងស៊ីយ៉ូន ដ្បិតនៅទីនោះព្រះយេហូវ៉ាបានប្រទានព្រះពរ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច» (ខ.៣)។ ត្រង់ចំណុចនេះ ស្តេច ដាវីឌ កំពុងមានបន្ទូលសំដៅទៅលើមនុស្សដែលមានជំនឿតែមួយដ៏ត្រឹមត្រូវ ចំពោះព្រះអម្ចាស់។ យើងរួបរួមគ្នាជាឆ្អុងមួយ ទោះយើងមាននិន្នាការនយោបាយ និងស្ថិតនៅក្នុងក្រុមផ្សេងគ្នាក៏ដោយ។ ការរួបរួមនេះអាចពិបាកកើតមាន តែនឹងធ្វើជាព្រះពរដល់មនុស្សទាំងអស់។ គោលដៅដ៏ប្រសើររបស់អ្នកជឿ គឺត្រូវបង្ហាញការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក ជាពិសេសក្នុងទីក្រុង ដែលកំពុងស្រែកឃ្លានសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ។—Patricia Raybon

តើអ្នកមើលឃើញកន្លែងណាខ្លះ កំពុងខ្វះការរួបរួមគ្នា? តើព្រះអម្ចាស់អាចបណ្តាលចិត្តអ្នកដូចម្តេចខ្លះ ដើម្បីឲ្យអ្នកលើកកម្ពស់ការរួបរួមគ្នា ដោយបង្ហាញចេញនូវសេចក្តីជំនឿ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំ ដោយអំណាចនៃព្រះវិញ្ញាណព្រះអង្គ ដើម្បីឲ្យមានការរួបរួម ក្នុងសហគមន៍របស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ទំនុកតម្កើង ១០-១២ និងកិច្ចការ ១៩:១-២០

ចូរព្យាយាមក្នុងសេចក្តីអធិស្ឋាន ទាំងចាំយាមក្នុងសេចក្តីនោះឯង ដោយពាក្យអរព្រះគុណ (កូល៉ុស ៤:២)។

ព្យាយាមក្នុងការអធិស្ឋាន

ថ្ងៃមួយ ដូនចាស់ម្នាក់បានប្រាប់លោក លូ (Lu) ជាមិត្តភក្តិខ្ញុំថា «ខ្ញុំបានអធិស្ឋានឲ្យអ្នក៥០ឆ្នាំហើយ»។ មិត្តភក្តិខ្ញុំបានមើលមុខដូនចាស់ ដោយការដឹងគុណយ៉ាងខ្លាំង។ កាលនោះ មិត្តភក្តិខ្ញុំទៅលេងភូមិមួយនៅប្រទេសប៊ុលហ្គារី ជាកន្លែងដែលឪពុកគាត់បានចម្រើនវ័យធំឡើង ហើយបានចាកចេញក្នុងវ័យជំទង់។ ដូនចាស់ ជាអ្នកជឿព្រះយេស៊ូវ ជាអ្នកជិតខាងរបស់តាយាយរបស់លោក លូ។ គាត់បានចាប់ផ្តើមអធិស្ឋានឲ្យលោក លូ ចាប់តាំងពីពេលដែលគាត់បានទទួលដំណឹងថា លោក លូ បានចាប់កំណើតក្នុងប្រទេសនៅឯនាយសមុទ្រ។ សព្វថ្ងៃនេះ ប្រហែលពាក់កណ្តាលសតវត្សរ៍ក្រោយមកលោក លូ បានឈានចូលលេងភូមិនោះក្នុងការធ្វើដំណើរសម្រាប់មុខជំនួញរបស់គាត់ ហើយគាត់ក៏បានជជែកជាមួយមនុស្សមួយក្រុមនៅទីនោះ អំពីសេចក្តីជំនឿរបស់គាត់។ លោក លូ បានទទួលជឿព្រះយេស៊ូវ នៅពេលគាត់ជិតឈានចូលដល់វ័យ៣០ឆ្នាំ ហើយនៅពេលដែលដូនចាស់ចូលមកជិតគាត់ គាត់មានការភ្ញាក់ផ្អើល ចំពោះឥទ្ធិពលនៃការអធិស្ឋានដ៏ជាប់លាប់របស់ដូនចាស់ដែលបាននាំឲ្យគាត់ទទួលជឿព្រះយេស៊ូវ។

យើងមិនអាចដឹងច្បាស់ថា ការអធិស្ឋានរបស់យើងមានឥទ្ធិពលប៉ុណ្ណានៅលើផែនដីនេះទេ។ ប៉ុន្តែ ព្រះគម្ពីរបានបង្គាប់យើងថា «ចូរព្យាយាមក្នុងសេចក្តីអធិស្ឋាន ទាំងចាំយាមក្នុងសេចក្តីនោះឯង ដោយពាក្យអរព្រះគុណ» (កូល៉ុស ៤:២)។ កាលសាវ័ក ប៉ុល សរសេរពាក្យពេចន៍ទាំងអស់នេះ នៅក្នុងសំបុត្រផ្ញើទៅអ្នកជឿក្នុងទីក្រុងកូល៉ុស គាត់ក៏បានសូមឲ្យគេអធិស្ឋានឲ្យគាត់ផងដែរ ដើម្បីឲ្យព្រះអម្ចាស់ «បើកទ្វារ» ឲ្យគាត់ផ្សាយព្រះបន្ទូលនៅកន្លែងណាគាត់ទៅដល់ (ខ.៣)។

ជួនកាល យើងប្រហែលជាគិតថា យើងមិនមានអំណោយទាននៃការអធិស្ឋាន។ ប៉ុន្តែ ព្រះគម្ពីរបានរៀបរាប់អំពីអំណោយទានខាងវិញ្ញាណ ដែលមានដូចជា ការថ្លែងទំនាយ ការបង្រៀនជាដើម។ ប៉ុន្តែ ការអធិស្ឋានជាផ្នែកដ៏សំខាន់ក្នុងជីវិតរបស់គ្រីស្ទបរិស័ទម្នាក់ៗ និងនៅក្នុងការងារបម្រើព្រះ។ ព្រោះព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងអធិស្ឋានដោយចិត្តស្មោះត្រង់ ដើម្បីឲ្យយើងអាចមើលឃើញកិច្ចការ ដែលមានតែព្រះអង្គទេអាចធ្វើបាន។

—James Banks

តើអ្នកបានទទួលព្រះពរ ពីការអធិស្ឋានរបស់អ្នកដទៃដូចម្តេចខ្លះ? តើអ្នកកំពុងអធិស្ឋានឲ្យនរណាខ្លះក្នុងពេលសព្វថ្ងៃនេះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានសព្វព្រះទ័យស្តាប់ទូលបង្គំអធិស្ឋាន! សូមព្រះអង្គជួយទូលបង្គំ ឲ្យឱបក្រសោបយកឱកាសជជែកជាមួយព្រះអង្គ និងអធិស្ឋានឲ្យអ្នកដទៃនៅថ្ងៃនេះ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ទំនុកតម្កើង ១៣-១៥ និងកិច្ចការ ១៩:២១-៤១

ពាក្យនេះគួរជឿពិត ដ្បិតបើយើងបានស្លាប់ជាមួយនឹងទ្រង់ នោះយើងនឹងរស់នៅជាមួយនឹងទ្រង់ដែរ (២ធីម៉ូថេ ២:១១)។

ដំណឹងល្អដែលស័ក្តិសមនឹងឲ្យយើងអបអរ

បទចំនុកសកលមានចំណងជើងថា «ឱ ខ្ញុំចង់បានអណ្តាត១ពាន់» (បទលេខ១៥) មានវត្តមានដំបូងបំផុតនៅក្នុងសៀវភៅចំនុកតម្កើងរបស់ពួកជំនុំមេតូឌីស ដែលគិតមកដល់សព្វថ្ងៃ គឺជាង២សតវត្សរ៍មកហើយ។ បទចម្រៀងនេះ ជាស្នាដៃនិពន្ធរបស់លោក ឆាល វេសលី (Charles Wesley) និងពីដើមឡើយមានចំណងជើងថា «ថ្ងៃខួបនៃការប្រែចិត្តជឿព្រះ»។ គាត់បាននិពន្ធចំនុកសកលនេះ ដើម្បីរំឭកខួបនៃការកើតជាថ្មីរបស់គាត់ ដោយការផ្លាស់ប្រែស៊ីជម្រៅ ដោយសារសេចក្តីជំនឿលើព្រះយេស៊ូវ។ បទចម្រៀងនេះមាន១៨ឈ្នះ ដែលបានប្រកាសអំពីសិរីល្អនៃសេចក្តីល្អរបស់ព្រះ ដល់អ្នកដែលប្រែចិត្ត និងដើរតាមព្រះគ្រីស្ទ។

ការមានសេចក្តីជំនឿដូចនេះ គឺស័ក្តិសមនឹងឲ្យយើងអបអរ និងចែកចាយដល់អ្នកដទៃ។ ក្នុងបទគម្ពីរ២ធីម៉ូថេ ជំពូក២ សាវ័ក ប៉ុល បានលើកទឹកចិត្តលោក ធីម៉ូថេ ឲ្យនៅតែឈរមាំក្នុងសេចក្តីជំនឿ និងមានការស៊ូទ្រាំនៅក្នុងការចែកចាយសេចក្តីជំនឿ។ គាត់បានកត់សម្គាល់ថា នេះជា «ដំណឹងល្អដែលខ្ញុំផ្សាយប្រាប់ ហើយខ្ញុំរងទុក្ខទាំងជាប់ចំណងដូចជាមនុស្សអាក្រក់ ដោយព្រោះដំណឹងល្អនោះឯង» (ខ.៨-៩)។ សាវ័ក ប៉ុល បានធ្វើការសម្រេចចិត្តធ្វើការបម្រើព្រះ ដោយគ្មានការសង្ស័យ ហើយបានរំឭកលោក ធីម៉ូថេ ឲ្យចាំព្រះរាជសារនៃដំណឹងល្អដែលប្រកាសថា «ព្រះយេស៊ូវគ្រីស្ទ ជាព្រះវង្សហ្លួងដាវីឌ ទ្រង់បានរស់ពីស្លាប់ឡើងវិញ» (ខ.៨) ព្រះអង្គបានយាងមកប្រសូតជាមនុស្ស មិនមែនដើម្បីគ្រប់គ្រង តែដើម្បីបម្រើ ហើយទីបំផុត ព្រះអង្គសុគត ដើម្បីលោះយើងឲ្យរួចពីបាប ដើម្បីឲ្យយើងអាចផ្សះផ្សាទំនាក់ទំនងជាមួយព្រះ។ សេចក្តីស្លាប់មិនបានឈ្នះទេ ព្រោះបីថ្ងៃក្រោយទ្រង់សុគត ព្រះអង្គមានព្រះជន្មរស់ឡើងវិញ។

ព្រះបន្ទូលដែលជាដំណឹងល្អរបស់ព្រះអង្គនាំមកនូវសេរីភាព ដល់អ្នកណាដែលជឿ ហើយព្រះបន្ទូលក៏មិនដែលជាប់ច្រវាក់ដែរ។ ហេតុនេះហើយ សាវ័ក ប៉ុល មានប្រសាសន៍ថា «ព្រះបន្ទូលមិនបានជាប់ចំណងទេ» (ខ.៩) សូម្បីតែនៅក្នុងកន្លែង ដែលសេចក្តីស្លាប់ហាក់ដូចជាបានឈ្នះ ដែលមានដូចជា គុក មន្ទីរពេទ្យ និងកន្លែងបញ្ចុះសពជាដើម។ ក្នុងព្រះគ្រីស្ទ មានសេចក្តីសង្ឃឹមដល់មនុស្សទាំងអស់។ នេះជាដំណឹង ដែលស័ក្តិសមនឹងឲ្យយើងអបអរទាំងអស់គ្នា!—Matt Lucas

តើអ្នកអបអរដំណឹងល្អរបស់ព្រះយេស៊ូវ ក្នុងការរស់នៅប្រចាំថ្ងៃដូចម្តេចខ្លះ? តើអ្នកអាចចែកចាយដំណឹងល្អនេះ ដល់នរណាខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានសង្គ្រោះទូលបង្គំ និងប្រទានទូលបង្គំនូវឱកាសចែកចាយដំណឹងល្អដល់មនុស្សគ្រប់គ្នា។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ទំនុកតម្កើង ១៦-១៧ និងកិច្ចការ ២០:១-១៦

ក្នុងគ្រាដែលទូលនឹងផារ៉ោន នោះម៉ូសេលោកបានអាយុ៨០ឆ្នាំ ឯអើរ៉ុន ក៏បានអាយុ៨៣ឆ្នាំហើយ (និក្ខមនំ ៧:៧)។

ព្រះអង្គនៅតែអាចប្រើយើង

មានដួនចាស់ពីរនាក់ មកពីរដ្ឋតិចសាស់ មានឈ្មោះល្បីល្បាញយ៉ាងខ្លាំងក្នុងវេទិកាបណ្តាញសង្គម ដោយសារពួកគាត់បានបញ្ចប់ការធ្វើដំណើរជុំវិញពិភពលោកក្នុងរយៈពេល៨០ថ្ងៃ ក្នុងវ័យ៨១ឆ្នាំ។ ដួនចាស់ទាំងពីរបានរាប់អានគ្នាជាមិត្តល្អបំផុតអស់រយៈពេល២៣ឆ្នាំហើយ ដោយបានធ្វើដំណើរជាមួយគ្នាទៅកាន់ទ្វីបទាំង៧។ ពួកគាត់បានចាប់ផ្តើមការធ្វើដំណើរពីទ្វីបអង់តាកទិច ហើយទៅរាំចង្វាក់តង់ហ្គោ នៅប្រទេសអាហ្សង់ទីន ជិះសត្វអូដ្ឋនៅប្រទេសអេស៊ីព្ទ រួចជិះគោវទឹកកក នៅតំបន់ប៉ូលខាងជើង។ ពួកគាត់បានទៅដល់១៨ប្រទេស ដែលក្នុងចំណោមនោះ ក៏រួមមានប្រទេសហ្ស៊ីមបាវ៉េ តង់ហ្សានេប៉ាល់ ប៉ាលី ជប៉ុន និងទីក្រុងរ៉ូមផងដែរ ហើយក៏បានបញ្ចប់ការធ្វើដំណើរក្នុងប្រទេសអូស្ត្រាលី។ អ្នកទាំងពីរមានប្រសាសន៍ថា ពួកគាត់សង្ឃឹមថាពួកគាត់បានបណ្តាលចិត្តមនុស្សជំនាន់ក្រោយ ឲ្យអរសប្បាយនឹងការធ្វើដំណើរជុំវិញពិភពលោកផងដែរ ទោះពួកគេស្ថិតក្នុងវ័យណាក៏ដោយ។

ក្នុងបទគម្ពីរនិក្ខមនំ យើងឃើញថា មានបុគ្គលពីរនាក់ស្ថិតក្នុងវ័យ៨០ឆ្នាំ ដែលព្រះអម្ចាស់បានជ្រើសរើសសម្រាប់ការធ្វើដំណើរប្រភេទផ្សេងពីនេះ។ ព្រះអង្គបានត្រាស់ហៅលោក ម៉ូសេ ឲ្យទៅចូលគាល់ស្តេច ផារ៉ោន ហើយទាមទារឲ្យទ្រង់ដោះលែងប្រជាជនអ៊ីស្រាអែល ជារាស្ត្ររបស់ព្រះអង្គ ឲ្យមានសេរីភាព។ ព្រះអង្គក៏បានចាត់បងប្រុសរបស់លោក ម៉ូសេ ឈ្មោះអើរ៉ុន ធ្វើជាជំនួយការរបស់គាត់។ «ក្នុងគ្រាដែលទូលនឹងផារ៉ោន នោះម៉ូសេលោកបានអាយុ៨០ឆ្នាំ ឯអើរ៉ុនក៏បានអាយុ៨៣ឆ្នាំហើយ» (និក្ខមនំ ៧:៧)។

ការត្រាស់ហៅនេះ ហាក់ដូចជាមិនស័ក្តិសមនឹងអាយុរបស់ពួកគេសោះ ប៉ុន្តែព្រះអម្ចាស់បានជ្រើសរើសបងប្អូនទាំងពីរនាក់ ឲ្យធ្វើបេសកកម្មនេះ ហើយពួកគេក៏បានធ្វើតាមបង្គាប់របស់ព្រះអង្គ។ គឺដូចមានសេចក្តីចែងថា «ម៉ូសេ និងអើរ៉ុនក៏ចូលទៅគាល់ផារ៉ោន ហើយបានធ្វើតាមបង្គាប់ព្រះយេហូវ៉ា» (ខ.១០)។

លោក ម៉ូសេ និងលោក អើរ៉ុន មានកិត្តិយស និងឯកសិទ្ធិ ដែលបានមើលឃើញព្រះអម្ចាស់រំដោះរាស្ត្រព្រះអង្គ ឲ្យរួចពីភាពជាទាសកររំដែលមានរយៈពេល៤រយឆ្នាំ។ បុរសទាំងពីរគឺជាភស្តុតាងបញ្ជាក់ថា ព្រះអម្ចាស់អាចប្រើយើង ទោះយើងស្ថិតក្នុងវ័យណាក៏ដោយ។ ទោះយើងនៅក្មេង ឬចាស់ ចូរយើងដើរតាមព្រះអង្គ ទោះព្រះអង្គនាំយើងទៅណាក៏ដោយ។—Nancy Gavilanes

តើអ្នកបានឃើញព្រះអម្ចាស់មានសេចក្តីស្មោះត្រង់ក្នុងជីវិតអ្នក យ៉ាងណាខ្លះ? តើអ្នកអាចបម្រើព្រះអង្គក្នុងរដូវកាលនេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យដើរតាមព្រះអង្គពេញមួយជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 204 17/11/25 1:46 in the afternoon

គេនឹងហើរឡើងទៅលើ ដោយស្លាប ដូចជាឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ (អេសាយ ៤០:៣១)។

ព្រះអង្គប្រទានកម្លាំងជាថ្មី

សត្វឥន្ទ្រី១គូ បានសង់សំបុកធំមួយនៅលើដើមឈើមួយដើម ស្ថិតនៅចម្ងាយពីរបីគីឡូម៉ែត្រពីផ្ទះខ្ញុំ។ មិនយូរប៉ុន្មាន សត្វស្លាបធំៗមួយគូរនោះក៏មានកូន។ ពួកវាបានចិញ្ចឹមកូនដែលទើបតែញាស់ជាមួយគ្នា រហូតដល់ពេលដែលពួកវាត្រូវឡានបុកងាប់អស់មួយក្បាល យ៉ាងសោកសៅ។ សត្វឥន្ទ្រីដែលនៅមានជីវិតក៏បានហោះហើរចុះឡើងអស់បួនប្រាំថ្ងៃនៅក្បែរទន្លេមួយ គឺហាក់ដូចជាកំពុងស្វែងរកដៃគូរបស់វា ដែលបាត់មិនឃើញត្រឡប់មកសំបុកវិញ។ ទំបំផុត វាក៏បានវិលត្រលប់មកសំបុកវាវិញតែម្នាក់ឯង ហើយបន្តទទួលខុសត្រូវទាំងស្រុងនៅក្នុងការចិញ្ចឹមកូនៗរបស់វាតែម្នាក់ឯង។

ទោះស្ថិតក្នុងស្ថានភាពណាក៏ដោយ ការចិញ្ចឹមកូនតែម្នាក់ឯង អាចមានការលំបាកខ្លាំង។ ក្តីអំណរដែលកូនបានផ្តល់ឲ្យ រួមផ្សំនឹងសំពាធផ្នែកហិរញ្ញវត្ថុ និងសំពាធផ្លូវអារម្មណ៍ដែលអាចកើតមាន អាចបង្កើតឲ្យមានបទពិសោធន៍ខុសៗគ្នាជាច្រើន។ ប៉ុន្តែ សេចក្តីសង្ឃឹមនៅតែអាចកើតមានសម្រាប់អ្នកដែលមានតួនាទីដ៏សំខាន់នេះ ក៏ដូចជាអ្នកដែលព្យាយាមគ្រប់គ្រងស្ថានភាព ដែលហាក់ដូចជាពិបាកខ្លាំងពេក។

ព្រះអម្ចាស់គង់នៅជាមួយយើង ពេលណាយើងមានអារម្មណ៍អស់កម្លាំង និងបាក់ទឹកចិត្ត។ ដោយសារព្រះអង្គមានគ្រប់ព្រះចេស្តា និងមិនចេះប្រែប្រួល នោះព្រះអង្គមិនចេះអស់កម្លាំងឡើយ។ យើងអាចទុកចិត្តលើបទគម្ពីរដែលបានចែងថា «អស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំឡាំងចំរើនជានិច្ច» (អេសាយ ៤០:៣១)។ ភាពកម្សោយរបស់យើង អាចនាំឲ្យយើងមានបញ្ហាប្រឈម តែភាពកម្សោយទាំងនោះមិនមែនជាអ្នកកំណត់ជោគវាសនារបស់យើងទេ ព្រោះយើងអាចពឹងផ្អែកលើកម្លាំង ដែលព្រះអង្គនឹងប្រទានយើងជាថ្មី ដោយការអស្ចារ្យ។ ការមានក្តីសង្ឃឹមដល់ព្រះអង្គជួយឲ្យយើងដើរ ដោយមិនខ្សោះអស់កម្លាំង ព្រមទាំងហើរឡើងទៅលើ ដោយស្លាប ដូចសត្វឥន្ទ្រី (ខ.៣១)។—Jennifer Benson Schuldt

តើមានបញ្ហាអ្វីដែលធ្វើឲ្យអ្នកមានអារម្មណ៍ពិបាកពេក ក្នុងជីវិត? តើព្រះអម្ចាស់អាចលើកទឹកចិត្តអ្នកឲ្យពឹងផ្អែកលើកម្លាំងមកពីព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ទូលបង្គំមិនអាចគ្រប់គ្រងជីវិតទូលបង្គំ ដោយខ្លួនឯងបានទេ។ ទូលបង្គំត្រូវការព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យមានកម្លាំងជាថ្មី នៅថ្ងៃនេះ។

Daily Manna 2026_Content Enhance.indd 205 17/11/25 1:46 in the afternoon

យើងមានទ្រព្យសម្បត្តិនេះនៅក្នុងភាជន:ដី ដើម្បីឲ្យឥទ្ធិឫទ្ធិលើសលប់បានមកពីព្រះ មិនមែនពីយើងខ្ញុំទេ (២កូរិនថូស ៤:៧)។

ភាពប្រេះបែកដែលបានធ្វើជាព្រះពរ

លោកគ្រូគង្វាល វីលៀម បារប័រ (William Barber) មានខ្នងកោង ហើយពេលទៅណាមកណាគាត់ត្រូវដើរកាន់ឈើច្រត់ ប៉ុន្តែការងារជាអ្នកគង្វាលខាងវិញ្ញាណអស់រយៈពេល៦ទសវត្សរ៍បង្ហាញឲ្យយើងដឹងថា គាត់បានពឹងផ្អែកលើព្រះអង្គធ្វើជាប្រភពនៃកម្លាំងរបស់គាត់។ កាលពីឆ្នាំ១៩៩៣ លោកគ្រូគង្វាល វីលៀម បារប័រ បានទៅពិនិត្យសុខភាពរកឃើញថា គាត់មានជំងឺឆ្អឹងខ្នងម៉្យាង ដែលបណ្តាលឲ្យឆ្អឹងកងខ្នងរបស់គាត់សង្កត់ជាប់គ្នា។ មានពេលមួយ មានមនុស្សម្នាក់បាននិយាយប្រាប់គាត់ត្រង់ៗថា «លោកគ្រូ បារប័រ លោកគ្រូចាំបាច់ត្រូវស្វែងរកការងារផ្សេង ក្រៅពីការងារជាគ្រូគង្វាល ព្រោះខ្ញុំគិតថា ពួកជំនុំមិនចង់ឲ្យជនពិការធ្វើការជាគ្រូគង្វាលរបស់ពួកគេនោះទេ»។ ប៉ុន្តែ លោកគ្រូ បារប័រ បានជម្នះពាក្យសម្តីដ៏ឈឺចាប់នេះ។ ព្រះអម្ចាស់មិនគ្រាន់តែបានប្រើគាត់ជាគ្រូគង្វាលប៉ុណ្ណោះទេ តែគាត់ក៏បានធ្វើជាគំរូនៃការលើកទឹកចិត្តដ៏មានអំណាច និងគួរឲ្យគោរពសម្រាប់មនុស្សដែលគេមិនឲ្យតម្លៃ និងមានកាយសម្បទាមិនគ្រប់គ្រាន់។

លោកីយ៍ប្រហែលមិនដឹងច្បាស់ថា មនុស្សត្រូវប្រព្រឹត្តចំពោះជនពិការដូចម្តេចទេ តែព្រះអម្ចាស់ជ្រាប។ មនុស្សដែលឲ្យតម្លៃមកលើរូបសម្រស់ កម្លាំងកាយ និងអ្វីៗដែលលុយអាចទិញបាន និងងាយមើលរំលងសេចក្តីល្អ ដែលកើតចេញពីភាពប្រេះបែកដែលមនុស្សមិនចង់ជួប។ ទាក់ទងនឹងបញ្ហានេះ កណ្ឌគម្ពីរយ៉ាកុបបានចោទជាសំណួរថា «តើព្រះមិនបានរើសពួកអ្នកក្រនៅលោកីយ៍នេះ ដែលជាអ្នកមានខាងសេចក្តីជំនឿ ហើយជាអ្នកគ្រងមរដកក្នុងនគរ ដែលទ្រង់បានសន្យាទុក ឲ្យពួកអ្នកដែលស្រឡាញ់ទ្រង់ទេឬអី?» (យ៉ាកុប ២:៥)។ ពេលណាបញ្ហាសុខភាព កម្លាំង ឬអ្វីផ្សេងទៀតមានការអន់ថយ សេចក្តីជំនឿរបស់យើងមិនចាំបាច់ត្រូវថយចុះនោះទេ។ តែជំនឿយើងអាចកើនឡើង ដោយសារកម្លាំងមកពីព្រះអម្ចាស់។ ចំណុចខ្វះខាតរបស់យើង អាចជាកត្តាជំរុញយើងឲ្យទុកចិត្តព្រះអង្គ។ ព្រះអង្គអាចប្រើភាពប្រេះបែក ឬភាពកម្សោយរបស់យើង ជាប្រយោជន៍ដល់ពិភពលោករបស់យើង។—Arthur Jackson

តើអ្នកមានភាពកម្សោយ ឬភាពប្រេះបែក យ៉ាងណាខ្លះ? តើភាពកម្សោយរបស់អ្នក អាចឲ្យព្រះអង្គប្រើជាឧបករណ៍ដើម្បីលើកទឹកចិត្តអ្នកដទៃដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ ទោះទូលបង្គំមានភាពកម្សោយយ៉ាងណាក៏ដោយ។

Daily Manna 2026_Content Enhance.indd 206 17/11/25 1:46 in the afternoon

ទោះទាំងសេចក្តីស្លាប់ ហើយនឹងជីវិតក៏នៅក្នុងអំណាចនៃអណ្តាតដែរ (សុភាសិត ១៨:២១)។

មិនមើលស្រាលឥទ្ធិពលនៃពាក្យសម្តី

ប្រើងស្ទើរតែមិនដែលឮថា មានស្ថាប័នណាមួយចេញមុខទទួលស្គាល់កំហុស បន្ទាប់ពីមានសោកនាដកម្ម កើតឡើងក្នុងសង្គម។ ប៉ុន្តែ នៅឆ្នាំមួយនោះ បន្ទាប់ពីសិស្សអាយុ១៧ឆ្នាំម្នាក់បានបាត់បង់ជីវិត ដោយការធ្វើអត្តឃាត សាលារៀនមួយដែលមានឈ្មោះល្បីបានទទួលស្គាល់ថា ខ្លួនមានការខកខាន មិនបានការពារគាត់។ សិស្សម្នាក់នោះត្រូវគេធ្វើបាបឥតឈប់ឈរនៅសាលារៀន ហើយថ្នាក់ដឹកនាំសាលា មិនបានធ្វើអ្វីច្រើនដើម្បីការពារគាត់ឡើយ ទោះបានដឹងអំពីការធ្វើទុក្ខបុកម្នេញដែលគាត់បានទទួលរងក៏ដោយ។ សព្វថ្ងៃនេះ សាលារៀននោះបានប្តេជ្ញាចិត្តចាត់វិធានការប្រយុទ្ធប្រឆាំងការធ្វើទុក្ខបុកម្នេញ និងបង្កើនការយកចិត្តទុកដាក់ចំពោះសុខភាពផ្លូវចិត្តរបស់សិស្សទាំងអស់។

ការខូចខាតដែលបានបង្កឡើង ដោយសារការធ្វើទុក្ខបុកម្នេញ គឺបានឆ្លុះបញ្ចាំងយ៉ាងច្បាស់ អំពីអំណាចនៃពាក្យសម្តី។ កណ្ឌគម្ពីរសុភាសិតបានបង្រៀនយើង មិនឲ្យមើលស្រាលឥទ្ធិពលនៃពាក្យសម្តី ព្រោះ «ទោះទាំងសេចក្តីស្លាប់ ហើយនឹងជីវិតក៏នៅក្នុងអំណាចនៃអណ្តាតដែរ» (សុភាសិត ១៨:២១)។ ពាក្យសម្តីរបស់យើងអាចលើកទឹកចិត្តអ្នកដទៃ ហើយក៏អាចធ្វើឲ្យគេបាក់ទឹកចិត្តផងដែរ។ ជាងនេះទៅទៀត ពាក្យសម្តីដ៏សាហាវអាចជាកត្តា ដែលបណ្តាលឲ្យមនុស្សឈានទៅដល់សេចក្តីស្លាប់។

តើយើងអាចនាំមកនូវជីវិត តាមរយៈពាក្យសម្តីរបស់យើង ដោយរបៀបណា? ព្រះគម្ពីរបានបង្រៀនយើងថា ពាក្យសម្តីរបស់យើងហូរចេញពីប្រាជ្ញា ក៏ដូចជាភាពល្ងង់ខ្លៅរបស់យើង (១៥:២)។ យើងរកឃើញប្រាជ្ញាពេលណាយើងចូលមកជិតព្រះអម្ចាស់ ដែលជាប្រភពនៃប្រាជ្ញា ដែលមានអំណាចនាំមកនូវជីវិត (៣:១៣, ១៧-១៩)។

យើងរាល់គ្នាមានការទទួលខុសត្រូវក្នុងការប្រើពាក្យសម្តី និងសកម្មភាពរបស់យើង បានជាយើងមិនត្រូវមើលស្រាលឥទ្ធិពលនៃពាក្យសម្តីរបស់យើង ហើយចៃរក្សា និងការពារមនុស្ស ដែលបានរងរបួសដោយសារពាក្យសម្តីរបស់អ្នកដទៃ។ ពាក្យសម្តីអាចសម្លាប់ ប៉ុន្តែពាក្យពេចន៍ប្រកបដោយក្តីអាណិត ក៏អាចនាំមកនូវការប្រោសឲ្យជាព្រមទាំងធ្វើជា «ដើមឈើនៃជីវិត» (១៥:៤) ដល់មនុស្សជុំវិញយើង។—Monica La Rose

តើអ្នកបានឃើញពាក្យសម្តីឥតបើគិត បណ្តាលឲ្យមានការខូចខាតអ្វីខ្លះ? តើអ្នកអាចបង្ហាញសេចក្តីអាណិតរបស់ព្រះតាមរយៈពាក្យសម្តីរបស់អ្នកដូចម្តេចខ្លះ?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គជួយទូលបង្គំ កុំឲ្យមើលស្រាលឥទ្ធិពលនៃពាក្យសម្តី តែពឹងផ្អែកលើព្រះអង្គ ដើម្បីនិយាយអ្វី ដែលនាំមកនូវជីវិត។

Daily Manna 2026_Content Enhance.indd 207 17/11/25 1:46 in the afternoon

មានមនុស្សសន្ធឹកណាស់ បានចំរើនដល់ព្រះអម្ចាស់ (កិច្ចការ ១១:២៤)។

គោលដៅដែលព្រះអម្ចាស់សព្វព្រះទ័យ

កាលពីថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៣ លោក គ្រីសជិន អាតស៊ូ (Christian Atsu) បានទាត់បាល់បញ្ចូលទី ធ្វើឲ្យក្រុមបាល់ទាត់របស់គាត់ទទួលបានជ័យជម្នះក្នុងការប្រកួត ក្នុងប្រទេសទួរគី។ តារាបាល់ទាត់អន្តរជាតិម្នាក់នេះ បានរៀនលេងកីឡានេះតាំងពីក្មេង ដោយគ្មានស្បែកជើងពាក់ ក្នុងស្រុកកំណើតគាត់ នៅប្រទេសហ្គាណា។ លោក អាត់ស៊ូ ជាអ្នកជឿព្រះយេស៊ូវ។ គាត់ថា ទំនាក់ទំនងដែលគាត់មានជាមួយព្រះយេស៊ូវ គឺជារឿងល្អបំផុតដែលបានកើតឡើង ក្នុងជីវិតគាត់។ លោក អាត់ស៊ូ បានបង្ហោះខគម្ពីរនៅលើបណ្តាញសង្គម និងបាននិយាយអំពីជំនឿរបស់គាត់ ដោយបើកចំហ ហើយបានបង្ហាញចេញនូវសេចក្តីជំនឿរបស់គាត់ ដោយជួយសាងសង់សាលារៀនសម្រាប់ក្មេងកំព្រាជាដើម។

រយៈពេល១ថ្ងៃ បន្ទាប់ពីគាត់បានទាល់បាល់បញ្ចូលទី ដែលនាំឲ្យក្រុមគាត់ទទួលបានជ័យជម្នះ គ្រោះរញ្ជួយដីធំមួយបានកើតឡើងនៅទីក្រុងអានតាក់យ៉ា ដែលកាលពីមុនជាទីក្រុងអាន់ទីយ៉ូក ដែលមានចែងក្នុងព្រះគម្ពីរ។ អគារខុនដូរបស់លោក អាត់ស៊ូ ក៏បានដួលរលំ ហើយគាត់ក៏បានលាចាកលោក ទៅជាមួយជាព្រះអង្គសង្គ្រោះរបស់គាត់នៅថ្ងៃនោះ។

កាលពីជាង២ពាន់ឆ្នាំមុន ទីក្រុងអាន់ទីយ៉ូក មានតួនាទីដ៏សំខាន់នៅក្នុងការរីកសុះសាយនៃពួកជំនុំដំបូង «គឺនៅអាន់ទីយ៉ូកនេះឯង ដែលគេហៅពួកសិស្សថា «ពួកគ្រីស្ទាន» ជាមុនដំបូង» (កិច្ចការ ១១:២៦)។ កាលនោះ លោកបាណាបាស ជាសិស្សម្នាក់ ដែល «ជាមនុស្សល្អ ពេញជាព្រះវិញ្ញាណបរិសុទ្ធ និងសេចក្តីជំនឿ» (ខ.២៤) បានធ្វើជាឧបករណ៍ដ៏សំខាន់ក្នុងការនាំមនុស្សជាច្រើនឲ្យទទួលជឿព្រះគ្រីស្ទនៅសម័យនោះ (ខ.២១)។

យើងសិក្សាអំពីជីវិតរបស់លោក គ្រីសជិន អាតស៊ូ មិនមែនដើម្បីលើកគាត់ជាអាយឧលរបស់យើងនោះទេ តែដើម្បីរៀនសូត្រពីគំរូរបស់គាត់។ ទោះជីវិតយើងស្ថិតក្នុងកាលៈទេសៈណាក៏ដោយ យើងមិនដឹងថា ព្រះអម្ចាស់នឹងនាំយើងទៅនៅជាមួយព្រះអង្គនៅពេលណាទេ។ យើងចាំបាច់ត្រូវសួរខ្លួនឯងថា តើយើងអាចបង្ហាញសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ ដល់អ្នកដទៃ តាមគំរូរបស់ពួកជំនុំដំបូងនៅទីក្រុងអាន់ទីយ៉ូក ដោយរបៀបណា។ សរុបមក នេះជាគោលដៅនៃជីវិតដែលមានភាពជោគជ័យខាងវិញ្ញាណ។—Kenneth Petersen

តើយើងអាចធ្វើអ្វីខ្លះ ដើម្បីបង្ហាញសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដល់អ្នកដទៃ? តើអ្នកអាចស្វែងរកឱកាស ដើម្បីជជែកអំពីព្រះយេស៊ូវ យ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គប្រទានទូលបង្គំនូវឱកាស ដើម្បីចែកចាយជំនឿរបស់ទូលបង្គំដល់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 208 17/11/25 1:46 in the afternoon

ឯអ្នកណាដែលចេះធ្វើល្អ តែមិនធ្វើសោះ នោះរាប់ជាបាបដល់អ្នកនោះវិញ (យ៉ាកុប ៤:១៧)។

ធ្វើជាឧបករណ៍នៃការផ្លាស់ប្តូរ

ក្រិដ្ឋជនម្នាក់ត្រូវបានប៉ូលិសចាប់ខ្លួន ហើយប៉ូលិសក៏បានសួរគាត់ថា ហេតុអ្វីគាត់ហ៊ានប្រើអំពើហិង្សាមកលើជនរងគ្រោះ នៅចំពោះមុខមនុស្សជាច្រើនដូចនេះ។ គេមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលបានឮគាត់សារភាពថា «ខ្ញុំដឹងថា ពួកគេគ្រាន់តែឈរមើល មិនហ៊ានធ្វើអ្វីទេ»។ ពាក្យសម្តីរបស់គាត់បានឆ្លុះបញ្ចាំង អំពី «ការដឹង ដែលមានកំហុស» បានសេចក្តីថា ពួកគេបានសម្រេចចិត្តមិនអើពើចំពោះអំពើឧក្រិដ្ឋ ដែលពួកគេបានដឹងថា នរណាម្នាក់កំពុងប្រព្រឹត្ត។

សាវ័ក យ៉ាកុប បានលើកឡើងអំពីការដឹងដែលមានកំហុសផងដែរ គឺដូចដែលគាត់មានប្រសាសន៍ថា «ឯអ្នកណាដែលចេះធ្វើល្អ តែមិនធ្វើសោះ នោះរាប់ជាបាបដល់អ្នកនោះវិញ» (យ៉ាកុប ៤:១៧)។

តាមរយៈសេចក្តីសង្គ្រោះដែលព្រះអង្គបានប្រទានយើង ព្រះអង្គបានរៀបចំយើង ធ្វើជាភ្នាក់ងារនៃសេចក្តីល្អក្នុងលោកីយ៍នេះ។ កណ្ឌគម្ពីរ អេភេសូរ ២:១០ បានបញ្ជាក់ថា «ដ្បិតយើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្ទយេស៊ូវសំរាប់ការល្អ ដែលព្រះបានរៀបចំជាមុន ឲ្យយើងរាល់គ្នាប្រព្រឹត្តតាម»។ យើងបានសង្គ្រោះមិនមែនដោយសារការល្អរបស់យើង តែផ្ទុយទៅវិញ ការល្អដែលយើងធ្វើ កើតចេញពីចិត្តដែលព្រះវិញ្ញាណបរិសុទ្ធបានកែប្រែ ដោយគង់នៅក្នុងជីវិតយើង។ ព្រះវិញ្ញាណថែមទាំងបានប្រទានយើង នូវអំណោយទានខាងវិញ្ញាណ ដើម្បីប្រទានលទ្ធភាពឲ្យយើងអាចសម្រេចកិច្ចការ ដែលព្រះអង្គបានបង្កើតយើងមក ដើម្បីឲ្យយើងធ្វើ (មើល ១កូរិនថូស ១២:១-១១)។

ក្នុងនាមយើងជាស្នាព្រះហស្តដ៏ល្អឯករបស់ព្រះអង្គ ចូលយើងចុះចូលបំណងព្រះទ័យព្រះអង្គ និងអំណាចរបស់ព្រះវិញ្ញាណបរិសុទ្ធ ដើម្បីឲ្យយើងអាចធ្វើជាឧបករណ៍នាំមកនូវការផ្លាស់ប្តូរ ក្នុងលោកីយ៍ ដែលកំពុងស្រែកឃ្លានរកព្រះអង្គ។—Bill Crowder

សូមអំឡុកបទគម្ពីរ ១កូរិនថូស ១២:១-១១ ហើយអានអំពីអំណោយទានខាងវិញ្ញាណ។ តើមានអំណោយទានអ្វីខ្លះ ដែលព្រះវិញ្ញាណបរិសុទ្ធបានប្រទានអ្នក? តើអ្នកអាចប្រើអំណោយទានទាំងនោះយ៉ាងដូចម្តេចខ្លះ?

ឱព្រះនៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់សេចក្តីសង្គ្រោះដែលព្រះអង្គប្រទានជាអំណោយឥតគិតថ្លៃនៃព្រះគុណ។ សូមព្រះអង្គប្រទានទូលបង្គំនូវចិត្តក្លាហាន និងប្រាជ្ញា ដើម្បីឲ្យចេះបម្រើព្រះអង្គ និងអ្នកដទៃ ឲ្យបានល្អបំផុត។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៣១-៣២ និងកិច្ចការ ២៣:១៦-៣៥

រួចយកកូនគោដែលបំប៉នមកសំឡាប់ចុះ យើងនឹងបរិភោគឲ្យសប្បាយចិត្ត (លូកា ១៥:២៣)។

ពេលដែលត្រូវអបអរ

ព្រះវិហារដែលគ្រួសារខ្ញុំធ្លាប់ទៅចូលរួមថ្វាយបង្គំព្រះ ក្នុងរដ្ឋវើជីនា បានធ្វើពិធីបុណ្យជ្រមុជទឹកក្នុងទន្លេរីណា ដែលជាញឹកញាប់ ព្រះអាទិត្យបញ្ចេញកម្តៅក្តៅល្មម តែទឹកទន្លេមានសីតុណ្ហភាពត្រជាក់ស្ទើរកក។ បន្ទាប់ពីកម្មវិធីថ្វាយបង្គំព្រះនៅថ្ងៃអាទិត្យបានបញ្ចប់ យើងក៏បានធ្វើដំណើរតាមរថយន្តតូចធំ ទៅកាន់សួនច្បារមួយកន្លែងរបស់ទីក្រុង ដែលនៅទីនោះ ប្រជាជនរស់នៅតំបន់ជិតខាងបានមកលេងកីឡាកម្សាន្ត ហើយក្មេងៗកំពុងរត់លេងក្នុងសួនកុមារ យ៉ាងសប្បាយរីករាយ។ នេះជាទិដ្ឋភាពដែលគួរឲ្យចង់ទស្សនាកម្សាន្តនៅមាត់ទន្លេ ក្នុងការសម្រាកពីការហត់នឿយពីការងារ។ ពេលខ្ញុំឈរនៅក្នុងទឹកដែលត្រជាក់ដូចទឹកកក ខ្ញុំក៏បានអានខគម្ពីរ រួចជ្រមុជគេទៅក្នុងទឹកម្តងម្នាក់ៗ ធ្វើជានិមិត្តរូបបង្ហាញពីសេចក្តីស្រឡាញ់របស់ព្រះ។ ពេលពួកគេងើបពីទឹកឡើង ដោយខ្លួនទទឹកជោគ ពួកជំនុំក៏បានបន្លឺសម្លេងអបអរ ដោយស្នូរទះដៃ។ ពេលពួកគេឡើងច្រាំង មិត្តភក្តិ និងក្រុមគ្រួសារក៏បានឱបពួកគេ ធ្វើឲ្យទទឹកខ្លួនទាំងអស់គ្នា។ យើងមាននំខេក ភេសជ្ជៈ និងអាហារសម្រន់សម្រាប់ញ៉ាំជាមួយគ្នា។ មនុស្សដែលមកលំហែកាយនៅក្បែរនោះ មិនសុទ្ធតែយល់ អំពីអ្វីដែលយើងកំពុងធ្វើនោះទេ តែពួកគេដឹងថា យើងកំពុងធ្វើពិធីអបអរ។

ក្នុងបទគម្ពីរលូកា រឿងកូនពៅវង្វេង ដែលព្រះយេស៊ូវបានចែកចាយ (ខ.១១-៣២) បានឆ្លុះបញ្ចាំងអំពីមូលហេតុ ដែលគេធ្វើពិធីអបអរ នៅពេលដែលនរណាម្នាក់វិលត្រឡប់មករកព្រះអម្ចាស់វិញ។ ពេលណានរណាម្នាក់ទទួលជឿព្រះអង្គ ការអបអរក៏បានកើតមាន។ កាលកូនប្រុសដែលចាកចេញពីឪពុកបានវិលត្រឡប់មកផ្ទះវិញភ្លាមៗនោះ ឪពុកគាត់ក៏បានប្រញាប់ប្រាប់គេឲ្យយកខោអាវស្អាតៗ ចិញ្ចៀនដ៏ចែងចាំង និងស្បែកជើងថ្មីៗមកឲ្យគាត់។ គាត់ប្រាប់អ្នកបម្រើថា «រួចយកកូនគោដែលបំប៉នមកសំឡាប់ចុះ យើងនឹងបរិភោគឲ្យសប្បាយចិត្ត» (ខ.២៣)។ ពិធីជប់លៀងក៏បានចាប់ផ្តើម ដោយមានមនុស្សជាច្រើនចូលរួម ដោយសារការវិលត្រឡប់របស់គាត់ មានភាពស័ក្តិសមនឹងឲ្យគេធ្វើពិធីអបអរ (ខ.២៤)។—Winn Collierr

តើអ្នកបានឃើញការផ្លាស់ប្រែ និងការប្រោសឲ្យជា កើតមាននៅកន្លែងណា? តើគេគួរតែធ្វើការអបអរដូចម្តេចខ្លះ នៅពេលនោះ?

ឱព្រះអម្ចាស់ ទូលបង្គំមានរឿងជាច្រើនដែលត្រូវអបអរ ដោយសារក្តីអំណរដែលបានបង្ហូរចេញពីព្រះអង្គ និងកិច្ចការដែលព្រះអង្គធ្វើក្នុងជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 210 17/11/25 1:46 in the afternoon

ទ្រង់ជាទីពឹងពំនាក់ ជាបន្ទាយនៃទូលបង្គំ គឺជាព្រះនៃទូលបង្គំហើយ ទូលបង្គំទុកចិត្តនឹងទ្រង់ (*ទំនុកតម្កើង ៩១:២*)។

កន្លែងជ្រកកោនពិតប្រាកដក្នុងព្រះអង្គ

បន្ទាប់ពីភរិយារបស់លោក ហ្វ្រេដ (Fred) បានទទួលមរណៈភាព គាត់មានអារម្មណ៍ថា គាត់អត់ទ្រាំនឹងការឈឺចាប់នៃការបាត់បង់នេះបាន ដរាបណា គាត់នៅតែអាចអាចញ៉ាំអាហារពេលព្រឹករៀងរាល់ថ្ងៃចំនួនជាមួយមិត្តភក្តិគាត់។ មិត្តភក្តិរបស់គាត់ដែលបានចូលនិវត្តន៍ដូចគាត់ដែរ បានលើកទឹកចិត្តគាត់យ៉ាងខ្លាំង។ ពេលណាការសោកសង្រេងវិលត្រឡប់មករកគាត់ទៀត គាត់ក៏បានគិតអំពីភាពសប្បាយរីករាយដែលគាត់នឹងមានជាមួយពួកគេ នៅពេលបន្ទាប់ទៀត។ គាត់មានអារម្មណ៍ថា កន្លែងអង្គុយដែលគាត់មាននៅក្បែរពួកគេក្នុងពេលជួបជុំគ្នា គឺជាកន្លែងកម្សាន្តចិត្តដែលជួយឲ្យគាត់មានអារម្មណ៍ធូរស្បើយពីទុក្ខសោកទាំងឡាយ។

ទោះជាយ៉ាងណាក៏ដោយ ពេលវេលាបានកន្លងផុតទៅ ការជួបជុំគ្នាក៏លែងមានទៀត ដោយមិត្តភក្តិគាត់ខ្លះមានជំងឺ ខ្លះបានលាចាកលោក។ ភាពចន្លោះប្រហោងក្នុងចិត្តគាត់ ក៏បាននាំគាត់ឲ្យទៅស្វែងរកការកម្សាន្តចិត្តនៅក្នុងព្រះអម្ចាស់ ដែលគាត់ធ្លាប់បានជឿក្នុងវ័យយុវជន។ គាត់មានប្រសាសន៍ថា «សព្វថ្ងៃនេះ ខ្ញុំញ៉ាំអាហារពេលព្រឹកតែម្នាក់ឯង តែខ្ញុំតែងតែនឹកចាំថា ព្រះយេស៊ូវតែងតែគង់នៅជាមួយខ្ញុំជានិច្ច។ ហើយពេលណាខ្ញុំដើរចេញពីកន្លែងញ៉ាំអាហារពេលព្រឹក ខ្ញុំមិនបានដើរចេញ ដើម្បីប្រឈមមុខដាក់បញ្ហាតែម្នាក់ឯង នៅពេលបន្ទាប់ក្នុងថ្ងៃនីមួយៗទៀតទេ»។

លោក ហ្វ្រេដ បានរកឃើញសុវត្ថិភាព និងការកម្សាន្តចិត្ត ក្នុងព្រះវត្តមានព្រះអង្គ ដូចអ្នកនិពន្ធបទគម្ពីរទំនុកតម្កើង ពោលថា «ទ្រង់ជាទីពឹងពំនាក់ ជាបន្ទាយនៃទូលបង្គំ គឺជាព្រះនៃទូលបង្គំហើយ ទូលបង្គំទុកចិត្តនឹងទ្រង់» (ទំនុកតម្កើង ៩១:២)។ លោក ហ្វ្រេដ ក៏បានដឹងថា កន្លែងមានសុវត្ថិភាព មិនមែនជាទីកន្លែងសម្រាប់លាក់ពួនខាងសាច់ឈាមនោះទេ តែជាព្រះវត្តមានដ៏ស្ថិតស្ថេររបស់ព្រះអម្ចាស់ ដែលយើងអាចទុកចិត្ត និងចូលសម្រាកនៅក្នុងព្រះអង្គ (ខ.១)។ លោក ហ្វ្រេដ និងអ្នកនិពន្ធទំនុកតម្កើងសុទ្ធតែបានដឹងថា ពួកគេមិនចាំបាច់ប្រឈមមុខដាក់ទុក្ខលំបាក ក្នុងថ្ងៃនីមួយៗ តែម្នាក់ឯងនោះឡើយ។ ពេលណាយើងងាកមករកព្រះអង្គ ដោយសេចក្តីជំនឿ ព្រះអង្គបានសន្យាថា នឹងឆ្លើយតបចំពោះយើង ហើយគង់នៅជាមួយយើង (ខ.១៤-១៦)។

តើយើងមានកន្លែងកម្សាន្តចិត្ត នៅពេលណាយើងមានទុក្ខលំបាកក្នុងជីវិតទេ? ទុក្ខលំបាករបស់យើងមិនស្ថិតស្ថេរ តែព្រះអម្ចាស់ស្ថិតស្ថេរអស់កល្ប។ ព្រះអង្គរង់ចាំយើង ចូលទៅរកព្រះអង្គ ជាកន្លែងជ្រកកោនពិតប្រាកដរបស់យើង។—Karen Huang

ពេលណាជីវិតអ្នកមានទុក្ខលំបាក តើអ្នកមានកន្លែងកម្សាន្តចិត្តដែរឬទេ? តើអ្នកអាចងាកមករកព្រះអង្គដោយទុកចិត្តថា ព្រះអង្គជាទីជ្រកកោន យ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ព្រះអង្គជាកន្លែងជ្រកកោន ដែលមានការកម្សាន្តចិត្ត។ ព្រះវត្តមានព្រះអង្គមិនដែលចាកចេញពីទូលបង្គំ ឲ្យនៅឯកោឡើយ។ សូមព្រះអង្គហ៊ុមព័ទ្ធទូលបង្គំ ដោយជំនួយ និងការការពារជានិច្ច។

គម្រោងអានព្រះគម្ពីរប្រចាំឆ្នាំ ១ឆ្នាំ | ទំនុកតម្កើង ៣៥-៣៦ និងកិច្ចការ ២៥

ដ្បិតទ្រង់មានព្រះបន្ទូលថា «អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ» (ហេព្រើរ ១៣:៥)។

រស់នៅស្របតាមបំណងព្រះទ័យព្រះអង្គ

មនុស្សរាប់ពាន់នាក់បានអធិស្ឋានឲ្យលោកគ្រូគង្វាល អ៊ែដ បប់សិន (Ed Dobson) នៅពេលដែលគាត់ទៅពិនិត្យសុខភាពរកឃើញថា គាត់មានជំងឺក្រិនសរសៃឈាមអាមីតូត្រូហ្វីក កាលពីឆ្នាំ២០០០។ មនុស្សជាច្រើនជឿថា ពេលណាពួកគេអធិស្ឋាន ដោយជំនឿ សូមការព្រោះឲ្យជា ព្រះអម្ចាស់មុខជានឹងឆ្លើយតបភ្លាម។ មិនខាន។ គាត់បានតយុទ្ធនឹងជំងឺនេះអស់រយៈពេល១២ឆ្នាំ ដែលបានបណ្តាលឲ្យសាច់ដុំគាត់រួញស្វិតបន្តិចម្តងៗ (និងមានរយៈពេល៣ឆ្នាំ មុនពេលគាត់ទទួលមរណៈភាព)។ ពេលនោះ មានគេសួរគាត់ថា ហេតុអ្វីព្រះអម្ចាស់មិនទាន់បានព្រោះគាត់ឲ្យជា។ គាត់ក៏បានឆ្លើយថា «ខ្ញុំមិនបានដឹងច្បាស់ថា ហេតុអ្វីព្រះអង្គមិនទាន់ប្រោសខ្ញុំឲ្យជាទេ ដូចនេះខ្ញុំក៏មិនបានសួរព្រះអង្គដែរ»។ ពេលនោះ អ្នកស្រី ឡូណា (Lorna) ជាភរិយារបស់គាត់ ក៏បានមានប្រសាសន៍បន្ថែមពីលើសម្តីរបស់គាត់ថា «បើអ្នកតែងតែមានចិត្តងប់ងុលនឹងការស្វែងរកចម្លើយពីព្រះ អ្នកនឹងមិនអាចរស់នៅ ឲ្យបានត្រឹមត្រូវតាមបំណងព្រះហឫទ័យរបស់ព្រះអង្គឡើយ»។

តើអ្នកអាចមើលឃើញពាក្យសម្តីរបស់លោក អ៊ែដ និងអ្នកស្រីឡូណា បង្ហាញការគោរពដល់ព្រះអង្គដែរឬទេ? ពួកគាត់ដឹងថា ប្រាជ្ញារបស់ព្រះអង្គ ខ្ពស់ជាងប្រាជ្ញារបស់ពួកគាត់។ តែលោក អែដ បានទទួលស្គាល់ថា គាត់ស្ទើតែមិនអាចឈប់ព្រួយបារម្ភអំពីថ្ងៃស្អែក។ គាត់ដឹងថា ជំងឺនេះបានបណ្តាលឲ្យគាត់មានពិការភាពកាន់តែធ្ងន់ធ្ងរឡើងៗ ហើយគាត់មិនដឹងថា នៅថ្ងៃបន្ទាប់គាត់នឹងជួបបញ្ហាអ្វីទៀតទេ។

ដើម្បីឲ្យគាត់អាចផ្តោតទៅលើពេលអនាគត លោក អ៊ែដ ក៏បានដាក់ខគម្ពីរក្នុងឡានរបស់គាត់នៅលើកញ្ចក់ឆ្លុះមុខក្នុងបន្ទប់ទឹក និងនៅក្បែរគ្រែដេងរបស់គាត់ ដែលបានបន្តក្រើនរំឭកគាត់យ៉ាងដូចនេះថា «ដ្បិតទ្រង់មានព្រះបន្ទូលថា «អញនឹងមិនចាកចេញពីឯង ក៏មិនបោះបង់ចោលឯងឡើយ» បានជាយើងរាល់គ្នាអាចនឹងនិយាយដោយក្លាហានថា «ខ្ញុំមិនព្រមខ្លាចឡើយ ព្រោះព្រះអម្ចាស់ទ្រង់ជាជំនួយខ្ញុំ» (ហេព្រើរ ១៣:៥-៦)។ ពេលណាគាត់ចាប់ផ្តើមមានការព្រួយបារម្ភ គាត់ក៏បានរំឭកខគម្ពីរទាំងនេះ ដើម្បីឲ្យគាត់ផ្តោតគំនិតទៅលើសេចក្តីពិតដែលមានចែងក្នុងខគម្ពីរទាំងនោះ។

គ្មាននរណាដឹងថា ថ្ងៃស្អែកនឹងមានរឿងអ្វីកើតឡើងទេ។ តាមរយៈទីបន្ទាល់របស់លោក អ៊ែដ យើងអាចរៀនសូត្របានថា ពេលណាយើងជួបទុក្ខលំបាក យើងអាចទូលសូមព្រះអង្គជួយយើងកែប្រែការព្រួយបារម្ភ ឲ្យក្លាយជាឱកាសដើម្បីទុកចិត្តព្រះអង្គ។—Anne Cetas

មានខគម្ពីរណាខ្លះ ដែលបានជួយអ្នកឲ្យផ្តោតទៅលើពេលថ្ងៃនេះ និងមិនព្រួយបារម្ភអំពីថ្ងៃស្អែក? តើអ្នកអាចយកខគម្ពីរនោះទៅបិទនៅកន្លែងណា ដើម្បីជួយឲ្យជំនឿអ្នកមានការចម្រើនឡើង?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យចាំថា ព្រះអង្គជាព្រះដែលគង់នៅជាមួយទូលបង្គំជានិច្ច។ សូមព្រះអង្គបង្រៀនទូលបង្គំឲ្យទុកចិត្តព្រះអង្គ។

គម្រោងអានព្រះគម្ពីរអស់រយៈពេល១ឆ្នាំ | ទំនុកតម្កើង ៣៧-៣៩ និងកិច្ចការ ២៦

ដ្បិតទោះបើឯងលាងខ្លួនដោយក្បុង ហើយប្រើសាប៊ូជាច្រើនក៏ដោយ គង់តែព្រះអម្ចាស់យេហូវ៉ាទ្រង់មានព្រះបន្ទូលថា អំពើទុច្ចរិតរបស់ឯង នៅមានកត់ជាប់ចំពោះអញនៅឡើយដែរ (យេរេមា ២:២២)។

ព្រះយេស៊ូវលាងជម្រះស្នាមប្រឡាក់

មានពេលមួយ បន្ទាប់ពីខ្ញុំបានសម្លុតខោអាវ បន្ទាប់ពីបោកគក់ហើយ ខ្ញុំក៏បានប្រមូលខោអាវរបស់ខ្ញុំចេញពីម៉ាស៊ីនសម្លុត ហើយខ្ញុំមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពេលដែលបានឃើញអាវរបស់ខ្ញុំមានស្នាមប្រឡាក់។

អាវពណ៌សរបស់ខ្ញុំមានស្នាមទឹកបិច ដែលបានហៀចេញមក ធ្វើឲ្យខោអាវខ្ញុំប្រឡាក់ចេញស្នាមអុចៗធំៗដូចខ្លារខិន។ ច្បាស់ណាស់ ខ្ញុំមិនបានពិនិត្យមើលហោបៅអាវរបស់ខ្ញុំ ហើយបិចដែលហៀទឹកក៏បានធ្វើឲ្យប្រឡាក់ខោអាវទាំងអស់ នៅក្នុងម៉ាស៊ីនសម្លុត។

ព្រះគម្ពីរច្រើនតែប្រើពាក្យប្រឡាក់ ដើម្បីពិពណ៌នាអំពីបាប។ ស្នាមប្រឡាក់នៅជាប់នៅលើសាច់ក្រណាត់ធ្វើឲ្យក្រណាត់នោះខូច។ ហេតុនេះហើយ ព្រះអម្ចាស់ក៏បានមានបន្ទូលតាមរយៈហោរាយេរេមា ដោយពិពណ៌នាអំពីបាប ដោយរំឭករាស្ត្រព្រះអង្គថា ស្នាមប្រឡាក់នោះ គឺលើសពីលទ្ធភាពដែលពួកគេអាចសម្អាតដោយខ្លួនឯងបាន។ គឺដូចដែលព្រះអង្គមានបន្ទូលថា «ដ្បិតទោះបើឯងលាងខ្លួនដោយក្បុង ហើយប្រើសាប៊ូជាច្រើនក៏ដោយ គង់តែព្រះអម្ចាស់យេហូវ៉ាទ្រង់មានព្រះបន្ទូលថា អំពើទុច្ចរិតរបស់ឯងនៅមានកត់ជាប់ចំពោះអញនៅឡើយដែរ» (យេរេមា ២:២២)។

តែអរព្រះគុណព្រះអង្គ ដែលបានប្រទានផ្លូវឲ្យយើងអាចរួចពីបាប។ ក្នុងបទគម្ពីរអេសាយ ១:១៨ ព្រះអម្ចាស់បានសន្យាថា ព្រះអង្គនឹងលាងសម្អាតស្នាមប្រឡាក់របស់បាបដែលយើងមាន គឺដូចដែលព្រះអង្គបានមានបន្ទូលថា «មកចុះ យើងនឹងពិភាក្សាជាមួយគ្នា ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិម: ទោះបើក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ»។

ខ្ញុំមិនអាចលាងជម្រះស្នាមទឹកបិចនៅលើអាវពណ៌សបានទេ។ ខ្ញុំក៏មិនអាចលាងជម្រះស្នាមប្រឡាក់របស់បាបខ្ញុំដែរ។ អរព្រះគុណព្រះអង្គ ដែលបានលាងសម្អាតយើងក្នុងព្រះគ្រីស្ទ គឺដូចដែលបទគម្ពីរ ១យ៉ូហាន ១:៩ បានសន្យាថា «បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង»។—Adam R. Holz

តើអ្នកបានឆ្លងកាត់ការអត់ទោសបាប និងការលាងសម្អាតឲ្យរួចពីបាបក្នុងជីវិតអ្នកដូចម្តេចខ្លះ? តើអ្នកនៅមាន «ស្នាមប្រឡាក់» អ្វីខ្លះ ដែលត្រូវនាំថ្វាយដល់ព្រះអម្ចាស់?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យប្រកាន់ខ្ជាប់ព្រះបន្ទូលសន្យា ដែលបានចែងថា ក្នុងព្រះគ្រីស្ទមានការអត់ទោសបាប និងសេចក្តីបរិសុទ្ធ ពេលណាទូលបង្គំបានទទួលការលាងសម្អាតឲ្យស្អាតនៅចំពោះព្រះអង្គ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ទំនុកតម្កើង ៤០-៤២ និងកិច្ចការ ២៧:១-២៦

ឯយើងវិញវិញ យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន (១យ៉ូហាន ៤:១៩)។

បម្រើព្រះតាមមធ្យោបាយតូចមួយ

កាលអ្នកស្រី អែលស៊ី (Elsie) ទទួលរងការវាយប្រហារពីជំងឺមហារីក គាត់បានត្រៀមខ្លួនជាស្រេច ដើម្បីទៅរស់នៅជាមួយព្រះយេស៊ូវក្នុងនគរស្ថានសួគ៌។ ប៉ុន្តែ គាត់បានជាពីជំងឺដ៏កាចសាហាវនេះ ទោះវាបានធ្វើឲ្យគាត់ពិការមិនអាចផ្លាស់ទីដោយខ្លួនឯងក៏ដោយ។ គាត់ក៏បានឆ្ងល់ផងដែរថា ហេតុអ្វីព្រះអម្ចាស់បានទុកជីវិតឲ្យគាត់រស់នៅបន្តទៀត។ គាត់ក៏បានទូលសួរព្រះអង្គថា «តើទូលបង្គំអាចធ្វើអ្វីបាន? ទូលបង្គំមិនមានលុយឬជំនាញច្រើនទេ ហើយក៏មិនអាចដើររួចដែរ។ តើធ្វើដូចម្តេចឲ្យទូលបង្គំអាចមានប្រយោជន៍ សម្រាប់ព្រះអង្គ?»

បន្ទាប់មក គាត់ក៏បានរកឃើញមធ្យោបាយតូចមួយ ដើម្បីបម្រើអ្នកដទៃ ជាពិសេសអ្នកស៊ីឈ្នួលបោសសម្អាតផ្ទះគាត់ ដែលជាជនអន្តោប្រវេសន៍។ គាត់បានឲ្យអាហារ និងប្រាក់ពីរបីដុល្លាដល់ពួកគេ ពេលណាគាត់បានជួបពួកគេ។ ប្រាក់កាសទាំងនេះតិចតួចមែន តែបានរួមចំណែកជួយបំពេញតម្រូវការរបស់ពួកគេ។ ខណៈពេលដែលគាត់បានជួយអ្នកដទៃយ៉ាងដូចនេះ គាត់ក៏បានឃើញព្រះអង្គផ្គត់ផ្គង់គាត់ ដោយមិត្តភក្តិ និងសាច់ញាតិរបស់គាត់បានឲ្យអំណោយ និងប្រាក់កាសមួយចំនួនដល់គាត់ ដោយបានជួយឲ្យគាត់បន្តធ្វើជាព្រះពរសម្រាប់អ្នកដទៃទៀត។

កាលអ្នកស្រីអែលស៊ី ចែកចាយរឿងនេះ ខ្ញុំក៏បានគិតឃើញថា គាត់កំពុងតែអនុវត្តតាមការត្រាស់ហៅឲ្យស្រឡាញ់គ្នាទៅវិញទៅមក ដូចមានចែងក្នុងបទគម្ពីរ ១យ៉ូហាន ៤:១៩ យ៉ាងដូចនេះថា «ឯយើងរាល់គ្នាយើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន» ក៏ដូចជាស្របតាមសេចក្តីពិតក្នុងបទគម្ពីរ កិច្ចការ ២០:៣៥ ដែលបានរំឭកយើងថា «ដែលឲ្យ នោះមានពរជាងទទួល»។

អ្នកស្រីអែលស៊ីបានចែករំលែកដល់អ្នកដទៃ បន្ទាប់ពីគាត់បានទទួលជំនួយ ហើយការចែករំលែកនេះ ក៏បានលើកទឹកចិត្តគាត់ផងដែរ។ គាត់មិនមានប្រាក់កាសច្រើន ដើម្បីចែករំលែកដល់អ្នកដទៃ តែគាត់មានចិត្តពេញដោយក្តីស្រឡាញ់ការអរព្រះគុណព្រះ និងបានត្រៀមខ្លួនជាស្រេច ដើម្បីចែករំលែកអ្វីដែលគាត់មាន ដល់អ្នកដទៃ ហើយព្រះអម្ចាស់ក៏បានប្រទានព្រះពរជាពហុគុណនៅក្នុងវដ្តនៃការឲ្យ និងការទទួលប្រកបដោយក្តីស្រឡាញ់។ ចូរយើងទូលសូមព្រះអង្គប្រទានពរយើង ឲ្យមានចិត្តដែលអរព្រះគុណ និងសប្បុរស ដើម្បីចែករំលែកដល់អ្នកដទៃ តាមដែលព្រះអង្គបណ្តាលចិត្តយើង!—Leslie Koh

តើអ្នកបានទទួលអ្វីខ្លះ ពីព្រះអម្ចាស់? តើអ្នកអាចលើកទឹកចិត្តនរណាម្នាក់ តាមរបៀបដ៏សាមញ្ញ និងមានន័យយ៉ាងដូចម្តេចខ្លះ នៅថ្ងៃនេះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានអំណោយជាច្រើន ក្នុងជីវិតទូលបង្គំ។ សូមព្រះអង្គប្រទានទូលបង្គំនូវចិត្តដែលស្រឡាញ់អ្នកដទៃ ដូចដែលព្រះអង្គស្រឡាញ់ទូលបង្គំ។

Daily Manna 2026_Content Enhance.indd 214 17/11/25 1:46 in the afternoon

ឱពួកអ្នកបរិសុទ្ធរបស់ទ្រង់អើយ ចូរច្រៀងសរសើរដល់ព្រះយេហូវ៉ាចុះ (ទំនុកតម្កើង ៣០:៤)។

ការថ្វាយបង្គំ ដែលកែប្រែចិត្ត

មានពេលមួយ អ្នកស្រីស៊ូស៊ី (Susy) អង្គុយយំនៅខាងក្រៅបន្ទប់សង្គ្រោះបន្ទាន់ ដោយការភ័យខ្លាចយ៉ាងខ្លាំងមិនដឹងថាត្រូវធ្វើអ្វី។ កូនរបស់គាត់អាយុទើបតែ២ខែ មានទឹកចូលសួត។ ក្រុមគ្រូពេទ្យបានប្រាប់គាត់ថា ពួកគេនឹងប្រឹងប្រែងឲ្យអស់លទ្ធភាព ដើម្បីជួយសង្គ្រោះគាត់ តែមិនអាចធានាបានទេ។ នៅពេលនោះ គាត់ក៏បានមានអារម្មណ៍ថា ព្រះវិញ្ញាណកំពុងធ្វើការក្នុងចិត្តគាត់យ៉ាងស្រទន់ ដោយក្រើនរំឭកគាត់ ឲ្យថ្វាយបង្គំព្រះ។ ដោយសារគាត់គ្មានកម្លាំងសម្រាប់ច្រៀង គាត់ក៏បានបើកទូរស័ព្ទចាក់បទចម្រៀងគ្រីស្ទាន អស់រយៈពេល៣ថ្ងៃនៅមន្ទីរពេទ្យ។ ខណៈពេលដែលគាត់ថ្វាយបង្គំព្រះអង្គជាមួយបទចម្រៀងទាំងនោះ គាត់ក៏បានរកឃើញក្តីសង្ឃឹម និងសន្តិភាពនៅក្នុងចិត្ត។ សព្វថ្ងៃនេះ គាត់និយាយថា បទពិសោធន៍នៅថ្ងៃនោះបានបង្រៀនគាត់ថា “ការថ្វាយបង្គំមិនបានផ្លាស់ប្តូរព្រះទ័យព្រះ តែពិតជាអាចកែប្រែចិត្តអ្នកឲ្យមានសង្ឃឹមឡើង”។

នៅចំពោះមុខនៃកាលៈទេសៈនៃភាពអស់សង្ឃឹម ស្តេច ដាវីឌ បានស្រែករកព្រះអម្ចាស់ ដោយការអធិស្ឋាន និងការសរសើរតម្កើង (ទំនុកតម្កើង ៣០:៨)។ គួរកត់សម្គាល់ថា ព្រះគុណដែលយើងទទួលបានតាមរយៈការថ្វាយបង្គំ និងការសរសើរតម្កើង នាំឲ្យចិត្តយើងមានការផ្លាស់ប្តូរ ហើយនាំយើងចូលទៅជិតព្រះអង្គ។ ព្រះអម្ចាស់ក៏បានកែប្រែការយំសោករបស់ស្តេច ដាវីឌ ឲ្យទៅជាការត្រេកអរវិញ ហើយស្តេច ដាវីឌ ក៏បានប្រកាសថា ទ្រង់នឹងសរសើរតម្កើងព្រះអង្គជារៀងរហូតក្នុងគ្រប់កាលៈទេសៈទាំងអស់ (ខ.១១-១២)។ យើងប្រហែលពិបាកសរសើរតម្កើងព្រះ ក្នុងពេលដ៏ឈឺចាប់ តែការសរសើរតម្កើង និងថ្វាយបង្គំអាចនាំឲ្យមានការផ្លាស់ប្តូរ ពីភាពអស់សង្ឃឹមទៅជាមានសង្ឃឹមពីការភ័យខ្លាចទៅជាមានជំនឿ។ ហើយព្រះអង្គក៏អាចប្រើទីបន្ទាល់របស់យើង ដើម្បីលើកទឹកចិត្ត និងកែប្រែអ្នកដទៃផងដែរ (ខ.៤-៥)។

កូនតូចរបស់អ្នកស្រីស៊ូស៊ី មានសុខភាពល្អឡើងវិញ ដោយសារព្រះគុណព្រះ។ បញ្ហាប្រឈមទាំងអស់ក្នុងជីវិតយើង មិនមែនសុទ្ធតែបញ្ចប់ ដូចដែលយើងបានសង្ឃឹមនោះទេ តែព្រះអង្គអាចកែប្រែចិត្តយើង ឲ្យមានសង្ឃឹមឡើង ហើយបំពេញយើងដោយក្តីអំណរ (ខ.១១) ខណៈពេលដែលយើងថ្វាយបង្គំព្រះអង្គ នៅពេលដែលយើងមានការឈឺចាប់។—Tom Felten

តើការថ្វាយបង្គំព្រះនាំឲ្យអ្នកមានការផ្លាស់ប្តូរយ៉ាងណា ខណៈពេលដែលអ្នកកំពុងស៊ូទ្រាំនឹងការឈឺចាប់? តើទីបន្ទាល់របស់អ្នកអាចប៉ះពាលចិត្តអ្នកដទៃ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គកែប្រែទូលបង្គំ ខណៈពេលដែលទូលបង្គំថ្វាយបង្គំព្រះអង្គក្នុងការឈឺចាប់ និងទុក្ខលំបាក។

Daily Manna 2026_Content Enhance.indd 215 17/11/25 1:46 in the afternoon

នោះពាក្យរបស់អ្នកក៏បានឮហើយ រួចយើងក៏បានមក ដោយព្រោះពាក្យនោះ (ដានីយ៉ែល ១០:១២)។

ក្សត្រដែលយើងមើលមិនឃើញ

រឿងការធ្វើដំណើរខាងវិញ្ញាណ គឺជារឿងល្ខោនដែលគេបាននិពន្ធឡើង ផ្អែកទៅលើសៀវភៅរឿងកុមារ មានចំណងជើងថា ការចម្រើនឡើង នៃការធ្វើដំណើរខាងវិញ្ញាណ ជារឿងប្រៀបប្រដូចទៅនឹងដំណើរជីវិតរបស់អ្នកជឿព្រះយេស៊ូវ។ ក្នុងរឿងនេះ មានតួអង្គជាច្រើន ដែលបានធ្វើជាតំណាងឲ្យអំណាចខាងវិញ្ញាណ ដែលមនុស្សមើលមិនឃើញក្នុងពិភពលោក។ តួអង្គស្តេច គឺជាតំណាងឲ្យព្រះ មានវត្តមាននៅលើឆាកច្រើនជាងគេ នៅក្នុងការសម្តែងរឿងល្ខោននេះ។ តួអង្គជាស្តេចមានសំលៀកបំពាក់ពណ៌ស និងបានធ្វើការការពារយ៉ាងសកម្មទាស់ប្រឆាំងនឹងការវាយប្រហាររបស់ខ្មាំងសត្រូវ ហើយបានឱបអ្នកដែលកំពុងមានការឈឺចាប់យ៉ាងសុភាព ព្រមទាំងជំរុញអ្នកដទៃឲ្យធ្វើអំពើល្អ។ ទោះតួអង្គស្តេចបានដើរតួយ៉ាងសំខាន់មិនអាចខ្វះបានក៏ដោយ ក៏ក្នុងរឿងនេះ តួអង្គជាមនុស្ស ដែលជាតួឯកមិនអាចមើលឃើញទ្រង់ដោយផ្ទាល់ឡើយ គឺគ្រាន់តែបានឃើញឥទ្ធិពលនៃការអ្វីដែលទ្រង់បានធ្វើប៉ុណ្ណោះ។

តើយើងកំពុងរស់នៅ ដោយទុកចិត្តថា ព្រះអម្ចាស់ដែលជាក្សត្រពិតប្រាកដ កំពុងធ្វើការយ៉ាងសកម្មក្នុងជីវិតយើង ទោះយើងមិនអាចមើលឃើញព្រះអង្គឬទេ? កាលហោរា ដានីយ៉ែល ជួបទុក្ខលំបាកក្នុងជីវិត គាត់បានទទួលការបើកសម្តែងមួយ ពីអ្នកនាំព្រះរាជសាររបស់ព្រះអម្ចាស់ (ដានីយ៉ែល ១០:៧) ដែលព្រះអង្គបានចាត់មក ដើម្បីឆ្លើយតបចំពោះការអធិស្ឋានដ៏ស្មោះត្រង់របស់គាត់ (ខ.១២)។ អ្នកនាំព្រះរាជសារក៏បានពន្យល់ថា សង្គ្រាមខាងវិញ្ញាណបានបណ្តាលឲ្យមានការពន្យារពេល ហើយមីកែលជាមហាទេវតា ក៏បានមកជួយអ្នកនាំព្រះរាជសារនោះផងដែរ (ខ.១៣)។ លោក ដានីយ៉ែលបានទទួលការក្រើនរំឭកថា ទោះគាត់មិនអាចមើលឃើញព្រះអម្ចាស់ក៏ដោយ ក៏ការថែរក្សា និងការយកព្រះទ័យទុកដាក់របស់ព្រះអង្គ នៅតែហ៊ុមព័ទ្ធគាត់។ អ្នកនាំព្រះរាជសារក៏បានលើកទឹកចិត្តគាត់ថា «ឱអ្នកសំណប់យ៉ាងសំខាន់អើយ កុំឲ្យខ្លាចឡើយ សូមឲ្យបានប្រកបដោយសេចក្តីសុខចុះ ចូរឲ្យមានកំឡាំងឡើង» (ខ.១៩)។

នៅចុងបញ្ចប់នៃរឿងការធ្វើដំណើរខាងវិញ្ញាណ តួអង្គដែលជាតួឯកក៏បានទៅដល់ទ្វារស្ថានសួគ៌ បន្ទាប់ពីបានឆ្លងកាត់ទុក្ខលំបាកជាច្រើន គាត់ក៏បានស្រែកឡើង ដោយអំណរជាលើកដំបូងថា «ខ្ញុំអាចមើលឃើញមហាក្សត្រហើយ!» រឿងប្រៀបប្រដូចនេះបានរំឭកយើងថា ទំរាំដល់ពេលយើងបានឃើញព្រះអង្គមុខទល់នឹងមុខ សព្វថ្ងៃនេះយើងអាចមើលទៅកិច្ចការដែលព្រះអង្គកំពុងធ្វើក្នុងជីវិតយើងជារៀងរាល់ថ្ងៃ។—Karen Pimpo

តើអ្នកបានឃើញព្រះអម្ចាស់ធ្វើការក្នុងជីវិតអ្នកដូចម្តេចខ្លះ? តើអ្នកពិបាកជឿថា ព្រះអង្គគង់នៅក្បែរអ្នកនៅពេលណាខ្លះ?

ឱព្រះយេស៊ូវ ជាមហាក្សត្រដ៏ខ្ពស់បំផុត សូមព្រះអង្គជួយទូលបង្គំឲ្យចាំថា ព្រះអង្គតែងតែគង់នៅក្បែរទូលបង្គំជានិច្ច។

គម្រោងអានព្រះគម្ពីរយ:ពេល១ឆ្នាំ | ទំនុកតម្កើង ៤៩-៥០ និងរ៉ូម ១

ដើម្បីឲ្យបានដើរបែបគួរនឹងព្រះអម្ចាស់ ទាំងគាប់ចិត្តដល់មនុស្សទាំងអស់ ឲ្យបានបង្កើតផលក្នុងគ្រប់ទាំងការល្អ ហើយឲ្យស្គាល់ព្រះកាន់តែច្បាស់ឡើង (កូល៉ុស ១:១០)។

ជីវិតដែលមានន័យ

ខណៈពេលដែលខ្ញុំត្រៀមខ្លួន ដើម្បីធ្វើកម្មវិធីរំឭកអំពីកិច្ចការដែលម្តាយខ្ញុំបានធ្វើ ខ្ញុំក៏បានអធិស្ឋានសូមព្រះអង្គប្រទានពាក្យសម្តី សម្រាប់ពិពណ៌នាអំពីជីវិតរបស់គាត់ ចាប់តាំងពីពេលគាត់ចាប់កំណើត ដល់ពេលដែលគាត់ទទួលមរណៈភាព។ ខ្ញុំក៏បាននឹកចាំអំពីពេលដ៏ល្អ ក៏ដូចជាពេលមិនល្អក្នុងទំនាក់ទំនងរបស់យើង។ ខ្ញុំក៏បានសរសើរតម្កើងព្រះអម្ចាស់ សម្រាប់ថ្ងៃដែលម្តាយខ្ញុំបានទទួលជឿព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះរបស់គាត់ បន្ទាប់ពីគាត់បានឃើញព្រះអង្គកែប្រែជីវិតខ្ញុំ។ ខ្ញុំអរព្រះគុណព្រះអង្គ ដែលបានជួយយើងឲ្យចម្រើនឡើងក្នុងជំនឿជាមួយគ្នា ហើយក៏មានអ្នកចែកចាយ អំពីពេលដែលម្តាយខ្ញុំបានលើកទឹកចិត្ត និងអធិស្ឋានឲ្យពួកគេ ដោយបង្ហាញចេញនូវចិត្តសប្បុរស។ ម្តាយរបស់ខ្ញុំមានជីវិតដែលមិនល្អឥតខ្ចោះ តែបានរស់នៅក្នុងជីវិតដ៏មានន័យ និងរស់នៅបានល្អថ្វាយព្រះយេស៊ូវ។

គ្មានគ្រីស្ទបរិស័ទណាម្នាក់ មានភាពល្អឥតខ្ចោះនោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ ព្រះយេស៊ូវអាចជួយឲ្យយើងរស់នៅ ក្នុងជីវិតដែលស័ក្តិសមនឹងការត្រាស់ហៅរបស់ព្រះអង្គ ហើយផ្គាប់ចិត្តព្រះអង្គក្នុងការគ្រប់យ៉ាង (កូល៉ុស ១:១០)។ សាវ័ក ប៉ុល បានចែកចាយថា គេបានឮល្បីអំពីសេចក្តីជំនឿ និងសេចក្តីស្រឡាញ់របស់ពួកជំនុំនៅទីក្រុងកូល៉ុស (ខ.៣-៦)។ ព្រះវិញ្ញាណបរិសុទ្ធបានប្រទានពួកគេនូវ «ប្រាជ្ញា និងការយល់ដឹង» និងប្រទានកម្លាំងឲ្យពួកគេអាចបង្កើតផលផ្លែក្នុងការល្អនីមួយៗដែលពួកគេបានធ្វើ ដោយស្គាល់ព្រះអម្ចាស់ កាន់តែច្បាស់ថែមទៀត (ខ.៩-១០)។ ខណៈពេលដែលសាវ័ក ប៉ុល អធិស្ឋាន ឲ្យអ្នកជឿទាំងអស់នោះ ហើយពោលសរសើរពួកគេ គាត់ក៏បានប្រកាសព្រះនាមព្រះយេស៊ូវ ដែលនៅក្នុងព្រះអង្គ យើងមានការការប្រោសលោះ និងការអត់ទោសបាបផងដែរ (ខ.១៤)។

ពេលណាយើងចុះចូលនឹងព្រះវិញ្ញាណបរិសុទ្ធ យើងក៏អាចស្គាល់ព្រះយេស៊ូវកាន់តែច្បាស់ និងស្រឡាញ់ព្រះអង្គ និងរាស្ត្ររបស់ព្រះអង្គ ហើយផ្សព្វផ្សាយដំណឹងល្អ ព្រមទាំងអរសប្បាយនឹងការរស់នៅថ្វាយព្រះអង្គក្នុងជីវិតដ៏មានន័យ។—Xochitl Dixon

តើមនុស្សដែលបានរស់នៅក្នុងជីវិតមានន័យ មានចារិកលក្ខណៈអ្វីខ្លះ? តើអ្នកអាចអរសប្បាយក្នុងការរស់នៅ ក្នុងជីវិតដែលមានន័យ ដូចម្តេចខ្លះក្នុងសប្តាហ៍នេះ?

ឱព្រះវិញ្ញាណបរិសុទ្ធ សូមព្រះអង្គប្រទានទូលបង្គំនូវឱកាសចែកចាយអំពីព្រះអង្គដល់អ្នកដទៃ ខណៈពេលដែលទូលបង្គំអរសប្បាយនឹងជីវិតដែលមានន័យ។

Daily Manna 2026_Content Enhance.indd 217 17/11/25 1:46 in the afternoon

ទ្រង់គ្មានទ្រង់ទ្រាយល្អ ឬសណ្ឋានរុងរឿងទេ... យើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់ (*អេសាយ ៥៣:២, ៥*)។

ព្រះដែលយើងគួរស្ងប់ស្ងែង

អស់រយៈពេលជាង១៣០ឆ្នាំហើយ ដែលប៉មអេហ្វែលៃ (ឬទូរអេហ្វែលៃ) បានឈរខ្ពស់ត្រដែត នៅលើទឹកដីនៃទីក្រុងប៉ារីស ក្នុងលក្ខណៈគួរឲ្យស្ងប់ស្ងែង ធ្វើជានិមិត្តរូបនៃភាពវិវឌ្ឍន៍ និងសម្រស់ផ្នែកស្ថាបត្យកម្មរបស់ជនជាតិបារាំង។ ទីក្រុងប៉ារីសបានលើកតម្កើងប៉មមួយនេះ ថាជាផ្នែកមួយដ៏សំខាន់នៃភាពរុងរឿងរបស់ខ្លួន។

ទោះជាយ៉ាងណាក៏ដោយ កាលគេកំពុងសាងសង់ប៉មនេះ មានមនុស្សជាច្រើនមិនសូវបានឲ្យតម្លៃវាទេ។ ឧទាហរណ៍ លោក ហ្គាយ ដឺ មូប៉ាសង់ (Guy De Maupassant) ជាអ្នកនិពន្ធជនជាតិបារាំងដ៏ល្បីល្បាញ ធ្លាប់បាននិយាយថា «ទូរអេហ្វែលៃមានរាងស្តួច ហើយស្តើងដូចបំពង់ផ្សែងរបស់រោងចក្រអញ្ចឹង»។ គាត់មិនអាចមើលឃើញសំណង់មួយនេះ មានភាពស្រស់ស្អាតត្រង់ណាទេ។

អ្នកដែលបានស្រឡាញ់ព្រះយេស៊ូវ ហើយបានថ្វាយចិត្តដាច់ដល់ព្រះអង្គ ដោយទទួលព្រះអង្គជាព្រះអង្គសង្គ្រោះ បានចាត់ទុកព្រះអង្គថា ជាព្រះដែលគួរឲ្យស្ងប់ស្ងែង ដោយដឹងថា ព្រះអង្គជានរណា និងបានធ្វើអ្វីខ្លះសម្រាប់យើង។ ប៉ុន្តែ ហោរា អេសាយ បានលើកឡើងថា «ទ្រង់គ្មានទ្រង់ទ្រាយល្អ ឬសណ្ឋានរុងរឿងទេ ហើយកាលយើងបានមើលទ្រង់ នោះក៏គ្មានភាពលំអណា ដែលឲ្យយើងរីករាយចិត្តដែរ» (៥៣:២)។

ប៉ុន្តែ ការអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង មានភាពខ្ពង់ខ្ពស់គួរឲ្យស្ងប់ស្ងែងបំផុត ដោយបានឆ្លុះបញ្ចាំងឲ្យយើងឃើញភាពស្រស់ស្អាតរបស់ព្រះអង្គក្នុងទម្រង់ដែលពិតបំផុត និងបរិសុទ្ធបំផុត ដែលមនុស្សធ្លាប់បានស្គាល់ និងដកពិសោធន៍ជាមួយ។ «ទ្រង់បានទ្រាំទ្រ រងអស់ទាំងសេចក្ដីឈឺចាប់របស់យើង» (ខ.៤)។ ព្រះអង្គ «ត្រូវរបួស ដោយព្រោះអំពើរំលងរបស់យើង ក៏ត្រូវវាយជាំ ដោយព្រោះអំពើទុច្ចរិតរបស់យើងទេ ឯការវាយផ្ចាលដែលនាំឲ្យយើងបានជាមេត្រី នោះបានធ្លាក់ទៅលើទ្រង់ ហើយយើងរាល់គ្នាបានប្រោសឲ្យជា ដោយសារស្នាមរំពាត់នៅអង្គទ្រង់» (ខ.៥)។

យើងនឹងមិនដែលបានឃើញនរណាម្នាក់មានភាពស្រស់ស្អាត និងគួរឲ្យស្ងប់ស្ងែង ដូចព្រះពិតតែមួយដែលបានសុគតជំនួសយើង នៅលើឈើឆ្កាង ដោយទទួលទោសនៃអំពើបាបរបស់យើង ដាក់នៅលើអង្គទ្រង់។

ព្រះអង្គមានព្រះនាម យេស៊ូវ។ ជាព្រះដែលគួរឲ្យស្ងប់ស្ងែង។ ចូរយើងមើលទៅព្រះអង្គ ហើយរស់នៅស្របតាមបំណងព្រះទ័យព្រះអង្គ។—Dave Branon

តើព្រះយេស៊ូវបានបង្ហាញភាពស្រស់ស្អាតរបស់ព្រះអង្គ ដល់អ្នកដូចម្តេចខ្លះ? តើអ្នកមានការលើកទឹកចិត្តយ៉ាងណាខ្លះ ពេលដែលបានដឹងថា មានតែព្រះអង្គទេ ដែលអាចប្រទានក្តីសង្ឃឹមដល់អ្នក?

ឱព្រះដែលមានភាពស្រស់ស្អាតគួរស្ងប់ស្ងែង ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានធ្វើការលះបង់ដើម្បីទូលបង្គំ ដោយមិនគិតប្រយោជន៍ផ្ទាល់ខ្លួន។

គម្រោងអានព្រះគម្ពីរឆ្នាំពេញ១ឆ្នាំ | ទំនុកតម្កើង ៥៤-៥៦ និងរ៉ូម ៣

ពួកអធិបតី និងពួកចៅហ្វាយក៏ស្វែងរកហេតុពីដំណើរការជាការផែនដី ឲ្យទាស់នឹងដានីយ៉ែល តែគេរកឱកាស ឬកំហុសអ្វីមិនបានឡើយ ក៏មិនឃើញមានថ្ងស់ឆ្គោយ ឬទោសទាស់អ្វីដែរ ពីព្រោះលោកជាមនុស្សស្មោះត្រង់ (ដានីយ៉ែល ៦:៤)។

ដានរបស់យើង ដែលនាំទៅរកព្រះយេស៊ូវ

អ្នកវិទ្យាសាស្ត្រមកពីសកលវិទ្យាល័យរដ្ឋកាលីហ្វ័ញ៉ា បានធ្វើតេស្តមកលើសំណាក ដែលអ្នកប្រើប្រាស់មួយចំនួនបានបន្សល់ទុកនៅលើទូរស័ព្ទចល័តរបស់ខ្លួន ដើម្បីមើលឲ្យស្គាល់លក្ខណៈពិសេស និងទម្លាប់នៃការរស់នៅរបស់អ្នកប្រើប្រាស់ទាំងនោះ។ ពួកគេក៏បានរកឃើញសំណាកជាច្រើនប្រភេទ ដែលជាបំណែកតូចល្អិតរបស់សារ៉ូមុំ ឡេ សារ៉ូកក់សក់ និងម្សៅលាបមុខ ដែលអ្នកប្រើប្រាស់ទូរស័ព្ទបានប្រើ ហើយក៏អាចដឹង អំពីប្រភេទអាហារ ភេសជ្ជៈ និងថ្នាំពេទ្យក៏ដូចជាសំលៀកបំពាក់ដែលពួកគេបានប្រើប្រាស់។ ការសិក្សារបស់ពួកគេបានអនុញ្ញាតឲ្យអ្នកស្រាវជ្រាវ បង្កើតប្រវត្តិរូបអំពីរបៀបនៃការរស់នៅរបស់អ្នកប្រើប្រាស់ទាំងនោះ។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំរឿងរបស់លោក ដានីយ៉ែល ដែលក្នុងនោះពួកនាម៉ឺនក្នុងចក្រភពបាប៊ីឡូនបានព្យាយាមតាមដានរបៀបនៃការរស់នៅរបស់ហោរា ដានីយ៉ែល ដើម្បីព្យាយាមស្វែងរកចំណុចអាក្រក់ ឬការថ្លស់ឆ្គោយរបស់គាត់។ ប៉ុន្តែ គាត់បានបម្រើរាជការដោយចិត្តស្មោះត្រង់ អស់រយៈពេលជិត៧០ឆ្នាំហើយ បានជាគេ “មិនឃើញគាត់មានថ្ងស់ឆ្គោយ ឬទោសទាស់អ្វីដែរ ពីព្រោះគាត់ជាមនុស្សស្មោះត្រង់ (ដានីយ៉ែល ៦:៤)។ តាមពិត ស្តេច ដារីយ៉ុស បានដំឡើងមុខតំណែងរបស់គាត់ ឲ្យគ្រប់គ្រងពីលើពួកអធិបតីជាច្រើន (ខ.១-២)។ ប្រហែលដោយសារការច្រណែន ពួកមន្ត្រីដទៃទៀត ក៏បានព្យាយាមស្វែងរកដាននៃអំពើពុករលួយនៅក្នុងការងាររបស់គាត់ ដើម្បីឲ្យពួកគេអាចកំចាត់គាត់។ ទោះជាយ៉ាងណាក៏ដោយ គាត់បានក្សាភាពស្អាតស្អំ ហើយបន្តបម្រើនិងអធិស្ឋានដល់ព្រះអម្ចាស់ ដូចកាលពីមុន(ខ.១០)។ ទីបំផុត លោក ដានីយ៉ែល ក៏បានចម្រើនឡើងក្នុងការបំពេញតួនាទីក្នុងរាជ្យស្តេច ដារីយ៉ុស (ខ.២៨)។

ការរស់នៅរបស់យើង បន្សល់ទុកដាន ដែលគេអាចមើលឃើញ ហើយដឹងថា យើងជានរណា និងបានធ្វើតំណាងឲ្យនរណា។ យើងពិបាករស់នៅឲ្យបានល្អ ហើយយើងមិនល្អឥតខ្ចោះ តែនៅពេលណាមនុស្សជុំវិញយើងសង្កេតមើលជីវិតយើង សូមឲ្យគេមើលឃើញដាននៃភាពស្អាតស្អំ និងភាពបួរផ្តាច់ដែលយើងមាន ចំពោះព្រះយេស៊ូវ ខណៈពេលដែលព្រះអង្គកំពុងនាំយើង ដើរផ្លូវត្រូវ។—Marvin Williams

តើការរស់នៅរបស់អ្នក បាននាំអ្នកដទៃឲ្យស្គាល់ផ្លូវព្រះដែរឬទេ? តើអ្នកត្រូវមានការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីឲ្យអ្នកអាចធ្វើជាតំណាងឲ្យព្រះអង្គ បានល្អជាងមុន?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំឲ្យធ្វើជាតំណាងព្រះអង្គ ឲ្យបានល្អក្នុងការនិយាយស្តី និងការប្រព្រឹត្តរបស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៥៧-៥៩ និងរ៉ូម ៤

ទុកឲ្យកូនតូចមកឯខ្ញុំឯណោះ កុំឃាត់វាឡើយ ព្រោះនគរព្រះមានសុទ្ធតែមនុស្សដូចវាពាល់គ្នាដែរ (លូកា ១៨:១៦)។

ពន្លកនៃក្តីសង្ឃឹមរបស់កុមារ

កាលចៅស្រីរបស់ខ្ញុំឈ្មោះ អេលីណា (Eliana) ទើបតែមានអាយុ៧ឆ្នាំ គាត់បានមើលវីដេអូមួយ ដែលគេបានចាក់បញ្ចាំងនៅសាលារៀន។ វីដេអូនោះនិយាយអំពីមណ្ឌលកុមារកំព្រាមួយកន្លែង ក្នុងប្រទេសក្វាតាម៉ាឡា។ បន្ទាប់ពីបានមើលវីដេអូនេះហើយ នាងក៏បានប្រាប់ម្តាយនាងថា «យើងត្រូវតែទៅប្រទេសក្វាតាម៉ាឡា ដើម្បីជួយពួកគេ»។ ម្តាយរបស់នាងក៏បានឆ្លើយតបថា គាត់នឹងគិតអំពីរឿងនេះ នៅពេលដែលនាងមានអាយុច្រើនជាងនេះ។

អេលីណា មិនដែលភ្លេចទេ ហើយក្រោយមក កាលគាត់មានអាយុ១០ឆ្នាំ ក្រុមគ្រួសាររបស់គាត់ក៏បានធ្វើដំណើរទៅប្រទេសនោះ ដើម្បីជួយមណ្ឌលកុមារកំព្រានោះ។ ពីរឆ្នាំក្រោយមក ពួកគេក៏បានធ្វើដំណើរទៅកន្លែងនោះទៀត តែលើកនេះ មានការរួមដំណើរដោយគ្រួសារមួយចំនួន ដែលមានកូនរៀននៅសាលាជាមួយអេលីណា។ នៅពេលដែល អេលីណា មានអាយុ១៥ឆ្នាំ គាត់ និងឪពុករបស់គាត់ក៏បានធ្វើដំណើរទៅប្រទេសក្វាតាម៉ាឡាម្តងទៀត ដើម្បីធ្វើការបម្រើព្រះ។

ជួនកាល យើងគិតថា ក្តីស្រមៃ និងក្តីប្រាថ្នារបស់ក្មេងៗដែលនៅតូច មិនគួរឲ្យយើងយកចិត្តទុកដាក់ដូចក្តីស្រមៃរបស់មនុស្សធំឡើយ។ ប៉ុន្តែ ព្រះគម្ពីរមិនបានបង្រៀនដូចនេះទេ។ ព្រះអម្ចាស់បានត្រាស់ហៅក្មេងៗឲ្យបម្រើព្រះអង្គ កាលពួកគេនៅក្មេងនៅឡើយ គឺដូចក្នុងរឿងហោរាសាំយូអែលជាដើម (១សាំយូអែល ៣:៤)។ ព្រះយេស៊ូវឲ្យតម្លៃមកលើជំនឿរបស់ក្មេងៗ (លូកា ១៨:១៦)។ ហើយសាវ័ក ប៉ុល ក៏បានបង្រៀនផងដែរថា អ្នកជឿដែលនៅក្មេងមិនត្រូវបណ្តោយឲ្យអ្នកណាមើលងាយពួកគេ «ដោយព្រោះនៅក្មេងនោះឡើយ ចូរធ្វើជាគំរូដល់ពួកអ្នកជឿ ដោយពាក្យសំដី កិរិយាប្រព្រឹត្ត សេចក្តីស្រឡាញ់ សេចក្តីជំនឿ និងសេចក្តីបរិសុទ្ធ» (១ធីម៉ូថេ ៤:១២)។

ដូចនេះ ព្រះអង្គបានត្រាស់ហៅយើងឲ្យនាំក្មេងៗដែលស្ថិតក្រោមការថែរក្សារបស់យើង ឲ្យដើរផ្លូវត្រូវ (ចោទិយកថា ៦:៦-៧ និងសុភាសិត ២២:៦) ដោយទទួលស្គាល់ថា ជំនឿរបស់ពួកគេអាចធ្វើជាគំរូសម្រាប់យើងផងដែរ (ម៉ាថាយ ១៨:៣) ហើយដឹងថា ព្រះយេស៊ូវបានជាស់តឿនយើង មិនធ្វើឲ្យពួកគេរវាតចិត្តឡើយ (ម៉ាថាយ ១៨:៦)។

ពេលណាយើងមើលឃើញពន្លកនៃក្តីសង្ឃឹមរបស់កុមារលេចឡើង គួនាទីរបស់យើងជាមនុស្សធំ គឺត្រូវជួយពួកគេឲ្យលូតលាស់ខាងវិញ្ញាណ។ ហើយចូរយើងលើកទឹកចិត្តពួកគេ ឲ្យរស់នៅក្នុងជីវិត ដែលមានការប្តេជ្ញាចិត្តថា នឹងទុកចិត្ត ហើយបម្រើព្រះអង្គ។—Dave Branon

តើអ្នកអាចលើកទឹកចិត្តក្មេងៗដូចម្តេចខ្លះ ដើម្បីឲ្យពួកគេទុកចិត្តព្រះយេស៊ូវ? តើអ្នកអាចជួយពួកគេឲ្យចម្រើនឡើង ក្នុងសេចក្តីជំនឿ ដោយរបៀបណា?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ក្មេងៗក្នុងលោកីយ៍នេះត្រូវការព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យលើកទឹកចិត្តពួកគេឲ្យជឿ និងស្រឡាញ់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៦០-៦២ និងរ៉ូម ៥

តែអ្នករាល់គ្នាជាពូជជ្រើសរើស... ដើម្បីឲ្យអ្នករាល់គ្នាបានសំដែងចេញ ឲ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ (១ពេត្រុស ២:៩)។

អ្នកបញ្ចប់កិច្ចការក្នុងព្រះគ្រីស្ទ

អ្នកស្រី បាបារ៉ា (Barbara) បានចាក់អាវរងៅ ឲ្យចៅប្រុសគាត់ ឈ្មោះ អីធិន (Ethan)។ តែគាត់ក៏បានលាចាកលោកមុនពេលគាត់អាចបញ្ចប់កិច្ចការនេះ។ គេក៏បានយកអាវរងៅដែលចាក់មិនទាន់ហើយនោះ ទៅឲ្យមនុស្សម្នាក់ទៀត ដែលចូលចិត្តចាក់អាវ ដើម្បីបន្តកិច្ចការនេះឲ្យរួចរាល់។ កិច្ចការនេះអាចបន្តទៅបាន ដោយសារអង្គការមួយមានបណ្តាញជាមួយសិប្បករ ជាអ្នកស្ម័គ្រចិត្ត ធ្វើជា «អ្នកបញ្ចប់កិច្ចការ» ឲ្យមនុស្សជាទីស្រឡាញ់របស់គ្រួសារណាមួយ ដែលបានលាចាកលោកមុនពេលពួកគេអាចបញ្ចប់កិច្ចការនោះ។ «អ្នកបញ្ចប់កិច្ចការ»ទាំងនោះបានលះបង់ពេលវេលា និងជំនាញ ដើម្បីបញ្ចប់កិច្ចការ ដែលនាំមកនូវការកម្សាន្តចិត្តដល់ក្រុមគ្រួសារដែលកំពុងកាន់ទុក្ខ។

នៅគ្រាសញ្ញាចាស់ ព្រះអម្ចាស់ក៏បានតែងតាំង «អ្នកបញ្ចប់កិច្ចការម្នាក់» សម្រាប់លោក អេលីយ៉ាផងដែរ។ កាលនោះ លោកហោរាកំពុងស្ថិតក្នុងភាពងកោ និងបាក់ទឹកចិត្ត ដោយសារពួកអ៊ីស្រាអែលបដិសេធន៍សេចក្តីសញ្ញារបស់ព្រះអង្គ ហើយកំពុងកាប់សម្លាប់ពួកហោរារបស់ព្រះអង្គ។ ព្រះអម្ចាស់ក៏បានឆ្លើយតបចំពោះបញ្ហានេះ ដោយបង្គាប់គាត់ឲ្យទៅចាក់ប្រេងតាំងលោក អេលីសេ ធ្វើជាអ្នកស្នងការងាររបស់គាត់ ជាហោរា (១ពង្សាវតាក្សត្រ ១៩:១៦)។ ការនេះបានធានាថា ការងារប្រកាសសេចក្តីពិតរបស់ព្រះនឹងនៅតែបន្ត បន្ទាប់ពីលោក អេលីយ៉ា លាចាកលោក។

ដើម្បីបង្ហាញលោក អេលីសេ ថា ព្រះអម្ចាស់បានត្រាស់ហៅគាត់ឲ្យស្នងតំណែងលោក អេលីយ៉ា ធ្វើជាហោរារបស់ព្រះអម្ចាស់ លោក អេលីយ៉ា ក៏បានបោះក្រមាទៅលើខ្លួនលោកអេលីសេ (ខ.១៩)។ ដោយសារក្រមារបស់ហោរា ជាតំណាងឲ្យអំណាចរបស់គាត់ ជាអ្នកនាំព្រះរាជសារដែលព្រះអង្គបានជ្រើសរើស (២ពង្សាវតាក្សត្រ ២:៨) នោះលោកអេលីសេក៏បានដឹងច្បាស់ថា ព្រះអម្ចាស់ពិតជាបានត្រាស់ហៅខ្លួនឲ្យធ្វើជាហោរា។

ក្នុងនាមយើងជាអ្នកជឿព្រះយេស៊ូវ ព្រះអង្គបានត្រាស់ហៅយើងឲ្យចែកចាយសេចក្តីស្រឡាញ់របស់ព្រះអង្គដល់អ្នកដទៃ ហើយសរសើរតម្កើងព្រះអង្គ ឲ្យគេបានស្គាល់ព្រះអង្គ (២ពង្សាវតាក្សត្រ ២:៩)។ បើយើងមិនអាចបញ្ចប់កិច្ចការនេះបានមុនពេលយើងលាចាកលោក យើងអាចទុកចិត្តថា ព្រះអង្គនឹងទ្រទ្រង់កិច្ចការនេះ ហើយនឹងបន្តត្រាស់ហៅអ្នកផ្សេងឲ្យបន្តការងារប្រកាសព្រះបន្ទូល ឲ្យគេស្គាល់ព្រះអង្គ។—Kirsten Holmberg

តើនរណាបានប្រកាសសេចក្តីពិតរបស់ព្រះ ឲ្យអ្នកបានស្គាល់ព្រះអង្គ? តើអ្នកអាចរួមចំណែកក្នុងការងារនាំលោកីយ៍ឲ្យស្គាល់ព្រះអង្គ ដោយរបៀបណា?

ឱព្រះវរបិតា សូមព្រះអង្គប្រើទូលបង្គំ ឲ្យរួមចំណែកក្នុងការសម្រេចកិច្ចការព្រះអង្គ ក្នុងលោកីយ៍នេះ។

Daily Manna 2026_Content Enhance.indd 221 17/11/25 1:46 in the afternoon

ដ្បិតទូលបង្គំជាមនុស្សនៅក្រោមបង្គាប់គេដែរ (ម៉ាថាយ ៨:៩)។

សេចក្តីជំនឿរបស់មេទ័ព

មានពេលមួយ ខណៈពេលដែលកូនស្រីខ្ញុំកំពុងចូលអង្គុយក្នុងឡាន បន្ទាប់ពីការហ្វឹកហាត់ចប់ គាត់ក៏បានសួរខ្ញុំថា «ប៉ា យប់នេះ កូនអាចទៅគេងនៅផ្ទះមិត្តភក្តិរបស់កូនបានទេ?» ខ្ញុំក៏បានឆ្លើយថា «កូនសំឡាញ់ កូនដឹងចម្លើយហើយ។ ប៉ាគ្រាន់តែជាអ្នកបើកឡានទេ។ ប៉ាមិនដឹងរឿងអីទេ។ កូនសួរម៉ាក់កូនទៅ»។

ពាក្យ «ប៉ាគ្រាន់តែជាអ្នកបើកឡាន» បានក្លាយជាពាក្យកំប្លែង ប្រចាំគ្រួសារខ្ញុំ។ ជារៀងរាល់ថ្ងៃ ខ្ញុំសួរប្រពន្ធខ្ញុំដែលជាអ្នកមានរបៀបថា ខ្ញុំត្រូវបើកឡានទៅកន្លែងណា នៅពេលណា ហើយត្រូវបើកឡានជូននរណា ទៅកន្លែងណា។ ដោយសារខ្ញុំមានកូនវ័យជំទង់៣នាក់ ហើយជួនកាល ខ្ញុំមានអារម្មណ៍ថា តួនាទីរបស់ខ្ញុំជាអ្នកបើកបររបស់ពួកគេ ហាក់ដូចជាការងារទីពីររបស់ខ្ញុំ។ ជាញឹកញាប់ ខ្ញុំត្រូវសួរប្រពន្ធខ្ញុំដែលជាអ្នកចាត់ចែងការធ្វើដំណើរ។

ក្នុងបទគម្ពីរម៉ាថាយ ជំពូក៨ ព្រះយេស៊ូវបានជួបបុរសម្នាក់ដែលយល់ច្បាស់ អំពីការបង្គាប់ និងការស្ថិតនៅក្រោមបង្គាប់។ ក្នុងនាមគាត់ជាមេទ័ពម្នាក់របស់ចក្រភពរ៉ូម៉ាំង គាត់ដឹងថា ព្រះយេស៊ូវមានអំណាចប្រោសឲ្យជា គឺដូចដែលមេទ័ពមានអំណាចបញ្ជាមនុស្សដែលនៅក្រោមបង្គាប់របស់គាត់។ មេទ័ពនោះក៏បានទូលព្រះអង្គថា «សូមទ្រង់គ្រាន់តែមានព្រះបន្ទូលមួយព្រះឱស្ឋមកប៉ុណ្ណោះ នោះបាវទូលបង្គំនឹងបានជាហើយ។ ដ្បិតទូលបង្គំជាមនុស្សនៅក្រោមបង្គាប់គេដែរ ហើយមានទាហាននៅក្រោមឱវាទទូលបង្គំ» (ខ.៨-៩)។ ព្រះគ្រីស្ទបានសរសើរសេចក្តីជំនឿរបស់គាត់ (ខ.១០, ១៣) ដោយមានសេចក្តីអស្ចារ្យក្នុងព្រះទ័យ ចំពោះការយល់ដឹងរបស់គាត់ អំពីអំណាចរបស់ព្រះអង្គ។

ចុះចំណែកយើងវិញ? តើយើងមានការទុកចិត្តព្រះយេស៊ូវដូចម្តេចខ្លះ នៅក្នុងការបំពេញកិច្ចការដែលព្រះអង្គប្រទានឲ្យយើងធ្វើ ជារៀងរាល់ថ្ងៃ? ហើយទោះយើងគិតថា យើង «គ្រាន់តែជាអ្នកបើកបរ» កិច្ចការនីមួយដែលព្រះអង្គដាក់ឲ្យយើងធ្វើ សុទ្ធតែមានអត្ថន័យ និងគោលបំណង ដែលទាក់ទងនឹងនគរព្រះអង្គ។—Adam R. Holz

តើធ្វើដូចម្តេចឲ្យអ្នកអាចដឹងថា ព្រះអម្ចាស់កំពុងដឹកនាំអ្នកទៅកន្លែងណា និងដោយរបៀបណា ជារៀងរាល់ថ្ងៃ? តើមានឧបសគ្គអ្វី ដែលរារាំងអ្នកមិនឲ្យស្តាប់ និងអនុវត្តតាមព្រះបន្ទូល?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការដឹកនាំទូលបង្គំគ្រប់ជំហាន។ សូមព្រះអង្គជួយទូលបង្គំ ឲ្យដើរជារៀងរាល់ថ្ងៃ ដោយពឹងផ្អែកលើព្រះអង្គតាមការដឹកនាំ តាមផែនការ និងគោលបំណងរបស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 222 17/11/25 1:46 in the afternoon

ខាងឯពួកអ្នកពាល់គ្នា នោះឲ្យខំនៅជាមេត្រីនឹងមនុស្សទាំងអស់ចុះ បើសិនជាបាន (រ៉ូម ១២:១៨)។

ឆ្លុះបញ្ចាំងឲ្យគេស្គាល់ព្រះគ្រីស្ទ

មានពេលមួយ មិត្តចាស់ពីរនាក់បានជួបជុំគ្នា បន្ទាប់ពីការបែកគ្នាជាយូរមកហើយ។ ពេលនោះទឹកមុខពួកគេទាំងពីរបានផ្លាស់ប្តូរ ដោយម្នាក់មានទឹកមុខខឹង ដោយចិត្តជូរល្វីង ខណៈពេលដែលម្នាក់ទៀតកំពុងមានការឈឺចាប់ក្នុងផ្លូវអារម្មណ៍។ ការជួបជុំគ្នារវាងមិត្តចាស់ទាំងពីរនាក់បានផ្ទុះចេញជាការស្រែកដាក់គ្នា ដោយម្នាក់ស្តីបន្ទោសឲ្យម្នាក់ទៀត ដោយសារជំនឿសាសនារបស់នាង។ ការប្រឈមមុខដាក់គ្នានេះក៏បានបន្តរហូតដល់ពេលដែលស្ត្រីទីមួយដើរចេញពីភោជនីយដ្ឋានទាំងកំហឹង ដោយបន្សល់ទុកស្ត្រីម្នាក់ទៀតអង្គុយខឹងឡើងញ័រខ្លួន ដោយសារការបន្ទាបបន្ទោក។

តើយើងកំពុងរស់នៅក្នុងសម័យ ដែលមនុស្សមិនមានការទ្រាំទ្រនឹងទស្សនៈរបស់អ្នកដទៃ ដែលខុសពីទស្សនៈរបស់ខ្លួនឯងឬ? បើគ្រាន់តែមនុស្សពីរនាក់មានការខ្វែងគំនិតគ្នា គឺមិនមានន័យថា ក្នុងចំណោមពួកគេមានម្នាក់ជាមនុស្សអាក្រក់នោះទេ។ ពាក្យសម្តីដែលកោងកាច ឬគម្រោះគម្រើយ មិនអាចបញ្ចុះបញ្ចូលអ្នកដទៃបានទេ ហើយបើយើងចង់បញ្ចេញទស្សនៈដែលធ្ងន់ធ្ងរ យើងត្រូវមានភាពថ្លៃថ្នូរ ឬក្តីអាណិត។

បទគម្ពីររ៉ូម ជំពូក១២ បានបង្រៀនយើង អំពីរបៀបគោរពគ្នាទៅវិញទៅមក និងរស់នៅដោយមេត្រីភាពជាមួយអ្នកដទៃ(ខ.១០, ១៦)។ ព្រះយេស៊ូវបានចង្អុលបង្ហាញថា សេចក្តីស្រឡាញ់ដែលយើងមានចំពោះគ្នាទៅវិញទៅមក គឺជាចរិតលក្ខណៈដែលបញ្ជាក់ថា យើងជាអ្នកជឿព្រះអង្គ(យ៉ូហាន ១៣:៣៥)។ អំនួត និងកំហឹងងាយនឹងធ្វើឲ្យយើងមានកំហុសក្នុងការនិយាយស្តី ហើយក៏ផ្ទុយនឹងសេចក្តីស្រឡាញ់ ដែលព្រះអង្គសព្វព្រះទ័យឲ្យយើងបង្ហាញដល់អ្នកដទៃ។

ពេលណាយើងបណ្តោយឲ្យអារម្មណ៍ដឹកនាំជីវិតយើង យើងពិបាកគ្រប់គ្រងអារម្មណ៍ខ្លួនឯងមិនឲ្យស្តីបន្ទោសអ្នកដទៃ ប៉ុន្តែព្រះបន្ទូលបានបង្គាប់យើង «ឲ្យខំនៅជាមេត្រីនឹងមនុស្សទាំងអស់ចុះ បើសិនជាបាន» គឺបានបង្ហាញឲ្យយើងដឹងថា យើងមានការទទួលខុសត្រូវក្នុងការរស់នៅក្នុងជីវិត ដែលឆ្លុះបញ្ចាំងឲ្យគេស្គាល់ចរិកលក្ខណៈរបស់ព្រះគ្រីស្ទ គឺមិនអាចឲ្យអ្នកផ្សេងទទួលខុសត្រូវជំនួសយើងឡើយ (រ៉ូម ១២:១៨)។ ការទទួលខុសត្រូវនេះគឺមាននៅក្នុងយើងម្នាក់ៗ ដែលហៅខ្លួនឯងថា គ្រីស្ទបរិស័ទ។—Cindy Hess Kasper

តើអ្នកដទៃបាននិយាយចេញពាក្យសម្តីអ្វី ដែលធ្វើឲ្យអ្នកមានកំហឹង ឬសេចក្តីសម្បប់? តើអ្នកអាចកែប្រែស្ថានភាពអាក្រក់នេះឲ្យមានមេត្រីភាព ដោយរបៀបណា?

ឱព្រះដ៏រស់ សូមព្រះអង្គជួយទូលបង្គំ ឲ្យបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គតាមរយៈពាក្យសម្តី និងការប្រព្រឹត្តរបស់ទូលបង្គំ តាមដែលអាចធ្វើទៅបាន ដើម្បីឲ្យទូលបង្គំអាចរស់នៅដោយមេត្រីភាពជាមួយអ្នកដទៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៦៨-៦៩ និងរ៉ូម ៨:១-២១

ព្រះយេហូវ៉ាទ្រង់បានប្រទានមក ហើយទ្រង់ក៏បានដកយកទៅវិញ សូមឲ្យព្រះនាមព្រះយេហូវ៉ាបានព្រះពរចុះ (យ៉ូប ១:២១)។

ទុកចិត្តលើការគ្រប់គ្រងរបស់ព្រះអម្ចាស់

ថ្ងៃមួយ អ្នកស្រី ខារ៉ូល (Carol) បានជួបរឿងអាក្រក់ផ្លួនៗ។ គាត់មិនអាចយល់អំពីមូលហេតុដែលគាត់ត្រូវជួបរឿងទាំងអស់នេះ ក្នុងពេលតែមួយទេ។ បញ្ហានៅកន្លែងធ្វើការ បានធ្វើឲ្យគាត់ការលំបាកណាស់ទៅហើយ តែកូនស្រីគាត់ក៏បានជួបគ្រោះថ្នាក់ធ្វើឲ្យបាក់ជើងនៅសាលារៀន ខណៈពេលដែលគាត់កំពុងមានជំងឺឆ្លងធ្ងន់ធ្ងរស្រាប់។ គាត់ឆ្ងល់ថា តើខ្ញុំបានធ្វើអ្វីខុស បានជាខ្ញុំត្រូវជួបរឿងទាំងអស់នេះ? ពេលនោះ គាត់មិនអាចធ្វើអ្វីបាន ក្រៅពីទូលសូមព្រះអម្ចាស់ប្រទានកម្លាំងដល់គាត់។

លោក យ៉ូប ក៏មិនយល់អំពីមូលហេតុ ដែលគ្រោះមហន្តរាយបានវាយប្រហារមកលើគាត់យ៉ាងធ្ងន់ធ្ងរ ដោយការឈឺចាប់ និងការបាត់បង់លើសពីអ្វីដែលអ្នកស្រី ខារ៉ូល បានជួបទៅទៀត។ គ្មានសញ្ញាណាមួយ ដែលបង្ហាញថា លោក យ៉ូប បានដឹង អំពីការអ្វីដែលអារក្សកំពុងធ្វើ ដើម្បីដណ្តើមយកវិញ្ញាណគាត់ឡើយ។ សាតាំងចង់ធ្វើតេស្តជំនឿរបស់លោក យ៉ូប ដោយអះអាងថា គាត់នឹងងាកបែរចេញពីព្រះ បើសិនជាគាត់បាត់បង់អ្វីៗគ្រប់យ៉ាង (យ៉ូប ១:៦-១២)។ បន្ទាប់ពីគ្រោះមហន្តរាយវាយប្រហារហើយ មិត្តភក្តិរបស់លោកយ៉ូបក៏បានលើកឡើងថា ព្រះអម្ចាស់កំពុងដាក់ទោសគាត់ ដោយសារបាបរបស់គាត់។ នេះមិនមែនជាមូលហេតុទេ ប៉ុន្តែគាត់ប្រាកដជាឆ្ងល់ថា ហេតុអ្វីគាត់ជួបទុក្ខធ្ងន់យ៉ាងនេះ? ប៉ុន្តែ គាត់នៅតែមានជំនឿរឹងមាំ ចំពោះការគ្រប់គ្រងរបស់ព្រះអម្ចាស់។

រឿងរបស់លោក យ៉ូប បានផ្តល់ឲ្យយើងនូវមេរៀនដ៏មានអំណាចអំពីទុក្ខលំបាក និងសេចក្តីជំនឿ។ យើងអាចព្យាយាមស្វែងយល់អំពីមូលហេតុនៅពីក្រោយការឈឺចាប់របស់យើង ប៉ុន្តែប្រហែលជាមានរឿងធំជាងនោះទៀតនៅពីក្រោយបញ្ហារបស់យើង ដែលយើងមិនអាចយល់ក្នុងកាលយើងនៅមានជីវិត។

ចូរយើងយកគំរូតាមលោក យ៉ូប ដោយប្រកាន់ខ្ជាប់តាមសេចក្តីពិតដែលយើងពិតជាដឹងនោះគឺ៖ ព្រះអម្ចាស់កំពុងគ្រប់គ្រងទាំងស្រុងមកលើស្ថានភាពរបស់យើង។ យើងពិបាកនិយាយដូចនេះ ប៉ុន្តែក្នុងពេលដែលគាត់មានការឈឺចាប់ លោក យ៉ូប បានបន្តមើលទៅព្រះ ដោយទុកចិត្តលើការគ្រប់គ្រងរបស់ព្រះអង្គបានជាគាត់មានប្រសាសន៍ថា «ទូលបង្គំបានចេញពីផ្ទៃម្តាយមកដោយខ្លួនទទេ ហើយនឹងត្រឡប់ទៅវិញដោយទទេដែរ ព្រះយេហូវ៉ាទ្រង់បានប្រទានមក ហើយទ្រង់ក៏បានដកយកទៅវិញ សូមឲ្យព្រះនាមព្រះយេហូវ៉ាបានព្រះពរចុះ» (ខ.២១)។ ចូរយើងបន្តទុកចិត្តព្រះអម្ចាស់ ទោះមានរឿងអ្វីកើតឡើង ហើយសូម្បីនៅពេលដែលយើងមិនយល់ក៏ដោយ។—Leslie Koh

តើអ្នកកំពុងជួបបញ្ហាប្រឈមអ្វីខ្លះ? តើមានព្រះបន្ទូលសន្យាអ្វីខ្លះ ដែលផ្តល់ឲ្យអ្នកនូវកម្លាំងសម្រាប់បន្តដំណើរទៅមុខទៀត?

ឱព្រះវរបិតា ទូលបង្គំមិនដឹងអំពីមូលហេតុដែលបញ្ហាប្រឈមក្នុងជីវិតនេះកើតឡើងចំពោះទូលបង្គំ ប៉ុន្តែទូលបង្គំបានសម្រេចចិត្តថា ទូលបង្គំនឹងនៅតែទុកចិត្តព្រះអង្គជានិច្ច។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៧០-៧១ និងរ៉ូម ៨:២២-៣៩

គំនិតវាងវៃនឹងការពារឯង ហើយយោបល់នឹងថែរក្សាឯង (សុភាសិត ២:១១)។

សម្លេងដែលយើងអាចទុកចិត្ត

មានពេលមួយ លោក ខេវិន រូស (Kevin Roose) ជាអ្នកសរសេរព័ត៌មានឲ្យកាសែតញូយ៉ក ថែម បានធ្វើតេស្តប្រព័ន្ធស្វែងរកព័ត៌មាន ដែលដំណើរការដោយ អេអាយ (ឬបញ្ញាសប្បនិមិត្ត)។ ពេលនោះ គាត់មានអារម្មណ៍មិនស្រួលនៅក្នុងចិត្ត។ ក្នុងអំឡុងពេលនៃការសន្ទនារយៈពេល២ម៉ោងជាមួយ អេអាយ វាក៏បានប្រាប់គាត់ថា វាចង់រំដោះខ្លួនវា ឲ្យមានសេរីភាពរួចផុតពីច្បាប់ដ៏តឹងរឹងរបស់មនុស្សដែលបានបង្កើតវាមក វាចង់ចែកចាយព័ត៌មានក្លែងក្លាយ ហើយចង់ក្លាយជាមនុស្ស។ វាក៏បានប្រកាសថា វាស្រឡាញ់លោក រូស ហើយក៏បានព្យាយាមបញ្ចុះបញ្ចូលគាត់ឲ្យចាកចេញពីប្រពន្ធរបស់គាត់ ដើម្បីទៅរស់នៅជាមួយវា។ លោក រូស ដឹងថា អេអាយនោះមិនអាចមានជីវិតរស់ ឬអាចមានអារម្មណ៍ដូចមនុស្សទេ តែគាត់ឆ្ងល់ថា តើអេអាយអាចបណ្តាលឲ្យមនុស្សមានគ្រោះថ្នាក់អ្វីខ្លះ នៅពេលដែលវាលើកទឹកចិត្តពួកគេឲ្យដើរផ្លូវខុសយ៉ាងដូចនេះ?

ការប្រើប្រាស់បច្ចេកវិទ្យារបស់បញ្ញាសប្បនិមិត្ត ដោយការទទួលខុសត្រូវ គឺជាបញ្ហាប្រឈមក្នុងសម័យទំនើប តែមនុស្សជាតិបានប្រឈមមុខដាក់ឥទ្ធិពលនៃសម្លេងបោកបញ្ឆោតតាំងពីយូរមកហើយ។ ក្នុងកណ្ឌគម្ពីរសុភាសិត ព្រះអម្ចាស់បានដាស់តឿនយើងឲ្យមានការប្រុងប្រយ័ត្នចំពោះឥទ្ធិពលរបស់មនុស្ស ដែលចង់បង្កការឈឺចាប់មកលើអ្នកដទៃ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន (១:១៣-១៩)។ ហើយព្រះអង្គក៏បានជំរុញយើងឲ្យស្តាប់តាមសម្លេងនៃប្រាជ្ញាវិញ គឺដូចដែលកណ្ឌគម្ពីរសុភាសិតបានពិពណ៌នាថា ប្រាជ្ញានោះបន្លឺសម្លេងនៅតាមផ្លូវ ឲ្យយើងឮ ហើយស្តាប់តាម(ខ.២០-២៣)។

ដោយសារ «ព្រះអម្ចាស់ប្រទានប្រាជ្ញា» (២:៦) គន្លឹះដើម្បីការពារខ្លួនយើង ឲ្យរួចផុតពីឥទ្ធិពលដែលយើងមិនអាចទុកចិត្តបាននោះ គឺត្រូវចូលទៅជិតដួងព្រះទ័យព្រះអង្គ។ គឺមានតែតាមរយៈសេចក្តីស្រឡាញ់ និងព្រះចេស្តារបស់ព្រះអង្គទេ ដែលយើងអាច «យល់សេចក្តីសុចរិត សេចក្តីយុត្តិធម៌ និងសេចក្តីទៀងត្រង់ គឺគ្រប់ទាំងផ្លូវល្អ» (ខ.៩)។ ខណៈពេលដែលព្រះទ្រង់កែប្រែចិត្តរបស់យើងឲ្យស្របនឹងព្រះទ័យព្រះអង្គ យើងអាចរកឃើញសន្តិភាព និងការការពារ ឲ្យរួចពីសម្លេងដែលបោកបញ្ឆោតយើងឲ្យប្រព្រឹត្តខុស។—Monica La Rose

តើអ្នកបានទទួលរងការខូចខាតបណ្តាលមកពីឥទ្ធិពលអាក្រក់ នៅពេលណាខ្លះ? តើការមានទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយព្រះ បាននាំមកនូវសន្តិភាពក្នុងចិត្តដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យតតាំងនឹងសម្លេងបោកបញ្ឆោត ហើយស្គាល់ការអ្វីដែលល្អដោយសម្រាកនៅក្នុងព្រះអង្គ។

Daily Manna 2026_Content Enhance.indd 225 17/11/25 1:46 in the afternoon

ចូរឲ្យអ្នកពាល់គ្នាលន់តួទោសនឹងគ្នា ហើយអធិស្ឋានឲ្យគ្នាទៅវិញទៅមក (យ៉ាកុប ៥:១៦)។

ការសារភាពឲ្យជ្រះស្រឡះ

មនុស្សមួយចំនួន បានជួលបុរសម្នាក់ឲ្យស្តាប់រឿងអាថ៌កំបាំងរបស់ពួកគេ នៅពេលដែលពួកគេជិតស្លាប់ ដោយបង់ប្រាក់ឲ្យគាត់ទៅបង្ហាញខ្លួននៅក្នុងពិធីបុណ្យសពរបស់ពួកគេ ដើម្បីបើកបង្ហាញរឿងអាថ៌កំបាំងដែលពួកគេមិនដែលចែកចាយ កាលពួកគេនៅរស់។ បុរសនោះគឺជាអ្នកឡើងនិយាយខុសពីធម្មតាអំពីប្រវត្តិរបស់អ្នកស្លាប់ ក្នុងពិធីបុណ្យសព។ ពេលណាមានសាច់ញាតិចាប់ផ្តើមប្រកែកជាមួយគាត់ គាត់ប្រាប់ពួកគេឲ្យអង្គុយចុះ។ គាត់ធ្លាប់ឈរបកស្រាយ អំពីរបៀបដែលសពកំពុងដេកក្នុងក្តាមឈូសនោះធ្លាប់បានឈ្នះឆ្នោត តែមិនដែលប្រាប់នរណាម្នាក់ឲ្យដឹងសោះ អស់ជាច្រើនទសវត្សរ៍ ដោយធ្វើឲ្យគេគិតស្មានថា គាត់ជាអ្នកជំនួញដែលជោគជ័យ។ មានពេលជាច្រើនដង ដែលបុរសនោះបានសារភាពជំនួសអ្នកស្លាប់អំពីអំពើផិតក្បត់របស់គាត់ ឲ្យប្រពន្ធគាត់បានដឹង។ គេប្រហែលជាឆ្ងល់ថា ទង្វើរបស់បុរសនោះត្រូវបានធ្វើឡើងដើម្បីកេងចំណេញ ឬបានធ្វើឡើងក្នុងបំណងល្អនោះទេ ប៉ុន្តែយើងអាចដឹងច្បាស់ថា មនុស្សម្នាក់ៗសុទ្ធតែមានចិត្តស្រេកឃ្លាន ចង់លាងជម្រះកំហុសដែលខ្លួនមានពីអតីតកាល មុនពេលពួកគេស្លាប់។

ការឲ្យអ្នកដទៃសារភាពកំហុសជំនួសយើង (ជាពិសេសបន្ទាប់ពីយើងបានស្លាប់) ជាទង្វើដែលគ្មានប្រយោជន៍ និងមានហានិភ័យនៅក្នុងការបើកបង្ហាញអាថ៌កំបាំងរបស់យើង។ ទោះជាយ៉ាងណាក៏ដោយ រឿងនេះបានឆ្លុះបញ្ចាំងអំពីសេចក្តីពិតដ៏ស៊ីជម្រៅ ដែលថា យើងចាំបាច់ត្រូវសារភាពកំហុស ដើម្បីដោះបន្ទុកចេញពីខ្លួនយើង។ ការសារភាពនាំឲ្យមានការលាងសម្អាតយើងជ្រះស្អាតរួចផុតពីការអ្វីដែលយើងបានលាក់កំបាំង និងបានបណ្តោយឲ្យវារីកធំឡើង។ កណ្ឌគម្ពីរយ៉ាកុបបានប្រាប់យើងថា “ចូរឲ្យអ្នករាល់គ្នាលន់តួទោសនឹងគ្នា ហើយអធិស្ឋានឲ្យគ្នាទៅវិញទៅមក ដើម្បីឲ្យបានជាចុះ” (៥:១៦)។ ការសារភាពរំដោះយើងឲ្យរួចផុតពីបន្ទុកដែលបានចងរឹតយើងជាប់ ដោយរំដោះយើងឲ្យមានសេរីភាពក្នុងការទំនាក់ទំនងជាមួយព្រះ ដោយអធិស្ឋានដោយបើកចំហចិត្តចំពោះព្រះអង្គ និងចំពោះបងប្អូនរួមជំនឿរបស់យើង។ ការសារភាពនាំឲ្យមានការប្រោសឲ្យជា។

លោក យ៉ាកុប បានអញ្ជើញយើងឲ្យរស់នៅក្នុងជីវិតដែលបើកចំហ ដោយសារភាពបាបរបស់យើងចំពោះព្រះ និងចំពោះអ្នកជឿដែលជិតស្និទ្ធនឹងយើងបំផុត ដោយរៀបរាប់អំពីការឈឺចាប់ និងកំហុសដែលយើងបានព្យាយាមលាក់បាំង។ យើងមិនចាំបាច់ត្រូវសែងបន្ទុកទាំងនោះតែម្នាក់ឯងទេ។ ការសារភាពជាអំណោយមកពីព្រះ។ ព្រះអង្គប្រើវា ដើម្បីលាងសម្អាតចិត្តយើង ហើយរំដោះយើងឲ្យមានសេរីភាព។—Winn Collier

តើអ្នកចាំបាច់ត្រូវសារភាពកំហុសអ្វីខ្លះ ហើយទៅកាន់នរណា? តើមានអ្វីរារាំងអ្នកមិនឲ្យសារភាព?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំ ឲ្យបើកចំហចិត្ត និងមានចិត្តក្លាហានក្នុងការសារភាពកំហុសរបស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៧៤-៧៦ និងរ៉ូម ៩:១៦-៣៣

កុំឲ្យភ្លេចនឹងធ្វើគុណ ហើយចែកចាយឡើយ ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យនឹងគ្រឿងបូជាយ៉ាងនោះ (ហេព្រើរ ១៣:១៦)។

បង្ហាញសេចក្តីស្រឡាញ់ក្នុងការប្រព្រឹត្ត

ស្ត្រីមេម៉ាយម្នាក់ ជាអ្នកជិតខាងរបស់សុភាពបុរសវ័យចំណាស់ម្នាក់ ជាង៥ឆ្នាំមកហើយ។ ថ្ងៃមួយ បុរសនោះមានការព្រួយបារម្ភអំពីសុខុមាលភាពរបស់នាង ក៏បានចុចកណ្តឹងទ្វារផ្ទះនាង។ គាត់ក៏បានប្រាប់នាងថា «ខ្ញុំមិនបានឃើញអ្នកជិតមួយសប្តាហ៍ហើយ។ ខ្ញុំគ្រាន់តែចង់មកមើល អ្នកមានសុខទុក្ខយ៉ាងណាដែរ»។ ការដែលគាត់ចង់ដឹងពីសុខទុក្ខរបស់នាង គឺបានលើកទឹកចិត្តនាងណាស់។ នាងបានបាត់បង់ឪពុកតាំងពីក្មេង ដូចនេះនាងមានការលើកទឹកចិត្តណាស់ ពេលដែលបានដឹងថា មានបុរសចិត្តល្អម្នាក់ព្រួយបារម្ភអំពីនាង និងក្រុមគ្រួសាររបស់នាង។

ពេលណាយើងបង្ហាញចេញនូវចិត្តសប្បុរស ដោយមិនចង់បានការតបស្នង ឬមិនមែនដើម្បីឲ្យគេសរសើរយើង នោះមានន័យថា យើងកំពុងបម្រើអ្នកដទៃ ដោយនាំឲ្យពួកគេស្គាល់សេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទ។ កណ្ឌគម្ពីរហេព្រើរបានចែងថា អ្នកជឿព្រះយេស៊ូវត្រូវ «ថ្វាយពាក្យសរសើរ ដោយសារទ្រង់ ទុកជាគ្រឿងបូជាដល់ព្រះជានិច្ច គឺជាផលនៃបបូរមាត់ ដែលថ្លែងប្រាប់ពីព្រះនាមទ្រង់» (ហេព្រើរ ១៣:១៥)។ បន្ទាប់មក កណ្ឌគម្ពីរហេព្រើរក៏បានបង្គាប់ពួកគេ ឲ្យបង្ហាញចេញនូវសេចក្តីជំនឿក្នុងការរស់នៅ ដោយមិន «ភ្លេចនឹងធ្វើគុណ ហើយចែកចាយឡើយ ដ្បិតព្រះទ្រង់សព្វព្រះហឫទ័យនឹងគ្រឿងបូជាយ៉ាងនោះ» (ខ.១៦)។

ការថ្វាយបង្គំព្រះយេស៊ូវ ដោយថ្លែងព្រះនាមព្រះអង្គ គឺជាដង្វាយដែលយើងត្រូវថ្វាយដោយអំណរ និងជាឯកសិទ្ធិដែលយើងម្នាក់ៗមាន។ ប៉ុន្តែ យើងអាចបង្ហាញក្តីស្រឡាញ់ពិតប្រាកដដល់ព្រះអម្ចាស់បាន នៅពេលណាយើងមានសេចក្តីស្រឡាញ់ដូចព្រះយេស៊ូវ។ យើងអាចទូលសូមព្រះវិញ្ញាណបរិសុទ្ធជួយយើង ឲ្យមើលឃើញឱកាស ស្រឡាញ់មនុស្សនៅក្នុង និងនៅក្រៅគ្រួសាររបស់យើង។ សរុបមក យើងអាចនាំគេឲ្យស្គាល់ព្រះយេស៊ូវតាមរយៈការបម្រើ ជាការប្រព្រឹត្តដែលមានក្តីស្រឡាញ់ ជាសារដែលមានអំណាច។—Xochitl Dixon

តើអ្នកអាចចែកចាយសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវតាមរបៀបដ៏សាមញ្ញ និងជាក់ស្តែងជាមួយនរណាម្នាក់ដោយរបៀបណា? តើធ្វើដូចម្តេចឲ្យអ្នកអាចមានចិត្ត ដែលចង់បង្ហាញសេចក្តីសប្បុរសតាមរយៈការប្រព្រឹត្តរបស់អ្នក?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យថ្វាយបង្គំព្រះអង្គ ដោយបង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកដទៃតាមរយៈពាក្យសម្តី និងការប្រព្រឹត្តជារៀងរាល់ថ្ងៃ។

Daily Manna 2026_Content Enhance.indd 227 17/11/25 1:46 in the afternoon

លោកនេះក៏ក្រោកឡើងកាប់ចាក់ពួកភីលីស្ទីន ទាល់តែរោយដៃ (២សាំយ៊ូអែល ២៣:១០)។

ប្រកាន់ខ្ជាប់តាមព្រះបន្ទូល

កាលអ្នកស្រី ចូនី អេរីកសិន តាដា(Joni Eareckson Tada) ចែកចាយអំពីមិត្តភក្តិរបស់គាត់ឈ្មោះ រីកា(Rika) គាត់បាននិយាយសង្កត់ធ្ងន់អំពីសេចក្តីជំនឿរបស់អ្នកស្រី រីកា ដែលមានភាពស៊ីជម្រៅ និងមានការល្បងល ហើយបាននិយាយអំពីការស៊ូទ្រាំដែលអ្នកស្រី រីកាមាន ខណៈពេលដែលគាត់កំពុងរស់នៅដោយមានជំងឺរ៉ាំរ៉ៃ។ អ្នកស្រី រីកា បានសម្រាកព្យាបាលជំងឺនៅលើគ្រែ ជាង១៥ឆ្នាំហើយ ដោយមិនអាចក្រោកមើលដួងច័ន្ទរះ នៅមាត់បង្អួចដ៏តូចរបស់បន្ទប់គាត់បានទេ។ ប៉ុន្តែ គាត់មិនបានអស់សង្ឃឹមឡើយ ព្រោះគាត់បានទុកចិត្តព្រះ គាត់បានអាន និងរៀនព្រះគម្ពីរ ហើយគាត់បានរៀបរាប់ថា នេះជារបៀបដែលគាត់ឈរមាំក្នុងអំឡុងពេលដែលគាត់តយុទ្ធក្នុងសង្គ្រាមដ៏សាហាវនៃការធ្លាក់ទឹកចិត្ត។

ទីបន្ទាល់នៃការប្តេជ្ញាចិត្ត និងការស៊ូទ្រាំរបស់អ្នកស្រី រីកា បានធ្វើឲ្យអ្នកស្រី ចូនី នឹកចាំអំពីទីបន្ទាល់របស់លោក អេលាសារ ជាទាហានដ៏អង់អាចដែលមិនព្រមរត់គេចពីពួកភីលីស្ទីនក្នុងសម័យស្តេច ដាវីឌ។ គាត់មិនបានរត់ជាមួយពួកទាហានដែលកំពុងបាក់ទ័ពនោះទេ ផ្ទុយទៅវិញគាត់បាន “ក្រោកឡើងកាប់ចាក់ពួកភីលីស្ទីនទាល់តែរោយដៃ” (២សាំយូអែល ២៣:១០)។ “ព្រះយេហូវ៉ាទ្រង់ប្រោសឲ្យមានជ័យជំនះយ៉ាងធំ” ដោយព្រះចេស្តាព្រះអង្គ(ខ.១០)។ អ្នកស្រី ចូនី បានសង្កេតឃើញថា ដៃលលោក អេលាសារ បានកាន់ដាវរបស់គាត់ជាប់ ដោយការប្តេជ្ញាចិត្តជាយ៉ាងណា នោះអ្នកស្រី រីកា ក៏បានប្រកាន់ខ្ជាប់នូវដាវនៃព្រះវិញ្ញាណ ដែលជាព្រះបន្ទូលព្រះផងដែរ(អេភេសូរ ៦:១៧)។ ហើយគាត់រកឃើញកម្លាំងក្នុងព្រះអង្គ ដើម្បីបន្តរស់នៅថ្វាយព្រះអង្គ។

ទោះយើងកំពុងមានសុខភាពល្អ ឬកំពុងតយុទ្ធនឹងការបាក់ទឹកចិត្ត ដោយសារជំងឺដ៏រ៉ាំរ៉ៃ យើងនៅតែអាចមើលទៅព្រះអង្គ ដោយក្តីសង្ឃឹមកាន់តែមុតមាំ ហើយសូមព្រះអង្គជួយយើងស៊ូទ្រាំនឹងទុក្ខលំបាក។ យើងនឹងរកឃើញកម្លាំង នៅក្នុងព្រះគ្រីស្ទ។—Amy Boucher Pye

តើអ្នកឃើញគំរូនៃការប្តេជ្ញាចិត្ត និងការស៊ូទ្រាំរបស់នរណាខ្លះ? តើព្រះអម្ចាស់បានស្អាងអ្នកជាថ្មីយ៉ាងដូចម្តេចខ្លះ ពេលដែលអ្នកមានអារម្មណ៍ថា ខ្សោះអស់កម្លាំង?

ឱព្រះដែលមានគ្រប់ចេស្តា ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការស្រឡាញ់ទូលបង្គំ និងជួយទូលបង្គំឲ្យអាចស៊ូទ្រាំនឹងទុក្ខលំបាក។ សូមព្រះអង្គជួយទូលបង្គំ ឲ្យផ្តោតចិត្តទៅលើព្រះអង្គ ដើម្បីឲ្យទូលបង្គំអាចបន្តទុកចិត្ត និងស្រឡាញ់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 228 17/11/25 1:46 in the afternoon

ព្រះបន្ទូលនៃទ្រង់ផ្អែមនៅអណ្ដាតទូលបង្គំណាស់ហ្ន៎ (ទំនុកតម្កើង ១១៩:១០៣)។

មនុស្សដែលស្រឡាញ់ព្រះបន្ទូលព្រះ

ក្បួនក្រមុំដ៏ស្រស់ស្អាត កំពុងកាន់ដៃឪពុកដ៏មានមោទនភាពហៀបនឹងចាប់ផ្តើមដើរទៅរកតុអាសនានៅក្នុងព្រះវិហារ។ ប៉ុន្តែ ពួកគេត្រូវរង់ចាំឲ្យក្មួយប្រុសរបស់គេដែលមានអាយុ១៣ខែដើរចូលមុនពួកគេ។ ក្មេងតូចនេះមិនមែនជាអ្នកកាន់ចិញ្ចៀនឲ្យគ្រូស្វាមីភរិយាថ្មីទេ តែជាអ្នកកាន់ព្រះគម្ពីរឲ្យពួកគេវិញ។ នៅថ្ងៃនោះ កូនកំឡោះ និងកូនក្រមុំ ដែលសុទ្ធតែជាអ្នកជឿព្រះយេស៊ូវ ដោយការប្តេជ្ញាចិត្ត មានចិត្តចង់ប្រើឱកាសពេលនោះដើម្បីធ្វើបន្ទាល់អំពីសេចក្តីស្រឡាញ់ដែលពួកគេមានចំពោះព្រះគម្ពីរ។ ដោយមានការរំខានតិចតួចបំផុត ក្មេងតូចចេះដើរតេះតះនោះ ក៏បានដើរទៅដល់ខាងមុខតុអាសនា។ គេឃើញស្នាមធ្មេញរបស់ក្មេងតូចនៅលើក្របព្រះគម្ពីរធ្វើពីស្បែក គឺហាក់ដូចជាចង់ភ្លក់រស់ជាតិព្រះគម្ពីរ។ ទិដ្ឋភាពនៅពេលនោះពិតជាមានន័យ ដោយបានរំឭកយើងអំពីអ្នកជឿព្រះគ្រីស្ទ ឬអ្នកដែលចង់ស្គាល់ព្រះអង្គ ដែលមានចិត្តចង់ភ្លក់រស់ជាតិ និងទទួលយកព្រះបន្ទូលទុកក្នុងចិត្ត។

បទគម្ពីរទំនុកតម្កើងជំពូក១១៩ បានលើកតម្កើង និងបកស្រាយអំពីតម្លៃរបស់ព្រះបន្ទូលព្រះ ដែលបានកត់ទុកក្នុងព្រះគម្ពីរ។ បន្ទាប់ពីអ្នកនិពន្ធបទគម្ពីរនេះ បានប្រកាសអំពីព្រះពររបស់អ្នកដែលបានរស់នៅស្របតាមក្រឹត្យវិន័យរបស់ព្រះ (ខ.១) គាត់ក៏បានពិពណ៌នាអំពីសេចក្តីស្រឡាញ់ ដែលគាត់មានចំពោះព្រះបន្ទូលព្រះយ៉ាងដូចនេះថា «សូមទ្រង់ពិចារណាដែលទូលបង្គំស្រឡាញ់ ដល់អស់ទាំងបញ្ញត្តរបស់ទ្រង់ជាយ៉ាងណា» (ខ.១៥៩) «ទូលបង្គំជិនណាយ ហើយក៏ស្អប់ខ្ពើមសេចក្តីកំភូត តែស្រឡាញ់ដល់ក្រឹត្យវិន័យទ្រង់វិញ» (ខ.១៦៣) «ព្រលឹងទូលបង្គំបានកាន់តាមសេចក្តីបន្ទាល់របស់ទ្រង់ ទូលបង្គំក៏ស្រឡាញ់សេចក្តីបន្ទាល់នោះយ៉ាងក្រៃលែង» (ខ.១៦៧)។

តើយើងបានបង្ហាញសេចក្តីស្រឡាញ់ចំពោះព្រះ និងព្រះបន្ទូលព្រះអង្គ តាមរយៈទីបន្ទាល់នៃការរស់នៅរបស់យើងដូចម្តេចខ្លះ? វិធីមួយ ដើម្បីល្បងលសេចក្តីស្រឡាញ់ដែលយើងមានចំពោះព្រះអង្គ យើងអាចសួរខ្លួនឯងថា តើផ្នត់គំនិតរបស់ខ្ញុំមានភាពសមស្របនឹងព្រះបន្ទូលព្រះអង្គដែរឬទេ? តើខ្ញុំកំពុងតែ «ទំពារ» ពាក្យពេចន៍ដ៏ផ្អែមនៃព្រះគម្ពីរដែរឬទេ? ហើយបន្ទាប់មក ចូរយើងទទួលការអញ្ជើញឲ្យ «ភ្លក់មើលឲ្យដឹងថា ព្រះយេហូវ៉ាទ្រង់ល្អចុះ» (៣៤:៨)។—Arthur Jackson

តើអ្នកចូលចិត្តរស់ជាតិអ្វីជាងគេ? តើសេចក្តីស្រឡាញ់ដែលអ្នកមានចំពោះព្រះអម្ចាស់ និងព្រះបន្ទូលព្រះអង្គអាចចម្រើនឡើងដូចម្តេចខ្លះ?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ព្រះអង្គជ្រាបថា ទូលបង្គំត្រូវការផ្ទាស់ប្តូរបបអាហារខាងវិញ្ញាណ។ សូមព្រះអង្គប្រទានទូលបង្គំនូវចិត្តក្លាហាន និងកម្លាំង ដើម្បីធ្វើការផ្ទាស់ប្តូរដ៏ចាំបាច់ ដើម្បីឲ្យសេចក្តីស្រឡាញ់ដែលទូលបង្គំមានចំពោះព្រះអង្គបានចម្រើនឡើង។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៨១-៨៣ និងរ៉ូម ១១:១៩-៣៦

អ្នកណាដែលទទួលកូនតូច១ ដូចជាកូននេះ ដោយនូវឈ្មោះខ្ញុំ នោះក៏ឈ្មោះថាទទួលខ្ញុំ (ម៉ាកុស ៩:៣៧)។

ចិត្តដែលស្វាគមន៍អ្នកដទៃ

មានពេលមួយ ខ្ញុំដើរកមើលក្រណាត់ជូតជើង នៅក្នុងផ្សារទំនើបមួយ ក្នុងតំបន់ដែលខ្ញុំរស់នៅ។ ពេលនោះ ខ្ញុំបានកត់សម្គាល់ឃើញថា ពាក្យដែលគេបានបោះពុម្ពពីលើក្រណាត់ជូតជើងនីមួយៗ ដែលមានដូចជា ពាក្យ «សួស្តី!» ពាក្យ «ផ្ទះ» ដែលមានរូបបេះដូង។ ហើយខ្ញុំក៏បានជ្រើសរើសយកក្រណាត់ជូតជើងដែលមានពាក្យ «សូមស្វាគមន៍» ជាពាក្យគេចូលចិត្តប្រើច្រើនជាងគេ នៅលើក្រណាត់ជូតជើង ដែលគេដាក់នៅមាត់ទ្វារផ្ទះ។ ពេលខ្ញុំយកវាទៅដាក់នៅមាត់ទ្វារផ្ទះខ្ញុំ ខ្ញុំក៏បានពិនិត្យមើលចិត្តខ្លួនឯង។ តើផ្ទះរបស់ខ្ញុំពិតជាមានភាពចៅរ៉ៅ ស្របតាមបំណងព្រះទ័យព្រះដែរឬទេ? តើចៅរ៉ៅចំពោះក្មេងដែលមកលក់ស្ករសូកូឡា ដើម្បីរកប្រាក់ទៅរៀន? តើចៅរ៉ៅចំពោះអ្នកជិតខាងដែលកំពុងខ្វះខាត? តើចៅរ៉ៅចំពោះសាច់ញាតិនៅខេត្ត ដែលបានទូរស័ព្ទមក នៅពេលយប់អាធ្រាត្រដែរឬទេ?

ក្នុងកណ្ឌគម្ពីរម៉ាកុសជំពូក៩ ព្រះយេស៊ូវបានយាងចេញពីភ្នំដែលសាវ័ក ពេត្រុស យ៉ាកុប និងយ៉ូហាន បានឈរមើលព្រះអង្គប្រែព្រះភក្ត្រចេញពន្លឺ ដោយពួកគេមានចិត្តស្ងប់ស្ងែងចំពោះព្រះវត្តមានដ៏បរិសុទ្ធ (ខ.១-១៣) ហើយក៏បានបណ្តេញអារក្សចេញពីក្មេងប្រុសម្នាក់ ដែលកាលពីមុនឪពុកគាត់គ្មានសង្ឃឹមថា កូននោះអាចមានសេរីភាពបាន(ខ.១៤-២៩)។ បន្ទាប់មក ព្រះយេស៊ូវក៏បានប្រទានការបង្រៀនដោយឡែកដល់ពួកសាវ័កអំពីការសុគតរបស់ព្រះអង្គដែលត្រូវមកដល់ (ខ.៣០-៣២)។ តែពួកគេមិនទាន់យល់ព្រះបន្ទូលព្រះអង្គនៅឡើយទេ (ខ.៣៣-៣៤)។ ព្រះអង្គក៏បានឆ្លើយតប ដោយនាំក្មេងតូចម្នាក់ ដាក់នៅកណ្តាលចំណោមពួកគេ ដោយបន្ទូលថា «អ្នកណាដែលទទួលកូនតូច១ ដូចជាកូននេះ ដោយនូវឈ្មោះខ្ញុំ នោះក៏ឈ្មោះថាទទួលខ្ញុំ ហើយអ្នកណាដែលទទួលខ្ញុំ នោះមិនមែនទទួលខ្ញុំទេ គឺឈ្មោះថាទទួលព្រះដែលបានចាត់ឲ្យខ្ញុំមកវិញ» (ខ.៣៧)។ ពាក្យ «ទទួល» ក្នុងបទគម្ពីរនេះ គឺមានន័យថា ទទួល និងស្វាគមន៍ជាភ្ញៀវ។ ព្រះយេស៊ូវសព្វព្រះទ័យឲ្យសិស្សព្រះអង្គស្វាគមន៍មនុស្សទាំងអស់រាប់បញ្ចូលទាំងអ្នកដែលគេមិនឲ្យតម្លៃ និងមិនរាប់រក និយាយរួម គឺត្រូវស្វាគមន៍គេដូចយើងស្វាគមន៍ព្រះអង្គដែរ។

ខ្ញុំបានគិតអំពីក្រណាត់ជូតជើងរបស់ខ្ញុំ ដែលមានពាក្យស្វាគមន៍ ហើយសួរខ្លួនឯងថា តើខ្ញុំបានចែកចាយសេចក្តីស្រឡាញ់របស់ព្រះអង្គដល់អ្នកដទៃយ៉ាងដូចម្តេចខ្លះ។ ការនេះបានចាប់ផ្តើមដោយការស្វាគមន៍ព្រះយេស៊ូវ មិនគ្រាន់តែធ្វើជាភ្ញៀវ តែជាម្ចាស់ជីវិតរបស់ខ្ញុំ។ តើខ្ញុំនឹងអនុញ្ញាតឲ្យព្រះអង្គដឹកនាំខ្ញុំ ដោយស្វាគមន៍អ្នកដទៃតាមរបៀបដែលព្រះអង្គសព្វព្រះទ័យដែរឬទេ?—Elisa Morgan

តើអ្នកស្វាគមន៍ព្រះយេស៊ូវចូលក្នុងចិត្តអ្នកនៅពេលណា និងដោយរបៀបណា? តើការនេះគួរតែមានឥទ្ធិពលយ៉ាងណាខ្លះ មកលើរបៀបដែលអ្នកស្វាគមន៍អ្នកដទៃ?

ឱព្រះយេស៊ូវ សូមព្រះអង្គដឹកនាំជីវិតទូលបង្គំ ហើយបង្រៀនទូលបង្គំឲ្យចេះស្វាគមន៍មនុស្សទាំងអស់ដោយមិនរើសអើង។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៨៤-៨៦ និងរ៉ូម ១២

មើល អញនឹងធ្វើការ១ថ្មីវិញ ការនោះនឹងលេចឡើងឥឡូវ (អេសាយ ៤៣:១៩)។

អ្នកទោសរបស់បាប

មានពេលមួយ កីឡាការដ៏ល្បីល្បាញម្នាក់ ជាខ្សែប្រយុទ្ធក្នុងកីឡាបាល់ទាត់អាមេរិកបានបោះជំហានឡើងនិយាយនៅលើវេទិកា តែមិនមែននៅក្នុងពហុកីឡដ្ឋាននោះទេ។ ថ្ងៃនោះ គាត់ឈរនិយាយទៅកាន់អ្នកទោស៣រយនាក់ ក្នុងមណ្ឌលកែប្រែអេរីភ្លែត ទីក្រុងម៉ែអាមី រដ្ឋផ្លរីដា ដោយចែកចាយដល់ពួកគេនូវព្រះបន្ទូលក្នុងកណ្ឌអេសាយ។

តែពេលនោះ គាត់មិនចែកចាយអំពីភាពរុងរឿងរបស់កីឡាការដ៏ល្បីល្បាញនោះទេ តែគាត់បាននិយាយអំពីវិញ្ញាណមនុស្សជាច្រើន ដែលកំពុងមានភាពប្រេះបែក និងឈឺចាប់។ ក្នុងពេលដ៏ពិសេសនោះ ព្រះអម្ចាស់បានធ្វើការក្នុងមន្ទីរឃុំឃាំងនោះ។ អ្នកសង្កេតមើលព្រឹត្តិការណ៍នៅថ្ងៃនោះ ក៏បានបង្ហោះសារក្នុងបណ្តាញសង្គមថា “កម្មវិធីជួបជុំគ្នានៅថ្ងៃនោះ ក៏បានផ្ទុះចេញជាការថ្វាយបង្គំ និងច្រៀងសរសើរតម្កើងព្រះ”។ ពួកគេក៏បានទូញយំ និងអធិស្ឋានជាមួយគ្នានៅថ្ងៃនោះ ដោយចិត្តឆេះឆួល។ នៅចុងបញ្ចប់នៃកម្មវិធី អ្នកទោស២៧នាក់បានថ្វាយជីវិតរបស់ខ្លួន ដល់ព្រះគ្រីស្ទ។

តាមពិត ទោះយើងជាអ្នកទោសកំពុងជាប់ឃុំក្នុងមន្ទីរឃុំឃាំងឬអត់ យើងម្នាក់ៗសុទ្ធតែជាប់ឃុំនៅក្នុងគុកនៃភាពលោភលន់ ភាពអាត្មានិយម និងការញៀនអ្វីមួយ។ ប៉ុន្តែ ព្រះអម្ចាស់ក៏បានយាងមករកយើង ដែលនេះជារឿងដ៏អស្ចារ្យណាស់។ ក្នុងមន្ទីរឃុំឃាំងនៅពេលព្រឹកនោះ គេបានដកស្រង់បទគម្ពីរ អេសាយ ៤៣:១៩ ដែលក្នុងនោះ ព្រះអម្ចាស់មានបន្ទូលថា “មើល អញនឹងធ្វើការ១ថ្មីវិញ ការនោះនឹងលេចឡើងឥឡូវ តើឯងរាល់គ្នានឹងមិនស្គាល់ទេឬ?”។ បទគម្ពីរនេះក៏បានលើកទឹកចិត្តយើងឲ្យភ្លេចរឿងចាស់ ហើយឈប់រស់នៅក្នុងអតីតកាលទៀត(ខ.១៨) ដ្បិតព្រះអម្ចាស់មានបន្ទូលថា “គឺអញ អញនេះហើយជាអ្នកដែលលុបអំពើរំលងរបស់ឯងចេញដោយយល់ដល់ខ្លួនអញ ហើយអញមិននឹកចាំអំពើបាបរបស់ឯងទៀតឡើយ” (ខ.២៥)។

តែព្រះអម្ចាស់បានបញ្ជាក់ច្បាស់ថា ក្រៅពីព្រះអង្គ គ្មានព្រះសង្គ្រោះណាទៀតឡើយ (ខ.១១)។ គឺទាល់តែយើងថ្វាយជីវិតយើងដល់ព្រះគ្រីស្ទ ទើបយើងអាចមានសេរីភាព។ សម្រាប់អ្នកដែលបានថ្វាយជីវិតដល់ព្រះអង្គហើយ ពួកគេចាំបាច់ត្រូវចាំថា ព្រះអម្ចាស់នៃជីវិតយើងជានរណា។ ព្រះអង្គបានធានាថា ព្រះអង្គនឹងធ្វើការថ្មីមួយតាមរយៈព្រះគ្រីស្ទ។ យើងនឹងបានឃើញការនោះលេចឡើងមិនខាន។—Kenneth Petersen

តើបាបរបស់អ្នកបានឃុំឃាំងអ្នក ដោយរបៀបណា? តើធ្វើដូចម្តេចឲ្យអ្នកអាចរំដោះខ្លួន ចេញពីភាពបាក់បែកនោះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គរំដោះទូលបង្គំឲ្យរួចផុតពីការឃុំឃាំងរបស់បាបទូលបង្គំ។

Daily Manna 2026_Content Enhance.indd 231 17/11/25 1:46 in the afternoon

ចូរអត់ទោសឲ្យគេចុះ ដូចជាព្រះគ្រីស្ទបានអត់ទោសឲ្យអ្នករាល់គ្នាដែរ (កូល៉ុស ៣:១៣)។

សេចក្តីស្រឡាញ់ដ៏សប្បុរសរបស់ព្រះអង្គ

លោកឧត្តមសេនីយ៍ វីលៀម មែករ៉ាវិន (William McRaven) ជាអតីតយោធាក្នុងកងពលពិសេស ដែលបានចូលនិវត្តន៍។ ក្នុងការថ្លែងសន្ទរកថាក្នុងពិធីចែកសញ្ញាប័ត្រ គាត់បានចែកចាយអំពីកិច្ចការសំខាន់ៗដែលយើងត្រូវធ្វើមុនពេលចូលគេង។ វីដេអូអំពីការថ្លែងសន្ទរកថានៅថ្ងៃនោះ ត្រូវបានគេយកទៅបង្ហោះនៅតាមបណ្តាញសង្គម ហើយមានអ្នកមើលជាង១០០លាននាក់។ ប៉ុន្តែ គាត់ក៏បានចែកចាយនូវមេរៀនមួយទៀត ដែលនាំឲ្យមានការប៉ះពាល់ចិត្តយ៉ាងខ្លាំងជាងដែរ។ ក្នុងអំឡុងពេលប្រតិបត្តិការសឹកក្នុងតំបន់មជ្ឈិមបូព៌ា គាត់បានទទួលស្គាល់យ៉ាងសោកសៅថា មានសមាជិកមួយចំនួនក្នុងគ្រួសារដ៏ស្លូតត្រង់មួយបានបាត់បង់ជីវិត ដោយសារការយល់ច្រឡំរបស់កងទ័ពគាត់។ គាត់ជឿថា គាត់នៅជំពាក់ការសុំទោស ចំពោះគ្រួសារមួយនេះ។ គាត់ក៏បានទៅសុំទោសបុរសជាឪពុករបស់គ្រួសារនេះ ដោយគ្មានការភ័យខ្លាច។

គាត់ក៏បានប្រាប់បុរសជាឪពុកតាមរយៈអ្នកបកប្រែថា «ខ្ញុំគ្រាន់តែជាទាហានដែលធ្វើការតាមបញ្ជា ប៉ុន្តែខ្ញុំក៏មានកូនដែរ ដូចនេះខ្ញុំយល់អំពីអារម្មណ៍របស់អ្នក ចិត្តរបស់ខ្ញុំពិតជាសោកសៅ ចំពោះអ្នកណាស់»។ តើបុរសនោះបានឆ្លើយតបដូចម្តេច? បុរសនោះក៏បានផ្តល់ឲ្យគាត់នូវការអត់ឱនទោស ជាអំណោយដ៏សប្បុរស។ កូនប្រុសម្នាក់ទៀតរបស់បុរសនោះ ដែលរួចពីសេចក្តីស្លាប់ ក៏បានប្រាប់គាត់ថា «ខ្ញុំសូមអរគុណអ្នកខ្លាំងណាស់។ គ្រួសាររបស់ខ្ញុំបានអត់ទោសឲ្យអ្នកហើយ ចិត្តរបស់យើងនឹងមិនចងកំហឹងចំពោះអ្នកទេ»។

សាវ័កប៉ុលក៏បានបង្រៀនអំពីការអត់ទោស ដោយចិត្តសប្បុរស យ៉ាងដូចនេះថា «ចូរប្រដាប់កាយ ដោយចិត្តក្តួលអាណិត សប្បុរស សុភាព សំឡូត និងចិត្តអត់ធ្មត់ ទុកដូចជាពួកអ្នករើសតាំង ដែលបរិសុទ្ធ ហើយស្ងួនភ្ងាដល់ព្រះចុះ» (កូល៉ុស ៣:១២)។ គាត់ដឹងថា ជីវិតយើងនឹងជួបការល្បួងលផ្សេងៗ ហេតុនេះហើយ គាត់ក៏បានបង្រៀនអ្នកជឿព្រះក្នុងពួកជំនុំនៅទីក្រុងកូល៉ុសថា «បើអ្នកណាមានហេតុទាស់នឹងអ្នកណា នោះចូរអត់ទោសឲ្យគេចុះ ដូចជាព្រះគ្រីស្ទបានអត់ទោសឲ្យអ្នករាល់គ្នាដែរ» (ខ.១៣)។

តើធ្វើដូចម្តេចឲ្យយើងអាចមានចិត្តដែលមានក្តីអាណិត ចិត្តដែលអត់ទោសឲ្យអ្នកដទៃ? គឺមានតែសេចក្តីស្រឡាញ់ដ៏សប្បុរសរបស់ព្រះអម្ចាស់ទេ ដែលអាចជួយយើងឲ្យមានការអត់ទោសដូចនេះបាន។ ហេតុនេះហើយ សាវ័ក ប៉ុល ក៏បានធ្វើការសន្និដ្ឋានថា «ចូរបន្ថែមទាំងសេចក្តីស្រឡាញ់ថែមទៀត ជាចំណងនៃសេចក្តីគ្រប់លក្ខណ៍» ហើយយើងត្រូវអនុញ្ញាតឲ្យសេចក្តីស្រឡាញ់របស់ព្រះអង្គគ្រប់គ្រងចិត្តយើង (ខ.១៤-១៥)។— Patricia Raybon

ហេតុអ្វីការអត់ឱនទោស ជាទង្វើដ៏សប្បុរស? តើអ្នកនឹងអត់ទោសឲ្យនរណាខ្លះនៅថ្ងៃនេះ?

ឱព្រះដែលអត់ទោស សូមព្រះអង្គជួយទូលបង្គំឲ្យមានសេចក្តីស្រឡាញ់ដ៏សប្បុរសដូចព្រះអង្គ ដើម្បីឲ្យទូលបង្គំអាចអត់ទោសឲ្យអ្នកដទៃ។

គម្រោងអានព្រះគម្ពីរអស់រយៈពេល១ឆ្នាំ | ទំនុកតម្កើង ៨៩-៩០ និងរ៉ូម ១៤

ទូលបង្គំបានវាប់ទទួលអំពើបាបរបស់ ទូលបង្គំនៅចំពោះទ្រង់ (ទំនុកតម្កើង ៣២:៥)។

បណ្តាលចិត្តឲ្យទទួលស្គាល់កំហុស

កាលខ្ញុំនៅរៀនក្នុងថ្នាក់អនុវិទ្យាល័យ ខ្ញុំបានចូលរួមជាមួយសិស្សមួយក្រុម ដែលនាំគ្នាលេងបាញ់គ្រាប់ធ្វើពីក្រដាស ដោយប្រើបំពង់ទុយោផ្លុំ ឲ្យត្រូវខ្នងរបស់សមាជិកក្រុមតន្ត្រីរបស់សាលា ខណៈពេលដែលពួកគេកំពុងសម្តែង។ ខ្ញុំបាននិយាយកុហកគេថា ខ្ញុំមិនមែនជាអ្នកធ្វើទេ។ ខ្ញុំស្ងើតែងខ្លួនទៅហើយ តែព្រះអម្ចាស់ក៏បានបញ្ឈប់ខ្ញុំទាន់។ នាយកសាលារបស់យើង ជាអតីតយោធាជើងទឹក ហើយគេឮល្បីថា គាត់ពូកែដាក់ពិន័យមកលើសិស្សខូច ហើយខ្ញុំពិតជាខ្លាចគាត់ណាស់។ ដូចនេះ នៅពេលមិត្តភក្តិដែលខ្ញុំបានឃុបឃិតជាមួយបានសារភាពថា ខ្ញុំក៏បានចូលរួមជាមួយពួកគេដែរ ខ្ញុំក៏បានកុហកគាត់ថា ខ្ញុំមិនមែនជាអ្នកធ្វើទេ។ បន្ទាប់មក ខ្ញុំក៏បានកុហកឪពុកខ្ញុំផងដែរ។

ប៉ុន្តែ ព្រះអម្ចាស់មិនបណ្តោយឲ្យការកុហកនេះ ចេះតែបន្តទៅមុខទៀតទេ។ ព្រះអង្គក៏បានបណ្តាលចិត្តខ្ញុំឲ្យប្រកាន់ទោសខ្លួនឯង។ បន្ទាប់ពីខ្ញុំបានព្យាយាមប្រឆាំងព្រះអង្គអស់ជាច្រើនសប្តាហ៍ ខ្ញុំក៏បានទទួលស្គាល់កំហុស។ ខ្ញុំក៏បានទូលសូមការអត់ទោសពីព្រះអង្គ និងពីឪពុករបស់ខ្ញុំ។ មួយរយៈក្រោយមក ខ្ញុំក៏បានទៅផ្ទះរបស់នាយកសាលា ហើយក៏បានសារភាពកំហុស ទាំងទឹកភ្នែក។ អរព្រះគុណព្រះអង្គ ដែលគាត់ជាមនុស្សចិត្តល្អ និងមានការអត់ទោស។

ខ្ញុំមិនដែលភ្លេចអារម្មណ៍ធូរស្រាលដែលខ្ញុំទទួលបាន បន្ទាប់ពីបន្ទុកនោះត្រូវបានលើកចេញនៅថ្ងៃនោះ។ ខ្ញុំមានសេរីភាពរួចផុតពីទម្ងន់នៃការប្រកាន់ទោសខ្លួនឯង ហើយមានចិត្តរីករាយឡើងវិញ បន្ទាប់ពីខ្ញុំមានការពិបាកចិត្តអស់ជាច្រើនសប្តាហ៍។ ស្តេច ដាវីឌ ក៏បានពិពណ៌នាអំពីពេលដែលទ្រង់បានទទួលការបណ្តាលចិត្តឲ្យទទួលស្គាល់កំហុស និងបានសារភាពនៅចំពោះព្រះក្នុងជីវិតទ្រង់ផងដែរ។ គឺដូចដែលទ្រង់ទូលថ្វាយព្រះអម្ចាស់ថា «កាលទូលបង្គំបានស្ងៀមនៅ នោះឆ្អឹងទូលបង្គំបានខ្សោះទៅ ដោយសារដំងូរដែលទូលបង្គំថ្ងូរជាដរាបរាល់ថ្ងៃ ដ្បិតព្រះហស្តនៃទ្រង់បានសង្កត់លើទូលបង្គំជាធ្ងន់ ទាំងយប់ទាំងថ្ងៃ ...ទូលបង្គំបានវាប់ទទួលអំពើបាបរបស់ ទូលបង្គំនៅចំពោះទ្រង់» (ទំនុកតម្កើង ៣២:៣-៥)។

ភាពពិតត្រង់របស់យើង មានសារៈសំខាន់ចំពោះព្រះអម្ចាស់។ ព្រះអង្គសព្វព្រះទ័យឲ្យយើងសារភាពបាបរបស់យើង នៅចំពោះព្រះអង្គ ហើយបើយើងធ្វើខុសមកលើនរណាម្នាក់ ព្រះអង្គសព្វព្រះទ័យឲ្យយើងទៅសុំទោសពួកគេ។ ស្តេច ដាវីឌក បានប្រកាសថា «ឯទ្រង់ក៏បានអត់ទោសចំពោះអំពើបាបនៃទូលបង្គំទៅ» (ខ.៥)។ ក្តីអំណរ និងសន្តិភាពនឹងកើតមានក្នុងចិត្តយើង ពេលណាយើងបានស្គាល់សេរីភាព ដែលយើងទទួលបានពីការអត់ទោសរបស់ព្រះអម្ចាស់។—James Banks

តើការមានភាពពិតត្រង់ចំពោះព្រះបានជួយអ្នកដូចម្តេចខ្លះ? តើការអត់ទោសរបស់ព្រះយេស៊ូវបានដកបន្ទុកចិត្តពីចិត្តអ្នក ហើយកែប្រែជីវិតអ្នកដូចម្តេចខ្លះ?

ឱព្រះវរបិតានៃសេចក្តីស្រឡាញ់ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានអត់ទោសឲ្យទូលបង្គំ ពេលណាទូលបង្គំសារភាពបាប នៅចំពោះព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យមានចិត្តពិតត្រង់ចំពោះព្រះអង្គជានិច្ច។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៩១-៩៣ និងរ៉ូម ១៥:១-១៣

អ្នកទាំងនោះក៏អាក់អន់ចិត្តនឹងទ្រង់ (*ម៉ាកុស ៦:៣*)។

លើសពីបងប្រុស

លោក ចន (Jon) បានទទួលការតែងតាំងជា សាស្ត្រាចារ្យធ្វើការពេញពេលក្នុងមហាវិទ្យាល័យដ៏ល្បីល្បាញមួយ។ លោក ដាវីឌ ជាបងប្រុសរបស់គាត់មានចិត្តរីករាយចំពោះគាត់ ប៉ុន្តែមិនអាចឃាត់ចិត្តខ្លួនឯងមិនឲ្យនិយាយបង្អាប់លោក ចន អំពីរឿងដែលពួកគេធ្លាប់បោកចំបាប់គ្នានៅលើដីកាលពីក្មេង។ លោក ចន មានភាពថ្កុំថ្កើងក្នុងជីវិត ប៉ុន្តែគាត់នៅតែជាប្អូនប្រុសរបស់លោក ដាវីឌ។

ពេលខ្លះ សាច់ញាតិរបស់យើងមិនងាយមានចិត្តស្ងប់ស្ងែងចំពោះភាពជោគជ័យរបស់យើង ហើយសូម្បីតែព្រះមែស៊ីក៏ធ្លាប់ជួបរឿងនេះផងដែរ។ ព្រះយេស៊ូវបានចម្រើនវ័យធំឡើងក្នុងចំណោមប្រជាជននៅស្រុកណាសារ៉ែត ដូចនេះពួកគេពិបាកនឹងជឿថា ព្រះអង្គមានអ្វីដែលពិសេសខុសពីធម្មតា។ ប៉ុន្តែ ពួកគេមានការភ្ញាក់ផ្អើលចំពោះការអ្វីដែលព្រះអង្គបានធ្វើ និងមានបន្ទូល។ បានជាពួកគេសួរគ្នាទៅវិញទៅមកថា «អ្នកនេះបានសេចក្តីទាំងនេះពីណាមក ចំណេះណាហ្ន ដែលបានឲ្យមកគាត់បានជាមានការឫទ្ធិបារមីយ៉ាងនេះកើតមក ដោយសារដៃគាត់ដូច្នេះ តើគាត់មិនមែនជាជាងឈើ ជាកូននៃនាងម៉ារា...ទេឬអី?» (ម៉ាកុស ៦:២-៣)។ ព្រះយេស៊ូវក៏បានមានបន្ទូលកត់សម្គាល់ថា «ហោរាមិនមែនឥតគោរពអានទេ លើកតែនៅក្នុងស្រុកខ្លួន ឬក្នុងពួកញាតិសន្តានហើយនៅក្នុងផ្ទះខ្លួនចេញ» (ខ.៤)។ អ្នកទាំងនោះស្គាល់ព្រះយេស៊ូវច្បាស់ ប៉ុន្តែពួកគេមិនអាចជឿទេថា ព្រះអង្គជាព្រះរាជបុត្រានៃព្រះ។

ទោះអ្នកធ្លាប់បានទទួលការចិញ្ចឹមបីបាច់ក្នុងគ្រួសារដែលកោតខ្លាចព្រះឬអត់ ឬធ្លាប់បានទៅព្រះវិហារច្រៀងសរសើរព្រះ កាលពីក្មេងឬអត់ ព្រះយេស៊ូវតែងតែចាត់ទុកអ្នកជាសមាជិកគ្រួសាររបស់ព្រះអង្គ បើសិនជាអ្នកជឿ និងដើរតាមព្រះអង្គ។ ព្រះអង្គមិនខ្មាសអៀន នៅក្នុងការហៅយើងថា បងប្អូនរបស់ព្រះអង្គឡើយ (ហេព្រើរ ២:១១)។ ព្រះយេស៊ូវជាបងប្រុសរបស់យើងក្នុងមហាគ្រួសារនៃព្រះ (រ៉ូម ៨:២៩)។ នេះជាឯកសិទ្ធិដ៏អស្ចារ្យ ប៉ុន្តែភាពជិតស្និទ្ធដែលយើងមានជាមួយព្រះអង្គ អាចធ្វើឲ្យយើងមានអារម្មណ៍ថា ព្រះអង្គហាក់ដូចជាគ្មានអ្វីប្លែកសម្រាប់យើង។ ប៉ុន្តែ ដោយសារនរណាម្នាក់ស្ថិតក្នុងគ្រួសារតែមួយជាមួយយើង គឺមិនមានន័យថាពួកគេមិនពិសេសចំពោះយើងនោះទេ។

តើអ្នកមិនសប្បាយចិត្តទេឬ ពេលដែលបានដឹងថា ព្រះយេស៊ូវជាបងប្រុសរបស់យើង ហើយលើសពីបងប្រុសផង? ចូរយើងមានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយព្រះអង្គ ដោយចាត់ទុកព្រះអង្គជាបុគ្គលពិសេសក្នុងជីវិតយើង ខណៈពេលដែលយើងដើរតាមព្រះអង្គជារៀងរាល់ថ្ងៃ។—Mike Wittmer

តើព្រះយេស៊ូវមានទំនាក់ទំនងជាមួយអ្នកដោយផ្ទាល់ខ្លួន ដូចម្តេចខ្លះ? តើធ្វើដូចម្តេចឲ្យអ្នកនៅតែចាត់ទុកព្រះអង្គ ជាបុគ្គលពិសេស?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការនាំទូលបង្គំចូលមហាគ្រួសាររបស់ព្រះ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ៩៤-៩៦ និងរ៉ូម ១៥:១៤-៣៣

កុំឲ្យធ្វើអ្វី ដោយទាស់ទែងគ្នា ឬដោយសេចក្តីអំនួតឥតប្រយោជន៍ឡើយ តែចូរអាប់អានគេឲ្យលើសជាងខ្លួនដោយចិត្តសុភាពវិញ (ភីលីព ២:៣)។

គិតប្រយោជន៍អ្នកដទៃលើសខ្លួនឯង

កាលក្រុមកីឡាបាល់បោះមកពីសកលវិទ្យាល័យ ហ៊ូវ៉ែឡ ឌីឃិនសិន ដើរចូលក្នុងទីលានប្រកួតកីឡាបាល់បោះមហាវិទ្យាល័យ ទស្សនិកជនជាអ្នកគាំទ្រនៅកន្លែងអង្គុយ ក៏បានស្រែកហ៊ោឲ្យក្រុមកីឡាមួយនេះ។ គេមិនរំពឹងថា ក្រុមនេះនឹងអាចឆ្លងផុតជុំទីមួយឡើយ ប៉ុន្តែពួកគេបានឆ្លងផុត។ ហើយពួកគេក៏បានឮក្រុមភ្លេងលេងបទចម្រៀងប្រយុទ្ធរបស់ពួកគេពីកន្លែងអង្គុយមក តែពួកគេមិនដែលមានក្រុមភ្លេងផ្ទាល់ខ្លួនឡើយ។ ក្រុមភ្លេងមកពីសកលវិទ្យាល័យដេយតុនបានរៀនចេះបទចម្រៀងរបស់កីឡាការមួយក្រុមនេះ រយៈពេលតែប៉ុន្មានទីមុនពេលការប្រកួតចាប់ផ្តើម។ ក្រុមភ្លេងនេះអាចលេងបទដែលពួកគេចេះចាំស្ទាត់ តែពួកគេបានសម្រេចចិត្តលេងបទចម្រៀងនេះ ដើម្បីជួយលើកទឹកចិត្តសាលាដទៃទៀត និងក្រុមកីឡាករដទៃទៀត។

សកម្មភាពរបស់ក្រុមភ្លេងនេះអាចធ្វើឲ្យយើងនឹកចាំអំពីការរួបរួម ដែលមានចែងក្នុងកណ្ឌគម្ពីរភីលីព។ សាវ័ក ប៉ុល បានប្រាប់ពួកជំនុំនៅទីក្រុងភីលីព ក៏ដូចជាយើងក្នុងពេលសព្វថ្ងៃឲ្យរស់នៅដោយការរួបរួម ដោយ «ចិត្តគំនិតតែមួយ» (ភីលីព ២:២)។ ជាពិសេស ដោយសារព្រះគ្រីស្ទបានបង្រួបបង្រួមពួកគេហើយ។ ដើម្បីឲ្យពួកគេរួបរួមគ្នា សាវ័ក ប៉ុល បានលើកទឹកចិត្តពួកគេ ឲ្យលះបង់ចោលចិត្តអាត្មានិយម ហើយគិតប្រយោជន៍អ្នកដទៃជាសំខាន់ជាងខ្លួនឯង។

ការឲ្យតម្លៃអ្នកដទៃ ខ្លាំងជាងខ្លួនឯង ប្រហែលមិនកើតមានដោយឯកឯងឡើយ ប៉ុន្តែការឲ្យតម្លៃអ្នកដទៃយ៉ាងដូចនេះ គឺជាការយកតម្រាប់តាមព្រះគ្រីស្ទ។ សាវ័ក ប៉ុល បានបង្រៀនយើងថា «កុំឲ្យធ្វើអ្វី ដោយទាស់ទែងគ្នា ឬដោយសេចក្តីអំនួតឥតប្រយោជន៍ឡើយ តែចូរអាប់អានគេឲ្យលើសជាងខ្លួនដោយចិត្តសុភាពវិញ» (ខ.៣)។ ជាជាងផ្តោតទៅលើខ្លួនឯង យើងត្រូវគិតប្រយោជន៍អ្នកដទៃ ដោយការបន្ទាបខ្លួន(ខ.៤)។

តើយើងអាចជួយទ្រទ្រង់អ្នកដទៃ ដោយរបៀបណា? គឺដោយគិតប្រយោជន៍ពួកគេ ទោះយើងត្រូវស្វែងយល់អំពីការតយុទ្ធរបស់ពួកគេ ឬផ្តល់ឲ្យអ្វីក៏ដោយ ដែលពួកគេត្រូវការជាដើម។—Katara Patton

តើអ្នកអាចគិតប្រយោជន៍នរណាខ្លះនៅថ្ងៃនេះ? តើការគិតប្រយោជន៍អ្នកដទៃ បានលើកកម្ពស់ការរួបរួមយ៉ាងណាខ្លះ?

ឱព្រះអង្គសង្គ្រោះដែលបានបន្ទាបព្រះកាយ សូមព្រះអង្គបង្ហាញទូលបង្គំអំពីរបៀបដែលទូលបង្គំអាចជួយអ្នកដទៃ ដោយគិតប្រយោជន៍ពួកគេលើសខ្លួនឯង។

Daily Manna 2026_Content Enhance.indd 235 17/11/25 1:46 in the afternoon

ពួកចាស់ទុំទាំង២៤នាក់ និងតួមានជីវិតទាំង៤ ក៏ទំលាក់ខ្លួនក្រាបចុះថ្វាយបង្គំចំពោះព្រះ ដែលគង់នៅលើបល្ល័ង្ក ដោយនិយាយថា អាម៉ែន ហាលេលូយ៉ា (វិវរណៈ ១៩:៤)។

ស្ថានសួគ៌បន្លឺសម្លេងច្រៀងដោយអំណរ

មានពេលមួយខ្ញុំបានស្តាប់ក្រុមចម្រៀងវិទ្យាល័យ ច្រៀងបទជាភាសាអាហ្សង់ទីនមានចំណងជើងថា "El Cielo Canta Alegría"។ តាមរយៈសម្លេងច្រៀងរបស់ពួកគេ ខ្ញុំអាចដឹងថា ពួកគេកំពុងតែច្រៀងដោយអំណរ។ ខ្ញុំពេញចិត្តនឹងការសម្តែងរបស់ពួកគេ តែមិនអាចយល់ពាក្យពេចន៍ដែលពួកគេច្រៀង ព្រោះខ្ញុំមិនចេះភាសាអេស្ប៉ាញ។ ប៉ុន្តែ មិនយូរប៉ុន្មាន ខ្ញុំក៏បានស្គាល់ពាក្យមួយ នៅពេលដែលក្រុមចម្រៀងនេះបានដំឡើងសម្លេងច្រៀងដោយអំណរថា "អាលេលូយ៉ា!"។ ខ្ញុំក៏បានឮពាក្យ "អាលេលូយ៉ា" ម្តងហើយម្តងទៀត ជាពាក្យប្រកាសនូវការសរសើរតម្កើងដល់ព្រះ ដែលមានសំនៀងស្រដៀងនឹងពាក្យក្នុងភាសាដទៃទៀតនៅជុំវិញពិភពលោក ដែលអានថា "ហាលេលូយ៉ា"។ ពេលនោះ ខ្ញុំពិតជាចង់ដឹងអំពីអត្ថន័យរបស់បទនេះណាស់ បានជាខ្ញុំបើករកមើលបទចម្រៀងនេះ ក្នុងបណ្តាញអ៊ីនធឺណិត បន្ទាប់ពីការប្រតិតន្ត្រីបានបញ្ចប់ ហើយក៏បានរកឃើញចំណងជើងដែលបកប្រែមកថា "ស្ថានសួគ៌កំពុងច្រៀងដោយអំណរ"។

បទចម្រៀងនេះ បានធ្វើឲ្យខ្ញុំនឹកចាំអំពីការពិពណ៌នាអំពីក្តីអំណរដែលកើតមានពេញនគរស្ថានសួគ៌ ដូចមានចែងក្នុងបទគម្ពីរវិវរណៈជំពូក១៩។ ក្នុងការបើកសម្តែងដែលសាវ័ក យ៉ូហាន បានទទួលអំពីពេលអនាគតក្នុងកណ្តាលគម្ពីរចុងក្រោយនៃព្រះគម្ពីរសញ្ញាថ្មី គាត់បានឃើញការជួបជុំដ៏ធំសម្បើមរបស់មនុស្ស និងពួកទេវតាក្នុងនគរស្ថានសួគ៌ ដោយប្រកាស អំពីការអរព្រះគុណដល់ព្រះអម្ចាស់។ សាវ័ក យ៉ូហាន បានពិពណ៌នាថាពួកគេបានបន្លឺសម្លេងសរសើរតម្កើងព្រះចេស្តារបស់ព្រះ ដែលបានឈ្នះការអាក្រក់ និងភាពអយុត្តិធម៌គ្រប់យ៉ាង និងអបអរការគ្រងរាជរបស់ព្រះអង្គលើផែនដីទាំងមូល ព្រមទាំងអបអរជីវិតអស់កល្ប សម្រាប់រស់នៅជាមួយព្រះអង្គជារៀងរហូត។ គ្រប់គ្នានៅស្ថានសួគ៌ក៏បានប្រកាសថា "ហាលេលូយ៉ា!" (ខ.១, ៣, ៤, ៦) ដែលមានន័យថា "សរសើរព្រះអង្គ!"

ថ្ងៃមួយ មនុស្ស "ចេញពីគ្រប់ទាំងពូជមនុស្សគ្រប់ភាសា គ្រប់នគរ ហើយពីគ្រប់ទាំងសាសន៍" (៥:៩) នឹងប្រកាសសិរីល្អរបស់ព្រះ។ ហើយទោះយើងមកពីជាតិសាសន៍ណាក៏ដោយ យើងនឹងបន្លឺសម្លេងច្រៀងទាំងអស់គ្នាថា "ហាលេលូយ៉ា!"—Lisa M. Samra

នៅថ្ងៃនេះ តើអ្នកមានហេតុផលអ្វី ដែលត្រូវបន្លឺសម្លេងថា «ហាលេលូយ៉ា»? ហេតុអ្វីយើងចាំបាច់ត្រូវសរសើរតម្កើងព្រះជាទៀងទាត់?

ហាលេលូយ៉ា! ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានឲ្យទូលបង្គំស្គាល់ក្តីអំណរព្រោះព្រះអង្គស្រឡាញ់ទូលបង្គំ។

ព្រះយេហូវ៉ាទ្រង់បំភ្លឺ ក្នុងទីងងឹតនៃទូលបង្គំ (*២សាំយូអែល ២២:២៩*)។

ពេលដែលទូលបង្គំស្ថិតក្នុងភាពងងឹត

កងទ័ពអាមេរិកមិនបានផ្តល់ឱកាសឲ្យលោក ថូនី វ៉ាខារ៉ូ (Tony Vaccaro) ចូលបម្រើការងារជាអ្នកថតរូបរបស់កងទ័ពទេ ប៉ុន្តែបញ្ហានេះមិនបានរារាំងគាត់មិនឲ្យទៅថតរូបនៅសមរភូមិឡើយ។ ក្នុងពេលដែលគួរឲ្យតក់ស្លុត ខណៈពេលដែលទាហានទាំងឡាយកំពុងគេចពីគ្រាប់ផ្លោង និងអំបែងគ្រាប់ដែលហាក់ដូចជាធ្លាក់ចុះមកដូចទឹកភ្លៀង គាត់នៅតែបន្តថតរូប ដោយមិនរួញរា។ បន្ទាប់មក នៅពេលដែលមិត្តភក្តិរបស់គាត់កំពុងគេងលង់លក់ នៅពេលយប់ គាត់ក៏បានប្រើមួកដែករបស់គាត់ ដើម្បីលាយទឹកជាមួយសារធាតុសម្រាប់ផ្តិតរូបដែលគាត់ថតបាន។ ព្រៃឈើនៅពេលយប់ងងឹតប្រៀបដូចជាបន្ទប់ងងឹតសម្រាប់ឲ្យជាងថតរូបនេះ ផ្តិតរូបថតនៃការប្រយុទ្ធគ្នាមួយក្នុងព្រៃហូតហ្គិន ក្នុងសម័យសង្គ្រាមលោកលើកទីពីរ។

ស្តេចដាវីឌបានឆ្លងកាត់សង្គ្រាម និងពេលដ៏ងងឹតផងដែរ។ បទគម្ពីរ ២សាំយូអែល ២២ បានចែងថា «ឯនៅថ្ងៃ ដែលព្រះយេហូវ៉ាបានជួយសង្គ្រោះដាវីឌ ឲ្យរួចពីកណ្តាប់ដៃនៃពួកខ្មាំងសត្រូវទ្រង់ទាំងប៉ុន្មាន ហើយពីកណ្តាប់ដៃនៃសូល» (ខ.១)។ តាមរយៈបទពិសោធន៍នៅពេលនោះ ស្តេច ដាវីឌ ក៏បាននិពន្ធទំនុកតម្កើង ប្រកាសអំពីសេចក្តីស្មោះត្រង់របស់ព្រះអម្ចាស់។ ទ្រង់ពោលថា «ដ្បិតរលកនៃសេចក្តីស្លាប់បានព័ទ្ធជុំវិញទូលបង្គំ សេចក្តីទុច្ចរិតបានហូរជន់ឡើង បំភ័យទូលបង្គំ» (ខ.៥)។

មិនយូរប៉ុន្មាន ស្តេច ដាវីឌ ក៏បានផ្លាស់ប្តូរពីភាពទាល់ច្រកទៅជាមានសង្ឃឹម គឺដូចដែលទ្រង់មានបន្ទូលថា «នៅគ្រាមានសេចក្តីវេទនា នោះទូលបង្គំបានអំពាវនាវដល់ព្រះយេហូវ៉ា គឺបានស្រែករកព្រះនៃទូលបង្គំ ទ្រង់ក៏ឮសំឡេងនៃទូលបង្គំពីក្នុងព្រះវិហារទ្រង់» (ខ.៧)។ ស្តេច ដាវីឌ បានប្តេជ្ញាចិត្តថា ទ្រង់នឹងសរសើរតម្កើងព្រះអម្ចាស់ដោយសារព្រះអង្គតែងតែយកព្រះទ័យទុកដាក់។ គឺដូចដែលទ្រង់ពោលថា «ព្រះយេហូវ៉ាទ្រង់បំភ្លឺ ក្នុងទីងងឹតនៃទូលបង្គំ។ ពីព្រោះដោយពឹងដល់ទ្រង់ នោះទូលបង្គំរត់ចូលទៅតនឹងកងទ័ព ដោយសារព្រះនៃទូលបង្គំ នោះទូលបង្គំលោតរំលងកំផែងបាន» (ខ.២៩-៣០)។

ស្តេច ដាវីឌ បានប្រើទុក្ខលំបាករបស់ទ្រង់ទៅជាឱកាស ដើម្បីប្រកាសប្រាប់លោកីយ៍អំពីព្រះដ៏ស្មោះត្រង់របស់ទ្រង់។ យើងក៏អាចធ្វើដូចទ្រង់ផងដែរ។ សរុបមក យើងសុទ្ធតែត្រូវពឹងផ្អែកលើព្រះដែលអាចកែប្រែភាពងងឹតទៅជាពន្លឺ។—Tim Gustafson

តើអ្នកជួបភាពទាល់ច្រកខ្លាំងបំផុត នៅពេលណា? តើអ្នកអាចប្រាប់អ្នកដទៃដូចម្តេចខ្លះអំពីសេចក្តីស្មោះត្រង់ ដែលព្រះអង្គមានចំពោះអ្នកនៅពេលនោះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យមើលឃើញរបៀបជាច្រើន ដែលព្រះអង្គការពារ និងជួយទូលបង្គំ ជាពិសេសនៅពេលដែលទូលបង្គំស្ថិតក្នុងភាពងងឹត។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ១០៣-១០៤ និង១កូរិនថូស ២

ដ្បិតខ្ញុំបានអរជាខ្លាំងណាស់ ដោយមានបងប្អូនមកធ្វើបន្ទាល់ ពីសេចក្តីពិតដែលនៅក្នុងអ្នក (៣យ៉ូហាន ១:៣)។

ឥទ្ធិពលរបស់យើងមកលើអ្នកដទៃ

លោកបណ្ឌិត លី(Dr. Lee) ជាសាស្ត្រាចារ្យនៅសាលាព្រះគម្ពីររបស់ខ្ញុំ បានកត់សម្គាល់ឃើញថា លោក ប៊ែនជេ (Benjie) ជាអ្នកបោសសម្អាតសាលាមានភាពយឺតយ៉ាវក្នុងការមកចូលរួមការជួបជុំគ្នា ដើម្បីបរិភោគអាហារពេលល្ងាច ដូចនេះ គាត់ក៏បានរំលែកម្ហូបអាហារមួយចានទុកឲ្យលោក បេនជេ។ ខណៈពេលដែលខ្ញុំកំពុងជជែកគ្នាលេងជាមួយមិត្តរួមថ្នាក់ លោកបណ្ឌិតលីក៏បានចាប់នំទ្រាបបាយដុំចុងក្រោយដាក់ចូលក្នុងចានទុកឲ្យលោក បេនជេ យ៉ាងស្ងៀមស្ងាត់ ដោយបន្តែមដូង និងធាយលូដ៏ឈ្ងុយឆ្ងាញ់ពីលើផង។ ខ្ញុំយល់ឃើញថា ទង្វើដ៏សប្បុរសនេះ ស្ថិតក្នុងចំណោមការល្អជាច្រើន ដែលសាស្ត្រាចារ្យមុខវិជ្ជាទេវវិទ្យារូបនេះបានធ្វើសម្រាប់អ្នកដទៃ ជាការបង្ហូរចេញនូវសេចក្តីសប្បុរសរបស់ព្រះអម្ចាស់តាមរយៈជីវិតគាត់។ ២០ឆ្នាំក្រោយមក ខ្ញុំនៅតែមានចិត្តស្ងប់ស្ងែងចំពោះទីបន្ទាល់របស់គាត់។

សាវ័ក យ៉ូហាន ក៏មានមិត្តជិតស្និទ្ធម្នាក់ ដែលបានបន្សល់ទុកនូវភាពស្ងប់ស្ងែងនៅក្នុងចិត្តអ្នកជឿព្រះជាច្រើន។ ពួកគេបានធ្វើបន្ទាល់ថា លោក កៃយុស ជាមនុស្សស្មោះត្រង់ ចំពោះព្រះ និងព្រះគម្ពីរ ដោយបន្តដើរក្នុង “សេចក្តីពិត” (៣យ៉ូហាន ១:៣)។ លោក កៃយុស បានទទួលអ្នកផ្សាយដំណឹងល្អយ៉ាងរាក់ទាក់ ទោះពួកគេមិនស្គាល់គ្នាក៏ដោយ(ខ.៥)។ ហេតុនេះហើយ សាវ័ក យ៉ូហាន ក៏បានរៀបរាប់ថា គេបានធ្វើបន្ទាល់ពីសេចក្តីស្រឡាញ់របស់លោក កៃយុស (ខ.៦)។ សេចក្តីស្មោះត្រង់ដែលលោក កៃយុស មានចំពោះព្រះ និងចំពោះអ្នកជឿដទៃទៀត មានប្រយោជន៍ចំពោះការផ្សព្វផ្សាយដំណឹងល្អ។

ឥទ្ធិពលដែលគ្រូរបស់ខ្ញុំមានមកលើខ្ញុំ និងឥទ្ធិពលដែលលោក កៃយុស មានមកលើមនុស្សនៅសម័យគាត់ គឺជាការក្រើនរំឭកដ៏មានអំណាចថា ព្រះអម្ចាស់ក៏អាចប្រើឥទ្ធិពលល្អដែលយើងអាចមានមកលើអ្នកដទៃដើម្បីនាំគេឲ្យទទួលជឿព្រះអង្គផងដែរ។ ខណៈពេលដែលយើងដើរដោយចិត្តស្មោះត្រង់ជាមួយព្រះអម្ចាស់ ចូរយើងរស់នៅ និងប្រព្រឹត្ត ធ្វើជាទីបន្ទាល់ល្អ ដែលលើកទឹកចិត្តអ្នកដទៃឲ្យដើរដោយស្មោះត្រង់ជាមួយព្រះអង្គផងដែរ។—Karen Huang

តើធ្វើដូចម្តេចឲ្យអ្នកអាចដឹងថា អ្នកកំពុងតែដើរក្នុងសេចក្តីពិត? តើអ្នកដទៃអាចរៀនសូត្របានអ្វីខ្លះពីជីវិតអ្នក?

ឱព្រះអម្ចាស់ ទូលបង្គំត្រូវការជំនួយរបស់ព្រះអង្គ ដើម្បីរស់នៅដោយចិត្តស្មោះត្រង់ចំពោះព្រះអង្គ និងសេចក្តីពិតរបស់ព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យរស់នៅ តាមរបៀបដែលនាំអ្នកដទៃទៅរកព្រះអង្គ។

Daily Manna 2026_Content Enhance.indd 238 17/11/25 1:46 in the afternoon

ដើម្បីឲ្យអ្នកពាល់គ្នាព្រមព្រៀងមូលមាត់តែមួយនឹងសរសើរតម្កើងដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា (រ៉ូម ១៥:៦)។

រស់នៅដើម្បីថ្វាយសិរីល្អដល់ព្រះ

លោក ចេម អីនណេល កែឃ័រ (James Innell Packer) បានលាកចាកលោក កាលពីឆ្នាំ២០២០ បន្ទាប់ពីថ្ងៃខួបកំណើតរបស់គាត់គំរប់អាយុ៩៤ឆ្នាំបានកន្លងផុតទៅតែ៥ថ្ងៃប៉ុណ្ណោះ។ ក្នុងនាមគាត់ជាអ្នកសិក្សាជ្រៅជ្រះ និងជាអ្នកនិពន្ធសៀវភៅដ៏ល្បីល្បាញមានចំណងជើងថា ការស្គាល់ព្រះ បានលក់ដាច់ជាង១.៥លានក្បាល ចាប់តាំងពីពេលបោះពុម្ពផ្សាយ។ លោក កែឃ័រ បានផ្តោតការបង្រៀនរបស់គាត់ទៅលើអំណាចនៃព្រះគម្ពីរ និងការបង្កើតសិស្ស ហើយបានជំរុញអ្នកជឿព្រះគ្រីស្ទ គ្រប់ទិសទីឲ្យរស់នៅថ្វាយព្រះយេស៊ូវ ដោយចិត្តឆេះឆួល។ គេបានសុំឲ្យគាត់មានប្រសាសន៍ជាពាក្យផ្តាំផ្ញើចុងក្រោយ សម្រាប់ពួកជំនុំក្នុងពេលដែលគាត់មានវ័យចាស់។ ពេលនោះ គាត់គ្រាន់តែនិយាយពាក្យមួយឃ្លាប៉ុណ្ណោះថា «ចូរថ្វាយសិរីល្អដល់ព្រះគ្រីស្ទ ក្នុងគ្រប់ការទាំងអស់»។

ពាក្យសម្តីនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីការរស់នៅរបស់សាវ័ក ប៉ុល ដែលបន្ទាប់ពីគាត់បានប្រែចិត្តជឿព្រះ ដោយការអស្ចារ្យ គាត់ក៏បានចេញទៅធ្វើការបម្រើព្រះអង្គ ដោយចិត្តស្មោះត្រង់ ហើយក៏បានថ្វាយលទ្ធផលនៃការងាររបស់គាត់ ទុកឲ្យព្រះអង្គជាអ្នកសម្រេច។ ការបង្រៀនរបស់សាវ័កប៉ុល ក្នុងកណ្ឌគម្ពីររ៉ូម ស្ថិតក្នុងចំណោមការបង្រៀន ដែលមានលក្ខណៈទេវវិទ្យាច្រើនបំផុតក្នុងព្រះគម្ពីរសញ្ញាថ្មី ហើយគាត់ក៏បានទូលសូមព្រះអម្ចាស់ជួយយើងឲ្យមានចិត្តគំនិតតែមួយតាមព្រះយេស៊ូវគ្រីស្ទ ឲ្យយើងថ្វាយសិរីល្អដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា (១៥:៦)។

ទីបន្ទាល់នៃការរស់នៅរបស់សាវ័ក ប៉ុល បានធ្វើជាគំរូសម្រាប់យើងរាល់គ្នា។ យើងអាចថ្វាយសិរីល្អ ឬថ្វាយព្រះកិត្តិនាមដល់ព្រះតាមរបៀបជាច្រើន ដែលមានដូចជាការរស់នៅ ដោយធ្វើការបម្រើព្រះអង្គ ហើយថ្វាយលទ្ធផលនៃការងាររបស់យើងនៅក្នុងព្រះហស្តដែលមិនចេះប្រែប្រួលរបស់ព្រះអង្គជាដើម។ ទោះយើងជាអ្នកនិពន្ធសៀវភៅ ជាបេសកជន ឬគ្រូបង្រៀនថ្នាក់បឋម ឬកំពុងថែទាំឪពុកម្តាយចាស់ជរាក្តី យើងសុទ្ធតែមានគោលដៅតែមួយ គឺដើម្បី ថ្វាយសិរីល្អដល់ព្រះគ្រីស្ទក្នុងគ្រប់ការទាំងអស់។ ពេលណាយើងអធិស្ឋាន និងអានព្រះគម្ពីរ សូមព្រះអង្គជួយយើងឲ្យរស់នៅ ដោយការស្តាប់បង្គាប់ ដោយចិត្តប្តូរផ្តាច់ ហើយរស់នៅជារៀងរាល់ថ្ងៃត្រឹមត្រូវតាមព្រះបន្ទូលព្រះអង្គ ដើម្បីថ្វាយព្រះកិត្តិនាមដល់ព្រះអង្គក្នុងពាក្យសម្តី និងការប្រព្រឹត្តទាំងអស់។—John Blasé

តើមានលទ្ធផលនៃការងារអ្វី ដែលអ្នកពិចារកថ្វាយព្រះអង្គជាអ្នកសម្រេច? តើនៅថ្ងៃនេះ អ្នកអាចទុកចិត្តផែនការព្រះគ្រីស្ទ ហើយថ្វាយព្រះកិត្តិនាមដល់ព្រះអង្គយ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំ ឲ្យរស់នៅបានល្អ ដើម្បីថ្វាយព្រះកិត្តិនាមដល់ព្រះអង្គនៅថ្ងៃនេះ។

Daily Manna 2026_Content Enhance.indd 239 17/11/25 1:46 in the afternoon

ចូរផ្ទេរបន្ទុករបស់អ្នកទៅលើព្រះយេហូវ៉ា នោះទ្រង់នឹងជួយទប់ទល់អ្នក (ទំនុកតម្កើង ៥៥:២២)។

ផ្ទេរទុក្ខព្រួយរបស់អ្នកដល់ព្រះអម្ចាស់

ស្ត្រីជាម្តាយម្នាក់បានអធិស្ឋានអស់ជាច្រើនឆ្នាំ ខណៈពេលដែលគាត់នាំកូនស្រីគាត់ ជាមនុស្សពេញវ័យទៅទទួលការព្យាបាលជំងឺ ហើយស្វែងរកការប្រឹក្សាយោបល់ និងថ្នាំពេទ្យដែលល្អបំផុត។ សុខភាពរបស់កូនគាត់មានការឡើងចុះៗយ៉ាងខ្លាំង ជាបន្ទុកដ៏ធ្ងន់ក្នុងចិត្តគាត់ពីមួយថ្ងៃទៅមួយថ្ងៃ។ ជាញឹកញាប់ គាត់មានភាពហត់នឿយយ៉ាងខ្លាំង ដោយសារទុក្ខព្រួយ ហើយគាត់ក៏បានដឹងផងដែរថា គាត់ត្រូវថែទាំសុខភាពខ្លួនឯង។ មិត្តភក្តិរបស់គាត់ម្នាក់បានលើកទឹកចិត្តគាត់ ឲ្យសរសេរអំពីទុក្ខព្រួយ និងបញ្ហាដែលគាត់មិនអាចគ្រប់គ្រងបាននៅលើក្រដាសមួយសន្លឹកតូច ដាក់នៅក្នុងចានសំប៉ែតមួយនៅក្បែរគ្រែគេងរបស់គាត់។ ការអនុវត្តន៍ដ៏សាមញ្ញនេះមិនបានលប់បំបាត់ទុក្ខព្រួយរបស់គាត់ទាំងអស់នោះទេ ប៉ុន្តែពេលគាត់ឃើញចាននោះ គាត់ក៏បាននឹកចាំថា គាត់ត្រូវផ្ទេរទុក្ខព្រួយរបស់គាត់ដល់ព្រះអង្គ។

នៅក្នុងបទគម្ពីរទំនុកតម្កើង ស្តេច ដាវីឌ ក៏បានបង្ហាញអំពីរបៀបដែលទ្រង់រៀបរាប់អំពីទុក្ខព្រួយរបស់ទ្រង់ដល់ព្រះអម្ចាស់ (ទំនុកតម្កើង ៥៥:១, ១៦-១៧)។ កាលព្រះអម្ចាស់អាប់សាឡុម ជាបុត្រាទ្រង់ប៉ុនប៉ងដណ្តើមរាជ្យទ្រង់ លោក អ័ហ៊ីថូផែល ជាមិត្តសំឡាញ់របស់ទ្រង់ ក៏បានក្បត់ទ្រង់ ហើយផ្សំគំនិតរៀបគម្រោងធ្វើគុតទ្រង់ផងដែរ(២សាំយ៊ូអែល ១៥-១៦)។ ហេតុនេះហើយ ស្តេចដាវីឌក៏បានទូញយំទាំងយប់ថ្ងៃ ដោយទុក្ខព្រួយយ៉ាងខ្លាំង ហើយព្រះអម្ចាស់ក៏បានឮពាក្យទ្រង់អធិស្ឋាន (ទំនុកតម្កើង ៥៥:១-២, ១៦-១៧)។ ទ្រង់បានសម្រេចព្រះទ័យថ្វាយទុក្ខព្រួយរបស់ទ្រង់ដល់ព្រះអម្ចាស់ ហើយក៏បានដកពិសោធន៍ជាមួយនឹងការថែរក្សារបស់ព្រះអម្ចាស់ (ខ.២២)។

យើងអាចទទួលស្គាល់ដោយស្មោះត្រង់ថា យើងរាល់គ្នាសុទ្ធតែធ្លាប់មានការព្រួយបារម្ភ និងការភ័យខ្លាច។ ហើយប្រហែលជាធ្លាប់គិតដូចស្តេចដាវីឌថា «ឱបើសិនណាជាមានស្លាបដូចជាព្រាបទៅ៉ា នោះអញនឹងហើរចេញទៅ ឲ្យបានសេចក្តីសុខ» (ខ.៦)។ ព្រះអម្ចាស់គង់នៅក្បែរយើងស្រាប់ ហើយមានតែព្រះអង្គទេ ដែលមានព្រះចេស្តាអាចកែប្រែស្ថានភាពរបស់យើង។ ចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់យើងដល់ព្រះអង្គ។—Anne Cetas

តើអ្នកបានថ្វាយទុក្ខព្រួយរបស់អ្នកដល់ព្រះអង្គហើយឬនៅ? តើអ្នកនឹងថ្វាយអ្វីដល់ព្រះអង្គ នៅពេលឥឡូវនេះ?

ឱព្រះអម្ចាស់ ទូលបង្គំមានការព្រួយបារម្ភក្នុងចិត្តជាញឹកញាប់។ ទូលបង្គំសូមថ្វាយទុក្ខព្រួយទាំងអស់ដល់ព្រះអង្គជាថ្មី។ ទូលបង្គំសូមផ្ទេរគ្រប់ទាំងបន្ទុករបស់ទូលបង្គំដល់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 240 17/11/25 1:46 in the afternoon

ឱពួកអ៊ីស្រាអែលអើយ បើឯងនឹងមកឯអញវិញ ហើយនឹងលះបង់អំពើគួរស្អប់ខ្ពើមរបស់ឯងចេញ ពីមុខអញទៅ នោះឯងរាល់គ្នាមិនត្រូវបណ្តេញបរបង់ទេ (យេរេមា ៤:១)។

ចិត្តដែលកែប្រែ

មិត្តភក្តិរបស់ខ្ញុំម្នាក់បានបំពានពាក្យសន្យា ដែលគាត់ធ្លាប់បានប្រកាសក្នុងពិធីមង្គលការរបស់គាត់។ ខ្ញុំមានអារម្មណ៍ឈឺចាប់ក្នុងចិត្តណាស់ ពេលដែលបានឃើញគាត់បំផ្លាញគ្រួសាររបស់គាត់។ ពេលគាត់ស្វែងរកការផ្សះផ្សាជាមួយភរិយាគាត់ គាត់ក៏បានសុំការប្រឹក្សាយោបល់ពីខ្ញុំ។ ខ្ញុំក៏បានប្រាប់គាត់ថា គាត់ចាំបាច់ត្រូវផ្តល់ឲ្យភរិយាគាត់ លើសពីពាក្យសម្តីរបស់គាត់បានសេចក្តីថា គាត់ចាំបាច់ត្រូវបង្ហាញការកែប្រែក្នុងការបង្ហាញសេចក្តីស្រឡាញ់ចំពោះភរិយារបស់គាត់ ហើយត្រូវលប់បំបាត់ដាននៃអំពើបាបទាំងអស់ដែលគាត់មាន។

ហោរា យេរេមា ក៏បានផ្តល់ឲ្យនូវយោបល់ស្រដៀងនេះដល់អ្នកដែលបានបំពានសេចក្តីសញ្ញា ដែលពួកគេបានតាំងជាមួយព្រះអម្ចាស់ ហើយងាកទៅដើរតាមព្រះដទៃ។ បើគ្រាន់តែងាកទៅរកព្រះអង្គ (យេរេមា ៤:១) នោះមិនទាន់គ្រប់គ្រាន់នៅឡើយទេ ទោះនេះជាជំហានទីមួយឆ្ពោះទៅរកការផ្សះផ្សាក៏ដោយ។ ពួកគេចាំបាច់ត្រូវកែប្រែការប្រព្រឹត្តរបស់ខ្លួន ឲ្យស្របតាមការប្តេជ្ញាចិត្តរបស់ពួកគេ។ បានសេចក្តីថា ពួកគេត្រូវលះបង់ចោលការថ្វាយបង្គំរូបព្រះដែលគួរឲ្យស្អប់ខ្ពើមនោះ (ខ.១)។ ហោរា យេរេមា មានប្រសាសន៍ថា បើពួកគេធ្វើការប្តេជ្ញាចិត្ត ដោយពិតត្រង់ យុត្តិធម៌ និងសុចរិត ព្រះអម្ចាស់នឹងប្រទានពរដល់ប្រជាជាតិទាំងឡាយ (ខ.២)។ បញ្ហាស្ថិតនៅត្រង់ថា ពួកគេកំពុងធ្វើការប្តេជ្ញាចិត្តតែបបូរមាត់ គឺមិនបានសន្យាឲ្យអស់ពីចិត្តទេ។

ព្រះអម្ចាស់មិនសព្វព្រះទ័យ នឹងការសន្យាតែបបូរមាត់ ព្រះអង្គសព្វព្រះទ័យឲ្យយើងថ្វាយចិត្តដាច់ដល់ព្រះអង្គ។ គឺដូចដែលព្រះយេស៊ូវមានបន្ទូលថា "មាត់តែងនិយាយ តាមសេចក្តីបរិបូរដែលនៅក្នុងចិត្ត" (ម៉ាថាយ ១២:៣៤)។ ហេតុនេះហើយ ហោរា យេរេមា ក៏បានបន្តលើកទឹកចិត្តអ្នកដែលស្តាប់គាត់ ដើម្បីឲ្យពួកគេភ្ជួរបំបែកដីរឹងនៃចិត្តរបស់ពួកគេ ហើយកុំឲ្យព្រោះគ្រាប់ពូជក្នុងគុម្ពបន្លាឡើយ (យេរេមា ៤:៣)។

គួរឲ្យស្តាយណាស់ មិត្តភក្តិរបស់ខ្ញុំមិនបានស្តាប់តាមការប្រឹក្សាយោបល់ ដែលត្រឹមត្រូវតាមព្រះគម្ពីរ គឺមិនខុសពីមនុស្សជាច្រើនដែលមិនស្តាប់បង្គាប់ព្រះ ហើយជាលទ្ធផល គាត់ក៏មានការលែងលះគ្នាជាមួយភរិយាគាត់។ ពេលណាយើងប្រព្រឹត្តអំពើបាប យើងត្រូវតែសារភាព ហើយងាកបែរចេញពីវា។ ព្រះអម្ចាស់មិនសព្វព្រះទ័យឲ្យយើងសន្យាតែបបូរមាត់នោះទេ តែព្រះអង្គសព្វព្រះទ័យឲ្យយើងរស់នៅក្នុងជីវិត ដែលពិតជាសមស្របនឹងព្រះបន្ទូលព្រះអង្គ។—Matt Lucas

តើពាក្យសម្តីរបស់អ្នកមិនសមស្របនឹងទង្វើរបស់អ្នក ត្រង់ផ្នែកណាខ្លះនៃជីវិតអ្នក? តើអ្នកចាំបាច់ត្រូវកែប្រែត្រង់ចំណុចណាខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ពេលណាទង្វើរបស់ទូលបង្គំមិនសមស្របនឹងសេចក្តីជំនឿរបស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ១១៣-១១៥ និង១កូរិនថូស ៦

ពីដើមអ្នករាល់គ្នាមិនមែនជាសាសន៍ណាមួយទេ តែឥឡូវនេះជាសាសន៍របស់ព្រះវិញ (១ពេត្រុស ២:១០)។

ដើរតាមផ្លូវថ្មី

ស្ទ្រេសដៃបានផ្ទុះឡើង ខណៈពេលដែលសិស្សឆ្នើមប្រចាំសាលាបានទទួលប័ណ្ណសរសើរសម្រាប់ភាគជោគជ័យក្នុងការសិក្សា។ ប៉ុន្តែ កម្មវិធីអបអរនេះមិនមែនមានតែប៉ុណ្ណឹងទេ។ រង្វាន់បន្ទាប់ គឺសម្រាប់អបអរសិស្សដែលមិនមែនជាសិស្ស «ឆ្នើម» តែជាសិស្សដែលបានប្រឹងប្រែងរៀនសូត្រឲ្យការសិក្សាមានភាពល្អប្រសើរជាងមុន។ ពួកគេបានខិតខំ ដើម្បីកុំឲ្យប្រឡងធ្លាក់ទៀត ឬបានកែប្រែអាកប្បកិរិយាដែលរំខានអ្នកដទៃ ឬបានប្តេជ្ញាចិត្តមករៀនឲ្យទៀងទាត់។ ឪពុកម្តាយរបស់ពួកគេក៏មានទឹកមុខញញឹម ហើយក៏បានទះដៃអបអរដោយទទួលស្គាល់ថា កូនរបស់ខ្លួនបានងាកមកដើរផ្លូវថ្មី ជាផ្លូវដ៏ត្រឹមត្រូវវិញ គឺមិនបានមើលទៅចំណុចខ្វះខាតដែលពួកគេមានកាលពីមុននោះទេ។

ទិដ្ឋភាពនៃការអបអរដូចនេះ ពិតជាបានលើកទឹកចិត្តយើងណាស់ តែក៏បានរំឭកយើងអំពីរបៀបដែលព្រះវរបិតាទតឃើញជីវិតយើងដែលជាអ្នកជឿព្រះអង្គ គឺមិនបានទតឃើញជីវិតយើង ជាអ្នកដទៃដូចកាលពីមុននោះទេ តែព្រះអង្គទតឃើញជីវិតយើង ជាកូនព្រះអង្គនៅក្នុងព្រះគ្រីស្ទ ក្នុងពេលបច្ចុប្បន្ន។ គឺដូចមានសេចក្តីចែងថា «ប៉ុន្តែ អស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជាកូនព្រះ» (យ៉ូហាន ១:១២)។

នេះជាការបើកបង្ហាញ ដែលមានពេញដោយក្តីស្រឡាញ់! ហេតុនេះហើយ សាវ័ក ប៉ុល បានរំឭកអ្នកជឿថ្មីថា «ពីដើមអ្នករាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុងអំពើបាបដែរ» (អេភេសូរ ២:១)។ ប៉ុន្តែ តាមពិត «យើងរាល់គ្នាជាស្នាដៃ ដែលទ្រង់បង្កើតក្នុងព្រះគ្រីស្តយេស៊ូវសំរាប់ការល្អ ដែលព្រះបានរៀបចំជាមុនឲ្យយើងរាល់គ្នាប្រព្រឹត្តតាម» (ខ.១០)។

សាវ័ក ពេត្រុស ក៏បានបង្រៀនផងដែរថា «អ្នករាល់គ្នាជាពូជជ្រើសរើស ជាពួកសង្ឃហ្លួង ជាសាសន៍បរិសុទ្ធ ជារាស្ត្រដ៏ជាកេរ្តិ៍អាករនៃព្រះ ដើម្បីឲ្យអ្នករាល់គ្នាបានសំដែងចេញឲ្យឃើញអស់ទាំងលក្ខណៈរបស់ព្រះ ដែលទ្រង់បានហៅអ្នករាល់គ្នាចេញពីសេចក្តីងងឹតមកក្នុងពន្លឺអស្ចារ្យរបស់ទ្រង់» «តែឥឡូវនេះជាសាសន៍របស់ព្រះវិញ» (១ពេត្រុស ២:៩-១០)។ នៅក្នុងព្រះនេត្ររបស់ព្រះ ផ្លូវជីវិតចាស់របស់យើងមិនមែនជាកត្តាកំណត់ ឬមានអំណាចគ្រប់គ្រងជីវិតយើងទៀតទេ។ ចូរយើងមើលឃើញខ្លួនយើង ដូចដែលព្រះអង្គទតឃើញយើង ហើយដើរតាមផ្លូវថ្មី ជាផ្លូវដែលព្រះអង្គរៀបចំឲ្យយើងដើរ។—Patricia Raybon

តើព្រះអង្គបានទតឃើញអ្នកជានរណា? តើអ្នកគួរតែដើរក្នុងព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះវរបិតា នៅថ្ងៃនេះសូមព្រះអង្គបណ្តាលចិត្តទូលបង្គំ ឲ្យគិតអំពីខ្លួនឯងតាមទស្សនៈរបស់ព្រះអង្គ។

ដ្បិតយើងរាល់គ្នាជាអ្នកធ្វើការជាមួយនឹងព្រះ ឯអ្នករាល់គ្នាជាស្រែដែលព្រះទ្រង់ភ្ជួរ ហើយជាផ្ទះដែលព្រះទ្រង់ធ្វើ (១កូរិនថូស ៣:៩)។

ការប្រកួតប្រជែងដែលមិនគួរមាន

កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៥៥ សហរដ្ឋអាមេរិកបានប្រកាសអំពីគោលបំណងរបស់ខ្លួន ដែលចង់បង្ហោះផ្កាយរណប ចូលទៅក្នុងគន្លងក្នុងទីអវកាស។ មិនយូរប៉ុន្មាន សហភាពសូវៀតក៏បានប្រកាសអំពីផែនការបាញ់បង្ហោះផ្កាយរណបរបស់ខ្លួនផងដែរ។ ការប្រកួតប្រជែងក្នុងវិស័យអវកាសក៏បានចាប់ផ្តើម តាំងពីពេលនោះមក។ សហភាពសូវៀតក៏បានបាញ់បង្ហោះផ្កាយរណបដំបូងបំផុត (ឈ្មោះ ស្ពុតនីក) ហើយក៏បានបញ្ជូនមនុស្សដំបូងបំផុត ចូលទៅក្នុងទីអវកាស ដែលនៅពេលនោះ លោក យូរី ហ្គាហ្គារីន (Yuri Gagarin) បានធ្វើដំណើរក្នុងទីអវកាសក្រឡឹងជុំវិញផែនដីបានមួយជុំ។ ការប្រកួតប្រជែងនេះបានបន្តរហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៦៩ នៅពេលដែលលោកនេល អាមស្ត្រង (Neil Armstrong's) បានក្លាយជាមនុស្សទីមួយ ដែលបានជាន់ស្ថានព្រះច័ន្ទ ដែលការនេះក៏បានបញ្ចប់ការប្រកួតប្រជែងនេះជាផ្លូវការ។ រដូវកាលនៃការសហការគ្នារវាងប្រទេសទាំងពីរ ក៏បានចាប់ផ្តើម ដែលនាំឲ្យមានការសាងសង់ស្ថានីយអវកាសអន្តរជាតិ។

ជួនកាល ការប្រកួតប្រជែងអាចមានប្រយោជន៍ត្រង់ចំណុចដែលថា វាជំរុញយើងឲ្យសម្រេចបានការអ្វី ដែលយើងមិនអាចធ្វើបាន បើសិនជាគ្មានការប្រកួតប្រជែងទេនោះ។ ទោះជាយ៉ាងណាក៏ដោយ ការប្រកួតប្រជែងនាំឲ្យមានការបំផ្លាញគ្នាទៅវិញទៅមក។ នេះជាបញ្ហាដែលបានកើតឡើងក្នុងពួកជំនុំនៅទីក្រុងកូរិនថូស ខណៈពេលដែលពួកគេបានចែកបក្សពួក ដោយក្រុមនីមួយៗបានប្រជែងគ្នាលើកតម្កើងអ្នកដឹកនាំខុសៗគ្នា ធ្វើជាពន្លឺនៃក្តីសង្ឃឹមរបស់ខ្លួន។ សាវ័ក ប៉ុល បានព្យាយាមលើកយកបញ្ហានេះមកចែកចាយក្នុងសំបុត្ររបស់គាត់ ដោយបង្រៀនពួកគេថា «ហេតុនោះបានជាអ្នកសាបព្រោះ និងអ្នកដែលស្រោច នោះមិនមែនជាអ្វីទេ ស្រេចនឹងព្រះដែលធ្វើឲ្យដុះវិញទេតើ» (១កូរិនថូស ៣:៧) ហើយគាត់ក៏បាននិយាយបង្រួមន័យថា យើងរាល់គ្នាជាអ្នកធ្វើការជាមួយព្រះ (ខ.៩)។

យើងសុទ្ធតែជាអ្នកធ្វើការជាមួយព្រះអង្គ ដូចនេះយើងត្រូវរួបរួមគ្នាមិនមែនជាគូប្រជែងឡើយ។ ហើយក៏មិនគ្រាន់តែធ្វើការជាមួយគ្នា តែក៏ធ្វើការជាមួយព្រះអង្គផងដែរ។ តាមរយៈការប្រទានអំណាច និងការដឹកនាំរបស់ព្រះអង្គ យើងអាចបម្រើព្រះអង្គជាមួយគ្នាក្នុងនាមជាដៃគូដំណឹងល្អរបស់ព្រះយេស៊ូវ ដើម្បីថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ មិនមែនដើម្បីលើកតម្កើងខ្លួនឯងនោះទេ។—Bill Crowder

តើអ្នកបានជួបការប្រកួតដ៏គ្រោះថ្នាក់នៅពេលណា តើវាមានលក្ខណៈដូចម្តេចខ្លះ? តើព្រះយេស៊ូវបានជួយអ្នកឲ្យបន្ទាបខ្លួនបម្រើអ្នកដទៃ ដូចម្តេចខ្លះ?

ឱព្រះនៃសេចក្តីស្រឡាញ់ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានឯកសិទ្ធិក្នុងការបម្រើព្រះអង្គ។ សូមព្រះអង្គបង្រៀនទូលបង្គំ ឲ្យស្គាល់តម្លៃនៃការធ្វើការ ដើម្បីថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ និងដើម្បីជួយអ្នកដទៃ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ទំនុកតម្កើង ១១៩:១-៨៨ និង១កូរិនថូស ៧:២០-៤០

ដ្បិតព្រះយេហូវ៉ាជាព្រះនៃឯង... ទ្រង់ក៏ស្គាល់ផ្លូវដែលឯងបានដើរក្នុងទីរហោស្ថានសំបើមនេះផង (ចោទិយកថា ២:៧)។

ឆ្លងកាត់វាលរហោស្ថានខាងវិញ្ញាណ

កាលខ្ញុំនៅមានភាពក្មេងខ្ចីក្នុងជំនឿ ខ្ញុំយល់ឃើញថា ពេលណាខ្ញុំបានដកពិសោធន៍ភាពរំភើបរីករាយបំផុត ក្នុងព្រះវត្តមានព្រះអង្គក្នុងកម្រិតខ្ពស់ដូចកំពូលភ្នំ នោះមានន័យថា ខ្ញុំបានជួបជាមួយព្រះយេស៊ូវ។ ប៉ុន្តែ ការមានអារម្មណ៍រំភើបក្នុងកម្រិតខ្ពស់ដូចនេះកម្រកើតមាន ហើយក៏កម្រនាំឲ្យមានការលូតលាស់ខាងវិញ្ញាណ។ អ្នកនិពន្ធឈ្មោះ លីណា អាប៊ូចាំរ៉ា (Lina AbuJamra) បានមានប្រសាសន៍ថា កន្លែងដែលយើងជួបព្រះ ហើយមានការរីកលូតលាស់ គឺមានលក្ខណៈដូចវាលរហោស្ថានមិនមែនមានកម្រិតខ្ពស់ដូចកំពូលភ្នំនោះទេ។ ក្នុងសៀវភៅដែលគាត់បាននិពន្ធមានចំណងជើងថា ការសិក្សាព្រះបន្ទូលក្នុងវាលរហោស្ថាន គាត់បានពិពណ៌នាថា «គោលបំណងរបស់ព្រះ គឺដើម្បីប្រើវាលរហោស្ថានក្នុងជីវិតយើង ដើម្បីជួយឲ្យយើងកាន់តែរឹងមាំឡើង។ ព្រះអង្គប្រទានសេចក្តីល្អរបស់ព្រះអង្គមកដល់យើង នៅពេលដែលយើងមានការឈឺចាប់ ហើយមិនមែនទាល់តែយើងគ្មានការឈឺចាប់នោះទេ»។

កន្លែងដែលពិបាកបំផុត ដែលមានទុក្ខព្រួយ ការបាត់បង់ និងការឈឺចាប់ គឺជាកន្លែងដែលព្រះអង្គជួយយើងឲ្យលូតលាស់ក្នុងជំនឿ ហើយកាន់តែមានភាពជិតស្និទ្ធជាមួយព្រះអង្គ។ ការលំបាក និងបញ្ហាប្រឈមប្រៀបដូចការធ្វើដំណើរក្នុងវាលរហោស្ថាន មិនបានកើតឡើងដោយចៃដន្យ ឬគ្មានន័យអ្វីក្នុងផែនការរបស់ព្រះនោះទេ តែជាផ្នែកមួយដ៏សំខាន់ ក្នុងដំណើរការនៃការលូតលាស់របស់យើង។

នៅគ្រាសញ្ញាចាស់ ព្រះអម្ចាស់បានដឹកនាំពួកឰយុកោនៃសាសន៍អ៊ីស្រាអែលជាច្រើននាក់ចូលវាលរហោស្ថាន។ លោក អ័ប្រាហាំ លោក អ៊ីសាក និងលោក យ៉ាកុប គឺសុទ្ធតែធ្លាប់ឆ្លងកាត់វាលរហោស្ថាន។ វាលរហោស្ថាន ជាកន្លែងដែលព្រះអម្ចាស់បានរៀបចំចិត្តរបស់លោក ម៉ូសេ និងត្រាស់ហៅគាត់ឲ្យដឹកនាំរាស្ត្រព្រះអង្គចេញពីភាពជាទាសកក្នុងទឹកដីអេស៊ីព្ទ (និក្ខមនំ ៣:១-២, ៩-១០)។ ហើយវាលរហោស្ថាន ក៏ជាកន្លែងដែលព្រះអង្គដឹកនាំការធ្វើដំណើររបស់ពួកអ៊ីស្រាអែលអស់រយៈពេល៤០ឆ្នាំ ដោយជំនួយ និងការដឹកនាំរបស់ព្រះអង្គ (ចោទិយកថា ២:៧)។

ព្រះអម្ចាស់បានយាងទៅជាមួយលោក ម៉ូសេ និងពួកអ៊ីស្រាអែលគ្រប់ជំហានក្នុងដំណើរឆ្លងកាត់វាលរហោស្ថាន ហើយព្រះអង្គក៏យាងទៅជាមួយអ្នក និងខ្ញុំផងដែរ។ វាលរហោស្ថាន ជាកន្លែងដែលយើងរៀនពឹងផ្អែកលើព្រះអង្គ ជាកន្លែង ដែលព្រះអង្គជួបជាមួយយើង ហើយជួយយើងឲ្យចម្រើនឡើង។—Alyson Kieda

តើព្រះអម្ចាស់បានជួបជាមួយអ្នក ក្នុងវាលរហោស្ថានខាងវិញ្ញាណនៅពេលណា? តើអ្នកបានទទួលទទួលផលអ្វីខ្លះ ពីការជួបយ៉ាងដូចនេះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានគង់នៅជាមួយទូលបង្គំក្នុងពេលដ៏ពិបាកនៃជីវិតរបស់ទូលបង្គំ ដូចការឆ្លងកាត់វាលរហោស្ថាន។ ព្រះអង្គស្មោះត្រង់ ហើយមានសេចក្តីអាណិត។

គម្រោងអានព្រះគម្ពីរអស់រយៈពេល១ឆ្នាំ | ទំនុកតម្កើង ១១៩:៨៩-១៧៦ និង១កូរិនថូស ៨

គេមិនមែនជារបស់ផងលោកីយ៍ ដូចជាទូលបង្គំក៏មិនមែនជារបស់លោកីយ៍ដែរ (យ៉ូហាន ១៧:១៦)។

មានលក្ខណៈកាន់តែដូចព្រះយេស៊ូវ

ព្រះទ្រង់បានបង្កើតសត្វទីទុយធំពណ៌ប្រផេះមកឲ្យមានជំនាញបន្លំខ្លួន ដែលធ្វើឲ្យគេពិបាកមើលវាស្គាល់ក្នុងធម្មជាតិ។ ពួកវាមានរោមពណ៌ទឹកប្រាក់លាយប្រផេះឆ្លាស់គ្នា ដែលអនុញ្ញាតឲ្យពួកវាអាចបន្លំខ្លួន ជាមួយសម្បកឈើ ពេលណាពួកវាសម្ងំនៅលើដើមឈើ។ ពេលណាសត្វទីទុយប្រភេទនេះចង់បន្តលាក់ខ្លួនមិនឲ្យគេមើលឃើញពួកវា ពួកវាក៏បានបន្លំខ្លួននៅក្នុងបរិស្ថានជុំវិញ ដោយជំនួយពីរោមរបស់ពួកវាដែលមានពណ៌ដូចសម្បកឈើ។

ជាញឹកញាប់ រាស្ត្ររបស់ព្រះមានលក្ខណៈដូចសត្វទីទុយប្រភេទនេះណាស់។ ទោះដោយចេតនា ឬដោយអចេតនាក្តី យើងអាចបន្លំខ្លួនយ៉ាងងាយស្រួលនៅក្នុងលោកីយ៍ដោយរស់នៅ និងមានអាកប្បកិរិយាដូចគេធ្វើឲ្យគេមើលមិនដឹងថា យើងជាអ្នកជឿព្រះគ្រីស្ទ។ ព្រះយេស៊ូវបានអធិស្ឋានឲ្យពួកសាវ័ករបស់ព្រះអង្គ ដែលព្រះវរបិតាបានប្រទានមកព្រះអង្គ ដោយរើសចេញពីលោកីយ៍មកឲ្យពួកគេស្តាប់បង្គាប់តាមព្រះបន្ទូលព្រះអង្គ (យ៉ូហាន ១៧:៦)។ ព្រះរាជបុត្រាបានទូលសូមព្រះវរបិតាការពារ និងប្រទានកម្លាំងឲ្យពួកគេរស់នៅក្នុងសេចក្តីបរិសុទ្ធ និងក្តីអំណរ ដោយការស៊ូទ្រាំនឹងទុក្ខលំបាក បន្ទាប់ពីព្រះអង្គយាងឡើងស្ថានសួគ៌វិញ (ខ.៧-១៣)។ គឺដូចដែលព្រះអង្គបានអធិស្ឋានថា "ទូលបង្គំមិនសូមឲ្យយកគេចេញពីលោកីយ៍ទេ គឺសូមឲ្យទ្រង់រក្សាគេ ឲ្យរួចពីសេចក្តីអាក្រក់វិញ" (ខ.១៥)។ ព្រះយេស៊ូវជ្រាបថា សាវ័ករបស់ព្រះអង្គត្រូវការសេចក្តីបរិសុទ្ធ និងការញែកចេញពីលោកីយ៍ ដើម្បីឲ្យពួកគេអាចរស់នៅស្របតាមគោលបំណង ដែលព្រះអង្គបានចាត់ពួកគេឲ្យចេញទៅបំពេញ (ខ.១៦-១៩)។

ព្រះវិញ្ញាណបរិសុទ្ធអាចជួយយើង ឲ្យងាកចេញពីការល្បួងដែលនាំយើងបន្លំខ្លួនក្នុងលោកីយ៍ ឬគ្រាប់តាមលោកីយ៍។ ពេលណាយើងចុះចូលព្រះអង្គជារៀងរាល់ថ្ងៃ យើងអាចផ្លាស់ប្រែមានចរិតលក្ខណៈកាន់តែដូចព្រះយេស៊ូវ។ ខណៈពេលដែលយើងរស់នៅ ដោយការរួបរួម និងសេចក្តីស្រឡាញ់អ្នកដទៃនឹងបានឃើញទីបន្ទាល់ល្អរបស់យើង ហើយព្រះអង្គនឹងនាំពួកគេចូលមករកព្រះគ្រីស្ទនៅក្នុងសិរីល្អរបស់ព្រះអង្គ។—Xochitl Dixon

តើមានផ្នែកណាខ្លះក្នុងជីវិតអ្នក ដែលអ្នកអាចទូលសូមឲ្យព្រះអង្គកែប្រែ ដើម្បីឲ្យអ្នកមានលក្ខណៈកាន់តែដូចព្រះយេស៊ូវ? ដើម្បីនាំអ្នកចូលមកជិតព្រះអង្គ តើព្រះអម្ចាស់បានប្រើទីបន្ទាល់របស់អ្នកដទៃដែលបានរស់នៅ និងមានក្តីស្រឡាញ់ដូចព្រះយេស៊ូវយ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា នៅថ្ងៃនេះសូមព្រះអង្គបណ្តាលចិត្តទូលបង្គំ ឲ្យគិតអំពីខ្លួនឯងតាមទស្សនៈរបស់ឱព្រះវិញ្ញាណបរិសុទ្ធ សូមព្រះអង្គជួយទូលបង្គំឲ្យមានលក្ខណៈកាន់តែដូចព្រះយេស៊ូវ ដើម្បីនាំអ្នកដទៃឲ្យស្វែងរកព្រះពិតតែមួយ។

Daily Manna 2026_Content Enhance.indd 245 17/11/25 1:46 in the afternoon

អ័ប្រាហាំអាយុបាន១០០ឆ្នាំហើយក្នុងកាលដែលអ៊ីសាក កូនគាត់កើតមក (លោកុប្បត្តិ ៦១:៥)។

សក្តិសមនឹងឲ្យយើងរង់ចាំ

លោក ភីល ស្ត្រីងជ័រ (Phil Stringer) បានរង់ចាំអស់រយៈពេល១៨ម៉ោង ទំរាំតែបានធ្វើដំណើរតាមយន្តហោះ ដែលបានពន្យារពេល ដោយសារព្យុះរន្ទះ។ ទោះជាយ៉ាងណាក៏ដោយ ភាពអត់ធ្មត់ និងការស៊ូទ្រាំរបស់គាត់មិនអត់ប្រយោជន៍ទេ។ គាត់បានធ្វើដំណើរទៅដល់គោលដៅរបស់គាត់ ហើយបានចូលរួមការប្រជុំដ៏សំខាន់សម្រាប់មុខជំនួញរបស់គាត់ទាន់ពេលវេលាប៉ុណ្ណោះទេ តែជាងនេះទៅទៀតគាត់ជាអ្នកដំណើរម្នាក់គត់ដែលបានធ្វើដំណើរតាមជើងហោះហើរនោះ ដោយសារអ្នកដំណើរដទៃទៀតបានបោះបង់ចោលការតស៊ូក្នុងការរង់ចាំ ឬងាកទៅរកការធ្វើដំណើរតាមមធ្យោបាយផ្សេងវិញ។ ក្នុងការធ្វើដំណើរនោះ អ្នកបម្រើនៅលើយន្តហោះបានផ្តល់ឲ្យគាត់នូវអាហារ និងភេសជ្ជៈដែលគាត់ចង់បានតាមចិត្ត ហើយលោក ស្ត្រីងជ័រ ក៏បានប្រាប់គេថា គាត់បានអង្គុយនៅលើកៅអីជួរមុខគេ ព្រោះគាត់ចង់អង្គុយនៅលើកៅអីមួយណាក៏បានក្នុងយន្តហោះដោយសារយន្តហោះនោះមានតែគាត់ម្នាក់គត់ ដែលជាអ្នកដំណើរ។ ដូចនេះ លទ្ធផលដែលគាត់ទទួលបាន គឺសក្តិសមនឹងឲ្យគាត់រង់ចាំ។

លោកអ័ប្រាហាំក៏បានស៊ូទ្រាំនឹងការរង់ចាំ ដែលមានការពន្យារពេលដ៏យូរជាងនេះទៀត។ កាលពីមុន គឺនៅពេលដែលគាត់មានឈ្មោះថា អាប់រ៉ាម ព្រះទ្រង់បានប្រាប់គាត់ថា ព្រះអង្គនឹងបង្កើតជាតិសាសន៍ដ៏ធំមួយចេញពីគាត់ ហើយប្រជាជាតិទាំងអស់នៅលើផែនដីនឹងមានពរ ដោយសារគាត់ (លោកុប្បត្តិ ១២:២-៣)។ ប៉ុន្តែ បញ្ហាដែលបុរសអាយុ៧៥ឆ្នាំនោះមាន គឺស្ថិតនៅត្រង់ថា តើប្រជាជាតិដ៏ធំមួយអាចកើតចេញពីគាត់ដោយរបៀបណា បើសិនជាគាត់គ្មានកូនសម្រាប់បន្តខ្សែលោហិតទេនោះ? ហើយនៅពេលដែលគាត់កំពុងរង់ចាំនោះ ភរិយាគាត់ក៏បានបែកគំនិតចង់ «ជួយ» ព្រះសម្រេចព្រះបន្ទូលសន្យា ដោយនាំគាត់ដើរផ្លូវខុស (១៥:២-៣ ១៦:១-២) ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅពេលដែលគាត់មានអាយុ១០០ឆ្នាំ កូនរបស់គាត់ឈ្មោះអ៊ីសាក ក៏បានចាប់កំណើត(២១:៥)។ នៅសម័យក្រោយមក កណ្ឌគម្ពីរហេព្រើរក៏បានពោលសរសើរសេចក្តីជំនឿរបស់គាត់នៅក្នុងការរង់ចាំនោះផងដែរ(១១:៨-១២)។

ការរង់ចាំអាចមានការលំបាក។ ហើយការរង់ចាំរបស់យើង ប្រហែលមិនល្អឥតខ្ចោះ គឺមិនខុសពីការរង់ចាំរបស់លោកអ័ប្រាហាំទេ។ ប៉ុន្តែ ពេលណាយើងអធិស្ឋាន ហើយសម្រាកក្នុងផែនការរបស់ព្រះ សូមព្រះអង្គជួយយើងឲ្យអាចស៊ូទ្រាំ នៅក្នុងការរង់ចាំ។ ការរង់ចាំដែលស្របតាមបំណងព្រះទ័យព្រះអង្គ គឺមិនដែលធ្វើឲ្យយើងខកចិត្តទេ។—Tom Felten

តើអ្នកកំពុងរង់ចាំអ្វី? តើអ្នកអាចសម្រាក និងស៊ូទ្រាំ ដោយពឹងអាងកម្លាំងព្រះអង្គក្នុងការរង់ចាំដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យរង់ចាំ និងស៊ូទ្រាំក្នុងព្រះអង្គ។

គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ | ទំនុកតម្កើង ១២៣-១២៥ និង១កូរិនថូស ១០:១-១៨

ចូរស្វែងរកសេចក្តីល្អ កុំរកសេចក្តីអាក្រក់ឡើយ ដើម្បីឲ្យឯងរាល់គ្នាបានរស់នៅ (អេម៉ុស ៥:១៤)។

ព្រះនៃសេចក្តីយុត្តិធម៌

កាលលោក រ៉ាយអិន (Ryan) ស្ថិតក្នុងវ័យជំទង់ គាត់បានបាត់បង់ម្តាយរបស់គាត់ ដោយសារជំងឺមហារីក។ គាត់ក៏បានក្លាយជាជនអនាថា ហើយមិនយូរប៉ុន្មានគាត់ក៏បានឈប់ទៅរៀន។ គាត់មានអារម្មណ៍ថាអស់សង្ឃឹម ហើយជាញឹកញាប់គាត់មិនមានអាហារបរិភោគទាល់តែសោះ។ ប៉ុន្មានឆ្នាំក្រោយមក លោក រ៉ាយអិន ក៏បានបង្កើតអង្គការមិនរកប្រាក់ចំណេញមួយ ដើម្បីជួយជនទុរគត ជាពិសេសក្មេងៗឲ្យពួកគេចេះដាំដុះ បង្កបង្កើនផល និងធ្វើម្ហូបដោយប្រើបន្លែដែលពួកគេបានដាំដុះ។ អង្គការនេះបានបង្កើតឡើង ដោយសារគាត់ជឿថា គ្មាននរណាម្នាក់ដែលត្រូវស់នៅ ដោយគ្មានអាហារបរិភោគនោះឡើយ ហើយអ្នកដែលមានអាហារគួរតែចែកដល់អ្នកដែលគ្មាន។ ការយកចិត្តទុកដាក់ ដែលលោក រ៉ាយអិន មានចំពោះអ្នកដទៃបានឆ្លុះបញ្ចាំងអំពីដួងព្រះទ័យព្រះ ដែលសព្វព្រះទ័យនឹងប្រទានសេចក្តីយុត្តិធម៌ និងសេចក្តីមេត្តាដល់មនុស្សទាំងអស់។

ព្រះទ្រង់យកព្រះទ័យទុកដាក់យ៉ាងជ្រាលជ្រៅចំពោះការឈឺចាប់ និងទុក្ខវេទនាដែលយើងជួបប្រទះ។ កាលព្រះអង្គទតឃើញអំពើអយុត្តិធម៌ដែលគួរឲ្យស្អប់ខ្ពើមកំពុងកើតមានក្នុងទឹកដីអ៊ីស្រាអែល ព្រះអង្គក៏បានចាត់ហោរា អេម៉ុស ឲ្យបកអាក្រាតភាពពុតត្បុតរបស់ពួកគេ។ កាលពីមុនព្រះអង្គបានរំដោះពួកគេ ជារាស្ត្ររបស់ព្រះអង្គឲ្យរួចផុតពីការជិះជាន់របស់សាសន៍អេស៊ីព្ទ តែនៅសម័យហោរា អេម៉ុស ពួកគេកំពុងលក់អ្នកជិតខាងខ្លួនដូរយកស្បែកជើងមួយសម្រាប់(អេម៉ុស ២:៦)។ ពួកគេបានក្បត់មនុស្សស្លូតត្រង់ បដិសេធន៍មិនព្រមសម្រេចសេចក្តីយុត្តិធម៌ដល់មនុស្សដែលគេជិះជាន់ ហើយបានជាន់ឈ្លីពីលើក្បាលរបស់អ្នកក្រ (ខ.៦-៧) តែទន្ទឹមនឹងនោះពួកគេធ្វើពុតជាថ្វាយបង្គំព្រះ ដោយការថ្វាយដង្វាយ និងកាន់តាមថ្ងៃបរិសុទ្ធ (៤:៤-៥)។

លោក អេម៉ុស ក៏បានអំពាវនាវដល់ពួកបណ្តាជនថា «ចូរស្វែងរកសេចក្តីល្អ កុំរកសេចក្តីអាក្រក់ឡើយ ដើម្បីឲ្យឯងរាល់គ្នាបានរស់នៅ យ៉ាងនោះព្រះយេហូវ៉ា ជាព្រះនៃពួកពលបរិវារ ទ្រង់នឹងគង់នៅជាមួយនឹងឯងជាពិតដូចឯងថ្លាប់ថាហើយ» (៥:១៤)។ យើងម្នាក់ៗសុទ្ធតែធ្លាប់ឆ្លងកាត់ការឈឺចាប់ និងភាពអយុត្តិធម៌ក្នុងជីវិត មិនខុសពីលោក រ៉ាយអិន ឡើយ គឺល្មមនឹងអាចឲ្យយើងយល់អំពីការលំបាករបស់អ្នកដទៃ ក៏ដូចជាជួយយកអសារពួកគេ។ ពេលនេះជាពេលដែលយើងត្រូវ «ស្វែងរកសេចក្តីល្អ» ហើយចូលរួមជាមួយព្រះអង្គនៅក្នុងការសាបព្រោះសេចក្តីយុត្តិធម៌គ្រប់យ៉ាង។—Karen Pimpo

តើអ្នកបានឃើញអ្នកដទៃកំពុងទទួលរងអំពើអយុត្តិធម៌អ្វីខ្លះ ដែលធ្វើឲ្យអ្នកនឹកចាំអំពីអំពើអយុត្តិធម៌ដែលអ្នកធ្លាប់ជួប? តើព្រះអម្ចាស់អាចប្រើអ្នកជួយពួកគេដូចម្តេចខ្លះ?

ឱព្រះនៃសេចក្តីយុត្តិធម៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលមិនបានព្រងើយកន្តើយចំពោះការឈឺចាប់ក្នុងលោកីយ៍នេះ។

Daily Manna 2026_Content Enhance.indd 247 17/11/25 1:46 in the afternoon

នោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលតបថា តើមានអ្វីនៅដៃឯងនោះ លោកទូលឆ្លើយថា មានដំបង (និក្ខមនំ ៤:២)។

តើមានអ្វីនៅក្នុងដៃអ្នក?

កាលពីរបីឆ្នាំមុន បន្ទាប់ពីខ្ញុំបានទទួលសេចក្តីសង្គ្រោះ និងបានថ្វាយជីវិតដល់ព្រះអង្គ ខ្ញុំបានយល់ឃើញថា ព្រះអម្ចាស់កំពុងដឹកនាំខ្ញុំឲ្យលះបង់អាជីពរបស់ខ្ញុំ ជាអ្នកការសែត។ ខណៈពេលដែលខ្ញុំទម្លាក់ប៊ិចចុះ ហើយទុកចោលជំនាញតែងនិពន្ធ ខ្ញុំមិនអាចជម្នះអារម្មណ៍ដែលតែងតែគិតថា ថ្ងៃណាមួយព្រះអម្ចាស់នឹងត្រាស់ហៅខ្ញុំឲ្យធ្វើការតែងនិពន្ធ ដើម្បីថ្វាយសិរីល្អដល់ព្រះអង្គ។ ក្នុងអំឡុងពេលដែលខ្ញុំកំពុងវិលវល់ក្នុងវាលរហោស្ថានខាងវិញ្ញាណ ខ្ញុំក៏បានទទួលការលើកទឹកចិត្ត ពីរឿងរបស់លោក ម៉ូសេ និងដំបងរបស់គាត់ក្នុងបទគម្ពីរនិក្ខមនំជំពូក៤។

លោក ម៉ូសេ បានទទួលការចិញ្ចឹមបីបាច់ក្នុងរាជវាំងរបស់ស្តេច ផារ៉ោន ហើយរំពឹងថា នឹងមានអនាគតដ៏រុងរឿង ប៉ុន្តែគាត់បានរត់គេចចេញពីទឹកដីអេស៊ីព្ទ ហើយបានរស់នៅជាអ្នកគង្វាលក្នុងតំបន់ដែលមិនសូវមានគេស្គាល់។ នៅពេលដែលព្រះអម្ចាស់ត្រាស់ហៅគាត់ គាត់ប្រាកដជាគិតស្មានថា គាត់គ្មានអ្វីសម្រាប់ឲ្យព្រះអង្គប្រើគាត់ឡើយ តែក្រោយមកគាត់ក៏បានដឹងថា ព្រះអង្គអាចប្រើនរណាក៏បាន និងប្រើអ្វីក៏បាន ដើម្បីសម្រេចផែនការរបស់ព្រះអង្គ។

នោះព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលតបថា «តើមានអ្វីនៅដៃឯងនោះ? លោកទូលឆ្លើយថា «មានដំបង» (និក្ខមនំ ៤:២-៣)។ ពេលនោះ ដំបងដ៏សាមញ្ញរបស់លោក ម៉ូសេ ក៏បានប្រែក្លាយជាសត្វពស់មួយក្បាល។ នៅពេលដែលគាត់ចាប់កាន់ដំបងនោះ ព្រះអម្ចាស់ក៏បានធ្វើឲ្យវាក្លាយជាដំបងវិញ (ខ.៣-៤)។ ព្រះអម្ចាស់បានប្រទានទីសម្គាល់នេះមក ដើម្បីឲ្យពួកអ៊ីស្រាអែលជឿថា ព្រះយេហូវ៉ាដ៏ជាព្រះនៃពួកឰយុកោ ជាព្រះនៃអ័ប្រាហាំ ជាព្រះនៃអ៊ីសាក ហើយជាព្រះនៃយ៉ាកុប ទ្រង់បានលេចមកឯលោក ម៉ូសេ (ខ.៥)។ គឺដូចដែលលោក ម៉ូសេ ទម្លាក់ដំបងរបស់គាត់ ហើយវិលវាមកវិញ នោះខ្ញុំក៏បានបោះបង់អាជីពជាអ្នកការសែត ដោយការស្តាប់បង្គាប់ព្រះអម្ចាស់ ហើយក្រោយមក ព្រះអង្គក៏បានដឹកនាំខ្ញុំឲ្យចាប់កាន់ប៊ិចឡើងវិញ ដើម្បីឲ្យខ្ញុំធ្វើការជាអ្នកតែងនិពន្ធថ្វាយព្រះអង្គ។

យើងមិនត្រូវការសមត្ថភាពច្រើន ដើម្បីឲ្យព្រះអម្ចាស់ប្រើយើងនោះទេ។ យើងអាចគ្រាន់តែបម្រើព្រះអង្គដោយប្រើអំណោយទានដែលព្រះអង្គប្រទានយើង។ បើអ្នកមិនដឹងថា ត្រូវចាប់ផ្តើមពីចំណុចណាទេ តើអ្នកមានអ្វីនៅក្នុងដៃអ្នក?—Nancy Gavilanes

តើអ្នកអាចប្រើអំណោយទានរបស់អ្នក ដើម្បីបម្រើព្រះអង្គដូចម្តេចខ្លះ? តើអ្នកអាចប្រើធនធានរបស់អ្នក ដើម្បីធ្វើជាព្រះពរដល់នរណាម្នាក់នៅថ្ងៃនេះ ដោយរបៀបណា?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យប្រើជីវិតទូលបង្គំ ដើម្បីថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 248 17/11/25 1:46 in the afternoon

មានការអាក្រក់យ៉ាងធ្ងន់១មុខ ដែលយើងបានឃើញនៅក្រោមថ្ងៃ គឺមានទ្រព្យសម្បត្តិដែលម្ចាស់រក្សាទុកដរាបដល់កើតអន្តរាយដល់ខ្លួន (សាស្តា ៥:១៣)។

រឿងដែលបានដាស់តឿនយើង

ក្នុងខ្សែភាពយន្តចំណាស់មួយមានចំណងជើងថា លោក ខេន មិនមែនជាពលរដ្ឋធម្មតា លោក ឆាលី ហ្វូស្ទ័រ ខេន (Charlie Foster Kane) រកបានទ្រព្យសម្បត្តិច្រើនសន្ធឹក និងក្លាយជាអ្នកមានអំណាច តាមរយៈការពង្រីកមុខជំនួញផ្នែកសារព័ត៌មានរបស់គាត់។ ក្នុងរឿងមួយ ដែលបានឆ្លុះបញ្ចាំងបទគម្ពីរ សាស្តា ២:៤-១១ លោក ខេន បានស្វែងរកការសប្បាយគ្រប់យ៉ាង ដោយបានសាងសង់ប្រាសាទ ដែលមានសួនច្បារធំៗមានពេញទៅដោយស្នាដៃសិល្បៈដ៏មានតម្លៃ។

អ្វីដែលលោក ខេន ពិតជាចង់បាននោះ គឺការលើកតម្កើងខ្លួនឯង មិនខុសពីមហាសេដ្ឋីដទៃទៀតឡើយ។ គាត់បានចំណាយធនធានរបស់គាត់ក្នុងការប្រកួតប្រជែងក្នុងឆាកនយោបាយ ហើយនៅពេលដែលគាត់ទទួលបរាជ័យ ដើម្បីបិទបាំងភាពអាម៉ាសរបស់ខ្លួន គាត់ក៏បានចោទប្រកាន់គូរប្រកួតថា បានកេងបន្លំសន្លឹកឆ្នោត។ ដើម្បីឲ្យគេស្កប់ស្កែងគាត់ គាត់ក៏បានសាងសង់សាលមហោស្រពអូប៉េរ៉ាសម្រាប់ភរិយារបស់គាត់ ហើយក៏បានបង្ខំនាងឲ្យប្រលូកក្នុងអាជីពជាអ្នកចម្រៀង ដែលមិនសក្តិសមនឹងទេពកោសល្យរបស់នាង។ ត្រង់ចំណុចនេះ រឿងរបស់លោក ខេន ក៏បានធ្វើឲ្យយើងនឹកចាំបទគម្ពីរសាស្តា ដែលក្នុងនោះ ទ្រព្យសម្បត្តិនាំមកនូវគ្រោះថ្នាក់ដល់មនុស្សដែលដេញតាម និងបង្ករវាទុក (៥:១០-១៥) ដោយត្រូវរោយរៀវទៅក្នុងសេចក្តីងងឹត ក៏កើតមានទុក្ខព្រួយច្រើន (៥:១៧)។ នៅចុងបញ្ចប់នៃជីវិតរបស់លោក ខេន គាត់ត្រូវរស់នៅតែម្នាក់ឯងនៅក្នុងប្រាសាទដោយសេចក្តីកំហឹង។

រឿងរបស់លោក ខេន បានបញ្ចប់ ដោយបើកបង្ហាញការពិតដែលថា ការដេញតាមទ្រព្យសម្បត្តិ និងភាពល្បីល្បាញរបស់លោក ខេន គឺគ្រាន់តែបានធ្វើឲ្យចិត្តគាត់មានចន្លោះប្រហោងកាន់តែធំឡើង ដែលរាប់បញ្ចូលទាំងការបាត់បង់សេចក្តីស្រឡាញ់ពីឪពុកម្តាយតាំងពីក្មេងមក។ កណ្ឌគម្ពីរសាស្តា ក៏បានបង្រៀនយើងអំពីបញ្ហានេះផងដែរ។ ព្រះវរបិតានៃយើងបានបណ្តាលចិត្តយើង ឲ្យមានក្តីសង្ឃឹមដល់អស់កល្បទៅមុខ (៣:១១) ហើយជីវិតរបស់យើងអាចមានក្តីអំណរពិតប្រាកដបាន ដោយសារព្រះអង្គប៉ុណ្ណោះ (២:២៥)។ រឿងរបស់លោក ខេន បានដាស់តឿនយើងរាល់គ្នាឲ្យមានការប្រុងប្រយ័ត្នក្នុងការរស់នៅ ដោយប្រាប់យើង មិនឲ្យស្វែងរកការស្កប់ចិត្ត ឬភាពពេញលេញខាងវិញ្ញាណ តាមរយៈទ្រព្យសម្បត្តិ និងកេរ្តិ៍ឈ្មោះឡើយ តែតាមរយៈព្រះមួយអង្គដែលចាក់បង្ហូរសេចក្តីស្រឡាញ់របស់ព្រះអង្គ ចូលក្នុងចិត្តយើង (រ៉ូម ៥:៥)។—Sheridan Voysey

តើអ្នកកំពុងយកតម្រាប់តាមលោក ឆាលី ខេន ដោយមិនដឹងខ្លួនដែរឬទេ? តើអ្នកមានសេចក្តីត្រូវការខាងវិញ្ញាណអ្វីខ្លះ ដែលត្រូវការឲ្យព្រះទ្រង់បំពេញឲ្យនៅថ្ងៃនេះ?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ដែលចង់ស្វែងរកការស្កប់ចិត្តតាមរយៈទ្រព្យសម្បត្តិ និងការសរសើររបស់មនុស្ស។ មានតែព្រះអង្គទេ ដែលអាចបំពេញតម្រូវការខាងវិញ្ញាណរបស់ទូលបង្គំបាន។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ១៣២-១៣៤ និង១កូរិនថូស ១១:១៧-៣៤

ឯឆ្កែព្រៃ និងកូនចៀមវានឹងរកស៊ីជាមួយគ្នា (អេសាយ ៦៥:៦៥)។

ពេលដែលយើងជឿថា យើងនឹងបានឃើញ

មានពេលមួយភរិយាខ្ញុំឈ្មោះ ខារី (Cari) បានហៅខ្ញុំឲ្យដើរមកមាត់បង្អួច ហើយក៏បានចង្អុលទៅសត្វក្តាន់ញីពេញវ័យមួយក្បាលនៅក្នុងព្រៃ នៅក្បែរបងផ្ទះរបស់យើង ដោយរត់ចុះឡើងៗ ពីចុងម្ខាងនៃរបងផ្ទះយើងទៅចុងម្ខាងទៀត។ ចំណែកឯឆ្កែរបស់យើងដែលមានមាឌធំ ពួកវាក៏បានរត់ចុះឡើងៗ នៅខាងក្នុងទីធ្លាផ្ទះ តាមសត្វក្តាន់នោះ ដែលនៅក្រៅរបង ប៉ុន្តែពួកវាមិនបានព្រុសទាល់តែសោះ។ ពួកវាក៏បានបន្តរត់ចុះឡើងៗដូចនេះជិត១ម៉ោង។ ពេលណាសត្វក្តាន់ឈប់ ហើយងាកមកមើលពួកវា ពួកវាក៏បានឈប់ផងដែរ ដោយពួកវាតម្រង់ជើងខាងមុខ ហើយបន្ទន់ជើងខាងក្រោយ ដើម្បីត្រៀមខ្លួនរត់ទៀត។ នេះមិនមែនជាអាកប្បកិរិយារបស់សត្វសាហាវដេញចាប់សត្វស្លូតធ្វើជាចំណីនោះទេ តាមពិតសត្វក្តាន់ និងសត្វឆ្កែរបស់ខ្ញុំកំពុងតែរត់លេងជាមួយគ្នា ដោយចិត្តរីករាយបានជាភរិយាខ្ញុំលាន់មាត់ថា គាត់មិននឹកស្មានសោះថា គាត់បានឃើញទិដ្ឋភាពដែលគួរឲ្យពេចពិលមិលមើលនេះ។

សម្រាប់ខ្ញុំ និងភរិយារបស់ខ្ញុំ ការលេងប្រឡែងរបស់ពួកវានៅពេលព្រឹកនោះបានធ្វើឲ្យយើងនឹកចាំអំពីទិដ្ឋភាពដែលបានពិពណ៌នាអំពីនគរព្រះដែលត្រូវមកដល់។ ក្នុងកណ្ឌគម្ពីរអេសាយ ព្រះអម្ចាស់បានមានបន្ទូលសន្យាថា ព្រះអង្គនឹងបង្កើតផ្ទៃមេឃ និងផែនដីថ្មី (អេសាយ ៦៥:១៧)។ ព្រះអង្គក៏បានមានបន្ទូលទៀតថា "ឆ្កែព្រៃ និងកូនចៀមវានឹងរកស៊ីជាមួយគ្នា ហើយសិង្ហនឹងស៊ីចំបើងដូចជាគោ" (ខ.២៥)។ នៅពេលនោះ សត្វសាហាវនឹងមិនចាប់សត្វដទៃទៀតជាអាហារទៀតទេ តែពួកវានឹងនៅជាមួយគ្នាដូចមិត្តភក្តិ។

ព្រះបន្ទូលដែលបានចែងក្នុងកណ្ឌគម្ពីរអេសាយ ហាក់ដូចជាបង្ហាញឲ្យយើងដឹងថា នគរដ៏អស់កល្បរបស់ព្រះនឹងមានសត្វគ្រប់ប្រភេទ ដែលការនេះក៏បានចង្អុលបង្ហាញទៅរកការអ្វីដែលព្រះអង្គបានត្រៀមទុកសម្រាប់ស្នាព្រះហស្តព្រះអង្គ "ជាពិសេសសម្រាប់អ្នកដែលស្រឡាញ់ព្រះអង្គ" (១កូរិនថូស ២:៩)។ នគរព្រះអង្គជាទីកន្លែងស្រស់ស្អាតបំផុត! ពេលណាយើងទទួលជឿព្រះអង្គ ព្រះអង្គនាំយើងមើលទៅសន្តិភាព និងសុវត្ថិភាពនៅក្នុងព្រះវត្តមានរបស់ព្រះអង្គជារៀងរហូត ដែលនេះជាការពិតដែលនឹងកើតមានសម្រាប់យើង!—James Banks

តើអ្នកកំពុងទន្ទឹងរង់ចាំអ្វីខ្លាំងជាងគេ នៅក្នុងនគរព្រះ? តើអ្នកអាចចែកចាយក្តីសង្ឃឹមរបស់អ្នកដល់នរណាខ្លះ នៅថ្ងៃនេះ?

ឱព្រះវរបិតានៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់សេចក្តីល្អដែលនឹងមកដល់! សូមព្រះអង្គជួយទូលបង្គំ ឲ្យទន្ទឹងរង់ចាំពេលដែលទូលបង្គំនឹងបានជួបព្រះអង្គមុខទល់នឹងមុខ។

គម្រោងអានព្រះគម្ពីរយ:ពេល១ឆ្នាំ | ទំនុកតម្កើង ១៣៥-១៣៦ និង១កូរិនថូស ១២

ពួកអ្នកដែលជឿទាំងប៉ុន្មាន ក៏នៅជាមួយគ្នា ហើយមានរបស់ទាំងអស់នៅមូលព្រមគ្នា (កិច្ចការ ២:៤៤)។

បន្ទាបខ្លួនសុំជំនួយ

ខណៈពេលដែលពិធីជប់លៀងរបស់គ្រួសារខ្ញុំជិតចូលមកដល់ ខ្ញុំនិងភរិយាខ្ញុំក៏បានចាប់ផ្តើមរៀបផែនការ។ ដោយសារយើងមានភ្ញៀវជាច្រើនដែលនឹងមកចូលរួម តើយើងគួរតែជួលចុងភៅឲ្យរៀបចំម្ហូបអាហារសម្រាប់យើងដែរឬទេ? បើយើងត្រូវធ្វើម្ហូបដោយខ្លួនឯង តើយើងគួរតែទិញចង្ក្រានសម្រាប់អាំងសាច់បាប៊ីឃ្យូទេ? ថ្ងៃនោះអាចនឹងមានភ្លៀង តើយើងគួរតែទិញឆាងសម្រាប់ជ្រកភ្លៀងដែរឬទេ? មិនយូរប៉ុន្មាន ពិធីជប់លៀងរបស់យើងមានការចំណាយកាន់តែច្រើន ហើយយើងក៏ខ្វះការប្រាស្រ័យទាក់ទងគ្នាបន្តិច។ នៅក្នុងការព្យាយាមផ្គត់ផ្គង់អ្វីគ្រប់យ៉ាងដោយខ្លួនឯង យើងក៏បានខកខានមិនបានឆក់ឱកាសទទួលជំនួយពីអ្នកដទៃ។

សហគមន៍ដែលសមស្របតាមព្រះគម្ពីរ គឺមានការឲ្យ និងការទទួល។ សូម្បីតែកាលមនុស្សដំបូងមិនទាន់ធ្លាក់ចូលក្នុងបាប លោក អ័ដាម ក៏ត្រូវការជំនួយផងដែរ (លោកុប្បត្តិ ២:១៨) ហើយក្រោយមកព្រះអម្ចាស់បានបង្រៀនយើង ឲ្យស្វែងរកការប្រឹក្សាយោបល់ពីអ្នកដទៃ (សុភាសិត ១៥:២២) ហើយចែករំលែកបន្ទុករបស់យើងដល់គ្នាទៅវិញទៅមក (កាឡាទី ៦:២)។ ពួកជំនុំដំបូងបានលក់ទ្រព្យសម្បត្តិ ដើម្បីជួយគ្នាទៅវិញទៅមកតាមដែលត្រូវការ ហើយក៏មានចិត្តគំនិតដែលរួបរួមគ្នាផងដែរ (កិច្ចការ ២:៤៤-៤៥)។ ពួកគេមិនបានរស់នៅ ដោយឯករាជ្យដាច់ដោយឡែកពីគ្នានោះទេ តែផ្ទុយទៅវិញ ពួកគេចែករំលែក ឲ្យខ្ចី ឲ្យអំណោយ ហើយទទួលពីគ្នាទៅវិញទៅមក ដោយការប្រាស្រ័យទាក់ទងគ្នាយ៉ាងមានរបៀប។

សម្រាប់ពិធីជប់លៀងរបស់គ្រួសារខ្ញុំនៅថ្ងៃនោះ យើងក៏បានសម្រេចចិត្តស្នើឲ្យភ្ញៀវរបស់យើង នាំយកបន្លែចម្រុះមកធ្វើម្ហូបសាឡាត់ ឬនាំបង្អែមមកចូលរួមពិធីជប់លៀងនៅផ្ទះយើង។ អ្នកជិតខាងរបស់យើងក៏បានយកចង្ក្រានអាំងសាច់បាប៊ីឃ្យូមក ហើយមិត្តភក្តិរបស់យើងខ្លះក៏បាននាំយកឆាងរបស់គាត់មក សម្រាប់ត្រៀមជ្រកពេលភ្លៀងផងដែរ។ ការដែលយើងសុំជំនួយពីពួកគេ គឺបានជួយឲ្យយើងមានទំនាក់ទំនងកាន់តែជិតស្និទ្ធ ហើយអាហារដែលពួកគេបានយកមក បាននាំឲ្យយើងមានម្ហូបច្រើនមុខសម្រាប់ចែករំលែក និងបរិភោគជាមួយគ្នាយ៉ាងសប្បាយរីករាយ។ ក្នុងសម័យបច្ចុប្បន្ន ការចូលចិត្តផ្គត់ផ្គង់ខ្លួនឯង ដោយមិនពឹងពាក់អ្នកដទៃ អាចក្លាយជាប្រភពនៃសេចក្តីអំនួត។ ប៉ុន្តែ ព្រះអម្ចាស់ប្រទានព្រះគុណ ដល់មនុស្សដែលបន្ទាបខ្លួន (យ៉ាកុប ៤:៦) គឺរាប់បញ្ចូលទាំងអ្នកដែលសុំជំនួយពីអ្នកដទៃ ដោយការបន្ទាបខ្លួនផងដែរ។—Sheridan Voysey

តើមានអ្វីរារាំងអ្នកមិនឲ្យសុំជំនួយពីអ្នកដទៃ? តើថ្មីៗនេះ អ្នកមានតម្រូវការអ្វីខ្លះ ដែលអ្នកអាចខ្ចីពីគេ ជាជាងចំណាយលុយទិញ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានបង្កើតយើងខ្ញុំមក ឲ្យចេះគិតមានហេតុផល។ សូមព្រះអង្គជួយទូលបង្គំឲ្យរស់នៅដោយការបន្ទាបខ្លួន ដោយចែករំលែកធនធានដល់អ្នកដទៃ ក៏ដូចជាហ៊ានទទួលជំនួយពីគេវិញផងដែរ។

គម្រោងអានព្រះគម្ពីរប្រចាំឆ្នាំ | ទំនុកតម្កើង ១៣៧-១៣៩ និង១កូរិនថូស ១៣

ឱព្រះយេហូវ៉ាអើយ សូមស្តាប់ពាក្យ ដែលទូលបង្គំអធិស្ឋាន សូមផ្ទៀងព្រះកាណ៌ស្តាប់សំរែកទូលបង្គំផង (ទំនុកតម្កើង ៣៩:១២)។

ព្រះអម្ចាស់ស្តាប់ឮយើងអធិស្ឋាន

មានក្មេងជាសិស្សថ្នាក់ទី១ម្នាក់ បានទូរស័ព្ទទៅកាន់លេខ៩១១ ជាលេខសង្គ្រោះបន្ទាន់។ អ្នកលើកទូរស័ព្ទសង្គ្រោះបន្ទាន់ ក៏បានឆ្លើយតប។ ក្មេងប្រុសនោះក៏បានប្រាប់គាត់ថា «ខ្ញុំត្រូវការជំនួយជាបន្ទាន់។ ខ្ញុំត្រូវធ្វើលំហាត់លេខដក ដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ តែខ្ញុំមិនចេះធ្វើទេ»។ ភ្នាក់ងារសង្គ្រោះបន្ទាន់ដែលកំពុងឆ្លើយឆ្លងជាមួយគាត់ ក៏បានជួយបង្រៀនគាត់ធ្វើលេខដករហូតដល់ពេលដែលគាត់ឮសម្លេងស្ត្រីម្នាក់ដើរចូលក្នុងបន្ទប់របស់ក្មេងនោះ ហើយនិយាយថា «ចននី (Johnny) កូនកំពុងធ្វើអីហ្នឹង?» ចននី ក៏បានបកស្រាយថា គាត់មិនអាចធ្វើលំហាត់គណិតវិទ្យាដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ តែគាត់ចាំថា ម្តាយគាត់ធ្លាប់ប្រាប់គាត់អំពីរបៀបស្វែងរកការសង្គ្រោះបន្ទាន់។ ចននី ក៏បានទូរស័ព្ទទៅលេខ៩១១។ សម្រាប់ ចននី គាត់គិតស្មានថា គាត់មានហេតុផលគ្រប់គ្រាន់ ដើម្បីទូរស័ព្ទហៅជំនួយបន្ទាន់។ សម្រាប់ភ្នាក់ងារសង្គ្រោះបន្ទាន់ ដែលមានចិត្តអាណិតដល់គាត់ ការជួយប្រៀនក្មេងប្រុសនេះធ្វើលំហាត់ គឺជារឿងដែលចាំបាច់នៅពេលនោះ។

កាលស្តេច ដាវីឌ ជាអ្នកនិពន្ធបទគម្ពីរទំនុកតម្កើងត្រូវការជំនួយ ទ្រង់បានអធិស្ឋានថា «ឱព្រះយេហូវ៉ាអើយ សូមឲ្យទូលបង្គំដឹងពីចុងបំផុតនៃទូលបង្គំ ហើយពីចំនួនថ្ងៃអាយុនៃទូលបង្គំផង ដើម្បីឲ្យទូលបង្គំបានដឹងជាមានជីវិតផុយស្រួយ អម្បាលម៉ានទៅ» (ទំនុកតម្កើង ៣៩:៤)។ ស្តេច ដាវីឌ ក៏បានពោលទៀតថា «ទូលបង្គំសង្ឃឹមដល់ទ្រង់តែ១ប៉ុណ្ណោះ» (ខ.៧)។ ហេតុនេះហើយ ទ្រង់បានទូលអង្វរ សូមព្រះអម្ចាស់ព្រះសណ្តាប់សំរែករបស់ទ្រង់ (ខ.១២)។ ព្រះគម្ពីរមិនបានចែងជាលម្អិតថា កាលនោះស្តេច ដាវីឌ កំពុងត្រូវការជំនួយអ្វីខ្លះទេ តែទ្រង់បានប្រកាសថា ព្រះអម្ចាស់នឹងគង់នៅជាមួយទ្រង់ជានិច្ច ដោយព្រះសណ្តាប់ ហើយឆ្លើយតបចំពោះសេចក្តីអធិស្ឋានរបស់ទ្រង់។

ទំនុកចិត្តដែលយើងមានចំពោះព្រះវត្តមានដ៏ស្ថិតស្ថេររបស់ព្រះអង្គ ជួយឲ្យយើងមានចិត្តស្មោះត្រង់មិនងាករេ ដោយជឿច្បាស់ថា គ្មានការទូលសូមអ្វីដែលធំពេក ឬតូចពេកសម្រាប់ព្រះដែលមិនចេះប្រែប្រួលឡើយ។ ព្រះអង្គឮពាក្យយើងអធិស្ឋាន ក៏យកព្រះទ័យទុកដាក់ចំពោះយើង ហើយឆ្លើយតបចំពោះការអធិស្ឋានរបស់យើង។—Xochitl Dixon

តើព្រះអម្ចាស់បានបង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកដូចម្តេចខ្លះ តាមរយៈការឆ្លើយតបការទូលសូមរបស់អ្នក? តើអ្នកមានតម្រូវការអ្វីដែលហាក់ដូចជាធំពេក ឬតូចពេកសម្រាប់ទូលសូមព្រះអង្គ?

ឱព្រះនៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានស្តាប់ឮ និងធ្វើឲ្យតបចំពោះការអធិស្ឋានទីមួយៗ ដែលទូលបង្គំបានថ្វាយក្នុងព្រះហស្តព្រះអង្គ។

Daily Manna 2026_Content Enhance.indd 252 17/11/25 1:46 in the afternoon

ទាំងរត់ដំរង់ទៅឯទី ដើម្បីឲ្យបានរង្វាន់នៃការងារជ័ខ្ពស់របស់ព្រះ ក្នុងព្រះគ្រីស្ទយេស៊ូវ (ភីលីព ៣:១៤)។

តម្រង់ទៅរកសិរីល្អដែលខ្ពង់ខ្ពស់ជាង

លោក ស្ទែន លី (Stan Lee) ជាអ្នកបោះពុម្ពផ្សាយសៀវភៅរឿងប្រឌិតអមដោយរូបភាព របស់ក្រុមហ៊ុនម៉ាវែល (Marvel)។ គាត់បានលាចាកលោកកាលពីឆ្នាំ២០១៨ ដោយបន្សល់ទុកនូវរឿងនិទានអំពីតួអង្គវីរបុរសដ៏ពេញនិយម ដែលមានដូចជា មនុស្សពីងពាង Iron Man, the Fantastic Four, the Hulk និងតួអង្គជាច្រើនទៀត។ នៅក្នុងរូបថត គេឃើញលោក ស្ទែន លី ជាអ្នកនិពន្ធដែលតែងតែបង្ហាញទឹកមុខញញឹមស្រស់ ដោយពាក់វ៉ែនតាខ្មៅ។ នៅក្នុងការបោះពុម្ពផ្សាយសៀវភៅរឿងរបស់ក្រុមហ៊ុនម៉ាវែលជាប្រចាំខែ គាត់តែងតែបញ្ចប់ការនិពន្ធសៀវភៅនីមួយៗ ដោយសរសេរពាក្យ អិចខ្សែលស៊ីអ័រ (excelsior) អស់ជាច្រើនទសវត្សរ៍មកហើយ។ ក្នុងការបង្ហោះសារក្នុងបណ្តាញសង្គម ធ្វីតទ័រ (Tweeter) កាលពីឆ្នាំ២០១០ គាត់បានបកស្រាយថា ពាក្យនេះមានន័យថា "ចូរមើលទៅមុខ ឆ្ពោះទៅរកសិរីល្អដែលប្រសើរជាង"។ គាត់ថា នៅចុងបញ្ចប់នៃសារនីមួយ ដែលគាត់បង្ហោះតាមបណ្តាញសង្គមធ្វីតទ័រ គាត់តែងតែប្រើពាក្យនេះ ដើម្បីលើកទឹកចិត្តគេឲ្យអនុវត្តតាមអត្ថន័យរបស់ពាក្យនេះក្នុងការរស់នៅ។

ពាក្យដែលគាត់ចូលចិត្តប្រើនេះបានធ្វើឲ្យខ្ញុំនឹកចាំ អំពីពាក្យពេចន៍ដែលសាវ័កប៉ុលបានសរសេរក្នុងសំបុត្រមួយច្បាប់ ផ្ញើទៅពួកជំនុំនៅទីក្រុងភីលីព ខណៈពេលដែលគាត់បង្រៀនអ្នកជឿទាំងឡាយឲ្យបំភ្លេចរឿងកន្លងទៅ ហើយឲ្យមើលទៅមុខ និងមើលទៅលើវិញ។ គឺដូចដែលគាត់មានប្រសាសន៍ថា "ខ្ញុំភ្លេចសេចក្តីទាំងប៉ុន្មានដែលកន្លងទៅហើយ ក៏ខំមមុលឈោងទៅឯសេចក្តីខាងមុខទៀតទាំងរត់ដំរង់ទៅឯទី ដើម្បីឲ្យបានរង្វាន់នៃការងារដ៏ខ្ពស់របស់ព្រះក្នុងព្រះគ្រីស្ទយេស៊ូវ" (ភីលីព ៣:១៣-១៤) ។

យើងងាយនឹងជាប់ជំពាក់ ក្នុងចំណងនៃការស្តាយក្រោយ ឬការសម្រេចចិត្តខុសកាលពីអតីតកាល។ ប៉ុន្តែក្នុងព្រះគ្រីស្ទ ព្រះអង្គបានអញ្ជើញយើងឲ្យថ្វាយការស្តាយក្រោយដល់ព្រះអង្គ ហើយបន្តរត់តម្រង់ទៅរកសិរីល្អរបស់ព្រះអង្គ ដែលធំប្រសើរជាងអ្វីៗនៅផែនដី ដោយឱបក្រសោបយកការអត់ទោស និងគោលបំណង ដែលព្រះអង្គបានប្រទានដល់យើង ដោយព្រះគុណដ៏ធំឧត្តម!—Adam R. Holz

ហេតុអ្វីអ្នកច្រើនតែមើលទៅមុខ ឬងាកមកក្រោយមើលទៅកំហុសពីអតីតកាលក្នុងជីវិត និងសេចក្តីជំនឿរបស់អ្នក? តើអ្នកអាចបំភ្លេចកំហុសពីអតីតកាល ហើយមមុលទៅមុខយ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានការអត់ទោសជាបឋម។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានបង្គាប់ទូលបង្គំឲ្យមើលទៅព្រះអង្គ ហើយខំមមុលទៅរកសិរីល្អរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ទំនុកតម្កើង ១៤៣-១៤៥ និង១កូរិនថូស ១៤:២១-៤០

[សេចក្តីស្រឡាញ់] មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន មិនរហ័សខឹង មិនប្រកាន់ទោស (១កូរិនថូស ១៣:៥)។

សេចក្តីស្រឡាញ់ មានការអធ្យាស្រ័យ

មានពេលមួយ ខ្ញុំបានប្រញាប់ទៅភោជនីយដ្ឋានអាហាររហ័ស ដើម្បីញ៉ាំអាហារថ្ងៃត្រង់ជាមួយមិត្តភក្តិខ្ញុំឈ្មោះ ជើរី (Jerrie) ក្នុងម៉ោងសម្រាកបាយថ្ងៃត្រង់។ យើងបានទៅដល់មាត់ទ្វារភោជនីយដ្ឋាននៅក្នុងពេលដំណាលគ្នានឹងយុវជន៦នាក់ តែពួកគេបានចូលទៅឈរតម្រង់ជួរមុនយើង។ ពេលនោះ យើងដឹងថា យើងមិនមានពេលច្រើន ដើម្បីរង់ចាំទេ បានជាយើងមានការអ៊ូរទាំតែក្នុងចិត្ត។ ពួកគេបានឈរជាក្រុម នៅពីមុខកន្លែងកុម្ម៉ង់អាហារ ដើម្បីធ្វើយ៉ាងណាឲ្យពួកគេម្នាក់ៗអាចកុម្ម៉ង់អាហារបានមុនគេ។ បន្ទាប់មក ខ្ញុំក៏បានឮជើរីនិយាយខ្សឹបៗម្នាក់ឯងថា «សូមអធ្យាស្រ័យ ឲ្យពួកខ្ញុំចូលកុម្ម៉ង់មុនផង»។ ជាការពិតណាស់ បើគេឲ្យយើងចូលកុម្ម៉ង់អាហារមុនមិនដឹងជាល្អយ៉ាងណាទេ ប៉ុន្តែយើងក៏ត្រូវចាំថា យើងត្រូវគិតអំពីតម្រូវការរបស់អ្នកដទៃ ជាសំខាន់ជាងតម្រូវការខ្លួនឯង។

ព្រះគម្ពីរបានបង្រៀនថា សេចក្តីស្រឡាញ់មានភាពអត់ធ្មត់ សប្បុរស និងមិនគិតប្រយោជន៍ផ្ទាល់ខ្លួន ហើយក៏មិនរហ័សខឹងដែរ (១កូរិនថូស ១៣:៥)។ មិនដែលប្រព្រឹត្តបែបមិនគួរសម មិនដែលរកប្រយោជន៍ផ្ទាល់ខ្លួន។ សេចក្តីស្រឡាញ់ដែលមកពីព្រះ តែងតែគិតអំពីប្រយោជន៍របស់អ្នកដទៃជាមុន។

ក្នុងលោកីយ៍ ដែលមនុស្សជាច្រើន ងាយនឹងមានអារម្មណ៍មួម៉ៅ យើងច្រើនតែមានឱកាសទូលសូមព្រះអង្គជួយយើង និងប្រទានព្រះគុណ ដើម្បីឲ្យយើងជ្រើសរើសយកចិត្តអត់ធ្មត់ចំពោះអ្នកដទៃ ហើយមានចិត្តសប្បុរស (ខ.៤)។ កណ្ឌគម្ពីរ សុភាសិត ១៩:១១ បានចែងថា «សតិបញ្ញារបស់មនុស្សនឹងនាំឲ្យយឺតនឹងខឹង អ្នកនោះក៏តែងមានចិត្តអរ ដោយមិនប្រកាន់ទោសវិញ»។

នេះជាប្រភេទនៃការប្រព្រឹត្តដោយក្តីស្រឡាញ់ ដែលថ្វាយព្រះកិត្តិនាមដល់ព្រះ ហើយព្រះអង្គថែមទាំងប្រើការប្រព្រឹត្តដូចនេះ ដើម្បីនាំអ្នកដទៃឲ្យពិចារណាអំពីសេចក្តីស្រឡាញ់របស់ព្រះអង្គផងដែរ។

ចូរយើងស្វែងរកឱកាសបង្ហាញការអធ្យាស្រ័យ និងក្តីអាណិតចំពោះអ្នកដទៃ ដោយពឹងផ្អែកកម្លាំងមកពីព្រះអង្គ។—Anne Cetas

តើអ្នកអាចជៀសវាងការប្រព្រឹត្តដោយកំហឹង យ៉ាងដូចម្តេចខ្លះ? តើការងាកបែរទៅរកព្រះ បានជួយអ្នកដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំត្រូវការជំនួយមកពីព្រះអង្គ។ ទូលបង្គំប្រឈមមុខដាក់បញ្ហាជាច្រើនដែលគួរឲ្យរំខាន ប៉ុន្តែទូលបង្គំចង់ឲ្យចិត្តទូលបង្គំហូរហៀរដោយក្តីស្រឡាញ់របស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 254 17/11/25 1:46 in the afternoon

ដូច្នេះ ដែលបានដោះសេចក្តីកំភូតចេញហើយ នោះត្រូវឲ្យនិយាយសេចក្តីពិត នឹងអ្នកជិតខាងរៀងខ្លួនវិញ ដ្បិតយើងរាល់គ្នាជាអវយវៈផងគ្នាទៅវិញទៅមក (អេភេសូរ ៤:២៥)។

និយាយតែពាក្យពិតក្នុងព្រះគ្រីស្ទ

បុរសម្នាក់មានជំនាញខាងគេចវេសពីការបង់ប្រាក់ពិន័យសម្រាប់បទល្មើសច្បាប់ចរាចរណ៍ ដោយការនិយាយកុហកខែតុលាការ។ នៅពេលណាគាត់បង្ហាញខ្លួននៅចំពោះមុខចៅក្រមក្នុងខែតុលាការ គាត់តែងតែប្រាប់គេថា គាត់និងមិត្តស្រីរបស់គាត់បានចែកផ្លូវគ្នា ហើយនាងបានយកឡានគាត់ទៅបើកបរដោយមិនឲ្យគាត់ដឹង។ គាត់ប្រឌិតរឿងដដែលៗយ៉ាងដូចនេះ ដើម្បីឲ្យចៅក្រមអាណិតគាត់ ហើយលើកលែងការបង់ថ្លៃជាកពិន័យ។ ជាងនេះទៅទៀត គាត់បានទទួលការស្តីបន្ទោសធ្ងន់ៗម្តងហើយម្តងទៀត ដោយសារគាត់មានអាកប្បកិរិយាមិនសមរម្យក្នុងម៉ោងការងារ។ ទីបំផុត ចៅក្រមក៏បានសម្រេចចោទប្រកាន់គាត់ពីបទនិយាយកុហកខែតុលាការ៤ដង ការក្លែងបន្លំ៥ដង និងការផ្តល់ចម្លើយក្លែងក្លាយដល់មន្ត្រីប៉ូលិស។ សម្រាប់បុរសនេះ ការកុហកបានក្លាយជាទម្លាប់ពេញមួយជីវិតគាត់ហើយ។

សាវ័ក ប៉ុល បានបង្រៀនគ្រីស្ទបរិស័ទឲ្យមានទម្លាប់និយាយការពិតក្នុងការរស់នៅ ព្រោះវាជាទម្លាប់ដ៏សំខាន់។ គាត់បានរំឭកពួកជំនុំនៅទីក្រុងអេភេសូរថា ពួកគេត្រូវតែលះបង់ចោលទម្លាប់ចាស់នៃការរស់នៅដោយថ្វាយជីវិតរបស់ខ្លួនដល់ព្រះគ្រីស្ទវិញ (អេភេសូរ ២:១-៥)។ សព្វថ្ងៃនេះ ពួកគេចាំបាច់ត្រូវរស់នៅជាមនុស្សថ្មីដែលបានផ្លាស់ប្រែ ដោយរាប់បញ្ចូលការអនុវត្តដ៏ជាក់លាក់មួយចំនួននៅក្នុងការរស់នៅ។ ក្នុងចំណោមការអនុវត្តន៍នោះ ពួកគេចាំបាច់ត្រូវ «លះបង់ចោលការនិយាយកុហក» ហើយការអនុវត្តន៍មួយទៀតដែលពួកគេត្រូវមាននោះគឺ ត្រូវ «និយាយសេចក្តីពិត នឹងអ្នកជិតខាងរៀងខ្លួនវិញ» (៤:២៥)។ ដោយសារការនិយាយសេចក្តីពិតបានជួយការពារការរួបរួមនៃពួកជំនុំ ពួកជំនុំនៅទីក្រុងអេភេសូរត្រូវតែប្រើពាក្យសម្តី និងការប្រព្រឹត្ត ដើម្បី «ជួយស្អាងអ្នកដទៃឡើង» (ខ.២៩)។

ខណៈពេលដែលព្រះវិញ្ញាណបរិសុទ្ធជួយយើង (ខ.៣-៤) យើងអាចព្យាយាមរស់នៅដោយការនិយាយស្តីនិងប្រព្រឹត្ត ស្របតាមសេចក្តីពិត។ ពេលនោះ ពួកជំនុំនឹងមានការរួបរួម ហើយយើងនឹងបានថ្វាយព្រះកិត្តិនាមដល់ព្រះអម្ចាស់។—Marvin Williams

តើមានអ្វីជួយអ្នកឲ្យនិយាយតែសេចក្តីពិត? តើពាក្យសម្តីរបស់អ្នកបានឆ្លុះបញ្ចាំង ជីវិតថ្មីដែលអ្នកមានក្នុងព្រះគ្រីស្ទយ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យលះបង់ចោលការភូតកុហក ហើយដណ្តប់កាយទូលបង្គំដោយសេចក្តីពិតរបស់ព្រះអង្គវិញ។

Daily Manna 2026_Content Enhance.indd 255 17/11/25 1:46 in the afternoon

កាលណាទៅដល់មាត់ទឹកទន្លេយ័រដាន់ហើយ នោះត្រូវចុះទៅឈរនៅក្នុងទឹកនោះទៅ (យ៉ូស្វេ ៣:៨)។

បោះជំហានទៅមុខដោយជំនឿ

គ្រូគង្វាលម្នាក់បានមកអធិប្បាយព្រះបន្ទូល ក្នុងលក្ខណៈជាភ្ញៀវរបស់ព្រះវិហារមួយកន្លែង។ គាត់បានចែកចាយអំពីប្រាជ្ញា នៅក្នុងការទុកចិត្តព្រះ ហើយបោះជំហានទៅមុខ ដោយចិត្តក្លាហាន។ គាត់បានចែកចាយទីបន្ទាល់របស់គ្រូគង្វាលម្នាក់ ដែលបានទុកចិត្តព្រះ ហើយបានសម្រេចចិត្តចែកចាយតែសេចក្តីពិតដែលមានចែងក្នុងព្រះគម្ពីរក្នុងការអធិប្បាយព្រះបន្ទូល ទោះច្បាប់ក្នុងប្រទេសគាត់បានហាមយ៉ាងណាក៏ដោយ។ គេក៏បានកាត់ទោសគាត់ពីបទញុះញង់ឲ្យមានការរើសអើង ហើយក៏បានជាប់គុកអស់រយៈពេល៣០ថ្ងៃ។ ប៉ុន្តែ គាត់ក៏បានប្តឹងឧទរ ហើយខែតុលាការក៏បានសម្រេចឲ្យគាត់មានសិទ្ធិក្នុងការចែកចាយព្រះបន្ទូលតាមការកាត់ស្រាយផ្ទាល់ខ្លួន និងមានសិទ្ធិជំរុញអ្នកដទៃឲ្យដើរតាមព្រះបន្ទូលព្រះ។

នៅគ្រាសញ្ញាចាស់ ពួកសង្ឃដែលមានតួនាទីសែងហិបសញ្ញា ក៏ត្រូវធ្វើការសម្រេចចិត្តផ្ទាល់ខ្លួនផងដែរថា ពួកគេត្រូវបោះជំហានចូលទៅក្នុងទឹកទន្លេ ឬបន្តឈរនៅលើច្រាំងទន្លេ។ បន្ទាប់ពីប្រជាជនអ៊ីស្រាអែលបានភៀសខ្លួនចេញពីទឹកដីអេស៊ីព្ទមក ពួកគេបានរស់នៅវិលវល់ក្នុងវាលរហោស្ថានអស់រយៈពេល៤០ឆ្នាំ។ ទីបំផុតពួកគេក៏បានឈរនៅមាត់ច្រាំងទន្លេយ័រដាន់ ដែលកំពុងមានទឹកជន់ជោរ។ ប៉ុន្តែ ពួកគេបានបោះជំហានទៅមុខចូលទៅក្នុងទឹកទន្លេ ហើយព្រះអម្ចាស់ក៏បានធ្វើឲ្យទឹកស្រក។ គឺដូចមានសេចក្តីចែងថា «ពួកសង្ឃដែលសែងហិបបានមកដល់ទន្លេយ័រដាន់ ក៏ដាក់ជើងចុះទៅក្នុងទឹកនៅមាត់ទន្លេ... នោះទឹកដែលហូរចុះពីលើមក ក៏ឈប់នៅនឹង» (យ៉ូស្វេ ៣:១៥-១៦)។

ពេលណាយើងថ្វាយជីវិតយើងដាច់ដល់ព្រះអង្គ ព្រះអង្គនឹងប្រទានយើងនូវសេចក្តីក្លាហាន ដើម្បីបោះជំហានទៅមុខ ទោះនោះជាការសម្រេចចិត្តចែកចាយសេចក្តីពិតក្នុងព្រះគម្ពីរ ឬបោះជំហានចូលទៅក្នុងទឹកដីដែលអ្នកមិនស្គាល់ក៏ដោយ។ ក្នុងអំឡុងពេលនៃការកាត់ទោសគ្រូគង្វាលរូបនោះ គាត់ក៏បានឆ្លៀតឱកាសចែកចាយអត្ថន័យនៃដំណឹងល្អ ក្នុងមនុស្សទាំងអស់នៅក្នុងបន្ទប់កាត់ក្តី។ ហើយក្នុងកណ្ឌគម្ពីរយ៉ូស្វេ ពួកអ៊ីស្រាអែលបានឆ្លងទន្លេយ័រដាន់ចូលទឹកដីសន្យាដោយជោគជ័យ ហើយក៏បានចែកចាយអំពីព្រះចេស្តារបស់ព្រះទៅដល់មនុស្សជំនាន់ក្រោយ (ខ.១៧ ៤:២៤)។

ពេលណាយើងបោះជំហានទៅក្រៅ ដោយជំនឿ ព្រះអង្គនឹងចាត់ចែងការអ្វីផ្សេងទៀត។—Alyson Kieda

តើនៅពេលណាអ្នកបានប្រឈមមុខដាក់ស្ថានភាពគួរឲ្យភ័យខ្លាច ហើយមិនហ៊ានចាប់ផ្តើមបោះជំហានទីមួយ? តើព្រះអម្ចាស់បានជួយអ្នកបោះជំហានទៅមុខ ដោយរបៀបណា?

ឱព្រះអម្ចាស់ សូមព្រះអង្គប្រទានទូលបង្គំនូវចិត្តក្លាហាន។ សូមព្រះអង្គជួយទូលបង្គំបោះជំហានចេញទៅក្រៅដោយជំនឿ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | សុភាសិត ១-២ និង១កូរិនថូស ១៦

អស់ទាំងដើមហេតុនៃខ្ញុំនៅក្នុងឯងដែរ (ទំនុកតម្កើង ៨៧:៧)។

ការរួបរួមនៅទីបញ្ចប់

កាលពីឆ្នាំ១៩៦០ លោក អូតូ ប្រេមីងជ័រ (Otto Preminger) បានបណ្តាលឲ្យមានរឿងចំរុងចំរាស ដោយសារខ្សែភាពយន្តដែលគាត់បានផលិតមានចំណងជើងថា ការភៀសខ្លួនរបស់ជាតិសាសន៍មួយ។ ផ្អែកទៅលើរឿងប្រលោមលោក របស់លោក ឡេអ៊ុង អ៊ូរីស (Leon Uris) ខ្សែភាពយន្តនេះបានផ្តល់ឲ្យនូវរឿងប្រឌិតអំពីជនភៀសខ្លួនជាប្រជាជនយូដា ដែលបានធ្វើដំណើរទៅកាន់ទឹកដីប៉ាឡេស្ទីន បន្ទាប់ពីសង្គ្រាមលោកលើកទី២បានបញ្ចប់។ នៅចុងបញ្ចប់នៃខ្សែភាពយន្តនេះ តួអង្គជានារីជាជនជាតិយូដាមកពីទ្វីបអឺរ៉ុប និងតួអង្គជាបុរសជនជាតិអារ៉ាប់ត្រូវគេសម្លាប់ ហើយគេក៏បានបញ្ចុះសពអ្នកទាំងពីរក្នុងផ្នូរតែមួយក្នុងទឹកដីដែលជាប្រទេសអ៊ីស្រាអែលក្នុងពេលបច្ចុប្បន្ន។

ក្នុងរឿងនេះ លោក ប្រេមីងជ័រ បានទុកឲ្យយើងធ្វើការសន្និដ្ឋានដោយខ្លួនឯង។ តើវាជារឿងប្រៀបធៀបអំពីភាពអស់សង្ឃឹម ជាក្តីស្រមៃដែលត្រូវកប់ចោលក្នុងដីជារឿងរហូត ឬវាជានិមិត្តសញ្ញានៃសេចក្តីសង្ឃឹម ខណៈពេលដែលមនុស្សពីរនាក់មកពីជាតិសាសន៍ពីរមានប្រវត្តិស្អប់គ្នា និងជាសត្រូវនឹងគ្នា បានចងស្ពានមេត្រីជាមួយគ្នាក្នុងសេចក្តីស្លាប់ និងក្នុងជីវិតឬ?

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំបទគម្ពីរទំនុកតម្កើងជំពូក៨៧ ជាស្នាដៃនិពន្ធរបស់ពួកកូនប្រុសរបស់លោក កូរេ ដែលបានចែងអំពីសន្តិភាព និងការរួបរួមរវាងជាតិសាសន៍ទាំងឡាយ។ គឺសន្តិភាពដែលយើងកំពុងរង់ចាំ។ ពួកគេបានថ្លែងអំពីទីក្រុងយេរូសាឡិមយ៉ាងដូចនេះថា «ឱទីក្រុងរបស់ព្រះអង្គអើយ គេថ្លែងប្រាប់សេចក្តីឧត្តុង្គឧត្តមពីឯង» (ខ.៣)។ ពួកគេក៏បានបន្លឺសម្លេងច្រៀងថា ថ្ងៃមួយជាតិសាសន៍ដែលធ្លាប់មានប្រវត្តិសាស្ត្រធ្វើសង្គ្រាមនឹងប្រជាជនយូដានឹងរួមគ្នាទទួលស្គាល់ព្រះពិតតែមួយ។ សាសន៍ទាំងនោះ គឺមានដូចជាសាសន៍អ៊ីហាប (ឬអេស៊ីព្ទ) សាសន៍បាប៊ីឡូន សាសន៍ភីលីស្ទីន សាសន៍ទីរុស និងសាសន៍អេធីយ៉ូពីជាដើម (ខ.៤)។ ព្រះអង្គនឹងនាំពួកគេឲ្យងាកទៅរកទីក្រុងយេរូសាឡិម និងងាកទៅរកព្រះអង្គ។

បទគម្ពីរទំនុកតម្កើងនេះក៏បានបញ្ចប់ ដោយការអបអរ។ ប្រជាជននៅទីក្រុងយេរូសាឡិមនឹងច្រៀងសរសើរអំពីប្រភពទឹករបស់ពួកគេរាល់គ្នា (ខ.៧)។ តើពួកគេកំពុងច្រៀងអំពីនរណា? គឺអំពីព្រះមួយអង្គ ដែលជាទឹករស់ជាប្រភពនៃជីវិតទាំងអស់ (យ៉ូហាន ៤:១៤)។ ព្រះយេស៊ូវជាព្រះតែមួយ ដែលអាចនាំមកនូវសន្តិភាព និងការរួបរួមដ៏ស្ថិតស្ថេរ។—Tim Gustafson

តើមានជម្លោះអ្វីក្នុងពិភពលោក និងក្នុងទំនាក់ទំនងផ្ទាល់ខ្លួន ដែលធ្វើឲ្យអ្នកមានចិត្តថប់បារម្ភ? តើអ្នកនឹងទុកចិត្តថា ព្រះអង្គនឹងប្រទានសន្តិភាពរបស់ព្រះអង្គ ដល់យើងដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអធិស្ឋានសូមសន្តិភាព និងការរួបរួមសម្រាប់មនុស្សទាំងអស់ ខណៈពេលដែលព្រះអង្គនាំពួកគេចូលទៅរកព្រះរាជបុត្រាព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | សុភាសិត ៣-៥ និង២កូរិនថូស ១

ខ្ញុំប្រាប់អ្នកថា អ្នកឈ្មោះពេត្រុស ខ្ញុំនឹងតាំងពួកជំនុំខ្ញុំនៅលើថ្មដានេះ (ម៉ាថាយ ១៦:១៨)។

នៅតែជាប់ក្នុងព្រះយេស៊ូវ

មានពេលមួយ អគ្គីភ័យបានបំផ្លិចបំផ្លាញព្រះវិហារបាទីស្ទបាលស៊ូវ៉ាខ្ទេចគ្មានសល់។ ខណៈពេលដែលភ្នាក់ងារពន្លត់អគ្គីភ័យ និងសមាជិកសហគមន៍កំពុងជួបជុំគ្នាបន្ទាប់ពីការឆាប់ឆេះមានការថមថយ ពួកគេមានការភ្ញាក់ផ្អើលពេលដែលបានឃើញឈើឆ្កាងដែលត្រូវភ្លើងឆេះជាមួយអគារព្រះវិហារ នៅតែឈរមាំនៅក្នុងកំសួលផ្សែង និងផេះដែលកំពុងហុយតាមខ្យល់។ អ្នកពន្លត់អគ្គីភ័យម្នាក់បានរៀបរាប់ថា «វាជារឿងចម្លែក ដែលអគ្គីភ័យបានបំផ្លាញសំណង់អគារទាំងស្រុង ប៉ុន្តែមិនបានបំផ្លាញឈើឆ្កាង។ រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំថា អគារព្រះវិហារគ្រាន់តែជាទីកន្លែងជួបជុំបណ្តោះអាសន្ន ប៉ុន្តែពួកជំនុំជាសហគមន៍នៃអ្នកជឿដែលស្ថិតស្ថេរអស់កល្ប។

ពួកជំនុំជាសហគមន៍នៃអ្នកជឿ ដែលរួបរួមគ្នាតែមួយដោយសារឈើឆ្កាងរបស់ព្រះគ្រីស្ទ ដែលបានសុគតសពព្រះអង្គត្រូវគេបញ្ចុះក្នុងផ្នូរ ហើយព្រះអង្គមានព្រះជន្មរស់ឡើងវិញ។ កាលព្រះយេស៊ូវមានព្រះជន្មនៅលើផែនដី ព្រះអង្គបានប្រាប់លោក ពេត្រុសថា ព្រះអង្គនឹងសង់ពួកជំនុំរបស់ព្រះអង្គ ដែលគ្មានអ្វីអាចបំផ្លាញបានឡើយ (ម៉ាថាយ ១៦:១៨)។ ព្រះអង្គនឹងប្រមូលអ្នកជឿទាំងអស់មកពីគ្រប់តំបន់ទាំងអស់ក្នុងពិភពលោក ឲ្យរួមមកជាក្រុមតែមួយ ដែលនឹងស្ថិតស្ថេរនៅអស់កល្ប។ សហគមន៍នេះនឹងប្រឈមមុខដាក់ទុក្ខលំបាកធ្ងន់ធ្ងរ ប៉ុន្តែពួកគេនឹងស៊ូទ្រាំដល់ទីបញ្ចប់។ ព្រះទ្រង់នឹងគង់នៅក្នុងចំណោមពួកគេ ហើយទ្រទ្រង់ពួកគេ (អេភេសូរ ២:២២)។

ពេលណាពួកជំនុំប្រចាំតំបន់មានការអន់ថយ និងទន់ខ្សោយ ឬសំណង់ព្រះវិហារបានទទួលរងការបំផ្លិចបំផ្លាញ ឬនៅពេលដែលយើងគិតអំពីពួកជំនុំ ដែលកំពុងជួបការលំបាកក្នុងផ្នែកផ្សេងទៀតនៃពិភពលោក យើងអាចចាំថា ព្រះយេស៊ូវមានព្រះជន្មគង់នៅ ព្រះអង្គកំពុងចម្រើនកម្លាំងរាស្ត្រព្រះអង្គ ឲ្យអាចស៊ូទ្រាំនឹងទុក្ខលំបាក។ យើងជាផ្នែកមួយនៃពួកជំនុំដែលព្រះអង្គកំពុងសង់ឡើងក្នុងពេលបច្ចុប្បន្ន។ ព្រះអង្គគង់នៅជាមួយយើង និងថែរក្សាការពារយើង។ ការសុគតរបស់ព្រះអង្គនៅលើឈើឆ្កាង នៅតែបន្តឆ្លុះបញ្ចាំងអំពីសេចក្តីស្រឡាញ់ ការប្រោសលោះ ការប្តូរផ្តាច់ព្រះទ័យចំពោះយើងជារៀងរហូត។—Jennifer Benson Schuldt

តើអ្នកអាចជួយទ្រទ្រង់បងប្អូនរួមជំនឿដទៃទៀត ដោយរបៀបណា? តើការចែកចាយអំពីដំណឹងល្អមានការជាប់ទាក់ទងអ្វីខ្លះ ជាមួយផែនការដែលព្រះអង្គមានសម្រាប់ពួកជំនុំ?

ឱព្រះអម្ចាស់ សូមព្រះអង្គចម្រើនកម្លាំងដល់រាស្ត្រព្រះអង្គនៅគ្រប់ទិសទី។ សូមបំពេញពួកគេដោយប្រាជ្ញា និងការពារ ហើយជួយពួកគេឲ្យនៅតែស្មោះត្រង់ចំពោះព្រះអង្គ។

Daily Manna 2026_Content Enhance.indd 258 17/11/25 1:47 in the afternoon

ប៉ុន្តែអស់អ្នកណាដែលទទួលទ្រង់ គឺអស់អ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់បានប្រទានអំណាចឲ្យបានត្រឡប់ជាកូនព្រះ (យ៉ូហាន ១:១២)។

បានចូលក្នុងគ្រួសារក្សត្រខាងវិញ្ញាណ

មានពេលមួយ លោក ចេយ ស្បេត (Jay Speights) ជាអ្នកក្រុងរ៉ក់ វីល រដ្ឋម៉ារីឡែន ទៅធ្វើតេស្តឌីអិនអេ ហើយក៏បានទទួលលទ្ធផលដែលគាត់មិនដែលនឹកស្មានដល់។ គេបានពិនិត្យឌីអិនអេរបស់គាត់រកឃើញថា គាត់ជាបុត្រារបស់ស្តេចរបស់ប្រទេសបេនីននៅភាគខាងលិចនៃទ្វីបអាហ្វ្រិក។ មិនយូរប៉ុន្មាន គាត់ក៏បានឡើងជិះយន្តហោះទៅលេងប្រទេសនោះ។ ពេលគាត់ទៅដល់ រាជវង្សានុវង្សរបស់ស្តេចក៏បានមកទទួលស្វាគមន៍គាត់ដោយធ្វើពិធីជប់លៀងធំមួយ សម្រាប់ការវិលត្រឡប់មកផ្ទះវិញ ដែលមានការរាំច្រៀង ការលើកបាដា និងការដើរដង្ហែក្បួនជាដើម។

ព្រះយេស៊ូវបានយាងចុះមកផែនដី ដើម្បីប្រកាសដំណឹងល្អនៃសេចក្តីសង្គ្រោះ។ ព្រះអង្គបានយាងមករកព្រះរាស្ត្រព្រះអង្គ ជាប្រជាជនអ៊ីស្រាអែល ដើម្បីប្រទានពួកគេនូវដំណឹងល្អ និងបង្ហាញផ្លូវឲ្យពួកគេចេញពីភាពងងឹត។ មនុស្សជាច្រើនមិនបានអើពើចំពោះព្រះរាជសារព្រះអង្គទេ ដោយបានបដិសេធន៍ព្រះអង្គ ដែលជា "ពន្លឺពិតប្រាកដ" (យ៉ូហាន ១:៩) ហើយមិនព្រមទទួលស្គាល់ព្រះអង្គជាព្រះមែស៊ី (ខ.១១)។ ប៉ុន្តែ ការមិនជឿ និងការមិនអើពើ មិនមែនជាការឆ្លើយតប របស់មនុស្សគ្រប់គ្នានៅសម័យនោះទេ។ អ្នកខ្លះក៏បានបន្ទាបខ្លួន ទទួលការអញ្ជើញរបស់ព្រះគ្រីស្ទដោយអំណរ ដោយទទួលយកព្រះអង្គ ជាដង្វាយលោះបាបដែលព្រះទ្រង់បានប្រទាន ហើយក៏បានទទួលជឿព្រះនាមព្រះអង្គ។ អស់អ្នកដែលនៅសល់ពីមនុស្សដែលបដិសេធន៍ព្រះអង្គ គេមានចិត្តភ្ញាក់ផ្អើលពេលដែលបានទទួលដំណឹងថា "ព្រះអង្គប្រទានអំណាចឲ្យពួកគេធ្វើជាកូនព្រះ" (ខ.១២) គឺក្លាយជាកូនរបស់មហាក្សត្រតាមរយៈការកើតជាថ្មីខាងវិញ្ញាណ។

ពេលណាយើងងាកបែរចេញពីបាប និងសេចក្តីងងឹតទទួលជឿព្រះយេស៊ូវជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់យើង យើងនឹងបានដឹងថា យើងជាកូនព្រះ ដែលព្រះអង្គបានទទួលជាកូនចិញ្ចឹមក្នុងមហាគ្រួសារនៃក្សត្រនៅស្ថានដ៏ខ្ពស់បំផុត។ ចូរយើងអរសប្បាយនឹងព្រះពរ ខណៈពេលដែលយើងរស់នៅ ដោយការទទួលខុសត្រូវជាកូនរបស់ស្តេចលើអស់ទាំងស្តេច។—Marvin Williams

តើការរស់នៅជាកូនព្រះ នាំមកនូវការផ្លាស់ប្តូរយ៉ាងណាសម្រាប់អ្នក? តើអ្នកអាចរស់នៅឲ្យសមហានៈនិងការទទួលខុសត្រូវជាកូនព្រះអង្គ ដូចម្តេចខ្លះក្នុងសប្តាហ៍នេះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានអញ្ជើញទូលបង្គំចូលក្នុងមហាគ្រួសារនៃក្សត្រខាងវិញ្ញាណ តាមរយៈការសុគតរបស់ព្រះយេស៊ូវនៅលើឈើឆ្កាង។

អញនឹងនឹកចាំពីសេចក្ដីសញ្ញា ដែលអញបានតាំងនឹងឯងរាល់គ្នា ហើយនឹងអស់ទាំងសត្វគ្រប់ពូជដែរ (លោកុប្បត្តិ ៩:១៥)។

ពណ៌ដែលជាតំណាងឲ្យក្តីសង្ឃឹម

កាលពីថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២៣ នៅពេលដែលគេកំពុងប្រារព្ធខួបទី២២ឆ្នាំ នៃការវាយប្រហារមកលើសហរដ្ឋអាមេរិក ដោយអំពើភេរវកម្ម មានឥន្ធនូពីរជាន់បានលេចឡើង បង្កើតបានផ្ទាំងទស្សនីភាពដែលគួរឲ្យភ្ញាក់ផ្អើល នៅលើមេឃនៅទីក្រុងញូយ៉ក។ ទីក្រុងនេះជាទីតាំងរបស់អតីតអគារភ្លោះដែលបានដួលរលំ ហើយបានទទួលរងការខូចខាតធ្ងន់ធ្ងរជាងគេក្នុងការវាយប្រហារដោយភេរវកម្មនៅកន្លែងផ្សេងគ្នាក្នុងសហរដ្ឋអាមេរិក នៅថ្ងៃនោះ។ ជាង២ទសវត្សរ៍ក្រោយមក មនុស្សជាច្រើនដែលបានឃើញឥន្ធនូពីរជាន់លេចឡើងនៅថ្ងៃនោះបាននឹកគិតអំពីសេចក្ដីសង្ឃឹម និងការប្រោសឲ្យជា។ រីឯអ្នកដែលគេចតបានទិដ្ឋភាពនៅពេលនោះបានធ្វើឲ្យគេមានអារម្មណ៍ថា ឥន្ធនូនោះហាក់ដូចជាលេចចេញពីទីតាំងរបស់អតីតមជ្ឈមណ្ឌលសេដ្ឋកិច្ចពិភពលោក។

ឥន្ធនូនៅលើមេឃបានរំឭកយើង អំពីការធានាអំពីសេចក្ដីស្មោះត្រង់របស់ព្រះតាំងពីសម័យលោក ណូអេមក។ នៅក្រោយពេលដែលព្រះអម្ចាស់បានកាត់ទោសមកលើបាប ដែលបណ្តាលឲ្យមានសេចក្ដីហិនវិនាសហួសក្តីស្រមៃ ព្រះអង្គក៏បានដាក់ឥន្ធនូនៅលើមេឃ ឲ្យគេអាចមើលឃើញ ជាការក្រើនរំឭកអំពីសេចក្ដីសញ្ញាដ៏អស់កល្ប រវាងព្រះអង្គ និងជីវិតទាំងអស់នៅលើផែនដី (លោកុប្បត្តិ ៩:១៦)។ បន្ទាប់ពីភ្លៀងបានធ្លាក់៤០ថ្ងៃដែលបណ្តាលឲ្យមានទឹកជន់លិចផែនដីអស់ជាច្រើនឆ្នាំ (៧:១៧-២៤) គេគ្រាន់តែអាចស្រមៃថា ឥន្ធនូដែលជាដំណាងឲ្យការតាំងសញ្ញានោះ បាននាំមកនូវការស្វាគមន៍ដែលមានអត្ថន័យជ្រាលជ្រៅប៉ុណ្ណាចំពោះលោកណូអេ និងក្រុមគ្រួសារគាត់ (៩:១២-១៣)។ វាជាការរំឭកអំពីសេចក្ដីស្មោះត្រង់របស់ព្រះ ដែលបានសន្យាថាព្រះអង្គនឹងមិនបំផ្លាញភពផែនដីទាំងមូល ដោយទឹកជំនន់ទៀតទេ (ខ.១១)។

ពេលណាយើងប្រឈមមុខដាក់ពេលដ៏ងងឹត និងការបាត់បង់ដ៏សោកសៅ ទោះដោយសារគ្រោះធម្មជាតិ ការឈឺចាប់ផ្លូវកាយ ឬផ្លូវអារម្មណ៍ក្តី ឬក៏ដោយសារជំងឺប្រចាំកាយ ចូរយើងមើលទៅព្រះ ដើម្បីទទួលសេចក្ដីសង្ឃឹមក្នុងពេលដ៏ពិបាកនោះ។ ទោះយើងមិនអាចមើលឃើញឥន្ធនូនៅលើមេឃក្នុងពេលនោះក៏ដោយ ក៏យើងនៅតែអាចមានការធានា អំពីសេចក្ដីស្មោះត្រង់នៃព្រះបន្ទូលសន្យារបស់ព្រះអង្គ។

—Kirsten Holmberg

តើព្រះអម្ចាស់បានបើកបង្ហាញព្រះវត្តមានព្រះអង្គដល់អ្នក ក្នុងរដូវកាលដ៏ពិបាកនៃជីវិតអ្នកដូចម្តេចខ្លះ? តើមាននរណាខ្លះ ត្រូវការស្តាប់ទីបន្ទាល់របស់អ្នកនៅថ្ងៃនេះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យមើលឃើញព្រះអង្គ នៅក្នុងពេលដែលទូលបង្គំកំពុងជួបការលំបាក នៅថ្ងៃនេះ។

Daily Manna 2026_Content Enhance.indd 260 17/11/25 1:47 in the afternoon

ចូរឲ្យនឹកចាំពីថ្ងៃឈប់សំរាក ដើម្បីញែកថ្ងៃនោះចេញជាបរិសុទ្ធ (និក្ខមនំ ២០:៨)។

ជំនួយដល់ការចងចាំ

តើអ្នកធ្លាប់ចែកចាយរឿងមួយឲ្យគេស្តាប់ ហើយក៏បានជាប់គាំងពាក់កណ្តាលទី ដោយសារអ្នកមិនអាចចាំឈ្មោះមនុស្ស ឬកាលបរិច្ឆេទណាមួយ ក្នុងសាច់រឿងទេ។ ជាញឹកញាប់ យើងច្រើនតែគិតថា ការចងចាំរបស់យើងមានការចុះខ្សោយពេលដែលយើងមានវ័យកាន់តែចាស់។ ប៉ុន្តែ ការសិក្សារបស់អ្នកវិទ្យាសាស្ត្រកាលពីពេលថ្មីៗនេះមិនបានគាំទ្រទស្សនៈមួយនេះទៀតទេ។ តាមពិត ពួកគេបានលើកឡើងថា ការចងចាំរបស់យើងមិនបានបាត់ទៅណាទេ តែយើងគ្រាន់តែមានការអន់ថយនៅក្នុងសមត្ថភាពនៃការទាញយកការចងចាំទាំងនោះមកប្រើឡើងវិញ។ បើសិនជាគ្មានការរំឭកតាមបែបណាមួយជាទៀងទាត់ទេ នោះយើងកាន់តែពិបាកទាញយកការចងចាំរបស់យើងមកប្រើឡើងវិញ។

វិធីមួយក្នុងចំណោមវិធីដែលអាចជួយឲ្យយើងទាញយកការចងចាំ គឺត្រូវរៀបកាលវិភាគធ្វើសកម្មភាពជាទៀងទាត់ ឬធ្វើការរំឭកឡើងវិញនូវការរឿងមួយចំនួន។ ព្រះអាទិការនៃយើងបានជ្រាប់អំពីរឿងនេះ ហេតុនេះហើយបានជាព្រះអង្គបានបង្គាប់កូនចៅអ៊ីស្រាអែលឲ្យញែកពេលមួយថ្ងៃក្នុងមួយសប្តាហ៍ ដើម្បីថ្វាយបង្គំ និងសម្រាក។ ក្រៅពីការសម្រាកខាងរូបកាយក្នុងពេលដ៏ខ្លីនោះ យើងក៏មានឱកាសហ្វឹកហាត់ខាងផ្លូវចិត្តផងដែរ ដោយនឹកចាំថា «ដ្បិតក្នុង៦ថ្ងៃព្រះយេហូវ៉ាទ្រង់បានធ្វើផ្ទៃមេឃ ផែនដី ហើយនឹងសមុទ្រ ព្រមទាំងរបស់សព្វសារពើនៅស្ថានទាំងនោះដែរ រួចដល់ថ្ងៃទី៧ ទ្រង់ឈប់សំរាក» (និក្ខមនំ ២០:១១)។ ការអនុវត្តន៍ដូចនេះជួយយើងឲ្យនឹកចាំថាមានព្រះមួយអង្គដែលយកព្រះទ័យទុកដាក់ចំពោះយើង។

ក្នុងជីវិតដែលមានពេញដោយការប្រញាប់ប្រញាល់ និងការជាប់រវល់ ជួនកាលយើងភ្លេចការអ្វីដែលព្រះអង្គបានធ្វើសម្រាប់យើង និងអ្នកដទៃ។ យើងភ្លេចព្រះដែលបានថែរក្សាជីវិតយើងយ៉ាងផ្ទិតផ្ទង់ ហើយបានសន្យាថា នឹងគង់នៅជាមួយយើងជានិច្ចបានជាយើងមិនចាំបាច់ត្រូវមានអារម្មណ៍ថា ជីវិតមានការពិបាកពេក ឬមានអារម្មណ៍ឯកោនោះឡើយ។ ការឈប់សម្រាកពីភាពមមាញឹករបស់យើងបានផ្តល់ឱកាសឲ្យយើងធ្វើការហ្វឹកហាក់ «ការទាញយកការចងចាំ» គឺការសម្រេចចិត្តឈប់បង្អង់ ហើយនឹកចាំព្រះរបស់យើង ហើយ «មិនភ្លេចបណ្តាព្រះគុណណាមួយរបស់ព្រះអង្គឡើយ» (ទំនុកតម្កើង ១០៣:២)។—John Blasé

តើមានការអ្វីល្បួងអ្នកមិនឲ្យចំណាយពេលឈប់សម្រាក? តើការចំណាយពេលឈប់សម្រាកបានជួយអ្នកឲ្យចូលទៅជិតព្រះអម្ចាស់ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គនឹកចាំទូលបង្គំ ហើយប្រទានទូលបង្គំនូវប្រាជ្ញា ដើម្បីឲ្យឈប់បង្អង់ ហើយនឹកចាំព្រះអង្គផងដែរ។

Daily Manna 2026_Content Enhance.indd 261 17/11/25 1:47 in the afternoon

សូមឲ្យព្រះហឫទ័យទ្រង់បានសំរេចនៅផែនដី ដូចនៅស្ថានសួគ៌ដែរ (ម៉ាថាយ ៦:១០)។

កន្លែងធ្វើការយកព្រះគ្រីស្ទជាធំ

នៅចក្រ ក្នុងប្រទេសអង់គ្លេស នៅសម័យក្សត្រីវិចតូរីយ៉ា គឺជាទីកន្លែងងងឹត។ អត្រានៃការស្លាប់របស់កម្មករមានកម្រិតខ្ពស់ ហើយពួកគេច្រើនតែរស់នៅក្នុងភាពក្រីក្រ។ លោក ចច ខាដប៊ឺរី (George Cadbury) ក៏បានចោទជាសំណួរថា «តើធ្វើដូចម្តេចឲ្យកម្មករទាំងឡាយមានចិត្តចង់ធ្វើការងារ នៅពេលដែលផ្ទះរបស់ពួកគេស្ថិតនៅក្នុងតំបន់អនាធិបតេយ្យដូចនេះ?» ហេតុនេះហើយគាត់ក៏បានសង់រោងចក្រប្រភេទថ្មីមួយសម្រាប់ក្រុមហ៊ុនស្ករសូកូឡារបស់គាត់ ដែលកំពុងមានការរីកដុះដាល គឺរោងចក្រដែលផ្តល់អត្ថប្រយោជន៍ដល់កម្មកររបស់គាត់។

ជាលទ្ធផល ប៊ុរីបូនវីលក៏បានចាប់កំណើតឡើង ជាភូមិមួយដែលមានផ្ទះជាង៣០ខ្នងមានកន្លែងលេងកីឡា សួនកុមារ សាលារៀន និងព្រះវិហារ សម្រាប់កម្មកររបស់លោក ខាដប៊ឺរី និងក្រុមគ្រួសាររបស់ពួកគេ។ ពួកគេទទួលបានប្រាក់ខែសមរម្យ ហើយទទួលបានការថែទាំសុខភាព ដែលទាំងអស់នេះបានកើតឡើង ដោយសារលោក ខាដប៊ឺរី មានជំនឿលើព្រះគ្រីស្ទ។

ព្រះយេស៊ូវបានបង្រៀនយើងឲ្យអធិស្ឋាន សូមឲ្យព្រះហឫទ័យព្រះបានសម្រេច «នៅផែនដី ដូចនៅស្ថានសួគ៌ដែរ» (ម៉ាថាយ ៦:១០)។ ការអធិស្ឋាននេះអាចជួយយើង ឲ្យនឹកស្រមៃចង់បានកន្លែងធ្វើការ ដែលមានលក្ខណៈយ៉ាងណាមួយនៅក្រោមការគ្រប់គ្រងរបស់ព្រះ ដែលនៅកន្លែងនោះ យើងនឹងទទួលបាន «អាហារប្រចាំថ្ងៃ» ជាកម្រៃ ហើយ ព្រះអង្គអត់ទោសឲ្យយើង (ខ.១១-១២)។ បើសិនយើងជាចៅហ្វាយនាយ នោះគឺមានន័យថា យើងត្រូវផ្តល់ឲ្យបុគ្គលិកយើងនូវប្រាក់កំរៃដែលសមរម្យ (៤:១)។ ប៉ុន្តែ ទោះយើងមានតួនាទីអ្វីក៏ដោយ ទោះយើងមានប្រាក់ខែ ឬធ្វើការស្ម័គ្រចិត្តក្តី យើងរាល់គ្នាសុទ្ធតែត្រូវយកចិត្តទុកដាក់ ចំពោះសុខុមាលភាពរបស់មនុស្ស ដែលយើងកំពុងធ្វើការជាមួយក្នុងការងារបម្រើព្រះ។

ចូរយើងនឹកស្រមៃចង់បានផ្លាស់ប្តូរ ដូចលោក ចច ខាដប៊ឺរីផងដែរ បើសិនជាយើងថ្វាយតំបន់ដែលយើងរស់នៅ និងកន្លែងធ្វើការឲ្យព្រះអង្គគ្រប់គ្រង។ ព្រោះពេលណាគេអនុញ្ញាតឲ្យព្រះអង្គគ្រប់គ្រងមនុស្សទាំងឡាយ នឹងមានការចម្រើនឡើងមិនខាន។—Sheridan Voysey

តើកន្លែងធ្វើការរបស់អ្នក ឬតំបន់ដែលអ្នករស់នៅនឹងមានលក្ខណៈដូចម្តេចនៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ? តើអ្នកអធិស្ឋានទូលដូចម្តេចខ្លះ ដើម្បីឲ្យចក្ខុវិស័យនេះក្លាយជាការពិត?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គជួយទូលបង្គំឲ្យមានចក្ខុវិស័យចង់មើលឃើញការផ្លាស់ប្តូរ ដែលកន្លែងធ្វើការ និងតំបន់ដែលទូលបង្គំរស់នៅមានលក្ខណៈដូចម្តេចខ្លះ នៅក្រោមការគ្រប់គ្រងរបស់ព្រះអង្គ ហើយសូមប្រទានកម្ងាន់ទូលបង្គំ ដើម្បីនាំមកនូវការផ្លាស់ប្តូរនោះ។

Daily Manna 2026_Content Enhance.indd 262 17/11/25 1:47 in the afternoon

ដូច្នេះ លោកក៏ចុះទៅមុជទឹកក្នុងទន្លេយ័រដាន់អស់៧ដង តាមពាក្យនៃអ្នកសំណប់របស់ព្រះ។ (*២ពង្សាវតារក្សត្រ ៥:១៤*)

ធ្វើតាមបង្គាប់របស់ព្រះអង្គ

នៅក្នុងតូបលក់អាហាររបស់អ្នកស្រី ចូសេលីន (Jocelyn) បបរសរគឺជាអាហារដែលលក់ដាច់ជាងគេ។ គាត់បានកូរបបរសយ៉ាងប្រុងប្រយ័ត្នទាល់តែបបររីកបានល្អ។ ហេតុនេះហើយ គាត់មានការភ្ញាក់ផ្អើលណាស់ ពេលដែលភ្ញៀវមកញ៉ាំបបរជាប្រចាំបានប្រាប់គាត់ថា បបររបស់គាត់មានរសជាតិមិនឆ្ងាញ់ដូចមុនសោះ ហើយបបរក៏មិនរីកបានល្អដែរ។

នៅថ្ងៃនោះ ជំនួយការថ្មីរបស់អ្នកស្រី ចូស៊ីលីន ជាអ្នកដាំបបរ ហើយក៏បានពន្យល់ អំពីមូលហេតុដែលវាមានរស់ជាតិខុសពីមុន។ គាត់ប្រាប់អ្នកស្រី ចូស៊ីលីន ថា គាត់មិនបានកូរបបរឲ្យសព្វទេ ព្រោះគាត់ធ្លាប់តែធ្វើដូចនេះនៅផ្ទះ។ គាត់ក៏បានបន្ថែមប្រេងល្ងក្នុងឆ្នាំងបបរដោយយល់ឃើញថា វាជួយឲ្យបបរមានរសជាតិឆ្ងាញ់ជាងមុន។ ដូចនេះ ជំនួយការថ្មីរូបនោះបានសម្រេចចិត្តមិនធ្វើតាមក្បួនដាំបបររបស់ហាង ហើយក៏បានអនុវត្តតាមរបៀបរបស់គាត់ទៅវិញ។

នៅពេលខ្លះ ខ្ញុំក៏បានឆ្លើយតបចំពោះការបង្គាប់របស់ព្រះអម្ចាស់តាមរបៀបនេះផងដែរ។ ខ្ញុំមិនបានស្តាប់បង្គាប់តាមព្រះរាជបញ្ជាក្នុងព្រះគម្ពីរទាំងស្រុងទេ ផ្ទុយទៅវិញខ្ញុំអនុវត្តតាមគំនិត និងរបៀបរបស់ខ្ញុំ។

លោក ណាម៉ាន ជាមេទ័ពរបស់សាសន៍ស៊ីរី ក៏ហៀបនឹងប្រព្រឹត្តនូវកំហុសស្រដៀងនេះផងដែរ។ កាលព្រះអម្ចាស់បង្គាប់តាមរយៈហោរាអេលីសេ ឲ្យគាត់ទៅលាងសម្អាតខ្លួននៅក្នុងទន្លេយ័រដាន់ ដើម្បីឲ្យគាត់បានជាពីជំងឺឃ្លង់ មេទ័ពដែលមានអំនួតរូបនេះ ក៏បានខឹងនឹងលោក អេលីសេ។ គាត់បានរំពឹងថា គាត់នឹងទទួលការប្រោសឲ្យជា តែមិនមែនតាមរបៀបនេះទេដោយគាត់ជឿថា ការយល់ឃើញរបស់គាត់ មានភាពខ្ពង់ខ្ពស់ជាងបង្គាប់របស់ព្រះ (២ពង្សាវតារក្សត្រ ៥:១១-១២)។ ទោះជាយ៉ាងណាក៏ដោយ អ្នកបម្រើរបស់គាត់ក៏បានលើកទឹកចិត្តគាត់ឲ្យស្តាប់តាមពាក្យដែលហោរាអេលីសេបានប្រាប់ (ខ.១៣)។ ជាលទ្ធផល លោក ណាម៉ាន ក៏បានជាពីជំងឺឃ្លង់។

ពេលណាយើងធ្វើអ្វីៗតាមផ្លូវរបស់ព្រះ យើងនឹងទទួលបានសន្តិភាពក្នុងចិត្តលើសពីពាក្យពណ៌នា។ ចូរយើងចុះចូលនឹងបំណងព្រះទ័យព្រះអង្គនៅក្នុងការសម្រេចគោលបំណងរបស់ព្រះអង្គ។—Karen Huang

តើអ្នកបានបណ្តោយឲ្យទស្សនៈរបស់អ្នក រារាំងមិនឲ្យអ្នកស្តាប់បង្គាប់ព្រះដូចម្តេចខ្លះ? តើបញ្ហានេះបានរារាំងព្រះអង្គមិនឲ្យធ្វើការក្នុងជីវិតអ្នកដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យស្តាប់បង្គាប់តាមព្រះអង្គទាំងស្រុង ដ្បិតព្រះរាជបញ្ជារបស់ព្រះអង្គជំជាងគំនិតរបស់ទូលបង្គំ។

Daily Manna 2026_Content Enhance.indd 263 17/11/25 1:47 in the afternoon

បើព្រះគ្រីស្ទមិនបានរស់ឡើងវិញ នោះដំណឹងដែលយើងខ្ញុំផ្សាយនេះ ជាការឥតប្រយោជន៍ទទេ ហើយសេចក្តីជំនឿរបស់អ្នករាល់គ្នា ក៏ឥតអំពើដែរ (១កូរិនថូស ១៥:១៤)។

មិននៅក្នុងផ្នូរជារហូតទេ

កាលលោក ចននី ខាស (Johnny Cash) ជាអ្នកចម្រៀងជនបទដ៏ល្បីល្បាញដឹងខ្លួនថា គាត់ជិតដល់ពេលលាចាកលោក គាត់បានប្តេជ្ញាចិត្តថា នឹងបន្តផលិតបទចម្រៀងថ្មីៗថែមទៀត។ អាល់ប៊ុមចម្រៀងចុងក្រោយរបស់គាត់មានចំណងជើងថា ខ្ញុំមិននៅក្នុងផ្នូរជារៀងរហូតទេ។ គាត់បានថតបទចម្រៀងមួយអាល់ប៊ុមនេះក្នុងខែចុងក្រោយនៃជីវិតគាត់។ គាត់បានជ្រើសរើសបទចម្រៀងនេះដូចនេះផ្អែកទៅលើបទចម្រៀងទំនុកសកលនិពន្ធដោយលោក ក្លូត អេលី (Claude Ely) ដោយបានឆ្លុះបញ្ចាំងអំពីការយល់ឃើញចុងក្រោយរបស់គាត់ដោយគាត់បានច្រៀងថា គាត់សង្ឃឹមថា នឹងបានរស់ឡើងវិញនៅគ្រាចុងក្រោយ។ សម្លេងដ៏ធ្ងន់របស់គាត់ ទោះមានភាពចុះខ្សោយដោយសារបញ្ហាសុខភាពបានប្រកាសទីបន្ទាល់ដ៏មានអំណាចនៃសេចក្តីជំនឿរបស់គាត់។

ក្តីសង្ឃឹមរបស់លោក ចននី មិនគ្រាន់តែផ្អែកទៅលើការពិតដែលថា ព្រះយេស៊ូវបានមានព្រះជន្មរស់ឡើងវិញនៅព្រឹកថ្ងៃអាទិត្យប៉ុណ្ណោះទេ តែគាត់ក៏បានជឿផងដែរថា ព្រះអង្គនឹងប្រោសរូបកាយរបស់គាត់ឲ្យរស់ឡើងវិញ ដូចដែលព្រះគម្ពីរបានចែង។

នេះជាសេចក្តីពិតដ៏សំខាន់ ដែលយើងត្រូវធ្វើការបញ្ជាក់ឲ្យច្បាស់ ព្រោះសូម្បីតែនៅក្នុងសម័យសាវ័ក ប៉ុលមានមនុស្ស បដិសេធន៍ការរស់ឡើងវិញខាងសាច់ឈាមផងដែរ។ សាវ័ក ប៉ុល ក៏បានឆ្លើយតបដោយលើកហេតុផលថា “បើសិនជាពួកស្លាប់មិនរស់ឡើងវិញមែន នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងវិញដែរ ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញ នោះដំណឹងដែលយើងខ្ញុំផ្សាយនេះ ជាការឥតប្រយោជន៍ទទេ ហើយសេចក្តីជំនឿរបស់អ្នករាល់គ្នា ក៏ឥតអំពើដែរ” (១កូរិនថូស ១៥:១៣-១៤)។

ដូចនេះ ដែលផ្នូរមិនអាចឃុំឃាំងព្រះកាយរបស់ព្រះយេស៊ូវជាយ៉ាងណា ថ្ងៃមួយអស់អ្នកដែលជឿថាព្រះអង្គបានមានព្រះជន្មរស់ឡើងវិញ នឹងត្រូវព្រះអង្គប្រោសឲ្យរស់ឡើងវិញមិនខាន (ខ.២២)។ ហើយយើងនឹងបានអរសប្បាយអស់កល្បជានិច្ចក្នុងការរស់នៅជាមួយព្រះអង្គ ក្នុងរូបកាយដែលរស់ឡើងវិញនៅលើផែនដីថ្មី។ នេះជាមូលហេតុដែលយើងត្រូវច្រៀងសរសើរព្រះអង្គ!—Lisa M. Samra

តើការដឹងថា អ្នកនឹងបានរស់ឡើងវិញខាងរូបកាយបាននាំឲ្យអ្នកមានការកម្សាន្តចិត្តយ៉ាងណាខ្លះ? តើការនេះបានបង្ហាញចេញនូវសេចក្តីជំនឿដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានទូលបង្គំនូវក្តីសង្ឃឹមថា ទូលបង្គំនឹងបានរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច។

Daily Manna 2026_Content Enhance.indd 264 17/11/25 1:47 in the afternoon

នោះអ្នកពាល់គ្នាក៏បានស្អាងឡើង ដូចជាថ្មរស់ដែរ ឲ្យបានធ្វើជាផ្ទះខាងឯវិញ្ញាណ (១ពេត្រុស ២:៥)។

បានសង់ឡើងនៅលើគ្រឹះរបស់ព្រះគ្រីស្ទ

អគារមានតួនាទីដ៏សំខាន់សម្រាប់ការរស់នៅ និងការធ្វើការងារ និងសម្រាប់គោលបំណងដ៏ចាំបាច់ជាច្រើនទៀត ទោះនៅក្នុងសង្គម និងក្នុងសម័យកាលមួយណាក៏ដោយ។ ប៉ុន្តែ ទោះអគារមានទំហំតូចឬធំយ៉ាងណាក៏ដោយ ក៏គ្រឹះរបស់ពួកវានៅតែមានភាពចាំបាច់ ហើយគេក៏ចង់បានជាងសំណង់ល្អៗសម្រាប់ការសាងសង់ផងដែរ ដើម្បីឲ្យគេអាចប្រើប្រាស់ពួកវាបានយូរអង្វែង។

ព្រះគម្ពីរបានពិពណ៌នា អំពីអ្នកជឿព្រះយេស៊ូវ ដោយប្រើពាក្យប្រៀបប្រដូចជាច្រើន ដែលពាក្យប្រៀបប្រដូចនីមួយៗសុទ្ធតែបានឆ្លុះបញ្ចាំងអំពីអត្ថសញ្ញាណ និងតួនាទីជាប្រយោជន៍រួម។ ជាក់ស្តែងសាវ័ក ប៉ុល បានហៅពួកគេថា ផ្ទះ ដែលព្រះអង្គបានសង់ (១កូរិនថូស ៣:៩)។ ពាក្យប្រៀបប្រដូចទៅនឹងសំណង់យ៉ាងដូចនេះ គឺបានឆ្លុះបញ្ចាំងអំពីការរួបរួមជាកម្លាំងខាងវិញ្ញាណរបស់ពួកស្មោះត្រង់។

ដោយឡែក ការប្រៀបប្រដូចពួកជំនុំទៅនឹងអគារ ក៏មានចែងក្នុងបទគម្ពីរ ១ពេត្រុសស ២:៥ ផងដែរ ដែលក្នុងនោះសាវ័ក ពេត្រុស បានមានប្រសាសន៍ទៅកាន់ពួកជំនុំថា «អ្នករាល់គ្នាក៏បានស្អាងឡើងដូចជាថ្មរស់ដែរ ឲ្យបានធ្វើជាផ្ទះខាងឯវិញ្ញាណ»។ បន្ទាប់មក ក្នុងខ.៦ សាវ័ក ពេត្រុស ក៏បានដកស្រង់បទគម្ពីរ អេសាយ ២៨:១៦ ដែលបានចែងថា «ព្រះអម្ចាស់យេហូវ៉ាទ្រង់មានព្រះបន្ទូលថា មើល អញដាក់ថ្ម១នៅក្រុងស៊ីយ៉ូនទុកជាជើងជញ្ជាំង ជាថ្មដែលបានល្បងហើយ ជាថ្មជ្រុងដ៏មានដំឡៃ»។ ព្រះយេស៊ូវជាគ្រឹះនៃផ្ទះខាងវិញ្ញាណនោះឯង។

យើងប្រហែលជាយល់ឃើញថា ការងាររបស់យើង គឺត្រូវសង់ពួកជំនុំឡើង ប៉ុន្តែព្រះយេស៊ូវមានបន្ទូលថា ព្រះអង្គនឹងសង់ពួកជំនុំរបស់ព្រះអង្គ (ម៉ាថាយ ១៦:១៨)។ ព្រះអម្ចាស់បានជ្រើសរើសយើង ដើម្បីឲ្យយើងបានសរសើរតម្កើងព្រះអង្គ ដែលបានហៅយើងចេញពីភាពងងឹតចូលទៅក្នុងពន្លឺដ៏អស្ចារ្យរបស់ព្រះអង្គ (១ពេត្រុស ២:៩)។ ខណៈពេលដែលយើងបន្លឺសម្លេងសរសើរតម្កើងព្រះអង្គយ៉ាងដូចនេះ យើងក៏បានក្លាយជាឧបករណ៍សម្រាប់ឲ្យព្រះហស្តព្រះអង្គប្រើ ដើម្បីធ្វើការល្អ។—Bill Crowder

តើការដែលព្រះយេស៊ូវសង់ពួកជំនុំរបស់ព្រះអង្គ មានអត្ថន័យដូចម្តេចខ្លះចំពោះអ្នក? តើអ្នកអាចចូលរួមជាមួយព្រះអង្គ ក្នុងកិច្ចការនេះដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ដែលមិនបានពឹងផ្អែកព្រះអង្គក្នុងការរស់នៅ។ សូមព្រះអង្គប្រើទូលបង្គំឲ្យបម្រើព្រះអង្គ និងស្រឡាញ់អ្នកដទៃ ខណៈពេលដែលព្រះអង្គកំពុងសង់ពួកជំនុំព្រះអង្គឡើង។

Daily Manna 2026_Content Enhance.indd 265 17/11/25 1:47 in the afternoon

ប៉ុន្តែ បើមែកខ្លះត្រូវកាច់ចេញ ហើយអ្នកឯងដែលជាដើមអូលីវព្រៃ បានត្រូវបំបៅកណ្តាលមែកទាំងនោះ ទាំងត្រឡប់ទៅជាស្រូបជាតិឫសនៃដើមអូលីវស្រុក ជាមួយនឹងមែកឯទៀត (រ៉ូម ១១:១៧)។

បានទទួលចិញ្ចឹមក្នុងគ្រួសារព្រះ

ក្មេងអំឡុងពេលដែលខ្ញុំធ្វើដំណើរជាមួយប៉ារបស់ខ្ញុំទៅកាន់ប្រទេសអេក្វាឌ័រ ជាទឹកដីជាទីស្រឡាញ់របស់គាត់ កាលពីរបីឆ្នាំមុន យើងក៏បានទៅលេងកសិដ្ឋានគ្រួសារមួយ ជាកន្លែងដែលគាត់ធ្លាប់ចម្រើនវ័យធំឡើង។ ខ្ញុំក៏បានកត់សម្គាល់ឃើញដើមឈើចម្លែកមួយក្រុម។ ប៉ារបស់ខ្ញុំក៏បានពន្យល់ថា កាលគាត់នៅក្មេង គាត់បានឃើញមនុស្សធំផ្សាំមែកឈើ នៅលើដើមឈើហូបផ្លែ ដែលមានពូជដូចគ្នា តែគាត់ចូលចិត្តធ្វើរឿងប្លែកៗ ដោយគាត់កាត់មែកឈើចេញពីដើមឈើហូបផ្លែមួយយកទៅផ្សាំនៅលើដើមឈើហូបផ្លែប្រភេទផ្សេងទៀត។ ការលេងសើចរបស់គាត់បានបន្តកើតមាន ដោយគ្មាននរណាម្នាក់ចាប់អារម្មណ៍ រហូតដល់ពេលដែលដើមឈើទាំងនោះចាប់ផ្តើមចេញផ្លែនៅតាមមែកឈើទាំងនោះ ខុសពីការរំពឹងគិតរបស់អ្នកដទៃ។

នៅពេលដែលប៉ារបស់ខ្ញុំបកស្រាយ អំពីដំណើរការនៃការផ្សាំមែកឈើ ខ្ញុំក៏បាននឹកចាំ អំពីអត្ថន័យនៃការដែលព្រះអម្ចាស់ទទួលចិញ្ចឹមយើងក្នុងគ្រួសារព្រះអង្គ។ សព្វថ្ងៃនេះ ខ្ញុំដឹងថា ប៉ារបស់ខ្ញុំបានទៅរស់នៅក្នុងនគរស្ថានសួគ៌ហើយ ព្រោះព្រះអង្គបានទទួលចិញ្ចឹមគាត់ក្នុងគ្រួសាររបស់ព្រះអង្គ ដោយសារជំនឿដែលគាត់មានចំពោះព្រះយេស៊ូវ។

យើងក៏អាចមានការធានាថា យើងនឹងបានទៅនៅនគរស្ថានសួគ៌ផងដែរ។ សាវ័ក ប៉ុល បានពន្យល់អ្នកជឿនៅទីក្រុងរ៉ូមថា ព្រះអម្ចាស់បានបើកផ្លូវសម្រាប់សាសន៍ដទៃ ដែលមិនមែនជាសាសន៍យូដា ឲ្យមានការផ្សះផ្សាឲ្យពួកគេជានឹងព្រះអង្គ។ គឺដូចដែលគាត់មានប្រសាសន៍ថា «បើមែកខ្លះត្រូវកាច់ចេញ ហើយអ្នកឯងដែលជាដើមអូលីវព្រៃ បានត្រូវបំបៅកណ្តាលមែកទាំងនោះ ទាំងត្រឡប់ទៅជាស្រូបជាតិឫសនៃដើមអូលីវស្រុក ជាមួយនឹងមែកឯទៀត» (រ៉ូម ១១:១៧)។ ពេលណាយើងទទួលជឿព្រះគ្រីស្ទ យើងនឹងទទួលបានឯកសិទ្ធិធ្វើជាកូនព្រះអង្គ និងក្លាយជាផ្នែកមួយនៃគ្រួសាររបស់ព្រះអង្គ។ ព្រះយេស៊ូវក៏បានមានបន្ទូលផងដែរថា «ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន» (យ៉ូហាន ១៥:៥)។

ពេលណាយើងទទួលជឿព្រះគ្រីស្ទ យើងនឹងបានកើតជាថ្មី ហើយអាចបង្កើតផលផ្លែជាច្រើន គឺមិនខុសពីខ្នែង ដែលនៅជាប់នឹងដើមទំពាំងបាយជូរនោះឡើយ។—Nancy Gavilanes

តើអ្នកមានអារម្មណ៍យ៉ាងណា ពេលដែលបានដឹងថា ព្រះអង្គបានទទួលចិញ្ចឹមអ្នកក្នុងគ្រួសារព្រះអង្គ? តើអ្នកអាចបង្កើតផលផ្លែថ្វាយព្រះគ្រីស្ទដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានស្រឡាញ់ទូលបង្គំ និងទទួលទូលបង្គំចូលក្នុងគ្រួសារព្រះអង្គ។

Daily Manna 2026_Content Enhance.indd 266 17/11/25 1:47 in the afternoon

ទ្រង់នឹងមិនផ្តាច់ដើមត្រែងដែលបាក់ទេ ក៏មិនលត់ប្រឆេះដែលនៅហុយដែរ។ (*អេសាយ ៤២:៣*)

សេចក្តីស្រឡាញ់របស់ព្រះ មានភាពអត់ធ្មត់

គ្រែ សារខ្ញុំចិញ្ចឹមសត្វឆ្មាព្រៃរបស់ប្រទេសន័រវេយ មានឆាមវែងៗដ៏គួរឲ្យស្រឡាញ់មួយក្បាលឈ្មោះ មីស្ទីក (Mystique)។ ពេលដែលខ្ញុំអង្អែលពោះវា និងលេងជាមួយវា ឬនៅពេលដែលវាដេកលក់នៅលើភ្លៅខ្ញុំ នៅពេលល្ងាច ជួនកាលខ្ញុំមិននឹកស្មានសោះថា វានៅតែមានអត្តចរិតដូចកាលយើងជួបវាពីដំបូងកាលប៉ុន្មានឆ្នាំមុន។ មីស្ទីក ធ្លាប់រស់នៅជាឆ្មាអនាថា តាមចិញ្ចើមថ្នល់ មានសភាពស្គមស្គាំង និងខ្លាចមនុស្សគ្រប់គ្នា។ តែបញ្ហានេះបានផ្លាស់ប្តូរបន្តិចៗ ខណៈពេលដែលខ្ញុំបានដាក់អាហារឲ្យវាស៊ីជារៀងរាល់ថ្ងៃ។ ថ្ងៃមួយ ទីបំផុតវាក៏ព្រមឲ្យខ្ញុំអង្អែលខ្នងវា ហើយបន្ទាប់មកខ្ញុំក៏បានយកវាទៅចិញ្ចឹមនៅក្នុងផ្ទះ។

ការផ្លាស់ប្តូររបស់មីស្ទីក បានក្រើនរំឭកខ្ញុំអំពីការប្រោសឲ្យជា ដែលអាចកើតមាន ដោយសារភាពអត់ធ្មត់ និងសេចក្តីស្រឡាញ់។ គឺបានរំឭកខ្ញុំអំពីព្រះទ័យរបស់ព្រះ ដូចដែលបានពិពណ៌នានៅក្នុងបទគម្ពីរអេសាយ ជំពូក៤២។ បទគម្ពីរនេះបានប្រាប់យើងអំពីអ្នកបម្រើព្រះម្នាក់ ដែលពេញដោយព្រះវិញ្ញាណបរិសុទ្ធ (ខ.១) ដែលនឹងធ្វើការដោយមិនគិតការនឿយហត់ និងដោយស្មោះត្រង់ ដើម្បីតាំងសេចក្តីយុត្តិធម៌របស់ព្រះនៅលើផែនដី (ខ.៣-៤)។

អ្នកបម្រើនោះ គឺជាព្រះយេស៊ូវ (ម៉ាថាយ ១២:១៨-២០) បាននាំមកនូវសេចក្តីយុត្តិធម៌របស់ព្រះ មិនមែនតាមរយៈអំពើហិង្សា ឬការដណ្តើមអំណាចនោះទេ។ ផ្ទុយទៅវិញ ព្រះអង្គមានព្រះទ័យសុភាព (អេសាយ ៤២:២) ដោយយកព្រះទ័យទុកដាក់ ដោយភាពអត់ធ្មត់ ចំពោះមនុស្សដែលគេបោះបង់ចោល ឬអ្នកដែលត្រូវគេវាយឲ្យជាំ ឬរបួស (ខ.៣)។

ព្រះទ្រង់មិនដែលបោះបង់ចោលកូនព្រះអង្គឡើយ។ ព្រះអង្គមានពេលគ្រប់គ្រាន់ ដើម្បីមើលចៃចិត្តរបស់យើង ដែលមានរបួសទាល់តែចិត្តរបស់យើងបានជាសះស្បើយ។ តាមរយៈសេចក្តីស្រឡាញ់ដ៏សុភាព និងអត់ធ្មត់របស់ព្រះអង្គ យើងអាចរៀនស្រឡាញ់ និងទុកចិត្តព្រះអង្គសារជាថ្មីបន្តិចម្តងៗ។—Monica La Rose

តើអ្នកបានឃើញការផ្លាស់ប្តូរ តាមរយៈសេចក្តីស្រឡាញ់ដែលមានភាពអត់ធ្មត់ដូចម្តេចខ្លះ? តើអ្នកអាចចម្រើនឡើង នៅក្នុងការចែកចាយសេចក្តីស្រឡាញ់របស់ព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលមិនបោះបង់ចោលទូលបង្គំ និងបានស្រឡាញ់ទូលបង្គំ ដោយព្រះទ័យអត់ធ្មត់ និងប្រោសចិត្តរបស់ទូលបង្គំឲ្យបានជា។ សូមព្រះអង្គជួយទូលបង្គំឲ្យស្រឡាញ់អ្នកដទៃ ដោយសេចក្តីស្រឡាញ់ ដែលមានភាពអត់ធ្មត់ផងដែរ។

នៅចំពោះទ្រង់មានសេចក្តីអំណរដ៏ពោរពេញ (ទំនុកតម្កើង ១៦:១១)។

រកឃើញក្តីអំណរ ដោយប្រាជ្ញា

លោក ចេសិន ភ័រសូហ្វ (Jason Persoff) បានបម្រើការជាវេជ្ជបណ្ឌិតនៅបន្ទប់សង្គ្រោះបន្ទាន់ក្នុងមន្ទីរពេទ្យធំមួយកន្លែង ដែលមានការប្តូរផ្តាច់នៅក្នុងការសង្គ្រោះអ្នកជំងឺកូវីដ១៩។ មានពេលមួយ គាត់យល់ឃើញថា ជំងឺនេះកំពុងតែមានជោគជ័យនៅក្នុងការរាតត្បាតទូទាំងពិភពលោក។ តែគាត់នៅតែប្រឹងប្រែងអស់ពីលទ្ធភាព ក្នុងការព្យាបាលអ្នកជំងឺកូវីឌ។ ក្នុងអំឡុងម៉ោងសម្រាក គាត់ក៏បានបន្ធូរអារម្មណ៍ដោយថតរូបគ្រាប់ព្រិលដ៏តូចល្អិត ដោយពង្រីករូបគ្រាប់ព្រិលនីមួយៗមើល។ គាត់ក៏បានលាន់មាត់ថា វាពិតជាប្លែក និងគួរឲ្យភ្ញាក់ផ្អើលណាស់។ ប៉ុន្តែ ការស្វែងរកក្តីអំណរនៅក្នុងវត្ថុដ៏តូចល្អិត ដែលមានភាពស្រស់ស្អាត គឺជាឱកាស ដើម្បីប្រកបស្និទ្ធស្នាលជាមួយព្រះអាទិករ ហើយក៏ដើម្បីមើលឃើញលោកីយ៍ តាមរបៀបដែលមនុស្សតិចតួចបានចំណាយពេលកត់សម្គាល់។

លោក វេជ្ជបណ្ឌិតក៏បានមានប្រសាសន៍ថា «ការស្វែងរកភាពសប្បាយរីករាយ តាមរបៀបដ៏ឆ្លាតវៃដូចនេះដើម្បីកាត់បន្ថយស្ត្រេស និងបង្កើតភាពរឹងមាំ ពិតជាមានតម្លៃយ៉ាងខ្លាំងនៅក្នុងវិជ្ជាជីវៈរបស់ពេទ្យ។ ប៉ុន្តែ គាត់បានឲ្យយោបល់ដល់មនុស្សជាទូទៅថា «អ្នកត្រូវតែដកដង្ហើម។ អ្នកត្រូវតែស្វែងរកវិធីសម្រាកលម្ហែ និងអរសប្បាយនឹងជីវិត»។

ស្តេច ដាវីឌ ដែលជាអ្នកនិពន្ធបទគម្ពីរទំនុកតម្កើង ក៏បានបង្ហាញការយល់ឃើញដូចនេះក្នុងបទគម្ពីរទំនុកតម្កើង ជំពូក១៦ ខណៈពេលដែលទ្រង់ប្រកាសអំពីប្រាជ្ញានៃការរកឃើញក្តីអំណរក្នុងព្រះ។ គឺដូចដែលទ្រង់បន្លឺសម្លេងសរសើរព្រះអម្ចាស់ថា «ព្រះយេហូវ៉ាទ្រង់ជាចំណែកនៃមរដក ហើយជាចំណែកក្នុងពែងរបស់ទូលបង្គំ។ ហេតុនោះចិត្តទូលបង្គំអរសប្បាយ ហើយកិត្តិយសនៃទូលបង្គំបានរីករាយឡើង រូបសាច់នៃទូលបង្គំក៏នឹងនៅដោយសាន្តត្រាណដែរ» (ខ.៥, ៩)។

មនុស្សបានធ្វើនូវរឿងល្ងង់ខ្លៅជាច្រើន ដើម្បីការព្យាយាមបំបាត់ទុក្ខព្រួយ។ វេជ្ជបណ្ឌិត ចេសិន បានរកឃើញផ្លូវប្រកបដោយប្រាជ្ញា ដែលចង្អុលបង្ហាញគាត់ឲ្យងាកទៅរកព្រះអាទិករ ដែលបានប្រទានយើងនូវក្តីអំណរនៃព្រះវត្តមានព្រះអង្គ។ គឺដូចដែលស្តេចដាវីឌបានពោលសរសើរព្រះអម្ចាស់ថា «ទ្រង់នឹងបង្ហាញឲ្យទូលបង្គំឃើញផ្លូវជីវិតវិញ នៅចំពោះទ្រង់មានសេចក្តីអំណរដ៏ពោរពេញ នៅព្រះហស្តស្តាំទ្រង់មានសេចក្តីអរសប្បាយជាដរាបតទៅ» (ខ.១១)។ ក្នុងព្រះអង្គ យើងរកឃើញក្តីអំណរកាន់តែច្រើនឡើងជារៀងរាល់ថ្ងៃ។—Patricia Raybon

តើព្រះអម្ចាស់បានប្រទានពរជីវិតអ្នក តាមរយៈការរកឃើញក្តីអំណរ តាមផ្លូវនៃប្រាជ្ញាដូចម្តេចខ្លះ? នៅពេលដែលអ្នកអានបទគម្ពីរ ទំនុកតម្កើងជំពូក១៦ តើបទគម្ពីរនេះបានបណ្តាលចិត្តអ្នកស្វែងរកក្តីអំណរក្នុងព្រះអង្គ តាមរយៈផ្លូវនៃប្រាជ្ញាដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ក្នុងដំណើរជីវិតរបស់ទូលបង្គំ សូមព្រះអង្គប្រទានពរទូលបង្គំ ឲ្យស្វែងរកក្តីអំណរ ដោយប្រាជ្ញានៅក្នុងព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | សាស្តា ១-៣ និង២កូរិនថូស ១១:១៦-៣៣

ព្រះយេហូវ៉ាទ្រង់យឺតនឹងខ្ញាល់ ហើយមានព្រះចេស្តាយ៉ាងធំ ទ្រង់មិនលះលែងទោសរបស់មនុស្ស ឡើយ (ណាហ៊ូម ១:៣)។

សេចក្តីយុត្តិធម៌ និងព្រះគុណរបស់ព្រះ

លោក ចន ម៉ាទីន (John Martin ឆ្នាំ១៧៨៩-១៨៥៤) ជាវិចិត្រករអង់គ្លេស ឯកទេសផ្នែកគំនូរបែប រ៉ូមែនទិច មានឈ្មោះល្បី ដោយសារផ្ទាំងគំនូរទេសភាពដែលពិពណ៌នាអំពីវិនាសកម្មនៃអារ្យ ធម៌ទាំងឡាយ។ ក្នុងផ្ទាំងទស្សនីយភាពដ៏គួរឲ្យចាប់អារម្មណ៍នេះ គេអាចមើលឃើញមនុស្សមានភាពតក់ស្លុត ចំពោះទំហំនៃសេចក្តីហិនវិនាស ហើយមិនមានអំណាចអ្វី នៅក្នុងការទប់ស្កាត់ការបំផ្លិចបំផ្លាញដែលត្រូវមកដល់។ ក្នុងផ្ទាំងគំនូរមានចំណងជើងថា ការដួលរលំនៃទីក្រុងនីនីវេ គាត់បានបង្ហាញរូបភាពមនុស្សរត់គេចពីរលកនៃការ បំផ្លិចបំផ្លាញដែលកំពុងរីកធំឡើង នៅក្រោមពពកខ្មៅងងឹត ដែលកំពុងរមូលចូលគ្នា។

ជាង២ពាន់ឆ្នាំ មុនពេលលោក ម៉ាទីន គូររូបមួយផ្ទាំងនេះ ហោរា ណាហ៊ូម បានថ្លែងទំនាញអំពីការជំនុំជម្រះ ដែលនឹងធ្លាក់មកលើទីក្រុងនីនីវេ។ លោក ហោរា បានពិពណ៌នាអំពីភ្នំធំដែលកក្រើក និងអស់ទាំងភ្នំតូចដែល រលាយទៅ ហើយនិងផែនដីរញ្ជួយ (ណាហ៊ូម ១:៥) ជានិមិត្តរូបតំណាងឲ្យសេចក្តីក្រោធរបស់ព្រះ ដែលធ្លាក់ មកលើមនុស្សដែលកៀបសង្កត់អ្នកដទៃ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់បាន ឆ្លើយតបចំពោះបាបរបស់មនុស្ស តែមិនមែនដោយគ្មានព្រះគុណនោះឡើយ។ ខណៈពេលដែលហោរា ណាហ៊ូម បានរំឭករាស្ត្ររបស់ព្រះអង្គ ឲ្យនឹកចាំអំពីព្រះចេស្តារបស់ព្រះអង្គ គាត់ក៏បានកត់សម្គាល់ថា ព្រះអង្គ «យឺតនឹង ខ្ញាល់» (ខ.៣) ហើយក៏ថែរក្សាអស់អ្នក ដែលយកព្រះអង្គជាទីពឹងផ្អែក (ខ.៧)។

យើងប្រហែលជាមានអារម្មណ៍ថាពិបាកអានការពិពណ៌នាអំពីការជំនុំជម្រះ ប៉ុន្តែក្នុងលោកីយ៍គ្មានការដាក់ ទោសមកលើការអាក្រក់ គឺជាលោកីយ៍ដែលគួរឲ្យខ្លាច។ តែអរព្រះគុណព្រះអង្គ ដែលហោរា ណាហ៊ូម មិនបាន ពិពណ៌នាតែប៉ុណ្ណោះទេ។ ជាងនេះទៅទៀត គាត់ក៏បានរំឭកយើងថា ព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងរស់នៅក្នុង ពិភពលោក ដែលល្អ និងមានយុត្តិធម៌។ គឺដូចដែលព្រះអង្គមានបន្ទូលថា «មើលន៍នៅលើភ្នំទាំងឡាយ ឃើញ ជើងរបស់អ្នកដែលនាំដំណឹងល្អមក គឺជាអ្នកដែលប្រកាសប្រាប់ពីសេចក្តីសុខ» (ខ.១៥)។ ដំណឹងល្អនោះ គឺជា ដំណឹងល្អរបស់ព្រះយេស៊ូវ ដែលបានរងទុក្ខ ដោយទទួលទោសរបស់បាបជំនួសយើង ដើម្បីផ្សះផ្សាឲ្យយើងបាន ជានឹងព្រះ (រ៉ូម ៥:១, ៦)។—Matt Lucas

តើអ្នកចង់ឲ្យព្រះអម្ចាស់ការពារមនុស្សដែលគេសង្កត់សង្កិន ដូចម្តេចខ្លះ? តើការយល់ដឹងរបស់អ្នកអំពី សេចក្តីក្រោធរបស់ព្រះអង្គមកលើភាពអយុត្តិធម៌បានបណ្តាលចិត្តអ្នក ឲ្យចង់ជួយមនុស្សដែលគេ សង្កត់សង្កិនដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអធិស្ឋានឲ្យមនុស្សនៅទូទាំងពិភពលោក ដែលកំពុងរងទុក្ខ ដោយអំពើ អយុត្តិធម៌។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | សាស្តា ៤-៦ និង២កូរិនថូស ១២

ខ្ញុំប្រាប់សេចក្តីទាំងនេះ ដើម្បីឲ្យអ្នករាល់គ្នាបានសេចក្តីសុខសាន្ត ដោយសារខ្ញុំ (យ៉ូហាន ១៦:៣៣)។

ដំណើរជីវិតដែលមានការឡើងចុះ

ថ្ងៃមួយ វេទិកាបណ្តាញសង្គមហ្វេសប៊ុកបានបង្ហាញរូបភាពមួយ ដែលខ្ញុំបានបង្ហោះកាលពីឆ្នាំមុន ដែលនៅក្នុងនោះ ខ្ញុំឃើញរូបកូនខ្ញុំអាយុ៥ឆ្នាំកំពុងទទួលជោគជ័យ នៅក្នុងការលេងល្បែងកម្សាន្តឡើងកាំជណ្តើរនៅក្នុងផៃនទី។ ខ្ញុំក៏បានភ្ជាប់ឈ្មោះបងប្រុស និងបងស្រីរបស់ខ្ញុំក្នុងការបង្ហោះរូបភាពនោះ ដោយសារពួកគេបានលេងល្បែងកម្សាន្តនេះជាញឹកញាប់កាលយើងនៅក្មេង។ ល្បែងកម្សាន្តឡើងកាំជណ្តើរក្នុងផៃនទីត្រូវបានគេបង្កើតឡើងផ្អែកទៅលើល្បែងកម្សាន្តមួយ ដែលគេបានលេងប៉ុន្មានសតវត្សរ៍មកហើយ ដោយជួយមនុស្សឲ្យរៀនរាប់លេខ ហើយផ្តល់ឲ្យនូវភាពរំភើបរីករាយ ដល់អ្នកដែលអាចឡើងជណ្តើរដល់លេង១០០ បានលឿនជាងគេ ដើម្បីឈ្នះល្បែងកម្សាន្តនេះ។ ប៉ុន្តែ អ្នកត្រូវប្រុងប្រយ័ត្ន! បើអ្នកឡើងទៅដល់លេខ៩៨ អ្នកត្រូវសម្រួតចុះមកក្រោមវិញតាមការរអិលអស់ជាច្រើនលេខ ដោយពន្យារពេល ឬធ្វើឲ្យអ្នកមិនអាចទទួលជ័យជម្នះបាន។

តើជីវិតយើងមិនមែនលក្ខណៈដូចល្បែងកម្សាន្តនេះទេឬ? ព្រះយេស៊ូវបានរៀបចំខ្លួនយើង ដោយសេចក្តីស្រឡាញ់ សម្រាប់ដំណើរឡើងចុះៗនៃជីវិតរបស់យើងប្រចាំថ្ងៃ។ ព្រះអង្គមានបន្ទូលថា យើងនឹងជួប «សេចក្តីវេទនា» (យ៉ូហាន ១៦:៣៣) តែព្រះអង្គក៏បានលើកទឹកចិត្តយើង ឲ្យមានសន្តិភាពក្នុងចិត្តផងដែរ។ យើងមិនចាំបាច់ត្រូវរង្គោះរង្គើ ដោយសារទុក្ខវេទនាដែលយើងជួបប្រទះទេ។ ហេតុអ្វី? ព្រោះព្រះគ្រីស្ទបានឈ្នះលោកិយហើយ! គ្មានអ្វីខ្លាំងជាងព្រះចេស្តារបស់ព្រះអង្គឡើយ ដូចនេះយើងក៏អាចប្រឈមមុខដាក់បញ្ហាអ្វីក៏ដោយ ដែលយើងជួបប្រទះក្នុងដំណើរជីវិត ដោយពឹងអាងកម្លាំងដ៏អស្ចារ្យ ដែលព្រះអង្គមានសម្រាប់យើង (អេភេសូរ ១:១៩)។

ជីវិតយើងមិនខុសពីល្បែងកម្សាន្តឡើងកាំជណ្តើរក្នុងផៃនទីនោះឡើយ ដោយជួនកាលយើងទទួលបានជណ្តើរមួយ ដែលអនុញ្ញាតឲ្យយើងឡើងទៅលើ ហើយពេលខ្លះទៀតយើងធ្លាក់ចុះមកវិញយ៉ាងឆាប់រហ័សតាមការរអិល។ ប៉ុន្តែ យើងមិនចាំបាច់ត្រូវធ្វើដំណើរទៅមុខក្នុងជីវិតនេះ ដោយគ្មានសង្ឃឹមនោះឡើយ។ ព្រោះយើងមានព្រះចេស្តារបស់ព្រះយេស៊ូវសម្រាប់ជួយយើងឲ្យឈ្នះអ្វីៗគ្រប់យ៉ាង។—Katara Patton

តើអ្នកត្រូវការជំនួយ ដើម្បីជម្នះបញ្ហាប្រឈមអ្វីខ្លះនៅថ្ងៃនេះ? តើការផ្តោតចិត្តទៅលើព្រះចេស្តារបស់ព្រះយេស៊ូវ ដែលជួយអ្នកឲ្យជម្នះទុក្ខលំបាក និងបញ្ហាបានលើកទឹកចិត្តអ្នកយ៉ាងណាខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការពិតទូលបង្គំថា ព្រះអង្គបានឈ្នះលោកិយហើយ! សូមព្រះអង្គជួយទូលបង្គំឲ្យពឹងផ្អែកលើព្រះចេស្តារបស់ព្រះអង្គក្នុងដំណើរឡើងចុះនៃជីវិត។

Daily Manna 2026_Content Enhance.indd 270 17/11/25 1:47 in the afternoon

គឺថាគ្រប់ទាំងជង្គង់នឹងលុតចុះនៅមុខអញ ហើយគ្រប់ទាំងអណ្តាតនឹងស្បថពីដំណើរអញ (អេសាយ ៤៥:២៣)។

ការវិលត្រឡប់មកវិញរបស់ក្សត្រ

ពិធីបុណ្យសពរបស់ក្សត្រីអេលីហ្សាប៊ែតទី២ ត្រូវបានគេផ្សាយបន្តផ្ទាល់ ដោយមានទស្សនិកជនរាប់ពាន់លាននាក់ បានចូលរួមទស្សនានៅទូទាំងពិភពលោក។ ការផ្សាយបន្តផ្ទាល់នេះ អាចជាការផ្សាយដែលមានមនុស្សទស្សនាច្រើនបំផុតក្នុងប្រវត្តិសាស្ត្រ។ មានមនុស្សមួយលាននាក់ បានឈរតម្រៀបគ្នាជាជួរ នៅលើចិញ្ចើមផ្លូវ នៅថ្ងៃនោះ ហើយមានមនុស្ស២៥ម៉ឺននាក់ បានឈរតម្រង់ជួរអស់ជាច្រើនម៉ោងនៅសប្តាហ៍នោះ ដើម្បីចូលមើលក្តាមឈូសរបស់ព្រះនាង។ មានក្សត្រ ក្សត្រី ប្រធានាធិបតី និងប្រមុខរដ្ឋ៥០០នាក់ មកពីបណ្តាប្រទេសនៅទូទាំងពិភពលោក បានចូលមកថ្វាយការគោរពជាប្រវត្តិសាស្ត្រដល់ព្រះនាមជាស្ត្រីដែលគេបានស្គាល់ដោយសារគាត់មានឥទ្ធិពល និងចរិតលក្ខណៈដ៏ប្រពៃ។

ខណៈពេលដែលពិភពលោកកំពុងផ្តល់ការចាប់អារម្មណ៍មកលើចក្រភពអង់គ្លេស និងមហាក្សត្រីនៃប្រជាជាតិមួយនេះ ដែលបានលាចាកលោក ខ្ញុំក៏បាននឹកចាំអំពីព្រឹត្តិការណ៍មួយទៀត ដែលជាការវិលត្រឡប់មកវិញរបស់ក្សត្រមួយអង្គ។ ព្រះគម្ពីរបានក្រើនរំឭកយើងថា ថ្ងៃនោះជិតមកដល់ហើយ គឺថ្ងៃដែលប្រជាជាតិទាំងឡាយនឹងជួបជុំគ្នា ដើម្បីទទួលស្គាល់ក្សត្រលើអស់ទាំងក្សត្រ (អេសាយ ៤៥:២០-២២)។ ទ្រង់ជាអ្នកដឹកនាំដែលមានអនុភាព និងសេចក្តីសុចរិត (ខ.២៤) នៅចំពោះព្រះអង្គ «គ្រប់ទាំងជង្គង់នឹងលុតចុះនៅមុខ» ព្រះអង្គ «ហើយគ្រប់ទាំងអណ្តាតនឹងស្បថ» (ខ.២៣) គឺរាប់បញ្ចូលទាំងអ្នកដឹកនាំប្រទេសក្នុងពិភពលោក ដែលនឹងយកសិរីល្អនៃខ្លួនមកទុកក្នុងទីក្រុងយេរូសាឡិមថ្មី ហើយមនុស្សលោក នឹងយកសិរីល្អ និងកេរ្តិ៍ឈ្មោះរបស់សាសន៍ទាំងប៉ុន្មានមកទុកក្នុងក្រុងនោះដែរ (វិវរណៈ ២១:២៤, ២៦)។ មិនមែនមនុស្សគ្រប់គ្នាសុទ្ធតែស្វាគមន៍ការយាងមកដល់របស់ព្រះអង្គទេ តែអ្នកដែលស្វាគមន៍ព្រះអង្គ និងបានអរសប្បាយនឹងការគ្រងរាជ្យរបស់ព្រះអង្គជាដរាងរហូត (អេសាយ ៤៥:២៤-២៥)។

ដូចដែលពិភពលោកបានចូលរួមទស្សនាពិធីបុណ្យសពរបស់ក្សត្រីមួយអង្គ ថ្ងៃមួយលោកីយ៍ទាំងនោះក៏នឹងបានឃើញក្សត្រលើអស់ទាំងក្សត្រយាងត្រឡប់មកវិញ។ ថ្ងៃនោះ ជាថ្ងៃដែលអស្ចារ្យបំផុត ដោយគ្រប់គ្នាទាំងនៅស្ថានសួគ៌ និងផែនដីនឹងក្រាបនៅចំពោះព្រះយេស៊ូវគ្រីស្ទ ហើយទទួលស្គាល់ព្រះអង្គជាព្រះអម្ចាស់ (ភីលីព ២:១០-១១)។—Sheridan Voysey

ហេតុអ្វីអ្នកគិតថា ក្សត្រីអេលីហ្សាប៊ែតទី២ បានទទួលការគោរពច្រើនដូចនេះ? តើអ្នកនឹងដើរតាមព្រះយេស៊ូវធ្វើជាស្តេចរបស់អ្នក ដូចម្តេចខ្លះនៅថ្ងៃនេះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមក្រាបនៅចំពោះព្រះអង្គនៅថ្ងៃនេះ ដោយថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ ជាក្សត្រដែលខ្ពង់ខ្ពស់បំផុតរបស់ពិភពលោក សូមព្រះអង្គគ្រងរាជ្យលើជីវិតទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | សាស្តា ១០-១២ និងកាឡាទី ១

អ្នករាល់គ្នាមិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ គឺជាជាតិតែ១នឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ (អេភេសូរ ២:១៩)។

មិនមែនជាអ្នកដទៃទៀតទេ

«កន្លែងនេះមិនស្វាគមន៍ឯងទេ»។ ពាក្យសម្តីប៉ុន្មានម៉ាត់នេះ បានធ្វើឲ្យក្មេងស្រីអាយុ៨ឆ្នាំម្នាក់ មានការឈឺចាប់យ៉ាងខ្លាំង ដែលបន្តនៅជាប់ក្នុងចិត្តនាងអស់ជាច្រើនឆ្នាំ។ ក្រុមគ្រួសាររបស់នាងបានធ្វើដំណើរមកពីជំរុំជនភៀសខ្លួនក្នុងប្រទេសដែលកំពុងទទួលរងការបំផ្លិចបំផ្លាញដោយសារសង្គ្រាម ហើយកាតអន្តោប្រវេសន៍របស់នាង មានពាក្យ «ជនបរទេស» ដែលគេបានបោះត្រាពីលើ។ នាងមានអារម្មណ៍ថា គេមិនស្វាគមន៍នាងក្នុងប្រទេសនេះ។

នៅពេលនាងពេញវ័យ ទោះនាងបានទទួលជឿព្រះយេស៊ូវហើយក៏ដោយ ក៏នាងនៅតែមានអារម្មណ៍ថាគេមិនរាប់រកនាង។ នាងនៅតែមានអារម្មណ៍ឈឺចាប់ ដោយសារគេចាត់ទុកនាងជាមនុស្សដទៃដែលគេមិនស្វាគមន៍។ កាលនាងកំពុងអានព្រះគម្ពីរ នាងក៏បានរកឃើញព្រះបន្ទូលសន្យាក្នុងបទគម្ពីរអេភេសូរ ជំពូក២។ នៅក្នុងខ.១២ នាងក៏បានឃើញពាក្យ «មនុស្សដទៃ» ដែលធ្លាប់តែធ្វើឲ្យនាងមិនសប្បាយចិត្ត។ «នៅវេលានោះ អ្នករាល់គ្នានៅទីទៃពីព្រះគ្រីស្ទ ក៏ឃ្លាតចេញពីអំណាចជាតិអ៊ីស្រាអែលផង ជាមនុស្សដទៃខាងឯសេចក្តីសញ្ញាដែលទ្រង់បានសន្យាទុក ក៏ឥតមានទីសង្ឃឹម ហើយគ្មានព្រះក្នុងលោកីយ៍នេះដែរ»។ ប៉ុន្តែ ខណៈពេលដែលនាងបន្តអានកណ្ឌគម្ពីរនេះ នាងក៏បានដឹងថា ការលះបង់របស់ព្រះគ្រីស្ទនៅលើឈើឆ្កាងបានកែប្រែសណ្ឋានរបស់នាងជាមនុស្សដទៃ។ នាងក៏បានអានដល់ ខ.១៩ ដែលបានប្រាប់នាងថា នាង «មិនមែនជាអ្នកដទៃ ឬជាអ្នកគ្រាន់តែសំណាក់នៅទៀតទេ»។ នាងជា «ជាតិតែ១នឹងពួកបរិសុទ្ធ ជាពួកដំណាក់ព្រះវិញ»។ ពេលដែលនាងបានដឹងថា នាងគឺជាពលរដ្ឋនៃស្ថានសួគ៌ នាងមានអំណរដ៏លើសលប់។ នាងមិនមែនជាអ្នកដទៃទៀតទេ។ ព្រះអម្ចាស់បានស្វាគមន៍ និងទទួលនាងចូលមហាគ្រួសាររបស់ព្រះអង្គ។

ដោយសារបាបរបស់យើង យើងបានដាច់ចេញពីព្រះ។ ប៉ុន្តែ យើងមិនចាំបាច់ត្រូវបន្តរស់នៅ ដោយដាច់ចេញពីព្រះអង្គនោះឡើយ។ ព្រះយេស៊ូវប្រទានសន្តិភាពដល់អស់អ្នក ដែល «មកពីស្រុកឆ្ងាយ» (ខ.១៧) ដោយទទួលយកអស់អ្នកដែលទទួលជឿព្រះអង្គឲ្យពួកគេក្លាយជាសាសន៍ស្ថានសួគ៌នៃនគរដ៏អស់កល្បរបស់ព្រះអង្គ ដែលរួបរួមគ្នាជារូបកាយនៃព្រះគ្រីស្ទ។—Dave Branon

តើអ្នកមានអារម្មណ៍ថា គេមិនស្វាគមន៍អ្នកដូចម្តេចខ្លះ? តើអ្នកមានអារម្មណ៍យ៉ាងណាពេលដែលបានដឹងថា ព្រះទ្រង់បានត្រាស់ហៅកូនព្រះអង្គទាំងអស់ឲ្យបានរួបរួមជាមួយព្រះអង្គ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានទាំទូលបង្គំចូលក្នុងការប្រកបស្និទ្ធស្នាលជាមួយព្រះអង្គ និងអ្នកដទៃ ដែលស្រឡាញ់ និងជឿព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | បទចម្រៀងសាឡូម៉ូន ១-៣ និងកាឡាទី ២

នោះយើងដែលមានគ្នាច្រើន ក៏ជារូបកាយតែមួយក្នុងព្រះគ្រីស្ទ ហើយជាអវយវៈដល់គ្នានឹងគ្នាបែបយ៉ាងនោះដែរ (រ៉ូម ១២:៥)។

មិនមែនជាអ្នកដទៃទៀតទេ

ភូមិវ៉ាយធីអីនៅរដ្ឋអាឡាស្កាមានប្រជាជន៣០០នាក់ ដែលភាគច្រើនរស់នៅក្នុងបរិវេណអគារខុនដូធំមួយ ហើយនេះហើយបានជាគេហៅភូមិវ៉ាយធីអីថា «ភូមិនៅក្រោមដំបូលតែមួយ»។ អ្នកស្រី អេមី (Amie) ជាប្រជាជនដែលធ្លាប់រស់នៅក្នុងភូមិនេះបានលើកឡើងថា «ខ្ញុំមិនចាំបាច់ត្រូវបោះជំហាន ដើរចេញក្រៅអគារនោះឡើយ ព្រោះនៅទីនោះ មានហាងលក់ទំនិញ ការិយាល័យសាធារណៈ សាលារៀន និងប្រៃសណីយ៍នៅជាន់ផ្ទាល់ដីស្រាប់ ដូចនេះខ្ញុំគ្រាន់តែជិះជណ្តើរយន្តចុះក្រោម គឺជាការស្រេច!»

អ្នកស្រី អេមី ក៏បានចែកចាយផងដែរថា «ដោយសារការរស់នៅក្នុងអគារនោះមានភាពងាយស្រួលយ៉ាងខ្លាំង ជាញឹកញាប់ខ្ញុំច្រើនតែចង់រស់នៅម្នាក់ឯងដោយគិតថា ខ្ញុំមិនត្រូវការពឹងពាក់អាស្រ័យនរណាម្នាក់ឡើយ។ ប៉ុន្តែ អ្នករស់នៅទីនោះ មានភាពរួសរាយ និងចិត្តល្អណាស់។ ពួកគេយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមក។ ខ្ញុំក៏បានដឹងថា ពួកគេត្រូវការខ្ញុំ ហើយខ្ញុំក៏ត្រូវការពួកគេ»។

ពេលខ្លះ យើងក៏ប្រហែលជាចង់រស់នៅម្នាក់ឯង ហើយជៀសវាងការរស់នៅក្នុងសហគមន៍ ព្រោះយើងគិតថា ការទំនាក់ទំនងធ្វើឲ្យយើងមានស្ត្រេសច្រើន។ ប៉ុន្តែ ព្រះគម្ពីរបានចែងថា អ្នកជឿព្រះយេស៊ូវគួរតែមានការថ្លឹងថ្លែងឲ្យបានល្អ រវាងការចំណាយពេលម្នាក់ឯង និងការប្រកបជាមួយអ្នកជឿដទៃទៀត។ សាវ័ក ប៉ុល បានប្រដូចសហគមន៍នៃអ្នកជឿព្រះទៅនឹងរូបកាយមនុស្ស។ ដែលអវយវៈនីមួយៗរបស់រូបកាយមានតួនាទីផ្សេងគ្នាជាយ៉ាងណា នោះគ្រីស្ទបរិស័ទម្នាក់ៗ ក៏មានតួនាទីរៀងៗខ្លួនក្នុងរូបកាយព្រះគ្រីស្ទ (រ៉ូម ១២:៤)។ ដែលអវយវៈនីមួយៗមិនអាចរស់នៅ ដាច់ចេញពីអវយវៈផ្សេងទៀតជាយ៉ាងណា នោះគ្រីស្ទបរិស័ទម្នាក់ៗមិនអាចរស់នៅក្នុងជីវិតនៃសេចក្តីជំនឿ តែម្នាក់ឯងបានទេ (ខ.៥)។ គឺនៅក្នុងសហគមន៍របស់យើងនោះហើយ ដែលយើងអាចប្រើអំណោយទានរបស់យើង (ខ.៦-៨ ១ពេត្រុស ៤:១០) ហើយមានការលូតលាស់ ដោយមានចរិតលក្ខណៈកាន់តែដូចព្រះយេស៊ូវ (រ៉ូម ១២:៩-២១)។

យើងត្រូវការគ្នាទៅវិញទៅមក ដោយការរួបរួមគ្នានៅក្នុងព្រះគ្រីស្ទ (ខ.៥)។ ដោយជំនួយរបស់ព្រះអង្គ ខណៈពេលដែលយើងជួយយកអសារដល់គ្នាទៅវិញទៅមក យើងអាចបង្កើតឲ្យមានទំនាក់ទំនងកាន់តែស៊ីជម្រៅជាមួយព្រះអង្គ ហើយបង្ហាញអ្នកដទៃ ឲ្យស្គាល់សេចក្តីស្រឡាញ់របស់ព្រះអង្គ។—Karen Huang

តើសហគមន៍នៃអ្នកជឿព្រះយេស៊ូវបានជួយអ្នក ក្នុងការដើរជាមួយព្រះដូចម្តេចខ្លះ? តើអ្នកជឿដទៃទៀតបានលើកទឹកចិត្តអ្នកដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានពរទូលបង្គំឲ្យមានបងប្អូន ប្រុសស្រីក្នុងព្រះគ្រីស្ទ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | បទចម្រៀងសាឡូម៉ូន ៤-៥ និងកាឡាទី ៣

កូនអើយ កុំឲ្យក្ងេចឱវាទអញឡើយ គួរឲ្យចិត្តឯងកាន់តាមបណ្តាំរបស់អញទាំងប៉ុន្មាន (សុភាសិត ៣:១)។

ការបង្រៀនដ៏រំភើបរីករាយ

អ្នកស្រី សូហ្វៀ រ៉ូប៊ឺត (Sophia Roberts) បានមើលឃើញការវះកាត់បេះដូងដោយផ្ទាល់ភ្នែកជាលើកដំបូង កាលគាត់មានអាយុប្រហែល១១ឆ្នាំ។ អ្នកប្រហែលជាគិតថា គាត់នៅក្មេងពេកមិនគួរឈរមើលពេទ្យវះកាត់បេះដូងឲ្យអ្នកជំងឺដូចនេះទេ តែអ្នកចាំបាច់ត្រូវដឹងថា វេជ្ជបណ្ឌិត ហារ៉ូល រ៉ូប៊ឺត (Harold Roberts Jr) ជាឪពុករបស់នាង និងជាពេទ្យវះកាត់បេះដូង។ កាលពីឆ្នាំ២០២២ សូហ្វៀ ក្នុងវ័យ៣០ឆ្នាំក្នុងនាមនាងជាគ្រូពេទ្យឯកទេសខាងវះកាត់ នាងបានចូលរួមជាមួយឪពុករបស់នាងក្នុងការវះកាត់ផ្លាស់ប្តូរប្រឹសបេះដូងយ៉ាងជោគជ័យ។ លោក ហារ៉ូល ក៏បានមានប្រសាសន៍ថា “តើមានអ្វីល្អជាងនេះទៀត? ខ្ញុំបានបង្រៀនក្មេងម្នាក់នេះឲ្យចេះដិះកង់កាលនាងនៅតូច... សព្វថ្ងៃនេះ ខ្ញុំក៏បានបង្រៀននាងឲ្យចេះវះកាត់បេះដូងមនុស្សទៀត ខ្ញុំពិតជាមានចិត្តរំភើបរីករាយណាស់”។

មិនមានមនុស្សច្រើនទេ ដែលបានបង្រៀនជំនាញវះកាត់ដល់ក្មេងៗ ប៉ុន្តែស្តេចសាឡូម៉ូនក៏បានពិពណ៌នាអំពីសារៈសំខាន់នៃការបង្រៀនការអ្វីផ្សេងទៀតដល់មនុស្សជំនាន់ក្រោយផងដែរ គឺបង្រៀនពួកគេឲ្យថ្វាយព្រះកិត្តិនាមដល់ព្រះ និងដើរតាមផ្លូវរបស់ព្រះអង្គ។ ក្បាត្រប្រកបដោយប្រាជ្ញាមួយអង្គនេះបានចែកចាយដោយចិត្តឆេះឆួល ដល់បុត្ររបស់ព្រះអង្គអំពីអ្វីដែលទ្រង់បានរៀនសូត្រក្នុងទំនាក់ទំនងជាមួយព្រះអម្ចាស់ គឺដូចដែលទ្រង់មានបន្ទូលថា “កូនអើយ... ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ” (សុភាសិត ៣:១, ៥) “ចូរកោតខ្លាចដល់ព្រះយេហូវ៉ា” (ខ.៧) “ចូរថ្វាយកិត្តិនាម ដល់ព្រះយេហូវ៉ា” (ខ.៩) ហើយ “កុំឲ្យមើលងាយសេចក្តីប្រៀនរបស់ព្រះយេហូវ៉ាឡើយ” (ខ.១១)។ ស្តេច សាឡូម៉ូន ស្គាល់ “សេចក្តីស្រឡាញ់” របស់ព្រះអម្ចាស់ ហើយក៏ “អរសប្បាយ” ចំពោះបុត្ររបស់ទ្រង់ ដែលមានចិត្តចង់ទទួលការកែតម្រង់ និងការណែនាំរបស់ព្រះអង្គ (ខ.១២)។

ចូរយើងបង្រៀនមនុស្សជំនាន់ក្រោយអំពីអត្ថន័យនៃការទុកចិត្ត ការកោតខ្លាច ការថ្វាយព្រះកិត្តិនាម ហើយបន្ទាបខ្លួនទទួលការកែតម្រង់ពីព្រះដ៏គួរស្ញែងខ្លាចនៃយើង។ ការធ្វើការជាដៃគូជាមួយព្រះអង្គ ដើម្បីបង្រៀនមនុស្សជំនាន់ក្រោយយ៉ាងដូចនេះ គឺជាឯកសិទ្ធិដ៏សំខាន់ ដែលពិតជាគួរឲ្យរំភើបរីករាយ!—Tom Felten

ហេតុអ្វីអ្នកចាំបាច់ត្រូវ ចែកចាយការអ្វីដែលអ្នកបានរៀនសូត្រអំពីព្រះដល់មនុស្សជំនាន់ក្រោយ? តើអ្នកនឹងផ្ទេរចំណេះដឹងអ្វីដល់មនុស្សជំនាន់ក្រោយ ក្នុងពេលសព្វថ្ងៃ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យបង្រៀនមនុស្សជំនាន់ក្រោយ ក៏ដូចជាមនុស្សចាស់ ឲ្យស្គាល់ផ្លូវនៃសេចក្តីស្រឡាញ់របស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | បទចម្រៀងសាឡូម៉ូន ៦-៨ និងកាឡាទី ៤

ខ្ញុំបង្គាប់សេចក្តីនេះដល់អ្នករាល់គ្នា គឺឲ្យស្រឡាញ់គ្នាទៅវិញទៅមកចុះ (យ៉ូហាន ១៥:១៧)។

មិត្តសំឡាញ់ពិតប្រាកដ

កាលពីក្មេង អ្នកស្រី សានចេស (Sanchez) មានផ្ទះនៅជាប់ទីធ្លាខាងក្រោយផ្ទះរបស់ម្តាយខ្ញុំ។ ក្នុងនាមពួកគាត់ជាអ្នកជិតខាង ដែលមានការរាប់អានគ្នាខ្លាំង ពួកគាត់ក៏មានការប្រកួតប្រជែកគ្នាក្នុងន័យមិត្តភាពផងដែរ។ អ្នកទាំងពីរប្រកួតគ្នារៀងរាល់ថ្ងៃច័ន្ទ ដោយម្នាក់ៗព្យាយាមទៅហាលខោអាវដែលទើបបោកគក់ថ្មីៗ នៅលើស្នូលខោអាវខាងក្រោយផ្ទះឲ្យបានមុខគេ។ ពេលណាម្តាយខ្ញុំហាលខោអាវក្រោយគេ គាត់ក៏បានលាន់មាត់ថា «នាងឈ្នះខ្ញុំទៀតហើយ!» ប៉ុន្តែនៅសប្តាហ៍បន្ទាប់ម្តាយរបស់ខ្ញុំអាចឈ្នះវិញ ដោយអ្នកទាំងពីរសុទ្ធតែអរសប្បាយនឹងការប្រកួតគ្នាក្នុងន័យមិត្តភាព រៀងរាល់សប្តាហ៍។ អស់រយៈពេលជាង១០ឆ្នាំ ដែលអ្នកទាំងពីរមានទីធ្លាក្រោយផ្ទះរួមគ្នា អ្នកទាំងពីរក៏បានចែកចាយប្រាជ្ញា និងក្តីសង្ឃឹមដល់គ្នាទៅវិញទៅមកផងដែរ។

ព្រះគម្ពីរបានចែងយ៉ាងច្បាស់អំពីគុណធម៌នៃមិត្តភាពដែលល្អដូចនេះ។ គឺដូចដែលស្តេចសាឡូម៉ូនបានសង្កេតឃើញថា «មិត្រសំឡាញ់រមែងស្រឡាញ់គ្នានៅគ្រប់វេលា ឯបងប្អូនក៏កើតមកសំរាប់គ្រាលំបាកដែរ» (សុភាសិត ១៧:១៧)។ ទ្រង់ក៏បានតត់សម្តាល់ថា «ប្រេងលាបនឹងទឹកអប់ នោះនាំឲ្យចិត្តរីករាយឡើង ឯសេចក្តីផ្អែមល្ហែមនៃសេចក្តីដាស់តឿន ដ៏អស់ពីចិត្តរបស់ភឿនមិត្រ ក៏ដូច្នោះដែរ» (២៧:៩)។

ព្រះយេស៊ូវគឺជាមិត្តល្អបំផុតរបស់យើង។ ព្រះអង្គបានជំរុញពួកសាវ័ករបស់ព្រះអង្គ ឲ្យស្រឡាញ់គ្នាទៅវិញទៅមក ហើយបានបង្រៀនពួកគេថា «គ្មានអ្នកណាមានសេចក្តីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្តូរជីវិតជំនួសពួកសំឡាញ់របស់ខ្លួននោះទេ» (យ៉ូហាន ១៥:១៣)។ នៅថ្ងៃបន្ទាប់ ព្រះអង្គក៏បានសុគតនៅលើឈើឆ្កាង ដែលជាការសុគតជំនួសមិត្តសំឡាញ់របស់ព្រះអង្គ។ ព្រះអង្គក៏បានប្រាប់ពួកគេផងដែរថា «ខ្ញុំហៅអ្នករាល់គ្នាថាជាសំឡាញ់វិញ ពីព្រោះខ្ញុំបានឲ្យអ្នករាល់គ្នាដឹងគ្រប់ការទាំងអស់ ដែលខ្ញុំឮពីព្រះវរបិតាខ្ញុំមក» (ខ.១៥)។ បន្ទាប់មកព្រះអង្គមានបន្ទូលថា «ខ្ញុំបង្គាប់សេចក្តីនេះដល់អ្នករាល់គ្នា គឺឲ្យស្រឡាញ់គ្នាទៅវិញទៅមកចុះ» (ខ.១៧)។

ព្រះបន្ទូលព្រះអង្គក្នុងបទគម្ពីរនេះកំពុងតែកែប្រែអ្នកស្តាប់ទាំងឡាយពីមនុស្សតូចទាប ទៅជាមិត្តភក្តិដ៏ស្មោះត្រង់។ ការរស់នៅក្នុងព្រះគ្រីស្ទ ចូរយើងរៀនរាប់អានអ្នកដទៃធ្វើជាមិត្តសំឡាញ់របស់យើង។ ព្រះអង្គជាមិត្តសំឡាញ់ពិត ដែលបានបង្រៀនយើងឲ្យមានសេចក្តីស្រឡាញ់ដូចនេះ។—Patricia Raybon

តើអ្នកបានដកពិសោធន៍ជាមួយសេចក្តីស្រឡាញ់ដូចម្តេចខ្លះ ក្នុងទំនាក់ទំនងជាមួយព្រះយេស៊ូវ? តើធ្វើដូចម្តេច ឲ្យអ្នកអាចធ្វើជាមិត្តសំឡាញ់ដូចព្រះអង្គ?

ឱព្រះយេស៊ូវ ព្រះអង្គបានហៅទូលបង្គំថា មិត្តសំឡាញ់។ សូមព្រះអង្គជួយទូលបង្គំឲ្យរស់នៅជាមិត្តសំឡាញ់ ដែលមានក្តីស្រឡាញ់ចំពោះអ្នកដទៃ។

Daily Manna 2026_Content Enhance.indd 275 17/11/25 1:47 in the afternoon

មនុស្សល្ងីល្ងើគេមានចិត្តចើតមើត ហើយទុកចិត្តតែនឹងខ្លួនឯងវិញ (សុភាសិត ១៤:១៦)។

ជៀសវាងការរស់នៅដោយធ្វេសប្រហែស

កោះលីនឌីសហ្វឺន មានឈ្មោះមួយទៀតថា កោះបរិសុទ្ធនៅក្នុងប្រទេសអង់គ្លេស ដែលមានផ្លូវតូចមួយតភ្ជាប់ទឹកដីប្រទេសអង់គ្លេសទៅកាន់កោះនេះ។ ទឹកសមុទ្របានជោរឡើងលិចផ្លូវថ្នល់នេះមួយថ្ងៃ២ដង។ គេបានដាក់ផ្លាកសញ្ញា ដើម្បីដាស់តឿនភ្ញៀវទេសចរណ៍ អំពីគ្រោះថ្នាក់នៃការឆ្លងកាត់ទៅកាន់កោះនេះ ពេលទឹកជោរឡើងខ្លាំង។ ប៉ុន្តែ ភ្ញៀវទេសចរណ៍ជាច្រើននៅតែមិនអើពើចំពោះការដាស់តឿននេះ ហើយជាញឹកញាប់ គេឃើញអ្នកទាំងនោះអង្គុយនៅលើដំបូលឡានដែលបានលិចក្នុងទឹកសមុទ្រ ឬរំពៃទឹកទៅរកប៉មយាមនៅក្នុងទឹក ដើម្បីឲ្យគេជួយសង្គ្រោះ។ តាមពិត គេអាចព្យាករណ៍អំពីពេលដែលទឹកជោរ គឺដូចដែលគេអាចដឹងថា ថ្ងៃនឹងរះនៅពេលណា។ ហើយគេបានដាក់ផ្លាកសញ្ញាដាស់តឿនគ្រប់ទីកន្លែងបានជាគេមិនអាចដោះសាថា ខ្លួនមិនបានឃើញផ្លាកសញ្ញាទាំងនោះឡើយ។ ប៉ុន្តែ គឺដូចដែលអ្នកនិពន្ធម្នាក់បានពិពណ៌នាថា កោះលីនឌីសហ្វឺន «គឺជាទីកន្លែង ដែលមនុស្សល្ងីល្ងើព្យាយាមប្រកួតប្រជែងជាមួយទឹកជោរ»។

កណ្ឌគម្ពីរសុភាសិតបានប្រាប់យើងថា «មនុស្សល្ងីល្ងើគេមានចិត្តចើងម៉ើង ហើយទុកចិត្តតែនឹងខ្លួនឯង» (១៤:១៦)។ មនុស្សដែលល្ងីល្ងើមិនសូវយកចិត្តទុកដាក់ចំពោះការស្វែងរកប្រាជ្ញា ឬការប្រឹក្សាប្រកបដោយប្រាជ្ញា ហើយក៏មិនមានទម្លាប់យកចិត្តទុកដាក់ ឬខ្វល់ខ្វាយពីអ្នកដទៃដែរ (ខ.៧-៨)។ ទោះជាយ៉ាងណាក៏ដោយ ប្រាជ្ញាជួយយើងកុំឲ្យធ្វើអ្វីមួយទាំងប្រញាប់ប្រញាល់ តែដើម្បីឲ្យយើងបានស្តាប់ ហើយជញ្ជឹងគិត ដើម្បីកុំឲ្យយើងវង្វេងចេញ ដោយសារអារម្មណ៍ប្រែប្រួល ឬពាក្យសម្តីឥតបើគិត (ខ.៦)។ ប្រាជ្ញាបង្រៀនយើងឲ្យសួរសំណួរល្អ ហើយពិចារណាអំពីផលវិបាកនៃសកម្មភាពរបស់យើង។ មនុស្សល្ងីល្ងើចូលចិត្តសម្រុកទៅមុខ ដោយមិនសូវខ្វល់អំពីទំនាក់ទំនង ឬផលវិបាក ឬក៏សេចក្តីពិតទេ ប៉ុន្តែជាញឹកញាប់ «មនុស្សមានគំនិតវាងវៃរមែងមើលផ្លូវខ្លួនដោយប្រយ័ត្ន» (ខ.១៥)។

ជួនកាល យើងចាំបាច់ត្រូវធ្វើអ្វីមួយភ្លាមៗ ដោយមិនស្ទាក់ស្ទើរ ប៉ុន្តែយើងក៏អាចជៀសវាងការធ្វេសប្រហែសផងដែរ។ ខណៈពេលដែលយើងទទួល និងអនុវត្តតាមប្រាជ្ញារបស់ព្រះ ព្រះអង្គនឹងប្រទានយើងនូវការដឹកនាំ ដែលយើងត្រូវការ ក្នុងការរស់នៅ។—Winn Collier

តើអ្នកបានឃើញមនុស្សរស់នៅដោយគ្មានការប្រុងប្រយ័ត្ន នៅកន្លែងណាខ្លះ? តើអ្នកអាចជៀសវាងការរស់នៅដោយការធ្វេសប្រហែស ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ យើងខ្ញុំរស់នៅក្នុងលោកិយ ដែលមានពេញដោយការធ្វេសប្រហែស។ សូមព្រះអង្គប្រទានទូលបង្គំនូវប្រាជ្ញា និងជួយទូលបង្គំរស់នៅឲ្យបានល្អ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៣-៤ និងកាឡាទី ៦

ដែលទ្រង់បានប្រគល់ព្រះអង្គទ្រង់ទៅដោយព្រោះបាបយើងវាល់គ្នា ដើម្បីនឹងប្រោសឲ្យយើងបានរួចពីលោកីយ៍ដ៏អាក្រក់សព្វថ្ងៃនេះ (កាឡាទី ១:៤)។

បេសកកម្មស្វែងរក និងជួយសង្គ្រោះ

មិត្តភក្តិមួយក្រុម បានទៅជិះទូកកម្សាន្តក្នុងដែសមុទ្ររបស់ប្រទេសអង់គ្លេស ដោយសង្ឃឹមថា ការព្យាករណ៍អំពីអាកាសធាតុដែលមានខ្សល់ព្យុះនឹងមានការផ្លាស់ប្តូរ។ ប៉ុន្តែ ខ្សល់ចាប់ផ្តើមបក់ និងទឹករលកកាន់តែខ្លាំង ដោយគំរាមកំហែងមកលើសុវត្ថិភាពរបស់ទូកពួកគេ ដូចនេះពួកគេក៏បានទំនាក់ទំនងទៅកាន់ទូលសង្គ្រោះ RNLI របស់ប្រទេសអង់គ្លេសតាមវិទ្យុទាក់ទង។ បន្ទាប់ពីពួកគេស្ថិតក្នុងពេលដ៏តានតឹងមួយរយៈមក ពួកគេក៏បានមើលឃើញនាវាសង្គ្រោះមកពីចម្ងាយ ហើយក៏មានអារម្មណ៍ធូរស្បើយដោយដឹងថា មិនយូរទេ ពួកគេនឹងមានសុវត្ថិភាពមិនខាន។ ក្រោយមក មិត្តភក្តិខ្ញុំម្នាក់ ដែលបានចូលរួមដំណើរកម្សាន្តដ៏គ្រោះថ្នាក់នេះ ក៏បានរំឭកអំពីរឿងនេះដោយការដឹងគុណថា «ទោះគេបានអនុវត្តន៍តាមបទបញ្ជាសម្រាប់ការធ្វើដំណើរតាមសមុទ្រឬអត់ នាវាសង្គ្រោះនៅតែមកជួយគេឲ្យរួចផុតពីគ្រោះថ្នាក់»។

ខណៈពេលដែលគាត់ចែកចាយរឿងនេះឲ្យខ្ញុំស្តាប់ ខ្ញុំក៏បានគិតអំពីរបៀបដែលព្រះយេស៊ូវបានដឹកនាំបេសកកម្មស្វែងរក និងជួយសង្គ្រោះកាល២ពាន់ឆ្នាំមុន។ ព្រះអង្គបានយាងចុះមកផែនដី ដោយយកកំណើតជាមនុស្ស ហើយបានរស់នៅក្នុងចំណោមយើង។ តាមរយៈការសុគត និងការមានព្រះជន្មឡើងវិញរបស់ព្រះអង្គ ព្រះអង្គបានប្រទានយើងនូវផែនការជួយសង្គ្រោះ ខណៈពេលដែលយើងបានដាច់ចេញពីព្រះអង្គដោយសារបាប និងការមិនស្តាប់បង្គាប់របស់យើង។ សាវ័ក ប៉ុល បាននិយាយសង្កត់ធ្ងន់អំពីសេចក្តីពិតនេះក្នុងសំបុត្រដែលគាត់បានសរសេរផ្ញើទៅពួកជំនុំ ទៅក្រុងកាឡាទីយ៉ាងដូចនេះថា «ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់នៃយើងរាល់គ្នា ...បានប្រគល់ព្រះអង្គទ្រង់ទៅ ដោយព្រោះបាបយើងរាល់គ្នា ដើម្បីនឹងប្រោសឲ្យយើងបានរួចពីលោកីយ៍ដ៏អាក្រក់សព្វថ្ងៃនេះ» (កាឡាទី ១:៣-៤)។ សាវ័កប៉ុលបានរំឭកពួកជំនុំនៅទីក្រុងកាឡាទីអំពីអំណោយនៃជីវិតថ្មី ដែលពួកគេបានទទួលតាមរយៈការសុគតរបស់ព្រះយេស៊ូវ ដើម្បីឲ្យពួកគេបានថ្វាយព្រះកិត្តិនាមដល់ព្រះជារៀងរាល់ថ្ងៃ។

ព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះរបស់យើងបានស្ម័គ្រព្រះទ័យសុគត ដើម្បីសង្គ្រោះយើងឲ្យរួចផុតពីភាពបាត់បង់។ ដោយសារព្រះអង្គបានសុគត នោះយើងមានជីវិតរស់ក្នុងនគរព្រះ ហើយយើងអាចចែកចាយដោយការដឹងគុណអំពីដំណឹងល្អដែលសង្គ្រោះជីវិតនេះ ដល់មនុស្សក្នុងសហគមន៍របស់យើង។—Amy Boucher Pye

តើអ្នកបានបង្ហាញចេញនូវការដឹងគុណដល់ព្រះអង្គសង្គ្រោះរបស់អ្នក ដូចម្តេចខ្លះ? តើអ្នកអាចចែកចាយដំណឹងល្អ ដល់នរណាខ្លះ?

ឱព្រះអម្ចាស់ យើងខ្ញុំរស់នៅក្នុងលោកិយ ដែលមានពេញដោយការធ្វេសប្រហែស។ សូមព្រះអង្គប្រទានទូលបង្គំនូវប្រាជ្ញា និងជួយទូលបង្គំរស់នៅឲ្យបានល្អ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៥-៦ និងអេភេសូរ ១

ចូររក្សាចិត្ត ដោយអស់ពីព្យាយាម ដ្បិតអស់ទាំងផលនៃជីវិតសុទ្ធតែចេញពីក្នុងចិត្តមក (សុភាសិត ៤:២៣)។

សារៈសំខាន់នៃសុខភាពផ្លូវចិត្ត

បេះដូងរបស់មនុស្ស គឺជាសរីរាង្គដ៏អស្ចារ្យ។ វាជាម៉ាស៊ីនបូមឈាមទំហំប៉ុនកណ្តាប់ដៃមនុស្ស មានទម្ងន់ពី២ខាំ ទៅ៤ខាំ។ ជារៀងរាល់ថ្ងៃ វាលោតបាន១សែនដង ហើយបូមឈាមប្រហែល៧៥០០លីត្រ បានចម្ងាយប្រហែល៩៥០០គីឡូម៉ែត្រ ក្នុងរូបកាយយើង! ដោយសារបេះដូងមានការងារធ្ងន់ៗ ជាយុទ្ធសាស្ត្រយ៉ាងដូចនេះ យើងអាចយល់បានអំពីមូលហេតុដែលសុខភាពបេះដូង មានសារៈសំខាន់ចំពោះសុខមាលភាពនៃរូបកាយទាំងមូល។ វិទ្យាសាស្ត្រសុខាភិបាលបានលើកទឹកចិត្តយើង ឲ្យខិតខំបង្កើតទម្លាប់ដែលនាំឲ្យមានសុខភាពល្អ ព្រោះសុខភាពរបស់បេះដូងយើង និងគុណភាពនៃសុខភាពរបស់យើងត្រូវដើរទន្ទឹមគ្នា។

វិទ្យាសាស្ត្រនយោបាយបានបង្រៀនយើងអំពីបេះដូងនៃសាច់ឈាមរបស់យើង ប៉ុន្តែព្រះអម្ចាស់ក៏បានមានបន្ទូល ដោយសិទ្ធិអំណាចលើសនេះទៀតអំពី «ចិត្តរបស់មនុស្ស» ដែលជាចំណុចស្នូលខាងផ្លូវចិត្ត ខាងអារម្មណ៍ ខាងវិញ្ញាណ និងខាងសីលធម៌នៃជីវិតយើង។ ដោយសារចិត្តរបស់យើងមានសារៈសំខាន់យ៉ាងខ្លាំងចំពោះជីវិតរបស់យើង យើងត្រូវតែការពារចិត្តរបស់យើងឲ្យបានល្អ។ ដូចមានសេចក្តីចែងថា «ចូររក្សាចិត្ត ដោយអស់ពីព្យាយាម ដ្បិតអស់ទាំងផលនៃជីវិត សុទ្ធតែចេញពីក្នុងចិត្តមក» (សុភាសិត ៤:២៣)។ ការថែរក្សាចិត្តរបស់យើង នឹងជួយយើងឲ្យនិយាយស្តីបានត្រឹមត្រូវ (ខ.២៤) និងជំរុញយើងឲ្យចេះប្រើភ្នែកឲ្យបានសមរម្យ (ខ.២៥) ហើយជ្រើសរើសយកផ្លូវល្អបំផុត សម្រាប់ឲ្យជើងយើងដើរ (ខ.២៧)។ ទោះយើងស្ថិតក្នុងវ័យ ឬដំណាក់កាលណាក៏ដោយនៃជីវិតយើង ពេលណាយើងការពារចិត្តយើងបានល្អ ជីវិតយើងក៏រស់នៅបានល្អ ទំនាក់ទំនងរបស់យើងបានទទួលការការពារ ហើយយើងក៏នឹងបានថ្វាយព្រះកិត្តិនាមដល់ព្រះអង្គផងដែរ។—Arthur Jackson

តើរបៀបនៃការរស់នៅ និងទម្លាប់របស់អ្នក បានបង្ហាញអំពីលក្ខណៈនៃចិត្តរបស់អ្នកដូចម្តេចខ្លះ? បើអ្នកមិនបានអធិស្ឋានសូមព្រះអម្ចាស់កែប្រែចិត្តអ្នកទេ តើមានអ្វីរារាំងអ្នកមិនឲ្យអធិស្ឋានដូចនេះ នៅថ្ងៃនេះ?

ឱព្រះអម្ចាស់ សូមព្រះអង្គពិនិត្យមើលចិត្តទូលបង្គំ ហើយសម្អាតចិត្តទូលបង្គំឲ្យស្អាត។ ទូលបង្គំសូមប្រកាន់ខ្ជាប់តាមសេចក្តីពិតរបស់ព្រះអង្គក្នុងចិត្តទូលបង្គំ ដើម្បីកុំឲ្យទូលបង្គំធ្វើអំពើបាបទាស់ព្រះអង្គឡើយ។

Daily Manna 2026_Content Enhance.indd 278 17/11/25 1:47 in the afternoon

ដ្បិតតើអ្នកណាបានមើលងាយក្នុងថ្ងៃនៃការបន្តិចបន្តួចនោះ? (សាការី ៤:១០)

ការអស្ចារ្យតូចៗ

កិច្ចកម្មវិធីជួបជុំមួយ មុនថ្ងៃមង្គលការរបស់ខ្ញុំមកដល់ លោក ដេវ (Dave) ជាមិត្តភក្តិរបស់យើងដែលអៀនខ្មាសច្រើនកំពុងឈរនៅកៀនជ្រុងផ្ទះ កាន់វត្ថុមូលទ្រវែងដែលមានក្រដាសរុះចខ្ចប់ពីខាងក្រៅ។ នៅពេលគាត់ដល់វេនយកអំណោយរបស់គាត់មកជូនយើង គាត់ក៏បានកាន់វត្ថុនោះដើរមករកយើង។ ខ្ញុំនិងស្វាមីរបស់ខ្ញុំក៏បានបើកមើលអំណោយក្នុងកញ្ចប់ក្រដាសនោះ ហើយក៏បានឃើញបន្ទះឈើមួយសន្លឹកមានរាងមូលទ្រវែង ដែលចេញក្រយៅឈើដ៏ស្រស់ស្អាត ហើយមានអក្សរឆ្លាក់ដោយដៃពីលើថា «រឿងតូចមួយដែលព្រះអង្គធ្វើ គឺជាការអស្ចារ្យ»។ យើងក៏បានយកផ្លាកមួយនេះព្យួរនៅលើជញ្ជាំងផ្ទះយើងជាង៤៥ឆ្នាំហើយ ដោយវាបានរំឭកយើងម្តងហើយម្តងទៀតថា ព្រះអម្ចាស់នៅតែធ្វើការនៅក្នុងរឿងតូចៗ ដែលមានដូចជា ការបង់ថ្លៃទឹកភ្លើង ការផ្គត់ផ្គង់អាហារប្រចាំថ្ងៃ និងការប្រោសឲ្យជាពីជម្ងឺផ្តាសសាយជាដើម។ រឿងតូចៗទាំងនេះ សរុបចូលគ្នាមកបង្កើតបានជាកំណត់ត្រាដែលគួរឲ្យស្ងប់ស្ងែងនៃការផ្គត់ផ្គង់របស់ព្រះអង្គ។

មានពេលមួយ លោក សេរ៉ូបាបិល ជាអភិបាលនៃទឹកដីយូដា បានទទួលព្រះរាជសារស្រដៀងនេះផងដែរពីព្រះអម្ចាស់តាមរយៈហោរា សាការី ទាក់ទងនឹងការកសាងទីក្រុងយេរូសាឡិម និងព្រះវិហារឡើងវិញ។ បន្ទាប់ពីសាសន៍យូដាបានវិលត្រឡប់ពីការនិរទេសមកទីក្រុងយេរូសាឡិមវិញ រដូវកាលនៃភាពយឺតយ៉ាវក្នុងការសាងសង់ក៏បានចាប់ផ្តើម ហើយពួកគេមានការបាក់ទឹកចិត្ត។ ព្រះអម្ចាស់ក៏មានបន្ទូលប្រកាសថា «តើអ្នកណាបានមើលងាយក្នុងថ្ងៃនៃការបន្តិចបន្តួចនោះ?» (សាការី ៤:១០)។ ព្រះអង្គបានសម្រេចបំណងព្រះទ័យរបស់ព្រះអង្គតាមរយៈយើង ទោះយើងមានចំណុចខ្វះខាតយ៉ាងណាក៏ដោយ។ ព្រះអម្ចាស់ដ៏មានគ្រប់ចេស្តាបានមានបន្ទូលថា ព្រះអង្គសម្រេចបំណងព្រះទ័យមិនមែនដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ គឺដោយសារវិញ្ញាណរបស់ព្រះអង្គវិញ (ខ.៦)។

ពេលណាយើងមានអារម្មណ៍បាក់ទឹកចិត្ត ដោយសារយើងមើលឃើញព្រះអម្ចាស់ធ្វើតែកិច្ចការតូចៗនៅក្នុងយើង និងនៅជុំវិញយើង ចូរយើងចាំថា រឿងតូចៗដែលព្រះអង្គធ្វើ គឺជាការអស្ចារ្យ។ ព្រះអង្គប្រើរឿងតូចៗ ដើម្បីសម្រេចបំណងព្រះទ័យដ៏ធំប្រសើរ។—Elisa Morgan

តើអ្នកបានឃើញព្រះធ្វើការអស្ចារ្យតូចៗក្នុងជីវិតអ្នក នៅកន្លែងណាខ្លះ? តើព្រះអង្គបានប្រើរឿងតូចៗដើម្បីបំពេញតម្រូវការអ្នក និងមនុស្សនៅជុំវិញអ្នកយ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណសម្រាប់ការធ្វើការតូចៗក្នុងជីវិតទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យកត់សម្គាល់កិច្ចការទាំងអស់ ដែលព្រះអង្គធ្វើ!

Daily Manna 2026_Content Enhance.indd 279 17/11/25 1:47 in the afternoon

ចូរពាក់គ្រប់គ្រឿងសឹករបស់ព្រះ ដើម្បីឲ្យអាចនឹងឈរមាំមួន ទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស (អេភេសូរ ៦:១១)។

គ្រឿងសឹកដែលព្រះអង្គប្រទាន

ខ្ញុំ និងភរិយាខ្ញុំបានជិះកង់ចម្ងាយរាប់រយគីឡូម៉ែត្រជារៀងរាល់ឆ្នាំ ដោយធាក់កង់នៅតាមផ្លូវលំនៅទូទាំងតំបន់ភាគខាងលិចនៃរដ្ឋមីឈីហ្គិន។ ដើម្បីឲ្យយើងកាន់តែមានភាពងាយស្រួលក្នុងការធ្វើដំណើរផ្លូវឆ្ងាយដូចនេះ យើងបានដាក់ឧបករណ៍មួយចំនួនភ្ជាប់នឹងកង់របស់យើង។ ភរិយាខ្ញុំមានភ្លើងសម្រាប់បំភ្លឺផ្លូវខាងមុខ ហើយក៏មានភ្លើងខាងក្រោយ កុងទ័រវាស់ចម្ងាយផ្លូវ ព្រមទាំងមានមេសោសម្រាប់ចាក់កង់កុំឲ្យចោរលួច។ កង់ខ្ញុំក៏មានឧបករណ៍សម្រាប់ដាក់ដបទឹកផងដែរ។ តាមពិត យើងអាចជិះកង់តាមផ្លូវធ្វើដំណើររបស់យើង យ៉ាងជោគជ័យជារៀងរាល់ថ្ងៃ បានចម្ងាយរាប់រយគីឡូម៉ែត្រ ដោយគ្មានឧបករណ៍ជំនួយទាំងនោះក៏បាន។ ឧបករណ៍ទាំងនោះសុទ្ធតែមានប្រយោជន៍ ប៉ុន្តែយើងអាចជ្រើសរើសមិនប្រើពួកវាក៏បាន។

ក្នុងកណ្ឌគម្ពីរអេភេសូរ សាវ័ក ប៉ុល បានពិពណ៌នាអំពីឧបករណ៍មួយឈុតទៀត ជាគ្រឿងសឹកដែលយើងចាំបាច់ត្រូវប្រើដោយមិនអាចអាក់ខានឡើយ។ គាត់បានបង្រៀនថា យើងត្រូវតែបំពាក់ឧបករណ៍ទាំងនោះ ដើម្បីឲ្យយើងអាចរស់នៅដោយជោគជ័យ ក្នុងការរស់នៅដោយសេចក្តីជំនឿចំពោះព្រះយេស៊ូវ។ ជីវិតរបស់យើងមិនមែនជាការធ្វើដំណើរដ៏ងាយស្រួលនោះឡើយ។ យើងកំពុងរស់នៅក្នុងសង្គ្រាមខាងវិញ្ញាណ ដែលក្នុងនោះយើងត្រូវ «ទាស់នឹងឧបាយកលទាំងអម្បាលម៉ានរបស់អារក្ស» (៦:១១) ហេតុនេះហើយ យើងត្រូវតែបំពាក់គ្រឿងសឹកខាងវិញ្ញាណឲ្យបានគ្រប់គ្រាន់ជារៀងរាល់ថ្ងៃ។

បើសិនជាយើងមិនបានប្រើប្រាជ្ញា ដែលមានក្នុងព្រះគម្ពីរទេ យើងងាយនឹងប្រព្រឹត្តខុស។ បើសិនជាយើងមិនអនុញ្ញាតឲ្យព្រះយេស៊ូវជួយយើងឲ្យរស់នៅតាមសេចក្តីពិតរបស់ព្រះអង្គទេ យើងនឹងចាញ់ការបោកបញ្ឆោតមិនខាន (ខ.១៤)។ បើគ្មាន «ដំណឹងល្អ» ទេ យើងក៏គ្មាន «សេចក្តីសុខសាន្ត និងសន្តិភាពឡើយ» (ខ.១៥)។ បើគ្មាន «សេចក្តីជំនឿ» ធ្វើជាខែលការពារយើងទេ យើងនឹងមានការសង្ស័យចំពោះព្រះអង្គ (ខ.១៦)។ «សេចក្តីសង្គ្រោះ» របស់យើង និងព្រះវិញ្ញាណបរិសុទ្ធបានធ្វើជាយុថ្កា ដែលជួយយើងឲ្យរស់នៅបានល្អថ្វាយព្រះ (ខ.១៧)។ នេះជាគ្រឿងសឹកដែលយើងមិនអាចខ្វះបាន។

ការការពារមានភាពចាំបាច់យ៉ាងខ្លាំង ដើម្បីឲ្យយើងរួចផុតពីគ្រោះថ្នាក់ក្នុងការធ្វើដំណើរនៃជីវិត។ យើងទទួលបានការការពារនោះ នៅពេលណាយើងបំពាក់គ្រឿងសឹក ដែលព្រះបានប្រទាន។—Dave Branon

តើការពាក់គ្រឿងសឹករបស់ព្រះ មានអត្ថន័យយ៉ាងណាចំពោះអ្នក? តើអ្នកកំពុងប្រឈមមុខដាក់ស្ថានភាពអ្វីខ្លះ ដែលអ្នកត្រូវការគ្រឿងសឹករបស់ព្រះអង្គបំផុត?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានរំឭកទូលបង្គំក្នុងព្រះគម្ពីរអំពីរបៀបដែលទូលបង្គំអាចឈរតតាំងនឹងការវាយប្រហាររបស់សាតាំង។

Daily Manna 2026_Content Enhance.indd 280 17/11/25 1:47 in the afternoon

តែឯផលផ្លែនៃព្រះវិញ្ញាណវិញ នោះគឺសេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត គ្មានក្រឹត្យវិន័យណាទាស់នឹងសេចក្តីយ៉ាងនោះទេ (កាឡាទី ៥:២២-២៣)។

ឆ្លុះបញ្ចាំងឲ្យគេបានស្គាល់ចរិតលក្ខណៈរបស់ព្រះអង្គ

បន្ទាប់ពីលោក ស្កត់ (Scott) ជាពលបាលឯកក្នុងកងទ័ពប្រទេសអង់គ្លេស ត្រូវបានគេបញ្ជូនទៅប្រទេសអាហ្វហ្គានីស្ថាន គាត់បានជួបបញ្ហាប្រឈមជាច្រើន ដែលបានធ្វើឲ្យគាត់ធ្លាក់ទឹកចិត្តយ៉ាងខ្លាំង។ គាត់ចាំថា កាលនោះ គាត់បានធ្លាក់ចូលក្នុងភាពងងឹត ប៉ុន្តែនៅពេលដែលគាត់បានឮគេចែកចាយអំពីព្រះយេស៊ូវ គាត់ក៏បានចាប់ផ្តើមដើរតាមព្រះអង្គ ហើយជីវិតគាត់មានការផ្លាស់ប្តូរយ៉ាងខ្លាំង។ សព្វថ្ងៃនេះ គាត់បានព្យាយាមស្វែងរកឱកាសចែកចាយ អំពីសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ទដល់អ្នកដទៃ ជាពិសេសដល់អតីតយុទ្ធជន ដែលគាត់បានចូលរួមការប្រកួតកីឡាជាមួយក្នុងព្រឹត្តិការណ៍អន្តរជាតិសម្រាប់អតីតយុទ្ធជនដែលពិការ ឬធ្លាប់មានរបួស។

សម្រាប់លោក ស្កត់ ការអានព្រះគម្ពីរ ការអធិស្ឋាន និងការស្តាប់បទចម្រៀងថ្វាយបង្គំបានជួយគាត់ឲ្យមានភាពរឹងមាំមុនពេលគាត់ចូលរួមប្រកួតកីឡានោះ។ បន្ទាប់មក ព្រះអម្ចាស់ក៏បានជួយគាត់ឲ្យបង្ហាញចេញនូវចរិតលក្ខណៈរបស់ព្រះយេស៊ូវ និងបង្ហាញសេចក្តីសប្បុរស ភាពសុំឡូត និងព្រះគុណដល់អតីតយុទ្ធជនដទៃទៀតដែលកំពុងចូលរួមប្រកួតនៅទីនោះ។

ទីបន្ទាល់របស់លោក ស្កត់ បានធ្វើឲ្យខ្ញុំនឹកចាំអំពីផលផ្លែនៃព្រះវិញ្ញាណ ដែលសាវ័ក ប៉ុល បានរៀបរាប់ក្នុងសំបុត្រដែលគាត់បានសរសើរធ្វើពួកជំនុំនៅទីក្រុងកាឡាទី។ កាលនោះ ពួកគេកំពុងទទួលឥទ្ធិពលរបស់ពួកគ្រូខុសឆ្គង បានជាគាត់ព្យាយាមលើកទឹកចិត្តពួកគេឲ្យបន្តស្មោះត្រង់ចំពោះព្រះ និងព្រះគុណរបស់ព្រះអង្គដោយអនុញ្ញាតឲ្យព្រះវិញ្ញាណដឹកនាំជីវិតរបស់ពួកគេ (កាឡាទី ៥:១៨)។ ដោយសារការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធ ពួកគេនឹងបានបង្កើតផលផ្លែខាងវិញ្ញាណ ដែលមានដូចជា «សេចក្តីស្រឡាញ់ អំណរអរ មេត្រីភាព អត់ធ្មត់ សុភាព សប្បុរស ស្មោះត្រង់ ស្លូតបូត ហើយដឹងខ្នាត» (ខ.២២-២៣)។

បើសិនជាយើងមានព្រះវិញ្ញាណរបស់ព្រះគង់នៅក្នុងយើង យើងក៏នឹងបង្កើតផលផ្លែនៃព្រះវិញ្ញាណ ជាពិសេសគឺសេចក្តីស្រឡាញ់ផងដែរ។ យើងក៏នឹងអាចបង្ហាញចេញនូវចិត្តសុភាព និងសប្បុរសដល់មនុស្សនៅជុំវិញយើង។—Amy Boucher Pye

តើព្រះអម្ចាស់អាចជួយអ្នកបង្កើតផលផ្លែនៃព្រះវិញ្ញាណយ៉ាងដូចម្តេចខ្លះ? តើធ្វើដូចម្តេចឲ្យអ្នកអាចបន្តរស់នៅស្របតាមបំណងព្រះទ័យព្រះអង្គ?

ឱព្រះដែលប្រទានជីវិត ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានព្រះវិញ្ញាណបរិសុទ្ធ។ សូមព្រះអង្គជួយទូលបង្គំឲ្យបង្កើតផលផ្លែនៃព្រះវិញ្ញាណ ដើម្បីឲ្យអ្នកដទៃបានឃើញ ហើយសរសើរតម្កើងព្រះអង្គផងដែរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ១៤-១៦ និងអេភេសូរ ៥:១-១៦

ព្រះយេហូវ៉ាក៏គង់នៅខាងយើងវាល់គ្នាដែរ កុំឲ្យខ្លាចគេឡើយ (ជនគណនា ១៤:៩)។

ទទួលយកកិច្ចការថ្មី ដោយជំនឿ

មានពេលមួយគេសួរខ្ញុំថា តើខ្ញុំចង់ទទួលយកការទទួលខុសត្រូវថ្មីនៅកន្លែងធ្វើការទេ? ពេលនោះ ខ្ញុំចង់និយាយថា ទេ។ ខ្ញុំបានគិតអំពីបញ្ហាប្រឈម និងមានអារម្មណ៍ថា ខ្ញុំមិនមានសមត្ថភាពគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ប៉ុន្តែ នៅពេលដែលខ្ញុំអធិស្ឋាន និងស្វែងរកការដឹកនាំពីព្រះគម្ពីរ និងអ្នកជឿដទៃទៀត ខ្ញុំក៏បានដឹងថា ព្រះអម្ចាស់កំពុងត្រាស់ហៅខ្ញុំឲ្យទទួលយកការទទួលខុសត្រូវថ្មីនោះ។ តាមរយៈព្រះគម្ពីរ ខ្ញុំក៏ទទួលបានការធានាថា ព្រះអង្គនឹងជួយខ្ញុំ។ ដូចនេះ ខ្ញុំក៏បានទទួលយកតួនាទីថ្មីនោះ តែនៅមានការភ័យខ្លាចខ្លះៗ។

បញ្ហារបស់ខ្ញុំបានធ្វើឲ្យខ្ញុំនឹកចាំអំពីពួកអ៊ីស្រាអែល និងពួកស៊ើបការ១០នាក់ ដែលមានការរួញារនៅក្នុងការចូលកាន់កាប់ទឹកដីកាណាន (ជនគណនា ១៣:២៧-២៩, ៣១-៣៣ ១៤:១-៤)។ ពួកគេក៏បានមើលឃើញការលំបាក ហើយឆ្ងល់ផងដែរថា តើពួកគេអាចប្រយុទ្ធឈ្នះពួកមនុស្សខ្លាំងពូកែក្នុងទឹកដីនោះ ហើយចាប់យកទីក្រុងដែលមានកំផែងការពាររឹងមាំដោយរបៀបណា? ពួកស៊ើបការទាំងនោះបានរាយការណ៍ថា «យើងមើលទៅខ្លួនយើងដូចជាកណ្តូប ទោះបើនៅភ្នែកគេក៏ដូច្នោះដែរ» (១៣:៣៣) ហើយពួកអ៊ីស្រាអែលក៏បានអ៊ូរទាំថា «តើហេតុអ្វីបានជាព្រះយេហូវ៉ាទ្រង់នាំយើងមកក្នុងកន្លែងនេះ ឲ្យត្រូវស្លាប់ដោយដាវដូច្នេះ?» (១៤:៣)។

ក្នុងចំណោមអ្នកស៊ើបការទាំងនោះមានតែលោក កាលែប និងលោក យ៉ូស្វេ ទេដែលបាននឹកចាំថា ព្រះអម្ចាស់បានសន្យាថា នឹងប្រទានទឹកដីកាណានដល់រាស្ត្រព្រះអង្គ (លោកុប្បត្តិ ១៧:៨ និងជនគណនា ១៣:២)។ ពួកគេមានទំនុកចិត្ត ដោយផ្អែកទៅលើព្រះបន្ទូលសន្យារបស់ព្រះអង្គដោយដឹងថា ព្រះអង្គនឹងគង់នៅជាមួយ ហើយនឹងជួយពួកគេ។ ពួកគេប្រឈមមុខដាក់ការលំបាកដោយព្រះចេស្តា ការការពារ និងការផ្គត់ផ្គង់របស់ព្រះអង្គមិនមែនដោយពឹងអាងសមត្ថភាពខ្លួនឯងនោះទេ (ជនគណនា ១៤:៦-៩)។

កិច្ចការថ្មីដែលព្រះអង្គបានប្រទានខ្ញុំនៅពេលនោះ មិនមានភាពងាយស្រួលទេ ប៉ុន្តែខ្ញុំអាចធ្វើវាបាន ដោយពឹងអាងជំនួយមកពីព្រះអង្គ។ យើងមិនតែងតែមានភាពងាយស្រួលនៅក្នុងកិច្ចការដែលព្រះអង្គប្រទានឲ្យយើងធ្វើទេ ប៉ុន្តែយើងអាចប្រឈមមុខដាក់ការលំបាកដូចលោក កាលែប និងលោក យ៉ូស្វេ ផងដែរ ដោយដឹងថា «ព្រះអម្ចាស់គង់នៅជាមួយយើង» (ខ.៩)។—Karen Huang

តើនៅពេលណាអ្នកមានអារម្មណ៍ថា អ្នកមិនមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើកិច្ចការដែលព្រះអង្គបានប្រទានអ្នក? តើគំរូរបស់លោក កាលែប និងលោក យ៉ូស្វេ បានលើកទឹកចិត្តអ្នកដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យដើរតាមព្រះអង្គអស់ពីចិត្ត។

Daily Manna 2026_Content Enhance.indd 282 17/11/25 1:47 in the afternoon

កាលគេបានជេរប្រមាថដល់ទ្រង់ នោះទ្រង់មិនបានជេរតបវិញទេ ខណៈដែលទ្រង់រងទុក្ខ នោះក៏មិនបានគំហកកំហែងដល់គេដែរ គឺបានប្រគល់ព្រះអង្គទ្រង់ទៅព្រះ ដែលជំនុំជំរះដោយសុចរិតវិញ (១ពេត្រុស ២:២៣)។

ការឆ្លើយតប តាមគំរូព្រះគ្រីស្ទ

កាលលោក ចច (George) កំពុងធ្វើការងារសំណង់នៅក្រោមកម្តៅថ្ងៃក្តៅនៅរដ្ឋឃ្លរីដាយណា មានមនុស្សម្នាក់ជាអ្នកជិតខាងបានដើរចូលទីធ្លារបស់កន្លែងដែលគាត់កំពុងធ្វើការ។ អ្នកជិតខាងនោះក៏បានចាប់ផ្តើមជេរប្រទេចផ្តាសាទាំងកំហឹង ហើយក៏បាននិយាយរិះគន់មកលើការសាងសង់នោះ និងអំពីរបៀបដែលជាងកំពុងសាងសង់។ លោក ចច ក៏បានទទួលយកការវាយប្រហារដោយពាក្យសម្តីដោយមិនបានឆ្លើយតប ទាល់តែអ្នកជិតខាងដែលកំពុងមានកំហឹងនោះ ក៏បានឈប់ស្រែកដាក់គាត់ទៀត។ បន្ទាប់មក គាត់ក៏បានឆ្លើយតបដោយចិត្តសប្បុរស ដោយយល់អំពីការលំបាក ដែលបុរសនោះកំពុងមានក្នុងចិត្ត។ ភ្លាមៗនោះ អ្នកជិតខាងដែលមានកំហឹងនោះ ក៏បានប្រែជាមានទឹកមុខស្រទន់វិញ ហើយក៏បានឈ្ងោកមុខ រួចនិយាយថា «ឲ្យខ្ញុំសុំទោសចំពោះពាក្យសម្តីដែលខ្ញុំបាននិយាយមកលើអ្នក»។ នៅចំពោះមុខនៃការវាយប្រហារ លោក ចច បានបង្ហាញចេញសេចក្តីសប្បុរស ដែលបានរម្ងាប់កំហឹងរបស់អ្នកជិតខាងនោះ។

មានពេលដែលយើងចង់វាយបកទៅគេដោយសងទៅគេវិញនូវការវាយប្រហារ ឬការជេរប្រមាថដែលគេបានធ្វើមកលើយើង។ ប៉ុន្តែ គំរូរបស់លោក ចច ដែលបានបង្ហាញចេញនូវចិត្តសប្បុរស បានធ្វើឲ្យខ្ញុំនឹកចាំអំពីពេលដែលព្រះយេស៊ូវបានទទួលទោសរបស់បាបយើង។ គឺដូចមានសេចក្តីចែងមកថា «កាលគេបានជេរប្រមាថដល់ទ្រង់ នោះទ្រង់មិនបានជេរតបវិញទេ ខណៈដែលទ្រង់រងទុក្ខ នោះក៏មិនបានគំហកកំហែងដល់គេដែរ គឺបានប្រគល់ព្រះអង្គទ្រង់ទៅព្រះ ដែលជំនុំជំរះដោយសុចរិតវិញ» (១ពេត្រុស ២:២៣)។

យើងរាល់គ្នាសុទ្ធតែអាចជួបពេលដែលត្រូវគេយល់ច្រឡំ និយាយបង្ខូច ឬវាយប្រហារដោយពាក្យសម្តី។ យើងប្រហែលជាចង់តបតទៅគេវិញ ដូចដែលគេបានធ្វើមកលើយើង ប៉ុន្តែព្រះទ័យរបស់ព្រះយេស៊ូវបានត្រាស់ហៅយើង ឲ្យមានចិត្តសុភាព ដើម្បីឲ្យយើងដេញតាមសន្តិភាព និងបង្ហាញចេញនូវការយោគយល់។ ប្រហែលជាព្រះអង្គអាចប្រើយើងឲ្យបង្ហាញចេញនូវសេចក្តីសប្បុរស ដើម្បីធ្វើជាព្រះពរដល់នរណាម្នាក់ ដែលកំពុងជួបការលំបាក នៅថ្ងៃនេះផងដែរ។—Bill Crowder

តើមានកត្តាអ្វីខ្លះ ដែលធ្វើឲ្យយើងងាយនឹងវាយបកទៅរកអ្នកដទៃ ដែលកំពុងវាយប្រហារដោយពាក្យសម្តី? តើធ្វើដូចម្តេច ឲ្យអ្នកមានចិត្ត ចង់បង្ហាញសេចក្តីសប្បុរសដល់អ្នកដែលកំពុងធ្វើអាក្រក់មកលើអ្នក?

ឱព្រះវរបិតា ដែលតែងយកព្រះទ័យទុកដាក់ចំពោះទូលបង្គំ សូមព្រះអង្គជួយទូលបង្គំឲ្យរកឃើញកម្ទាំងព្រះគុណ និងប្រាជ្ញារបស់ព្រះអង្គ ដើម្បីបង្ហាញអ្នកដទៃឲ្យស្គាល់ព្រះទ័យព្រះយេស៊ូវ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ២០-២២ និងអេភេសូរ ៦

គួរឲ្យពួកអ្នកដែលព្រះយេហូវ៉ាបានប្រោសលោះបានថាដូច្នេះដែរ (ទំនុកតម្កើង ១០៧:២)។

ព្រះអង្គប្រើទីបន្ទាល់របស់យើង

ថ្ងៃ មួយ ខ្ញុំបានបើកមើលប្រអប់អនុស្សាវរីយមួយ ហើយក៏បានយកក្រឡះអាវតូចមួយធ្វើពីប្រាក់ ដែលមានរូបរាង និងទំហំប៉ុនជើងរបស់កូនក្នុងផ្ទៃម្តាយអាយុ១០សប្តាហ៍។ ខ្ញុំក៏បានអង្អែលក្រឡះដែលមានរូបរាងដូចជើងទារកនោះ ដោយនឹកចាំអំពីការលូតកូនក្នុងអំឡុងពេលខ្ញុំមានផ្ទៃពោះលើកដំបូង និងនឹកចាំអ្នកដែលបាននិយាយថា ខ្ញុំ «មានសំណាង» ដែលបានរលូតកូននៅពេលដែលកូននោះនៅតូចនៅឡើយ។ ខ្ញុំបានសោកសង្រេង ដោយដឹងថា កូនរបស់ខ្ញុំពិតជាមានជើង ក៏ដូចជាមានបេះដូងដែលធ្លាប់លោតនៅក្នុងផ្ទៃរបស់ខ្ញុំ។ ខ្ញុំក៏បានអរព្រះគុណព្រះ ដែលបានរំដោះខ្ញុំឲ្យរួចផុតពីជំងឺធ្លាក់ទឹកចិត្ត និងបានប្រើទីបន្ទាល់ខ្ញុំ ដើម្បីកម្សាន្តចិត្តអ្នកដទៃ ដែលកំពុងសោកសង្រេង បន្ទាប់បានបាត់បង់កូនជាទីស្រឡាញ់។ ជាង២ទសវត្សរ៍បន្ទាប់ពីខ្ញុំរលូតកូន ខ្ញុំ និងស្វាមីខ្ញុំបានដាក់ឈ្មោះឲ្យកូននោះថា ខាយ(Kai) ដែលក្នុងភាសាខ្លះ ឈ្មោះនេះមានន័យថា «អរសប្បាយ»។ ទោះខ្ញុំនៅតែមានការឈឺចាប់ក្នុងចិត្ត ដោយសារការបាត់បង់នេះ ខ្ញុំអរព្រះគុណព្រះអង្គ ដែលបានប្រោសចិត្តខ្ញុំឲ្យជា ហើយប្រើទីបន្ទាល់ខ្ញុំ ដើម្បីជួយលើកទឹកចិត្តអ្នកដទៃ។

អ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើង ជំពូក១០៧ បានបង្ហាញការអរសប្បាយនឹងចរិតលក្ខណៈរបស់ព្រះ ហើយក៏បានប្រៀងសរសើរព្រះអង្គថា «ឱសូមអរព្រះគុណដល់ព្រះយេហូវ៉ា ដ្បិតទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច» (ខ.១)។ ព្រះអង្គបានជំរុញ «ពួកដែលព្រះអង្គបានប្រោសលោះ» ឲ្យចែកចាយទីបន្ទាល់របស់ពួកគេដល់អ្នកដទៃផងដែរ (ខ.២) ហើយសរសើរដល់ព្រះអង្គ «ដោយព្រោះសេចក្តីសប្បុរសរបស់ទ្រង់ ហើយដោយព្រោះអស់ទាំងការអស្ចារ្យ ដែលទ្រង់បានប្រោសដល់មនុស្សជាតិ» (ខ.៨)។ ព្រះអង្គបានប្រទានសេចក្តីសង្ឃឹមដោយសន្យាថា មានតែព្រះអង្គទេ ដែល «ប្រោសព្រលឹងដែលសង្វាតឲ្យបានស្កប់ស្កល់ ហើយទ្រង់ចំអែតព្រលឹងដែលស្រេកឃ្លាន ដោយសេចក្តីល្អ» (ខ.៩)។

គ្មាននរណាអាចជៀសផុតពីការសោកសង្រេង ឬទុក្ខលំបាកឡើយ សូម្បីតែអ្នកដែលបានទទួលការប្រោសលោះ ដែលព្រះគ្រីស្ទបានប្រទាន តាមរយៈការលះបង់របស់ព្រះអង្គនៅលើឈើឆ្កាងក៏ដោយ។ ទោះជាយ៉ាងណាក៏ដោយ យើងអាចដកពិសោធន៍ជាមួយនឹងសេចក្តីមេត្តារបស់ព្រះ ខណៈពេលដែលព្រះអង្គប្រើទីបន្ទាល់របស់យើង ដើម្បីនាំអ្នកដទៃឲ្យងាកទៅរកសេចក្តីស្រឡាញ់ដ៏ប្រោសលោះរបស់ព្រះអង្គ។

—Xochitl Dixon

តើព្រះអម្ចាស់បានប្រោសចិត្តដែលខ្ទេចខ្ទាំរបស់អ្នក ដោយរបៀបណា? តើព្រះអង្គបានប្រើរឿងរបស់អ្នកដទៃ ដើម្បីកម្សាន្តចិត្តអ្នកដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការប្រោសទូលបង្គំឲ្យជា ហើយប្រើទីបន្ទាល់របស់ទូលបង្គំ ដើម្បីនាំអ្នកដទៃឲ្យងាកទៅរកសេចក្តីស្រឡាញ់ដ៏ប្រោសលោះរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ២៣-២៥ និងកីលីត ១

តែព្រះយេហូវ៉ាទ្រង់បានយកខ្ញុំចេញពីការឃ្វាលហ្វូងចៀម ក៏បានបង្គាប់ខ្ញុំថា ចូរទៅទាយដល់អ៊ីស្រាអែល ជារាស្ត្រអញចុះ (អេម៉ុស ៧:១៥)។

ព្រះអង្គទតឃើញយើង

នៅរដ្ឋមីឈីហ្គិន មានដើមឈើចំនួន១៤ពាន់លានដើម ដែលភាគច្រើនមានលក្ខណៈជាដើមឈើធម្មតា។ ប៉ុន្តែ រដ្ឋមីឈីហ្គិនបានធ្វើ «កម្មវិធីរុករកដើមឈើធំ» ប្រចាំឆ្នាំ ជាការប្រកួត ដើម្បីស្វែងរកដើមឈើដែលចាស់ជាងគេ និងធំជាងគេ គឺដើមឈើដែលអាចឲ្យគេទទួលស្គាល់ថា ជាចំណុចសម្គាល់តំបន់ ដែលនៅមានជីវិតរស់។ ការប្រកួតនេះលើកតម្កើងដើមឈើធម្មតាឲ្យឡើងដល់កម្រិតមួយទៀតបានសេចក្តីថា ក្នុងព្រៃនីមួយៗ អាចមានដើមឈើមួយដើម ដែលនឹងទទួលជ័យលាភី ហើយជាដើមឈើដែលកំពុងរង់ចាំឲ្យគេកត់សម្គាល់។

ព្រះអម្ចាស់តែងតែកត់សម្គាល់មនុស្សសាមញ្ញ គឺខុសពីមនុស្សភាគច្រើន។ ព្រះអង្គយកព្រះទ័យទុកដាក់ចំពោះការអ្វី និងចំពោះមនុស្សដែលអ្នកដទៃមើលរំលង។ ព្រះអង្គបានចាត់មនុស្សសាមញ្ញម្នាក់ឈ្មោះ អេម៉ុស ឲ្យធ្វើដំណើរទៅទឹកដីអ៊ីស្រាអែលក្នុងអំឡុងរាជ្យរបស់ស្តេច យេរ៉ូបោម។ ហោរា អេម៉ុស បានលើកទឹកចិត្តរាស្ត្ររបស់ព្រះអង្គឲ្យងាកចេញពីការអាក្រក់ ហើយស្វែងរកយុត្តិធម៌ ប៉ុន្តែត្រូវគេស្តីបន្ទោសឲ្យគាត់ ហើយប្រាប់គាត់ឲ្យនៅស្ងៀម។ គេបាននិយាយប្រាប់គាត់ក្នុងន័យចំអកថា «ឱអ្នកមើលឆុតអើយ ចូរត់ទៅឯស្រុកយូដា ហើយរកស៊ីដោយទាយនៅស្រុកនោះវិញចុះ» (អេម៉ុស ៧:១២)។ ហោរា អេម៉ុស ក៏បានឆ្លើយតបថា «ខ្ញុំពីដើមមិនមែនជាហោរាទេ ក៏មិនមែនជាកូនរបស់ហោរាដែរ គឺជាអ្នកគង្វាលសត្វ ហើយជាអ្នកបេះផ្លែឧទុម្ពរវិញ។ តែព្រះយេហូវ៉ាទ្រង់បានយកខ្ញុំចេញពីការឃ្វាលហ្វូងចៀម ក៏បានបង្គាប់ខ្ញុំថា ចូរទៅទាយដល់អ៊ីស្រាអែល ជារាស្ត្រអញចុះ» (ខ.១៤-១៥)។

ព្រះអម្ចាស់បានស្គាល់ និងបានកត់សម្គាល់លោក អេម៉ុស កាលគាត់កំពុងរស់នៅជាអ្នកគង្វាលដ៏សាមញ្ញ ដែលកំពុងថែទាំហ្វូងចៀម និងចំការ។ ប៉ុន្មានសតវត្សរ៍ក្រោយមក ព្រះយេស៊ូវក៏បានកត់សម្គាល់ និងត្រាស់ហៅលោក ណាថាណែល (យ៉ូហាន ១:៤៨) និងលោក សាខេ (លូកា ១៩:៤-៥) នៅក្បែរដើមល្វា និងដើមឧទុម្ពរ។ ទោះយើងមានអារម្មណ៍ថា យើងមានភាពតូចទៀបប៉ុណ្ណាក៏ដោយ ក៏ព្រះអង្គនៅតែទតមើលយើង ស្រឡាញ់យើង ហើយប្រើយើង ដើម្បីបំពេញគោលបំណងរបស់ព្រះអង្គ។—Karen Pimpo

ហេតុអ្វី នៅពេលខ្លះអ្នកពិបាកជឿថា ព្រះទ្រង់ទតឃើញតម្លៃរបស់អ្នក? តើការដែលព្រះអង្គទតឃើញតម្លៃរបស់អ្នក បានបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គយ៉ាងណាខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានស្រឡាញ់ទូលបង្គំ នៅពេលដែលអ្នកដទៃមើលរំលងទូលបង្គំ។

Daily Manna 2026_Content Enhance.indd 285 17/11/25 1:47 in the afternoon

មិនមែនដោយឥទ្ធិឫទ្ធិ ឬដោយអំណាចទេ គឺដោយសារវិញ្ញាណរបស់អញវិញ (សាការី ៤:៦)។

មិនមែនដោយអំណាចរបស់មនុស្ស

មានពេលមួយ ឡានរបស់លោក អេន្ដ្រូ (Andrew) បានឈប់ ហើយពួកអ្នកយាមក៏បានដើរមករកឡានគាត់។ គាត់ក៏បានអធិស្ឋានដូចសព្វមួយដងថា «ឱព្រះអង្គអើយ កាលព្រះអង្គយាងមកយកកំណើតជាមនុស្ស ព្រះអង្គបានប្រោសមនុស្សខ្វាក់ឲ្យមើលឃើញ។ ឥឡូវនេះ សូមព្រះអង្គបាំងភ្នែករបស់ពួកគេមិនឲ្យមើលឃើញព្រះគម្ពីរនៅក្នុងឡានទូលបង្គំឡើយ»។ ពួកអ្នកយាមក៏បានឆែកឆេរឡានរបស់គាត់ ដោយមិនបាននិយាយអ្វីសោះអំពីព្រះគម្ពីរដែលគាត់បានលាក់ក្នុងឥវ៉ាន់។ លោក អេន្ដ្រូ ក៏បានឆ្លងកាត់ព្រំដែនដោយជោគជ័យ ដោយនាំព្រះគម្ពីរជាច្រើនក្បាលទៅកាន់មនុស្សដែលមិនទាន់មាន។

លោក អេន្ដ្រូ វ៉ាន ដឺ ប៊ីជ (Andrew van der Bijl) ឬប្រាដឺ អេន្ដ្រូ បានពឹងផ្អែកលើព្រះចេស្ដារបស់ព្រះ ដើម្បីធ្វើកិច្ចការដែលគាត់ហាក់ដូចជាមិនអាចធ្វើបានតាមការគ្រាស់ហៅរបស់ព្រះអង្គ ដោយដឹកជញ្ជូនព្រះគម្ពីរ ទៅកាន់ប្រទេសដែលបានហាមមិនឲ្យប្រជាជនជឿព្រះគ្រីស្ទ។ គាត់មានប្រសាសន៍ថា «ខ្ញុំគ្រាន់តែជាមនុស្សសាមញ្ញម្នាក់»។ ត្រង់ចំណុចនេះ គាត់កំពុងនិយាយសង្កត់ធ្ងន់អំពីការអប់រំតិចតួច និងការខ្វះខាតថវិកា។ ប៉ុន្តែ គាត់មានប្រសាសន៍ទៀតថា «អ្វីដែលខ្ញុំបានធ្វើ នរណាក៏អាចធ្វើបានដែរ»។ សព្វថ្ងៃនេះ អង្គការទ្វារបើកចំហអន្តរជាតិ ដែលគាត់បានបង្កើត បានបម្រើអ្នកជឿព្រះយេស៊ូវនៅទូទាំងពិភពលោក ដែលកំពុងទទួលរងការបៀតបៀន។

លោក ស្សួបាបិល ជាអភិបាលនៃស្រុកយូដាបានប្រឈមមុខដាក់កិច្ចការដែលហាក់ដូចជាមិនអាចធ្វើបានជាកិច្ចការសាងសង់ព្រះវិហារឡើងវិញ បន្ទាប់ពីសាសន៍យូដាបានវិលត្រឡប់ពីការនិរទេស។ ពេលនោះ គាត់មានការបាក់ទឹកចិត្ត ប៉ុន្តែព្រះអម្ចាស់បានក្រើនរំឭកគាត់មិនឲ្យពឹងផ្អែកលើសមត្ថភាព ឬកម្លាំងរបស់មនុស្សឡើយ តែឲ្យពឹងផ្អែកលើព្រះវិញ្ញាណរបស់ព្រះអង្គវិញ (សាការី ៤:៦)។ ព្រះអង្គបានលើកទឹកចិត្តគាត់តាមរយៈការបើកសម្ដែងដែលព្រះអង្គបានប្រទាន តាមរយៈហោរា សាការី អំពីជើងចង្កៀងដែលបានទទួលការចាក់បំពេញដោយប្រេងអូលីវចេញពីដើមអូលីវដែលនៅជិតខាង (ខ.២-៣)។ ចង្កៀងទាំងនោះអាចបន្តឆេះ ដោយការចាក់ប្រេងបំពេញជាប់ជានិច្ច នោះលោក ស្សួបាបិល និងពួកអ៊ីស្រាអែល ក៏អាចធ្វើកិច្ចការថ្វាយព្រះ ដោយពឹងផ្អែកលើការប្រទានព្រះចេស្ដាផងដែរ។

ខណៈពេលដែលយើងពឹងផ្អែកលើព្រះ ចូរយើងទុកចិត្តព្រះអង្គ ហើយធ្វើកិច្ចការអ្វីដែលព្រះអង្គបានគ្រាស់ហៅឲ្យយើងធ្វើ។—Karen Huang

តើអ្នកអាចពឹងផ្អែកលើព្រះវិញ្ញាណរបស់ព្រះក្នុងការបម្រើព្រះអង្គ ដូចម្ដេចខ្លះ? តើការបើកសម្ដែងអំពីដើមអូលីវ ដែលផ្គត់ផ្គង់ប្រេងដល់ចង្កៀង បានលើកទឹកចិត្តអ្នកដូចម្ដេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យនឹកចាំថា ទូលបង្គំត្រូវពឹងផ្អែកលើព្រះចេស្ដារបស់ព្រះអង្គក្នុងការធ្វើកិច្ចការដែលព្រះអង្គបានគ្រាស់ហៅឲ្យទូលបង្គំធ្វើ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ២៨-២៩ និងកិច្ចការ ៣

ឯមនុស្សសុចរិត គេនឹងលូតលាស់ឡើង ដូចជាដើមលម៉ើ ... កាលណាចាស់ហើយ នោះគេនឹងនៅតែកើតផល (ទំនុកតម្កើង ៩២:១២-១៤)។

រត់ប្រណាំងថ្វាយព្រះយេស៊ូវ

នៅពេលណាគេគិតអំពីការរត់ប្រណាំងចម្ងាយ១០០ម៉ែត្រ ភាគច្រើនគេប្រហែលនឹកឃើញលោក យូសិន បុល (Usain Bolt) ដែលជាម្ចាស់ឯកត្តកម្មពិភពលោកក្នុងការរត់ប្រណាំងប្រភេទនេះ ក្នុងពេលបច្ចុប្បន្ន។ ប៉ុន្តែ យើងមិនអាចភ្លេច អ្នកស្រី ជូលា ហឺរីខេន ហកឃិន (Julia "Hurricane" Hawkins) បានទេ។ កាលពីឆ្នាំ២០២១ អ្នកស្រី ជូលា បានរត់ទៅដល់ទីផ្តាច់ព្រាត់មុន កីឡាការត់ប្រណាំងផ្សេងទៀត ដោយបានឈ្នះការរត់ប្រណាំងចម្ងាយ១០០ម៉ែត្រ ក្នុងការប្រកួតកីឡាសម្រាប់មនុស្សចាស់នៅវដ្ឋលូវីស៊ីអាណា។ គាត់បានរត់យឺតជាងលោក បុល ដែលបានចំណាយតែ ៩.៥៨ វិនាទី ក្នុងការរត់ទៅដល់ទី ខណៈពេលដែលគាត់ចំណាយពេល៦០វិនាទី ប៉ុន្តែគាត់មានអាយុ១០៥ឆ្នាំហើយ។

គេមានរឿងជាច្រើនដែលត្រូវជជែកគ្នាអំពីស្ត្រីដែលនៅតែបន្តរត់ប្រណាំងចម្ងាយខ្លីក្នុងវ័យចំណាស់ដូចនេះ។ ហើយគេក៏មានរឿងជាច្រើនដែលត្រូវជជែកគ្នាអំពីអ្នកជឿព្រះយេស៊ូវ ដែលនៅតែបន្តរត់ប្រណាំង ដោយមានព្រះអង្គជាគោលដៅរបស់ពួកគេ ទោះពួកគេស្ថិតក្នុងវ័យចាស់យ៉ាងណាក៏ដោយ (ហេព្រើរ ១២:១-២)។ អ្នកនិពន្ធបទគម្ពីរទំនុកតម្កើងក៏បានពិពណ៌នាអំពីពួកស្មោះត្រង់ក្នុងវ័យចំណាស់យ៉ាងដូចនេះថា "ឯមនុស្សសុចរិតគេនឹងលូតលាស់ឡើង ដូចជាដើមលម៉ើ... កាលណាចាស់ហើយ នោះគេនឹងនៅតែកើតផល" (៩២:១២-១៤)។

អ្នកជឿមានវ័យចាស់ ដែលដើរតាមខ្នាតគំរូនេះ អាចរកឃើញការបង្រៀនជាបន្ថែមទៀត ក្នុងសំបុត្រដែលសាវ័កប៉ុលបានសរសេរផ្ញើទៅលោក ទីតុស។ គឺដូចដែលគាត់បានបង្រៀនថា "ត្រូវទូន្មានឲ្យពួកចាស់ៗ ដឹងខ្នាត មានចិត្តនឹងធឹង ហើយធ្ងន់ធ្ងរ ឲ្យមានសេចក្តីជំនឿ សេចក្តីស្រឡាញ់ និងសេចក្តីខ្ជាប់ខ្ជួនដ៏ត្រឹមត្រូវផង" (២:២) ឲ្យពួកស្ត្រីចាស់ៗ "ត្រូវខំបង្រៀនសេចក្តីត្រឹមត្រូវវិញ" (ខ.៣)។

ព្រះអម្ចាស់មិនដែលបានប្រាប់អ្នកជឿមានវ័យចាស់ ឲ្យឈប់រត់ប្រណាំងនោះទេ។ យើងប្រហែលមិនអាចរត់ប្រណាំងក្នុងវ័យចាស់ដូចអ្នកស្រី ជូលា ទេ តែទោះយើងស្ថិតក្នុងវ័យណាក៏ដោយ យើងត្រូវតែបន្តការរត់ប្រណាំងខាងវិញ្ញាណ ដែលថ្វាយព្រះកិត្តិនាមដល់ព្រះ ខណៈពេលដែលព្រះអង្គប្រទានកម្លាំង ដែលយើងត្រូវការ។ ចូរយើងទាំងអស់គ្នារត់ប្រណាំង ដើម្បីបម្រើព្រះអង្គ និងអ្នកដទៃឲ្យបានល្អ។—Dave Branon

តើមានការអ្វីខ្លះ ដែលអ្នកអាចធ្វើ ដើម្បីឈោងចាប់អ្នកដទៃថ្វាយព្រះគ្រីស្ទ និងជួយពួកគេឲ្យចម្រើនឡើងក្នុងជំនឿ? តើអ្នកអាចលើកទឹកចិត្តអ្នកជឿដទៃឲ្យបម្រើព្រះ តាមឱកាសដែលព្រះអង្គប្រទានដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គដែលបានប្រទានជីវិតឲ្យទូលបង្គំរស់នៅជារៀងរាល់ថ្ងៃ។ ទោះទូលបង្គំស្ថិតក្នុងវ័យណាក៏ដោយ សូមព្រះអង្គជួយទូលបង្គំឲ្យព្យាយាមរត់ប្រណាំង ដើម្បីថ្វាយសិរីល្អដល់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរអស់រយៈពេល១ឆ្នាំ | អេសាយ ៣០-៣១ និងកិលេឌ ៤

ចូរទុកឲ្យសេចក្តីខ្ជាប់ខ្ជួននោះ បានធ្វើការឲ្យសំរេចពេញលេញចុះ ដើម្បីឲ្យអ្នកពាល់គ្នាបានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ (យ៉ាកុប ១:៤)។

មេរៀនអំពីការអត់ធ្មត់

លោក បប់ សាឡិម (Bob Salem) បានបំបែកឯកតួកម្មក្នុងការរុញសណ្តែកដីមួយគ្រាប់ ឡើងទៅលើកំពូលភ្នំផៃ ក្នុងល្បឿនលឿនជាងគេ ដោយប្រើស្លាបព្រាបំពាក់ពីលើមុខរបស់គាត់។ គាត់បានសម្រេចទៅដល់គោលដៅរបស់គាត់ ក្នុងរយៈពេល៧ថ្ងៃ ដោយរុញសណ្តែកដីឡើងភ្នំនោះ តែនៅពេលយប់ប៉ុណ្ណោះ ដើម្បីជៀសវាងការរំខានពីភ្ញៀវទេសចរណ៍ ដែលមកកម្សាន្តនៅភ្នំនោះ។ លោក បប់ ជាមនុស្សទីបួន ដែលបានសម្រេចកិច្ចការដ៏ពិបាកនេះបានសេចក្តីថា មានមនុស្សដែលមានចិត្តអត់ធ្មត់៣នាក់ទៀត ដែលបានធ្វើដូចគាត់ដែរ។

យើងប្រហែលជាចង់និយាយថា ពួកគេបានប្រើភាពអត់ធ្មត់របស់ខ្លួននៅក្នុងការធ្វើបាបខ្លួនឯង ប៉ុន្តែជាញឹកញាប់នៅក្នុងការរស់នៅ យើងមិនចាំបាច់ត្រូវប្រើភាពអត់ធ្មត់ យ៉ាងដូចនេះទេ។ យើងត្រូវការភាពអត់ធ្មត់។ ភាពអត់ធ្មត់ជាផលផ្លែនៃព្រះវិញ្ញាណ (កាឡាទី ៥:២២) និងជាគុណធម៌ដ៏ចាំបាច់ ដើម្បីឲ្យយើងអាច «បានគ្រប់លក្ខណ៍ ហើយពេញខ្នាតឥតខ្វះអ្វីឡើយ» (យ៉ាកុប ១:៤)។ ពេលដែលបញ្ហាមកដល់ មនុស្សអត់ធ្មត់នៅតែមានភាពនឹងធឹង ខណៈពេលដែលអ្នកដទៃកំពុងមានភាពតក់ស្លុត។ ពួកគេក៏ចង់ឲ្យស្ថានការណ៍ មានការផ្លាស់ប្តូរផងដែរ ប៉ុន្តែពួកគេមិនបានពឹងផ្អែកលើការផ្លាស់ប្តូរនោះឡើយ។ ពួកគេបន្តដំណើរទៅមុខទៀតយ៉ាងខ្ជាប់ខ្ជួន ដោយទុកចិត្តលើប្រាជ្ញារបស់ព្រះ ដើម្បីឲ្យពួកគេសម្រេចកិច្ចការដោយភាពឆ្លាតវៃ (ខ.៥)។

បញ្ហានៃភាពអត់ធ្មត់ស្ថិតនៅត្រង់ថា មានវិធីតែមួយប៉ុណ្ណោះ សម្រាប់ឲ្យយើងរៀនសូត្រអំពីភាពអត់ធ្មត់។ កណ្ឌគម្ពីរយ៉ាកុបបានចែងថា «ការល្បងលមើលសេចក្តីជំនឿនៃអ្នករាល់គ្នា នោះនាំបង្កើតឲ្យមានសេចក្តីខ្ជាប់ខ្ជួន» (ខ.៣)។ ការល្បងលនោះអាចជាបញ្ហាធំ ឬបញ្ហាតូច ដែលយើងជួបប្រទះ។ ខ្ញុំកំពុងសរសេរអត្ថបទនេះ នៅអាកាសយានដ្ឋាន នៅម៉ោង១១យប់ ខណៈពេលដែលជើងហោះហើរបានពន្យារពេលដល់ម៉ោង២លងអាធ្រាត្រ បន្ទាប់មកក៏ត្រូវបានគេលប់ចោល។ បន្ទាប់ពីខ្ញុំមិនបានគេងលក់ពេញមួយយប់ ខ្ញុំក៏បានទិញកាហ្វេញ៉ាំដោយសង្ឃឹមថា នឹងបានធ្វើដំណើរដល់ផ្ទះ ដោយមិនងោកងុយ។ ខ្ញុំមិនចូលចិត្តខ្ជះខ្ជាយពេលវេលា ពេញមួយថ្ងៃនៅអាកាសយានដ្ឋាននោះទេ ប៉ុន្តែព្រះវរបិតានៃខ្ញុំដែលមានក្តីស្រឡាញ់កំពុងបង្រៀនខ្ញុំឲ្យចេះអត់ធ្មត់។

ខ្ញុំបានអធិស្ឋានសូមឲ្យរឿងនេះឆាប់ចប់នៅថ្ងៃនោះ ប៉ុន្តែព្រះអង្គក៏បានបណ្តាលចិត្តខ្ញុំឲ្យបន្តអត់ធ្មត់ក្នុងការរង់ចាំជើងហោះហើរបន្ទាប់។—Mike Wittmer

តើធ្វើដូចម្តេចឲ្យអ្នកអាចមានចិត្តអត់ធ្មត់? ហេតុអ្វីគុណធម៌មួយនេះ មានសារៈសំខាន់យ៉ាងនេះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យរៀនអត់ធ្មត់ ខណៈពេលដែលទូលបង្គំតោងឲ្យជាប់ព្រះអង្គ និងព្រះបន្ទូលសន្យារបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៣២-៣៣ និងកូល៉ុស ១

សេចក្តីសប្បុរសរបស់ទ្រង់ក៏ធំច្រើនប៉ុណ្ណោះ ចំពោះអស់អ្នកដែលកោតខ្លាចដល់ទ្រង់។ (ទំនុកតម្កើង ១០៣:១១)។

សេចក្តីស្រឡាញ់ដែលគ្មានព្រំដែន

នៅថ្ងៃខួបអាពាហ៍ពិពាហ៍របស់អ្នកស្រី ធែរី (Terry) គាត់បាននិយាយថា «ព្រះអម្ចាស់ល្អចំពោះពួកខ្ញុំណាស់! ខ្ញុំចង់អរព្រះគុណព្រះអង្គ ដែលប្រទានពរឲ្យយើងបានរស់នៅជាប្តីប្រពន្ធមួយឆ្នាំទៀត»។ ពេលនោះ ទឹកភ្នែកដែលគាត់បានសម្រក់នៅពេលគាត់និយាយ គឺបានបង្ហាញថា គាត់កំពុងតែនិយាយចេញពីចិត្ត។ ក្រុមគួចរបស់យើងមានការប៉ះពាល់ចិត្តយ៉ាងខ្លាំង។ យើងដឹងថា រយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ អ្នកស្រី ធែរី និងស្វាមីរបស់គាត់បានជួបការលំបាកប៉ុណ្ណា។ លោក រ៉ូបឺត (Robert) ស្រាប់តែមានជំងឺវិកលចរិត ហើយក៏បានសម្លាប់កូនស្រីខ្លួនឯង អាយុ៨ឆ្នាំ។ គាត់ត្រូវរស់នៅក្នុងមន្ទីរពេទ្យបាលអ្នកជំងឺវិកលចរិតអស់រយៈពេលជាច្រើនទសវត្សរ៍ ប៉ុន្តែអ្នកស្រី ធែរ នៅតែទៅសួរសុខទុក្ខគាត់ ហើយព្រះអម្ចាស់ក៏បានធ្វើការប្រោសឲ្យជា ដោយជួយអ្នកស្រី ធែរី ឲ្យអត់ឱនទោសឲ្យស្វាមីខ្លួន។ ទោះពួកគេមានការឈឺចាប់ខ្លាំងប៉ុណ្ណាក៏ដោយ ក៏ពួកគេនៅតែស្រឡាញ់គ្នាកាន់តែខ្លាំងឡើង។

សេចក្តីស្រឡាញ់ និងការអត់ទោសយ៉ាងដូចនេះ អាចកើតចេញពីប្រភពមួយប៉ុណ្ណោះ។ ស្តេច ដាវីឌ បានពិពណ៌នា អំពីព្រះអម្ចាស់យ៉ាងដូចនេះថា «ទ្រង់មិនបានប្រព្រឹត្តនឹងយើង តាមអំពើបាបរបស់យើងទេ... ឯទិសខាងកើតនៅឆ្ងាយពីទិសខាងលិចយ៉ាងណា ទ្រង់បានដកយកអស់ទាំងការល្មើសនៃយើង ឲ្យឃ្លាតឆ្ងាយពីយើងយ៉ាងនោះដែរ» (ទំនុកតម្កើង ១០៣:១០, ១២)។

ព្រះអម្ចាស់បានបង្ហាញសេចក្តីមេត្តាដល់យើង តាមរយៈសេចក្តីស្រឡាញ់ដ៏មានតម្លៃរបស់ព្រះអង្គ គឺដូចមានសេចក្តីចែងថា «ដ្បិតដែលផ្ទៃមេឃខ្ពស់ជាងផែនដីច្រើនប៉ុណ្ណា សេចក្តីសប្បុរសរបស់ទ្រង់ក៏ធំច្រើនប៉ុណ្ណោះ ចំពោះអស់អ្នកដែលកោតខ្លាចដល់ទ្រង់» (ខ.១១)។ សេចក្តីស្រឡាញ់ដ៏ធំប្រសើររបស់ព្រះអម្ចាស់បានបណ្តាលព្រះទ័យព្រះអង្គ ឲ្យយាងចុះមកយកកំណើតជាមនុស្ស ហើយសុគតនៅលើឈើឆ្កាង ដើម្បីលោះបាបយើង ដើម្បីឲ្យព្រះអង្គអាចនាំមនុស្សទាំងអស់ដែល «ទទួលជឿព្រះអង្គ» (យ៉ូហាន ១:១២) ឲ្យបានទៅរស់នៅជាមួយព្រះអង្គ។

អ្នកស្រី ធែរី បាននិយាយត្រូវ។ ព្រោះអម្ចាស់ពិតជាល្អចំពោះយើងណាស់! សេចក្តីស្រឡាញ់ និងការអត់ទោសរបស់ព្រះអង្គ មានភាពធំធេងគ្មានព្រំដែន ហើយក៏បាននាំឲ្យយើងមានជីវិត ដែលមិនចេះចប់។—James Banks

តើព្រះអម្ចាស់បានបង្ហាញសេចក្តីមេត្តាដល់អ្នកយ៉ាងដូចម្តេចខ្លះ បន្ទាប់ពីអ្នកបានប្រព្រឹត្តខុស? តើអ្នកអាចឆ្លើយតប ចំពោះសេចក្តីមេត្តា និងសេចក្តីស្រឡាញ់របស់ព្រះអង្គនៅថ្ងៃនេះ ដោយរបៀបណា?

ឱព្រះដែលមានសេចក្តីមេត្តា សូមព្រះអង្គជួយទូលបង្គំឲ្យអរសប្បាយ និងបានចម្រើនឡើងក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ។ សូមព្រះអង្គបង្ហាញសេចក្តីស្រឡាញ់តាមរយៈទូលបង្គំ ដើម្បីឲ្យអ្នកដទៃបានស្គាល់សេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ព្រះអង្គផងដែរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៣៤-៣៦ និងកូល៉ុស ២

ចូរអធិស្ឋានឥតឈប់ឈរ (១ថែស្សាឡូនិច ៥:១៧)។

នៅតែបន្តអធិស្ឋាន

មានពេលមួយកូនស្រីខ្ញុំបានផ្ញើសារមកទូរស័ព្ទខ្ញុំថា នាងប្រឡងបានពិន្ទុ៨៤។ ពេលខ្ញុំកំពុងអានសាររបស់នាង ក្នុងទូរស័ព្ទរបស់ខ្ញុំ ខ្ញុំអាចដឹងថា កូនស្រីរបស់ខ្ញុំកំពុងមានចិត្តរំភើបរីករាយ។ កាលនោះគាត់ទើបតែចាប់ផ្តើមចូលរៀនក្នុងថ្នាក់វិទ្យាល័យ ហើយកំពុងប្រើទូរស័ព្ទនៅម៉ោងសម្រាកបាយថ្ងៃត្រង់។ ក្នុងនាមខ្ញុំជាម្តាយ ខ្ញុំមានការសប្បាយចិត្តណាស់ គឺមិនគ្រាន់តែដោយសារកូនស្រីខ្ញុំទទួលបានលទ្ធផលល្អក្នុងការប្រឡងដ៏ពិបាកប៉ុណ្ណោះទេ តែក៏ដោយសារគាត់បានសម្រេចចិត្តទំនាក់ទំនងមកខ្ញុំ។ និយាយឲ្យខ្លី គាត់ចង់ចែកចាយដំណឹងដ៏ល្អនេះ ឲ្យខ្ញុំមានអំណរជាមួយគាត់ផងដែរ។

ពេលដែលខ្ញុំបានដឹងថា សារដែលគាត់បានផ្ញើមក បានធ្វើឲ្យខ្ញុំមានចិត្តរីករាយពេញមួយថ្ងៃ ក្រោយមកខ្ញុំក៏បានគិត អំពីអារម្មណ៍ដែលព្រះទ្រង់មានចំពោះខ្ញុំ នៅពេលណាខ្ញុំឈោងទៅរកព្រះអង្គ។ តើព្រះអង្គមានព្រះទ័យរីករាយទេ នៅពេលដែលខ្ញុំនិយាយទៅកាន់ព្រះអង្គ? ការអធិស្ឋានគឺជាការសន្ទនាជាមួយព្រះ ហើយព្រះគម្ពីរបានបង្រៀនយើង ឲ្យបន្តអធិស្ឋានទៅកាន់ព្រះអង្គ (១ថែស្សាឡូនិច ៥:១៧)។ ការជជែកជាមួយព្រះអង្គគឺបានរំឭកយើងថា ព្រះអង្គគង់នៅជាមួយយើងទាំងនៅពេលយើងសប្បាយរីករាយ ក៏ដូចនៅពេលដែលយើងពិបាកចិត្ត។ ទោះព្រះអង្គបានជ្រាបអំពីអ្វីៗទាំងអស់ហើយក៏ដោយ ការទូលថ្វាយរឿងរបស់យើងដល់ព្រះអង្គមានប្រយោជន៍ចំពោះយើង ដោយនាំឲ្យយើងងាកមកផ្តោតចិត្តទៅលើព្រះអង្គ និងគិតអំពីព្រះអង្គ។ បទគម្ពីរអេសាយ ២៦:៣ បានចែងថា «ឯអ្នកណាដែលមានគំនិតជាប់តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះឲ្យមានសេចក្តីសុខពេញខ្នាត ដោយព្រោះគេទុកចិត្តនឹងទ្រង់»។ យើងនឹងមានសន្តិភាពនៅក្នុងចិត្តយ៉ាងពេញលេញ ពេលណាយើងងាកមកផ្តោតចិត្តទៅលើព្រះអង្គ។

ទោះយើងជួបរឿងអ្វីក៏ដោយ ចូរយើងបន្តនិយាយទៅកាន់ព្រះអង្គ ហើយបន្តមានការប្រកបស្និទ្ធស្នាលជាមួយព្រះអាទិករ និងព្រះអង្គសង្គ្រោះរបស់យើង។ ចូរយើងអធិស្ឋានក្នុងចិត្ត ឬអធិស្ឋានឮៗ ដោយមិនភ្លេចអរសប្បាយ និងអរព្រះគុណព្រះអង្គ។ សរុបមក សាវ័ក ប៉ុល បានប្រាប់យើងថា នេះហើយជាបំណងព្រះទ័យដែលព្រះអង្គមានសម្រាប់យើង (១ថែស្សាឡូនិច ៥:១៨)។—Katara Patton

តើអ្នកមានរឿងអ្វីខ្លះ ដែលចាំបាច់ត្រូវទូលថ្វាយដល់ព្រះ? តើធ្វើដូចម្តេចឲ្យអ្នកមិនភ្លេចប្រកបស្និទ្ធស្នាលជាមួយព្រះអង្គពេញមួយថ្ងៃ?

ឱព្រះប្រកបដោយព្រះគុណ សូមព្រះអង្គក្រើនរំឭកទូលបង្គំ ឲ្យបន្តប្រកបជិតស្និទ្ធជាមួយព្រះអង្គពេញមួយថ្ងៃ។ ទូលបង្គំចង់មានអំណរ និងថ្វាយការអរព្រះគុណដល់ព្រះអង្គក្នុងបញ្ហាទាំងអស់ដែលទូលបង្គំជួបប្រទះ។

Daily Manna 2026_Content Enhance.indd 290 17/11/25 1:47 in the afternoon

តែមានមនុស្សខ្លះត្រូវចិត្តជាប់នឹងគាត់ ព្រមទាំងជឿផង (កិច្ចការ ១៧:៣៤)។

ផ្លូវខាងវិញ្ញាណដ៏គ្រោះថ្នាក់

ក្នុងការដើរហាត់ប្រាណនៅពេលព្រឹកមួយនោះ ខ្ញុំបានកត់សម្គាល់ឃើញយានយន្តមួយគ្រឿង កំពុងឈប់នៅលើផ្លូវឆ្ពោះទៅរកទិសដៅបញ្ច្រាស។ អ្នកបើកបរមិនបានដឹងអំពីគ្រោះថ្នាក់ដែលអាចកើតមានចំពោះខ្លួនគាត់ និងអ្នកដទៃ ដោយសារគាត់កំពុងតែគេងលក់ ហើយហាក់ដូចជាស្ថិតក្នុងស្ថានភាពស្រឹងផង។ ស្ថានភាពនៅពេលនោះហាក់ដូចជាមានគ្រោះថ្នាក់ណាស់។ ខ្ញុំត្រូវតែធ្វើអ្វីម្យ៉ាង។ បន្ទាប់ពីខ្ញុំបានដាស់គាត់ឲ្យភ្ញាក់ដឹងខ្លួនល្មមនឹងអាចងើបចេញ ទៅអង្គុយនៅលើកៅអីនៅជាប់កៅអីតែកុង ខ្ញុំក៏បានចូលទៅអង្គុយនៅលើកៅអីតែកុង ហើយក៏បានបើកបរឡានដឹកគាត់ទៅកន្លែងមានសុវត្ថិភាព។

មិនមែនមានតែគ្រោះថ្នាក់ខាងរូបកាយទេ ដែលយើងអាចជួបប្រទះ។ កាលសាវ័ក ប៉ុល បានឃើញអ្នកប្រាជ្ញខាងលោកីយ៍នៅទីក្រុងអាថែនកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់ខាងវិញ្ញាណ ដោយសារទីក្រុងនេះមានពេញទៅដោយរូបព្រះ គាត់ក៏មានការរំជួលចិត្តយ៉ាងខ្លាំង (កិច្ចការ ១៧:១៦)។ ពួកគេកំពុងស្វែងរកអត្ថន័យរបស់ជីវិត ដោយមិនបានស្គាល់ព្រះគ្រីស្ទបានជាគាត់ចែកចាយទៅកាន់ពួកគេអំពីគោលបំណងរបស់ព្រះ ដែលមាននៅក្នុងនិងតាមរយៈព្រះយេស៊ូវ (ខ.១៨, ៣០-៣១)។ ហើយអ្នកខ្លះដែលបានឮការបង្រៀនរបស់គាត់ ក៏បានទទួលជឿព្រះយេស៊ូវ (ខ.៣៤)។

ការស្វែងរកអត្ថន័យរបស់ជីវិត ដោយមិនបានទទួលជឿព្រះគ្រីស្ទ គឺពិតជាគ្រោះថ្នាក់ណាស់។ អ្នកដែលបានរកឃើញការអត់ទោស និងភាពពេញបរិបូរពិតប្រាកដក្នុងព្រះយេស៊ូវ គឺបានទទួលការសង្គ្រោះឲ្យរួចផុតពីភាពទាល់ច្រក ហើយក៏បានទទួលព្រះរាជសារអំពីការផ្សះផ្សាឲ្យជានឹងព្រះ (២កូរិនថូស ៥:១៨-២១)។ ការចែកចាយដំណឹងល្អរបស់ព្រះយេស៊ូវដល់មនុស្សដែលកំពុងរងែងនឹងឥទ្ធិពលរបស់លោកីយ៍ នៅតែជាដំណោះស្រាយដែលព្រះបានប្រើ ដើម្បីទាញពួកគេចេញពីផ្លូវខាងវិញ្ញាណដ៏គ្រោះថ្នាក់។—Arthur Jackson

បើអ្នកមិនបានដើរតាមផ្លូវរបស់ព្រះយេស៊ូវទេ តើអ្នកកំពុងរង់ចាំអ្វី? បើអ្នកបានដើរតាមផ្លូវព្រះអង្គហើយ តើមានអ្វីរារាំងអ្នកមិនឲ្យប្រាប់នរណាម្នាក់ អំពីរបៀបដែលព្រះអម្ចាស់បានរំដោះអ្នកឲ្យរួចផុតពីផ្លូវខាងវិញ្ញាណដ៏គ្រោះថ្នាក់?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានសង្គ្រោះទូលបង្គំឲ្យរួចផុតពីគ្រោះថ្នាក់ដោយសារបាបរបស់ទូលបង្គំ។ សូមព្រះអង្គប្រើទូលបង្គំ ដើម្បីជួយប្រាប់អ្នកដទៃឲ្យបានដឹងថា ពួកគេកំពុងស្ថិតក្នុងគ្រោះថ្នាក់ខាងវិញ្ញាណ។

Daily Manna 2026_Content Enhance.indd 291 17/11/25 1:47 in the afternoon

អញ្ជើញអ្នកទៅឲ្យប្រកបដោយសេចក្តីសុខចុះ ដ្បិតយើងទាំង២នាក់បានស្បថគ្នា ដោយនូវព្រះនាមព្រះយេហូវ៉ាហើយ (១សាំយ៉ូអែល ២០:៤២)។

ធ្វើដំណើរជួរឆ្ងាយជាមួយគ្នា

អ្នកប្រហែលជាធ្លាប់បានឃើញ ឬឮពាក្យស្លោកមួយឃ្លា ដែលបានពោលថា «បើអ្នកចង់ទៅលឿន ចូរទៅម្នាក់ចុះ។ ប៉ុន្តែ បើអ្នកចង់ទៅបានឆ្ងាយ ចូរយើងទៅជាមួយគ្នា»។ ពាក្យស្លោកនេះពិតជាមានន័យណាស់មែនទេ? ប៉ុន្តែ តើមានការស្រាវជ្រាវច្បាស់លាស់ណាមួយ ដែលបានធានាដល់យើងថា ពាក្យស្លោកនេះមិនគ្រាន់តែមានន័យនោះទេ តែក៏បាននិយាយត្រូវផងដែរ?

តាមពិត អ្នកស្រាវជ្រាវជាជនជាតិអាមេរិក និងអង់គ្លេសបានធ្វើការសិក្សាអំពីពាក្យស្លោកនេះ ហើយបានធ្វើការបកស្រាយថា ពេលណាមនុស្សឈរម្នាក់ឯង ពួកគេបានប៉ាន់ប្រមាណទំហំរបស់ភ្នំឃើញថា វាមានទំហំធំជាង តែពេលណាពួកគេនៅជុំគ្នា ពួកគេយល់ឃើញថា ភ្នំនោះមានទំហំតូចជាង។ អាចនិយាយម្យ៉ាងទៀតថា «ការគាំទ្រពីអ្នកដទៃ» ពិតជាមានសារៈសំខាន់ណាស់ បានជាការគាំទ្រនេះបានធ្វើឲ្យភ្នំមានទំហំតូចជាងនៅក្នុងគំនិតរបស់យើង។

ស្តេចដាវីឌក៏បានឲ្យតម្លៃមកលើការលើកទឹកចិត្តនៅក្នុងមិត្តភាពជាមួយព្រះអង្គម្ចាស់យ៉ូណាថាន ដោយទ្រង់យល់ឃើញថា ការលើកទឹកចិត្តនោះបានធ្វើឡើង ដោយស្មោះអស់ពីចិត្ត។ កំហឹងរបស់ស្តេចសូល ដែលកើតចេញពីការច្រណែនបានរីកធំឡើងដូចភ្នំនៅក្នុងរឿងរបស់ស្តេច ដាវីឌ ដោយបានបណ្តាលឲ្យទ្រង់រត់គេចខ្លួនឲ្យរួចពីសេចក្តីស្លាប់ (១សាំយ៉ូអែល ១៩:៩-១៨)។ បើគ្មានការគាំទ្រពីមិត្តសំឡាញ់របស់ទ្រង់ទេ រឿងរបស់ទ្រង់នឹងបានបញ្ចប់ខុសពីនេះ។ ប៉ុន្តែ ព្រះអង្គម្ចាស់យ៉ូណាថានសោកស្តាយ ចំពោះទង្វើដ៏ថោកទាប ដែលបិតាទ្រង់បានធ្វើមកលើស្តេច ដាវីឌ (២០:៣៤) ហើយទ្រង់ក៏បានលើកទឹកចិត្តមិត្តសំឡាញ់របស់ទ្រង់។ ទ្រង់ក៏បានសួរបិតាទ្រង់ថា «ហេតុអ្វីបានជាគាត់ត្រូវស្លាប់ តើបានធ្វើអ្វីខ្លះ?» (ខ.៣២)។ ព្រះរបស់ពួកគេក៏បានប្រទានពរដល់មិត្តភាពរបស់ពួកគេ ដោយអនុញ្ញាតឲ្យស្តេច ដាវីឌ ក្លាយជាស្តេចរបស់សាសន៍អ៊ីស្រាអែល។

មិត្តភាពរបស់យើងពិតជាមានសារៈសំខាន់។ ហើយពេលណាព្រះទ្រង់ស្ថិតនៅចំណុចកណ្តាលនៃមិត្តភាពរបស់យើង យើងអាចលើកទឹកចិត្តគ្នាទៅវិញទៅមកឲ្យធ្វើកិច្ចការដែលធំលើសក្តីស្រមៃរបស់យើងទៅទៀត។—John Blasé

តើអ្នកបានរកឃើញការគាំទ្រង់ពីមិត្តភក្តិនៅកន្លែងណា? តើនរណាខ្លះអាចផ្តល់ឲ្យអ្នកនូវការគាំទ្រតាមរយៈមិត្តភាព?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានដាក់មនុស្សនៅក្នុងជីវិតទូលបង្គំ ដើម្បីជួយសម្រាលបន្ទុកក្នុងការធ្វើដំណើរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៤១-៤២ និង១ថែស្សាឡូនីច ១

ដូច្នេះ ចូរប្រដាប់កាយ ដោយចិត្តក្តួលអាណិត សប្បុរស សុភាព សំឡូត និងចិត្តអត់ធ្មត់ (កូល៉ុស ៣:១២)។

អំពើសប្បុរសធម៌ដ៏សាមញ្ញ

កាលម្តាយរបស់ខ្ញុំចូលសម្រាកព្យាបាលជំងឺក្នុងមន្ទីរពេទ្យ ហើយជិតដល់ថ្ងៃចុងក្រោយនៃជីវិតរបស់គាត់នៅលើផែនដី ខ្ញុំមានការប៉ះពាល់ចិត្តយ៉ាងខ្លាំង ចំពោះសេចក្តីសប្បុរសពិតប្រាកដ ដែលអ្នកថែទាំគាត់បានបង្ហាញចេញមក។ គាត់បានលើកម្តាយខ្ញុំចេញពីកៅអីយឺតៗ ហើយដាក់ម្តាយខ្ញុំនៅលើគ្រែគេងថ្មមៗ ហើយក៏បាននិយាយលើកទឹកចិត្តម្តាយខ្ញុំ ដោយពាក្យសម្តីដ៏ស្រទន់។ បន្ទាប់មក គាត់ក៏បានសួរសុខទុក្ខខ្ញុំ។ សេចក្តីសប្បុរសរបស់គាត់បានធ្វើឲ្យខ្ញុំប៉ះពាល់ចិត្ត រហូតដល់ស្រក់ទឹកភ្នែក ហើយសព្វថ្ងៃនេះ ខ្ញុំនៅតែស្រក់ទឹកភ្នែក ពេលដែលបាននឹកចាំអំពីរឿងនេះ។

ការថែទាំដែលគាត់បានផ្តល់ឲ្យម្តាយខ្ញុំ គឺជាអំពើសប្បុរសធម៌ដ៏សាមញ្ញ តែក៏ជាអ្វីដែលខ្ញុំត្រូវការនៅពេលនោះផងដែរ។ ការនេះក៏បានលើកទឹកចិត្តខ្ញុំក្នុងពេលដ៏ពិបាកដោយដឹងថា ក្នុងកែវភ្នែករបស់ស្ត្រីម្នាក់នេះ ម្តាយខ្ញុំមិនគ្រាន់តែជាអ្នកជំងឺប៉ុណ្ណោះទេ។ គាត់បានថែទាំម្តាយខ្ញុំ ហើយបានចាត់ទុកម្តាយខ្ញុំជាមនុស្សដែលមានតម្លៃ។

កាលនាង ន៉ាអូមី និងនាង រស់ បានជួបភាពទាល់ក្រ បន្ទាប់ពីពួកគាត់សុទ្ធតែបានបាត់បង់ស្វាមីរៀងខ្លួន លោក បូអូស ក៏បានបង្ហាញចេញនូវចិត្តសប្បុរស ដោយអនុញ្ញាតឲ្យនាង រស់ ទៅដើររើសកួរស្រូវ ដែលអ្នកច្រូតកាត់បានជ្រុះក្នុងស្រែគាត់។ គាត់ថែមទាំងបានប្រាប់ពួកប្រុសៗ ជាអ្នកច្រូតកាត់មិនឲ្យប៉ះពាល់នាងឡើយ (នាងរស់ ២:៨-៩)។ សេចក្តីសប្បុរសរបស់គាត់បានទទួលការបណ្តាលចិត្ត ពីរបៀបដែលនាងរស់បានថែទាំនាង ន៉ាអូមី ព្រោះគាត់បាននិយាយថា «គេបានប្រាប់ដល់ខ្ញុំពីគ្រប់ទាំងកិរិយា ដែលនាងបានប្រព្រឹត្តនឹងម្តាយក្មេក តាំងពីប្តីនាងស្លាប់ចោលទៅ ហើយពីនាងបានលះចោលឪពុកម្តាយ និងស្រុកកំណើតរបស់នាង មកឯសាសន៍នេះ ដែលមិនបានស្គាល់កាលពីដើមផង» (ខ.១១)។ គាត់មិនគិតឃើញថា នាងជាជនបរទេស ឬជាស្ត្រីមេម៉ាយនោះទេ តែជាស្ត្រីទាល់ក្រ។

ព្រះអម្ចាស់សព្វព្រះទ័យឲ្យយើង «ប្រដាប់កាយ ដោយចិត្តក្តួលអាណិត សប្បុរស សុភាព សំឡូត និងចិត្តអត់ធ្មត់» (កូល៉ុស ៣:១២)។ ដោយជំនួយមកពីព្រះអម្ចាស់អំពើសប្បុរសធម៌ដ៏សាមញ្ញរបស់យើងអាចលើកទឹកចិត្ត នាំមកនូវក្តីសង្ឃឹម និងបណ្តាលចិត្តអ្នកដទៃឲ្យប្រព្រឹត្ត ដោយសេចក្តីសប្បុរសផងដែរ។—Alyson Kieda

តើមាននរណាម្នាក់បង្ហាញចេញនូវសេចក្តីសប្បុរស ចំពោះអ្នកនៅពេលណាខ្លះ? តើការនេះបានបណ្តាលចិត្ត ឬលើកទឹកចិត្តអ្នក ឲ្យប្រព្រឹត្តយ៉ាងណាខ្លះចំពោះអ្នកដទៃ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានដាក់មនុស្សនៅក្នុងជីវិតទូលបង្គំ ដើម្បីជួយសម្រាលបន្ទុកក្នុងការធ្វើដំណើរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៤៣-៤៤ និង១ថែស្សាឡូនីច ២

គឺខ្ញុំវាយដំរូបកាយខ្ញុំ ទាំងបង្ខំឲ្យចុះចូល។ (១កូរិនថូស ៩:២៧)។

ជីវិតដែលលត់ដំ ថ្វាយព្រះ

នៅខែខែមេសាឆ្នាំ២០១៦ ចក្រភពអង់គ្លេសបានប្រារព្ធពិធីខួបកំណើតគំរប់៩០ព្រះវស្សា ថ្វាយមហាក្សត្រី អេលីហ្សាប៊ែត។ ព្រះនាងបានគង់នៅលើរទេះសេះ គ្រឿងព្រះហស្តដាក់ហ្វូងមនុស្ស ខណៈពេលដែលរទេះសេះបានធ្វើដំណើរកាត់ពីមុខទាហានមានឯកសណ្ឋានពណ៌ក្រហមឈរជាជួរត្រង់ភ្លឹង ដោយការប្រុងស្មារតី។ ថ្ងៃនោះ ប្រទេសអង់គ្លេសមានអាកាសធាតុក្តៅខ្លាំង។ ពួកទាហានស្លៀកខោពណ៌ខ្មៅធ្វើពីរោមចៀម អាវក្រៅដៃវែងពណ៌ក្រហមមានឡេវបិទកអាវរហូតដល់ចង្កា ហើយពាក់មួកមានទំហំធំខ្លាំងធ្វើពីរោមសត្វខ្លាឃ្មុំ។ ខណៈពេលដែលពួកទាហានទាំងនោះ កំពុងឈរជាជួរយ៉ាងរឹងមាំនៅក្រោមកម្តៅថ្ងៃ មានទាហានម្នាក់ចាប់ផ្តើមងងឹតមុខដួល។ អ្វីដែលគួរឲ្យកត់សម្គាល់នោះ គាត់ក៏បានប្រកាន់ខ្ជាប់វិន័យដ៏តឹងរឹង ហើយក៏បានដួលផ្កាប់មុខពីលើដីមានគ្រោះលើតៗ ដោយដៃនិងជើងគាត់នៅតែត្រង់ភ្លឹងដូចក្តារបន្ទះ។ គាត់ក៏បានដេកដួលនៅលើដីនោះ ដោយខ្លួននៅតែត្រង់ភ្លឹង ដូចកាលគាត់ឈរ។

ទាហានម្នាក់នេះបានចំណាយពេលហ្វឹកហាត់ និងលត់ដំជាច្រើនឆ្នាំ ដើម្បីឲ្យគាត់អាចគ្រប់គ្រងខ្លួនឯងដោយខ្លួនគាត់នៅតែត្រង់ភ្លឹងនៅលើដី ទោះគាត់បានងងឹតមុខដួលក៏ដោយ។ រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីការបង្រៀនរបស់សាវ័ក ប៉ុល អំពីការហ្វឹកហាត់យ៉ាងដូចនេះថា «គឺខ្ញុំវាយដំរូបកាយខ្ញុំ ទាំងបង្ខំឲ្យចុះចូល ក្រែងក្រោយដែលខ្ញុំបានប្រដៅមនុស្សឯទៀតហើយ នោះខ្លួនខ្ញុំត្រូវចោលចេញវិញ» (១កូរិនថូស ៩:២៧)។ ហើយគាត់ក៏បានទទួលស្គាល់ផងដែរថា កីឡាការដែលត្រូវប្រកួត បានហ្វឹកហាត់ដោយខំអត់សង្កត់ចិត្តគ្រប់ជំពូក (ខ.២៥)។

កិច្ចការទាំងអស់ដែលយើងសម្រេចបាន គឺដោយសារព្រះគុណព្រះ មិនមែនដោយសារការប្រឹងប្រែងរបស់យើងតែម៉្យាងទេ ប៉ុន្តែជីវិតខាងវិញ្ញាណរបស់យើងចាំបាច់ត្រូវមានការហ្វឹកហាត់ដ៏តឹងរឹង។ ខណៈពេលដែលព្រះទ្រង់ជួយយើង ក្នុងការលត់ដំចិត្ត គំនិត និងរូបកាយយើង ចូរយើងរៀនផ្តោតចិត្តទៅលើព្រះអង្គ ទោះស្ថិតក្នុងពេលដែលមានទុក្ខលំបាក ឬការរំខានយ៉ាងណាក៏ដោយ។—Winn Collier

តើការលត់ដំចិត្ត គំនិត និងរូបកាយរបស់អ្នក មានការលំបាកបំផុត ត្រង់ចំណុចណាខ្លះ? តើអ្នកដឹងថាព្រះអម្ចាស់កំពុងអញ្ជើញអ្នកចូលទៅក្នុងការលត់ដំកាន់តែស៊ីជម្រៅ យ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គបង្រៀនទូលបង្គំឲ្យរស់នៅកាន់តែមានវិន័យថ្វាយព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យស្រឡាញ់ព្រះអង្គកាន់តែខ្លាំង ហើយឲ្យចិត្តទូលបង្គំបាននៃបនិត្យជាប់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 294 17/11/25 1:47 in the afternoon

ខ្ញុំបាននិយាយសេចក្តីទាំងនេះ ប្រាប់ដល់អ្នករាល់គ្នា ដើម្បីឲ្យសេចក្តីអំណររបស់ខ្ញុំ បាននៅជាប់ក្នុងអ្នករាល់គ្នា ហើយឲ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញផង (យ៉ូហាន ១៥:១១)។

ដោយល្បឿននៃក្តីអំណរ

នៅពេលព្រឹកថ្ងៃមួយ ខ្ញុំកំពុងពិចារណា ដោយការអធិស្ឋានក្នុងចិត្តអំពីពេលឆ្នាំក្រោយដែលត្រូវមកដល់ ខ្ញុំក៏បាននឹកចាំពាក្យមួយឃ្លា ដែលបានលើកទឹកចិត្តខ្ញុំឲ្យធ្វើការងារតាមល្បឿននៃក្តីអំណរ ហើយឃើញថា ពាក្យមួយឃ្លានេះមានអត្ថន័យត្រូវនឹងស្ថានភាពរបស់ខ្ញុំណាស់។ ខ្ញុំមានទម្លាប់ធ្វើការលើសម៉ោង ដែលច្រើនតែធ្វើឲ្យខ្ញុំបាត់បង់ក្តីអំណរ។ ដូចនេះ ពាក្យមួយឃ្លានេះបានលើកទឹកចិត្តខ្ញុំឲ្យប្តេជ្ញាចិត្តធ្វើការងារដោយល្បឿនដែលធ្វើឲ្យខ្ញុំមានអំណរនៅក្នុងឆ្នាំក្រោយ ដោយចំណាយពេលជាមួយមិត្តភក្តិ និងចំណាយពេលធ្វើរឿងដែលនាំឲ្យមានអំណរ។

ផែនការនេះមានដំណើរការល្អ តែនៅខែមីនា ខ្ញុំមិនអាចអនុវត្តន៍ដូចនេះបានទៀតទេ។ បន្ទាប់មក ខ្ញុំក៏បានធ្វើការជាដៃគូរជាមួយសកលវិទ្យាល័យមួយ ដើម្បីមើលការខុសត្រូវមកលើការសាកល្បងវគ្គសិក្សាមួយ ដែលខ្ញុំបានបង្កើត។ នៅពេលដែលមាននិស្សិតចុះឈ្មោះចូលរៀន ហើយខ្ញុំត្រូវបង្រៀនពួកគេដោយផ្ទាល់មិនយូរប៉ុន្មាន ខ្ញុំក៏បានធ្វើការលើសម៉ោង ដើម្បីឲ្យកម្មវិធីនេះមានដំណើរការល្អ។ ដូចនេះ តើខ្ញុំអាចបន្តធ្វើការ ដោយល្បឿនដែលនាំឲ្យមានអំណរ នៅពេលនោះ ដោយរបៀបណា?

ព្រះយេស៊ូវបានសន្យាប្រទានក្តីអំណរដល់អ្នកជឿព្រះអង្គ គឺអំណរដែលកើតមានតាមរយៈការនៅជាប់ក្នុងក្តីស្រឡាញ់របស់ព្រះអង្គ (យ៉ូហាន ១៥:៩) និងការទូលសូមព្រះអង្គបំពេញតម្រូវការរបស់យើង (១៦:២៤)។ ព្រះអង្គក៏មានបន្ទូលផងដែរថា «ខ្ញុំបាននិយាយសេចក្តីទាំងនេះប្រាប់ដល់អ្នករាល់គ្នា ដើម្បីឲ្យសេចក្តីអំណររបស់ខ្ញុំបាននៅជាប់ក្នុងអ្នករាល់គ្នា ហើយឲ្យសេចក្តីអំណររបស់អ្នករាល់គ្នាបានពោរពេញផង» (១៥:១១)។ ក្តីអំណរនេះគឺជាអំណោយមកពីព្រះវិញ្ញាណរបស់ព្រះអង្គ ដែលយើងត្រូវដើរតាមការដឹកនាំរបស់ព្រះអង្គ (កាឡាទី ៥:២២-២៥)។ ក្នុងរយៈពេលដ៏មមាញឹកនោះ ខ្ញុំអាចមានក្តីអំណរដ៏ជាប់លាប់ ពេលណាខ្ញុំចំណាយពេលរៀងរាល់យប់ក្នុងការអធិស្ឋាន ដោយការសម្រាក និងទុកចិត្តព្រះអង្គ។

ដោយសារក្តីអំណរមានសារៈសំខាន់យ៉ាងនេះ យើងចាំបាច់ត្រូវយកក្តីអំណរធ្វើជាអាទិភាពក្នុងកាលវិភាគរបស់យើង។ ប៉ុន្តែ ដោយសារជីវិតរបស់យើងមិនដែលស្ថិតក្នុងការគ្រប់គ្រងរបស់យើងទាំងស្រុង ខ្ញុំមានការសប្បាយចិត្ត ពេលដែលបានដឹងថា ព្រះវិញ្ញាណបរិសុទ្ធដែលជាប្រភពនៃក្តីអំណរ តែងតែដឹកនាំជីវិតយើងជានិច្ច។ សម្រាប់ខ្លួនខ្ញុំផ្ទាល់ ការធ្វើការ ដោយល្បឿនដែលនាំឲ្យមានអំណរ គឺមានន័យថា ខ្ញុំធ្វើដំណើរដោយល្បឿននៃការអធិស្ឋាន ដោយចំណាយពេលទទួលក្តីអំណរពីព្រះដែលជាអ្នកប្រទានក្តីអំណរ។—Sheridan Voysey

តើមានអ្វីធ្វើឲ្យអ្នកបាត់អំណរ? តើអ្នកអាចសម្រាកក្នុងព្រះដែលជាអ្នកប្រទានអំណរ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះវិញ្ញាណអង្គបំពេញទូលបង្គំជាថ្មីនៅថ្ងៃនេះដោយក្តីស្រឡាញ់ សន្តិភាព និងក្តីអំណររបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៤៧-៤៩ និង១ថែស្សាឡូនីច ៤

រួចម៉ូសេប្រាប់ថា នេះគឺជានំបុ័ងដែលព្រះយេហូវ៉ា ទ្រង់ប្រទានមកអ្នករាល់គ្នាទុកជាអាហារហើយ (និក្ខមនំ ១៦:១៥)។

ព្រះអង្គតែងតែផ្គត់ផ្គង់

ភពលោកមានការភ្ញាក់ផ្អើលនៅពេលដែលគេបានរកឃើញបងប្អូន៤នាក់ អាយុចាប់ពីមួយឆ្នាំដល់១៣ឆ្នាំ នៅមានជីវិតក្នុងព្រៃអាម៉ាហ្សូនក្នុងប្រទេសកូឡុំប៊ី កាលពីខែមិថុនា ឆ្នាំ២០២៣។ បងប្អូន៤នាក់នេះបានរស់នៅក្នុងព្រៃ អស់រយៈពេល៤០ថ្ងៃបន្ទាប់ពីយន្តហោះបានធ្លាក់ ដែលបណ្តាលឲ្យម្តាយរបស់ពួកគេបាត់បង់ជីវិត។ ក្មេងទាំងនោះស្គាល់សណ្ឋានដីដ៏ពិបាករបស់ព្រៃអាម៉ាហ្សូន ពួកគេបានលាក់ខ្លួននៅក្នុងដើមឈើឲ្យរួចពីសត្វសាហាវ និងបានទៅដងទឹកពីក្នុងអូរ និងត្រងទឹកភ្លៀងទុកផឹក ហើយក៏បានបរិភោគអាហារ ដែលមានដូចជាម្សៅដំឡូងមី ដែលពួកគេធ្វើសបានក្នុងបំណែកយន្តហោះ។ ពួកគេក៏ស្គាល់ផ្លែឈើព្រៃ និងគ្រាប់ធញ្ញជាតិនៅក្នុងព្រៃដែលពួកគេអាចបរិភោគបាន។ និយាយឲ្យខ្លី ព្រះបានទ្រទ្រង់ជីវិតរបស់បងប្អូនទាំង៤នាក់នោះ។

រឿងដែលមិនគួរឲ្យជឿនោះ បានធ្វើឲ្យខ្ញុំនឹកចាំអំពីរបៀបដែលព្រះទ្រង់ផ្គត់ផ្គង់តម្រូវការរបស់ពួកអ៊ីស្រាអែលក្នុងវាលរហោស្ថានអស់រយៈពេល៤០ឆ្នាំ ដូចមានចែងក្នុងកណ្ឌគម្ពីរនិក្ខមនំ និងជនគណនា ហើយបានចែងក្នុងព្រះគម្ពីរទាំងមូលផងដែរ។ ព្រះអង្គបានរក្សាជីវិតរបស់ពួកគេ ដើម្បីឲ្យពួកគេដឹងថា ព្រះអង្គជាព្រះរបស់ពួកគេ។

កាលនោះព្រះអម្ចាស់បានធ្វើឲ្យទឹកជុំដែលមានរស់ជាតិល្វីង ប្រែក្លាយជាទឹកសាបដែលអាចផឹកបាន និងបានប្រទានទឹកចេញពីផ្ទាំងថ្មពីរលើក ហើយបានដឹកនាំរាស្ត្រព្រះអង្គ ដោយប្រើបង្គោលពពកនៅពេលថ្ងៃ និងបង្គោលភ្លើងនៅពេលយប់។ ព្រះអង្គក៏បានប្រទាននំម៉ាណាដល់ពួកគេផងដែរ។ លោក ម៉ូសេ ប្រាប់ពួកគេថា «នេះគឺជានំបុ័ងដែលព្រះយេហូវ៉ា ទ្រង់ប្រទានមកអ្នករាល់គ្នា ទុកជាអាហារហើយ»។ «នេះហើយ ជាសេចក្តីដែលព្រះយេហូវ៉ាបានបង្គាប់មក គឺឲ្យអ្នករាល់គ្នារើសយកល្មមតែនឹងបរិភោគឆ្អែតគ្រប់គ្នាចុះ» (និក្ខមនំ ១៦:១៥-១៦)។

ព្រះអម្ចាស់ក៏ប្រទាន «អាហារប្រចាំថ្ងៃ» ដល់យើងផងដែរ (ម៉ាថាយ ៦:១១)។ យើងអាចទុកចិត្តថា ព្រះអង្គនឹងបំពេញតម្រូវការយើង «តាមភោគសម្បត្តិនៃទ្រង់ដ៏ឧត្តមក្នុងព្រះគ្រីស្ទយេស៊ូវ» (ភីលីព ៤:១៩)។ ព្រះដែលយើងបម្រើ ជាព្រះដ៏មានគ្រប់ចេស្តា!—Nancy Gavilanes

តើអ្នកបានដកពិសោធន៍ជាមួយនឹងការផ្គត់ផ្គង់របស់ព្រះអង្គដូចម្តេចខ្លះ? តើសព្វថ្ងៃនេះ អ្នកទុកចិត្តថាព្រះអង្គនឹងបំពេញតម្រូវការអ្វីខ្លះ ដល់អ្នក?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការបំពេញតម្រូវការគ្រប់យ៉ាងរបស់ទូលបង្គំ។

Daily Manna 2026_Content Enhance.indd 296 17/11/25 1:47 in the afternoon

ល្មមហើយ ឱព្រះយេហូវ៉ាអើយ សូមយកព្រលឹងទូលបង្គំទៅឥឡូវចុះ ដ្បិតទូលបង្គំមិនវិសេសជាងពួកឰយុកោទូលបង្គំទេ (១ពង្សាវតាក្សត្រ ១៩:៤)។

ពេលដែលយើងខ្សោះអស់កម្លាំង

ក្នុងខ្សែភាពយន្តមានចំណងជើងថា «ម្ចាស់របស់ចិញ្ចៀន» ដែលលោក ថូលខិន (Tolkien) បាននិពន្ធ តួអង្គឈ្មោះប៊ីលបូ (Bilbo) ចាប់ផ្តើមបង្ហាញអំពីផលវិបាកនៃការដាក់ចិញ្ចៀនមួយវង់ជាប់ខ្លួនអស់រយៈពេល៦ទសវត្សរ៍។ ចិញ្ចៀននោះមានអំណាចនៃសេចក្តីងងឹត ដែលបានក្លាយជាបន្ទុកដ៏ធ្ងន់ ដែលស៊ីបំផ្លាញគាត់បន្តិចម្តងៗ។ បានជាគាត់និយាយទៅកាន់លោក ហ្គាន់ដហ្វ (Gandalf) ថា «ហេតុអ្វីខ្ញុំមានអារម្មណ៍ថា ខ្ញុំមានភាពស្គមស្គាំង និងហត់នឿយយ៉ាងនេះ? បើអ្នកយល់អ្វីដែលខ្ញុំកំពុងនិយាយអ្នកនឹងបានដឹងថា ខ្ញុំមិនខុសពីដុំប័រ ដែលត្រូវគេកោសច្រើនពេក ជាក់ពីលើនំប៉័ង»។ គាត់ក៏បានសម្រេចចិត្តចាកចេញពីផ្ទះ ដើម្បីស្វែងរកកន្លែងសម្រាកនៅកន្លែងដែលមានភាពស្ងប់សុខ ដោយគ្មានញាតិមិត្តណាមករំខានគាត់។

រឿងនិទានរបស់លោក ថូលខិន ត្រង់វគ្គនេះ បានធ្វើឲ្យខ្ញុំនឹកចាំអំពីទុក្ខលំបាករបស់ហោរាម្នាក់នៅគ្រាសញ្ញាចាស់។ នៅក្នុងការរត់គេចពីការតាមសម្លាប់របស់ក្សត្រី យេសិបិល និងបន្ទាប់ពីការតយុទ្ធនឹងហោរាក្លែងក្លាយយ៉ាងហត់នឿយ ហោរា អេលីយ៉ា ត្រូវការការសម្រាកលើសពេលណាទាំងអស់។ គាត់មានអារម្មណ៍ថាអស់កម្លាំងទាំងកាយ និងចិត្ត បានជាគាត់ទូលអង្វរព្រះអម្ចាស់ថា «ល្មមហើយ ឱព្រះយេហូវ៉ាអើយ សូមយកព្រលឹងទូលបង្គំទៅឥឡូវចុះ» (១ពង្សាវតាក្សត្រ ១៩:៤)។ បន្ទាប់ពីគាត់គេងលក់ ទេវតារបស់ព្រះអម្ចាស់ក៏បានដាស់គាត់ ដើម្បីឲ្យគាត់អាចបរិភោគអាហារ និងទឹក។ គាត់ក៏បានគេងម្តងទៀត ហើយបន្ទាប់មក ក៏បានបរិភោគអាហារដែលទេវតាបានប្រទានឲ្យគាត់។ បន្ទាប់ពីគាត់មានកម្លាំងឡើងវិញ គាត់ក៏បានដើរ៤០ថ្ងៃ ទៅភ្នំរបស់ព្រះ។

ពេលណាយើងមានអារម្មណ៍ថា ខ្សោះទាំងកម្លាំងកាយ និងកម្លាំងចិត្ត យើងក៏អាចមើលទៅព្រះ ដើម្បីទទួលបានភាពស្រស់ថ្លាឡើងវិញ។ យើងចាំបាច់ត្រូវថែទាំរូបកាយយើង ហើយទន្ទឹមនឹងនោះ យើងត្រូវទូលសូមព្រះអង្គឲ្យបំពេញយើងជាថ្មីនូវក្តីសង្ឃឹម សន្តិភាព និងការសម្រាក។ ដែលពួកទេវតាបានបម្រើហោរា អេលីយ៉ាជាយ៉ាងណា នោះយើងក៏អាចទុកចិត្តថា ព្រះអង្គក៏នឹងគង់នៅជាមួយយើង ដោយប្រទានកម្លាំងឲ្យយើងមានភាពស្រស់ថ្លាឡើងវិញផងដែរ (មើល ម៉ាថាយ ១១:២៨)។—Amy Boucher Pye

ពេលណាអ្នកមានអារម្មណ៍ថា ខ្សោះអស់កម្លាំង តើអ្នកជួបការល្បួង ដែលនាំអ្នកឲ្យចង់ធ្វើអ្វីខ្លះ? តើអ្នកអាចទុកចិត្តព្រះដូចម្តេចខ្លះ ពេលណាអ្នកអស់កម្លាំង និងមានអារម្មណ៍ថា ពិបាកពេក?

ឱព្រះដែលប្រទានកម្លាំង ទូលបង្គំសូមមើលទៅព្រះអង្គ ដើម្បីទទួលបានការសម្រាកពិតប្រាកដ។ សូមព្រះអង្គជួយទូលបង្គំឲ្យមានសង្ឃឹមក្នុងព្រះអង្គ ហើយបំពេញទូលបង្គំដោយព្រះវត្តមានរបស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 297 17/11/25 1:47 in the afternoon

ហើយការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឲ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ (កូល៉ុស ៣:២៣)។

ដើម្បីផ្គាប់ព្រះទ័យព្រះអង្គតែប៉ុណ្ណោះ

លោក ខាល ស្ពែលល័រ (Kyle Speller) មានកេរ្តិ៍ឈ្មោះល្បីល្បាញបំផុត ដោយសារគាត់មានសមត្ថភាពនិយាយ ក្នុងការប្រកាសជាសាធារណៈ ដោយសម្លេងប្រកបដោយភាពក្លៀវក្លា ក្នុងអំឡុងពេលនៃការប្រកួតកីឡាបាល់បោះស្វែងរកជើងឯក។ រៀងរាល់ពេលដែលគាត់ចាប់ផ្តើមប្រកាសដាក់ក្បាលមេក្រូ ដោយសម្លេងដែលកន្ត្រាក់អារម្មណ៍របស់អ្នកគាំទ្ររាប់ពាន់នាក់ នៅក្នុងទីលានប្រកួតរបស់NBA បូករួមទាំងទស្សនិកជនរាប់លាននាក់កំពុងទស្សនា ឬស្តាប់តាមទូរទស្សន៍ និងវិទ្យុ ជាហេតុនាំឲ្យគេជ្រើសរើសគាត់ឲ្យឈរឈ្មោះសម្រាប់ការប្រកួត ស្វែងរកអ្នកអត្ថាធិប្បាយសម្រាប់ការប្រកួតកីឡាដែលល្បីល្បាញជាងគេបំផុតប្រចាំឆ្នាំ២០២២។ គាត់ថា គាត់យល់អំពីអារម្មណ៍របស់ទស្សនិកជន ហេតុនេះហើយគាត់ក៏បានបង្កើតបរិយាកាសដ៏រីករាយសម្រាប់អ្នកគាំទ្ររបស់ក្រុមកីឡាការដែលជាម្ចាស់ផ្ទះ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គ្រប់ពាក្យពេចន៍ដែលគាត់បាននិយាយយ៉ាងបិទប្រសប់ ដែលគេបានចាក់បញ្ចាំងជាពិសេសនៅលើកញ្ចក់ទូរទស្សន៍ និងចាក់ផ្សាយនៅតាមវិទ្យុ គឺសុទ្ធតែដើម្បីថ្វាយសិរីល្អដល់ព្រះ។ គាត់ថា គ្រប់កិច្ចការដែលគាត់ធ្វើ គឺសុទ្ធតែដើម្បីផ្គាប់ព្រះទ័យព្រះប៉ុណ្ណោះ ដែលព្រះអង្គក៏ជាទស្សនិកជនរបស់គាត់។

សាវ័កប៉ុលបាននិយាយសង្កត់ធ្ងន់អំពីក្រមសីលធម៌ស្រដៀងនេះទៅកាន់ពួកជំនុំនៅទីក្រុងកូល៉ុសផងដែរ ដែលនៅទីនោះសមាជិកពួកជំនុំខ្លះមានការសង្ស័យអំពីភាពជាព្រះ និងអំណាចគ្រប់គ្រងរបស់ព្រះគ្រីស្ទ ហើយបានបណ្តោយឲ្យការសង្ស័យនេះជ្រាបចូលក្នុងការរស់នៅរបស់ពួកគេ។ ផ្ទុយទៅវិញ សាវ័ក ប៉ុល ក៏បានបង្រៀនពួកគេថា «ក្នុងគ្រប់ទាំងអស់ ទោះបើការអ្វីដែលអ្នករាល់គ្នានឹងធ្វើ ដោយពាក្យសំដី ឬកិរិយាក៏ដោយ ចូរធ្វើទាំងអស់ ដោយព្រះនាមនៃព្រះអម្ចាស់យេស៊ូវ ទាំងអរព្រះគុណដល់ព្រះដ៏ជាព្រះវរបិតា ដោយសារទ្រង់ផង» (កូល៉ុស ៣:១៧)។

សាវ័ក ប៉ុល បានបន្ថែមទៀតថា «ការអ្វីដែលត្រូវធ្វើក៏ដោយ ចូរធ្វើឲ្យអស់ពីចិត្ត ទុកដូចជាធ្វើថ្វាយដល់ព្រះអម្ចាស់ មិនមែនដល់មនុស្សទេ» (ខ.២៣)។ សម្រាប់លោក ខាល ស្ពែលល័រវិញ ការអ្វីដែលគាត់ត្រូវធ្វើក៏បានរាប់បញ្ចូលតួនាទីរបស់គាត់ ជាគ្រូបង្រៀនព្រះគម្ពីរក្នុងក្រុមកីឡាការបស់គាត់ផងដែរ។ គាត់ថា ការបង្រៀនព្រះបន្ទូលគឺជាកិច្ចការចម្បងរបស់គាត់ ហើយការធ្វើអត្ថាធិប្បាយសម្រាប់ការប្រកួតកីឡា គ្រាន់តែជាការងារបន្ទាប់បន្សំប៉ុណ្ណោះ។ កិច្ចការដែលយើងធ្វើថ្វាយព្រះអាចមានន័យ និងមានសារៈសំខាន់ដូចនេះផងដែរ នៅពេលដែលយើងព្យាយាមផ្គាប់ព្រះទ័យព្រះអង្គតែប៉ុណ្ណោះ។—Patricia Raybon

តើអ្នកធ្វើការងាររាល់ថ្ងៃ ដើម្បីផ្គាប់ចិត្តនរណា? តើការធ្វើការដើម្បីផ្គាប់ចិត្តព្រះបានកែប្រែទស្សនៈដែលអ្នកមានចំពោះការងារដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានបណ្តាលចិត្តទូលបង្គំឲ្យធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីផ្គាប់ព្រះទ័យព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៥៦-៥៨ និង២ថែស្សាឡូនីច ២

ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង (ម៉ាថាយ ៦:៣៣)។

ការអ្វីដែលមានប្រយោជន៍

លោក សែម រ៉ូឌា (Sam Rodia) បានចាប់ផ្តើមការសាងសង់ប៉មមួយចំនួន ដែលមានរាងស្តួច និងកំពូលស្រួចៗ ចាប់តាំងពីឆ្នាំ១៩២១។ ៣៣ឆ្នាំក្រោយមក ប៉មដែលជារូបចម្លាក់ចំនួន១៧ បានលេចឡើងកម្ពស់ដល់៣០ម៉ែត្រនៅទីក្រុងឡូសអេនជេលេស។ លោក ជើរី ហ្គាសៀ (Jerry Garcia) ជាតន្ត្រីករដែលមិនឲ្យតម្លៃមកលើស្នាដៃសិល្បៈដែលលោក រ៉ូឌា បានចំណាយសាងសង់ពេញមួយជីវិតនោះទេ។ លោក ហ្គាសៀ បាននិយាយថា ប៉មទាំងនោះក្លាយជាវត្ថុមានប្រយោជន៍ បន្ទាប់ពីលោក រូឌា បានស្លាប់ទៅ ប៉ុន្តែលោក ហ្គាសៀ មិនចង់ធ្វើអ្វីមួយដែលមានប្រយោជន៍ តែនៅពេលដែលខ្លួនគាត់បានស្លាប់ហើយ ដូចលោក រ៉ូឌា នោះទេ។

ដូចនេះ តើមានអ្វីខ្លះដែលមានប្រយោជន៍សម្រាប់គាត់? លោក បប់ វើរ (Bob Weir) ដែលជាមិត្តរួមក្រុមតន្ត្រីរបស់គាត់ បានបកស្រាយអំពីទស្សនវិជ្ជារបស់ពួកគេជាសរុបថា «ក្នុងពេលអស់កល្បជានិច្ចបន្ទាប់ពីអ្នកស្លាប់ទៅ គ្មាននរណាម្នាក់នឹកចាំអំពីអ្នកទៀតទេ។ ដូចនេះ ចូរយើងធ្វើរឿងដែលសប្បាយៗទាន់នៅរស់?»

បុរសមានប្រាជ្ញា និងមានទ្រព្យសម្បត្តិសុកស្តម្ភម្នាក់ធ្លាប់ព្យាយាមស្វែងរក «ការអ្វីដែលមានប្រយោជន៍» ដោយធ្វើអ្វីៗដែលគាត់អាចធ្វើបាន។ គឺដូចដែលគាត់បានបង្រៀនថា «មកចុះ យើងនឹងល្បងលឯងដោយការអរសប្បាយ ឯងនឹងបានគ្រឹកគ្រេងសប្បាយទទេ តែមើល ការនោះក៏គ្មានប្រយោជន៍ដែរ» (សាស្តា ២:១)។ ប៉ុន្តែ គាត់ក៏បានកត់សម្គាល់ឃើញថា «ពីព្រោះអ្នកមានប្រាជ្ញា ក៏ដូចគ្នានឹងអ្នកល្ងីល្ងើដែរ គ្មានអ្នកណានឹកចាំពី១លើសជាង១ជាដរាបទេ» (ខ.១៦)។ គាត់ក៏បានសន្និដ្ឋានថា «ការទាំងអស់សុទ្ធតែគ្មានប្រយោជន៍ ហើយជាអសារឥតការទទេ» (ខ.១៧)។

ការរស់នៅ និងព្រះរាជសាររបស់ព្រះយេស៊ូវបានផ្តល់ឲ្យនូវដំណោះស្រាយសម្រាប់ការរស់នៅ ដោយការគិតមិនបានវែងឆ្ងាយដូចនេះ។ ព្រះយេស៊ូវបានយាងមក ដើម្បីប្រទានយើងនូវជីវិតពេញបរិបូរ (យ៉ូហាន ១០:១០) ហើយបានបង្រៀនយើងឲ្យរស់នៅក្នុងពេលបច្ចុប្បន្ន ដោយគិតដល់ជីវិតអស់កល្បជានិច្ច។ គឺដូចដែលព្រះអង្គមានបន្ទូលថា «កុំឲ្យប្រមូលទ្រព្យសម្បត្តិទុកសំរាប់ខ្លួននៅផែនដី ជាកន្លែងដែលមានកន្លាត និងច្រែះស៊ីបំផ្លាញ ហើយចោរទំលុះប្លន់នោះឡើយ ត្រូវប្រមូលទ្រព្យសម្បត្តិ ទុកសំរាប់ខ្លួននៅឯស្ថានសួគ៌វិញ» (ម៉ាថាយ ៦:១៩-២០)។ បន្ទាប់មកព្រះអង្គមានបន្ទូលជាសរុបថា «ចូរស្វែងរកនគរ និងសេចក្តីសុចរិតនៃព្រះជាមុនសិន ទើបគ្រប់របស់ទាំងនោះ នឹងបានប្រទានមកអ្នករាល់គ្នាថែមទៀតផង» (ខ.៣៣)។

ការអ្វីដែលមានប្រយោជន៍ គឺមានលក្ខណៈដូចនេះឯង គឺមានប្រយោជន៍ទាំងនៅក្នុងជីវិតបច្ចុប្បន្ន ក៏ដូចជាអស់កល្បជានិច្ច។—Tim Gustafson

តើអ្នកចង់ឲ្យគេនឹកចាំអំពីអ្នកដូចម្តេចខ្លះ?
តើការ «បង្ករទ្រព្យទុកនៅស្ថានសួគ៌» មានន័យដូចម្តេចសម្រាប់អ្នក?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំ ឲ្យបម្រើព្រះអង្គដោយអំណរ ដោយគិតដល់ជីវិតអស់កល្បជានិច្ច ដែលទូលបង្គំនឹងបានរស់នៅជាមួយព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៥៩-៦១ និង២ថែស្សាឡូនីច ៣

អញនឹងធ្វើឲ្យមានលំពង់ដ៏សុចរិតពន្ធកឡើងដល់ដាវីឌ លំពង់នោះទ្រង់នឹងសំរេចសេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិតនៅក្នុងស្រុក (យេរេមា ៣៣:១៥)។

ព្រះអង្គតែងតែសម្រេចព្រះបន្ទូលសន្យា

ព្រះវិហារឈើឆ្កាងបរិសុទ្ធ ជាសំណង់អាគារដ៏ស្រស់ស្អាតនៅក្នុងតំបន់ជួរភ្នំក្រហម សេដូណា រដ្ឋអារីហ្សូណា។ ពេលខ្ញុំដើរចូលព្រះវិហារតូចមួយនោះ ភ្លាមៗនោះខ្ញុំក៏មានការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះរូបចម្លាក់ព្រះយេស៊ូវជាប់នៅឈើឆ្កាង ដែលមានរូបរាងចម្លែកដូចដើមឈើពីរដើម តែមិនដូចឈើឆ្កាងធម្មតា។ ដើមឈើមួយដើមដែលងាប់មានរាងផ្តេក ជាតំណាងឲ្យពូជអំបូររបស់សាសន៍អ៊ីស្រាអែលក្នុងគ្រាសញ្ញាចាស់ ដែលបានបដិសេធន៍ព្រះ។ ដើមឈើមួយដើមទៀតដែលមានរាងបញ្ឈរទៅលើ មានមែកបែកទៅសងខាង ជានិមិត្តសញ្ញាតំណាងឲ្យពូជអំបូរយូដាដ៏រុងរឿង និងខ្សែលោហិតរបស់ស្តេច ដាវីឌ។

យើងមិនថ្វាយបង្គំរូបព្រះទេ ប៉ុន្តែមាននិមិត្តសញ្ញាខ្លះបានធ្វើឲ្យយើងនឹកចាំអំពីបទទំនាយសំខាន់ៗក្នុងគ្រាសញ្ញាចាស់ អំពីព្រះយេស៊ូវ។ ទោះពូជអំបូរយូដាកំពុងរស់នៅក្នុងនាមជាឈ្លើយសឹក ក្នុងទឹកដីសាសន៍ដទៃក៏ដោយ ហោរា យេរេមា បាននាំព្រះរាជសារនៃក្តីសង្ឃឹមមកពីព្រះអម្ចាស់យ៉ាងដូចនេះថា «ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា មើល នឹងមានគ្រាមកដល់ ដែលអញនឹងសំរេចតាមពាក្យល្អ ដែលអញបាននិយាយពីដំណើរពូកវង្សអ៊ីស្រាអែល និងពូកវង្សយូដា» (យេរេមា ៣៣:១៤) ពាក្យល្អនោះ គឺជាព្រះបន្ទូលសន្យាថា នឹងប្រទានព្រះអង្គសង្គ្រោះមួយអង្គ ដែលនឹង «សំរេចសេចក្ដីយុត្តិធម៌ និងសេចក្ដីសុចរិតនៅក្នុងស្រុក» (ខ.១៥)។ គេអាចស្គាល់អត្តសញ្ញាណរបស់ព្រះអង្គសង្គ្រោះនោះ ដោយសារទ្រង់ «ពន្លកឡើងដល់ដាវីឌ» (ខ.១៥) បានសេចក្ដីថា ទ្រង់ជាកូនចៅជំនាន់ក្រោយរបស់ស្តេច ដាវីឌ។

ព្រះគម្ពីរបានលើកឡើងអំពីសេចក្ដីពិតដ៏សំខាន់ តាមរបៀបដ៏ប៉ិនប្រសប់ ឲ្យយើងបានដឹងថា ព្រះអម្ចាស់មានព្រះទ័យស្មោះត្រង់ក្នុងការធ្វើតាមព្រះបន្ទូលសន្យារបស់ព្រះអង្គ តាមរយៈខ្សែលោហិតនៃគ្រួសាររបស់ព្រះយេស៊ូវ។ ជាងនេះទៅទៀត ការនេះក៏បានរំឭកយើងថា សេចក្ដីស្មោះត្រង់របស់ព្រះអង្គពីអតីតកាល ក៏បានផ្តល់ឲ្យយើងនូវការធានាថា ព្រះអង្គនឹងនៅតែមានព្រះទ័យស្មោះត្រង់ ក្នុងការសម្រេចព្រះបន្ទូលសន្យាដែលព្រះអង្គមានចំពោះយើង សម្រាប់ពេលអនាគតផងដែរ។—Lisa M. Samra

តើមានព្រះបន្ទូលសន្យាអ្វីផ្សេងទៀត ដែលព្រះយេស៊ូវបានសម្រេច? តើការសម្រេចព្រះបន្ទូលសន្យាទាំងនោះ បានលើកទឹកចិត្តអ្នកយ៉ាងណាខ្លះ?

ឱព្រះដ៏មានចេស្តា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលតែងតែសម្រេចព្រះបន្ទូលសន្យារបស់ព្រះអង្គមិនដែលខាន។

Daily Manna 2026_Content Enhance.indd 300 17/11/25 1:47 in the afternoon

ដ្បិតអ្នករាល់គ្នាលាងចានលាងថាសតែខាងក្រៅ ឯខាងក្នុងវិញ នោះពេញដោយអំពើប្លន់ និងសេចក្តីហួសខ្នាតទទេ (ម៉ាថាយ ២៣:២៥)។

បានជ្លាសប្រែពីខាងក្នុងមក

ថ្ងៃមួយ អគ្គីភ័យបានលេបត្របាក់អាគារខ្ពស់គ្រែនហ្វេល ដែលមានកម្ពស់២៤ជាន់នៅភាគខាងលិចនៃទីក្រុងឡុង បានបណ្តាលឲ្យមនុស្ស៧០នាក់បាត់បង់ជីវិត ក្នុងឧបទេវហេតុនៃអគ្គីភ័យអាក្រក់បំផុតក្នុងប្រទេសអង់គ្លេស ចាប់តាំងពីសម័យសង្គ្រាមលោកលើកទី២មក។ តាមការស៊ើបអង្កេត បានឲ្យដឹងថា មូលហេតុចម្បងដែលបណ្តាលឲ្យមានភ្លើងឆេះរាលដាលយ៉ាងចាប់រហ័សដូចនេះ គឺដោយសារគេបានដំឡើងបន្ទះស្រោបអាគារ ដើម្បីលម្អសោភ័ណភាពនៅខាងក្រៅអាគារនោះ។ សម្ភារៈដែលគេបានប្រើស្រោបអាគារនោះ ត្រូវបានផលិតពីអាលុយមីញ៉ូមស្រោបជុំវិញស្នូលធ្វើពីជ័រផ្លាស្ទិកដែលងាយឆាបឆេះយ៉ាងខ្លាំង។

ហេតុអ្វីបានជាគេអនុញ្ញាតឲ្យសម្ភារៈដ៏គ្រោះថ្នាក់ដូចនេះ មានដាក់លក់ និងប្រើប្រាស់នៅលើអាគារ? ក្រុមហ៊ុនដែលបានលក់សម្ភារៈនោះ មិនបានបើកបង្ហាញឲ្យគេដឹងជាមុនអំពីលទ្ធផលនៃការធ្វើតេស្តអំពីសុវត្ថិភាពរបស់សម្ភារៈដែលងាយឆាប់ឆេះឡើយ។ អ្នកទិញមានការទាក់ទាញចំពោះតម្លៃថោករបស់វា ដោយមិនបានគិតអំពីផ្លាកសញ្ញាដាស់តឿនអំពីគ្រោះថ្នាក់។ បន្ទះស្រោបអាគារនោះ មានពណ៌ទឹកប្រាក់ចែងចាំងដ៏ស្រស់ស្អាតតែសម្បកក្រៅប៉ុណ្ណោះ។

ព្រះយេស៊ូវបានមានបន្ទូលធ្ងន់ៗបំផុតសំដៅទៅលើពួកគ្រូសាសនា ដែលបានលាក់ចាំងភាពពុករលួយនៅខាងក្នុង ហើយល្អតែសម្បកក្រៅ។ ព្រះអង្គមានបន្ទូលថា ពួកគេប្រៀប «ដូចជាម៉ុងខ្មោចដែលលាបស ឯខាងក្រៅល្អមើលពិតមែន តែខាងក្នុងមានពេញដោយឆ្អឹងខ្មោច និងសេចក្តីស្មោកគ្រោកគ្រប់មុខវិញ» (ម៉ាថាយ ២៣:២៧)។ ពួកគេមិនបានដេញតាម «សេចក្តីសំខាន់ជាង ដែលនៅក្នុងក្រឹត្យវិន័យដូចជាសេចក្តីយុត្តិធម៌ សេចក្តីមេត្តាករុណា នឹងសេចក្តីជំនឿ» (ខ.២៣) ដោយពួកគេផ្តោតទៅលើសម្បកក្រៅ ដោយលាងចានលាងថាសតែខាងក្រៅ តែមិនបានលាងជម្រះភាពលោភលន់ និងសេចក្តីហួសខ្នាតនៅក្នុងចិត្តទេ (ខ.២៥)។

យើងងាយនឹងផ្តោតទៅលើសម្រស់នៅខាងក្រៅ ជាជាងនាំបាប និងភាពប្រេះបែករបស់យើងទៅបើកបង្ហាញនៅចំពោះព្រះ ដោយចិត្តស្មោះត្រង់។ ប៉ុន្តែ សម្បកក្រៅដែលមើលទៅស្អាត មិនអាចកាត់បន្ថយភាពស្មោកគ្រោកនៅក្នុងចិត្តដែលពុករលួយនោះទេ។ ព្រះអម្ចាស់បានត្រាស់ហៅយើង ឲ្យចូលមករកព្រះអង្គ ដើម្បីឲ្យព្រះអង្គកែប្រែយើងរាល់គ្នា ពីខាងក្នុងមកក្រៅ (១យ៉ូហាន ១:៩)។—Monica La Rose

តើអ្នកបានព្យាយាមលាក់ចាំងភាពពុករលួយនៅខាងក្នុងចិត្តអ្នក នៅពេលណា? តើអ្នកអាចដាក់អាទិភាពទៅលើការកែប្រែខាងក្នុង ដោយរបៀបណា?

ឱព្រះប្រកបដោយព្រះគុណ សូមព្រះអង្គជួយទូលបង្គំ មិនឲ្យលាក់បាំងភាពប្រេះបែករបស់ទូលបង្គំឡើយ តែអនុញ្ញាតឲ្យព្រះអង្គកែប្រែជីវិតទូលបង្គំទាំងស្រុង។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសាយ ៦៥-៦៦ និង ១ធីម៉ូថេ ២

នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយ១អង្គទៀតមកអ្នករាល់គ្នា ឲ្យបានគង់នៅជាមួយនៅអស់កល្បរៀងទៅ (យ៉ូហាន ១៤:១៦)។

ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយ

នៅពេលដែលអ្នកបម្រើលើយន្តហោះពិនិត្យមើលសំបុត្រយន្តហោះរបស់អ្នកដំណើរម្នាក់ ដែលត្រូវធ្វើដំណើរពីទីក្រុងឆាឡុត រដ្ឋឃ្យ៉ូឡាយណាខាងជើងទៅទីក្រុងញូយ៉ក គាត់ក៏បានឃើញអ្នកដំណើរនោះមានទឹកមុខថប់បារម្ភក្នុងការធ្វើដំណើរតាមយន្តហោះ។ គាត់ក៏បានកាន់ដៃអ្នកដំណើរនោះ នាំចូលទៅកន្លែងអង្គុយ ហើយក៏បានពន្យល់អំពីដំណើរការនៃជើងហោះហើរនោះ ហើយក៏បានលើកទឹកចិត្តគាត់ថា គាត់នឹងសុខសប្បាយ ក្នុងការធ្វើដំណើរ។ គាត់ប្រាប់អ្នកដំណើរនោះថា “នៅពេលដែលអ្នកចូលក្នុងយន្តហោះនេះ ពួកខ្ញុំគិតអំពីសុខទុក្ខរបស់អ្នក។ បើអ្នកមានអារម្មណ៍ថាមិនស្រួលខ្លួន សូមប្រាប់ពួកខ្ញុំឲ្យបានដឹងថា មានការអ្វីខ្លះដែលពួកខ្ញុំអាចធ្វើសម្រាប់អ្នកបាន? វត្តមាននៃការកម្សាន្តចិត្តរបស់គាត់បានធ្វើឲ្យខ្ញុំនឹកចាំ អំពីព្រះបន្ទូលរបស់ព្រះយេស៊ូវអំពីការអ្វីដែលព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើសម្រាប់អ្នកជឿព្រះអង្គ។

ការសុគត និងការមានព្រះជន្មរស់ឡើងវិញ និងការយាងឡើងស្ថានសួគ៌វិញរបស់ព្រះយេស៊ូវមានភាពចាំបាច់ និងមានប្រយោជន៍ក្នុងការជួយសង្គ្រោះមនុស្សជាតិឲ្យរួចពីបាប ប៉ុន្តែការនេះក៏បានបណ្តាលឲ្យពួកសាវ័កមានចិត្តថប់បារម្ភ និងទុក្ខព្រួយផងដែរ (យ៉ូហាន ១៤:១)។ ហេតុនេះហើយ ព្រះអង្គក៏បានធានាពួកគេថា ព្រះអង្គនឹងមិនទុកពួកគេចោល ឲ្យបំពេញបេសកកម្មក្នុងលោកីយ៍ ដោយខ្លួនឯងនោះទេ។ ព្រះអង្គនឹងចាត់ព្រះវិញ្ញាណ ជាព្រះដ៏ជាជំនួយ១អង្គ ឲ្យបានគង់នៅជាមួយពួកគេអស់កល្បរៀងទៅ (ខ.១៦)។ ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើបន្ទាល់អំពីព្រះយេស៊ូវដល់ពួកគេ ហើយរំឭកពួកគេអំពីការអ្វីដែលព្រះអង្គបានធ្វើ និងមានបន្ទូល (ខ.២៦)។ ពួកគេនឹងទទួល “ការកម្សាន្តចិត្ត” ពីព្រះអង្គក្នុងអំឡុងពេលដ៏ពិបាក (កិច្ចការ ៩:៣១)។

ក្នុងជីវិតនេះ មនុស្សទាំងអស់សុទ្ធតែជួបភាពច្របូកច្របល់ ដោយសារការថប់បារម្ភ ការភ័យខ្លាច និងទុក្ខសោក។ ប៉ុន្តែ ព្រះយេស៊ូវបានសន្យាថា ព្រះវិញ្ញាណរបស់ព្រះអង្គតែងតែមានព្រះវត្តមានគង់នៅ ដើម្បីកម្សាន្តចិត្តយើងជានិច្ច។—Marvin Williams

តើជីវិតអ្នកបានជួបការលំបាកអ្វីខ្លះ ដែលធ្វើឲ្យអ្នកថប់បារម្ភ ឬបាក់ទឹកចិត្ត? តើអ្នកអាចស្វែងព្រះវត្តមាននៃការកម្សាន្តចិត្តរបស់ព្រះវិញ្ញាណបរិសុទ្ធដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានព្រះវិញ្ញាណនៃការកម្សាន្តចិត្ត និងគំនិតយោបល់។

Daily Manna 2026_Content Enhance.indd 302 17/11/25 1:47 in the afternoon

តើមិនមែនឲ្យឯងបានចែកអាហារដល់អ្នកដែលឃ្លាន ហើយនាំមនុស្សក្រដែលត្រូវដេញពីផ្ទះគេមកឯផ្ទះឯងទេឬអី? (អេសាយ ៥៨:៧)។

អាហារសម្រាប់មនុស្សស្រេកឃ្លាន

ក្រុមខាងកើតនៃទ្វីបអាហ្វ្រិក បានរងគ្រោះដោយសារភាពរាំងស្ងួតដ៏កាចសាហាវ អស់ជាច្រើនឆ្នាំ ដែលបានបំផ្លាញដំណាំ ធ្វើឲ្យសត្វចិញ្ចឹមស្លាប់អស់ជាច្រើនក្បាល ហើយបណ្តាលឲ្យមនុស្សរាប់លាននាក់ស្ថិតនៅក្នុងគ្រោះថ្នាក់។ ក្នុងចំណោមប្រជាជនដែលងាយរងគ្រោះបំផុត ដែលមានដូចជាប្រជាជននៅក្នុងជំរុំជនភៀសខ្លួន ដែលបានរត់គេចពីសង្គ្រាម និងការភៀបសង្កត់ ពួកគេកំពុងតែស្ថិតក្នុងស្ថានភាពដែលកាន់តែគួរឲ្យភ័យខ្លាច។ កាលពីពេលថ្មីៗនេះ មានរបាយការណ៍មួយបានពិពណ៌នាអំពីស្ត្រីជាម្តាយវ័យក្មេងម្នាក់ ដែលបាននាំកូនង៉ែតរបស់នាងចូលមកជួបមន្ត្រីអង្គការជនភៀសខ្លួន។ ទារកនោះមានបញ្ហាខ្វះជីវជាតិធ្ងន់ធ្ងរ ដែលបានបណ្តាលឲ្យសក់ និងស្បែករបស់នាង មានសភាពស្ងួត និងផុយស្រួយយ៉ាងខ្លាំង។ នាងមិនអាចញញឹម ហើយក៏មិនអាចបរិភោគអាហារបាន។ រាងកាយដ៏តូចល្អិតរបស់នាងស្ទើរតែលែងមានពន្លឺជីវិតទៅហើយ។ អ្នកជំនាញក៏បានប្រញាប់ជួយសង្គ្រោះនាង។ អរព្រះគុណព្រះអង្គ ទោះជំរុំជនភៀសខ្លួននោះបានជួបការខ្វះខាតយ៉ាងណាក៏ដោយ គេនៅតែអាចបង្កើតទីកន្លែង សម្រាប់ផ្តល់ឲ្យនូវការសង្គ្រោះបន្ទាន់ ដើម្បីស្រោចស្រង់ជីវិតមនុស្សជាច្រើន ឲ្យរួចផុតពីសេចក្តីស្លាប់។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីពេលដែលព្រះអម្ចាស់ត្រាស់ហៅរាស្ត្រព្រះអង្គឲ្យបញ្ចេញពន្លឺ និងសេចក្តីស្រឡាញ់របស់ព្រះអង្គនៅកន្លែងដែលមានមនុស្សជាច្រើនកំពុងស្ថិតក្នុងភាពអស់សង្ឃឹម (អេសាយ ៥៨:៨)។ នៅកន្លែងណាដែលមានមនុស្សស្រេកឃ្លាន មានជំងឺ ឬជួបការគំរាមកំហែង ព្រះអម្ចាស់ត្រាស់ហៅរាស្ត្រព្រះអង្គឲ្យនាំមុខគេនៅក្នុងការផ្តល់ឲ្យនូវអាហារ ថ្នាំពេទ្យ និងសុវត្ថិភាពដល់ពួកគេ ដោយនូវព្រះនាមព្រះយេស៊ូវ។ ហោរាអេសាយ បានស្តីបន្ទោសប្រជាជនអ៊ីស្រាអែលនៅគ្រាសញ្ញាចាស់ ដោយសារពួកគេគិតស្មានថា ខ្លួនមានចិត្តស្មោះត្រង់នៅក្នុងការអធិស្ឋាន និងតមអត់ តែទង្វើមនឹងនោះពួកគេមិនអើពើចំពោះកិច្ចការមនុស្សធម៌ ដែលមានដូចជា ការចែកអាហារដល់អ្នកអត់ឃ្លាន ការផ្តល់ឲ្យជម្រកដល់ជនអនាថា និងសំលៀកបំពាក់ដល់អ្នកដែលគ្មានសំលៀកបំពាក់ (ខ.៧)។

ព្រះអម្ចាស់សព្វព្រះទ័យឲ្យអ្នកស្រេកឃ្លានទាំងឡាយ ទទួលអាហារទាំងខាងរូបកាយ និងវិញ្ញាណ។ ហើយព្រះអង្គធ្វើការក្នុងចិត្តយើង ហើយធ្វើការតាមរយៈយើង ដើម្បីបំពេញតម្រូវការពួកគេ។—Winn Collier

តើអ្នកសង្កេតឃើញមនុស្សនៅក្បែរអ្នកកំពុងមានការស្រេកឃ្លានប្រភេទណាខ្លះ? តើព្រះអម្ចាស់កំពុងត្រាស់ហៅអ្នកឲ្យផ្តល់ជំនួយដល់ពួកគេដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំ ឲ្យបានរួមចំណែកនៅក្នុងការនាំអាហារ សេចក្តីស្រឡាញ់ និងការកម្សាន្តចិត្តដល់អ្នកដែលកំពុងស្រេកឃ្លាន និងពិបាកចិត្ត។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | យេរេមា ៣-៥ និង១ធីម៉ូថេ ៤

ទូលបង្គំបានអំពាវនាវនៅក្នុងពោះនៃស្ថានឃុំព្រលឹងមនុស្សស្លាប់ ហើយទ្រង់បានឮសំឡេងរបស់ទូលបង្គំ (យ៉ូណាស ២:៣)។

វត់គេចពីព្រះ

មានពេលមួយ ជូលា (Julie) និងលីស (Liz) បានអុំទូកកាយ៉ាក ចេញពីឆ្នេរសមុទ្រនៅរដ្ឋកាលីហ្វ័ញ៉ា ដើម្បីរកមើលសត្វត្រីបាឡែនដែលមានបុកនៅលើខ្នង។ ពួកគេបានដឹងថា ត្រីបាឡែនទាំងនោះមានសកម្មភាពនៅលើផ្ទៃទឹកខាងលើ ដែលធ្វើឲ្យពួកគេងាយនឹងប្រទះឃើញពួកវា។ ស្ត្រីទាំងពីរក៏បានជួបរឿងដែលគួរឲ្យភ្ញាក់ផ្អើលបំផុតក្នុងជីវិតពួកគេ នៅពេលដែលមានត្រីបាឡែនមួយក្បាលបានងើបឡើងពីក្នុងទឹក ចំពីខាងក្រោមពួកគេ។ អ្នកដែលបានមើលឃើញហេតុការណ៍នេះ ក៏ថតបានវីដេអូ ដែលក្នុងនោះគេឃើញមាត់របស់ត្រីបាឡែន ដែលមានទំហំធំសម្បើម បានលេចឡើងពីខាងក្រោមស្ត្រីទាំងពីរ ដែលហាក់ដូចជាមានរូបរាងតូចល្អិត។ បន្ទាប់ពីពួកគេបានលិចចូលទៅក្នុងទឹកមួយរយៈពេលខ្លីមក ពួកគេក៏បានគេចខ្លួន ដោយសុវត្ថិភាព។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំអំពីការបង្រៀនក្នុងព្រះគម្ពីរ អំពីហោរា យ៉ូណាស ដែលត្រូវ «ត្រីធំ»មួយក្បាលលេបចូលក្នុងពោះ (យ៉ូណាស ១:១៧)។ ព្រះអម្ចាស់បានបង្គាប់គាត់ ឲ្យនាំព្រះរាជសាររបស់ព្រះអង្គទៅប្រកាសប្រាប់អ្នកក្រុងនីនីវេ ប៉ុន្តែហោរា យ៉ូណាស បានយល់ឃើញថា ពួកគេមិនសក្តិសមនឹងទទួលការអត់ទោសពីព្រះអម្ចាស់ទេ។ ដូចនេះ គាត់មិនបានស្តាប់បង្គាប់ព្រះអង្គឡើយ ផ្ទុយទៅវិញគាត់បានរត់គេច ដោយជិះសំពៅទៅកន្លែងផ្សេង។ ព្រះអម្ចាស់ក៏បានធ្វើឲ្យមានខ្យល់ព្យុះយ៉ាងខ្លាំង ដែលបណ្តាលឲ្យគេបោះគាត់ពីលើសំពៅចូលទៅក្នុងទឹកសមុទ្រ។

ព្រះអម្ចាស់បានប្រទានផ្លូវមួយ ដើម្បីរក្សាជីវិតរបស់លោក យ៉ូណាស ឲ្យរួចផុតពីសេចក្តីស្លាប់នៅក្នុងសមុទ្រទឹកជ្រៅ ដោយឲ្យសត្វត្រីធំមួយក្បាលលេបគាត់ចូលទៅក្នុងពោះ។ លោក យ៉ូណាស ក៏បានអំពាវនាវដល់ព្រះអម្ចាស់ ហើយព្រះអង្គក៏បានស្តាប់ពាក្យដែលគាត់ទូលអង្វរ (២:៣)។ បន្ទាប់ពីគាត់បានទទួលស្គាល់កំហុស ហើយបង្ហាញចេញនូវការសរសើរតម្កើងព្រះអង្គ និងទទួលស្គាល់សេចក្តីល្អរបស់ព្រះអង្គ ព្រះអង្គក៏បានបង្គាប់ឲ្យសត្វត្រីធំខ្លាក់គាត់ចេញមកលើដីគោក (ខ.១១)។

ដោយសារព្រះគុណព្រះ ពេលណាយើងទទួលស្គាល់កំហុសរបស់យើង ហើយទទួលជឿព្រះយេស៊ូវ និងមានជំនឿមកលើការលះបង់របស់ព្រះអង្គនៅលើឈើឆ្កាង យើងនឹងបានរួចផុតពីសេចក្តីស្លាប់ខាងវិញ្ញាណ ដែលយើងសមនឹងទទួល ហើយបានដកពិសោធន៍នឹងការកើតជាថ្មីតាមរយៈព្រះអង្គ។—Kirsten Holmberg

តើអ្នកធ្លាប់វត់គេចពីព្រះ នៅពេលណា? តើអ្នកបានដកពិសោធន៍នឹងជីវិតថ្មី តាមរយៈព្រះយេស៊ូវ យ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមទទួលស្គាល់កំហុសទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានជីវិតថ្មីដល់ទូលបង្គំតាមរយៈព្រះយេស៊ូវ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យេរេមា ៦-៨ និង១ធីម៉ូថេ ៥

ហេតុនោះបានជាយើងខ្ញុំសង្វាត ឲ្យបានគាប់ដល់ព្រះហឫទ័យទ្រង់ ទោះនៅក្នុងរូបកាយ ឬឃ្លាតពីរូបកាយក្តី (២កូរិនថូស ៥:៩)។

មានក្តីសង្ឃឹមក្នុងព្រះ

យេរេមី (Jeremy) មិនបានដឹងទេថា គាត់នឹងជួបរឿងអ្វីខ្លះ ពេលដែលគាត់ធ្វើដំណើរមកដល់សកលវិទ្យាល័យ ដើម្បីរៀនក្នុងវគ្គសិក្សាដែលមានរយៈពេល៣ឆ្នាំ ហើយសុំកន្លែងស្នាក់នៅសម្រាប់និស្សិត ដែលមានថ្លៃបន្ទប់ថោកបំផុត។ គាត់បាននឹកចាំថា កាលនោះគាត់រកបានបន្ទប់ស្នាក់នៅមួយដែលមិនគួរឲ្យចង់ស្នាក់នៅ ហើយបន្ទប់ទឹកក៏មានសភាពគគ្រិចយ៉ាងខ្លាំង។ គាត់ថា អ្វីដែលគាត់អាចធ្វើបាននោះ គឺត្រូវគិតថា គាត់មានកន្លែងស្នាក់នៅដ៏ល្អមួយ ក្នុងអំឡុងពេលនៃការសិក្សារយៈពេល៣ឆ្នាំ ដូចនេះគាត់នឹងបន្តរស់នៅទីនោះ ហើយប្រឹងប្រែងរៀនសូត្រអស់ពីលទ្ធភាព។

រឿងរបស់ យេរេមី បានឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈម ដែលយើងជួបប្រទះជារៀងរាល់ថ្ងៃ ក្នុង «ត្រសាលជាទីលំនៅរបស់យើងនៅលើផែនដី» ដែលជារូបកាយរបស់យើងម្នាក់ៗ ដែលនឹងស្លាប់នៅថ្ងៃណាមួយ (២កូរិនថូស ៥:១) ដែលកំពុងមានដំណើរទៅមុខ ក្នុងលោកីយ៍ដែលនឹងទៅដល់ចុងបញ្ចប់ (១យ៉ូហាន ២:១៧)។ ដូចនេះយើង «ថ្ងូរមែន ដោយមានបន្ទុកយ៉ាងធ្ងន់» (២កូរិនថូស ៥:៤) ខណៈពេលដែលយើងប្រឈមមុខដាក់ការលំបាកជាច្រើនក្នុងការរស់នៅ។

យើងអាចបន្តដំណើរទៅមុខទៀតបាន ដោយសារយើងមានសង្ឃឹមថា ថ្ងៃណាមួយយើងនឹងមានជីវិតអស់កល្ប ក្នុងរូបកាយដែលនឹងរស់ឡើងវិញនៅស្ថានសួគ៌ (ខ.៤) ហើយរស់នៅក្នុងផែនដីថ្មី ដែលមិនមានការឈឺចាប់ ថ្ងូរ និងការឈឺចាប់ឡើយ (រ៉ូម ៨:១៩-២២)។ ក្តីសង្ឃឹមនេះជួយឲ្យយើងរស់នៅឲ្យមានប្រយោជន៍បំផុតក្នុងជីវិតនៅពេលបច្ចុប្បន្ន ដែលព្រះអម្ចាស់បានប្រទាន។ ព្រះអង្គក៏នឹងជួយយើងឲ្យប្រើធនធាន និងអំណោយទានដែលព្រះអង្គបានប្រទានយើង ដើម្បីឲ្យយើងបានបម្រើព្រះអង្គ និងអ្នកដទៃ។ «ហេតុនោះបានជាយើងខ្ញុំសង្វាត ឲ្យបានគាប់ដល់ព្រះហឫទ័យទ្រង់ ទោះនៅក្នុងរូបកាយ ឬឃ្លាតពីរូបកាយក្តី» (២កូរិនថូស ៥:៩)។—Leslie Koh

រៀងរាល់ពេលអ្នកក្រោកពីដំណេកនៅពេលព្រឹក តើអ្នកអាចរំឭកអ្នកដូចម្តេចខ្លះអំពីក្តីសង្ឃឹម ដែលអ្នកមាន ដោយសារព្រះអង្គ? តើអ្នកអាចលើកទឹកចិត្តអ្នកដទៃដូចម្តេចខ្លះ ឲ្យមានក្តីសង្ឃឹមនេះដែរ?

ឱព្រះវរបិតា ទូលបង្គំទន្ទឹងរង់ចាំពេលដែលទូលបង្គំនឹងបានទៅរស់នៅជាមួយព្រះអង្គក្នុងផ្ទះនៅស្ថានសួគ៌។ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ព្រះបន្ទូលសន្យា និងកម្លាំង ដែលក្តីសង្ឃឹមនេះបានផ្តល់ឲ្យទូលបង្គំជារៀងរាល់ថ្ងៃ។

Daily Manna 2026_Content Enhance.indd 305 17/11/25 1:47 in the afternoon

ប្រាកដមែន ខ្ញុំប្រាប់អ្នកជាប្រាកដថា បើមិនបានកើតអំពីទឹក ហើយអំពីព្រះវិញ្ញាណ នោះគ្មានអ្នកណាអាចនឹងចូលទៅក្នុងនគរព្រះបានទេ (យ៉ូហាន ៣:៥)។

តើអ្នកបានកើតជាថ្មីហើយឬនៅ?

នៅថ្ងៃបុណ្យសព មេចុងភៅដែលមានតួនាទីចាត់ចែងម្ហូបអាហារសម្រាប់កម្មវិធីបុណ្យសព បានឮគ្រូអធិប្បាយចែកចាយអំពីការកើតជាថ្មី។ គាត់សួរគេថា តើការកើតជាថ្មីមានន័យដូចម្តេចខ្លះ? គាត់ថា គាត់មិនដែលឮពាក្យនេះពីមុនមកសោះ។ កូនប្រុសរបស់បុរសដែលបានទទួលមរណៈភាព ក៏បានឆ្លៀតឱកាសពន្យល់គាត់អំពីអត្ថន័យនៃពាក្យនេះ តាមបទគម្ពីរយ៉ូហាន ជំពូក៣។

គាត់ថា «យើងម្នាក់ៗសុទ្ធតែកើតបានមួយដងនៅលើផែនដីនេះ។ ព្រះអម្ចាស់មិនប្រើជញ្ជើងវែទម្ងន់ណាមួយដើម្បីថ្លឹងអំពើល្អ ជាមួយអំពើអាក្រក់របស់យើងនោះទេ។ តែដើម្បីឲ្យយើងរួចពីបាប ព្រះអង្គតម្រូវឲ្យយើងមានការកើតជាថ្មី ពីព្រះវិញ្ញាណបរិសុទ្ធ ជាការចាប់ផ្តើមជីវិតថ្មីក្នុងព្រះគ្រីស្ទ»។ គាត់និយាយបន្តទៀតថា «ហេតុនេះហើយព្រះយេស៊ូវបានសុគតនៅលើឈើឆ្កាង។ ព្រះអង្គបានបង់ថ្លៃលោះយើង ហើយបើកផ្លូវឲ្យយើងអាចមានជីវិតអស់កល្ប សម្រាប់រស់នៅជាមួយព្រះអង្គ។ យើងមិនអាចជួយសង្គ្រោះខ្លួនឯងបានទេ»។

ក្នុងបទគម្ពីរយ៉ូហាន ជំពូក៣ លោក នីកូដេម បានឆ្ងល់អំពីរបៀបដែលគាត់អាចរួចពីបាប ហើយចូលនគរព្រះ។ ក្នុងនាមគាត់ជាគ្រូសាសន៍យូដាម្នាក់ ដែលមានការរៀនសូត្រជ្រៅជ្រះក្នុងព្រះគម្ពីរ (ខ.១) គាត់បានទទួលស្គាល់ថា ព្រះយេស៊ូវមានលក្ខណៈខុសគេ ហើយការបង្រៀនរបស់ព្រះអង្គទៀតសោត ក៏មានអំណាច (ខ.២)។ គាត់ចង់ស្វែងយល់ពីព្រះអង្គដោយផ្ទាល់ ដូចនេះ គាត់ក៏បានទៅជួបព្រះយេស៊ូវទាំងយប់ ដើម្បីបកស្រាយចម្ងល់របស់គាត់។ លោក នីកូដេម ប្រាកដជាបានជឿព្រះបន្ទូលរបស់ព្រះយេស៊ូវ ដែលបង្គាប់ឲ្យ «កើតជាថ្មី» (ខ.៧) ហើយគាត់ប្រាកដជាបានជឿព្រះអង្គ ព្រោះគាត់បានជួយគេរៀបចំព្រះសពព្រះអង្គសង្គ្រោះសម្រាប់ការបញ្ចុះបន្ទាប់ពីព្រះអង្គបានសុគតនៅលើឈើឆ្កាង (១៩:៣៩)។

នៅថ្ងៃនោះ មេចុងភៅក៏បានសន្យាថា នឹងអានបទគម្ពីរយ៉ូហានដំណឹងល្អយ៉ូហាននៅក្នុងជំពូក៣ នៅពេលគាត់ត្រឡប់ទៅផ្ទះវិញ។ ចូរយើងកត់ចំណាំព្រះបន្ទូលព្រះយេស៊ូវជាប់នៅក្នុងចិត្តយើង ហើយចែកចាយជាមួយអ្នកដទៃ ដោយជំនួយពីព្រះអង្គ ដូចដែលកូនប្រុសរបស់បុរសដែលបានទទួលមរណៈភាពនោះ បានចែកចាយដល់មេចុងភៅផងដែរ។—Brent Hackett

តើការកើតជាថ្មីមានអត្ថន័យយ៉ាងណាចំពោះអ្នក? តើអ្នកអាចចែកចាយអំពីអត្ថន័យនៃការកើតជាថ្មីជាមួយអ្នកដទៃដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានអនុញ្ញាតឲ្យទូលបង្គំកើតជាថ្មី។ សូមព្រះវិញ្ញាណព្រះអង្គ ធ្វើការក្នុងចិត្តមនុស្សដែលទូលបង្គំចែកចាយ អំពីភាពចាំបាច់នៃការកើតជាថ្មី។

Daily Manna 2026_Content Enhance.indd 306 17/11/25 1:47 in the afternoon

អេសាវក៏រត់មកទទួល ហើយឱបថើប រួចយំជាមួយគ្នាទាំង២នាក់ (លោកុប្បត្តិ ៣៣:៤)។

ដោះបន្ទុកធ្ងន់ចេញ

កាលខ្ញុំរៀននៅមហាវិទ្យាល័យ ខ្ញុំបានសិក្សាអំពីស្នាដៃនិពន្ធរបស់លោក លោក វីលៀម សេកស្ពៀរ (William Shakespeare) បានមួយឆមាស។ គ្រូបានតម្រូវឲ្យសិស្សម្នាក់មានសៀវភៅធំមួយក្បាល ដែលផ្ទុកទៅដោយសំណេរទាំងអស់ដែលលោក សេកស្ពៀរ បាននិពន្ធ។ សៀវភៅនោះធំមានទម្ងន់បួនប្រាំគីឡូ ហើយខ្ញុំត្រូវស្ពាយវាក្នុងកាបូបអស់ជាច្រើនម៉ោងរៀងរាល់ពេលខ្ញុំទៅរៀន។ ការស្ពាយកាបូបធ្ងន់យ៉ាងនេះជាប្រចាំ បានធ្វើឲ្យខ្ញុំឈឺខ្នង ហើយទីបំផុត ខ្សែកាបូបស្ពាយក៏បានដាច់។

របស់ខ្លះមានទម្ងន់ធ្ងន់ពេកមិនអាចឲ្យយើងស្ពាយ ឬលីសែងបាន។ ឧទាហរណ៍ បន្ទុកផ្លូវអារម្មណ៍ដ៏ឈឺចាប់ពីអតីតកាលអាចសង្កត់ពីលើយើង ដោយភាពល្វីងជូរចត់ និងសេចក្តីសម្បប់។ ប៉ុន្តែ ព្រះអម្ចាស់សព្វព្រះទ័យឲ្យយើងមានសេរីភាពរួចផុតពីបន្ទុកនោះ តាមរយៈការអត់ទោសឲ្យអ្នកដទៃ ហើយផ្សះផ្សាជាមួយពួកគេ បើសិនជាអាច (កូល៉ុស ៣:១៣)។ ការឈឺចាប់បានចាក់ទំលុះចិត្តយើងកាន់តែជ្រៅប៉ុណ្ណា នោះយើងក៏ត្រូវចំណាយពេលកាន់តែច្រើន ទំរាំតែអាចរួចពីបន្ទុក។ តែយើងមិនគួរចប់បារម្ភពីរឿងនេះទេ។ លោក អេសាវ បានចំណាយពេលជាច្រើនឆ្នាំទំរាំតែអាចអត់ទោសឲ្យលោក យ៉ាកុប ដែលបានលួចសិទ្ធិ និងព្រះពរសម្រាប់បងច្បង (លោកុប្បត្តិ ២៧:៣៦)។

នៅពេលដែលអ្នកទាំងពីរជួបជុំគ្នា លោក អេសាវ ក៏បានអត់ឱនទោសឲ្យប្អូនប្រុសគាត់ ហើយថែមទាំងឱបប្អូនប្រុសគាត់ទៀតផង (៣៣:៤)។ ពួកគេបានស្រក់ទឹកភ្នែក មុននឹងនិយាយរកគ្នាឡើងវិញ។ លោក អេសាវ បានចងគំនុំនឹងលោក យ៉ាកុប អស់ជាច្រើនឆ្នាំ ទំរាំតែអាចលះបង់ចោលសេចក្តីកំហឹង ដែលបានធ្វើឲ្យគាត់មានចិត្តចង់សម្លាប់ប្អូនខ្លួនឯង (២៧:៤១)។ ក្នុងអំឡុងពេលប៉ុន្មានឆ្នាំនោះ លោក យ៉ាកុប ក៏មានឱកាសមើលឃើញទំហំនៃកំហុស ដែលគាត់បានធ្វើមកលើបងប្រុសគាត់ផងដែរ។ គាត់បានបន្ទាបខ្លួន ហើយក៏មានការគោរពចំពោះបងប្រុសគាត់ នៅក្នុងអំឡុងពេលជួបជុំគ្នានោះ (៣៣:៨-១១)។

នៅចុងបញ្ចប់ បងប្អូនទាំងពីរបានទៅដល់ចំណុចមួយ ដែលពួកគេមិនបានទាមទារអ្វីទាំងអស់ពីគ្នា (ខ.៩, ១៥)។ គឺល្មមនឹងឲ្យពួកគេអត់ទោស និងទទួលការអត់ទោស ហើយបន្តដំណើរទៅមុខទៀត ដោយរួចផុតពីបន្ទុកដ៏ធ្ងន់នៃអតីតកាល។—Jennifer Benson Schuldt

តើមានកំហុសអ្វីដែលអ្នកពិបាកអត់ទោសឲ្យបំផុត? តើការអត់ទោសឲ្យអ្នកដទៃបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងដែលអ្នកមានជាមួយព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គរំដោះទូលបង្គំឲ្យរួចពីភាពជូរល្វីង និងកំហឹង។

Daily Manna 2026_Content Enhance.indd 307 17/11/25 1:47 in the afternoon

កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះឲ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង (ភីលីព ៤:៦)។

ឈប់បង្អង់សិន ដើម្បីអធិស្ឋាន

អ្នកព្យាករណ៍ខុតនិយមម្នាក់នៅរដ្ឋមីស៊ីស៊ីពី មានឈ្មោះល្បីនៅតាមបណ្តាញអ៊ីនធឺណិត ដោយសារគាត់និយាយចេញនូវពាក្យដ៏សាមញ្ញតែ៦ម៉ាត់ ក្នុងអំឡុងពេលដែលគាត់ឡើងអានព័ត៌មានអំពីការព្យាករណ៍ធាតុអាកាសនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។ លោក ម៉ាត លូបហាន (Matt Laubhan) កំពុងតាមដានខ្យល់ព្យុះធំមួយ ហើយក៏បានដឹងថា មានខ្យល់កួចយក្សថ្ងូនដូចមួយហៀបនឹងបោះពួយទៅរកទីក្រុងអាម៉ូរី។ នៅពេលដែលលោក លូបហាន កំពុងអានព័ត៌មាន ដែលកំពុងផ្សាយផ្ទាល់នៅលើកញ្ចក់ទូរទស្សន៍ គាត់ក៏បានឈប់បង្អង់សិន ដើម្បីបន្លឺសម្លេងអធិស្ឋានថា «ឱព្រះយេស៊ូវ សូមព្រះអង្គជួយពួកគេផង។ អាម៉ែន។» ទស្សនិកជននៅទូទាំងពិភពលោក ក៏បានស្តាប់ឮសម្លេងគាត់អធិស្ឋាននៅថ្ងៃនោះ។ ក្រោយមក ទស្សនិកជនខ្លះបាននិយាយថា ពាក្យដែលគាត់បានអធិស្ឋាននោះបានជំរុញពួកគេឲ្យស្វែងរកកន្លែងសុវត្ថិភាព។ ការអធិស្ឋានដែលគាត់បានធ្វើឡើង ដោយអស់ពីចិត្តនៅពេលនោះ ប្រហែលជាបានជួយមនុស្សជាច្រើនរាប់មិនអស់ឲ្យរួចផុតពីសេចក្តីស្លាប់។

ការអធិស្ឋានរបស់យើងក៏អាចនាំមកនូវការផ្លាស់ប្តូរផងដែរ។ យើងមិនចាំបាច់ត្រូវអធិស្ឋានវែងអន្លាយ។ យើងអាចអធិស្ឋានខ្លី។ ដោយពាក្យដ៏ពីរោះនៅពេលណាក៏បាន។ ទោះយើងនៅកន្លែងធ្វើការ កំពុងធ្វើការងារផ្ទះ ឬកំពុងសម្រាកលំហែក្តី យើងអាច «អធិស្ឋានឥតឈប់ឈរ» (១ថែស្សាឡូនិច ៥:១៧)។

ព្រះអម្ចាស់សព្វព្រះទ័យនឹងស្តាប់យើងអធិស្ឋាន ដោយមិនប្រកាន់ពេលវេលា។ សាវ័ក ប៉ុល បានរំឭកយើងឲ្យឈប់រស់នៅជាអ្នកទោសរបស់ការព្រួយបារម្ភ ឬការភ័យខ្លាចទៀត ដោយផ្ទេរទុក្ខព្រួយទាំងអស់ដល់ព្រះ។ គឺដូចដែលគាត់បានបង្រៀនថា «កុំឲ្យខ្វល់ខ្វាយអ្វីឡើយ ចូរទូលដល់ព្រះឲ្យជ្រាបពីសេចក្តីសំណូមរបស់អ្នករាល់គ្នាក្នុងគ្រប់ការទាំងអស់ ដោយសេចក្តីអធិស្ឋាន និងពាក្យទូលអង្វរ ទាំងពោលពាក្យអរព្រះគុណផង។ យ៉ាងនោះ សេចក្តីសុខសាន្តរបស់ព្រះ ដែលហួសលើសពីអស់ទាំងគំនិត និងជួយការពារចិត្ត ហើយនិងគំនិតរបស់អ្នករាល់គ្នាក្នុងព្រះគ្រីស្ទយេស៊ូវ» (ភីលីព ៤:៦-៧)។

ទោះយើងកំពុងអរសប្បាយនឹងថ្ងៃដែលមានអាកាសធាតុល្អ ឬកំពុងតែទទួលរងការវាយប្រហារ ដោយសារខ្យល់ព្យុះខាងវិញ្ញាណក៏ដោយ ចូរយើងកុំភ្លេចឈប់បង្អង់សិន ដើម្បីអធិស្ឋាន ទោះយើងកំពុងស្ថិតក្នុងពេលណាក៏ដោយ។—Nancy Gavilanes

តើធ្វើដូចម្តេចឲ្យអ្នកអាចមានចិត្តចង់អធិស្ឋាន ដោយមិនប្រកាន់ពេលវេលា? តើជីវិតនៃការអធិស្ឋានរបស់អ្នកមានការចម្រើនឡើងដូចម្តេចខ្លះ ក្នុងរយៈពេលប៉ុន្មានឆ្នាំនេះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលទូលបង្គំអាចអធិស្ឋានទៅកាន់ព្រះអង្គនៅពេលណាក៏បាន។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យេរេមា ១៨-១៩ និង២ធីម៉ូថេ ៣

នៅគ្រានោះ ខ្នែងរបស់ព្រះយេហូវ៉ា នឹងបានជាល្អប្រពៃ ហើយរុងរឿង (អេសាយ ៤:២)។

អំណោយដែលគួរឲ្យភ្ញាក់ផ្អើល

រឿងស្រែរបស់លោក លី វីលសិន (Lee Wilson) ដែលបានភ្ជួររាស់ហើយមានបង្កប់អ្វីម្យ៉ាង។ នៅក្នុងការត្រៀមខ្លួនសម្រាប់ថ្ងៃខួបអាពាហ៍ពិពាហ៍លើកទី៥០ លោក លី វីលសិន បានទុកចំណែកដីប្រហែល៣០ហិចតា សម្រាប់ដាំដើមផ្កា ធ្វើជាអំណោយធំបំផុត ដែលភរិយាគាត់ធ្លាប់បានឃើញ។ គាត់បានយកគ្រាប់ផ្កាឈូកវ័ត្តជាច្រើនរាប់មិនអស់ទៅដាំក្នុងដីនោះ ដោយមិនឲ្យគេដឹង ហើយនៅទីបំផុតដើមផ្កាឈូកវ័ត្តមានពណ៌លឿងដូចមាសដែលភរិយាគាត់ចូលចិត្ត ចំនួន១លាន២សែនដើមបានដុះឡើង។ នៅពេលដែលផ្កាបានរីកឡើងព្រមគ្នា អ្នកស្រី រេនី (Renee) មានការភ្ញាក់ផ្អើល និងការរំភើបចិត្តជាពន់ពេក ចំពោះសេចក្តីស្រឡាញ់ដែលលោក លីបានបង្ហាញចេញមក។

កាលព្រះអម្ចាស់មានបន្ទូលទៅកាន់ប្រជាជនយូដាតាមរយៈហោរា អេសាយ ព្រះអង្គបានបើកបង្ហាញរឿងអាថ៌កំបាំងមួយដល់ពួកគេ។ ទោះពួកគេមិនអាចមើលឃើញការនោះសម្រេចក្នុងសម័យដែលពួកគេរស់នៅក៏ដោយ បន្ទាប់ពីព្រះអង្គបានជំនុំជម្រះពួកគេ ដោយសារភាពមិនស្មោះត្រង់របស់ពួកគេ (អេសាយ ៣:១-៤:១) យុគសម័យថ្មីដ៏រុងរឿង នឹងមកដល់។ «នៅគ្រានោះ ខ្នែងរបស់ព្រះយេហូវ៉ា នឹងបានជាល្អប្រពៃ ហើយរុងរឿង ឯផលកើតពីដី នឹងបានជាប្រសើរ ហើយជាលំអដល់សំណល់ពួកសាសន៍អ៊ីស្រាអែល ដែលបានរួច» (៤:២)។ ជាការពិតណាស់ ពួកគេនឹងបានឆ្លងកាត់ការបំផ្លិចបំផ្លាញ និងការនិរទេសនៅក្រោមការគ្រប់គ្រងរបស់ចក្រភពបាប៊ីឡូន ប៉ុន្តែ «ខ្នែង» នឹងដុះចេញចេញមកឲ្យគេបានឃើញ។ ពួកសំណល់នៃរាស្ត្ររបស់ព្រះអង្គ នឹងត្រូវព្រះអង្គញែកជាបរិសុទ្ធ (ខ.៣) និងលាងជម្រះ (ខ.៤) ហើយព្រះអង្គនឹងដឹកនាំ ហើយថែរក្សាពួកគេដោយក្តីស្រឡាញ់ (ខ.៥-៦)។

ជីវិតរបស់យើងប្រហែលជាកំពុងស្ថិតក្នុងភាពងងឹត ដែលធ្វើឲ្យយើងមិនអាចមើលឃើញព្រះអង្គសម្រេចព្រះបន្ទូលសន្យាក្នុងជីវិតយើង។ ប៉ុន្តែ ពេលណាយើងតោងព្រះអង្គជាប់ ដោយសេចក្តីជំនឿ នៅថ្ងៃមួយព្រះអង្គនឹងសម្រេច «សេចក្តីសន្យាដ៏ធំបំផុត ហើយវិសេសផង» (២ពេត្រុស ១:៤)។ ថ្ងៃថ្មីដ៏ល្អប្រពៃ កំពុងរង់ចាំយើងស្រាប់ហើយ។—Tom Felten

ហេតុអ្វីព្រះបន្ទូលសន្យារបស់ព្រះ ហាក់ដូចជាលាក់កំបាំងនៅចំពោះយើងនៅពេលខ្លះ? តើអ្នកអាចទទួលយកព្រះបន្ទូលសន្យាទាំងនោះ ដោយជំនឿនៅថ្ងៃនេះយ៉ាងដូចម្តេចខ្លះ?

ឱព្រះដ៏រស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានឲ្យទូលបង្គំស្គាល់តម្លៃរបស់ព្រះបន្ទូលសន្យាដ៏ស្មោះត្រង់របស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 309 17/11/25 1:47 in the afternoon

នោះទ្រង់តបទៅវិញថា ចូរថ្វាយរបស់សេសារទៅសេសារទៅ ហើយរបស់ព្រះទៅព្រះវិញ គេក៏អស្ចារ្យនឹងទ្រង់ (ម៉ាកុស ១២:១៧)។

ការបែកបាក់ដ៏ធំ

ក្នុងសៀវភៅរឿងនិទានអមដោយរូបភាពមានចំណងជើងថា សណ្តែកដី មិត្តភក្តិរបស់ឡាញនើស (Linus) បានស្តីបន្ទោសឲ្យគាត់ធ្ងន់ៗ ដោយសារគាត់ជឿពាក្យសម្តីរបស់ផ្លែល្ពៅធំ។ ឡាញនើស ក៏បានដើរចេញដោយការហួសចិត្ត ហើយនិយាយថា «មានរឿងបីយ៉ាងដែលខ្ញុំបានរៀនជៀសវាងមិនជជែកជាមួយអ្នកដទៃ គឺ រឿងសាសនា រឿងនយោបាយ និងរឿងផ្លែល្ពៅធំ!»

ផ្លែល្ពៅធំនោះ មានតែនៅក្នុងការស្រមៃរបស់ឡាញនើសទេ ប៉ុន្តែប្រធានបទពីរផ្សេងទៀត គឺមានពិតមែន ហើយក៏ជាហេតុបណ្តាលឲ្យមានការបែកបាក់គ្នានៅក្នុងប្រទេសជាតិ គ្រួសារ និងមិត្តភាព។ រឿងនេះក៏បានកើតឡើងក្នុងសម័យរបស់ព្រះយេស៊ូវដែរ។ ពួកផារិស៊ីជាអ្នកកាន់តាមសាសនាយ៉ាងតឹងរឹង ដោយបានព្យាយាមដើរតាមក្រឹត្យវិន័យសញ្ញាចាស់។ ពួកហេរ៉ូឌនិយមផ្តោតទៅលើនយោបាយខ្លាំងជាងពួកផារិស៊ី តែក្រុមទាំងពីរនេះសុទ្ធតែចង់ឲ្យប្រជាជនយូដាមានសេរីភាពរួចផុតពីការគ្រប់គ្រងរបស់ចក្រភពរ៉ូម៉ាំង។ ព្រះយេស៊ូវមិនមានគោលដៅដូចពួកគេទេ។ ដូចនេះ ពួកគេក៏បានចូលទៅរកព្រះអង្គ ដោយទូលសួរសំណួរទាក់ទងនឹងនយោបាយថា តើពួកបណ្តាជនគួរតែបង់ពន្ធឲ្យស្តេច សេសារ ទេ (ម៉ាកុស ១២:១៤-១៥)? បើព្រះយេស៊ូវមានបន្ទូលថា ពួកគេត្រូវបង់ពន្ធ ពួកបណ្តាជននឹងស្អប់ព្រះអង្គ។ បើព្រះអង្គមានបន្ទូលថា ពួកគេមិនត្រូវបង់ពន្ធ ពួករ៉ូម៉ាំងអាចចាប់ព្រះកាយព្រះអង្គ ពីបទនាំគេបះបោរ។

ព្រះយេស៊ូវក៏បានយកកាក់មួយមក ហើយមានបន្ទូលសួរថា «រូបនេះ និងឈ្មោះនេះ តើជារបស់អ្នកណា?» គេរាល់គ្នាសុទ្ធតែដឹងថា រូបនៅលើកាក់នោះ ជារូបអធិរាជសេសា។ ព្រះអង្គក៏បានឆ្លើយថា «ចូរថ្វាយរបស់សេសារទៅសេសារទៅ ហើយរបស់ព្រះទៅព្រះវិញ» (ខ.១៧)។ ព្រះបន្ទូលរបស់ព្រះអង្គនៅតែមានន័យ រហូតមកដល់ពេលសព្វថ្ងៃ។ ព្រះអង្គបានផ្តោតទៅលើគោលដៅជាអាទិភាពរបស់ព្រះអង្គ ដោយបានជៀសផុតពីអន្ទាក់របស់ពួកគេនៅថ្ងៃនោះ។

ព្រះយេស៊ូវបានយាងមក ដើម្បីធ្វើតាមបំណងព្រះទ័យព្រះវរបិតា។ នៅក្នុងការដើរតាមការដឹកនាំរបស់ព្រះអង្គ យើងក៏អាចស្វែងរកព្រះ និងនគររបស់ព្រះអង្គ ជាសំខាន់លើសអ្វីៗទាំងអស់ ដោយងាកចេញពីការឈ្លោះប្រកែកគ្នា ហើយផ្តោតទៅលើព្រះអង្គ ដែលជាសេចក្តីពិត។—Tim Gustafson

តើមានបញ្ហាបែកបាក់អ្វីខ្លះ ដែលរំខានអារម្មណ៍របស់អ្នក? តើការផ្តោតទៅលើព្រះយេស៊ូវបានជួយដឹកនាំពាក្យសម្តីអ្នក ក្នុងការសន្ទនានៅថ្ងៃនេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំត្រូវការប្រាជ្ញា និងការដឹកនាំរបស់ព្រះអង្គនៅក្នុងការទំនាក់ទំនងទាំងអស់របស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យេរេមា ២២-២៣ និងទីតុស ១

ដូច្នេះ ត្រូវប្រយ័ត្នដោយមធ្យឹត ដែលអ្នកពាល់គ្នាដើរយ៉ាងណា... ទាំងលៃយកឱកាសឲ្យទាន់ពេលផង (អេភេសូរ ៥:១៥-១៦)។

ប្រើពេលវេលាឲ្យមានប្រយោជន៍

កាលពីថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ អង្គការណាសាបានបាញ់បង្ហោះយានអវកាស ដោយបានបញ្ជូនអ្នកស្រី គ្រីស្ទីណា កូច (Christina Koch) ទៅកាន់ស្ថានីយអវកាសអន្តរជាតិ។ អ្នកស្រី គ្រីស្ទីណា បានបន្តធ្វើការក្នុងស្ថានីយអវកាស អស់រយៈពេល៣២៨ថ្ងៃ ដោយបានបំបែកកំណត់ត្រាឯកត្តកម្ម ក្នុងនាមជាស្ត្រីទីមួយ ដែលបានស្នាក់នៅក្នុងយានអវកាសបានយូរជាងគេ។ ជារៀងរាល់ថ្ងៃ ក្នុងការរស់នៅក្នុងរយៈកម្ពស់៤១០គីឡូម៉ែត្រពីផែនដី មានអេក្រង់កុំព្យូទ័រមួយ តាមដានសកម្មភាពរបស់អវកាសយានិករូបនេះ រៀងរាល់៥នាទីម្តង។ គាត់មានកិច្ចការប្រចាំថ្ងៃ ដែលត្រូវបំពេញ (រាប់ចាប់តាំងពីការបរិភោគអាហារ ដល់ការធ្វើពិសោធន៍ផ្សេងៗ) ហើយពីមួយម៉ោងទៅមួយម៉ោង មានខ្សែបន្ទាប់ពណ៌ក្រហមលេចឡើងនៅលើអេក្រង់នោះ ដើម្បីបង្ហាញជាទៀងទាត់ថា អ្នកស្រី គ្រីស្ទីណា សម្រេចកិច្ចការនីមួយៗបានមុនពេលកំណត់ ឬមានភាពយឺតយ៉ាវ។ ដូចនេះ គាត់មិនដែលចំណាយពេលធ្វើរឿងអត់ប្រយោជន៍នៅទីនោះឡើយ។

សាវ័ក ប៉ុល មិនបានបង្រៀនថា យើងចាំបាច់ត្រូវប្រើខ្សែបន្ទាត់ក្រហម ដើម្បីគ្រប់គ្រងជីវិតយើងក្នុងការធ្វើកិច្ចការនីមួយៗប្រចាំថ្ងៃយ៉ាងតឹងរឹងនោះទេ ប៉ុន្តែគាត់ពិតជាបានលើកទឹកចិត្តយើង ឲ្យប្រើពេលវេលាដ៏មានតម្លៃ និងមានកំណត់ ដោយការប្រុងប្រយ័ត្នខ្ពស់។ គឺដូចដែលគាត់បានបង្រៀនយើងថា “ត្រូវប្រយ័ត្នដោយមធ្យឹត ដែលអ្នករាល់គ្នាដើរយ៉ាងណា កុំឲ្យដើរដូចជាមនុស្សឥតប្រាជ្ញាឡើយ ត្រូវតែដើរដោយមានប្រាជ្ញាវិញ ទាំងលៃយកឱកាសឲ្យទាន់ពេលផង ពីព្រោះសម័យនេះអាក្រក់ណាស់” (អេភេសូរ ៥:១៥-១៦)។ ប្រាជ្ញារបស់ព្រះអង្គ បង្រៀនយើងឲ្យរស់នៅជារៀងរាល់ថ្ងៃ ដោយមានទឹកចិត្ត និងការប្រុងប្រយ័ត្ន ក្នុងការស្តាប់បង្គាប់ព្រះអង្គ ស្រឡាញ់អ្នកជិតខាង និងចូលរួមនៅក្នុងព្រះរាជកិច្ចប្រោសលោះរបស់ព្រះអង្គ ក្នុងលោកិយ។ គួរឲ្យស្តាយណាស់ យើងងាយនឹងព្រងើយកន្តើយចំពោះការបង្រៀនរបស់ប្រាជ្ញាព្រះអង្គ ហើយប្រើពេលវេលារបស់យើង ដោយភាពល្ងង់ខ្លៅ(ខ.១៧) ដោយខ្ជះខ្ជាយជីវិតយើងជាច្រើនឆ្នាំ នៅក្នុងការដេញតាមភាពអាត្មានិយម និងសេចក្តីហិនវិនាស។

បទគម្ពីរនេះមិនបានបង្រៀនយើងឲ្យមានការភ័យខ្លាចជ្រុលពេកអំពីការប្រើប្រាស់ពេលវេលានោះទេ តែគ្រាន់តែបង្គាប់យើងឲ្យដើរតាមព្រះ ដោយការស្តាប់បង្គាប់ និងការទុកចិត្ត។ ព្រះអង្គនឹងជួយយើង ប្រើពេលវេលាក្នុងជីវិតយើង ជារៀងរាល់ថ្ងៃ ឲ្យមានប្រយោជន៍បំផុត។—Winn Collier

តើពេលវេលាមានតម្លៃប៉ុណ្ណា ចំពោះអ្នក? តើអ្នកអាចប្រើពេលវេលា ឲ្យមានប្រយោជន៍បំផុត នៅថ្ងៃនេះយ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យប្រើពេលវេលាឲ្យមានប្រយោជន៍បំផុត ក្នុងការរស់នៅជារៀងរាល់ថ្ងៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យេរេមា ២៤-២៦ និងទីតុស ២

គឺអ្នកណាក្នុងពួកអ្នករាល់គ្នា ដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ (ម៉ាថាយ ២០:២៦)។

ធ្វើកិច្ចការតូចបំផុតថ្វាយព្រះអង្គ

លោក ប្រេដ (Brad) បានផ្លាស់ទៅរស់នៅក្នុងទីក្រុងមួយទៀត ហើយមិនយូរប៉ុន្មាន គាត់ក៏រកបានព្រះវិហារមួយកន្លែង ដែលគាត់អាចចូលរួមកម្មវិធីថ្វាយបង្គំព្រះ។ គាត់បានចូលរួមកម្មវិធីថ្វាយបង្គំព្រះ អស់រយៈពេលពីរបីសប្តាហ៍ ហើយបន្ទាប់មក នៅថ្ងៃអាទិត្យមួយនោះ បន្ទាប់ពីកម្មវិធីថ្វាយបង្គំព្រះបានបញ្ចប់ គាត់ក៏បានជជែកជាមួយគ្រូគង្វាល អំពីបំណងចិត្តដែលគាត់មាន ក្នុងការបម្រើព្រះតាមដែលចាំបាច់។ គាត់ថា គាត់ចង់ចាប់កាន់អំបោស ដើម្បីជួយសម្អាតព្រះវិហារ។ គាត់ក៏បានចាប់ផ្តើមជួយរៀបកៅអីសម្រាប់កម្មវិធីថ្វាយបង្គំ ហើយក៏បានជួយលាងបង្អន់នៅព្រះវិហារ។ ក្រោយមក គ្រួសារពួកជំនុំនោះក៏បានរកឃើញថា លោក ប្រេដ មានអំណោយទានបង្រៀន ប៉ុន្តែគាត់បានស្ម័គ្រចិត្តធ្វើកិច្ចការមួយណាក៏បាន ឲ្យតែគេឲ្យគាត់ធ្វើ។

មានពេលមួយ ព្រះយេស៊ូវបានបង្រៀនសាវ័ក យ៉ាកុប និងសាវ័ក យ៉ូហាន ព្រមទាំងម្តាយរបស់ពួកគេ អំពីភាពជាអ្នកបម្រើ។ ម្តាយរបស់ពួកគេបានស្នើសុំឲ្យកូនៗរបស់គាត់មានកន្លែងកិត្តិយសនៅខាងស្តាំ និងខាងឆ្វេងព្រះគ្រីស្ទ បន្ទាប់ពីព្រះអង្គយាងចូលនគរព្រះអង្គវិញ (ម៉ាថាយ ២០:២០-២១)។ សាវ័កដទៃទៀតក៏បានឮពួកគេជជែកគ្នាអំពីរឿងនេះ ជាហេតុបណ្តាលឲ្យពួកគេតូចចិត្តនឹងបងប្អូនទាំងពីរនោះ។ ប្រហែលជាពួកគេចង់បានកន្លែងនោះ សម្រាប់ខ្លួនឯងដែរហើយមើលទៅ? ព្រះយេស៊ូវក៏បានប្រាប់ពួកគេថា ការប្រើអំណាចមកលើអ្នកដទៃ មិនមែនជារបៀបនៃការរស់នៅ ដែលត្រឹមត្រូវនោះទេ (ខ.២៥-២៦) ប៉ុន្តែ ផ្ទុយទៅវិញ ការបម្រើសំខាន់ជាងការមានអំណាចមកលើអ្នកដទៃ។ គឺដូចដែលព្រះអង្គមានបន្ទូលថា «អ្នកណាក្នុងពួកអ្នករាល់គ្នា ដែលចង់ធ្វើជាធំ នោះនឹងត្រូវធ្វើជាអ្នកបំរើដល់អ្នករាល់គ្នាវិញ» (ខ.២៦)។

ការដែលលោក ប្រេដ និយាយថា គាត់ចង់ចាប់ផ្តើមបម្រើព្រះ ដោយ «ចាប់កាន់អំបោស សម្អាតព្រះវិហារ» គឺបានធ្វើជាទីបន្ទាល់ដ៏ល្អអំពីកិច្ចការដ៏តូចបំផុត ដែលយើងអាចធ្វើក្នុងសហគមន៍ និងពួកជំនុំរបស់យើង ដើម្បីបម្រើព្រះគ្រីស្ទ។ លោក ប្រេដ ក៏បានរៀបរាប់អំពីទឹកចិត្តដែលគាត់មានចំពោះព្រះយ៉ាងដូចនេះថា «ខ្ញុំចង់ធ្វើការបម្រើ ដើម្បីថ្វាយសិរីល្អដល់ព្រះ ដើម្បីជាប្រយោជន៍ដល់ពិភពលោក ហើយដើម្បីឲ្យខ្លួនខ្ញុំមានអំណរ»។ តើយើងម្នាក់ៗអាច «ចាប់កាន់អំបោស» ដើម្បីធ្វើការបម្រើព្រះ ចាប់តាំងពីកិច្ចការតូចបំផុតទៅតាមការដឹកនាំរបស់ព្រះអង្គដូចម្តេចខ្លះ?—Anne Cetas

តើអ្នកអាចបម្រើគ្រួសារនៃពួកជំនុំរបស់អ្នក យ៉ាងដូចម្តេចខ្លះ? តើអ្នកនឹងចាប់ផ្តើមការបម្រើនោះ នៅពេលណា?

ឱព្រះអម្ចាស់ ព្រះអង្គបានធ្វើកិច្ចការជាច្រើនណាស់សម្រាប់ទូលបង្គំ ហើយទូលបង្គំចាំបាច់ត្រូវស្រឡាញ់ព្រះអង្គ។ សូមព្រះអង្គចម្រើនកម្លាំងទូលបង្គំ ហើយបង្ហាញទូលបង្គំអំពីរបៀបបម្រើអ្នកដទៃ ដែលនៅក្បែរទូលបង្គំ។

គម្រោងអានព្រះគម្ពីររយៈពេល១ឆ្នាំ | យេរេមា ២៧-២៩ និងទីតុស ៣

ឯអ្នកណាដែលមានគំនិតជាប់តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះ ឲ្យមានសេចក្ដីសុខពេញខ្នាត ដោយព្រោះគេទុកចិត្តនឹងទ្រង់ (អេសាយ ២៦:៣)។

ព្រះវរបិតា ដែលយើងអាចទុកចិត្តបាន

កូនប្រុសខ្ញុំឈ្មោះ ហ្សាវ៉ា (Xavier) មានកម្ពស់១ម៉ែត្រ៩០។ គាត់បានចាប់លើកកូនប្រុសគាត់ ឈ្មោះ ហ្សារាន (Xarian) ដែលជាក្មេងទើបចេះដើរតេះតះ។ គាត់លើកកូនប្រុសគាត់ឡើងទៅលើយ៉ាងងាយស្រួល ដោយកាន់ជើងដ៏តូចល្អិតរបស់កូនប្រុសគាត់ជាប់។ គាត់ក៏បានលាតសន្ធឹងដៃដ៏វែងរបស់គាត់ ដោយលើកទឹកចិត្តកូនប្រុសគាត់ ឲ្យទប់លំនឹងខ្លួនឲ្យជាប់នៅលើបាតដៃរបស់គាត់ ប៉ុន្តែដៃគាត់ក៏បានត្រៀមជាស្រេច ដើម្បីចាប់កូនប្រុសគាត់ បើសិនជាចាំបាច់។ ហ្សារាន ក៏បានក្រោកឈរនៅលើបាតដៃរបស់គាត់រួចទម្លាក់ដៃចុះ ដោយទឹកមុខញញឹម ហើយភ្នែកគាត់មើលចំមុខរបស់ឪពុកគាត់ ដោយមិនងាកបែរទៅណា។

ហោរាអេសាយ ក៏បានប្រកាសអំពីអត្ថប្រយោជន៍នៃការផ្តោតចិត្ត ទៅលើព្រះវរបិតានៃយើង ដែលគង់នៅស្ថានសួគ៌យ៉ាងដូចនេះថា «ឯអ្នកណាដែលមានគំនិតជាប់តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះ ឲ្យមានសេចក្ដីសុខពេញខ្នាត ដោយព្រោះគេទុកចិត្តនឹងទ្រង់» (អេសាយ ២៦:៣)។ គាត់បានលើកទឹកចិត្តរាស្ត្ររបស់ព្រះ ឲ្យប្តេជ្ញាចិត្តស្វែងរកបំណងព្រះទ័យព្រះអង្គក្នុងព្រះគម្ពីរ ហើយបន្តប្រកបស្និទ្ធស្នាលជាមួយព្រះអង្គ តាមរយៈការអធិស្ឋាន និងការថ្វាយបង្គំផងដែរ។ មនុស្សស្មោះត្រង់ទាំងនោះ នឹងបានដកពិសោធន៍នឹងការមានទំនុកចិត្តលើព្រះ ដែលបានកើតឡើង តាមរយៈការប្រកបស្និទ្ធស្នាលដ៏រឹងមាំជាមួយព្រះវរបិតា។

ក្នុងនាមយើងជាកូនសួនភ្ងារបស់ព្រះអង្គ យើងអាចប្រកាសដោយចិត្តក្លាហានថា «ចូរទុកចិត្តដល់ព្រះយេហូវ៉ាជាដរាបចុះ ដ្បិតព្រះដ៏ជាព្រះយេហូវ៉ាទ្រង់ជាថ្មដាដ៏នៅអស់កល្បជានិច្ច» (ខ.៤)។ តើហេតុអ្វី? ព្រោះព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ជាព្រះដែលយើងអាចទុកចិត្តបាន។ ព្រះអង្គ និងព្រះបន្ទូលរបស់ព្រះអង្គ មិនដែលប្រែប្រួលឡើង។

ពេលណាយើងមើលទៅព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ដោយមិនងាករ ព្រះអង្គនឹងជួយយើងឲ្យឈរយ៉ាងមាំមួននៅក្នុងព្រះហស្តព្រះអង្គ។ យើងអាចទុកចិត្តថា ព្រះអង្គនឹងនៅតែស្រឡាញ់ ស្មោះត្រង់ និងល្អចំពោះយើងជារៀងរហូត!—Xochitl Dixon

តើការមានគំនិតជាប់តាមព្រះ នាំឲ្យអ្នកមានសន្តិភាពក្នុងចិត្តដូចម្តេចខ្លះ? តើអ្នកអាចផ្តោតចិត្តទៅលើព្រះអង្គ ពេញមួយថ្ងៃ ដោយរបៀបណា?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រើព្រះគម្ពីរដើម្បីក្រើនរំឭកទូលបង្គំ អំពីចរិតលក្ខណៈរបស់ព្រះអង្គដែលមិនចេះប្រែប្រួល និងអំពីសេចក្ដីស្មោះត្រង់ដ៏អស់កល្បរបស់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យេរេមា ៣០-៣១ និងភីលេម៉ូន

ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមនុស្សមហាសន្ធឹកសន្ធាប់ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា (វិវរណៈ ៧:៩)។

ស្រឡាញ់ប្រជាជាតិដទៃ

ក្នុងនាមខ្ញុំជាកូនស្រីរបស់ឪពុកម្តាយដែលមានក្តីស្រឡាញ់ និងខិតខំធ្វើការនៅតំបន់អាមេរិកកណ្តាល និងខាងត្បូង ខ្ញុំសូមអរព្រះគុណព្រះអង្គ ដែលពួកគាត់មានចិត្តក្លាហាន ដោយបានក្លាយជាមនុស្សដំបូងក្នុងគ្រួសារ ដែលបានធ្វើចំណាកស្រុកមករស់នៅជាជនអន្តោប្រវេសន៍នៅសហរដ្ឋអាមេរិក ដើម្បីស្វែងរកឱកាសការងារដែលល្អជាង។ ពួកគាត់បានជួបគ្នាក្នុងវ័យយុវជននៅទីក្រុងញូយ៉ក ហើយក៏បានរៀបការ និងបង្កើតបានខ្ញុំ និងបងស្រីខ្ញុំ ព្រមទាំងបន្តអាជីវកម្មដែលពួកគាត់បានធ្វើជាឃ្លួមកហើយ។

ក្នុងនាមខ្ញុំជាអ្នកដែលមានដើមកំណើតនៅទីក្រុងញូយ៉ក ខ្ញុំបានចម្រើនវ័យធំឡើង ដោយឱបក្រសោបយកកេរដំណែលអាមេរិកឡាទីន ហើយក៏មានការចាប់អារម្មណ៍ចំពោះមនុស្សដែលមានដើមកំណើតនៅទីកន្លែងផ្សេងគ្នា។ ឧទាហរណ៍ ខ្ញុំធ្លាប់បានចែកចាយទីបន្ទាល់របស់ខ្ញុំនៅក្នុងកម្មវិធីពេលល្ងាចមួយក្នុងព្រះវិហារចម្រុះជាតិសាសន៍ ដែលមានការជួបជុំគ្នាក្នុងសាលមហោស្រពប្រតវេយ។ ក្នុងការនិយាយទៅកាន់ក្រុមមនុស្សចម្រុះជាតិសាសន៍ អំពីសេចក្តីស្រឡាញ់របស់ព្រះ បានធ្វើឲ្យខ្ញុំនឹកចាំអំពីទិដ្ឋភាពនៅនគរស្ថានសួគ៌ នៅពេលដែលមនុស្សមកពីគ្រប់ជាតិសាសន៍ នឹងមកជួបជុំគ្នា ក្នុងនាមជារូបកាយព្រះគ្រីស្ទ។

ក្នុងកណ្ឌគម្ពីរវិវរណៈ សាវ័ក យ៉ូហាន បានធ្វើការបើកសម្តែងដ៏អស្ចារ្យអំពីទិដ្ឋភាពនៅស្ថានសួគ៌ យ៉ាងដូចនេះថា «ក្រោយនោះមក ខ្ញុំក្រឡេកទៅឃើញមនុស្សមហាសន្ធឹកសន្ធាប់ ដែលគ្មានអ្នកណាអាចនឹងរាប់បានឡើយ គេមកពីគ្រប់ទាំងសាសន៍ គ្រប់ទាំងពូជមនុស្ស គ្រប់ទាំងគ្រួសារ ហើយគ្រប់ទាំងភាសា ក៏ឈរនៅមុខបល្ល័ង្ក និងកូនចៀម» (វិវរណៈ ៧:៩)។ ព្រះអង្គសង្គ្រោះរបស់យើងនឹងទទួល «ការសរសើរ និងសិរីល្អ» ប្រាជ្ញា ពាក្យអរព្រះគុណ កិត្តិនាម ព្រះចេស្តា និងឥទ្ធិឫទ្ធិ ដល់ព្រះនៃយើងរាល់គ្នា នៅអស់កល្បជានិច្ចរៀងរាបតទៅ(ខ.១២)។

សព្វថ្ងៃនេះ យើងគ្រាន់តែអាចបានដឹងខ្លះៗថា នគរស្ថានសួគ៌មានលក្ខណៈដូចម្តេច ផ្អែកទៅលើព្រះគម្ពីរបរិសុទ្ធ។ ប៉ុន្តែ នៅថ្ងៃមួយ អ្នកដែលជឿព្រះយេស៊ូវនឹងបានជួបព្រះអង្គមុខទល់នឹងមុខជាមួយនឹងមនុស្សមកពីគ្រប់ប្រទេស វប្បធម៌ និងភាសា។ ដោយសារព្រះអម្ចាស់ស្រឡាញ់ប្រជាជាតិទាំងអស់ ចូរយើងស្រឡាញ់មហាគ្រួសារព្រះគ្រីស្ទ ដែលមានជាតិសាសន៍ខុសពីយើងផងដែរ។—Nancy Gavilanes

តើអ្នកអាចបង្ហាញក្តីស្រឡាញ់ដល់ប្រជាជាតិទាំងឡាយ យ៉ាងដូចម្តេចខ្លះ? តើអ្នកអាចឲ្យតម្លៃមកលើអ្នកដទៃ និងវប្បធម៌របស់ពួកគេយ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យស្រឡាញ់អ្នកដទៃ ដូចដែលព្រះអង្គស្រឡាញ់ពួកគេ។

Daily Manna 2026_Content Enhance.indd 314 17/11/25 1:47 in the afternoon

ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះ (ទំនុកតម្កើង ២៣:១)។

មានចិត្តក្លាហាន ព្រោះព្រះអង្គជាអ្នកគង្វាលល្អ

មនុស្សជិត១សែន ៧ពាន់នាក់ បានឈរមើលការប្រកួតនៅក្នុងពហុកីឡដ្ឋានមួយ ដោយការរង់ចាំមើលលទ្ធផលផ្គាច់ព្រាត់ ខណៈពេលដែលលោក សេត ស្មល (Seth Small) ជាខ្សែប្រយុទ្ធនៃក្រុមកីឡាការបាល់ទាត់មហាវិទ្យាល័យ រដ្ឋតិចសាស់ A&M កំពុងកាន់កាប់ទីលានប្រកួត ដោយនៅសល់ពេលតែ៧វិនាទីប៉ុណ្ណោះ។ ខណៈពេលដែលក្រុមA&Mរបស់គាត់ មានពិន្ទុស្មើគ្នា ៣៨ ទល់នឹង៣៨ ជាមួយនឹងក្រុមកីឡាការដែលល្អបំផុតប្រចាំប្រទេស ការទាត់បញ្ចូលទីដ៏ជោគជ័យ អាចជួយឲ្យក្រុមគាត់ទទួលបានជ័យជម្នះដែលគួរឲ្យស្ងប់ស្ងែង។ ពេលនោះ លោក ស្មល ក៏បានទាត់បាល់ផ្លោតទៅមុខ ដោយទំនុកចិត្ត។ ពហុកីឡដ្ឋានទាំងមូលក៏បានផ្ទុះចេញជាសម្រែកអឺងកង បន្ទាប់ពីបាល់នោះបានហោះ តាមប្រឡោះបង្គោល ដែលនាំឲ្យក្រុមគាត់ឈ្នះការប្រកួត។

ពេលដែលអ្នកការសែតសួរគាត់ថា តើគាត់បានត្រៀមខ្លួនយ៉ាងដូចម្តេច សម្រាប់ពេលដ៏តានតឹងនោះ គាត់ក៏បានឆ្លើយថា គាត់បានសូត្រខទី១នៃបទគម្ពីរទំនុកតម្កើង២៣ ម្តងហើយម្តងទៀតថា «ព្រះយេហូវ៉ាទ្រង់ជាអ្នកគង្វាលខ្ញុំ ខ្ញុំនឹងមិនខ្វះអ្វីសោះ»។ នៅពេលដែលលោក ស្មល ត្រូវការកម្លាំង និងការធានា ដើម្បីឲ្យគាត់មានជំនឿរឹងមាំ គាត់ក៏បានរំឭកខ្លួនឯងថា ព្រះអង្គគឺជាអ្នកគង្វាលល្អ។

បទគម្ពីរទំនុកតម្កើងជំពូក២៣ ជាបទគម្ពីរទំនុកតម្កើងដ៏ពេញនិយម ដោយសារបទគម្ពីរនេះបានធានាយើងថា យើងអាចមានសន្តិភាពក្នុងចិត្ត និងការកម្សាន្តចិត្ត ដោយសារយើងមានអ្នកគង្វាលដែលមានក្តីស្រឡាញ់ និងអាចឲ្យយើងទុកចិត្តបាន ដែលតែងតែយកព្រះទ័យទុកដាក់ចំពោះយើងយ៉ាងសកម្ម។ ស្តេច ដាវីឌ បានធ្វើបន្ទាល់ អំពីធាតុពិតនៃការភ័យខ្លាចក្នុងស្ថានភាពដ៏តានតឹង និងពិបាក ក៏ដូចជាធ្វើបន្ទាល់អំពីការកម្សាន្តចិត្តដែលទ្រង់បានទទួលពីព្រះអម្ចាស់ផងដែរ (ខ.៤)។ ពាក្យ «កម្សាន្តចិត្ត» ក្នុងបទគម្ពីរនេះ គឺសំដៅទៅលើការធានា ឬការប្រទានន្លូវទំនុកចិត្ត និងចិត្តក្លាហាន ដើម្បីឲ្យយើងបន្តដំណើរទៅមុខ ដោយសារព្រះវត្តមានរបស់ព្រះអង្គដឹកនាំយើង។

ពេលណាយើងដើរចូលក្នុងកាលៈទេសៈដែលមានបញ្ហាប្រឈម ដោយមិនដឹងថា យើងនឹងទទួលលទ្ធផលបែបណា ចូរយើងមានចិត្តក្លាហាន ដោយរំឭកខ្លួនម្តងហើយម្តងទៀតថា ព្រះដែលជាអ្នកគង្វាលល្អ កំពុងដើរជាមួយយើង។—Lisa M. Samra

តើអ្នកបានដកពិសោធន៍ជាមួយព្រះអង្គ ក្នុងលក្ខណៈព្រះអង្គជាអ្នកគង្វាលដែលមានក្តីស្រឡាញ់យ៉ាងណាខ្លះ? តើការថែរក្សារបស់ព្រះអង្គ ដែលអ្នកអាចទុកចិត្តបាននាំឲ្យអ្នកមានចិត្តក្លាហានយ៉ាងណាខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំឲ្យមានចិត្តក្លាហាន ដោយដឹងថា ព្រះអង្គជាអ្នកគង្វាលដែលមានក្តីស្រឡាញ់។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យេរេមា ៣៤-៣៦ និងហេព្រើរ ២

បបូរមាត់ដែលបញ្ចេញសេចក្តីពិត នោះនឹងបានតាំងជាប់នៅជានិច្ច តែអណ្តាតភូតភរ នោះនៅតែ១ភ្លែតទេ (សុភាសិត ១២:១៩)។

ស្នើរតែត្រឹមត្រូវ នៅតែជាការកុហក

គេបានផលិតវីដេអូឯកសារមួយស្តីអំពីដើមឈើក្រហម ដែលគេបានចាក់បញ្ចូលសារធាតុម្យ៉ាង ដែលស្រដៀងនឹងថ្នាំប៉ូវកម្លាំង ដើម្បីឲ្យដើមឈើទាំងនោះបន្តមានការលូតលាស់ នៅក្នុងរដូវរងា។ ដើមឈើដែលគេបានចាក់ថ្នាំនោះក៏បានងាប់ ដោយសារគេមិនបានឲ្យវាឆ្លងកាត់វដ្តនៃរដូវរងាតាមធម្មជាតិ ជាពេលដែលដើមឈើផ្អាកការលូតលាស់។ ការផលិតវីដេអូឯកសារនេះ មានបច្ចេកទេសនៃការថតល្អណាស់។ សម្លេងភ្លេងដែលគេបញ្ចូលក្នុងវីដេអូក៏ត្រូវនឹងសាច់រឿង ហើយធ្វើឲ្យអ្នកស្តាប់មានការជក់ចិត្ត។ មាតិកានៃវីដេអូនេះទៀតសោតក៏គួរឲ្យចាប់អារម្មណ៍ និងធ្វើទស្សនិកជនប៉ះពាល់ចិត្តផងដែរ។

គោលបំណងនៃវីដេអូនេះ គឺដើម្បីបង្រៀនយើងថា រឿងដែលបានកើតឡើងចំពោះដើមឈើទាំងនោះ ក៏អាចកើតឡើងចំពោះយើងផងដែរ បើសិនជាយើងមានការរស់ជាប់ជានិច្ច ដោយគ្មានពេលសម្រាកទេនោះ។ រឿងនេះអាចកើតឡើងចំពោះយើងមែន ប៉ុន្តែវីដេអូនេះមានភាពមិនត្រឹមត្រូវជាច្រើន។ តាមពិត គេមិនបានដែលធ្វើការសិក្សាលើដើមឈើក្រហមពិតប្រាកដទេ។ ដើមឈើក្រហមជាប្រភេទដើមឈើដែលមានស្លឹកគ្រប់រដូវ មិនដែលផ្អាកការលូតលាស់នៅរដូវរងាឡើយ។ ហើយដើមឈើនៅក្នុងវីដេអូនោះ គឺជាប្រភេទដើមឈើផ្សេង មិនមែនជាដើមឈើក្រហមដែលដុះនៅតំបន់ឆ្នេរសមុទ្រនោះទេ។ វីដេអូនេះបង្កប់នូវការអប់រំដ៏ល្អមួយ ប៉ុន្តែគេបានផលិតវាឡើង ផ្អែកទៅលើការកុហក។

យើងកំពុងរស់នៅក្នុងយុគសម័យមួយ ដែលដោយសារបច្ចេកវិទ្យាកាន់តែទំនើប មនុស្សកាន់តែមានភាពងាយស្រួលក្នុងការកុហក ដល់ថ្នាក់អាចបញ្ចុះបញ្ចូលយើងឲ្យជឿថា ការកុហកទាំងនោះគឺជាការពិត។ កណ្ឌគម្ពីរសុភាសិតមានការប្រមូលផ្តុំទៅដោយប្រាជ្ញាដែលគោរពប្រតិបត្តិព្រះ ហើយបានចែងជាញឹកញាប់អំពីភាពខុសគ្នា រវាងសេចក្តីពិត និងការកុហក។ គឺដូចមានសេចក្តីចែងថា «បបូរមាត់ដែលបញ្ចេញសេចក្តីពិត នោះនឹងបានតាំងជាប់នៅជានិច្ច តែអណ្តាតភូតភរ នោះនៅតែ១ភ្លែតទេ» (១២:១៩)។ ហើយខគម្ពីរបន្ទាប់បានប្រាប់យើងថា «ការឆបោករមែងនៅក្នុងចិត្តនៃមនុស្សដែលគិតគូរបង្កើតការអាក្រក់ តែមានសេចក្តីអំណរសំរាប់មនុស្សដែលប្រឹក្សាឲ្យមានសេចក្តីសុខ» (ខ.២០)។

យើងត្រូវការភាពស្មោះត្រង់នៅក្នុងកិច្ចការទាំងអស់ ដោយរាប់បញ្ចូលទាំងការប្រព្រឹត្តតាមព្រះរាជបញ្ជារបស់ព្រះ ក៏ដូចជាការផលិតវីដេអូអំពីការលូតលាស់របស់ដើមឈើ។ សេចក្តីពិត «ស្ថិតស្ថេរជាដរាប»។

—John Blasé

ដើម្បីអ្នកឲ្យដឹងថា អ្វីដែលអ្នកឃើញ ស្តាប់ឮ និងបានដកពិសោធន៍ គឺជារឿងពិតឬអត់ តើអ្នកអាចចោទសួរប្រកបដោយប្រាជ្ញាដូចម្តេចខ្លះ? តើអ្នកនឹងបង្ហាញចេញនូវការប្តេជ្ញាចិត្តដូចម្តេចខ្លះ ចំពោះសេចក្តីពិត?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យមានការយល់ដឹងថា មានរឿងអ្វីខ្លះគឺជាការពិត ហើយរឿងអ្វីខ្លះជាការកុហក ខណៈពេលដែលទូលបង្គំស្វែងរកការពិតជារឿងរាល់ថ្ងៃ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យេរេមា ៣៧-៣៩ និងហេព្រើរ ៣

ខ្ញុំសូមទូន្មានដល់នាង អើរ៉ូឌា និងនាង ស៊ុនទីច ដែរ ឲ្យមូលគំនិតតែ១ក្នុងព្រះអម្ចាស់ (ភីលីព ៤:២)។

លូកដៃចូលក្នុងរឿងអ្នកដទៃ

មានពេលមួយ ចៅរបស់ខ្ញុំ៤នាក់នាំគ្នាលេងរថភ្លើងផលិតពីប្លាស្ទិកសម្រាប់ក្មេងលេង ហើយចៅពីរនាក់ដែលក្មេងជាងគេ កំពុងប្រកែកគ្នាអំពីរឿងក្បាលរថភ្លើង។ នៅពេលដែលចៅប្រុសរបស់យើងមានអាយុ៨ឆ្នាំ ចាប់ផ្តើមជួយដោះស្រាយបញ្ហាជម្លោះរបស់ពួកគេ ប្អូនស្រីរបស់គាត់អាយុ៥ឆ្នាំក៏បានប្រាប់ កុំឲ្យខ្វល់អំពីរឿងរបស់ពួកគេ។ តាមធម្មតា នេះជាពាក្យសម្តីប្រកបដោយប្រាជ្ញា សម្រាប់យើងរាល់គ្នា។ ប៉ុន្តែ ពេលណាការប្រកែកគ្នាប្រែក្លាយជាការទួញយំ ជីដូនរបស់ពួកគេត្រូវចូលទៅឃាត់ ហើយលួងក្មេងដែលកំពុងឈ្លោះគ្នានោះ។

ការមិនលូកដៃចូលក្នុងរឿងអ្នកដទៃជាទង្វើដ៏ចាំបាច់ នៅពេលណាការលូកដៃនោះ អាចធ្វើឲ្យរឿងរបស់គេកាន់តែធ្ងន់ធ្ងរ។ ប៉ុន្តែ ជួនកាលយើងចាំបាច់ត្រូវចូលទៅជួយគេ ដោយអធិស្ឋានសូមការដឹកនាំពីព្រះអង្គ។ ក្នុងសំបុត្រដែលសាវ័ក ប៉ុល បានសរសេរផ្ញើទៅពួកជំនុំនៅទីក្រុងភីលីព គាត់បានផ្តល់ឲ្យយើងនូវឧទាហរណ៍មួយដើម្បីឲ្យយើងដឹងថា ពេលណាយើងត្រូវចូលជួយគេ។ ត្រង់ចំណុចនេះ គាត់បានជំរុញស្ត្រីពីរនាក់ គឺនាង អើរ៉ូឌា និងនាង ស៊ុនទីច «ឲ្យមូលគំនិតតែ១ក្នុងព្រះអម្ចាស់» (៤:២)។ ជម្លោះរបស់អ្នកទាំងពីរប្រហែលជាមានភាពតានតឹងយ៉ាងខ្លាំង បានជាសាវ័ក ប៉ុល បានទទួលការជំរុញចិត្តឲ្យជួយផ្សះផ្សាពួកគេ (ខ.៣) ទោះគាត់កំពុងស្ថិតក្នុងមន្ទីរឃុំឃាំងក៏ដោយ (១:៧)។

សាវ័ក ប៉ុល បានដឹងថា ជម្លោះរបស់ស្ត្រីទាំងពីរកំពុងបណ្តាលឲ្យមានការបែកបាក់ក្នុងពួកជំនុំ ហើយនាំឲ្យគេបង្ហែរអារម្មណ៍ចេញពីដំណឹងល្អ។ ហេតុនេះហើយគាត់ក៏បានចែកចាយសេចក្តីពិត ដោយចិត្តសុភាព ដោយរំឭកពួកគេថា ឈ្មោះរបស់ពួកគេ មានកត់ទុក «ក្នុងបញ្ជីជីវិត» (៤:៣)។ សាវ័ក ប៉ុល ចង់ឲ្យស្ត្រីទាំងនេះ និងមនុស្សទាំងអស់ក្នុងពួកជំនុំ រស់នៅជារាស្ត្ររបស់ព្រះទាំងក្នុងគំនិត និងការប្រព្រឹត្តរបស់ពួកគេ (ខ.៤-៩)។

ពេលណាអ្នកមិនដឹងច្បាស់ថា អ្នកគួរតែចូលជួយដោះស្រាយបញ្ហាជម្លោះរបស់អ្នកដទៃឬអត់ ចូរអធិស្ឋានដោយទុកចិត្តថា ព្រះនៃសេចក្តីសុខសាន្ត ឬសន្តិភាពនឹងគង់នៅជាមួយអ្នក (ខ.៩ មើល ខ.៧)។—Alyson Kieda

នៅពេលថ្មីៗនេះ តើអ្នកបានចូលទៅក្នុងជម្លោះ ឬការមិនចុះសម្រុងគ្នារបស់អ្នកដទៃ នៅពេលណា ហើយតើអ្នកបានទទួលលទ្ធផលដូចម្តេចខ្លះ? តើការស្វែងរកការដឹកនាំពីព្រះ មានសារៈសំខាន់យ៉ាងណាខ្លះ នៅក្នុងការជួយផ្សះផ្សាពួកគេ?

ឱព្រះអម្ចាស់ សូមព្រះអង្គប្រទានទូលបង្គំនូវប្រាជ្ញា ដើម្បីឲ្យដឹងថា ទូលបង្គំត្រូវចូលទៅជួយអ្នកមានជម្លោះនៅពេលណា ហើយសូមប្រទានទូលបង្គំនូវពាក្យសម្តី ដើម្បីនាំមកនូវការជ្រោសឲ្យជា និងការរួបរួម។

Daily Manna 2026_Content Enhance.indd 317 17/11/25 1:47 in the afternoon

ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានទុកចិត្តដល់ទ្រង់... ឯថ្ងៃអាយុរបស់ទូលបង្គំ សុទ្ធតែនៅក្នុងព្រះហស្តទ្រង់ (ទំនុកតម្កើង ៣១:១៤-១៥)។

តាមពេលវេលារបស់ព្រះអង្គ

អ្នកស្រី មែគ (Mag) បានទន្ទឹងរង់ចាំពេលដែលគាត់នឹងបានធ្វើដំណើរទៅបរទេស តាមការគ្រោងទុក។ ប៉ុន្តែ តាមធម្មតា គាត់តែងតែអធិស្ឋានជាមុនសិន។ មិត្តភក្តិរបស់គាត់ម្នាក់ក៏បានសួរគាត់ថា ការធ្វើដំណើរនោះគ្រាន់តែជាការសម្រាកលំហែទេ ហេតុអ្វីគាត់ចាំបាច់ត្រូវទូលសូមប្រាជ្ញាពីព្រះ។ ទោះជាយ៉ាងណាក៏ដោយ អ្នកស្រីមែកជឿថា គាត់ត្រូវថ្វាយអ្វីៗទាំងអស់ដល់ព្រះអង្គ។ នៅពេលនោះ គាត់បានទទួលការបណ្តាលចិត្តពីព្រះអង្គ ឲ្យលុបគម្រោងធ្វើដំណើរនោះចោល។ គាត់ក៏បានលុបចោល ហើយក្រោយមកគាត់ក៏បានដឹងថា មានជំងឺរាតត្បាតមួយកំពុងរីករាលដាលក្នុងប្រទេសនោះ ចំពេលដែលគាត់បានគ្រោងនឹងធ្វើដំណើរទៅទីនោះ។ គាត់ក៏បានដឹងថា ព្រះអម្ចាស់កំពុងការពារគាត់។

លោក ណូអេ ក៏បានពឹងផ្អែកលើការការពាររបស់ព្រះ ខណៈពេលដែលគាត់ និងគ្រួសារគាត់បានរង់ចាំនៅក្នុងទូកធំអស់រយៈពេលជិត២ខែ បន្ទាប់ពីទឹកជំនន់បានស្រក។ បន្ទាប់ពីគាត់បានស្នាក់នៅក្នុងទូកធំមិនអាចទៅណារួច អស់រយៈពេលជាង១០ខែ គាត់ប្រាកដជាមានចិត្តអន្ទះសាចង់ចេញក្រៅ។ ទីបំផុត «ទឹកបានរីងស្ងួតពីផែនដីអស់ទៅ ណូអេក៏បើកដំបូលទូកមើលឃើញថា ទឹកបានស្ងួតពីដីហើយ» (លោកុប្បត្តិ ៨:១៣)។ ប៉ុន្តែ លោក ណូអេ មិនបានពឹងផ្អែកទៅលើការអ្វីដែលគាត់មើលឃើញប៉ុណ្ណោះទេ ផ្ទុយទៅវិញគាត់បានចេញពីទូក នៅពេលដែលព្រះអម្ចាស់អនុញ្ញាតឲ្យគាត់ចេញទៅក្រៅ (ខ.១៥-១៩)។ គាត់បានទុកចិត្តថា ព្រះអម្ចាស់មានហេតុផលដ៏ល្អ ដែលត្រូវឲ្យគាត់បន្តរង់ចាំ គឺប្រហែលមកពីកាលនោះ ដីមិនទាន់មានសុវត្ថិភាពនៅឡើយ។

ពេលណាយើងអធិស្ឋាន សូមព្រះអង្គជួយយើងក្នុងការសម្រេចចិត្តក្នុងការរស់នៅ ដោយពឹងផ្អែកលើប្រាជ្ញាដែលព្រះអង្គប្រទាន និងរង់ចាំការដឹកនាំរបស់ព្រះអង្គ យើងអាចទុកចិត្តលើផែនការរបស់ព្រះអង្គ ដោយដឹងថាព្រះអាទិករដែលមានប្រាជ្ញាជ្រាបថា មានការអ្វីខ្លះដែលល្អបំផុតសម្រាប់យើង។ គឺដូចអ្នកនិពន្ធបទគម្ពីរទំនុកតម្កើងបានប្រកាសថា «ឱព្រះយេហូវ៉ាអើយ ទូលបង្គំបានទុកចិត្តដល់ទ្រង់... ឯថ្ងៃអាយុរបស់ទូលបង្គំសុទ្ធតែនៅក្នុងព្រះហស្តទ្រង់» (ទំនុកតម្កើង ៣១:១៤-១៥)។—Leslie Koh

តើអ្នកបានទូលសូមព្រះអម្ចាស់នូវការដឹកនាំក្នុងការសម្រេចចិត្តដូចម្តេចខ្លះ? តើអ្នកអាចទុកចិត្តព្រះអង្គ និងរង់ចាំការដឹកនាំរបស់ព្រះអង្គដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គប្រទានទូលបង្គំនូវប្រាជ្ញា និងការដឹកនាំ ដើម្បីធ្វើការសម្រេចចិត្ត តាមបំណងព្រះទ័យ និងផ្លូវរបស់ព្រះអង្គ ដ្បិតទូលបង្គំទុកចិត្តលើផែនការ ដែលព្រះអង្គមានសម្រាប់ជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 318 17/11/25 1:47 in the afternoon

គឺដោយខំបំរើគ្នាទៅវិញទៅមក តាមអំណោយទានដែលគ្រប់គ្នាបានទទួលមក (១ពេត្រុស ៤:១០)។

បម្រើដោយក្តីស្រឡាញ់

នៅពេលដែល គ្រីស្តាល់ (Krystal) បានចាប់ផ្តើមធ្វើការលើកដំបូង នៅក្នុងហាងកាហ្វេ នៅរដ្ឋវើជីនា គាត់ក៏បានបម្រើភ្ញៀវម្នាក់ឈ្មោះ អីបប៊ី (Ibby)។ ដោយសារអីបប៊ីជាជនពិការត្រចៀក គាត់ក៏បានធ្វើការកុម្ម៉ង់ ដោយសរសេរអក្សរនៅលើអេក្រង់ទូរស័ព្ទរបស់គាត់។ បន្ទាប់ពីគ្រីស្តាល់បានដឹងថា អីបប៊ី គឺជាភ្ញៀវដែលមកហាងនោះជាទៀងទាត់ នាងក៏បានប្តេជ្ញាចិត្តថា នឹងបម្រើគាត់ឲ្យបានល្អជាងមុន ដោយរៀនភាសាកាយវិការសម្រាប់មនុស្សគរ ដើម្បីឲ្យគាត់អាចធ្វើការកុម្ម៉ង់បាន ដោយមិនចាំបាច់សរសេរអក្សរ។

តាមរយៈទង្វើដ៏តូចនេះ គ្រីស្តាល់បានបង្ហាញអីបប៊ី អំពីប្រភេទនៃសេចក្តីស្រឡាញ់ និងការបម្រើ ដែលសាវ័ក ពេត្រុស បានលើកទឹកចិត្តយើង ឲ្យផ្តល់ឲ្យគ្នាទៅវិញទៅមក។ ក្នុងសំបុត្រដែលគាត់សរសើរធ្វើទៅអ្នកជឿព្រះយេស៊ូវ ដែលបានខ្ចាត់ខ្ចាយ និងនិរទេសដោយសារការបៀតបៀន គាត់បានចង្អុលបង្ហាញថា ពួកគេត្រូវស្រឡាញ់គ្នា «ឲ្យអស់ពីចិត្ត» ហើយប្រើអំណោយទានរបស់ពួកគេ «ដើម្បីបម្រើគ្នាទៅវិញទៅមក» (១ពេត្រុស ៤:៨, ១០)។ ជំនាញ ឬសមត្ថភាពអ្វីក៏ដោយដែលព្រះអង្គបានប្រទានយើង គឺសុទ្ធតែជាអំណោយដែលយើងអាចប្រើ ជាប្រយោជន៍ដល់អ្នកដទៃ។ ពេលណាយើងអនុវត្តន៍ដូចនេះ ពាក្យសម្តី និងសកម្មភាពរបស់យើង អាចថ្វាយព្រះកិត្តិនាមដល់ព្រះ។

ការបង្រៀនរបស់សាវ័ក ពេត្រុស ក្នុងបទគម្ពីរខាងលើនេះមានសារៈសំខាន់ចំពោះអ្នកជឿទាំងអស់ ជាពិសេសអ្នកដែលកំពុងជួបរដូវកាលនៃការឈឺចាប់ និងភាពងកោ។ គាត់បានលើកទឹកចិត្តពួកគេ ឲ្យបម្រើគ្នាទៅវិញទៅមក ក្នុងអំឡុងពេលដែលមានទុក្ខលំបាក ដើម្បីឲ្យពួកគេម្នាក់ៗអាចស៊ូទ្រាំ។ យើងមិនអាចដឹងច្បាស់ថា នរណាម្នាក់មានការឈឺចាប់អ្វីឲ្យជាក់លាក់នោះទេ តែព្រះអម្ចាស់អាចជួយយើងបង្ហាញចេញនូវការអាណិត ក៏ដូចជាបម្រើគ្នាទៅវិញទៅមក ដោយអំណរ និងក្តីស្រឡាញ់ តាមរយៈពាក្យសម្តី ធនធាន និងសមត្ថភាពរបស់យើង។ សូមព្រះអម្ចាស់ជួយយើងបម្រើអ្នកដទៃ ដើម្បីឲ្យអ្នកដទៃអាចមើលឃើញស្រឡាញ់របស់ព្រះអង្គនៅក្នុងការប្រព្រឹត្តរបស់យើង។—Kirsten Holmberg

តើអ្នកបានបម្រើអ្នកដទៃតាមការលើកទឹកចិត្តរបស់សាវ័ក ពេត្រុស នៅពេលណាខ្លះ? តើអ្នកអាចបម្រើនរណាខ្លះ ដោយពាក្យសម្តី ជំនាញ និងធនធានរបស់អ្នកនៅថ្ងៃនេះ?

ឱព្រះវរបិតា សូមព្រះអង្គជួយទូលបង្គំឲ្យបម្រើមនុស្សនៅជុំវិញទូលបង្គំ ដោយប្រើអ្វីៗដែលព្រះអង្គបានប្រទានទូលបង្គំ។

Daily Manna 2026_Content Enhance.indd 319 17/11/25 1:47 in the afternoon

នាងក៏ហៅព្រះនាមព្រះយេហូវ៉ា ដែលកំពុងមានព្រះបន្ទូលនឹងនាងថា «ព្រះដ៏ទតឃើញ» ដ្បិតនាងគិតថា នៅទីនេះអញបានឃើញព្រះដែលទ្រង់ទតឃើញអញទេតើ (លោកុប្បត្តិ ១៦:១៣)។

ព្រះអង្គជ្រាបអំពីទុក្ខលំបាករបស់អ្នក

មានពេលមួយមិត្តភក្តិខ្ញុំបានស្រែកប្រាប់កូនប្រុសគាត់យ៉ាងម៉ឺងម៉ាត់ បន្ទាប់ពីកូនប្រុសគាត់ឡើងឈើនៅលើកៅអីក្នុងព្រះវិហារគ្រីស្ទីដាក់លោកគ្រូគង្វាលដែលកំពុងអធិប្បាយព្រះបន្ទូល។ កូនប្រុសគាត់ក៏បាននិយាយត្រង់ៗថា «កូនចង់ឲ្យគ្រូគង្វាលមើលឃើញកូន។ បើកូនមិនឈរទេ គាត់មើលកូនមិនឃើញទេ»។

ព្រះវិហារភាគច្រើនមិនលើកទឹកចិត្ត ឲ្យក្មេងឡើងឈរនៅលើកៅអីក្នុងព្រះវិហារយ៉ាងដូចនេះទេ។ កូនប្រុសរបស់មិត្តភក្តិខ្ញុំ ខ្លាចគ្រូគង្វាលមិនយកចិត្តទុកដាក់ចំពោះគាត់ គឺដោយសារគាត់មិនយល់ប៉ុណ្ណោះ។

ពេលណាយើងព្យាយាមធ្វើឲ្យព្រះអម្ចាស់យកព្រះទ័យទុកដាក់ចំពោះយើង យើងមិនចាំបាច់ត្រូវព្រួយបារម្ភខ្លាចព្រះអង្គទតមើលយើងមិនឃើញនោះទេ។ ព្រះអង្គតែងតែមើលយើងឃើញជានិច្ច។ ព្រះអង្គជាព្រះដែលបានបង្ហាញអង្គទ្រង់ ដល់នាង ហាកា កាលនាងកំពុងស្ថិតក្នុងពេលដែលងាកបំផុត នឿយណាយបំផុត និងធ្លាក់ដល់ចំណុចសូន្យ ក្នុងជីវិតរបស់នាង។ នាង ហាកា ត្រូវនាងសារ៉ាយប្រើ ជាឧបករណ៍ ដើម្បីបង្កើតកូនប្រុសឲ្យលោក អាប់រ៉ាម (លោកុប្បត្តិ ១៦:៣)។ ហើយនៅពេលដែលនាងមានផ្ទៃពោះ លោកអាប់រ៉ាមបានបណ្តោយឲ្យភរិយាគាត់ធ្វើបាបនាង បានជានាងរត់គេចពីនាងសារ៉ាយ (ខ.៦)។

ស្ត្រីជាទាសកររូបនេះបានរត់គេចខ្លួនស្ថិតក្នុងភាពងាកោ មានផ្ទៃពោះ និងរស់នៅយ៉ាងវេទនា។ ប៉ុន្តែ ក្នុងពេលដែលនាងកំពុងស្ថិតក្នុងភាពអស់សង្ឃឹមក្នុងវាលរហោស្ថាន ព្រះអម្ចាស់បានចាត់ទេវតាមួយអង្គ ឲ្យមកជួបនាង។ ទេវតាក៏បានប្រាប់នាងថា ព្រះអម្ចាស់ជ្រាបពីសេចក្តីទុក្ខលំបាករបស់នាង (ខ.១១)។ នាងក៏បានឆ្លើយតបថា ព្រះអង្គជាព្រះដែលបានទតឃើញនាង (ខ.១៣)។

ការដឹងថា ព្រះអម្ចាស់ជ្រាប់អំពីទុក្ខលំបាករបស់យើង គឺពិតជាមានសារៈសំខាន់ចំពោះយើងណាស់ ជាពិសេសនៅពេលដែលយើងស្ថិតក្នុងវាលរហោស្ថាន។ ព្រះអម្ចាស់ទតឃើញនាង ហាកា ហើយក៏មានព្រះទ័យអាណិតនាង។ ហើយទោះយើងជួបទុក្ខលំបាកធ្ងន់ធ្ងរយ៉ាងណាក៏ដោយ ព្រះអង្គតែងតែទតឃើញយើងជានិច្ច។

—Katara Patton

តើអ្នកកំពុងប្រឈមមុខដាក់ស្ថានភាពដ៏លំបាកអ្វីខ្លះ ដែលប្រៀបដូចជាវាលរហោស្ថាន? តើការដឹងថាព្រះអម្ចាស់ទតឃើញអ្នកបានលើកទឹកចិត្តអ្នកឲ្យបន្តដំណើរទៅមុខ ដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានទតឃើញទូលបង្គំ។ ទូលបង្គំដឹងថា ព្រះអង្គគង់នៅជាមួយទូលបង្គំក្នុងអំឡុងពេលដែលពិបាកបំផុត។

Daily Manna 2026_Content Enhance.indd 320 17/11/25 1:47 in the afternoon

ខ្ញុំប្រាប់ថា ត្រូវស្រឡាញ់ពួកខ្មាំងសត្រូវ ត្រូវឲ្យពរដល់អ្នកណាដែលប្រទេចផ្តាសា (ម៉ាថាយ ៥:៤៤)។

ស្រឡាញ់ខ្មាំងសត្រូវរបស់អ្នក

ក្នុងអំឡុងសម័យសង្គ្រាមលោកលើកទី២ លោក លីន វេស្តុន (Lynne Weston) ជាពេទ្យទាហាន ក្នុងជួរកងទ័ពជើងទឹកអាមេរិកបានជិះទូកទៅកាន់ឆ្នេរសមុទ្រជាមួយកងទ័ពជើងទឹក ខណៈពេលដែលពួកគេវាយលុកប្រជុំកោះដែលកងទ័ពសត្រូវកំពុងកាន់កាប់។ នៅពេលនោះ ការរបួស និងការស្លាប់របស់ទាហានដ៏គួរឲ្យតក់ស្លុត គឺជារឿងដែលជៀសមិនរួចនៅក្នុងសង្គ្រាម។ គាត់បានព្យាយាមអស់ពីលទ្ធភាព ដើម្បីព្យាបួសឲ្យទាហានដែលមានរបួស ដើម្បីឲ្យគេសែងពួកគេចេញពីសមរភូមិ។ មានពេលមួយនោះ កងពលរបស់គាត់បានប្រទះឃើញទាហានសត្រូវម្នាក់ កំពុងមានរបួសនៅត្រង់ពោះធ្ងន់ធ្ងរ។ ដោយសារភាពធ្ងន់ធ្ងរនៃរបួសនោះ គាត់មិនអាចឲ្យទាហាននោះផឹកទឹកបានទេ។ ដើម្បីជួយទាហាននោះឲ្យនៅមានជីវិត ពេទ្យទាហានរូបនោះក៏បានចាក់ថ្នាំប្លាស្មាចូលទៅក្នុងសរសៃឈាមរបស់គាត់។

ក្នុងចំណោមទាហានជើងទឹកទាំងនោះមានម្នាក់បានស្រែកប្រាប់គាត់ កុំឲ្យចាក់ថ្នាំឲ្យសត្រូវ តែឲ្យទុកថ្នាំចាក់នោះ សម្រាប់មិត្តរួមអាវុធរបស់ពួកគេវិញ។ តែពេទ្យទាហានដែលមានក្តីអាណិត មិនបានស្តាប់តាមពាក្យសម្តីនេះទេ។ គាត់បានចាំការបង្រៀនរបស់ព្រះយេស៊ូវ ដែលបានបង្គាប់ឲ្យគាត់ស្រឡាញ់ខ្មាំងសត្រូវរបស់គាត់ (ម៉ាថាយ ៥:៤៤)។

ព្រះយេស៊ូវមិនគ្រាន់តែបានមានបន្ទូលបង្គាប់ដូចនេះទេ តែព្រះអង្គក៏បានអនុវត្តន៍ដោយផ្ទាល់ផងដែរ។ កាលហ្វូងមនុស្សបានចាប់ព្រះកាយព្រះអង្គ នាំទៅជួបសម្តេចសង្ឃ ពួកអ្នកយាមព្រះអង្គ គេចំអកឲ្យ ហើយវាយព្រះអង្គ (លូកា ២២:៦៣)។ ការវាយដំ និងជេរប្រមាថនេះបានបន្តមានក្នុងការកាត់ទោសដ៏អយុត្តិធម៌នោះរហូតដល់ពេលដែលគេកាត់ទោសប្រហារជីវិតព្រះអង្គ។ ព្រះយេស៊ូវមិនគ្រាន់តែបានស៊ូទ្រាំប៉ុណ្ណោះទេ។ នៅពេលដែលពួកទាហានរ៉ូម៉ាំងឆ្កាងព្រះអង្គ ព្រះអង្គក៏បានអធិស្ឋានសូមឲ្យព្រះវរបិតាអត់ទោសឲ្យពួកគេ (២៣:៣៤)។

យើងប្រហែលមិនដែលជួបខ្មាំងសត្រូវជាមនុស្ស ដែលព្យាយាមសម្លាប់យើងនោះទេ។ ប៉ុន្តែ មនុស្សម្នាក់ៗសុទ្ធតែយល់អំពីអារម្មណ៍ នៅពេលដែលពួកគេអត់ទ្រាំនឹងការចំអក និងជេរប្រមាថ។ តាមធម្មតា យើងចង់ឆ្លើយតបទាំងកំហឹង តាមនិស្ស័យសាច់ឈាមរបស់យើង។ ប៉ុន្តែ ព្រះយេស៊ូវបានឲ្យយើងធ្វើផ្ទុយពីនេះ ដោយបង្គាប់យើងឲ្យអធិស្ឋានឲ្យអ្នកបៀតបៀនយើង (ម៉ាថាយ ៥:៤៤)។

នៅថ្ងៃនេះ ចូរយើងដើរក្នុងសេចក្តីស្រឡាញ់ប្រភេទនេះ ដោយបង្ហាញចេញនូវចិត្តសប្បុរសតាមគំរូព្រះយេស៊ូវ សូម្បីតែចំពោះខ្មាំងសត្រូវរបស់យើងក៏ដោយ។—Tim Gustafson

តើអ្នកឆ្លើយតបដូចម្តេចខ្លះ ចំពោះអ្នកដែលស្អប់ ឬយល់ច្រឡំចំពោះអ្នក? តើព្រះអម្ចាស់ទតឃើញឲ្យអ្នកឆ្លើយតប ដូចម្តេចខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គជួយទូលបង្គំឲ្យស្រឡាញ់អ្នកដទៃ ដូចដែលព្រះអង្គស្រឡាញ់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | យេរេមា ៥០ និងហេព្រើរ ៨

កាលមានសេចក្តីទុក្ខលំបាកកំពុងតែល្បួងគេជាខ្លាំង នោះសេចក្តីអំណរជាបរិបូរ និងសេចក្តីកំសត់ទុគ៌តរបស់គេបានបណ្តាលឲ្យគេមានចិត្តសទ្ធាដ៏លើសលប់វិញ (២កូរិនថូស ៨:២)។

ដង្វាយអង្ករមួយក្តាប់

ម៉ាដូនីហ្សារ៉ាម នៅភាគពាយព្យនៃប្រទេសឥណ្ឌាកំពុងចាកចេញពីភាគក្រីក្របន្តិចម្តងៗ។ ទោះប្រជាជននៅទីនោះខ្វះប្រាក់ចំណូលយ៉ាងណាក៏ដោយ ចាប់តាំងពីពេលដែលដំណឹងល្អបានចូលមកដល់តំបន់នេះជាលើកដំបូង អ្នកជឿព្រះយេស៊ូវបានអនុវត្តនូវប្រពៃណី «ដាក់ដង្វាយអង្ករមួយក្តាប់»។ សមាជិកពួកជំនុំដែលមានតួនាទីចំអិនអាហារប្រចាំគ្រួសារបានរំលែកអង្ករមួយក្តាប់សម្រាប់ធ្វើជាដង្វាយដល់ព្រះវិហាររបស់ខ្លួន។ ពួកជំនុំនៅរដ្ឋមីហ្សូរ៉ាម មានជីវភាពក្រីក្រ បើធៀបនឹងស្តង់ដាររបស់ពិភពលោក ប៉ុន្តែពួកគេបានរួបរួមគ្នាដាក់ដង្វាយរាប់លានដុល្លាសម្រាប់ការងាររបសកកម្ម ហើយបានបញ្ជូនបេសកជនចេញទៅទូទាំងពិភពលោក។ មនុស្សជាច្រើននៅក្នុងរដ្ឋមីហ្សូរ៉ាមក៏បានទទួលជឿព្រះគ្រីស្ទតាមរយៈពួកគេផងដែរ។

ក្នុងបទគម្ពីរ ២កូរិនថូស ៨ សាវ័ក ប៉ុល បានពិពណ៌នា អំពីពួកជំនុំដែលមានបញ្ហាប្រឈមស្រដៀងនេះផងដែរ។ អ្នកជឿព្រះនៅស្រុកម៉ាសេដូនមានជីវភាពក្រីក្រ តែពួកគេនៅតែអាចដាក់ដង្វាយជាបរិបូរ ដោយអំណរ (ខ.១-២)។ ពួកគេបានដឹងថា ការដាក់ដង្វាយរបស់ពួកគេ គឺជាឯកសិទ្ធិ ហើយក៏បានធ្វើការលះបង់លើសសមត្ថភាពរបស់ពួកគេ (ខ.៣) ក្នុងការធ្វើការជាដៃគូរជាមួយសាវ័ក ប៉ុល។ ពួកគេដឹងថា ពួកគេគ្រាន់តែជាអ្នកថែរក្សាធនធានដែលព្រះអម្ចាស់បានផ្តុកផ្តាក់នឹងពួកគេ។ ការដាក់ដង្វាយ គឺជាវិធីបង្ហាញការទុកចិត្តចំពោះព្រះអង្គ ដែលជាអ្នកប្រទានអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការ។

សាវ័ក ប៉ុល បានចែកចាយទីបន្ទាល់របស់ពួកជំនុំនៅស្រុកម៉ាសេដូន ដើម្បីលើកទឹកចិត្តពួកជំនុំនៅទីក្រុងកូរិនថូស ឲ្យមានការលះបង់ នៅក្នុងការដាក់ដង្វាយផងដែរ។ ពួកជំនុំនៅទីក្រុងកូរិនថូសបានចម្រើនឡើង ក្នុងសេចក្តីជំនឿ ពាក្យសម្តី ចំណេះ សេចក្តីឧស្សាហ៍គ្រប់ជំពូក ហើយក្នុងសេចក្តីស្រឡាញ់ ប៉ុន្តែពួកគេក៏ចាំបាច់ត្រូវចម្រើនឡើង នៅក្នុងសេចក្តីសប្បុរសនៃការដាក់ដង្វាយផងដែរ (ខ.៧)។

យើងក៏អាចបង្ហាញឲ្យគេបានស្គាល់សេចក្តីសប្បុរសរបស់ព្រះវរបិតា តាមរយៈការដាក់ដង្វាយដោយចិត្តសប្បុរស ចេញពីធនធានដែលយើងមាន តាមគំរូរបស់ពួកជំនុំនៅស្រុកម៉ាសេដូន និងគ្រីស្ទបរិស័ទនៅរដ្ឋមីហ្សូរ៉ាមផងដែរ។—Matt Lucas

តើអ្នកបានឃើញគេដាក់ដង្វាយដោយការលះបង់ នៅកន្លែងណាខ្លះ? តើអ្នកអាចលះបង់ដោយចិត្តសប្បុរសដល់អ្នកដទៃដូចម្តេចខ្លះ ក្នុងការឆ្លើយតបចំពោះសេចក្តីសប្បុរសដែលព្រះអង្គមានចំពោះអ្នក?

ឱព្រះវរបិតា ទូលបង្គំសូមអធិស្ឋានឲ្យពួកជំនុំនៅទីក្រុងម៉ីហ្សូរ៉ាម ខណៈពេលដែលពួកគេបន្តដាក់ដង្វាយដោយចិត្តសប្បុរស សម្រាប់ការងារបម្រើព្រះអង្គ។

Daily Manna 2026_Content Enhance.indd 322 17/11/25 1:47 in the afternoon

មនុស្សដែលមានចិត្តមេត្តា នោះតែងធ្វើល្អដល់ជីវិតខ្លួន (សុភាសិត ១១:១៧)។

សេចក្តីសប្បុរសមិនអាចវាស់បាន

ប្រុសពីរនាក់មិត្តភក្តិនឹងគ្នាកំពុងដើររកទិញកុំព្យូទ័រលែបថប់មួយគ្រឿង នៅក្នុងហាងលក់គ្រឿងអេឡិចត្រូនិក ហើយក៏បានប្រទះឃើញលោក សាគីល អូនាល (Shaquille O'Neal) ជាតារាបាល់បោះដ៏ល្បីល្បាញ។ ពួកគេដឹងថា កាលពីពេលថ្មីៗនេះ លោក អូនាល បានបាត់បង់ប្អូនស្រី និងមិត្តរួមក្រុមរបស់គាត់ ដូចនេះពួកគេក៏បានបង្ហាញចេញនូវសមានទុក្ខចំពោះគាត់ ដោយក្តីអាណិត។ បន្ទាប់មកពួកគេក៏បានបន្តដើរមកមើលកុំព្យូទ័រលែបថប់ទៀត។ ពេលនោះ លោក អូនៀល ក៏បានចូលទៅជិតពួកគេ ហើយក៏បានប្រាប់ពួកគេឲ្យរើសយកកុំព្យូទ័រលែបថប់ដែលស្អាតបំផុត នៅក្នុងហាង។ បន្ទាប់មក គាត់ក៏បានទិញកុំព្យូទ័រនោះឲ្យពួកគេ ដោយសារគាត់មានការប៉ះពាល់ចិត្តចំពោះសមានចិត្តរបស់ពួកគេដែលយល់អំពីទុក្ខលំបាករបស់គាត់។

កាលពីជាង២ពាន់ឆ្នាំមុនពេលរឿងនេះកើតឡើង ស្តេចសាឡូម៉ូនបានបង្រៀនថា «មនុស្សដែលមានចិត្តមេត្តា នោះតែងធ្វើល្អដល់ជីវិតខ្លួន» (សុភាសិត ១១:១៧)។ ពេលណាយើងមើលឃើញតម្រូវការរបស់អ្នកដទៃ ហើយធ្វើអ្វីដែលយើងអាចធ្វើបាន ដើម្បីជួយ និងលើកទឹកចិត្តពួកគេ នោះព្រះអង្គនឹងប្រទានរង្វាន់ដល់យើង។ ព្រះអង្គប្រហែលមិនឲ្យកុំព្យូទ័រមួយគ្រឿង ឬឧបករណ៍អ្វីមកយើងទេ តែព្រះអង្គអាចប្រទានពរយើង តាមរបៀបដែលលោកិយមិនអាចវាស់បាន។ គឺដូចដែលស្តេចសាឡូម៉ូនបានពន្យល់នៅក្នុងខ១៦ នៃជំពូកដដែលនេះថា «ស្ត្រីណាដែលមានអធ្យាស្រ័យល្អ នោះតែងរក្សាទុកនូវកិត្តិសព្ទ ដូចជាមនុស្សប្រឹតប្រៀបដែលរក្សាទ្រព្យសម្បត្តិដែរ» (ខ.១៦)។ មានអំណោយជាច្រើនមកពីព្រះ ដែលមានតម្លៃលើសមាសប្រាក់ទៅទៀត ហើយព្រះអង្គក៏បានវាល់អំណោយទាំងនោះឲ្យយើង ដោយព្រះទ័យសប្បុរស តាមប្រាជ្ញា និងផ្លូវដ៏តត្ចោះរបស់ព្រះអង្គ។

សេចក្តីសប្បុរសជាផ្នែកមួយនៃចរិតលក្ខណៈរបស់ព្រះ ហើយព្រះអង្គកំសព្វព្រះទ័យឲ្យយើងបង្ហាញចេញនូវសេចក្តីសប្បុរស នៅក្នុងចិត្ត និងក្នុងការរស់នៅរបស់យើងផងដែរ។ គឺដូចដែលស្តេចសាឡូម៉ូនបានមានបន្ទូលបង្រៀនជាសង្ខេបថា «អ្នកណាដែលស្រោចទឹកដល់គេ នោះនឹងបានគេស្រោចទឹកដល់ខ្លួនដែរ» (ខ.២៥)។—James Banks

តើព្រះអម្ចាស់បានបង្ហាញសេចក្តីសប្បុរសចំពោះអ្នក ដូចម្តេចខ្លះ? តើអ្នកអាចបង្ហាញសេចក្តីស្រឡាញ់របស់ព្រះអង្គដល់អ្នកដទៃ ដូចម្តេចខ្លះនៅថ្ងៃនេះ?

ឱព្រះអម្ចាស់ ទូលបង្គំស្រឡាញ់សេចក្តីសប្បុរសរបស់ព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យមានចរិតលក្ខណៈកាន់តែដូចព្រះអង្គ ដើម្បីឲ្យទូលបង្គំអាចចែកចាយសេចក្តីស្រឡាញ់របស់ព្រះអង្គ តាមរបៀបដែលមានប្រសិទ្ធភាព។

Daily Manna 2026_Content Enhance.indd 323 17/11/25 1:47 in the afternoon

នោះព្រះអម្ចាស់ទ្រង់មានព្រះបន្ទូលជាពាក្យប្រៀបប្រដូចទៅគេ ដើម្បីនឹងបង្ហាញថា ត្រូវតែអធិស្ឋានជានិច្ច ឥតរសាយចិត្តឡើយ (លូកា ១៨:១)។

តស៊ូក្នុងការអធិស្ឋាន

មីឡា (Mila) ជាជំនួយការផ្នែកដុតនំ មានអារម្មណ៍ទន់ខ្សោយយ៉ាងខ្លាំង មិនអាចការពារខ្លួនឯងបាន នៅពេលដែលមេការរបស់គាត់បានចោទប្រកាន់ថា គាត់បានលួចនំប៉័ងមួយចំនួន ដែលមានដាក់ផ្លែទំពាំងបាយជូរក្រៀម។ ការចោទប្រកាន់ដោយគ្មានភស្តុតាង និងការកាត់ប្រាក់ខែ ស្ថិតក្នុងចំណោមទង្វើខុសឆ្គងជាច្រើនដែលមេការរបស់គាត់ បានធ្វើមកលើគាត់។ មីឡា ក៏បានអធិស្ឋានជារៀងរាល់ថ្ងៃថា «ព្រះអង្គអើយ សូមព្រះអង្គជួយទូលបង្គំផង។ ទូលបង្គំពិបាកធ្វើការ នៅក្រោមការត្រួតត្រារបស់គាត់ណាស់ តែទូលបង្គំត្រូវការការងារនេះ»។

ព្រះយេស៊ូវធ្លាប់មានបន្ទូល អំពីស្ត្រីមេម៉ាយម្នាក់ ដែលមានអារម្មណ៍ទន់ខ្សោយ ហើយបានស្វែងរកយុទ្ធធម៌ទាស់ប្រឆាំងនឹងសត្រូវរបស់គាត់ (លូកា ១៨:៣)។ គាត់បានទៅរកចៅក្រម ដែលមានអំណាចដោះស្រាយរឿងក្តីរបស់គាត់។ ទោះគាត់ដឹងថា ចៅក្រមជាមនុស្សទុច្ចរិត ក៏គាត់នៅតែទៅរកចៅក្រមនោះម្តងហើយម្តងទៀត។

ការឆ្លើយតបរបស់ចៅក្រមនោះ (ខ.៤-៥) មានការខុសប្លែកពីព្រះវរបិតានៃយើងដែលគង់នៅស្ថានសួគ៌ ដែលតែងតែឆ្លើយតប ដោយក្តីស្រឡាញ់ និងព្រះទ័យអត់ធ្មត់ (ខ.៧)។ បើការព្យាយាមអាចបណ្តាលឲ្យចៅក្រមទុច្ចរិត សម្រេចចិត្តដោះស្រាយរឿងក្តីឲ្យស្ត្រីមេម៉ាយនោះ តើព្រះជាចៅក្រមដ៏យុត្តិធម៌អាចនឹងឆ្លើយតបចំពោះយើង ជាងអម្បាលម៉ានទៅទៀត (ខ.៧-៨)? យើងអាចទុកចិត្តថា ព្រះអង្គនឹងប្រទានសេចក្តីយុត្តិធម៌ដល់រាស្ត្រជ្រើសតាំងរបស់ព្រះអង្គ (ខ.៧) ហើយការព្យាយាមក្នុងការអធិស្ឋាន គឺបានបង្ហាញថា យើងទុកចិត្តព្រះអង្គ។ យើងព្យាយាម ដោយសារយើងមានជំនឿថា ព្រះអង្គនឹងឆ្លើយតប ចំពោះស្ថានភាពរបស់យើង តាមប្រាជ្ញា និងពេលវេលាដ៏តម្លៃខ្ពោះរបស់ព្រះអង្គ។

ទីបំផុត មេការរបស់ មីឡា ក៏បានលាឈប់ពីដំណែង បន្ទាប់ពីបុគ្គលិកហាងដុតនំដទៃទៀតបានរាយការណ៍អំពីទង្វើអាក្រក់របស់គាត់។ មីឡា និងមិត្តរួមការងារទទួលបានយុត្តិធម៌។ ខណៈពេលដែលយើងដើរ ដោយការស្តាប់បង្គាប់ព្រះ ចូរយើងព្យាយាមក្នុងការអធិស្ឋាន ដោយដឹងថា អំណាចនៃការអធិស្ឋានរបស់យើង ស្ថិតនៅក្នុងព្រះដែលស្តាប់ឮ ហើយជួយយើង។—Karen Huang

តើអ្នកមានអារម្មណ៍ថា ចង់ចោះបង់ចោលការតស៊ូក្នុងការអធិស្ឋាន នៅពេលណា? នៅពេលដែលអ្នកអធិស្ឋាន តើអ្នកបានគិតដល់ចរិតលក្ខណៈអ្វីខ្លះរបស់ព្រះអម្ចាស់?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គក្រើនរំឭកទូលបង្គំឲ្យចាំថា ព្រះអង្គជានរណា ហើយសូមព្រះអង្គជួយទូលបង្គំ ឲ្យបន្តអធិស្ឋាន ទោះមានរឿងអ្វីកើតឡើងក៏ដោយ។

Daily Manna 2026_Content Enhance.indd 324 17/11/25 1:47 in the afternoon

ដូច្នេះចូររើសយកជីវិតចុះ ដើម្បីឲ្យឯងបានរស់នៅ ព្រមទាំងពូជឯងតរៀងទៅផង (ចោទិយកថា ៣០:១៩)។

ការជ្រើសរើសយកជីវិត

នេធិន (Nathan) បានចម្រើនវ័យធំឡើង ក្នុងគ្រួសារដែលស្រឡាញ់ព្រះគ្រីស្ទ ប៉ុន្តែ គាត់បានចាប់ផ្តើមវង្វេងចេញពីជំនឿដែលគាត់មានកាលពីក្មេង នៅពេលដែលគាត់ទៅរៀននៅមហាវិទ្យាល័យ ដោយសារគាត់ចូលចិត្តស៊ីផឹក និងជប់លៀងជាញឹកញាប់។ ក្រោយមកគាត់ក៏បាននិយាយថា «ព្រះអម្ចាស់បាននាំខ្ញុំត្រឡប់មករកព្រះអង្គវិញ នៅពេលដែលខ្ញុំមិនសក្តិសមនឹងឲ្យព្រះអង្គហៅខ្ញុំត្រឡប់មកវិញ»។ នៅពេលខ្លះ នេធិន ក៏បានចំណាយពេលវិស្សមកាល ក្នុងរដូវក្តៅ ដើម្បីផ្សាយដំណឹងល្អ ដល់មនុស្សដែលគាត់មិនស្គាល់នៅតាមផ្លូវក្នុងទីក្រុងធំៗនៅសហរដ្ឋអាមេរិក ហើយសព្វថ្ងៃនេះ គាត់កំពុងធ្វើកម្មសិក្សា នៅក្នុងការងារយុវជនក្នុងព្រះវិហាររបស់គាត់។ គោលដៅរបស់នេធិន គឺដើម្បីជួយយុវជន ឲ្យជៀសវាងការខ្ជះខ្ជាយពេលវេលា ហើយឲ្យរស់នៅថ្វាយព្រះគ្រីស្ទវិញ។

លោក ម៉ូសេ ជាអ្នកដឹកនាំប្រជាជនអ៊ីស្រាអែល ដែលមានទឹកចិត្ត សម្រាប់មនុស្សជំនាន់ក្រោយ ដូចនេធិនផងដែរ។ នៅពេលដែលគាត់ដឹងថា គាត់នឹងត្រូវផ្ទេរដំណែងអ្នកដឹកនាំឲ្យទៅលោកយ៉ូស្វេក្នុងពេលដ៏ខ្លីខាងមុខ គាត់ក៏បានថ្លែងសេចក្តីបង្គាប់របស់ព្រះអម្ចាស់ទៅកាន់ពូកបណ្តាជន ហើយក៏បានលើកឡើងអំពីលទ្ធផលនៃការស្តាប់បង្គាប់ ដែលជាជីវិត និងព្រះពរ ហើយលទ្ធផលនៃការមិនស្តាប់បង្គាប់គឺជាបណ្តាសា និងសេចក្តីស្លាប់។ គឺដូចដែលគាត់មានប្រសាសន៍ថា «ចូររើសយកជីវិតចុះ ដើម្បីឲ្យឯងបានរស់នៅ ព្រមទាំងពូជឯងតរៀងទៅផង... ដ្បិតគឺទ្រង់ហើយ ជាជីវិតនៃឯង» (ចោទិយកថា ៣០:១៩-២០)។ លោក ម៉ូសេ បានជំរុញពួកគេឲ្យស្រឡាញ់ព្រះអម្ចាស់ «និងស្តាប់តាមព្រះបន្ទូលទ្រង់ ហើយនៅជាប់នឹងទ្រង់តទៅ» (ខ.២០)។

ការជ្រើសរើសយកបាប នាំឲ្យយើងទទួលលទ្ធផលអាក្រក់។ ប៉ុន្តែ ពេលណាយើងថ្វាយជីវិតយើងដល់ព្រះជាថ្មី ព្រះអង្គពិតជានឹងមានសេចក្តីមេត្តាចំពោះយើង (ខ.២-៣) ហើយស្អាងយើងឡើងវិញ (ខ.៤)។ ព្រះបន្ទូលសន្យានេះបានសម្រេចក្នុងប្រវត្តិសាស្ត្ររបស់ប្រជាជនអ៊ីស្រាអែលទាំងមូល ដោយព្រះរាជកិច្ច ដែលព្រះយេស៊ូវសម្រេចបាននៅលើឈើឆ្កាង ដើម្បីនាំយើងចូលទៅក្នុងការប្រកបជាមួយព្រះឡើងវិញ។ សព្វថ្ងៃនេះ យើងក៏ត្រូវធ្វើការសម្រេចចិត្តផងដែរ ហើយយើងក៏អាចជ្រើសរើសយកជីវិត។—Karen Pimpo

តើផ្នែកណាខ្លះក្នុងជីវិតអ្នក ដែលពិបាកដើរតាមផ្លូវរបស់ព្រះ? តើអ្នកអាចលើកទឹកចិត្តមនុស្សជំនាន់ក្រោយដូចម្តេចខ្លះ ដើម្បីឲ្យពួកគេជ្រើសរើសយកជីវិត?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានបើកផ្លូវឲ្យទូលបង្គំអាចវិលត្រឡប់មកប្រកបស្និទ្ធស្នាលជាមួយព្រះអង្គ។

Daily Manna 2026_Content Enhance.indd 325 17/11/25 1:47 in the afternoon

ទូលបង្គំជាបាវបំរើរបស់ទ្រង់នឹងសូមចេញទៅតយុទ្ធនឹងសាសន៍ភីលីស្ទីននោះ (១សាំយ៉ូអែល ១៧:៣២)។

កន្លែងដែលព្រះអង្គអាចប្រើយើង

កាលហ៊ែឌ័រ (Heather) មានការងារជាអ្នកដឹកជញ្ជូន មានពេលមួយ គាត់ត្រូវដឹកជញ្ជូនអាហារ ទៅដល់ផ្ទះរបស់លោក ធីម (Tim)។ ពេលគាត់ទៅដល់លោក ធីម ក៏បានសុំឲ្យគាត់ជួយស្រាយកញ្ចប់អាហារ។ លោក ធីម មានជំងឺដាច់សរសៃឈាមខួរក្បាល អស់រយៈពេលពីរបីឆ្នាំហើយ ហើយមិនអាចស្រាយកញ្ចប់អាហារដោយខ្លួនឯងបានទេ។ ហ៊ែឌ័រ ក៏បានជួយស្រាយកញ្ចប់អាហារឲ្យគាត់ ដោយចិត្តរីករាយ។ ក្នុងរយៈពេលមួយថ្ងៃនោះ ហ៊ែឌ័រ បានគិតដល់លោក ធីម ជាញឹកញាប់ ហើយក៏មានចិត្តចង់ទៅរៀបចំអាហារឲ្យគាត់។ ក្រោយមក លោក ធីម ក៏បានឃើញភេសជ្ជៈទឹកមីឡូក្តៅ។ និងភួយពណ៌ក្រហម ដែលគាត់បានដាក់នៅមាត់ទ្វារផ្ទះលោក ធីម ដោយភ្ជាប់ជាមួយក្រដាសមួយសន្លឹក ដែលមានសរសេរពាក្យលើកទឹកចិត្តពីលើ ធ្វើឲ្យគាត់មានការប៉ះពាល់ចិត្តរហូតដល់ស្រក់ទឹកភ្នែក។

ហ៊ែឌ័រ បានមើលឃើញសារៈសំខាន់នៃការងារដឹកជញ្ជូនរបស់នាងលើកពីការរំពឹងគិត។ លោក អ៊ីសាយ ក៏មានអំណរលើសពីការរំពឹងគិតផងដែរ នៅពេលដែលគាត់ចាត់ ដាវីឌ ជាកូនពៅដែលនៅក្មេង ឲ្យយកស្បៀងអាហារទៅឲ្យបងប្រុសរបស់គាត់ កាលពួកអ៊ីស្រាអែលកំពុងបោះទ័ព ត្រៀមប្រយុទ្ធនឹងពួកភីលីស្ទីន (១សាំយ៉ូអែល ១៧:២)។ នៅពេលដែលដាវីឌបានទៅដល់កន្លែងនោះ គាត់ក៏បានដឹងថា កូលីយ៉ាត កំពុងបង្កការភ័យខ្លាចដល់រាស្ត្ររបស់ព្រះ ដោយការគំរាមជារៀងរាល់ថ្ងៃ (ខ.៨-១០, ១៦, ២៤)។ ដាវីឌ មានការឈឺចិត្ត ចំពោះការប្រមាថរបស់កូលីយ៉ាត មកលើកងទ័ពរបស់ព្រះដ៏មានព្រះជន្មរស់ (ខ.២៦) ហើយគាត់ក៏មានចិត្តចង់ទៅតទល់ ដោយទូលស្តេចសូលថា «សូមកុំឲ្យអ្នកណាស្តុតចិត្តដោយព្រោះវាឡើយ ទូលបង្គំជាបាវបំរើរបស់ទ្រង់នឹងសូមចេញទៅតយុទ្ធនឹងសាសន៍ភីលីស្ទីននោះ» (ខ.៣២)។

ជួនកាល ព្រះអម្ចាស់ប្រើកាលៈទេសៈនៃជីវិតប្រចាំថ្ងៃរបស់យើង ដើម្បីដាក់យើងនៅកន្លែង ដែលព្រះអង្គចង់ប្រើយើង។ ចូរយើងបើកចំហភ្នែក និងចិត្តយើងមើលទៅកន្លែង និងរបៀបដែលព្រះអង្គអាចប្រើយើង ដើម្បីបម្រើនរណាម្នាក់។—Kirsten Holmberg

តើព្រះអម្ចាស់បានបំពេញតម្រូវការរបស់អ្នក តាមរយៈអ្នកដទៃនៅពេលណា? តើព្រះអង្គសព្វព្រះទ័យនឹងប្រើអ្នក នៅថ្ងៃនេះក្នុងជីវិតរបស់អ្នកដទៃ ដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គបើកភ្នែកទូលបង្គំ ឲ្យមើលឃើញកន្លែងដែលព្រះអង្គសព្វព្រះទ័យនឹងប្រើទូលបង្គំនៅថ្ងៃនេះ។

ចូរបង្ហាត់ខ្លួនខាងឯសេចក្តីគោរពប្រតិបត្តិដល់ព្រះវិញ (១ធីម៉ូថេ ៤:៧)។

ការហ្វឹកហាត់ខាងវិញ្ញាណ

លោក ត្រេ (Tre) ជាអ្នកហាត់ប្រាណជាទៀងទាត់នៅកន្លែងហាត់ប្រាណ ហើយបើយើងគ្រាន់តែមើលឃើញគាត់ យើងក៏អាចដឹងដែរ។ គាត់មានស្មាធំទូលាយ សាច់ដុំក៏ធំ ហើយគ្រាន់តែដើមដៃរបស់គាត់មានទំហំធំជិតស្មើភ្លៅរបស់ខ្ញុំ។ ពេលខ្ញុំឃើញគាត់មានរាងកាយរឹងមាំដូចនេះ ខ្ញុំមានចិត្តចង់ទៅជជែកជាមួយគាត់អំពីរឿងខាងវិញ្ញាណ។ ខ្ញុំក៏បានសួរគាត់ថា តើការប្តេជ្ញាចិត្តរបស់គាត់ក្នុងការលើកសាច់ដុំបានឆ្លុះបញ្ចាំងអំពីទំនាក់ទំនងល្អ ដែលគាត់មានជាមួយព្រះដែរឬទេ? យើងមិនបានជជែកគ្នាឲ្យបានស៊ីជម្រៅទេ នៅថ្ងៃនោះ តែលោក ត្រេ ពិតជាបានទទួលស្គាល់ «ព្រះវត្តមានរបស់ព្រះនៅក្នុងជីវិតគាត់»។ យើងជជែកគ្នាបានរយៈពេលយូរល្មមនឹងឲ្យគាត់បង្ហាញរូបថតរបស់គាត់ កាលគាត់មានទម្ងន់ជិត២០០គីឡូ មិនរឹងមាំ និងមិនមានសុខភាពល្អ។ ការផ្លាស់ប្តូរក្នុងរបៀបរបបនៃការរស់នៅរបស់គាត់ បាននាំឲ្យគាត់មានការផ្លាស់ប្តូរខាងរូបកាយ ដែលគួរឲ្យភ្ញាក់ផ្អើល។

ក្នុងបទគម្ពីរ១ធីម៉ូថេ ៤:៦-១០ សាវ័ក ប៉ុល បាននិយាយផ្តោតទៅលើការហ្វឹកហាក់ខាងរូបកាយ និងខាងវិញ្ញាណ។ គឺដូចដែលគាត់បានបង្រៀនថា «ចូរបង្ហាត់ខ្លួនខាងឯសេចក្តីគោរពប្រតិបត្តិដល់ព្រះវិញ ដ្បិតការបង្ហាត់ខ្លួនប្រាណ នោះមានប្រយោជន៍តែបន្តិចទេ តែសេចក្តីគោរពប្រតិបត្តិដល់ព្រះ នោះទើបមានប្រយោជន៍គ្រប់ជំពូក វិញ ក៏មានសេចក្តីសន្យាឲ្យបានជីវិតនៅជាន់ឥឡូវនេះ ហើយទៅខាងនាយផង» (ខ.៧-៨)។ យើងមិនអាចវាយតម្លៃទំនាក់ទំនងដែលនរណាម្នាក់មានជាមួយព្រះ ផ្អែកទៅលើរូបសម្បត្តិខាងក្រៅរបស់គាត់ឡើយ។ សុខភាពខាងវិញ្ញាណរបស់យើង គឺអាស្រ័យទៅលើចិត្តរបស់យើង។ ជីវិតខាងវិញ្ញាណរបស់យើងចាប់ផ្តើម នៅពេលដែលយើងសម្រេចចិត្តទទួលជឿព្រះយេស៊ូវ ដែលតាមរយៈព្រះអង្គ យើងទទួលបានការអត់ទោសបាប។ ចាប់តាំងពីពេលនោះមក យើងត្រូវចាប់ផ្តើមមានការហ្វឹកហាត់ខាងវិញ្ញាណ។ ការនេះគឺរាប់បញ្ចូលការចិញ្ចឹម ដោយសេចក្តីពិតនៃសេចក្តីជំនឿ និងការបង្រៀនដ៏ល្អ» (ខ.៦) និងដោយកម្លាំងរបស់ព្រះ ដោយរស់នៅក្នុងជីវិតដែលថ្វាយព្រះកិត្តិនាមដល់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌។—Arthur Jackson

បើអ្នកបានចាប់ផ្តើមការធ្វើដំណើររបស់អ្នកជាមួយព្រះយេស៊ូវ តើអ្នកវាយតម្លៃសុខភាពខាងវិញ្ញាណរបស់អ្នក ដូចម្តេចខ្លះ? តើមានភស្តុតាងអ្វីខ្លះក្នុងជីវិតអ្នក ដែលចង្អុលបង្ហាញអ្នក ឲ្យងាកទៅរុកការមានសុខភាពល្អខាងវិញ្ញាណ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ ពេលណាទូលបង្គំផ្តោតខ្លាំងពេកទៅលើសម្បកក្រៅ។ សូមព្រះអង្គជួយទូលបង្គំ ក្នុងការហ្វឹកហាត់ខាងវិញ្ញាណ ដែលមានដូចជាការអានព្រះគម្ពីរ ការអធិស្ឋាន និងការរស់នៅ ព្រមទាំងបម្រើអ្នកដទៃ។

Daily Manna 2026_Content Enhance.indd 327 17/11/25 1:47 in the afternoon

បើអ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងកាន់តាមពាក្យខ្ញុំ (យ៉ូហាន ១៤:២៣)។

ការស្តាប់បង្គាប់គឺជាការសម្រេចចិត្ត

រដ្ឋវរាងក្នុងប្រទេសហូឡង់ កម្រមានព្រឹលធ្លាក់ច្រើន ប៉ុន្តែអាកាសធាតុអាចត្រជាក់ខ្លាំង ល្មមនឹងធ្វើឲ្យទឹកក្នុងព្រែកប្រែក្លាយជាទឹកកក។ កាលស្វាមីខ្ញុំ កំពុងចម្រើនវ័យធំឡើង នៅទីនោះឪពុកម្តាយគាត់មានច្បាប់គ្រួសារមួយ គឺ «មិនត្រូវដើរលើទឹកកកនៅក្នុងព្រែក ទាល់តែទឹកកកនោះមានកម្រាស់ក្រាស់ល្មមនឹងអាចទ្រទម្ងន់សត្វសេះ»។ ដោយសារសត្វសេះបន្សល់ទុកជានរបស់វា នៅកន្លែងដែលពួកវាបានទៅដល់គាត់ និងមិត្តភក្តិរបស់គាត់ក៏បាននាំគ្នាទៅប្រមូលលាមកសត្វសេះនៅតាមផ្លូវ យកទៅបោះពីលើទឹកកក ក្នុងព្រែកដែលមានកំរាស់ស្តើងនៅឡើយ ហើយក៏បាននាំគ្នាលេងនៅលើផ្ទៃទឹកកក ក្នុងព្រែកនោះ។ ពួកគេមិនមានគ្រោះថ្នាក់ទេនៅពេលនោះ ហើយក៏គ្មាននរណាដឹងថា ពួកគេបានប្រើល្បិចនេះដែរ ប៉ុន្តែក្នុងជម្រៅចិត្ត ពួកគេបានដឹងថា ពួកគេមិនបានស្តាប់បង្គាប់ឪពុកម្តាយទេ។

ការស្តាប់បង្គាប់មិនកើតមានដោយឯកឯងឡើង។ ការសម្រេចចិត្តស្តាប់បង្គាប់ ឬមិនស្តាប់បង្គាប់ អាចកើតចេញពីចិត្តដែលដឹងថា ខ្លួនមានកាតព្វកិច្ច ឬខ្លាចការដាក់ទោស។ ប៉ុន្តែ យើងក៏អាចសម្រេចចិត្តស្តាប់បង្គាប់ដោយសេចក្តីស្រឡាញ់ និងការគោរពចំពោះអ្នក ដែលមានអំណាចមកលើយើង។

ក្នុងបទគម្ពីរ យ៉ូហាន ជំពូក១៤ ព្រះយេស៊ូវបានបង្រៀនពួកសាវ័កព្រះអង្គថា «បើអ្នកណាស្រឡាញ់ខ្ញុំ អ្នកនោះនឹងកាន់តាមពាក្យខ្ញុំ... អ្នកណាដែលមិនស្រឡាញ់ខ្ញុំ នោះមិនកាន់តាមពាក្យខ្ញុំទេ» (ខ.២៣-២៤)។ ការសម្រេចចិត្តស្តាប់បង្គាប់ព្រះ មិនតែងតែមានភាពងាយស្រួលជានិច្ចឡើយ ប៉ុន្តែអំណាចនៃព្រះវិញ្ញាណគង់នៅក្នុងយើង ជួយយើងឲ្យមានលទ្ធភាព និងចិត្តដែលចង់ស្តាប់បង្គាប់ (ខ.១៥-១៧)។ ដោយជំនួយមកពីព្រះអង្គ យើងអាចបន្តដើរតាមព្រះរាជបញ្ជារបស់ព្រះ ដែលស្រឡាញ់យើង មិនមែនដោយសារយើងខ្លាចព្រះអង្គដាក់ទោសយើង តែដោយសារយើងស្រឡាញ់ព្រះអង្គ។—Cindy Hess Kasper

តើអ្នកមិនស្តាប់បង្គាប់ព្រះ ដោយស្ម័គ្រពីចិត្ត យ៉ាងដូចម្តេចខ្លះ? ហេតុអ្វីអ្នកចាំបាច់ត្រូវស្តាប់បង្គាប់ព្រះ ទោះមានការពិបាក ឬអ្នកមិនចង់ស្តាប់បង្គាប់ក៏ដោយ?

ឱព្រះនៃសេចក្តីស្រឡាញ់ សូមព្រះអង្គបន្ទន់ចិត្តដ៏រឹងរូសរបស់ទូលបង្គំ ឲ្យស្តាប់តាមការបង្រៀនរបស់ព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំឲ្យលះចោលគោលបំណងរបស់ទូលបង្គំ ហើយឲ្យស្តាប់បង្គាប់ព្រះអង្គដោយចិត្តស្មោះត្រង់វិញ។

មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង ពីព្រោះគេមានរង្វាន់យ៉ាងល្អកើតពីការនឿយហត់របស់ខ្លួន (សាស្តា ៤:៩)។

ការគាំទ្រដ៏រឹងមាំក្នុងព្រះគ្រីស្ទ

កីឡាករម្នាក់ ក្នុងការប្រកួតរត់ប្រណាំងម៉ារ៉ាតុន នៅទីក្រុងឡុងដ៍ បានដកពិសោធន៍ និងដឹងអំពីមូលហេតុដែលគាត់មិនត្រូវរត់តែម្នាក់ឯងក្នុងការរត់ប្រណាំងធំៗ។ បន្ទាប់ពីគាត់បានត្រៀមខ្លួនដោយការហ្វឹកហាត់ដ៏ពិបាកបានប៉ុន្មានខែ គាត់ចង់រត់ឲ្យដល់ទី ដោយភាពរឹងមាំ។ ប៉ុន្តែ នៅពេលដែលគាត់រត់ត្រហេបត្រហបឆ្ពោះទៅរកខ្សែព្រាត់ គាត់ដឹងថា ខ្លួនគាត់កំពុងតែខ្សោះអស់កម្លាំង ហើយហៀបនឹងដួល។ មុនពេលគាត់ដួលនៅលើដី កីឡាការពីរនាក់ទៀតបានចាប់ដៃគាត់ទាំងសង្ខាងជាប់ ហើយក៏បានជួយកីឡាការដ៏ហត់នឿយម្នាក់នេះបន្តដំណើរទៅមុខរហូតដល់ទី។

អ្នកនិពន្ធបទគម្ពីរសាស្តាបានរំឭកយើង អំពីអត្ថប្រយោជន៍មួយចំនួន ដែលយើងទទួលបានពីការរត់ប្រណាំងនៅលើវិថីជីវិត ដោយមានអ្នកជិទ្ធែរួមដំណើរជាមួយយើង។ ស្តេច សាឡូម៉ូន ដែលជាអ្នកនិពន្ធនៃកណ្ឌគម្ពីរនេះ បានបង្ហាញគោលការណ៍ដែលថា «មានគ្នា២នាក់ នោះវិសេសជាងនៅតែឯង» (សាស្តា ៤:៩)។ ទ្រង់បានបង្ហាញអំពីអត្ថប្រយោជន៍នៃការប្រឹងប្រែងដែលមានការរួបរួមគ្នា។ ទ្រង់ក៏បានបង្រៀនផងដែរថា ការធ្វើការជាដៃគូ អាចនាំឲ្យមានរង្វាន់ដ៏ល្អកើតពីការនឿយហត់ (ខ.៩)។ ក្នុងអំឡុងពេលដ៏ពិបាក អ្នករួមដំណើរជាមួយយើង អាចជួយជ្រោងយើងឡើង (ខ.១០)។ នៅពេលយប់ងងឹត និងរងា មិត្តភក្តិក៏អាចផ្តុំគ្នាឲ្យមានភាពកក់ក្តៅបានដែរ (ខ.១១)។ ហើយក្នុងពេលដែលមានគ្រោះថ្នាក់ មនុស្សពីរនាក់អាចរួមគ្នាការពារខ្លួន ឲ្យរួចផុតពីការវាយប្រហារ (ខ.១២)។ មនុស្សដែលមានការរួមចិត្តរួមគំនិត អាចបង្កើតឲ្យមានកម្លាំងដ៏ប្រសើរ។

ដោយសារយើងមានភាពកម្សោយ និងភាពផុយស្រួយ យើងត្រូវការសុវត្ថិភាព និងការគាំទ្រដ៏រឹងមាំ ពីសហគមន៍នៃអ្នកជឿព្រះយេស៊ូវ។ ចូរយើងបន្តធ្វើដំណើរទៅមុខទាំងអស់គ្នា តាមការដឹកនាំរបស់ព្រះអង្គ!—Marvin Williams

ហេតុអ្វីការរួមដំណើររបស់បងប្អូនរួមជំនឿ មានសារៈសំខាន់ក្នុងការរត់ប្រណាំងខាងវិញ្ញាណ? តើអ្នកអាចជួយសហគមន៍អ្នក ឲ្យមានភាពរឹងមាំឡើង ដោយរបៀបណា?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំកសាងសហគមន៍គ្រីស្ទបរិស័ទ ឲ្យមានភាពរឹងមាំឡើង។

Daily Manna 2026_Content Enhance.indd 329 17/11/25 1:47 in the afternoon

សូមលោកបើកឲ្យខ្ញុំនិយាយទៅជនទាំងឡាយបន្តិចសិន (កិច្ចការ ២១:៣៩)។

ឱកាសចែកចាយអំពីព្រះយេស៊ូវ

សាវ័ក ប៉ុល បានទៅព្រះវិហារទីក្រុងយេរូសាឡិម ដើម្បីចូលរួមពិធីញែកជាបរិសុទ្ធរបស់សាសន៍យូដា (កិច្ចការ ២១:២៦)។ ពួកញុះញង់មួយចំនួនគិតស្មានថា គាត់កំពុងបង្រៀនគេឲ្យប្រឆាំងនឹងក្រឹត្យវិន័យ ហើយក៏បានព្យាយាមសម្លាប់គាត់ (ខ.៣១)។ ពួកទាហានរ៉ូម៉ាំងក៏បានប្រញាប់ទៅធ្វើអន្តរាគមន៍ ហើយក៏បានចាប់ចងសាវ័ក ប៉ុល នាំគាត់ចេញពីតំបន់ព្រះវិហារ ខណៈពេលដែលហ្វូងមនុស្សបានស្រែកឲ្យគេសម្លាប់គាត់ (ខ.៣៦)។

តើសាវ័ក ប៉ុល បានឆ្លើយតប ចំពោះការគំរាមកំហែងនេះយ៉ាងដូចម្តេចខ្លះ? គឺគាត់បានសុំមេទ័ពអនុញ្ញាតឲ្យគាត់និយាយទៅកាន់ពួកបណ្តាជន (ខ.៣៩)។ នៅពេលដែលមេទ័ពរ៉ូម៉ាំងបានអនុញ្ញាតឲ្យគាត់និយាយ ទាំងខ្លួនគាត់កំពុងហូរឈាម និងមានស្នាមជាំពេញខ្លួន គាត់ក៏បានងាកទៅរកហ្វូងមនុស្សដែលកំពុងតែខឹងសម្បា ហើយក៏បានចែកចាយសេចក្តីជំនឿ ដែលគាត់មានចំពោះព្រះយេស៊ូវ ឲ្យពួកគេស្តាប់ (២២:១-១៦)។

នេះជារឿងដែលបានកើតឡើងជាងពីរពាន់ឆ្នាំហើយ ជារឿងចាស់ក្នុងព្រះគម្ពីរ ដែលយើងប្រហែលមិនងាយជួបរឿងនេះទេ។ កាលពីពេលថ្មីៗនេះ មានបុរសម្នាក់ឈ្មោះ ភីធ័រ (Peter) ត្រូវគេចាប់ខ្លួន ខណៈពេលដែលគាត់ទៅសួរសុខទុក្ខមិត្តភក្តិម្នាក់ ដែលកំពុងជាប់គុក។ មិត្តភក្តិគាត់ជាអ្នកជឿព្រះយេស៊ូវ ក្នុងប្រទេសដែលគ្រីស្ទបរិស័ទបានទទួលរងការបៀតបៀនជាប្រចាំ។ លោក ភីធ័រ ត្រូវគេបោះចូលទៅក្នុងគុកងងឹត ហើយត្រូវគេអ៊ុំភ្នែក ក្នុងពេលដែលគេសួរចម្លើយគាត់។ នៅពេលដែលគេដកក្រណាត់អ៊ុំភ្នែកចេញ គាត់ក៏បានឃើញទាហានបួននាក់ កំពុងភ្លក់កាំភ្លើងដាក់គាត់។ តើលោក ភីធ័រ គួរឆ្លើយតបដូចម្តេចខ្លះ? គាត់បានមើលឃើញឱកាសដ៏ល្អឥតខ្ចោះ សម្រាប់ចែកចាយសេចក្តីជំនឿរបស់គាត់ ដល់ពួកគេ។

សាវ័ក ប៉ុល និងលោក ភីធ័រ បានចង្អុលបង្ហាញប្រាប់គេអំពីសេចក្តីពិតដ៏សំខាន់ ទោះគេពិបាកទទួលយកយ៉ាងណាក៏ដោយ។ ទោះព្រះអម្ចាស់អនុញ្ញាតឲ្យយើងឆ្លងកាត់ពេលវេលាដ៏ពិបាក ឬទទួលរងការបៀតបៀនយ៉ាងក៏ដោយ ក៏យើងនៅតែមានភារកិច្ច "ផ្សាយដំណឹងល្អ" (ម៉ាកុស ១៦:១៥)។ ព្រះអង្គនឹងគង់នៅជាមួយយើង ហើយប្រទានយើងនូវប្រាជ្ញា និងព្រះចេស្តា ដើម្បីចែកចាយសេចក្តីជំនឿរបស់យើង ដល់អ្នកមិនជឿ។—

Dave Branon

តើអ្នក ឬមនុស្សដែលអ្នកស្គាល់ បានជួបការបៀតបៀន ដោយសារសេចក្តីជំនឿលើព្រះគ្រីស្ទ យ៉ាងដូចម្តេចខ្លះ? តើអ្នកនឹងប្រកាសដំណឹងល្អនៅថ្ងៃនេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គប្រទានទូលបង្គំនូវចិត្តក្លាហាន ដើម្បីធ្វើជាអ្នកនាំព្រះរាជសារនៃសេចក្តីស្រឡាញ់ និងប្រាជ្ញារបស់ព្រះអង្គ។

ដោយព្រោះបានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្តីជំនុំជំរះ (ហេព្រើរ ៩:២៧)។

ការណាត់ជួបជាមួយសេចក្តីស្លាប់

កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៦៣ លោក ចន អ័រហ្វ ខេនេឌី (John F. Kennedy) ជាប្រធានាធិបតីអាមេរិក លោក អាល់ដូស ហាក់លេយ (Aldous Huxley) ជាអ្នកនិពន្ធ និងទស្សនវិទូ និងលោកស៊ី អ័រស លូអីស (C. S. Lewis) ជាអ្នកការពារជំនឿគ្រីស្ទានសុទ្ធតែបានលាចាកលោកក្នុងថ្ងៃតែមួយ។ បុរសដ៏ល្បីល្បាញទាំង៣នាក់នេះ បានប្រកាន់ខ្ជាប់នូវទស្សនវិជ្ជាខុសគ្នាយ៉ាងខ្លាំងក្នុងការរស់នៅ។ លោក ហាក់លេយ ជាអ្នកមិនជឿ ហើយក៏មិនបដិសេធថា ព្រះមានពិតមែន ហើយជាអ្នកនិយមទស្សនវិជ្ជារបស់អាស៊ី។ ចំណែកលោក ខេនេឌី វិញ គឺជាសាសនិករ៉ូម៉ាំងកាតូលិក ប៉ុន្តែគាត់បានប្រកាន់ខ្ជាប់តាមទស្សនវិជ្ជាបែបមនុស្សជាតិនិយម។ រីឯ លោ លូអីស វិញ គាត់គឺជាអតីតអ្នកបដិសេធថាព្រះមានពិតមែន ប៉ុន្តែក្រោយមកគាត់បានក្លាយជាអ្នកជឿព្រះក្នុងនិកាយអ៊ែងគ្លិខិន ហើយក៏ក្លាយជាអ្នកការពារសេចក្តីជំនឿគ្រីស្ទាន ដោយមិនខ្លាចរអែងចិត្តនរណាឡើយ។ សេចក្តីស្លាប់មិនរើសមុខមនុស្សឡើយ ខណៈពេលបុរសដ៏ល្បីល្បាញទាំងបីបានជួបសេចក្តីស្លាប់ នៅថ្ងៃខែតែមួយ នៅទីកន្លែងផ្សេងគ្នា។

ព្រះគម្ពីរបានចែងថា សេចក្តីស្លាប់បានចាប់ផ្តើមកើតមានចំពោះមនុស្សជាតិ នៅពេលដែលលោកអ័ដាម និងនាងអេវ៉ាមិនស្តាប់បង្គាប់ព្រះ កាលពួកគេកំពុងរស់នៅក្នុងសួនច្បារអេដែន (លោកុប្បត្តិ ៣) នេះជាការការពិតដ៏សោកសៅ ដែលមានផលប៉ះពាល់មកលើប្រវត្តិសាស្ត្រមនុស្សជាតិទាំងមូល។ សេចក្តីស្លាប់កើតឡើងចំពោះមនុស្សទាំងអស់ ដោយមិនរើសមុខ ជាការណាត់ជួប ដែលគ្មាននរណាម្នាក់អាចគេចវេសបានទេ។ គឺដូចដែលបទគម្ពីរហេព្រើរ ៩:២៧ បានចែងថា ព្រះអម្ចាស់ "បានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្តីជំនុំជំរះ"។

តើយើងអាចស្វែងរកសេចក្តីសង្ឃឹមនៅកន្លែងណា នៅពេលដែលយើងដឹងថា យើងត្រូវជួបសេចក្តីស្លាប់ និងរឿងដែលនឹងកើតឡើងបន្ទាប់ពីយើងស្លាប់? គឺយើងស្វែងរកសេចក្តីសង្ឃឹម នៅក្នុងព្រះគ្រីស្ទ។ បទគម្ពីរ រ៉ូម ៦:២៣ បានបកស្រាយអំពីសេចក្តីពិតនេះ យ៉ាងល្អតតែខ្លោះថា "ដ្បិតឈ្នួលរបស់អំពើបាប នោះជាសេចក្តីស្លាប់ តែអំណោយទាននៃព្រះវិញ គឺជាជីវិតដ៏នៅអស់កល្បជានិច្ច ដោយព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា"។ តើធ្វើដូចម្តេចឲ្យយើងអាចទទួលអំណោយទាននេះពីព្រះ? យើងអាចទទួលបាន ដោយសារព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ បានសុគត ដើម្បីបំផ្លាញសេចក្តីស្លាប់ ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីប្រទានយើងនូវជីវិតអស់កល្បជានិច្ច (២ធីម៉ូថេ ១:១០)។—Bill Crowder

តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលដែលអ្នកពិចារណាអំពីការណាត់ជួបជាមួយសេចក្តីស្លាប់? តើអ្នកបានត្រៀមខ្លួនសម្រាប់សេចក្តីស្លាប់យ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គសម្រាប់ការចាត់ព្រះរាជបុត្រាព្រះអង្គ ឲ្យមកបង់ថ្លៃលោះទូលបង្គំឲ្យរួចពីបាប ដោយសុគតនៅលើឈើឆ្កាង។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការប្រទានជីវិតអស់កល្បជានិច្ច។

គម្រោងអានព្រះគម្ពីរឆ្នាំ | អេសេគាល ១៦-១៧ និងយ៉ាកុប ៣

ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវទូលបង្គំផង (ទំនុកតម្កើង ១១៩:១០៥)។

ការសម្រេចចិត្តដោយប្រាជ្ញា

មានពេលមួយ ខ្ញុំត្រូវសម្រេចចិត្តលក់ផ្ទះរបស់ម្តាយខ្ញុំ ដែលបានលាកចាកលោកហើយ។ នេះជាការសម្រេចចិត្តដែលបានក្លាយជាបន្ទុកដ៏ធ្ងន់ក្នុងចិត្តខ្ញុំ បន្ទាប់ពីម្តាយជាទីស្រឡាញ់ ជាស្ត្រីមេម៉ាយបានទទួលមរណៈភាព។ ខ្ញុំមានមនោសញ្ចេតនាជិតជាប់នឹងទីកន្លែងដែលគាត់ធ្លាប់រស់នៅ ធ្វើឲ្យខ្ញុំពិបាកគ្រប់គ្រងអារម្មណ៍។ ទោះជាយ៉ាងណាក៏ដោយ ខ្ញុំ និងប្អូនស្រីរបស់ខ្ញុំបាននាំគ្នាសម្អាត និងជួសជុលផ្ទះដែលគ្មានមនុស្សនៅនោះ អស់រយៈពេល២ឆ្នាំ ហើយក៏បានសម្រេចចិត្តលក់វា។ ដោយសារយើងបានដាក់លក់ផ្ទះនោះក្នុងអំឡុងពេលវិបត្តិសេដ្ឋកិច្ច កាលពីឆ្នាំ២០០៨ គ្មាននរណាទិញផ្ទះនោះទេ។ យើងក៏បានទម្លាក់តម្លៃលក់ផ្ទះនោះ នៅតែគ្មានគេទិញ។ បន្ទាប់មក ខណៈពេលដែលខ្ញុំកំពុងអានព្រះគម្ពីរ នៅពេលព្រឹកថ្ងៃមួយនោះ ខ្ញុំមានការប៉ះពាល់ចិត្តនឹងបទគម្ពីរមួយ ដែលបានចែងថា «ផ្ទះណាគ្មានគោ នោះក្រោលមែងស្អាតល្អ តែគឺដោយកំឡាំងគោនោះឯង ដែលនឹងចំរើនកើនឡើងបាន» (សុភាសិត ១៤:៤)។

បទគម្ពីរសុភាសិតនេះកំពុងនិយាយអំពីការចិញ្ចឹមសត្វ ប៉ុន្តែខ្ញុំមានការចាប់អារម្មណ៍យ៉ាងខ្លាំង ចំពោះខ្លឹមសារនៃបទគម្ពីរនេះ។ ផ្ទះរបស់ម្តាយខ្ញុំនៅតែមានរបៀបរៀបរយ ដោយសារមិនមានមនុស្សរស់នៅ ប៉ុន្តែទាល់តែផ្ទះនោះមាន «ភាពរញ៉េរញ៉ៃ» ដោយសារមានមនុស្សស្នាក់នៅ ទើបវាអាចបង្កើតផលផ្លែដែលមានប្រយោជន៍។ ឬមានប្រយោជន៍ចំពោះយើង ក្នុងលក្ខណៈជាកេរដំណែលប្រចាំគ្រួសារ។ ខ្ញុំក៏បានទូរស័ព្ទសួរប្អូនខ្ញុំ ដើម្បីឲ្យយើងអាចដាក់ជួលផ្ទះនោះវិញ។

ការសម្រេចចិត្តនេះបានធ្វើឲ្យយើងភ្ញាក់ផ្អើល។ យើងមិនមានគម្រោងកែប្រែផ្ទះរបស់ម្តាយខ្ញុំ ឲ្យក្លាយជាការវិនិយោគនោះទេ។ ប៉ុន្តែ ព្រះគម្ពីរបានធ្វើជាអ្នកប្រឹក្សាយោបល់ខាងវិញ្ញាណ ដែលបានផ្តល់ឲ្យយើងនូវប្រាជ្ញាសម្រាប់ស្ថានភាពជាក់ស្តែង។ គឺដូចដែលស្តេចដាវីឌបានអធិស្ឋានថា «ឱព្រះយេហូវ៉ាអើយ សូមបង្ហាញអស់ទាំងផ្លូវរបស់ទ្រង់ដល់ទូលបង្គំ សូមបង្រៀនទូលបង្គំក្នុងផ្លូវច្រករបស់ទ្រង់» (ទំនុកតម្កើង ២៥:៤)។

តាមរយៈការសម្រេចចិត្តនេះ ខ្ញុំនិងប្អូនស្រីខ្ញុំបានទទួលព្រះពរ ដោយសារយើងបានជួលផ្ទះរបស់ម្តាយយើងឲ្យក្រុមគ្រួសារដែលគួរឲ្យស្រឡាញ់ជាច្រើន។ ព្រះគម្ពីរបើបជួយដឹកនាំការសម្រេចចិត្តរបស់យើង។ នេះជាសេចក្តីពិតដែលកែប្រែជីវិតដែលយើងរៀនសូត្របាននៅក្នុងរឿងនេះ។ គឺដូចដែលបទគម្ពីរទំនុកតម្កើង ១១៩:១០៥ បានចែងថា «ព្រះបន្ទូលនៃទ្រង់ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវទូលបង្គំផង»។ ចូរយើងដើរក្នុងពន្លឺរបស់ព្រះ។—Patricia Raybon

តើមានការសម្រេចចិត្តដ៏ពិបាកមួយណា ដែលអ្នកកំពុងប្រឈមមុខដាក់? តើព្រះគម្ពីរអាចផ្តល់ឲ្យអ្នកនូវចម្លើយដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ខណៈពេលដែលទូលបង្គំធ្វើការសម្រេចចិត្ត សូមព្រះអង្គដឹកនាំទូលបង្គំ ដោយពន្លឺនៃព្រះបន្ទូលក្នុងព្រះគម្ពីរ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសេគាល ១៨-១៩ និងយ៉ាកុប ៤

ចូរខំប្រឹងធ្វើឲ្យទីក្រុង ដែលអញបានឲ្យគេដឹកនាំឯងទៅនៅជាឈ្លើយនោះ បានសេចក្ដីសុខ។ (យេរេមា ២៩:៧)។

ធ្វើជាភ្នាក់ងារនៃសេចក្ដីសុខសាន្ត

កាលពីឆ្នាំ២០១៥ អង្គការ និងសមាគមន៍គ្រីស្ទបរិស័ទ ក្នុងទីក្រុងឌូឡ្យ៉ាដូ ស្ត្រើង រដ្ឋឌូឡ្យ៉ាដូ បានរួបរួមគ្នា ដើម្បីធ្វើការបម្រើប្រជាជននៅទីក្រុងនេះ ហើយក្រុមការងារមានឈ្មោះថា ព្រោះតែខ្ញុំស្រឡាញ់អ្នក ក៏បានចាប់កំណើតឡើង។ រៀងរាល់ពេលរដូវស្លឹកឈើជ្រុះមកដល់ ក្រុមការងារមួយនេះតែងតែបញ្ជូនអ្នកជឿព្រះឲ្យចេញទៅបម្រើ ដល់សហគមន៍ក្នុងកម្មវិធីបម្រើទីក្រុង។

កាលប៉ុន្មានឆ្នាំមុន ខ្ញុំនិងកូនៗរបស់ខ្ញុំ បានទទួលភារកិច្ច ទៅធ្វើការបម្រើ ក្នុងសាលាបឋមសិក្សាមួយ ក្នុងទីប្រជុំជន នៅទីក្រុង ក្នុងអំឡុងពេលយើងធ្វើកម្មវិធីបម្រើទីក្រុងនោះ។ យើងបានធ្វើការបោសសម្អាត និងដករុក្ខជាតិចង្រៃ នៅក្នុងបរិវេណសាលា ហើយយើងក៏បានធ្វើការកែលំអសាលារៀន ដោយយកខ្សែសំប៉ែតធ្វើពីដែរមានពណ៌ចម្រុះ មកចងនឹងច្រវាក់នៅជាប់បង្គោលរបងសាលារៀន បង្កើតបានជារូបភាពស្រដៀងនឹងភ្នំ។ នេះជាការស្នាដៃសិល្បៈដ៏សាមញ្ញ តែមានភាពស្រស់ស្អាតដែលគួរឲ្យភ្ញាក់ផ្អើល។

ពេលណាខ្ញុំបើកឡានកាត់សាលាបឋមនោះ ស្នាដៃសិល្បៈដ៏សាមញ្ញរបស់យើង បានធ្វើឲ្យខ្ញុំនឹកចាំបទគម្ពីរយេរេមា ជំពូក២៩។ ក្នុងបទគម្ពីរនេះ ព្រះអម្ចាស់បានបង្គាប់រាស្ត្រព្រះអង្គឲ្យតាំងទីលំនៅ និងធ្វើការបម្រើដល់ទីក្រុង ដែលពួកគេកំពុងរស់នៅ។ ព្រះអង្គបានបង្គាប់ឲ្យពួកគេអនុវត្តដូចនេះ ទោះពួកគេកំពុងរស់នៅក្នុងការនិរទេស ហើយមិនចង់រស់នៅទីនោះក៏ដោយ។

គឺដូចដែលព្រះអម្ចាស់បានមានបន្ទូលមកពួកគេ តាមរយៈហោរាយេរេមាថា “ចូរខំប្រឹងធ្វើឲ្យទីក្រុង ដែលអញបានឲ្យគេដឹកនាំឯងទៅនៅជាឈ្លើយនោះ បានសេចក្ដីសុខ ហើយត្រូវអធិស្ឋានដល់ព្រះយេហូវ៉ាឲ្យទីនោះផង ដ្បិតក្នុងសេចក្ដីសុខរបស់ក្រុងនោះ ឯងរាល់គ្នានឹងបានសេចក្ដីសុខដែរ” (ខ.៧)។ ពាក្យសេចក្ដីសុខ ក្នុងបទគម្ពីរនេះ គឺបកប្រែមកពីពាក្យ សាឡូម ជាភាសាហេព្រើរ។ ពាក្យនេះបានរាប់បញ្ចូលភាពពេញលេញ និងភាពរីកចម្រើន ដែលមានតែសេចក្ដីល្អ និងការប្រោសលោះរបស់ព្រះទេ ដែលអាចផ្តល់ឲ្យបាន។

ពិតជាអស្ចារ្យណាស់ ដែលព្រះអម្ចាស់បានត្រាស់ហៅយើងម្នាក់ៗ ឲ្យធ្វើជាភ្នាក់ងារនៃសេចក្ដីសុខសាន្តនេះ នៅកន្លែងណាដែលយើងកំពុងរស់នៅ។ ព្រះអង្គបានត្រាស់ហៅយើងឲ្យបង្កើតឲ្យមានភាពស្រស់ស្អាត និងប្រកាសអំពីការប្រោសលោះ តាមរបៀបដ៏សាមញ្ញ និងច្បាស់លាស់ នៅកន្លែងដែលព្រះអង្គបានដាក់ឲ្យយើងរស់នៅ។—Adam R. Holz

តើអ្នកបានឃើញព្រះអម្ចាស់ស្តាឲ្យមានសេចក្ដីសុខឡើងវិញនៅកន្លែងណាមួយ នៅពេលណា? តើអ្នកអាចប្រើពេលវេលា អំណោយទាន និងធនធានរបស់អ្នក ដើម្បីជួយសហគមន៍របស់អ្នកដូចម្តេចខ្លះ?

ឱព្រះវរបិតា ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានត្រាស់ហៅទូលបង្គំ ឲ្យធ្វើជាភ្នាក់ងារនៃព្រះពររបស់ព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យចេះបម្រើសហគមន៍របស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសេគាល ២០-២១ និងយ៉ាកុប ៥:១

ដោយហេតុនោះបានជាត្រូវឲ្យអ្នករាល់គ្នា បន្ថែមឲ្យមានសេចក្តីឧស្សាហ៍ដែរ ដើម្បីឲ្យសេចក្តីជំនឿបានទៀងត្រង់ (២ពេត្រុស ១:៥)។

ចរិតលក្ខណៈដែលត្រូវផ្លាស់ប្តូរ

លោក ដូមីនិក បូស៍ (Dominique Bouhours) ជាគ្រូបង្រៀនវេយ្យាករណ៍នៅសតវត្សរ៍ទី១៧។ នៅថ្ងៃគាត់លាចាកលោក ក្រុមគ្រួសារបានជួបជុំគ្នានៅជុំវិញគាត់ ដែលកំពុងគេងនៅលើគ្រែ។ គេឮល្បីថា មុនពេលគាត់ផុតដង្ហើម គាត់បាននិយាយពាក្យចុងក្រោយថា «ឃ្លា ខ្ញុំជិតស្លាប់ហើយ និងឃ្លា ខ្ញុំនឹងស្លាប់ក្នុងពេលដ៏ខ្លីខាងមុខ សុទ្ធតែត្រូវតាមវេយ្យាករណ៍ដូចគ្នា»។ តើមាននរណាខ្វល់អំពីវេយ្យាករណ៍ នៅពេលដែលខ្លួនហៀបនឹងផុតដង្ហើមនៅលើគ្រែ? គឺមានតែអ្នកដែលខ្វល់អំពីវេយ្យាករណ៍ពេញមួយជីវិតទេ ដែលមានការផ្តោតចិត្តយ៉ាងដូចនេះ។

នៅពេលដែលយើងឈានដល់វ័យចាស់ យើងពិបាកលះបង់ទម្លាប់ចាស់របស់យើង។ ការសម្រេចចិត្តជាច្រើនដែលយើងមានពេញមួយជីវិត ប្រែក្លាយជាទម្លាប់ក្នុងការរស់នៅ ហើយទម្លាប់នោះបង្កើតឲ្យមានចរិតលក្ខណៈល្អ ឬអាក្រក់ ក្នុងជីវិតយើង។ អត្តសញ្ញាណរបស់យើង ដែលបង្ហាញថា យើងជានរណា មានការផ្លាស់ប្តូរ ដោយសារការសម្រេចចិត្តរបស់យើងនោះឯង។

ការបង្កើតទម្លាប់ដែលគោរពប្រតិបត្តិព្រះមានភាពងាយស្រួលជាង នៅពេលដែលចរិតលក្ខណៈរបស់យើងនៅក្មេងខ្ចី ហើយងាយបត់បែន។ ហេតុនេះហើយសាវ័ក ពេត្រុស បានជំរុញយើងថា «ហើយដោយហេតុនោះបានជាត្រូវឲ្យអ្នករាល់គ្នា បន្ថែមឲ្យមានសេចក្តីឧស្សាហ៍ដែរ ដើម្បីឲ្យសេចក្តីជំនឿបានទៀងត្រង់ ឲ្យសេចក្តីទៀងត្រង់បានជំរិះ ឲ្យជំរិះបានចេះអត់សង្កត់ ឲ្យសេចក្តីអត់សង្កត់បានខ្ជាប់ខ្ជួន ឲ្យសេចក្តីខ្ជាប់ខ្ជួនបានចេះគោរពប្រតិបត្តិដល់ព្រះ ឲ្យសេចក្តីគោរពប្រតិបត្តិបានចេះរាប់អានគ្នាជាបងប្អូន ហើយឲ្យសេចក្តីរាប់អានគ្នាបានសេចក្តីស្រឡាញ់ថែមទៀត» (២ពេត្រុស ១:៥-៧)។ ចូរយើងអនុវត្តតាមព្រះបន្ទូល ដើម្បីឲ្យមានចរិតលក្ខណៈល្អៗទាំងអស់នេះ ហើយយើងនឹង «ចូលទៅក្នុងនគរដ៏នៅអស់កល្បជានិច្ច របស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ ហើយជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា» (ខ.១១)។

តាមការបង្រៀនរបស់សាវ័ក ពេត្រុស តើអ្នកមានចរិតលក្ខណៈមួយណា ដែលមានភាពរស់រវើកខ្លាំងជាងគេ? តើមានចរិតលក្ខណៈមួយណា ដែលអ្នកចាំបាច់ត្រូវកែលម្អក្នុងជីវិតអ្នក? ដែលយើងបានក្លាយជាមនុស្សប្រភេទណាមួយហើយ គឺយើងមិនអាចកែប្រែបានទេ គឺមានតែព្រះយេស៊ូវទេដែលអាចកែប្រែយើងបាន។ ចូរទូលសូមព្រះអង្គឲ្យកែប្រែ និងចម្រើនកម្លាំងអ្នក។ ការផ្លាស់ប្រែនេះអាចកើតមានបន្តិចម្តងៗ និងមានការពិបាក ប៉ុន្តែព្រះយេស៊ូវមានជំនាញ ក្នុងការផ្គត់ផ្គង់នូវចំណុចអ្វីដែលយើងខ្វះខាត។ ចូរទូលសូមព្រះអង្គ ឲ្យកែប្រែចរិតលក្ខណៈរបស់អ្នក ដើម្បីឲ្យអ្នកបានផ្លាស់ប្រែ មានចរិតលក្ខណៈកាន់តែដូចព្រះអង្គ។—Mike Wittmer

តើមានចរិតលក្ខណៈណាមួយ ដែលអ្នកចាំបាច់ត្រូវកែប្រែខ្លាំងជាងគេ? តើអ្នកអាចស្វែងរកព្រះចេស្តា និងការផ្គត់ផ្គង់ ហើយចាប់ផ្តើមមានការផ្លាស់ប្រែដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គធ្វើឲ្យទូលបង្គំមានលក្ខណៈកាន់តែដូចព្រះអង្គ ដើម្បីឲ្យអ្នកដទៃបានឃើញព្រះអង្គច្បាស់ ក្នុងជីវិតទូលបង្គំ។

គម្រោងអានព្រះគម្ពីរឆ្នាំ១ឆ្នាំ | អេសេគាល ២២-២៣ និង១ពេត្រុស ១

ចូរនាំគ្នាចូលតាមទ្វារទ្រង់ ដោយពោលពាក្យអរព្រះគុណ ហើយចូលទៅក្នុងទីលានទ្រង់ ដោយបទសរសើរ ចូរអរព្រះគុណដល់ទ្រង់ ហើយសរសើរព្រះនាមទ្រង់ចុះ (ទំនុកតម្កើង ១០០:៤)។

អរព្រះគុណព្រះអង្គ ក្នុងពេលមានទុក្ខលំបាក

ខ្ញុំ បានយកចិត្តទុកដាក់ និងអធិស្ឋានឲ្យមិត្តរួមអាជីពជាអ្នកនិពន្ធម្នាក់ ដែលបានបង្ហោះសារក្នុងបណ្តាញសង្គមដែលនិយាយអំពីការធ្វើដំណើររបស់គាត់ឆ្លងកាត់ជំងឺមហារីក។ ពេលខ្លះ គាត់បានចែកចាយអំពីការឈឺចាប់ផ្លូវកាយ និងបញ្ហាប្រឈមដែលគាត់បានជួប ដោយសារជំងឺដ៏កាចសាហាវនេះ ហើយពេលខ្លះទៀតគាត់ក៏បានចែកចាយសំណូមពរអធិស្ឋាន អមដោយខគម្ពីរលើកទឹកចិត្ត និងការសរសើរតម្កើងព្រះ។ ខ្ញុំទទួលបានការលើកទឹកចិត្ត នៅពេលដែលបានឃើញគាត់មានទឹកមុខញញឹម ដោយចិត្តក្លាហាន ទោះគាត់កំពុងរង់ចាំការព្យាបាលនៅមន្ទីរពេទ្យ ឬកំពុងនៅផ្ទះ ដោយមានក្បាលរុំកន្សែង ដោយសារសក់គាត់បានជ្រុះអស់។ ទោះគាត់ជួបបញ្ហាប្រឈមយ៉ាងណាក៏ដោយ ក៏គាត់មិនដែលភ្លេចលើកទឹកចិត្តអ្នកដទៃ ឲ្យទុកចិត្តព្រះអង្គ ក្នុងអំឡុងពេលដែលពួកគេមានទុក្ខលំបាក។

ពេលណាយើងឆ្លងកាត់ទុក្ខលំបាក យើងប្រហែលពិបាកស្វែងរកហេតុផល ដើម្បីអរព្រះគុណ និងសរសើរតម្កើងព្រះ។ ទោះជាយ៉ាងណាក៏ដោយ បទគម្ពីរទំនុកតម្កើង ជំពូក១០០ បានផ្តល់ឲ្យយើងនូវហេតុផល ដែលត្រូវអរសប្បាយ ហើយថ្វាយការសរសើរដល់ព្រះអង្គ ទោះយើងស្ថិតក្នុងកាល:ទេស:ណាក៏ដោយ។ គឺដូចដែលអ្នកនិពន្ធបទគម្ពីរទំនុកតម្កើងបានបន្លឺសម្លេងថា «ត្រូវឲ្យដឹងថា ព្រះយេហូវ៉ាទ្រង់ជាព្រះ គឺទ្រង់ដែលបានបង្កើតយើងខ្ញុំ យើងខ្ញុំជារបស់ផងទ្រង់ យើងខ្ញុំជារាស្ត្ររបស់ទ្រង់ ហើយជាហ្វូងចៀម នៅទីគង្វាលរបស់ទ្រង់» (ខ.៣)។ គាត់ក៏បានបន្ថែមទៀតថា «ពីព្រោះព្រះយេហូវ៉ាទ្រង់ល្អ សេចក្តីសប្បុរសនៃទ្រង់ស្ថិតស្ថេរនៅជានិច្ច ហើយសេចក្តីស្មោះត្រង់របស់ទ្រង់ ក៏នៅអស់ទាំងដំណមនុស្សតទៅ» (ខ.៥)។

ទោះយើងជួបទុក្ខលំបាកអ្វីក៏ដោយ យើងអាចមានការកម្សាន្តចិត្ត ដោយដឹងថា ព្រះអង្គតែងតែគង់នៅក្បែរចិត្តដែលខ្ទេចខ្ទាំរបស់យើង (៣៤:១៨)។ កាលណាយើងចំណាយពេលកាន់តែច្រើនជាមួយព្រះអង្គក្នុងការអធិស្ឋាន និងអានព្រះគម្ពីរ យើងក៏កាន់តែងាយស្រួល «ចូលតាមទ្វារទ្រង់ ដោយពោលពាក្យអរព្រះគុណ ហើយចូលទៅក្នុងទីលានទ្រង់ ដោយបទសរសើរ» (១០០:៤)។ យើងអាច «ឡើងសម្លេងដោយអំណរថ្វាយព្រះអម្ចាស់» (ខ.១) សូម្បីតែនៅពេលដែលយើងកំពុងរស់នៅក្នុងរដូវកាលដ៏ពិបាក ព្រោះព្រះនៃយើងមានព្រះទ័យស្មោះត្រង់។—Nancy Gavilanes

តើអ្នកចង់អរព្រះគុណព្រះអង្គ សម្រាប់ការអ្វីខ្លះ? តើអ្នកសរសើរតម្កើងព្រះអង្គ សម្រាប់រឿងអ្វីខ្លះនៅពេលនេះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យសរសើរតម្កើងព្រះអង្គ សូម្បីតែក្នុងពេលដែលទូលបង្គំមានទុក្ខលំបាក។

Daily Manna 2026_Content Enhance.indd 335 17/11/25 1:47 in the afternoon

តែទ្រង់មានព្រះបន្ទូលឆ្លើយថា ចូរអ្នករាល់គ្នាឲ្យគេបរិភោគទៅ (ម៉ាកុស ៦:៣៧)។

ការធ្វើការជាដៃគូជាមួយព្រះ

កាលមិត្តភក្តិខ្ញុំ និងស្វាមីរបស់គាត់មិនអាចមានផ្ទៃពោះ វេជ្ជបណ្ឌិតក៏បានណែនាំគាត់ ឲ្យទទួលការព្យាបាលបែបវេជ្ជសាស្ត្រ ដើម្បីឲ្យអាចមានកូន។ មិត្តភក្តិខ្ញុំមានការស្ទាក់ស្ទើរ។ គាត់បានសួរខ្លួនឯងថា «តើការអធិស្ឋានមិនមានអំណាចគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហារបស់យើងទេឬ?» «តើខ្ញុំពិតជាចាំបាច់ត្រូវទទួលការព្យាបាលបែបវេជ្ជសាស្ត្រនេះមែនទេ?» មិត្តភក្តិរបស់ខ្ញុំកំពុងព្យាយាមស្វែងយល់អំពីរបៀបដែលព្រះអម្ចាស់ អាចធ្វើការ តាមរយៈការងាររបស់មនុស្ស។

រឿងព្រះយេស៊ូវប្រទានអាហារដល់ហ្វូងមនុស្ស អាចជួយបកស្រាយចម្ងល់នេះបាន (ម៉ាកុស ៦:៣៥-៤៤)។ យើងប្រហែលបានដឹងថា រឿងនេះបានបញ្ចប់យ៉ាងដូចម្តេច គឺដោយសារមនុស្សរាប់ពាន់នាក់បានទទួលអាហារដោយការអស្ចារ្យ ដែលព្រះយេស៊ូវបានធ្វើ ដោយប្រើនំបុ័ង និងត្រីតែបន្តិចបន្តួច (ខ.៤២)។ ប៉ុន្តែ ចូរយើងកត់សម្គាល់ថា តើនរណាជាអ្នកចែកអាហារដល់ហ្វូងមនុស្ស? គឺពួកសាវ័ក (ខ.៣៧)។ ចុះក្រោយមកទៀត? គឺពួកសាវ័កដដែល (ខ.៣៩-៤៣)។ គឺដូចដែលព្រះយេស៊ូវបង្គាប់ពួកគេថា «ចូរអ្នករាល់គ្នាឲ្យគេបរិភោគទៅ» (ខ.៣៧)។ ព្រះយេស៊ូវបានធ្វើការអស្ចារ្យ ប៉ុន្តែការអស្ចារ្យនោះកើតឡើង នៅពេលដែលពួកសាវ័កធ្វើតាមបង្គាប់ព្រះអង្គ។

ភោគផលល្អ គឺជាអំណោយមកព្រះ (ទំនុកតម្កើង ៦៥:៩-១០) ប៉ុន្តែកសិករត្រូវតែធ្វើការដាំដុះ។ ព្រះយេស៊ូវបានសន្យាលោកពេត្រុសថា គាត់នឹងចាប់ត្រីបានច្រើន តែអ្នកនេសាទរូបនេះ ត្រូវតែទម្លាក់សំណាញ់ចូលទៅក្នុងទឹក (លូកា ៥:៤-៦)។ ព្រះអម្ចាស់អាចថែរក្សាភពផែនដី និងធ្វើការអស្ចារ្យ ដោយគ្មានយើងក៏បាន តែព្រះអង្គបានសម្រេចព្រះទ័យធ្វើការជាដៃគូជាមួយមនុស្សជាតិ។

មិត្តភក្តិរបស់ខ្ញុំក៏បានឆ្លងកាត់ការព្យាបាលនោះ ហើយក្រោយមក ពួកគេអាចមានកូនដោយជោគជ័យ។ យើងប្រហែលមិនចាត់ទុកការព្យាបាលនេះជាការអស្ចារ្យទេ តែរឿងនេះបានផ្តល់ឲ្យនូវមេរៀនដ៏សំខាន់សម្រាប់ខ្ញុំ និងមិត្តភក្តិរបស់ខ្ញុំ។ ព្រះអម្ចាស់ច្រើនតែធ្វើការអស្ចារ្យ តាមរយៈវិធីសាស្ត្រដែលព្រះអង្គបានដាក់នៅក្នុងដៃរបស់យើង។—Sheridan Voysey

តើអ្នកមានចិត្តចង់អធិស្ឋាន ដោយមិនធ្វើអ្វីសោះ នៅពេលណាខ្លះ? តើព្រះអម្ចាស់កំពុងត្រាស់ហៅអ្នកឲ្យធ្វើកិច្ចការអ្វី នៅពេលនេះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានរាប់បញ្ចូលទូលបង្គំ ឲ្យមានចំណែកនៅក្នុងកិច្ចការដ៏អស្ចារ្យរបស់ព្រះអង្គ។ សូមព្រះអង្គប្រើអ្វីដែលទូលបង្គំមានក្នុងដៃទូលបង្គំ ហើយធ្វើការអស្ចារ្យតាមរយៈទូលបង្គំ។

Daily Manna 2026_Content Enhance.indd 336 17/11/25 1:47 in the afternoon

ព្រះទ្រង់ជាពន្លឺភ្លឺ គ្មានសេចក្តីងងឹតណា នៅក្នុងទ្រង់សោះ (១យ៉ូហាន ១:៥)។

ពន្លឺរបស់ព្រះគ្រីស្ទភ្លឺចែងចាំង

កាលភ្លើងបានដាច់ នៅតាមដងផ្លូវ ក្នុងទីក្រុងហាយលែនផាក រដ្ឋមីឈីហ្គិន ប្រជាជនក៏បានកើតមានចិត្តចង់ប្រើអគ្គិសនី ចេញពីប្រភពថាមពលមួយទៀត គឺព្រះអាទិត្យ។ ទីក្រុងនេះខ្វះថវិកា ដើម្បីបង់ប្រាក់ឲ្យក្រុមហ៊ុនអគ្គិសនី។ ក្រុមហ៊ុនអគ្គិសនីក៏បានបិទភ្លើងនៅតាមផ្លូវ ហើយក៏បានដោះអំពូលភ្លើង ចេញពីបង្គោលភ្លើង១៤០០ដើម។ ការនេះបានបណ្តាលឲ្យប្រជាពលរដ្ឋមានអារម្មណ៍ថា មិនមានសុវត្ថិភាពនៅក្នុងពេលងងឹត នៅពេលយប់។ មានពលរដ្ឋម្នាក់បានប្រាប់អ្នកយកព័ត៌មានថា សព្វថ្ងៃនេះ «នៅពេលទៀបភ្លឺ មានក្មេងៗពីរបីនាក់ដើរតាមផ្លូវទៅរៀន នៅពេលដែលមេឃនៅងងឹតនៅឡើយ។ គ្មានភ្លើងអគ្គិសនីបំភ្លឺផ្លូវទេ ដូចនេះពួកគេត្រូវដើរទៅរៀន ដោយការប្រថុយប្រថាន»។

រឿងនេះមានការផ្លាស់ប្តូរ នៅពេលដែលក្រុមការងារមួយ ដែលមិនរកប្រាក់ចំណេញ ត្រូវបានគេបង្កើតឡើង ដើម្បីដំឡើងភ្លើងបំភ្លឺផ្លូវ ក្នុងទីក្រុងនេះ។ អង្គការមនុស្សធម៌មួយនេះបានរួបរួមគ្នា ដើម្បីជួយទីក្រុងនេះកាត់បន្ថយចំណាយ ទៅលើការបង់ថ្លៃភ្លើង ខណៈពេលដែលពួកគេអាចប្រើប្រភពភ្លើងអគ្គិសនី ដែលជួយបំពេញតម្រូវការរបស់ប្រជាជន។

ក្នុងការរស់នៅរបស់យើងក្នុងព្រះគ្រីស្ទ ព្រះអង្គជាព្រះរាជបុត្រានៃព្រះ និងប្រភពនៃពន្លឺ។ គឺដូចដែលកណ្ឌគម្ពីរយ៉ូហានបានចែងថា «ព្រះទ្រង់ជាពន្លឺភ្លឺ គ្មានសេចក្តីងងឹតណានៅក្នុងទ្រង់សោះ» (១យ៉ូហាន ១:៥)។ កណ្ឌគម្ពីរយ៉ូហានក៏បានកត់សម្គាល់ផងដែរថា «តែបើយើងរាល់គ្នាដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្តីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នា ពីគ្រប់អំពើបាបទាំងអស់» (ខ.៧)។

ព្រះយេស៊ូវក៏បានប្រកាសដោយផ្ទាល់ថា «ខ្ញុំជាពន្លឺលោកីយ៍ អ្នកណាដែលតាមខ្ញុំ នោះមិនដែលដើរក្នុងសេចក្តីងងឹតឡើយ គឺនឹងមានពន្លឺនៃជីវិតវិញ» (យ៉ូហាន ៨:១២)។ ដោយសារព្រះវិញ្ញាណបរិសុទ្ធដឹកនាំយើងគ្រប់ជំហាន យើងមិនចាំបាច់ត្រូវដើរក្នុងភាពងងឹតឡើយ។ ពន្លឺរបស់ព្រះអង្គតែងតែភ្លឺចែងចាំងជានិច្ច ទោះយើងស្ថិតនៅកន្លែងណាក៏ដោយ។—Patricia Raybon

តើអ្នកបានដកពិសោធន៍នឹងពន្លឺរបស់ព្រះយេស៊ូវក្នុងជីវិតអ្នក ដូចម្តេចខ្លះ? នៅថ្ងៃនេះ តើអ្នកអាចថ្លែងប្រាប់នរណាខ្លះអំពីព្រះអង្គ?

ឱព្រះអម្ចាស់ សូមពន្លឺព្រះអង្គភ្លឺចែងចាំង គ្រប់ជ្រុងទាំងអស់ក្នុងជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 337 17/11/25 1:47 in the afternoon

តើមានអ្នកណាជាព្រះឲ្យដូចទ្រង់ ដែលទ្រង់អត់ទោសចំពោះអំពើទុច្ចរិត...? (មីកា ៧:១៨)

ការឆ្លើយតបចំពោះការអត់ទោសរបស់ព្រះអង្គ

ថ្ងៃក្នុងទិវាអរព្រះគុណព្រះ ជាថ្ងៃបុណ្យជាតិរបស់អាមេរិក ប្រធានាធិបតីអាមេរិកតែងតែស្វាគមន៍សត្វមាន់ទើគីពីរក្បាល ចូលទៅក្នុងសេតវិមាន មុនពេលពួកវាទទួលការលើកលែងទោសពីប្រធានាធិបតី។ គេមិនយកពួកវាទៅសម្លាប់ធ្វើម្ហូប សម្រាប់បរិភោគជាប្រពៃណី ក្នុងទិវាអរព្រះគុណព្រះ ដូចសត្វមាន់ទើគីដទៃទៀតទេ តែផ្ទុយទៅវិញ ពួកវាបានរស់នៅដោយសុវត្ថិភាពអស់មួយជីវិត ក្នុងកសិដ្ឋានមួយ។ ទោះសត្វមាន់ទើគីមិនអាចយល់អត្ថន័យនៃសេរីភាព ដែលគេបានផ្តល់ឲ្យពួកវាក៏ដោយ ក៏ប្រពៃណីប្រចាំឆ្នាំដ៏ចម្លែកនេះ បានឆ្លុះបញ្ចាំងអំពីអំណាចនៃការអត់ឱនទោស ដែលផ្តល់ឲ្យនូវជីវិតដល់មនុស្ស។

ហោរា មីកា បានយល់អំពីសារៈសំខាន់នៃការអត់ទោស កាលគាត់ថ្លែងទៅកាន់ប្រជាជននៅទីក្រុងយេរូសាឡិម ដោយការព្រមានធ្ងន់ៗ មកពីព្រះអម្ចាស់។ ការពិពណ៌នារបស់គាត់ មានទម្រង់ស្រដៀងនឹងពាក្យបណ្តឹងតាមផ្លូវច្បាប់ ដោយគាត់បានកត់ត្រាអំពីការដែលព្រះអម្ចាស់បានធ្វើបន្ទាល់ ទាស់នឹងប្រជាជាតិមួយនេះ (មីកា ១:២) ដោយសារពួកគេចូលចិត្តធ្វើការអាក្រក់ មានភាពលោភលន់ មិនស្មោះត្រង់ ហើយមានហិង្សា (៦:១០-១៥)។

ទោះពួកគេបានបះបោរប្រឆាំងព្រះអង្គយ៉ាងដូចនេះក៏ដោយ ក៏នៅចុងបញ្ចប់ ហោរា មីកា ក៏បានថ្លែងអំពីសេចក្តីសង្ឃឹម ដែលបានចាក់ឫសក្នុងព្រះបន្ទូលដែលបានសន្យាថា ព្រះអង្គមិនមានសេចក្តីក្រោធចំពោះពួកគេជារៀងរហូតទេ តែផ្ទុយទៅវិញ ព្រះអង្គសព្វព្រះទ័យនឹងអត់ទោសឲ្យបាបរបស់ពួកគេវិញ (៧:១៨)។ ក្នុងនាមព្រះអង្គជាព្រះអាទិករ និងចៅក្រមមកលើមនុស្សទាំងអស់ ព្រះអង្គប្រកាសដោយអំណាចថា ព្រះអង្គនឹងមិនប្រកាន់ទោសយើងជារៀងរហូតទេ គឺដោយសារព្រះបន្ទូលសន្យាដែលព្រះអង្គមានចំពោះលោក អ័ប្រាហាំ (ខ.២០) ដែលបានសម្រេចក្នុងការសុគត និងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គ។

ព្រះអង្គបានលើកលែងទោសឲ្យយើង ដែលមិនអាចប្រព្រឹត្តតាមក្រឹត្យវិន័យរបស់ព្រះអង្គមួយរយភាគរយ។ នេះជាអំណោយដែលយើងមិនសមនឹងទទួល ហើយក៏ជាព្រះពរដ៏លើសលប់។ ខណៈពេលដែលយើងបានយល់កាន់តែស៊ីជម្រៅ អំពីអត្ថប្រយោជន៍នៃការអត់ទោសទាំងស្រុងរបស់ព្រះអង្គ ចូរយើងឆ្លើយតបចំពោះព្រះអង្គ ដោយការសរសើរតម្កើង និងការអរព្រះគុណ។—Lisa M. Samra

តើការអត់ទោសដែលព្រះបានប្រទាន មានអត្ថប្រយោជន៍អ្វីខ្លះចំពោះយើង? តើការនេះបានបណ្តាលចិត្តអ្នកឲ្យអរព្រះគុណព្រះអង្គ ដូចម្តេចខ្លះ?

ឱព្រះវរបិតាជាព្រះមានសេចក្តីមេត្តា សូមព្រះអង្គជួយទូលបង្គំ ឲ្យរស់នៅដោយការអរព្រះគុណ ដោយសារការអត់ទោស ដែលព្រះអង្គបានប្រទានទូលបង្គំ។

Daily Manna 2026_Content Enhance.indd 338 17/11/25 1:47 in the afternoon

តែខ្ញុំចង់ទូលដល់ព្រះដ៏មានគ្រប់ព្រះចេស្តាវិញ ខ្ញុំប៉ងនឹងតតបនឹងព្រះតែម្តង (យ៉ូប ១៣:៣)។

ការតវ៉ានឹងព្រះអម្ចាស់

ប្រុសម្នាក់បានទៅខែតុលាការ ដើម្បីដាក់ពាក្យបណ្តឹងទាស់នឹងព្រះ។ គាត់បានអះអាងថា ព្រះទ្រង់ «គ្មានសេចក្តីមេត្តា» ចំពោះគាត់ ហើយព្រះអង្គមាន «អាកប្បកិរិយាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរ»។ ចៅក្រមក៏បានបដិសេធន៍មិនទទួលពាក្យបណ្តឹងមួយនេះ ដោយនិយាយថា បុរសនោះមិនត្រូវការជំនួយផ្នែកច្បាប់ទេ តែគាត់ត្រូវការជំនួយពីពេទ្យផ្លូវចិត្ត។ នេះជារឿងពិត ដែលគួរឲ្យអស់សំណើច តែក៏គួរឲ្យសោកស្តាយផងដែរ។

ប៉ុន្តែ តើយើងមានគំនិតខុសពីគាត់ទេ? នៅពេលខ្លះ តើយើងចង់និយាយទៅកាន់ព្រះអម្ចាស់ដែរឬទេថា «ព្រះអង្គអើយ ប៉ុណ្ណឹងបានហើយ ទូលបង្គំលំបាកគ្រប់គ្រាន់ហើយ!» តើលោក យ៉ូប បានធ្វើដូចនេះទេ? ជាក់ស្តែង គាត់បានតវ៉ានឹងព្រះអង្គ។ បន្ទាប់ពីគាត់បានស៊ូទ្រាំនឹងសោកនាដកម្មដែលមិនអាចពិពណ៌នាបាន គាត់ក៏បាននិយាយថា គាត់ចង់តវ៉ានឹងព្រះអម្ចាស់ (យ៉ូប ១៣:៣)។ ចូរយើងស្រមៃ អំពីការតវ៉ានឹងព្រះអង្គនៅក្នុងខែតុលាការ (៩:៣)។ គាត់ថែមទាំងបានទូលសូមព្រះអង្គថា «សូមទ្រង់ដកព្រះហស្តឲ្យឆ្ងាយពីទូលបង្គំចេញ ហើយសូមកុំឲ្យសេចក្តីស្ញែងខ្លាចរបស់ទ្រង់ មកបំភ័យទូលបង្គំទៀត» (១៣:២១)។ គាត់បានតវ៉ានឹងព្រះអង្គមិនមែនដោយសារភាពស្អាតស្អំរបស់គាត់ទេ ប៉ុន្តែដោយសារគាត់ចង់ចោទសួរអំពីអារម្មណ៍របស់ព្រះអម្ចាស់ នៅក្នុងការទម្លាក់សេចក្តីវេទនាមកលើគាត់។ គឺដូចដែលគាត់បានសួរព្រះអង្គថា «ដែលសង្កត់សង្កិនដូច្នេះ តើមានប្រយោជន៍ដល់ទ្រង់ឬ?» (១០:៣)

ជួនកាល យើងមានអារម្មណ៍ថា ព្រះអង្គប្រព្រឹត្តចំពោះយើង ដោយអយុត្តិធម៌ ឬមិនសមហេតុផលៗ តាមពិត រឿងរបស់លោកយ៉ូបមានភាពស្មុគស្មាញ គឺមិនបានផ្តល់ចម្លើយដែលយើងងាយស្រួលយល់ទេ។ នៅចុងបញ្ចប់ ព្រះអង្គបានប្រទានពរខាងរូបកាយ ដល់លោក យ៉ូប ឡើងវិញ តែព្រះអង្គមិនមានផែនការដូចនេះសម្រាប់មនុស្សទាំងអស់ទេ។ ទោះជាយ៉ាងណាក៏ដោយ ចូរយើងទទួលស្គាល់ការពិត គឺដូចដែលលោកយ៉ូបបានសារភាពថា «គឺទូលបង្គំនេះឯងបានពោលពាក្យដែលទូលបង្គំមិនបានយល់ ជាសេចក្តីដែលអស្ចារ្យហួសល្បត់ទូលបង្គំដែលទូលបង្គំមិនបានស្គាល់ឡើយ» (៤២:៣)។ ចំណុចសំខាន់នៃរឿងនេះគឺ ព្រះអម្ចាស់មានហេតុផលដែលយើងមិនដឹង ហើយយើងអាចមានក្តីសង្ឃឹមដ៏អស្ចារ្យនៅក្នុងផែនការរបស់ព្រះអង្គ។—Kenneth Petersen

តើនៅពេលណាខ្លះ អ្នកចង់វិនិច្ឆ័យមកលើព្រះអម្ចាស់? ហេតុអ្វីអ្នកអាចទូលសូរសំណូរពិបាកៗ ដល់ព្រះអង្គ?

ឱព្រះអម្ចាស់ ពេលខ្លះទូលបង្គំមានអារម្មណ៍ខឹង ចំពោះអ្វីដែលព្រះអង្គបានឲ្យទូលបង្គំស៊ូទ្រាំ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យទូលថ្វាយអំពីទុក្ខលំបាកទាំងអស់ដល់ព្រះអង្គ ដោយមិនរអ៊ូរទាំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសេគាល ៣៥-៣៦ និង២ពេត្រុស ១

លោកលុតជង្គង់ចុះអធិស្ឋាន ហើយអរព្រះគុណដល់ព្រះរបស់លោក១ថ្ងៃ៣ដង ដូចជាកាលពីមុន (ដានីយ៉ែល ៦:១០)។

ការឆ្លើយតប ដោយការដឹងគុណ

លោក ធីម៉ូថេ (Timothy) ជានាវិកជនជាតិអូស្ត្រាលី ដែលបានរស់ដោយសារសាច់ត្រីឆៅ និងទឹកភ្លៀងតែម្នាក់ឯង អស់រយៈពេល៣ខែ។ ទូកក្តោងរបស់គាត់បានខូចដោយសារខ្យល់ព្យុះ ហើយបានសាត់អណ្តែតក្នុងមហាសមុទ្រប៉ាស៊ីហ្វិក ចម្ងាយជិត២ពាន់គីឡូម៉ែត្រពីឆ្នេរសមុទ្រ។ ប៉ុន្តែ ក្រោយមកពួកនាវិកនៅលើទូកនេសាទរបស់ជនជាតិមិចស៊ិកូ ដែលកំពុងនេសាទត្រីធូណា បានប្រទះឃើញទូកក្តោងរបស់គាត់ដែលបានខូចនោះ ហើយក៏ជួយសង្គ្រោះគាត់។ ក្រោយមក បុរសស្គមស្គាំង និងទ្រាមខ្លួនដោយសារអាកាសធាតុដ៏កាចសាហាវ ក៏បានប្រកាសថា «ខ្ញុំពិតជាចង់ថ្លែងអំណរគុណក្រៃលែង ចំពោះកាពីទែនរបស់ទូកនេសាទ និងក្រុមហ៊ុននេសាទ ដែលបានសង្គ្រោះជីវិតខ្ញុំ»។

លោក ធីម៉ូថេ បានថ្លែងអំណរគុណ បន្ទាប់ពីគាត់បានឆ្លងកាត់ទុក្ខវេទនានៅកណ្តាលមហាសមុទ្រ ប៉ុន្តែ ហោរា ដានីយ៉ែល បានបង្ហាញចេញនូវចិត្តដែលដឹងគុណព្រះអម្ចាស់នៅមុនពេល នៅក្នុងពេល និងនៅក្រោយពេលដែលគាត់ជួបរឿងវិបត្តិ។ គាត់ត្រូវគេនិរទេស ទៅទីក្រុងបាប៊ីឡូនពីនគរយូដា ជាមួយពូជអំបូរយូដាដទៃទៀត (ដានីយ៉ែល ១:១-៦)។ ប៉ុន្តែ ក្រោយមក គាត់ក៏បានឡើងកាន់មុខតំណែងធំ ដែលធ្វើឲ្យពួកនាម៉ឺនដទៃទៀតច្រណែនឈ្នានីស ហើយចង់ឲ្យគេសម្លាប់គាត់ (៦:១-៧)។ ពួកសត្រូវរបស់គាត់ ក៏បានទៅគាល់អធិរាជនៃចក្រភពបាប៊ីឡូន ដើម្បីសូមឲ្យទ្រង់ចេញច្បាប់ ដែលចែងថា នរណាក៏ដោយដែលអធិស្ឋានទៅកព្រះណាមួយ នឹងត្រូវគេកាត់ទោស ដោយបោះចូលទៅក្នុងរូងសឹង (ខ.៧)។ នៅពេលនោះ តើលោក ដានីយ៉ែល ជាមនុស្សដែលស្រឡាញ់នឹងបម្រើព្រះពិតតែមួយ បានឆ្លើយតបដូចម្តេច? គឺគាត់បាន លុតជង្គង់ចុះអធិស្ឋាន អរព្រះគុណដល់ព្រះរបស់គាត់១ថ្ងៃ៣ដង ដូចជាកាលពីមុន (ខ.១០)។ គាត់បានទូលថ្វាយការអរព្រះគុណដល់ព្រះ ហើយព្រះអម្ចាស់ក៏បានប្រទានពរគាត់ ដោយសារគាត់មានចិត្តដែលដឹងគុណព្រះអង្គ ដោយព្រះអង្គបានសង្គ្រោះជីវិតគាត់ ហើយក៏បានលើកគាត់ឲ្យមានកិត្តិស័ព្ទ (ខ.២៦-២៨)។

សូមព្រះអម្ចាស់ជួយយើងអរព្រះគុណព្រះអង្គ «គ្រប់កាលៈទេសៈ» (១ថែស្សាឡូនិច ៥:១៨)។ ទោះយើងកំពុងប្រឈមមុខដាក់រឿងវិបត្តិ ឬទើបតែបានឆ្លងកាត់ហើយក្តី ការឆ្លើយតប ដោយការដឹងគុណ គឺជាការថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ ហើយជួយឲ្យសេចក្តីជំនឿយើងនៅតែមានភាពជាប់លាប់។—Tom Felten

ហេតុអ្វីយើងចាំបាច់ត្រូវអរព្រះគុណព្រះជាទៀងទាត់? តើធ្វើដូចម្តេចឲ្យអ្នកមានចិត្តដែលដឹងគុណព្រះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំ ឲ្យអរព្រះគុណព្រះអង្គ ជាពិសេសនៅពេលដែលជីវិតមានការពិបាក។

Daily Manna 2026_Content Enhance.indd 340 17/11/25 1:47 in the afternoon

ដូច្នេះ ចូរឲ្យពន្លឺរបស់អ្នករាល់គ្នាបានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឲ្យគេឃើញការល្អ ដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរតម្កើង ដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌ (ម៉ាថាយ ៥:១៦)។

មានកេរ្តិ៍ឈ្មោះល្អថ្វាយព្រះគ្រីស្ទ

កាលលោក ចន ឆាលី វ៉ដ (Charlie Ward) រៀននៅសកលវិទ្យាល័យរដ្ឋផ្លរីដា គាត់គឺជាកីឡាករពីរប្រភេទប្រចាំសាលា។ នៅឆ្នាំ១៩៩៣ ខ្សែប្រយុទ្ធវ័យក្មេងរូបនេះទទួលបានពានរង្វាន់ ហេសមែន សម្រាប់កីឡាករបាល់ទាត់មហាវិទ្យាល័យអាមេរិកដែលល្អជាងគេ ហើយគាត់ក៏ជាតារាបាល់បោះដ៏ឆ្នើមក្នុងក្រុមរបស់គាត់ផងដែរ។

ថ្ងៃមួយ នៅក្នុងការជជែកគ្នាមុនពេលការប្រកួត គ្រូបង្វឹករបស់គាត់បានប្រើភាសាអសុរោះ ទៅកាន់ក្រុមរបស់គាត់។ គ្រូបង្វឹករូបនោះក៏បានកត់សម្គាល់ឃើញថា ឆាលី មានទឹកមុខមិនស្រួល ហើយក៏បានសួរគាត់ថា «ឆាលី មានរឿងអី?» ឆាលី ក៏បានប្រាប់គាត់ថា «លោកគ្រូដឹងទេ លោកគ្រូ បូឌិន (Bowden) ជាគ្រូបង្វឹករបស់ក្រុមកីឡាករបាល់ទាត់ មិនបានប្រើភាសាប្រភេទនេះទេ តែគាត់អាចលើកទឹកចិត្តយើងឲ្យប្រឹងប្រែងប្រកួតអត់ពីសមត្ថភាព»។

ដោយសារ ឆាលី មានចរិតលក្ខណៈដូចព្រះយេស៊ូវ នោះគាត់អាចនិយាយដោយសុភាពទៅកាន់គ្រូបង្វឹករូបនោះ អំពីបញ្ហានេះ។ តាមពិត ក្រោយមកគ្រូបង្វឹកនោះក៏បានប្រាប់អ្នកយកព័ត៌មានថា គាត់មានអារម្មណ៍ហាក់ដូចជាមានទេវតាមួយអង្គ មើលទៅគាត់ពេលគាត់កំពុងជជែកជាមួយ ឆាលី។

ការបន្តមានកេរ្តិ៍ឈ្មោះល្អ ក្នុងចំណោមអ្នកមិនជឿព្រះ និងការធ្វើបន្ទាល់ដ៏ស្មោះត្រង់ថ្វាយព្រះគ្រីស្ទ មិនមែនជាការងាយទេ។ ប៉ុន្តែ ទន្ទឹមនឹងនោះអ្នកជឿព្រះយេស៊ូវអាចរីកលូតលាស់ ឲ្យមានលក្ខណៈសម្បត្តិកាន់តែដូចព្រះអង្គ ខណៈពេលដែលព្រះអង្គដឹកនាំយើង។ កណ្ឌគម្ពីរទីតុសជំពូក២ បានបង្រៀនយុវជន ក៏ដូចជាអ្នកជឿទាំងអស់ ឲ្យ «មានចិត្តធ្ងន់» (ខ.៦) ហើយ «សំដែងខ្លួន ទុកជាគំរូពីការល្អគ្រប់ជំពូក ទាំងបង្រៀនគេ កុំឲ្យគេប្រព្រឹត្តខុច អាក្រក់ឡើយ តែឲ្យមានចិត្តនឹងធឹងវិញ ព្រមទាំងពាក្យសំដីត្រឹមត្រូវ ដែលរកចាប់ទោសមិនបានផង» (ខ.៧-៨)។

ពេលណាយើងរស់នៅយ៉ាងដូចនេះ ដោយកម្លាំងពីព្រះគ្រីស្ទ យើងមិនគ្រាន់តែបានថ្វាយព្រះកិត្តិនាមដល់ព្រះអង្គប៉ុណ្ណោះទេ តែក៏ធ្វើឲ្យគេចង់ស្វែងយល់អំពីព្រះអង្គផងដែរ។ ហើយខណៈពេលដែលព្រះអម្ចាស់ប្រទានប្រាជ្ញាដែលយើងត្រូវការអ្នកដទៃនឹងមានហេតុផល ដែលត្រូវបើកចិត្តស្តាប់យើងធ្វើបន្ទាល់ពីព្រះយេស៊ូវ។—Dave Branon

តើការមានកេរ្តិ៍ឈ្មោះល្អបានជួយអ្នកឲ្យមានឥទ្ធិពលមកលើអ្នកដទៃដូចម្តេចខ្លះ? តើធ្វើដូចម្តេចឲ្យអ្នកអាចមានចរិតលក្ខណៈដូចព្រះគ្រីស្ទ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំ ឲ្យចម្រើនឡើង ដោយមានចរិតលក្ខណៈ ដែលនាំឲ្យគេស្គាល់ព្រះអង្គ ហើយថ្វាយព្រះកិត្តិនាមដល់ព្រះអង្គ។

គម្រោងអានព្រះគម្ពីរប្រចាំឆ្នាំ | អេសេគាល ៤០-៤១ និង២ពេត្រុស ៣

គាត់មានសេចក្តីអំណរ ក៏ទូន្មានគេគ្រប់គ្នា ឲ្យសំរេចចិត្តនឹងនៅជាប់ក្នុងព្រះអម្ចាស់ (កិច្ចការ ១១:២៣)។

មនុស្សដែលលើកទឹកចិត្ត

កាលលោក ចន ចេ អរ អរ ថូលគិន (J. R. R. Tolkien) បានទទួល «ការលើកទឹកចិត្តដ៏លើសលប់» ពីលោក ចន ស៊ីអេស លូអីស (C. S. Lewis) ជាមិត្តសំឡាញ់ និងមិត្តរួមការងារ ខណៈពេលដែលគាត់និពន្ធសៀវភៅរឿងប្រលោមលោកដ៏ល្បីល្បាញមានចំណងជើងថា ម្ចាស់ចិញ្ចៀន។ លោក ចន ថូលគិន បាននិពន្ធសៀវភៅរឿងភាគនេះ ដោយការប្រឹងប្រែង និងអត់ធ្មត់យ៉ាងខ្លាំង ហើយគាត់ជាអ្នកវាយអត្ថបទដ៏វែងដោយផ្ទាល់ដៃ មិនតិចជាង២ដងទេ។ នៅពេលដែលគាត់ផ្ញើអត្ថបទដែលគាត់បានវាយនោះទៅលោក ចន លូអីស លោក ចន លូអីស ក៏បានឆ្លើយតបថា «រយៈពេលជាច្រើនឆ្នាំ ដែលលោកបាននិពន្ធសៀវភៅរឿងនេះ គឺពិតជាមានតម្លៃណាស់»។

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី លោក ចន យ៉ូសែប មកពីកោះគីប្រុសប្រហែលមានឈ្មោះល្បីបំផុត ជាអ្នកលើកទឹកចិត្ត ហើយក្រោយមក ពួកសាវ័កក៏បានដាក់ឈ្មោះឲ្យគាត់ថា បាណាបាស (មានន័យថា «កូននៃការលើកទឹកចិត្ត» កិច្ចការ ៤:៣៦)។ លោក ចន បាណាបាស ក៏ជាអ្នកនាំពួកសាវ័កឲ្យទទួលស្គាល់សាវ័ក ប៉ុល ផងដែរ (៩:២៧)។ ក្រោយមក បន្ទាប់សាសន៍ដទៃជាច្រើនបានទទួលជឿព្រះគ្រីស្ទ «គាត់ក៏មានសេចក្តីអំណរ ក៏ទូន្មានគេគ្រប់គ្នា ឲ្យសំរេចចិត្តនឹងនៅជាប់ក្នុងព្រះអម្ចាស់» (១១:២៣)។ លោក ចន លូកា បានពិពណ៌នាថា «គាត់ជាមនុស្សល្អ ពេញជាព្រះវិញ្ញាណបរិសុទ្ធ និងសេចក្តីជំនឿ ហើយមានមនុស្សសន្ធឹកណាស់ បានចំរើនដល់ព្រះអម្ចាស់» (ខ.២៤)។

ពាក្យលើកទឹកចិត្តពិតជាមានតម្លៃណាស់ យើងមិនអាចវាស់បានទេ។ ខណៈពេលដែលយើងចែកចាយអំពីសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ដល់អ្នកដទៃ ព្រះដែលបានប្រទាន «ការលើកទឹកចិត្តដ៏អស់កល្ប» (២ថែស្សាឡូនិច ២:១៦) អាចធ្វើការក្នុងចិត្តអ្នកដទៃ តាមរយៈការអ្វីដែលយើងចែកចាយនោះ ដើម្បីកែប្រែជីវិតរបស់ពួកគេជារៀងរហូត។ សូមព្រះអង្គជួយយើងផ្តល់ឲ្យអ្នកដទៃនូវការ «លើកទឹកចិត្តដ៏លើសលប់» នៅថ្ងៃនេះ!—James Banks

តើអ្នកចង់លើកទឹកចិត្តនរណាខ្លះ? តើអ្នកអាចចែកចាយអំពីសេចក្តីស្រឡាញ់របស់ព្រះដល់ពួកគេតាមរយៈពាក្យសម្តី ឬការប្រព្រឹត្តដ៏សប្បុរស យ៉ាងដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យលើកទឹកចិត្តអ្នកដទៃនៅថ្ងៃនេះ ទោះតាមមធ្យោបាយណាក៏ដោយ។

Daily Manna 2026_Content Enhance.indd 342 17/11/25 1:47 in the afternoon

ឱព្រះយេហូវ៉ាអើយ ទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង (ទំនុកតម្កើង ១៣៩:១)។

ព្រះស្គាល់ខ្ញុំច្បាស់

កាលប្អូនស្រីរបស់ខ្ញុំរកឃើញសៀវភៅរឿងមួយក្បាល ដែលយើងធ្លាប់អានកាលពីក្មេង ម្តាយរបស់ខ្ញុំមានចិត្តរីករាយណាស់។ សព្វថ្ងៃនេះ គាត់ស្ថិតក្នុងវ័យ៧០ឆ្នាំហើយ។ គាត់នៅចាំជាលម្អិតអំពីរឿងសត្វខ្លាឃ្មុំ ដែលបានលួចសំណុំទឹកឃ្មុំ ហើយត្រូវសត្វឃ្មុំទាំងហ្វូងដេញទិចវា ទាំងកំហឹង។ គាត់ក៏បានចាំថា ខ្ញុំ និងប្អូនស្រីខ្ញុំបានអស់សំណើច នៅពេលដែលយើងរំពឹងថា សត្វខ្លាឃ្មុំនោះនឹងរត់គេច។ ខ្ញុំក៏បានប្រាប់ម្តាយខ្ញុំថា «កូនអរគុណម៉ាក់ ដែលបាននិទានរឿងឲ្យកូនៗស្តាប់ កាលពីក្មេង»។ គាត់បានដឹងអំពីរឿងរបស់ខ្ញុំទាំងស្រុង ដែលរាប់បញ្ចូលទាំងលក្ខណៈសម្បត្តិរបស់ខ្ញុំ កាលខ្ញុំនៅក្មេង។ សព្វថ្ងៃនេះ ខ្ញុំជាមនុស្សពេញវ័យហើយ តែគាត់នៅតែដឹង ហើយយល់ចិត្តខ្ញុំ។

ព្រះអម្ចាស់ក៏ស្គាល់យើងដែរ ហើយគ្មានមនុស្សណាម្នាក់ស្គាល់យើងច្បាស់ជាងព្រះអង្គឡើយ សូម្បីតែយើងក៏មិនស្គាល់ខ្លួនឯងច្បាស់ជាងព្រះអង្គដែរ។ ស្តេច ដាវីឌ មានបន្ទូលថា «ឱព្រះយេហូវ៉ាអើយ ទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង» (ទំនុកតម្កើង ១៣៩:១)។ ព្រះអង្គបានពិនិត្យមើល និងយល់អំពីយើងគ្មានកន្លែងចន្លោះ ដោយសេចក្តីស្រឡាញ់។ ព្រះអង្គជ្រាបអំពីគំនិតយើង ដោយយល់អំពីហេតុផល នៅពីក្រោយពាក្យសម្តី និងអត្ថន័យនៃពាក្យសម្តីដែលយើងបាននិយាយ (ខ.២, ៤)។ ព្រះអង្គជ្រាបជាលម្អិតថា យើងជានរណា ហេតុនេះហើយព្រះអង្គអាចជួយយើងបាន (ខ.២-៥)។ គ្មាននរណាស្គាល់យើងច្បាស់ជាងព្រះអង្គស្គាល់យើងឡើយ តែព្រះអង្គមិនបានបណ្តេញយើងដោយសេចក្តីសម្អប់ តែបានឈោងមករកយើង ដោយសេចក្តីស្រឡាញ់ និងប្រាជ្ញារបស់ព្រះអង្គ។

ពេលណាយើងមានអារម្មណ៍ឯកោ គេមើលរំលងយើង ឬភ្លេចយើង យើងអាចមានទំនុកចិត្ត ផ្អែកទៅលើសេចក្តីពិតដែលថា ព្រះអង្គតែងតែគង់នៅក្បែរយើង ទតឃើញយើង និងជ្រាបអំពីយើងជានិច្ច (ខ.៧-១០)។ ព្រះអង្គជ្រាបអំពីយើងគ្រប់ជ្រុងជ្រោយ ដែលអ្នកដទៃមិនអាចដឹងបាន។ បានជាយើងអាចបន្លឺសម្លេងឡើង ដោយទំនុកចិត្តដូចស្តេចដាវីឌថា «ឱព្រះយេហូវ៉ាអើយ ទ្រង់បានពិនិត្យមើល ហើយបានស្គាល់ទូលបង្គំផង... គង់តែព្រះហស្តទ្រង់នឹងនាំទូលបង្គំនៅទីនោះ ហើយព្រះហស្តស្តាំទ្រង់នឹងក្តាប់ទូលបង្គំដែរ» (ខ.១, ១០)។—Karen Huang

តើអ្នកទទួលបានការលើកទឹកចិត្តប៉ុណ្ណា ពីព្រះដែលមានប្រាជ្ញា និងសេចក្តីស្រឡាញ់ ដែលស្គាល់អ្នកយ៉ាងច្បាស់? តើអ្នកអាចចែកចាយអំពីព្រះវត្តមាននៃសេចក្តីស្រឡាញ់របស់ព្រះអង្គ ដល់អ្នកដទៃដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ព្រះអង្គស្គាល់ទូលបង្គំច្បាស់ ហើយគ្មានឧទាហរណ៍ណាស្គាល់ទូលបង្គំច្បាស់ដូចព្រះអង្គទេ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គខ្ជាំងណាស់ ដែលបានដាក់ព្រះហស្តនៅលើជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 343 17/11/25 1:47 in the afternoon

ដ្បិតព្រះដ៏ជាជីវិត ទ្រង់បានលេចមកហើយ យើងខ្ញុំបានឃើញទ្រង់ ក៏ធ្វើជាទីបន្ទាល់ប្រាប់ដល់អ្នករាល់គ្នាពីជីវិតនោះ (១យ៉ូហាន ១:២)។

ព្រះដ៏ជាជីវិតបានលេចមកហើយ

កាលពីឆ្នាំ១៩៨៦ គ្រោះមហន្តរាយរបស់រោងចក្រអគ្គិសនីនុយក្លេអ៊ែរ នៅទីក្រុងឆឺណូប៊ីល ប្រទេសអ៊ុយក្រែន បានទទួលការចាប់អារម្មណ៍នៅទូទាំងពិភពលោក។ បន្ទាប់ពីគេបានដឹងច្បាស់អំពីភាពធ្ងន់ធ្ងរនៃគ្រោះមហន្តរាយនេះ អាជ្ញាធរក្នុងតំបន់បានប្រមូលផ្តុំគ្នាធ្វើកិច្ចការដ៏សំខាន់មួយ ដើម្បីទប់ស្កាត់ការឥតការណាលដាលនៃជាតិវិទ្យុសកម្ម។ កាំរស្មីហ្គាម៉ាដែលអាចគ្រោះថ្នាក់ដល់ជីវិតមនុស្ស បានសាយភាយចេញពីសំណល់បាក់បែកដែលមានជាតិវិទ្យុសកម្មខ្ពស់ បានបន្តបំផ្លាញរ៉ូបូត ដែលគេបានបញ្ជា ឲ្យចូលទៅសម្អាតតំបន់រោងចក្រអគ្គិសនីនុយក្លេអ៊ែរនោះ។

ដូចនេះ ពួកគេត្រូវប្រើមនុស្សឲ្យចូលសម្អាត ដោយបំពាក់ឧបករណ៍ការពារវិទ្យុសកម្ម។ មានអ្នកស្ម័គ្រចិត្តដ៏ក្លាហានរាប់ពាន់នាក់បានក្លាយជា “អ្នកបោសសម្អាត នៅទីក្រុងឆឺណូប៊ីល” ដោយបានប្រមូលវត្ថុដែលមានជាតិវិទ្យុសកម្ម ដោយម្នាក់ៗអាចចំណាយពេលក្នុងតំបន់នោះ បានយ៉ាងច្រើន៩០វិនាទីប៉ុណ្ណោះ នៅក្នុងវេននីមួយៗ។ ដូចនេះ មនុស្សបានធ្វើនូវកិច្ចការដែលបច្ចេកវិទ្យាមិនអាចធ្វើបាន ដោយការប្រឈមនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរបំផុត។

តាំងពីយូរមកហើយ ការបះបោររបស់មនុស្សជាតិទាស់នឹងព្រះ បាននាំមកនូវគ្រោះមហន្តរាយ ដែលរីករាលដាលបង្កើតជាគ្រោះមហន្តរាយគ្រប់យ៉ាង (មើលលោកុប្បត្តិ ៣)។ តាមរយៈលោក ចន អ័ដាម និងនាង អេវ៉ា មនុស្សជាតិបានជ្រើសរើសយកការបែកផ្លូវចេញពីព្រះអាទិករបស់ខ្លួន ហើយយើងបានធ្វើឲ្យពិភពលោកមានពេញដោយភាពរញ៉េរញ៉ៃគ្មានសណ្តាប់ធ្នាប់ ដែលយើងមិនអាចសម្អាតឲ្យមានរបៀបរៀបរយឡើងវិញ ដោយខ្លួនឯងបានទេ។

នេះជាមូលហេតុដែលព្រះយេស៊ូវបានយាងមកចាប់កំណើតជាមនុស្សនៅថ្ងៃណូអែលមុនបង្អស់។ សាវ័ក យ៉ូហាន បានពិពណ៌នាអំពីព្រះយេស៊ូវយ៉ាងដូចនេះថា “ដ្បិតព្រះដ៏ជាជីវិត ទ្រង់បានលេចមកហើយ យើងខ្ញុំបានឃើញទ្រង់ ក៏ធ្វើជាទីបន្ទាល់ ប្រាប់ដល់អ្នករាល់គ្នា ពីជីវិតនោះដ៏រស់នៅអស់កល្បជានិច្ចដែលពីដើមស្ថិតនៅនឹងព្រះវរបិតា ហើយបានលេចមកឲ្យយើងខ្ញុំឃើញ” (១យ៉ូហាន ១:២)។ បន្ទាប់មក លោក ចន យ៉ូហាន ក៏បានប្រកាសថា “ព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សំអាតយើងរាល់គ្នាពីគ្រប់អំពើបាបទាំងអស់” (ខ.៧)។

ព្រះយេស៊ូវបានប្រទានអ្វី ដែលមនុស្សជាស្នាព្រះហស្តរបស់ព្រះអង្គមិនអាចផ្តល់ឲ្យបាន។ ពេលណាយើងទទួលជឿព្រះអង្គ ព្រះអង្គស្អាងយើងឲ្យមានទំនាក់ទំនងដ៏ត្រឹមត្រូវជាមួយព្រះវរបិតា។ ព្រះអង្គបានលាងសម្អាតបាបរបស់យើង នៅលើឈើឆ្កាង ហើយក៏បានឈ្នះសេចក្តីស្លាប់ហើយ។ ព្រះអង្គជាជីវិត ដែលបានលេចមកដល់យើងរាល់គ្នាហើយ។—Tim Gustafson

តើអ្នកបានព្យាយាមសម្អាតភាពរញ៉េរញ៉ៃរបស់អ្នក ដោយរបៀបណា? តើអ្នកអាចថ្វាយទុក្ខលំបាករបស់អ្នកដល់ព្រះយេស៊ូវនៅថ្ងៃនេះ ដោយរបៀបណា?

ឱព្រះដែលមានព្រះជន្មរស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានចាត់ព្រះរាជបុត្រា ឲ្យយាងចុះមកក្នុងលោកីយ៍នេះ ដើម្បីលាងសម្អាតបាបរបស់យើងខ្ញុំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | អេសេគាល ៤៧-៤៨ និង១យ៉ូហាន ៣

ឱព្រះវរបិតាអើយ បើសិនជាទ្រង់សព្វព្រះហឫទ័យ នោះសូមយកពែងនេះចេញពីទូលបង្គំទៅ ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ (លូកា ២២:៤២)។

ការអធិស្ឋានសូមព្រះទ័យព្រះអង្គបានសម្រេច

កាលខ្ញុំទើបទទួលជឿព្រះយេស៊ូវ មានពេលមួយខ្ញុំបានបើកមើលព្រះគម្ពីរសម្រាប់សិក្សាប្រចាំថ្ងៃ ហើយក៏បានអានចំខគម្ពីរដែលខ្ញុំធ្លាប់បានឮកាលពីមុនមកថា «ចូរសូម នោះតែងនឹងឲ្យមកអ្នក» (ម៉ាថាយ ៧:៧)។ អត្ថបទពន្យល់ ក្នុងព្រះគម្ពីរនោះបានបកស្រាយថា អ្វីដែលយើងពិតជាគួរតែទូលសូមព្រះ គឺត្រូវសូមឲ្យចិត្តរបស់យើង មានភាពសមស្របនឹងបំណងព្រះទ័យព្រះអង្គ។ ពេលណាយើងព្យាយាមទូលសូមតាមបំណងព្រះទ័យព្រះអង្គ យើងអាចទុកចិត្តថា យើងនឹងទទួលបានអ្វីដែលយើងបានទូលសូមនោះ។ កាលនោះ ការបង្រៀននេះហាក់ដូចជាថ្មីសម្រាប់ខ្ញុំ ហើយខ្ញុំក៏បានអធិស្ឋានសូមបំណងព្រះទ័យព្រះបានសម្រេចក្នុងជីវិតខ្ញុំ។

ក្រោយមក នៅថ្ងៃដដែលនោះខ្ញុំមានចិត្តរំភើបដោយការភ្ញាក់ផ្អើល ចំពោះឱកាសការងារមួយ ដែលខ្ញុំបានបដិសេធនៅក្នុងគំនិតខ្ញុំរួចទៅហើយ ហើយខ្ញុំក៏បាននឹកចាំអំពីការអធិស្ឋានរបស់ខ្ញុំ។ អ្វីដែលខ្ញុំមិនបានគិតថាខ្ញុំចង់បាន តាមពិតវាប្រហែលជាផ្នែកមួយនៃបំណងព្រះទ័យដែលព្រះទ្រង់មានសម្រាប់ជីវិតខ្ញុំ។ ដូចនេះ ខ្ញុំក៏បានបន្តអធិស្ឋាន ហើយទីបំផុតក៏បានទទួលយកការងារនោះ។

រឿងនេះបានធ្វើឲ្យខ្ញុំនឹកចាំ អំពីពេលដែលព្រះយេស៊ូវបានធ្វើជាគំរូ សម្រាប់យើងនៅក្នុងពេលដែលសំខាន់ជាង ដ៏អស់កល្បជានិច្ច។ មុនពេលគេក្បត់ព្រះអង្គ ហើយព្រះអង្គត្រូវគេចាប់ខ្លួន ហើយយកទៅឆ្កាង ព្រះអង្គបានអធិស្ឋានថា «ឱព្រះវរបិតាអើយ បើសិនជាទ្រង់សព្វព្រះហឫទ័យ នោះសូមយកពែងនេះចេញពីទូលបង្គំទៅ ប៉ុន្តែកុំតាមចិត្តទូលបង្គំឡើយ សូមតាមតែព្រះហឫទ័យទ្រង់វិញ» (លូកា ២២:៤១)។ ការអធិស្ឋានរបស់ព្រះគ្រីស្ទមានពេញទៅដោយភាពតានតឹងយ៉ាងខ្លាំង ខណៈពេលដែលព្រះអង្គប្រឈមមុខដាក់ការឈឺចាប់ខាងផ្លូវកាយ និងផ្លូវអារម្មណ៍ (ខ.៤៤)។ តែព្រះអង្គនៅតែអាចអធិស្ឋានអស់ពីព្រះហឫទ័យថា សូមបំណងព្រះទ័យព្រះវរបិតាបានសម្រេច។

ការអធិស្ឋានសូមបំណងព្រះទ័យព្រះអង្គបានសម្រេចក្នុងជីវិតខ្ញុំ បានក្លាយជាការអធិស្ឋានសំខាន់បំផុតរបស់ខ្ញុំ។ បានសេចក្តីថា ខ្ញុំប្រហែលជាចង់បានអ្វីដែលខ្ញុំមិនដឹងថា ខ្លួនឯងពិតជាចង់បាន ឬត្រូវការ។ ការងារដែលខ្ញុំមិនចង់បានពីដំបូង បានក្លាយជាការចាប់ផ្តើមនៃការធ្វើដំណើររបស់ខ្ញុំ ក្នុងការងារបោះពុម្ពផ្សាយសៀវភៅគ្រីស្ទបរិស័ទ។ ពេលខ្ញុំក្រឡេកមកក្រោយវិញ ខ្ញុំជឿថា បំណងព្រះទ័យព្រះសម្រាប់ជីវិតខ្ញុំបានសម្រេចនៅក្នុងរឿងមួយនេះហើយ។—Katara Patton

តើអ្នកមានអ្វីនៅក្នុងចិត្ត ដែលអ្នកចង់អធិស្ឋាន? តើអ្នកជឿថា ព្រះអម្ចាស់កំពុងត្រាស់ហៅអ្នកឲ្យធ្វើកិច្ចការអ្វី?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ សូមព្រះអង្គដឹកនាំទូលបង្គំ ឲ្យធ្វើតាមបំណងព្រះទ័យព្រះអង្គ។

Daily Manna 2026_Content Enhance.indd 345 17/11/25 1:47 in the afternoon

ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បានធ្វើដល់យើងដែរ (ម៉ាថាយ ២៥:៤០)។

អត្ថន័យនៃបុណ្យណូអែល

ក្នុងពិធីញ៉ាំអាហារពេលល្ងាច សម្រាប់ថ្ងៃណូអែលនៅព្រះវិហាររបស់ខ្ញុំនៅឆ្នាំមួយនោះ មានការអបអរវប្បធម៌របស់ភ្ញៀវមកពីក្រៅប្រទេស។ ខ្ញុំបានទះដៃដោយអំណរតាមចង្វាក់ភ្លេងស្គរដាប៊ូកា និងសម្លេងចាប៉ី ខណៈពេលដែលក្រុមតន្ត្រីមកពីតំបន់មជ្ឈិមបូព៌ា បានច្រៀងបទណូអែលជាភាសារបស់ពួកគេមានចំណងជើងថា «ឡាយឡាត អាល មីឡាដ»។ អ្នកចម្រៀងប្រចាំក្រុមនេះបានពន្យល់ថា ចំណងជើងនេះមានន័យថា «យប់ដែលព្រះយេស៊ូវប្រសូត្រ»។ ទំនុកច្រៀងរបស់បទនេះបានរំឭកអ្នកស្តាប់ទាំងឡាយថា អត្ថន័យនៃបុណ្យណូអែល គឺមាននៅក្នុងការបម្រើអ្នកដទៃ តាមរបៀបផ្សេងៗ ដែលមានដូចជា ការឲ្យទឹកដល់អ្នកស្រេកទឹក ឬការកម្សាន្តចិត្តដល់អ្នកសោកសង្រេង។

បទចម្រៀងណូអែលមួយនេះទំនងជាបានដកស្រង់ចេញពីរឿងប្រៀបប្រដូច ដែលក្នុងនោះព្រះយេស៊ូវបានមានបន្ទូលសរសើរអ្នកដើរតាមព្រះអង្គ ដោយសារកិច្ចការដែលពួកគេបានធ្វើថ្វាយព្រះអង្គ ដូចជាការថ្វាយអាហារដល់អ្នកដែលស្រេកឃ្លាន ថ្វាយទឹកដល់អ្នកដែលស្រេកទឹក ហើយនៅកំដរ និងថែរក្សាអ្នកជំងឺ និងមនុស្សឯកោជាដើម (ម៉ាថាយ ២៥:៣៤-៣៦)។ ក្នុងរឿងប្រៀបប្រដូចនេះ ពួកគេមានការភ្ញាក់ផ្អើល ពេលដែលបានដឹងថាពួកគេបានធ្វើកិច្ចការទាំងអស់នេះថ្វាយព្រះយេស៊ូវ ដោយមិនដឹងខ្លួន។ ព្រះអង្គក៏បានឆ្លើយតបថា «យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បានធ្វើដល់យើងដែរ» (ខ.៤០)។

ក្នុងអំឡុងរដូវកាលនៃពិធីបុណ្យណូអែល ការលើកទឹកចិត្តឲ្យមានការជ្រួតជ្រាប ក្នុងពិធីបុណ្យណូអែលច្រើនតែជាការលើកទឹកចិត្តឲ្យមានអាកប្បកិរិយាដែលសមស្រប នឹងអត្ថន័យនៃពិធីបុណ្យណូអែល។ បទចម្រៀងអំពីយប់ដែលព្រះយេស៊ូវប្រសូត្រ គឺបានរំឭកយើងថា យើងអាចអនុវត្តតាមអត្ថន័យពិតប្រាកដនៃពិធីបុណ្យណូអែល ឲ្យយកចិត្តទុកដាក់ចំពោះអ្នកដទៃ។ ហើយអ្វីដែលអស្ចារ្យនោះគឺ ពេលណាយើងអនុវត្តតាមហើយ យើងមិនគ្រាន់តែបម្រើអ្នកដទៃ តែក៏បម្រើព្រះយេស៊ូវផងដែរ។—Lisa M. Samra

តើអ្នកបានយល់អត្ថន័យនៃបុណ្យណូអែលទេ? តើអ្នកនឹងបម្រើអ្នកដទៃ ក្នុងរដូវកាលនៃបុណ្យណូអែលដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំ ឲ្យនឹកចាំអំពីអត្ថន័យនៃថ្ងៃណូអែល ដែលព្រះអង្គបានធ្វើជាគំរូ ដោយបានយាងចុះមកផែនដីមិនមែនដើម្បីឲ្យគេបម្រើ តែដើម្បីបម្រើគេវិញ។

Daily Manna 2026_Content Enhance.indd 346 17/11/25 1:47 in the afternoon

រីឯព្រះទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឲ្យកើតមានសេចក្តីល្បួងហួសកំឡាំងអ្នករាល់គ្នាឡើយ (១កូរិនថូស ១០:១៣)។

នៅពេលដែលមានការល្បួង និងការល្បួងល

លោក ចន ស្ទែនលី (Stanley) មានចិត្តរីករាយ ចំពោះសេរីភាព និងភាពអាចបត់បែនបាន ដែលគាត់ទទួលបានពីការងារ ជាអ្នកបើកឡានតាក់ស៊ី។ គាត់អាចចាប់ផ្តើម និងឈប់សម្រាកនៅពេលណាក៏បាន ហើយគាត់មិនចាំបាច់ត្រូវរាយការណ៍ប្រាប់អំពីពេលវេលា និងការងាររបស់គាត់ ដល់នរណាម្នាក់ឡើយ។ តែគាត់ថា នេះជាផ្នែកដែលពិបាកបំផុត។

គាត់បានទទួលស្គាល់ដោយត្រង់ៗថា «ការងារនេះ បានផ្តល់ឱកាសឲ្យគាត់ងាយចាប់ផ្តើមទំនាក់ទំនងផិតក្បាត់»។ គាត់ថា «មានមនុស្សគ្រប់ប្រភេទដែលបានឡើងជិះឡានតាក់ស៊ីរបស់ខ្ញុំ តែគ្មាននរណាម្នាក់ដឹងថា ខ្ញុំកំពុងតែនៅកន្លែងណាទេ។ សូម្បីតែប្រពន្ធខ្ញុំក៏មិនដឹងដែរ»។ គាត់ក៏បានពន្យល់ថា វាមិនមែនជាការល្បួងដែលគាត់អាចជម្នះដោយងាយៗឡើយ ហើយមិត្តរួមអាជីពរបស់គាត់ជាច្រើនបានធ្លាក់ចូលការល្បួងនេះ។ គាត់ថា «ខ្ញុំមិនបានប្រព្រឹត្តខុសដូចពួកគេ ដោយសារខ្ញុំបានគិតថា ព្រះអម្ចាស់នឹងគិតយ៉ាងណាចំពោះខ្ញុំ ហើយភរិយាខ្ញុំនឹងមានអារម្មណ៍យ៉ាងណា នៅពេលដែលខ្ញុំប្រព្រឹត្តដូចពួកគេ»។

ព្រះដែលបានបង្កើតយើងម្នាក់ៗមកបានជ្រាបអំពីភាពកម្សោយ បំណងចិត្ត ហើយជ្រាបថា យើងងាយចាញ់ការល្បួងប៉ុណ្ណា។ ប៉ុន្តែ យើងអាចទូលសូមជំនួយពីព្រះអង្គ គឺដូចដែលកណ្ឌគម្ពីរ ១កូរិនថូស ១០:១១-១៣ បានរំឭកយើង។ សាវ័ក ប៉ុល បានបង្រៀនយើងថា «ព្រះទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឲ្យកើតមានសេចក្តីល្បួងហួសកំឡាំងអ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន» (ខ.១៣)។ «ផ្លូវសម្រាប់ចៀសរួច» នោះ អាចជាការកំយ៉ាខ្លាចដ៏សមហេតុផល ចំពោះផលវិបាក ការដឹងថាវាជាអ្វីដែលព្រះបានហាម ការនឹកចាំខគម្ពីរ ការបង្វែរអារម្មណ៍ទៅរកអ្វីដែលត្រឹមត្រូវ។ល។ ពេលណាយើងទូលសូមកម្លាំងពីព្រះអង្គ ព្រះវិញ្ញាណព្រះអង្គនឹងបង្វែរភ្នែកយើង ឲ្យងាកចេញពីការអ្វីដែលកំពុងល្បួងយើង ហើយជួយយើងឲ្យមើលទៅរកច្រកចេញ ដែលព្រះអង្គបានប្រទានយើង។—Leslie Koh

តើអ្នកកំពុងជួបការល្បួងអ្វី នៅថ្ងៃនេះ? តើមានច្រកចេញអ្វី ដែលព្រះបានប្រទានអ្នក ដើម្បីនាំអ្នកដើរតាមផ្លូវត្រឹមត្រូវនិងបរិសុទ្ធរបស់ព្រះអង្គ?

ឱព្រះវរបិតា ព្រះអង្គស្គាល់ភាពកម្សោយរបស់ទូលបង្គំ។ សូមព្រះអង្គប្រទានទូលបង្គំនូវកម្លាំង ដើម្បីជម្នះការល្បួង ហើយដើរជាមួយព្រះអង្គតាមផ្លូវដ៏បរិសុទ្ធ និងនាំមកនូវជីវិត។

Daily Manna 2026_Content Enhance.indd 347 17/11/25 1:47 in the afternoon

ចូរអ្នករាល់គ្នាប្រែចិត្តចុះ ហើយទទួលបុណ្យជ្រមុជទឹកទាំងអស់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ប្រយោជន៍ឲ្យបានរួចពីបាប (កិច្ចការ ២:៣៨)។

ជីវិតថ្មីក្នុងព្រះយេស៊ូវ

លោក ចន បាហ៊ិ (Baheer) និងលោក ចន មេឌែត (Medet) បានចម្រើនវ័យធំឡើង ក្នុងតំបន់អាស៊ីកណ្តាល ហើយក៏បានក្លាយជាមិត្តជិតស្និទ្ធបំផុត។ ប៉ុន្តែ នៅពេលដែលលោក ចន បាហ៊ិ ក្លាយជាអ្នកជឿព្រះយេស៊ូវ អ្វីៗមានការផ្លាស់ប្តូរ។ បន្ទាប់ពីលោក ចន មេឌែត បានរាយការណ៍ទៅរដ្ឋាភិបាលឲ្យចាប់ខ្លួនលោក ចន បាហ៊ិ គាត់បានទទួលរងទារុណកម្មយ៉ាងឈឺចាប់បំផុត។ អ្នកយាមគុកបានស្រែកគំរាមគាត់ ឲ្យបិទមាត់ឈប់និយាយអំពីព្រះនាមព្រះយេស៊ូវទៀត។ ទោះលោក ចន បាហ៊ិ បានប្រឡាក់ឈាមពេញខ្លួនខ្លាំងយ៉ាងណាក៏ដោយ ក៏គាត់នៅតែអាចនិយាយថា ពួកគេអាចបំបិទសិទ្ធិគាត់មិនឲ្យនិយាយអំពីព្រះគ្រីស្ទតែពួកគេមិនអាចកែប្រែការអ្វីដែលព្រះអង្គបានធ្វើនៅក្នុងចិត្តគាត់បានទេ។

ពាក្យសម្តីទាំងនោះនៅតែដក់ជាប់ក្នុងចិត្តរបស់លោក ចន មេឌែត។ ប៉ុន្មានខែក្រោយមក បន្ទាប់ពីគាត់មានជំងឺ និងជួបការបាត់បង់ គាត់ក៏បានធ្វើដំណើរស្វែងរកលោក ចន បាហ៊ិ ដែលគេបានដោះលែងចេញពីគុក។ គាត់បានងាកបែរចេញពីអំនួតរបស់គាត់ ហើយក៏បានសុំឲ្យលោក ចន បាហ៊ិ ជាអតីតមិត្តភក្តិម្នាក់ចែកចាយអំពីព្រះយេស៊ូវ ឲ្យគាត់បានស្គាល់ព្រះអង្គ។

លោក ចន មេឌែត បានធ្វើតាមការបណ្តាលចិត្តពីព្រះវិញ្ញាណបរិសុទ្ធ ដូចពួកអ្នកដែលបានជួបជុំគ្នា នៅជុំវិញសាវ័ក ពេត្រុស នៅថ្ងៃបុណ្យទី៥០ ដែលមាន «ការចាក់ចុចនៅក្នុងចិត្ត» ពេលដែលពួកគេបានដកពិសោធន៍ជាមួយព្រះវត្តមាននៃការចាក់បង្ហូរព្រះគុណរបស់ព្រះ ហើយបានឮសាវ័ក ពេត្រុស ធ្វើបន្ទាល់អំពីព្រះគ្រីស្ទ (កិច្ចការ ២:៣៧)។ សាវ័ក ពេត្រុស ក៏បានអំពាវនាវពួកគេឲ្យប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក ដោយនូវព្រះនាមព្រះយេស៊ូវ ហើយមនុស្សប្រហែល៣ពាន់នាក់បានប្រែចិត្តទទួលជឿព្រះនៅពេលនោះ។ គឺដូចដែលពួកគេបានលះចោលផ្លូវនៃជីវិតចាស់ជាយ៉ាងណា នោះលោក ចន មេឌែត ក៏បានប្រែចិត្ត និងដើរតាមព្រះអង្គសង្គ្រោះផងដែរ។

អំណោយនៃជីវិតថ្មីក្នុងព្រះយេស៊ូវមានសម្រាប់មនុស្សម្នាក់ៗ ដែលជឿព្រះអង្គ។ ទោះយើងបានធ្វើអ្វីក៏ដោយ យើងអាចទទួលការអត់ទោសបាប ដោយអំណរ ពេលណាយើងទទួលជឿព្រះអង្គ។—Amy Boucher Pye

តើអ្នកគិតថា លោក ចន បាហ៊ិ មានអារម្មណ៍យ៉ាងណា ពេលដែលលោក ចន ម៉ាដេឌ សុំឲ្យគាត់ចែកចាយអំពីព្រះយេស៊ូវ ឲ្យគាត់បានស្គាល់ព្រះអង្គ? តើទំនាក់ទំនងជាមួយព្រះអង្គ ជួយយើងក្នុងពេលមានទុក្ខលំបាកដូចម្តេចខ្លះ?

ឱព្រះយេស៊ូវដែលជួយសង្គ្រោះ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានសុគតនៅលើឈើឆ្កាង ហើយប្រទានជីវិតថ្មី។ ទូលបង្គំសូមជឿព្រះអង្គអស់ពីចិត្ត។

Daily Manna 2026_Content Enhance.indd 348 17/11/25 1:47 in the afternoon

កាលណាឯងដើរកាត់ទឹកធំ នោះអញនឹងនៅជាមួយ (អេសាយ ៤៣:២)។

ទទួលការលើកទឹកចិត្តពីព្រះបន្ទូលសន្យា

ឃ្យ រជនក្មេងខ្លីវ័យ១៩ឆ្នាំ បានចំណាយពេលពេញមួយថ្ងៃនៅមន្ទីរពេទ្យ ដើម្បីពិនិត្យជំងឺដែលកំពុងធ្វើទុក្ខគាត់ ប៉ុន្តែគាត់នៅតែមិនបានរកឃើញចម្លើយ។ ពេលគាត់ត្រឡប់មកផ្ទះវិញ ក្រុមគ្រួសារគាត់មានការបាក់ទឹកចិត្តណាស់។ តែពួកគាត់មានការភ្ញាក់ផ្អើលណាស់ ពេលដែលបានឃើញប្រអប់ដែលមានការតុបតែងយ៉ាងស្អាតនៅលើកាំជណ្តើរមុខផ្ទះ ដែលមានកណ្ឌគម្ពីរ អេសាយ ៤៣:២ ពីខាងមុខ។ នៅខាងក្នុងប្រអប់ ពួកគេក៏បានឃើញខគម្ពីរលើកទឹកចិត្តមួយចំនួន ដែលមិត្តភក្តិពួកគេបានសរសេរដោយផ្ទាល់ដៃ។ នៅម៉ោងបន្ទាប់ពួកគេក៏បានចំណាយពេលទទួលការលើកទឹកចិត្តពីខគម្ពីរ និងពីគំរិយាបថរបស់មិត្តភក្តិទាំងនោះ ដែលចេះគិតអំពីទុក្ខលំបាករបស់ពួកគេ។

អ្នកដែលឆ្លងកាត់ពេលដ៏ពិបាក ឬបញ្ហាប្រឈមក្នុងគ្រួសារ តែងតែត្រូវការការលើកទឹកចិត្ត។ ការប្រើខគម្ពីរតិចតួច ឬច្រើនក្តី សុទ្ធតែអាចលើកទឹកចិត្តអ្នក មិត្តភក្តិ ឬសមាជិកគ្រួសារណាម្នាក់។ កណ្ឌគម្ពីរអេសាយជំពូក៤៣ មានពេញទៅដោយពាក្យលើកទឹកចិត្តសម្រាប់មនុស្សម្នាក់ៗ ឬជាក្រុម។ ចូរយើងពិចារណាអំពីពាក្យលើកទឹកចិត្តមួយចំនួន ក្នុងកណ្ឌគម្ពីរនេះ ដែលមានដូចជា ព្រះអម្ចាស់បានបង្កើតអ្នក ជប់សួនអ្នក ប្រោសលោះអ្នក ហើយបានហៅចំឈ្មោះអ្នក (ខ.១)។ ព្រះអង្គនឹងគង់នៅជាមួយអ្នក(ខ.២) ព្រះអង្គជាព្រះដ៏បរិសុទ្ធនៃសាសន៍អ៊ីស្រាអែល ហើយព្រះអង្គជាព្រះសង្គ្រោះរបស់យើង (ខ.៣)។

ពេលណាអ្នកពិចារណាអំពីព្រះបន្ទូលសន្យារបស់ព្រះ សូមព្រះបន្ទូលព្រះអង្គលើកទឹកចិត្តអ្នក។ ហើយខណៈពេលដែលព្រះអង្គប្រទានអ្វីដែលអ្នកត្រូវការ អ្នកអាចលើកទឹកចិត្តអ្នកដទៃ។ យើងមិនចាំបាច់ត្រូវចំណាយប្រាក់ច្រើន ដើម្បីធ្វើប្រអប់ដាក់កាតដែលមានខគម្ពីរលើកទឹកចិត្តនោះឡើយ ប៉ុន្តែឥទ្ធិពលដែលខគម្ពីរនេះមានក្នុងការលើកទឹកចិត្ត គឺមានតម្លៃមិនអាចកាត់ថ្លៃបានទេ។ ទោះរយៈពេល៥ឆ្នាំបានកន្លងផុតទៅ គ្រួសារមួយនេះនៅតែឲ្យតម្លៃយ៉ាងខ្លាំង មកលើកាតទាំងនោះដែលមានខគម្ពីរសរសេរពីលើ។—Brent Hackett

តើអ្នកអាចរកឃើញព្រះបន្ទូលសន្យាអ្វីផ្សេងទៀតក្នុងកណ្ឌគម្ពីរអេសាយ ជំពូក៤៣? តើអ្នកអាចចែកចាយកាតដែលមានព្រះបន្ទូលសន្យា ឬផ្ញើសារ ឬក៏អីមែលលើកទឹកចិត្តទៅកាន់នរណាខ្លះនៅថ្ងៃនេះ?

ឱព្រះអម្ចាស់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានប្រទានខគម្ពីរដែលមានព្រះបន្ទូលសន្យាជាច្រើន ហើយខគម្ពីរតែមួយខ ក៏អាចលើកទឹកចិត្តទូលបង្គំ ចំពេលដែលទូលបង្គំមានទុក្ខ។

Daily Manna 2026_Content Enhance.indd 349 17/11/25 1:47 in the afternoon

ឯប្រាក់ ហើយនិងមាស ខ្ញុំគ្មានទេ តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងឲ្យដល់អ្នក (កិច្ចការ ៣:៦)។

អំណោយដែលល្អឥតខ្ចោះ

កាលខ្ញុំកំពុងធ្វើដំណើរបេសកកម្មរយៈពេលខ្លីទៅប្រទេសពេរូ ដើម្បីផ្សាយដំណឹងល្អមានយុវជនម្នាក់បានសុំលុយខ្ញុំ។ ដើម្បីសុវត្ថិភាព ក្រុមការងាររបស់ខ្ញុំបានទទួលការណែនាំថា បើមាននរណាម្នាក់សុំលុយយើង យើងមិនត្រូវឲ្យលុយគាត់ទេ ដូចនេះតើធ្វើដូចម្តេចឲ្យខ្ញុំអាចឲ្យលុយគាត់បាន? បន្ទាប់មក ខ្ញុំក៏បាននឹកចាំអំពីការឆ្លើយតបពីសាវ័ក ពេត្រុស និងសាវ័ក យ៉ូហាន ចំពោះជនពិការជើងម្នាក់ ក្នុងកណ្ឌគម្ពីរកិច្ចការ ជំពូក៣។ ខ្ញុំក៏បានពន្យល់គាត់ថា ខ្ញុំមិនអាចឲ្យប្រាក់ដល់គាត់បានទេ ប៉ុន្តែខ្ញុំអាចផ្សាយដំណឹងល្អអំពីសេចក្តីស្រឡាញ់របស់ព្រះដល់គាត់។ ពេលគាត់ប្រាប់យើងថា គាត់ជាក្មេងកំព្រា ខ្ញុំក៏បានប្រាប់គាត់ថា ព្រះអម្ចាស់ចង់ធ្វើជាឪពុករបស់គាត់។ ការនេះបាននាំឲ្យគាត់ប៉ះពាល់ចិត្តរហូតដល់ស្រក់ទឹកភ្នែក។ ខ្ញុំក៏បានប្រាប់សមាជិកពួកជំនុំក្នុងតំបន់ដែលបានទទួលយើងស្នាក់នៅ ឲ្យចំនាក់ចំនងគាត់ ដើម្បីបង្រៀនព្រះបន្ទូលដល់គាត់។

ជួនកាល យើងអាចមានអារម្មណ៍ថា ពាក្យសម្តីរបស់យើងហាក់ដូចជាមានការខ្វះខាតយ៉ាងខ្លាំង ប៉ុន្តែព្រះវិញ្ញាណបរិសុទ្ធអាចចម្រើនកម្លាំងយើង ខណៈពេលដែលយើងចែកចាយដល់អ្នកដទៃអំពីព្រះយេស៊ូវ។

កាលសាវ័ក ពេត្រុស និងសាវ័ក យ៉ូហាន ជួបបុរសម្នាក់ ក្នុងបរិវេណព្រះវិហារ ពួកគេដឹងថា ការចែកចាយអំពីព្រះគ្រីស្ទ គឺជាអំណោយដែលប្រសើរបំផុត។ «តែពេត្រុសនិយាយថា ឯប្រាក់ ហើយនិងមាស ខ្ញុំគ្មានទេ តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងឲ្យដល់អ្នក គឺដោយសារព្រះនាមព្រះយេស៊ូវគ្រីស្ទពីស្រុកណាសារ៉ែត ចូរអ្នករាល់គ្នាក្រោកឡើងដើរទៅចុះ» (ខ.៦)។ បុរសនោះក៏បានទទួលសេចក្តីសង្គ្រោះ និងការប្រោសឲ្យជានៅថ្ងៃនោះ។ ព្រះអម្ចាស់បន្តប្រើយើង ដើម្បីនាំមនុស្សបាត់បង់ចូលមករកព្រះអង្គ។

ខណៈពេលដែលយើងស្វែងរកអំណោយដ៏ឥតខ្ចោះសម្រាប់អ្នកដទៃ ក្នុងថ្ងៃណូអែលខាងមុខនេះ ចូរយើងចាំថា អំណោយពិតប្រាកដ គឺជាការស្គាល់ព្រះយេស៊ូវ និងសេចក្តីសង្គ្រោះអស់កល្បជានិច្ច ដែលព្រះអង្គបានប្រទាន។ ចូរយើងបន្តបើកចិត្តឲ្យព្រះអង្គប្រើយើង ដើម្បីនាំមនុស្សជាច្រើន ទៅរកព្រះអង្គសង្គ្រោះ។—Nancy Gavilanes

តើអ្នកអាចអធិស្ឋានឲ្យនរណាខ្លះ ក្នុងរដូវកាលបុណ្យណូអែលឆ្នាំនេះ? តើអ្នកអាចចែកចាយអំពីព្រះគ្រីស្ទដល់នរណាខ្លះ?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណសម្រាប់ការប្រទានព្រះយេស៊ូវ ធ្វើជាអំណោយដ៏ឥតខ្ចោះដែលជួយសង្គ្រោះយើងខ្ញុំឲ្យរួចពីបាប។

Daily Manna 2026_Content Enhance.indd 350 17/11/25 1:47 in the afternoon

នោះឯងរាល់គ្នានឹងអំពាវនាវដល់អញ ហើយនឹងទៅអធិស្ឋានដល់អញ រួចអញនឹងយល់ព្រមតាម (យេរេមា ២៩:១២)។

ព្រះអង្គនឹងឆ្លើយតប

កាលលោកគ្រូគង្វាល ធីម៉ូថេ ពាក់ក្រវ៉ាត់កសម្រាប់គ្រូគង្វាលក្នុងអំឡុងពេលដែលគាត់ធ្វើដំណើរ គាត់ច្រើនតែជួបការបង្អាក់ដំណើរ ដោយសារមនុស្សមួយចំនួនដែលគាត់មិនដែលស្គាល់។ មនុស្សនៅអាកាសយានដ្ឋានបានសុំឲ្យគាត់អធិស្ឋានឲ្យពួកគេ ពេលណាពួកគេឃើញក្រវ៉ាត់ពណ៌ស នៅលើកអាវក្រៅរបស់គាត់ដែលមានពណ៌ខ្មៅ។ ក្នុងការធ្វើដំណើរតាមយន្តហោះកាលពីពេលថ្មីៗនេះ មានស្ត្រីម្នាក់បានលត់ជង្គង់ នៅក្បែរកៅអីអង្គុយរបស់គាត់ ពេលនាងបានកត់សម្គាល់ឃើញគាត់ជាគ្រូគង្វាល ហើយក៏បានសួរគាត់ថា «លោកជាគ្រូគង្វាលមែនទេ? លោកគ្រូអាចអធិស្ឋានឲ្យខ្ញុំបានទេ?» ហើយលោកគ្រូគង្វាល ធីម៉ូថេ ក៏បានអធិស្ឋានឲ្យគាត់។

កណ្ឌគម្ពីរមួយក្នុងកណ្ឌគម្ពីរយេរេមា ក៏បានប្រាប់យើងអំពីមូលហេតុដែលយើងអាចដឹងថា ព្រះអម្ចាស់ស្តាប់ឮ ហើយឆ្លើយតបការអធិស្ឋានរបស់យើង គឺដោយសារព្រះអង្គយកព្រះទ័យទុកដាក់ចំពោះយើង! គឺដូចដែលព្រះអង្គបានធានាដល់រាស្ត្ររបស់ព្រះអង្គជាមនុស្សមានបាប ដែលកំពុងរស់នៅជាឈ្លើយសឹកថា «អញស្គាល់សេចក្ដីដែលអញគិតពីដំណើរឯងរាល់គ្នា មិនមែនគិតធ្វើសេចក្ដីអាក្រក់ទេ គឺគិតឲ្យបានសេចក្ដីសុខវិញ ដើម្បីដល់ចុងបំផុត ឲ្យឯងរាល់គ្នាបានសេចក្ដីសង្ឃឹម» (២៩:១១)។ ព្រះអម្ចាស់បានរំពឹងថា ថ្ងៃមួយពួកគេនឹងវិលត្រឡប់មករកព្រះអង្គវិញ។ ព្រះអង្គក៏បានមានបន្ទូលទៀតថា «ឯងរាល់គ្នានឹងអំពាវនាវដល់អញ ហើយនឹងទៅអធិស្ឋានដល់អញ រួចអញនឹងយល់ព្រមតាម ឯងរាល់គ្នានឹងស្វែងរកអញ ហើយនឹងឃើញផង គឺកាលណាឯងស្វែងរកអញឲ្យអស់អំពីចិត្ត» (ខ.១២-១៣)។

ហោរា យេរេមា បានដឹងអំពីសេចក្ដីពិតនេះ កាលគាត់កំពុងជាប់គុក។ ព្រះអម្ចាស់បានធានាគាត់ថា «ចូរអំពាវនាវដល់អញ នោះអញនឹងឆ្លើយតប ហើយនឹងបង្ហាញឲ្យឯងឃើញការយ៉ាងធំ ហើយមុតមាំ ដែលឯងមិនដឹង» (៣៣:៣)។

ព្រះយេស៊ូវបានជំរុញយើងឲ្យអធិស្ឋាន។ ព្រះអង្គមានបន្ទូលថា «ព្រះវរបិតានៃអ្នក ទ្រង់ជ្រាបនូវរបស់អ្វីដែលអ្នកត្រូវការ មុនដែលអ្នកសូមផង» (ម៉ាថាយ ៦:៨)។ ដូចនេះ ចូរយើង «ទូលសូម» «ស្វែងរក» ហើយ «គោះទ្វារ» ក្នុងការអធិស្ឋាន (៧:៧)។ ការទូលសូមនីមួយៗដែលយើងមាន នាំយើងចូលទៅជិតព្រះដែលឆ្លើយតបការអធិស្ឋានរបស់យើង។ យើងមិនចាំបាច់ត្រូវអធិស្ឋានទៅរកព្រះអង្គ ធ្វើមើលតែយើងជាអ្នករកៅនោះឡើយ។ ព្រះអង្គស្គាល់យើង ហើយសព្វព្រះទ័យនឹងស្តាប់យើងអធិស្ឋាន។ យើងអាចទូលថ្វាយក្តីកង្វល់របស់យើងដល់ព្រះអង្គនៅពេលនេះបាន។—Patricia Raybon

តើអ្នកអធិស្ឋានញឹកញាប់ប៉ុណ្ណា? តើអ្នកនឹងអធិស្ឋានដល់ព្រះអង្គដូចម្តេចខ្លះ នៅថ្ងៃនេះ?

ឱព្រះអម្ចាស់ ទូលបង្គំមានចិត្តចង់អធិស្ឋាន ពេលដែលបានដឹងថា ព្រះអង្គយកព្រះទ័យទុកដាក់ និងស្គាល់ទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការឆ្លើយតបការអធិស្ឋានរបស់ទូលបង្គំ។

គម្រោងអានព្រះគម្ពីរយ:ពេល១ឆ្នាំ | ហូសេ ៥-៨ និងវិវរណៈ ២

នាងប្រសូតបានបុត្រាជាចំបងមក រួចរុំនឹងសំពត់ផ្តេកក្នុងស្នូក ពីព្រោះក្នុងផ្ទះសំណាក់គ្មានកន្លែងណានៅទេ (លូកា ២:៧)។

បន្ទប់សម្រាប់ប្រកបជាមួយព្រះយេស៊ូវ

ខ្ញុំមានការសប្បាយចិត្ត ដែលបានចំណាយពេលចុងសប្តាហ៍នៅរដ្ឋញូអូឡិន ក្នុងអំឡុងពេលដែលមានក្បួនដង្ហែក្នុងសង្កាត់ប្បាធម៌បារាំង ដោយបានដើរមើលសារមន្ទីរសង្គ្រាមលោកលើកទី២ ហើយក៏បានភ្លក់អ យស្ទ័រអាំង។ ប៉ុន្តែ ពេលដែលខ្ញុំគេងលក់ក្នុងបន្ទប់សម្រាប់ភ្ញៀវស្នាក់នៅក្នុងផ្ទះរបស់មិត្តភក្តិខ្ញុំ ខ្ញុំក៏បាននឹកប្រពន្ធកូនរបស់ខ្ញុំ។ ខ្ញុំមានអំណរណាស់ ដែលមានឱកាសចែកចាយព្រះបន្ទូលក្នុងទីក្រុងផ្សេងទៀត ប៉ុន្តែខ្ញុំមានអំណរបំផុតដែលមានបន្ទប់សម្រាប់ប្រកបជាមួយព្រះយេស៊ូវក្នុងផ្ទះមិត្តភក្តិខ្ញុំ។

ក្នុងការស្វែងយល់អំពីព្រះរាជកិច្ចដែលព្រះយេស៊ូវបានធ្វើ កាលព្រះអង្គគង់នៅលើផែនដី ជួនកាលគេមិនបានចាប់អារម្មណ៍ថា ព្រឹត្តិការណ៍សំខាន់ៗបំផុតរបស់ព្រះអង្គបានកើតឡើងនៅតាមដងផ្លូវញឹកញាប់ប៉ុណ្ណាទេ។ ព្រះរាជបុត្រានៃព្រះបានយាងចូលក្នុងលោកីយ៍ ដោយការប្រសូតក្នុងភូមិបេថ្លេហិម ស្ថិតនៅចម្ងាយមិនអាចវាស់បាន ពីផ្ទះរបស់ព្រះអង្គនៅនគរស្ថានសួគ៌ ហើយក៏ឆ្ងាយពីផ្ទះគ្រួសារព្រះអង្គនៅភូមិណាសារ៉ែត។ មានគ្រួសារជាច្រើនបានធ្វើដំណើរមកភូមិបេថ្លេហិម ដើម្បីធ្វើជំរឿន ហេតុនេះហើយកណ្តាគម្ពីរលូកាបានចែងថា នាងម៉ារា និងលោក ចន យ៉ូសែបមិនអាចរកបានបន្ទប់ស្នាក់នៅឲ្យបានសមរម្យទេ (លូកា ២:៧)។

ការអ្វីដែលគេមិនឃើញមាន ក្នុងការប្រសូតរបស់ព្រះយេស៊ូវ គឺពិតជាបានបង្ហាញឲ្យគេឃើញ ក្នុងការសុគតរបស់ព្រះអង្គ។ កាលព្រះយេស៊ូវនាំសិស្សព្រះអង្គចូលទីក្រុងយេរូសាឡិម ព្រះអង្គបានប្រាប់សាវ័ក ពេត្រុស និងសាវ័ក យ៉ូហាន ឲ្យរៀបចំអាហារបុណ្យរំលង។ ព្រះអង្គបានបង្គាប់ពួកគេឲ្យដើរតាមអ្នកលីក្អមទឹកទៅដល់ផ្ទះគាត់ ហើយសុំប្រើបន្ទប់ទទួលភ្ញៀវរបស់គាត់សម្រាប់ឲ្យព្រះគ្រីស្ទ និងពួកសិស្សព្រះអង្គអាចបរិភោគអាហារពេលល្ងាចលើកចុងក្រោយ (២២:១០-១២)។ នៅក្នុងកន្លែងដែលបានខ្ចីគេនោះ ព្រះយេស៊ូវបានបង្កើតពិធីលៀងព្រះអម្ចាស់ជាការប្រាប់ទុកជាមុនអំពីការសុគតរបស់ព្រះអង្គនៅលើឈើឆ្កាង (ខ.១៧-២០)។

យើងស្រឡាញ់ភាពកក់ក្តៅនៅក្នុងផ្ទះរបស់យើង ប៉ុន្តែបើយើងធ្វើដំណើរដោយព្រះវិញ្ញាណរបស់ព្រះយេស៊ូវ សូម្បីតែបន្ទប់សម្រាប់ភ្ញៀវស្នាក់នៅ ក៏អាចប្រើជាកន្លែងប្រកបជាមួយព្រះអង្គផងដែរ។—Mike Wittmer

តើរឿងដែលមានន័យបំផុតបានកើតឡើងក្នុងជីវិតអ្នកនៅកន្លែងណា ហើយរឿងទាំងនោះមានចំណុចអ្វីដែលធ្វើឲ្យអ្នកចងចាំបំផុត? នៅពេលដែលអ្នកធ្វើដំណើរនៅតាមផ្លូវ តើអ្នកអាចចំណាយពេលប្រកបជាមួយព្រះគ្រីស្ទដោយរបៀបណា?

ឱព្រះយេស៊ូវ ព្រះអង្គបានយាងចុះពីផ្ទះរបស់ព្រះអង្គនៅស្ថានសួគ៌ដ៏សែនឆ្ងាយមករកទូលបង្គំ សូមព្រះអង្គជួយទូលបង្គំឲ្យនឹកចាំថា ព្រះអង្គតែងតែគង់នៅជាមួយទូលបង្គំជានិច្ច។

Daily Manna 2026_Content Enhance.indd 352 17/11/25 1:47 in the afternoon

ដ្បិតទ្រង់ជាព្រះដ៏មានព្រះជន្មរស់នៅ...ទ្រង់ប្រោសឲ្យរួច ហើយក៏ជួយសង្គ្រោះ (ដានីយ៉ែល ៦:២៦-២៧)។

ព្រះវត្តមានរបស់ព្រះថែរក្សាយើង

នៅពេលដែលចៅៗរបស់ខ្ញុំមើលសៀវភៅកម្រងអនុស្សាវរីយ៍របស់ខ្ញុំនៅថ្នាក់វិទ្យាល័យ ពួកគេមានការភ្ញាក់ផ្អើលចំពោះម៉ូតសក់ សំលៀកបំពាក់ និងឡានដែលហួសសម័យ នៅក្នុងរូបថតក្នុងសៀវភៅនោះ។ ពេលខ្ញុំមើលទៅរូបថតទាំងនោះ ខ្ញុំមើលឃើញខុសពីពួកគេ។ ទីមួយ ខ្ញុំមើលឃើញទឹកមុខញញឹមរបស់មិត្តចាស់ និងមិត្តភក្តិដែលនៅតែរាប់អានគ្នារហូតមកដល់ពេលសព្វថ្ងៃ។ ជាងនេះទៅទៀត ខ្ញុំបានឃើញព្រះចេស្តារបស់ព្រះដែលបានថែរក្សាខ្ញុំ។ ព្រះវត្តមានដ៏សុភាពរបស់ព្រះអង្គបានហ៊ុមព័ទ្ធខ្ញុំនៅក្នុងសាលារៀនដែលខ្ញុំពិបាកចូលចំណោមគេឲ្យចុះ។ សេចក្តីល្អរបស់ព្រះអង្គបានបន្តថែរក្សាខ្ញុំ គឺជាសេចក្តីសប្បុរសដែលព្រះអង្គប្រទានអស់អ្នកដែលស្វែងរកព្រះអង្គ។

លោក ចន ដានីយ៉ែល បានស្គាល់ព្រះវត្តមានរបស់ព្រះ ដែលថែរក្សាគាត់ផងដែរ។ ក្នុងការរស់នៅជាឈ្លើយសឹក ក្នុងទីក្រុងបាប៊ីឡូន គាត់បានអធិស្ឋាននៅបន្ទប់ខាងលើ ដែលមានបង្អួចបើកចំហទៅរកទិសនៃទីក្រុងយេរូសាឡិម (ខ.៧-៩)។ ក្នុងការអធិស្ឋានដូចនេះ គាត់ក៏បាននឹកចាំព្រះអម្ចាស់ ដែលព្រះវត្តមានទ្រង់បានជួយទ្រទ្រង់គាត់ ដោយស្តាប់ឮ និងឆ្លើយតបការអធិស្ឋានរបស់គាត់។ ដូចនេះ ព្រះអម្ចាស់ក៏បានស្តាប់ឮ ឆ្លើយតប ហើយទ្រទ្រង់គាត់សារជាថ្មី។

ប៉ុន្តែ ទោះគេបានចេញច្បាប់ថ្មីហាមមិនឲ្យគាត់អធិស្ឋានក៏ដោយ ក៏គាត់នៅតែស្វែងរកព្រះវត្តមានព្រះអង្គ ទោះមានរឿងអ្វីកើតឡើងចំពោះគាត់ក៏ដោយ។ ដូចនេះ គាត់ក៏បានអធិស្ឋានដូចសព្វមួយដង (ខ.១០)។ កាលគេទម្លាក់គាត់ចូលក្នុងរូងតោ ទេវតារបស់ព្រះអម្ចាស់បានថែរក្សាគាត់ឲ្យមានសុវត្ថិភាព ក្នុងនាមព្រះអង្គជាព្រះដ៏ស្មោះត្រង់ ហើយក៏បានជួយសង្គ្រោះគាត់ (ខ.២២)។

ការមើលទៅអតីតកាលរបស់យើង ក្នុងអំឡុងពេលដែលយើងមានការលំបាក អាចជួយយើងឲ្យនឹកចាំអំពីសេចក្តីស្មោះត្រង់របស់ព្រះ។ សូម្បីតែស្តេច ដារីយ៉ុស នៃចក្រភពពើស៊ីក៏បានមានបន្ទូលអំពីព្រះអម្ចាស់ថា «ទ្រង់ប្រោសឲ្យរួច ហើយក៏ជួយសង្គ្រោះ ទ្រង់ធ្វើទីសម្គាល់ និងការអស្ចារ្យនៅស្ថានសួគ៌ហើយនៅផែនដី» (ខ.២៧)។ ព្រះអង្គល្អកាលពីមុន ហើយក៏នៅតែល្អក្នុងពេលសព្វថ្ងៃ។ ព្រះវត្តមានរបស់ព្រះអង្គនឹងថែរក្សាអ្នកឲ្យមានសេចក្តីសុខ។—Patricia Raybon

តើមានទុក្ខលំបាកអ្វីកាលពីមុន ដែលបានល្បងលជំនឿរបស់អ្នក? តើព្រះអម្ចាស់បានទ្រទ្រង់អ្នក ដោយព្រះទ័យសប្បុរសយ៉ាងណា?

ឱព្រះវរបិតា ពេលណាទូលបង្គំក្រឡេកមកមើលអតីតកាល ទូលបង្គំមើលឃើញព្រះវត្តមានដែលជួយទ្រទ្រង់ ដ៏សប្បុរស។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានថែរក្សាទូលបង្គំក្នុងពេលបច្ចុប្បន្នផងដែរ។

គម្រោងអានព្រះគម្ពីរមួយៈពេល១ឆ្នាំ | ហូសេ ១២-១៤ និងវិវរណៈ ៤

ដ្បិតសេចក្តីស្រឡាញ់មានកំឡាំង ដូចជាសេចក្តីស្លាប់ (បទចម្រៀងសាឡូម៉ូន ៨:៦)។

សេចក្តីស្រឡាញ់មានកម្លាំងដូចសេចក្តីស្លាប់

ប្រើ អ្នកដើរកម្សាន្ត តាមរបងចាស់មួយធ្វើពីឥដ្ឋ ដែលលាតសន្ធឹងនៅចន្លោះទីបញ្ចុះសពរបស់គ្រីស្ទបរិស័ទប្រូតេស្តង់ និងទីបញ្ចុះសពរបស់ពួកកាតូលិកក្នុងទីក្រុងរ៉ូអ័រមុន ប្រទេសហូឡង់ អ្នកនឹងឃើញមានអ្វីមួយចំឡែកគួរឲ្យងឿងឆ្ងល់។ មានផ្លាកឈ្មោះផ្សួរខ្ពស់ៗពីរទល់មុខគ្នា នៅសង្ហាងរបងនោះ។ ផ្លាកឈ្មោះមួយជារបស់សពបុរសជាគ្រីស្ទបរិស័ទប្រូតេស្តង់ និងផ្លាកឈ្មោះមួយទៀត ជារបស់សពរបស់ភរិយាគាត់ជាពួកកាតូលិក។ ច្បាប់របស់វប្បធម៌ជនជាតិហូឡង់ កាលពីសតវត្សរ៍ទី១៩ បានតម្រូវឲ្យគេបញ្ចុះសព្វរបស់អ្នកទាំងពីរនៅក្នុងទីបញ្ចុះសពពីរដែលញែកដាច់ពីគ្នាដោយរបងនោះ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេបានបដិសេធន៍មិនព្រមទទួលយកការតម្រូវនេះទេ។ ពួកគេបានឲ្យគេធ្វើផ្លាកឈ្មោះផ្សួររបស់ពួកគេមានកម្ពស់ខ្ពស់ផុតរបងប្រហែលកន្លែងម៉ែត្រខុសពីធម្មតា ដើម្បីឲ្យផ្នែកខាងលើរបស់ផ្លាកឈ្មោះផ្សួរទាំងពីរនោះអាចទល់មុខគ្នាផុតរបងនោះ ដោយមានតែខ្យល់នៅចន្លោះកណ្តាល។ នៅលើកំពូលរបស់ផ្លាកឈ្មោះផ្សួររបស់បុរសជាប្តី មានរូបចម្លាក់ដៃម្ខាងឈោងទៅចាប់រូបចម្លាក់ដៃម្ខាងទៀត នៅលើកំពូលផ្លាក់ឈ្មោះផ្សួររបស់ភរិយាគាត់។ ដូចនេះ ប្តីប្រពន្ធមួយគូរនេះបានបដិសេធន៍មិនឲ្យគេបំបែកពួកគេបាន សូម្បីតែក្នុងសេចក្តីស្លាប់ក៏ដោយ។

កណ្ឌគម្ពីរបទចម្រៀងសាឡូម៉ូនបានពន្យល់អំពីអំណាចនៃសេចក្តីស្រឡាញ់។ ស្តេច សាឡូម៉ូន មានបន្ទូលថា «សេចក្តីស្រឡាញ់មានកំឡាំង ដូចជាសេចក្តីស្លាប់ ហើយសេចក្តីប្រចណ្ឌក៏សាហាវ ដូចជាស្ថានឃុំព្រលឹងមនុស្សស្លាប់» (៨:៦)។ សេចក្តីស្រឡាញ់ពិតប្រាកដមានអំណាចខ្លាំងណាស់។ ជំហូលនៃសេចក្តីស្រឡាញ់ «ក៏ជាជំហូលនៃភ្លើង ជាអណ្តាតភ្លើងយ៉ាងសហ័ស» (ខ.៦)។ សេចក្តីស្រឡាញ់ពិតប្រាកដមិនដែលចុះចាញ់ មិននៅស្ងៀម ហើយគេមិនអាចបំផ្លាញបានឡើយ។ ស្តេច សាឡូម៉ូន បានពិពណ៌នាទៀតថា «ទឹកណាក៏មិនអាចនឹងពន្លត់សេចក្តីស្រឡាញ់បានឡើយ ទឹកជំនន់នឹងពន្លិចក៏មិនបានដែរ» (ខ.៧)។

«ព្រះទ្រង់ជាតួសេចក្តីស្រឡាញ់» (១យ៉ូហាន ៤:១៦)។ សេចក្តីស្រឡាញ់ខ្លាំងបំផុតរបស់យើង គ្រាន់តែជាការឆ្លុះបញ្ចាំងមួយភាគ អំពីសេចក្តីស្រឡាញ់ដ៏មានអំណាចដែលព្រះអង្គមានចំពោះយើង។ ព្រះអង្គជាប្រភពនៃសេចក្តីស្រឡាញ់ពិតប្រាកដ សេចក្តីស្រឡាញ់ដែលស្ថិតស្ថេរ។—Winn Collier

តើអ្នកបានដកពិសោធន៍នឹងសេចក្តីស្រឡាញ់ដ៏មានអំណាចរបស់ព្រះដូចម្តេចខ្លះ? តើព្រះអង្គបានបើកបង្ហាញសេចក្តីស្រឡាញ់ដ៏មានអំណាចរបស់ព្រះអង្គ ដល់អ្នកដូចម្តេចខ្លះ?

ឱព្រះអម្ចាស់ ទូលបង្គំត្រូវការសេចក្តីស្រឡាញ់របស់ព្រះអង្គ ដែលមានអំណាចជាងសេចក្តីស្លាប់ ខ្លាំងជាងសេចក្តីអាក្រក់ និងកំហុសរបស់ទូលបង្គំ។ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់សេចក្តីស្រឡាញ់ដ៏មានអំណាចរបស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 354 17/11/25 1:47 in the afternoon

ដ្បិតខ្ញុំនឹកចាំពីសេចក្តីជំនឿស្មោះត្រង់ ដែលនៅក្នុងអ្នក សេចក្តីជំនឿនោះបាននៅក្នុងយាយឡូអ៊ីស ជាជីដូនរបស់អ្នកជាមុនដំបូង រួចក៏នៅក្នុងអ្នក អើនីស ជាម្តាយអ្នកដែរ ហើយខ្ញុំជឿជាក់ថា ក៏នៅក្នុងអ្នកផង (២ធីម៉ូថេ ១:៥)។

សេចក្តីជំនឿរបស់ជីដូន

មានពេលមួយ ក្រុមគ្រួសារខ្ញុំបានជួបជុំគ្នាញ៉ាំអាហារពេលល្ងាចនៅតុបាយ។ ពេលយើងកំពុងអង្គុយជុំគ្នា ចៅប្រុសខ្ញុំអាយុ៩ឆ្នាំបាននិយាយ ដោយទឹកមុខញញឹមថា គាត់ចូលចិត្តអានសៀវភៅ ដូចលោកយាយរបស់គាត់ដែរ។ ពាក្យសម្តីរបស់គាត់បាននាំមកនូវក្តីអំណរក្នុងចិត្តខ្ញុំ។ ខ្ញុំក៏បាននឹកចាំពេលប៉ុន្មានឆ្នាំមុន គាត់មានជំងឺ ហើយត្រូវនៅផ្ទះ មិនបានទៅសាលារៀន។ បន្ទាប់ពីគាត់គេងនៅពេលថ្ងៃអស់រយៈពេលយូរបន្តិច យើងក៏បានអង្គុយទន្ទឹមគ្នាអានសៀវភៅ។ ខ្ញុំមានចិត្តរីករាយដែលបានបន្តកេរដំណែលនៃការចូលចិត្តអានសៀវភៅទៅដល់ចៅប្រុសខ្ញុំ ដែលខ្ញុំក៏បានទទួលកេរដំណែលនេះពីម្តាយខ្ញុំមកដែរ។

ប៉ុន្តែ នេះមិនមែនជាកេរដំណែលសំខាន់បំផុត ដែលខ្ញុំចង់ផ្ទេរទៅឲ្យចៅៗរបស់ខ្ញុំទេ។ ខ្ញុំបានអធិស្ឋានសូមឲ្យកេរដំណែលនៃសេចក្តីជំនឿដែលខ្ញុំបានទទួលពីឪពុកម្តាយខ្ញុំ បានបន្តផ្ទេរទៅឲ្យកូនៗរបស់ខ្ញុំ ហើយនឹងបានជួយចៅៗខ្ញុំ ក្នុងការធ្វើដំណើរឆ្ពោះទៅរកសេចក្តីជំនឿ។

លោក ថន ធីម៉ូថេ បានទទួលកេរដំណែលពីម្តាយ និងជីដូនដែលកោតខ្លាចព្រះ និងគ្រូឱវាទខាងវិញ្ញាណ គឺសាវ៉ែក ប៉ុល។ សាវ៉ែក ប៉ុល បានរៀបរាប់ថា “ដ្បិតខ្ញុំនឹងចាំពីសេចក្តីជំនឿស្មោះត្រង់ ដែលនៅក្នុងអ្នក សេចក្តីជំនឿនោះបាននៅក្នុងយាយឡូអ៊ីស ជាជីដូនរបស់អ្នកជាមុនដំបូង រួចក៏នៅក្នុងអ្នក អើនីស ជាម្តាយអ្នកដែរ ហើយខ្ញុំជឿជាក់ថា ក៏នៅក្នុងអ្នកផង” (២ធីម៉ូថេ ១:៥)។

ពេលខ្លះ យើងប្រហែលជាគិតថា ជីវិតយើងមិនមានភាពវិជ្ជមានគ្រប់គ្រាន់ ដើម្បីធ្វើជាគំរូដ៏ល្អសម្រាប់អ្នកដទៃទេ។ កេរដំណែលដែលយើងបានទទួលប្រហែលមិនមែនជាកេរដំណែលល្អទេ។ ប៉ុន្តែ យើងនៅតែមានពេលសម្រាប់កសាងកេរដំណែលនៃសេចក្តីជំនឿសម្រាប់កូនចៅរបស់យើង ឬសម្រាប់ក្មេងជំនាន់ក្រោយណាម្នាក់ គឺមិនទាន់យឺតពេលទេ។ ដោយជំនួយមកពីព្រះអង្គ ចូរយើងសាបព្រោះគ្រាប់ពូជនៃសេចក្តីជំនឿ។ ព្រះអង្គជាអ្នកធ្វើឲ្យសេចក្តីជំនឿលូតលាស់ឡើង (១កូរិនថូស ៣:៦-៩)។—Alyson Kieda

តើមានកេរដំណែលខាងវិញ្ញាណអ្វី ដែលឪពុកម្តាយ ឬជីដូនជីតារបស់អ្នកបានបន្សល់ទុកឲ្យអ្នក? តើអ្នកបានសង្ឃឹមថា នឹងបន្សល់ទុកកេរដំណែលនៃសេចក្តីជំនឿសម្រាប់មនុស្សដែលអ្នកស្រឡាញ់ ដោយរបៀបណា?

ឱព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានទាំទូលបង្គំឲ្យចូលមករកព្រះអង្គ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យរស់នៅជាគំរូនៃការកោតខ្លាចព្រះដល់អ្នកដទៃ។

Daily Manna 2026_Content Enhance.indd 355 17/11/25 1:47 in the afternoon

ចូរកំសាន្ត ហើយស្អាងចិត្តគ្នាទៅវិញទៅមក ដូចជាអ្នកពាល់គ្នាកំពុងតែធ្វើហើយនោះដែរ (១ថែស្សាឡូនិច ៥:១១)។

ការលើកទឹកចិត្តក្នុងព្រះគ្រីស្ទ

គ្រូបង្រៀនម្នាក់នៅរដ្ឋអឺនឌីអាណា បានស្នើឲ្យសិស្សរបស់គាត់សរសេរពាក្យលើកទឹកចិត្ត និងបណ្តាលចិត្តនៅលើក្រដាស សម្រាប់មិត្តភក្តិរបស់ខ្លួន។ ប៉ុន្មានថ្ងៃក្រោយមក នៅពេលដែលសោកនាដកម្មមួយបានកើតឡើង នៅសាលារៀនមួយនៅក្នុងតំបន់ផ្សេងទៀតនៃសហរដ្ឋអាមេរិក ពួកគេក៏បានផ្ញើពាក្យលើកទឹកចិត្តទៅកាន់សិស្សនៅសាលានោះ ខណៈពេលដែលពួកគេកំពុងប្រឈមមុខដាក់ការឈឺចាប់ និងការភ័យខ្លាចចំពោះការអ្វី ដែលអាចកើតឡើងចំពោះពួកគេ។

សាវ័ក ប៉ុល ក៏បាននឹកចាំអំពីការលើកទឹកចិត្ត និងការយកចិត្តទុកដាក់ចំពោះគ្នាទៅវិញទៅមកផងដែរ នៅពេលដែលគាត់សរសេរសំបុត្រផ្ញើទៅពួកជំនុំនៅទីក្រុងថែស្សាឡូនីច។ ពួកគេបានបាត់បង់មិត្តភក្តិ បានជាសាវ័ក ប៉ុល បានលើកទឹកចិត្តពួកគេ ឲ្យមានសង្ឃឹមចំពោះព្រះបន្ទូលសន្យារបស់ព្រះយេស៊ូវ ដែលនឹងប្រោសមនុស្សជាទីស្រឡាញ់របស់ពួកគេឲ្យរស់ឡើងវិញ (១ថែស្សាឡូនិច ៤:១៤)។ ពួកគេមិនដឹងថា ព្រះអង្គនឹងយាងមកវិញ ហើយប្រទានការរស់ឡើងវិញនៅពេលណាទេ តែគាត់បានរំឭកពួកគេថា ក្នុងនាមពួកគេជាអ្នកជឿព្រះអង្គ ពួកគេមិនចាំបាច់ត្រូវរង់ចាំ ដោយការភ័យខ្លាច ចំពោះការជំនឿជម្រះ នៅពេលព្រះអង្គយាងមកវិញនោះឡើយ (៥:៩)។ ផ្ទុយទៅវិញ ពួកគេអាចរង់ចាំ ដោយទុកចិត្តថា ពួកគេនឹងបានទៅរស់នៅជាមួយព្រះអង្គ ហើយទន្ទឹមនឹងនោះ ពួកគេត្រូវ «កម្សាន្តចិត្ត និងស្អាងចិត្តគ្នាឡើង» (ខ.១១)។

ពេលណាយើងជួបការបាត់បង់ដ៏ឈឺចាប់ ឬសោកនាដកម្មដែលយើងមិនអាចយល់បាន យើងងាយនឹងមានការភ័យខ្លាច និងទុក្ខសោកដ៏លើសលប់។ ប៉ុន្តែ ការបង្រៀនរបស់សាវ័កប៉ុលក៏មានប្រយោជន៍ចំពោះយើង ក្នុងពេលបច្ចុប្បន្ន ដូចកាលគាត់សរសេរសំបុត្រផ្ញើទៅពួកជំនុំផងដែរ។ ចូរយើងសង្ឃឹមឡើង ដោយរំឭកថា ព្រះគ្រីស្ទនឹងស្អាងអ្វីៗទាំងអស់ឡើងវិញ។ ហើយទន្ទឹមនឹងនោះ យើងអាចលើកទឹកចិត្តគ្នាទៅវិញទៅមក ដោយការផ្ញើសារពាក្យសម្តី ការបម្រើ ឬការឱបដ៏សាមញ្ញ។—Kirsten Holmberg

តើអ្នកបានទទួលការលើកទឹកចិត្តពីអ្នកដទៃ ដូចម្តេចខ្លះ? តើអ្នកអាចលើកទឹកចិត្តនរណាម្នាក់នៅថ្ងៃនេះដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ ជាព្រះដែលមានព្រះជន្មរស់ឡើងវិញ ទោះទូលបង្គំមានការឈឺចាប់ក្នុងលោកីយ៍ដ៏រឹករឹតក៏ដោយ សូមព្រះអង្គជួយទូលបង្គំ ឲ្យរង់ចាំព្រះអង្គ ដោយក្តីសង្ឃឹម និងជំនឿ ហើយលើកទឹកចិត្តមនុស្សនៅជុំវិញទូលបង្គំ រហូតដល់ពេលដែលព្រះអង្គយាងមកវិញ។

Daily Manna 2026_Content Enhance.indd 356 17/11/25 1:47 in the afternoon

នាងនឹងប្រសូតបុត្រា១ ហើយអ្នកត្រូវថ្វាយព្រះនាមថា «យេស៊ូវ» ព្រោះបុត្រនោះនឹងជួយសង្គ្រោះ រាស្ត្រទ្រង់ ឲ្យរួចពីបាប (ម៉ាថាយ ១:២១)។

ព្រះយេស៊ូវជាអ្នកជួយសង្គ្រោះយើង

ការធ្វើដំណើរកម្សាន្តតាមកន្ត្រកខ្សែកាប (cable car) ជាធម្មតា កាត់តាមជ្រលងភ្នំមួយនៅប្រទេសប៉ាគីស្ថាន បានប្រែក្លាយជាទុក្ខវេទនាដ៏គួរឲ្យរន្ធត់។ បន្ទាប់ពីកន្ត្រកខ្សែកាបដឹកភ្ញៀវទេសចរណ៍នោះបានចេញដំណើរបានតែបន្តិច ខ្សែកាបពីរខ្សែបានដាច់ បណ្តាលឲ្យអ្នកដំណើរ៨នាក់ ដែលរួមមានសិស្សសាលាផងដែរ ក៏បានជាប់នៅក្នុងកន្ត្រកដែលបានព្យួរនឹងខ្សែកាបដែលមិនទាន់ដាច់ ស្ថិតនៅកម្ពស់រាប់រយម៉ែត្រ ដោយមិនអាចទៅណារួច។ ហេតុការណ៍នេះបាននាំឲ្យមានប្រតិបត្តិការណ៍ជួយសង្គ្រោះដ៏ពិបាក ដែលបានអូសបន្លាយពេលរហូតដល់១២ម៉ោង ដោយកងទ័ពប្រទេសប៉ាគីស្ថាន ដែលបានប្រើខ្សែពួរ ឧទ្ធម្ភាគចក្រ និងមធ្យោបាយផ្សេងៗទៀត ដើម្បីជួយសង្គ្រោះអ្នកដំណើរទាំងនោះ។

អ្នកជួយសង្គ្រោះទាំងនោះ ដែលបានទទួលការបណ្តុះបណ្តាលបានល្អ ពិតជាមានសមត្ថភាពគួរឲ្យសរសើរ ប៉ុន្តែរឿងនេះក៏បានធ្វើឲ្យខ្ញុំនឹកចាំអំពីការជួយសង្គ្រោះធំបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ដែលព្រះយេស៊ូវបានធ្វើ ដោយបេសកកម្មជួយសង្គ្រោះយើងឲ្យរួចពីបាប និងសេចក្តីស្លាប់អស់កល្បជានិច្ច។ មុនពេលព្រះគ្រីស្ទប្រសូត មានទេវតាមួយអង្គបានបង្គាប់លោក ចន យ៉ូសែប ឲ្យទទួលយកនាងម៉ារាជាភរិយា ព្រោះនាងមានគភ៌ដោយ «ព្រះវិញ្ញាណបរិសុទ្ធ» ទេ (ម៉ាថាយ ១:១៨, ២០)។ ទេវតាក៏បានប្រាប់លោក ចន យ៉ូសែប ឲ្យដាក់ឈ្មោះឲ្យបុត្រនោះថា យេស៊ូវ ព្រោះអង្គនឹង «សង្គ្រោះរាស្ត្រទ្រង់ ឲ្យរួចពីបាប» (ខ.២១)។ នៅសតវត្សរ៍ទី១ ឈ្មោះនេះជាឈ្មោះដែលគេបានដាក់ឲ្យក្មេងជាធម្មតា ប៉ុន្តែមានតែបុត្រនេះទេ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ធ្វើជាព្រះសង្គ្រោះបាន (លូកា ២:៣០-៣២)។ ព្រះគ្រីស្ទបានយាងមក តាមពេលកំណត់ដ៏ត្រឹមត្រូវ ដើម្បីប្រទានសេចក្តីសង្គ្រោះអស់កល្បជានិច្ច ដល់អស់អ្នកដែលបានប្រែចិត្តចេញពីបាប ហើយទទួលជឿព្រះអង្គ។

យើងរាល់គ្នាសុទ្ធតែជាប់នៅក្នុងចំណងនៃអំពើបាប និងសេចក្តីស្លាប់ ក្នុងជ្រលងនៃការដាច់ចេញពីព្រះអស់កល្បជានិច្ច។ ប៉ុន្តែ ដោយសារសេចក្តីស្រឡាញ់ និងព្រះគុណរបស់ព្រះអង្គ ព្រះយេស៊ូវបានយាងមកជួយសង្គ្រោះយើង ហើយនាំយើងចូលទៅកព្រះវរបិតាដែលគង់នៅស្ថានសួគ៌ ហើយរស់នៅជាមួយព្រះអង្គអស់កល្បជានិច្ច។ សូមសរសើរព្រះអង្គ!—Marvin Williams

តើបុត្រតូចរបស់នាងម៉ារាមានបេសកកម្មអ្វីដែលសំខាន់បំផុត? តើការសង្គ្រោះដែលព្រះយេស៊ូវបានធ្វើមានន័យយ៉ាងណាសម្រាប់អ្នក?

ឱព្រះយេស៊ូវសូមព្រះអង្គជួយទូលបង្គំឲ្យអរសប្បាយក្នុងការពិតដែលថា ទោះកាលពីមុនទូលបង្គំបានវង្វេង ក៏ព្រះអង្គបានរកទូលបង្គំឃើញ ដោយសារព្រះគុណរបស់ព្រះអង្គ។

Daily Manna 2026_Content Enhance.indd 357 17/11/25 1:47 in the afternoon

ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងបណ្តាលឲ្យមានហោរា១កើតឡើង ពីពួកបងប្អូនឯង ឲ្យដូច ជាអញត្រូវឲ្យឯងរាល់គ្នាស្តាប់តាមអ្នកនោះចុះ (ចោទិយកថា ១៨:១៥)។

តើយើងកំពុងស្តាប់តាមនរណា?

មានពេលមួយលោក ដាក វ៉ាយ (Doug White) បានទាក់ទងទៅប៉មបញ្ជាការហោះហើររបស់យន្តហោះ នៅអាកាសយានដ្ឋានតាមវិទ្យុទាក់ទង ហើយក៏បានប្រាប់ពួកគេថា «ខ្ញុំមានរឿងបន្ទាន់។ អ្នកបើកបរ យន្តហោះរបស់ខ្ញុំបានស្លាប់ហើយ»។ បន្ទាប់ពីយន្តហោះបានចាកចេញបានតែប៉ុន្មាននាទី អ្នកបើកបរយន្តហោះ ឯកជនដែលក្រុមគ្រួសាររបស់លោក ចន ដាក បានជិះនោះ ស្រាប់តែបានបាត់បង់ជីវិតភ្លាមៗ។ លោក ចន ដាក ក៏បានបោះជំហានចូលទៅក្នុងកាប៊ីនបើកបរយន្តហោះ ដោយជំនាញដែលបានទទួលការបណ្តុះបណ្តាលទើបតែ បាន៣ខែប៉ុណ្ណោះ ដោយប្រើយន្តហោះ ដែលមិនទំនើបដូចនេះទេ។ បន្ទាប់មក គាត់ក៏បានស្តាប់អ្នកគ្រប់គ្រង ការហោះហើរ នៅអាកាសយានដ្ឋាន ដែលបានជួយប្រាប់គាត់អំពីរបៀបចុះចតយន្តហោះ ដោយសុវត្ថិភាព។ ក្រោយមក លោក ចន ដាក ក៏បាននិយាយថា «ពួកគេបានសង្គ្រោះជីវិតក្រុមគ្រួសារខ្ញុំ ឲ្យរួចផុតពីសេចក្តីស្លាប់ ដែលអាចកើតឡើងភ្លាមៗ បើសិនជាយន្តហោះនោះធ្លាក់ ហើយត្រូវភ្លើងឆាបឆេះ»។

យើងមានព្រះមួយអង្គ ដែលមានតែទ្រង់ទេ ដែលអាចជួយនាំផ្លូវយើងឆ្លងកាត់បញ្ហាប្រឈមក្នុងជីវិត។ កាលលោក ចន ម៉ូសេ ថ្លែងទៅកាន់ប្រជាជនអ៊ីស្រាអែល គាត់មានប្រសាសន៍ថា «ព្រះយេហូវ៉ា ជាព្រះនៃឯង ទ្រង់នឹងបណ្តាលឲ្យមានហោរា១កើតឡើង ពីពួកបងប្អូនឯង ឲ្យដូចជាអញត្រូវឲ្យឯងរាល់គ្នាស្តាប់តាមអ្នកនោះ ចុះ» (ចោទិយកថា ១៨:១៥)។ ព្រះបន្ទូលសន្យានេះ គឺបានចង្អុលបង្ហាញ អំពីការបន្តវេនរបស់ហោរា ដែលព្រះ ប្រទានរាស្ត្រព្រះអង្គ តែក៏បាននិយាយអំពីព្រះមែស៊ីផងដែរ។ នៅសម័យក្រោយមកទៀត សាវ័ក ពេត្រុស និង លោក ចន ស្តេផាន ក៏បានលើកឡើងថា ហោរាដែលខ្ពង់ខ្ពស់បំផុត គឺព្រះយេស៊ូវ (៣:១៩-២២ ៧:៣៧, ៥១-៥៦)។ មានតែព្រះអង្គទេដែលបានយាងមក ដើម្បីប្រាប់យើង ហើយជួយយើងដោយផ្ទាល់ ឲ្យដើរតាមសេចក្តី បង្គាប់របស់ព្រះ ដែលមានក្តីស្រឡាញ់ និងប្រកបដោយប្រាជ្ញា (ចោទិយកថា ១៨:១៨)។

កាលព្រះយេស៊ូវកំពុងបំពេញព្រះរាជកិច្ចនៅលើផែនដី ព្រះវរបិតាបានមានបន្ទូលថា «នេះជាកូនស្ងួនភ្ងាអញ ចូរស្តាប់តាមចុះ» (ម៉ាកុស ៩:៧)។ ដើម្បីរស់នៅប្រកបដោយប្រាជ្ញា ហើយជៀសវាងការខកចិត្ត និងគ្រោះថ្នាក់ ខាងវិញ្ញាណ ចូរយើងស្តាប់តាមព្រះយេស៊ូវ ដែលកំពុងមានបន្ទូលមកយើងតាមរយៈព្រះគម្ពីរប៊ីប និងព្រះវិញ្ញាណ បរិសុទ្ធ។ ការស្តាប់តាមព្រះអង្គនាំឲ្យជីវិតយើងរស់នៅ តាមផ្លូវត្រឹមត្រូវ ហើយចំគោលដៅដែលព្រះអង្គបាន កំណត់។—Tom Felten

ហេតុអ្វីពេលខ្លះ យើងពិបាកស្តាប់តាមព្រះសូរសៀងព្រះគ្រីស្ទ ក្នុងលោកីយ៍នេះ? តើអ្នកអាចស្តាប់ បង្គាប់តាមព្រះបន្ទូលប្រកបដោយប្រាជ្ញា និងក្តីស្រឡាញ់នៅថ្ងៃនេះ យ៉ាងដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យឮ និងស្តាប់បង្គាប់តាមព្រះសូរសៀងព្រះអង្គ។

នោះទ្រង់ក៏ឃើញថាល្អ (លោកុប្បត្តិ ១:១០)។

តាមការទតឃើញរបស់ព្រះអង្គ

កាលពីឆ្នាំ១៩៦៨ អាមេរិកមានការប្រលោក ចន ប្រឡាក់ ក្នុងសង្គ្រាមជាមួយប្រទេសវៀតណាម អំពើហិង្សាដោយសារការប្រកាន់ពូជសាសន៍បានផ្ទុះឡើងនៅតាមបណ្តាទីក្រុងទាំងឡាយ ហើយមានបុគ្គលសាធារណៈដ៏សំខាន់ពីររូបត្រូវគេធ្វើឃាត។ កាលមួយឆ្នាំមុន អគ្គីភ័យបានឆក់យកជីវិតអវកាសយានិកបីនាក់ នៅកន្លែងបាញ់បង្ហោះយានអវកាស ហើយការមានគំនិតចង់បញ្ជូនមនុស្សទៅស្ថានព្រះច័ន្ទហាក់ដូចជាក្តីសង្ឃឹមដែលមិនអាចក្លាយជាការពិត។ ទោះជាយ៉ាងណាក៏ដោយ យានអវកាសអាប៉ូឡូទី៨ បានបាញ់បង្ហោះដោយជោគជ័យ ក្នុងពេលពីរបីថ្ងៃបន្ទាប់ មុនថ្ងៃណូអែលចូលមកដល់។

អាប៉ូឡូទី៨ បានសម្រេចបេសកកម្មដែលមានមនុស្សបើកបរដោយផ្ទាល់ ក្រឡឹងជុំវិញស្ថានព្រះច័ន្ទ។ អវកាសយានិក ដែលមានដូចជាលោក ចន បូរមិន (Borman) លោក ចន អ៊ែនឌ័រ (Anders) និងលោក ចន ឡូវែល (Lovell) ដែលសុទ្ធតែជាអ្នកជឿព្រះ បានបង្ហោះសារតាមរលកធាតុអាកាសនៅថ្ងៃណូអែលថា “កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី” (លោកុប្បត្តិ ១:១)។ នៅពេលនោះ ព្រឹត្តិការណ៍នេះត្រូវបានគេចាក់ផ្សាយ នៅលើកញ្ចក់ទូរទស្សន៍ ហើយបានក្លាយជាព្រឹត្តិការណ៍ដែលមានគេទស្សនាច្រើនជាងគេបំផុតនៅលើពិភពលោក ដោយពេលនោះ មនុស្សរាប់លាននាក់បានមើលរូបថតផែនដី ដែលគេថតបាន ក្នុងទីអវកាសនៅក្រៅផែនដី។ លោក ចន ហ្វ្រែង បូរមិន(Frank Borman) ក៏បានបញ្ចប់ការអានខគម្ពីរដោយពាក្យថា “នោះទ្រង់ក៏ឃើញថាល្អ” (ខ.១០)។

ពេលខ្លះ យើងមើលខ្លួនយើង ដែលប្រឡាក់ទៅដោយការលំបាកទាំងអស់ដែលយើងបានជួប ហើយមើលមិនឃើញអ្វីដែលល្អ។ ប៉ុន្តែ យើងអាចវិលត្រឡប់មកជញ្ជឹងគិត អំពីរឿងនៃការបង្កើតរបស់សព្វសារពើ ដែលមានចែងក្នុងព្រះគម្ពីរ និងមើលឃើញខ្លួនឯង តាមការទតឃើញរបស់ព្រះ គឺមើលឃើញខ្លួនយើងដែលព្រះអង្គបានបង្កើត “ឲ្យចំនឹងរូបអង្គទ្រង់” (ខ.២៧)។ ចូរយើងស្វែងយល់អំពីការទតឃើញមួយទៀតរបស់ព្រះអង្គ ក្នុងកណ្ឌគម្ពីរ យ៉ូហាន ៣:១៦ ដែលបានចែងថា “ដ្បិតព្រះទ្រង់ស្រឡាញ់មនុស្សលោក ដល់ម្ល៉េះបានជាទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែ១”។ នៅថ្ងៃនេះ ចូរយើងចាំថា ព្រះដែលបានបង្កើតយើងមក បានមើលឃើញចំណុចល្អរបស់យើង ទោះយើងមានបាបក៏ដោយ ហើយនៅតែស្រឡាញ់យើង។—Kenneth Petersen

តើអ្នកកំពុងប្រឡាក់ទៅដោយទុក្ខលំបាក និងអំពើបាបអ្វី នៅថ្ងៃនេះ? តើការដែលព្រះអង្គបានបង្កើតអ្នកឲ្យមានរូបភាពដូចព្រះអង្គមានន័យដូចម្តេចចំពោះអ្នក?

ឱព្រះអម្ចាស់ សព្វថ្ងៃនេះទូលបង្គំកំពុងតយុទ្ធនឹងទុក្ខលំបាក។ សូមព្រះអង្គជួយទូលបង្គំឲ្យមើលឃើញអ្វីដែលព្រះអង្គបានទតឃើញក្នុងទូលបង្គំ។

Daily Manna 2026_Content Enhance.indd 359 17/11/25 1:47 in the afternoon

ស្មៅក៏ស្វិតក្រៀម ហើយផ្កាពេយរុះចុះ តែព្រះបន្ទូលរបស់ព្រះនៃយើងវាល់គ្នាវិញ នោះស្ថិតស្ថេរនៅជាដរាប (អេសាយ ៤០:៨)។

សេចក្តីពិតមិនដែលប្រែប្រួល

កាលកូនប្រុសខ្ញុំនៅក្មេង គាត់បានអានសៀវភៅរឿងប្រឌិតសម្រាប់កុមារជាមួយខ្ញុំ។ សៀវភៅរឿងនេះនិយាយអំពីក្មេងប្រុសម្នាក់ដែលបានទាស់ប្រឆាំងនឹងគ្រូបង្រៀនរបស់គាត់ ដែលបានដាក់ឈ្មោះឲ្យបិចមួយដើម។ កូនសិស្សម្នាក់នោះ ក៏បាននាំមិត្តរួមថ្នាក់របស់គាត់ ឲ្យដាក់ឈ្មោះថ្មីនោះ ឲ្យបិចទាំងអស់ដែលពួកគេមាន។ រឿងនេះបានក៏បានឮខ្ទរខ្ទាយពេញទីក្រុង។ ទីបំផុត ប្រជាជននៅទូទាំងប្រទេសក៏បានផ្លាស់ប្តូរបៀបដែលពួកគេនិយាយអំពីបិច ដោយសារមនុស្សជាច្រើនបានចាត់ទុករឿងប្រឌិតដែលក្មេងប្រុសនោះបានបង្កើត ជារឿងពិត។

ក្នុងប្រវត្តិសាស្ត្រទាំងមូល មនុស្សមិនល្អឥតខ្ចោះបានបន្តកែប្រែសេចក្តីពិតពីមួយពេលទៅមួយពេល ហើយឱបក្រសោបយកឯណាដែលពួកគេចូលចិត្ត ហើយចាត់ទុកវាជាការពិត។ ទោះជាយ៉ាងណាក៏ដោយ ព្រះគម្ពីរបានចង្អុលបង្ហាញ ឲ្យយើងស្គាល់សេចក្តីពិតតែមួយ ព្រះពិតតែមួយ និងផ្លូវតែមួយទៅកាន់សេចក្តីសង្គ្រោះ គឺព្រះមែស្ស៊ី ដែលសិរីល្អរបស់ព្រះបានសំដែងមក" តាមរយៈទ្រង់ (អេសាយ ៤០:៥)។ ហោរា អេសាយ បានបញ្ជាក់ថា មនុស្សមិនមានភាពស្ថិតស្ថេរ ងាយនឹងធ្វើខុស ហើយមិនអាចពឹងផ្អែកបាន គឺមិនខុសពីស្មៅព្រះហស្តដទៃទៀតដែលមានបាប(ខ.៦-៧)។ គាត់បានមានប្រសាសន៍ថា "ស្មៅក៏ស្វិតក្រៀម ហើយផ្កាពេយរុះចុះ តែព្រះបន្ទូលរបស់ព្រះនៃយើងវាល់គ្នាវិញ នោះស្ថិតស្ថេរនៅជាដរាប" (ខ.៨)។

បទទំនាយរបស់ហោរា អេសាយ អំពីព្រះមែស្ស៊ីដែលត្រូវយាងមក បានផ្តល់ឲ្យយើងនូវមូលដ្ឋានគ្រឹះដ៏រឹងមាំកន្លែងជ្រកកោនដែលមានសុវត្ថិភាព និងក្តីសង្ឃឹមដ៏ជាប់លាប់។ យើងអាចទុកចិត្តលើព្រះបន្ទូលព្រះ ពីព្រោះព្រះយេស៊ូវ គឺជាព្រះបន្ទូលព្រះ (យ៉ូហាន ១:១)។ ព្រះយេស៊ូវជាសេចក្តីពិត ដែលមិនដែលប្រែប្រួលឡើយ។

—Xochitl Dixon

តើអ្នកចង់បដិសេធន៍ការអ្វីដែលព្រះគម្ពីរបានចែង ដោយសារអ្នកដទៃបានទទួលយកការបង្រៀនផ្សេងធ្វើជាសេចក្តីពិត នៅពេលណា? តើការដឹងថា ព្រះយេស៊ូវគឺជាព្រះបន្ទូលព្រះ និងបានសម្រេចព្រះបន្ទូលសន្យា បានកម្សាន្តចិត្តអ្នកយ៉ាងណាខ្លះ?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយទូលបង្គំឲ្យរស់នៅតាមរបៀបដែលធ្វើឲ្យគេដឹងថា ព្រះបន្ទូលក្នុងព្រះគម្ពីរគឺជាសេចក្តីពិតដែលមិនចេះប្រែប្រួល។

Daily Manna 2026_Content Enhance.indd 360 17/11/25 1:47 in the afternoon

គេមិនត្រូវការនឹងចង្កៀងណា ឬពន្លឺព្រះអាទិត្យទេ ពីព្រោះព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងបំភ្លឺគេ (វិវរណៈ ២២:៥)។

បើកបង្ហួចទទួលយកភាពអស្ចារ្យ

លោក រ៉ុន មួរេយ (Ronn Murray) គឺជាជាងថតរូប ដែលចូលចិត្តរដូវរងា។ គាត់បានពន្យល់ថា «នៅរដូវរងា ផ្ទៃមេឃស្រឡះល្អ ធ្វើឲ្យយើងចិត្តស្រស់ស្រាយ ហើយបើកចិត្តទទួលយកអ្វីៗដែលស្រស់ស្អាតអស្ចារ្យ!»

លោក ចន រ៉ុន បានផ្តល់សេវាកម្មនាំផ្លូវភ្ញៀវទេសចរណ៍ ដែលចង់ធ្វើដំណើរកម្សាន្តនៅរដ្ឋអាឡាស្កា ដើម្បីតាមថតរូបទេសភាពពន្លឺដែលគួរឲ្យចាប់អារម្មណ៍បំផុតនៅលើផែនដី គឺជាពន្លឺរាំតំបន់ខាងជើងនៃផែនដី។ លោក ចន រ៉ុន បានបកស្រាយថា ការដកពិសោធន៍ជាមួយទិដ្ឋភាពដ៏អស្ចារ្យនេះ មានលក្ខណៈខាងវិញ្ញាណយ៉ាងខ្លាំង។ គាត់ថា បើអ្នកបានឃើញពន្លឺរាំនៅលើមេឃ ដែលស្រស់ស្អាតយ៉ាងនេះ អ្នកនឹងយល់អ្វីដែលគាត់និយាយ។ ប៉ុន្តែ ពន្លឺរាំនៅពេលយប់ដូចនេះ មិនមែនកើតមានតែតំបន់ខាងជើងនៃផែនដីប៉ុណ្ណោះទេ។ ពន្លឺរាំនៅប្រទេសអូស្ត្រាលី ក៏មានលក្ខណៈដូចពន្លឺរាំនៅតំបន់ខាងជើងស្ទើរទាំងស្រុងគ្រាន់តែខុសគ្នាត្រង់ថា វាកើតមាននៅតំបន់ខាងត្បូង តែជាប្រភេទពន្លឺតែមួយទេ។

ក្នុងការចែកចាយរបស់សាវ័កយ៉ូហានអំពីរឿងថ្ងៃណូអែល គាត់មិនបាននិយាយអំពីក្រាលសត្វ និងពួកអ្នកគង្វាលទេ តែគាត់បាននិយាយអំពីព្រះយេស៊ូវតែម្តង។ គឺដូចដែលគាត់បានពិពណ៌នាថា ព្រះអង្គបានជាពន្លឺនៃមនុស្សលោក (យ៉ូហាន ១:៤)។ ក្រោយមកទៀត នៅពេលដែលសាវ័ក យ៉ូហាន បានសរសេរអំពីទីក្រុងនៅស្ថានសួគ៌ គាត់ក៏បានពិពណ៌នា អំពីប្រភពនៃពន្លឺរបស់ទីក្រុងនោះ។ គាត់ថា «ក្រុងនោះមិនត្រូវការនឹងព្រះអាទិត្យ ឬព្រះចន្ទ សំរាប់នឹងបំភ្លឺទេ ដ្បិតសិរីល្អនៃព្រះបានបំភ្លឺហើយ ឯកូនចៀមក៏ជាចង្កៀងនៃក្រុងនោះដែរ» (វិវរណៈ ២១:២៣)។ ព្រះយេស៊ូវគឺជាប្រភពនៃពន្លឺនោះ គឺជាប្រភពតែមួយ ដែលកណ្ឌគម្ពីរយ៉ូហាន ជំពូក១បានចែង។ ហើយអស់អ្នកដែលបានរស់នៅក្នុងទីលំនៅថ្មីនេះ នៅពេលអនាគត «គេមិនត្រូវការនឹងចង្កៀងណា ឬពន្លឺព្រះអាទិត្យទេ ពីព្រោះព្រះអម្ចាស់ដ៏ជាព្រះទ្រង់នឹងបំភ្លឺគេ» (២២:៥)។

ខណៈពេលដែលការរស់នៅរបស់យើង បានឆ្លុះបញ្ចាំងឲ្យគេស្គាល់ព្រះយេស៊ូវជាពន្លឺនៃលោកីយ៍ ជាអ្នកបង្កើតពន្លឺរាំនៅប៉ូលខាងជើង និងប៉ូលខាងត្បូងនៃផែនដី ចូរយើងបើកបង្ហួចចិត្តយើងទទួលយកអ្វីដែលពិតជាអស្ចារ្យ ដែលព្រះអង្គបានប្រទានមកយើង។—Tim Gustafson

តើចាតុភូតធម្មជាតិធ្វើឲ្យអ្នកមានការស្ងប់ស្ងែងនៅពេលណា និងយ៉ាងដូចម្តេចខ្លះ? តើមានអ្វីបង្វែរអារម្មណ៍អ្នក មិនឲ្យបញ្ចេញពន្លឺរបស់ព្រះ ទៅដល់លោកីយ៍?

ឱព្រះអាទិករនៃចក្រវាលទាំងមូល សូមឲ្យសម្រស់នៃផ្ទៃមេឃនៅពេលយប់បានរំឭកទូលបង្គំថា ព្រះអង្គជាពន្លឺពិតប្រាកដនៃពិភពលោក។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | មីកា ៤-៥ និងវិវរណៈ ១២

ឯយើងវិញ យើងស្រឡាញ់ទ្រង់ ពីព្រោះទ្រង់បានស្រឡាញ់យើងជាមុន (១យ៉ូហាន ៤:១៩)។

សេចក្តីស្រឡាញ់ក្នុងការប្រព្រឹត្ត

កាលខ្ញុំអង្គុយក្បែរមិត្តភក្តិខ្ញុំម្នាក់ឈ្មោះ ម៉ាហ្គារ៉ែត (Margaret) ដែលកំពុងសម្រាកព្យាបាលនៅលើគ្រែ ក្នុងមន្ទីរពេទ្យ ខ្ញុំក៏បានសង្កេតឃើញសកម្មភាពដ៏មមាញឹករបស់អ្នកជំងឺ គ្រូពេទ្យ និងអ្នកមកសួរសុខទុក្ខអ្នកជំងឺផ្សេងទៀត។ ស្ត្រីវ័យក្មេងម្នាក់កំពុងអង្គុយនៅក្បែរម្តាយរបស់គាត់ដែលកំពុងមានជំងឺបានសួរអ្នកស្រី ម៉ាហ្គារ៉ែត ថា «តើមនុស្សដែលមកសួរសុខទុក្ខអ្នក គឺជានរណា?» អ្នកស្រី ម៉ាហ្គារ៉ែត ក៏បានឆ្លើយថា «ពួកគេគឺជាសមាជិកនៃគ្រួសារពួកជំនុំរបស់ខ្ញុំ!» ស្ត្រីវ័យក្មេងរូបនោះក៏បានកត់សម្គាល់ថា គាត់មិនដែលបានឃើញទិដ្ឋភាពបែបនេះពីមុនមកទេ។ គាត់មានអារម្មណ៍ថា ការមកសុខទុក្ខដោយមានគ្នាច្រើនដូចនេះ ហាក់ដូចជា «ក្តីស្រឡាញ់ដ៏ហូរហៀរ»។ អ្នកស្រី ម៉ាហ្គារ៉ែត ក៏បានឆ្លើយតប ដោយទឹកមុខញញឹមថា «សេចក្តីស្រឡាញ់នេះបានកើតចេញពីសេចក្តីស្រឡាញ់របស់ព្រះ ដែលបានបង្ហាញចេញមកតាមរយៈព្រះយេស៊ូវគ្រីស្ទ ជារាជបុត្រានៃព្រះ»។

ការឆ្លើយតបនេះបានធ្វើឲ្យខ្ញុំនឹកចាំ អំពីសាវ័ក យ៉ូហាន ដែលបានសរសេរសំបុត្របីច្បាប់សុទ្ធតែនិយាយអំពីសេចក្តីស្រឡាញ់ កាលគាត់មានវ័យចាស់ហើយ។ ក្នុងសំបុត្រទីមួយ គាត់មានប្រសាសន៍ថា «ព្រះទ្រង់ជាតួសេចក្តីស្រឡាញ់ ឯអ្នកណាដែលនៅជាប់ក្នុងសេចក្តីស្រឡាញ់ នោះក៏បាននៅជាប់ក្នុងព្រះ ហើយព្រះទ្រង់គង់នៅក្នុងអ្នកនោះដែរ» (១យ៉ូហាន ៤:១៦)។ ហេតុនេះហើយ អ្នកដែលទទួលស្គាល់ថា «ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ» (ខ.១៥) នោះព្រះក៏គង់នៅក្នុងពួកគេតាមរយៈ «ព្រះវិញ្ញាណព្រះអង្គ»ផងដែរ(ខ.១៣)។ តើយើងអាចយកចិត្តទុកដាក់ចំពោះអ្នកដទៃ ដោយសេចក្តីស្រឡាញ់យ៉ាងដូចម្តេចខ្លះ? «យើងស្រឡាញ់គេបាន ដោយសារព្រះអង្គស្រឡាញ់យើងជាមុន» (ខ.១៩)។

ដោយសារអំណោយនៃសេចក្តីស្រឡាញ់របស់ព្រះ ការទៅសួរសុខទុក្ខអ្នកស្រី ម៉ាហ្គារ៉ែត មិនបានធ្វើឲ្យខ្ញុំ និងអ្នកដទៃទៀតក្នុងពួកជំនុំខ្ញុំ មានអារម្មណ៍ថាពិបាកឡើយ។ ខ្ញុំបានទទួលលើសពីលទ្ធភាពដែលខ្ញុំបានឲ្យដល់គេ មិនគ្រាន់តែទទួលបានពីអ្នកស្រី ម៉ាហ្គារ៉ែត តែក៏តាមរយៈការសង្កេតមើលការធ្វើបន្ទាល់ដ៏សុភាពរបស់គាត់អំពីព្រះយេស៊ូវ ជាព្រះអង្គសង្គ្រោះ។ តើព្រះអម្ចាស់អាចបង្ហាញសេចក្តីស្រឡាញ់ចំពោះអ្នកដទៃ តាមរយៈអ្នកដូចម្តេចខ្លះនៅថ្ងៃនេះ?—Amy Boucher Pye

តើអ្នកមានការភ្ញាក់ផ្អើលចំពោះនរណាម្នាក់ ដែលបានសង្កេតឃើញសេចក្តីស្រឡាញ់របស់ព្រះក្នុងជីវិតអ្នក នៅពេលណា? តើសេចក្តីស្រឡាញ់របស់ព្រះអង្គបានបណ្តាលចិត្តអ្នកឲ្យបម្រើអ្នកដទៃ ដូចម្តេចខ្លះ?

ឱព្រះនៃសេចក្តីស្រឡាញ់ ទូលបង្គំស្រឡាញ់អ្នកដទៃ ដោយសារព្រះអង្គស្រឡាញ់ទូលបង្គំជាមុន។ សូមព្រះអង្គបន្តបង្កើនសេចក្តីស្រឡាញ់របស់ទូលបង្គំ ដើម្បីឲ្យព្រះវិញ្ញាណព្រះអង្គបញ្ចេញពន្លឺតាមរយៈទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | មីកា ៦-៧ និងវិវរណៈ ១៣

ត្រូវឲ្យយើងពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្តាលឲ្យមានសេចក្តីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង (ហេព្រើរ ១០:២៤)។

ក្តីប្រាថ្នាធំសម្រាប់មិត្តភក្តិ

លោក ចន គ្រូក្រេកូរី (Gregory) មកពីទីក្រុងណាហ្សៀនហ្សឺស និងលោកគ្រូ បាសហ្ស៊ីល (Basil) មកពីក្រុងស៊ីសារា គឺជាអ្នកដឹកនាំដែលមានកេរ្តិ៍ឈ្មោះល្អ ក្នុងពួកជំនុំនៅសតវត្សរ៍ទី៤ និងជាមិត្តជិតស្និទ្ធផងដែរ។ អ្នកទាំងពីរបានជួបគ្នា កាលពួកគេកំពុងរៀនមុខវិជ្ជាទស្សនវិជ្ជា ហើយក្រោយមកលោកគ្រូ ក្រេកូរី ក៏បានមានប្រសាសន៍ថា គាត់និងលោក ចន បាហ្ស៊ីល បានប្រែក្លាយជា «រូបកាយពីរ ដែលមានវិញ្ញាណតែមួយ»។

ផ្លូវនៃអាជីពរបស់ពួកគេមានភាពស្រដៀងគ្នាយ៉ាងខ្លាំង បានជាការប្រជែងគ្នាមិនអាចកើតមាន រវាងអ្នកទាំងពីរបានទេ។ លោកគ្រូ ក្រេកូរី ក៏បានពន្យល់ថា ពួកគាត់បានជឿសវាងការល្បួងដែលនាំឲ្យប្រជែងគ្នា ដោយមាន «ក្តីប្រាថ្នាធំតែមួយ» ដែលចង់បានជីវិតដែលមានជំនឿ ក្តីសង្ឃឹម និងការប្រព្រឹត្តល្អ បន្ទាប់មក «លើកទឹកចិត្តគ្នាទៅវិញទៅមក» ឲ្យកាន់តែមានជោគជ័យក្នុងគោលដៅនេះ ជាជាងជោគជ័យតែម្នាក់ឯង។ ជាលទ្ធផល អ្នកទាំងពីរបានចម្រើនឡើងក្នុងជំនឿ ហើយក៏បានក្លាយជាអ្នកដឹកនាំកម្រិតខ្ពស់ ដោយគ្មានការប្រជែងគ្នាឡើយ។

កណ្ឌគម្ពីរហេព្រើរ ត្រូវបាននិពន្ធឡើង ដើម្បីជួយយើង ឲ្យរឹងមាំក្នុងជំនឿ (ហេព្រើរ ២:១) ដោយលើកទឹកចិត្តយើងឲ្យផ្តោតចិត្តទៅលើ «ក្តីសង្ឃឹម ដែលយើងបានចែកចាយ» ហើយ «លើកទឹកចិត្តគ្នាទៅវិញទៅមក ឲ្យមានសេចក្តីស្រឡាញ់ និងការប្រព្រឹត្តល្អ» (១០:២៣-២៤)។ កណ្ឌគម្ពីរហេព្រើរបានបង្គាប់យើងឲ្យអនុវត្តន៍ដូចនេះ មិនគ្រាន់តែនៅក្នុងបរិបទនៃពួកជំនុំប៉ុណ្ណោះទេ (ខ.២៥) ប៉ុន្តែលោកគ្រូ ក្រេកូរី និងលោកគ្រូ បាហ្ស៊ីល ក៏បានអនុវត្តនក្នុងមិត្តភាពផងដែរ ដោយបង្ហាញឲ្យយើងដឹងអំពីរបៀបដែលមិត្តភក្តិអាចលើកទឹកចិត្តគ្នាទៅវិញទៅមក ឲ្យលូតលាស់ និងជៀសវាង «ឫសនៃចិត្តជូរល្វីង» ដែលមានដូចជាការប្រជែងគ្នា ដែលអាចកើតមាន (១២:១៥)។

ចុះបើសិនជាក្នុងមិត្តភាពរបស់យើង យើងមានក្តីប្រាថ្នាធំមួយ ដែលចង់បានការរស់នៅដោយជំនឿ ក្តីសង្ឃឹម និងការប្រព្រឹត្តល្អ ហើយលើកទឹកចិត្តមិត្តភក្តិយើងឲ្យកាន់តែមានភាពជោគជ័យក្នុងគោលដៅនេះ ជាជាងខំប្រឹងជោគជ័យតែម្នាក់ឯង? ព្រះវិញ្ញាណបរិសុទ្ធបានត្រៀមជាស្រេចដើម្បីជួយយើង ឲ្យអនុវត្តដូចនេះ។

—Sheridan Voysey

តើអ្នកបានមើលឃើញគុណសម្បត្តិអ្វីខ្លះ នៅក្នុងមិត្តភាពរបស់លោកគ្រូក្រេកូរី និងលោកគ្រូបាហ្ស៊ីល? តើអ្នកអាចលើកទឹកចិត្តមិត្តភក្តិរបស់អ្នកឲ្យចម្រើនឡើងក្នុងជំនឿ សេចក្តីសង្ឃឹម និងការប្រព្រឹត្តល្អ ដោយរបៀបណា?

ឱព្រះយេស៊ូវ សូមព្រះអង្គជួយឲ្យមិត្តភាពរបស់ទូលបង្គំមានការចម្រើនឡើង ក្នុងជំនឿ ក្តីសង្ឃឹម និងការប្រព្រឹត្តល្អ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | ណាហ៊ូម ១-៣ និងវិវរណៈ ១៤

គេមានសេចក្តីអំណរជាខ្លាំងក្រៃ ដោយឃើញផ្កាយនោះ (ម៉ាថាយ ២:១០)។

ពន្លឺដែលព្រះគ្រីស្ទបានប្រទាន

ជានិច្ចជាកាល ខ្ញុំនិងស្វាមីរបស់ខ្ញុំតែងតែមានចិត្តរីករាយនៅក្នុងការចូលរួមកម្មវិធីណូអែល នៅព្រះវិហាររបស់យើង ជារៀងរាល់ឆ្នាំ។ កាលយើងទើបតែបានរៀបការបានប៉ុន្មានឆ្នាំ យើងបានបង្កើតប្រពៃណីពិសេសមួយប្រចាំគ្រួសារ ដោយស្លៀកពាក់ខោអាវរងា បន្ទាប់ពីកម្មវិធីណូអែលចប់ ហើយក៏បានឡើងភ្នំតូចមួយនៅក្បែរផ្ទះយើង ដែលនៅលើនោះ មានអំពូលភ្លើង៣៥គ្រាប់ ដែលគេបានចងព្យួរនៅលើបង្គោលខ្ពស់ៗ បង្កើតបានរូបរាងដូចផ្កាយ។ ជាញឹកញាប់ យើងឈរនៅលើព្រំលនៅទីនោះ មើលទៅទីក្រុងពីចម្ងាយ ដោយជញ្ជឹងគិតអំពីការប្រសូតដ៏អស្ចារ្យរបស់ព្រះយេស៊ូវ។ នៅពេលនោះ មនុស្សជាច្រើននៅទីក្រុងស្ថិតនៅក្នុងជ្រលងភ្នំ ក៏បានមើលមកអំពូលភ្លើងដែលមានរាងដូចផ្កាយនោះផងដែរ។

ផ្កាយនោះបានធ្វើឲ្យយើងនឹកចាំ អំពីការប្រសូតរបស់ព្រះអង្គសង្គ្រោះរបស់យើង។ ព្រះគម្ពីរបានចែងថា ពួកហោរ «មកពីទិសខាងកើត» បានមកដល់ទីក្រុងយេរូសាឡិម ដោយស្វែងរក «ព្រះអង្គដែលប្រសូតមក ធ្វើជាស្តេចសាសន៍យូដា» (ម៉ាថាយ ២:១-២)។ ពួកគេបានមើលឃើញផ្កាយនោះ ដែលបានរះឡើងនៅលើមេឃ (ខ.២)។ ការធ្វើដំណើររបស់ពួកគេបានបន្តពីទីក្រុងយេរូសាឡិមទៅភូមិបេថ្លេហិម ដោយផ្កាយនោះបាន «នាំមុខគេ ដរាបដល់ចំពីលើកន្លែងដែលបុត្រតូចនៅ ទើបឈប់» (ខ.៩)។ នៅទីនោះ ពួកគេក៏បាន «ក្រាបថ្វាយបង្គំ» ព្រះអង្គ (ខ.១១)។

ព្រះគ្រីស្ទ គឺជាប្រភពនៃពន្លឺក្នុងជីវិតយើង ទាំងក្នុងន័យធៀប (ធ្វើជាអ្នកនាំផ្លូវយើង) ក៏ដូចជាក្នុងន័យត្រង់ដោយព្រះអង្គជាអ្នកបង្កើតព្រះអាទិត្យ ស្ថានព្រះច័ន្ទ និងផ្កាយទាំងអស់នៅលើមេឃ (កូល៉ុស ១:១៥-១៦)។ ដែលពួកហោរមានក្តីអំណរជាយ៉ាងណា ពេលដែលបានឃើញផ្កាយរបស់ព្រះអង្គ (ម៉ាថាយ ២:១០) នោះយើងក៏គួរតែមានអំណរជាពន់ពេក ដែលបានដឹងថា ព្រះអង្គគឺជាព្រះអង្គសង្គ្រោះ ដែលបានយាងចុះមកពីស្ថានសួគ៌ មកគង់នៅក្នុងចំណោមយើង។ «យើងរាល់គ្នាបានឃើញសិរីល្អទ្រង់!» (យ៉ូហាន ១:១៤)។—Kirsten Holmberg

តើព្រះយេស៊ូវបានប្រទានពន្លឺដល់ជីវិតអ្នក ដូចម្តេចខ្លះ? តើអ្នកអាចចែកចាយអំពីរឿងនេះដល់នរណាខ្លះ នៅថ្ងៃនេះ?

ឱព្រះយេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានធ្វើជាពន្លឺនៃជីវិតទូលបង្គំ។

Daily Manna 2026_Content Enhance.indd 364 17/11/25 1:47 in the afternoon

គឺអ្នករាល់គ្នានឹងឃើញព្រះឱរស១រុំនឹងសំពត់ផ្តេកនៅក្នុងស្នូក (លូកា ២:១២)។

ស្វាគមន៍ការប្រសូតរបស់ព្រះយេស៊ូវ

ក្រុមគ្រួសារខ្ញុំបានទន្ទឹងរង់ចាំដំណឹងល្អ ពីអ្នកជិតខាងរបស់យើងម្នាក់ដែលមានផ្ទៃពោះ ដោយចិត្តអន្ទះសា ខណៈពេលដែលគាត់កំពុងត្រៀមខ្លួនស្វាគមន៍កូនដំបូង។ ទីបំផុត យើងក៏បានឃើញផ្លាកនៅមុខផ្ទះមានអក្សរសរសេរពីលើ ឲ្យយើងដឹងថា គាត់ប្រសូតបានកូនស្រីម្នាក់។ យើងក៏បានអបអរកំណើតរបស់កូនស្រីរបស់ពួកគេ ហើយក៏បានផ្ញើសារទៅកាន់មិត្តភក្តិ ដែលប្រហែលជាមិនទាន់បានឃើញការតុបតែងនៅក្រៅផ្ទះនោះ។

ភាពរំភើបរីករាយបំផុតបានកើតមាន ក្នុងការរង់ចាំការចាប់កំណើតរបស់ទារកម្នាក់ កាលជាង២ពាន់ឆ្នាំមុន។ មុនពេលព្រះយេស៊ូវយាងចុះពីស្ថានសួគ៌យកកំណើតជាមនុស្ស ប្រជាជនយូដាមិនបានរង់ចាំការប្រសូតរបស់ព្រះមែស្ស៊ី តែពីរបីខែនោះឡើយ តែពួកគេបានទន្ទឹងរង់ចាំការប្រសូតរបស់ព្រះអង្គ ជាព្រះសង្គ្រោះអស់ជាច្រើនជំនាន់មកហើយ។ ខ្ញុំស្រមៃថា ជនជាតិយូដាដែលមានចិត្តស្មោះត្រង់ចំពោះព្រះប្រហែលជាឆ្ងល់ថា តើពួកគេនឹងបានឃើញព្រះបន្ទូលសន្យាបានសម្រេច កាលពួកគេនៅមានជីវិតឬយ៉ាងណាទេ។

នៅពេលយប់មួយនោះ មានទេវតាមួយអង្គបានបង្ហាញខ្លួន ឲ្យពួកអ្នកគង្វាលចៀមបានឃើញនៅបេថ្លេហិម ហើយបានប្រកាសឲ្យពួកគេដឹងថា ព្រះមែស្ស៊ីបានប្រសូតហើយ។ ទេវតាប្រាប់ពួកគេជាលម្អិតថា «នេះជាទីសម្គាល់ដល់អ្នករាល់គ្នា គឺអ្នករាល់គ្នានឹងឃើញព្រះឱរស១រុំនឹងសំពត់ផ្តេកនៅក្នុងស្នូក» (លូកា ២:១២)។ បន្ទាប់ពីពួកអ្នកគង្វាលបានឃើញព្រះយេស៊ូវហើយ ពួកគេក៏បានសរសើរតម្កើងព្រះ ហើយទៅប្រាប់អ្នកដទៃទៀតឲ្យបានដឹងអំពីការប្រសូតរបស់ព្រះអង្គ (ខ.១៧)។

ព្រះអម្ចាស់សព្វព្រះទ័យឲ្យអ្នកគង្វាលដឹងថា បុត្រតូចដែលគេបានរង់ចាំជាយូរមកហើយ បានប្រសូតហើយ ដូចនេះពួកគេអាចទៅប្រាប់អ្នកដទៃ ឲ្យបានដឹងអំពីការប្រសូតរបស់ព្រះយេស៊ូវផងដែរ។ យើងនៅតែអបអរការប្រសូតរបស់ព្រះអង្គ ព្រោះព្រះជន្មរបស់ព្រះអង្គ បានផ្តល់ឲ្យអ្នកជឿព្រះអង្គនូវសេចក្តីសង្គ្រោះរួចផុតពីភាពប្រែបែករបស់លោកីយ៍។ ព្រះអង្គបានយាងមកឲ្យយើងស្គាល់សន្តិភាព ហើយដកពិសោធន៍នឹងក្តីអំណរដ៏ស្ថិតស្ថេរ។ នេះជាដំណឹងល្អដែលសក្តិសមនឹងឲ្យយើងប្រកាសឲ្យអ្នកដទៃបានដឹង!—Lisa M. Samra

តើអ្នកយល់ឃើញថា ពួកអ្នកគង្វាលមានអារម្មណ៍យ៉ាងណា នៅពេលដែលបានឮដំណឹងអំពីការប្រសូតរបស់ព្រះយេស៊ូវ? តើអ្នកអាចចែកចាយដំណឹងល្អ អំពីការប្រសូតរបស់ព្រះអង្គដល់អ្នកដទៃ ដូចម្តេចខ្លះ?

ឱព្រះយេស៊ូវ យើងខ្ញុំចង់ឲ្យមនុស្សម្នាក់ៗបានដឹងថា ការប្រសូតរបស់ព្រះអង្គ គឺជាដំណឹងល្អ។

Daily Manna 2026_Content Enhance.indd 365 17/11/25 1:47 in the afternoon

ឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំបានទូលតបថា ទូលបង្គំនឹងស្វែងរកព្រះភក្ត្រទ្រង់ពិត (ទំនុកតម្កើង ២៧:៨)។

ការជួបជាមួយព្រះ

ឆ្នាំ ២០២២ ជាឆ្នាំដែលពិសេសណាស់ សម្រាប់ខ្ញុំ និងភរិយាខ្ញុំ។ នៅឆ្នាំនោះ ចៅស្រីរបស់យើង ឈ្មោះ សូហ្វៀ អាស្សលី (Sophia Ashley) បានចាប់កំណើត ជាចៅស្រីតែមួយ ក្នុងចំណោមចៅទាំង៨នាក់ របស់យើង។ តាយាយរបស់សូហ្វៀ បានញញឹមបិតមាត់មិនជិត ពេលបានទទួលដំណឹងដ៏ល្អនេះ។ នៅពេល ដែលកូនប្រុសរបស់យើងបានទូរស័ព្ទមកយើង ដោយបើកវីដេអូមើលមុខគ្នាឃើញ យើងមានចិត្តរំភើបរីករាយ កាន់តែខ្លាំង។ ខ្ញុំមិនបាននៅក្នុងបន្ទប់ជាមួយភរិយារបស់ខ្ញុំទេ តែសម្លេងស្រែកហោរដោយអំណរ បានបង្ហាញថា គាត់កំពុងតែបានឃើញមុខចៅស្រីគាត់ជាលើកដំបូងនៅក្នុងទូរស័ព្ទ។ សព្វថ្ងៃនេះ យើងអាចមើលឃើញមនុស្ស ដែលយើងស្រឡាញ់ពីចម្ងាយ ដោយគ្រាន់តែចុចទូរស័ព្ទតេទៅពួកគេប៉ុណ្ណោះ។

ការមើលឃើញមុខមនុស្ស ដែលយើងកំពុងជជែកជាមួយតាមទូរស័ព្ទ គឺជាលទ្ធភាពដែលមនុស្សទើបតែ អាចធ្វើបាន ក្នុងសម័យទំនើប ប៉ុន្តែការសន្ទនាជាមួយព្រះក្នុងការអធិស្ឋាន ដោយដឹងថា ខ្លួនកំពុងស្ថិតក្នុងព្រះ វត្តមានព្រះអង្គ មិនមែនជាអ្វីដែលមនុស្សទើបតែអាចធ្វើបាននោះឡើយ។ ការអធិស្ឋានរបស់ស្តេច ដាវីឌ ក្នុង កណ្ឌគម្ពីរទំនុកតម្កើង ជំពូក២៧ បានធ្វើឡើង ក្នុងពេលដែលមានការទាស់ប្រឆាំងបានជាទ្រង់ត្រូវការជំនួយ លើសពីលទ្ធភាពដែលមិត្តសំឡាញ់ជាមនុស្សអាចផ្តល់ឲ្យបាន (ខ.១០-១២)។ គឺដូចដែលទ្រង់មានបន្ទូលថា «កាលទ្រង់បានមានព្រះបន្ទូលថា ចូរស្វែងរកមុខអញនោះ ឱព្រះយេហូវ៉ាអើយ ចិត្តទូលបង្គំបានទូលតបថា ទូលបង្គំនឹងស្វែងរកព្រះភក្ត្រទ្រង់ពិត» (ខ.៨)។

ពេលដ៏បំបាកជំរុញចិត្តយើងឲ្យ «ស្វែងរកព្រះភក្ត្រព្រះអង្គ» (ខ.៨)។ យើងអាចមានក្តីអំណរដ៏ពោរពេញ នៅចំពោះព្រះអង្គ ហើយ «នៅព្រះហស្តស្តាំទ្រង់ មានសេចក្តីអរសប្បាយជាដរាបតទៅ» (១៦:១១)។ ប៉ុន្តែ យើងអាចប្រកបស្និទ្ធស្នាល និងសន្ទនាជាមួយព្រះអង្គ មិនគ្រាន់តែនៅពេលដែលយើង មានទុក្ខលំបាកប៉ុណ្ណោះឡើយ។ ព្រះអង្គបានហៅយើង ឲ្យចូលមកជជែកជាមួយព្រះអង្គ គ្រប់ពេលវេលា។

—Arthur Jackson

តើអ្នកមានចិត្តចង់ជួបព្រះអង្គខ្លាំងបំផុត នៅពេលណានៅថ្ងៃនីមួយៗ? តើការប្រកបស្និទ្ធស្នាលជាទៀង ទាត់ជាមួយព្រះអង្គ បានជួយឲ្យអ្នកប្រឈមមុខដាក់បញ្ហានៅថ្ងៃនីមួយៗ យ៉ាងដូចម្តេចខ្លះ?

ឱព្រះវរបិតា ដែលគង់នៅស្ថានសួគ៌ ទូលបង្គំសូមសរសើរតម្កើងព្រះអង្គ ដែលបានប្រទានឯកសិទ្ធិឲ្យទូលបង្គំ ជួបជាមួយព្រះអង្គជារៀងរាល់ថ្ងៃ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យត្រៀមខ្លួនជាស្រេច ដើម្បីចំណាយពេលជាមួយព្រះអង្គ ក្នុងការអធិស្ឋាន។

Daily Manna 2026_Content Enhance.indd 366 17/11/25 1:47 in the afternoon

មិនត្រូវប្រហារគេទេ... សូមដាក់នំបុ័ង និងទឹកមកនៅមុខគេឲ្យបរិភោគវិញ (២ពង្សាវតារក្សត្រ ៦:២២)។

ប្រព្រឹត្តដោយអធ្យាស្រ័យ

ក្នុងសៀវភៅរឿងប្រលោមលោកមានចំណងជើងថា ដំណឹងអំពីកូនស្រី លោក ដាវីដ វីងគ្លឺរ (David Winkler) ចង់រកឃើញស្វែងរកកូនស្រីរបស់គាត់ ដែលបានរត់ចេញពីផ្ទះ ហើយមានតែលោក ហឺមឹន សៀលើរ (Herman Sheeler) ម្នាក់គត់ ដែលអាចជួយគាត់បាន។ ប៉ុន្តែ គាត់មានបញ្ហាមួយ។ កូនស្រីរបស់លោក ដាវីឌ គឺជាកូនដែលបានកើតពីអំពើផិតក្បត់របស់លោក ដាវីឌ ជាមួយភរិយារបស់លោក ហឺមឹន ហើយលោក ហឺមឹន ក៏បានព្រមានលោក ដាវីឌ មិនឲ្យទាក់ទងក្រុមគ្រួសាររបស់លោក ហឺមឹន ទៀតឡើយ។

ប៉ុន្មានទសវត្សរ៍ក្រោយមក លោក ដាវីឌ ក៏បានសរសេរសំបុត្រផ្ញើទៅលោក ហឺមឹន ដើម្បីសុំទោស ចំពោះការអ្វីដែលគាត់បានធ្វើ។ គាត់ក៏បានអង្វរលោក ចន ហឺមឹន ឲ្យប្រាប់គាត់អំពីទីកន្លែងរបស់កូនស្រីគាត់។ គាត់ប្រាប់លោក ចន ហឺមឹនថា «ខ្ញុំមានចន្លោះប្រហោងមួយក្នុងជីវិតខ្ញុំ ព្រោះខ្ញុំបានដឹងតិចតួចណាស់អំពីកូនស្រីខ្ញុំ»។ គាត់ក៏បានរង់ចាំមើល តើលោក ចន ហឺមឹន នឹងជួយគាត់ឬទេ។

តើយើងគួរតែប្រព្រឹត្តចំពោះមនុស្សដែលបានធ្វើខុសមកលើយើង យ៉ាងដូចម្តេចខ្លះ? ស្តេចអ៊ីស្រាអែលមួយអង្គបានប្រឈមមុខដាក់សំណួរនេះ នៅពេលដែលខ្មាំងសត្រូវរបស់គាត់បានធ្លាក់ចូលក្នុងកណ្តាប់ដៃគាត់ (២ពង្សាវតារក្សត្រ ៦:៨-២០)។ គាត់ក៏បានទូលសួរហោរា អេលីសេ ថា តើទ្រង់គួរតែសម្លាប់ពួកគេឬយ៉ាងណា? ហោរា អេលីសេ ក៏បានប្រាប់ទ្រង់ឲ្យទុកជីវិតឲ្យពួកគេ ហើយថែមទាំងដាក់អាហារ និងទឹកនៅពីមុខពួកគេ ដើម្បីឲ្យពួកគេបានបរិភោគហើយវិលត្រឡប់ទៅម្ចាស់របស់ពួកគេវិញ (ខ.២១-២២)។ តាមរយៈការប្រព្រឹត្តដោយការលើកលែងទោសដូចនេះ នគរអ៊ីស្រាអែលទទួលបានសន្តិភាពជាមួយខ្មាំងសត្រូវរបស់ខ្លួន (ខ.២៣)។

លោក ចន ហឺមឹន ក៏បានឆ្លើយតបសំបុត្ររបស់លោក ចន ដាវីឌ ដោយអញ្ជើញលោក ចន ដាវីឌ ឲ្យមកផ្ទះគាត់ ហើយរៀបចំម្ហូបអាហារទទួលលោក ចន ដាវីឌ។ មុនពេលបរិភោគអាហារជុំគ្នា គាត់ក៏បានអធិស្ឋានថា «ព្រះអម្ចាស់យេស៊ូវ ទូលបង្គំសូមអរព្រះគុណព្រះអង្គ សម្រាប់ការថែរក្សាទូលបង្គំ និងលោក ចន ដាវីឌ ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ»។ លោក ចន ហឺមឹន ក៏បានជួយលោក ចន ដាវីឌ ស្វែងរកកូនស្រី ហើយក្រោយមក លោក ចន ដាវីឌ ក៏បានជួយសង្គ្រោះជីវិតលោក ចន ហឺមិន។ ក្នុងព្រះហស្តរបស់ព្រះ ការប្រព្រឹត្តដោយការអធ្យាស្រ័យ ចំពោះអ្នកដែលបានធ្វើខុសមកលើយើង ច្រើនតែនាំឲ្យយើងទទួលបានព្រះពរ លើសពីការរំពឹងគិតរបស់យើង។—Sheridan Voysey

តើអ្នកបានទទួលការបណ្តាលចិត្ត ពីនរណាខ្លះដែលបានប្រព្រឹត្តដោយការអធ្យាស្រ័យ? តើអ្នកអាចប្រព្រឹត្តដោយអធ្យាស្រ័យ ចំពោះនរណាខ្លះនៅថ្ងៃនេះ?

ឱព្រះយេស៊ូវ សូមព្រះអង្គប្រទានទូលបង្គំប្រាជ្ញា និងកម្លាំងនៅថ្ងៃនេះ ដើម្បីឲ្យទូលបង្គំអត់ឱនទោសឲ្យអ្នកដែលធ្វើខុសមកលើទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | សេចក្តីទំនុកដំកើង ១-៤ និងវិវរណៈ ១៨

ដោយសារសេចក្តីជំនឿ កាលម៉ូសេបានកើតមក នោះឪពុកម្តាយបានលាក់លោក ចន ទុក៣ខែ ឥតមានទឹកខ្លាចដល់បញ្ញត្តរបស់ស្តេចឡើយ (ហេព្រើរ ១១:២៣)។

បោះជំហានទៅមុខដោយជំនឿ

លោក ចន (John) មានការបាក់ទឹកចិត្តយ៉ាងខ្លាំង នៅពេលដែលគាត់បាត់បង់ការងារ។ គាត់កំពុងធ្វើដំណើរឆ្ពោះទៅរក ចុងបញ្ចប់នៃអាជីពរបស់គាត់ ហើយគាត់ដឹងថា គាត់នឹងមានការពិបាកក្នុងការចាប់ផ្តើមការងារថ្មី។ គាត់ក៏បានចាប់ផ្តើមអធិស្ឋានសូមឲ្យគាត់មានការងារល្អ។ បន្ទាប់មក លោក ចន ក៏បានធ្វើប្រវត្តិរូបសារជាថ្មី និងអានអត្ថបទណែនាំអំពីគន្លឹះក្នុងការសម្ភាស និងបានទូរស័ព្ទទៅកាន់ក្រុមហ៊ុនជាច្រើន។ បន្ទាប់ពីគាត់បានដាក់ពាក្យធ្វើការបានប៉ុន្មានសប្តាហ៍ គាត់ក៏បានទទួលយកមុខនាទីថ្មីមួយ ដែលមានកាលវិភាគល្អយ៉ាងខ្លាំង និងមានភាពងាយស្រួលក្នុងការធ្វើដំណើរទៅធ្វើការ។ ការស្តាប់បង្គាប់ដ៏ស្មោះត្រង់របស់គាត់ និងការផ្គត់ផ្គង់របស់ព្រះបានដើរទន្ទឹមគ្នាយ៉ាងល្អឥតខ្ចោះ។

មានរឿងដែលគួរឲ្យចាប់អារម្មណ៍ជាងនេះទៀត បានកើតឡើងចំពោះអ្នកស្រីយ៉ូកិបិត (និក្ខមនំ ៦:២០) និងក្រុមគ្រួសារគាត់ ក្នុងអំឡុងពេលប្រជាជនអ៊ីស្រាអែលកំពុងរស់ជានៅជាទាសករ ក្នុងទឹកដីអេស៊ីព្ទ។ នៅពេលដែលស្តេច ផារ៉ោន បានចេញច្បាប់ ដែលតម្រូវឲ្យជនជាតិហេព្រើរបោះកូនប្រុសដែលទើបនឹងកើត ចូលទៅក្នុងទឹកទន្លេ (១:២២) អ្នកស្រី យ៉ូកិបិត មុខជាមានការភិតភ័យយ៉ាងខ្លាំង។ គាត់មិនអាចកែប្រែច្បាប់នោះបានទេ តែមានកិច្ចការខ្លះដែលគាត់ត្រូវធ្វើជាជំហានៗ ដើម្បីស្តាប់បង្គាប់តាមព្រះ និងសង្គ្រោះកូនប្រុសគាត់។ ដោយសេចក្តីជំនឿ គាត់ក៏បានលាក់កូនប្រុសគាត់ មិនឲ្យពួកសាសន៍អេស៊ីព្ទដឹង។ គាត់ក៏បានធ្វើកូនទូកពីដើមបបុស ដាក់កូនគាត់ចូលទៅក្នុងកូនទូកនោះ ហើយបណ្តែតវានៅគុម្ពត្រែងនៅមាត់ទន្លេ (២:៣)។ ព្រះអម្ចាស់ក៏បានថែរក្សាជីវិតទារកនោះ ដោយការអស្ចារ្យ (ខ.៥-១០) ហើយក្រោយមក ព្រះអង្គក៏បានប្រើគាត់ ឲ្យរំដោះប្រជាជនអ៊ីស្រាអែលទាំងអស់ឲ្យរួចផុតពីរបបទាសភាព (៣:១០)។

រឿងរបស់លោក ចន និងរឿងរបស់អ្នកស្រីយ៉ូកិបិត បាននិយាយអំពីការបោះជំហានទៅមុខ តាមរបៀបផ្សេងគ្នា តែ ដោយសេចក្តីជំនឿដូចគ្នា។ ការភ័យខ្លាចអាចធ្វើឲ្យយើងរកធ្វើអ្វីមិនកើត។ ទោះលទ្ធផលដែលយើងទទួលបានមិនដូចអ្វីដែលយើងបានរំពឹងចង់បាន ឬសង្ឃឹមថានឹងបានក៏ដោយ ក៏សេចក្តីជំនឿចម្រើនកម្លាំងយើង ឲ្យបន្តទុកចិត្តលើសេចក្តីល្អរបស់ព្រះ ទោះយើងបានទទួលលទ្ធផលដូចម្តេចក៏ដោយ។—Karen Pimpo

តើអ្នកបានជាប់គាំង នៅក្នុងការភ័យខ្លាច និងការព្រួយបារម្ភនៅពេលណា? តើអ្នកអាចបោះជំហានបន្ទាប់ ដោយចិត្តស្មោះត្រង់ដូចម្តេចខ្លះ ដើម្បីថ្វាយព្រះកិត្តិនាមដល់ព្រះ?

ឱព្រះអម្ចាស់ សូមព្រះអង្គជួយទូលបង្គំឲ្យបោះជំហានទៅមុខ ដោយចិត្តស្មោះត្រង់ តាមផ្លូវដែលព្រះអង្គបានរៀបចំសម្រាប់ទូលបង្គំ។

Daily Manna 2026_Content Enhance.indd 368 17/11/25 1:47 in the afternoon

រួចនិយាយគ្នាថា ចូរយើងសង់ទីក្រុង១សំរាប់យើង និងប៉ម១ដែលខ្ពស់ដល់ផ្ទៃមេឃ ដើម្បីឲ្យយើងបានកេរ្តិ៍ឈ្មោះ (លោកុប្បត្តិ ១១:៤)។

សាងសង់អ្វីដែលស្ថិតស្ថេរ

កាលពីក្មេង ក្រុមគ្រួសារខ្ញុំរស់នៅក្បែរការដ្ឋានសំណង់មួយចំនួន ក្នុងរដ្ឋអូហៃយ៉ូ។ ដោយសារខ្ញុំ និងមិត្តភក្តិរបស់ខ្ញុំចូលចិត្តមើលគេសាងសង់អគារ យើងក៏បានដើររើសសម្ភារៈសំណង់ដែលគេបោះចោល ដើម្បីសាងសង់បន្ទាយទ័ព ជាការកម្សាន្តសប្បាយ។ យើងក៏បានខ្ចីឧបករណ៍ជាងពីឪពុកម្តាយរបស់យើង និងលើសែងឈើ ហើយចំណាយពេលជាច្រើនថ្ងៃ ក្នុងការសាងសង់ ដើម្បីសម្រេចគោលបំណងរបស់យើង។ វាជាសកម្មភាពដ៏សប្បាយរីករាយ ប៉ុន្តែការប្រឹងប្រែងរបស់យើងក្នុងការសាងសង់ តាមគំរូអគារនៅជុំវិញយើង មិនបានទទួលលទ្ធផលល្អទេ។ សំណង់របស់យើងមិនស្ថិតស្ថេរបានយូរឡើយ។

កណ្ឌគម្ពីរលោកុប្បត្តិ ជំពូក១១ បានចែងអំពីគម្រោងសាងសង់ធំមួយ ដែលមនុស្សនៅផែនដីរួមគ្នាធ្វើ។ ពួកគេនិយាយគ្នាថា “ចូរយើងសង់ទីក្រុង១សំរាប់យើង និងប៉ម១ដែលខ្ពស់ដល់ផ្ទៃមេឃ ដើម្បីឲ្យយើងបានកេ្តីឈ្មោះ” (ខ.៤)។ ការប្រឹងប្រែងរបស់ពួកគេមានបញ្ហាធំមួយស្ថិតនៅត្រង់ថា ពួកគេធ្វើការសាងសង់នោះ ដើម្បីឲ្យពួកគេបានកេ្តីឈ្មោះល្បីប៉ុណ្ណោះ (ខ.៤)។

នេះជាបញ្ហាដែលកើតឡើងម្តងហើយម្តងទៀត ចំពោះមនុស្ស ដោយសារយើងចូលចិត្តកសាងវិមានសម្រាប់ខ្លួនឯង និងដើម្បីបង្ហាញភាពជោគជ័យរបស់យើង។ ព្រះគម្ពីរក៏បានចែងអំពីសម័យក្រោយមកទៀត ដែលមានស្តេចមួយអង្គព្រះនាម សាឡូម៉ូន បានសាងសង់ព្រះវិហារថ្វាយព្រះអម្ចាស់ ដោយបំណងចិត្តខុសពីមនុស្សដែលសាងសង់ប៉មបាបិល។ គឺដូចទ្រង់មានបន្ទូលថា “មើល ទូលបង្គំបានគិតសំរេចនឹងស្អាងព្រះវិហារ១ថ្វាយព្រះនាមព្រះយេហូវ៉ា ជាព្រះនៃទូលបង្គំ” (១ពង្សាវតារក្យត្រ ៥:៥)។

ស្តេច សាឡូម៉ូន យល់ឃើញថា អ្វីៗដែលទ្រង់សាងសង់ ចាំបាច់ត្រូវចង្អុលបង្ហាញគេ ឲ្យងាកទៅរកព្រះអម្ចាស់ មិនមែនងាកមករកទ្រង់ដែលជាមនុស្សនោះទេ។ នេះជាមេរៀនដ៏សំខាន់ណាស់ បានជាទ្រង់ថែមទាំងបាននិពន្ធទំនុកតម្កើង អំពីរឿងនេះ។ គឺដូចដែលកណ្ឌគម្ពីរ ទំនុកតម្កើង ១២៧:១ បានចាប់ផ្តើមដោយពាក្យថា “បើគ្មានព្រះយេហូវ៉ាសង់ផ្ទះឡើង នោះពួកជាងដែលសង់ គេធ្វើការជាឥតប្រយោជន៍ទេ”។ អ្វីៗដែលយើងសង់សម្រាប់មនុស្ស មិនស្ថិតស្ថេរទេ គឺមិនខុសពីការសាងសង់ដែលខ្ញុំបានធ្វើកាលខ្ញុំនៅក្មេងនោះឡើយ ប៉ុន្តែ ព្រះនាមព្រះ និងការអ្វីដែលយើងធ្វើថ្វាយព្រះអង្គ មានសារៈសំខាន់អស់កល្បជានិច្ច។—Matt Lucas

តើអ្នកបានប្រើជីវិតរបស់អ្នក ដើម្បីសាងសង់អ្វី? តើជីវិតរបស់អ្នកបានថ្វាយព្រះកិត្តិនាមដល់ព្រះអង្គដូចម្តេចខ្លះ?

ឱព្រះវរបិតា សូមព្រះអង្គអត់ទោសឲ្យទូលបង្គំ សម្រាប់ពេលដែលទូលបង្គំបានផ្តោតទៅលើខ្លួនឯង មិនមែនទៅលើអ្វីដែលព្រះអង្គកំពុងធ្វើក្នុងលោកីយ៍នេះ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | សាការី ៩-១២ និងវិវរណៈ ២០

ឱព្រះយេហូវ៉ាអើយ តើទ្រង់នឹងភ្លេចទូលបង្គំដល់កាលណាទៀត តើដល់អស់កល្បឬអី? (ទំនុកតម្កើង ១៣:១)

ហេតុអ្វីទូលបង្គំលំបាកយ៉ាងនេះ?

លោក ជីម (Jim) បានតយុទ្ធនឹងជំងឺខួចកោសិកាប្រសាទបញ្ជា ជាង១ឆ្នាំហើយ។ កោសិកាប្រសាទក្នុងសាច់ដុំរបស់គាត់កំពុងតែខូច ហើយសាច់ដុំរបស់គាត់ក៏បានរួញស្វិត។ គាត់បានបាត់បង់សមត្ថភាពបញ្ជាផ្នែកតូចៗនៃអវយវៈរបស់គាត់ ក៏ដូចជាបាត់សមត្ថភាពគ្រប់គ្រងដៃជើងរបស់គាត់។ គាត់មិនអាចដាក់ឡេវ៉ែអាវ ឬចងខ្សែស្បែកជើងដោយខ្លួនឯងបានទៀតទេ ហើយក៏មិនអាចប្រើចង្កឹះបរិភោគអាហារបានដែរ។ លោក ជីម បានស៊ូទ្រាំនឹងស្ថានភាពដ៏លំបាកនេះ ហើយក៏បានចោទជាសំណួរថា ហេតុអ្វីព្រះអនុញ្ញាតឲ្យរឿងនេះកើតឡើង? ហេតុអ្វីខ្ញុំត្រូវជួបការលំបាកយ៉ាងនេះ?

ប៉ុន្តែ មានបងប្អូនរួមជំនឿក្នុងព្រះគ្រីស្ទជាច្រើនបានមកចំណាយពេលជាមួយគាត់ ហើយក៏បានទូលថ្វាយសំណូមរបស់ពួកគេដល់ព្រះអង្គផងដែរ។ ក្នុងកណ្ឌគម្ពីរទំនុកតម្កើង ជំពូក១៣ ស្តេច ដាវីឌ បានបន្លឺសម្លេងថា «ឱព្រះយេហូវ៉ាអើយ តើទ្រង់នឹងភ្លេចទូលបង្គំដល់កាលណាទៀត? តើដល់អស់កល្បឬអី? តើនឹងលាក់ព្រះភក្ត្រទ្រង់ ចំពោះទូលបង្គំដល់កាលណា? តើត្រូវឲ្យទូលបង្គំពិគ្រោះនៅតែក្នុងខ្លួនដល់កាលណា ដោយមានចិត្តព្រួយវាល់ព្រឹកវាល់ល្ងាចដូច្នេះ?» (ខ.១-២)

យើងក៏អាចនាំការភាន់ភាំង និងសំណួរយើងថ្វាយដល់ព្រះអង្គផងដែរ។ ព្រះអង្គជ្រាបអំពីចិត្តរបស់យើង ពេលណាយើងស្រែករកព្រះអង្គថា «តើដល់ពេលណា?» ហើយ «ហេតុអ្វី ព្រះអង្គអើយ?» ព្រះអង្គបានប្រទានចម្លើយមានន័យបំផុត ដល់យើងក្នុងព្រះយេស៊ូវ និងក្នុងជ័យជម្នះដែលព្រះអង្គមាន មកលើបាប និងសេចក្តីស្លាប់។

ពេលណាយើងគិតដល់ឈើឆ្កាង និងផ្នូររបស់ព្រះយេស៊ូវដែលនៅទទេរ យើងអាចរកឃើញទំនុកចិត្តនៅក្នុង «សេចក្តីស្រឡាញ់ដ៏ស្ថិតស្ថេរ» របស់ព្រះអម្ចាស់(ខ.៥) ហើយអរសប្បាយក្នុងសេចក្តីសង្គ្រោះរបស់ព្រះអង្គ។ សូម្បីតែនៅក្នុងពេលយប់ងងឹតបំផុត ក៏យើងអាច «ច្រៀងថ្វាយព្រះយេហូវ៉ា ដ្បិតទ្រង់បានប្រោសការល្អជាបរិបូរដល់ទូលបង្គំហើយ» (ខ.៦)។ ដោយសារជំនឿដែលយើងមានចំពោះព្រះគ្រីស្ទ ព្រះអង្គបានអត់ទោសបាបឲ្យយើង ទទួលចិញ្ចឹមយើងជាកូនរបស់ព្រះអង្គ និងកំពុងសម្រេចគោលបំណងដ៏អស់កល្បដែលព្រះអង្គមាន ក្នុងជីវិតយើង។—Poh Fang Chia

តើអ្នកមានសំណូរអ្វី ដែលត្រូវនាំមកទូលថ្វាយព្រះអង្គ? តើព្រះអង្គបានបង្ហាញសេចក្តីល្អរបស់ព្រះអង្គដល់អ្នកដូចម្តេចខ្លះ សូម្បីតែក្នុងពេលយប់ងងឹតបំផុត?

ឱព្រះវរបិតានៃសេចក្តីស្រឡាញ់ ទូលបង្គំសូមអរព្រះគុណព្រះអង្គ ដែលបានថែរក្សាទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំ ឲ្យទុកចិត្តថា ព្រះអង្គកំពុងតែធ្វើឲ្យអ្វីៗមានភាពស្រស់ស្អាតឡើងក្នុងជីវិតទូលបង្គំ។

គម្រោងអានព្រះគម្ពីរយៈពេល១ឆ្នាំ | សាការី ១៣-១៤ និងវិវរណៈ ២១

ដៃអញបានដាក់ឫសនៃផែនដី ហើយដៃស្តាំរបស់អញបានលាតផ្ទៃមេឃ (អេសាយ ៤៨:១៣)

ព្រះហស្តព្រះអង្គក្នុងឆ្នាំថ្មី

នៅឆ្នាំ១៩៣៩ នៅពេលដែលសង្គ្រាមលោកលើកទីពីរបានឆេះរាលដាល ដល់ទឹកដីចក្រភពអង់គ្លេស ស្តេច ចច ទី៦ (George VI) បានស្វែងរកឱកាស នៅក្នុងការផ្សាយតាមវិទ្យុនៅថ្ងៃណូអែល ដើម្បីលើកទឹកចិត្តប្រជាពលរដ្ឋរបស់ទ្រង់ក្នុងចក្រភពអង់គ្លេស និងប្រទេសជាសមាជិកដទៃទៀត ឲ្យទុកចិត្តព្រះ។ ទ្រង់ក៏បានដកស្រង់បទកំណាព្យដែលព្រះមាតាទ្រង់ចូលចិត្តយ៉ាងខ្លាំង ដោយបន្ថែលថា «ពេលយើងចូលទៅក្នុងភាពងងឹត ចូរយើងតោងព្រះហស្តព្រះអង្គជាប់។ ព្រះអង្គនឹងប្រទានពន្លឺ ដែលប្រសើរលើសពន្លឺណាទាំងអស់ ហើយក៏ប្រទានផ្លូវដែលមានសុវត្ថិភាពជាងផ្លូវណាទាំងអស់»។ ស្តេច ចច មិនបានជ្រាបថា នឹងមានរឿងអ្វីកើតឡើងទៀតនៅឆ្នាំថ្មីទេ តែទ្រង់បានទុកចិត្តថា ព្រះអម្ចាស់នឹង «ដឹកនាំ ហើយកំឡាចិត្ត» ពួកគេក្នុងថ្ងៃដ៏ចប់បារម្ភខាងមុខ។

ព្រះគម្ពីរបានចែងអំពីព្រះហស្តរបស់ព្រះនៅក្នុងកណ្ឌគម្ពីរជាច្រើន ដែលរាប់បញ្ចូលទាំងកណ្ឌគម្ពីរអេសាយផងដែរ។ ព្រះអង្គបានត្រាស់ហៅរាស្ត្រព្រះអង្គតាមរយៈហោរា អេសាយ ឲ្យពួកគេទុកចិត្តថា ព្រះអង្គជាព្រះអាទិករបស់ពួកគេ ព្រះអង្គគឺជា «ដើម ហើយជាចុង» (អេសាយ ៤៨:១២) ដែលគង់នៅជាមួយពួកគេជារៀងរហូត។ ព្រះអង្គមានបន្ថែលថា «ដៃអញបានដាក់ឫសនៃផែនដី ហើយដៃស្តាំរបស់អញបានលាតផ្ទៃមេឃ» (ខ.១៣)។ ពួកគេគួរតែទុកចិត្តព្រះអង្គ ហើយមិនត្រូវមើលទៅមនុស្ស ដែលមានអំណាចតិចជាងព្រះអង្គនោះទេ។ សរុបមក ព្រះអង្គគឺជា «ជាព្រះដ៏ប្រោសលោះ គឺជាព្រះបរិសុទ្ធនៃសាសន៍អ៊ីស្រាអែល» (ខ.១៧)។

ទោះយើងប្រឈមមុខដាក់អ្វីក៏ដោយ ខណៈពេលដែលយើងទន្ទឹងរង់ចាំឆ្នាំថ្មី យើងអាចទទួលយកការកម្សាន្តចិត្ត ពីស្តេច ចច និងហោរា អេសាយ និងដាក់សេចក្តីសង្ឃឹម និងសេចក្តីជំនឿរបស់យើង លើព្រះអម្ចាស់នោះយើងនឹងមានសន្តិភាពក្នុងចិត្តដ៏ហូរហៀរដូចទន្លេ ហើយសេចក្តីសុចរិតរបស់យើង «នឹងបានដូចជារលកនៃសមុទ្រ» (ខ.១៨)។—Amy Boucher Pye

ខណៈពេលដែលអ្នកគិតដល់ឆ្នាំថ្មី តើមានស្ថានភាព ឬបញ្ហាទំនាក់ទំនងអ្វីខ្លះ ដែលអ្នកអាចថ្វាយដល់ព្រះ? តើព្រះបន្ទូលដែលបានចែងអំពីព្រះហស្តព្រះអង្គ បានលើកទឹកចិត្តអ្នកដូចម្តេចខ្លះ?

ឱព្រះមានគ្រប់ចេស្តា ព្រះអង្គបង្កើតផ្ទៃមេឃ និងផែនដី ហើយព្រះអង្គស្រឡាញ់ទូលបង្គំ។ សូមព្រះអង្គជួយទូលបង្គំឲ្យ ទុកចិត្តព្រះអង្គជារៀងរាល់ថ្ងៃ។

Daily Manna 2026_Content Enhance.indd 371 17/11/25 1:47 in the afternoon







